វ៉ាន់ឌី កាអុន

Vandy Kaonn

# សុបិន និង ការពិត



Cambodge : rêves et réalités

វ៉ាន់ឌី កាអុន

# សុបិន និង ការពិត

## ភាគ ១



បន្ទាប់ពី របប « សាធារណរដ្ឋខ្មែរ » ត្រូវប្រទេសកុម្មុយនិស្ត នៅក្នុងតំបន់ វាយរំលំ នៅថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ប្រទេសកម្ពុជា បានធ្លាក់ទៅក្នុងវិនាសកម្មមួយ ដ៏គ្រៀមក្រំ ។ នៅក្នុង របប ខ្មែរក្រហម ដឹកនាំដោយ ប៉ុល ពត ហើយដែលមាន ប្រទេសចិនកុម្មុយនិស្តជាបង្អែក ប្រជាជនខ្មែរជាង ១ លាន នាក់ បានត្រូវគេសម្លាប់នៅក្នុងស្ថានភាព គួរឲ្យសង្វេគពន់ពេកក្រៃ ។ នៅដើមឆ្នាំ ១៩៧៩ កងទ័ពវៀតណាម ដែលមានជំនួយ ពីសហភាព សូវៀត បានចូលមកក្នុងស្រុកខ្មែរវាយរំលំ របបកម្ពុជា ប្រជាធិបតេយ្យ។ អធិករណ៍ រវាងកុម្មុយនិស្តចិន និង កុម្មុយនិស្ត វៀតណាម តាមរយៈអ្នកដឹកនាំខ្មែរ នេះតែមានបន្តទៀត។ កិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស៍ ឆ្នាំ ១៩៩១ និង អន្តរាគមន៍ របស់អង្គការសហប្រជាជាតិ នៅឆ្នាំ ១៩៩២ បានរៀបចំ ការបោះឆ្នោតសេរី ដែលបានផ្តល់ជ័យជំនះទៅឲ្យគណបក្សរាជានិយម ដឹកនាំដោយព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ។ ប៉ុន្តែ រដ្ឋប្រហារ ខែកក្កដា ឆ្នាំ ១៩៩៧ បានបើកផ្លូវ ឲ្យបក្សប្រជាជនកាន់អំណាចបន្តទៀត។ សុបិន របស់ប្រទេសដែលដណ្តើមគ្នាលេបទឹកដីខ្មែរ ក៏តុងតែក្លាយទៅជាការពិត ។ អ្នកដឹកនាំខ្មែរ ព្រមទាំងប្រទេសជាប់ពាក់ព័ន្ធ ពុំព្រម អនុវត្តកិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស៍ឡើយ ហើយរុញច្រាន ស្រុកខ្មែរឲ្យធ្លាក់ជ្រៅទៅៗ ទៅក្នុងមហន្តរាយមួយ ដ៏ ធំធេង សាជាថ្មីទៀត។

**Cambodge : rêves et réalités**

**Vandy Kaonn**

ភាគ ១ សុបិន និង ការពិត វ៉ាន់ឌី កាអុន

វ៉ាន់ឌី កាអុន

**Vandy Kaonn**

# សុបិន និង ការពិត

## ភាគ ១



**Cambodge : rêves et réalités**

វ៉ាន់ឌី កាអុន

**Vandy Kaonn**

# សុបិន និង ការពិត

## ភាគ ១

## ប្រទេសកម្ពុជា : ១៨៦៣-១៩៩២
## ពី សម័យអាណានិគមចាស់
## មកសម័យ អាណានិគមថ្មី

# CAMBODGE : rêves et réalités
## Tome I

សមាគម កម្ពុជា-អាស៊ី ឆ្នាំ ២០១២

**(Association Cambodge-Asie France - 2012)**

រក្សាសិទ្ធិ គ្រប់បែបយ៉ាង

# មាតិកា

-មាតិកា ........................................................................................ ៣

-អារម្ភកថា ................................................................................ ... ...........៧

-លំនាំដើម ..........................................................................................២២

**- តេជានុភាព និង ការចុះដុនដាប នៃ ចក្រភពខ្មែរ** ....................... ៣៩

Grandeur et décadence de l'Empire khmer

ជំពូក ១ : មុនសម័យ អាណាព្យាបាលបារាំង

- ពីតេជានុភាព មកភាពដុនដាប - រឿងព្រេងទាក់ទងនឹង ការកកើត នៃ រាជាណាចក្រខ្មែរ - សម័យអង្គរ - ការឈ្លានពាន របស់សៀមនៅពាក់កណ្ដាល និង ចុងសតវត្សរ៍ ទី ១៤ នៅដើមសតវត្សរ៍ ទី ១៥ និង ចុងសតវត្សរ៍ ទី ១៦ បដិវត្តន៍ ពុទ្ធសាសនា នៅសតវត្សរ៍ទី ១៤- ស្ដេច កន - សតវត្សរ៍ ទី ១៧ និង ទី ១៨ - ការប្រទាញប្រទង់ រវាងសៀម និងយួន - ទ្រឿង មិញ យ៉ាង ត្រួតត្រាស្រុកខ្មែរ

**- ទំនៀមទម្លាប់ខ្មែរ និង អភិក្រមទំនើបកម្ម** ................................ ៨៩

Moeurs et coutumes khmères et processus de modernisation

ជំពូក ២ : វត្តមាន បារាំង នៅស្រុកខ្មែរ

- រជ្ជកាល ហ្លួងនរោត្តម - ចលនាបះបោរ ប្រឆាំង នឹង បារាំង - កុបកម្មទូទាំងប្រទេស -ព្រះអង្គម្ចាស់ យុគន្ធរ

**- ទំនើបកម្ម : បដិវាទកម្ម រវាង វប្បធម៌ ពីរ** ......................... ១២១

Modernisation : conflit de deux cultures





ជំពូក ៣ : ការផ្សាំ អារ្យធម៌ខ្មែរ ជាមួយ វប្បធម៌បារាំង

- រជ្ជកាលហ្លួង ស៊ីសុវត្ថិ (១៩០៤-១៩២៧) - ព្រឹត្តិការណ៍ ថ្ងៃ ១៨ មេសា ឆ្នាំ ១៩២៥ - ទិដ្ឋភាពខ្លះៗ នៃអភិក្រមទំនើបកម្ម -សភាពការណ៍ប្រទេសកម្ពុជានៅក្នុងរជ្ជកាលហ្លួង មុនីវង្ស - ការធ្វើទំនើបកម្ម នៅក្នុងរាជ្យហ្លួង នរោត្តម ហ្លួង ស៊ីសុវត្ថិ និង ហ្លួងមុនីវង្ស - ការឡើងសោយរាជ្យលើកទី ១ នៅឆ្នាំ ១៩៤១ នៃ ព្រះបាទនរោត្តម សីហនុ - ឆ្ពោះទៅរកការទាមទារឯករាជ្យ និង ការកកើតឡើង នៃ គណបក្សប្រជាធិបតេយ្យ- ពី របបរាជានិយមទេវរាជ ទៅរបប រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ - វាសនា នៃ គណបក្សប្រជាធិបតេយ្យនិង ចលនាឥស្សរៈខ្មែរ - វិបត្តិរដ្ឋាភិបាល នៅចន្លោះឆ្នាំ ១៩៤៨-១៩៥០ -ការកកើតឡើង នៃអ្នកប្រជាធិបតេយ្យខ្មែរជំនាន់ឆ្នាំ ១៩៥០-១៩៦០

**- ការស្វែង រកតុល្យភាព ដ៏ពិបាក រវាង ប្រពៃណី និង ភាពសម័យទំនើប** ....................................................... ១៦៩

Equilibrage difficile entre tradition et modernité

ជំពូក ៤ : ឆ្ពោះទៅរក របប «គណបក្សតែមួយ»

- ព្រឹត្តិការណ៍ ដែលកើតមានឡើង មុនរាជបូជនីយកិច្ចដើម្បីឯករាជ្យ របស់ព្រះបាទនរោត្តម សីហនុ - ព្រះរាជបូជនីយកិច្ច ដើម្បី ឯករាជ្យខ្មែរ របស់ ព្រះបាទនរោត្តម សីហនុ - ព្រះរាជបូជនីយកិច្ច ទាមទារឯករាជ្យ ដំណាក់ការទី ២ របស់ ព្រះបាទ នរោត្តម សីហនុ-កំណែនកម្លាំងប្រជាជាតិទាំងមូល នៅថ្ងៃ ២៨ មិថុនាឆ្នាំ ១៩៥៣ - សន្និសីទ ទីក្រុងហ្សឺណែវឆ្នាំ ១៩៥៤ - បរិយាកាស នៃសន្និសីទទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤

**- ដំណើរឆ្ពោះទៅរកភាពរណប នឹង អាណានិគមនិយមថ្មី**......... ១៩៣

Dans l'orbite du nouveau colonialisme

ជំពូក ៥ : ស្រុកខ្មែរធ្លាក់ក្នុងអន្ទាក់ លោកកុម្មុយនិស្ត

- នយោបាយនៅក្នុងប្រទេសកម្ពុជា ក្រោយកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ - ព្រឹត្តិការណ៍ សំខាន់ៗ នៅឆ្នាំ ១៩៥៥ - គម្រោងការ កែ រដ្ឋធម្មនុញ្ញខ្មែរ - ការបោះឆ្នោតសភា ខែកញ្ញា ឆ្នាំ ១៩៥៥ - ចលនា «សង្គមរាស្ត្រនិយម» និង ចលនាខ្មែរកុម្មុយនិស្ត ការកែទម្រង់ ស្ថាប័ន នយោបាយ តាមរយៈ ការប្រកាស ឲ្យប្រើនីតិក្រម ចុះថ្ងៃ ១៥ធ្នូឆ្នាំ ១៩៥៦ -សង្គមរាស្ត្រនិយម : ការប្រទាញប្រទង់ រវាង និន្នាការស្តាំអភិរក្ស និង និន្នាការឆ្វេង - បញ្ហាអព្យាក្រឹតភាពខ្មែរ - ការប៉ុនប៉ងវាយរំលំ របប សម្តេចនរោត្តម សីហនុ នៅឆ្នាំ ១៩៥៩ -សភាពការណ៍ នយោបាយនៅឆ្នាំ ១៩៦០ - បញ្ហាតែងតាំង សម្តេចនរោត្តម សីហនុ ជាប្រមុខរដ្ឋ នៃ ប្រទេសកម្ពុជា នៅឆ្នាំ ១៩៦០ - តុល្យភាព ដ៏ពិបាក រវាង ចលនា កុម្មុយនិស្ត និង ចលនាខ្មែរសេរី - ការផ្តាច់ជំនួយយោធា និង សេដ្ឋកិច្ច សហរដ្ឋ អាមេរិក នៅឆ្នាំ ១៩៦៣ - សេដ្ឋកិច្ច ប្រទេសកម្ពុជាសម័យ «សង្គមរាស្ត្រនិយម» - បញ្ហា អព្យាក្រឹតភាព និង បូរណភាពដែនដីខ្មែរ នៅឆ្នាំ ១៩៦៤ - ទីបញ្ចប់ នៃ អព្យាក្រឹតភាព របស់ ប្រទេសកម្ពុជា នៅ ឆ្នាំ ១៩៦៥ - ជ័យជំនះ របស់ អ្នកអភិរក្ស នៅក្នុងការបោះឆ្នោតសភា ឆ្នាំ ១៩៦៦ - ការបះបោរ នៅសម្លូត នៅថ្ងៃ ២ មេសា ឆ្នាំ ១៩៦៧ - ការជ្រើសរើស ដ៏ ពិបាក របស់ សម្តេច នរោត្តម សីហនុ រវាង លោកកុម្មុយនិស្ត និង លោកសេរី - «រដ្ឋាភិបាល ស្រោចស្រង់ជាតិ» - សមិទ្ធិ សំខាន់ៗ នៃ របប «សង្គមរាស្ត្រនិយម» - ការវិវត្តន៍ឆ្ពោះទៅរក ព្រឹត្តិការណ៍ ថ្ងៃ ១៨ មិនាឆ្នាំ ១៩៧០ - មហាបាតុកម្ម នា ថ្ងៃ ១១ និង ១៦ មិនាឆ្នាំ ១៩៧០

**-បដិវត្តន៍ របស់ អ្នកអភិរក្ស** ................................................ ២៧១

La Révolution des conservateurs

ជំពូក ៦ : បេញមិនរួចពី របនាសម្ព័ន្ធចាស់



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

- ព្រឹត្តិការណ៍ ថ្ងៃ ១៨ មិនាឆ្នាំ ១៩៧០ - សភាពការណ៍ប្រទេសកម្ពុជាក្រោយការទម្លាក់សម្តេចនរោត្តម សីហនុ - ការប្រកាស របប «សាធារណរដ្ឋខ្មែរ» នៅថ្ងៃ ៩ តុលាឆ្នាំ ១៩៧០ - ការកកើតឡើង នៃរបប «សាធារណរដ្ឋខ្មែរ» - ឆ្នាំ ១៩៧៣ : សហរដ្ឋ អាមេរិក បោះបង់ «សាធារណរដ្ឋខ្មែរ» ចោល - ការប្រេះឆា នៃ របប «សាធារណរដ្ឋខ្មែរ» - ឆ្ពោះទៅរកការរលំរលាយ នៃ របប «សាធារណរដ្ឋខ្មែរ» - សភាពការណ៍ នៅប្រទេសកម្ពុជា មុនថ្ងៃ ១៧ មេសាឆ្នាំ ១៩៧៥ -

**-បដិវត្តន៍ ដែលគ្មានប្រជាជនគាំទ្រ** ........................................ ៣០១

Une révolution sans soutien populaire

ជំពូក ៧ : ការកម្ទេចវប្បធម៌មួយ ដើម្បីយក មនោគមវិជ្ជា មួយ មកជំនួស

- ព្រឹត្តិការណ៍ ថ្ងៃ ១៧ មេសាឆ្នាំ ១៩៧៥ - អាកប្បកិរិយា របស់ ពួកខ្មែរក្រហម -របប «កម្ពុជាប្រជាធិបតេយ្យ» - ការកកើតឡើង នៃ របប ខ្មែរក្រហម - ចលនា កុម្មុយនិស្តខ្មែរ ពីឆ្នាំ ១៩៥៧ មកឆ្នាំ ១៩៦៩-ការប្រែក្លាយ ពី «បក្សពលករកម្ពុជា» ទៅជា «បក្សកុម្មុយនិស្តកម្ពុជា» - ការវាយរំលំវប្បធម៌ខ្មែរដោយ របប ខ្មែរក្រហម - ការប្រែឈ្មោះ ពី «បក្សប្រជាជនបដិវត្តកម្ពុជា» មកជា «បក្សកុម្មុយនិស្ត កម្ពុជា - ការកកើតឡើង នៃ កងប្រដាប់អាវុធខ្មែរក្រហម នៅចុងឆ្នាំ ១៩៦៧

**កាលប្បវត្តិ សង្ខេប** ........................................................................ ៣៥៤

**ស្តេចដែលគ្រងរាជ្យ នៅស្រុកខ្មែរ**................................................... ៤០១

**គន្ថនិទ្ទេស** .......................................................................... ៤១៥

# អារម្ភកថា

*សុបិន និង ការពិត* ជាការសិក្សា ហេតុផល នៃ ព្រឹត្តិការណ៍សំខាន់ៗ ទាំងឡាយដែលកើតមានឡើង នៅប្រទេសកម្ពុជា តាំងពីដើមសតវត្សរ៍ ទី ១៩ មកទល់នឹង សព្វថ្ងៃនេះ។ ការវិវត្តន៍ នៃព្រឹត្តិការណ៍នៅក្នុងសង្គមមួយមិនត្រឹមតែទាក់ទង នឹង ដំណើរ របស់ ពិភពលោក ឬ ការប្រជែងកម្លាំងនៅក្នុងតំបន់ប៉ុណ្ណោះទេ តែមានកត្តាខាងក្នុងផ្សេងៗទៀត ដែលកកើតឡើង នៅក្នុង បរិបទវប្បធម៌ និង ប្រវត្តិសាស្ត្រ នៃ សង្គមមួយជាកំណត់។ ក្នុងចំណោម កត្តាចុងក្រោយនេះ មាន កត្តាម៉្យាង ដែលជំរុញឲ្យ «ព្រឹត្តិការណ៍ចម្បង» មួយ ចេញជារូបរាងឡើង។ យើងកំណត់ហៅ កត្តានោះ ថា «កត្តាឧបហេតុ» (catalyseur)។ កតាឧបហេតុនេះ ទោះមិនសូវសំខាន់ប៉ុន្មានក្តី ក៏ជាហេតុ ដែលបង្កើតឲ្យមាន ព្រឹត្តិការណ៍ចម្បងនោះ ដោយផ្ទាល់ភ្លាមៗ មួយរំពេចដែរ។ រីឯរូបភាព នៃ «ព្រឹត្តិការណ៍ចម្បង» នោះ គឺ អាស្រ័យទៅតាមបច្ច័យបដិច្ចសមុប្បាទរបស់វាផ្ទាល់ ។ ការវិវត្តន៍ នៃវប្បធម៌ និង ការប្រែប្រួលស្ថានភាព សង្គម-សេដ្ឋកិច្ចនៃសង្គមមួយ ក៏ជាកត្តាសំខាន់ នៃការកកើតឡើង នៃ បាតុភូតផ្សេងៗ ខុសប្រក្រតីមួយចំនួន (une série de phénomènes atypiques) ដែលកើតមាននៅក្នុងសង្គមនោះដែរ។ សង្គមកំពុងអភិវឌ្ឍខ្លះ និង សង្គមលូតលាស់ដែលចុះខ្សោយដោយប្រការផ្សេងៗ តែងតែ មានការពិបាក នឹង សម្របខ្លួន តាមសភាពការណ៍ ពិភពលោក ។ នៅក្នុងករណីបែបនេះ ប្រជាជាតិ ឬ សហគមន៍នោះ តែងតែបារម្ភ ខ្លាចបាត់បង់ នូវ





របៀបរស់នៅ ពីដូនតា របស់គេ ដែលគេចាត់ទុកថា ជា អត្តសញ្ញាណ (identité) ជាអត្ថិភាព (entité) នៃ ប្រជាជាតិមួយ។ នៅក្នុងសង្គមខ្លះទៀត អ្នកចេះដឹងដែលយល់ថា ការវិវត្តន៍ ជាការចាំបាច់ បែរជា មិនបានរៀបចំ ការវិវត្តន៍ នោះ ឲ្យបានជ្រៅនៅក្នុងវប្បធម៌ជាតិ របស់ គេទៅវិញ ហើយ ប្រញាប់ប្រញាល់ធ្វើបដិវត្តន៍ (ការវិវត្តន៍ ខ្លាំង) តែម្តង ជាហេតុនាំមក នូវ ការប្រទាញប្រទង់ និង ប្រតិកម្ម ពីសំណាក់អ្នកអភិរក្ស និង ក្រុមប្រជាជន ដែលអ្នកប្រភេទចុងក្រោយនេះ ធ្វើអ្វីគ្រប់បែបយ៉ាង ដើម្បី ផ្តាច់ ឲ្យចេញផុត ពី ចរន្ត វិទ្យាសាស្ត្រ និង ទស្សនវិជ្ជាថ្មីៗ ដែលបាននាំពិភពលោក មកដល់ចំណុចមួយគ្មានការវិលវិញ។ តាមធម្មតា ការវិវត្តន៍ ក្តី បដិវត្តន៍ ក្តី មិនមែន សុទ្ធតែនាំមក នូវភាពមនោរម្យ នូវសុក្រឹតភាព នៃ ការរស់នៅ ឬ សុភមង្គល ទាំងអស់នោះទេ ប៉ុន្តែ ការមិនព្រមវិវត្តទៅតាមក្រឹត្យក្រមសត្យានុម័ត (loi objective) ក៏ជាគ្រោះថ្នាក់មួយដ៏ធំដែរ ។ យ៉ាងណាមិញ សង្គមខ្មែរ ជាសង្គមដែលមាន អរិយធម៌ រុងរឿង តាំងពីយូរណាស់មកហើយៗ ខ្មែរគ្រប់រូប តែងមានមោទនភាព នឹង អតីតកាលរបស់ខ្លួន ។ នេះជាការធម្មតាទេ ប៉ុន្តែ ការពុំយល់ ពីដំណាក់ការ នីមួយៗ នៃ ការវិវត្តន៍ និង ពី មូលដ្ឋានពិតប្រាកដ នៃ ការអភិវឌ្ឍន៍ ក៏ងាយ នឹងធ្វើឲ្យមាន ការយល់ភ្លាំភ្លងដែរ។ ចក្រភពខ្មែរ ចាប់ផ្តើមចុះដុនដាបតាំងពីសម័យស្តេចឥន្ទ្រវរ្ម័នទី ៣ មក (១២៩៥-១៣០៨) ហើយជាពិសេស តាំងពីសៀមវាយយកបន្ទាយលង្វែកបាន នៅចុងសតវត្សរ៍ ទី១៦ (១៥៩៤) ហើយក្រោយមក ត្រូវយួនវាយលុក ចូលត្រួតត្រា ស្ទើរតែផុតពូជ រលត់ រលាយជាតិ។ ខ្មែរ បានធ្វើការតស៊ូ យ៉ាងសស្វិតស្វាញ ប៉ុន្តែ ទប់ទល់មិនបាន នឹង ការបែក ឯកភាពជាតិ (ដូចជា ជារប្រយុទ្ធគ្នា ដណ្តើម រាជសម្បត្តិជាដើម) ។ ឧបហេតុនេះ បណ្តាលមួយចំណែក មកពី ការញុះញង់ ពីសំណាក់ប្រទេស ដែលមានមហិច្ឆតាលេបទឹកដីខ្មែរ ឬ ក៏ មកពី ការលោភលន់ របស់ អ្នកដែល ពុំមាន សញ្ញាណ នយោបាយ ច្បាស់លាស់ (ការកាប់បំផ្លាញ កំផែងឫស្សី បន្ទាយលង្វែក) ។ ឧបហេតុនេះ អាចមានរូបភាពផ្សេងៗទៀត ដូចជា លក្ខណៈមិនច្បាស់លាស់ នៃ ស្ថាប័នគ្រប់គ្រង ជាដើម (កង្វះច្បាប់មួយ

ដ៏ តឹងតែងស្តីពី ការស្នងរាជ្យជាអាទិ៍) ។ ឧបហេតុនោះ ក៏អាចជា កម្លាំងបង្កប់ (forces sous-jacentes) ដែលបណ្តាលមកពីការប្រជែង ការវិវាទគ្នា រវាងអ្នកដណ្តើមឥទ្ធិពលគ្នានៅផ្ទៃវាំងដែរ។ ដោយខ្វះឯកសារស្តីពី រឿងរ៉ាវទាំងនេះ ខ្ញុំមិនអាចនិយាយ ពី បញ្ហានេះបានឡើយ ក្រៅពីពត៌មានខ្លះដែលបានមក ពីសាស្ត្រាស្លឹករឹតនានា ដែលកវីខ្មែរបានចារទុក និងពី លោកអាត់ដេម៉ា ឡឺក្លែរ និង ប្រកពអ្នកស្រាវជ្រាវ បរទេស មួយចំនួន។ ឧទាហរណ៍ : ទំនាស់ រវាង ស្តេច នរោត្តម និង អង្គ ស៊ីវត្ថា ជាព្រះអនុជ (សូមអានបន្ថែមសៀវភៅ *ប្រវត្តិសាស្ត្រខ្មែរ ភាគ ១* របស់ ខ្ញុំ ត្រង់ទំព័រ ២៧) ទំនាស់ រវាង យុនហ្វងកន និងស្រីសុគ្គបទ ព្រមទាំងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខ្មែរសម័យឆ្នាំ ១៩៥០-១៩៧០។ សូមបញ្ជាក់ថា ប្រភេទ នៃ ឧបហេតុដែលខ្ញុំបានលើកឡើងខាងលើនេះ គ្រាន់តែជា ការសន្និដ្ឋានប៉ុណ្ណោះ។ មុនពេលបារាំង ចូលមកធ្វើអាណាព្យាបាល (ដូចសេចក្តីប៉ងប្រាថ្នា របស់ព្រះបាទអង្គដួង) ស្រុកខ្មែរបាក់បែករចនាសម្ព័ន្ធសង្គម ខ្ទេចខ្ទាំអស់ទៅហើយ (សូមអានបន្ថែម *Notes cambodgiennes Au coeur du Pays Khmer* របស់ Dr A.Pannetier, Paris Payot, 1921 et Editions Cedoreck, Paris, 1983) ។ ពេលនោះ ប្រជាជនខ្មែរមានត្រឹមមួយ លាន ៥ សែន នាក់ ប៉ុណ្ណោះ បើតាមលោក អេដែន អៃម៉ូញេ (Etienne Aymonnier, *Le Cambodge*, 3 volumes, Paris 1900) ។ ប្រវត្តិវិទូខ្លះ កំណត់ចំនួននេះ ក្នុងចន្លោះ ៩០០០០០ នាក់ នឹង ១ លាន ៥ សែននាក់)។ បារាំងដែលមកធ្វើទំនើបកម្មនៅស្រុកខ្មែរ បានធ្វើឲ្យប៉ះពាល់ ជាទម្ងន់ ដល់អធិបតេយ្យនិងទំនៀមទម្លាប់ខ្មែរ ជាហេតុនាំឲ្យមាន ការបះបោរក្នុងប្រទេស។ ទន្ទឹមនោះអស់រយៈពេល ៩០ ឆ្នាំ ពួកគេក៏បានផ្តល់មកឲ្យខ្មែរ នូវមូលដ្ឋានទំនើបកម្មមួយផងដែរ។ ប៉ុន្តែ ក្រោយមក ខ្មែរក្រហម បានកំទេច មូលដ្ឋាននេះ ចោលអស់គ្មានសល់។ តាំងពីពេលនោះមក ខ្មែរបាត់បង់ នូវ មូលដ្ឋានថ្មីមួយទៀត នៃ ការរីកចម្រើន និងទំនើបកម្ម របស់ខ្លួន (មូលដ្ឋានដំបូងបង្អស់ គឺនៅសតវត្សរ៍ ទី ១ បន្ទាប់មក នៅសតវត្សរ៍ ទី ៥ និងទី ៩ ពោលគឺ សម័យអង្គរ) ។ ប្រទេសចិន ដោយសារការ





ឈ្លាសវៃ របស់លោក តេង ស៊ាវ ពីង បានពង្រឹងមូលដ្ឋានរីកចម្រើននេះ បានវិញ នៅឆ្នាំ ១៩៧៩ គឺ មូលដ្ឋានដែលខ្មែរ បានបាត់បង់ នៅឆ្នាំ ១៩៧៥ ព្រោះតែ អ្នកនយោបាយខ្មែរខ្លះ និង អ្នកបដិវត្តជាច់ខាតមួយចំនួន បានជំរុញ ឲ្យបោះបង់ចោល នៅក្នុងសម័យ លោក ម៉ៅ សេ ទុង។

ព្រឹត្តិការណ៍ ដែលខ្ញុំ យកមក វិភាគ ក្នុងសៀវភៅ នេះ គឺជា ការចុះបង្ហាញឲ្យឃើញ តាមរយៈព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រ លំអិត នូវ ការរអាក់រអួល ដែលប្រទេសកម្ពុជា បានទទួលរងគ្រោះ ដោយប្រការផ្សេងៗ នៅក្នុងអភិក្រមទំនើបកម្ម របស់ ខ្លួន។ ប៉ុន្តែដើម្បីយល់ពី ការវិវត្តន៍ នៃ សង្គមខ្មែរ ឲ្យបានច្បាស់ ខ្ញុំ ក៏លើកឡើងផងដែរ ពីដំណើរទាំងមូល នៃប្រវត្តិសាស្ត្រខ្មែរ តែម្តងនៅក្នុងជំពូកទី ១ ដែលមានចំណងជើង ថា *តេជានុភាព និង ការចុះដុនដាប នៃ ចក្រភពខ្មែរ* ឬ *Grandeur et décadence de l’Empire khmer* ។តាមទំព័រប្រវត្តិសាស្ត្រ របស់ខ្លួន តាំងពី សម័យ ហ៊្វូណន់- ចេន-ឡាមកទល់ពេលបច្ចុប្បន្ន ស្រុកខ្មែរបានទទួលឥទ្ធិពលវប្បធម៌បរទេសច្រើន (ព្រហ្មញ្ញសាសនា, ពុទ្ធសាសនា មហាយាន, ពុទ្ធសាសនាថេរវាទ, វប្បធម៌បារាំង)។ ឥទ្ធិពលវប្បធម៌ទាំងនេះ បានចូលលាយឡំជាមួយ សញ្ញាណដើម របស់ខ្មែរ ដូចជា ជំនឿអារក្ខអ្នកតា (animisme) ការបកស្រាយ តថភាព ពិភពលោក ទៅតាម ចក្ខុនិមិត្ត ប្រជាប្រិយផ្សេងៗ (représentations collectives, visions populaires) ជាដើម ក៏អាចពន្យល់ហេតុផល នៃ ព្រឹត្តិការណ៍ នយោបាយ មួយចំនួនដែរ ដូចជា ព្រឹត្តិការណ៍ទាក់ទង នឹង ការបះបោរ របស់ ស្តេច កន ដែលបណ្តាល មកពី ជំនឿទៅលើការយល់សប្តិ និង ការបកស្រាយសុបិន ទៅតាម បុរេនិច្ឆ័យជាដើម (គឺរឿងដែលមិនទាន់កើតមាននៅឡើយ បានក្លាយទៅជាការពិត)។ រីឯការពិតនោះ គឺ សង្គ្រាមផ្ទៃក្នុងមួយដ៏ធំ ដែលកើតឡើងនៅក្នុងនគរទាំងមូល។ ពេលបារាំងចូលស្រុក វប្បធម៌ខ្មែរ បានត្រូវភ្ជាប់ ជាមួយ វប្បធម៌បារាំង (ដើមកំណើត នៃ «បញ្ញវន្ត» ខ្មែរសម័យទំនើប) ។ ពេលបាន ឯករាជ្យនៅឆ្នាំ ១៩៥៣ គឺ អ្នកទាំងនេះហើយ ដែលជា អ្នកបន្តវេន ជំរុញ

សង្គមខ្មែរ ធ្លោះទៅរក វឌ្ឍនភាព។ ប៉ុន្តែ ជាអកុសល គេបានបែកគ្នា ជាពីរក្រុម ៖ ម្ខាងទៅរកការជឿនលឿន តាមបែបកុម្មុយនិស្ត ហើយ ម្ខាងទៀត បន្តប្រពៃណី នៃ វប្បធម៌ខ្មែរដែលផ្សំជាមួយវប្បធម៌បារាំង នៃ វណ្ណៈគហបតី (influence de la tradition bourgeoise française)។ ពេលកុម្មុយនិស្តអស់ឥទ្ធិពល ខ្មែរ ក៏ វិលមករក វប្បធម៌ខ្មែរដែលផ្សំ ជាមួយ វប្បធម៌ បារាំងវិញ ប៉ុន្តែ គឺ ជ្រុលពេលអស់ទៅហើយ ព្រោះ ប៉ុល ពត បានវាយកំទេចអស់គ្មានទុកឲ្យសល់អ្វីបន្តិចបន្តួចឡើយ។ សូម្បី តែ ពាក្យបារាំង ឬ អង់គ្លេសមួយម៉ាត់ ពោលគឺ ភាសា របស់ ពួកស្បែកស ក៏ ត្រូវ ចាត់ទុកថាជា មេរោគ នៃ ឥទ្ធិពលមិនល្អចំពោះខ្មែរគ្រប់រូបដែរ។ ខ្មែរដែលចេះភាសា ទាំងនេះ ហើយដែលនៅសល់ ពី ការកាប់សម្លាប់ នៅក្រោមរបប ប៉ុល ពត ក៏ បាន ត្រូវរបបក្រោយៗមកទៀត បង្អាប់បង្អោន ដើម្បីឲ្យខ្មែរបាត់បង់មូលដ្ឋានចាស់ ចោល ជាស្ថាពរ។ គេចង់បង្កើតមូលដ្ឋានវប្បធម៌មួយថ្មីទៀត ពោលគឺ វប្បធម៌ម៉្យាង ដែល ប្រទេសនៅអាស៊ីខ្លះ បានយកវប្បធម៌ របស់គេ រៀងៗខ្លួន ទៅផ្សំជាមួយបច្ចេកវិជ្ជា បស្ចិមប្រទេស រួចយកមកឲ្យខ្មែរវិញដដែល ដោយដកហូត តែសេរីភាព នៃ ការគិត (liberté de pensée) និង សេរីភាព ធ្វើនយោបាយតែប៉ុណ្ណោះ។ គេ ពុំជឿថា គឺ សេរីភាពនោះហើយ ដែលជាមូលដ្ឋាន នៃ ការរីកចម្រើន ផ្នែកទស្សនវិជ្ជា និង វិទ្យាសាស្ត្រ។ គេភ្លេចគិតថា ព្រោះតែគេបានប្រានចោលសេរីភាពនោះ កាល ពីសម័យ មុន (ដូចជា ការធ្វើបាបអ្នកប្រាជ្ញ ដែលមិនព្រម យល់តាមគេ ដូចកាល ជំនាន់ ហ្គាលីឡេ ជាដើម) បានជាគេបានធ្លាក់ខ្លួនមកដល់ភាពទ្រឹងនៅមួយកន្លែង) អស់រយៈពេល ដ៏ យូរ ទម្រាំបានដឹង (marasme intellectuel)។ ប្រទេសខ្លះធ្វើការផ្សាំបែបនេះ ក្រោយខ្មែរ ក៏ពិតមែន ប៉ុន្តែ គេបានឈានទៅដល់ សន្ទុះមួយ ដ៏ខ្លាំង ហើយ យ៉ាងឆាប់រហ័ស ព្រោះតែគេបានដក បទពិសោធន៍ ទាន់ពេលវេលា ហើយ យល់ពីលក្ខណៈអវិជ្ជមាន នៃ ការប្រឆាំង ដ៏ឆោតល្ងង់ នឹង សទ្ធិសេរីភាព របស់ បុគ្គល។ សេរីភាព ក្នុងការគិត ពិចារណា តែងតែធ្វើឲ្យរដ្ឋអំណាចរង្គោះរង្គើ ប៉ុន្តែបើមិនធ្វើពលិកម្មខ្លះ ទេនោះ ប្រទេស





ដែលគេគ្រប់គ្រងនោះ ក៏នឹងត្រូវប្រទេសជិតខាង ប្រមាថមើលងាយដែរ។ ប្រទេសអាច ខ្លាំងបាន លុះណាតែមានអ្នកប្រាជ្ញ គឺ អ្នកដែលមាន សេរីភាពគ្រប់គ្រាន់ ក្នុងការគិត ពិចារណា ក្នុងការជំរុញសង្គម ឲ្យមានអ្វីសព្វបែបយ៉ាង ដូចប្រទេសនានា ។ បើពុំនោះ សោតទេ គឺ ត្រូវរណបគេរហូត ។

នៅក្នុងសៀវភៅ ប្រវត្តិសាស្ត្រ នៃ ប្រទេស កម្ពុជា ទាំង ៣ ភាគ ដែលខ្ញុំ បាន សរសេរ កាលពីឆ្នាំ ២០០៥ ខ្ញុំបានរៀបរាប់ ព្រឹត្តិការណ៍ ទាំងនោះ ម្តងរួចមកហើយ ប៉ុន្តែ ពុំបាននិយាយពី ហេតុផលដែលជាកត្តាដែលនាំឲ្យមាន ព្រឹត្តិការណ៍ទាំងនោះទេ ។ កាលនោះ គោលដៅរបស់ខ្ញុំ គឺគ្រាន់តែធ្វើយ៉ាងណា ប្រមូល ព្រឹត្តិការណ៍ សំខាន់ៗ ឲ្យ បានសិនតែប៉ុណ្ណោះ បន្ទាប់មកធ្វើការផ្ទួរផ្ទងឯកសារ និង សក្ខីកម្មផ្សេងៗ ដើម្បីបញ្ជាក់ ពីលក្ខណៈសត្យានុម័ត នៃ ព្រឹត្តិការណ៍នីមួយៗ។ នៅក្នុងសៀវភៅ សុបិន និង ការពិត នេះ ខ្ញុំសាកល្បង យកព្រឹត្តិការណ៍ ទាំងនោះ មកវិភាគ តាមបែបបទ សង្គមសាស្ត្រ ពោលគឺ ទំនាក់ទំនង រវាង របនាសម្ព័ន្ធ វប្បធម៌ និង ព្រឹត្តិការណ៍ នយោបាយ។ ព្រឹត្តិការណ៍ នយោបាយ នីមួយៗ កើតឡើង នៅក្នុងបរិបទ នៃ សម័យកាលប្រវត្តិសាស្ត្រ របស់វា ក៏ពិតមែន ប៉ុន្តែ គេក៏មិនអាចកាត់ផ្តាច់ ព្រឹត្តិការណ៍នោះ ចេញពី វប្បធម៌ និង ពីចិត្ត គំនិត របស់ ប្រជាជន របស់ អ្នកដឹកនាំ ដែលជាអ្នកបង្កើត ឬ ជា អ្នកដែលបកស្រាយព្រឹត្តិការណ៍នានា នៅ សម័យកាល របស់គេ ទៅតាម អារម្មណ៍រួម (សមូហរម្មណ៍) ដែរ ។ ចំពោះ សញ្ញាណ ស្តីពី ការតំណាង និង ដឹកនាំ ប្រជាជាតិ នេះ មាន ករណីជាច្រើន ខុសៗ ពីគ្នា ។ ប្រជាជាតិខ្លះ ត្រូវដឹកនាំដោយប្រជាជន ដែលមាន សទ្ធិ សេរីភាព គ្រប់គ្រាន់ (ប្រទេសដែលកាន់លទ្ធិប្រជាធិបតេយ្យ) ដើម្បី អារកាត់ សេចក្តី សម្រេចផ្សេងៗ ។ ប្រជាជាតិខ្លះទៀត បានត្រូវ បុគ្គលម្នាក់ ហួងហែង យក សិទ្ធិនេះ សម្រាប់តែម្នាក់ឯង ហើយនៅក្នុងរយៈពេល ដ៏យូរអង្វែង ។ នៅក្នុងករណី ចុងក្រោយ នេះ ប្រជាជាតិទាំងមូលជាចំណាប់ (ôtage) របស់ មនុស្សម្នាក់ ដែលបាន ប្លន់យក រដ្ឋអំណាច យក នគរបាល និង យោធា ធ្វើជាឧបករណ៍ សម្រាប់ បម្រើ ប្រយោជន៍

របស់ បក្សពួក និង ក្រុមគ្រួសារខ្លួន ។ ចំពោះ ការដាច់ឯកភាព រវាង ប្រជាជន រវាង អ្នកបេះដឹង និង អ្នកកាន់អំណាច (rupture du consensus populaire ou identification d’un homme fort à une nation) គេពុំអាចនិយាយ ពី ប្រជាជាតិបានទេ។ ទោះជាយ៉ាងណាក្តី ប្រជាជាតិទាំងមូល បានត្រូវបង្រួមមកត្រឹម បុគ្គលម្នាក់ ប៉ុណ្ណោះ ហើយ ផ្សងវាសនា តែទៅតាម បុគ្គលនោះ ។ ដូច្នេះ ប្រជាជាតិ និង រដ្ឋទាំងមូល គឺ មនុស្សតែម្នាក់។ ក្រៅពីនោះ គឺមានតែទាសករ និង អ្នកស៊ីឈ្នួល (les mercenaires) តែប៉ុណ្ណោះ។ ទស្សនវិទូក្រេក ឌេម៉ូគ្រីត (Démocrite) បាននិយាយដូច្នេះថា៖ វាសនា របស់ មនុស្សម្នាក់ គឺជា ការកំណត់ នៃ ចរិត របស់ គេ («C’est le caractère de l’homme qui fait son destin») ។ យ៉ាងណាមិញ បើមនុស្សនោះ ជា អ្នកដឹកនាំ ផ្តាច់ការ គឺ ប្រជាជាតិទាំងមូល ដែលជា អ្នកទទួលរងគ្រោះ ។ អំណាចផ្តាច់ការ ជា ផលិតផល នៃ វប្បធម៌មួយ ដែលនៅទ្រឹងមួយកន្លែង ដែលត្រូវរាំងស្ទះ មិនវិវត្ត ដោយ ប្រការផ្សេងៗ តែបើវប្បធម៌ មាន ការវិវត្តន៍ តាមដំណើរ របស់ ពិភពលោក របប ផ្តាច់ការនោះ ក៏ ត្រូវ រលំរលាយទៅវិញដែរ។

ព្រឹត្តិការណ៍ នីមួយៗ សុទ្ធតែមាន កត្តាកំណត់ ប៉ុន្តែ កត្តាទាំងនោះ មានច្រើន ណាស់ ហើយ មានលក្ខណៈស្មុគស្មាញប្រទាក់ក្រឡាគ្នាទៀត។ ព្រឹត្តិកាណ៍ខ្លះ មាន ឫសគល់របស់វា តាំងពីយូរមកហើយ ដូចនេះ គេត្រូវពិពណ៌នាដំណាក់ការសំខាន់ៗ នៃ ការវិវត្តន៍ របស់វា (diachronie) តាំងពីដើម រហូត ដល់ពេលដែលព្រឹត្តិការណ៍ ដែលគេសិក្សានោះ កើតមានឡើង ។ ការចេញរូបរាង នៃ ព្រឹត្តការណ៍មួយ នៅក្នុង លំហ និង រយៈពេលមួយជាកំណត់ ទាក់ទង ជាពិសេស នឹង ពេលដែលព្រឹត្តិការណ៍ នោះកើតឡើង ព្រោះវាតែងតែមាន កត្តាផ្សំប្រុងក្រោយជាដរាប (catalyseur)។ ប៉ុន្តែ ទន្ទឹមនោះ គេក៏ត្រូវដឹងដែរថា ឧបករណ៍ទាំងនោះ ក៏សុទ្ធតែមានប្រវត្តិផ្ទាល់របស់វាដែរ គឺ វប្បធម៌ និង ប្រវត្តិសាស្ត្រ (diachronie) គឺកត្តាដែលគេពុំអាចកាត់ផ្តាច់បាន ដើម្បី ពន្យល់មូលហេតុស៊ីជម្រៅ នៃព្រឹត្តិការណ៍នោះ។ សំយោគ នៃ ឧបករណ៍នៅក្នុងពេល





មួយជាកំណត់ ពោលគឺ រចនាសម្ព័ន្ធ នៃ ឧបករណ៍ ដែលគេហៅថា «សហកាល» (synchronie) តម្រូវឲ្យគេស្គាល់ប្រវត្តិ នៃឧបករណ៍នីមួយៗ ឲ្យបានច្បាស់ ។ កត្តា ដែលមានឫសគល់ នៅក្នុង អតីតកាល ជាកត្តាសំខាន់ ប៉ុន្តែ ពុំធ្វើ អំពើដោយផ្ទាល់ ទៅលើព្រឹត្តការណ៍ទេ។ ទោះជាយ៉ាងនេះក្តី ក៏វា ជាឫស នៃ ព្រឹត្តិការណ៍ដែរ។ កត្តា នៅ ក្នុងសហកាល (synchronie) ជាកត្តាកំណត់ផ្ទាល់ នៃ ការស្តែងចេញឡើង នៃ ព្រឹត្តិ ការណ៍។ សំយោគ របស់វា នៅក្នុងខណៈមួយជាកំណត់ ក៏អាចជា កត្តាកំណត់ នៃ ព្រឹត្តិការណ៍នោះដែរ។ ព្រឹត្តិការណ៍ខ្លះ នៅក្នុងដំណាក់ការតែមួយ ក៏អាចជាប្រតិករ បង្កើតដោយផ្ទាល់ (catalyseur) នូវ ព្រឹត្តិការណ៍ ដែលយើងយកមកសិក្សានោះដែរ។ សហកាល ជា សំយោគមួយ ដ៏ធំទូលាយ ដែលគ្របដណ្តប់ ព្រឹត្តិការណ៍ ទាំងឡាយ នៅក្នុងសកលលោក នៅក្នុងពេលមួយជាកំណត់ ទោះនៅក្នុងរចនាសម្ព័ន្ធណាមួយ នៅ បច្ចុប្បន្នកាល ឬ ក្នុងអតីតកាលក្តី ។ ប៉ុន្តែគេក៏ត្រូវបេះបែងចែកដំណាក់ការ ឬ សម័យ កាលនីមួយៗ ផងដែរ ។ (délimitation d’une structure synchronique)។ កិច្ចការ សំខាន់ នៃ ការវិភាគ សង្គមសាស្ត្រ គឺ ការសំគាល់ នូវ បាតុភូតពិសេស (phénomènes spécifiques) នៃ សង្គមដែលគេសិក្សា ។ គេហៅ បាតុភូតនោះថា «បាតុភូត សង្គមសាស្ត្រ» (phénomènes sociologiques) ។ ព្រឹត្តិការណ៍ ដែលកើតមាន នៅ ក្នុងសង្គមមួយ មាន ឫសគល់ របស់ វា នៅក្នុងសង្គម នោះ គឺ រចនាសម្ព័ន្ធសង្គម-វប្បធម៌ និង សង្គម-សេដ្ឋកិច្ច ។ ឧ : នៅក្នុងសង្គមមួយ គេសង្កេតឃើញថា មនុស្ស ចូលចិត្តធ្វើនាម៉ឺន ធ្វើទាហាន ឬ ភ្នាក់ងារនគរបាល។ នៅក្នុងសង្គមមួយទៀត យុវជន បែរជាពុំព្រម ចូលរួមរស់ ក្នុងសង្គម។ ការពន្យល់មូលហេតុ នៃ ឥរិយាបថ ទាំងពីរនេះ តម្រូវឲ្យអ្នកវិភាគ យល់ច្បាស់ អំពី សង្គម-វប្បធម៌ អំពី សង្គម-នយោបាយ និង សង្គម-សេដ្ឋកិច្ច យ៉ាងច្បាស់ ។ ឧបករណ៍ ពីក្រៅ ដែលគេយកមក បន្តប់ផ្សាំ ឬក៏ យកមកបង្កាត់ (hybridation) នៅក្នុង រចនាសម្ព័ន្ធ ទាំងនោះ ទោះជា ក្នុងក្របខ័ណ្ឌ វប្បធម៌ នយោបាយ ឬ សេដ្ឋកិច្ចក្តី ក៏ អាចចាត់ទុកថា ជា ប្រតិករកំណត់ព្រឹត្តិការណ៍

ដែរៗ ប៉ុន្តែ ការបន្តុបព្រឹត្តិការណ៍មួយ មកលើសង្គមមួយ (transposition) មិនអាចចាត់ទុកថាជា «បាតុភូតសង្គមសាស្ត្រ» បានឡើយ ព្រោះ «បាតុភូតសង្គមសាស្ត្រ» មានប្រភពចេញមកពី រចនាសម្ព័ន្ធ នៃ សង្គមមួយដែលមានស្ថិរភាពគ្រប់គ្រាន់ ។ ជាទូទៅ សង្គមមានពីរប្រភេទសំខាន់ៗ គឺសង្គមដែលមិនវិវត្ត (société stagnante, ultra-conservatrice) និងសង្គមដែលកំពុងវិវត្តៗ នៅក្នុងសង្គមទី ១ ការរីកចម្រើនមិនអាចមានទៅបានទេ ប៉ុន្តែក៏ពុំមានអស្ថិរភាពដែរៗ សង្គម ទី ២ មានការរីកចម្រើនយ៉ាងឆាប់រហ័ស ប៉ុន្តែការផ្លាស់ប្តូរអ្នកដឹកនាំ ឲ្យទាន់សភាពការណ៍ ក៏ ជាការចាំបាច់ឌរ ។ សង្គមចុងក្រោយនេះ អាចតាម សភាពការណ៍ ពិភពលោកបាន ហើយ អាចការពារខ្លួនបាន គឺ ខុសពីសង្គមទី ១ ដែលដាច់ចេញពីខ្សែរយៈពិភពលោក ដូចជា ពួកប្រជាជនដើមនៅសហរដ្ឋ អាមេរិក ឬសង្គមកុម្មុយនិស្ត ដែលបិទជិតស្កុង ជាដើមៗ កាលណាសង្គម មានការរំជើបរំជួល គឺជាសញ្ញាល្អ ព្រោះគឺ ជាសង្គម ដែលកំពុងប្រែប្រួល ដើម្បីរកតុល្យភាព (le mécanisme d’auto-régulation fonctionne) ។ ឧ : នគរហ៊្វីណាន់ នគរ ចេន-ឡា សម័យអង្គរ ។ កត្តា ចលករ នៃ ការប្រែប្រួល គឺការវិវត្តន៍ នៃ វប្បធម៌ ដែលមិននៅទ្រឹងមួយកន្លែងៗ ឧទាហរណ៍: បដិវត្តន៍បារាំងចេញមកពី ការវិវត្តន៍ នៃវប្បធម៌បារាំង ដែលបានឈាន មកដល់ កម្រិតវិទ្យាសាស្ត្រមួយ ដ៏ខ្ពស់ ដោយសារ បទនិពន្ធផ្សេងៗ របស់ ទស្សនវិទូ បារាំង ដែលបាននាំគ្នាសរសេរសៀវភៅ វិជ្ជាសមាធាន (Encyclopédie) មួយដ៏ធំ ហើយ តាមរយៈនោះបាននាំលោកទស្សនៈថ្មី មកឲ្យអ្នកចេះដឹង និង ប្រជាជនបារាំង ។ ការរីកចម្រើន នៃការចេះ ដឹង បានធ្វើឲ្យការបកស្រាយតថភាព (réalités) របស់ ប្រជាជន បារាំងមានការប្រែប្រួល ជាមូលដ្ឋាន ហើយទន្ទឹមនោះ បានធ្វើឲ្យ អបីយជំនឿ ព្រមទាំងជំនឿគ្មានមូលដ្ឋានផ្សេងៗ ចុះថយឥទ្ធិពល របស់វា ជាបន្តបន្ទាប់ឌរ ។ បដិវត្តន៍ ពិតប្រាកដដែលកើតឡើង នៅក្នុងសង្គមមួយ ជាកំណត់ ជាការប្រជុំ ការប្រទាក់ក្រឡាគ្នា រវាងការវិត្តន៍ នៃ រចនាសម្ព័ន្ធបី គឺ ការវិវត្តន៍ នៅក្នុងវប្បធម៌ (ទស្សនវិជ្ជា បច្ចេកវិជ្ជា





វិទ្យាសាស្ត្រ) ការប្រែប្រួលស្ថានភាព សេដ្ឋកិច្ច និង ការរង្គោះរង្គើ នៃ ស្ថាប័ន ជាប្រពៃណី ។ បដិវត្តន៍ នយោបាយ គ្រាន់តែជា ការសម្រេច នៃ ការវិវត្តន៍ ទាំងបីនេះ ប៉ុណ្ណោះ បើពុំមែនជា ការដណ្តើមអំណាចគ្នា តាមបែបទសក្តិភូមិ ឬ ក៏ជា ការកំហិតមកពីខាងក្រៅរចនាសម្ព័ន្ធ នៃ សង្គមនោះទេ ។ បដិវត្តន៍សង្គម (គឺការវិវត្តន៍ ខ្លាំងដែលផ្ទុះឡើងតាមរយៈសំយោគ ខាងលើនេះ ដែលបានមកដល់កម្រិតមួយខ្ពស់ បំផុត) ជាបាតុភូតធម្មតាទេ កាលណា រដ្ឋអំណាចនយោបាយ រាំងខ្ទប់ការវិវត្តន៍នោះ មិនឲ្យចេញរូបៗ អ្នកនយោបាយខ្លះ ដែលយល់ហេតុផល ក៏ ធ្វើការផ្លាស់ប្តូរបន្តិចបន្តួច ដើម្បីកុំឲ្យមានការផ្ទុះ (អ្នកកែទម្រង់និយម, les réformistes)ៗ ប៉ុន្តែអ្នកនយោបាយខ្លះ ដែលចង់ឲ្យមានការផ្ទុះខ្លាំង គេធ្វើយ៉ាងណា មិនឲ្យមានការផ្លាស់ប្តូរមុន ដូច្នេះឡើយ ។ ទោះជាយ៉ាងណាក្តី បដិវត្តន៍សង្គម (ការបះបោរធម្មតា) ដែលគ្មាន ការលូតលាស់វប្បធម៌ ជាមូលដ្ឋាន ហើយដែល ការចេះដឹង ខាងវិទ្យាសាស្ត្រ និង ទស្សនវិជ្ជា ពុំបានចូលជ្រៅទៅក្នុងសង្គមទាំងមូល គ្រាន់តែជា ការប្រយុទ្ធផ្នែកនយោបាយសុទ្ធសាធ តែប៉ុណ្ណោះៗ បដិវត្តន៍ បែបនេះ តែងតែវិល មករក ចំណុចដើមដដែល ដោយគេចពុំផុត ។ នៅក្នុងករណីនេះ គេខាតបង់ពេលសម្រាប់ធ្វើបដិវត្តន៍ពិតប្រាកដទទេ គឺដាច់ចេញ ពី អភិក្រម នៃ ការវិវត្តន៍ដែលនាំសន្សឹមៗ ទៅរកបដិវត្តន៍ គឺការប្រែប្រួលខ្លាំងនៅ ដំណាក់ការចុងក្រោយបង្អស់របស់វា ។ ហេតុដូច្នេះហើយ បានជា អ្នកកាន់អំណាចខ្លះ ដែលពុំចង់ឲ្យមាន បដិវត្តន៍មែនទែន តែងតែរាំងស្កាត់ មិនឲ្យមានការរីកចម្រើន ឬ ការវិតត្តន៍ ផ្នែកវប្បធម៌ ជាពិសេសផ្នែកទស្សនវិជ្ជា ហើយ តាំងនាមគេជាអ្នកការពារវប្បធម៌ជាតិ គេរក្សាទុកតែ អ្វីៗ ដែលគេហៅថា ទំនៀមទម្លាប់ជាតិ តែប៉ុណ្ណោះ ពោល គឺ មិនឲ្យមានទស្សនៈអ្វីទៀត ក្រៅពីការគោរពទស្សនៈចាស់ឡើយ ។ បើនិយាយឲ្យចំ គឺ គេចង់គ្រប់គ្រងទាសករ ជាងចង់គ្រប់គ្រងពលរដ្ឋ ដែលមាន សេរីភាព និង ការចេះដឹង ។ រីឯតួនាទី ពិតប្រាកដ របស់ ទីប្រឹក្សា ក៏ពុំអាចមានទៅកើតដែរ ព្រោះអ្នកកាន់អំណាចតែងតែខ្វាចអំណាច របស់គេ ធ្លាក់ទៅក្នុងដៃ ទីប្រឹក្សាតែម្តង ។ ការពិត គឺ ពុំមែន ការ

រីកចម្រើន នៃ សង្គមទេ ដែលគេចង់បាននោះ តែជាអំណាចដែលគេយក មកសម្រាប់បម្រើបក្សពួក ឬ ក្រុមគ្រួសារ របស់គេ តែប៉ុណ្ណោះ។ គេអាចនិយាយបាន ថា បដិវត្តន៍នយោបាយ ជាផលិតផល នៃការវិវត្តន៍ ផ្នែកវប្បធម៌ របស់ សង្គមមួយជាកំណត់ (ករណី នៃ បដិវត្តន៍បារាំងឆ្នាំ ១៧៨៩)។ បដិវត្តន៍ ដែលយកឧបករណ៍ ពីក្រៅមកបន្ទុបដោយគ្មានការផ្សព្វ ឬបង្កាត់ គឺជា ព្រឹត្តិការណ៍ នយោបាយ សុទ្ធសាធ ហើយដូចនេះពុំអាច មានស្ថិរភាពបានទេ នៅក្នុងករណីដែល ប្រជាជន យល់មិនបានច្បាស់ ពីអត្ថប្រយោជន៍ នៃព្រឹត្តិការណ៍នោះ ចំពោះខ្លួនគេម្នាក់ៗ ក៏ដូចជា ចំពោះ ការលូតលាស់ នៃសង្គមទាំងមូល។ ទោះជាយ៉ាងនេះក្តី ការផ្ទុះ ឬ ការផុសចេញឡើង នៃ បដិវត្តន៍មួយសុទ្ធតែមាន ប្រតិករ របស់វា (catalyseur) នៅក្នុង សហកាល មួយជាកំណត់។ នៅក្នុងករណីដដែលនេះ គេអាចនិយាយបានថា ព្រឹត្តិការណ៍មួយដូចជា បដិវត្តន៍សង្គមជាដើម ដែលស្តែងចេញ នៅក្នុងសង្គមមួយ គឺជាតំណាក់ការ ចុងក្រោយ នៃ ការវិវត្តន៍របស់វា។ ក៏ប៉ុន្តែ បើពុំមែនដូច្នេះទេនោះ គេអាចនិយាយថា គឺជាការលូត ឬ ការពន្លូតព្រឹត្តិការណ៍មួយ មុនពេលដល់កម្រិតកំណត់ របស់វា។ បដិវត្តន៍ នៅប្រទេសរុស្ស៊ី និងនៅប្រទេសនានា ឯទៀត ត្រូវចាយពេលជាច្រើន ដើម្បីវិល ទៅរកចំណុចដើមវិញសិនជាបណ្តើរៗ ព្រោះដើរ ពុំទាន់ដល់ការយល់ដឹង អំពី គោលដៅ របស់អ្នកធ្វើបដិវត្តន៍។ និយាយមួយបែបទៀត កាលណាគ្មាន ការជាប់ពាក់ព័ន្ធ នឹង ការយល់ដឹង របស់ ប្រជាជន (ការវិវត្តន៍នៃការចេះដឹង) គឺគ្រាន់តែជា បាតុភូតនយោបាយប៉ុណ្ណោះ ពោលគឺ ការផ្លាស់ប្តូរអ្នកដឹកនាំ តែមិនមែនជាការប្រែប្រួល ជាសត្យានុម័ត នៃ សង្គមនោះឡើយ។ នៅក្នុងករណីនៃការបះបោរធម្មតា គេមិនអាចហៅថាបដិវត្តន៍បានទេ ព្រោះគ្មានគម្រោងធ្វើការកែប្រែរចនាសម្ព័ន្ធ ហើយបើគ្មានគម្រោងកែប្រែរចនាសម្ព័ន្ធនេះទេ គេ គ្រាន់តែប្តូរពីមនុស្សម្នាក់ ទៅមនុស្សម្នាក់ទៀត ដែលត្រូវរចនាសម្ព័ន្ធ ចាស់ កំណត់ឲ្យធ្វើឡើងវិញនូវអ្វីៗ ដែលគេចង់កំចាត់ចោលតែ ប៉ុណ្ណោះ។ បដិវត្តន៍ ពិតប្រាកដ ស្វែងរកអ្នកដឹកនាំ គឺមិនមែនអ្នកដឹកនាំនយោបាយ ណាម្នាក់ស្វែងរកអ្នកគាំទ្រខ្លួននោះទេ។





ខ្ញុំបានធ្វើការសិក្សាសង្គមខ្មែរ តាំងពីខ្ញុំនៅរៀននៅវិទ្យាល័យ។ ទន្ទឹមនឹង ការសិក្សាឯកសារ ខ្ញុំបានតាមដាន ព្រឹត្តិការណ៍នយោបាយ សំខាន់ៗ យ៉ាងប្រយ័ត្នប្រយែង ហើយ បានជួបសន្ទនា ជាមួយ តួអង្គ ប្រវត្តិសាស្ត្រ និង បញ្ញវន្តជាអ្នកនយោបាយ និង ទស្សនវិទូ ជាច្រើននាក់ ។ ខ្ញុំសង្កេតឃើញថា អ្នកនយោបាយ តែងតែ ចង់រក្សាទំនៀមទម្លាប់ចាស់ ដើម្បីអាចរក្សាអំណាច របស់គេ បន្តទៅទៀត ប៉ុន្តែ ទន្ទឹមនោះ គេក៏ទទួលស្គាល់ផងដែរ នូវ កត្តាទាំងឡាយ ដែលបានធ្វើឲ្យ ប្រទេស មានការលូតលាស់ មានវឌ្ឍនភាព ។ គួរកត់សំគាល់ផងដែរថា ទោះស្ថិតនៅក្នុង ស្ថានភាព ពិបាក បែបណាក្តី ស្តេចខ្មែរខ្លះ ដូចជា ស្តេច អង្គ អេង (ក.ឆ្នាំ ១៧៧២ -† ១៧៩៧)[1] អង្គ ច័ន្ទ ទី ៣ (ក.ឆ្នាំ ១៧៩១ -† ១៨៣៥)[2] អង្គ ដួង (ក. ឆ្នាំ ១៧៩១ -† ១៨៦០)[3] និង ស៊ីសុវត្ថិ (ក. ឆ្នាំ១៨៤០-† ១៩២៧)[4] ជាដើម បានយល់ច្បាស់ ពីការចាំបាច់ ត្រូវបើកចំហទទួលចរន្ត នៃ ការរីកចម្រើន មកពីបរទេស ហើយ ខិតខំ បើកផ្លូវឲ្យមានពន្លឺ មកពីបស្ចិមប្រទេស ប៉ុន្តែ ស្តេចខ្លះទៀត ពុំបានធ្វើតាមទេ នៅពេលដែលនៅស្រុកសៀមឯណោះ ស្តេចសៀម ជូឡាឡុងកន (១៨៥៣-១៩១០) បានជួលអ្នកប្រាជ្ញបស្ចិមប្រទេស មកឲ្យជួយបង្រៀន អ្នកដឹកនាំរបស់គេ។ នៅស្រុកយួនឯណោះវិញ នៅឆ្នាំ ១៨០២ រាជវង្សង្វៀង ដែលមានបង្អែក ពីបារាំង បានកសាង ចក្រភពមួយ នៅអណ្ណាម។ នៅស្រុកខ្មែរ នៅពេលក្រោយៗ មកទៀត គំនិតបែបនេះ ក៏មាន បន្តមកទៀតដែរ ។ មន្ត្រីរាជការ តែងតែបញ្ជូន កូនចៅ ឲ្យទៅរៀន នៅសាលាបារាំង ។ ប៉ុន្តែក្រោយមក «ពួក

---

[1] អង្គ អេង គ្រងរាជ្យ តាំងពីអាយុ ៦ឆ្នាំ គឺ ពី ឆ្នាំ ១៧៧៩ ដល់ឆ្នាំ ១៧៩៦។

[2] អង្គ ច័ន្ទ គ្រងរាជ្យពី ឆ្នាំ ១៨០៦ ដល់ឆ្នាំ ១៨៣៤។

[3] អង្គ ឌួង គ្រងរាជ្យពីឆ្នាំ ១៨៤១ ដល់ឆ្នាំ ១៨៥៩។

[4] ស៊ីសុវត្ថិ គ្រងរាជ្យ ពីឆ្នាំ ១៩០៤ ដល់ឆ្នាំ ១៩២៧។

អ្នកបដិវត្តអករក្សនិយម» បាននាំគ្នាបំផុសគំនិត ឲ្យបន្ទយ បរន្តនេះ មកវិញ ដោយជំរុញឲ្យយកភាសាខ្មែរ ធ្វើជាភាសាយាន នៅពេលមួយដែលប្រទេស ខ្វះឯកសារគ្រប់គ្រាន់សម្រាប់គ្រេបយកវិជ្ជាផ្សេងៗ ជាហេតុធ្វើឲ្យការចេះដឹង របស់ អ្នកជំនាន់ក្រោយចុះថយជាអតិបរមា។ ការពិត ចំពោះអ្នកនយោបាយ នៅពេលនោះ ចលនា ខេមរយានកម្ម មានគោលដៅ ផ្តាច់សង្គមខ្មែរទាំងមូល ពីការវិវត្តន៍ របស់ បស្ចិមប្រទេស តែប៉ុណ្ណោះ) ការសិក្សាទស្សនវិជ្ជា នៅថ្នាក់បញ្ចប់វិទ្យាល័យ ក៏ត្រូវបំបិទ មិនឲ្យមានតមកទៀតដែរ គឺ ឲ្យមានតែ អ្នកបច្ចេកទេស ខាងវិជ្ជាវិស្វកម្ម វេជ្ជសាស្ត្រជាដើម។ នយោបាយនេះ ជាហេតុដែលធ្វើឲ្យខ្មែរជំនាន់ក្រោយៗ មកទៀត ពុំបានយល់ច្បាស់អំពី តួនាទី របស់គេ នៅក្នុងបច្ចុប្បន្នកាល។ ហេតុនេះហើយ បានជាស្រុកខ្មែរ មានការពិបាកច្រើនក្នុងការសម្របខ្លួនទៅតាមដំណើរ និង សភាពការណ៍ ពិភពលោក ។ បច្ចុប្បន្ននេះ គេសង្កេតឃើញថា ប្រទេសណាក៏ដោយ ជាពិសេស ប្រទេសចិនកុម្មុយនិស្តនេះតែម្តង បាននាំគ្នា យកវប្បធម៌ អារ្យធម៌ តាមបែបបស្ចិមប្រទេស ធ្វើជា កត្តា នៃការលូតលាស់គ្រប់វិស័យ របស់គេ ជាហេតុ ធ្វើឲ្យយើង គិតឃើញ ថា បើស្រុកខ្មែរបានបន្តរបៀបនេះ តាំងពីពេលបានឯករាជ្យរហូតមក ម៉្លេះប្រទេសកម្ពុជា ប្រហែលជាមានការរីកចម្រើនខ្លាំង នៅពេលបច្ចុប្បន្ននេះដែរ។

មូលបទ ដែលខ្ញុំបានកំណត់ សម្រាប់ធ្វើការវិភាគមានទាំងអស់ ៧ មូលបទ ៖ *១) តេជានុភាព និង ការបុះដុនដាប នៃ បក្រភពខ្មែរ - ២) ទំនៀមទម្លាប់ខ្មែរ និង អភិក្រម ទំនើបកម្ម -៣) ទំនើបកម្ម : បដិវាទកម្ម រវាង វប្បធម៌ពីរ - ៤) ការស្វែងរកតុល្យភាព ដ៏ពិបាក រវាង ប្រពៃណី និង ភាពសម័យទំនើប - ៥) ដំណើរឆ្ពោះទៅរកភាពរណប នឹងអាណានិគមនិយមថ្មី - បដិវត្តន៍ របស់ អ្នកអភិរក្ស - បដិ វត្តន៍ដែលគ្មានប្រជាជនគាំទ្រ។*

*សុបិន* មានន័យថា មហិច្ឆតាគ្រប់គ្រងពិភពលោក និង ឈ្លានពានទឹកដី របស់ប្រទេសដែលចង់តាំងខ្លួនគេថាជាមហាអំណាច។ ប៉ុន្តែ *ការពិត* បានបង្ហាញឲ្យឃើញ ថា





ការបេញសោហ៊ុយ ដើម្បីប្រែក្លាយសុបិនទាំងនោះឲ្យទៅជាការពិត មានតម្លៃ ថ្លៃពន់ពេកក្រៃ ដូចជា សង្គ្រាម ការបង្ហូរឈាម ការកាប់សម្លាប់ប្រជាជន ដ៏គួរឲ្យរន្ធត់ ការបំបាត់សិទ្ធិសេរីភាព របស់ បុគ្គល ដើម្បី បុព្វហេតុផ្ទាល់ខ្លួន ឬ របស់ មនុស្សមួយក្រុម។ ធ្ងន់ធ្ងរជាងនេះទៅទៀត គឺ ការដែលគេយកប្រយោជន៍ផ្ទាល់ខ្លួនទាំងនោះ មកធ្វើជា បុព្វហេតុ នៃការប្រយុទ្ធរបស់សង្គមទាំងមូល និង របស់ មនុស្សជាតិ ផងទៀតក៏អាចថាបាន។ សោកនាដកម្ម នៅ *ពាល ហាប់ប័រ* នៅ *អៀរ៉ូស៊ីម៉ា* និង *ណាហ្គាសាគី* ការកាប់សម្លាប់ប្រជាជន នៅក្រោមរបប ប៉ុល ពត ការឈ្លានពានទឹកដី ពីសំណាក់ប្រទេសជិតខាង ការកសាងរដ្ឋកុម្មុយនិស្តដែលឈរនៅលើ ភេរវវិធី តែងតែនាំទៅរកការបង្ហូរឈាម ទៅរកសង្គ្រាម ព្រមទាំងការបំបាត់សិទ្ធិសេរីភាព ជាមូលដ្ឋានរបស់បុគ្គល។ មហិច្ឆតាទាំងនេះ ដែលបានធ្វើឲ្យពិភពលោក មានសង្គ្រាម ដ៏សោកសង្រេង សុទ្ធតែចេញមកពី សុបិន ទាំងអស់ ដូចប្រវត្តិសាស្ត្របានបង្ហាញឲ្យយើងឃើញយ៉ាងប្រត្យក្សស្រាប់។

មុន នឹង បញ្ចប់ សូមបញ្ជាក់ថា ឯកសារ ដែលជាមូលដ្ឋាន នៃ ការសិក្សានេះ មានប្រភពជាច្រើនទៀត ក្រៅពីឈ្មោះឯកសារ ដែលមានរាយ តាមលំដាប់លំដោយ នៅក្នុងគន្ថនិទ្ទេស (bibliographie) ដែលខ្ញុំដាក់នៅខាងក្រោយសៀវភៅ ។ កាលបរិច្ឆេទខ្លះ មានខុសគ្នាមួយឆ្នាំ ឬ ពីរឆ្នាំ រវាងប្រតិទិន ចន្ទគតិ និង សុរិយគតិ (ប្រតិទិនបារាំង-ខ្មែរ) ដូចការកត់សំគាល់ របស់ លោក យឹង ហុក ឌី នៅក្នុង កំណត់ ហតុសៀវភៅ *អក្សរសិល្ប៍ខ្មែរសតវត្ស ទី ១៩* របស់លោក នៅទំព័រ ៥ ។ ចំពោះកាលបរិច្ឆេទ ទាក់ទងនឹង រាជ្យស្តេចក្រោយសម័យអង្គរ ខ្ញុំផ្អែកមួយផ្នែកធំ ទៅលើការស្រាវជ្រាវ របស់ បណ្ឌិត ម៉ក់ ភឿន[5] ដែលបានធ្វើការផ្ទៀងផ្ទាត់ច្បាស់លាស់ នូវឯកសារជាច្រើនដែលលោកបានសិក្សាស្រាវជ្រាវយ៉ាងហ្មត់ចត់។

---

5) Essai de tableau chronologique des rois du Cambodge de la période post-angkorienne par Mak Phoeun, Directeur de recherche au CNRS (FRE

ចំពោះទិន្នន័យទាក់ទង នឹង សម័យ បុរេអង្គរ ដែលខ្ញុំលើកឡើងខ្លះៗដែរ គឺអាស្រ័យទាំងស្រុងទៅតាម ការស្រាវជ្រាវ ដែលចេះតែមាន ជាហូរហែបន្តបន្ទាប់ រហូតមកទល់ នឹងពេលនេះ ដោយ មិនអះអាងដាច់ខាត ទៅលើ ការស្រាវជ្រាវណាមួយ ជាពិសេសទេ ព្រោះនៅមានចំណុចច្រើនណាស់ ដែលយើងមិនទាន់ដឹងច្បាស់នៅឡើយ ទម្រាំបានលទ្ធផល នៃ ការស្រាវជ្រាវថ្មីៗទៀត ដែលត្រូវការចាយពេល ជាច្រើនទៀត ដើម្បីបញ្ជាក់ ។ គោលដៅ នៃ សៀវភៅ *សុបិន និង ការពិត* នេះ ជាការសិក្សាសង្គមសាស្ត្រ ទាក់ទងនឹង ព្រឹត្តិការណ៍ នៃ ទំព័រប្រវត្តិសាស្ត្រចុងក្រោយបង្អស់ ដែលខ្ញុំបានដឹងដោយផ្ទាល់ ប៉ុន្តែ ការពិចារណា អំពី អតីតកាលដែលមាន តាំងពីយូរមកហើយ ក៏ជាការចាំបាច់ដែរ ដើម្បីធ្វើការប្រៀបធៀប អំពី ការវិវត្តន៍ នៃ ស្ថានភាពភូមិសាស្ត្រ-នយោបាយ និង ប្រជាសាស្ត្រ តាមសម័យកាលនីមួយៗ។ ទន្ទឹមនោះ អ្វីដែលខ្ញុំចង់ លើកឡើងជាពិសេស ក្នុងសិក្សាកថានេះ គឺទំនាក់ទំនង រវាង សង្គមខ្មែរ និង ព្រឹត្តិ ការណ៍ នយោបាយ រវាង ដំណើរប្រវត្តិសាស្ត្រ និង វប្បធម៌។

វ៉ាន់ឌី កាអុន

ទីក្រុងប៉ារីស៍ ថ្ងៃ ទី ៩ តុលា ឆ្នាំ ២០១២

---

2380 : Asie du Dud-Est continentale. Peuples et contacts). *Journal Asiatique* 290.1 (2002) : 101-161. Voir aussi *Anthologie de la littérature khmèredu XIX ème siècle* de Khing Hoc Dy, chercheur au CNRS, p. 131 (note de bas de page).



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

# លំនាំដើម

បន្ទាប់ពីបានធ្វើការតស៊ូ យ៉ាងស្វិតស្វាញអស់រយៈពេល ៩០ ឆ្នាំ ដើម្បីដេញបារាំងចេញពីស្រុក អ្នកតស៊ូខ្មែរបានធ្លាក់ទៅក្នុងក្រញាំដៃ នៃ ពួកអាណានិគមនិយមថ្មីៗ ពេលបានឯករាជ្យពីបារាំង នៅឆ្នាំ ១៩៥៣ ព្រះមហាក្សត្រខ្មែរ ព្រះបាទនរោត្តម សីហនុ បែរទៅរកបង្អែក ពីប្រទេសកុម្មុយនិស្ត យួន និង ចិន ហើយ ចូលរួមធ្វើការប្រយុទ្ធតស៊ូប្រឆាំង នឹង បស្ចិមប្រទេសយ៉ាងពេញទំហឹង។ មិនមែនតែស្តេចខ្មែរ និង បញ្ញវន្តខ្មែរភាគច្រើន ប៉ុណ្ណោះទេ ដែលបានរួមចំណែក ក្នុងចលនោះ អ្នកដឹកនាំ និង បញ្ញវន្ត នៃ ប្រទេសកំពុងអភិវឌ្ឍជាច្រើន នៅក្នុងពិភពលោក ក៏គេចពុំផុតពី ចលនាផ្លាស់ប្តូរអាណានិគម ដ៏ធំនេះដែរ។ នៅឆ្នាំ ១៨៤៧ ទស្សនវិទូ អាល្លឺម៉ង់ កាល់ ម៉ាក្ស និង សេដ្ឋីជាមិត្តរបស់គាត់ម្នាក់ឈ្មោះ អង់ហ្គិល បានចេញផ្សាយ និវេតនកថា មួយមានចំណងជើងថា *និវេតនកថា នៃ បក្សកុម្មុយនិស្ត* (Manifeste du Parti communiste) ដែលបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើអ្វីដែលកាល់ ម៉ាក្ស ហៅថា «វណ្ណៈអធន» និង ទៅលើបញ្ញវន្ត គ្រប់ទិសទី ផងដែរ ។ នៅឆ្នាំ ១៨៦៤ «សមាគមពលករអន្តរជាតិទី ១» (Première Internationale) បានចាប់បដិសន្ធិ ។ នៅថ្ងៃ ២៥ តុលា ឆ្នាំ ១៩១៧ បដិវត្តន៍ បុលឆេវិក នៅប្រទេសរុស្ស៊ីបានផ្ទុះឡើង។ ស្តេចរុស្ស៊ី នីកូឡា ទី ២ ព្រមទាំងគ្រួសារ បានត្រូវ គេយកទៅប្រហារជីវិត ហើយ លេនីន ក៏ ឡើងកាន់អំណាច ។ បន្ទាប់ពីបាន ឆ្លងកាត់ វិបត្តិ នយោបាយមួយ ដ៏ធំ សាធារណរដ្ឋសង្គមនិយម សូវៀត បានចាប់បដិសន្ធិ នៅថ្ងៃ ៣០ ធ្នូឆ្នាំ ១៩២២ ហើយមាន តួនាទី ជាអ្នកដឹកនាំ បដិវត្តន៍ កុម្មុយនិស្ត នៅក្នុងសកលលោក ។ ចាប់តាំងពីឆ្នាំ ១៩៤៥ មករហូត ដល់ឆ្នាំ ១៩៧៥ នៅក្នុង «ប្រទេសកំពុងអភិវឌ្ឍ» ដែលកាលនោះ គេហៅថា

«ប្រទេសតតិយលោក» ចលនាតស៊ូរំដោះខ្លួនចេញពី អាណានិគមនិយម កាន់តែមាន ទ្រង់ទ្រាយដ៏ធំមហិមា។ អ្នកដឹកនាំ និងបញ្ញវន្តភាគច្រើន នៃ ប្រទេសទាំងនោះ ក៏បាន ចូលរួមចំណែក ក្នុងមហាចលនានោះដែរ។ ការពិត គឺគ្រាន់តែនាំគ្នាដេញខ្លាមួយ ហើយ បញ្ចូលខ្លាមួយទៀត មកក្នុងស្រុក ប៉ុណ្ណោះ។ ទន្ទឹមនោះ សង្គ្រាមត្រជាក់ រវាង សហរដ្ឋ អាមេរិក និង សហភាព សូវៀត រវាង លទ្ធិមូលធននិយម និង លទ្ធិសង្គមនិយម ឬ រវាងវណ្ណៈគហបតី និង វណ្ណៈអធន បានធ្វើឲ្យ ពិភពលោកទាំងមូល រំជើបរំជួលយ៉ាង ខ្លាំង ជាពិសេស សង្គ្រាម រវាង សហរដ្ឋ អាមេរិក និង វៀតណាម កុម្មុយនិស្ត ដែល មានប្រទេសចិនប្រជាមានិតុ (រហូតដល់ ឆ្នាំ ១៩៧៥) និង សហភាព សូវៀត នៅពី ក្រោយ។ នៅឥណ្ឌូចិន ប្រទេសកម្ពុជា ប្រទេសវៀតណាម ខាងជើង និង ប្រទេសឡាវ ចលនា ទាមទារឯករាជ្យ មានលក្ខណៈ ផុសផុល គួរឲ្យកត់សំគាល់ ប៉ុន្តែ ប្រទេស នីមួយៗ មានយុទ្ធសាស្ត្រ ពមុដូចគ្នា ទាំងស្រុងទេ។ នៅប្រទេសកម្ពុជា ស្តេចខ្មែរ នរោត្តម សីហនុ ដែលបារាំងដាក់ឲ្យគ្រងរាជ្យនៅឆ្នាំ ១៩៤១ ធ្វើការបរបោ ជាមួយបារាំង រីឯនៅប្រទេសវៀតណាម ខាងជើងវិញ ពួកវៀតមិញ ធ្វើការតស៊ូ ដោយប្រើអាវុធ ។ បារាំង ប្រគល់ឯករាជ្យ ឲ្យខ្មែរនៅឆ្នាំ ១៩៥៣ ហើយ នៅប្រទេសវៀតណាម ខាងជើង ពួកវៀតមិញ វាយឈ្នះ កងទ័ពបារាំង នៅ ឌៀន បៀន ភូ នៅឆ្នាំ ១៩៥៤ ។ នៅក្នុង ការតស៊ូដេញបារាំងនេះ ពួកវៀតមិញ បានបង្កើត ចលនាឥស្សរៈខ្មែរវៀតមិញ នៅលើ ទឹកដីខ្មែរ ដែលមាន សឺន ង៉ុក មិញ ជាអ្នកដឹកនាំ។ សន្និសីទទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ តម្រូវឲ្យពួកវៀតមិញ ចាកចេញពីទឹកដីខ្មែរ ប៉ុន្តែ នៅក្នុងគោលដៅ ប្រែក្លាយ អតីតឥណ្ឌូចិនបារាំង ឲ្យទៅជាកុម្មុយនិស្ត ពួកវៀតមិញ បានបង្កើតស្នូលកុម្មុយនិស្ត ដ៏ ធំមួយនៅលើ ទឹកដីខ្មែរ។ បន្ទាប់ពី មានទំនាស់មួយ ដ៏សំខាន់ រវាង ចិន និង សហភាព សូវៀត នៅឆ្នាំ ១៩៥៩ ចលនា កុម្មុយនិស្តខ្មែរ មាន ចរន្ត សំខាន់ពីរ គឺ មួយផ្អែក វាសនាទៅលើ បដិវត្តន៍វៀតណាមកុម្មុយនិស្ត និង សហភាព សូវៀត ហើយមួយទៀត ដឹកនាំដោយ សាឡុត សរ ហៅ ប៉ុល ពត បានយកចិនជាបង្អែក។ ទោះជាយ៉ាងនេះក្តី





នៅក្នុងក្របខ័ណ្ឌ នៃការតស៊ូរួម ប្រឆាំង នឹង «ចក្រពត្រអាមេរិក» អ្នកបដិវត្តចិន និង វៀតណាមកុម្មុយនិស្ត នៅតែធ្វើសហការគ្នា បន្តមកទៀត ដើម្បីដេញ កងទ័ព អាមេរិក ចេញ ពីឥណ្ឌូចិន។ នៅពេលនោះ ខ្មែរក្រហមនៅមាន ទំនាក់ទំនង ជាមួយវៀតណាម នៅឡើយ។ ពេលដែលសម្តេច នរោត្តម សីហនុ ត្រូវសភាទាំងពីរ ទម្លាក់ចេញ ពីមុខ នាទី ប្រមុខរដ្ឋ នៅថ្ងៃ ១៨ មិនាឆ្នាំ ១៩៧០ សម្តេច នរោត្តម សីហនុ បានទៅចូលរួម ជាមួយ ខ្មែរក្រហម ហើយ ថែមទាំងអំពាវនាវ ឲ្យកងទ័ពវៀតណាម កុម្មុយនិស្ត វាយ កងទ័ពឧត្តមសេនីយ៍ លន់ នល់ និង អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ផងទៀត។ នៅ ថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហម បានវាយរំលំរបប សាធារណរដ្ឋខ្មែរ ដូចគោល បំណង។ របប សាធារណរដ្ឋខ្មែរនេះ បានត្រូវឧត្តមសេនីយ៍ លន់ នល់ និង អ្នកអង្គ ម្ចាស់ សិរិមតៈ ប្រកាសនៅថ្ងៃ ៩ តុលាឆ្នាំ ១៩៧០ តាមការទាមទារ របស់បញ្ញវន្ត និង យុវជន ដែលមិននិយមកុម្មុយនិស្ត ។ លុះវាយរំលំ របបបនេះ - ដែលមានបស្ចិម ប្រទេស និង សហគមន៍ អន្តរជាតិគាំទ្រ - បានហើយ ពួកខ្មែរក្រហម ក៏ ចូលមកកាន់ កាប់អំណាច នៅ ថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ។ របប «កម្ពុជាប្រជាធិបតេយ្យ» របស់ ខ្មែរក្រហម បានកាប់សម្លាប់ប្រជាជនខ្មែរ អស់ជិត ២ លាន នាក់ មុន នឹង ត្រូវកងទ័ព វៀតណាម ដែលមាន សហភាព សូវៀត នៅពីក្រោយ វាយរំលំ ហើយចូលមកកាន់ កាប់ ទឹកដីខ្មែរ នៅថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩ ។ តាមមតិខ្លះ ការវាយប្រហារ របស់វៀត ណាមកុម្មុយនិស្ត និង សហភាព សូវៀត ទៅលើ របបខ្មែរក្រហមនេះ ជាការរំលោភ ទឹកដី និង អធិបតេយ្យខ្មែរ យ៉ាងជាក់ស្តែង ក៏ពិតមែន តែក៏បានរំដោះ ប្រជាជនខ្មែរ ដែលនៅសេសសល់ពីស្លាប់ ក្រោមរបប ប៉ុល ពត ឲ្យផុតពី ការកាប់សម្លាប់ បន្តទៅ ទៀតផងដែរ។ ប៉ុន្តែ តាមផ្លូវច្បាប់អន្តរជាតិ គឺ ជាការឈ្លានពានមួយដ៏ធំ របស់ កងទ័ពវៀតណាម មកលើប្រទេសកម្ពុជា។ បើនិយាយពីយុទ្ធសាស្ត្រវិញ ព្រឹត្តិការណ៍ នេះ ជាជ័យជំនះ របស់ប្រទេស វៀត ណាម និងសហភាព សូវៀត ទៅលើចិន ដែល ជាសម្ព័ន្ធមិត្ត របស់ពួកខ្មែរក្រហម ខាងប៉ុល ពត។ ទោះជាយ៉ាងណាក្តី ការចូលលុក

*លុយប្រទេស កម្ពុជា ដោយកង ទ័ពវៀត ណាមនេះ ក៏ ជាគោលបំណង តាំងពីយូរ អង្វែងមក របស់ ហូ ជីមិញ ដែរ ។ ពេលដែល គេបបួលខ្មែរ ឲ្យដេញបារាំង ចេញ ពីឥណ្ឌូចិន ហូ ជី មិញ គិតថា អតីតឥណ្ឌូចិនបារាំង ទាំងមូល និង ស្ថិតនៅក្រោម ការត្រួតត្រា របស់ ប្រទេសវៀតណាម កុម្មុយនិស្ត បន្ទាប់ពី វាយយកភាគខាងត្បូង បាន។ ការចូលលុកលុយ ប្រទេសកម្ពុជា នៅឆ្នាំ ១៩៧៩ គឺ ជាការសម្រេចគោល បំណងនេះ របស់វៀតណាម ពោល គឺ សុបិន របស់ហូ ជី មិញ បានក្លាយទៅជា ការពិត ។ ប៉ុន្តែ សហគមន៍អន្តជាតិ ជាពិសេស ចិន និង អាមេរិក ព្រមទាំងប្រទេស ភាគច្រើន នៃ សមាគមប្រជាជាតិ អាស៊ីអាគ្នេយ៍ ពុំបានបណ្តោយឲ្យ វៀតណាម ដែល មានសូវៀត ជាសម្ព័ន្ធមិត្ត យកតំបន់នេះ បានឡើយ។ ការប្រយុទ្ធ រវាង ប្រទេសវៀត ណាម សហភាព សូវៀត តទល់ នឹងចិន ព្រមទាំង សហរដ្ឋ អាមេរិក និង ប្រទេស នៃ សមាគមអាស៊ាន បានក្លាយ ទៅជា ការវិវាទមួយ ដ៏ធំ នៅក្នុងស្រុកខ្មែរ (១៩៧៩-១៩៨៩) ។ ប្រទេសដែលប្រឆាំង នឹង វៀតណាម ជាពិសេស ប្រឆាំង នឹង សហភាព សូវៀត បាននាំគ្នាជួយ ចលនាតស៊ូខ្មែរ វាយដេញកងទ័ពវៀតណាមយ៉ាងពេញទំហឹង។ គាប់ជួនពេលនោះ សហភាព សូវៀត ដែលមានវិបត្តិ មួយដ៏ធំ ទាំងផ្នែកនយោបាយ ទាំងផ្នែកសេដ្ឋកិច្ច បានប្តូរនយោបាយ របស់ គេ ហើយ គ្មានលទ្ធភាពផ្តល់ជំនួយ ទៅ ឲ្យវៀតណាម ទៀតឡើយ។ សហភាព សូវៀត ក៏បង្ខំចិត្ត ជានាជាមួយចិនវិញ។ នៅឆ្នាំ ១៩៨៩ បណ្តា ប្រទេសមហាអំណាច បានបើកសន្និសីទអន្តរជាតិមួយនៅទីក្រុងប៉ារីស៍ ដើម្បី បញ្ឈប់ការវិវាទ។ កិច្ចព្រមព្រៀង សន្តិភាពទីក្រុងប៉ារីស៍ នា ថ្ងៃ ២៣ តុលា ឆ្នាំ ១៩៩១ តម្រូវឲ្យ ភាគីបដិបក្ខខ្មែរទាំងបួនក្រុម ជានាគ្នាវិញ។ បន្ទាប់ពីបានចេញសេចក្តី សម្រេច ចិត្ត លេខ ៧៤៥ ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហប្រជាជាតិ ធ្វើអន្តរាគមន៍ នៅកម្ពុជា នៅឆ្នាំ ១៩៩២ ដើម្បីនាំសន្តិភាពមកវិញ។ អង្គការ «អាប្រូនុច»* (A.P.R.O. N.U.C.) *ពោលគឺ «អាជ្ញាធរបណ្តោះអាសន្ន នៃអង្គការ សហប្រជាជាតិ នៅកម្ពុជា» បានចាត់តាំងការបោះឆ្នោតសេរី  នៅថ្ងៃ ២៣ ឧសភាឆ្នាំ ១៩៩៣។ គណបក្ស រាជា*





*និយមដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ បានទទួលជ័យជំនះទៅលើ គណបក្ស «ប្រជាជន» របស់លោក ហ៊ុន សែន ដែលកាន់អំណាច តាំងពីឆ្នាំ ១៩៧៩ មក។ លោកហ៊ុន សែន ពុំព្រមទទួលស្គាល់លទ្ធផល នៃ ការបោះឆ្នោតនោះទេ។ នៅពេល នោះ ប្រទេសកម្ពុជាហៀបតែនឹងត្រូវបែងចែកជាពីរ* (*អបគមន៍*)*។ ព្រះអង្គម្ចាស់ ចក្រពង្ស បុត្រមួយអង្គ របស់ សម្តេច នរោត្តម សីហនុ ដែលនៅខាងលោក ហ៊ុន សែន មិនព្រមឲ្យ ព្រះអង្គម្ចាស់រណឫទ្ធិ ជាបង ឡើងកាន់អំណាចឡើយ។ ប៉ុន្តែបន្ទាប់ ពីបាន រកការស្រុះស្រួលមួយបាន* (*គឺព្រះអង្គម្ចាស់ រណឫទ្ធិ និង លោក ហ៊ុន សែន ឡើងធ្វើ ជានាយករដ្ឋមន្ត្រី ទាំងពីរនាក់ ក្នុងពេលតែមួយ*) *រដ្ឋាភិបាល «ក្បាលពីរ» នេះគ្រប់ គ្រងប្រទេសកម្ពុជា រហូតដល់ ខែកក្កដា ឆ្នាំ ១៩៩៧ គឺ ពេលដែលកម្លាំង កងទ័ព របស់ គណបក្សប្រជាជន និង កម្លាំងកងទ័ពខាងគណបក្ស «ហ៊្វុនស៊ិនប៉េច» ព្រឈម មុខដាក់គ្នាយ៉ាងខ្លាំង។ ព្រះអង្គម្ចាស់រណឫទ្ធិ សហនាយករដ្ឋមន្ត្រីទី ១ មានការពិបាក ទ្រាំទ្រ នឹង ការគាបសង្កត់ ពីសំណាក់លោក ហ៊ុន សែន សហនាយករដ្ឋ មន្ត្រី ទី ២ ។ រីឯលោក ហ៊ុន សែន លោកមិនព្រម ផ្តល់អំណាច ទៅឲ្យ គណបក្ស «ហ៊្វុនស៊ិនប៉េច» ទេ។ ប៉ុន្តែ នៅទីបំផុត កងទ័ពគណបក្សប្រជាជន បានយកឈ្នះទៅលើកងទ័ព ហ៊្វុនស៊ិន ប៉េចបាន ហើយព្រះអង្គម្ចាស់រណឫទ្ធិ ក៏ ភៀសខ្លួនទៅបរទេសបាត់ទៅ ។ ប៉ុន្តែ ចំពោះ ការដណ្តើមអំណាចគ្នាបែបនេះ  ការបកស្រាយមានខុសៗគ្នា  តាមការប្រកាន់ម្ខាងៗ។ មតិខ្លះ ចាត់ទុកថា ជារដ្ឋប្រហារ របស់ លោក ហ៊ុន សែន ព្រោះគណបក្សរាជានិយម «ហ៊្វុនស៊ិនប៉េច» ជាអ្នកឈ្នះឆ្នោតហើយរឿងអ្វី ដែលត្រូវ ប្រគល់អំណាច ទៅឲ្យលោក ហ៊ុន សែន នោះ។ នៅពេលនោះ លោក ហ៊ុន សែន  បានតែងតាំង លោក អ៊ឹង ហួត នៃ គណបក្ស ហ៊្វុនស៊ិនប៉េច ឲ្យជំនួសព្រះអង្គ ម្ចាស់រណឫទ្ធិ។ តាមការពិត ទាំងលោក ហ៊ុន សែន ទាំងរដ្ឋសភា គ្មានសិទ្ធិតែងតាំង នាយករដ្ឋមន្ត្រី ជំនួសព្រះអង្គម្ចាស់ រណឫទ្ធិ បានឡើយ ព្រោះ ព្រះអង្គម្ចាស់ណោឫទ្ធិ ជាអ្នកឈ្នះ ក្នុងការបោះឆ្នោត ហើយ ទោះបី នាយករដ្ឋមន្ត្រីថ្មី ជាសមាជិក គណបក្ស ហ៊្វុនស៊ិនប៉េចក្តី ។ ព្រឹត្តិការណ៍ នេះធ្វុះ*

បង្ហាញឲ្យឃើញខ្លះៗថា ការវិវាទដណ្ដើមឥទ្ធិពលគ្នា រវាងទីក្រុងប៉េកាំង និង ទីក្រុងហាណូយ បានឈានមកដល់ កម្រិតមួយ ដ៏ខ្ពស់ ។ ដូច្នេះឃើញថា ទីក្រុងប៉េកាំង បានទទួលបរាជ័យម្ដងទៀត ។ ទោះជាយ៉ាងណាក្ដី ការ ដណ្ដើមអំណាចគ្នា បែបនេះ បានធ្វើ ឲ្យប្រទេសកម្ពុជា ត្រូវបាត់បង់ និត្យានុកូលភាព របស់ ខ្លួន តាំងពីពេលនោះមក។ ប៉ុន្ដែការបរបោ ក៏បេះតែមាន បន្តមកទៀត ដើម្បីវិល ទៅរកនិត្យានុកូលភាពវិញ ទោះជាខុស នឹង គោលការណ៍កិច្ចព្រមព្រៀង សន្តិភាព ទីក្រុងប៉ារីស៍ឆ្នាំ ១៩៩១ ទាំងស្រុងក្ដី។ កិច្ចព្រមព្រៀង សន្តិភាព ទីក្រុងប៉ារីស៍ ហាមដាច់ខាតមិនឲ្យ ធ្វើការបរបោឡើយ គឺអ្វីៗត្រូវសម្រេច ទៅតាមលទ្ធផល នៃ ការបោះ ឆ្នោត។ សហគមន៍អន្តរជាតិ ដែលមិនចង់ឲ្យ ការអនុវត្តន៍ កិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស៍ ទទួលបរាជ័យ ព្រោះតែរឿងឥតព្រាងទុកនេះ ក៏ បណ្ដោយ ទៅតាម សភាពការណ៍តែម្ដងទៅ។ ម៉្យាងទៀតព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ ចង់ធ្វើការបង្រួបបង្រួមជាតិ ដោយព្រះអង្គផ្ទាល់ផង គឺធ្វើយ៉ាងណា ឲ្យពួកអតីតកុម្មុយនិស្ត គ្រប់គ្រងស្រុកខ្មែរបន្តទៅមុខទៀត ទោះត្រូវនាំគណបក្សរាជានិយមរបស់ព្រះអង្គ ទៅ រកបរាជ័យ ដ៏គួរឲ្យអាមាសមុខ យ៉ាងណាក៏ដោយ។ បន្ទាប់ពីបាននាំគ្នាក្បត់ កិច្ចព្រម ព្រៀងសន្តិភាពទីក្រុងប៉ារីស៍ សង្គ្រាមផ្ទៃក្នុងបិទមុខមួយ ក៏កើតមានឡើង គឺ សង្គ្រាម រវាងពួកអតីតកុម្មុយនិស្ត ដែលមាន វៀតណាមជាបង្អែក និងពួកអតីតកុម្មុយនិស្ត ដែលមានចិននៅពីក្រោយ មួយចំណែក ហើយ មួយចំណែកទៀត រវាង អ្នកមិនមែនកុម្មុយនិស្ត និង ពួកកុម្មុយនិស្តទាំងពីរប្រភេទនេះ។

គេអាចបែងចែក ការតស៊ូរបស់ប្រជាជាតិមួយ ទៅតាមសម័យកាលនីមួយៗ។ នៅក្នុងសម័យកាលចុងក្រោយនេះ គឺការស្វែងរកឯករាជ្យម្ដងទៀត ព្រមទាំងការកសាងមូលដ្ឋាន នៃ សេរីភាព និង អធិបតេយ្យ របស់ប្រជាជន និងបញ្ញវន្តឲ្យបានរឹងមាំ។ ចំពោះ ខ្មែរដែលមានការអប់រំតាមបែបបស្ចិមប្រទេស មានតែការពង្រឹង សេរីភាពនេះ





និងការរំដោះខ្លួនចេញពី យួន និង ចិនប៉ុណ្ណោះដែលអាចឃាត់ឃាំង មិនឲ្យ មនុស្សម្នាក់យកប្រទេស ទាំងមូលទៅធ្វើជា កម្មសិទ្ធិ ផ្ទាល់ខ្លួនរបស់គេបាន។

# ព្រឹត្តិការណ៍ សំខាន់ៗ នៅ សតវត្សរ៍ ទី ១៩ និង ទី ២០

ប្រវត្តិសាស្ត្រ មិនត្រឹមតែជាការតស៊ូ ដើម្បីរំដោះមនុស្សចេញពី ការជិះជាន់សង្កត់សង្កិន ពី អំពើអយុត្តិធម៌ ដូចការអះអាង របស់ អេហ្គិល ឬ ក៏ជា ការរកឃើញទ្វីប ថ្មីៗ ដោយពួកអ្នកផ្សងព្រេងស្បែកស ប៉ុណ្ណោះទេ តែ ក៏ជា ផលិតផល នៃ សុបិន របស់ អ្នកដឹកនាំ ចលនានយោបាយ នានា ដែលចង់តាំងខ្លួនជាអាទិទេពផងដែរ។ ជួនកាលទៅ សុបិនទាំងនោះស្រប នឹងសុបិន របស់បញ្ញវន្ត ជួនកាលទៅក៏ត្រូវប្រឈមមុខ នឹង អរិភាព របស់ អ្នកទាំងនោះទៅវិញដែរ។ នៅអាស៊ី ពួកអ្នកជាតិនិយម ដែលចង់រក្សា ទំនៀមទម្លាប់ដូនតា របស់គេ ប្រាថ្នាចង់បោសសំអាតពួកស្បែកសឲ្យចេញអស់ ពីដែនដី របស់គេ ព្រោះតាំងពីសតវត្សរ៍ ទី ១៣ មក ពួកនេះរុករានទន្ទ្រានប្រទេស របស់ពួកគេ ដោយឥតកោតក្រែងហើយបញ្ចូលវប្បធម៌ របស់ខ្លួន មកក្នុងប្រទេសទាំងនោះ ជាហេតុធ្វើឲ្យប៉ះពាល់ជាទម្ងន់ដល់ទំនៀមទម្លាប់ របៀបរបបរស់នៅ នៃ បណ្ដាប្រទេសអាស៊ីទាំងឡាយនោះ ជាពិសេស ដល់អាជ្ញារបស់អ្នកដឹកនាំសក្ដិភូមិទាំងនោះ ដែលចង់រក្សាអំណាចរបស់គេ ដោយមិនឲ្យប្រជាជន មានទស្សនៈណាមួយទៀត ដែលខុសពីឱវាទ របស់ ពួកគេឡើយ។ ប៉ុន្ដែ នេះជាការមួយដ៏ពិបាក ព្រោះចរន្តទស្សនវិជ្ជា និងវឌ្ឍនភាព នៃ វិទ្យាសាស្ត្រ មកពីបស្ចិមប្រទេស បានត្រូវបញ្ញវន្ត ដែលចង់រើបម្រាសចេញ ពីទំនៀមទម្លាប់ មិនសមហេតុផល និង ពី អំណាចសក្ដិភូមិ របស់អ្នកដឹកនាំរបស់គេ យល់ថាជាកត្តា នៃ ការរីកចម្រើនទៅវិញ។

នៅប្រទេសសៀម នៅចន្លោះសតវត្សរ៍ ទី ១៩ និង ទី ២០ ស្តេច ជូឡាឡុងកន បាន ហៅឲ្យបារាំង និង អង់គ្លេស ចូលមកជួយកសាងប្រទេស។ ស្តេចសៀមអង្គនេះដែល មានកូន ៧៧ នាក់ និង ប្រពន្ធ ៣៦ នាក់ ក្នុងចំណោមប្រពន្ធទាំងអស់ ៩២ នាក់ បាន បំបាត់របប ទាសភាព នៅឆ្នាំ ១៨៩៥ ។ ៤២ ឆ្នាំមុនព្រឹត្តិការណ៍នេះ គឺ នៅឆ្នាំ ១៨៥៣ ស្តេចខ្មែរព្រះបាទ អង្គ ដួង ដែលយកតម្រាប់តាម ព្រះបាទអង្គច័ន្ទ ជាព្រះរៀម ខិតខំ បើកចំហឲ្យស្រុកខ្មែរ ទទួលចរន្ត សម័យទំនើប ហើយនៅឆ្នាំ ១៨៥៣ បានស្វែងរក បារាំង ឲ្យមកជួយរំដោះស្រុកខ្មែរចេញពីការគំរាមកំហែងរបស់ ប្រទេសសៀម និង ប្រទេសវៀតណាម ដែលចង់វាយយក ស្រុកខ្មែរ តែរៀងៗ ខ្លួន បើពុំនោះសោតទេ គឺ យកទៅចែកគ្នា មួយចំណែកម្នាក់ ។ មុនពេលដែល បារាំងមកបោះទី តាំងរបស់គេ នៅកូសាំងស៊ីន ប្រទេសវៀតណាម បានដាក់បន្ទុប ព្រះអង្គម្ចាស់ក្សត្រីខ្មែរ អង្គ មី (១៨៣៥-១៨៤៧) ឲ្យឡើងគ្រងរាជ្យ។ នៅសម័យនោះ ស្តេចយួន មិញ ម៉ាង បានដាក់ ទ្រឿង មិញ យ៉ាង, ផាំ វ៉ាន់ ខៀន និង ត្រឹង វ៉ាន់ ណាង ឲ្យ គ្រប់គ្រងស្រុកខ្មែរ ទាំងមូល។ នៅពេលនោះ ទីក្រុងភ្នំពេញ បានត្រូវគេហៅថា ទីក្រុងណាំយ៉ាង ។ ប៉ុន្តែ ខ្មែរបានងើបឡើងបះបោរដេញយួន ចេញពីស្រុកបានវិញ (សូមអានរឿងនេះ ដែលមាន បរិយាយ លំអិត នៅជំពូកទី ១) ។ នៅដើមសតវត្សរ៍ ទី ២០ ក្រោមការដឹកនាំ របស់ ហូ ជិមិញ ដែលបានបង្កើត បក្សកុម្មុយនិស្ត ឥណ្ឌូចិន នៅឆ្នាំ ១៩៣០ ចលនា ទាមទារ ឯករាជ្យយួន ដែលមានទំនាក់ទំនង ជាមួយ ចលនា កុម្មុយនិស្ត អន្តរជាតិ នាំគ្នាបបួល ខ្មែរ ឲ្យ ដេញអាណានិគមនិយម បារាំង ចេញពីស្រុក ។ លុះបារាំងចេញពីស្រុកខ្មែរ ហើយ គេនឹងគ្រប់គ្រងស្រុកខ្មែរ ជំនួសបារាំងតែម្តង ។ នៅដើមសតវត្សរ៍ ទី ២០ ប្រទេសជប៉ុន ក្រោមការដឹកនាំ របស់ ពួកយោធានិយម បានចាប់ផ្តើម វាយយកអាស៊ី និង សហរដ្ឋ អាមេរិកតែម្តង។ នៅឆ្នាំ ១៩១០ ជប៉ុន វាយយកប្រទេសកូរ៉េ បន្ទាប់មក នៅឆ្នាំ ១៩៣១ វាយយក ម៉ាន់ជូរី និង ខេត្តផ្នែកខាងជើង នៃ ប្រទេសចិន ហើយនៅឆ្នាំ ១៩៣៧ វាយយកប្រទេសចិន តែម្តង ដោយទម្លាក់គ្រាប់ បែកយ៉ាងដំណំទៅលើ សៀង





ហៃ និង កង់តុង បន្ទាប់មកចូលលុកលុយ សម្លាប់ប្រជាជនស៊ីវិលចិន នៅ ណង់កាំង។ នៅឆ្នាំ ១៩៣៩ សង្គ្រាមលោក លើកទី ២ បានផ្ទុះឡើង ។ ហ៊ីត្លែរ វាយលុកយកផ្នែក ជាច្រើន នៃ ពិភពលោក រួមទាំង ទ្វីបអឺរ៉ុប និង ប្រទេសចិនផងដែរ ។ បន្ទាប់មកទៀត នៅឆ្នាំ១៩៤១ កងទ័ពជប៉ុន វាយប្រហារទៅលើ មូលដ្ឋានយោធា អាមេរិកនៅ ពាល ហាប័រ ជ្រោយ ហាវ៉ៃ ហើយនៅពេលដដែលនោះ ក៏ចូលមកលុកលុយស្រុកខ្មែរដែរ។ រីឯប្រទេសចិនវិញ ទោះបីមានបញ្ហាផ្ទៃក្នុង ស្មុគស្មាញយ៉ាងណាក្តី សុបិន របស់គេ គឺ ត្រួតត្រាតំបន់អាស៊ីទាំងមូលតែម្តង។ សហរដ្ឋ អាមេរិកចូលប្រឡូកក្នុងសង្គ្រាម ប្រឆាំង នឹង ការលុកលុយ របស់ ពួកហ៊ីត្លែរ នៅខែមិថុនា ឆ្នាំ ១៩៤១ ។ សន្និសីទយ៉ាល់តា (Yalta) រវាងអ្នកដឹកនាំ សូវៀត (ស្តាហ្សេហ្វ ស្តាលីន) អាមេរិក (ហ្វ្រង់ក្លាំង រូស្វ៊ែវែល) អង់គ្លេស (វីនស្តុន ឈើរឈីល) បានកំណត់យក គោលការណ៍សំខាន់ៗ ៣ យ៉ាង ៖ ១) កំណត់យុទ្ធសាស្ត្ររួមមួយ ដើម្បីបញ្ចប់សង្គ្រាមលោក ឲ្យបានឆាប់រហ័ស -២) កំណត់ ជោគវាសនា របស់ អឺរ៉ុប បន្ទាប់ពី បរាជ័យ របស់ ពួកណាស៊ី ហ៊ីត្លែរ - ៣) កំណត់ស្ថិរភាព ពិភពលោក។ សង្គ្រាមលោក លើកទី ២ បានត្រូវបញ្ចប់ នៅ ថ្ងៃ ៨ ឧសភាឆ្នាំ ១៩៤៥ នៅអឺរ៉ុប នៅថ្ងៃ ២ កញ្ញាឆ្នាំ ១៩៤៥ នៅអាស៊ី និង នៅក្នុងពិភព លោកទាំងមូល។ របប ណាស៊ី ហ៊ីត្លែរ បានទទួល បរាជ័យ យ៉ាងដំណំ ។ នៅថ្ងៃ ៦ និង ៩ សីហា ឆ្នាំ ១៩៤៥ សហរដ្ឋ អាមេរិក បានទម្លាក់គ្រាប់បែក បរមាណូទៅលើ ហៀរ៉ូស៊ីម៉ា និង ណាហ្កាសាគី បណ្តាលឲ្យមានវិនាសកម្មមួយ ដ៏ធំសម្បើម។

# ចលនាទាមទារ ឯករាជ្យ និង លោកកុម្មុយនិស្ត

គេអាចនិយាយបានថា ការទាមទារឯករាជ្យ នៃ បណ្តាប្រទេសទាំងនោះ បានទទួលការគាំទ្រយ៉ាងមាំ ពី បណ្តាប្រទេសកុម្មុយនិស្ត ដែលជាសត្រូវ របស់ សហរដ្ឋអាមេរិក។ នៅប្រទេសវៀតណាម ចលនាអ្នកជាតិនិយមដែលប្រឆាំង នឹងពួកអាណានិគមនិយមបារាំង បានក្លាយទៅជា ចលនាកុម្មុយនិស្ត ហើយនៅក្នុងន័យនេះ ធ្វើការប្រយុទ្ធ នឹង សហរដ្ឋអាមេរិក យ៉ាងខ្លាំងក្លា។ ចលនាកម្មុយនិស្ត ចង់ផ្លាស់ប្តូរមុខ មាត់ពិភពលោក ហើយ ធ្វើការប្រយុទ្ធតស៊ូ ដើម្បីឲ្យមាន យុត្តិធម៌ នៅក្នុងសង្គម ។ វណ្ណៈគហបតី ជិះជាន់សង្កត់សង្កិន អ្នកខ្សត់ខ្សោយក្រីក្រ ឥតត្រាប្រណី ប៉ុន្តែអង្គការកុម្មុយនិស្តអន្តរជាតិ ប្រកាន់ របៀបផ្តាច់ការ បំបាត់សិទ្ធិ សេរីភាព ក្នុងការគិតពិចារណា និង ការបញ្ចេញមតិ សព្វបែបយ៉ាង ហើយថែមទាំងដាក់ប្រទេសកុម្មុយនិស្ត នានាឲ្យរណប នឹង ខ្លួនទៀតផង ជាហេតុបង្កើតឲ្យមាន អារិភាព មួយដ៏ធំ ជាមួយបញ្ញវន្តនៅសម័យនោះ។ នៅឆ្នាំ ១៩៥៧ កវីរុស្ស៊ី បូរីស ប៉ាស្ទែរណាក់ បានត្រូវរដ្ឋអំណាចសូវៀតឃាត់ឃាំងមិនឲ្យទៅទទួលរង្វាន់ណូបែលអក្សរសិល្ប៍ (Prix Nobel de littérature) ហើយ ជាពិសេស នៅថ្ងៃ ២១ សីហាឆ្នាំ ១៩៦៨ រថក្រោះ សូវៀតបានចូលមកក្នុងទីក្រុងប្រ៉ាកឃ៍ ចាប់ខ្លួនអាឡេចសង់ដ្រ៍ ឌុបឆេកអ្នកកែទម្រង់ប្រទេសឆេកូស្លូវ៉ាគីតែម្តង។ អាឡេចសង់ដ្រ៍ ឌុបឆេក បានចាប់ផ្តើមធ្វើការកែទម្រង់ ប្រែក្លាយរបបសង្គមនិយម ឲ្យមានលក្ខណៈមនុស្សធម៌ បានតែ ៨ ខែប៉ុណ្ណោះ គឺ ពី ថ្ងៃ ៥ មករាឆ្នាំ ១៩៦៨ មក។ តាំងពីពេលនោះមក ចលនា បញ្ញវន្ត នៅ សហភាព សូវៀត និង នៅប្រទេសបារាំង ក៏ចាប់ផ្តើមដឹងថា អ្នកដឹកនាំប្រទេសកុម្មុយនិស មិនមែនជាមិត្តរបស់គេទេ ។ ប៉ុន្តែ នៅប្រទេសកម្ពុជា គេឃើញមានប្រតិកម្ម បែបនេះ តែក្នុង





ចំណោមបញ្ញវន្តមួយចំនួន ប៉ុណ្ណោះ ។ សុបិន កុម្មុយនិស្ត ក៏ចាប់ផ្តើមជួបនឹង ការពិត គឺ ការតស៊ូ ជាអចិន្ត្រៃយ៍ នៃ សង្គមមនុស្ស ដើម្បីទាមទារសេរីភាព។ នៅប្រទេសកម្ពុជា ក្រោយពេលបានឯករាជ្យ ពីបារាំងៗ នៅតែជួយពង្រឹង ការកសាងមូលដ្ឋានបច្ចេកទេស និង ចំណេះវិជ្ជាបន្តមកទៀត។ ប៉ុន្តែ ប្រទេសចិនកុម្មុយនិស្តដែលចង់បំបាត់ឥទ្ធិពលបារាំង ឲ្យផុតរលត់តែម្តង ដើម្បីអាចដើរតួនាទីជំនួសបារាំង ក៏ប្រមែប្រមូលអ្នកចេះដឹងខ្មែរមួយចំនួនជាពិសេសអ្នករៀននៅស្រុកបារាំង ឲ្យនាំគ្នាបោសសំអាត វប្បធម៌បារាំង ចេញអស់ ពីស្រុកខ្មែរ ដោយបង្កើតស្នូលកុម្មុយនិស្ត នៅក្នុងចំណោមអ្នកចេះដឹង។ គឺស្នូលនេះហើយ ដែលក្រោយមក បានក្លាយទៅជាសំបុកពួកខ្មែរក្រហម។ វិទ្យាល័យឯកជនពីរ គឺ *ចំរើនវិជ្ជា* និង*កម្ពុជាបុត្រ* ព្រមទាំងកាសែតខ្មែរមួយចំនួន ដូចជាកាសែត *ឯកភាព* របស់ លោក ពីង សយ ជាដើម ដើរតួនាទី ដ៏សំខាន់ក្នុងការ បញ្ចុះឥទ្ធិពលបារាំង នៅកម្ពុជា ។ ទោះជាយ៉ាងនេះក្តី ក៏អ្នកដែលបានរៀននៅ សាលាបារាំង បានក្លាយទៅជា មូលដ្ឋានមួយ ដ៏សំខាន់ សម្រាប់ឲ្យ សម្តេចនរោត្តម សីហនុ កសាង របបមួយ ដែលមិនយោល ទៅតាម របនាបទ កុម្មុយនិស្តទាំងស្រុងពេកដែរ។ នៅដើមដំបូង នយោបាយ នៃ ចលនាសង្គមរាស្ត្រនិយម របស់សម្តេច សីហនុ មានលំនឹងល្អ ជាហេតុធ្វើឲ្យខ្មែរមានកេរិតវប្បធម៌ និង ជីវភាពល្អប្រសើរ ព្រមទាំង សន្តិសុខគ្រប់គ្រាន់ ជាហេតុធ្វើឲ្យអ្នកដែលធ្លាប់បានស្គាល់របបនេះ តែងតែសរសើរមិនដាច់ ប៉ុន្តែ ដោយមិនដឹងថា លទ្ធផល ដែលបានមកនេះ ក៏ ដោយសាតែ ការរីកចម្រើនផ្នែកវប្បធម៌បារាំងនោះដែរ។ ទោះជាយ៉ាងនេះក្តី ដោយគេបំផុសឲ្យមាន មោទនភាពជាតិ ហួសហេតុ ដើម្បីរៀបចំកន្លែង ឲ្យពួកអាណានិគមនិយមថ្មីចូលមកដោយស្រួល គេក៏តាំងរៀបចំឯករាជ្យផ្នែកវប្បធម៌តែម្តង។ កម្មវិធី*ខេមរយានកម្ម* ក៏ចាប់ផ្តើម ទោះជាសៀវភៅបច្ចេកទេស និងទស្សនវិជ្ជា ជាភាសាខ្មែរ គ្មានគ្រប់គ្រាន់ក៏ដោយ។ តាមការពិត គោលដៅ របស់ អ្នកដឹកនាំ នៅពេលនោះ គឺ រៀបចំអំណាចមួយថ្មីទៀត ដោយកាត់ផ្តាច់ការពិចារណាតាមបែបបស្ចិមប្រទេស ចេញ ឲ្យ

ដាច់ស្រឡះ ជាពិសេស គំនិតទាក់ទង នឹង បដិវត្តន៍បារាំង នាឆ្នាំ ១៧៨៩ ដែលបាន យកស្តេចបារាំង ល្វី ទី ១៦ ទៅកាត់ក។ គេតម្រូវឲ្យមានតែបច្ចេកទេស វិស្វកម្ម វេជ្ជសាស្ត្រ និងបច្ចេកទេសមួយចំនួនទៀត ដែលមិនបង្កគ្រោះថ្នាក់ដល់របប ថ្មីប៉ុណ្ណោះ។ កម្មវិធីសិក្សាទស្សនវិជ្ជានៅថ្នាក់បញ្ចប់ នៃ មធ្យមសិក្សាត្រូវលុបចោល គឺរក្សាទុកតែផ្នែកវិទ្យាសាស្ត្រ (sciences exp.) និង គណិតវិទ្យាប៉ុណ្ណោះ ( math. élémentaires) ហើយគេនាំគ្នាឃោសនាបន្អាប់បន្អោនមុខវិជ្ជានេះថែមទៀត។ បញ្ញវន្ត មួយចំនួនតូច ដែលដឹងជាស្រេចថា គឺ ជាការកាត់ផ្តាច់វិចារណញ្ញាណ ពីកូនខ្មែរ ក៏ ខំនាំ គ្នាបើកសាលាបង្រៀន ទស្សនវិជ្ជានេះ នៅតាម សាលាឯកជន ដូចជា វិទ្យាល័យ វ៉ុលតែរ (Lycée Voltaire) វិទ្យាល័យ នូ កន ជាដើម ។

## ការតស៊ូ ទាមទារឯករាជ្យ នៅ ប្រទេសកម្ពុជា

ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ ដែលបានត្រូវ បារាំងដាក់ឲ្យឡើងសោយរាជ្យនៅឆ្នាំ ១៩៤១ បានចាប់ផ្តើមទាមទារឯករាជ្យនៅឆ្នាំ ១៩៥២។ ព្រះអង្គឡើងគ្រងរាជ្យ នៅសម័យសង្គ្រាមលោក លើកទី ២។ កាលនោះរបប វីស៊ី (Vichy ) មានទំនាក់ទំនងជាមួយ ជប៉ុន ហើយជប៉ុនក៏បណ្តោយឲ្យបារាំងចាត់ចែងការងារ នៅស្រុកខ្មែរបន្តមកទៀត។ បន្ទាប់ពី «រាជបូជនីយកិច្ចដើម្បីឯករាជ្យ» («Croisade royale pour l'Indépendance») នៅឆ្នាំ ១៩៥២ ព្រះមហាក្សត្រខ្មែរបានទទួល ឯករាជ្យបរិបូរពីបារាំង នៅខែវិច្ឆិកា ឆ្នាំ ១៩៥៣។ ឯករាជ្យនេះ បានត្រូវទទួលស្គាល់ ដោយសន្និសីទអន្តរជាតិ ទីក្រុងហ្សឺណែវ ខែ ឧសភា-កក្កដា ឆ្នាំ ១៩៥៤ ។ លោក សម សារី នៃ គណប្រតិភូបរោកម្ពុជា បានទាមទារឲ្យមាន ការធានាគ្រប់បែបយ៉ាង រួម





បញ្ចូលទាំងសិទ្ធិ ក្នុងការជ្រើសរើសសម្ព័ន្ធមិត្ត របស់ខ្លួនទៀតផង ជាពិសេស ការដកកងទ័ពវៀតមិញចេញអស់ ពីទឹកដីខ្មែរ។ អស់ពេញមួយយប់ នៅក្នុងរាត្រីថ្ងៃ ២០- ២១ កក្កដា លោក សម សារី បានទាមទារ នៅក្នុងបរិយាកាសមួយ ដ៏ តានតឹង នូវការធានាទាំងឡាយនេះ ។ នៅទីបំផុតលោក ម៉ូឡូតុហ្វ ខាងសហភាព សូវៀត ក៏សុខចិត្តយល់ព្រម។ អ្នកប្រកាន់ខាងកុម្មុយនិស្ត មិនសប្បាយចិត្តប៉ុន្មាន នឹង ការទាមទារ របស់ លោក សម សារី ឡើយ ។ ចលនា ទាមទារឯករាជ្យចាប់ផ្តើមមានរូបរាងយ៉ាងច្បាស់តាំងពីឆ្នាំ ១៩៣៦ នៅក្នុងចំណោម បញ្ញវន្តខ្មែរ មកឯណោះ ។ ឥស្សរៈ ខ្មែរមួយក្រុម ដែលមានការឧបត្ថម្ភ ពី ពួកវៀតណាមកុម្មុយនិស្ត ហើយដែលមាន សឺន ង៉ុក មិញ ហៅអាចារ្យ មាន ជាអ្នកដឹកនាំ កំណត់យក ការដេញបារាំងចេញពីស្រុកតាមផ្លូវអាវុធ ប៉ុន្តែ ទាល់តែពេលក្រោយមកទៀត ទើបអ្នកទាំងនោះដឹងថា ហូជិមិញ មានគោលដៅមួយទៀត គឺ ផុតពីបារាំងទៅ គេនឹងជំនួសបារាំងតែម្តង។ អ្នកឆ្វេងនិយមក្រោយៗមកទៀត ដូចជា សាឡុត សរ ជាដើម ក៏ ធ្វើការតស៊ូ តាមផ្លូវអាវុធដែរ។ នៅឆ្នាំ ១៩៣៦ សឺន ង៉ុក ថាន់ បានបង្កើតកាសែតខ្មែរមួយឈ្មោះ នគរវត្ត (Nagarawatta) ជាមួយ លោក ប៉ាច ឈឿន ព្រមទាំង អ្នកស្នេហាជាតិ មួយចំនួនទៀត ដូចជា អាចារ្យ ហែម ចៀវ លោក ប៉ិន ចាន់ ម៉ុល ជាដើម ។ នៅឆ្នាំ ១៩៤២ ក្រុមនេះ បាននាំគ្នាធ្វើបាតុកម្ម ដេញបារាំង យ៉ាងគគ្រឹកគគ្រេង នៅកណ្តាល ទីក្រុងភ្នំពេញ ។ អាចារ្យ ហែម ចៀវ និង លោក ប៉ិន ចាន់ម៉ុល បានត្រូវបារាំងចាប់បានហើយយកទៅដាក់គុក នៅកោះត្រឡាច (Poulo Condor) ។ លោក សឺន ង៉ុក ថាន់ បានរត់ទៅប្រទេសជប៉ុន តាមប្រទេសសៀម ។ ក្រុមមួយទៀត ដែលមិនចូលរួមចំណែក ជាមួយ ពួកវៀតមិញ ដូចលោក សឺន ង៉ុក ថាន់ ដែរ គឺ ក្រុមអ្នកអង្គម្ចាស់ នរោត្តម ចន្ទរង្សី ធ្វើការតស៊ូតាមទារឯករាជ្យដើម្បី រក្សារបបរាជានិយម ដូចអង្គ ស៊ីវត្ថា កាលពីសតវត្សរ៍ ទី ១៩ ដូច្នេះដែរ ។ នៅឆ្នាំ ១៩៤៦ បញ្ញវន្តល្បីៗមួយចំនួន ដូចជា លោក ស៊ឹម វ៉ា លោក អៀវ កឺះ បាននាំគ្នា បង្កើត គណបក្ស ជាផ្លូវការមួយ

ឈ្មោះ គណបក្សប្រជាធិបតេយ្យ ដែលមានកម្មវិធី ទាមទារឯករាជ្យដូចគ្នាដូច្នេះដែរ។ អ្នកអង្គម្ចាស់យុត្តិវង្ស ក៏បានត្រឡប់មកពីស្រុកបារាំងនៅឆ្នាំ ១៩៤៦ មកចូលរួមជាមួយគណក្សប្រជាធិបតេយ្យ នេះដែរ បន្ទាប់មក បានទទួលតួនាទីដឹកនាំ គណបក្សប្រជាធិបតេយ្យ នេះតែម្តង។ គណបក្សប្រជាធិបតេយ្យ ដែលមាននិន្នាការជឿនលឿននិយម បានទទួលជ័យជំនះ យ៉ាងត្រចះត្រចង់ ក្នុងការបោះឆ្នោត សភាធម្មនុញ្ញ និងក្នុងការបោះឆ្នោតសភា ក្រោយៗមកទៀត ប៉ុន្តែ ជាអកុសល អ្នកអង្គម្ចាស់យុត្តិវង្ស ចូលជីវង្គត នៅថ្ងៃ ១១ កក្កដាឆ្នាំ ១៩៤៧ ហើយលោក អៀវ កើះ ត្រូវគេធ្វើឃាត នៅថ្ងៃ ១៤ មករាឆ្នាំ ១៩៥០ ។ ពេលព្រះមហាក្សត្រ នរោត្តម សីហនុ ទាមទារឯករាជ្យ មានបញ្ញវន្តមួយក្រុម ដូចជាលោក សម សារី លោក ញឹក ជូឡុង និង អ្នករាជការមួយចំនួន ជាអ្នកគាំទ្រយ៉ាងសកម្ម។ នៅឆ្នាំ ១៩៥៩ គឺ ៦ ឆ្នាំក្រោយពេលបានទទួលឯករាជ្យពីបារាំង លោក សម សារី ដែលប្រឆាំង នឹង នយោបាយ បែរទៅរកលោកកុម្មុយនិស្ត របស់ សម្តេច នរោត្តម សីហនុ បានត្រូវ សម្តេច នរោត្តម សីហនុ រកលេសចោទថាជាជនក្បត់ជាតិ។ លោក សម សារី ត្រូវបង្ខំចិត្តភៀសខ្លួនទៅបរទេសសិន ប៉ុន្តែ សម្តេច សីហនុ នៅតែពុំព្រមដូរ នយោបាយដដែល។ លោក សម សារី ក៏ទៅចូលរួមតស៊ូជាមួយ សឺន ង៉ុក ថាញ់ ហើយត្រូវគេធ្វើឃាតនៅក្នុងកាពដ៏អាថ៌កំបាំង។ ចាប់តាំងពីឆ្នាំ ១៩៦០ មក សម្តេច នរោត្តម សីហនុ ដែលបានថ្វាយរាជ្យសម្បត្តិ ទៅព្រះរាជបិតា និង ព្រះមាតាជានិមិត្តរូប បានក្លាយទៅជា ប្រមុខរដ្ឋ នៃប្រទេសកម្ពុជា គឺរបបមួយថ្មីដែលមានលក្ខណៈពាក់កណ្តាលរបបរាជានិយមពាក់កណ្តាល របបសាធារណរដ្ឋ ។ ព្រះអង្គបានយកបញ្ញវន្តឆ្វេងនិយម មកឲ្យ ជួយគ្រប់គ្រងប្រទេស។ នៅពេលនោះ ស្រុកខ្មែរកាន់តែធ្លាក់ជ្រៅទៅៗ ក្នុងនយោបាយរបស់ លោកកុម្មុយនិស្ត ។ ព្រះអង្គ បានបើកផ្លូវឲ្យកងទ័ពពួកកុម្មុយនិស្ត វៀតណាមមកតាំងទីនៅលើទឹកដីខ្មែរ ។ មិនតែប៉ុណ្ណោះសោត ព្រះអង្គបានបើកផែ កំពង់ សោមឲ្យពួកកុម្មុយនិស្តប្រើប្រាស់ ដឹកជញ្ជូនសព្វាវុធ មកពីប្រទេសចិន ដើម្បីរៀបចំធ្វើការ





វាយប្រហារ ប្រទេសវៀតណាម ខាងត្បូង នៅពេល ចូលឆ្នាំចិន ឆ្នាំ ១៩៦៨ ថែមទៀត។ បន្ទាប់ពី អ្នកអភិរក្សស្តាំនិយមបានទទួលជោគជ័យនៅក្នុងការបោះឆ្នោតសភាឆ្នាំ ១៩៦៦ ឧត្តមសេនីយ៍ លន់ នល់ បានត្រូវតែងតាំងជារដ្ឋមន្ត្រី ទី ១ ហើយ វរជនដែលប្រឆាំង នឹង «នយោបាយអែបពួកកុម្មុយនិស្ត» របស់ សម្តេច នរោត្តម សីហនុ ដូចជា លោក ម៉ៅ សាយ និង លោក សឹម វ៉ា ជាដើម បានត្រូវតែងតាំងជា ឧបនាយករដ្ឋមន្ត្រី ។ នៅថ្ងៃ ១៤ សីហាឆ្នាំ ១៩៦៩ រដ្ឋាភិបាលរបស់ ឧត្តមសេនីយ៍ លន់ នល់ បានត្រូវតែងតាំងម្តងទៀត គឺ ក្រោយ រដ្ឋាភិបាល ប៉ែន នុត ដែលបានត្រូវតែងតាំងនៅថ្ងៃ ៣១ មករាឆ្នាំ ១៩៦៨ ហើយដែលបានត្រូវប្រសិទ្ធិនាមថា «រដ្ឋាភិបាលផ្សងសំណាងចុងក្រោយ» («Gouvernement de la dernière chance»)។ រដ្ឋាភិបាលទី ២ របស់ ឧត្តមសេនីយ៍នេះ ដែលបានត្រូវប្រសិទ្ធិនាមថា «រដ្ឋាភិបាលស្រោចស្រង់ជាតិ» («Gouvernement de sauvetage») មាន អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ជាឧបនាយករដ្ឋមន្ត្រី។ នៅថ្ងៃ ១៨ មិនា ឆ្នាំ ១៩៧០ សភាទាំងពីរ ដែលបានតែងតាំងព្រះអង្គ ជាប្រមុខរដ្ឋនៅឆ្នាំ ១៩៦០ បានសម្រេចទម្លាក់ព្រះអង្គ ចេញពីតួនាទីនេះវិញនៅពេលដែលព្រះអង្គភៀសខ្លួនទៅប្រទេសបារាំង។ លោក ចេង ហេង ប្រធានរដ្ឋសភា បានត្រូវតែងតាំងជាប្រមុខរដ្ឋជំនួស។ តាមសេចក្តីស្នើសុំ របស់ បញ្ញវន្ត និង យុវជន រដ្ឋាភិបាល លន់ នល់ បានប្រកាស របប សាធារណរដ្ឋ នៅថ្ងៃ ៩ តុលា ឆ្នាំ ១៩៧០ ដដែលនោះ។ នេះជាលើកដំបូងហើយ ដែលរបបរាជានិយម ដែលមានមក ជាង ១ ពាន់ ឆ្នាំ មកហើយ បានត្រូវរំលំចោល។

របប «សាធារណរដ្ឋខ្មែរ» មានរយៈពេលតែ ៥ ឆ្នាំប៉ុណ្ណោះ ព្រោះនៅពេលដែល សភាទាំងពីរទម្លាក់ សម្តេច នរោត្តម សីហនុ ចេញពីមុខនាទីប្រមុខរដ្ឋ សម្តេច នរោត្តម សីហនុ បានហៅឲ្យកងទ័ពយួនកុម្មុយនិស្ត គឺពួកវៀតមិញ និង ពួកវៀតកុងវាយរំលំរបបសាធារណរដ្ឋខ្មែរ។ ពេលធ្លាក់ពីអំណាចសម្តេច នរោត្តម សីហនុ ដែលបានចូលទៅរួបរួមជាមួយខ្មែរក្រហម បានឆ្មៀតឲ្យទីក្រុងហាណូយ និង ទីក្រុងប៉េកាំង

ប្រើម្តងទៀត។ ពួកយួន និង ចិនកុម្មុយនិស្តនៅពេលនោះ រង់ចាំតែការអំពាវនាវនោះ ប៉ុណ្ណោះ ដើម្បីវាយរំលំ របបសាធារណរដ្ឋខ្មែរ ដឹកនាំដោយ ឧត្តមសេនីយ៍ លន់ នល់ និង អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ គាំទ្រ ដោយ សហរដ្ឋ អាមេរិក។ ពួកកុម្មុយនិស្ត ទាំងចិន ទាំងវៀតណាម ភូតកុហក់ សម្តេច នរោត្តម សីហនុ ថា នឹង យកអំណាចមក ឲ្យ សីហនុ វិញ ។ ទំព័រ ប្រវត្តិសាស្ត្រ បានបញ្ជាក់យ៉ាងប្រត្យក្សថា នៅ ពេលក្រោយ មកទៀត ទាំងរបបខ្មែរក្រហម ប៉ុល ពត (ដែលមានចិនជាបង្អែក) ទាំងរបបខ្មែរក្រហម ហេង សំរិន ដែលមាន វៀតណាមកុម្មុយនិស្ត ជាមេកើយ) ពុំ បានប្រគល់អំណាចមក សីហនុ វិញឡើយ។ ក្រោយការរលំរលាយ នៃ របប សាធារណរដ្ឋខ្មែរ ស្រុកខ្មែរ បាន វិលមករក សម័យមុនឆ្នាំ ១៨៦៣ វិញ ប៉ុន្តែ កិច្ចព្រមព្រៀង សន្តិភាពទីក្រុងប៉ារីស៍ ឆ្នាំ ១៩៩១ បានខំប្រឹងប្រែង ផ្តល់ទៅឲ្យកម្ពុជា នូវ ការធាគ្រប់បែបយ៉ាង ដើម្បី ឲ្យអ្នកដឹក នាំខ្មែរក្រោយៗ មកទៀត មានលទ្ធភាព ការពារខ្លួន ហើយដឹកនាំប្រទេស ទៅតាមលទ្ធិ ប្រជាធិបតេយ្យ ដោយមាន ការគោរពសិទ្ធិមនុស្ស ជា មូលដ្ឋាន ។ ប៉ុន្តែ អ្នកដែលបាន ចុះហត្ថលេខា ទៅលើ កិច្ចព្រមព្រៀង សន្តិភាពនេះ ពុំបានអនុវត្តន៍ កិច្ចព្រមព្រៀងនោះ ឡើយ។ សាជាថ្មីទៀត អ្នកនយោបាយខ្មែរ គិតជាអាទិ៍ភាពពីទួនាទីរបស់គេរៀងៗ ខ្លួន។ អ្នកដែលធ្លាប់ដឹកនាំស្រុកខ្មែរ ពីពេលមុនៗ ក្រោមឱវាទ របស់ប្រទេសចិន និងប្រទេស យួនពុំព្រម អនុវត្តគោលការណ៍ ប្រជាធិបតេយ្យឡើយ។ លោក ហ៊ុន សែន ដែលបាន ត្រូវវៀតណាមដាក់ឲ្យកាន់អំណាច  មិនព្រមទទួលស្គាល់លទ្ធផលនៃការបោះឆ្នោតដែល បានផ្តល់ ជ័យជំនះទៅឲ្យ គណបក្សរាជានិយមឡើយ។ រីឯ ព្រះមហាក្សត្រខ្មែរវិញ ព្រះ អង្គចង់ធ្វើ ការបង្រួបបង្រួមជាតិ ដោយ ផ្ទាល់ព្រះអង្គ ហើយ នៅក្នុងន័យនេះ ចង់ឲ្យ ព្រះអង្គម្ចាស់ម្ចាស់រណឫទ្ធិ រួបរួម ជាមួយលោក ហ៊ុន សែន ទោះបី ខុសគោលការណ៍ កិច្ចព្រមព្រៀងទាំងស្រុងក្តី ។ ការពិត គឺព្រះអង្គចង់ឲ្យ ពួកអតីតកុម្មុយនិស្តខ្មែរ ឈ្នះ ពួកអ្នកប្រជាធិបតេយ្យខ្មែរ ដែលមាន និន្នាការ បស្ចិមប្រទេសនិយម តែប៉ុណ្ណោះ។ រី ឯ ការសម្រុះសម្រួល គឺលោក ហ៊ុន សែន និង ព្រះអង្គម្ចាស់រណឫទ្ធិ ឡើងធ្វើជា នាយក





រដ្ឋមន្ត្រី ទាំងពីរនាក់ តែម្តង ។ បន្ទាប់ ពីរដ្ឋប្រហារ នៅ ខែកក្កដា ឆ្នាំ ១៩៩៧ អតីតគ ណបក្សកុម្មុយនិស្តខ្មែរ ដែលបានត្រូវប្រទេសវៀតណាម ដាក់ឲ្យកាន់អំណាច នៅស្រុក ខ្មែរ នៅឆ្នាំ ១៩៧៩ បានឡើង មកកាន់ អំណាច ដូចកាល ពីមុន ដដែលវិញ។ តាំងពី ពេលនោះមក ស្រុកខ្មែរ វិវត្ត ឆ្ពោះ ទៅរក របនាសម្ព័ន្ធ ភូមិសាស្ត្រ-នយោបាយមួយ ដូចកាលពីជំនាន់ ដែលបារាំង ចង់តាំងមូលដ្ឋាន របស់គេ នៅក្នុងភូមិភាគនោះ ពោល គឺ សហភាពបារាំង (les trois Etats de l’Union française) ដែល មិនយូរ មិនឆាប់ នឹង ក្លាយទៅជា សហព័ន្ធឥណ្ឌូចិន (Fédération indochinoise)។ ប៉ុន្តែ ការប្រទាញ ប្រទង់ ជាមួយចិន អាចប្រែក្លាយ តំបន់ទាំងមូល ឲ្យទៅជាលានប្រយុទ្ធមួយ ដែលមួយ ចំណែក មានចិន ហើយ មួយចំណែកទៀត មានយួន និង អ្នកដែលផ្តល់បង្អែកទៅ ឲ្យយួន ។ ផ្លូវមួយទៀត គឺ ផ្លូវដែលមាន លក្ខណៈប្រហាក់ប្រហែល នឹង ប្រទេស មីយ៉ាន់ម៉ា ឬ ភូមា ដែលអាចនាំទៅរក វាសនា ដូចប្រទេស ទីបេ៊ (Tibet) ដូច្នេះ ដែរ។ ប៉ុន្តែ វាសនា មួយទៀត គឺ ការវិលទៅរក ការអនុវត្តន៍ កិច្ចព្រមព្រៀង សន្តិភាព ទីក្រុងប៉ារីស៍ ឆ្នាំ ១៩៩១ វិញ ប្រសិនណាជា មានសភាពការណ៍ថ្មី មួយទៀត នៅក្នុង ពិភពលោក។

# តេជានុភាព និង ការចុះដុនដាប នៃ ចក្រភពខ្មែរ

## Grandeur et décadence de l’Empire khmer



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

# ជំពូក ១

## មុនសម័យអាណាព្យាបាលបារាំង

## Avant la présence française

នៅដើមសតវត្សរ៍ ទី ៩ ស្តេចខ្មែរ ជ័យវរ្ម័ន ទី ២ ចាប់ផ្តើមបើកសកករាជ នៃ លទ្ធិទេវរាជ ។ នៅសម័យនោះ ខ្មែរគោរពបូជាព្រះរូបសិវលិង្គ ដែលជាអវតារមួយ នៃ ព្រះសិវ។ សិវលិង្គ ជានិមិត្តរូប នៃ ការលូតលាស់ និង និម្មិតកម្ម ដ៏ ខ្លាំងក្លា។ ចំពោះរាជាណាចក្រខ្មែរកាលជំនាន់នោះ ព្រះសិវ បានត្រូវគេចាត់ទុកជា «ស្តេចភ្នំ» (នគរភ្នំ ដែលចិនហៅថា ហ្វូណន់)។ នៅប្រទេសឥណ្ឌា ក៏ដូចជានៅ ឥណ្ឌូចិន លិង្គ ជា និមិត្តរូប នៃ ព្រះសិវ ប៉ុន្តែ នៅក្នុង ទស្សនាទាន លទ្ធិព្រហ្មញ្ញសាសនា នៅស្រុក ខ្មែរ ព្រះសិវ គឺ ព្រះឥន្ទ្រ (Indra)។ នៅប្រទេសឥណ្ឌា ព្រះឥន្ទ្រ ជាស្តេច នៃ ទេវ ទាំង ៣៣ អង្គដែលគង់នៅតាមជំរាលភ្នំព្រះសុមេរុ ។ នៅក្នុងទស្សនាទានខ្មែរ អវតារ នៃ ព្រះសិវ ជួនកាលជាព្រះឥន្ទ្រ ជួនកាលជាព្រះវិស្ណុ ។ តាម រយៈរូបចម្លាក់នានា គឺ ព្រះហរិហរ (Hari-Hara) ដែលជា សំយោគ រវាង ព្រះសិវ និង ព្រះវិស្ណុ ។ នៅ សម័យនគរភ្នំ ឬ ហ្វូណន់ និង ចិនឡា (ពីសតវត្សរ៍ ទី ១ មកដល់សតវត្សរ៍ ទី ៧ ) គេបានបង្រួម ព្រះសិវ ព្រះវិស្ណុ និង ព្រះឥន្ទ្រ មកត្រឹមសំយោគរួមតែមួយប៉ុណ្ណោះ គឺ ព្រះហរិហរ ។ នៅប្រទេសកម្ពុជា អ្នកដែលគោរពបូជា ព្រះសិវ និង អ្នកដែល គោរពបូជាព្រះវិស្ណុ មានខ្សែរយៈជាហូរហែ របស់គេ រៀងៗខ្លួន តាំងពីដើមមក។ រីឯ ទេវបន្ទាប់បន្សំ ក្រៅពីព្រះឥន្ទ្រដែលគេតែងតែឃើញតាមបដិមា និង ក្បាច់ចម្លាក់ នៅ

*តាមវត្ត និងវិហារផ្សេងៗ មានជាអាទិ៍៖ ព្រះគនេស ព្រះស្កន្ទ ព្រះក្រឹស្នា ព្រះអគ្គី ព្រះសុរិយៈ ព្រះសោមៈ ប្រមទាំងទេវទាំង ៨ អង្គទៀតគឺ ៖ ទេវ អសុរា ទ្វារបាល អប្សរៈ គ្រុឌ មករៈ និង នាគ ។ នៅសម័យអង្គរ លទ្ធិប្រហ្មញ្ញសាសនា មាន លក្ខណៈជាទស្សនវិជ្ជា សាសនាមួយបែប ដែលចេញមកពីគម្ពីរវេទ។ រីឯទេវ ដែលគេគោរពបូជា ជា សំយោគ រវាងទេវបីអង្គ ដែលតំណាង សភាវបី គឺព្រះព្រហ្ម តំណាងគំនិត ព្រះសីវ តំណាង អ្នកកម្ទេចពិភពលោកផង អ្នកកសាងពិភពលោកផង* (Dieu destructeur et constructeur à la fois) *។ ចំណែកឯព្រះវិស្ណុ គឺ ជា អ្នកថែរក្សាពិភពលោក ប៉ុន្តែ ក៏ ជាអាទិទេពដែល នាំដំណើរ ពិភពលោកផងដែរ។*

*លទ្ធិពុទ្ធសាសនា ហិនយាន មានវត្តមាន នៅប្រទេសកម្ពុជា មុនការគោរព បូជាលទ្ធិព្រហ្មញ្ញសាសនាជាផ្លូវការទៅទៀតគឺ តាំងពីសតវត្សរ៍ទី ៣ មក ហើយថែមទាំងមានឥទ្ធិពលខ្លាំងនៅសតវត្សរ៍ ទី ៥ និង ទី ៦ ទៀតផង។ ប៉ុន្តែ ព្រះមហាវិរិយបណ្ឌិតោ ប៉ាងខាត់ (១៩១០-១៩៧៥) បានសរសេរថា បើតាមឯកសារប្រទេស សីឡង់ ពុទ្ធសាស នា បានមកដល់ស្រុកខ្មែរ តាំងពី ឆ្នាំ ៣០២ មុនគ្រឹស្តសករាជ ឯណោះ។ ប៉ុន្តែ ហ្សក សឺដេស យល់ឃើញថា មិនអាចមកដល់ មុនសតវត្សរ៍ ទី ៣ បានឡើយ។ ទោះជា យ៉ាងណាក្តី គេសង្កេតឃើញថា ចាប់តាំង ពីសតវត្សរ៍ ទី ១ មក ដល់សតវត្សរ៍ ទី ១៣ ស្តេចខ្មែរ ដែលគោរពបូជា ព្រះសីវ មានច្រើនជាងស្តេច ដែលគោរព បូជាពុទ្ធសាសនា ។ នៅ សម័យស្តេចជ័យវរ្ម័ន ទី ៧ (១១៨១-១២១៨) លទ្ធិពុទ្ធសាសនាមហាយាន មានឥទ្ធិពល ដ៏ខ្លាំង ព្រោះ ស្តេចខ្មែរអង្គនេះ ជាអ្នកកាន់លទ្ធិពុទ្ធសាសនាមហាយាន ហើយបានត្រូវគេចាត់ទុកថា ជា ព្រះពោធិសត្វទៀត ផង (លោកស្វរៈ) ។ ផ្ទុយពីពុទ្ធសាសនា ថេរវាទ ឬ បុរាណ ដែលចាត់ទុក ព្រះពុទ្ធថាជា ព្រះបរមគ្រូ លទ្ធិពុទ្ធ សាសនាមហាយាន ចាត់ទុកព្រះពុទ្ធ ជា ទេវ ដែលមក ជួយសង្គ្រោះ មនុស្សលោក ។ នៅ សម័យជ័យវរ្ម័ន ទី ៧ គេគ្រាន់តែប្តូរ ពីសីវលិង្គ (ព្រហ្មញ្ញសាសនា) មក លោកកេស្វរប៉ុណ្ណោះ ហើយរក្សាលទ្ធិទេវរាជ ឬ «កម្រាតេងអញ» ក្រោយមក*



*សុបិន និង ការពិត ភាគ ១*- Rêves et réalités –Tome 1

*«កម្រាតេងជគតតរាជ») ដែលមានន័យថា«មហាក្សត្រម្ចាស់ នៃ ចក្រវាឡ) (ចក្រវាទិន) ដូចមុនដដែល»។ លទ្ធិពុទ្ធសាសនាហិនយាន ដែលបានចេញរូបរាង សា ជាថ្មីទៀត នៅសម័យ ស្តេចឥន្ទ្រាវរ្ម័នទី ៣ (ស្រី-ឥន្ទ្រវរ្ម័ន ១២៩៥-១៣០៨) ចាប់ផ្តើម មានឥទ្ធិពលខ្លាំង នៅស្រុកខ្មែរ ចាប់តាំងពីឆ្នាំ ១៤៣២ មក គឺ នៅសតវត្សរ៍ ទី ១៥ ។ គឺ ចាប់ពីពេលនោះមកហើយ ដែលលទ្ធិពុទ្ធនិយម ថេរវាទនេះ បានចាក់ឫសគល់ នៅក្នុងមជ្ឈដ្ឋានអ្នកចេះដឹងនានា នៃ សង្គមខ្មែរ ។ ប៉ុន្តែនេះ ក៏ពុំមានន័យថា ខ្មែរ នៅតាមស្រែចម្ការ និងអភិជន កាន់លទ្ធិនេះយ៉ាងប្រិតប្រៀង ដូចការអះអាងខ្លះ នោះទេ។ នៅតាមជនបទ ខ្មែរមានជំនឿ ទៅលើ អារក្ខ អ្នកតា ដើម្បីដោះស្រាយ បញ្ហាចំពោះមុខ ហើយ យកពុទ្ធសាសនា ជាបង្អែកផ្លូវចិត្ត និង ជា ចរិយាធម៌ ក្នុងសណ្តាប់ធ្នាប់រស់នៅប្រចាំថ្ងៃ ទោះជាមានបដិវាទកម្ម រវាង អបិយជំនឿទាំងនោះ និង ទ្រឹស្តីពុទ្ធនិយមក្តី (ផ្លូវដែលនាំទៅជា អរហន្ត) រីឯនៅក្នុងមជ្ឈដ្ឋានអភិជន លទ្ធិព្រហ្មនិយម នៅមានឥទ្ធិពលខ្លាំងដដែល នៅក្នុងនយោបាយ ក៏ដូចជានៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ ក្សត្រមាន ប្រពន្ធច្រើន ហើយការដណ្តើមរាជ្យគ្នា ក៏មាន មិនដាច់ដែរ ។ ជាការពិត ហើយដែលថា អ្នកកាន់លទ្ធិពុទ្ធសាសនា ជាពិសេស អ្នកចេះដឹង បានបញ្ចូលលទ្ធិនេះ ទៅក្នុងអក្សរសិល្ប៍ខ្មែរ ប៉ុន្តែ តួអង្គច្រើនតែជា ពោធិសត្វ (ឥទ្ធិពល នៃ ពុទ្ធសាសនា មហាយាន) ។ ក្រៅពី ឥទ្ធិពល នៃសាសនាទាំងនេះ និង ជំនឿអារក្ខអ្នកតាខ្មែរ ក៏មានទស្សនវិជ្ជា ផ្សេងទៀតដែរ គឺរឿងព្រេងបុរាណប្រជាប្រិយខ្មែរ ដែលគេនិយាយតៗគ្នាសម្រាប់ ដាស់តឿនកូនចៅឲ្យយល់ពី ធាតុដើមរបស់មនុស្សលោក។ រឿងនិទានទាំងនោះ ភាគច្រើន ពុំមានលក្ខណៈពុទ្ធនិយម ឬលើកតម្កើង វិរភាពអ្វីប៉ុន្មានទេ ដូចជារឿងអាឡេវ រឿង ធនជ័យ ជាដើម ដែលបានត្រូវប្រជាជនខ្មែរ គ្រប់ជាន់ថ្នាក់ និយមចូលចិត្ត ហើយដែលគេតែងតែយកមកធ្វើជាការសំអាងផ្សេងៗ ផងទៀត នៅ ក្នុងករណីខ្លះ នៃ ឆាកជីវិត។*

# ពី តេជានុភាព មកដល់ភាពចុះដុនដាប

តាំងពីយូរលង់មក មុនគ្រិស្តសករាជ នៅលើទឹកដីជ្រោយឥណ្ឌូចិន មាន ក្រុមប្រជាជនជាច្រើន ដែលរស់នៅ ជាកុលសម្ព័ន្ធ ហើយ ដែលឈ្លោះទាស់ទែងគ្នាជាញឹកញាប់ រហូតដល់ការកកើតឡើងនៃរដ្ឋមួយ ដែលគេហៅថា នគរគោកធ្លក ហើយដែលមានស្រីម្នាក់ឈ្មោះនាងនាគ (Nāga) ជាស្តេច។ ប្រជាជន នៃ នគរនោះ គឺជនជាតិខ្មែរ (ខេមរ) ។ ចាប់តាំង ពីដើម គ្រិស្តសករាជ មក មានពាណិជ្ជករ មកពី ប្រទេសឥណ្ឌា ប្រទេសជ្វា ម៉ាឡាយូ និង ពីប្រទេសចិន បានឆ្លងកាត់ នគរគោកធ្លកនេះ។ អ្នកមកពីប្រទេសឥណ្ឌា ឬពីកោះនៅទក្សិណទិសបាននាំលទ្ធិព្រហ្មញ្ញសាសនា ចូលមកពង្រឹកមូលដ្ឋាននៃរបៀបរស់នៅ របស់ ប្រជាជនគោកធ្លក ដែល ចិនហៅថា ហ៊្វូណន់។ គឺជាការចាប់ផ្តើមនៃ អភិក្រម ហិណ្ឌូនីយកម្ម គឺ ការយកសាសនា ប្រពៃណី និង ទេវកថាហិណ្ឌូ (hindouïsme) មកធ្វើអាណានិគមកិច្ច។ រីឯឈ្មួញចិន ក៏បាននាំ របៀបគ្រប់គ្រងសេដ្ឋកិច្ច មកផ្សំជាមួយអភិក្រម ហិណ្ឌូនិយកម្មនោះដែរ។ ទោះជាយ៉ាងនេះក្តី ក៏ភាសាមន-ខ្មែរ ដែលគេប្រើប្រាស់ តាំងពីដើមមកនៅឥណ្ឌូចិន នៅតែមានគង់វង់រហូតតរៀងមក ប៉ុន្តែពុំមានអក្សរទេ គឺគ្រាន់តែជាភាសាសម្រាប់និយាយប៉ុណ្ណោះ។ ក្រោយមក ភាសានេះ ក៏មានអក្សរ ហើយ លាយឡំ ជាមួយ ភាសាសំស្ក្រិត និង បាលី ។ រីឯពាក្យ ថា «ហ៊្វូណន់» គឺ ជាពាក្យដែលចិនហៅថា «ភ្នំ» តាមពាក្យ មន-ខ្មែរ។

ចលនាហិណ្ឌូនីយកម្ម បាននាំមក នូវប្រព័ន្ធគ្រប់គ្រងដែលមានវណ្ណៈបួន ព្រមទាំងពុទ្ធសាសនា មកជាមួយផងដែរ។ តាមការស្រាវជ្រាវ របស់លោក ហ្សក៍ សឺដេស ពុទ្ធសាសនាហិនយាន មាននៅហ៊្វូណន់ តាំងពីសតវត្សរ៍ ទី ៣ មក ។ នៅក្នុងសៀវភៅ *បណ្តារដ្ឋនៅឥណ្ឌូចិននិងនៅឥណ្ឌូណេស៊ី ដែលបានត្រូវគេធ្វើហិណ្ឌូនីយកម្ម (Les Etats hindouisés d’Indochine et d’Indonésie)* លោកហ្សក៍ សឺដេស សរសេរដូច្នេះថា «[…] ពុទ្ធសាសនា ហិនយាន ប្រើភាសាសំស្ក្រិត ដែលបានត្រូវគេបញ្ជាក់ថាមានមក តាំងពីសតវត្សរ៍ទី ៣ មានការរីកចម្រើនយ៉ាងខ្លាំង នៅសតវត្សរ៍ ទី ៥ និងទី ៦ នៅរាជ្យស្តេចជ័យវរ្ម័ន និង រុទ្រាវរ្ម័ន […] »។ នៅដើមសតវត្សរ៍ ទី ១ ក្នុងចំណោមពួកព្រហ្មណ៍ ចំនួន ៥ ម៉ឺនគ្រួសារដែលមកពីប្រទេសឥណ្ឌា ហើយ មកតាំងទីនៅប្រទេសជ្វា (Java) មាន មួយចំនួន ក៏បាន មកដល់ទឹកដី ហ៊្វូណន់ ឬ គោកធ្លកនេះដែរ។ ពួកគេបានបណ្តុះបណ្តាលអារ្យធម៌ នេះ បន្តិចម្តងៗនៅហ៊្វូណន់។ មិនតែប៉ុណ្ណោះ ជនជាតិឥណ្ឌាទេសន្តរប្រវេស៍ ទាំងនោះថែមទាំងរៀបការជាមួយស្រី នៃនគរហ៊្វូណន់ នោះថែមទៀត។ បើតាមឯកសារខ្លះ គឺនៅសម័យនោះដែរ ដែលព្រាហ្មណ៍ម្នាក់ ឈ្មោះ ហ្វឹនទៀន ឬ ហ៊ុហិនទៀន បាន យល់សប្តិឃើញអ្នកតាដែល ថែរក្សាគាត់ បានឲ្យ ធ្នូទិព្វមួយ មកគាត់ ហើយ តម្រូវឲ្យគាត់ចេញដំណើរតាមសំពៅឈ្មួញដ៏ធំមួយ។ លុះព្រឹកឡើង ហ្វឹនទៀន ក៏ដើរទៅវិហារ អ្នកតានោះ ហើយក៏ឃើញធ្នូមួយបញ្ឈរនៅគល់ដើមឈើនោះមែន។ ហ្វឹនទៀន ក៏ចេញ ដំណើរជាបន្ទាន់ តាមសំពៅឈ្មួញធំមួយ ដែលអ្នកតាថែរក្សានោះជាអ្នកនាំទិសឲ្យមកចុះ នៅត្រង់ដីគោកធ្លកនេះតែម្តង។ តាមរឿងនិទានចិន ព្រាហ្មណ៍នោះ ទំនង ជាមកពីប្រទេសឥណ្ឌា ក៏មិនដឹងមកពីជ្រោយម៉ាឡេស៊ី ឬ ក៏មកពី បណ្តាកោះនៅទក្សិណទិស ក៏មិនដឹង។ កាលនោះក្សត្រី លីវ យី ជាស្តេចនគរគោកធ្លក គឺហ៊្វូណន់ (ហ៊្វូណន់ ជាពាក្យដែលចិនហៅ «ភ្នំ» ពោលគឺ «នគរភ្នំ»)។ លីវ យី បានលើកទ័ពបម្រុងចូលទៅប្លន់សំពៅ របស់ ហ្វឹនទៀន ប៉ុន្តែ ត្រូវហ្វឹនទៀន ទាញធ្នូទិព្វ បាញ់ទូក របស់ លីវ យី ធ្លុះធ្លាយអស់ ជាហេតុធ្វើឲ្យ លីវ យី ភ័យយ៉ាងខ្លាំង ហើយសុំចុះចាញ់ ហ្វឹនទៀន។ ហ្វឹនទៀន ក៏រៀបការជាមួយក្សត្រី លីវ យី នេះតែម្តងទៅ។ ដោយឃើញក្សត្រី លីវ យី ស្រាតនទលគ្មានអ្វីបិទបាំងកាយ ហ្វឹនទៀន ក៏យកក្រណាត់មួយផ្ទាំងបត់ជាពីររួចចោះរន្ធមួយនៅកណ្តាល ហើយ យកទៅពាក់ គ្របដណ្តប់កាយក្សត្រី លីវ យី ។ ហ្វឹនទៀន ក៏ចាប់ផ្តើមគ្រប់គ្រងនគរ របស់ លីវ យី ហើយនាំប្រពៃណី នៃ ប្រទេស របស់គេ មកឲ្យប្រជាជន

គោកធ្លក ឬ នគរហ្វ៊ូណន់ ធ្វើតាមជាហូរហែ តរៀងមក ។ រឿងព្រេងនេះ ដែលមកពីប្រកពផ្សេងៗទៀត ក៏មានដំណើរប្រហាក់ប្រហែលគ្នាដែរ។ រឿងព្រេងឥណ្ឌា ដែលនិទាន ពីព្រះថោង នាងនាគ (នាគ = Nāga) នេះ ទំនង ជាលើកឡើងពីរឿងនេះដែរ ប៉ុន្តែពុំមានកាលបរិច្ឆេទ ច្បាស់លាស់ទេ ។ បើតាមការស្រាវជ្រាវ ដែលមានជាហូរ ហែមក គេកំណត់ថា ហ្វ៊ីនទៀន [កៅណ្ឌិនទី ១] មកដល់ ហ្វ៊ូណន់ ឬ គោកធ្លកនៅអំឡុងឆ្នាំ ៦៨ នៃ គ្រឹស្តសករាជ។ លោក ហ្សក់ សឺដេស (George Coedes, 1886 - †1969) យល់ឃើញថា រឿងនេះ មិនអាចកើតមាន ក្រោយសតវត្សរ៍ ទី ១ បានទេ ព្រោះនៅ សតវត្សរ៍ ទី ២ និង សតវត្សរ៍ក្រោយៗមកទៀត គេឃើញមានស្តេចផ្សេងទៀតដែល មានការបញ្ជាក់ច្បាស់ តាមសិលាចារឹក និង តាមឯកសារ របស់ ប្រវត្តិវិទូចិន ។ ទោះជាយ៉ាងណាក្តី អ្វីដែលច្បាស់ គឺថា ក្រោយ ហ្វ៊ីន ទៀន-លីវ យី មានរាជវង្ស ហ្វ៊ីនទៀន សោយរាជ្យ បន្តមកទៀត (អានទំព័រ ៤០៨-៤២១)។ ប្រវត្តិវិទូចិនម្នាក់ អះអាងថាស្តេច នៃ រាជវង្សហ្វ៊ីនទៀន មួយអង្គ ដែលគ្រងរាជ្យក្រោយមកទៀត គឺ ហ្វ៊ីន ប៉ាន់ ហ្វាង (Houen p’an houang) គ្រងរាជ្យ រហូតដល់អាយុ ៩០ ឆ្នាំ។ យោងទៅតាមសិលាចារឹក និង ឯកសារចិនផងដែរ ស្តេចនគរហ្វ៊ូណន់ ដែលគ្រងរាជ្យ រវាងឆ្នាំ ៤២០-៤៣៤ ក៏ ជារាជវង្សកៅណ្ឌិន្យ [ហ្វ៊ីនទៀន] ដែរ គឺ កៅណ្ឌិនទី ២។ នៅ ឆ្នាំ ៤៧៨ គឺ ពាក់កណ្តាល ទី ២ នៃ សតវត្សរ៍ទី ៥ មាន ស្តេចមួយអង្គទៀតឈ្មោះថា ជ័យវរ្ម័ន-កៅណ្ឌិន្យ ឡើងគ្រងរាជ្យរហូតដល់ឆ្នាំ ៥១៤។ រឿងឈ្មោះស្តេច «កៅណ្ឌិន្យ» នេះនាំឲ្យមានការបកស្រាយខុសៗគ្នា។ លោក អាត់ដេម៉ា ឡឺក្លែរ (កើតឆ្នាំ ១៨៥៣-†១៩១៧) បានធ្វើការកត់សម្គាល់នៅក្នុង កំណត់ហេតុ ទំព័រ ២៥ នៃ សៀវភៅ ប្រវត្តិសាស្ត្រ នៃ ប្រទេសកម្ពុជា (Histoire du Cambodge) របស់លោកដូច្នេះថា គេគួរឈប់និយាយទៀតថា ហ្វ៊ីនទៀន (ឬ ហ៊ូហិនទៀន) គឺ កៅណ្ឌិន្យ ព្រោះឯកសារ ចិន បានបញ្ជាក់យ៉ាងច្បាស់ថា កៅណ្ឌិន្យ គឺ ស្តេចជ័យវរ្ម័ន ហើយស្តេចជ័យវរ្ម័ននេះ ថែមទាំងបានយកសួយសារអាករ ទៅថ្វាយស្តេចចិន នៅឆ្នាំ



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

៤៨៣ ម្តង នៅឆ្នាំ ៥០៣ ម្តងទៀត។ ដូច្នេះឃើញថា ពី ហ្វ៊ីនទៀន មកកៅណ្ឌិន្យ គឺ ត្រូវឆ្លងកាត់ ៤ សតវត្សរ៍ ឯណោះ។ លោក អាត់ដេម៉ា ឡឺក្លែរ ដែលយល់ថា ហ្វ៊ីនទៀន ពុំមែនកៅណ្ឌិន្យ ហើយ កៅណ្ឌិន ចំពោះលោកគឺ ជ័យវរ្ម័ន-កៅណ្ឌិន្យ ក៏ បាននិយាយផងដែរថា ការសោកល្បងភ្ជាប់ឈ្មោះ ហ្វ៊ីនទៀនទៅ នឹង កៅណ្ឌិន្យ គ្រាន់តែជា ការសន្និដ្ឋាន របស់ ស្លេហ្កិល (Schlegel) និង ប៉ូល ប៉ែលលីយ៉ូ (Paul Pelliot) តែប៉ុណ្ណោះ បន្ទាប់មកទៀត លោកល្វី ហ្វ៊ីណូ (Louis Finot) ក៏ បានប្រើការសន្និដ្ឋាននេះដែរ។ អាត់ដេម៉ា ឡឺក្លែរ បានបញ្ជាក់ទៀតថាលោក ប៉ូល ប៉ែលលីយ៉ូ ក៏ ដឹងយ៉ាងច្បាស់ដែរថា មានការខុសគ្នា ជាច្រើនសតវត្សរ៍ ព្រោះលោក ក៏បាន និយាយ ពី ស្តេចដែលបានសោយរាជ្យក្រោយ ហ្វ៊ីន ទៀន-លីវយី នេះ ដែរ ដូចជា ម៉ាន់ ស៊ីចាន់ (Man-t’si-chan) ជាដើម។ ទោះជាយ៉ាងនេះក្តី ការស្រាវជ្រាវក្រោយៗ មកទៀត បាន កំណត់ថា ហ្វ៊ីនទៀន គឺ កៅណ្ឌិន្យទី ១ ហើយ នៅចន្លោះ ឆ្នាំ ៤២០ និង ៤៣៤ ស្តេចដែលសោយរាជ្យ នៅ ហ្វ៊ូណន់ គឺ កៅណ្ឌិន្យទី ២ ។ នៅឆ្នាំ ៤៧៨ មានស្តេចមួយអង្គ ព្រះនាម ជ័យវរ្ម័ន-កៅណ្ឌិន្យ គ្រងរាជ្យ ពីឆ្នាំ ៤៧៨ ដល់ឆ្នាំ ៥១៤។ ក្រោយ ជ័យវរ្ម័ន-កៅណ្ឌិន្យ មានស្តេច ២ អង្គទៀតដែលសោយរាជ្យបន្ត គឺ គុណវរ្ម័ន (៥១៤-៥១៤) ដែលជាបុត្ររបស់ ជ័យ វរ្ម័ន-កៅណ្ឌិន្យនេះ ជាមួយព្រះ មហាក្សត្រិយានីព្រះនាមកុលាព្រះភវត្តី ។ ប៉ុន្តែ គុណ វរ្ម័ន បានត្រូវ រុទ្រាវរ្ម័ន ដែលជាបុត្រមួយអង្គ ទៀតជាមួយប្រពន្ធម្នាក់ទៀត ធ្វើគុតដើម្បី ដណ្តើមរាជ្យ ។ រុទ្រាវរ្ម័ន គ្រងរាជ្យយ៉ាងតិចណាស់ក៏ពីឆ្នាំ ៥១៤ រហូតដល់ឆ្នាំ ៥៣៩ ដែរ (George Coedes) ឬក៏មកទល់ឆ្នាំ ៥៥០ តែម្តង បើតាមឯកសារផ្សេងទៀត។ ឆ្នាំ ៥៥០ នោះ ជា ឆ្នាំដែលសង្គ្រាម រវាង ហ្វ៊ូណន់ និង ចេន-ឡា បានចាប់ផ្តើម (៥៥០- ៦២៦) ។ គឺ ការបះបោរ ដែលភវវរ្ម័ន ទី ១ និង ចិត្រាសេនា បានបង្កើតឡើង ហើយដែលបាននាំទៅដល់ការបែកបាក់ នៃ នគរហ្វ៊ូណន់។ រុទ្រាវរ្ម័នជា ស្តេចនគរហ្វ៊ូណន់ ចុងក្រោយ បង្អស់ ព្រោះបន្ទាប់ពីនោះមក ហ្វ៊ូណន់ ត្រូវនគរ ចេន-ឡា គ្រប់គ្រង។ ភវវរ្ម័នទី ១ ត្រូវគេ ចាត់ទុកថា ជាស្តេច នៃ ប្រទេស

កម្ពុជា (គឺហ្វ៊ូណន់ និង ចេន-ឡា) [សម័យ បុរេអង្គរ] មុនគេបង្អស់។ ពីដើមសតវត្សរ៍ ទី ៨ ដល់ ដើមសត វត្សរ៍ ទី ៩ (៧០៦- ៨០២) ចេន-ឡា បែកចេញជា រាជាណាចក្រពីរ គឺ ចេន-ឡាទឹក និង ចេន-ឡាដី គោក ហើយពី ឆ្នាំ ៧៧៤ ដល់ឆ្នាំ ៨០២ បានត្រូវកងទ័ពជ្វា ចូលលុកលុយ ។

អស់រយៈពេល ៥ សតវត្សរ៍ ពី សតវត្សរ៍ ទី ១ មក ដល់ពាក់កណ្តាល សតវត្សរ៍ ទី ៦ ហ្វ៊ូណន់ ជាចក្រភពមួយ ដ៏មានមហិទ្ធិឫទ្ធិ ជាពិសេសនៅសតវត្សរ៍ ទី ៥ ក្រោមរាជ្យកៅណ្ឌិន្យទី ២ (៤២០-៤៣៤) និង ជ័យវរ្ម័ន-កៅណ្ឌិន្យ (១៤៧៨-១៥១៤) ដែលហិណ្ឌូនីយកម្ម បាននាំ ហ្វ៊ូណន់ មកដល់កម្រិតអារ្យធម៌មួយ ដ៏ខ្ពស់ ។ នៅសតវត្សរ ទី ៣ និង ទី ៤ នៃ គ្រឹស្តសករាជ នគរហ្វ៊ូណន់ បានទទួល ឥទ្ធិពល វប្បធម៌ ហិណ្ឌូនិយម (hindouisme) យ៉ាងក្រាស់ក្រែល រួចស្រេចទៅហើយដែរ ។ នៅដើមសតវត្សរ៍ ទី ៣ ចក្រភពហ្វ៊ូណន់ ឬ នគរភ្នំនេះ មានព្រំដែនខាងត្បូង រហូតទៅដល់ ផ្នែកខាងត្បូង នៃ ប្រទេស ម៉ាឡេស៊ី ហើយ ព្រំដែន ខាងលិច រហូតដល់ អៀរ៉ាវ៉ាឌី ពោលគឺ បច្ចុប្បន្ន មីយ៉ាន់ម៉ារ (ភូមា)។ ទីតាំងភូមិសាស្ត្រ របស់ ហ្វ៊ូណន់ គឺ ជ្រោយ ឥណ្ឌូចិន ផ្នែកកណ្តាល និងផ្នែកខាងត្បូង បានក្លាយទៅជាផ្លូវ មួយដ៏សំខាន់ សម្រាប់ពួកពាណិជ្ជករ ដែលធ្វើការដោះដូរ រវាង ប្រទេសចិន និងប្រទេសឥណ្ឌា។ ម្យ៉ាងទៀត បន្ទាប់ពីនគរ នៃ រាជវង្ស វូ (Wou) នៃ ប្រទេសចិនខាងត្បូងត្រូវរាជាណាចក្រ វ៉ី (Wei) ជាសត្រូវ បិទផ្លូវ មិនឲ្យធ្វើពាណិជ្ជកម្ម ជាមួយ បស្ចិមប្រទេស នគរហ្វ៊ូណន់ បានក្លាយជាផ្លូវសំខាន់មួយ ជាចាំបាច់។ ឯកសារចិន បានពិពណ៌នាថា ប្រជាជន នៃ នគរហ្វ៊ូណន់នេះ ដែលមានសម្បុរខ្មៅ និង សក់ក្រញាញ់ ជាប្រជាជនឆ្លាតណាស់ ។ បើ នគរជិតខាងណា មិនព្រមចុះចូល គឺ វាយយក នគរនោះតែម្តង ។ ប៉ុន្តែ នៅពាក់កណ្តាលសតវត្សរ៍ ទី ៦ នគរនោះ បានបាត់បង់តេជានុភាព របស់ខ្លួនវិញអស់ ។ ដូចយើងបានដឹង នៅខាងលើរួចមកហើយ កត្តាសំខាន់មួយ នៃ ការបែកបាក់នេះ គឺ ការដែលរុទ្រវរ្ម័ន បានធ្វើគុត គុណវរ្ម័ន ដែលជាព្រះទាយាទ។ នៅដើមសតវត្សរ៍ទី ៦





គឺ នៅឆ្នាំ ៥១៤ ក្រោយស្តេចជ័យវរ្ម័នចូលទីវង្គត ព្រះរាជបុត្រមួយអង្គ របស់ ជ័យវរ្ម័ន (រុទ្រវរ្ម័ន) ជាមួយប្រពន្ធចុងម្នាក់ បានសម្លាប់រាជទាយាទ ដើម្បីដណ្តើមរាជ្យ។ នៅពេលនោះ ញាតិវង្ស របស់ រាជទាយាទ មួយអង្គ គឺ ភវវរ្ម័ន បានរត់ទៅជ្រកកោន នៅ នគរ ចេន-ឡា ដែលកាលនោះ ជា នគរចំណុះ នឹង ហ្វ៊ូណន់ ។ ភវវរ្ម័នបានរៀបការជាមួយ ព្រះអង្គម្ចាស់ក្សត្រីមួយអង្គ ដែលជារាជទាយាទ នៃ នគរនោះ ហើយតាមរយៈអាពាហ៍ពិពាហ៍នោះ បានក្លាយទៅជាស្តេច នៃ នគរ ចេន-ឡា តែម្តង នៅពេលក្រោយមកទៀត ។ ដោយមាន ជំនួយពី ចិត្រាសេនា ជាព្រះអនុជ (មហិន្ទ្រវរ្ម័ន) / ភវវរ្ម័ន បានវាយយកនគរ ហ្វ៊ូណន់ បាន នៅឆ្នាំ ៥៥០ ហើយបង្រួបបង្រួមនគរ ទាំងពីរនេះដែលបានទទួល ឥទ្ធិពលអារិយធម៌ ហិណ្ឌូដូចគ្នាជានគរតែមួយ។ ប៉ុន្តែ គឺនៅពេលនោះដែរដែលសង្គ្រាម រវាង ហ្វ៊ូណន់ និងចេន-ឡា បានចាប់ផ្តើម។ គឺជាសម័យដែលប្រទេសកម្ពុជាចាប់បដិសន្ធិឡើង។ សម័យនោះ បានត្រូវប្រវត្តិវិទូកំណត់ ហៅថា សម័យបុរេអង្គរ (époque préangkorienne) ប៉ុន្តែក្រោយមកខ្មែរ បានចុះឥទ្ធិពលទៅវិញ ហើយធ្លាក់ ទៅក្នុង អានាធិបតេយ្យមួយ ដ៏ប្របូកប្របល់ ជាហេតុធ្វើឲ្យស្តេច នៃ នគរជ្វា ឆ្លៀតឱកាសដាក់ ការត្រួតត្រា របស់គេ មកលើស្រុកខ្មែរ ។ បន្ទាប់ពីបានដេញចាម ដែលចូលមកលុកលុយ ព្រះបាទជ័យវរ្ម័នទី ២ ឡើងគ្រងរាជ្យនៅឆ្នាំ ៨០២ ដែលជាការចាប់ផ្តើម នៃ សម័យអង្គរ។ ចិន-ឡា បានត្រូវគេពិពណ៌នាថា ជាប្រភពដើម នៃ ពូជសាសន៍ របស់ ខ្មែរ និង ការកកើត នៃប្រទេសកម្ពុជា ដោយយកឈ្មោះព្រាហ្មណ៍ «កម្ពុ» ធ្វើជារឿងសម្រាប់និទាន ពីការកកើតឡើង (mythe fondateur) នៃអារ្យធម៌ ខ្មែរជំនាន់ក្រោយៗ មកទៀត ហើយដែលជាប្រភព នៃស្តេច«វរ្ម័ន» ទាំងអស់ ផងទៀត ។ ស្តេច នគរចេន-ឡា កាលសម័យចំណុះ នឹងហ្វ៊ូណន់ គឺស្រុតវរ្ម័ន និង ស្រេស្ឋាវរ្ម័ន។ រីឯក្សត្រីកម្ពុជរាជាលក្ស្មី ជាបុត្រី របស់ស្រេស្ឋាវរ្ម័ន។ ប៉ុន្តែ ស្តេចក្រោយៗមកទៀត ចាប់ពីភវវរ្ម័នទី ១ មក តែងតែភ្ជាប់ពូជអម្បូរ ទៅនឹងត្រកូលស្តេចនគហ្វ៊ូណន់ ឬ ស្តេច នគរភ្នំទាំងអស់ ។ ជ័យវរ្ម័នទី ២ ដែលជាអ្នកបើកសករាជ

សម័យអង្គរ ក៏តាំងខ្លួនព្រះអង្គថាជា ស្តេចនគរភ្នំដែរ។ ពីឆ្នាំ ៨០២ មក អរិយធម៌ខ្មែរ បានចាប់ផ្តើមមាន សន្ទុះមួយថ្មីទៀត ហើយ មានការរីកចម្រើន យ៉ាងខ្លាំង ។ ចាប់តាំងពី ពាក់កណ្តាលសតវត្សរ៍ ទី ៦ មក ស្រុកខ្មែរមានឈ្មោះថា «ប្រទេសកម្ពុជា» (ប្រែមកថា សុវណ្ណភូមិ) ។

# រឿងព្រេង ទាក់ទង នឹង ការកកើត នៃ រាជាណាចក្រខ្មែរ

## Les mythes fondateurs du Royaume khmer

មានរឿងព្រេង ជាច្រើនដែលលើកឡើង ពីការកកើត នៃ រាជាណាចក្រខ្មែរ។ បើប្រៀបធៀបមក ឯកសារប្រវត្តិសាស្ត្រ ដែលមានតម្លៃ ខ្ពស់ (សិលាចារឹកវត្តអារាម កំណត់ហេតុ ប្រវត្តិ ប្រទេសចិន ឥណ្ឌា និង ប្រទេសផ្សេងៗទៀត) គេសង្កេតឃើញថា រឿងព្រេងទាំងនោះ មិនមែនសុទ្ធតែជា ការប្រឌិតសុទ្ធសាធនោះទេ ។ មានកន្លែងខ្លះ អ្នកលើកឡើង នូវ រឿង ទាំងនោះ ប្រើជំនោរអារម្មណ៍ ហួសហេតុ ប៉ុន្តែ មានកន្លែងខ្លះ មានលក្ខណៈ ស្រដៀង នឹង ព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រខ្លះៗ ដែរ ទោះបី គ្មានការកំណត់កាលបរិច្ឆេទត្រឹមត្រូវក្តី ។ រឿងនិទានខ្លះ ស្រដៀង នឹង រឿងដែលគេនិទាននៅប្រទេសឥណ្ឌា ឬ នៅ ម៉ាឡេស៊ី។ ម៉្យាងទៀត ចក្រភពហ្វូណន់នេះ ធំណាស់ ហើយ នៅនគរណា នៅក្នុងចក្រភពនោះ ក៏គេនិទានរឿងទាំងនេះដែរ។ ការយល់ដឹង អំពី ប្រវត្តិសាស្ត្រខ្មែរ បានត្រូវគេចងភ្ជាប់ទៅ ជាមួយរឿងទាំងនោះ ជាហេតុធ្វើឲ្យមានការបកស្រាយមិនដូចគ្នាទាំងស្រុងទេ។ ម៉្យាងទៀត គេមិនដឹងថាចាប់ផ្តើមពិតប្រាកដពីសម័យណាផង។ ជួនកាល មានការច្រឡំ ជំនាន់ស្តេច ដែលមាននាមត្រកូល តែមួយ។ ប៉ុន្តែ អ្វីដែលសំខាន់ គឺការដាក់រឿងទាំងនោះឲ្យត្រូវ នឹងកាលបរិច្ឆេទ នៃ ព្រឹត្តិការណ៍ប្រវត្តិ



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

សាស្ត្រ ពិតៗ ដែលគេបានដឹងច្បាស់ តាមប្រភពឯកសារ ដែល គេសន្មតថា មានលក្ខណៈត្រឹមត្រូវ ច្បាស់លាស់ ។

**រឿង «ព្រះថោងនាងនាគ»** : គឺ ជារឿងដែលមាន ប្រភពមកពី ឥណ្ឌា ហើយដែលទាក់ទង នឹង ការកកើតឡើង នៃ ស្រុកខ្មែរ (ស្រុករបស់ជនជាតិខ្មែរ) មុនគ្រិស្តសករាជ។ តាមសេចក្តីដំណាល នៅនគរមួយឈ្មោះ ឥន្ទ្របទ ស្ថិតនៅប្រទេសឥណ្ឌាភាគខាងជើង (Indraprasta ) [បើតាមការស្រាវជ្រាវ ទីកន្លែង នៃ នគរនោះ គឺ ស្ថិតនៅចម្ងាយជាង ២០ គ. ម. ពី ទីក្រុង ញូ ដេល្ហី ] មានស្តេចមួយអង្គ មានកូនប្រុស ៥ នាក់ ។ ស្តេចនោះ បានប្រគល់ខេត្តបួនទៅឲ្យកូន ៤ នាក់គ្រប់គ្រង ប៉ុន្តែ ទុកកូន ទី ៥ ដែលជាកូនពៅ ឲ្យនៅជិតព្រះអង្គ ។ ពេលដែលកូនពៅនោះ ធំដឹងក្តីហើយ ស្តេចនោះក៏ដាក់រាជ្យ ប្រគល់ទៅឲ្យកូននោះ។ កូនបង បីនាក់ ក្នុងចំណោម កូនទាំងបួន ដែលបានខេត្តម្នាក់មួយគ្រប់គ្រង មិនយល់ទាស់ទេ តែកូន ទី ៤ គឺ ព្រះថោង មិនព្រម ជាដាច់ខាត ព្រោះមិនយល់ស្របនឹង ការលើកប្អូនឲ្យគ្រប់គ្រងបងៗដូច្នេះ។ ព្រះថោង មិនព្រមទៅចូលរួមក្នុងពិធី អភិសេកស្តេចជាប្អូនពៅនោះទេ។ ស្តេចជាព្រះបិតា ក៏គិតឲ្យកូនទាំង ៣ នាក់ទៀតទៅចាប់ព្រះថោង ដែលហ៊ាន បះបោរប្រឆាំង នឹង ព្រះអង្គ ប៉ុន្តែក្រោយមកដោយព្រះថោង មានប្រជានុរាស្ត្រ ស្រឡាញ់ចូលចិត្ត ព្រះអង្គ ក៏ សម្រេច បំបរបង់ព្រះថោង ទៅវិញ ដោយចាត់ទុក ព្រះរាជបុត្រនោះ ថា ជាកូន «កាត់សាសនា»។ ព្រះថោង ក៏ធ្វើដំណើរ ទៅដល់ គោកធ្លក ដែលកាលនោះ មានជនជាតិចាម ចង់ត្រួតត្រាជនជាតិខ្មែរ។ ព្រះថោង មិនត្រូវ នឹង ចាមទេ ហើយ ក៏ជួយដេញចាម ចេញពី នគរគោកធ្លក ។ ពួកចាមក៏នាំគ្នារត់ទៅចម្ប៉ាសាក់ (ទឹកដីឡាវ សព្វថ្ងៃនេះ) ហើយ ព្រះថោងក៏សោយរាជ្យនៅលើទឹកដី ដែលចាមបោះបង់ចោលតែម្តងទៅ។ ព្រះថោង បានរៀបការជាមួយនាងនាគ ហើយគ្រប់គ្រង ទាំងទឹកដីដែល ព្រះអង្គ វាយយកបាន ពីចាមវិញ ទាំងទឹកដី របស់ ឪពុកនាងនាគ។

**រឿងព្រះគ្រូ«កម្ពុ» (Kambu) :** រឿងដែលគេតំណាល តៗគ្នានេះ ហើយដែលគេដឹង តាមសិលាចារឹក បានត្រូវគេយកមកពន្យល់ ពីដើមកំណើត នៃ ប្រទេសកម្ពុជា រហូតមកដល់ សព្វថ្ងៃនេះ ។ «កម្ពុ» ( kambu < Kambujā < Kampuchéa ) ជាឈ្មោះ របស់ព្រះគ្រូម្នាក់ដែលជាដើមកំណើត នៃរាជាណាចក្រខ្មែរ។ ស្តេចខ្មែរ «វរ្ម័ន» ទាំងអស់ សុទ្ធតែជាកូនចៅ របស់ ឥសី្ស «កម្ពុ» ដែលទំនងជាសាវ័ក នៃព្រះសីវ។ ពាក្យ «កម្ពុ» នេះ ខ្មែរយើងបកប្រែមកថា «មាស»។ ទឹកដីស្រុកខ្មែរ ជាទឹកដីមាស (សុវណ្ណភូមិ) ហើយក៏ជា ទឹកដី របស់ ព្រះសីវដែរ ។ រីឯ ផ្ទៃរឿង មានដូចតទៅ ៖ កាលពីព្រេងនាយ ទឹកដីខ្មែរ ជាវាលមួយ ដ៏ស្ងួតហួតហែង គ្មានស៊ឹងបឹងបួអ្វីទាំងអស់ សូម្បីតែទឹកភ្លៀង ក៏គ្មានធ្លាក់មួយដំណក់ដែរ។ ភ្នំទាំងឡាយខ្លោចរោលអស់គ្មានសល់ ដោយកំដៅព្រះអាទិត្យ ហើយ បង្ហាញ នូវទិដ្ឋភាពគួរឲ្យខ្លាច។ សត្វព្រៃ មាន គោ ជា អាទិ៍ គ្រហឹមគួរឲ្យស្ដុត សត្វកង្កែប ដែលមានខ្លួនធំមហិមា ហាក់បីដូចជា ត្រៀមខ្លួនវាជាស្រេច ដើម្បីហក់មក ។ ថ្ងៃមួយ មាន អ្នកដំណើរម្នាក់ មកពីឆ្ងាយ មានឈ្មោះថា «កម្ពុស្វយម្ភូ» [6] បានដើរមកដល់ នគរ នោះ ។ តាំងពីប្រពន្ធ របស់ គាត់ឈ្មោះ មេរ (Mera) ដែលព្រះសីវ បានប្រទានឲ្យ ស្លាប់បាត់ទៅ កម្ពុស្វយម្ភូ ដើរតែលតោល គ្មានគោលដៅ អ្វីទាំងអស់ រង់ចាំតែ សេចក្ដីស្លាប់ប៉ុណ្ណោះ។ ពេលដើររកជម្រក គាត់បាន ឃើញគុហាមួយ រួចក៏ចូលទៅក្នុង គុហានោះ ហើយ ឃើញសុទ្ធតែ ពស់ដែលសម្លក់គាត់ឥតដាក់ភ្នែក។ ដៃកាន់ដាវ កម្ពុដើរឆ្ពោះទៅពស់ដែលធំជាងគេ ។ គាត់ភ្ញាក់ក្រញាង ហើយថយក្រោយមួយជំហាន កាលបើឮ ពស់នោះ និយាយរកគាត់ ។ នាគនោះសួរថា «តើអ្នកមកពីណា បានជាចូលមកក្នុង គុហា របស់ ពួកនាគយើង ដែលជាម្ចាស់ នៃ នគរនេះ» ។ កម្ពុឆ្លើយថា «គាត់ឈ្មោះកម្ពុស្វយម្ភូ ស្តេចពួកអារ្យ ។ ប្រពន្ធគាត់ ឈ្មោះ មេរ ស្រ្តីល្អ លើសគេ ដែល ព្រះសីវ បានប្រទានឲ្យ ។ ប្រពន្ធ

[6] ស្វយម្ភូ មានន័យថា ដែលកើតមកឯងៗ គ្មានអ្នកណាបង្កើត។





គាត់បានបែកឋាន បាត់ទៅហើយៗ គាត់បោះបង់ស្រុកកំណើតគាត់ចោល ដើម្បីមកស្លាប់ នៅដីវាល ដ៏ ល្ងឹងល្ងើយនេះ ដែលគាត់ខំស្វែងរក។ ឥឡូវនេះ គាត់បានរកឃើញហើយ ដូច្នេះអ្នកអាចសម្លាប់ខ្ញុំបានហើយ»។ នាគនិយាយតបវិញថា «អ្នកបាននិយាយពី ព្រះសីវ អម្បាញ់មិញនេះ។ ព្រះសីវ ជាស្តេច របស់ ខ្ញុំ ហើយខ្ញុំ ជាស្តេចនាគ។ អ្នកមានសេចក្ដីក្លាហានណាស់ បើអ៊ីចឹង អ្នកនៅជាមួយយើងទៅ ហើយបំភ្លេចទុក្ខព្រួយទាំងអម្បាលម៉ាន នោះចោលទៅ» ។ កម្ពុស្វយម្ភូ រស់នៅ ជាមួយនាគអស់ជាច្រើនឆ្នាំ។ នាគ ដែលជាស្តេច នៃ ព្រះគង្គា និង កម្ពុ រាប់អានគ្នាទៅវិញទៅមក។ នៅទីបំផុត កម្ពុ ឈប់នឹកប្រពន្ធគាត់ទៀតហើយក៏រៀបការជាមួយស្តេចនាគនោះទៅ។ នាងនាគ ស្រឡាញ់មនុស្សណាស់ ហើយចេះសិល្បសាស្ត្រអាចកាឡាខ្លួន ជាមនុស្សក៏បាន។ កម្ពុ តែងតែនិយាយពីស្រុកកំណើតរបស់គាត់ប្រាប់នាងនាគ ។ គាត់និយាយពីសម្ផស្ស នៃ អតីតមាតុភូមិ របស់គាត់ អំពី របៀបធ្វើឲ្យស្រូវ និង ដើមឈើដុះហើយចេញជាផ្លែ ព្រមទាំង ការដាំរុក្ខជាតិ នានាទៀតដែលមានប្រយោជន៍។ គាត់ក៏និយាយប្រាប់ផងដែរ ពីជ្រលងភ្នំ ដែលប្រកបទៅដោយ រុក្ខជាតិស្រស់បំព្រង ព្រមទាំងព្រៃព្រឹក្សា។ ស្តេចនាគនិយាយ ថា ការធ្វើឲ្យមានទឹកភ្លៀងធ្លាក់មក និងការធ្វើឲ្យមានជីវិតរស់ស្រស់បំព្រង ជាការងាយស្រួលទេ។ លុះនិយាយហើយ ស្តេចនាគ ក៏សូត្រពាក្យ ពី-បីម៉ាត់ ហើយមួយស្របក់ បន្ទាប់មក ស្រាប់តែទឹកភ្លៀងធ្លាក់មកលើដី និង សិលា ។ ដើមឈើ តូច ធំ ក៏ ដុះឡើង ព្រោងព្រាត ចេញពីដី ។ នៅពេលនោះ ព្រះសីវ ក៏ចេញមក ។ លុះឃើញដូច្នេះ ស្តេចនាគ ក៏រត់ម្ដងទៅខាងនេះ ម្ដងទៅខាងនោះ ។ មុននឹងត្រឡប់ទៅវិញ ព្រះសីវ និយាយទៅកាន់ កម្ពុស្វយម្ភូ ថា គឺ ជាអម្បូរពូជសាសន៍ មនុស្សថ្មី ដែលនឹងបង្កើត រាជាណាចក្រ នៃ ប្រទេស កម្ពុជា គឺប្រទេស នៃ កូនចៅ របស់ កម្ពុ ។ តាមការស្រាវជ្រាវ ផ្នែកបុរាណវត្ថុវិទ្យា របស់លោក ប៊ែរណា ហ្វ៊ីលីព ក្រូល្យេ (*Indochine carrefour des arts*, Bernard Philippe Groslier, Editions Albin Michel, 1961, p. 84 ) ថេន-ឡា បាន

ត្រូវបាក់បែកអស់ទៅវិញ នៅចុងសតវត្សរ៍ទី ៨ ប៉ុន្តែ ដោយ ទឹកដី ចេន-ឡា នេះ ស្ថិតនៅខាងក្នុងដីគោក ហើយ ដោយទំនាក់ទំនង ជាមួយប្រទេស នានា តាមសមុទ្រ បានត្រូវកាត់ផ្តាច់ ចេន-ឡាក៏ចាប់ផ្តើមដោះស្រាយបញ្ហា ដោយខ្លួនឯងផ្ទាល់។ គឺ តាំង ពីពេលនោះមកហើយ ដែលប្រទេសនេះចាប់ផ្តើមមានទេពកោសល្យ ខាងការកសាង ប្រព័ន្ធចែកចាយទឹក នៅសម័យអង្គរដូចជា បារាយណ៍ ជាដើម។ ហេតុដូច្នេះហើយ បានជា អារ្យធម៌ខ្មែរ សម័យ អង្គរ មានកម្រិត ខ្ពស់បំផុត ហើយ ជាស្នាដៃ របស់ ស្ថាបត្យករ និងវិស្វករខ្មែរផងទៀត។ របនាបទប្រាសាទទាំងឡាយ ដែលយើងឃើញ ជា របនាបទ ខ្មែរសុទ្ធសាធ គ្មានចម្លង ពីក្រៅមកទេ។

**ហ្វឺនទៀន-លីវ យី :** *រឿង ហ្វឺនទៀន* (Houen - t' ien) ដែលបានរៀបការនឹង ស្តេចស្រីខ្មែរ លីវ យី នៃ នគរគោកធ្លក ដូចដែលខ្ញុំបានលើកឡើង នៅខាងលើ មាន ប្រភព មកពីឯកសារចិន ប៉ុន្តែ ពុំបានបញ្ជាក់ថាជាជ្វាព្រាហ្មណ៍ ដូចឯកសារផ្សេង ទៀតទេ គឺគ្រាន់តែនិយាយពីបុរសម្នាក់ កាន់លទ្ធិព្រហ្មញ្ញសាសនា មកពី សមុទ្រខាង ត្បូង ពោលគឺ អាចមកពីស្រុកជ្វា (Java) ឬក៏មកពីប្រទេសឥណ្ឌា។ បើតាមអត់ដេម៉ា ឡឺក្លែរ គឺ អាចជាជនជាតិឥណ្ឌានៅក្នុងចំណោមគ្រួសារចំនួន ២ ម៉ឺននាក់ ដែលមកពី ឥណ្ឌា មកតាំងទី នៅស្រុកជ្វានៅដើមគ្រឹស្តសករាជ។ រឿងព្រេងខ្មែរបាននិទានថា ជន ទាំងនោះ មានសម្បុរខ្មៅ ហើយ អ្នកទាំងនោះ ថែមទាំងបានអះអាង ថា ពួកគេ មកពី «ពារាណសី» (Bénarès) ទៀតផង។ អត់ដេម៉ាឡឺក្លែរ បានសរសេរថា បើតាមឯក សារចិន ក្រោយ ហ្វឺនទៀន ឬហ៊ូហិនទៀន មានស្តេច ៦ អង្គទៀត ដែលសោយរាជ្យ បន្តបន្ទាប់គ្នា អស់រយៈពេល ពីរសតវត្សរ៍ នៅហ្វ៊ូណន់។ ឯកសារនោះ បានបញ្ជាក់ ថា ស្តេចត្រកូលហ្វឺនទៀន មួយអង្គព្រះនាម ហ្វឺន ប៉ាន់ ហ្វាង (Houen p'an Houang ) សោយរាជ្យរហូតដល់ អាយុ ៩០ ឆ្នាំ។ លុះ ហ្វឺនទៀន ទទួលមរណភាព ទៅ កូនរបស់ ហ្វឺនទៀន ឈ្មោះ ហ្វាន់ បានត្រូវជ្រើសតាំងឲ្យសោយរាជ្យបន្ត។ ស្តេច អង្គនេះ បាន ប្រគល់ អំណាចទាំងអស់ ទៅឲ្យមេទ័ពឈ្មោះ ហ្វាន់ ឆេ ម៉ាន់ ឬ ហ្វាន់ ម៉ាន់។ ស្តេច





ហ្វាន់ សោយរាជ្យ បានតែ បីឆ្នាំ ប៉ុណ្ណោះ ហើយ ក៏សុគតបាត់ទៅ ។ មេទ័ព ហ្វាន់ ឆេ ម៉ាន់ ត្រូវគេតែងតាំងឲ្យឡើងសោយរាជ្យនៅ ហ្វ៊ូណន់បន្តមកទៀត។ ការឡើង សោយ រាជ្យ របស់ ហ្វាន់ ឆេ ម៉ាន់ ពុំបានធ្វើឲ្យ ស្តេច នៃ នគរ ជិតខាង សប្បាយចិត្តទេ ជា ពិសេសបណ្តាក្សត្រ នៃ នគរ រណប ព្រោះ ហ្វាន់ ឆេ ម៉ាន់ នេះ ជាស្តេចចូលចិត្ត ធ្វើសង្គ្រាម គឺ តែងតែវាយយក ប្រទេសជិតខាង ធ្វើជារណប របស់ ខ្លួន។ ហ្វាន់ ឆេ ម៉ាន់ ធ្វើសំពៅធំៗ ជាច្រើន ហើយបានវាយយក ១០ នគរ ធ្វើ ជារណប នៅក្នុងនោះ នគរមួយចំនួន នៅជ្រោយម៉ាឡាក់កា។ ថ្ងៃមួយ ដោយធ្លាក់ឈឺ ហ្វាន់ ឆេ ម៉ាន ក៏ឲ្យកូនប្រុសច្បងឈ្មោះ គីន ចេង ដឹកទ័ពទៅច្បាំង ហើយ ទុកតែ ទ័ព ចំនួន ២ ពាន់ នាក់ ឲ្យក្មួយ ឈ្មោះ ចាន់ (កូនប្រុសច្បង របស់ បងស្រីគាត់) សម្រាប់ការពារគាត់។ ប៉ុន្តែ ចាន់ បែរជាប្រើទ័ព ២ ពាន់ នាក់នោះ ដើម្បីដណ្តើម អំណាចពី ហ្វាន់ ឆេ ម៉ាន់ ជាឪពុកមាទៅវិញ។ ចាន់ ក្លាយទៅជាស្តេច នគរហ្វ៊ូណន់ ហើយឲ្យគេ ទៅសម្លាប់ រាជ ទាយាទ គីន ចេង ផងទៀត។ បើតាមឯកសារចិនដដែល-ដែលអាត់ដេម៉ា ឡឺក្លែរ បាន លើកឡើងនោះ - ការដណ្តើមរាជ្យនេះ កើតមានឡើងនៅឆ្នាំ ២៣០ នៃគ. ស. ។ ហ្វាន់ ឆេ ម៉ាន់ មានកូនប្រុស ម្នាក់ទៀត ប៉ុន្តែ កាល នោះ នៅតូចនៅឡើយ។ លុះបានអាយុ ២០ ឆ្នាំ កូននោះ ក៏ប្រមូលទ័ព ទៅវាយស្តេច ចាន់ ដែលបានជ្រែករាជ្យ និង សម្លាប់ ឪពុកខ្លួន។ លុះសម្លាប់ស្តេច ចាន់ បានហើយ មេទ័ពស្តេច ចាន់ ឈ្មោះ ស៊ីយុន ក៏ សម្លាប់កូន របស់ ហ្វាន់ ឆេ ម៉ាន់ បានវិញ រួចក៏ឡើងសោយរាជ្យខ្លួនឯងតែម្តង។ រឿងនេះ - តាមឯកសារចិនដដែល - កើតឡើងនៅឆ្នាំ ២៥០ នៃ គ. ស.។ បើតាម រឿង ដែលខ្មែរបានលើកឡើង ក៏ឃើញ ថាមិនខុសគ្នា ប៉ុន្មានដែរ ។ បើតាមការចារទុក របស់ ខ្មែរក្រោយហ្វឺនទៀន មានស្តេច ៦ អង្គ សោយរាជ្យបន្ត ។ ឯកសារ របស់ អាត់ដេម៉ា ឡឺក្លែរ សរសេរ ឈ្មោះស្តេច ទាំងនោះ ជាអក្សរបារាំងតាមសូរសៀខ្មែរគឺ ៖

*youyouvormonti*[7], *Kavéalareach-Kaumar, Sauryavormonti, Tornîntrévor-monti, Adityvormonti, Assāchey* ។ ជ័យវរ្ម័ន សោយរាជ្យ ៧០ ឆ្នាំ កវាលរាជ-កុមារ ២០ ឆ្នាំ សុរិយាវរ្ម័ន ២០ ឆ្នាំ ធនិន្ទ្រវរ្ម័ន ២០ ឆ្នាំ អាទិត្យវរ្ម័ន ២០ ឆ្នាំ អស្សាជ័យ ១១ ឆ្នាំ ។ បូករួមមកទាំងអស់គឺ ១៦១ ឆ្នាំ (១ សតវត្សរ៍ កន្លះជាង ឬ ២ សតវត្សរ៍ បើគិតពីរយៈពេលខ្វះ ដែលគ្មានស្តេចសោយរាជ្យ) ។ ស្តេចទាំងនេះ មាននាមប្រហាក់ប្រហែលគ្នា នឹង ស្តេច «វរ្ម័ន» នៅ សម័យ អង្គរ ដែរ ពោលគឺឈ្មោះ ជាភាសា សំស្រ្កិត ដែលបញ្ជាក់ពី វត្តមាន នៃ ព្រហ្មញ្ញសាសនា។

## សម័យអង្គរ

នៅឆ្នាំ ៨០២ ស្តេចខ្មែរជ័យវរ្ម័ន ទី ២ ដែល មានប្រភពមកពីរាជវង្ស នៃ ចេន -ឡាទឹក បានក្លាយទៅជា ស្តេចនគរភ្នំ ដូចស្តេចនានា នៃហ៊្វូណន់ ដូច្នេះដែរ។ ជ័យ វរ្ម័នទី ២ បានចាប់ផ្តើមកសាង រាជាណាចក្រមួយ ដ៏ធំ គឺ រាជាណាចក្រអង្គរ ហើយ បាននាំមក នូវ ប្រព័ន្ធគ្រប់គ្រងមួយ ដែលគេហៅថា ទេវរាជ (Devarāja) ដែលមានសីវលិង្គ ជា និមិត្តរូប នៅភ្នំគូលែន ។ ជ័យវរ្ម័នទី ២ ឲ្យគេគោរពបូជា ព្រះអង្គជាចក្រវាទិន (monarque universel) ។ បើតាមលទ្ធិទេវរាជនេះ ស្តេចជា ម្ចាស់ នៃពពួកទេវទាំងអស់ (le roi des dieux) ។ ស្តេចអង្គនេះ បានរំដោះប្រទេស ពីការត្រួតត្រារបស់ជ្វា ហើយ បានបង្រួបបង្រួមជាតិ ឡើងវិញ ។ រាជធានី កាលសម័យ នោះ គឺ

[7] បើតាមអាត់ដេម៉ា ឡឺក្លែរ ជដែលគឺ *YouYou* < yāyā < Jaja = ជ័យ + *vormonti* ពោលគឺ វរ្ម័ន [*varman*] ។ *yoyovormonti* = *Jayavarman* (ជ័យវរ្ម័ន) ។ ឈ្មោះ ស្តេច ៥ អង្គទៀត អាចសរសេរ ៖ កវាលរាជ-កុមារ, សុរិយាវរ្ម័ន, ធនិន្ទ្រវរ្ម័ន, អាទិត្យវរ្ម័ន, អស្សាជ័យ ។





ហរិហរល័យ នៅរលួស (សៀមរាប)។ ស្តេចខ្មែរ សម័យអង្គរក្រោយៗមកទៀត បានរិតចំពង្រឹង ឯកភាពខ្មែរ ហើយកសាងប្រាសាទជាច្រើន។ ឥន្រ្ទវរ្ម័ន (៨៧៧-៨៨៩) បានសាងប្រាសាទព្រះគោ ប្រាសាទបាគង ឧទ្ទិសចំពោះទេវរាជ។ យសោវរ្ម័នទី ១ (៨៨៩-៩១០) សាងសង់ បុរីអង្គរ ប្រាសាទបាខែង ប្រាសាទភ្នំបូក ហើយរៀបចំប្រព័ន្ធ ទឹកសម្រាប់ជំរុញកសិកម្ម ដោយ ជីកបារាយណ៍ លលៃ ដែលមានបណ្តោយប្រវែង ៧ គ.ម. និង ទទឹង ១, ៨៨ គ.ម.។ ជ័យវរ្ម័ន ទី ៤ (៩២៨- ៩៤១) ដែលជាប្អូនថ្លៃ យសោវរ័នទី ១ [ជ័យវរ្ម័ន ទី ៤ បានរៀបការ ជាមួយព្រះអង្គ ម្ចាស់ក្សត្រីជ័យទេវី ដែលជាប្អូនស្រី យសោវរ្ម័ន ទី ១] បានបង្កើតរាជធានីថ្មី នៅ កោះកែ ចម្ងាយ ១០០ គ. ម. ពីអង្គរ។ រាជេន្ទ្រវរ្ម័ន ទី ២ (៩៤៤-៩៦៨) ដែលបាន រៀបការជាមួយ ព្រះអង្គម្ចាស់ក្សត្រីមហេន្ទ្រទេវី ជាព្រះធីតុបតី (កូនប្រសា) របស់យសោវរ្ម័នទី ១ បានសង់ប្រាសាទមេបូន ប្រាសាទប្រែរូប, (ខាងត្បូង មេបូន) ប្រាសាទភិមានអាកាស ដែលស្ថិតនៅខាងត្បូងប្រាសាទព្រះប៉ាលីឡៃ ហើយ ព្រាហ្មណ៍ម្នាក់ព្រះនាម យជ្ញវរាហៈ ទីប្រឹក្សា របស់ស្តេច រាជេន្ទ្រវរ្ម័ន (៩៤៤-៩៦៨) បានសង់ ប្រាសាទបន្ទាយស្រី នៅក្បែរនោះដែរ ។ រីឯ បត់ជុំ ដែលស្ថិតនៅ ខាងត្បូង ស្រះស្រង់ ជាប្រាសាទ ដែលនាម៉ឺនម្នាក់ឈ្មោះ កវិន្ទ្ររិមត្ថណៈ បានសាងសង់ ។ សោយរាជ្យ បានមួយឆ្នាំ រាជេន្ទ្រវរ្ម័នត្រូវប្រឈមមុខនឹង សង្រ្គាមជាមួយចាម នៃ ប្រទេសចម្ប៉ា នៅឆ្នាំ ៩៤៥។ នៅឆ្នាំ ៩៦៨ បុត្រ របស់ រាជេន្ទ្រវរ្ម័ន ឡើងគ្រងរាជ្យក្រោមឈ្មោះថា ជ័យវរ្ម័នទី ៥។ តាមការពិត គឺពួកព្រាហ្មណ៍ ដែលធ្លាប់បានធ្វើការជាមួយ រាជេន្ទ្រវរ្ម័ន ជាបិតាទេ ដែលគ្រប់គ្រងប្រទេស ។ ជ័យវរ្ម័ន ទី ៥ សុគត នៅឆ្នាំ ១០០១ ដោយ គ្មានរាជទាយាទ សម្រាប់ស្នងរាជ្យ ។ រាជវង្សទី ២ នៃ ក្សត្រ សម័យអង្គរ ចាប់ផ្តើម ពីដើមសតវត្សរ៍ ទី ១១ គឺ ពីឆ្នាំ ១០០២ ដល់ឆ្នាំ ១០៨០។ សុរិយាវរ្ម័នទី ១ ដែលជារាជ្យកន្ត (usurpateur) បានប្រយុទ្ធដណ្តើមរាជ្យ អស់រយៈពេល ៩ ឆ្នាំ ទើបបានឡើងគ្រងរាជ្យ (ឆ្នាំ ១០០២ រហូត ដល់ឆ្នាំ ១០៥០) ។ បុត្រទាំងពីរ របស់ ស្តេច អង្គនេះ បានរក្សារាជ្យ រហូតដល់ឆ្នាំ ១០៨០។ សុរិយាវរ្ម័ន

ទី១ និងបុត្រទាំងពីរ របស់ ព្រះអង្គ បានសាងសង់ ប្រាសាទភ្នំជីសូរ សាងសង់បង្ហើយ ប្រាសាទភិមានអាកាស កសាងមួយផ្នែក នៃប្រាសាទព្រះវិហារ (ប្រាសាទនេះ បានត្រូវសាងសង់ក្រោមរាជ្យស្តេច ៧ អង្គ គឺ ពី យសោវរ្ម័នទី ១ [៨៨៩-៩១០] ដល់សុរិយាវរ្ម័ន ទី ២ [១១១៣- ១១៥០]) ។ ប្រាសាទ ព្រះខ័ន កំពង់ស្វាយ ក៏ជា ស្នាដៃ របស់ សុរិយាវរ្ម័នទី ១ ដែរ។ ឧទ័យទិត្យវរ្ម័នទី ២ កូន ទី ១ របស់ សុរិយាវរ្ម័នទី ១ បានចាប់ផ្តើមជីកបារាយណ៍ មួយដ៏ធំ គឺ បារាយណ៍ ទឹកថ្លា (Baray occidental) ស្ថិតនៅខាងលិច អង្គរធំ ព្រមទាំងកសាង ប្រាសាទបាភួន ផងដែរ ។ បន្ទាប់ពីកូនចុងក្រោយ របស់ សុរិយាវរ្ម័នទី ១ សុគតទៅ រាជាណាចក្រខ្មែរ ធ្លាក់ទៅក្នុង កលិយុគមួយដ៏ធំ។ រាជ្យកន្តមួយអង្គទៀត គឺ ជ័យវរ្ម័នទី ៦ បានបង្កើតរាជវង្សមួយទៀត ដែលមានរហូតដល់ឆ្នាំ ១១៦០។ ស្តេចអង្គនេះ បានកសាងប្រាសាទភិមៃ (បច្ចុប្បន្ននៅក្នុងដីសៀម) កសាងបន្តប្រាសាទព្រះវិហារ ប្រាសាទវត្តភូ ។ សុរិយាវរ្ម័ន ទី ២ ឡើងគ្រងរាជ្យ បន្ទាប់ពីបានធ្វើគុត ស្តេចជាឪពុកធំ របស់ព្រះអង្គ ហើយដែលជា ព្រះអនុជ របស់ ស្តេចជ័យវរ្ម័នទី ៦ ។ សុរិយាវរ្ម័ន ទី ២ ដែលគ្រងរាជ្យ ពីឆ្នាំ ១១១២ / ១១១៣ រហូតដល់ឆ្នាំ ១១៥០/៥២ ជាក្សត្រខ្មែរមួយអង្គ ដ៏ ខ្លាំងពូកែ ហើយ ដែលស្តេចក្រុងចិន ចាត់ទុកថា ជាដៃគូម្នាក់ដ៏ធំ។ គឺស្តេចអង្គនេះហើយ ដែលបានសាងសង់ប្រាសាទ អង្គរវត្ត បឹងមាលា ព្រមទាំងបានសាងសង់បង្ហើយ ប្រាសាទវត្តភូ ប្រាសាទព្រះវិហារ។ នៅឆ្នាំ ១១២៣ សុរិយាវរ្ម័ន ទី ២ បានវាយ ប្រទេស ហ្វៃ វៀត (ប្រទេសវៀតណាម) ដែលទើបនឹង បានឯករាជ្យពីចិននៅឆ្នាំ ៩៣៩។ ការវាយលុកនេះ ដែលត្រូវបញ្ចប់ នៅឆ្នាំ ១១៣៦ ពុំបានលទ្ធផលអ្វីទេ ។ នៅឆ្នាំ ១១៤៤ សុរិយាវរ្ម័ន បានវាយយក ប្រទេស ចម្ប៉ា ហើយដាក់ ហរិទេវ ជាប្អូនថ្លៃឲ្យគ្រប់គ្រង នគរចម្ប៉ា មួយឆ្នាំក្រោយមក ប៉ុន្តែ ហរិទេវ បានត្រូវ ក្សត្រចាមម្នាក់ ឈ្មោះ ជ័យហរិវរ្ម័នទី ១ ធ្វើគុតនៅឆ្នាំ ១១៤៧ ។ លុះ សុរិយាវរ្ម័នទី ២ សុគតទៅ ធរនិន្ទ្រវរ្ម័នទី ១ ឡើងគ្រងរាជ្យ (១១៥០-១១៦០)។ ស្តេចបន្ទាប់ គឺ យសោវរ្ម័ន ទី ២ (១១៦០-១១៦៦) ។





នៅឆ្នាំ ១១៦៦ រាជ្យកន្តម្នាក់ទៀតដែលជានាម៉ឺនស្តេច បានធ្វើគុតស្តេចយសោវរ្ម័ន ទី ២ ហើយក្រោមឈ្មោះថា ត្រីភូវនាទិត្យវរ្ម័ន គ្រប់គ្រងប្រទេស រហូតដល់ពេលចាមចូលលុកលុយអង្គរ នៅឆ្នាំ ១១៧៧។

នៅដើមគ្រឹស្តសករាជ ជនជាតិយួន បានចាកចេញពីស្រុកចិនភាគខាងត្បូងហើយមកតាំងទី នៅ ទន្លេក្រហម គឺតំបន់ បាក់បូ ឬ តុងកឹង ហើយក្រុមខ្លះទៀត ទៅរស់នៅតាមភ្នំក្នុងតំបន់ តុងកឹង និង ម្តុំខាងជើងប្រទេសឡាវ (ជនជាតិម៉េវ និង មួង)។ រវាងសតវត្សរ៍ ទី ១០ និង ទី ១១ ប្រជាជន ដែលរស់នៅខាងត្បូងប្រទេសចិន រួមបញ្ចូលទាំង ប្រជាជន យូណាន់ ផងដែរ បានចាប់ផ្តើម នាំគ្នាចុះមកតាំងទី នៅតំបន់ខាងត្បូងបន្តិចម្តងៗ តាមជ្រលងទន្លេមេណាម (ជនជាតិថៃ) ទន្លេមេកុង (ជនជាតិឡាវ) ទន្លេសាលូអង់ និង ទន្លេអៀរ៉ាវ៉ាឌី (ភូមា)។ ជនជាតិថៃខ្លះ មករស់នៅ ក្នុងចក្រភពខ្មែរតែម្តង ។ នៅដើមសតវត្សរ៍ ទី ១៣ ដោយត្រូវ ពួកម៉ុងហ្គោល ក្រោមការដឹកនាំរបស់យង់ ឃីសខាន់ (Gengis Khan) វាយប្រហារ កុលសម្ព័ន្ធមួយ នៃ ជនជាតិថៃដែលរស់នៅផ្នែកនិរតីប្រទេសចិនក្នុងខេត្តយូណាន់ នាំគ្នាមករស់នៅម្តុំ ទន្លេមេណាម។ នៅឆ្នាំ ១២៨៣ ជនជាតិថៃ ដែលបានមកតាំងទីនៅត្រង់ ទន្លេមេណាម ភាគកណ្តាល បានបង្កើតរដ្ឋមួយឈ្មោះ សុខោទ័យ។ កុលសម្ព័ន្ធថៃ នានាទៀត ក៏នាំគ្នាបង្កើតរដ្ឋផ្សេងទៀត ៖ អាយុធ្យា (នៅខាងត្បូង ទន្លេមេណាម) និង ឡាន់ណា (នៅខាងជើង)។ រដ្ឋទាំងនេះ ទាស់ទែងគ្នា ឥតស្រាកស្រាន្ត ។ នៅទីបំផុត អាយុធ្យា បានយកឈ្នះទៅលើសុខោទ័យនៅឆ្នាំ ១៣៥០ ហើយបង្កើតរដ្ឋមួយ ឈ្មោះប្រទេសសៀម ។ រដ្ឋសុខោទ័យរលាយបាត់ ទៅវិញនៅឆ្នាំ ១៤៣៨ ហើយ ប្រទេសសៀមនេះ ចូលមកលុកលុយ អង្គរនៅឆ្នាំបន្ទាប់ៗ មុននឹងលើកឡើងអំពី ប្រជាជនទាំងនេះ យើងវិលមកនិយាយពី ក្សត្រខ្មែរសម័យអង្គរ បន្តមកទៀត។

នៅឆ្នាំ ១១៧៧ កងទ័ពចាម នៃ ប្រទេសចម្ប៉ា បានវាយលុកបុរីអង្គរ។ កងទ័ពជើងទឹកចាម ដឹកនាំដោយជនជាតិចិនម្នាក់ បានឡើងដោយសម្ងាត់ មកដល់អង្គរ តាម

ទន្លេសាប ហើយវាយយកទីក្រុងខ្មែរបាន បន្ទាប់ពីមានការទប់ទល់ បង្គូរឈាមមួយ ដ៏សម្បើមអស្ចារ្យ។ ពួកនេះសម្លាប់ស្តេចខ្មែរ ត្រីភូវនាទិត្យវរ្ម័ន បាន ហើយក៏តាំងទី នៅអង្គរ អស់រយៈ ពេល ៤ ឆ្នាំ គឺ រហូត ដល់ ឆ្នាំ ១១៨១ ។ គឺនៅឆ្នាំនោះហើយ ដែលជ័យវរ្ម័ន ទី ៧ នាំទ័ពជើងទឹកមកវាយ ដេញចាមខ្ចាត់ខ្ចាយអស់ ។ ជ័យវរ្ម័ន ទី ៧ ជាស្តេចខ្មែរមួយអង្គ ដ៏ខ្លាំងក្លា នៅក្នុងប្រវត្តិសាស្ត្រខ្មែរ។ ព្រះអង្គ បានរំដោះប្រទេស ពី«សមុទ្រទុក្ខ» ព្រោះតែការឈ្លានពាន ពីសំណាក់ នគរចម្ប៉ានេះ។ ព្រះអង្គ មិនត្រឹមតែជាអ្នកដឹកនាំកងទ័ព ដ៏ពូកែ ប៉ុណ្ណោះទេ តែ ក៏ ជាអ្នកកសាងប្រទេស ប្រកបដោយចិត្តមនុស្សធម៌ទៀតផង។ មិនយូរប៉ុន្មាន ព្រះអង្គវាយយក នគរចម្ប៉ាវិញ ហើយគ្រប់គ្រងនគរនោះអស់រយៈ ពេល ២០ ឆ្នាំ។ នៅក្នុងរាជ្យស្តេចខ្មែរអង្គនេះ ទឹកដីប្រទេសកម្ពុជា គ្របដណ្តប់នៅទិសពាយព្យ រហូត ដល់ ទន្លេ ម៉េណាម (ចៅប្រាយ៉ា) ទិសអាគ្នេយ៍ ដីសណ្ត ទន្លេមេកុង ទាំងអស់ រួមបញ្ចូលទាំង ទឹកដី កូសាំងស៊ីន (វៀតណាមខាងត្បូង) ផងទៀត ព្រមទាំងទិសឦសាន ផ្នែកកណ្តាល និង ខាងក្រោមប្រទេសឡាវ។ ជនជាតិថៃ ដែលកាលនោះ បានត្រូវខ្មែរចាត់ទុកជា អនារ្យជន បានជ្រៀតចូលមកតាំងទី នៅតាមជាយទឹកដី នៃ ចក្រភពខ្មែរ ហើយ ឆ្លៀតឱកាសខ្មែរចុះទន់ខ្សោយបាន កសាងរដ្ឋអំណាចរបស់គេយ៉ាងខ្លាំង រួចវាយលុក ចក្រភពខ្មែរតែម្តង។ ជនជាតិខ្មែរ នៅប្រទេសសៀម មាន ចំនួនច្រើនលាននាក់ ដូចខ្មែរក្រោមដែលរស់នៅ កូសាំងស៊ីន អតីតដីខ្មែរ ព្រៃនគរ ដែល ប្រទេសវៀតណាម បានច្រឹបយក នៅឆ្នាំ ១៦៩៨ ដូច្នេះដែរ។ ជ័យវរ្ម័នទី ៧ ជាអ្នកកាន់ពុទ្ធសាសនាមហាយាន។ ព្រះអង្គ បានកសាងអង្គរធំ ប្រាសាទបាយ័ន ប្រាសាទព្រះខ័ន តាព្រហ្ម នាគព័ន្ធ ។ ស្តេចបន្ទាប់មកទៀត គឺឥន្ទ្រវរ្ម័នទី ២ ព្រះរាជ បុត្រ របស់ ជ័យវរ្ម័នទី ៧ ជាមួយ មហាក្សត្រី ជ័យរាជទេវី សោយរាជ្យ ពីឆ្នាំ ១២១៨ ដល់ឆ្នាំ ១២៤៣ ។ ប៉ុន្តែ បន្ទាប់ពីស្តេចអង្គនេះ មានស្តេចមួយអង្គ ដែលពុំជាប់ខ្សែរាជវង្សជ័យវរ្ម័នទី ៧ បានឡើងមកគ្រងរាជ្យ ក្រោមព្រះនាមជាជ័យវរ្ម័ន ទី ៨ (១២៤៣-១២៩៥) ។ នៅក្នុងរាជ្យជ័យវរ្ម័ន ទី ៨ នេះ លទ្ធិព្រហ្មញ្ញ





សាសនា វិលមកវិញ។ គឺជាប្រតិកម្មប្រឆាំង និង លទ្ធិពុទ្ធសាសនា ដែលស្តេច ជ័យវរ្ម័នទី ៧ គោរពបូជា (ពុទ្ធសាសនាមហាយាន)។ ឥន្ទ្រវរ្ម័នទី ៣ (ស្រី-ឥន្ទ្រវរ្ម័ន) ក៏បាននាំ លទ្ធិពុទ្ធសាសនាហិនយាន មកផងទៀត។ ឥន្ទ្រវរ្ម័នទ ី៣ (ឬស្រី ឥន្ទ្រវរ្ម័ន) ដែលបានរៀបការ ជាមួយក្សត្រី ឥន្ទ្រភូបេស្វរសុតា បុត្រី របស់ជ័យវរ្ម័នទី ៨ ជាអ្នកកាន់លទ្ធិពុទ្ធសាសនា ហិនយាន ។ អ្នកទាំងពីរ បានលួចយកព្រះខ័នមាស ហើយចាប់បង្ខំឲ្យ ស្តេចជ័យវរ្ម័នទី ៨ ដាក់រាជ្យ ព្រមទាំងយកកូនស្តេចអង្គនេះ ដែលជា រាជទាយាទ ទៅឃុំឃាំងធ្វើទារុណកម្ម កាត់អវយវ ដើម្បីដណ្តើមរាជ្យសម្បត្តិ ។ ជ័យវរ្ម័នទី ៨ ជាអ្នកគោរពបូជា ព្រះសីវយ៉ាងខ្លាំងក្លា ។ ព្រះអង្គឲ្យគេកំទេចបដិមាព្រះពុទ្ធ នៅបន្ទាយក្តី នៅប្រាសាទ តាព្រហ្ម ប្រាសាទ បាយ័ន ប្រាសាទព្រះខ័ន ។ ចលនាប្រឆាំងនឹងលទ្ធិពុទ្ធសាសនា កាលនោះមានលក្ខណៈ ដ៏ ពុះកញ្ជ្រោល ។ ឥន្ទ្រវរ្ម័នទី ៣ ឡើងគ្រងរាជ្យពីឆ្នាំ ១២៩៥ ដល់ឆ្នាំ ១៣០៨។ គឺស្តេច អង្គនេះហើយ ដែលបានទទួល អ្នកការទូតចិន ជូ តា ក្វាន់ នៅវាំងឆ្នាំ ១២៩៦/ ១២៩៧។ ក្រោយស្តេចស្រី-ឥន្ទ្រវរ្ម័ននេះ (១២៩៥-១៣០៨) មានស្តេច ពីរអង្គ គឺ ឥន្ទ្រជ័យវរ្ម័ន (១៣០៨-១៣២៧) និង ជ័យវរ្ម័នទី ៩ [បរមេស្វរៈ] (១៣២៧-១៣៣៦) ដែលសុទ្ធតែជា អ្នកគោរពបូជាព្រះសីវ យ៉ាងស្វិតស្វាញ។ មកដល់ត្រង់នេះ គួរកត់សំគាល់ថា រឿង តាត្រសក់ផ្អែម ដែលថា បានចោលលំពែងធ្វើគុតស្តេច ដែលមកលួចបេះត្រសក់ នៅក្នុងចម្ការ ដោយក័ន្តប្រទ្បំ រួចឡើងធ្វើស្តេចខ្លួនឯងតែម្តង ជាការបកស្រាយ រឿងពិត តែមួយកំណាត់ប៉ុណ្ណោះ ព្រោះបើតាមការសន្និដ្ឋាន របស់អ្នកសាវជ្រាវប្រវត្តិសាស្ត្រខ្លះ គឺជារឿងដែលទាក់ទង និងបដិវត្តន៍ពុទ្ធសាសនា ដែលកើតមានឡើងនៅសម័យនោះ។ ព្រឹត្តិការណ៍នេះស្រប នឹងការធ្វើគុតស្តេចមួយអង្គ ដែលរាជពង្សាវតារ (Chronique royale) ប្រាប់ថា ព្រះនាម «សីហនុរាជ» ។ ឯកសារនោះ ទំនងជា និយាយមិនច្បាស់លាស់ ដោយមូលហេតុផ្សេងៗ ហើយជួនកាល មានលក្ខណៈស្រដៀង នឹងរឿងនិទាន នៃ ប្រទេស ម៉ាឡេស៊ី ឬ ប្រទេសឥណ្ឌាទៀតផង ។ ប៉ុន្តែ បើគេវិល មកពិនិត្យ ឯកសារ ប្រវត្តិសាស្ត្រ

ជាក់លាក់ ស្តេចដែលបានប្រគល់លំពែង ឲ្យតាត្រសក់ផ្អែម ដើម្បីការពារចម្ការ ត្រសក់ ហើយដែលបានត្រូវ តាត្រសក់ផ្អែមធ្វើគុត ដោយលំពែងនោះ គឺ ប្រហែល ជា ស្តេច ជ័យវរ្ម័នទី ៩ (ជ័យវរ្ម័នបរមេស្វរៈ)។ ការដែលគួរកត់សំគាល់ គឺថា ជ័យវរ្ម័ន ទី ៩ ជាអ្នកគោរពបូជាព្រះសីវ ហើយតាត្រសក់ផ្អែម ឬ តាជ័យនេះ (ពញាជ័យ) ដែលកាន់ លទ្ធិពុទ្ធសាសនា (ហិនយាន) បានត្រូវ នាម៉ឺន លើកឲ្យឡើងស្នងរាជ្យស្តេច ដែលគាត់ បានធ្វើគុត «ដោយប្រឡំ» នោះ។ តាមការសន្និដ្ឋានរបស់ ប្រវត្តិវិទូ គឺពួកនាម៉ឺនទេ ដែល បានធ្វើគុតជ័យវរ្ម័ន ទី ៩ នោះ ដែលកាន់លទ្ធិព្រហ្មញ្ញសាសនា ។ កាលនោះប្រជាជន ទ្រាំទ្រ នឹងការគ្រប់គ្រង របស់បណ្តាស្តេច «វរ្ម័ន»ទៀត លែងកើត ព្រោះ ត្រូវគេកេណ្ឌ ឲ្យទៅសាងសង់ប្រាសាទ និង ជីកបារាយណ៍ ឬ ក៏ធ្វើសង្គ្រាម គ្មានថ្ងៃចប់ បណ្តាល ឲ្យបាក់បែកគ្រួសារ គួរឲ្យសង្វេគ ។ នៅក្នុងន័យនេះ ឯកសារ ខ្លះបានបញ្ជាក់ថា កាល បើ បានដឹងថា តាត្រសក់ផ្អែម ដែលជាអ្នកកាន់លទ្ធិពុទ្ធសាសនា បានឡើងគ្រងរាជ្យ ជំនួស ពួកស្តេច «វរ្ម័ន» ពួកគេ សប្បាយចិត្ត ក្រៃលែង ។ ការវិភាគ ឯកសារ ប្រវត្តិ សាស្រ្ត បានបញ្ជាក់ម៉្យាងទៀតថា ចាប់តាំងពី តាត្រសក់ផ្អែម មក ស្តេចខ្មែរគ្មានឈ្មោះ «វរ្ម័ន» ទៀតទេ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ លទ្ធិពុទ្ធនិយម មហាយាន (តួអង្គពោធិ សត្វ) នៅតែមានបន្តមកទៀត ហើយលាយឡំ ជាមួយព្រហ្មញ្ញសាសនា និង ពុទ្ធ សាសនាហិនយាន ជាលំដាប់ដែរ ។ ស្តេចមួយអង្គ នាពាក់កណ្តាលទី ២ នៃ សត វត្សរ៍ទី ១៥ គឺ ស្រីធម្មរាជា ទី ១ បានត្រូវគេចាត់ទុកថាជា ព្រះពោធិសត្វ ។

បន្ទាប់ពីជ័យវរ្ម័នទី ៧ បាត់ខ្លួន នៅឆ្នាំ ១២១៨ (ដើមសតវត្សរ៍ទី ១៣) ចក្រកព ខ្មែរ ចាប់ផ្តើមចុះខ្សោយ។ នៅ ឆ្នាំ ១២៣៨ ចៅហ្វាយខែត្រខ្មែរនៅសុខោទ័យ បានត្រូវ ជនជាតិថៃ ផាមឿង និង បាង ក្លាំង ចៅ ដេញចេញ ពីសុខោទ័យ។ នៅឆ្នាំ ១២៣៨ នោះ សុខោទ័យ រំដោះខ្លួនចេញពីចក្រកពខ្មែរ។ នៅឆ្នាំ ១២៨៥ ស្តេចជ័យវរ្ម័នទី ៨ ត្រូវបង់សួយសារអាករឲ្យអធិរាជម៉ុងហ្គោល យុប៊ីល័យខាន់ (Khoubilai Khan) ដែល កាលនោះជាអធិរាជនៃប្រទេសចិន ហើយ ជាស្ថាបនិក នៃ រាជវង្ស យ័ន (dynastie





des Yuan) ។ ការគំរាមកំហែង ពីសំណាក់សៀម បានជំរុញ ឲ្យស្តេចខ្មែរ ចៅពញា យ៉ាត បោះបង់រាជធានីអង្គរចោលនៅឆ្នាំ ១៤៣២ ហើយមកតាំង រាជធានី នៅ បាសាន ស្រីសន្ធរ (ឬស្រីសឈរ) វិញ។ នៅឆ្នាំ ១៣៨៤ កងទ័ពចាម បានវាយយកទីក្រុង ថាង ឡុង (ហាណូយ) ។ ទីក្រុងយួននេះ ហៀបតែ នឹង ធ្លាក់ ទៅក្នុងកណ្តាប់ដៃចាម ទៅ ហើយ ប៉ុន្តែ បានត្រូវយួន វាយដេញវិញបាន ។ យួនប្រយុទ្ធតទល់ នឹង ចាម ម្តងចាញ់ ម្តងឈ្នះ អស់រយៈពេលដ៏យូរ ប៉ុន្តែ នៅឆ្នាំ ១៤៧១ ហ្សេ វៀត បានវាយយក ប្រទេស ចម្ប៉ាបានទាំងមូល ហើយ ផ្តាច់ព្រ័ត្រតែម្តង។

ផុតពីចាមទៅ ប្រទេសកម្ពុជា បាត់បង់ សត្រូវឈ្លានពាន មួយ ដ៏ធំ ក៏ពិតមែន ប៉ុន្តែ តាំងពីពេលនោះមក ស្រុកខ្មែរ ត្រូវព្រឈមមុខ នឹង សៀមផង នឹង រាជាណា ចក្រយួនអណ្ណាមផង។ ទោះជាយ៉ាងនេះក្តី ទាល់តែឆ្នាំ ១៦៥៨ ទើបយួន ចូលមកឈ្លាន ពាន ទឹកដីខ្មែរបាន។ ខាងប្រទេសសៀមឯណោះវិញ គេក៏វាយយក ទឹកដីខ្មែរ ជា បន្ត បន្ទាប់ដែរ ចាប់តាំងពី ពាក់កណ្តាលសតវត្សរ៍ ទី ១៤ មក។ អង្គ ច័ន្ទ ទី ១ [បរមរាជា ទី ២, ចៅ ពញាចន្ទ ហៅ ចន្ទរាជា] (១៥១៦-១៥៦៦) ស្តេចខ្មែរ នៃ រាជវង្សថ្មី បាន មកតាំងរាជធានី នៅបន្ទាយលង្វែក (ស្នាកទ្រូ) ។ នៅឆ្នាំ ១៥៨៣ សៀមបានសាកល្បង វាយយក បន្ទាយដ៏ធំនេះ ប៉ុន្តែ មិនបានសម្រេច។ អង្គ ច័ន្ទ ទី ១ បានយកជ័យជំនះ ទៅលើទ័ព សៀមវិញបានទៅសៀមរាប។ នៅក្នុងរាជ្យបរមរាជាទី ៣ (១៥៦៦-១៥៧៦) ដែលជា បុត្ររបស់ព្រះអង្គ ស្រុកខ្មែរ មានការរីកចម្រើនលូតលាស់ល្អ ។ ស្តេចអង្គនេះ បានដឹកនាំប្រជាជនឲ្យទៅរស់នៅ អង្គរវិញ។ នៅឆ្នាំ ១៥៧០ អង្គរ បានក្លាយទៅជា រាជ ធានីខ្មែរវិញ។ ប៉ុន្តែ មិនយូរប៉ុន្មាន សៀមចុះមកលុកលុយស្រុកខ្មែរបន្តមកទៀត។ កន្លង មក សៀមបានចាប់ផ្តើមវាយយកទឹកដីខ្មែរ ៣ លើក (១៣៥១, ១៤៤៤, ១៥៩៣) ។ ខ្មែរ បានដេញ ទៅវិញអស់ ប៉ុន្តែ នៅឆ្នាំ ១៥៩៤ សៀមវាយយក បន្ទាយលង្វែក បាន។ តាំងពីពេលនោះមក ស្រុកខ្មែរ ក៏ធ្លាក់ចុះដុនដាបរហូត។ លោកប៉ែរណា-ហ្វីលីព គ្រូ ល្យ ចោទសួរថា តើមកពី ធ្វើអាជីវកម្ម ដីអង្គរ ច្រើនហួសហេតុ និង ប្រើទុនមនុស្ស

ហួសប្រមាណ ឬ មួយ ក៏ មកពី លទ្ធិពុទ្ធសាសនា ថេរវាទ ? អ្វីដែលគេពុំអាចប្រកែកបាន គឺការប្រជែងកម្លាំង នៅក្នុងតំបន់ បន្ទាប់ពីមាន ការប្រែប្រួល ផ្នែកភូមិសាស្ត្រ-នយោបាយ និង ចលនាប្រជាសាស្រ្ត នៅក្នុងតំបន់ តាំងពីសតវត្សរ៍ទី ១៣ មក គឺ តាំងពីពួកម៉ុងហ្គោល ចូលលុកលុយ អាស៊ីខាងជើង។ ចលនា នេះ បានរុញច្រាន ប្រជាជនថៃ ឲ្យចុះមកតំបន់ខាងត្បូង។ សុខោទ័យ និង អាយុធ្យា មានមហិច្ឆតាមួយ ដ៏ធំ គឺវាយយក ចក្រភពខ្មែរ ដែលកំពុងហត់នឿយ យ៉ាងខ្លាំង ក្នុងការកសាង ចក្រភពមួយ ដ៏ធំសម្បើម អស់រយៈពេល ជាច្រើនសតវត្សរ៍ កន្លងមក។

## ការឈ្លានពាន របស់សៀម នៅពាក់កណ្ដាល និង ចុងសតវត្សរ៍ទី ១៤ នៅដើមសតវត្សរ៍ ទី១៥ និង ចុងសតវត្សរ៍ ទី ១៦

នៅឆ្នាំ ១៣៥១ នៅក្នុងរាជ្យស្ដេចស្រី-លំពង្សរាជា កងទ័ពសៀមមកពីអាយុធ្យា ដែលកាលនោះស្ថិតនៅក្រោមរាជ្យ របស់ អ៊ូ ថុង (រាមាធិបតីទី ១) ចូល មកលុកលុយក្រុងអង្គរ (ឥន្ទបទ)[8] ។ នៅឆ្នាំនោះឯង ស្ដេចសៀមបានបញ្ជូនកងទ័ព ប្រមាណ ១

[8] អ៊ូ ថុង ជាអ្នកបង្កើត រាជាណាចក្រអាយុធ្យា នៅឆ្នាំ ១៣៤៧ ហើយបានត្រូវគេចាត់ទុកថាជាស្ថាបនិក នៃប្រទេសសៀម(១៣៥០)។ នគរសុខោទ័យស្ថិតនៅក្រោមអំណាចយោធា របស់អាយុធ្យានៅឆ្នាំ ១៣៧៨ ហើយរលាយចូលអាយុធ្យា នៅឆ្នាំ ១៤៣៨ ។ ប៉ុន្តែដោយត្រូវ ភូមា ចូលវាយលុក អាយុធ្យា ក៏ត្រូវ ភូមា យកបាននៅឆ្នាំ ១៧៦៧។ ប៉ុន្តែ នៅឆ្នាំ ១៧៧៥ ឧត្តមសេនីយ៍ តាក់ស៊ីន បានរុញច្រានទ័ពភូមាចេញពីអាយុធ្យា ហើយឡើងគ្រងរាជ្យរហូតដល់ឆ្នាំ ១៧៨២។





ម៉ឺន ៥ ពាន់ នាក់ មកទីក្រុងអង្គរ ។ កងទ័ពមួយ មានចំនួន ប្រាំពាន់នាក់ បានត្រូវប្រគល់ទៅឲ្យ ស៊ី សាវ៉ាត ជាព្រះរាជនត្តា។ កងទ័ពមួយទៀត មានចំនួនមួយម៉ឺន នាក់ស្ថិតនៅ ក្រោមបញ្ជាការ របស់ រាមា សួន ។ កងទ័ពទាំងពីរ ត្រូវធ្វើដំណើរ ទាំង យប់ទាំងថ្ងៃទៅអង្គរ ។ ដោយមិនបានដឹងជាមុន កងទ័ពខ្មែរនៅព្រំដែន ទប់ទល់ នឹង ទ័ពសៀមពុំបាន ។ លុះ នាម៉ឺន ឥន្ទបទបុរី (អង្គរធំ) បានដឹងរឿងនេះ លំពង្សរាជា ក៏ប្រញាប់បញ្ជូនទ័ព ទៅទប់ទល់ ។ ស៊ីសាវ៉ាត មេទ័ពសៀម បានត្រូវខ្មែរបាញ់ស្លាប់នៅលើខ្នងដំរី ។ បានដំណឹងនោះ កាលណា ស្ដេចសៀម បញ្ជូនកងទ័ព ដ៏ច្រើនមកថែមទៀត ក្រោមបញ្ជាការ របស់ បរមរាជា ព្រះធីតុបតី [៩] គឺ កូនប្រសាប្រុស មកស្រុកខ្មែរ ហើយឲ្យកូនបីនាក់ របស់ រាមា សួន គឺ ចៅ បាសាត ចៅ បាអាត និង ចៅក្តុំបង-ពីសី ឲ្យដឹកទ័ពមកជួយរាមា សួន ផងទៀត ។ រីឯកងទ័ពខ្មែរ កាលបើសម្លាប់មេទ័ពសៀម ស៊ី សាវ៉ាត់ បានហើយៗ ឃើញ ទ័ពសៀមដកថយទៅទល់ដែនវិញ ក៏ស្មានថា ទ័ពខ្មែរឈ្នះទ័ពសៀមចប់សព្វគ្រប់អស់ហើយ ក៏ត្រឡប់ទៅ ឥន្ទបទបុរី វិញដោយនាំ ទាំងសេះ ដំរី របស់ បច្ចាមិត្ត ដែលគេយកបាន មកជាមួយផង។ មិនតែប៉ុណ្ណោះសោត លុះបានដល់ អង្គរធំ ហើយ ក៏រំសាយ កងទ័ពចោល អស់ទៅវិញ ។ ដោយទីក្រុងទាំងមូល មានកងទ័ព តែ បន្តិចបន្តួច ប៉ុណ្ណោះ កងទ័ពសៀម ក៏វាយយកអង្គរ បានដោយស្រួល ។ ពេលនោះ ស្ដេចលំពង្សរាជា ដឹកទ័ព មួយកង ទៅប្រយុទ្ធនឹង កងទ័ពសៀម បណ្ដាលឲ្យមាន ការបង្ហូរឈាម មួយដ៏ធំ ។ បន្ទាប់មក ព្រះអង្គ ក៏ដកថយ មករាជវាំងវិញ ។ ទោះជាយ៉ាងនេះក្តី ក៏អង្គរស្ថិតនៅ ក្នុងដៃសៀមដដែល ។ ស្រី-លំពង្សរាជាសុគតនៅឆ្នាំ ១៣៥៣ ដោយជម្ងឺ ។ ស្រីសុរិយោទ័យ ជាព្រះអនុជគ្រងរាជ្យបន្ត មិនបានមួយឆ្នាំផង ក៏សុគតបាត់ទៅ នៅក្នុងការប្រយុទ្ធផ្ទាល់មួយ ជា

[៩] កូនប្រសាប្រុស (កូនប្រសាស្រី : រាជសុណិសា)

មួយសៀម។ ស្តេចសៀមដាក់ ចៅ បាសាត ឲ្យគ្រងរាជ្យនៅអង្គរ ដោយប្រគល់ទ័ព ១ ម៉ឺននាក់ សម្រាប់ការពារទីក្រុង។ ស្តេចសៀមនេះ បានឲ្យដឹកជញ្ជូនទ្រព្យសម្បត្តិ គ្រឿង មាស ពេជ្រ សេះ ដំរី យកទៅស្រុកសៀមអស់ ។ សៀមគ្រប់គ្រងអង្គរ អស់រយៈ ពេល ៦ ឆ្នាំ ។ នៅឆ្នាំ ១៣៥៧ ស្រី-សុរិយោវង្ស បានលើកទ័ព មកវាយយក អង្គរ បានវិញ។

នៅឆ្នាំ ១៣៩៣ នៅក្នុងរាជ្យព្រះធម្មាសោក (១៣៧១-១៣៩៣) សៀមចូលលុក លុយស្រុកខ្មែរសាជាថ្មីទៀត ហើយវាយយក ទីក្រុងអង្គរបាន ។ កងទ័ពថៃ ថែមទាំង បានសម្លាប់ស្តេចខ្មែរ ព្រះធម្មាសោក នៅ កណ្តាលថ្នល់ ផងទៀត ។ សៀម បានចាប់ នាម៉ឺនខ្មែរ និងទ័ពខ្មែរជាច្រើន គឺប្រមាណ ៧ ម៉ឺននាក់យកទៅស្រុកសៀម លើកលែង តែប្រជាជនខ្មែរភាគច្រើន នៅឥន្ទបទបុរី ព្រមទាំងពួកបរោហិតដែលបានរត់រួច ហើយ ទៅតាម ចៅពញាយ៉ាត ដោយនាំយកព្រះខ័នរាជ្យ និង លំពែងជ័យ ទៅមួយផង។ គឺ នៅពេលសៀម ចូលលុកលុយ នៅលើកនោះហើយ ដែល សៀម បានយក ព្រះគោ ពីស្រុក ខ្មែរទៅស្រុកសៀម។ ចៅពញាយ៉ាត ដែលបានរត់រួចពីសៀម បាន មកតាំង ទី នៅស្រុកស្រីសន្ធរ។ ចៅពញាយ៉ាត (បរមរាជាទី១) ពុំលើកទ័ព ទៅវាយសៀមទេ តែបានបញ្ជូន រាជង្គរក្ស (មហាត) ពីរនាក់ មានគ្នាទាំងអស់ ១៧ នាក់ទៅលួចសម្លាប់ ពញាព្រែក គឺ កូនស្តេចសៀម ដែលស្តេចសៀមចាត់ ឲ្យមកគ្រប់គ្រង អង្គរ ។ ចៅ ពញាយ៉ាត បានសម្រេចគោលដៅនេះ តែរាជជង្គរក្សទាំងពីរនាក់ របស់ ព្រះអង្គត្រូវ អង្គរក្ស របស់ ពញាព្រែក (ឥន្ទរាជា) ប្រល័យជីវិតបានវិញ ។ បន្ទាប់មក ចៅពញា យ៉ាត នាំទ័ព និង ប្រជាជន នៅអង្គរ ចូលទៅវាយដេញទ័ពសៀម ។ នៅពេលចូល ទៅក្នុងរាជវាំង ស្រាប់តែចៅពញាយ៉ាត ឃើញស្រីសៀមម្នាក់កំពុងយំខ្សឹកខ្សួល។ នាងនោះ ឈ្មោះ «ស្សៀម» ជា ប្រពន្ធ របស់ ស្តេចសៀម ដែលទើប នឹង បានត្រូវ មហាត របស់ពញាយ៉ាតសម្លាប់។ ចៅពញាយ៉ាត ចាប់ចិត្តស្នេហាទៅលើនាង ហើយ ក៏ លើកឲ្យធ្វើជាស្នំឯក របស់ ព្រះ អង្គតែម្តង ។





នៅជំនាន់ ស្តេច បរមរាជាទី ទី ២ (ចៅពញាចន្ទ ឬ ច័ន្ទរាជា, ១៥១៦-១៥៦៦) សៀមបានតម្រូវឲ្យស្តេចខ្មែរថ្វាយសួយសារអាករ ដំរីស ប៉ុន្តែ ដោយ ចន្ទរាជា ពុំ ព្រម សៀមក៏ លើកទ័ពមួយសាទៀត មកវាយយកអង្គរ ប៉ុន្តែ ត្រូវទ័ពខ្មែរ រុញច្រាន ទៅវិញអស់ ហើយថែមទាំងចាប់បាន ទាហានសៀម ចំនួនមួយម៉ឺននាក់ ធ្វើជាឈ្លើយ ទៀតផង។

នៅឆ្នាំ ១៥៨៨ នៅក្នុងរាជ្យស្តេចជ័យជេដ្ឋាទី ១ បុត្ររបស់ព្រះសុត្ថា (បរមរាជា ទី៤, ១៥៧៦-១៥៩៤) ដែលមាន អាយុ ១១ ឆ្នាំ (ប៉ុន្តែដែលកិច្ចការប្រទេស ស្ថិតនៅ ក្នុងដៃព្រះសត្ថាដដែល) សៀមបានវាយលុកម្តងទៀត ទោះបី កាលជំនាន់រាជ្យព្រះសត្ថា ស្តេចខ្មែរបានបញ្ជូន កងទ័ពខ្មែរចំនួន ២ ម៉ឺននាក់ ទៅជួយសៀម នៅពេលដែល ទីក្រុង អាយុធ្យា ច្បាំងតទល់ នឹង ភូមា រហូតដល់ បានជ័យជំនះ ក៏ដោយ។ ការវាយ របស់ សៀមលើកនេះ មិនបានទទួលជោគជ័យទេ ប៉ុន្តែ មុននឹងដកទ័ពថយទៅវិញ ព្រោះអស់ ស្បៀង សៀមបានប្រើកលល្បិចមួយ ដ៏មានពិសពុល គឺ បានបាញ់ ប្រាក់ដួងជាច្រើន ចូលគុម្ពឫស្សី ដែលជារបង ការពារបន្ទាយលង្វែក ជាហេតុធ្វើឲ្យ ពួកមន្ត្រីខ្មែរ ដែល មានចិត្តក្លើតក្លើន ឲ្យគេកាប់ឆ្ការ របងឫស្សី ដើម្បីយកប្រាក់ដួង។ លុះដឹងថា ល្បិចកល របស់ខ្លួន បានហុចលទ្ធផលល្អ សៀមលើកទ័ពមកសាជាថ្មីទៀត ដ៏ច្រើន សន្ធឹកសន្ធាប់ ហើយវាយយក បន្ទាយលង្វែកបាន នៅឆ្នាំ ១៥៩៤។ តាំងពីពេលនោះមក ស្រុកខ្មែរ ធ្លាក់ចុះដុនដាបយ៉ាងខ្លាំង។

គួរកត់សំគាល់ផងដែរថា ការធ្លាក់ចុះដុនដាប នៃ រាជាណាចក្រខ្មែរ មានដើម ហេតុ មុនដំបូងបង្អស់ មកពីការប្រែប្រួលផ្នែកភូមិសាស្ត្រ-នយោបាយនៅក្នុងតំបន់ នៅ សតវត្សរ៍ទី ១៣។ កាលនោះ ប្រទេសម៉ុងហ្គោល បានចូលវាយលុក ទ្វីបអាស៊ីខាងជើង អស់មួយភាគធំ ព្រមទាំងអឺរ៉ុបផ្នែកបូព៌ា មួយភាគដែរ។ ទោះបីប្រទេសកម្ពុជា បានគេច ផុតពី មហិច្ឆតានេះ របស់ ពួកម៉ុងហ្គោលក្តី (ព្រោះរាជាណាចក្រខ្មែរ ពេលនោះ ក៏មាន កម្លាំងខ្លាំងក្លាដែរ) ក៏ប្រជាជនថៃ ដែលរស់នៅផ្នែកនិរតី នៃ ប្រទេសចិន បាននាំគ្នារត់

*មកតាំងទីនៅ គ្រង់អានទន្លេមេណាម។ ក្រោយពី បានកសាងរដ្ឋ (សុខោទ័យ ឡាន់ណា អាយុធ្យា) របស់គេបានខ្លាំងក្លាហើយ ជនជាតិថៃ ក៏ តាំងវាយ រាជាណាចក្រខ្មែររហូត គឺ អស់រយៈពេល ៤ សតវត្សរ៍ រហូតដល់ វាយយក បន្ទាយលង្វែក បាន នៅ ចុងសតវត្សរ៍ ទី ១៦ ។ បន្ទាប់មក ពួកយួនចូលមកលុកលុយស្រុកខ្មែរថែមទៀត ទន្ទឹម នឹង ការឈ្លានពាន ឥតស្រាកស្រាន្ត ពីសំណាក់ប្រទេសសៀម។*

# *បដិវត្តន៍ ពុទ្ធសាសនា នៅសតវត្សរ៍ ទី ១៤*

*ចាប់តាំងពីសតវត្សរ៍ទី ១៤ មក គេពុំឃើញមាន ឯកសារសិលាចារឹកទៀត ទេ។ ឯកសារប្រវត្តិសាស្ត្រខ្មែរ ក្រោយៗមក ជាការលើកឡើង របស់ នាម៉ឺន និង កវី ខ្មែរ ដូចជា «ព្រះរាជពង្សាវតារនគរខ្មែរ» នៃ វត្តកោកកាក «ព្រះរាជពង្សាវតារខត្តិយ មហារាជ» នៃ វត្តសិតបូ «ព្រះរាជពង្សាវតារក្រុងកម្ពុជាធិតី» របស វាំង ជួន ឬ ក៏ ស្នាដៃ បទកំណាព្យរបស់កវី បទុម បារមីពេជ្រ ជាដើម ។ លោកអាត់ដេម៉ា ឡឺក្លែរដែលសរសេរ សៀវភៅ «ប្រវត្តិសាស្ត្រ នៃ ប្រទេសកម្ពុជា»* (*Histoire du Cambodge depuisle1er siècle de notre ère*, Paris, Paul Geuthner, 1914) *បាន ស្រាវជ្រាវសាស្ត្រាស្លឹករឹត និងក្រាំងជាច្រើន ព្រមទាំងអត្ថបទដែលមានចុះផ្សាយ នៅក្នុងព្រឹត្តប័ត្រសាលាបារាំង ខាងចុងបូព៌ាប្រទេស* (B.E.F.E.O.)*។ លោកបានធ្វើការផ្ទៀងផ្ទាត់ជាមួយ ឯកសារចិន សៀម វៀតណាម ឥណ្ឌា ព្រមទាំង ប្រភពផ្សេងៗទៀត។ លោកអាត់ដេម៉ា កត់សម្គាល់ថា មានកន្លែងខ្លះ រឿងព្រេង និងព្រឹត្តិការណ៍ប្រវត្តិសាស្រ ស្របគ្នា ប៉ុន្តែ មានកន្លែងខ្លះ បកស្រាយតាមទស្សនៈ ប្រជាប្រិយ។ រឿងដែលថា តាត្រសក់ផ្អែម ហៅ «នាយចាយ» បានសម្លាប់ ស្តេច និង លំពែង ដោយប្រទ្បំ ហើយ ឡើងសោយរាជ្យខ្លួនឯង តែម្តងនោះ ក៏ មានបែបផែន ប្រហាក់ប្រហែល នឹង ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខ្លះ*





*នៅពេលនោះដែរ គឺ អាចមាន អាថ៌កំបាំងជ្រៅជាងនេះ ដូចជា ការសម្លាប់ស្តេច ដោយពួកនាម៉ឺនជាដើម។ អ្វីដែលច្បាស់ គឺ បន្ទាប់ពី ស្តេច សីហនុរាជ បុត្រ របស់ សេនាកា (តាមឯកសាររាជពង្សាវតារ* Chronique royale) *ប៉ុន្តែតាមការស្រាវជ្រាវថ្មីៗ គឺ ជ័យវរ្ម័ន ទី ៩ [បរមេស្វរ] ១៣២៧-១៣៣៦*) *បានត្រូវតាត្រសក់ផ្អែមសម្លាប់ហើយ គេឃើញមានការប្តូរ ពីលទ្ធិព្រហ្មញ្ញសាសនា មកពុទ្ធសាសនាវិញ។ នៅក្នុងន័យនេះ គេអាចសន្និដ្ឋានថានៅសតវត្សរ៍ទី ១៤ មានការផ្លាស់ ប្តូរមួយដ៏ធំ ។ គួរបញ្ជាក់ផងដែរថា បន្ទាប់ពីបាន សម្លាប់ស្តេច ព្រះនាម សីហនុរាជ នោះហើយ តាត្រសក់ផ្អែមបានរៀបការជាមួយ ព្រះអង្គម្ចាស់ក្សត្រី ច័ន្ទវរវត្តី បុត្រី របស់ ស្តេចអង្គនេះ ដែលជាស្តេចកាន់លទ្ធិព្រហ្មញ្ញសាសនា ។ ព្រះអង្គម្ចាស់ក្សត្រី ច័ន្ទវរវត្តី ពេលតាត្រសក់ផ្អែម ឡើងសោយរាជ្យ មាន ព្រះនាមថា ស្រី-ចន្ទរាជ ។ ចំពោះកាលបរិច្ឆេទវិញ ខ្ញុះយល់ថា បដិវត្តន៍ពុទ្ធសាសនានោះ គួរតែកើតឡើងនៅចុងសតវត្សរ៍ ទី ១៣ គឺ នៅ ឆ្នាំ ១២៩០។ ការសិក្សាតាមឯកសារ រាជពង្សាវតារ ពុំបានផ្តល់ នូវកាលបរិច្ឆេទច្បាស់ទេ* (Cf *Les chroniques royales*, Khin Sok, Mon-khmer studies VI, 191-215, cf *Essai de classification*, 17, George Coedes) *ប៉ុន្តែ ជា ឯកសារសំខាន់បំផុតក្រោយសិលាចារឹក ។ ស្តេចខ្មែរចុងក្រោយ បង្អស់ដែលមាន នៅក្នុងសិលាចារឹក គឺ ជ័យវរ្ម័ន-បរមេស្វរ។ ចាប់តាំង ពីឆ្នាំ ១៣៤០ មក មានតែ ឯកសារ ដែល នាម៉ឺនខ្មែរបានសរសេរប៉ុណ្ណោះ ដែលផ្តល់ពត៌មាន ទាក់ទងនឹង ប្រវត្តិសាស្ត្រខ្មែរបន្តមកទៀត ប៉ុន្តែ មានខុសកាលបរិច្ឆេទគួរឲ្យកត់សំគាល់។ ដោយហេតុនេះហើយ បានជា លោកអាត់ដេម៉ា ឡឺក្លែរ អះអាង តាមរាជ ពង្សាវតារថា លោកមានឯកសារមួយ ដែលបញ្ជាក់ថា តាត្រសក់ផ្អែម ទទួលមរណភាព នៅឆ្នាំ ១៣១៧ នៅក្នុងជន្មាយុ ៧០ ឆ្នាំ បន្ទាប់ពីបានគ្រងរាជ្យ អស់រយៈពេល ១៧ ឆ្នាំ គឺ មិនមែន ទទួលមរណភាពនៅ ឆ្នាំ ១៣៤០ ទេ។ ការពិត គឺនៅឆ្នាំ ១៣៤០ (គ្រងរាជ្យ ពីឆ្នាំ ១៣៣៦)។ ជាមួយព្រះអង្គម្ចាស់ក្សត្រី ច័ន្ទវរវត្តី តាត្រសក់*

ផ្អែមមាន បុត្រពីរអង្គ គឺ ព្រះបរមនិព្វានបទ (១៣៤៦-១៣៥១/២) និង ព្រះសិទ្ធានរាជា (១៣៥១/២ ) ។

## ស្តេច កន

ស្រី-សុគន្ធបទ បុត្ររបស់ ធម្មោរាជា (១៤៦៨-១៥០៤) ឡើងគ្រងរាជ្យ នៅឆ្នាំ ១៥០៤។ ពេលនោះព្រះអង្គ មានព្រះជន្មាយុ ៣២ ព្រះវស្សា។ ព្រះរាជអនុជ របស់ ព្រះអង្គ ពញាច័ន្ទរាជា មិនយល់ព្រម ហើយ ក៏ចាកចេញពីទីក្រុងទៅ កទ័ព បះបោរប្រឆាំង នឹង ស្រី-សុគន្ធបទ ។ លុះបានគ្រងរាជ្យហើយ ស្រីសគន្ធបទ បានចាកចេញពីលង្វែក ទៅតាំងរាជធានីនៅ បាសាន ក្នុងស្រុកស្រីសន្ធរ គឺ កន្លែងដែលស្តេចពញាយ៉ាតជាព្រះអយ្យកោ បានមកតាំងរាជធានី។ បុរសម្នាក់ឈ្មោះ ពិជ័យនាគ ព្រមទាំងកិរិយាឈ្មោះ «មេ បាន» បានយកនាងស ដែលមានរូបល្អស្រស់ប្រិមប្រិយ ជាកូនស្រី ទៅថ្វាយព្រះអង្គធ្វើជាស្នំ ។ ស្រី-សុគន្ធបទ ក៏យល់ព្រម ហើយលើកនាងឲ្យធ្វើជា ស្នំឯក ហើយ តែងតាំង បងប្រុសនាង ឈ្មោះ កន ឲ្យធ្វើជា មហាតលិក។ ក្រោយមកទៀត កន បានទទួលគោរមងារ ជា ឧកញ៉ា ម៉ឺន ស្នេហាចោមចិត្ត ។ ព្រះអង្គ បានទទួលការរិះគន់យ៉ាងខ្លាំង ព្រោះគ្រួសារ ពិជ័យនាគនេះ ជា «ពលព្រះ» មិនអាចឡើងឋានៈខ្ពស់បានឡើយ។ នៅរាត្រីមួយនោះ នាខែចេត្រឆ្នាំ ១៥០៨ ហ្លួង ស្រី-សុគន្ធបទ យល់សប្តិឃើញ នគរធ្លាក់ទៅក្នុង កលិយុគ។ ព្រះអង្គទ្រង់ព្រះសុបិនឃើញនាគមួយ មានឫទ្ធិអស្ចារ្យ ដេញព្រះអង្គ ព្រមទាំង បរិវា ចេញអស់ ពីវាំង។ នាគនោះព្រួសពិស និងភ្លើងដុតទីក្រុង ឆេះឆាបអស់ គ្មានសល់។ វាស្ទុះទៅពាំស្វេតច្ឆត្រ រួចរត់ទៅទិសខាងកើតបាត់ទៅ ។ លុះព្រឹកឡើង ពេលព្រះអង្គចូលទៅក្នុងបន្ទប់ប្រជុំ ស្រាប់តែព្រះអង្គ មើលឃើញ នាគពីរ ឈ្មោលមួយ ញីមួយ នៅពីលើក្បាលឃុនហ្លួងកន





តែម្តង។ ព្រះអង្គ សាកសួរនាម៉ឺនសព្វមុខមន្ត្រីថា មានឃើញនាគនោះទេ។ ប៉ុន្តែ គ្មានមន្ត្រីណាថាបានឃើញនាគនោះឡើយ ។ នៅពេលនោះ គេបានផ្តល់ដំណឹងមួយមកថា ទឹកសម្រាប់ ស្តេចស្រង់ទឹកនៅក្នុងគុហាភ្នំបាណាន់ ឡើងពណ៌ក្រហមដូចទឹកល័ក្ខ។ ព្រះអង្គ ក៏កោះហៅ មេបារគូ ព្រះឥសីភ័ទ្ទ មហាព្រះរាជគ្រូ និង ព្រះហោរាធិបតី មកសាកសួរកាត់សុបិន ដ៏ចម្លែកនោះ។ ព្រះឥសីភ័ទ្ទ ទូលព្រះរាជាថា ព្រឹកមិញនេះ គេបានឃើញព្រះខ័នរាជ្យ មានដុះស្នឹម ហើយនេះ ជាប្រផ្នូលមិនល្អសោះ គឺ ស្រុកអាចកើតកោលាហល។ ព្រះរាជហោរា ទូលព្រះអង្គទៀតថា មាន បុរសម្នាក់ កើតនៅឆ្នាំខាល គឺ ឆ្នាំខ្លា នឹងជ្រែករាជ្យ ហើយតាំងទីនៅទិសបូព៌ា ។ ស្តេចស្រី-សុគន្ធបទ មានការភិតភ័យកក្កមា ព្រោះ ឃុនហ្លួងកន កើតនៅឆ្នាំខាល។ ព្រះអង្គ ក៏ បញ្ជាឲ្យគេចាត់ចែងរៀបចំពិធីនេសាទត្រីមួយ ដែលមានអ្នកមុខអ្នកការ ជំទាវឃុនណាង ហែហមទៅផង។ ស្តេចឲ្យបញ្ជាថា នៅថ្ងៃនោះព្រះអង្គ នឹង បញ្ជាឲ្យ កន មុជទឹក ហើយឲ្យគេបោះសំណាញ់ក្តោប ឃុន ហ្លួងកន ទុកឲ្យថប់ដង្ហើមស្លាប់ក្នុងទឹកតែម្តង។ ស្នំឯក ជាប្អូនស្រីឃុនហ្លួងកន លបស្តាប់បានដំណឹងកាលណា ព្រឹកឡើងថ្ងៃនេសាទ ក៏សរសេរសំបុត្រមួយដាក់ក្នុងបាយសំណុំផ្ញើទៅ ឃុនហ្លួងកន ជាបង ប្រាប់ពី ឧបាយកលនេះ របស់ស្តេច ហើយអង្វរកុំឲ្យ កន ជាបងត្រឡប់មកវាំងវិញឲ្យសោះ ។ ដឹងរឿងនេះភ្លាម កន ក៏ លើកដៃ ប្រណម្យលើក្បាល ស្រែកឡើងថា ខ្លួនជា អ្នកបម្រើស្តេច ដោយភក្តីភាពបំផុត ចុះហេតុដូចម្តេច ក៏បែរទៅជាដូច្នេះទៅវិញ។ ពេលចាប់ផ្តើមការនេសាទ ស្តេចក៏បញ្ជាឲ្យកនមុជទឹកដូច្នេះមែន។ កន មុជជ្រៅទៅក្នុងទឹកផុតពីសំណាញ់ រួចក៏ហែលទៅឆ្ងាយពីទីនោះទៅដល់បឹងទទា ហើយសម្ងំពួននៅគុម្ពត្រែង រហូតដល់ពេលថ្ងៃរះ។ ថ្ងៃងពីស្តេចវិញ កាលបើមិនឃើញសាកសព ឃុនហ្លួងកន នៅក្នុងសំណាញ់ ក៏កាន់តែមានការភិតភ័យថែមទៀត។ ព្រះអង្គបញ្ជាឲ្យគេរកចាប់ កនឲ្យបាន។ កនទៅពួននៅក្នុងវត្តដែលគ្រូចាស់របស់គេ ធ្វើធម៌នៅទីនោះ។ គ្រូរបស់ ឃុនហ្លួងកន ឲ្យអ្នកបម្រើស្តេច ដ៏អភ័ព្វនេះ រត់ទៅទិសខាងកើត ហើយ រង់ចាំវាសនារបស់ខ្លួន ។ ឃុនហ្លួងកនឲ្យ

អស់ពួកបាវព្រាវ របស់ខ្លួន និង គ្នីគ្នាប្រមាណ ៥០ នាក់ យកគ្រឿងអាវុធ មកឲ្យនៅព្រៃថ្មដា ដោយសម្ងាត់ៗ បានអាវុធហើយ ឃុនហ្លួងកន និង បក្សពួក ក៏ធ្វើដំណើរទៅខែត្របាភ្នំជាបន្ទាន់ ។ ទៅដល់បាភ្នំ ឃុនហ្លួងកន សម្លាប់ចៅហ្វាយស្រុក នៅចំពោះមុខពួកក្រុមការតែម្តង ហើយប្រកាសថា ចៅហ្វាយស្រុកក្បត់ស្តេច ចូលដៃច័ន្ទរាជា ដែលតាំងខ្លួន ត្រួតត្រា ចតុមុខ ដោយប្រើឈ្មោះស្តេច ហើយខ្លួន ដែលមកបាភ្នំនេះ គឺ តាមបញ្ជាព្រះរាជាឲ្យលើកទ័ពតទល់នឹងច័ន្ទរាជា។ ប៉ុន្តែក្រោយមក ទើបឃុនហ្លួងកន ប្រាប់ថា គឺដើម្បីខ្លួនគេទៅវិញ។ ឃុនហ្លួងកនប្រាប់ទៀតថា អ្នកណាស្មោះ នឹង ស្តេច ក៏ស្មោះទៅ ប៉ុន្តែត្រូវដឹងថា ដល់ ខ្លួនគេបានអំណាច គេនឹងរំដោះទាសករ ឲ្យចេញផុតពីការប្រកាន់វណ្ណៈ ពោលគឺ ពីការចាត់ទុកថា វណ្ណៈវៃស្យ និងសូទ្រសុទ្ធតែជាអ្នកមានទោសនោះ។ ឃុនហ្លួងកន និយាយទៀតថា នឹង រំដោះអ្នកទាំងនោះឲ្យទៅជា «ព្រៃងារ» វិញគឺ ឲ្យមានសេរីភាពវិញ ហើយ នឹង តម្លើងស័ក្តិយសឲ្យ អ្នកទាំងនោះ ថែមទៀត។ ពាក្យសម្តីរបស់ កន បានធ្វើឲ្យឃុនហ្លួងកនបង្កើតកងទ័ពមួយដ៏រឹងមាំបាន ហើយចេញវាយយកខែត្រដែលស្ថិតនៅជិតៗនោះថែមទៀត។ កងទ័ពឧទ្ទាមកាន់តែរីកធំទៅៗយ៉ាងឆាប់រហ័ស។ ស្តាប់យោបល់ របស់ យោមរាជ ស្តេចបង្គាប់ ពិជ័យនាគ ជាឪពុក ឃុនហ្លួងកន ឲ្យសរសេរសំុត្រ ទៅឃុនហ្លួងកនប្រាប់ថា បើចុះចូលព្រះរាជាៗ នឹង ប្រទានបុណ្យស័ក្តិជាទីគាប់ចិត្ត។ ស្នំឯកជាប្អូន ក៏ សរសេរសំបុត្រ ហៅឲ្យកន មកវិញដែរ ។ កនប្រាប់ទៅនារសារស្តេចដូច្នេះថា ខ្លួនគេ គង់នឹង ត្រឡប់ទៅ លង្វែកវិញទេ ព្រោះខ្លួនគេ ពុំដែលមានគំនិតចង់បះបោរអ្វីឡើយ ប៉ុន្តែខ្លួនគេត្រូវរំសាយទ័ពហើយបញ្ជូនមេៗរបស់គេ ឲ្យត្រឡប់ទៅផ្ទះគេ វិញសិន ។ លុះអ្នកនាំសារ របស់ ស្តេច ត្រឡប់ទៅវិញបាត់ទៅ ឃុនហ្លួងកន ប្រកាសប្រាប់ ប្រជានុរាស្ត្រថា ស្តេចបានតែងតាំងខ្លួន ជាមេទ័ព «កងទាប» (ប្រហាក់ប្រហែលស័ក្តិឧត្តមសេនីយ៍) ហើយឲ្យលើកទ័ព ទៅកំចាត់ ច័ន្ទរាជា ដែលកំពុងផ្តាច់យកខែត្រខាងត្បូង ហើយដែលមានទីតាំង នៅចតុមុខ។ ឃុនហ្លួងកនថែមទាំងប្រកាសទៀតថា បើអ្នកណាអាចសម្លាប់ មេក្បត់ ច័ន្ទរាជា បាន នឹង ត្រូវ





ទទួលរង្វាន់ជាមាស ១០០ តម្លឹង ។ ព្រោះតែចង់បានរង្វាន់ មនុស្សម្នាជាច្រើន បាននាំគ្នាចូលឃុនហ្លួងកនយ៉ាងសន្ធឹកសន្ធាប់។ ស្នំឯកប្អូនស្រី ឃុនហ្លួងកន [ដែលឯកសារ ខ្លះបញ្ជាក់ថា មានឈ្មោះថា នាង ពៅ ហើយដែលរឿងព្រេងនិយាយថា គឺនាង «ស្រីសឈរ» → ស្រីសន្ធរ] បានអង្វរ ប្រពន្ធម្នាក់ របស់ ឃុនហ្លួងកន ឲ្យទៅជួយនិយាយ នឹង កនផង ប៉ុន្តែ កនប្រាប់វិញថា ឲ្យចាំមួយខែទៀតសិន ត្បិតមេៗ ពួកទ័ពពុំទាន់ទៅដល់ផ្ទះគេ អស់នៅឡើយទេ។ តាមការពិត ឃុនហ្លួងកន ធ្វើផ្ទុយ ពីនេះ ទាំងស្រុង គឺយកចំណេញពេល ដើម្បី ប្រមូលទ័ព ឲ្យបាន កាន់តែច្រើនថែមទៀតនៅតាមខែត្រនានា ដោយបំផុសបំផុលថា ស្តេចឲ្យកេណ្ឌមនុស្ស លើកទ័ពទៅចាប់ ច័ន្ទរាជា ។ រឿងនេះ បានត្រូវគេយកមកនិយាយ ជាហូរហែ ពាសពេញ ក្នុងស្រុកខ្មែរទាំងមូល ។ ប៉ុន្តែ ស្តេចក៏សុខចិត្តជឿសិនដែរ ហើយហាមមិនឲ្យអ្នកណាធ្វើអ្វីទៅលើ ឃុនហ្លួងកនឡើយ នៅក្នុងពេលមួយខែនោះ។ ច័ន្ទរាជា នៅពេលនោះ ក៏ជឿថា ស្តេចមានការព្រមព្រៀងជាមួយកនដែរ ហើយដោយមានការភិតភ័យ ក៏ភៀសខ្លួនទៅប្រទេសសៀមបាត់ទៅ ។ នៅឆ្នាំ ១៥០៨ ច័ន្ទរាជា សុំជ្រកកោននៅប្រទេសសៀម។

នៅស្រុកខ្មែរឯនេះវិញ ស្តេចសុគន្ធបទ ប្រមែប្រមូលកងសេនា ហើយបែងចែកជា ៤ កង ៖ ទ័ពស្រួច ទ័ពស្តាំ ទ័ពក្រោយ ទ័ពឆ្វេង។ ព្រះអង្គបញ្ជាកងទ័ព មួយម៉ឺននាក់ ហើយបោះជំរំ នៅជាយខែត្រស្រីសន្ធរ។ ព្រះរាជាប្រគល់ទ័ព ៣០០០ នាក់ឲ្យចៅពញាសង្គ្រាម មេទ័ពស្រួច និង ឧកញ៉ាចក្រី មន្ត្រីខាងកងទ័ព ឲ្យទៅឈ្លបមើល និងទប់ទល់ នឹង ទ័ព របស់ ឃុនហ្លួងកន ។ ព្រះអង្គ រង់ចាំ កងទ័ពមួយផ្នែកទៀត ដែលព្រះអង្គគិតបញ្ជូនទៅដាក់ឲ្យនៅក្រោមបញ្ជាការ របស់ ច័ន្ទរាជា ប៉ុន្តែក្រោយមក ព្រះអង្គទ្រង់ជ្រាបថា ព្រះអនុជបានភៀសខ្លួន ទៅស្រុកសៀមបាត់ទៅហើយ ។ នៅព្រឹកមួយ ចៅពញាសង្គ្រាម ក៏ជួបឃុនហ្លួងកន ហើយ ស្តីបន្ទោសកន យ៉ាងខ្លាំង។ នៅលើខ្នងដំរី កណ្តាលរហ៍ពល ហើយ មានគេ បាំងក្លស់ឲ្យទៀត កនសួរថា តើស្តេចឲ្យមកចរចា ឬ ក៏ យ៉ាងណា? ដោយមិនចាំស្តាប់ ចម្លើយ មកវិញ កន ទាញធ្នូបាញ់ចៅ

ពញាសង្គ្រាមត្រូវចំបំពង់ក។ មេទ័ពស្រួច របស់ ស្ដេច ធ្លាក់ពីលើខ្នងដំរី ហើយក្ស័យជីវិតបាត់ទៅ។ ឃើញដូច្នេះ កងទ័ពស្ដេចដកថយ រប៉ាត់រប៉ាយ ហើយ ទៅជួបកងទ័ពរបស់ឧកញ៉ាចក្រី។ ដោយមើលទៅឃើញថា ទប់នឹងទ័ពឃុនហ្លួងកនមិនឈ្នះ ទាំងទ័ពចៅពញាសង្គ្រាមបាត់មេ ទាំងទ័ពឧកញ៉ាចក្រីក៏នាំគ្នាធ្វើដំណើរទៅដល់ គោកខាន់ រួចក៏ឈប់នៅទីនោះ ។ ស្ដេច មានកង្វល់យ៉ាងខ្លាំង កាលបើបានដឹងរឿងនេះ។ ពិជ័យនាគ ឪពុក របស់ កនសុំកងទ័ព ១ ពាន់នាក់ ពីស្ដេចទៅចាប់កូន។ ស្ដេចក៏យល់ព្រម។ ឧកញ៉ាយោមរាជ ទូលស្ដេចថា កងទ័ពការពាររាជធានីសម្រាប់ទប់ទល់ មានចំនួនមិនដល់ ១ ម៉ឺននាក់ផង។ ការបារម្ភ របស់ ឧកញ៉ាយោមរាជ មិនខុសទេព្រោះ កន មានកងទ័ពដល់ទៅ ជាង ៥ ម៉ឺននាក់ឯណោះ។ នៅទីបំផុត កងទ័ពស្ដេច និង កងទ័ព របស់ កន ប្រយុទ្ធគ្នាយ៉ាងស្វិតស្វាញ អស់រយៈពេល បីថ្ងៃ គ្មានចាញ់គ្មានឈ្នះ ។ នៅរាត្រី ថ្ងៃទី ៣ កនបញ្ជូនទ័ពមួយកងតូច ដោយស្ងាត់ៗ ចេញពីទិសខាងលិច ទៅឲ្យនៅពី ខាងក្រោយទ័ព របស់ ស្ដេចវិញ ។ ព្រឹកឡើង កងទ័ពស្ដេចត្រូវកងទ័ព របស់កន វាយ ពីមុខផង ពីក្រោយផង។ កងទ័ពស្ដេច នាំគ្នារត់ដកថយ ទៅតាមទិសខាងជើង ឆ្ពោះទៅលង្វែកតែម្ដង។ ស្ដេចព្រមទាំងបរិវារកៀសខ្លួនទៅតាំងទី នៅសន្ទុកមាត់ស្ទឹងសែនវិញ។ លុះឈ្នះទ័ពស្ដេចហើយ កនក្ដាប់បតុមុខបានទាំងស្រុងហើយ តែងតាំងចៅហ្វាយខេត្ត និង មន្ត្រីថ្មី ត្រៀមក្ដាប់យកខេត្តផ្នែកខាងលិច និងផ្នែកខាងត្បូងទៀត។ ប្រជាជន អបអរសាទរ នឹង ជ័យជំនះ របស់ ឃុនហ្លួងកន ហើយចាត់ទុកថា ឃុនហ្លួងកន ជា «អ្នកមានបុណ្យ»ទៀតផង ។

នៅខែមិគសិរ ឆ្នាំ ១៥១០ ឃុនហ្លួងកនដឹកទ័ពចំនួន ៥ ម៉ឺននាក់ ទៅឡោមព័ទ្ធលង្វែករាជធានីថ្មី នៃ ប្រទេសកម្ពុជា។ កងទ័ពស្ដេចទប់ទល់បាន។ សង្គ្រាម រវាង កន និងកងទ័ពស្ដេច មានរយៈពេលយូរ គឺ តាំងពីឆ្នាំ ១៥០៨ ដល់ឆ្នាំ ១៥២៥ ។ កន បានបញ្ជូនអ្នកម៉ឺន សុរិន កែវ ដែលជាកូន របស់ ចៅពញាសង្គ្រាមឲ្យទៅធ្វើគុតស្ដេចសុគន្ធបទ ដែលជាសត្រូវ តែម្នាក់គត់ របស់ កន ហើយនេះ ក៏ព្រោះតែស្ដេចជឿងប់



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

ងល់ខ្លាំងពេកទៅលើសុបិន។ នៅខែមិនាឆ្នាំ ១៥១២ អ្នកម៉ឺន សុរិន កែវប្រើកលល្បិចបានចូលទៅដល់ក្នុងបន្ទប់ជំនុំរបស់ស្ដេច ហើយសម្លាប់ទាំងស្ដេច ទាំងហោរា។ សុគន្ធបទ សុគតនៅ ១៥ ថ្ងៃពេញបូណ៌មី ខែជេស្ឋ ឆ្នាំវក ត្រូវនឹងឆ្នាំ ១៥១២ ។ អ្នកម៉ឺន សុរិន កែវ យល់ថា ការដែលស្ដេច បានបញ្ជូន ចៅពញាសង្គ្រាម ជា ឪពុក ឲ្យទៅតតាំងជាមួយកន គឺ មានគោលបំណង សម្លាប់ឪពុកខ្លួន ព្រោះបានប្រគល់ទ័ពចំនួន តិចពេក។ តាំងពីពេលនោះមក អ្នកម៉ឺន សុរិន កែវ ស្អប់ស្ដេចពេក ក៏ ចូលជាមួយឃុនហ្លួងកនតែម្ដង។ រីឯឃុនហ្លួងកនវិញ គេ ក៏មិនចង់បះបោរ ប្រឆាំងស្ដេច ឯណាដែរ តែគេ មានជំនឿយ៉ាងមាំថា ស្ដេច មិនងាយអត់ឱនទោសឲ្យខ្លួនឡើយ។ តាំងពីពេលស្ដេចសុគន្ធបទ សុគតបាត់ទៅ កនច្បាំងជាមួយ ពញាច័ន្ទរាជាវិញម្ដង។ ព្រះច័ន្ទរាជាឡើងគ្រងរាជ្យនៅឆ្នាំ ១៥១៦។ ព្រះអង្គមានកងទ័ពប្រមាណ ១២ ម៉ឺននាក់ រីឯ ឃុនហ្លួងកនវិញ ដោយយកខេត្តបានច្រើន ក៏កេណ្ឌទ័ពបានចំនួន ពី ២ ម៉ឺននាក់ ដល់ចំនួន ១៧ ម៉ឺននាក់ ហើយចំនួននេះ ចេះតែកើនថែមទៀត។ ក្រោយមក ឃុនហ្លួងកន ដែលឯកសារសាស្ត្រាហៅថា ស្ដេចកន ឬ ឃុនហ្លួងព្រះស្ដេចកន បានទៅតាំងទី នៅក្រុងស្រឡប់ពិជ័យព្រៃនគរ ជិតភូមិសំរោងព្រះជី ស្រុកទទឹងថ្ងៃ ។ កន បានតែងតាំងខ្លួនឯងថា ព្រះស្រីជេដ្ឋាក្រុងស្រឡប់ពិជ័យព្រៃនគរ ម្ចាស់ផែនដីខាងកើត។ ឃុនហ្លួងព្រះស្ដេចកន ពុំមានមហេសីទេ តែមានស្នំឯកម្នាក់ ឈ្មោះនាងផាខ្សែន។ នៅរាត្រីមួយឆ្នាំ ១៥២៥ កងទ័ពព្រះចន្ទរាជា បានទៅដល់បន្ទាយ របស់ ស្ដេចកន ហើយ នាំគ្នាដុតស្មៅងាប់ ជុំវិញទីក្រុងបណ្ដាលឲ្យអ្នកស្រុកអ្នកភូមិ ឃើញភ្លើងឆេះគ្រប់ទិសទី ហើយនាំគ្នាគិតថា ទ័ពសៀមចូល មកចាប់ពួកគេ យកធ្វើជាឈ្លើយ ។ ប្រជាជននាំគ្នារត់ទៅបន្ទាយស្ដេចកន ហើយនាំគ្នាបើកទ្វារបន្ទាយ។ កងទ័ពស្ដេចកន ក៏នាំគ្នាចេញទៅមើលហេតុផលតែទៅតែមួយទិសជាមួយគ្នាទាំងអស់។ កងទ័ពច័ន្ទរាជាសម្លាប់កងទ័ព ស្ដេចកន បានជាច្រើន ហើយក៏នាំគ្នាចូលទៅក្នុងបន្ទាយ។ គឺ នៅទីនោះហើយដែលឧកញ៉ាវាំង សម្លាប់ស្ដេចកនបាន។ ស្ដេចកនត្រូវរបួស ដោយស្នា របស់ ឧកញ៉ាវាំង រីឯ ចៅ

ហ្វាកែវ ជាមារបស់កន ត្រូវឧកញ៉ាចក្រីចាក់ត្រូវមួយដាវ នៅ មាត់ទ្វារបន្ទាយ ។ យុន ហ្វូងព្រះស្ដេចកន ត្រូវគេចាប់បាន ហើយ ត្រូវគេយកទៅកាត់ក ជាមួយក្រុមបក្ស ពួករបស់គេ។

# សតវត្សរ៍ ទី ១៧ និង ទី ១៨

បន្ទាប់ពី សៀមវាយយកបន្ទាយលង្វែកបាន នៅចុងសតវត្សរ៍ ទី ១៦ ប្រទេសកម្ពុជា បាត់បង់នូវភាពអង់អាចរបស់ខ្លួន។ ស្ដេចនៃរាជវង្សផ្សេងៗ មិនត្រឹមតែដណ្ដើមអំណាចគ្នាដោយឥតកោតក្រែងប៉ុណ្ណោះទេ គឺថែមទាំងការពារទឹកដីមិនបានទៀតផង។ ព្រឹត្តិការណ៍ពីរ គួរឲ្យកត់សម្គាល់ ជាពិសេស គឺ ការដែល ស្ដេចខ្មែរ ជ័យជេដ្ឋាទី ២ (១៦១៩-១៦២៧) បានយកម្ចាស់ក្សត្រីយួនឈ្មោះ កូជិនស៊ីន ធ្វើជាមហេសី (១៦២០) ហើយបើកផ្លូវ ឲ្យយួនមកតាំងទី នៅលើទឹកដីខ្មែរ ។ ព្រះអង្គ សុគត នៅឆ្នាំ ១៦២៧ ប៉ុន្តែ បានផ្ដល់ក្ខណៈ ឲ្យយួនយក ព្រៃនគរ បានជាស្ថាពរ នៅឆ្នាំ ១៦៩៨ ។ ទឹកដីដែលយួនយកបាន មានឈ្មោះថា «កូសាំងស៊ីន» គឺ ឈ្មោះ របស់ ក្សត្រីកូជិនស៊ីន មហេសីយួន របស់ជ័យជេដ្ឋាទី ២។ បន្ទាប់ពីជ័យជេដ្ឋាទី ២ សុគតបាត់ទៅ ចៅពញាតូ បុត្ររបស់ព្រះអង្គ ឡើងស្នងរាជ្យ ដោយមានព្រះនាមថា ស្រី-ធម្មោរាជាទី ១។ ស្ដេចអង្គនេះ ដែលមានឈ្មោះមួយទៀតថាព្រះរាជសម្ភារ ជាកវី ជាអ្នកអក្សរសាស្ត្រ ហើយជាអ្នកកាន់ពុទ្ធសាសនា យ៉ាងជ្រៅជ្រះ។ ព្រះអង្គចូលបួស ជាសង្ឃតាំងពីមុនព្រះបិតាចូលជីវង្គត។ កាលនោះ ព្រះឧទ័យ ជាឪពុកមា របស់ព្រះអង្គ ដែលមានអាយុ ៤៨ ព្រះវស្សាហើយដែលត្រូវ ជ័យជេដ្ឋាជាបង តែងតាំងឲ្យធ្វើជាឧបរាជ តាំងពីឆ្នាំ ១៦១៨ មក មានតួនាទី ជារាជសិទ្ធ (Régent) ។ ដោយ ព្រះរាជសម្ភារជាក្មួយ បួសយូរពេក ព្រះឧទ័យ ក៏រក្សាទុកតួនាទីនេះសិន ទម្រាំព្រះរាជសម្ភារបាកសិក្ខាបទ។ លុះបានត្រូវ





អភិសេកជាស្ដេចរួចហើយ យុវក្សត្រអង្គនេះ ដែលកាលនោះមានព្រះជន្ម ២៦ ព្រះវស្សា បែរជាប្រគល់ការគ្រប់គ្រងប្រទេសទៅឲ្យអតីតរាជានុសិទ្ធ ទៅវិញ ហើយដក ខ្លួនទៅតាក់តែងកំណាព្យនៅកោះឃ្លោក ។ ពេលដែលព្រះអង្គបួស ព្រះឧទ័យ បានរៀបការ ជាមួយព្រះសុជាតិក្សត្រី គឺ នារីដែលត្រូវរៀបការ ជាមួយ ព្រះរាជសម្ភារ។ ក្រោយពេលឡើងសោយរាជ្យហើយ មួយឆ្នាំ ក្រោយពេល ដែលព្រះអង្គទៅគង់ នៅកោះឃ្លោក ព្រះរាជសម្ភារ ក៏លើកទ័ព ទៅវាយយកខែត្រកូ៉ត ដែលសៀមកាត់ផ្ដាច់យកទៅកាលពីពេលមុន។ ប៉ុន្តែ ប្រតិបត្តិការសឹក នេះ ពុំបានទទួលជោគជ័យទេ។ ថ្ងៃមួយព្រះឧទ័យទៅគាល់ព្រះអង្គ នៅអង្គរ ដោយនាំព្រះសុជាតិក្សត្រី ជា ជាយា ទៅជាមួយផង។ គឺនៅពេលនោះហើយ ដែលព្រះរាជសម្ភារ ចាប់ចិត្តស្នេហា យ៉ាងខ្លាំងទៅលើកិរិយានេះ របស់ព្រះបិតុលា។ អ្នកទាំងពីរគិតថា ដោយព្រះឧទ័យចាស់ណាស់ទៅហើយៗ កំពុងថ្លាក់ឈើ គេអាច នឹង រួមរស់ យកគ្នាជាប្ដីប្រពន្ធ ក្រោយព្រះឧទ័យសុគតបាត់ទៅ ។ ប៉ុន្តែ ក្រោយមក ព្រះឧទ័យបែរជា ជាសះស្បើយទៅវិញ។ ដោយខ្លាចបែកការ អ្នកទាំងពីរ ក៏នាំគ្នារត់ទៅរាជវាំង ។ ព្រះឧទ័យឲ្យទ័ពដេញចាប់ ប៉ុន្តែ ព្រះរាជសម្ភារ ក៏ បញ្ជូនកងទ័ព ទៅឲ្យទប់ទល់ ។ ប៉ុន្តែ ដោយកងទ័ពព្រះរាជសម្ភារ វាយបាញ់កងទ័ពព្រះឧទ័យ ព្រះរាជសម្ភារ និង សុជាតិក្សត្រី ក៏រត់ទៅដល់ស្រុកញួរ ប៉ុន្តែ កងទ័ពព្រះឧទ័យដេញចាប់បាន ហើយក៏សម្លាប់អ្នកទាំងពីរបាន។ ព្រះរាជសម្ភារ សុគត នៅក្នុងជន្មាយុ ២៩ ព្រះវស្សា។ ព្រឹត្តការណ៍មួយទៀតទាក់ទង នឹង ស្ដេចពញាចន្ទ ឬ បុទុមរាជាទី ២ ដែលបានសម្លាប់ព្រះឧទ័យ (១៦៤២) ជា ឧបរាជ របស់ជ័យជេដ្ឋាទី ២ និង ស្ដេច បទុមរាជា ទី ១ ជាបង ដោយប្រើ ជនជាតិជ្វា ឲ្យជួយដណ្ដើមរាជ្យ។ នៅ ថ្ងៃ ៥ មករា ឆ្នាំ ១៦៤២ នោះ ពញាចន្ទ បានសម្លាប់ ព្រះឧទ័យ ព្រមទាំងសមាជិក រាជវង្សមួយចំនួន ប៉ុន្តែកូន បីនាក់ របស់ អង្គ នន់ បានរត់រួច។ ពេលនោះ អង្គ នន់ ទៅបរបាញ់សត្វ នៅឆ្ងាយពីរាជធានី ។ ពញាចន្ទ ចាត់គ្នីគ្នា ប្រមាណ ៥ កង ឲ្យទៅចាប់ អង្គ នន់ ដែលមានមហាតលិក និង អ្នកអមដំណើរ តែ

៦០ នាក់ប៉ុណ្ណោះ។ លុះចាប់បានហើយ ក៏នាំមករាជធានី ។ ពញាចន្ទ ដែលជាមនុស្សកាចសាហាវ ស្អប់ បទុមរាជា ទី ១ ណាស់ ព្រោះព្រះអង្គ ជាមនុស្សស្លូតបូត មានគេស្រឡាញ់ច្រើន ។ ពញាចន្ទ ឲ្យបងថ្លៃ ចោទ អង្គ នន់ ថា បានលួចចប៉ែចចង់ករិយារបស់ពញាចន្ទ។ ពញាចន្ទ ឲ្យគេយកបទុមរាជា ទៅសម្លាប់ចោល បន្ទាប់មកចោទបងថ្លៃនោះថា បាននិយាយភូតករ ហើយក៏យកបងថ្លៃនោះទៅសម្លាប់ចោលបាត់ទៅ។ ពញាចន្ទជាមនុស្សមានល្បិចខ្ពស់ ក្នុងការសម្លាប់គូសត្រូវ ហើយ យករូបខ្លួន ។ ស្តេចអង្គ នេះ បានត្រូវគេហៅថា «រាមចូលសាសន៍ជ្វា» ។ ក្រោយមក នៅឆ្នាំ ១៦៥៨ ពញាច័ន្ទ (រាមាធិបតី ទី ១, សជ្ជា, អ៊ីប្រាហិម) បានត្រូវបរមរាជាទី ៨ (អង្គ សូរ) ជាបងប្អូនជីដូនមួយ និងជាកូន របស់ឧបយោរាជឧទ័យ ធ្វើឃាតម្តងវិញ។ ស្តេចអង្គនេះ ដែលកាលនោះមានអាយុ ៣៣ ឆ្នាំ បានបង្ខំឲ្យ ភគ្គវត្តីព្រះចមក្សត្រី ដែលជា មហេសីជ្វាម៉េម៉ាយ របស់ ពញាច័ន្ទ ធ្វើជាអគ្គមហេសី។ នៅឆ្នាំ ១៦៧២ ស្រីជ្វានោះ ក៏សម្លាប់ អង្គ សូរ ដើម្បីសងសឹកពញាច័ន្ទជាប្តី។ ទោះជាយ៉ាងនេះក្តី ក៏ រាជបល្ល័ង្ក ពុំបានធ្លាក់ទៅក្នុងដៃ បក្សពួក របស់ អ៊ីប្រាហ៊ីមដែរ។ ស្តេចដែលសោយ រាជ្យបន្ត គឺ បុទុមរាជា ទី ២ (ស្រីជ័យជេដ្ឋ) ដែលជាកូន របស់ បទុមរាជាទី ១ (អង្គ នន់) ហើយជាក្មួយ និងជាកូនប្រសារបស់ អង្គ សូរ។ គឺនៅពេលនោះហើយ ដែលយួនចូលលុកលុយស្រុកខ្មែរ។ សង្គ្រាមរវាងយួន និងខ្មែរ បានប្រព្រឹត្តទៅ អស់រយៈពេលពេញមួយឆ្នាំ ហើយ នៅក្នុងការប្រយុទ្ធ បទុរមរាជា ទី ២ ក៏ ក្ស័យជីវិត បាត់ទៅ នៅឆ្នាំ ១៦៧៣។ ស្តេចអង្គនេះ សោយរាជ្យមិនបាន ២ ឆ្នាំផង (១៦៧២-១៦៧៣)។ កងទ័ពយួនដែលចូលមកលុកលុយស្រុកខ្មែរ នៅពេលនោះអះអាងថា ពួកគេមក សងសឹក បទុមរាជា ទី ១ (អង្គ នន់) ដែលបានត្រូវពញាច័ន្ទធ្វើគុត។ តាមការពិតស្តេច អង្គ ជី [កែវហ្វាទី ២ ](១៦៧៣- ១៦៧៧) កូន របស់ អង្គ សូរ ដែលនៅពេលនោះស្នងរាជ បទុមរាជា ទី ២ (ដែលជាបងប្អូន ជីដូនមួយ) គ្មានរឿងអ្វីទាក់ទងអ្វី នឹង ពញាច័ន្ទ ឡើយ។





# ស្រុកខ្មែរ : ការប្រទាញប្រទង់ រវាង សៀម និង យួន

នៅ ដើមសតវត្សរ៍ ទី ១៨ អំណាចស្តេចខ្មែរ បានចុះខ្សោយ ជាអតិបរមា គឺខុសប្លែកច្រើន ពីពេលមុនៗ ហើយនេះ ព្រោះតែនៅសតវត្សរ៍ ទី ១៧ ក្សត្រខ្មែរគិតតែពីដណ្តើមរាជ្យដណ្តើមអំណាចគ្នា។ ម្យ៉ាងទៀត ច្បាប់ស្នងរាជ្យ ក៏គ្មានលក្ខណៈច្បាស់លាស់ទាល់តែសោះ។ នាម៉ឺនស្តេច ក៏បាត់បង់ស្មារតីស្នេហាជាតិដែរ។ មានតែអ្នកចេះដឹង នៅតាមវត្តអារ៉ាមប៉ុណ្ណោះ ដែលយល់ដឹងច្បាស់ ពីសោកនាដកម្មខ្មែរ។ កវី បទុមបារមីពេជ្រ បានលើកឡើង ពីទំព័រប្រវត្តិសាស្ត្រនេះ យ៉ាងក្បោះក្បាយ[10]។ សភាពការណ៍នេះ បានបង្កលក្ខណៈងាយស្រួលដល់មហិច្ឆតា របស់ យួន និង សៀមដែលអនុវត្តផែនការលេបទឹកដីខ្មែរ បន្តិចម្តងៗ មុននឹងលេបយកទាំងមូលតែម្តង នៅពេលដែលឱកាសហុចឲ្យ ។ ប៉ុន្តែប្រជាជនខ្មែរ ព្រមទាំងអ្នកស្នេហាជាតិបាន វាយដេញរុញច្រានកងទ័ពឈ្លានពានទាំងនោះ បានវិញ រហូតដល់ពេលបារាំង មកធ្វើជាអាណាព្យាបាលនៅឆ្នាំ១៨៦៣។ ប៉ុន្តែ បារាំងដែលមកធ្វើអាណានិគមកិច្ចយួន នៅលើទឹកដីកូសាំង

[10] សាស្ត្រា វត្តក្រូច ឃុំក្រូច ស្រុកព្រៃឈរ កំពង់ចាម។ លោក ឃីន សុខ បានបកប្រែឯកសារនេះមកជាភាសា បារាំង (អាន*រឿងកំពប់តែអុង* របស់ ឃីន សុខ –Khin Sok : *L’annexion du Cambodge par les vietnamiens au XIX ème siècle*, Editions You-Feng, 2002) ។ ចំពោះរឿង *របាក្សត្រ* របស់ បទុម បារមីពេជ្រ លោក ឃីង ហុក ឌី បានបញ្ជាក់នៅក្នុង *មាលាបទអក្សរសិល្ប៍ខ្មែរសតវត្ស ទី ១៩* របស់ លោកថា បទុមបារមីពេជ្រ «ផ្តើមសរសេរ [...] នៅ រវាង គ. ស. ១៨៣៥ ហើយ បានចូលមរណកាលប្រហែលនៅរវាងពាក់កណ្តាល ទី ២ នៃ សតវត្ស ទី ១៩ ព្រោះលោកនិពន្ធចប់ របាក្សត្រមួយទៀត នៅក្រោយ គ. ស. ១៨៥៥ [... ]។ »

ស៊ីន ដែលជាទឹកដីខ្មែរ ចង់បង្កើត សហព័ន្ធឥណ្ឌូចិនបារាំងតែម្ដង សម្រាប់ទុកធ្វើជាជាមូលដ្ឋានវត្តមាន របស់គេ នៅអាស៊ីអាគ្នេយ៍។ ដូចនេះ គេជួយខ្មែរ ឲ្យទប់ទល់ នឹងសៀម ជាងជួយរំដោះខ្មែរ ចេញពី ការគាបសង្កត់ របស់ យួន ។ ទោះជាយ៉ាងនេះក្ដី ក៏បារាំងចាញ់បោកសៀមដែរ (អានជំពូក ២) ។

# ទ្រឿង មិញ យ៉ាង ត្រួតត្រាស្រុកខ្មែរ

នៅសតវត្សរ៍ ទី១៧ ដោយស្រុកខ្មែរចុះទន់ខ្សោយ យួនអណ្ណាម ក្រោមការដឹក នាំរបស់រាជវង្ស ង្វៀង នៃ ក្រុងវេ៉ ចាប់ផ្ដើមឈ្លានពានស្រុកខ្មែរ ហើយផ្ដាច់យកទឹក ដីជាច្រើន។ នៅឆ្នាំ ១៦៩៨ យួន បានផ្ដាច់យក ព្រៃនគរ (សាយហ្គន ឬ ទីក្រុង ហូជីមិញ) ។ នៅសតវត្សរ៍ ទី ១៨ យួនផ្ដាច់យកមួយផ្នែកធំ នៃដីសណ្ដទន្លេមេគុង ដែលជាច្រកចេញទៅសមុទ្រមួយដ៏សំខាន់ មានជាអាទិ៍ មីថូ និងវិញឡុង (១៧៣២) ត្រាវិញ (១៧៧៥) ហើយ សុកត្រាំង នៅសតវត្សរ៍ទី ១៩ (១៨៤០) ។ នៅចុងសតវត្សរ៍ ទី ១៨ នៅឆ្នាំ ១៧៩៥ គឺ មុនស្ដេចខ្មែរ អង្គ អេង (១៧៧៩-១៧៩៦) ចូលជីវង្គត សៀមបានផ្ដាច់យកទឹកដីខ្មែរ ផ្នែកខាងលិច គឺ បាត់ដំបង និង អង្គរ ។ ព្រះបាទអង្គ អេង បានទាមទារ យកខេត្តទាំងនោះមកវិញដែរ បន្ទាប់ពីបានបណ្ដោយឲ្យសៀមផ្ដាច់យកទៅ។ ប៉ុន្តែ សៀមពុំព្រមដាច់ខាត។ អង្គ អេង ចូលជីវង្គត នៅឆ្នាំ ១៧៩៦ នៅក្នុងព្រះជន្មាយុ ២៦ ព្រះវស្សា បន្ទាប់ពី បានសោយរាជ្យ ១៨ ឆ្នាំ (ពីអាយុ ៦ ឆ្នាំ ប៉ុន្តែ បានគ្រងរាជ្យពីរដង គឺ មានចន្លោះ ៣ ឆ្នាំ)។ ចៅហ្វាប៉ុក ជាឧបរាជ មិនបាន ប្រញាប់ប្រញាល់ រកស្ដេចស្នងរាជ្យ ឲ្យគ្រប់គ្រងប្រទេស បន្តមកទៀតទេ ព្រោះនៅពេលនោះ រាជវង្សានុ





វង្ស បាក់បែកខ្ចាត់ព្រាត់អស់ទៅហើយ ។ នៅទីបំផុត អង្គ ច័ន្ទ ទី ៣ [11] (ក. ១៧៩១-†១៨៣៥) ដែលជារាជបុត្ររបស់ ព្រះបាទអង្គ អេង (ក.១៧៧២-†១៧៩៧) ហើយដែលទើបនឹងមានអាយុ ១៦ ព្រះវស្សា បានត្រូវរាជាភិសេកដោយស្ដេចសៀម រាមាទី ១ នៅទីក្រុងបាងកកនៅឆ្នាំ ១៨០៦ ដោយមានព្រះនាមថា ឧទ័យរាជា។ កាលនោះ សៀមក្ដាប់ខេត្តបាត់ដំបង និងសៀមរាប តាមរយៈនាម៉ឺនខ្មែរឈ្មោះបែនដែលស្មោះត្រង់ នឹងស្ដេចសៀមតាំងពីរាជ្យស្ដេច អង្គ អេង (នារាយណ៍រាមា) មក។ ព្រះបាទ អង្គ អេងមានកូនប្រុសប្រាំអង្គ គឺ អង្គ ច័ន្ទ, អង្គ ស្ងួន (ក.១៧៩៤-†១៨២៤ ), អង្គ កឹម (ក.១៧៩៣-†១៨០០), អង្គ ឯម (ក.១៧៩៤ -†១៨៤៣) និង អង្គ ដួង (ក. ១៧៩៦-†១៨៦០ ) ព្រមទាំងបុត្រីម្នាក់ ព្រះនាម មាតុប្ផា (ក.១៧៩៦-†១៨... ? )។

ព្រះបាទអង្គច័ន្ទ មកដល់ទីក្រុងឧដុង្គ នៅថ្ងៃ ១៥ កញ្ញាឆ្នាំ ១៨០៦ ។ នាម៉ឺនសព្វមុខមន្ត្រី បានមកធ្វើគារវកិច្ចស្ដេចខ្មែរនៅទីក្រុងឧដុង្គ លើកលែងចេញតែ តេជោមឿងប៉ុណ្ណោះដែលពុំព្រមមក។ នៅខែធ្នូឆ្នាំដដែល ស្ដេចខ្មែរអង្គនេះបានត្រូវអភិសេកម្ដងទៀតតាមប្រពៃណីខ្មែរ ។ នៅថ្ងៃ ១១ ធ្នូ ឆ្នាំ ១៨០៦ នោះ អធិរាជយួន យ៉ា ឡុងបានបញ្ជូនគណៈប្រតិភូមួយ ដឹកនាំដោយ ចាន់ ស៊ី ង៉ោ យក ត្រាមាសមួយ រាងបួនជ្រុងស្មើ ព្រមទាំងអ្នកបម្រើ ៥០០ នាក់ មកថ្វាយព្រះអង្គ ។ ថ្ងៃងពី ស្ដេចសៀមរាមាទី ២ វិញ ដោយខ្លាចស្ដេចខ្មែរក្បត់ ក៏រក្សាសមាជិកព្រះរាជវង្សទុក នៅទីក្រុងបាងកក។ នៅ ខែមករា ឆ្នាំ ១៨០៨ អង្គច័ន្ទ បានបញ្ជូន ព្រះអង្គ កែវ ដួង និង ឧកញ៉ាចក្រីកែប ទៅទីក្រុងបាងកក យកសួយសារអាករ ទៅថ្វាយស្ដេចសៀមហើយទន្ទឹមនោះស្នើសុំឲ្យស្ដេចសៀមអនុញាតឲ្យ ព្រះអង្គម្ចាស់ក្សត្រី អង្គ ពៅ អង្គ ម៉ែន

[11] ឯកសារខ្លះ ហៅថា អង្គ ច័ន្ទ ទី ២ ប៉ុន្តែ តាមឯកសារ *Etat présent de la Maison royale* (1994), p. 36 និពន្ធ ដោយ ហ្សាក់ ណេប៉ូត និង ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ រិវត្តនា មុនីពង្ស គឺ អង្គច័ន្ទ ទី ៣ ដូច្នេះវិញ ។

និងអ្នកម្នាង បុប្ផាវតីត្រឡប់មកស្រុកខ្មែរវិញ។ នៅចុងឆ្នាំ ១៨០៨ នោះ ដោយតេជោ មឿង ចៅហ្វាខែត្រកំពង់ស្វាយ នៅតែមិនព្រមមកគាល់ព្រះអង្គទៀត ព្រះបាទអង្គច័ន្ទ ក៏បញ្ជាឲ្យចៅហ្វា នួន ទៅចាប់ខ្លួន តេជោមឿង ប៉ុន្តែដោយដឹងរឿងនេះ តេជោមឿង ក៏ រត់ទៅស្រុកសៀមបាត់ទៅ។ នៅខែ ធ្នូឆ្នាំ ១៨០៨ អង្គច័ន្ទយាងទៅទីក្រុងបាងកក។ ព្រះអង្គគង់នៅរាជធានីសៀម អស់រយៈពេល ៦ ខែ។ នៅក្នុងរាជ្យស្តេចអង្គច័ន្ទទី ៣ សៀម បានលើកទ័ពចូលមកស្រុកខ្មែរពីរដង ម្តងនៅឆ្នាំ ១៨១២ ម្តងទៀត នៅឆ្នាំ ១៨៣៣ ។ ពីឆ្នាំ ១៨១២ មកឆ្នាំ ១៨៣៤ ស្តេច អង្គច័ន្ទ ស្ថិត នៅក្នុង ការប្រទាញ ប្រទង់ រវាងមហិច្ឆតារបស់ស្តេចសៀម និងអធិរាជយួន យ៉ា ឡុង (១៨០២-១៨២០) បន្ទាប់មក មីង ម៉ាង (១៨២០-១៨៤១)។ សៀមខិតខំថែរក្សាអង្គ ស្ងួន ទុកជាស្រេច ព្រោះខ្លាច អង្គ ច័ន្ទ ក្បត់ទៅរកជំនួយពីយួន ដើម្បីដេញសៀម ។ ការដែលអង្គច័ន្ទ ថ្វាយសួយសារអាករទៅឲ្យសៀមផង យួនផង ធ្វើឲ្យសៀមមិនទុកចិត្តសោះ។ នៅឆ្នាំ ១៨១០ ព្រោះតែចៅហ្វាយខែត្រខ្មែរខ្លះ មិនទទួលស្គាល់អាជ្ញា របស់ព្រះអង្គ អង្គ ច័ន្ទ ក៏ប្រកាសកាត់ទោសប្រហារជីវិត ក្រឡាហោម មឿង ឧកញ៉ាចក្រី បែន និង ចក្រី កែប ដោយចោទប្រកាន់ថា ជាភ្នាក់ងារសម្ងាត់ របស់ ស្តេចសៀម ។ ដឹងរឿងនេះ ក្រឡាហោមមឿង និងឧកញ៉ាចក្រី បែន [12] ក៏តាំងរៀបចំទ័ពត្រៀមទប់ទល់នឹង ទ័ព ហ្លួង។ នៅដើមឆ្នាំ ១៨១១ អង្គ ច័ន្ទ បានបញ្ជូនឧកញ៉ាវង្សាអគ្គរាជ្យឲ្យទៅចាប់ក្រឡា ហោមមឿង ប៉ុន្តែក្រឡាហោមមឿងរត់ទៅស្រុកសៀមបាត់ទៅ។ នៅឆ្នាំ ១៨១២ អង្គ ច័ន្ទ ទៅពឹងអធិរាជយួន យ៉ា ឡុង ឲ្យជួយ។ នៅឆ្នាំ ១៨១២ ស្តេចសៀម ដែលមាន គោលដៅលេបទឹកដីខ្មែរឲ្យបានទាន់ពេល ក៏បញ្ជូនទ័ពមកស្រុកខ្មែរ ហើយ ថែមទាំង

[12] នៅឆ្នាំ ១៧៨៣ ស្តេចសៀម រាមាទី ១ បានតែងតាំង បែន ជាចៅហ្វាយខែត្រ បាត់ដំបង កែប ជាចៅហ្វាយខែត្រសៀមរាប ហើយ កន ជាចៅហ្វាយខែត្រពោធិ សាត់ ។





ដាក់ អង្គ ស្ងួន ឲ្យឡើងសោយរាជ្យ នៅទីក្រុងឧដុង្គទៀតផង។ អង្គ ច័ន្ទ រត់ទៅស្រុក យួន ហើយ នៅឆ្នាំបន្ទាប់ គឺ ឆ្នាំ ១៨១៣ ដោយមានជំនួយពីទ័ពយួនខ្លះ ខ្មែរខ្លះ ដឹក នាំដោយឧត្តមសេនីយ៍ តា គុន អង្គ ច័ន្ទ ក៏ បានមកដល់ កំពង់ហ្លួង ហើយវាយយក ទីក្រុងឧដុង្គវិញបាន នៅថ្ងៃ ១៤ ឧសភា។ សៀម ដកកងទ័ពថយទៅវិញ ប៉ុន្តែកាត់ យកខែត្រពោធិសាត់ និង ស្ទឹងត្រែងបាត់ទៅ។ អង្គ ច័ន្ទ សុខចិត្តបញ្ជូនសួយសារអា ករទៅឲ្យស្តេចសៀមទៀត ហើយស្តេចសៀម ក៏ផ្តល់ប្រាក់ ២ ពាន់ បាទ និង រទេះ ដឹកស្រូវចំនួន ១០០ មកឲ្យស្តេចខ្មែរវិញ។ ប៉ុន្តែនៅឆ្នាំ ១៨១៤ សាជាថ្មីទៀត សៀម បញ្ជូនទ័ព មកដាក់នៅខែត្រ ដែលស្ថិតនៅ ផ្នែក ខាងជើង កំពង់ស្វាយ (ព្រៃ ស, ស្ទឹង ប៉ា‌រ, ម្លូព្រៃ និង ទន្លេរពៅ) ។ នៅឆ្នាំ ១៨៣២ ស្រុកយួនជាប់ដៃ នឹង ការបះ បោរផ្ទៃក្នុង នៅភាគខាងត្បូងប្រទេស។ ស្តេចសៀម រាមាទី ៣ ក៏ ឆ្លៀតឱកាសនេះ ចូលលុកលុយស្រុកខ្មែរទៀតនៅឆ្នាំ ១៨៣៣។ ស្តេចសៀម យល់ឃើញថា ខ្មែរកំពុង ស្អប់យួនខ្លាំងណាស់ ព្រោះយួនធ្វើបាបខ្មែរ ដោយឥតអាសូរ ដូចនេះ ខ្មែរច្បាស់ជា ពេញចិត្តនឹងអន្តរាគមន៍សៀមជាពុំខាន។ ទោះជាយ៉ាងនេះក្តី ក៏សៀមមិនបានសម្រេច គោលដៅរបស់គេឡើយ ព្រោះយួនក្តាប់ស្រុកខ្មែរយ៉ាងណែន រួចស្រេចទៅហើយ ។ នៅឆ្នាំ ១៨១៣ ស្តេច អង្គ ចន្ទ ដែលទៅពឹងយួនឲ្យជួយទប់ទល់ នឹងសៀម បានត្រូវ ទាំងសៀមទាំងយួនធ្វើបាបពន់ពេកក្រៃ។ សៀមបានយកទឹកដីខ្មែរផ្នែកខាងលិចហើយ ជម្លៀសប្រជាជនខ្មែរ ជាច្រើនយកទៅដាក់នៅខែត្រខាងលិច ទុកសម្រាប់ធ្វើរបាំពល ប្រយុទ្ធនឹងយួន។ សៀមយកដីខ្មែរ ភាគខាងលិចទន្លេមេគុង ហើយយួនមកតាំងទីនៅ ផ្នែកបូព៌ា ព្រមទាំងទីក្រុងភ្នំពេញ ផងដែរ។ នៅថ្ងៃ ១៤ ធ្នូ ឆ្នាំ ១៨១៥ អធិរាជយួន យ៉ា ឡុង បានតម្រូវឲ្យកេណ្ឌខ្មែរចំនួន ៤ ពាន់នាក់ ទៅឲ្យសាងសង់បន្ទាយមួយ នៅ ខែត្រ «មាត់ជ្រូក» (ចូវ ឌឹក) ។ នៅ ឆ្នាំបន្ទាប់មកទៀត (១៨១៥, ១៨១៦) អាជ្ញាធរ យួន ឲ្យកេណ្ឌខ្មែរចំនួន ៥ ពាន់ នាក់ ឲ្យទៅជីកព្រែកមួយ នៅ «វិញ តេ» ។ ព្រែក នោះ

មានប្រវែង ៥៣ គ. ម. ទទឹង ៣៣ ម៉ែត្រ ហើយមានជម្រៅ ២, ៦០ ម៉ែត្រ ។ អង្គ ច័ន្ទ ចូលជីវង្គត នៅឆ្នាំ ១៨៣៥ ។

ពេលដែលស្តេច អង្គ ច័ន្ទ សុគតទៅ ព្រះអង្គ គ្មានកូនប្រុស សម្រាប់ស្នងរាជ្យទេ ព្រោះព្រះអង្គម្ចាស់ពោធិកំបោរ សុគត តាំងពីអាយុ ៧ ឆ្នាំ [13] ។ ម៉្យាងទៀត សមាជិក រាជវង្សប្រុសៗ ដូចជា អង្គ ដួង អង្គ ឯម ជាដើម សុទ្ធតែនៅ ខាងសៀមទាំងអស់ ហើយដែលយួន មិនអាចទទួលយក ឲ្យធ្វើជាស្តេចបាន។ អង្គ ច័ន្ទ មានតែបុត្រី ៤ អង្គដែលស្ថិតនៅលើទឹកដីដែលយួនកាន់កាប់ (ដំណាក់ស្វាកែត នៅកៀនស្វាយ) គឺព្រះអង្គម្ចាស់ក្សត្រី អង្គ ប៉ែន (ក.១៨០៩-†១៨៤០), អង្គ ពៅ (ក. ១៨២២ -† ?), អង្គ មុី (ក. ១៨១៤-† ១៨៧៨) និង អង្គ ស្ងួន [14] (ក.១៨២៩- †១៨៧៥) ។ ពេលនោះ អធិរាជយួនមានយុទ្ធសាស្ត្រ ២ ដើម្បីយកទឹកដីខ្មែរ។ យុទ្ធសាស្ត្រទី ១ គឺ សម្ព័ន្ធភាព រវាង រាជវង្សខ្មែរ និងរាជវង្សវៀង នៃចក្រភពអណ្ណាម។ បើយុទ្ធសាស្ត្រនេះមិនបានសម្រេចទេនោះ យួនត្រូវបង្ខំចិត្ត ប្រើធម៌ក្តៅតែម្តង។ អធិរាជយួន បានបញ្ជូន ឧត្តមសេនីយ៍ ទ្រឿង មិញ យ៉ាង ឲ្យមករៀបចំ អាពាហ៍ពិពាហ៍ ក្សត្រយួន (ទ្រឿង គុន) ជាមួយព្រះអង្គម្ចាស់ អង្គ ពៅ ។ ប៉ុន្តែ កលល្បិច នេះ ពុំបានសម្រេចឡើយ ព្រោះព្រះអង្គម្ចាស់ក្សត្រី អង្គ ប៉ែន ពុំព្រម។ ទ្រឿង គុន ក៏ត្រឡប់ទៅវិញបាត់ទៅ។ នៅចំពោះមុខបរាជ័យនេះ អធិរាជយួន ក៏ចាត់ឲ្យដាក់ អង្គ មុី ឡើងគ្រង

---

[13] ព្រះអង្គម្ចាស់ពោធិកំបោរ (កើតឆ្នាំ ១៨១៨-†១៨២៥) បានត្រូវបលនាតស៊ូ ប្រឆាំងនឹងបារាំង យកឈ្មោះ មកប្រើ នៅរាជ្យ ហ្វូង នរោត្តម ។

[14] ព្រះអង្គម្ចាស់ក្សត្រី អង្គ ស្ងួន (មាននាមដូច នាមរបស់ ឪពុកមា) ជា ជាយារបស់ព្រះអង្គម្ចាស់ អង្គ ភីម។ លុះ អង្គ ភីម សុគតបាត់ទៅ (១៨២២-១៨៤៨) អង្គស្ងួន បានក្លាយទៅជាជាយា របស់ អង្គ ដួង)។ អង្គស្ងួន ជាបុត្រី របស់ អង្គ ច័ន្ទ ជាមួយ អ្នកម្នាងក្របាន់។



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

រាជ្យ ប៉ុន្តែ ដោយយកអំណាចស្តេចខ្មែរទាំងអស់ មកគ្រប់គ្រងផ្ទាល់ (យោងតាមការស្រាវជ្រាវ របស់ ប្រវត្តិវិទូ ឃីន សុខ : *L'annexion du Cambodge par les vietnamiens au XIX siècle d'après les Deux Poèmes du vénérable Bâtum Baramey Pich ឬ រឿងកំពប់តែអុង*, Khin Sok, Editions You -Feng, Paris, 2002 )។ លោកឃីន សុខ បាននិយាយរៀបរាប់ យ៉ាងពិស្តារ អំពីសំណុំ រឿងនេះ ប៉ុន្តែខ្ញុំសូមលើកឡើងតែចំណុចខ្លះៗប៉ុណ្ណោះ មកបញ្ចូលក្នុងការវិភាគ របស់ ខ្ញុំ។ បើតាមប្រពៃណីអារ្យធម៌ នៃ ប្រទេសកម្ពុជា តាំងពី សម័យដើមមក ស្តេចស្រីពុំអាចឡើងសោយរាជ្យ បានទេ ប៉ុន្តែ អធិរាជយួនមិនខ្វល់ នឹងប្រពៃណីនោះឡើយ។ អង្គ មុី ឡើងគ្រងរាជ្យ នៅឆ្នាំ ១៨៣៥ ដោយមានងារយួនថា «បាក្វាន់ជូ» (ម្ចាស់ នៃ នាម៉ឺនទាំងអស់) ។ រីឯព្រះអង្គម្ចាស់ក្សត្រី អង្គ ពៅ ជាប្អូន បានទទួលនាទី ជាឧបរាជ ហើយ ព្រះអង្គម្ចាស់ក្សត្រី អង្គ ស្ងួន បានទទួលកិត្តិយសក្នុងលំដាប់ថ្នាក់រាជវង្ស ជាកេវហ្វា (បន្ទាប់ពីឧបរាជ)។ ចំពោះ ព្រះអង្គម្ចាស់ក្សត្រី អង្គ ប៉ែន វិញ បន្ទាប់ពីពុំព្រមឲ្យ អង្គ ពៅ រៀបការជាមួយក្សត្រយួន ទ្រឿង គុន ពុំបានទទួលកិត្តិយស និង ងារអ្វីឡើយ។ ម៉្យាងទៀត ម្តាយ របស់ ព្រះអង្គម្ចាស់ អង្គ ប៉ែន គឺ អ្នកម្នាង ទេព ជាបុត្រី របស់ អក្ញាតែ្បស បែន ចៅហ្វាយខេត្របាត់ដំបង ដែលស្តេចសៀមបានតែងតាំងផងទៀត។ នៅសម័យនោះ គឺ ជំនាន់ រជ្ជកាល អធិរាជ យួន មីង ម៉ាង (Ming Mang, ១៨២០-១៨៤១) អំណាចទាំងអស់ បានធ្លាក់មក លើកណ្តាប់ដៃដែករបស់ឧត្តមសេនីយ៍យួន ទ្រឿង មិញ យ៉ាង។ ឧត្តមសេនីយ៍យួននេះ ដែលមានគោលបំណង ប្រែក្លាយស្រុកខ្មែរ ឲ្យទៅជាស្រុកយួន បានកំហិតឲ្យ នាម៉ឺន និង ស្តេចខ្មែរស្លៀកពាក់ តាមរបៀបយួន។ ទ្រឿង មិញ យ៉ាង មិនឲ្យខ្មែរកាន់ពុទ្ធសាសនាទេ ហើយបញ្ជាឲ្យគេកំទេចវត្តអារ៉ាម ចេតិយ ព្រមទាំងកាប់ដើមពោធិ៍ ចោលទាំងអស់។ អ្នកស្នេហាជាតិ ក៏នាំគ្នាងើបឡើងបះបោរដេញយួនចេញ ពីស្រុក។ នៅឆ្នាំ ១៨៣៦ នៅខេត្រកំពង់ស្វាយ នង បានប្រមែប្រមូលខ្មែរឲ្យងើបបះបោរ ប្រឆាំងយួន។ នៅឆ្នាំ

*១៨៣៧ ដូ ចៅហ្វាយខែត្រកំពង់សោម ព្រមទាំងប្អូនឈ្មោះ ជ័យ ពុំព្រមស្តាប់បង្គាប់យួនឡើយ ហើយ បំពាក់អាវុធ អ្នកស្នេហាជាតិខ្មែរ ឲ្យងើបឡើងបះបោរដេញយួន។ នៅចុងឆ្នាំ ១៨៣៩ ទ្រឿង មិញ យ៉ាង បានប្រើកលល្បិចមួយ ដ៏ ពិសពុល គឺ បានសរសេរសំបុត្រមួយទៅព្រះអង្គម្ចាស់ អង្គ ឯម ដែលគង់នៅ ទីក្រុងបាងកក ទូលព្រះអង្គថា អធិរាជក្រុងអណ្ណាម ប្រាថ្នាចង់ដាក់ព្រះអង្គម្ចាស់ អង្គ ឯម ដែលជា បិតុលា របស់ អង្គមុី ឲ្យឡើងគ្រងរាជ្យ តែដោយគ្មាន ស្តេចប្រុស ក៏ដាក់ អង្គ មុី សិនទៅ ។ អង្គ អឹម ក៏ ធ្លាក់ក្នុង ឧបាយកល របស់ ទ្រឿង មិញ យ៉ាង ។ ពេលត្រឡប់មកស្រុកខ្មែរវិញ នារសារ របស់ ទ្រឿង មិញ យ៉ាង បានទៅជួបព្រះអង្គម្ចាស់ អង្គ ដួង នៅ មង្គលបុរី ទៀត ហើយនិយាយប្រាប់អង្គ ដួង ដូច បាននិយាយប្រាប់ អង្គ ឯម ដូច្នេះដែរ ប៉ុន្តែ អង្គ ដួង យល់ភ្លាមថា ជា ឧបាយកល របស់ យួន។ អង្គ ឯម ក៏ ធ្វើដំណើរមកភ្នំពេញ តែ អង្គរក្ស របស់ ព្រះអង្គបានត្រូវ ទ្រឿង គុន សម្លាប់ចោលអស់ រួចក៏ ចាប់ អង្គ ឯម បញ្ជូនទៅទីក្រុងវ៉េ តែម្តង។ ថ្លែងពីព្រះអង្គម្ចាស់ អង្គ ប៉ែន វិញ ដោយដឹងខ្លួនថាស្ថិតនៅក្នុងគ្រោះថ្នាក់ ក៏សរសេរសំបុត្រ ទៅអ្នកម្នាងទេពជាម្តាយដែលស្ថិតនៅទីក្រុងបាងកក។ អ្នកម្នាងទេព បានសុំឲ្យ កែវ ម៉ា ជាប្អូនដែលនៅបាត់ដំបង ទៅជួយរំដោះអង្គ ប៉ែន។ ប៉ុន្តែរឿងនេះបានបែកការ ហើយទាហានយួនក៏ចាប់ អង្គ ប៉ែន ទៅដាក់គុក រីឯ ព្រះអង្គម្ចាស់ក្សត្រី ៣ អង្គទៀត បានត្រូវបញ្ជូនទៅព្រៃនគរ នៅខែកញ្ញាឆ្នាំ ១៨៤០។ នៅក្នុងគុក ដោយទ្រាំ នឹង ទារុណកម្មមិនបាន ព្រះអង្គម្ចាស់ អង្គ ប៉ែន ក៏ក្ស័យជីវិតបាត់ទៅ ហើយ សាកសពត្រូវគេយកទៅបោះចោលក្នុងទន្លេ។ ដោយយួនធ្វើបាបខ្មែរ ខ្លាំងពេកដូច្នេះ អ្នកមុខ អ្នកការ នាម៉ឺនសព្វមុខមន្ត្រី និងប្រជាជនខ្មែរ ក៏ងើបឡើងបះបោរ ។ ទ្រឿង មិញ យ៉ាង បញ្ជូនទ័ពខ្មែរទៅបង្ក្រាប ។ កងទ័ពនោះ ដែលស្ថិតនៅក្រោមបញ្ជាការ របស់ ឧកញ៉ាយោមរាជ ដែលយួន បានយកទៅដាក់គុកនៅកោះត្រឡាច ក៏ ធ្វើដំណើរទៅសំរោងទង ។ កាលបើបានជួបទ័ពអ្នកស្នេហាជាតិខ្មែរ នៅទីនោះ កងទ័ពដឹកនាំដោយឧកញ៉ាយោមរាជ ក៏*





*បែរត្រឡប់ក្រោយវិញ។ គ្មានកងទ័ពយួនណា អាចទប់ទល់ នឹង ការបះបោរ របស់ខ្មែរ បានឡើយ នៅពេលនោះ ។ ទ្រឿង គុន ដែលជាមេបញ្ជាការកងទ័ពយួន ក៏រត់ទៅព្រៃនគរ ប៉ុន្តែ ដោយត្រូវជាប់អន្ទាក់កងទ័ព របស់ ធម្មាប៉ុក ក៏បែរមុខទ័ពឆ្ពោះទៅភ្នំពេញវិញ។ ការប្រយុទ្ធបេះតែប្រព្រឹត្តបន្តទៅទៀត ព្រោះកងទ័ពយួនមានកម្លាំងដ៏ខ្លាំង មហិមា ។ ដោយស្ថិតនៅក្នុងភាពទាល់ច្រក ហើយ ខ្វះអ្នកដឹកនាំ មន្ត្រីខ្មែរពីរនាក់ បានសរសេរសំបុត្រទៅ សុំឲ្យ អង្គ ដួង ដឹកនាំការបះបោរនោះ។ ស្តេចសៀម រាមាទី ៣ ដែលរង់ចាំតែ ឱកាសបែបនេះ ក៏ បញ្ជាឲ្យកងទ័ពដែលដាក់នៅបាត់ដំបង រុលទៅមុខ។ ឧត្តមសេនីយ៍សៀម ប៉ាឌិនតេជៈ ដឹកនាំទ័ពជាមួយ អង្គ ដួង ចូលទៅប្រយុទ្ធ។ ដោយឃើញ អង្គ ដួង មកជាមួយកងទ័ពសៀម ប្រជាជនខ្មែរក៏នាំគ្នាអបអរសាទរ ហើយចូលរួមក្នុងការប្រយុទ្ធ។ ទ័ពសៀមវាយយកពោធិសាត់បាន ហើយ រុលទៅមុខទៀត រហូតដល់ «មាត់ជ្រូក» គឺ កន្លែងដែលយួនឃុំក្សត្រីខ្មែរ អង្គ មុី។ ត្រង់ចំណុចនេះ លោក ឃីន សុខ សរសេរ ដូច្នេះថា «អ្នកនិពន្ធខ្មែរពុំបាននិយាយឲ្យបានច្បាស់ ពី ក្សត្រី អង្គ មុី ដែលបានត្រូវរំដោះ ហើយ ទៅគង់នៅ ទីក្រុងឧដុង្គ នៅឆ្នាំ ១៨៤៧ ទេ។ អ្នកសរសេរឯកសារ តាមការបកស្រាយ របស់ វាំង ជួន គ្រាន់តែប្រាប់ថាស្តេចស្រីអង្គនេះ សុគតនៅទីក្រុងឧដុង្គនៅឆ្នាំ ១៨៧៤ ក្នុងជន្មាយុ៦១ ព្រះវស្សា ដោយគ្រោះរបួសរលាក តែប៉ុណ្ណោះ។ ការពិត ដោយត្រូវគេនិយាយត្មះតេះដៀលពីព្រះអង្គច្រើនពេក ក្សត្រី អង្គ មុី ក៏ធ្លាក់ទៅក្នុងភាពវិកលចរិត។» ។ ខ្ញុំសូមបញ្ជាក់ថា តាមឯកសារ Etat présent de la Maison Royale du Cambodge,* (Edition 1994) *ក្សត្រី អង្គ មុី សុគត នៅឆ្នាំ ១៨៧៨ គឺ ពុំមែន ឆ្នាំ ១៨៧៤ ទេ ។ យើងវិលមកនិយាយពីព្រះអង្គម្ចាស់ អង្គ ដួង បន្តទៅទៀត។ នៅឆ្នាំ ១៨៤៣ បន្ទាប់ពីបាន រំដោះប្រជាជនខ្មែរហើយ អង្គ ឌួង ក៏ស្នើសុំ ឲ្យអធិរាជក្រុងអណ្ណាម ដាក់ទំនាក់ទំនង ពាណិជ្ជកម្ម រវាង ប្រទេស ទាំងពីរឡើងវិញ។ រវាងឆ្នាំ ១៨៤៥ និង ១៨៤៧ ស្រុកខ្មែរ ស្ថិតនៅក្នុងការ ប្រទាញ ប្រទង់ រវាងសៀម និង យួន ដ៏ តានតឹង*

*បំផុត។ នៅឆ្នាំ ១៨៤៥ កងទ័ពយួន បាន បើកការប្រយុទ្ធ នឹង កងទ័ពខ្មែរ នៅក្នុងទ្រង់ទ្រាយ មួយដ៏ធំ។ កងទ័ពខ្មែរ ដកថយ ស៊ើងតែគ្រប់កន្លែង។ បន្ទាប់ពីបានវាយយកត្រើយខាងលិច ទន្លេសាប បាន កងទ័ពយួន ក៏មកតាំងទី នៅភ្នំពេញ កំពង់ហ្លួង ពាមជំនិក និង កំពង់ឆ្នាំង ។ ប៉ុន្តែ ពេលវាយកងទ័ពរបស់ អង្គ ដួង កងទ័ពយួន មិនបានសម្រេច គោលដៅឡើយ ព្រោះ មាន កងទ័ពសៀម ជួយទប់ទល់។ នៅចំពោះមុខ ការប្រទាញប្រទង់ រវាង សៀម និង យួន ព្រះបាទអង្គ ដួង ក៏ស្នើសុំឲ្យ អធិរាជយួនអនុវត្ត មាគ៌ាសន្តិភាព។ ពីពេលមុន ដោយទ័ពយួនមានប្រៀប ទៅលើកងទ័ពថៃ របស់ឧត្តមសេនីយ៍ បាឌិនតេជះ យួនមិនព្រមចរចាទេ។ ប៉ុន្តែបន្ទាប់ពី វាយទម្លុះខ្សែការពាររបស់ ខ្មែរមិនបាន ហើយ ទទួលខាតបង់ ជីវិតទ័ពច្រើនពេក ឧត្តមសេនីយ៍ ខាំ សាយនៃកងទ័ព យួន ក៏យល់ថា ត្រូវតែបញ្ចប់ ការវាយប្រហារ ។ កាលនោះ ខ្សែការពារខ្មែររាយ តាំងពី វិហារសំណ ទៅដល់ ភ្នំឧដុង្គ ហើយ ពីឧដុង្គ ទៅដល់ ពោធិបីដើម តែម្តង។ នៅខែ មករា ឆ្នាំ ១៨៤៦ ការចរចារវាង ឧត្តមសេនីយ៍ បាឌិនតេជះ បានប្រព្រឹត្តទៅ នៅពោធិបីដើម។ រីឯលក្ខខ័ណ្ឌ គឺ ១) យួនត្រូវបញ្ជូនចំណាប់ខ្មែរ មកឲ្យខ្មែរ វិញហើយ ២) ទីក្រុងវ៉េ ត្រូវទទួលស្គាល់ព្រះបាទ អង្គ ដួង ជាមហាក្សត្រខ្មែរ។ នៅថ្ងៃ ២៤ មេសាឆ្នាំ ១៨៤៧ ព្រះចៅក្រុងវ៉េ ធីវ ទ្រី បានបញ្ជាឲ្យទ្រៀង គុន ដោះ លែងព្រះអង្គម្ចាស់ក្សត្រីខ្មែរទាំងបីអង្គ ព្រមទាំងអ្នកបម្រើ។ នៅក្នុងចំណោមចំណាប់ខ្មែរដែលមកដល់ទីក្រុងឧដុង្គ គេឃើញ ព្រះអង្គម្ចាស់ អង្គ ភីម ដែរ (យោងតាម ឃីន សុខ, L’annexion du Cambodge par les vietnamiens au XIX siècle d’après les Deux Poèmes du vénérable Bâtum Baramey Pich ឬ រឿងកំពប់តែអុង,* Khin Sok, op. cit., p. 88, Editions You-Feng, Paris, 2002 ) *គឺ បុត្រ របស់ អង្គ ឯម ដែលសុគតនៅស្រុកយួន។*

# ទំនៀមទម្លាប់ខ្មែរ និង អភិក្រម ទំនើបកម្ម

**(Moeurs et coutumes khmères et processus de modernisation)**





# ជំពូក ២

# វត្តមានបារាំង នៅស្រុកខ្មែរ

## La présence française au Cambodge

*កាលសម័យ ស្តេច អង្គ ដួង ស្រុកខ្មែរ ចុះដុនដាប សឹងតែ រលត់រលាយ ។ សង្គ្រាម និង ការចូលលុកលុយពីប្រទេសជិតខាង អស់ជាងប្រាំសតវត្សរ៍កន្លងមក បានធ្វើឲ្យខ្មែរបាត់បង់ថាមពល និងបាក់ទឹកចិត្តយ៉ាងខ្លាំង។ មុនពេលស្តេច អង្គ ដួង ឡើងសោយរាជ្យ គឺ នៅក្នុងរាជ្យក្សត្រ បីអង្គ អង្គ អេង, អង្គ ចន្ទ និង អង្គ មី ស្រុកខ្មែរបាត់អធិបតេយ្យ របស់ខ្លួន នៅក្នុងកម្រិតមួយ ដ៏ខ្ពស់បំផុត ជាពិសេសក្នុងរាជ្យក្សត្រី អង្គ មី ដែលយួនបានបន្តុបឲ្យធ្វើស្តេច ដើម្បីស្រួលយកស្រុកខ្មែរទាំងមូលធ្វើជាខែត្រយួនដោយមិនបាច់ប្រយុទ្ធ។ នៅទសវត្សរ៍ ១៨៤០ ចំនួនប្រជាជនចុះថយគួរឲ្យកត់សំគាល់ គឺនៅសល់តែជាងមួយលាននាក់ ប៉ុណ្ណោះ ។ គ្រួសារភាគច្រើន ទាំងរាជវង្ស ទាំងរាស្ត្រ ខ្ចាត់ព្រាត់បែកបាក់គ្នាអស់។ ខ្លះស្លាប់ដោយសង្គ្រាម ហើយខ្លះទៀតត្រូវប្រទេសជិតខាង កេណ្ឌយកទៅធ្វើ ជាឈ្លើយឬទៅធ្វើការជាទម្ងន់នៅស្រុកគេ។ ក្សត្រខ្មែរត្រូវយួនចាប់យកទៅដាក់គុក ធ្វើទារុណកម្មយ៉ាងខ្លោចផ្សា។ ខ្លះក្ស័យជីវិត ឬ ក៏ធ្លាក់ទៅក្នុងភាពវិកលចរិត ដោយគេធ្វើបាបខ្លាំងពេក។ ទាល់តែមកដល់រាជ្យហ្លួង ស៊ីសុវត្ថិ ទើបគេបានដឹងថា ចំនួនប្រជាជន បានកើនមកដល់ ២*

លាននាក់ គឺ ១ លាន ៥ សែន នៅក្នុងស្រុក ២៥ ម៉ឺន នៅ កូសាំងស៊ីន ហើយ ២៥ ម៉ឺនទៀត នៅទ្រសាសៀម (*Notes cambodgiennes, Au coeur du pays khmer*, Dr Pannetier, Paris, Payot, 1921. Rééd. Cedoreck, Paris, 1983, op. cit. p. 13) ។ លទ្ធិពុទ្ធសាសនា នៅពេលនោះ មានឥទ្ធិពលយ៉ាងខ្លាំង ទៅលើប្រជាជនខ្មែរ ទន្ទឹម នឹង ជំនឿទៅលើ អារក្ខអ្នកតា (អាន : *Le cultes des génies protecteurs au Cambodge*, Alain Forest, Paris, l'Harmattan, 1992, អាន: ប្រជុំរឿងព្រេងខ្មែរ ភាគ ៨ – Editions de l'Asie du Sud-Est, Paris , 1982)។ សកម្មភាពផ្នែកពាណិជ្ជកម្ម មានតែបន្តិចបន្តួចប៉ុណ្ណោះ តាមរយៈការដោះដូរទំនិញ ដូចជា ស្បែក ស្នែង ភ្លុក ម្រ័ក្សណ៍ ជាដើម ។ ប្រជាជនស្រទាប់ក្រោម មិនដែលមាន ភ័ព្វសំណាង បានចាយប្រាក់សំណប៉ាហាំង ដែលធ្វើនៅស្រុកយួនសោះឡើយ ។ មាសបន្តិចបន្តួច ដែលមាននៅក្នុងនគរ ជា គ្រឿងអលង្ការ ដែលជាកម្មសិទ្ធិ របស់ប្រពន្ធនាម៉ឺន ឬ ក៏ត្រូវគេយកទៅធ្វើជាក្បាក់ដាក់ស្នាម្ជូ តែប៉ុណ្ណោះ។ វត្តអារ៉ាមដែលជា មណ្ឌលវប្បធម៌ ផ្ទះសម្បែង ដ៏ល្អៗ ព្រមទាំងដើមឈើដែលធ្លាប់តែឲ្យផ្លែ និង ដើមត្នោត បានត្រូវកងទ័ពឈ្លានពាន ដុតបំផ្លាញអស់សឹងតែគ្មានសល់។ មិនតែប៉ុណ្ណោះ ស្ត្រីភេទបានត្រូវពួកទាំងនោះ រំលោភយ៉ាងព្រៃផ្សៃ ជាហេតុនាំឲ្យមានការអស់សង្ឃឹម នៅក្នុងគ្រួសារ និង ធ្វើឲ្យម្នាក់ៗ មើលឃើញអនាគតរបស់គេ ពោរពេញទៅដោយភាពអាប់អួ។

ខាងផ្នែក អក្សរសាស្ត្រ ក្រៅពី គម្ពីរពុទ្ធសាសនា ព្រះសង្ឃ តាមវត្តអារ៉ាម រក្សាទុកបាន នូវ ឯកសារប្រវត្តិសាស្ត្រខ្លះៗ និង វណ្ណកម្ម អក្សរសិល្ប៍ មួយចំនួន ដែលនៅសល់ ពីពេលមុនៗ ដូចជា ៖ សិលាចារឹកអង្គរវត្ត របស់ បណ្ឌិត ជ័យនន្ទ (សតវត្សរ៍ ទី ១៦) ល្បើកអង្គរ របស់ អ្នកប៉ាង (១៥៩៨ ) សារសើរហេមន្ត , កាព្យនិរាស, ច្បាប់ព្រះរាជសម្ភារ បទនិពន្ធ របស់ ព្រះរាជសម្ភារ (១៦៣៤) រឿងក្រុងសុភមិត្រ (១៧៧៨) របស់ឧកញ៉ា កោសាធិបតីកៅ ច្បាប់សុភាសិត (១៧៩០)





លោកនេយ្យជាតក (១៧៩៤) រឿងបុញ្ញសារសិរសា ( ១៧៩៨) រឿងភោគកុលកុមារ (១៨០៤) រឿងវរនេត្រវរនុជ (១៨០៦) រឿងព្រះសមុទ្រ (១៨០៨) របស់ ឧកញ៉ា ព្រះឃ្លាំងនង រឿងវេបាក្សត្រ (១៨១៨) របស់ បទុមបារមីពេជ្រ ល្បើកជេតពន (១៨១៣) របស់ ឧកញ៉ាសោទស ខែក រឿងមុជលិន (១៨៣៣) របស់ បណ្ឌិតសំអាត; រឿងដាវរឿង (១៧៤១) របស់ ឧកញ៉ាចក្រី កែវ ជាដើម។ នៅឆ្នាំ ១៨១៣ ក្សត្រ អង្គ ដួង ទ្រង់បាននិពន្ធ រឿងនាងកាកី ។ នៅចុងរាជ្យព្រះបាទ អង្គ ឌួង មានវណ្ណកម្ម អក្សរសិល្ប៍ជាច្រើនទៀត ដូចជា ៖រឿងព្រះជិនវង្ស (១៨៥៦) របស់ អារិយគាមុនី ហ៊ីង, រឿងពេជតា (១៨៥៧) របស់ ធម្មបញ្ញា ម៉ែន, រឿងវិមានចន្ទ (១៨៥៨) របស់ឧកញ៉ាធិបតី យ៉ែម, ល្បើកស្រីវិជ័យ (១៨៥៨ ) របស់ ពញាវិជិត្រស្រី, រឿងទេវន្ទ និង ល្បើកចចក (១៨៥៩) របស់ ឧកញ៉ា សន្ធរ ម៉ុក។ មានរឿងប្រជាប្រិយ ជាច្រើនទៀត ដែលខ្ញុំ មិនអាចលើកឡើង បានទាំងអស់ទេ ដូចជា រឿងទឹកភ្លៅភាំ, រឿងហង្សយន្ត ជាដើម ដែលគ្មានកាលបរិច្ឆេទច្បាស់លាស់។

នៅពេលដែល បារាំងចូលមកដល់ស្រុកខ្មែរជាផ្លូវការ បាន ១៤ ឆ្នាំ វណ្ណកម្ម អក្សរសិល្ប៍ ក៏ចេះតែមានជាហូរហែ បន្តមកទៀត។ រី ឯ មូលបទ ពុំមានអ្វី ក្រៅពីរឿងកម្មផល តាមទស្សនៈ ពុទ្ធនិយម ប៉ុន្មានដែរ ជាពិសេស រឿងទាក់ទង នឹងតួអង្គ ពោធិសត្វ ដែលមាននៅក្នុងទស្សនៈ ពុទ្ធនិយម មហាយាន។ ក្រៅពីនោះ គេជឿទៅលើ មន្តអាគមគាថា សិល្បសាស្ត្រ ផ្សេងៗ ដូចជា យន្ត្រ និង មន្ត្រគាថា ជាដើម (*La guirlande de joyaux* ឬ ឥតិបិសោរតនមាលា, François Bizot / O. von Hinüber, Ecole française d'Extrême-Orient, 1994 ) សម្រាប់ការពារខ្លួន ឬប្រែក្លាយខ្លួនឲ្យទៅជាអ្នកខ្លាំងពូកែ។ តាមការពិត មិនមែនតែទស្សនវិជ្ជាពុទ្ធនិយមប៉ុណ្ណោះទេដែលមានឥទ្ធិពលទៅលើជីវិតប្រចាំថ្ងៃ ឬ ទៅលើការប្រកបមុខរបរ។ ទន្ទឹម នឹងរឿងរាមកេរ្តិ៍ ប្រជាប្រិយ តាមបែបបទនិទាន របស់ តាចក់ (រឿងរាមកេរ្តិ៍ នៃ តាចក់ ដកស្រង់ដោយហ្វ្រង់ស្វា ប៊ីហ្សូត៍) ជាពិសេស រឿងព្រេង

បុរាណខ្មែរដែលមិនមែន ជារឿង កម្មផលពុទ្ធនិយម (ដូចជា *រឿងធនជ័យ*, *រឿងអាឡេវ*) ក៏បានត្រូវសាធារណជន និយមចូលចិត្តដែរ។  មេដឹកនាំ ចលនា បះបោរ តួយ៉ាង *ពោធិកំបោរ* ព្រមទាំង អាចារ្យៗ ដែលមានឈ្មោះល្បី នៅក្នុងទំព័រប្រវត្តិសាស្ត្រខ្មែរ សុទ្ធតែជាអ្នកដែលចេះ វិជ្ជាមន្តអាគមគាថាទាំងនេះ ។ ទាល់តែមកដល់ទសវត្សរ៍ ១៩៣០ ទើបការ វិភាគ អំពី សង្គម ចាប់ផ្តើមមាន តាមរយៈប្រលោមលោក សម័យទំនើប របស់ លោក រីម គីន (*រឿងសូផាត*) ឬ របស់ លោក នូ ហាច (*ផ្កាស្រពោន* ) ឬ របស់ លោក សាស្ត្រាចារ្យ ញ៉ុក ថែម (*កុលាប ប៉ៃលិន* ) ជាដើម។

មុន នឹងឈានទៅ ដល់ ប្រលោមលោក ផ្នែកសង្គមទាំងនោះ ពី ឆ្នាំ ១៨៧៧ មកដល់ ឆ្នាំ ១៩៣៦ មូលបទ កម្មផល តាមទស្សនៈពុទ្ធនិយម ចេះតែមានបន្តមកទៀតមិនដាច់ឡើយ ប៉ុន្តែ ការដោះស្រាយបញ្ហាជីវិត និងជំបូន្មានប្រាកដនិយម តាមទស្សនៈលោកិយសច្ចៈ ក៏មានចូលលាយឡំដែរ។ ឥទ្ធិពលនៃវប្បធម៌បារាំង ពុំទាន់ចូលមកក្នុងរបៀបគិតពិចារណារបស់ខ្មែរទេនៅសម័យនោះព្រោះមួយចំណែកបារាំងគ្មានថវិកាច្បាស់លាស់ សម្រាប់ធ្វើកិច្ចការនេះ ហើយមួយចំណែកទៀត ខ្មែរនៅតែបញ្ជូនកូនទៅឲ្យរៀន នៅសាលាវត្តបន្តមកទៀត។ ការរៀន ភាសាបារាំង មានបន្តិចបន្តួចតាំង ពីឆ្នាំ ១៨៧៣ មក ប៉ុន្តែ ទាល់តែមកដល់ឆ្នាំ ១៩០៣ ទើប ហ្វូងនរោត្តម បើកសាលា បារាំង-ខ្មែរ បី មួយនៅភ្នំពេញ (*សាលានរោត្តម* ) ហើយ ២ ទៀត នៅតាមខេត្ត គឺ កំពង់ចាមមួយ ពោធិសាត់មួយ (យោងតាម អាឡាំង ហ្វូរ៉េស្ត : *Le Cambodge et la colonisation française*, Paris, L'Harmattan, 1980, , p. 152)។ នៅចន្លោះឆ្នាំ ១៩០៥-១៩០៧ សាលាបារាំងខ្មែរ បានឡើងទៅ ដល់ចំនួន ១៨។ ពីឆ្នាំ ១៩០៨ មក សាលាបារាំង មានទាំងអស់បី នៅទីក្រុងភ្នំពេញ  (សាលានរោត្តម, សាលា ឌូដា ដឺ ឡាគ្រេ, សាលា ហ្វ្រង់ស៊ី ហ្គារញេ) ។ នៅឆ្នាំ ១៩១១ សាលា បារាំង-ខ្មែរឯកជន  ក៏មានដែរ គឺ សាលាសត្ថារត និង សាលា ម៉ាលីកា។





ពីឆ្នាំ ១៩១៥ មក ឆ្នាំ ១៩២១ ចំនួន សិស្សប្រុសដែលចូលរៀនសាលាបារាំង មាន ពី ២២១៣ នាក់ មក ៥៣៥១ នាក់។ ចំនួនសិស្សស្រី មាន ពី ៤០០ នាក់ មក ៤៩៥ នាក់ ។ ចាប់តាំងពីឆ្នាំ ១៩១៦ មក សាលាវត្ត ពុំមានបន្តមកទៀតឡើយ។ នៅឆ្នាំ ១៩១៤ បារាំងបានបង្កើតសាលារដ្ឋបាលមួយ គឺ សាលាក្រមការ។ ពី ឆ្នាំ ១៨៧៧ មក មានស្នាដៃ អក្សរសិល្ប៍ ជាច្រើនទៀត ៖ *រឿងមរណមាតា*  (១៨៧៧) របស់ ធម្មបញ្ញា អ៊ុក, *រឿងពោធិវង្ស* (១៨៨១) របស់ ព្រហ្មបរកក្តី, *រឿងចៅមាស* (១៨៨៧) របស់ ឃុនសន្ធរពិនិត្យ, *រឿងសព្វសិទ្ធិ* (១៨៩៩) របស់ ម៉ឺនភក្តីអក្សរតេន, *រឿងសន្ធសិល្បជ័យ* (១៨៨២) របស់ឧកញ៉ា វង្សាធិបតី អ៊ុក, *រឿងព្រះលក្ខណវង្ស* (១៨៩០) រៀបរៀងដោយចៅអធិការ វត្ត ព្រែកប្រណាក, *រឿងអំបែងបែក* (១៨៨៩) *គតិលោក* (១៩២០) និង*កាពនិពាសអក្សរ* (១៩២៦ ) របស់ ឧកញ៉ា សុត្តន្តប្រីជាឥន្ទ (កើតឆ្នាំ ១៨៥៩-†១៩២៤), *រឿងពិម្ពាពិលាប* (១៩២០) របស់អ្នកស្រីសីទ្ធិ (កើតឆ្នាំ ១៨៨១ -†១៩៦៣), *រឿង ពិម្ពានិពា្វន* (១៩២០) និង *រឿងទាវឯក* (១៩៤២) របស់ លោក វិបុល កន (កើត ឆ្នាំ ១៨៧៤ -† ១៩៤៧), *រឿងបិសាចស្នេហា* (១៩៤០) និង *រឿងកុលាបប៉ៃលិន* (១៩៣៦) របស់លោក ញ៉ុក ថែម (កើតឆ្នាំ ១៩០៣ -† ១៩៧៤), *រឿងសោកសោមបណ្ឌិត* (១៩៣៣) និង *រឿងទឹកទន្លេសាប* (១៩៤១) របស់ គឹម ហាក់ (កើត ឆ្នាំ ១៩១០-† ?), *រឿងសូផាត* (១៩៣៨) របស់លោក រីម គីន (កើតឆ្នាំ ១៩១១ -†១៩៥៩ ) ។

រឿងកម្មផល ដូចជារឿង *មរណមាតា* ជាដើម ជារឿងកំសត់បែកបាក់ព្រាត់ប្រាសគ្រួសារ ព្រោះតែមាន មនុស្សចិត្តអាក្រក់ ឥតធម៌មេត្តា តាមព្យាបាទ។ ភាគច្រើន នៃរឿងទាំងនោះ តែងតែលើកឡើងពីអន្តរាគមន៍ របស់ ព្រះឥន្ទ្រាធិរាជ នៅពេលដែលតួអង្គស្ថិតនៅក្នុងភាពទាល់ច្រក។ តួអង្គខ្លះស្លាប់ តែត្រូវព្រះឥន្ទ្រ ប្រោសឲ្យរស់ឡើងវិញ។ នៅក្នុងអារម្មណ៍របស់ប្រជាជនខ្មែរ មិនថា រាស្ត្រសាមញ្ញ ឬ ស្តេចទេ គេជឿថាព្រះអាទិទេព ជាអ្នកកំណត់ជោគវាសនា លោកយើងនេះ ព្រម

ទាំងបុគ្គលម្នាក់ៗទៀតផង។ ហេតុដូច្នេះហើយ បានជាស្តេចសម័យអង្គរ ក៏ដូច ជាស្តេចសម័យក្រោយៗ មកទៀតដែរ តែងតែតាំងខ្លួនគេ ជាអ្នកតំណាងពពួកទេវទាំងនោះ។ ម្ល៉ោះហើយ ប្រជាជនខ្មែរ តែងតែ ផ្អែកវាសនា ខ្លួនគេម្នាក់ៗ ទៅលើពពួកទេវ ទាំងឡាយនោះ ហើយកត់សំគាល់ថាសុទ្ធតែជាអ្នកដែលមានបុណ្យបារមីគ្រប់គ្រាន់ដើម្បីការពារស្រុកទេស និង ខ្លួនគេម្នាក់ៗ ផ្ទាល់ផងដែរ ។ នេះជាឱកាសមួយ ដ៏ល្អ សម្រាប់អ្នកកាន់អំណាចផ្តាច់ការ។ បើជួយពុំរួចទេ គេអះអាងថា មកពីបានទទួលកម្មក្រាស់ពេក ពីជាតិមុនៗ ហើយគេមិនត្រូវលើកតម្កើង ពួក «ពលព្រះ» ទាំងឡាយនោះផងទៀត។ បើមិនគោរពគោលការណ៍នេះទេ គឺ ជា ការខុសឆ្គងមួយ ដ៏ធំ ។ ការពិត មិនមែនតែប្រជាជនខ្មែរប៉ុណ្ណោះទេ ដែលមានជំនឿបែបនេះ។ នៅអឺរ៉ុប សម័យយុគកណ្តាល ក៏ដូចជាសម័យក្រោយៗ មកទៀតដែរ គេតែងតែជឿ ទៅលើ អន្តាគមន៍ របស់ ព្រះដែលគេសន្មតថា ជាអ្នកបង្កើតពិភពលោក។ ប៉ុន្តែ តាំងពីសតវត្សរ៍ ទី ១៨ មក ទស្សនវិទូបារាំង បានខិតខំពន្យល់ហេតុផលតាមក្រឹត្យក្រម រូបធាតុនិយម (conception matérialiste du monde) រហូត ដល់បានសម្រេច ។ គេពន្យល់ថា សោកនាដ្យកម្ម ផ្សេងៗ របស់មនុស្សបណ្តាល មកតែពី អំពើ ពី ចិត្តគំនិត របស់ មនុស្សតែប៉ុណ្ណោះ។ ព្រះពុទ្ធ ក៏ បានពន្យល់ពីហេតុផលតាមបែបបទ រូបធាតុនិយមទាំងនេះដែរ (ទ្រឹស្តីបដិច្ចសមុប្បាទ) ប៉ុន្តែ ការបកស្រាយខ្លះ ឈានទៅដល់ បរមត្ថភព ទៀតផងរ។ ប៉ុន្តែទន្ទឹមនោះ រឿងព្រេងបុរាណខ្មែរ ភាគច្រើន ក៏តែងតែលើកឡើងអំពី ក្រឹត្យក្រមលោកិយសច្ចៈដែរ។ ហេតុដូច្នេះ ហើយ បានជាខ្មែរខ្លះ បកស្រាយ លទ្ធិពុទ្ធនិយម នៅក្នុងក្របខ័ណ្ឌមួយដែលមានលក្ខណៈវិជ្ជមានបំផុត។ ទោះជាយ៉ាងណាក្តីខ្មែរយើងយល់យ៉ាងច្បាស់អំពីក្រឹត្យក្រម «កើត ចាស់ ឈឺស្លាប់»។ ដើម្បីផ្តាច់ចំណងទាំងប្រាំប្រការ ខ្មែរនាំគ្នាចូលបួសធ្វើធម៌អាថ៌ ហើយប្រគល់កិច្ចការរដ្ឋ ទៅឲ្យពួកអ្នកតំណាងព្រះអាទិទេព តែម្តង។ ខ្មែរគ្រប់រូប ស្គាល់រឿង ព្រះវេសន្តរជាតក គ្រប់ៗគ្នា ប៉ុន្តែ ដូចព្រះវេសន្តរ





ដូច្នេះដែរ ពុំអាចផ្តាច់ ចំណងទាំងប្រាំប្រការនោះ បានឡើយ។ បញ្ញវន្តខ្មែរជំនាន់ក្រោយ ដែលបានរៀននៅសាលាបារាំង-ខ្មែរ ឬ នៅស្រុកបារាំងតែម្តង បានប្តូរទស្សនៈ នេះបន្តិចម្តងៗ ទោះគេជាអ្នកកាន់ពុទ្ធសាសនាក្តី។ គេច្រើននាំគ្នាផ្អែកការរកសច្ចៈភាព តាមតថភាពជាក់ស្តែង (faits et réalités) និង តាមបែបបទពិចារណា របស់ ទស្សនវិទូ ដេកាត (Descartes) ។ តាមរយៈ រឿង *សូផាត* របស់ លោក រឹម គីន និង *ផ្កាស្រពោន* របស់ លោក នូ ហាច គេសង្កេតឃើញថា ការពិចារណា និងការវិភាគ ឃ្លាតឆ្ងាយបន្តិច ពី ទស្សនៈប្រពៃណី គឺ បែរទៅ រកទស្សនៈមួយថ្មីទៀតដែលស្របនឹង ការវិវត្តន៍ របស់ពិភពលោក ។ ប៉ុន្តែ ទន្ទឹមនោះ ទស្សនៈអ្នកអភិរក្ស ក៏ មិនផុតរលត់ដែរ ជាហេតុបណ្តាលឲ្យមានបដិវាទកម្មមួយ ដ៏ ចម្បង ហើយ ដែលជាទំនាស់មួយជាមូលដ្ឋាន នៅក្នុងសង្គមខ្មែរ ដូចនៅក្នុង វិស័យ នយោបាយដូច្នេះដែរ។ នៅពេលនោះ គេសង្កេតឃើញមានការវិវត្តន៍មួយ ដ៏ សំខាន់ នៅក្នុងជីវិត របស់បញ្ញវន្តខ្មែរ។ អនក្ខរជនចុះថយមិនច្រើនប៉ុន្មានទេ ជាពិសេសនៅក្នុងចំណោមនារី ព្រោះគ្រួសារខ្មែរមួយចំនួនចង់រក្សាប្រពៃណីដើម ហើយមិនសូវហ៊ានឲ្យកូនស្រីទៅរៀននៅសាលា។ នៅឆ្នាំ ១៩៦២ សិស្សដែលរៀនមបឋមសិក្សាចប់មានចំនួន ៨ ម៉ឺន ៥ ពាន់ នាក់ (៨. ៥០០០) ប៉ុណ្ណោះ។ សិស្សរៀនមធ្យមសិក្សាចប់ មានចំនួន ១ ម៉ឺន ៦ ពាន់ ១០០ នាក់ ហើយនិស្សិតឧត្តមសិក្សាដែល មានសញ្ញាប័ត្រ ពេលចេញពីមហាវិទ្យាល័យ មានប្រមាណ ៣០០ នាក់ ប៉ុណ្ណោះ។

## រជ្ជកាល ហ្លួងនរោត្តម (១៨៦០-១៩០៤)
## Sous le règne de Norodom (1860-1904)

វត្តមាន បារាំង នៅប្រទេសកម្ពុជា ចាប់ផ្តើម ជាផ្លូវការ នៅថ្ងៃ ១១ សីហា ឆ្នាំ១៨៦៣ ។ កាលនោះ គឺ សម័យ ហ្លួងនរោត្តម បារាំង បានបញ្ចុះបញ្ចូល ឲ្យស្តេច

ខ្មែរអង្គនេះ ចុះហត្ថលេខា ទៅលើ សន្ធិសញ្ញាមួយ ដែលមានឈ្មោះ ថា សន្ធិសញ្ញា «អាណាព្យាបាលបារាំង» ។ តាមការពិត ទំនាក់ទំនងរវាងបារាំង និង ខ្មែរ មាន តាំងពីឆ្នាំ ១៨៥៥ មក គឺ ២ ឆ្នាំ ក្រោយពេល ដែលព្រះមហាក្សត្រ ខ្មែរ ព្រះបាទអង្គឌួង បានផ្ញើសារលិខិតមួយ ចុះថ្ងៃ ១៤ មិថុនាឆ្នាំ ១៨៥៣ ទៅ ព្រះចៅអធិរាជបារាំង ណាប៉ូឡេអុង ទី៣ ស្នើសុំឲ្យ មកជួយ ធ្វើអន្តរាគមន៍ រំដោះប្រទេស កម្ពុជា ចេញពីការប្រទាញប្រទង់ រវាងប្រទេស សៀម និងប្រទេសវៀតណាម ។ នៅឆ្នាំ ១៨៥៥ ដីម៉ុងទីញី ភារធារីបារាំង ទទួលបន្ទុក កិច្ចការពាណិជ្ជកម្ម នៅប្រទេសសៀម និង សីង្ហបុរី បាន ទទួលបញ្ជា ពីទីក្រុងប៉ារីស៍ ឲ្យចុះហត្ថលេខា ជាមួយខ្មែរ ទៅលើ សន្ធិសញ្ញាមួយ រួចមកហើយដែរ តែជាសន្ធិសញ្ញាពាណិជ្ជកម្ម និង សម្ព័ន្ធភាពប៉ុណ្ណោះ។ ទាល់តែប្រាំបី ឆ្នាំក្រោយពីនេះ ទើបបារាំង ប្រកាសចូលជាផ្លូវការ មកស្រុកខ្មែរ គឺមួយឆ្នាំ ក្រោយពេលដែលបារាំង បានចូលមកកាន់កាប់ទឹកដី កូសាំងស៊ីន តាមរយៈសន្ធិសញ្ញា ចុះថ្ងៃ ទី ៥ មិថុនា ឆ្នាំ ១៨៦២។ នៅ ខែកក្កដា ឆ្នាំ ១៨៦៣ ឧត្តមនាវីបារាំង ដឺ ឡាក្រង់ឌីយែរ៍ ធ្វើដំណើរមក ទីក្រុងឧដុង្គដើម្បី បញ្ចុះបញ្ចូល ឲ្យស្តេចខ្មែរនរោត្តម រំដោះប្រទេសកម្ពុជា ឲ្យចេញផុតពីការរំលោភ អធិបតេយ្យ ពី សំណាក់ប្រទេសសៀម។ ស្តេច នរោត្តម មានការអល់អែកយ៉ាងខ្លាំង ព្រោះណាមួយ ខ្លាចស្តេចសៀម ធ្វើទុក្ខបុកម្នេញ ណាមួយខ្លាចបារាំង ការពារស្រុកខ្មែរមិនបាន ហើយបណ្តោយឲ្យប្រទេសវៀតណាម លេបទឹកដី ។ ព្រះអង្គទ្រង់ឈ្វេងយល់ថា ការដែលព្រះបិតា របស់ ព្រះអង្គ តែងតែសង្ឃឹមទៅលើអន្តរាគមន៍ របស់ បារាំង ដើម្បីរំដោះប្រទេសឲ្យផុត ពីការ បែងចែកទឹកដីខ្មែររវាងសៀម និងយួន ក៏ ជាមធ្យោបាយមួយដែរ ។ ប៉ុន្តែ កាលពេលនោះ បារាំង មិនទាន់ធ្វើអាណានិគមកិច្ច ប្រទេសវៀតណាមនៅឡើយទេ ។ រីឯ នៅ ឆ្នាំ ១៨៦៣ ស្ថានភាព ខុសពីពេលមុន គឺថា បើគ្មានបង្អែកពីសៀមទេនោះយួន អាចនឹងយកទឹកដីខ្មែរបានដោយស្រួល តាមរយៈបារាំង។ ម្យ៉ាងទៀត បារាំង ក៏មាន គោលដៅ ផ្តាច់ឥទ្ធិពលសៀមចេញ ពី តំបន់ដែលគេបម្រុង





វាតទីដែរ ពោលគឺ ស្រុកខ្មែរនេះឯង។ នៅក្នុងន័យនេះ បារាំង អាចយកស្រុកខ្មែរទៅបញ្ចូល ជាមួយយួន តែម្តង។ ទោះជាយ៉ាងនេះក្តី នៅទីបំផុត នៅថ្ងៃ ១១ សីហា ឆ្នាំ ១៨៦៣ ឡាក្រង់ឌីយែរ បានសម្រេច ផែនការនេះ ដូចគោលបំណងមែន។ ពេលដែលឡាក្រង់ឌីយែរ មកដល់ទីក្រុងឧដុង្គ លើកទី ១ នៅខែកក្កដាឆ្នាំ ១៨៦៣ ដដែលនោះ គឺ ជាង ១ ឆ្នាំ ក្រោយលោក ឌូដា ដឺ ឡាគ្រេ (ខែ មេសា ឆ្នាំ ១៨៦២) ទេសាភិបាលបារាំង ឡាក្រង់ឌីយែរ មានគោលដៅមួយរួចជាស្រេច គឺ មិនឲ្យស្រុកខ្មែរធ្លាក់ទៅក្នុងរង្វង់ឥទ្ធិពលសៀមជាដាច់ខាតដោយហេតុថា នៅពេលនោះ ប្រទេសអង់គ្លេសដែលជាគូប្រជែង របស់គេ បានដាក់ទីតាំងរបស់គេ នៅស្រុកសៀម ហើយ បម្រុងនឹង ពង្រីកឥទ្ធិពល របស់គេ នៅផ្នែកអាគ្នេយ៍ទៀត ។ នេះជារឿងមួយ ដ៏ សំខាន់ចំពោះ បារាំង ។ យោងទៅតាម សន្ធិសញ្ញា ថ្ងៃ ១១ សីហា ឆ្នាំ ១៨៦៣ នោះដែលមានជាច្រើនប្រការ រាជាណាចក្រខ្មែរ ត្រូវប្រគល់សិទ្ធិសេរីភាព របស់ ខ្លួនជាច្រើនទៅឲ្យបារាំង។ ខាងបារាំងវិញ គេ ក៏ត្រូវមាន ភារកិច្ច ការពារស្រុកខ្មែរ កុំឲ្យប្រទេសក្រៅ ឈ្លានពានដែរ។  ប៉ុន្តែ សន្ធិសញ្ញានោះ ក៏ បានចែងផងដែរ មិនឲ្យស្តេចខ្មែរ ដាក់ ការទាក់ទង របស់ ខ្លួន ជាមួយប្រទេសណា ទៀតទេ បើគ្មាន ការយល់ព្រម ពី បារាំង។ ដើម្បីអនុវត្ត សន្ធិសញ្ញានេះ បារាំងដាក់រ៉េស៊ីដង់ម្នាក់ ឲ្យនៅប្រចាំការ នៅប្រទេសកម្ពុជា ហើយប្រទេសកម្ពុជា ត្រូវដាក់ អ្នកតំណាង របស់ខ្លួនម្នាក់ នៅ សាយហ្គន។ បន្ទាប់ពីបាន ចុះហត្ថលេខា ទៅលើ សន្ធិសញ្ញានេះ ស្តេចនរោត្តម មានការបារម្ភយ៉ាងខ្លាំង ដោយហេតុថា ព្រះចៅអធិរាជបារាំង ណាប៉ូឡេអុងទី ៣ ពុំទាន់ឲ្យសច្ចាប័ននៅឡើយ ។ ស្តេចខ្មែររង់ចាំ អស់រយៈពេល ជាង ២ ខែហើយនៅថ្ងៃ ១ ធ្នូ ឆ្នាំដដែលនោះ ដោយ អស់សង្ឃឹមថា បារាំងអាច នឹងជួយបានព្រះអង្គ ក៏ សម្រេចចុះហត្ថលេខា ទៅ លើសន្ធិសញ្ញា ជាមួយ សៀមវិញ ។ សន្ធិសញ្ញានោះ ទទួលស្គាល់អាជ្ញា នៃ ប្រទេសសៀមទៅលើប្រទេសកម្ពុជា។ ប៉ុន្តែក្រោយមក នៅខែមិនាឆ្នាំ ១៨៦៤ ព្រះចៅណាប៉ូឡេអុងទី ៣ ក៏ព្រមឲ្យ សច្ចាប័ន

ទៅលើសន្ធិសញ្ញា អាណាព្យាបាលបារាំង ។ នៅក្នុងស្ថានភាព ប្រទាញប្រទង់ បែបនេះ ស្តេចនរោត្តម ពុំអាចបែរខ្នងដាក់សៀមបានឡើយ ។ ពេលរាជាភិសេក ហ្លួងនរោត្តម ជាផ្លូវការនៅថ្ងៃ ទី៣ មិថុនាឆ្នាំ ១៨៦៤ វត្តមាន របស់ អ្នកតំណាងបារាំងមិនគ្រប់គ្រាន់ទេ គឺ ត្រូវមាន អ្នកតំណាងសៀម ផងដែរ ។ បារាំងបានបង្ខំ ឲ្យហ្លួងនរោត្តម បោះបង់សៀមចោល ប៉ុន្តែ ក្សត្រខ្មែរអង្គនេះ ពុំហ៊ានទ។ ទាល់តែ ៣ ឆ្នាំក្រោយមក តាមរយៈសន្ធិសញ្ញា ជាមួយសៀម ចុះ ថ្ងៃ ១៥ កក្កដា ឆ្នាំ ១៨៦៧ ទើបបារាំង បង្ខំឲ្យសៀម បោះបង់ចោលមហិច្ឆតា របស់គេ ទៅលើ ស្រុកខ្មែរបាន ។ នៅក្នុង សន្ធិសញ្ញានោះ សៀមទទួលស្គាល់ អាណាព្យាបាលបារាំងទៅលើ ប្រទេសកម្ពុជា ប៉ុន្តែ បារាំង ក៏ត្រូវសន្យាផងដែរថា នឹងមិនបញ្ចូលស្រុកខ្មែរទៅក្នុង ក្របខ័ណ្ឌនៃ ទឹកដីកូសាំងស៊ីន ដែលបារាំងកាន់កាប់ឡើយ។ សន្ធិសញ្ញានេះ បានធ្វើឲ្យខ្មែរខាតបង់ខេត្តពីរ គឺបាត់ដំបង និងសៀមរាប។ តាម ការពិត រឿងនេះ បណ្តាលមកពីការធ្វេសប្រហែស តាមសភាពការណ៍ មិនទាន់ របស់ ភារធារីបារាំង នៅទីក្រុងបាងកក ដែលបានចុះហត្ថលេខា ជាមួយសៀម ទៅលើ សន្ធិសញ្ញាមួយទៀត ដែលទទួលស្គាល់ ខេត្តខ្មែរទាំង ២ នេះ ជារបស់សៀម។ ហ្លួងនរោត្តម  និង លោក រ៉េស៊ីដង់ បារាំង នៅប្រទេសកម្ពុជា ឌូដា ដឺឡាគ្រេ មាន ការក្រេវក្រោធ យ៉ាងខ្លាំង ។ បារាំង និង ខ្មែរ ធ្វើការតស៊ូអស់រយៈពេល កន្លះសតវត្សរ៍ ទម្រាំ ទាមទារយកខេត្តទាំងពីរនេះបានមកវិញ ។ នៅក្នុងរយៈពេល ៩០ ឆ្នាំ ដែលបារាំងបានត្រួតត្រា ស្រុកខ្មែរ គឺពីឆ្នាំ ១៨៦៣ ដល់ ឆ្នាំ ១៩៥៣ គេអាចធ្វើ ការបែងចែក ជា ៣ ដំណាក់ការ ។ ដំណាក់ការ ទី ១ ពីឆ្នាំ ១៨៦៣ ដល់ឆ្នាំ ១៨៨៤ ។ ដំណាក់ការ ទី ២ ពី ឆ្នាំ ១៨៨៤ ដល់ឆ្នាំ ១៩០៤ ។ ដំណាក់ការ ទី ៣ គិត ពីឆ្នាំ ១៩០៤ ទៅទល់ នឹងពេលបានឯករាជ្យនៅឆ្នាំ ១៩៥៣ ។ នៅក្នុងដំណាក់ការ ទី១ បារាំង ខិតខំពង្រឹងជំហរ របស់ហ្លួងនរោត្តម និងស្ថានភាពក្នុងប្រទេស។ ប៉ុន្តែស្រាប់តែនៅថ្ងៃ ១៧ មិថុនាឆ្នាំ ១៨៨៤ ទេសាភិបាល បារាំង តុមសុន តម្រូវឲ្យ មហាក្សត្រខ្មែរ ចុះហត្ថលេខាទៅលើ អនុ



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

សញ្ញាមួយ ដែលដកហូតអំណាចទាំងអស់ ពីព្រះអង្គ ហើយ ប្រគល់ កិច្ចការដឹកនាំប្រទេសទៅឲ្យ រ៉េស៊ីដង់ បារាំង តែម្តង ។ នៅពេលនោះ បារាំង ចង់កែទម្រង់ច្បាប់យកពន្ធ គឺ គេយកចំណូលពន្ធនោះទាំងអស់ សម្រាប់ខ្លួនគេ ដោយ សំអាងថា គេយកទៅ កសាង ហេដ្ឋារចនាសម្ព័ន្ធ ។ មិនតែប៉ុណ្ណោះសោត គេចង់កែច្បាប់ ស្តីពីកម្មសិទ្ធិ ដីធ្លី ផងទៀត ។ នៅក្នុង របប រាជានិយមខ្មែរ ដីធ្លី ទាំងអស់ ជារបស់ស្តេច ប៉ុន្តែ បារាំងចង់កែ មកជា របស់ បុគ្គលវិញ ។ តាមការពិត ការដែលស្តេច និង ពួកអភិជន មិនសប្បាយចិត្ត គឺជារឿង ដែលគេអាចយល់បាន ប៉ុន្តែ ការដែលប្រជានុរាស្ត្រ មិនសប្បាយចិត្តដែរ ហើយនាំគ្នាបះបោរ គឺមកពី បារាំង ចង់យកច្បាប់កម្មសិទ្ធិឯកជន ទៅធ្វើអាជីវកម្មរបស់គេផ្ទាល់តែម្តង។ មួយវិញទៀត អនុសញ្ញានោះមានលក្ខណៈដូចអនុសញ្ញា ដែលបារាំង តម្រូវឲ្យព្រះចៅអណ្ណាម ចុះហត្ថលេខា ក្នុងពេលជាមួយគ្នានោះដែរ ។ តាំងពីពេលនោះមក ហើយ ជាពិសេស ចាប់តាំង ពីឆ្នាំ ១៨៨៥ ចលនា តស៊ូ ប្រឆាំង នឹង បារាំង កើតឡើងព្រោងព្រាត នៅក្នុងប្រទេសដូចជាចលនា របស់ អង្គ ស៊ីវត្ថា ដែលជាប្អូន របស់ ហ្លួង នរោត្តម ជាដើម ។ រវាងឆ្នាំ ១៨៦៤ -១៨៦៧  ចលនា ពោធិកំបោរ និងចលនា របស់ អាចារ្យស្វរ * ជាដើមបានធ្វើឲ្យបារាំង មានការភិតភ័យតក្កមាម្តងរួចមកហើយៗ តាំងពីមាន មហាកុបកម្មនា ឆ្នាំ ១៨៨៥ នោះមក ហ្លួង នរោត្តម ក៏ ឈប់ធ្វើ សហការ ជាមួយបារាំងទៀត ។ ការបះបោរនោះ មានទ្រង់ទ្រាយ ដ៏ ធំ សម្បើម ហើយបង្កើតឡើង នូវ បរិយាកាសអសន្តិសុខ នៅក្នុងទូទាំងប្រទេស។ បារាំងបានធ្វើការបង្ក្រាប យ៉ាងខ្លាំងក្លា ប៉ុន្តែមិនបានសម្រេច ហើយ បារាំង ចំនួន ជាច្រើនពាន់នាក់ បានបាត់បង់ជីវិត ។ នៅឆ្នាំ ១៨៨៦ ហ្លួង នរោត្តម ដែលចាប់ផ្តើមបារម្ភខ្លាចអង្គ ស៊ីវត្ថា ជាប្អូន វាយយកអំណាច ក៏អែបបារាំងវិញ ហើយនៅខែមិថុនា ក៏សម្រេចបញ្ចប់ ការបះបោរនៅក្នុងប្រទេស ។ ដើម្បីបន្ធូរបរិយាកាស ដ៏ តានតឹងនេះ នៅខែ មករា ឆ្នាំ ១៨៨៧ បារាំង បានកែប្រែអនុសញ្ញា ចុះ ថ្ងៃ ១៧ មិថុនាឆ្នាំ ១៨៨៤។ តាមការពិត បារាំង គ្រាន់តែដោះដៃ មួយ

រយៈពេលសិន ប៉ុណ្ណោះ ទម្រាំស្ថានការណ៍ បានធូរស្រាល គេនឹងគិតគូរ រៀបចំពង្រឹងអំណាចរបស់គេឡើងវិញ ។ គេអាចនិយាយបាន ថា ហ្លួង នរោត្តម មិនយល់ពីគោលបំណងមិនល្អ របស់ អាណានិគមបារាំងទេ។ ការបែកបាក់ កម្លាំងនៅចំពោះមុខបរទេស គឺជាការបើកផ្លូវ សម្រាប់ឲ្យ បរទេស គ្រប់គ្រង តែប៉ុណ្ណោះ ។ នៅ ឆ្នាំ ១៨៩៧ បារាំងបានបង្ខំស្តេចខ្មែរ ឲ្យចុះហត្ថលេខា ទៅលើ អនុសញ្ញាមួយទៀត ដែលប្រគល់ សិទ្ធិគ្រប់គ្រង ប្រទេសកម្ពុជា ទាំងអស់ទៅឲ្យបារាំង ។

ដំណាក់ការ ទី៣ ចាប់ផ្តើម ពី រជ្ជកាល ហ្លួង ស៊ីសុវត្ថិ គឺ នៅ ឆ្នាំ ១៩០៦ ។ នៅក្នុងដំណាក់ការនេះ ដែលហ្លួងស៊ីសុវត្ថិធ្វើសហការជិតស្និទ្ធជាមួយបារាំង ប្រទេសកម្ពុជាប្រែក្លាយខ្លួនបន្តិចម្តងៗ ទៅជាប្រទេសមួយ ដែលបោះជំហាន សន្សឹមៗ ឆ្ពោះទៅរក ភាពសម័យទំនើប ។ ប៉ុន្តែ មិនយូរប៉ុន្មាន ដោយ មានទំនាស់ រវាង វប្បធម៌

---

*ឯកសារ របស់ អាត់ដេម៉ា ឡឺក្លែរ Histoire du Cambodge សរសេរ A-sua ។ ប៉ុន្តែ ប្រវត្តិវិទូខ្មែរ និងបរទេសខ្លះហៅ "**អាចារ្យស្វា** " ។ អ្នកស្រាវជ្រាវមួយចំនួនយល់ថា គឺ **អាចារ្យស្លួរ** ដូច្នេះវិញទេ។ មុនការកកើតឡើង នៃ ចលនា ទាំងពីរនេះដែលផុត រលត់អស់ទៅវិញ នៅឆ្នាំ ១៨៦៧ (អាចារ្យស្លួរ ឬអាចារ្យ ស្វា បានត្រូវឧដា ដឹ ឡាគ្រេ ចាប់បាននៅ ចូវ ឌឹក នៅថ្ងៃ ១៩ សីហា ឆ្នាំ ១៨៦៦ រី ឯពោធិកំបោរ ត្រូវកាត់ ក នៅ ខែធ្នូ ឆ្នាំ ១៨៦៧ ) ។ អង្គ ស៊ីវត្ថា ដែលជាប្អូន របស់ហ្លួងនរោត្តម ក៏បានបង្កកម្លាំងបម្រុងដណ្តើមរាជ្យ ពីស្តេច នរោត្តម ជាបងដែរ ។រីឯមេទ័ពសំខាន់ ៗ នៅពេលនោះ មានជាអាទិ៍ រាមាយុធ្យា និង ស្នងសួរ ។





ទាំងពីរ គឺ ច្បាប់បារាំង និង របៀបរស់នៅ បេស់ ខ្មែរ ចលនាតស៊ូ ក៏ កើតឡើងជាបន្ត បន្ទាប់សឹង តែពេញមួយចំហៀងនគរ ។

# ចលនា បះបោរ ប្រឆាំង នឹង បារាំង

## La révolte anti-française

នៅពេលដែល បារាំងចាប់ផ្តើមកាន់កាប់ស្រុកខ្មែរ ចលនាតស៊ូ ក៏ចាប់ផ្តើមកកើត ឡើងដែរ ។ នៅចន្លោះឆ្នាំ ១៨៦៤-១៨៦៦ អាចារ្យស្លួរ បានប្រមែប្រមូលគ្នាបានជាច្រើន វាយបារាំងបង្ខំ ឲ្យចេញពីស្រុក។ នៅឆ្នាំ ១៨៦៥ ពោធិកំបោរ បានបង្កើតចលនាមួយ ដ៏ធំ សំបើមអស្ចារ្យ ហើយ បានកាន់កាប់ សឹងតែមួយចំហៀងប្រទេស ប៉ុន្តែនៅឆ្នាំ ១៨៦៧ បានត្រូវបារាំង ចាប់បាន ហើយកាត់ក យកក្បាលទៅដាក់តាំង នៅ កណ្តាលរាជធានី ។ ចលនាបះបោរ ទាំងនេះ មិនត្រឹមតែ ប្រឆាំង នឹងបារាំងប៉ុណ្ណោះ ទេ គឺ ប្រឆាំង នឹងហ្លួង នរោត្តម ផងទៀត ព្រោះតែស្តេចអង្គនេះបានសុខចិត្ត ឲ្យបារាំងត្រួតត្រាខ្មែរ ។ មុនការកកើតឡើង នៃ ចលនា ទាំងពីរនេះ អ្នកអង្គម្ចាស់ អង្គ ស៊ីវត្ថា ដែលជាព្រះរាជអនុជ របស់ ហ្លួងនរោត្តម ក៏ បានបង្កកម្លាំង បម្រុងដណ្តើមរាជ្យ ពី ហ្លួងនរោត្តម ជាបងដែរ ។

### ១)ចលនា អាចារ្យ ស្លួរ ឬ អាចារ្យ ស្វា (១៨៥៩-១៨៦៦)

នៅពេលដែលឧត្តមនាវីបារាំង ឡាក្រង់ឌីយែរ ចុះកប៉ាល់នៅកំពង់ហ្លួងមកជួបហ្លួងនរោត្តមនៅទីក្រុងឧដុង្គ នៅខែ កក្កដា ឆ្នាំ ១៨៦៣ ដើម្បីបញ្ចុះបញ្ចូល ឲ្យស្តេចខ្មែរ ទទួលយក «សន្ធិសញ្ញា អាណាព្យាបាល បារាំង» ស្ថានការណ៍ ចង់ជ្រុល

*បន្តិចទៅហើយ ព្រោះ នៅថ្ងៃ ២ មិនា ឆ្នាំ ១៨៦៣ ដោយខ្លាចស្តេចសៀមធ្វើបាប បណ្តាយឲ្យយួន យកទឹកដីខ្មែរ ហ្ស៊ូងនរោត្តម បានប្រគល់ខែត្រខ្មែរពីរទៅឲ្យសៀម គឺ ពោធិសាត់ និង កំពុងស្វាយ។ បារាំងខឹងណាស់ តែពុំដឹងធ្វើដូចម្តេច។ នៅទីបំផុត ហ្ស៊ូងនរោត្តម ក៏បានចុះហត្ថលេខា ទៅលើ សន្ធិសញ្ញា ជាមួយ បារាំងវិញ ។ ប៉ុន្តែនៅពេលដដែលនោះ ហ្ស៊ូងនរោត្តម ក៏បានបញ្ជូនព្រះរាជអនុជទី២ របស់ ព្រះអង្គ ព្រះនាម អង្គ សរ ទៅប្រទេសសៀម ផងដែរ ។ ម៉្យាងទៀត ក្សត្រអង្គនេះមាន ប្រជាប្រិយភាព ជាងព្រះអង្គផង។ នាម៉ឺនសៀមម្នាក់បាន មកទទួលយកព្រះអង្គម្ចាស់ អង្គ សរ នៅខែ វិច្ឆិកា ឆ្នាំដដែលនោះ ។ ប្រាំពីរខែក្រោយ មក គឺ នៅថ្ងៃ ៣ មិថុនា ឆ្នាំ ១៨៦៤ ហ្ស៊ូងនរោត្តម បានត្រូវរាជាភិសេកដោយបារាំងផង ដោយសៀមផង គឺនៅពេលនោះហើយ ដែលមេបះបោរម្នាក់ ឈ្មោះ «ស្វា» ងើបឡើង ប្រឆាំងនឹង បារាំង។ នៅឆ្នាំ ១៨៥៩ មេបះបោរនេះ បានធ្វើឲ្យមានការជ្រួលច្របល់ ម្តងរួចមកហើយ។ គេតាំងខ្លួនគេថាជាព្រះអង្គម្ចាស់ អង្គ ភឹម ដែលត្រូវជាព្រះរាជបុត្រ របស់ អតីតឧបរាជ អង្គ ឯម ។ តាមការពិត ព្រះអង្គម្ចាស់ អង្គ ភឹម ជាក្សត្រមួយអង្គ ដែលមានជម្ងឺវិកលចរិត ហើយ ដែលសុគត នៅទីក្រុងបាងកក តាំងពីឆ្នាំ ១៨៤៣ នៅក្នុង ជន្មាយុ ២១ ព្រះវស្សាមកឯណោះ។ នៅពេលដែលចេញធ្វើសកម្មភាព នៅឆ្នាំ ១៨៥៩ អាចារ្យស្វានេះ មានគេជឿថាជាអ្នកមានបុណ្យបារមីម្នាក់ ដែលត្រូវឡើងគ្រងរាជ្យស្រុកខ្មែរ។ កាលនោះ អាចារ្យ ស្វា ឬអាចារ្យសួរនេះ ដែលតាមការពិត ជាជនជាតិរដេសម្នាក់ប៉ុណ្ណោះ បានត្រូវស្តេច អង្គ ដួង ចាប់បានហើយលែងឲ្យមានសេរីភាពវិញ។*

*ក្រោយពីនោះមក អាចារ្យស្វាដើរប្រមូលគ្នីគ្នា នៅគ្រប់ខែត្រគ្រប់ទិសទី ជាពិសេសនៅខែត្រទ្រាំង បាទី ពាម និង ព្រៃកប្បាស។ រីឯអ្នកដែលចុះចូល សុទ្ធតែជាមេបះបោរធំៗ កាលជំនាន់ដែល អ្នកអង្គម្ចាស់ អង្គ ស៊ីវត្ថា កេណ្ឌ រេហ៍ពល បម្រុងដណ្តើមរាជ្យ ពីហ្ស៊ូងនរោត្តម គឺ តាំងពីសម័យបារាំង មិនទាន់ចូលស្រុកនៅឡើយ ។*



*សុបិន និង ការពិត ភាគ ១*- Rêves et réalités –Tome 1

*ពួកមេៗ ទាំងនោះ មានជាអាទិ៍ : រាមាយុធ្យា និង ស្នងសួរ ។ ពួកទាំងនេះធ្វើការវាយប្រហារ ទៅលើអ្នករាជការដោយឥតរអែង ។ ឧកញ៉ាចក្រី កែប បានត្រូវពួកនេះសម្លាប់នៅខេត្តកំពត។ អំពើឃោរឃៅទាំងឡាយនេះ បានត្រូវ លោកអាត់ដេម៉ា ឡឺក្លែរ ពិពណ៌នា នៅក្នុងសៀវភៅ របស់ លោក យ៉ាងពិស្តារ។ ប៉ុន្តែ ចំពោះប្រវត្តិវិទូខ្លះ គឺជាអ្នកស្នេហាជាតិដែលបានតស៊ូ យ៉ាងស្វិតស្វាញ ក្នុងគោលដៅ ដេញបារាំងចេញពីស្រុក គឺ មិនមែន ដើម្បីដណ្តើមអំណាច តែមួយមុខ នោះទេ ។ ទោះជាយ៉ាងណាក្តី នៅពេលដែលបារាំង ចូលមកស្រុកខ្មែរ អាចារ្យស្វាបានប្រមែប្រមូល ប្រជាជន ជាច្រើន វាយលុកយក ទីក្រុងភ្នំពេញ តែម្តង ។ ប៉ុន្តែ នៅក្នុងការប្រយុទ្ធនោះ អាចារ្យស្វា បែរជាត្រូវបាក់ទ័ពខ្ចាត់ខ្ចាយ ទៅវិញ ព្រោះកងទ័ពរាជការ និង ទាហានបារាំង ក៏ ធ្វើការទប់ទល់យ៉ាងខ្លាំងក្លាដែរ ។ អាចារ្យស្វា បានរត់ទៅលាក់ខ្លួនពួនអាត្មា នៅកូសាំងស៊ីន ដោយមានឧបរាជយួននៅខែត្រវិញឡុង ចៅឌឹក និង ហាទៀងជាអ្នកការពារ។ បារាំងមិនសុខចិត្ត ឲ្យអាចារ្យស្វា រួចខ្លួនឡើយ កាលបើបានដឹងថាយួនជួយលាក់ អាចារ្យស្វា ។ នៅថ្ងៃ ១៩ សីហា ឆ្នាំ១៨៦៦ ឌូដា ដឺ ឡាគ្រេ ទៅជួបឧបរាជយួន ហើយភ្ជួងកាំភ្លើងបន្ទំឲ្យប្រគល់អាចារ្យស្វាមកឲ្យបារាំង ។ វីរភាព របស់អាចារ្យស្វា ឬ អាចារ្យសួរនេះ បានត្រូវប្រវត្តិវិទូនានា លើកឡើង យ៉ាងក្បោះក្បាយនៅក្នុង ចលនា ស្នេហាជាតិ តស៊ូដេញបារាំងចេញពីស្រុក ។ អាចារ្យស្វាក៏ដូចជាពោធិកំបោរដែរ ជាអ្នកដឹកនាំ ចលនាតស៊ូ របស់ ប្រជានុរាស្ត្រ ដែលត្រូវបារាំង ជិះជាន់សង្កត់សង្កិនយ៉ាងខ្លោចផ្សា។ ស្តេចខ្មែរបានឲ្យដៃបារាំង ចាប់ ពោធិកំបោរ ព្រោះខ្លាច មេដឹកនាំ ចលនា តស៊ូនេះ ដណ្តើមរាជ្យសម្បត្តិ ។ ហ្ស៊ូង នរោត្តម ក៏ ប្រឆាំងនឹង បារាំងដែរ ប៉ុន្តែ ខ្លាចបាត់បង់អំណាច ជាងខ្លាចបារាំងត្រួតត្រាស្រុក ។ គួរកត់សំគាល់ផងដែរថា អ្វីដែល ស្តេចនរោត្តម បារម្ភ ជាងគេ បំផុត គឺ ការដែលបារាំងរៀបចំស្រុកទេស តាមរបៀប របស់គេ ដើម្បីសម្រួល ដល់ការយកប្រទេសខ្មែរ ទៅធ្វើអាជីវកម្ម របស់ ពួកគេ ។ ប៉ុន្តែ ទន្ទឹមនោះ បារាំងក៏បានប្រែក្លាយ កម្មសិទ្ធិ របស់*

ព្រះរាជវង្សានុវង្ស មកជា កម្មសិទ្ធិ សាធារណៈដែរ ។ ជាអកុសល បារាំង បែរជាសម្រួលសិទ្ធិនេះ ដល់ ជនជាតិ ចិន និង យួន ទៅវិញ ។

## ២) ចលនា ពោធិកំបោរ (១៨៦៥-១៨៦៧)

នៅចុងឆ្នាំ ១៨៨៥ អ្នកបះបោរប្រឆាំង នឹងបារាំង ម្នាក់ទៀតឈ្មោះ ពោធិកំបោរ បានធ្វើឲ្យបារាំង និងហ្លួងនរោត្តម មានការភិតភ័យតក្កមា។ ពោធិកំបោរបេញខ្លួន នៅខែត្រក្រចេះ ហើយក្តាប់បានខេត្តជាច្រើន នៅទិសបូព៌ា រួមបញ្ចូលទាំង និគម មួយនៅបាសាក់ ក្នុងដែនដីកូសាំងស៊ីន ទៀតផង។ មេបះបោរនេះ ដែលតាំងខ្លួនថា ជាព្រះរាជបុត្រមួយអង្គ របស់ ស្តេច អង្គ ចន្ទ មានប្រជានុរាស្ត្រ ចុះចូលច្រើនណាស់ ព្រោះចេះវេទមន្ត ខ្លាំងពូកែអស្ចារ្យ។ តាមការពិត មេបះបោរដែលបានយក ឈ្មោះព្រះអង្គម្ចាស់ពោធិកំបោរនេះ មកប្រើមានដើមកំណើត ជាជនជាតិ រដេស ។ ព្រះអង្គម្ចាស់ ពោធិកំបោរ សុគតតាំងពី នៅកុមារ (១៨១៨ - ១៨២៥)មក ឯណោះ ។ រីឯពោធិកំបោរ ដែលជា មេបះបោរ ជនជាតិ រដេស នេះ ដែលមាន ប្រពន្ធ ប្រាំនាក់ (ព្នងម្នាក់ យួនមកពី អណ្ណាមម្នាក់ និង ខ្មែរបីនាក់) ជាមនុស្សកាចសាហាវណាស់ ។ បើអ្នកណា មិនព្រមស្តាប់បង្គាប់ខ្លួន ពោធិកំបោរ សម្លាប់ចោល ដោយ ឥតស្តាយស្រណោះ ។ ចៅហ្វាយខេត្តក្រចេះ និង សំបុក ក៏បានត្រូវពោធិកំបោរនេះ សម្លាប់ចោលដែរ។ ក្រោយមក ពោធិកំបោរ មកតាំងទី នៅភូមិ ឈើទាលភ្លោះ នៅក្នុងខែត្រកញ្ជរ។ ភាគខាងកើត ទាំងអស់ នៃទន្លេ មេកុង រួមបញ្ចូលទាំង ត្បូងឃ្មុំផងស្ថិតនៅក្រោមអំណាចរបស់ ពោធិកំបោរទាំងស្រុង។ នៅខែមិថុនា ឆ្នាំ ១៨៦៦ ស្តេចនរោត្តម បានបញ្ជូនក្រឡាហោម គឺមេទ័ពជើងទឹកឲ្យទៅវាយឆ្មក់ ចាប់ពោធិកំបោរនៅបាភ្នំ ។ ប៉ុន្តែ ពោធិកំបោររត់រួច ហើយក្រោយមក បេញមុខសាជាថ្មីទៀត។ បារាំងក៏តាមចាប់ យ៉ាងកកិត ណាស់ដែរ ។ កងទ័ពបារាំង មួយអង្គភាព ចាប់ ពោធិកំបោរ





បាន នៅថ្ងៃ ២៥-២៦ វិច្ឆិកា ឆ្នាំ១៨៦៦ ប៉ុន្តែ ពោធិកំបោររត់រួចម្តងទៀត ។ នៅខែមករា ឆ្នាំ១៨៦៧ បារាំងចាប់បានម្តងទៀត តែពោធិកំបោរ គេចបាត់សាជាថ្មីទៀត ហើយទៅចេញនៅម្តុំ កំពង់ ឡេង និង បារាយណ៍ ឯណោះវិញ ។ នៅពេលនោះ ពោធិកំបោរ ចង់វាយយកទីក្រុងឧដុង្គតែម្តង។ កងទ័ពរាជការ និង បារាំង វាយទប់ទល់ យ៉ាងពេញទំហឹង ។ ពោធិកំបោរទ្រាំទ្រមិនបាន ក៏ រត់ទៅពួននៅ កំពង់ធំ ។ នៅទីបំផុត កងទ័ពស្តេចនរោត្តម ក៏ ចាប់បាន នៅពេលដែល ពោធិកំបោរ កំពុងពួនសម្ងំ លាក់ខ្លួននៅក្នុងត្រពាំងមួយ។ ពោធិកំបោរត្រូវគេកាត់ក យកក្បាលទៅប្រឡាក់អំបិល រួចយកទៅ តាំង ជា សាធារណៈ នៅ កណ្តាល ទីក្រុងភ្នំពេញ នៅ ខែធ្នូ ឆ្នាំ ១៨៦៧ ។

## ៣ ) អ្នកអង្គម្ចាស់ស៊ីវត្ថា (ប្រសូត នៅឆ្នាំ ១៨៤១ សុគត នៅ ឆ្នាំ ១៨៩១)

បន្ទាប់ពី ព្រះបាទ អង្គ ឌួង ចូលជីវង្គត នៅឆ្នាំ ១៨៦០ នាម៉ឺនសព្វមុខមន្ត្រី ក៏លើកព្រះអង្គម្ចាស់ អង្គ វត្តី (ហ្លួងនរោត្តម) ដែលជាបុត្រច្បង ឲ្យឡើងស្នងរាជ្យ តាមពាក្យផ្តែផ្តាំ របស់ព្រះបាទ អង្គ ឌួង ។ កាលនោះ អង្គ ស៊ីវត្ថា ដែលជាព្រះរាជបុត្រពៅ របស់ ព្រះបាទ អង្គ ឌួង មានអាយុ ១៩ ព្រះវស្សា ។ ការលើកព្រះអង្គម្ចាស់ អង្គ វត្តី ឲ្យស្នងរាជ្យ ពុំបានធ្វើឲ្យ អង្គ ស៊ីវត្ថា សព្វព្រះរាជហឫទ័យឡើយ។ ពីពេលនោះមក អង្គ ស៊ីវត្ថា ចាប់ផ្តើមធ្វើសកម្មភាពប្រឆាំង នឹងហ្លួង នរោត្តម ព្រមទាំងនាម៉ឺនសព្វមុខមន្ត្រី ជាពិសេស ប្រឆាំងនឹង ចៅហ្វាមាស ដែលជាអ្នកការពារហ្លួងនរោត្តម។ អង្គ ស៊ីវត្ថា ជាក្សត្រមួយអង្គ ប្រកបទៅដោយរូបសម្បត្តិ និង ប្រាជ្ញាឈ្លាសវៃ ពូកែខាងវោហារ និយាយខ្មែរ ស្ទាត់ជំនាញជាងស្តេច នរោត្តម ដែលចូលចិត្តនិយាយភាសាសៀមជាង។ អ្នកណាក៏ចូលចិត្តស្តាប់អ្នកអង្គម្ចាស់ ស៊ីវត្ថាដែរ មិនថាប្រុស ឬស្រីឡើយ។ អ្នកអង្គម្ចាស់ស៊ីវត្ថា មាននារីជាច្រើន ចោមស្រឡាញ់ ។

មិនតែប៉ុណ្ណោះ អង្គ ស៊ីវត្ថា មាន ប្រជាប្រិយភាព ដ៏ខ្ពស់ នៅក្នុងចំណោមប្រជានុរាស្ត្រ ផងទៀត។ ប៉ុន្តែអ្វីដែលធ្វើឲ្យហ្លួង នរោត្តមមានកង្វល់ខ្លាំងជាងគេ គឺមហិច្ឆតាដ៏ គ្មានព្រំដែន របស់ ព្រះអនុជអង្គ នេះ។ មិនយូរប៉ុន្មាន អង្គ ស៊ីវត្ថា ក៏បង្កើតទ័ពបម្រុងវាយយករាជ្យសម្បត្តិ ពីហ្លួងនរោត្តមមែន។ មុនដំបូងស៊ីវត្ថា ចាប់ផ្តើម កេណ្ឌទ័ព នៅដីបាភ្នំ ជាមួយ ស្នងសួរ ដែលជាញាតិខាងម្តាយ ។ លុះបានដឹងថា មានរឿងបែបនេះ ហ្លួង នរោត្តម ចេញរាជបញ្ជាឲ្យ ស្នងសួរ ចូលខ្លួនមកឧដុង្គ ដើម្បីឲ្យចៅហ្វា មាស យកទៅកាត់ទោស ។ ស្នង សួរ ពុំព្រមចូលមកបង្ហាញខ្លួន តាមរាជបញ្ជាទេ ហើយរត់ទៅលាក់ខ្លួនពួនអាត្មា នៅកន្លែង របស់ ព្រះអង្គម្ចាស់ស៊ីវត្ថា ដែល តាំងពីពេលនោះមក លែងទៅគាល់ព្រះរាជាទៀត ។ ម្យ៉ាងទៀត មានលេចឮពាក្យថា ស្តេចសៀម បានចាត់ ស៊ីវត្ថា ឲ្យឃ្លាំមើលហ្លួង នរោត្តម ក្រែងស្តេចខ្មែរអង្គនេះ និង នាម៉ឺនសព្វមុខមន្ត្រី លួចក្បត់សៀម ។ ហ្លួង នរោត្តម ទ្រង់ចង់ដឹងរឿងនេះដែរ ប៉ុន្តែ អង្គ ស៊ីវត្ថា មិនចេញមកជួបព្រះអង្គសោះ សូម្បីតែពេលបុណ្យសពព្រះបាទអង្គ ឌួង ជាព្រះបិតា ក៏អ្នកអង្គម្ចាស់ អង្គ ស៊ីវត្ថា មិនបានយាងមកជួបជុំ សមាជិកព្រះរាជ វង្សានុវង្សដែរ។ នៅទីបំផុត ហ្លួងនរោត្តម ក៏សម្រេចដេញ ព្រះអនុជអង្គនេះ ឲ្យទៅស្រុកសៀមតែម្តង។ ប៉ុន្តែជាការឥតប្រយោជន៍ ព្រោះ អ្នកអង្គម្ចាស់ ស៊ីវត្ថា និង ព្រះអង្គម្ចាស់ក្សត្រី សិរីវង្ស ជាព្រះជាយាពុំព្រមដាច់អហង្ការ ។ ហ្លួងនរោត្តម ក្រេវក្រោធយ៉ាងខ្លាំង ព្រោះជាការប្រមាថព្រះបេស្តាយ៉ាងជាក់ ស្តែង។ ព្រះអង្គទ្រង់បញ្ជាឲ្យនាម៉ឺន ព្រមទាំងសេនាបតីទៅចាប់ស៊ីវត្ថា។ ប៉ុន្តែ គ្មានមន្ត្រីណាហ៊ានចាប់ឡើយ ដោយហេតុថា គេមិនអាចដឹងបាន ដោយប្រាកដថា តើ ក្សត្រអង្គណា ដែលនឹងត្រូវ ឡើងគ្រងរាជ្យវិញ នៅពេលខាងមុខ ។ ម្យ៉ាងទៀត ប្រជានុរាស្ត្រស្រឡាញ់អ្នកអង្គម្ចាស់ ស៊ីវត្ថា ជាងហ្លួងនរោត្តមទៅទៀត ។ ដោយទ្រង់យល់សភាព ការណ៍នេះ ហ្លួងនរោត្តម ក៏ចាត់តាំងក្រុមមួយ ដែលមាន សុទ្ធតែអ្នកកាន់សាសនាកាតូលិក និង ពួកកូនចៅញាតិញោមពួក «ព័រទុយហ្គេ» ឲ្យទៅចាប់ស៊ីវត្ថា។





ថ្ងៃមួយ ពួកនេះ ឡោមព័ទ្ធស៊ីវត្ថាបាន ប៉ុន្តែ អ្នកអង្គម្ចាស់ ស៊ីវត្ថា ផាយសេះ លឿនដូចព្រួញ ហើយ បោះពួយចូលទៅក្នុង រាជវាំងតែម្តង ដើម្បីទៅនាំ នារីម្នាក់ ចេញមកជាមួយ។ គឺនារីនោះ ហើយដែលអង្គ ស៊ីវត្ថា និង ហ្លួងនរោត្តមដណ្តើមគ្នា តាំងពីយូរមកហើយៗ ដែលជា មូលហេតុ នៃទំនាស់ រវាង ក្សត្រទាំងពីរអង្គនេះ។ បន្ទាប់ពីរឿងនោះមក ម្តាយ របស់ អ្នកអង្គម្ចាស់ ស៊ីវត្ថា បានត្រូវគេឃុំទុកនៅក្នុង រាជវាំង ។ នៅឆ្នាំ ១៨៦០ នោះ ស្នង សួរ និងរាមាយុធ្យា មេទ័ព របស់ ស៊ីវត្ថា បានប្រយុទ្ធយកឈ្នះទៅលើ កងទ័ព ចៅហ្វាយខេត្ត របស់ ហ្លួង នរោត្តមនៅបាភ្នំ។ ប៉ុន្តែក្រោយមក ក៏ទទួលបរាជ័យទៅវិញ។ ទោះជាយ៉ាងនេះក្តី ក៏ហ្លួងនរោត្តម នៅតែមានការព្រួយបារម្ភ ព្រមទាំងអាក់អន់ហឫទ័យដែរ។ នៅ ខែ សីហា ឆ្នាំ ១៨៦១ ព្រះអង្គក៏យាងទៅគង់ នៅខែត្របាត់ដំបង ដោយនាំទាំង ព្រះខ័នរាជ្យ ទៅជាមួយផង។ នៅពេលនោះ រាមាយុធ្យា វាយយកទីក្រុងឧដុង្គបានទាំងមូល ប៉ុន្តែ ពុំមានសមត្ថភាពគ្រប់គ្រងផ្នែកនយោបាយ។ បើនិយាយពី ការប្រយុទ្ធផ្នែកយោ ធារាមាយុធ្យា ពិតជាមាន ទេពកោសល្យខ្ពស់ គ្មានអ្នកណាអាចប្រៀបផ្ទឹមបាន ។ ប៉ុន្តែ ដើម្បីគ្រប់គ្រងប្រទេស ជ័យជំនះ យោធា តែមួយមុខ មិនគ្រប់គ្រាន់ឡើយ ។ រាមាយុធ្យា បានអំណាចហើយ តែមិនដឹងត្រូវធ្វើអ្វីទាំងអស់ គឺដូចពាក្យ គេថា «ការយកអំណាច ជាការងាយស្រួល ប៉ុន្តែ គឺការរក្សាអំណាចទេ ដែលជាការពិបាក» ដូច្នេះដែរ ។ ដោយមេទ័ព ដ៏ពូកែនេះ មិនចេះទាក់ទាញ ឲ្យចៅហ្វាយខែត្រ នៃ រាជាណាចក្រទាំងមូលគាំទ្រខ្លួន អំណាចទាំងមូល ក៏របូតបាត់ទៅវិញទៅ។ មិនតែប៉ុណ្ណោះសោត គឺជាគ្រោះថ្នាក់មួយ ដ៏ធំផងទៀត ដោយហេតុថា អំណាចដែល របូតទៅវិញនោះ តែងតែត្រូវអ្នកផ្សេងទៀតដណ្តើមយក។ នៅពេលនោះឯង ពួកចាមនៅត្បូងឃ្មុំ ដែលបានបះបោរប្រឆាំងនឹង ស្តេច អង្គ ឌួង ហើយដែលបានត្រូវ ស្តេចអង្គនេះ បង្ក្រាបបានវិញ ហើយ ដែលបន្ទាប់មកទៀត បាននាំគ្នា ទៅលាក់ខ្លួន នៅ ចូវ ឌឹក ក៏ឆ្លៀតយកឱកាសនោះ ទាក់ទងខ្សែរយៈរបស់គេ នៅឧដុង្គ ឲ្យទៅនិយាយ ពន្យល់ ព្រះមហា

*ក្សត្រិយានី ជា មាតារបស់ ហ្វូង នរោត្តម ព្រមទាំង នាម៉ឺនស្តេច ថាត្រូវតែនាំគ្នាការពារហ្វូងនរោត្តម ទប់ទល់ នឹងរាមាយុធ្យា។ នៅទីបំផុត នៅចំពោះមុខឥរិយាបថម៉ឺងម៉ាត់ របស់ ព្រះមហាក្សត្រិយានី ដែលបានហៅ រាមាយុធ្យា ឲ្យមកគាល់ ហើយស្តីបន្ទោសចោទថា ជាអំពើក្បត់ មេបះបោររូបនេះ ដែលនៅខ្លាចបារមី ព្រះរាជានៅឡើយ ក៏នាំកងទ័ព ចេញពីឧដុង្គ ធ្វើដំណើរឆ្ពោះទៅ ភ្នំពេញវិញបាត់ទៅ ។ នេះជារឿងដែលរកយល់សឹងមិនបាន ព្រោះមិនដឹងជាយ៉ាងដូចម្តេច បានជា អ្នកអង្គម្ចាស់ស៊ីវត្ថា មិនដឹកនាំ ការវាយយកឧដុង្គដោយផ្ទាល់ ។ បើគ្មានមេដឹកនាំ នយោបាយទេនោះ កងទ័ពគ្រាន់តែជាចោរព្រៃប៉ុណ្ណោះ ។ នៅក្នុងន័យនេះ រាមាយុធ្យា គ្មានប្រកឯណាទៀតក្រៅពីជកថយទេ ព្រោះ ពួកចៅហ្វាយខេត្រ អាចនឹងវាយក្តោបមកវិញ។ ម្យ៉ាងទៀត សៀមគេច្បាស់ជា នឹងមិនបណ្តោយ ឲ្យរាមាយុធ្យាយកអំណាច ដូច្នេះបានឡើយ។ រីឯពួកអ្នកផ្សព្វផ្សាយ សាសនាកាតូលិកនៅពេលនោះ មានម៉ុងសេញ៉ររមីស្ស* (Monseigneur Miche) *ជាដើម សុទ្ធសឹងតែ ជា អ្នក ការពារហ្វូង នរោត្តមផងទៀត។ ពេលនោះ បារាំងមិនទាន់ទាំងមានកងទ័ព នៅស្រុក ខ្មែរផង គឺ មានត្រឹមអ្នកបាញ់កាណុង មួយក្រុមតូច សម្រាប់ ការពារវិហារ របស់ ពួកគេតែប៉ុណ្ណោះ ។ ព្រោះតែខ្លាច កាណុងនេះ រាមាយុធ្យា ចាញ់សម្ពុត រហូតដល់ ថ្នាក់សុខចិត្តបង់ប្រាក់ដ៏សន្ធឹកសន្ធាប់ សងជម្ងឺចិត្ត ពួកអ្នកទាំងនោះទៀតផង គឺសង ប្រាក់ថ្លៃខូចខាតវិហារ នៅពញាឮ ដែលពួកគេបានបំផ្លាញចោលកាល ពីពេលមុន នេះបន្តិច ។ បន្តមក ពួករាមាយុធ្យា ធ្វើសកម្មភាពបះបោរទៀត នៅតាមជាយដែន ភាគខាងត្បូង ប៉ុន្តែ ធ្វើការវាយលុក ចូលជ្រៅមិនបាន។ ចៅហ្វាយខេត្តត្បូងឃ្មុំ ធ្វើ ការទប់ទល់វិញដោយឥតរួញរា ។ នៅពេលនោះ ដោយ ហ្វូងនរោត្តម ពុំមាន វត្ត មាននៅក្នុងស្រុក អង្គ សរ ជាព្រះអនុជត្រូវទទួលរាជសិទ្ធិគ្រប់គ្រងប្រទេស ជំនួស សិន។ អង្គ សរ បញ្ជាឲ្យទាហានបារាំង ៥ នាក់ដែលការពារ វិហារកាតូលិក ដឹកនាំ កងទ័ពជើងទឹកទៅចាប់ មេបះបោរ រាមាយុធ្យា ។ ដោយដឹងថា មានទាហានបារាំង ធ្វើសហការផង*



*សុបិន និង ការពិត ភាគ ១*- Rêves et réalités –Tome 1

*នោះ  រាមាយុធ្យាក៏ដកកងទ័ព រត់បាត់ទៅ ។ កាលបើបានដឹងរឿងនេះ ហ្វូងនរោត្តមដែលគង់ នៅទីក្រុងបាងកក ក៏កើតក្តីបារម្ភខ្លាចក្រែង អង្គ សរ ដណ្តើមរាជ្យ ។ ក្រោយ មកទើបដឹងថា មិនមែនដូច្នេះទេ ហើយ បែរ ជាមានមន្ទិល សង្ស័យទៅលើព្រះអង្គម្ចាស់ ស៊ីសុវត្ថិ វិញ ។ នៅចំពោះមុខ ភាពមិនច្បាស់លាស់នេះ ម៉ុងសេញ៉ររមីស្ស ក៏សរសេរសំបុត្រ ទៅស្តេចសៀម សុំកប៉ាល់មួយ ដឹក ហ្វូងនរោត្តម មកភ្នំពេញវិញ ហើយថែមទាំង សុំឲ្យកងទ័ពសៀម មួយចំនួន ចូលមកស្រុកខ្មែរ តាមខេត្តបាត់ដំបងទៀតផង។ ស្តេចសៀម អរណាស់ ដោយមានឱកាស ជួយស្តេចខ្មែរដូច្នេះ ។ ហ្វូង នរោត្តម មកដល់ទីក្រុង ឧដុង្គវិញ នៅខែមិនាឆ្នាំ ១៨៦២ ។ ប៉ុន្តែសៀម ឲ្យតែកប៉ាល់ជូនមកប៉ុណ្ណោះ គឺ មិនហ៊ានបញ្ជូនកងទ័ពមកទេ ។ រីឯ ម៉ុងសេញ៉ររ មីស្ស វិញ បានត្រូវអាជ្ញាធរបារាំង នៅកូសាំងស៊ីន ស្តីបន្ទោសយ៉ាងខ្លាំងព្រោះ មិនគិតពីងបារាំងដែលនៅជិតបង្កើយ ហើយ បែរជា ទៅពឹងសៀម ទៅវិញ។ មុនព្រឹត្តិការណ៍នេះ គឺតាំងពីមុន ខែមិនា ឆ្នាំ ១៨៦១ ឧត្តមនាវីបារាំង សារន៉ែរ* (l’amiral Charner) *មេបញ្ជាការ នៅទីក្រុងសាយហ្គន បានបញ្ជូនបេសកជនម្នាក់ទៅទូលថ្វាយមហាក្សត្រខ្មែរថា បារាំងមានគោលបំណងតាំងទីនៅកូសាំងស៊ីន ហើយនៅក្នុងន័យនេះ ប្រាថ្នាចង់មានទំនាក់ទំនងល្អ ជាមួយព្រះរាជាខ្មែរ ។ ក្រោយពេលដែល ហ្វូង នរោត្តម យាងវិលត្រឡប់មកស្រុកខ្មែរវិញ នៅខែ មិនា ឆ្នាំ ១៨៦២ រាមាយុធ្យា និង ស្នងសួរ បានត្រូវគេចាប់ខ្លួនបាន ហើយកាត់ក យកក្បាលទៅថ្វាយព្រះរាជា។ គេបានយកក្បាលជនបះបោរទាំងពីររូបនេះ ទៅដោតនឹងដងឫសីត្រួតលើគ្នា ហើយដើរបង្ហាញអ្នកស្រុក អ្នកភូមិ បន្ទាប់មក យកទៅដោតតាំង នៅ ខាងលិចព្រះរាជវាំង ឧដុង្គ ។ នៅពេលដែលបារាំង ចាប់អ្នកចូលដៃជើង របស់ អ្នកអង្គម្ចាស់ស៊ីវត្ថា ទៅដាក់គុក នៅកោះត្រឡាច អស់ទៅ អ្នកអង្គម្ចាស់ស៊ីវត្ថា ក៏លាក់ខ្លួនរហូតដល់ ខែមករាឆ្នាំ ១៨៨៥ ទើបចាប់ធ្វើការតស៊ូ នៅក្នុងព្រៃ សាជាថ្មីទៀត នៅតំបន់ព្សាន។ ប៉ុន្តែម្តងនេះ គឺ ដើម្បីចូលរួមចំណែក ជាមួយ ប្រជានុរាស្ត្រ ទូទាំង*

ប្រទេស ដែលងើប ឡើងបះបោរប្រឆាំង នឹង បារាំង ព្រោះតែបារាំង ធ្វើទុក្ខបុកម្នេញ កំហិតយកពន្ធដារ ដោយឥតអាសូរ ហើយបង្ខំឲ្យស្តេចខ្មែរប្រគល់អំណាចទាំងអស់ទៅឲ្យគេទៀត ។ ការបះបោរម្តងនេះ របស់ ព្រះអង្គម្ចាស់ស៊ីវត្ថា មាន ការយល់ព្រម ពីព្រះមហាក្សត្រផងដែរ ។ ប៉ុន្តែ ចាប់ពី ខែមិថុនាឆ្នាំ ១៨៨៦ នៅពេលដែលការបះបោរ មានកម្លាំងខ្លាំងមហិមា ហ្លួងនរោត្តម ក៏ចាប់ផ្តើម មានការបារម្ភខ្លាចក្រែង អង្គ ស៊ីវត្ថា អាចនឹង ឡើងសោយរាជ្យជំនួស ព្រោះ អង្គ ស៊ីវត្ថា មានប្រជាប្រិយភាពច្រើន នៅក្នុងចំណោម មន្ត្រី ក៏ដូចជា នៅក្នុងចំណោម ប្រជានុរាស្ត្រ ។ នៅ ខែ មិថុនាឆ្នាំ ១៨៨៦ ហ្លួងនរោត្តម សម្រេចបញ្ឈប់ការបះបោរ ហើយសន្យានឹងបារាំងថា នឹងធ្វើសហការ ជាមួយបារាំងផងទៀត ។ តាមការពិត ហ្លួងនរោត្តម មានគោលបំណងត្រឹមទាមទារឲ្យបារាំងប្រគល់អំណាចមកវិញ តែប៉ុណ្ណោះ គឺដោយប្រើ កម្លាំងអ្នកស្នេហាជាតិ និងចលនាបះបោរ របស់អង្គស៊ីវត្ថាជាប្អូន។ អង្គ ស៊ីវត្ថា បានទៅតាំងទីនៅខេត្តសម្បូណ៌ ហើយរង់ចាំស្ថានការណ៍ថ្មី ដើម្បីឡើងគ្រងរាជ្យ ប៉ុន្តែ ពុំបានជួបនឹង ឱកាសនោះសោះឡើយ ព្រោះបារាំងបានពង្រឹងអំណាច របស់ហ្លួង នរោត្តម យ៉ាងរឹងមាំ ។ អង្គ ស៊ីវត្ថា ចូលជីវង្គត នៅឆ្នាំ ១៨៩១ នៅក្នុងជន្មាយុ ៥០ ព្រះវស្សា ។

## កុបកម្មទូទាំង ប្រទេស នា ឆ្នាំ ១៨៨៥-១៨៨៦

## La révolte générale

មុនឆ្នាំ ១៨៨០ បារាំងគ្មានគោលដៅអ្វី ច្បាស់លាស់ប៉ុន្មានទេ ចំពោះប្រទេស កម្ពុជា ក្រៅពីការរក្សាទុកទឹកដីខ្មែរឲ្យគង់វង់ ឲ្យស្ថិតនៅក្នុងរង្វង់ សហភាព





ឥណ្ឌូចិន របស់គេ។ អ្វីដែលទាក់ទាញបារាំង ជាពិសេស នៅស្រុកខ្មែរ កាលពេលនោះ គឺ ទន្លេមេគុង សម្បត្តិធម្មជាតិនានាដូចជាព្រៃឈើ ដំណាំជាដើម។ បេសកជនពិសេសបារាំង លោក ឌូដា ដឺឡាគ្រេ និង ហ្វ្រង់ស៊ី គ្នារញេ មានភារកិច្ច ត្រឹមប្រើប្រាស់ ទន្លេមេគុង ដើម្បីឆ្លងកាត់ ទៅប្រទេសចិន ប៉ុណ្ណោះ ។ ប៉ុន្តែ នៅឆ្នាំ ១៨៦៨ ដោយគេដឹង យ៉ាងច្បាស់ថា ទន្លេ នេះ ពុំមែនជាផ្លូវទឹកដែលគេអាចប្រើប្រាស់ ដឹកជញ្ជូនទំនិញ ឆ្ពោះទៅ ភាគខាងជើងបាន បារាំង ក៏សម្រេច បោះយុថ្កា ក្តាប់ជ្រោយឥណ្ឌូចិន យ៉ាងណែនតែម្តងទៅ ។ គាប់ជួនពេលនោះ នៅប្រទេសបារាំង រដ្ឋាភិបាលលោក ស៊្ហូល ហ្វែរ៉ី បានកំណត់ផែនការ ជាច្រើន សម្រាប់ធ្វើ ការកែទម្រង់ធំៗ ផ្នែករដ្ឋបាល នៅប្រទេសកម្ពុជា ព្រោះថា នៅពេលនោះ មាន សេចក្តីរាយការណ៍ ជាច្រើន ដែលផ្តល់ពត៌មាន អត្តនោម័ត មួលបង្កាច់ស្តេចខ្មែរ ព្រមទាំង សភាពការណ៍នៅក្នុងស្រុក។ ការពិត ជនជាតិបារាំង ដែលជាអ្នកសរសេរ សេចក្តីរាយការណ៍អំពីស្រុកខ្មែរ  ពុំយល់អំពី ទំនៀមទម្លាប់ វប្បធម៌ និងអារ្យធម៌ខ្មែរអ្វីទាំងអស់ ដែលជាហេតុធ្វើឲ្យ មានការភ័ន្ត ប្រឡំ ដ៏ធ្ងន់ធ្ងរ អំពីសភាពការណ៍ នៅក្នុងរាជាណាចក្រ ។ ក្នុងក្របខ័ណ្ឌ នៃ ការអនុវត្តន៍ វិធានការថ្មី លោក តុមសុន ទេសាភិបាលបារាំងនៅ កូសាំងស៊ីន ធ្វើដំណើរ តាមកប៉ាល់ចម្បាំង ទៅទីក្រុងភ្នំពេញ នៅថ្ងៃ ១៧ មិនាឆ្នាំ ១៨៨៤។ តុមសុន ជា មនុស្សក្រម្រោលបួនជ្រុង។ ពេលទៅដល់មុខព្រះ រាជវាំងនៅពេលយប់ ទេសាភិបាល បារាំងនេះ ក៏បញ្ជាឲ្យគេដាស់ ហ្លួង នរោត្តម ទាំងកណ្តាលរាត្រី ដើម្បីបង្ខំឲ្យព្រះអង្គ ឡាយព្រះហស្តលេខា ប្រគល់អំណាចទាំងអស់ទៅឲ្យរ៉េស៊ីដង់ ស៊ូពេរីយើរបារាំង ។ ប្រាំខែក្រោយព្រឹត្តិការណ៍នេះ គឺ នៅខែវិច្ឆិកា ឆ្នាំដដែល ចលនាបះបោរមួយ ក៏បានផ្ទុះឡើងក្នុងទូទាំងប្រទេស។ មុនពេលដែលព្រឹត្តិការណ៍នេះ កើតឡើង ទេសាភិបាល តុមសុន ស្មានថា ខ្មែរជាមនុស្សស្លូតបូតមិនចេះ តដៃឡើយ។ ការពិត នៅក្រោមអាការ ស្លូតបូតនេះ ខ្មែរបង្កប់នៅក្នុងខ្លួនគេម្នាក់ៗ នូវថាមពល ដ៏ខ្លាំងក្លាដែលគេតែងតែប្រើជារឿយៗ នៅពេលដែល ឱកាស

ហុចឲ្យ។ ប៉ុន្តែហ្លួង នរោត្តម ត្រូវគិតជាបឋម ដល់គ្រោះថ្នាក់ចំពោះមុខ គឺ ការបែក ទឹកដីខ្មែរជាពីរ ដោយយួន និង សៀម។ បើទាស់នឹងបារាំងៗ អាចឲ្យយួន យកទឹកដី ខ្មែរដោយស្រួលតែម្តង។ ប៉ុន្តែបើនឹងប្រគល់អំណាចទៅឲ្យបារាំងតែម្តង ក៏ដូចតែគ្នា។ មហាកុបកម្ម នាឆ្នាំ ១៨៨៤-១៨៨៦ គឺជា ការប្រយុទ្ធ រើបម្រះ ចេញពី ការគំរាម កំហែងនេះ ។ ប៉ុន្តែ អ្នកអង្គម្ចាស់ ស៊ីវត្ថា ដែលជាមេដឹកនាំការបះបោរ ក៏ ឆ្លៀតយក ឱកាសនោះ ដើម្បី ដណ្តើមយកអំណាច ពី ហ្លួង នរោត្តម ជាបងដែរ ។ មានរឿងជា ច្រើនទៀត ដែលបានជំរុញ ឲ្យអង្គស៊ីវត្ថា ឆ្លៀតយកការតស៊ូ របស់ អ្នកស្នេហាជាតិ កាលពេលនោះ មកដឹកនាំ មហាកុបកម្មនោះ ។ បារាំង មានការពិបាក ទប់ទល់ ក្រៃលែង ។ ទាហាន របស់គេរាប់ពាន់នាក់ បានបាត់បង់ជីវិត ។ ខ្លះស្លាប់ក្នុងការប្រយុទ្ធ ខ្លះទៀតស្លាប់ ដោយរោគគ្រុនចាញ់ ប៉ុន្តែ ខាងអ្នកតស៊ូខ្មែរវិញ ក៏ស្លាប់ច្រើនណាស់ ដែរ ។ បើតាម លោក អាត់ដេម៉ា ឡឺឃ្លែរ ខ្មែរ ១ ម៉ឺន នាក់ បានពលីជីវិត នៅក្នុង ការប្រយុទ្ធនេះ។ នៅទីបំផុត បារាំងក៏យល់ថា ដើម្បីបញ្ចប់ការបះបោរ គេត្រូវប្តូរ យុទ្ធសាស្ត្រ។ គេក៏ដឹងដែរថា គឺហ្លួងនរោត្តម និងនាម៉ឺនខ្មែរតែម្តង ដែលនៅពីក្រោយ ការបះបោរ ។ ហ្លួងនរោត្តម ប្រើកម្លាំង អង្គ ស៊ីវត្ថា ឲ្យវាយបារាំង ដើម្បីទប់ទល់ នឹង ការកែទម្រង់។ អ្នកអង្គម្ចាស់ស៊ីវត្ថា ឆ្លៀតយក អប្រជាប្រិយភាព របស់ ហ្លួង នរោត្តម ដើម្បី ដណ្តើមអំណាច ឡើងគ្រងរាជ្យ ។ ដោយឃើញ កម្លាំងខ្លាំងមហិមា របស់ អង្គ ស៊ីវត្ថា ហ្លួង នរោត្តម ក៏អែបបារាំងវិញ។ នៅខែមិថុនា ឆ្នាំ ១៨៨៦ ហ្លួងនរោត្តម សម្រេចធ្វើសន្តិការូបនីយកម្ម ហើយបន្ទាប់មកនៅខែមករា ឆ្នាំ ១៨៨៧ រដ្ឋាភិបាលបារាំង សន្យា នឹង ហ្លួងនរោត្តមថា នឹង កែអត្ថបទ អនុសញ្ញា ឆ្នាំ ១៨៨៤ សម្របទៅតាមខ្មែរវិញ នៅក្នុងករណី ដែលស្តេចខ្មែរ បញ្ឈប់មហាកុបកម្មនេះបាន ជាស្ថាពរ។ ព្រះរាជាទ្រង់ យល់ព្រមតាមសេចក្តីស្នើនេះរបស់បារាំង។ ក្នុងរយៈពេល តែពីរ-បីសប្តាហ៍ប៉ុណ្ណោះ ពួកកុបករ បាននាំគ្នា ចុះចូល ស្តេច នរោត្តម សឹងតែទាំង អស់ ។ ព្រះមហាក្សត្រខ្មែរ រក្សាអំណាចបានវិញ ដូចពីពេលមុន ប៉ុន្តែ ក៏ត្រូវយល់





ស្រប ឲ្យបារាំងធ្វើការកែទម្រង់រដ្ឋបាលដែរ។ ចាប់តាំងពីឆ្នាំ ១៨៨៨ បារាំង ខំបញ្ចុះបញ្ចូលឲ្យស្តេចខ្មែរ ទទួលយក ការរៀបចំ ស្ថាប័នរដ្ឋ តាមបែបបទ សម័យទំនើប ជាពិសេសខាងផ្នែកហិរញ្ញវត្ថុ។ ហ្លួងនរោត្តម ក៏មិនយល់ទាស់អ្វីដែរ ដរាបណា ព្រះអង្គ នៅជាអ្នកសម្រេចកិច្ចការផ្សេងៗ របស់ ប្រទេស ។ ក្សត្រខ្មែរបានប្រគល់ សិទ្ធិ ទៅឲ្យអ្នកតំណាងអាណាព្យាបាលបារាំង ដឹកនាំគណរដ្ឋមន្ត្រី ដើម្បីធ្វើការកែទម្រង់ ផងទៀត ប៉ុន្តែ បារាំង ត្រូវផ្តល់ប្រាក់ចំនួន ៤០ ម៉ឺន ពីយ៉ាស (400.000 piastres) ទុកសម្រាប់ឲ្យស្តេចខ្មែរចាត់ចែងធ្វើទំនើបកម្ម ដោយផ្ទាល់ព្រះអង្គ។ ការធ្វើទំនើបកម្ម ជាកិច្ចការមួយ ដ៏ សែនពិបាក ព្រោះថា មិនត្រឹមតែ ហេដ្ឋារចនាសម្ព័ន្ធ ប៉ុណ្ណោះទេ ដែលគេត្រូវកសាង ។ ច្បាប់ចាត់តាំងរដ្ឋបាល ក៏ត្រូវកែប្រែ សឹងតែទាំងស្រុងដែរ ។ គឺនៅពេលនោះហើយ ដែលទំនាស់ រវាង វប្បធម៌ពីរ ស្តែងចេញឡើង ជាពិសេស នៅក្នុងការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ ទំនាស់នេះ បាននាំមក នូវការប្របូក ប្របល់មួយ ដ៏ធំ ប៉ុន្តែ សម្រេចសម្រួលទៅ  ដោយមាន ការប្រទាញប្រទង់គ្នា ខ្លាំង ពេក ប្រទេសកម្ពុជា ក៏ ធ្លាក់ទៅក្នុងវិបត្តិ រចនាសម្ព័ន្ធ មួយ ដែលធ្វើឲ្យសកម្មភាព សេដ្ឋកិច្ចរាំងស្ទះទៅវិញ។ អ្នកដែលបានទទួលផល គឺ មានតែបារាំង និង ជនជាតិ ចិន ប៉ុណ្ណោះ ។ ឈ្មួញចិន រកស៊ីកេងប្រវ័ញ្ច ប្រជាកសិករខ្មែរដោយឥតអាសូរ ។ នៅឆ្នាំ ១៨៩៧ លោក ប៉ូល  ឌូមែរ បានត្រូវតែងតាំងជាអគ្គទេសាភិបាល ។ អ្នក តំណាងបារាំងនេះ យល់ឃើញថាគេគួរតែប្តូរ នយោបាយបារាំង នៅកម្ពុជា គឺ យក អំណាចទាំងអស់ ពីស្តេចខ្មែរ ឲ្យបានមកវិញម្តងទៀត។ នៅ ថ្ងៃ ១១ កក្កដា ឆ្នាំ ១៨៩៧ លោកអគ្គទេសាភិបាលឌូមែរ ធ្វើការគាបសង្កត់ ឲ្យហ្លួងនរោត្តម ទទួលយក អនុសញ្ញាមួយ ដែលមានលក្ខណៈដូច រដ្ឋធម្មនុញ្ញ មួយ ដូច្នេះដែរ។ នៅពេលនោះ ហ្លួងនរោត្តម មានវ័យចាស់ណាស់ទៅហើយ ។

# ព្រះអង្គម្ចាស់ យុគន្ធរ
## Le prince Yukunthor

នៅឆ្នាំ ១៨៩៦ ហ្វូង នរោត្តម ចាប់ផ្ដើម មានកង្វល់មួយថ្មីទៀត។ ព្រះអង្គសព្វព្រះរាជហឫទ័យ ចង់ឲ្យ ព្រះអង្គម្ចាស់ យុគន្ធរ ជាព្រះរាជបុត្រ ឡើងស្នងរាជ្យ បន្ទាប់ពីព្រះអង្គសោយទីវង្គតទៅ។ ប៉ុន្តែព្រះអង្គ ពុំអាចសម្រេច សេចក្ដីប៉ងប្រាថ្នានេះបានទេ ព្រោះ ឃុន ថាន់ ដែលជា ជាយាសំណព្វ ចង់ឲ្យព្រះអង្គម្ចាស់ ដួង ចក្រ ជាបុត្រឡើងស្នងរាជ្យវិញ។ ក្រោយមកដោយអ្នកអង្គម្ចាស់ ឌួង ចក្រ ទៅជ្រកកោននៅប្រទេសវៀតណាម ហើយសោយទីវង្គតបាត់ទៅ ឃុនថាន់ បានទទូចសុំឲ្យព្រះអង្គម្ចាស់ផានុវង្សស្នងរាជ្យម្ដងវិញ។ ម្យ៉ាងទៀត បារាំងពុំចង់ឲ្យព្រះអង្គម្ចាស់យុគន្ធរស្នងរាជ្យទេ ព្រោះក្សត្រអង្គនេះ ប្រឆាំង នឹងសន្ធិសញ្ញាឆ្នាំ ១៨៨៤ និង អនុសញ្ញាឆ្នាំ ១៨៩៧។ បារាំងនៅពេលនោះ រៀបចំជាស្រេចឲ្យព្រះអង្គម្ចាស់ស៊ីសុវត្ថិ ដែលជាប្អូនហ្វូង នរោត្តមឡើងស្នងរាជ្យ។ ដោយដឹងថា ស្ដេច នរោត្តមមានគោលបំណងចង់ឲ្យព្រះអង្គម្ចាស់យុគន្ធរឡើងគ្រងរាជ្យដូច្នេះ រ៉េស៊ីដង់បារាំង ដឺវែរណឺវិល (De Verneville) មានការព្រួយបារម្ភយ៉ាងខ្លាំង។ អគ្គទេសាភិបាលរូស្សូ (Rousseau) ក៏មាន យោបល់ ដូច ដឺ វែរណឺវិលដែរ។ ដើម្បីរៀបចំ ផែនការដាក់ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ឲ្យស្នងរាជ្យ ឲ្យបានស្រេចបាច់តែម្ដង រ៉េស៊ីដង់ ដឺវែរណឺវិល ក៏ សរសេរសេចក្ដីរាយការណ៍មួយ ផ្ញើទៅទីក្រុងបារីស៍ប្រាប់ថា ហ្វូងនរោត្តមមាន ព្រះរាជសុខភាព មិនសូវល្អ ហើយ អាចសោយទីវង្គត ក្នុងពេលឆាប់ៗទៀតផង។ ដឺ វែរណឺវិល ស្នើថា គួរតែរៀបចំ ឲ្យព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ឡើងគ្រងរាជ្យឲ្យហើយ តែម្ដងទៅ។ ប៉ុន្តែ នៅខែមិនា ឆ្នាំ ១៨៩៧ លោក ឌូមែរ (Doumer) បានត្រូវ តែងតាំងជាអគ្គទេសាភិបាល ជំនួសលោករូស្សូ។ បន្ទាប់ ពីបានជួប ហ្វូងនរោត្តម អគ្គទេសាភិបាល ឌូមែរ ក៏ដឹងថា ដឺ វែរណឺវិល បានរាយការណ៍មួលបង្កាច់ ហ្វូង នរោត្តម



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

ព្រោះលោកបានឃើញ សុខភាពព្រះរាជា នៅមាំមួនល្អនៅឡើយ ។ ប៉ុន្តែ ឌូមែរ មិនសូវគិត ពី រឿងស្នងរាជ្យនេះ ប៉ុន្មានទេ ។ គោលដៅចម្បង របស់ បារាំង នៅពេលនោះ គឺ ធ្វើការកែទម្រង់ប្រព័ន្ធរដ្ឋបាល នៃ រាជាណាចក្រខ្មែរ ។ នេះក៏ជា បញ្ហាមួយដ៏ ធំដែរ ប៉ុន្តែលោក ឌូមែរ ក៏មិនយកតម្រាប់តាមលោក តុមសុន កាលពី ឆ្នាំ ១៨៨៤ ដែរ។ លោក ឌូមែរ ក៏ ដឹងដែរថា លោក ដឺ វែរណឺវិល ចង់ដាក់ព្រះអង្គម្ចាស់ស៊ីសុវត្ថិ ឲ្យឡើងស្នងរាជ្យ ប៉ុន្តែ លោក ឌូមែរ យល់ថាហ្វូង នរោត្តម អាចនឹង ធ្វើសហការល្អ ជាមួយបារាំង នៅក្នុងការកែទម្រង់។ ម្យ៉ាងទៀត ព្រះអង្គ ក៏ពុំមាន ព្រះរាជសុខភាពទ្រុឌទ្រោម ដូចការអះអាង របស់ ដឺ វែរណឺវិល ឯណាដែរ។ អគ្គទេសាភិបាល បារាំង ឌូមែរ ខិតខំ បញ្ចុះបញ្ចូល ហ្វូង នរោត្តម ទាល់តែបានសម្រេច។ តាមរយៈព្រះរាជក្រឹត្យមួយ ចុះថ្ងៃ ១១ កក្កដា ឆ្នាំ ១៨៩៧ អំណាចទាំងមូល របស់ ព្រះមហាក្សត្រ បានធ្លាក់ ទៅក្នុងដៃ អ្នកតំណាងបារាំង នៅ កម្ពុជា ។ សភាពការណ៍ នេះ ធ្វើឲ្យព្រះអង្គម្ចាស់យុគន្ធរ មានកង្វល់យ៉ាងខ្លាំង ចំពោះអនាគតស្រុកខ្មែរ ។ ព្រះអង្គ មិនប្រឆាំង នឹង បារាំង ក៏ពិតមែន ប៉ុន្តែ ព្រះអង្គខ្វាចបារាំងដើរជ្រុលហួស ព្រំដែនដោយចាត់ចែង កិច្ចការ រាជាណាចក្រខ្មែរ ទៅតាមទំនើងចិត្តរបស់គេ ។ អ្វីដែលរាជបុត្រអង្គនេះ របស់ ហ្វូង នរោត្តម ព្រួយបារម្ភជាទីបំផុត គឺព្រះអង្គខ្វាចបារាំង ដកហូត មន្ត្រីដែលមាន ចិត្តស្វាមីភក្ដិចំពោះព្រះបិតា របស់ ព្រះអង្គ ហើយ យកមន្ត្រី ពុករលួយ មកជំនួសវិញ។ សេចក្ដីព្រួយបារម្ភ របស់ ព្រះអង្គម្ចាស់យុគន្ធរ មិនមែនជា ការភ័ន្តច្រឡំឡើយ ព្រោះ សិទ្ធិអំណាច របស់ ហ្វូង នរោត្តម ចេះតែចុះថយជាលំដាប់។ ទោះជាយ៉ាងណាក្ដី ក៏ ស្ដេច នរោត្តម នៅតែរកគ្រប់មធ្យោបាយ ដើម្បីឲ្យព្រះអង្គម្ចាស់យុគន្ធរ ឡើងស្នងរាជ្យដែរ។ នៅ ឆ្នាំ ១៩០០ មហាក្សត្រខ្មែរ បានសម្រេចឲ្យព្រះអង្គម្ចាស់ យុគន្ធរ យាងទៅ ទីក្រុងបារីស៍ ជំនួសព្រះអង្គ ដើម្បី ចូលរួមក្នុង ពិពណ៌ ប្រទេសអាណានិគម ដែលរៀបចំឡើង នៅក្នុងរដ្ឋធានីបារាំង ។ ហ្វូងនរោត្តម សង្ឃឹមថា ពួកអ្នកអន្ទ្រើសបារាំង នៅទីក្រុងបារីស៍

អាច នឹង ទទួលស្គាល់ ព្រះអង្គម្ចាស់យុគន្ធរ ជា អានាគតស្ដេចស្រុកខ្មែរ ជាពុំខាន ឡើយ។ ព្រះអង្គម្ចាស់ យុគន្ធរ ជាក្សត្រមួយអង្គ ដែលពុំចេះអែបអប ហើយ ជឿតែ ទៅលើសេចក្ដីទៀងត្រង់ ។ ព្រះអង្គជឿថា បារាំង នៅទីក្រុងបារីស៍ អាចនឹងជួយរក យុត្តិធ៌ម ។ គឺនៅក្នុងន័យនេះ ហើយ ដែលនៅឱកាស បុណ្យពិពណ៌នៅទីក្រុងបារីស៍ ព្រះអង្គបានប្រគល់អនុស្សរណៈមួយ ទៅឲ្យអាជ្ញាធរបារាំង ។ នៅក្នុងឯកសារនោះ ព្រះអង្គលាតត្រដាងនូវ អំពើ មិនគួរគប្បី របស់រេស៊ីដង់ បារាំង ទៅលើបិតា របស់ ព្រះអង្គ។ អ្នកទទួលខុសត្រូវបារាំង មិនត្រឹមតែខិតខំលាក់រឿងនេះ ដើម្បីជួយគ្នាគេ ប៉ុណ្ណោះទេ គឺថែមទាំងនាំគ្នាគិតធ្វើបាបព្រះអង្គថែមទៀត។ ប៉ុន្តែ អ្នកកាសែត បារាំង ម្នាក់ នៃ សារពត៌មាន «ឡឺ ម៉ាតាំង» (“Le Matin”) ដែលស្មោះត្រង់ នឹងហ្វូង នរោត្តម ហើយ ដែលបានអមដំណើរ ព្រះអង្គម្ចាស់យុគន្ធរទៅស្រុកបារាំង បានយក សំណុំរឿងនេះទៅលាតត្រដាង នៅក្នុងទំព័រកាសែត របស់គេ នៅក្នុងលេខចុះផ្សាយ ថ្ងៃ ទី ១១ តុលា ឆ្នាំ ១៩០០។ មន្ត្រីបារាំង ត្រូវបង្ខំចិត្តបាត់វិធានការ ដោយដកហូត អ្នកតំណាង នៅកម្ពុជា ជាបន្ទាន់ ។ ក្រោយពីនោះបន្តិច រឿងនោះ ក៏ ស្ងប់ស្ងាត់ ទៅវិញ ។ តាំងពីពេលនោះមក បារាំងស្អប់ខ្ពើម ព្រះអង្គម្ចាស់យុគន្ធរណាស់ ហើយ ធ្វើអ្វីគ្រប់បែបយ៉ាង ដើម្បីរៀបចំដាក់ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ឲ្យស្នងរាជ្យ នៅពេល ហ្វូងនរោត្តមសោយ ជីវង្គត។ ប្រវត្តវិទូបារាំង «ព្យែរឡាម៉ង់» បានយកសំណុំរឿង យុគន្ធរនេះ មកអធិប្បាយយ៉ាងពិស្ដារ នៅក្នុងនិក្ខេបបទរបស់ លោក ក្រោមចំណង ជើងថា : « សំណុំរឿងយុគន្ធរ » (“l’Affaire Yukanthor”) ។ នៅពេលដែល រឿងនោះផ្ទុះឡើង មន្ត្រីបារាំងនៅទីក្រុងបារីស៍ បានសុំឲ្យ ហ្វូងនរោត្តម ចេញបញ្ជា ឲ្យព្រះអង្គម្ចាស់យុគន្ធរ វិលត្រឡប់ទៅស្រុកខ្មែរវិញជាបន្ទាន់ ។ ប៉ុន្តែ ព្រះអង្គម្ចាស់ យុគន្ធរ ពុំព្រម ព្រោះទ្រង់ដឹងជាស្រេចថា បារាំងបម្រុងធ្វើបាប។ ពេលបារាំងរៀប ចំចេញកប៉ាល់ ព្រះអង្គ បានបញ្ឆោតបារាំង ដោយដាក់មនុស្សម្នាក់ជំនួស ។ ព្រះអង្គ ម្ចាស់ យុគន្ធរ ចង់បន្តការតស៊ូទៀត នៅប្រទេសបារាំង ប៉ុន្តែបានត្រូវបារាំង និរទេស



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

ទៅ សឹង្ហបុរី ។ នៅថ្ងៃ ២៥ មេសា ឆ្នាំ ១៩០៤ ហ្វូង នរោត្តម ជាព្រហបិតា ចូល ជីវង្គត។ ព្រះអង្គម្ចាស់យុគន្ធរ ក៏អស់បង្អែក គឺនៅសល់តែ អ្នកដែលស្មោះ នឹង ព្រះអង្គ នៅស្រុកខ្មែរខ្លះតែប៉ុណ្ណោះ ដូចជាអ្នកម្នាងព្យាមជាដើម ដែលនៅឆ្នាំ ១៩០១ បានខិតខំផ្ញើប្រាក់ ទៅព្រះអង្គ ដោយសង្ឃឹមថា ព្រះអង្គ អាចនឹង ធ្វើការតស៊ូបាន ឡើងគ្រងរាជ្យ។ នៅស្រុកខ្មែរ អ្នកម្នាងព្យាម បានខំខ្នះខ្នែងជួយព្រះអង្គ យ៉ាងសកម្ម ដោយផ្សព្វផ្សាយដំណឹងថាព្រះអង្គ បានបង្កើតចលនាតស៊ូ ដើម្បីវិលមកកម្ពុជា ស្នង រាជ្យព្រះបិតា។ នៅ ថ្ងៃ ២៥ កុម្ភៈ ឆ្នាំ ១៩០៤ បារាំង បានបញ្ចេញ ឲ្យដឹងថា ព្រះ អង្គម្ចាស់ស៊ីសុវត្ថិ នឹង ត្រូវឡើងគ្រងរាជ្យ។ នៅ ថ្ងៃ ២៥ មេសា ឆ្នាំដដែល ដោយ ទ្រង់មាន រោគាព្យាធិ ផង ព្រះអង្គម្ចាស់យុគន្ធរ ក៏ សុគតបាត់ទៅ ។ ពាក្យចចាម អារាម បានអះអាងថា ដោយនឹកស្រុកពេក ព្រះអង្គបានសាកល្បង ឆ្លងសមុទ្រ ពី ស្រុកសៀមមកស្រុកខ្មែរ ប៉ុន្តែ បានត្រូវគេប្រហារជីវិតចោល បាត់ទៅ ។



ព្រះអង្គម្ចាស់ នរោត្តម យុគន្ធរ



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

# ទំនើបកម្ម : បដិវាទកម្ម រវាង វប្បធម៌ ពីរ

# La modernisation : conflit de deux cultures





# ជំពូក ៣

## ការផ្សាំ អារ្យធម៌ ខ្មែរ ជាមួយ វប្បធម៌បារាំង

ខុសពី ហ្វូង នរោត្តម ដែលយល់ព្រមធ្វើការកែទម្រង់ ដោយទើសទាល់ ហ្វូង ស៊ីសុវត្ថិ មាន ទស្សនៈ ដូចស្ដេច អង្គ អេង ជាព្រះអយ្យកោ និងស្ដេច អង្គ ដួង ជាព្រះបិតាដូច្នេះដែរ ។ ព្រះអង្គឈ្វេងយល់ថា បើយកបារាំងជាបង្អែក ខ្មែរមិនត្រឹមតែរំដោះប្រទេស ឲ្យផុតពីក្រញាំយួន និងសៀមប៉ុណ្ណោះទេ គឺ អាចនឹងឈានទៅរកភាពសម័យទំនើប នៃសតវត្សរ៍ទី ២០ ទៀតផង។ គឺនៅក្នុងន័យនេះដែរ ដែលនៅឆ្នាំ ១៨៦៥ ព្រះបាទស៊ីសុវត្ថិ បានខិតខំជួយបារាំងរកចាប់ពោធិកំបោរ ដែលមានបង្អែកពីនាម៉ឺនយួន។ ការធ្វើទំនើបកម្ម ជាកិច្ចការដ៏ពិបាក ព្រោះជាការដែលប៉ះពាល់ ដល់ទំនៀមទម្លាប់ ទស្សនៈជីវិត និង ចិត្តគំនិត របស់ ប្រជាជន ជាពិសេស ដល់អំណាចព្រមទាំង ស្ថាប័ន សេដ្ឋកិច្ច ហិរញ្ញវត្ថុ នៃ របបរាជានិយម កាលជំនាន់នោះ។ ព្រះរាជក្រឹត្យចុះថ្ងៃ ទី ២៤ មករាឆ្នាំ ១៩០៨ បានបញ្ចូល របបសេដ្ឋកិច្ច សេរីនិយម មកក្នុង ប្រទេសកម្ពុជា ប៉ុន្តែពុំបានផ្តល់ ផលប្រយោជន៍ អ្វីប៉ុន្មាន ដល់ប្រជារាស្ត្រខ្មែរទេ ហើយបែរជាហុចផល ដ៏ច្រើន ឲ្យបារាំង និង ជនជាតិចិនទៅវិញ។

តាមការពិតទៅ របៀបរស់នៅ របស់ជនជាតិខ្មែរមិនមែន ទទួលឥទ្ធិពល តែពីបារាំងប៉ុណ្ណោះទេ។ នៅក្នុងបរិបទ នៃចំណីអាហារ ខ្មែរដែលរស់នៅតាមទីក្រុង ជាពិសេសមន្ត្រីរាជការដែលមានប្រាក់កាសធូរធារ នាំគ្នាបរិភោគ គុយទាវ ស៊ុយម៉ៃ នំប៉ាវ ចាខ្វៃ នៅពេលព្រឹក ឬ ក៏ចំណីយួន ដូចជា «បាញ់ហយ» «បាញ់ឆែវ» ជាដើម នៅពេលបរិភោគអាហារថ្ងៃត្រង់ ឬពេលល្ងាច ។ ទន្ទឹមនោះដែរ ខ្លះបរិភោគ នំ

បញ្ចុក បបរត្រី គុយទាវឆា ឬ បើតាមរបៀបបារាំង នំប៉័ងដាក់សាច់ ឬ «សង់វិច»។ ចិនបើកហាងលក់ម្ហូបចិន ព្រោងព្រាតតាមទីក្រុង (ស៊ុបមី ស៊ុបគាវ ឡុកឡាក់ ទាខ្វៃ ជ្រូកខ្វៃជាដើម) ។ បើមិនបើកហាងទេ ជនជាតិចិន ធ្វើរទេះរុញ។ យួនច្រើនរែកលក់ ហើយខ្មែរទូលអន្សមចេក នំកង នំក្រូច ឬផ្លែឈើ ដូចជាព្រីង ចេកជាដើម លក់តាមផ្ទះ។ បើតាមឯកសារខ្លះ ខ្មែរបរិភោគ ម្ហូបចិនតាំងពីយូរ មកហើយ។ កវីខ្មែរសន្ធម៉ុក បានលើកឡើង អំពី ឥទ្ធិពលម្ហូបចិន នៅក្នុងរបៀបរស់នៅប្រចាំថ្ងៃ របស់ ខ្មែរនៅទីក្រុងឧដុង្គដូចតទៅនេះ៖ «រើយនែ អាចិក ឆាមួយកាក់ អាចិកកន្ទ្រាក់ បានសាច់ខ្វៃ ទាញខ្វាក កាប់ខ្វាប់ សាប់ញាប់ដៃ  រើយលៃឲ្យឆាប់ ប្រញាប់ឆាន់»។ របៀបបរិភោគអាហារនៅតាមទីក្រុង ក៏ ទទួលឥទ្ធិពល ពី បារាំង និង ចិនដែរ (តុ ស្លក ស្លាបព្រា ចង្កឹះ) ។ ចិនយកប្រពន្ធខ្មែរ ហើយសម្របរបៀបរស់នៅ ទៅតាម ប្រពៃណីខ្មែរ ប៉ុន្តែ គេកម្រឃើញស្រីខ្មែរយកប្តីយួនណាស់ ដោយមូលហេតុ ប្រវត្តិសាស្ត្រ និង ទស្សនវិជ្ជា។ គេ ក៏កម្រឃើញនារីខ្មែរយកប្តីបារាំងដែរ ព្រោះ ចំពោះបារាំងអាពាហ៍ពិពាហ៍ រវាងមនុស្សពីរនាក់ ពុំមានន័យថា ជាចំណង រវាងគ្រួសារពីរទេ (l’union de deux individus et non de deux groupes de famille)។  ខ្មែរមិនយកសេរីភាពបុគ្គលជាធំទេ គឺ យកគ្រួសារសាច់ញាតិ បងប្អូនជាធំ។ ពេលរៀបការហើយ កូនត្រូវស្តាប់បង្គាប់ឪពុកម្តាយ បងប្អូនជីដូនជីតា មាមីង ចាស់ទុំបន្តទៀត ។ រីឯការរើសគូស្រករ ក៏ ឪពុក ម្តាយ រើសឲ្យដែរ ដោយមានការស្វាគមន៍ ពីសាច់ញាតិជិតឆ្ងាយផងទៀត។ គឺ មិនអាចយកប្តី ចិត្តឯង បានឡើយ ។ កាលដើមឡើយ សង្គមខ្មែរ ជា សង្គមមាតេយ្យកា ឬ មាតាធិបតី (société matriarcale) គឺ ស្រីជាអធិបតី ប៉ុន្តែ ឥទ្ធិពលព្រហ្មញ្ញសាសនា បាននាំមក នូវឥទ្ធិពលបេតេយ្យកា ឬ បិតាធិបតី (patriarcat ) ។ ប៉ុន្តែ ទំនាស់ រវាងឥទ្ធិពលអ្នកម្ចាស់ស្រុក និងឥទ្ធិពល មកពីបរទេស បានផ្តល់ជ័យជំនះទៅឲ្យអ្នកម្ចាស់ស្រុក (រឿងភ្នំប្រុសភ្នំស្រី)។ ទោះបីតាមផ្លូវច្បាប់ ប្រុសជា មេគ្រួសារក្តី ក៏នៅតែប្រពន្ធ ជាអ្នកសម្រេច ចុងក្រោយដដែល ទោះនៅក្នុងវិស័យណា ក៏



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

ដោយ។ លើកលែងតែករណីពិសេស ស្ត្រីកម្របានឡើងសោយរាជ្យណាស់។ ប៉ុន្តែ ផ្ទុយទៅវិញ ប្រុសត្រូវបញ្ជូន សួយសារអារករ (លើកជំនូន) ទៅឲ្យស្រី មុនពេលរៀបការ។ ឥទ្ធិពលបិតាធិបតី មិនមែនមកតែពី ឥណ្ឌាទេ តែ ក៏មកពី ទំនៀមទម្លាប់ចិនដែរ។ ឥទ្ធិពលបារាំង មានជាពិសេសខាងវិស័យច្បាប់ (ស្ថាប័នរដ្ឋបាល សេដ្ឋកិច្ច ហិរញ្ញវត្ថុ) វប្បធម៌/អរិយធម៌ (ការប្រែប្រួលទំនៀមទម្លាប់ ទៅតាមបារាំងនៅមជ្ឈដ្ឋានអ្នកអន្ទ្រើស និស្សិត បញ្ញវន្ត អភិជន) បច្ចេកទេស (ប្រដាប់ប្រដាប្រើប្រាស់ប្រចាំថ្ងៃទំនើបៗនិងទាន់សម័យ) វិទ្យាសាស្ត្រ (វេជ្ជសាស្ត្រ ឱសថសាស្ត្រ កសិកម្ម ឧស្សាហកម្ម) ។ នៅទសវត្សរ៍ ១៩៥០ នៅក្នុងវិស័យអរិយធម៌ ក្រៅពី ការអានសៀវភៅ និងទស្សនាវដ្តី បរទេស ខ្មែរដែលរៀន ភាសាបារាំង ច្រើននាំគ្នាទៅមើលខ្សែភាពយន្តបារាំង រឿងកូវបោយ អាមេរិក ឬ អ៊ីតាលី ជាដើម ។ អ្នកដែលទទួលការអប់រំតាមបែបខ្មែរសុទ្ធសាធ ចូលចិត្តមើលខ្សែភាពយន្តឥណ្ឌា និង ខ្មែរ ។ អ្នកដែលរៀននៅវិទ្យាល័យ មានគូប្រចាំចិត្ត និង មានទស្សនៈជឿនលឿនក្នុងទំនាក់ទំនង រវាង បុគ្គល និង បុគ្គល រវាងស្រី និង ប្រុស ដូចជា ការទទួលស្គាល់ សេរីភាព របស់ បុគ្គល គឺ មិនបង្ខំឲ្យមិត្តភក្តិ បងប្អូន មានទស្សនៈ ដូចខ្លួនដាច់ខាតអ្វីទេ។

ជនជាតិចិនដែលរស់នៅស្រុកខ្មែរ នៅជំនាន់អាណាព្យាបាលបារាំង មានចំនួនច្រើនរួចមកហើយ តាំងពី ឆ្នាំ ១៨៦៣ មក ។ ចំនួននេះ ចេះតែកើនឡើងថែមទៀត គឺ ១០៦៧៨៤ នាក់ នៅឆ្នាំ ១៨៧៤។ បើប្រៀបធៀបមកចំនួនប្រជាជនខ្មែរកាលសម័យនោះ គឺ ១០ ភាគរយ នៃប្រជាជនក្នុងស្រុកទាំងអស់។ ជនជាតិចិន មិនពិបាករួមរស់ជាមួយខ្មែរទេ ព្រោះចេះដាក់ខ្លួន ហើយគោរពទំនៀមទម្លាប់ខ្មែរ។ ខ្មែរកាត់ចិន ក៏ចាប់មានច្រើនដែរ។ យុវជនដែលរៀននៅវិទ្យាល័យបារាំង-ខ្មែរ ក៏រស់តាមរបៀបខ្មែរដែរ ហើយសឹងតែទាំងអស់គ្នាពុំចេះភាសាចិនឡើយ គឺចេះតែភាសាខ្មែរ និងបារាំង ឬអង់គ្លេស ។ នៅទសវត្សរ៍ ១៩៥០-៦០ នៅពេលដែលប្រជាជនខ្មែរកើនមកដល់ចំនួន ពី ៤. ២៨៩. ០០០ មក ៥. ៤៦៣. ០០០ នាក់ ប្រជាជននៅទីក្រុងភ្នំពេញ ក៏កើនឡើង

ច្រើនដែរ ( ១៩៣៩: ១០៨. ០០០ នាក់; ១៩៥៨ : ៤៥០.០០០ នាក់; ១៩៧៥: ២ លាន ៥ សែននាក់) ។

## រជ្ជកាល ហ្លួង ស៊ីសុវត្ថិ (១៩០៤-១៩២៧)

## Le règne du roi Sisowath

នៅពេលដែលហ្លួង នរោត្តម សោយទីវង្គតក្ខាម គឺ នៅឆ្នាំ ១៩០៤ រេស៊ីដង់ បារាំង ហង់រី ដឺឡាម៉ុត (Henri de Lamothe) បានរៀបចំឲ្យព្រះអង្គ ម្ចាស់ស៊ីសុវត្ថិ ឡើងស្នងរាជ្យជាបន្ទាន់ ។ ប៉ុន្តែ ទាល់តែ ២ ឆ្នាំក្រោយមក ទើបព្រះអង្គបានត្រូវ អភិសេក ។ រីឯ ពិធីអភិសេកនេះ គឺបានប្រព្រឹត្តិទៅ នៅក្រោមអធិបតីភាព នៃលោក ប៉ូល បូ (Paul Beau) ដែលពេលនោះ ជាអគ្គទេសាភិបាលបារាំងនៅឥណ្ឌូចិន ។ ព្រះបាទស៊ីសុវត្ថិ ពុំមាននយោបាយ ដូចព្រះបាទ នរោត្តមទេ ។ ខុសពីហ្លួងនរោត្តម ដែលខិតខំរក្សា តុល្យភាព រវាង សៀម និង បារាំង ហើយដែលសង្ឃឹមថា វត្តមាន បារាំង នៅឥណ្ឌូចិន នឹងត្រូវបញ្ចប់ក្នុងពេលឆាប់ៗព្រោះតែមាន ចលនាតស៊ូ នៅក្នុង ប្រទេស ហ្លួងស៊ីសុវត្ថិ មានជំនឿដូច្នេះវិញថា មានតែបារាំងប៉ុណ្ណោះ ដែលអាចប្រែ ក្លាយប្រទេសកម្ពុជា ឲ្យទៅជាប្រទេសមួយ ដ៏ទំនើបនៅក្នុងតំបន់ ។ ហេតុដូច្នេះហើយ បានជានៅក្នុងរជ្ជកាល របស់ ព្រះអង្គ គឺពី ឆ្នាំ ១៩០៤ ដល់ឆ្នាំ ១៩២៧ ការកែ ទម្រង់ បានប្រព្រឹត្តិទៅដោយសុវត្ថិភាព។ ក្រោមរាជ្យស្តេចអង្គនេះ ស្រុកខ្មែរបានបោះ ជំហាន ជាសន្សឹមៗ ឆ្ពោះទៅរក ភាពសម័យទំនើប នៃ សតវត្សរ៍ទី ២០ ។ ព្រះបាទស៊ីសុវត្ថិ ជាបុត្រមួយអង្គ របស់ព្រះបាទ អង្គ ឌួង ជាមួយអ្នកម្នាងពៅ។ ប្រសូតនៅឆ្នាំ ១៨៤០ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជាព្រះអនុជ របស់ ហ្លួងនរោត្តម និង ជាបង របស់ អង្គ ស៊ីវត្ថា ។ ព្រះបាទស៊ីសុវត្ថិ បានទទួលការអប់រំមួយផ្នែក នៅទី ក្រុងបាងកក (១៨៥៤-១៨៥៨) ។





## អង្គ ដួង

(ប្រសូតឆ្នាំ ១៧៩៦ - † ១៨៦០)

គ្រងរាជ្យ ពីឆ្នាំ ១៨៤១ ដល់ឆ្នាំ ១៨៦០

| | |
|---|---|
| ជាមួយ អ្នកម្នាង ប៉ែន<br>↓<br>**អង្គ វត្តី (នរោត្តម)**<br>(ប្រសូតឆ្នាំ ១៨៣៤ -† ១៩០៤) | ជាមួយ អ្នកម្នាងពៅ<br>↓<br>**អង្គ ស៊ីសុវត្ថិ**<br>(ប្រសូតឆ្នាំ ១៨៤០ -† ១៩២៧) |
| ជាមួយអ្នកម្នាង<br>ផលទេព សាក៉ាន<br>(កើតឆ្នាំ ១៨២៥? - † ?)<br>↓<br>សេរីវង្ស<br>(ប្រសូតឆ្នាំ ១៨៤២ -† ១៨៨៣ ) | ជាមួយអ្នកម្នាង នួន<br>(ឃុន ថាន់)<br>(កើតឆ្នាំ ១៨៤០-† ១៩ ... )<br>↓<br>នព្វរោជ<br>(ប្រសូតឆ្នាំ ១៨៥៣ -† ១៨៩១ ) |
| ជាមួយ អ្នកម្នាង ខាំ<br>(កើត ឆ្នាំ ១៨៤១ -† ?)<br>↓<br>អង្គ ស៊ីវត្ថា<br>(ប្រសូតឆ្នាំ ១៨៤១ -† ១៨៩១ ) | |

# នរោត្តម

គ្រងរាជ្យ ពីឆ្នាំ ១៨៦០ ដល់ឆ្នាំ ១៩០៤

| | |
|---|---|
| ជាមួយ អៀមបុស្សបា<br>↓ ↓<br>កែតសារា សុត្ថារ៉ុត<br>១៨៦៩ ១៨៧២ | ជាមួយ អ្នកម្នាងឃ្វិត<br>↓<br>សុត្ថាវង្ស<br>១៨៧៥ |
| ជាមួយ ឃុន ថាន់<br>↓<br>ផានុវង្ស | ជាមួយម៉ម ថាត<br>↓<br>ចន្ទលេខា |

## នរោត្តម សុត្ថារ៉ុត

| |
|---|
| ជាមួយ នរោត្តម ផាង៉ាង៉ាម*<br>↓<br>**សុរាម្រិត**<br>( ១៨៩៦-† ១៩៦០ ) |
| |

* បុត្រី របស់ ហ្លួង នរោត្តម និង ឃុន ថាន់





# ស៊ីសុវត្ថិ

(ប្រសូតឆ្នាំ ១៨៤០ - † ១៩២៧)

គ្រងរាជ្យ ពីឆ្នាំ ១៩០៤ ដល់ឆ្នាំ ១៩២៧

| | |
|---|---|
| ជាមួយអ្នកម្នាង ពុយ<br>↓<br>វត្តនាវង្ស<br>(ប្រសូតឆ្នាំ ១៨៥៨ -† ១៩០៤) | ជាមួយព្រះអគ្គម្ចាស់ក្សត្រី សាម័រ<br>↓<br>លំពង្ស ឥស្សរ៉ា<br>(ប្រសូតនៅឆ្នាំ ១៨៦០-† ១៩០៥) |
| ជាមួយព្រះអគ្គម្ចាស់ក្សត្រី<br>Changkolaney<br>↓<br>ឥស្សរាវង្ស<br>(ប្រសូតឆ្នាំ ១៨៦០- †១៩០៧ ) | ជាមួយ អ្នកម្នាង កែស<br>↓ ↓<br>នុព្វកៅ រត្នណៃ<br>(១៨៦១-† ?) (១៨៦២-†១៩០១) |
| ជាមួយ អ្នកម្នាង វ៉ាន<br>↓<br>**មុនីវង្ស** | ជាមួយ ព្រះបរមទីបកេត នារី<br>↓<br>Duonglakhana<br>(ប្រសូតឆ្នាំ ១៨៧៦-†១៩៥៣) |

# មុនីវង្ស

(ប្រសូតឆ្នាំ ១៨៧៦ - † ១៩៤១)

គ្រងរាជ្យ ពីឆ្នាំ ១៩២៧ ដល់ឆ្នាំ ១៩៤១

| ជាមួយអ្នកអង្គម្ចាស់<br>**នរោត្តម កាន់វិម៉ាន់***  | |
|---|---|
| Thavet Roeungsy<br>Nearyvong<br>(១៨៩៩) | <u>ពិណ្ណារេត</u><br>(១៩០២) |
| **កុសមៈ**<br>(១៩០៤-†១៩៧៥) | មុនីរេត<br>(១៩០៩- †១៩៧៥) |
| មុនីពង្ស<br>(១៩១២-†១៩៥៦) | |

* អ្នកអង្គម្ចាស់ នរោត្តម កាន់វិម៉ាន់ ជាបុត្រី របស់ ព្រះអង្គម្ចាស់ ហាស្សុកាន់ ។ ព្រះអង្គម្ចាស់ ហាស្សុកាន់ ជាបុត្រ របស់ ហ្លួង នរោត្តម។





នៅពេលដែលព្រះបាទ អង្គ ឌួង សោយជីវង្គតទៅ ហើយ នៅពេលដែលព្រះអង្គម្ចាស់ អង្គ វត្តី (នរោត្តម) ឡើងស្នងរាជ្យ អ្នកអង្គម្ចាស់ អង្គ ស៊ីវត្ថា ជំរុញឲ្យព្រះ អង្គម្ចាស់ ស៊ីសុវត្ថិ ទៅស្រុកសៀម ដើម្បីទុកលទ្ធភាពឲ្យព្រះអង្គ ធ្វើចលនាប្រឆាំង នឹង ហ្លួងនរោត្តម តែម្នាក់ព្រះអង្គ ។ ដោយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ពុំព្រម អង្គ ស៊ីវត្ថា ក៏ ធ្វើការតស៊ូប្រឆាំង នឹងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ តែម្តង ។ ឥរិយាបថនេះ ពុំបានធ្វើឲ្យអ្នក អង្គម្ចាស់ អង្គ ស៊ីវត្ថា អត់ឱនឲ្យបានឡើយ ហើយ ក៏ពុំបានធ្វើឲ្យព្រះបាទ នរោត្តម សព្វព្រះរាជហឫទ័យដែរ ។ ហ្លួងនរោត្តម ចង់ឲ្យព្រះអង្គម្ចាស់ ស៊ីសុវត្ថិ យាងទៅប្រទេសសៀម ទើបព្រះអង្គ មានការកក់ក្តៅ ព្រោះខ្លាច ព្រះអនុជអង្គនេះ ដណ្តើមរាជ្យ។ នៅទី បំផុត នៅឆ្នាំ ១៨៦៣ តាមសេចក្តីស្នើ ដ៏ ទទូច របស់ព្រះមហាក្សត្រ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ក៏ យាងទៅស្រុកសៀម ។ នៅឆ្នាំ ១៨៦៥ គឺនៅពេលដែល ចលនា តស៊ូ ប្រឆាំង នឹង បារាំង របស់ ពោធិកំបោរ បានផ្ទុះឡើង ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ក៏ សម្រេច ត្រឡប់ពី ទីក្រុងបាងកក ហើយយាងទៅទីក្រុង សាយហ្កន (Saïgon) ដើម្បីជួយបារាំងបង្ក្រាបពោធិកំបោរ ។ លុះ ចលនា ពោធិកំបោរ បានឈានដល់ទីបញ្ចប់ ព្រះអង្គក៏យាងវិល មកកម្ពុជាវិញ ។ នៅ ឆ្នាំ ១៨៧០ ក្រោមការគាបសង្កត់ របស់ បារាំង ហ្លួង នរោត្តម ក៏តែងតាំងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ជាឧបរាជ។ ទាល់តែ ៣៦ ឆ្នាំក្រោយមក គឺ នៅ ពេលដែលព្រះអង្គមាន ព្រះជន្មាយុ ៦៦ ព្រះវស្សា ទើបព្រះអង្គ បានឡើងគ្រងរាជ្យ។ គឺនៅក្នុងរាជ្យក្សត្រអង្គនេះ ហើយ ដែលបារាំង បានខិតខំគាបសង្កត់សៀម ឲ្យប្រគល់ទឹកដីខ្មែរទាំងអស់មកវិញ គឺទាំងទឹកដីខ្មែរដែលសៀមបានដណ្តើមយកតាំងពីឆ្នាំ ១៧៩៤ ទាំងខែត្រខ្មែរពីរ ដែលសៀមបានរក្សាទុក តាមរយៈសន្ធិសញ្ញា បារាំង-សៀម នា ថ្ងៃ ១៥ កក្កដា ឆ្នាំ ១៨៦៧ ។ សន្ធិសញ្ញាចុះថ្ងៃ ២៣ មិនាឆ្នាំ ១៩០៧ បូករួមជាមួយសន្ធិសញ្ញាឆ្នាំ ១៩០៤ បានផ្តល់មកឲ្យខ្មែរវិញ នូវទឹកដីមួយភាគធំ ដែលខ្មែរបាន បាត់បង់ ពីពេលមុនៗ ក្រៅពីខែត្របាត់ដំបង និង សៀមរាប ដែលបានត្រូវប្រគល់ មកឲ្យខ្មែរវិញ តាមរយៈ

សន្ធិសញ្ញាឆ្នាំ ១៩០៧ ទឹកដីមួយផ្នែកទៀត គឺ ទន្លេរពៅ, ម្លូព្រៃ, កោះកុង, ខែត្រ ស្ទឹងត្រែង ក៏សៀម បានប្រគល់មកឲ្យខ្មែរវិញដែរ តាមរយៈសន្ធិសញ្ញាឆ្នាំ ១៩០៤។ ប៉ុន្តែទន្ទឹមនេះ ទឹកដីខ្មែរ ដែលប្រទេសវៀតណាម បានដណ្តើមយក មុនពេល បារាំងមក គឺ កាលពីជំនាន់រាជ្យព្រះបាទ អង្គ ដួង បែរជាបានត្រូវបារាំងដាក់ ឲ្យស្ថិត នៅក្រោម ការគ្រប់គ្រង របស់ គេសិនទៅវិញ ។ នៅពេលដែលបារាំង ចេញផុតទៅ បារាំងបែរជា ប្រគល់ទឹកដីទាំងនោះ ទៅឲ្យវៀតណាម តែម្តង។ នៅក្នុងរជ្ជកាល ហ្លួង ស៊ីសុវត្ថិ បារាំង បានបណ្តោយ ឲ្យជនជាតិ ចិន និង យួន ដែលរស់នៅស្រុកខ្មែរ មានសិទ្ធិ ដ៏ច្រើន លើសលុប ទៅលើប្រជាជនខ្មែរ ជាពិសេស នៅក្នុងវិស័យ យុត្តិធម៌ និង សេដ្ឋកិច្ច ។ ប្រជាជនខ្មែរ បានងើបឡើងបះបោរ ប្រឆាំង នឹង បារាំង យ៉ាងខ្លាំងក្លា ព្រោះបារាំង ទារពន្ធដារ ហួសហេតុ ហើយ ធ្វើការគាបសង្កត់ ឥតត្រាប្រណី ។ នៅចន្លោះ ឆ្នាំ ១៩១៤-១៩១៨ នៅពេលដែល សង្គ្រាមលោក លើក ទី ១ បានផ្ទុះឡើង បារាំងបានកេណ្ឌខ្មែរ យកទៅច្បាំង។ នៅឆ្នាំ ១៩១៤ បារាំង នៅតែបន្ត ទារឲ្យកសិករ បង់ពន្ធយ៉ាងច្រើនទៀត ទោះបីមានគ្រោះទុរ្ភិក្ស គ្រោះរាំងស្ងួត រកទឹក ធ្វើស្រែមិនបាន ក៏ដោយ។ ប្រវត្តិវិទូ អាមេរិកាំង ដេវីដ ចិនដ្លែរ (David Chandler) បានសរសេរថា នៅ ខែវិច្ឆិកា ឆ្នាំ ១៩១៤ នោះ កសិករខ្មែរ ប្រមាណបីរយនាក់ បាននាំគ្នា ដើរចូលទីក្រុងភ្នំពេញ យកញត្តិមួយ ទៅថ្វាយព្រះមហាក្សត្រខ្មែរ គឺ ហ្លួង ស៊ីសុវត្ថិ ដើម្បីសុំ ឲ្យព្រះអង្គ ជួយបន្ធូរបន្ថយ ពន្ធដារ ។ ហ្លួងស៊ីសុវត្ថិ សុំឲ្យ បាតុករ ត្រឡប់ទៅវិញសិន ទម្រាំរកមធ្យោបាយ ដោះស្រាយ ។ ប៉ុន្តែ នៅដើមឆ្នាំ ១៩១៦ នៅពេលដែល កសិករកំពុងច្រូតស្រូវ ស្រាប់តែភ្នាក់ងារពន្ធដារ និង ពួកខ្មែរ អ្នកកេណ្ឌទ័ព ប្រដាប់ដោយកាំភ្លើង នាំគ្នាមកយាយីកសិករ តែម្តង ។ ដោយអត់ទ្រាំ មិនបាន អ្នកភូមិ ក៏ឈប់ច្រូតស្រូវ ហើយប្រមែប្រមូលគ្នីគ្នា បានរាប់ពាន់នាក់ ដើរ ចូលទៅ ទីក្រុងភ្នំពេញ ដោយគ្មានបង្អង់ ។ ឃើញ សភាពការណ៍បែបនេះ បារាំង ប្រញាប់យកស្តេចខ្មែរ ធ្វើជាខែល ព្រោះមិនហ៊ាន ធ្វើការបង្ក្រាបដោយ អំពើ ហិង្សា



*សុបិន និង ការពិត ភាគ ១*- Rêves et réalités –Tome 1

ដូចកាលពី ៣០ ឆ្នាំ មុន នោះទេ ។ បារាំងបានដកមេរៀន ពី កុបកម្ម នា ឆ្នាំ ១៨៨៥ ដែលកាលនោះ គេឥតយកឈ្នះ ទៅលើ ចលនាបះបោរ បានឡើយ។ បន្ទាប់ពី ហ្លួងស៊ីសុវត្ថិ សន្យាថា នឹង ដោះស្រាយ បញ្ហានេះ ពួកបាតុករ ក៏នាំគ្នាត្រឡប់ទៅ ស្រុក-ភូមិ របស់គេវិញ ។ ទំនាស់ រវាង ទីក្រុង និង ជនបទ ជាទំនាស់ រវាង អារ្យធម៌ពីរ ដែលរកលក្ខណៈ ចុះសម្រុងគ្នា មិនបាន ។ ទំនាស់នេះ មានតាំងពី យូរ លង់ មកហើយ គឺ តាំងពី ពេលដែលស្រុកខ្មែរ ស្ថិតនៅក្រោម ការគ្រប់គ្រង នៃ លទ្ធិព្រហ្មញ្ញសាសនា រហូតមកដល់ សម័យអាណានិគមបារាំង ។ របប រាជានិយម តាមបែបបទ *ទេវរាជ* ដែលចេះតែមាន ជារៀងរហូតមក ទោះនៅពេលដែលប្រទេស កម្ពុជា គោរពបូជា លទ្ធិពុទ្ធសាសនាទៅហើយ ក្តី ។ កាលជំនាន់ ព្រះបាទជ័យវរ្ម័នទី ៧ (សតវត្សរ៍ ទី ១២ - ១៣) គឺ ពុទ្ធសាសនា *មហាយាន* ហើយ ចាប់ពីឆ្នាំ ១២៩០ មក គឺពុទ្ធសាសនា *ហិនយាន* ឬ *ថេរវាទ* ។ ស្តេចខ្មែរ បានយក លទ្ធិ ទាំងនេះ មកធ្វើជាមូលដ្ឋាន នៃការរីកចម្រើន ប៉ុន្តែប្រជាជនខ្មែរ រក្សារបៀបរស់នៅដើម របស់គេជានិច្ច។ ការផ្សាភ្ជាប់ រវាង របៀបរបប ទាំងពីរនេះ ពុំសូវ ទទួលជោគជ័យ ប៉ុន្មានទេ ដោយអ្នកដឹកនាំនៅទីក្រុងពុំបាន យកចិត្តទុកដាក់ លើកតម្កើង ជីវភាព ប្រជាជន ហើយ ដោយ រដ្ឋបាល ធ្វើការគាបសង្កត់ ឥតត្រាប្រណី។

## ព្រឹត្តិការណ៍ ថ្ងៃ ១៨ មេសា ឆ្នាំ ១៩២៥
### L'événement du 18 avril 1925

បារាំង ចាប់ផ្តើមរៀបចំ ប្រទេសកម្ពុជា ឲ្យបានក្លាយ ទៅជាប្រទេស សម័យ ទំនើប តាមបែបបទ បារាំង តាំងពី សម័យ ហ្លួង នរោត្តម មក ។ នៅក្នុងរាជ្យ ហ្លួង ស៊ីសុវត្ថិ អភិក្រម ទំនើបកម្ម កាន់តែមានលក្ខណៈខ្លាំងក្លាថែមទៀត ។ ជំនាន់ហ្លួង នរោត្តម រ៉េស៊ីដង់ បារាំង និង អគ្គទេសាភិបាល បារាំង នៅកូសាំងស៊ីន ដែលជាអ្នក

ដឹកនាំកិច្ចការនេះ បានប្រើមធ្យោបាយមួយ ប្រកបដោយគ្រោះថ្នាក់ គឺដកហូតអំណាចទាំងអស់ ពីស្តេចខ្មែរ។ មធ្យោយនេះ បានហុចនូវ លទ្ធផល ផុយស្រឡះពី ការដែលគេចង់បាន ។ ការដកហូតអំណាច ពីស្តេចខ្មែរ បាននាំមក នូវ ការបះបោរ សឹងតែពេញផ្ទៃប្រទេស ព្រោះជា ការរំលោភ អធិបតេយ្យ នៃ ប្រទេសមួយ ។ នៅក្នុងរាជ្យហ្លួងស៊ីសុវត្ថិ បារាំង ពុំបានដកហូតសិទ្ធិអំណាច ពីព្រះមហាក្សត្រខ្មែរ ក៏ពិតមែន ប៉ុន្តែ គេបានដឹកនាំការកែទម្រង់ ដោយផ្ទាល់តែម្តង ។ មួយវិញទៀត បារាំង មិនត្រឹមតែ មិនសូវស្គាល់ ចិត្តគំនិតខ្មែរ ប៉ុណ្ណោះទេ គឺ ថែមទាំងគ្មាន មធ្យោបាយប្រាក់កាសគ្រប់គ្រាន់ទៀត សម្រាបធ្វើការកែទម្រង់ រចនាសម្ព័ន្ធ ។ គឺ មូលហេតុ ទាំងនេះហើយដែលបានជំរុញឲ្យមានព្រឹត្តិការណ៍ថ្ងៃ ១៨ មេសា ឆ្នាំ ១៩២៥ ដែល លោកបារដេស (Bardez) រ៉េស៊ីដង់ បារាំង នៅខេត្ត កំពង់ឆ្នាំង បានត្រូវ មនុស្ស ដែដល់ មួយក្រុមសម្លាប់ចោល។ ព្រឹត្តិការណ៍នេះ ដែលកើតមានឡើង នៅភូមិក្រាំងលាវ បានត្រូវលោក ឱក គាម និង លោក ឡើក អ៊ំ លើក ឡើងនៅក្នុងសៀវភៅមួយ ដែល មានចំណងជើងថា *ភូមិតិរច្ឆាន* ។ នៅថ្ងៃ ១៨ មេសា ឆ្នាំ ១៩២៥ នោះឯង រ៉េស៊ីដង់បារដេស បាននាំខ្មែរពីរនាក់ ទៅទារពន្ធដោយពុំបានប្រាប់ ចៅហ្វាយខេត្តខ្មែរ។ បារដេស យល់ថា ខ្មែរធ្វើការយឺតពេក បើទារពន្ធមិនទាន់ទេនោះ លោកនឹង ត្រូវ លោកប្រ្វង់ស្វា បូដ្វាំង (François Baudoin) រ៉េស៊ីដង់នៅភ្នំពេញ ស្តីបន្ទោសជាពុំខាន ។ បារដេស ជាមនុស្សក្រម្រោល ចូលចិត្តធ្វើការដោយតក់ក្រហល់ ។ មិនតែប៉ុណ្ណោះ «ចៅហ្វាយខេត្តបារាំង» កំពង់ឆ្នាំងនេះ មានជំនឿថា ទាល់តែប្រើធម៌ក្តៅទើបមានប្រសិទ្ធិភាព។ បើអ្នកណាគ្មានប្រាក់បង់ពន្ធទេ បារដេស ឲ្យគេដាក់ខ្នោះជើង អ្នកនោះហើយបង្អត់បាយបង្អត់ទឹក យ៉ាងឃោរឃៅ ។ នៅទីបំផុត អ្នកភូមិក្រាំងលាវ បានពួតដៃគ្នា សម្លាប់ បារដេស ព្រមទាំង អ្នកអមដំណើរ ចោលតែម្តង ។ ប៉ុន្តែ ក្រោយមកបារាំង បានបង្រ្កាប អ្នកភូមិក្រាំងលាវ ដោយឥតត្រាប្រណី ។ ការធ្វើទំនើបកម្មប្រទេសកម្ពុជា នៅ ជំនាន់ហ្លួង ស៊ីសុវត្ថិ ពមុមាន ចលនាតស៊ូ ប្រឆាំងដឹកនាំ ដោយ





ព្រះមហាក្សត្រ និងពួកនាម៉ឺន ក៏ពិតមែន ប៉ុន្តែរដ្ឋបាលបារាំង បានធ្វើឲ្យប្រជាកសិករក្តៅក្រហាយ ព្រោះតែ ការអនុវត្តន៍ ច្បាប់មួយបែប ដែលចាត់ទុកប្រជាជន ថា ជាខ្មាំង ឬ ជាចោរ មុនរួចជាស្រេច ។ បើជនណា គ្មានលទ្ធភាព គ្រប់គ្រាន់ សម្រាប់គោរពគោលការណ៍ របស់គេ គឺ គេមិនជួយបង្កលក្ខណៈ ឲ្យសិនទេ។ នៅក្នុងស្ថានភាពបែបនេះ ប្រជាជនខ្មែរ មិនដឹងជាត្រូវរំពឹង ទៅលើអ្វីទាំងអស់។ រីឯ ការកែទម្រង់នោះសោតទៀត ក៏ គ្មានអ្វីជាដុំកំភួន ប៉ុន្មានដែរ បើប្រៀបធៀប ទៅស្រុកយួន។ នៅពេលនោះ បារាំងផ្តោតអារម្មណ៍ ជាពិសេស ទៅលើប្រទេសវៀតណាម ព្រោះប្រទេសនេះ ជាទឹកដី ដែលគេកំពុងធ្វើអាណានិគមកិច្ច យកទៅធ្វើជាមូលដ្ឋាន របស់គេ នៅក្នុងតំបន់អាស៊ី ។ គឺ នៅក្នុងន័យនេះហើយ ដែលបារាំង ខិតខំធ្វើ ទំនើបកម្មនៅកូសាំងស៊ីន ជាងនៅប្រទេសកម្ពុជា។ ម្យ៉ាងទៀត នៅពេលដែលបារាំង បានយល់ច្បាស់ អំពី អតីតកាល ដ៏ រុងរឿង របស់ ខ្មែរ ដែលមាន អង្គរ ជានិមិត្តរូប បារាំងចង់រក្សាទុកសម្បត្តិវប្បធម៌ និង ទំនៀមទម្លាប់ឲ្យនៅដដែល ដូចដើម ពោល គឺទុកជាសារមន្ទីរមួយ តែប៉ុណ្ណោះ។ គឺ ទស្សនៈនេះ ហើយដែលបានធ្វើ ឲ្យទំនើបកម្ម នៅកម្ពុជា មានការយឺតយ៉ាវ ជាអតិបរមា ហើយ ទន្ទឹម នោះ ក៏ បង្កើតឡើងផងដែរ នូវមនោសញ្ចេតនា និង មោទនភាពជាតិនិយមមួយ ប្រកប ដោយគ្រោះថ្នាក់ ។ របបរាជានិយមខ្មែរ ក៏ បានទទួល ចំណែកមួយ ដ៏ធំ នៃ មោទនភាព នោះដែរ ។ បារាំងគេយល់ដូច្នេះទៀតថា ការត្រូវរ៉ូវជាមួយស្តេចខ្មែរតែមួយមុខគឺជាការស្រេច សម្រាប់ពង្រឹងឥទ្ធិពល របស់គេ នៅក្នុងប្រទេសនេះ ។ គឺ ព្រោះតែដូច្នេះហើយ បានជានៅពេលក្រោយមកទៀត បារាំងមិនសូវគាំទ្រ អភិក្រម ទំនើបកម្ម ផ្នែកបញ្ញា និងនយោបាយ របស់ខ្មែរប៉ុន្មានទេ ។ ទោះជាយ៉ាងណាក្តី ក៏ប្រទេសកម្ពុជា មិនអាចគេចផុតពី ចរន្ត ទំនើបកម្មនេះដែរ តែការយឺតយ៉ាវ បាននាំមកនូវ ផលវិបាក ដ៏ ធ្ងន់ធ្ងរ។ ពាក្យ «ទំនើបកម្ម» នេះពុំមានន័យថា ជា ការវិវត្តន៍រីកចម្រើន នៃ អារ្យធម៌ នៃប្រទេសដែលគេ ធ្វើទំនើបកម្មនោះទេ តែជាការយកអារ្យធម៌បារាំង មកធ្វើជាគំរូ

ដោយត្រង់ៗ តែម្តងៗ នេះជាទំនាស់មួយដ៏ធំ ដែលបានធ្វើឲ្យគំនិតជាតិនិយម កាន់តែខ្លាំងខ្លាថែមទៀត។ ការដែលគួរកត់សំគាល់ គឺថា អារ្យធម៌ខ្មែរ ពុំអាចវិវត្តបាន ព្រោះអ្នកប្រាជ្ញខ្មែរ ដែលស្ថិតនៅក្រោម ការគាបសង្កត់ របស់ ស្តេចពុំ អាចបញ្ចេញ មតិ និង ទេពកោសល្យ របស់ គេបានឡើយ។ រឿងធនជ័យ ឬធនញ្ជ័យជា សក្ខីកម្មមួយ ដែលបញ្ជាក់យ៉ាងច្បាស់ អំពីបញ្ហានេះ ។

## ទិដ្ឋភាព ខ្លះៗ នៃ អភិក្រមទំនើបកម្ម

## Quelques aspects du processus de modernisation

ការប្រែក្លាយ ប្រទេសកម្ពុជាឲ្យទៅជាប្រទេសមួយ សម័យទំនើប ជាកិច្ចការដ៏ពិបាក។ បារាំងដែលជាអ្នកដឹកនាំកិច្ចការនេះ តាំងពីឆ្នាំ ១៨៨៨ មក ស្ថិតនៅចំពោះមុខកាតព្វកិច្ចពីរ ផ្ទុយពីគ្នា ៖ ណាមួយ ត្រូវកែប្រែរបៀបគ្រប់គ្រងប្រទេស ទាំងផ្នែករដ្ឋបាល ទាំងផ្នែកសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ណាមួយ ត្រូវរក្សារបៀបរស់នៅ ទំនៀមទម្លាប់ប្រពៃណីរបស់ខ្មែរ ។ ម្យ៉ាងទៀត មុនពេលដែលបារាំងមកដល់ស្រុកខ្មែរ អ្វីៗសឹងតែបាក់បែកខ្ទេចខ្ទី អស់ទៅហើយ ព្រោះតែសង្គ្រាមក្នុងស្រុក និង ការឈ្លានពានពីប្រទេសជិតខាង អស់រយៈពេល ប្រាំរយឆ្នាំ កន្លងមក ។ រីឯ ទឹកដីវិញ ក៏បាត់បង់ច្រើនណាស់ដែរ ។ នៅជំនាន់ ស្តេច អង្គ ដួង (១៨៤១-១៨៦០) ប្រទេស កម្ពុជាបានធ្លាក់ចុះដុនដាបយ៉ាងខ្លាំង ។ ជនជាតិចិន រកស៊ីកេងប្រវ័ញ្ចខ្មែរ ដោយឥតអាសូរ។ ពេលនោះ ខ្មែរយើងចេញចូល សមុទ្រផ្នែកអាគ្នេយ៍តាម ទន្លេមេគុងមិនបានទៅទៀត ព្រោះយួនត្រួតត្រា បិទប្រកនេះ អស់គ្មានសល់កន្លែងណាទេ ។ នៅឆ្នាំ ១៨៤៩ ស្រុកខ្មែរ ត្រូវវាតត្បាតដោយជម្ងឺប៉េស្ត ដែលបានបណ្តាលឲ្យ មនុស្សស្លាប់ ប្រមាណប្រាំរយនាក់ក្នុងមួយថ្ងៃៗ ។ ដោយព្រោះតែមូលហេតុទាំងឡាយនេះ ប្រទេសជិតខាង



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

ចង់យកទឹកដីខ្មែរ ទៅបែងចែកគ្នា ជា ២ ផ្នែកតែម្តងៗ ប្រទេសសៀម នៅពេលនោះប្រាថ្នា យកខេត្ត ពោធិ៍សាត់ កំពុងស្វាយ ឧដុង្គ សម្បូណ៌ ក្រចេះ និង ត្បូងឃ្មុំ ។ រីឯ ប្រទេសយួនវិញ គេចង់ក្តិចយក ផ្នែក ខាងត្បូង ទាំងអស់ តែម្តង មានជាអាទិ៍ ៖ ទឹកដីបាភ្នំ ទ្រាំង និង ភ្នំពេញ ។ នៅចំពោះមុខ ស្ថានភាពប្រកបដោយគ្រោះថ្នាក់នេះ ស្តេច អង្គ ដួង ក៏សម្រេចហៅបារាំងឲ្យមកជួយ ។ ប្រជាជនខ្មែរនៅពេលនោះ មានចំនួន មិនដល់ មួយលាន នាក់ ផង បើ យោងតាមឯកសារបារាំងខ្លះ។ ប៉ុន្តែតាមឯកសារខ្លះទៀត គឺ មានចំនួន ១ លាន ២ សែននាក់ ។ នៅពេលដដែលនោះ ប្រជាជនសៀម និងយួន ចេះតែកើនឡើងជាលំដាប់។ នៅឆ្នាំ ១៨៧៥ គឺ នៅពេលដែលបារាំងមកគ្រប់គ្រងស្រុកខ្មែរ បាន ១៣ ឆ្នាំ ប្រជាជនខ្មែរ មានតែ ១ លាន មួយសែន នាក់ប៉ុណ្ណោះ។ នេះ បើយោង ទៅតាមឯកសារ របស់ លោក អេដែន អែម៉ូញេ៉។ ប៉ុន្តែ ពីឆ្នាំ ១៨៧៥ មកដល់ឆ្នាំ ១៩៥៥ គឺ នៅក្នុងរយៈពេល ៩០ ឆ្នាំ ដែល បារាំង ត្រួតត្រាជួយរៀបចំស្រុក ប្រជាជនខ្មែរ បានកើន មួយជាបួន គឺ បានឈាន ដល់ ៤ លាន ៦ សែននាក់ នៅឆ្នាំ ១៩៥៧ ។

កិច្ចការ កែទម្រង់ ដែលបារាំង បានបង្ខំឲ្យខ្មែរធ្វើ ដើម្បីឈានទៅរក ភាពសម័យទំនើប ចាប់ផ្តើមពី ការទារពន្ធដារ និង ការវាយរំលំអ្វី ដែលបារាំងចាត់ទុកថាជា ទាសភាព និង ជាអំពើពុករលួយ របស់មន្ត្រីរាជការ។ ប្រជាជនខ្មែរបានចេញផុតបន្តិចម្តងៗ ពី របបសក្តិភូមិ ប៉ុន្តែ ពន្ធអាករ ធ្ងន់ធ្ងរពេក ជាហេតុបណ្តាល ឲ្យមានទំនាស់ រវាង ប្រជាជន នឹងរដ្ឋបាលបារាំង។ បារាំងចូលចិត្ត ប្រើជនជាតិចិន ឲ្យរៀបចំបណ្តាញសេដ្ឋកិច្ច។ ពួកគេឡើងបាន ហើយមាន សិទ្ធិជាងខ្មែរ ជាម្ចាស់ស្រុកទៅទៀត។ បន្តិចម្តងៗ ជនជាតិចិននៅស្រុកខ្មែរ ក្តាប់ សេដ្ឋកិច្ច ខ្មែរ យ៉ាងណែន ហើយបន្តិចម្តងៗ កសិករខ្មែរ ជំពាក់ប្រាក់ចិនរកដោះខ្លួនមិនរួច ។ ស្រូវមួយថាំង ត្រូវសងវិញពីរថាំង។ ចិនធ្វើពាណិជ្ជកម្ម ផលិតផលស្រូវ ទាំងអស់ ។ ប៉ុន្តែ បើគេចង់ធ្វើការគាបសង្កត់ទៅលើឈ្មួញចិន ក៏កាន់តែពិបាកទៅទៀត។ នៅជំនាន់ ឆ្នាំ ១៩៥០

បញ្ញវន្តខ្មែរម្នាក់ បានកត់សំគាល់ថា ៖ ប្របាច់ ក ចិន លៀនអណ្តាតខ្មែរ ។ ដូច្នេះ កសិករខ្មែរ មានប្រកតែមួយគត់ គឺលក់ដីស្រែចំការតែម្តង ហើយរត់ទៅរកស៊ី បន្តិច បន្តួចនៅតាមទីក្រុង។ តាមការពិតទៅ អភិក្រមទំនើបកម្មប្រទេសកម្ពុជា ក៏ជាការនាំ ឲ្យមាន ទំនាស់ រវាង វប្បធម៌ នឹង វប្បធម៌ ដែរ ។ បារាំងយល់ថា របៀបរស់នៅ របស់ខ្មែរច្រើនតែមានលក្ខណៈផុយពីក្រិតក្រម នៃ ការរីកចម្រើន ។ ខ្មែរច្រើន គិត អ្វីៗ ទៅតាម មនោសញ្ចេតនា គឺ និយមការអាណិតអាសូរជាងគោលការណ៍ច្បាប់។ ហេតុដូច្នេះហើយ បានជា គេតែងតែត្អូញត្អែរថា «យល់ញាតិ ឃាតច្បាប់» ។ ខ្មែរ ជាអ្នកដែលចូលចិត្តយកអាសាគ្នា។ ប៉ុន្តែក្រឹត្យក្រម សេដ្ឋកិច្ចសេរីនិយម ដែលបារាំង បាននាំមក ជា ក្រឹត្យក្រម នាំទៅរក ការរីកចំរើន ក៏ពិតមែនតែ ក៏ ប្រាសចាកមនោ សញ្ចេតនា និង ការយោគយល់ផងដែរ ។ ខ្មែរពិបាកទ្រាំទ្រណាស់ ។ ទោះជាយ៉ាង ណាក្តី នៅជំនាន់ហ្លួង ស៊ីសុវត្ថិ ខ្មែរបានរក្សាទឹកដី ផ្នែកខាងជើង របស់ខ្លួន បាន គង់វង់ដដែលវិញ ដោយសារបារាំង ។ ជីវភាពប្រជាជនទោះបីមិនបានធូរធារ ក៏កាន់ តែមានលក្ខណៈទំនើបដែរ គឺ មានពេទ្យព្យាបាលរោគ មានសាលារៀន ថ្វីបើ ពុំមាន គ្រប់គ្រាន់ក៏ដោយ។ តាំងពីពេលនោះមក ខ្មែរយើងត្រូវស្ថិតនៅ រវាង លោកទស្សនៈ ពីរ៖ មួយ តាមបែបបទមនោសញ្ចេតនានិយម ដែលជារបៀបខ្មែរ ហើយមួយទៀត គឺ ការគោរពច្បាប់ គោរព សណ្តាប់ធ្នាប់ថ្មី ដែលធានាការរីកចំរើន ទៅតាម ដំណើរ ពិភពលោកសម័យទំនើប។ តាំងពីពេលនោះមក សង្គមខ្មែរចាប់ផ្តើម មានការបែង បែកច្បាស់ រវាង អ្នករស់នៅ តាមបែបប្រពៃណីខ្មែរសុទ្ធសាធ នឹង អ្នកដែលរស់នៅ តាមរបៀបបារាំង។ គឺ អ្នកចុងក្រោយនេះហើយ ដែលក្រោយមក បានក្លាយទៅជា បញ្ញវន្ត។ អ្នកមានធូរធារ ព្រមទាំងរាជវង្សានុវង្ស និងមន្ត្រីតូចធំ បញ្ជូនកូនឲ្យទៅ រៀន សាលាបារាំង ។ នៅតាមជនបទ កុមារ និង យុវជន ទៅរៀននៅសាលាវត្ត ។ អ្នកស្រែចំការ ដែលចង់ ឲ្យកូន មានអនាគតល្អ ក៏ ដាច់ចិត្ត បញ្ជូនកូនឲ្យទៅរៀន សាលាបារាំង នៅទីក្រុងដែរ ទោះជាត្រូវលក់ ដីស្រែ ក៏ដោយ ។





# សភាពការណ៍ ប្រទេស កម្ពុជា នៅក្នុងរជ្ជកាល ហ្លួង មុនីវង្ស

## La situation du Cambodge sous le règne de Monivong

នៅក្នុងរាជ្យព្រះបាទស៊ីសុវត្ថិ មុនីវង្ស មានព្រឹត្តិការណ៍សំខាន់ពីរ ដែលធ្វើឲ្យ ប្រវត្តិវិទូ ចាប់អារម្មណ៍ជាងគេ។ ព្រឹត្តិការណ៍ ទី ១ គឺសៀមឈ្លានពានទឹកដីខ្មែរ សា ជាថ្មីទៀត ។ ព្រឹត្តិការណ៍មួយទៀត គឺការតស៊ូរបស់ បញ្ញវន្តខ្មែរ ដេញបារាំងចេញពី ស្រុក។ នៅឆ្នាំ ១៩៤០ ឆ្លៀតឱកាសបារាំងចាញ់សង្គ្រាមនៅអឺរ៉ុប កងទ័ពជប៉ុន បាន ចូលមកក្នុងតំបន់អាស៊ីអាគ្នេយ៍។ ប្រទេសសៀម ដែលនៅពេលនោះ ទើបនឹងបានប្តូរ ឈ្មោះ មកជា ប្រទេសថៃ បានឆ្លៀតយកពេលបារាំង ចុះទន់ខ្សោយ ដើម្បីវាយយក ទឹកដីខ្មែរ ម្តងទៀត ។ ទោះបីបារាំងមានតែ កងវរសេនាតូចប្រាំប៉ុណ្ណោះនៅលើទឹកដី ខ្មែរក្តី ក៏បារាំងបានធ្វើការទប់ល់យ៉ាងស្វិតស្វាញដែរ ។ កងទ័ពថៃ ចូលមកក្នុង ទឹកដី ខ្មែរបានតែ ១០០ គ,ម. ប៉ុណ្ណោះ ។ ថៃ បានបញ្ជូនកងទ័ព តាមសមុទ្រទៀត ប៉ុន្តែ បារាំងបានកំទេចនាវាចម្បាំងថៃ អស់គ្មានសល់ ។ ថ្វីបើ ថៃ ទទួលបរាជ័យក្តី ក៏ជប៉ុន បានជួយថៃ ឲ្យវាយយកខេត្របាត់ដំបង និងសៀមរាប របស់ខ្មែរវិញបានដែរ។ ទន្ទឹម នោះ ទឹកដីខ្មែរដែលស្ថិតនៅ ត្រើយខាងលិចទន្លេ មេគុង បានធ្លាក់ទៅក្នុងកណ្តាប់ ដៃសៀម។ ជប៉ុន បានធ្វើការគាបសង្កត់ ទៅលើឧត្តមសេនីយ៍បារាំង ស្ហង់ ដឺគូ (Jean Decoux) ឲ្យ ចុះហត្ថលេខា ទៅលើសន្ធិសញ្ញាមួយចុះ ថ្ងៃ ៩ ឧសភាឆ្នាំ ១៩៤១ ។ តាមរយៈសន្ធិសញ្ញានោះ បារាំងបានធ្វើ សម្បទានសំខាន់ៗ ទៅឲ្យជប៉ុន។ សូមបញ្ជាក់ថា ព្រឹត្តិការណ៍នេះ កើតមានឡើង នៅចុងរាជ្យ ព្រះបាទមុនីវង្ស និង មុនការឡើងគ្រងរាជ្យ នៃ ព្រះបាទ នរោត្តម សីហនុ បន្តិច ។

នៅឆ្នាំ ១៩៣៦ គឺ ប្រាំឆ្នាំមុនពេលដែលព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ចូលជីវង្គត ប្រទេសកម្ពុជា បានជួបប្រទះ នឹង ព្រឹត្តិការណ៍មួយទៀត គឺ ការកកើតឡើង នៃ ក្រុម បញ្ញវន្តអ្នកស្នេហាជាតិមួយក្រុម ដែលបន្តវេន ពីអាចារ្យស្វា ពោធិកំបោរ អ្នកតស៊ូដេញបារាំង នៃសតវត្ស ទី ១៩។ នៅ ថ្ងៃ ៥ ឧសភាឆ្នាំ ១៩៣៦ នោះ សិស្សវិទ្យា ល័យស៊ីសុវត្ថិ នាំគ្នាធ្វើកូដកម្ម ប្រឆាំង នឹង បារាំង ព្រោះ បារាំងបានតម្រូវឲ្យសិស្ស លើសពីអាយុ ២០ ឆ្នាំឡើងទៅ បង់ពន្ធដារ។ ព្រឹត្តិការណ៍ មួយទៀត ដែលបញ្ជាក់ ពីការវិវត្តន៍ នៃ សកម្មភាព របស់បញ្ញវន្តខ្មែរ នៅពេលនោះ គឺ ការបង្កើតកាសែត ជាភាសាខ្មែរមួយឈ្មោះ *នគរវត្ត* ។ គឺជា កាសែត ភាសាខ្មែរមុនដំបូងបង្អស់ ដែលបានក្លាយទៅជាមូលដ្ឋានមួយ ដ៏សំខាន់ នៃ ការតស៊ូប្រឆាំង នឹង បារាំង។ មុន កាសែត *នគរវត្ត* នេះ ខ្មែរមានទស្សនាវដ្ដី អក្សរសាស្ត្របី គឺ ៖ *កម្ពុជាសុរិយា*, *រាត្រី ថ្ងៃសៅរ៍* និង *ស្រុកខ្មែរ* ។ កាសែត *នគរវត្ត* ដែលបានត្រូវបង្កើតឡើងនៅ ខែ ធ្នូ ឆ្នាំ ១៩៣៦ ដោយ លោក សឺន ង៉ុក ថាញ់ និង លោក ប៉ាច ឈឺន មានឥទ្ធិពលដ៏ធំ ទៅលើប្រជាជនខ្មែរ ព្រោះជាកាសែត ដែលសរសេរជាភាសាខ្មែរ។ លោក ប៊ុន ចាន់ ម៉ុល បានកត់សំគាល់នៅក្នុងសៀវភៅ *"គុកនយោបាយ"* របស់លោកថា «ការតស៊ូបានធ្វើដំបូងឡើង តាមផ្លូវសារពត៌មាន" ។ លោក ប៊ុន ចាន់ម៉ុល ដែលនៅ ឆ្នាំ ១៩៤២ បាន ត្រូវបារាំងចាប់ យកទៅដាក់គុក នៅ កោះត្រឡាច បានបញ្ជាក់ថា ៖ ក្រៅ ពីលោក សឺន ង៉ុក ថាញ់ និង លោក ប៉ាច ឈឺន អ្នកដែលបានចូលរួម បង្កើតកាសែតនេះ មានជាអាទិ៍ លោក នួន ប៊ុត (ម្ចាស់បណ្ណាគារ ប៊ុត នាង) លោក អ៊ុក សេន, លោក ស៊ុន វ៉ាន់, លោក ប៊ូ ហ៊ីង, លោក ជុំ មួង, លោកគ្រូអាចារ្យ ហែម ចៀវ និង លោក នួន ឌួង។ អ្នកដែលបានជួយ ជ្រោមជ្រែង កាសែតនេះម្នាក់ទៀត គឺលោកចៅក្រមសាលាដំបូង ស៊ឹម វ៉ា។ បញ្ហានយោបាយ ដែលចោទឡើងនៅពេលនោះ គឺការដែលបារាំង ដាក់ឲ្យជនជាតិវៀតណាមត្រួតត្រាខ្មែរ ជាហេតុធ្វើឲ្យខ្មែរ មាន ការទោមនស្ស យ៉ាងខ្លាំង ។ នៅឆ្នាំ ១៩៣០ នៅក្នុងរជ្ជកាលហ្លួង





មុនីវង្ស នេះដែរ នៅប្រទេសវៀតណាម «បក្សកុម្មុយនិស្តឥណ្ឌូចិន» បានចាប់បដិសន្ធិឡើង ក្រោមការ ដឹកនាំ របស់ ហូ ជី មិញ។ ជនជាតិខ្មែរម្នាក់ ឈ្មោះ សឺង ង៉ុក មិញ ក៏ជា សមា ជិក បក្សកុម្មុយនិស្តឥណ្ឌូចិននោះដែរ។ ក្រោយមក សឺង ង៉ុក មិញ បានក្លាយទៅជាអ្នកដឹកនាំ ចលនាឥស្សរៈខ្មែរមួយក្រុមហើយមានឈ្មោះថា «អាចារ្យមាន» ដូច្នេះវិញ ។ ក្រោយមកទៀត ចលនាឥស្សរៈខ្មែរ មានច្រើនក្រុម ដែលមានគោលដៅខុសៗគ្នា។ ចលនាឥស្សរៈ របស់ លោក សឺន ង៉ុក ថាញ់ ដែលមានឈ្មោះថា ចលនា «ខ្មែរសេរី» មិនត្រឹមតែប្រឆាំង នឹង បារាំងប៉ុណ្ណោះទេ គឺក្រោយមក ប្រឆាំង នឹង យួន កុម្មុយនិស្តទៀតផង ។ ចលនាឥស្សរៈ របស់ អ្នកអង្គម្ចាស់ នរោត្តម ច័ន្ទរង្សី ក៏ ជា ចលនាប្រឆាំង នឹង បារាំងដែរ ប៉ុន្តែ ជាអ្នកការពារ របបរាជានិយមជាពិសេស ការពារ ខ្សែរាជវង្ស នរោត្តម ។ មតិខ្លះយល់ថា ច័ន្ទរង្សី ចង់ឡើងគ្រងរាជ្យ ។ ការពិត អ្នកអង្គម្ចាស់អង្គនេះ ដែលជាបុត្រ របស់ ព្រះអង្គម្ចាស់ចន្ទលេខា (ព្រះរាជបុត្រ របស់ ព្រះបាទនរោត្តម) គ្រាន់តែជាមេឥស្សរៈម្នាក់ តំណាងរាជវង្ស នរោត្តម ដែលធ្វើការតស៊ូប្រឆាំង នឹងបារាំងប៉ុណ្ណោះ ។ ប៉ុន្តែ ពេលត្រឡប់មកពីសន្និសីទទីក្រុងហ្សឺណែវ (ឆ្នាំ ១៩៥៤) ស្រាប់តែត្រូវព្រះមហាក្សត្រ ចាប់យកទៅដាក់គុកតែម្ដង ដោយត្រូវចោទ ប្រកាន់ថា ជាជនក្បត់ចង់វាយរំលំព្រះអង្គ ។ អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រខ្មែរ បានអធិប្បាយរឿងនេះ យ៉ាងក្បោះក្បាយ (Ros Chantraboth : *La République khmère*, Editions L'Harmattan, Paris,1993, p. 87; Khing Hoc Dy : *Ecrivains et expressions littéraires du Cambodge au XX ème siècle*, L'Harmattan, Paris, 1993, p. 78 ) ។

រជ្ជកាល ហ្លួងមុនីវង្ស (១៩២៧-១៩៤១) ជាសម័យកាលមួយ ដែលបារាំងខិតខំប្រឹងប្រែងជួយ ឲ្យវប្បធម៌ខ្មែរ រីកចម្រើនឡើងវិញ ។ អ្នកប្រាជ្ញបារាំង លោកស្រី ស៊ុយសាន ការពើឡេស (Suzanne Kapelès) បានបង្កើតការិយាល័យ ស្រាវជ្រាវអក្សរសាស្ត្រខ្មែរមួយនៅឆ្នាំ ១៩២៧ ហើយបានចាប់បោះពុម្ពផ្សាយទស្សនាវដ្ដី *កម្ពុជា សុរិយា* ពីពេលនោះមក។ លោកស្រី ស៊ុយស្សាន ជាបញ្ញវន្តបារាំងម្នាក់ដែលប្រឆាំង នឹង អាណា

*និគមនិយមបារាំង។ មកដល់ ឆ្នាំ ១៩៣០ ការិយាល័យនោះ មានឈ្មោះជាផ្លូវការ ថា វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ។ បញ្ញវ័ន្តបារាំង ដែលខិតខំការពារវប្បធម៌ខ្មែរ មានច្រើនទៀត ដូចជាលោក យ៉ក ក្រូល្យេ* (George Groslier) *ជាដើម ដែលនៅឆ្នាំ ១៩២០ បានបង្កើត «សាលារចនា» ។ នៅក្នុងវិស័យ រដ្ឋបាល ដើម្បីពង្រឹងការគ្រប់គ្រង តាមរបៀបសម័យទំនើប បារាំងបានបង្កើត «សាលាក្រមការ» មួយនៅឆ្នាំ ១៩១៤។ ក្រោយមក នៅឆ្នាំ ១៩១៧ «សាលាក្រមការ» នេះ បានក្លាយទៅជា «សាលារដ្ឋបាល» ខ្មែរ។ ទន្ទឹមនោះ គេក៏ធ្វើការកែទម្រង់ ់រចនាសម្ព័ន្ធ ពុទ្ធសាសនាដែរ ដោយបង្កើត «សាលាបាលីជាន់ខ្ពស់» នៅថ្ងៃ ១៥ កុម្ភៈឆ្នាំ ១៩១៥។ តាមការពិត នេះក៏ជា វិធានការ មួយដែរ សម្រាប់កុំឲ្យព្រះសង្ឃ ទៅសិក្សានៅទីក្រុងបាងកក បន្ទាប់ ពីបានដំណឹងថា មុនពេលសុគត ឬបាត់ខ្លួននៅឆ្នាំ ១៩០៤ ព្រះអង្គម្ចាស់យុគន្ធរ បានរៀបចំគម្រោងការប្រឆាំង នឹងបារាំង ជាមួយព្រះសង្ឃ ពីរ-បី អង្គ នៅស្រុកសៀម ។*

# *ការធ្វើទំនើបកម្ម នៅក្នុងរាជ្យហ្លួងនរោត្តម ហ្លួងស៊ីសុវត្ថិ និង ហ្លួងមុនីវង្ស*

## La modernisation du Cambodge sous les règnes de Norodom et Sisowath

*នៅឆ្នាំ ១៨៦៦ ដោយមាន ការផ្តួចផ្តើមគំនិត ពី រ៉េស៊ីដង់បារាំង ឌូដា ដឺ ឡាគ្រេ* (Doudart de Lagrée) *ព្រះបាទ នរោត្តម បានប្តូររាជធានីពី ឧដុង្គ មកភ្នំពេញ ។ ប៉ុន្តែទាល់តែមកដល់ឆ្នាំ ១៨៩៧ ទើបបារាំងចាប់ផ្តើមធ្វើការកែទម្រង់សំខាន់ៗបាន។ ការរៀបចំមុខមាត់ថ្មី នៃ ប្រទេសកម្ពុជា តាមព្រះរាជក្រិត្យ ចុះថ្ងៃ ១១ កក្កដា ឆ្នាំ១៨៩៧ បានជួប នឹង ឧបសគ្គច្រើនណាស់ ។ ព្រះបាទ នរោត្តម បានចាត់វិធានការ ធំៗ មួយ*





*ចំនួន តាមសេចក្តីស្នើសុំ ពី ទេសាភិបាល បារាំង ប៉ូល ឌូមែរ* (Paul Doumer) *។ នៅក្នុងវិស័យ រដ្ឋបាល ព្រះអង្គ បានបែងចែក និង កំណត់អំណាច ព្រមទាំងសមត្ថកិច្ចផ្សេងៗ ទៅតាមទស្សនាទាន បារាំង។ នៅឆ្នាំ ១៩០១ បារាំង បានសាកល្បងបង្កើតឃុំ ប៉ុន្តែនៅចន្លោះឆ្នាំ ១៩០២-១៩០៨ ឃុំ នៅតែគ្មានអត្ថិភាពដដែល។ ទាល់តែចាប់ពី ថ្ងៃ ៥ មិថុនាឆ្នាំ ១៩០៨ ទៅ នៅក្នុងរាជ្យ ហ្លួងស៊ីសុវត្ថិ ទើបការរៀបចំឃុំបានចាប់ផ្តើម ដោយអនុលោមទៅតាមព្រះរាជក្រឹត្យមួយ ដែលលុបតួនាទីចៅហ្វាយស្រុកចោល ។ គោលដៅនៃ ការបង្កើតឃុំ គឺដើម្បីសម្រួលដល់ ការទារពន្ធដារផង ហើយ បង្កើត ថវិការដ្ឋ តែមួយ ឲ្យបានច្បាស់លាស់ផង។ ទន្ទឹមនោះ របបទាសភាព ក៏បានត្រូវ លុបបំបាត់ចោលដែរ។ អ្នកបម្រើ របស់ ស្តេចដែលនៅឆ្នាំ ១៨៩០ មានចំនួន ដល់ទៅ ប្រាំពីរពាន់ប្រាំរយនាក់ (៧៥០០) នៅក្នុងនោះ មាន ទាសាទាសី ៥០០ នាក់ ក៏បានត្រូវបារាំងកាត់បន្ថយដែរ។ នៅក្នុងផែនការប្រែក្លាយរាជធានីភ្នំពេញ ឲ្យទៅជាទីក្រុងទំនើបមួយ ជាមជ្ឈមណ្ឌលនយោបាយ រដ្ឋបាល និងសេដ្ឋកិច្ច ឲ្យបានសមរម្យ បារាំង បានជីកព្រែកមួយ ប្រវែង ជាង ៣ គ.ម. នៅកណ្តាលទីក្រុង ដើម្បីយកដី ទៅចាក់ បំពេញ ថ្លុក បឹងបួ ផង ហើយ ដើម្បីឲ្យទូកចេញចូល ដឹកទំនិញ សព្វសារពើ បានស្រួលផង។ គឺ នៅសម័យនោះហើយ ដែលគេចាប់សង់ផ្ទះថ្ម ដ៏ល្អៗ តាមរចនាបទ បារាំងខ្លះ តាមទំនងស្ថាបត្យកម្ម ខ្មែរបុរាណខ្លះ ដូចជាព្រះរាជវាំង និង សារមន្ទីរ អាល់ប៊ែរ សារ៉ូ* (Musée Albert Sarrault) *ជាដើម ។ ព្រះរាជវាំង បានត្រូវបារាំងសាងសង់ តាំងពីពាក់កណ្តាលសតវត្សរ៍ ទី ១៩ មក ប៉ុន្តែ ទាល់តែមកដល់ឆ្នាំ ១៩១៩ ទើបបានត្រូវសម្ពោធ។ ឈ្មួញចិននាំគ្នារៀបចំតាំងហាងលក់ដូរ ព្រោងព្រាត។ ដើម្បីសម្រួលដល់ការទាក់ទង រវាងទីក្រុងសាយហ្គន និង ទីក្រុងភ្នំពេញ បារាំងបាន សាងថ្នល់ចាក់កៅស៊ូមួយប្រវែងជាង ១០០ គ. ម. តភ្ជាប់ ទីក្រុងទាំងពីរនេះ។ រីឯ ផ្លូវថ្នល់ ភ្នំពេញ-កំពត-ហាទៀង ដែលចាប់ផ្តើមស្ថាបនាតាំងពីឆ្នាំ ១៨៩៧ មក បាន ត្រូវអូសបន្លាយរហូត ដល់ឆ្នាំ ១៩១០ គឺអស់រយៈពេល ១៣ ឆ្នាំ ទើបបានធ្វើចប់ សព្វគ្រប់។ ផ្លូវនេះ មានប្រវែង ១៥២ គ.ម.។*

កិច្ចការទាំងឡាយដែលបារាំងធ្វើ នៅពេលនោះ គឺមានគោលដៅរៀបចំលំហ ភូមិសាស្ត្រនយោបាយមួយ សម្រាប់ ពង្រីងឥទ្ធិពល របស់គេ ។ តាំងពី ឆ្នាំ ១៨៨៧ មក បារាំងបានខិតខំធ្វើយ៉ាងណា បញ្ចូលប្រទេសកម្ពុជា ប្រទេសលាវ និង ប្រទេសវៀតណាមទៅក្នុងក្របខ័ណ្ឌភូមិសាស្ត្រនយោបាយនេះដែលគេហៅថា «សហភាពឥណ្ឌូចិន បារាំង» ដើម្បីឈាន ទៅបង្កើត «សហព័ន្ធឥណ្ឌូចិន» តែម្តងៗ ដោយគេមិនអាចកាត់ផ្តាច់ប្រទេសកម្ពុជា ពីប្រទេសសៀមបាន នៅឆ្នាំ ១៩៣២-១៩៣៣ បារាំង ក៏សម្រេចសាងសង់ ផ្លូវរទេះភ្លើង តភ្ជាប់ទីក្រុងភ្នំពេញ និង អារញ្ញ នៅជិតព្រំប្រទល់ថៃ ។ ក្រៅពីផ្លូវគមនាគមន៍ជាយុទ្ធសាស្ត្រនេះ បារាំង បានសាងសង់ផ្លូវជាតិ មួយចំនួនទៀត ដូចជា ផ្លូវភ្នំពេញ-បាត់ដំបង, ភ្នំពេញ-តាកែវ, ភ្នំពេញ-កំពង់ស្ពឺ ជាដើម ។ ផែនការ សាងសង់ ផ្លូវថ្នល់ផ្សេងៗទៀត ត្រូវទុកចោល ដោយមូលហេតុ ខ្វះថវិកា។ គ្រាន់តែផ្លូវទាំងនោះ សាងសង់ហើយភ្លាម ក្រុមហ៊ុនដឹកជញ្ជូនចិន ក៏កើតឡើង ព្រោងព្រាតភ្លាមដែរ ។ នៅឆ្នាំ ១៩១៨ រថយន្តឈ្នួលសម្រាប់ដឹកអ្នកដំណើរ មានចំនួន១៥ ។ សកម្មភាពសេដ្ឋកិច្ច ក៏ ចាប់ផ្តើមរីកចម្រើនៗ នៅក្នុងក្របខ័ណ្ឌនៃនយោបាយទំនើបកម្មនេះ ទន្ទឹមនឹងការទារពន្ធដារ យ៉ាងសន្ធឹកសន្ធាប់ បារាំង ក៏លើកកម្ពស់ ជីវភាពប្រជាជនដែរ ប៉ុន្តែ មិនសូវខ្លាំងក្លាប៉ុន្មានដូចនៅស្រុកយួនទេ គឺ មានតែមន្ទីរពេទ្យពីរប៉ុណ្ណោះ។ នៅក្នុងវិស័យយុត្តិធម៌ ទាល់តែមកដល់ ឆ្នាំ១៩២២ ទើប អំណាចតុលាការ ត្រូវកាត់ផ្តាច់ចេញពី អំណាចរដ្ឋបាល។ តាំងពីពេលនោះមក ចៅហ្វាយខេត្ត ត្រូវប្រគល់ការកាត់ក្តី ទៅឲ្យតុលាការដែលស្ថិតនៅក្រោមអំណាច របស់ ចៅក្រមបារាំងម្នាក់ ។ ដើម្បីសម្រួលកិច្ចការនៅក្នុងវិស័យ នេះ អ្នកឯកទេស បានចងក្រងសៀវភៅច្បាប់ និងបទបញ្ញត្តិផ្សេងៗ ដូចជាច្បាប់ រដ្ឋប្បវេណី ច្បាប់ព្រហ្មទណ្ឌជាដើម។ សៀវភៅទាំងនេះបានត្រូវបោះពុម្ពផ្សាយជាលើក ដំបូងបង្អស់ នៅឆ្នាំ ១៩១២ ។ ការកែទម្រង់ ដែលបារាំងបានធ្វើនៅក្នុងរាជ្យ ហ្លួងនរោត្តម និង ស៊ីសុវត្ថិ មានច្រើនណាស់ ប៉ុន្តែការកែទម្រង់ដែលសំខាន់ជាងគេ គឺ ការបង្កើត កម្មសិទ្ធិឯកជន ។ នេះជារឿងមួយថ្មី ចំពោះខ្មែរ ដែលធ្លាប់តែយល់ថា ដីធ្លី ជាកម្មសិទ្ធិ របស់





ស្តេចផែនដី។ នៅចន្លោះឆ្នាំ ១៨៨៤-១៩១២ ការដែលបារាំង ខិតខំនាំរបបសេដ្ឋកិច្ច សេរីនិយមនេះ មកដាក់នៅស្រុកខ្មែរ គឺគេមានគោលបំណង ពង្រីងមូលដ្ឋានសេដ្ឋកិច្ច របស់គេផ្ទាល់នៅក្នុងតំបន់ឥណ្ឌូចិន។ ការរៀបចំ របនាសម្ព័ននេះ បាននាំមក នូវ ភាពច្របូកច្របល់ និងបញ្ហាស្មុគស្មាញ ក្រៃលែង។ សម្រេចសម្រួលទៅ បរទេសក្តាប់ សេដ្ឋកិច្ចខ្មែរទាំងអស់។ ខ្មែរភាគច្រើនដែលធ្លាប់រាប់អាន ញាតិមិត្តជិតឆ្ងាយយកអាសាគ្នា ទៅវិញទៅមក មានការពិបាកយ៉ាងខ្លាំង ក្នុងការអនុវត្តន៍ គោលការណ៍ សេដ្ឋកិច្ចនេះ ។ បារាំងគេថា នេះមកតែពី ខ្មែរកាន់លទ្ធិពុទ្ធសាសនា។ តាមការពិត ខ្មែរកាន់ពុទ្ធសាសនា ក៏ ពិតមែន ប៉ុន្តែគេ ក៏ជាអ្នកដែលមិនបោះបង់ ប្រយោជន៍ លោកីយសច្ចៈចោល ឯណាដែរ ។ នៅតាមស្រែចម្ការ ក្រៅពីពុទ្ធសាសនា គេជឿអារក្ខអ្នកតា ដែលគ្មានប្រព័ន្ធ ទស្សនវិជ្ជាអ្វី ជ្រៅជ្រះ។ ទោះជាយ៉ាងណាក្តី ការអនុវត្តន៍ គោលការណ៍ច្បាប់ តាមបែបផែន លទ្ធិមូលធននិយម ដែលបារាំងបាននាំចូលមកនេះ មានអំណោយផល ជាពិសេស សម្រាប់អ្នក ដែលជោគជាំ ទៅដោយ ទស្សនវិជ្ជាកុងជឺ (confucius) ព្រមទាំងសាសនាផ្សេងៗទៀត។ កាលពីពេលមុន ខ្មែរធ្លាប់មានស្តេចជាអ្នកគ្រប់គ្រងទឹកដី ។ ស្តេចឲ្យអ្វី ក៏ចេះតែយកទៅហើយ ស្តេចយកអ្វីទៅវិញ ក៏មិនតវ៉ាអ្វីដែរ ។ ដីស្រែ ដែលស្តេចប្រទានឲ្យ មិនអាចយកទៅ លក់ដូរ បានទេ គឺត្រូវប្រគល់ទៅឲ្យស្តេចវិញ បើមិនព្រមយកទៅបង្កបង្កើតផលទេនោះ។ បើម្ចាស់ដីស្រែ ស្លាប់ប្រពន្ធ-កូន ដែលជាអ្នកទទួលមត៌កអស់ពោលគឺបើគ្មានអ្នកទទួល មត៌កទេនោះ ស្តេចយកដីនោះទៅវិញ។ នៅក្នុងក្របខ័ណ្ឌ នៃការប្រណាំងប្រជែង តាមបែបបទ នៃច្បាប់បារាំង ខ្មែររត់តាមចិន មិនទាន់ទេ ។ ខ្មែរជាផលិតករ រីឯ ចិន ជាអ្នកលក់ដូរផលិតផល ។ ខ្មែរ ចង់បានប្រាក់ប៉ុន្មាន យកទៅធ្វើបុណ្យទាន ក៏ចិនឲ្យខ្ចីដែរ តែត្រូវសងវិញ មួយថាំង ជា ពីរថាំងស្រូវ ។ នៅទីបំផុត អ្នកស្រែចម្ការ លក់កម្មសិទ្ធិ របស់គេអស់ ហើយដើរផ្សងព្រេងតាមទីក្រុង។ ដូច្នេះឃើញថា តាមរយៈការកែទម្រង់នេះ អ្នកទទួលផលល្អ គឺមានតែបារាំង និង ចិនប៉ុណ្ណោះ។ ជនជាតិចិន នៅស្រុកខ្មែរ មានតាំងពី សតវត្សរ៍ ទី ១៣ មក ប៉ុន្តែ នៅ ឆ្នាំ ១៨៧៤ កាន់តែ

មានចំនួនច្រើនថែមទៀត គឺ ១០ ភាគរយ នៃចំនួន ប្រជាជនខ្មែរទូទាំងប្រទេស។ តាំងពីពាក់កណ្ដាលសតវត្សរ៍ទី ១៩ មក ជនជាតិចិន នៅកម្ពុជា ក្ដាប់វិស័យ ពាណិជ្ជកម្ម វិស័យដឹកជញ្ជូនសឹងតែទាំងអស់ រួមបញ្ចូលទាំង សិប្បកម្មទីក្រុង ផងទៀត ។ នៅក្នុងវិស័យអប់រំ និង សិក្សាធិការ មុនឆ្នាំ ១៩២៧ ខ្មែរយើង រៀនសូត្រតាមសាលាវត្ត ប៉ុន្តែចាប់តាំង ពីឆ្នាំនោះមក សាលាវត្តទាំងនោះ បានត្រូវកែទម្រង់ រៀបចំខ្លួន ដើម្បី បោះជំហានឆ្ពោះទៅរកភាពសម័យទំនើប។ រីឯវិទ្យាល័យស៊ីសុវត្ថិ គឺសម្រាប់តែ កូនមន្ត្រីបារាំង និងមន្ត្រីខ្មែរប៉ុណ្ណោះ។ ទាល់តែមកដល់សម័យ សង្គមរាស្ត្រនិយម របស់ សម្ដេច នរោត្តម សីហនុ ទើបអនុវិទ្យាល័យ និង វិទ្យាល័យ ចាប់ផ្ដើមមាន នៅតាមខេត្ត ។







# ការឡើងសោយរាជ្យ លើកទី១ នៅ ឆ្នាំ១៩៤១ នៃ ព្រះបាទ នរោត្តម សីហនុ

## Premier règne du roi Norodom Sihanouk (1941)

នៅឆ្នាំ ១៩៤០ កងទ័ព ជប៉ុន បានចូលមកតាំងទី នៅក្នុង ភូមិភាគអាគ្នេយ៍ នៃ ទ្វីបអាស៊ី។ ប្រទេសថៃ ដែលនៅពេលនោះ ស្ថិតនៅក្រោម ឥទ្ធិពល របស់ ជប៉ុន បាន ឆ្លៀតយកស្ថានការណ៍នេះ ដើម្បីអែបជប៉ុនវាយយកទឹកដីខ្មែរម្ដងទៀត។ ប៉ុន្តែ ដោយមិនបានសម្រេចគោលបំណង ព្រោះតែបារាំង បានកំទេចនាវាចម្បាំងថៃអស់ ជប៉ុន ក៏ដើរតួជាអាជ្ញាកណ្ដាលវិញ។ ប៉ុន្តែក្រោយមកទៀត ជប៉ុនបានយកទឹកដីខ្មែរមួយផ្នែក ទៅឲ្យថៃ គឺ ទឹកដីដែលបារាំង បានយកមកឲ្យខ្មែរវិញ កាលពីឆ្នាំ ១៩០៧ ។ ជប៉ុន មិនហ៊ានប៉ះពាល់ដល់ ទីក្រុងសៀមរាប និង បុរីអង្គរទេ គឺរក្សាទុកឲ្យខ្មែរដដែល។ ហ្លួងមុនីវង្ស មានការអស់សង្ឃឹមយ៉ាងខ្លាំង ហើយ ក៏ចូលជីវង្គត នៅថ្ងៃ ២៣ មេសា ឆ្នាំ ១៩៤១ ។ ក្សត្រដែលត្រូវស្នងរាជ្យនៅពេលនោះ មានយ៉ាងហោចណាស់ ក៏ ពីរអង្គដែរ គឺព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត បុត្រច្បង របស់ព្រះបាទមុនីវង្ស និង ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស ដែលជាបុត្រពៅ របស់ព្រះអង្គម្ចាស់ចំរើនវង្ស (ដែលជាខ្សែព្រះបាទអង្គអេង) និង អ្នកអង្គម្ចាស់ក្សត្រី ស៊ីសុវត្ថិ យុពីផាន់ ។ ប៉ុន្តែ ដោយ ច្បាប់បន្តរាជ្យ បានត្រូវកំណត់យក ចាប់តាំងត្រឹមពី ខ្សែព្រះរាជវង្សព្រះបាទ អង្គ ឌួង គេពុំរាប់បញ្ចូល ព្រះអង្គម្ចាស់យុត្តិវង្ស ផងទេ ។ នៅចំពោះមុខ បញ្ហា ដ៏ ស្មុគស្មាញនេះ ឧត្តមនាវីបារាំង ស្ហង់ ដឺគូ (Jean Decoux) យល់ឃើញថា ដើម្បី ចៀសវាង ទំនាស់ រវាង ព្រះរាជវង្ស ស៊ីសុវត្ថិ និងព្រះរាជវង្ស នរោត្តម គេត្រូវ ជ្រើសរើសយក ក្សត្រអង្គណា ដែលជាប់ខ្សែ ព្រះរាជវង្សទាំងពីរតែម្ដង។ ដោយអនុវត្ត ទៅតាមទ្រឹស្ដីនេះ ឧត្តមនាវី ដឺគូ ក៏ដាក់ព្រះ

អង្គម្ចាស់ នរោត្តម សីហនុ ឲ្យឡើងគ្រងរាជ្យ បន្តពីហ្លួង មុនីវង្ស។ ព្រះបាទ នរោត្តម សីហនុ នៅពេលនោះ មានព្រះជន ១៩ ព្រះវស្សា។ ព្រះអង្គ កំពុងតែបំពេញវិជ្ជា នៅវិទ្យាល័យ សាស្ស៊្រឺលូ ឡូបាត៍ (Chasseloup Laubat) នៅ ទីក្រុងសាយហ្គន ។ ព្រះបាទនរោត្តម សីហនុ ជាបុត្រ របស់ព្រះអង្គម្ចាស់ នរោត្តម សុរាម្រឹត និង ព្រះអង្គម្ចាស់ក្សត្រីស៊ីសុវត្ថិ កុសមៈ ដែលជាបុត្រី របស់ ហ្លួងស៊ីសុវត្ថិ មុនីវង្ស ជាមួយ និង ព្រះអង្គម្ចាស់ក្សត្រី កាន់វិម៉ាន់ នរលក្ខណ៍ទេវី (បុត្រី របស់ ព្រះអង្គម្ចាស់ នរោត្តម ហាស្សកាន់) ។ ព្រះអង្គម្ចាស់ នរោត្តម ហាស្សកាន់ ជាព្រះរាជបុត្រ របស់ ព្រះបាទ នរោត្តម ។ រីឯព្រះអង្គម្ចាស់ នរោត្តម សុរាម្រិត ជាបុត្រ របស់ ព្រះអង្គម្ចាស់ សុត្ថារត្ន ដែលជាព្រះរាជបុត្រ របស់ ព្រះបាទនរោត្តមដែរ។ តាមការយល់ឃើញ របស់ អ្នកវិភាគខ្លះ ការដែលបារាំង បានសម្រេចជ្រើសរើសយកព្រះអង្គម្ចាស់ នរោត្តម សីហនុ គឺមកពី បារាំងចង់ផ្លាស់វេន ពីព្រះរាជវង្ស ស៊ីសុវត្ថិ មកព្រះរាជវង្ស នរោត្តម វិញម្តង ដើម្បីលុបបំបាត់អនុស្សាវរីយ៍អាក្រក់ ទាក់ទង នឹង ព្រះអង្គម្ចាស់យុគន្ធរ។ តាមប្រភពខ្លះទៀត ព្រះអង្គម្ចាស់ នរោត្តម សីហនុ អាច នឹងមានយុទ្ធសាស្ត្រទន់ភ្លន់ ជាមួយបារាំង ជាងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត ។ ការពិត ព្រះអង្គម្ចាស់ នរោត្តម សីហនុ មានលក្ខណៈពិសេសមួយ គឺ ព្រះអង្គចេះសម្របតាមស្ថានការណ៍ ទោះបីជាឥរិយាបទប្រកបទៅដោយគ្រោះថ្នាក់ក្តី។ នៅក្នុងទសវត្ស ១៩៤០នោះ ព្រះបាទ នរោត្តម សីហនុ ត្រូវប្រឈមមុខ នឹង ចលនាទាមទារឯករាជ្យ របស់ បញ្ញវន្តខ្មែរ ដឹកនាំដោយ សឺន ង៉ុកថាញ់ ហើយបន្ទាប់មកទៀត ត្រូវទប់ទល់នឹង គណបក្សប្រជាធិបតេយ្យ ជាពិសេស នឹងព្រះអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស ដែលបានត្រូវគេចាត់ទុកថា ជាបញ្ញវន្ត ម្នាក់ ដ៏ឆ្នើម និងដ៏វិសេសវិសាល។ ព្រះអង្គម្ចាស់យុត្តិវង្ស មិនត្រឹមតែមានសញ្ញាប័ត្របណ្ឌិតរដ្ឋ ខាងរូបវិទ្យា នៃសកលវិទ្យាល័យបារាំងប៉ុណ្ណោះទេ គឺថែមទាំងមានបទពិសោធន៍ នយោបាយផងទៀត។ នៅពេលដែលព្រះអង្គម្ចាស់ នរោត្តម សីហនុ ឡើងគ្រងរាជ្យ ប្រទេសកម្ពុជាស្ថិតនៅក្នុងស្ថានភាពមួយ ដ៏ស្មុគស្មាញ ។ កាលនោះ ប្រទេសបារាំង ក្រោមការដឹកនាំ



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

របស់ សេនាប្រមុខប៉េតាំង (Pétain) ត្រូវកងទ័ព ហ៊ីត្លែរ ចូលឈ្លានពានទឹកដី។ រីឯប្រទេសកម្ពុជាវិញ ក៏ស្ថិតនៅចំពោះមុខ ការគំរាមកំហែង ពីសំណាក់ប្រទេស ថៃ និងពីកងទ័ពជប៉ុនដែរ។ ចលនាបញ្ញវន្តខ្មែរ ប្រឆាំងនឹងបារាំង ក្រោមការដឹកនាំរបស់ សឺន ង៉ុកថាញ់ សង្ឃឹមថា ជប៉ុន អាចជា បង្អែកមួយ ក្នុងការតស៊ូ របស់គេ ទៀតផង ។ នៅថ្ងៃ ២០ កក្កដាឆ្នាំ ១៩៤២ ក្រោម ការដឹកនាំ របស់សឺនង៉ុកថាញ់ មហាបាតុកម្មប្រឆាំង នឹងបារាំងមួយ បានផ្ទុះឡើងនៅ កណ្តាលទីក្រុងភ្នំពេញ។ ព្រះសង្ឃជាច្រើនអង្គ បានចូលរួម។ បាតុករមួយចំនួន ដូចជាអាចារ្យ ហែម ចៀវ លោក ប៉ាច ឈឺន លោក ប៊ុន ចាន់ម៉ុល ជាដើម បានត្រូវបារាំង ចាប់យកទៅដាក់គុក នៅកោះត្រឡាច។ រីឯ លោក សឺន ង៉ុក ថាញ់ លោក បានគេចរួចផុតពីការចាប់ខ្លួន ហើយរត់កៀសខ្លួនទៅដល់ ទីក្រុងតូក្យូ ប្រទេសជប៉ុន។

នៅថ្ងៃ ៦ មិថុនា ឆ្នាំ ១៩៤៤ ប្រទេសបារាំង ចាប់ផ្តើមរំដោះខ្លួនចេញ ពីរបបហ៊ីត្លែរ ហើយនៅថ្ងៃ ២៤ សីហា ឆ្នាំដដែលនោះ ឧត្តមសេនីយ៍ ដឺ ហ្គោល (le général De Gaulle) និង អ្នកតស៊ូបារាំង បានដណ្តើមយក ទីក្រុងប៉ារីស៍ ពីអាល្លឺម៉ង់ បានមកវិញ។ នៅខែកុម្ភៈ ឆ្នាំ ១៩៤៥ យន្តហោះ សម្ព័ន្ធមិត្តប្រឆាំង នឹងហ៊ីត្លែរ គឺ បារាំង និង អាមេរិកាំង បានទម្លាក់គ្រាប់បែក ទៅលើទីក្រុងភ្នំពេញ ដើម្បីកំទេច ទិតាំង កងទ័ពជប៉ុន។ ប៉ុន្តែនៅ ថ្ងៃ ៩ មិនា ឆ្នាំដដែល ជប៉ុន បានវាយទីតាំងបារាំង នៅកម្ពុជាបានវិញ ហើយនៅថ្ងៃ១២ មិនា ជំរុញឲ្យ ព្រះមហាក្សត្រខ្មែរ ប្រកាសឯករាជ្យ បញ្ចប់អាណាព្យាបាលបារាំងនៅស្រុកខ្មែរ។ កងទ័ពជប៉ុន ដឹកនាំដោយ ឧត្តមសេនីយ តូសូ (Tojo) បានស្នើឲ្យលោក តាន់ ប៉ា ធ្វើប្រមុខរដ្ឋាភិបាលខ្មែរ ។ លោក តាន់ ប៉ា ដែលជាសេដ្ឋីចិនម្នាក់មានឥទ្ធិពលនៅស្រុកខ្មែរ ពុំព្រមទទួលភារកិច្ចនេះទេ។ នៅទីបំផុត ឧត្តមសេនីយ៍ជប៉ុន ក៏តែងតាំង លោក អ៊ឹង ហ៊ី ជានាយករដ្ឋមន្ត្រី។ គណរដ្ឋមន្ត្រី ដែលចាត់តាំងនៅថ្ងៃ ៩ មិនា ឆ្នាំ ១៩៤៥ នោះ មាន លោក ទា សាន ជា អ្នកទទួលបន្ទុកខាងកស្តុភារ លោក មាស ណាល់ ខាងអប់រំជាតិ លោក ចាន់ ណាក់ ក្រសួងយុត្តិធម៌

*ព្រះអង្គម្ចាស់ នរោត្តម ម៉ុងតាណា ទទួលបន្ទុកខាងសេដ្ឋកិច្ច លោក ស៊ុម ហ៊ាង ក្រសួងមហាផ្ទៃ ។ នៅថ្ងៃ ១៦ មេសា លោក ប៉ែន នុត ត្រូវតែងតាំងជា អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុ ដោយមាន លោក ប្រាក់ប្រាព្រឿង ជា អធិការហិរញ្ញវត្ថុ បន្ថែមទៀត ។ ព្រះមហាក្សត្រខ្មែរ ព្រះបាទនរោត្តម សីហនុ ក៏បានត្រូវបង្ខំចិត្ត ដឹកនាំ អង្គប្រជុំក្រុមប្រឹក្សារដ្ឋមន្ត្រី នេះដែរ។ ប៉ុន្តែស្រាប់តែនៅ ថ្ងៃ ៦ មិថុនា លោក សឺន ង៉ុក ថាញ់ ដែលទើបនឹង វិលត្រឡប់មក ពី ប្រទេសជប៉ុន បានត្រូវតែងតាំង ជា រដ្ឋមន្ត្រី ការបរទេស។ បន្ទាប់មក នៅថ្ងៃ ១០ សីហាឆ្នាំ ១៩៤៥ ដដែលនោះ លោក សឺន ង៉ុក ថាញ់បានត្រូវតែងតាំង ជារដ្ឋមន្ត្រី ទី ១ តែម្តង។ សមាជិក គណរដ្ឋមន្ត្រី ដែលបានត្រូវចាត់តាំង នៅថ្ងៃ ១៤ សីហា គឺ ៤ ថ្ងៃ ក្រោយមក មានជាអាទិ៍ ៖ ព្រះអង្គម្ចាស់ នរោត្តម ម៉ុងតាណា រដ្ឋមន្ត្រីកសិកម្ម លោក ស៊ុម ហ៊ាង រដមន្ត្រីមហាផ្ទៃ លោក ប៉ាច ឈឺន រដ្ឋមន្ត្រីកស្តុការ លោក វ៉ា កាម៉ែល ខាងធម្មការ លោក ពីទូ ដឺ ម៉ុងតេរ៉ូ ខាងយុត្តិធម៌ លោក ឃីម ទិត ខាងការពារប្រទេស លោក ញឹក ជូឡុង សេដ្ឋកិច្ច លោក ប៉ែន នុត ហិរញ្ញវត្ថុ ។ មួយថ្ងៃក្រោយមក ជប៉ុន ប្រកាសចុះចាញ់សង្គ្រាម ហើយបារាំង ក៏ វិលមក ឥណ្ឌូចិនវិញ ។ នៅ ថ្ងៃ ១៥ តុលា ឧត្តមសេនីយ៍ បារាំង ឡឺក្លែរ មកដល់ទីក្រុងភ្នំពេញ ហើយ ចាប់ លោក សឺន ង៉ុក ថាញ់ យកទៅដាក់គុក នៅប្រទេសបារាំង ។*

## *ឆ្ពោះទៅរក ការទាមទារ ឯករាជ្យ និង ការកកើតឡើង នៃ គណបក្សប្រជាធិបតេយ្យ*

## Vers l'Indépendance nationale et la création du Parti démocrate





*នៅពេលដែលព្រះបាទ នរោត្តម សីហនុ បានត្រូវអភិសេកជាព្រះមហាក្សត្រនៃ ប្រទេសកម្ពុជា - គឺ នៅថ្ងៃ ២៨ តុលាឆ្នាំ ១៩៤១ - ព្រះអង្គមានព្រះជន ១៩ ព្រះវស្សា។ កាលព្រះអង្គនៅជាព្រះរាជកុមារ ព្រះរាជហោរា របស់ហ្លួង មុនីវង្ស បានទស្សន៍ទាយថា ព្រះអង្គ នឹង កាន់មុខតំណែងមួយ ដ៏ធំ ក្នុងព្រះរាជាណាចក្រ ប៉ុន្តែព្រះអង្គត្រូវប្រយុទ្ធ នឹងសត្រូវ ដ៏គ្រាក់ៗដោយគេចពុំផុត។ ទំនាយនេះ ក៏ពុំខុសប៉ុន្មានដែរ ព្រោះថា បន្ទាប់ពីបានប្រយុទ្ធ នឹង គូប្រជែង ព្រះអង្គ ត្រូវប្រយុទ្ធ នឹង សត្រូវដែលមាន ឫទ្ធិអំណាច ខ្លាំងក្លាអស្ចារ្យថែមទៀត។ នៅឆ្នាំ ១៩៤៩ នៅពេលដែល គណបក្សប្រជាធិបតេយ្យ បានបាត់បង់អ្នកដឹកនាំសំខាន់ៗ របស់គេសឹងតែអស់ ព្រះបាទនរោត្តម សីហនុ ចាប់ផ្តើមទទួលជ័យជំនះ ជាបន្តបន្ទាប់នៅក្នុងឆាកនយោបាយ ក្នុងប្រទេស ។ គឺជ័យជំនះនេះហើយ ដែលបានកំណត់ ជោគវាសនា របស់ ប្រទេស កម្ពុជា ជាង ២០ ឆ្នាំក្រោយមក ឬ ក៏ រហូត មកដល់សព្វថ្ងៃនេះផង  ក៏អាចថាបាន ។*

*ពីពេលបានឯករាជ្យ នៅឆ្នាំ ១៩៥៣ មកដល់ ឆ្នាំ ១៩៦៨ ប្រវត្តិវិទូខ្លះ យល់ថាជាសម័យ រុងរឿង ដែលប្រជាកសិករ រស់នៅ ក្នុងសុខសន្តិភាព ហើយមាន ជីវភាពមិនសូវ ជាយ៉ាប់យ៉ឺនប៉ុន្មាន។ ចំពោះមតិខ្លះទៀត គឺជា សម័យ ដែលមហាព្យុះសង្ឃរាមួយ បានបោកបក់វក់វី ទៅលើ «នាវា» កំសត់តូចមួយ ដែលអណ្តែតត្រសែតទៅតាមរលក ដ៏ធំមហិមា នៃ មហាសាគរ ។ តាមការពិតទៅ វាសនា របស់ ប្រទេសកម្ពុជាក៏ដូចជា វាសនា របស់ អ្នកដឹកនាំខ្មែរ នៅពេលនោះដែរ ពុំអាចកាត់ផ្តាច់ចេញ ពីការប្រទាញប្រទង់ ពីការវិវាទ រវាង ប្រទេសមហាអំណាចបានទេ គឺថា បើចូលទៅក្នុងជួងមហាអំណាចណាមួយ នឹង ត្រូវម្ខាងទៀត វាយសំប៉ែតដូចតែគ្នា ។ ខ្ញុំ នឹងនិយាយ រៀបរាប់ អំពី ការប្រជែងកម្លាំងគ្នានេះ ជាបន្តបន្ទាប់មកទៀត។  រជ្ជកាល ព្រះបាទ នរោត្តម ស៊ីហនុ មានជាច្រើនដំណាក់ការ ។ ដំណាក់ការដែល បារាំងវិលត្រឡប់ មកកម្ពុជាវិញ អាចចាត់ទុកថា ជាដំណាក់ការទី ២។ ដើម្បីស្រួលយល់ អំពី ដំណាក់ការទី ២ នេះ ខ្ញុំសូមបញ្ជាក់ថា ចាប់តាំង ពីឆ្នាំ ១៩៤៨ ទៅ ព្រះបាទ នរោត្តម ស៊ីហនុ ត្រូវប្រយុទ្ធ នឹង*

គូប្រជែងផង នឹង គូសត្រូវផង ។ ពេលខ្លះគូប្រជែង ក្លាយទៅជាគូសត្រូវ ហើយសត្រូវក្លាយទៅជាសម្ព័ន្ធមិត្ត ។ គូប្រជែងខ្លះ បានបាត់បង់ជីវិត នៅក្នុងវិរភាព ខ្លះទៀតសុខចិត្តជ្រកកោនក្រោមម្លប់បារមី របស់ព្រះអង្គ ហើយខ្លះទៀតបាត់បង់ទ្រព្យសម្បត្តិ កិត្តិយសអស់គ្មានសល់។ នៅ ក្នុងរយៈពេលជាងកន្លះ សតវត្សរ៍ កន្លងមកនេះ ក្រោមការដឹកនាំរបស់ ព្រះបាទនរោត្តម សីហនុ ក៏ ដូចជា របស់ តួអង្គ នយោបាយ នានាឯទៀតដែរប្រទេសកម្ពុជា បានប្រយុទ្ធ ទាមទារឯករាជ្យ យ៉ាងស្វិតស្វាញ ហើយក្រោយមកទៀតត្រូវប្រទេស មហាយក្សនានា ប្រទាញប្រទង់ ដោយឥតអាសូរ ។ យោងទៅតាមមតិខ្លះសោកនាដ្យ កម្មរបស់ខ្មែរ គឺ បណ្តាលមកពី ការដែលប្រទេស មហាយក្ស ទាំងឡាយនោះ បានយកតំបន់ ឥណ្ឌូចិន ទាំងមូល ធ្វើជាលានប្រយុទ្ធ ដណ្តើមឥទ្ធិពលគ្នាតែម្តង ។ រីឯ ប្រទេសកម្ពុជា ក៏ធ្វើការទាមទារឯករាជ្យ របស់ខ្លួន នៅពេលព្យុះសង្ឃរានោះដែរ គឺ នៅពេលមួយ ដែលនៅក្នុងពិភពលោកទាំងមូល ប្រទេស ដែលត្រូវគេធ្វើ អាណានិគម បាននាំគ្នាងើបឡើងប្រឆាំង នឹង ពួកអាណានិគមនិយម ។ តទៅនេះ ខ្ញុំសូមជូន នូវទិដ្ឋភាពខ្លះៗ នៃ ការតស៊ូ ដ៏ សំបើមអស្ចារ្យនេះ ដែលមានលក្ខណៈ ដ៏ ស្មុគស្មាញ ព្រោះតែ វរជនខ្មែរអ្នកស្នេហាជាតិ បានកំណត់យុទ្ធសាស្ត្រ និង បានជ្រើសរើស យកមនោគមវិជ្ជា និង បង្អែកខុសៗ ពីគ្នា ។ នៅថ្ងៃ ទី ៦ និង ទី ៩ សីហាឆ្នាំ ១៩៤៥ បន្ទាប់ពី សហរដ្ឋ អាមេរិក បានទម្លាក់គ្រាប់បែកបរមាណូ ទៅលើ អៀរ៉ូស៊ីម៉ា និង ណាក្កាសាគី គឺ ៤ ឆ្នាំ ក្រោយសោកនាដ្យកម្ម នៅ ពាល ហាប័រ / កងទ័ពជប៉ុន ត្រូវដកថយ ចេញពី តំបន់ដែលគេបានសាកល្បងកាន់កាប់ ។ បារាំង ក៏បានវិលមក ឥណ្ឌូចិនវិញ។ នៅថ្ងៃ ទី ១៥ តុលា ឆ្នាំដដែល ឧត្តមសេនីយ៍បារាំង ឡឺក្លែរ (Leclerc) បានបញ្ជាឲ្យចាប់ លោក សឺន ង៉ុកថាញ់ ហើយ បញ្ជូនទៅដាក់ ពន្ធនាគារ នៅ ប្រទេសបារាំង។ ព្រះបាទ នរោត្តម សីហនុ ដែលបានទៅសាងព្រះផ្នួស នៅ វត្ត បទុមវត្តី បានត្រូវបារាំងមកទទួល យាងត្រឡប់ទៅព្រះបរមរាជវាំងវិញ។ បន្ទាប់ពីបានជួបសន្ទនា ជាមួយ ស្នងការ ទី ១ នៃ សាធារណៈរដ្ឋ បារាំង គឺ វរសេនីយ៍ឯក ហ៊ុយអាដ៏ (Huard)





ព្រះបាទ នរោត្តម ស៊ីហនុ បានតែងតាំង ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត ជាព្រះបិតុលាឲ្យធ្វើជានាយករដ្ឋមន្ត្រី ហើយ បន្ត ការកសាង វាសនា ប្រទេសកម្ពុជា ជាមួយ បារាំងសាជាថ្មីទៀត ប៉ុន្តែ ដោយឈរនៅលើ មូលដ្ឋានមួយថ្មី ដែលគេហៅ ថា Modus Vivendi គឺ កិច្ចសន្យាមួយ ជាបណ្តោះអាសន្ន ដែលខ្មែរ និង បារាំង ត្រូវអត់ឱនឲ្យគ្នាទៅវិញទៅមកសិន ទម្រាំរក ដំណោះស្រាយ។ នៅឆ្នាំបន្ទាប់មក គឺ នៅថ្ងៃ ៧ មករា ឆ្នាំ ១៩៤៦ អ្នកតំណាង ខាងខ្មែរ និងបារាំង បានចុះហត្ថលេខា ទៅលើ កិច្ចសន្យាបណ្តោះអាសន្ននោះ។ រដ្ឋាភិបាល ដែលដឹកនាំដោយ ព្រះអង្គម្ចាស់ មុនីរ៉េត នៅពេលនោះ មានសមាសភាព ដូចតទៅ ៖ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីពង្ស ទទួលបន្ទុកខាងអប់រំជាតិ និង កិច្ចការក្រៅប្រទេស លោក ញឹក ជូឡុង ខាងហិរញ្ញវត្ថុ / លោក ស៊ុម ហ៊ាង ធម្មការ និង វិចិត្រសិល្បៈ លោក យឹម ទិត ដែលជាអតីតរដ្ឋមន្ត្រីការពារប្រទេស របស់ លោក សឺង ង៉ុក ថាញ់ ហើយ ដែលក្រោយមក បានតាម ឧត្តមសេនីយ៍ ឡឺក្លែរ តាំងពី ទីក្រុងសាយហ្គនមក បានត្រូវតែងតាំងជា រដ្ឋមន្ត្រីសុខាភិបាល និង សាធារណការ។ លោក ចាន់ ណាក់ កាន់ខាងយុត្តិធម៌ ហើយ លោក វ៉ា កាម៉ែល ទទួលបន្ទុកខាងសេដ្ឋកិច្ច ។ នៅពេលដែលប្រទេសវៀតណាម ប្រយុទ្ធតស៊ូ រំដោះប្រទេសរបស់គេចេញពីបារាំង តាមផ្លូវអាវុធ ដោយមានការគាំទ្រ ពីចលនាកុម្មុយនីស្តអន្តរជាតិ និង ពីប្រទេសកុម្មុយនិស្ត ជាបន្តបន្ទាប់ ប្រទេសកម្ពុជា បានខិតខំប្រឹងប្រែង ធ្វើការតស៊ូ ទាមទារឯករាជ្យ របស់ខ្លួន យ៉ាងសកម្មណាស់ដែរ ប៉ុន្តែ ដោយមធ្យោបាយ ផ្ទាល់ខ្លួន សុទ្ធសាធ។ នៅខណៈនោះ នៅប្រទេសបារាំង បញ្ញវន្តខ្មែរមួយចំនួន ក្រោមការដឹកនាំ របស់ព្រះអង្គម្ចាស់យុត្តិវង្ស ក៏ នាំគ្នាគិតគូរយ៉ាងខ្លាំង ពី បញ្ហាឯករាជ្យនេះដែរ។ បញ្ញវន្តដែលគេបានស្គាល់ឈ្មោះជាងគេ នៅពេលនោះ មានជាអាទិ៍ លោក ឈាន វ៉ម លោក ថុន អ៊ុក លោក ងិន ការេត។ បញ្ញវន្ត ទាំងនេះ នឹងដើរតួនាទីមួយ ដ៏សំខាន់ នៅក្នុងឆាកនយោបាយខ្មែរ នៅចន្លោះឆ្នាំ ១៩៤៦-១៩៤៩ ជាពិសេស ក្នុងការពង្រឹងយុទ្ធសាស្ត្រ របស់គណបក្សប្រជាធិបតេយ្យ ដែលបានចាប់បដិសន្ធិ នៅ កម្ពុជា នៅ ខែមិនា ឆ្នាំ ១៩៤៦។

សូមបញ្ជាក់ថា នៅពេលក្រោយនេះបន្តិច ព្រះអង្គម្ចាស់យុត្តិវង្ស បានយាងត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីជួយពង្រឹង ជំហរគណបក្សប្រជាធិបតេយ្យ។ ខ្ញុំនឹងនិយាយរៀបរាប់ ពី ការកកើតឡើង និង ពីសកម្មភាព របស់ គណបក្សនេះ នៅពេលក្រោយជាបន្តបន្ទាប់ ។ ប៉ុន្តែមុន នឹងឈានទៅដល់ ដំណាក់ការ នោះ ខ្ញុំសូមបញ្ជាក់ ថា បន្ទាប់ពីការចុះហត្ថលេខា ទៅលើ កិច្ចសន្យា បណ្ដោះអាសន្ន រវាង បារាំង និង ខ្មែរ នៅថ្ងៃ ៧ មករា ឆ្នាំ ១៩៤៦ ប្រទេសកម្ពុជា បានរៀបចំស្ថាប័ន នយោបាយថ្មីមួយ ដែលបើកឲ្យមាន ការបោះឆ្នោតជ្រើសតាំង សមាជិក សភាពិគ្រោះមួយ ដែលមាន ភារកិច្ចរៀបចំ រដ្ឋធម្មនុញ្ញ។ ការបោះឆ្នោត បានប្រព្រឹត្តិទៅ នៅថ្ងៃ ១ កញ្ញា ឆ្នាំ ១៩៤៦ ហើយ គណបក្ស ប្រជាធិបតេយ្យ បានទទួលជ័យជំនះ ដ៏ត្រចះត្រចង់ ។

## ពី របប រាជានិយម ទេវរាជ
## ទៅ របប រាជានិយម អាស្រ័យ រដ្ឋធម្មនុញ្ញ

### **Du Devar**āJa à la monarchie constitutionnelle

បន្ទាប់ពី ព្រះបាទ នរោត្ដម សីហនុ បានប្រកាសទុក ជាមោឃៈ នូវ សេចក្ដីប្រកាសឯករាជ្យ នាថ្ងៃ ១២ មិនាឆ្នាំ ១៩៤៥ – គឺ ការប្រកាសឯករាជ្យ ដែលព្រះអង្គបានធ្វើក្រោមការគាបសង្កត់ របស់ ជប៉ុន – បារាំងបានបញ្ជូនទីប្រឹក្សាជាច្រើន ឲ្យមកជួយចាត់ចែងរៀបចំការងារនៅកម្ពុជា ដែលពេលនោះ មានព្រះអង្គម្ចាស់ មុនីរ៉េត ជានាយករដ្ឋមន្ត្រី ។ ១០ ខែ ក្រោយ ការចុះហត្ថលេខា ទៅលើ កិច្ចសន្យាយោគយល់គ្នាបណ្ដោះអាសន្នសិន (Modus Vivendi) ដែលបានផ្ដល់ ស្វ័យភាពផ្ទៃក្នុង ទៅឲ្យខ្មែរ ប៉ុន្តែ ដែលដាក់ ប្រទេសកម្ពុជា ឲ្យស្ថិតនៅក្នុងក្របខ័ណ្ឌ នៃ សហភាពឥណ្ឌូចិន ហើយ





ដែលបារាំង នៅតែបន្តរក្សាសិទ្ធិចាត់ចែង នយោបាយក្រៅប្រទេស/ ទឹកដីខ្មែរ ផ្នែកខាងជើង-ដែលសៀម បានកាត់ផ្ដាច់យក នៅពេលដែលកងទ័ពជប៉ុន ចូលមករាតត្បាត – បានត្រូវប្រគល់ មកឲ្យខ្មែរវិញ នៅថ្ងៃ ៩ វិច្ឆិកា ឆ្នាំ ១៩៤៦ តាមរយៈសន្ធិសញ្ញាសិនហ្វ្រីនស៊ីស្កូ (San Francisco) ។ សូមបញ្ជាក់ថា ការចរចាស្ដីពី បញ្ហានេះ ជាការមួយដ៏ពិបាក ព្រោះត្រូវឆ្លងកាត់ការវិនិច្ឆ័យ របស់អង្គការអន្តរជាតិ ។ គឺនៅឆ្នាំ ១៩៤៦ នោះហើយ ដែល ចលនាខ្មែរឥស្សរៈ ធ្វើសកម្មភាពយ៉ាងខ្លាំង ។ ក្រុម ខ្លះមានការគាំទ្រពីប្រទេសជិតខាង ហើយក្រុមខ្លះ ជា ចលនា រំដោះទាមទារឯករាជ្យ ខ្មែរពិតប្រាកដ។ ក្រុម សឺង ង៉ុក មិញ ជា ចលនា តស៊ូ វៀតមិញ។ ក្រុមរបស់ ដាប ឈួន ត្រូវគេចោទប្រកាន់ថា ធ្លាប់មាន ទំនាក់ទំនងជាមួយថៃផង ជាមួយអង្គការ វៀតមិញផង នេះបើយោង ទៅតាមការបកស្រាយ របស់លោក ជា សុទ្ធ។ ចលនា របស់ អ្នកអង្គម្ចាស់ នរោត្ដម ចន្ទរង្សី ក៏ ជាចលនាតស៊ូ ដើម្បីឯករាជ្យដែរ តែ ក៏ មានគោលដៅផ្ទាល់ខ្លួន របស់ ព្រះអង្គដែរ ព្រោះ អ្នកអង្គម្ចាស់ នរោត្ដម ចន្ទរង្សី ត្រូវគេចាត់ទុកថា ជាគូប្រជែងមួយអង្គ ដ៏សំខាន់ របស់ ព្រះមហាក្សត្រ ព្រះបាទ នរោត្ដម សីហនុ ។ នៅក្នុងក្របខ័ណ្ឌ នៃ ការទាមទារឯករាជ្យតាមផ្លូវអាវុធ ក្រុមឥស្សរៈ ទាំងនេះ ក៏មាន ឥទ្ធិពលច្រើនដែរ ក្នុងការគាបសង្កត់ ទៅលើបារាំង ។ ទោះបី គេ ការពារប្រយោជន៍ ឬ មានបង្អែកខុសគ្នាក្ដី ក៏នៅពេលនោះ គេធ្វើសកម្មភាព រួមគ្នាដែរ។ ហេតុដូច្នេះហើយ បានជានៅថ្ងៃ ៧ សីហា ឆ្នាំ ១៩៤៦ ខ្មែរឥស្សរៈប្រមាណ បីរយ នាក់ ដឹកនាំដោយ ដាបឈួនផង ដោយ សឺង ង៉ុក មិញ នឹង ដោយ អ្នកអង្គម្ចាស់ នរោត្ដម ចន្ទ រង្សី ផង បានវាយលុកទីក្រុងសៀមរាប និង បុរី អង្គរ យកធ្វើជាទីតាំង របស់គេ។ ប៉ុន្តែ បានតែរយៈពេល ៦ ថ្ងៃប៉ុណ្ណោះ។ នៅថ្ងៃទី ១ កញ្ញា ឆ្នាំ ដដែលនោះ ការបោះឆ្នោតជ្រើសតាំងសភាពិគ្រោះ បានប្រព្រឹត្តិទៅ ជាលើកដំបូងបង្អស់ នៅក្នុងប្រវត្តិសាស្ត្រខ្មែរ ។ បីខែមុនព្រឹត្តិការណ៍នេះ អ្នកអង្គម្ចាស់ យុត្តិវង្ស បានវិលត្រឡប់មកកម្ពុជា ហើយ បានត្រូវជ្រើសតាំង ជា ប្រធានគណបក្សប្រជាធិបតេយ្យ ។ សូមបញ្ជាក់ថា គណបក្សប្រជា

ធិបតេយ្យ ដែលបានត្រូវ បង្កើតនៅខែមិនា ឆ្នាំ ១៩៤៦ មាន ការចូលរួម ពីសំណាក់ បញ្ញវន្ត ជាច្រើន ហើយ មាន អ្នកដឹកនាំ គ្រាក់ៗ ដូចជា លោក ស៊ីម វ៉ា លោក ឈាន វ៉ម លោក អៀវ កឺះ ជាដើម ។ ការបោះឆ្នោត សភាពិគ្រោះនាថ្ងៃ ១ កញ្ញា បានផ្តល់ ជោគជ័យ ដ៏ត្រចះត្រចង់ទៅ ឲ្យគណបក្សប្រជាធិបតេយ្យ ដែលយកបាន ៥០ អាសនៈ ក្នុងចំណោមអាសនៈទាំង អស់ ៦៩។ បន្ទាប់មក នៅ ថ្ងៃ ១៥ ធ្នូ អ្នកអង្គម្ចាស់ យុត្តិវង្ស ត្រូវតែងតាំងជា នាយករដ្ឋមន្ត្រី ជំនួសព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត ។ ជោគជ័យ របស់ គណបក្ស ប្រជាធិបតេយ្យ បានធ្វើឲ្យបារាំង មានកង្វល់យ៉ាងខ្លាំង។ ទន្ទឹមនោះ បារាំងបានជំរុញឲ្យព្រះអង្គម្ចាស់ នរិនដេត បង្កើត គណបក្សនយោបាយមួយ គឺ គណបក្ស «សេរីភាព» (Parti libéral) ដើម្បីចូលប្រកួត ក្នុងការបោះឆ្នោតសភា ។ នៅ ថ្ងៃ ៦ ឧសភា ឆ្នាំ ១៩៤៧ រដ្ឋធម្មនុញ្ញលើកដំបូងបង្អស់ នៃ ប្រទេសកម្ពុជា បាន ត្រូវប្រកាសឲ្យប្រើ។ គឺ នៅថ្ងៃនោះហើយ ដែល ប្រទេសកម្ពុជា បានប្តូរ ពី របបរាជា និយម «ស្តេចជាម្ចាស់ទឹកម្ចាស់ដី» មកជារបប រាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ។ រដ្ឋ ធម្មនុញ្ញ ថ្ងៃ ៦ ឧសភា ឆ្នាំ ១៩៤៧ មានលក្ខណៈប្រហាក់ប្រហែល និង រដ្ឋធម្មនុញ្ញ សាធារណៈរដ្ឋទី ៤ បារាំង ព្រោះអំណាចធ្លាក់ទៅក្នុងកណ្តាប់ដៃសភាទាំងស្រុង ពោល គឺប្រព័ន្ធសភា ២ (système du bicamérisme) រួមមានរដ្ឋសភា និងព្រឹទ្ធសភា ដែល មានឈ្មោះថា ក្រុមប្រឹក្សារាជាណាចក្រ។ ទោះជាយ៉ាងនេះក្តី ដោយ គណបក្សប្រជាធិប តេយ្យ ប៉ាន់ស្មានកម្លាំង របស់ ព្រះបាទ នរោត្តម ស៊ីហនុ និងការវិវត្តន៍ មិនត្រូវ គេ ក៏ ពុំបាន ចាប់អារម្មណ៍ ទៅលើមាត្រា ២១ ដែលកំណត់ថា អំណាចទាំងអស់ បានមក ពី ព្រះមហាក្សត្រ ជាហេតុនាំឲ្យ ព្រះមហាក្សត្រយកមាត្រា ២១ នោះ ទៅអនុវត្ត នៅពេល ក្រោយមកទៀត ។ តាមការពិតទៅ អ្នកដឹកនាំ គណបក្ស ប្រជាធិបតេយ្យ នៅពេល នោះ មានជំនឿថា ព្រះមហាក្សត្រ មុខជាធ្វើសហការ ដោយជិតស្និទ្ធ ជាពុំខាន ព្រោះ គេសង្កេតឃើញថា ព្រះបាទ នរោត្តម សីហនុ ទ្រង់អានអត្ថបទ របស់ ព្រះអង្គម្ចាស់ យុត្តិវង្សចុះផ្សាយក្នុងកាសែត «អ្នកប្រជាធិបតេយ្យ» (Le démocrate) ដោយសព្វ



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

ព្រះរាជហឫទ័យ ជាទីបំផុត ហើយ តែងតែសរសើរជារឿយៗ អំពី របៀបពិចារណា ដ៏ មធ្យ័ត របស់ ព្រះអង្គម្ចាស់ យុត្តិវង្ស ដែលបានជាប់សញ្ញាប័ត្របណ្ឌិតរដ្ឋ ខាងរូប វិទ្យា នៅប្រទេសបារាំង ។ មុន នឹងឈានទៅនិយាយ អំពី ការប្រើសិទ្ធិនេះ ដោយ ព្រះមហាក្សត្រ នៅថ្ងៃ ១៨ កញ្ញា ឆ្នាំ ១៩៤៩ គឺ ថ្ងៃ ដែលព្រះបាទ នរោត្តម សីហនុ បានប្រកាសរំលាយរដ្ឋសភាចោល ខ្ញុំសូមនិយាយ ពី សមាសភាព នៃគណៈរដ្ឋមន្ត្រី របស់ ព្រះអង្គម្ចាស់ យុត្តិវង្ស ដែលបានត្រូវតែងតាំងនៅថ្ងៃ ១៥ ធ្នូ ឆ្នាំ ១៩៤៦ បន្ត មកទៀត។ ព្រះអង្គម្ចាស់យុត្តិវង្សបានតែងតាំងព្រះអង្គម្ចាស់ ស៊ីសុវត្ថិ វឌ្ឍឆាយាវង្ស ឲ្យធ្វើជារដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ លោក សុន វឹនសៃ កាន់ខាងក្រសួងការពារជាតិ លោក សឺន សាន កាន់ខាងហិរញ្ញវត្ថុលោក ប៉ែន សំអែល សេដ្ឋកិច្ច លោក ឈាន វ៉ម អប់រំជាតិ លោក ប្រាក់ សារិន សាធារណការ គមនាគមន៍ និង សុខាភិបាល លោក ប៉ែន នុត ទេសរដ្ឋមន្ត្រីទទួលបន្ទុកខាង រដ្ឋបាលទីក្រុងភ្នំពេញ លោក ហ៊ុយ កន្ធុល រដ្ឋលេខាធិការ ខាងឃោសនាការ និងពត៌មាន លោក ហាក់ ម៉ុង សេង រដ្ឋ លេខាធិការ ហិរញ្ញវត្ថុ លោក អូ ឈឹន ធម្មការ និង វិចិត្រសិល្បៈ លោក អ៊ុច ធុច ខាងកសិកម្ម។ ប៉ុន្តែ គួរឲ្យអកុសល អ្នកអង្គម្ចាស់ យុត្តិវង្ស ចូលជីវង្គត នៅថ្ងៃ ១១ កក្កដា ឆ្នាំ ១៩៤៧ នៅក្នុងជន្មាយុ ៣៥ ព្រះវស្សា ។

## វាសនា នៃ គណបក្ស ប្រជាធិបតេយ្យ និង ចលនា ឥស្សរៈ ខ្មែរ

## Le sort du Parti démocrate et le Mouvement Issarak Khmer

ការបោះឆ្នោតជ្រើសតាំង សភា ដែលរៀបចំនៅថ្ងៃ ២១ ធ្នូឆ្នាំ ១៩៤៧ បាន ផ្តល់ជ័យជំនះ ដ៏រន្ទឹសុសសាយ ទៅឲ្យគណៈបក្សប្រជាធិបតេយ្យដែលយកបានដល់ ទៅ ៥៤ អាសនៈ។ គណៈបក្ស សេរីភាព របស់ព្រះអង្គម្ចាស់ នរិនដេត ដែល មាន

ការគាំទ្រ ពី បារាំងយកបានតែ ២១ អាសនៈប៉ុណ្ណោះ។ រីឯគណៈបក្សនានាទៀត ដែលបានត្រូវបង្កើតឡើង នៅពេលនោះ ដូចជា គណបក្សអភិរក្ស ហៅ «រ៉ណូវ» (Rénovation) ជាដើមយកតែមួយអាសនៈ មិនទាំងបានផង ប៉ុន្តែ បានត្រូវតាំង ឲ្យធ្វើជាអ្នកតំណាង នៅព្រឹទ្ធសភា គឺ ក្រុមប្រឹក្សារាជាណាចក្រ ។ នៅដើមឆ្នាំ ១៩៤៧ នោះ ចលនាឥស្សរៈដែលតំណាងប្រទេសទាំងបី នៅឥណ្ឌូចិន បានបញ្ជូន អនុស្សរណៈមួយ ទៅអង្គការ សហប្រជាជាតិ តាមរយៈក្រសួង ការបរទេសអាមេរិក ប៉ុន្តែអាមេរិកពុំព្រមបញ្ជូន អនុស្សារណៈនោះ ទៅឲ្យអង្គការ សហប្រជាជាតិទេ ។ នៅឆ្នាំបន្ទាប់មក មួយខែក្រោយពេលដែលលោក ឈាន វ៉ម បានត្រូវតែងតាំង ជា នាយករដ្ឋមន្ត្រី ចលនា ខ្មែរឥស្សរៈ ដែលមានឈ្មោះថា «គណកម្មការ រំដោះ ប្រជាជនខ្មែរ» បានត្រូវបង្កើតឡើងនៅខែត្របាត់ដំបង។ ក្រុមឥស្សរៈខ្មែរនេះ ដែលមានគ្នា ប្រមាណ ៨ រយនាក់ ហើយ ដែលដឹកនាំ ដោយអតីតពលទោ ដាប ឈួន បានត្រូវឯកសារជាច្រើន បញ្ជាក់ថា មានទំនាក់ទំនង ជាមួយអង្គការវៀតមិញ។ តាមការពិត ចលនាឥស្សរៈនោះមានអត្ថិភាព តាំងពី ឆ្នាំ ១៩៤៥ មក គឺ ចាប់ផ្តើមចេញ ជារូបរាងតាំងពីខែមិថុនាឆ្នាំ ១៩៤៥ មកឯណោះ គឺ មួយខែក្រោយពេលដែល លោក សឺន ង៉ុក ថាញ់ បានត្រូវតែងតាំងជារដ្ឋមន្ត្រី ការបរទេស។ កាលឆ្នាំ ១៩៤៥ ចលនានោះ ស្ថិតនៅក្រោមការដឹកនាំ របស់ សឺង ង៉ុក មិញ ហៅ «អាចារ្យមាន» តែម្តង ពោលគឺ ចលនា ដែលជាសាខា របស់ អង្គការវៀតមិញ។ នៅថ្ងៃ ២៥ មិថុនាឆ្នាំ ១៩៤៥ នោះ ព្រះមហាក្សត្រខ្មែរ ព្រះបាទ នរោត្តម សីហនុ បានទាមទារយក ទឹកដី កូសាំងស៊ីនមកវិញ ប៉ុន្តែស្រាប់តែ ២ ខែ ក្រោយមក គឺ នៅ ថ្ងៃ ៩ សីហា យុវជន ៧ រូបដែលជាសមាជិក សមាគម អតីតសិស្ស វិទ្យាល័យ ស៊ីសុវត្ថិ បាននាំគ្នាចូលទៅក្នុង ព្រះរាជវាំងទាំងកណ្តាលរាត្រី ដើម្បីបង្ខំឲ្យព្រះមហាក្សត្រខ្មែរ ដាក់រាជ្យ ហើយ ដកហូតសមាជិក រដ្ឋាភិបាល លោក សឺន ង៉ុក ថាញ់ សឹងតែទាំងអស់ ។ លោក សឺន ង៉ុក ថាញ់ បានចាប់អ្នកធ្វើការប៉ុនប៉ង ទាំងនោះ បានទាំងអស់ ហើយ យកទៅឃុំឃាំង។





ប៉ុន្តែ យុវជន ៥ នាក់ បានរត់រួច ហើយក្រោយមក គឺ នៅឆ្នាំ ១៩៤៦ បានក្លាយទៅជាសមាជិក បក្សកុម្មុយនិស្តឥណ្ឌូចិន។ ចលនាយុវជន ទាំងនោះ បានចោទព្រះមហាក្សត្រខ្មែរ និង រដ្ឋាភិបាល លោក សឺន ង៉ុក ថាញ់ ថា មានលក្ខណៈអភិរក្សនិយមពេក ។ សូមបញ្ជាក់ថា នៅសម័យរដ្ឋាភិបាល លោក សឺន ង៉ុក ថាញ់ នាឆ្នាំ ១៩៤៥ នោះ ព្រះមហាក្សត្រខ្មែរ បានផ្ញើ សារលិខិតមួយ ទៅ ឧត្តមនាវីបារាំង ធៀរី ដារហ្សង់ល្យឺ (Thierry d'Argenlieu) ដែលជា អគ្គស្នងការបារាំង នៅ ឥណ្ឌូចិន ដើម្បីធ្វើការតវ៉ាបរិហារ ពីឯករាជ្យខ្មែរ ។ ប៉ុន្តែពេលដែលបារាំង ពង្រឹងជំហររបស់គេ នៅឥណ្ឌូចិន បានវិញ រឿងនោះ ក៏បាត់ស្ងាត់រហូតទៅ។ ដូច្នេះឃើញថា ចលនា ទាមទារ ឯករាជ្យតាមផ្លូវអាវុធ ទោះបី មានការប្រទាក់ក្រឡាគ្នា ស្មុគស្មាញ យ៉ាងណាក្តី ក៏បែកចេញជានិន្នាការ ២ សំខាន់ៗ ដែរនៅពេលនោះ។ ប៉ុន្តែទាល់តែមកដល់ ខែ មិនា ឆ្នាំ ១៩៤៩ ទើប ទំនាស់នេះ បានស្តែងចេញជា រូបរាង ឡើងយ៉ាងច្បាស់។

នៅពាក់កណ្តាលឆ្នាំ ១៩៤៩ នោះ គឺនៅចន្លោះ ខែមិនា និង ខែមិថុនា ក្រុមឥស្សរៈខ្មែរ នានា បានធ្វើការវាយប្រហារគ្នា ទៅវិញទៅមកយ៉ាងខ្លាំងក្លា ។ ក្រុមខ្មែរឥស្សរៈខ្លះយល់ថា ត្រូវធ្វើសហការ ជាមួយវៀតមិញ ក្រុមខ្លះទៀតប្រឆាំងដាច់ខាតនឹងគំនិតនេះ។ ប៉ុន្តែ គឺ នៅពេលនោះដែរ ដែលពួកអ្នកជាតិនិយម បែកចេញជាពីរក្រុម ៖ មួយប្រកាន់ឆ្វេង មួយប្រកាន់ស្តាំ ។ មុននឹងនិយាយអំពីការវិវត្តន៍ នៃ ចលនាខ្មែរឥស្សរៈនេះ បន្តទៅទៀត ខ្ញុំសូមវិលមកនិយាយ អំពីរដ្ឋាភិបាល លោក ឈាន វ៉ម និងដំណើរការ នៃ គណបក្ស ប្រជាធិបតេយ្យ វិញសិន ព្រោះថាការ ទាមទារ ឯករាជ្យរបស់ ចលនាខ្មែរឥស្សរៈ និង ការចូលប្រយុទ្ធ ក្នុងឆាកនយោបាយ របស់ គណបក្សប្រជាធិបតេយ្យ ប្រព្រឹត្តិទៅ ក្នុងពេលតែមួយ ។ រដ្ឋាភិបាល របស់ លោក ឈាន វ៉ម ដែលបានត្រូវតែងតាំង នៅថ្ងៃ ២ មករាឆ្នាំ ១៩៤៨ គឺ ១០ថ្ងៃ ក្រោយ ការបោះឆ្នោតសភា នាថ្ងៃ ២១ ធ្នូ ឆ្នាំ ១៩៤៧ មាន សមាសភាព ដូចតទៅ ៖

លោក ឈាន វ៉ម ដែលជារដ្ឋមន្ត្រី ទី ១ ក៏ទទួលបន្ទុក ខាងអប់រំជាតិ ដែរ។ លោក សឺន សាន បានត្រូវតែងតាំងជាឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកខាង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ លោក ពីទូ ដឺ ម៉ុងតេរ៉ូ យុត្តិធម៌ លោក យិត ស្រុន មហា ផ្ទៃ លោក សុន វ៉ុនសៃ កាន់បីក្រសួងតែម្នាក់ឯង គឺ ៖ រដ្ឋមន្ត្រីសេដ្ឋកិច្ចជាតិ, រដ្ឋមន្ត្រីសាធារណការ និង រដ្ឋមន្ត្រី ការពារប្រទេស លោក ហ៊ុយ កន្ធុល ធម្មការ វិចិត្រសិល្បៈ និង សង្គមកិច្ច វេជបណ្ឌិត សុន ម៉ម សុខាភិបាល ។ រីឯ រដ្ឋ លេខាធិការ មាន ៥ គឺ លោក យ៉ែម សំបូ រដ្ឋលេខាធិការមហាផ្ទៃ ទទួលខុសត្រូវ ខាង នគរបាលជាតិ លោក មាជ គុន រដ្ឋលេខាធិការហិរញ្ញវត្ថុ លោក ហ៊ុយ ម៉ោង រដ្ឋលេខាធិការការពារប្រទេស លោក ថុន អ៊ុក រដ្ឋលេខាធិការ ក្រសួងឃោសនាការ លោក អ៊ិត សៀម រដ្ឋលេខាធិការ ពាណិជ្ជកម្ម ឧស្សាហកម្ម និង ពស្តុការ។ រដ្ឋាភិបាលលោក ឈាន វ៉ម បានត្រូវបញ្ចប់ ៨ ខែក្រោយមក។ លោក ប៉ែន នុត ដែលមិនបានត្រូវ រដ្ឋាភិបាល ប្រជាធិបតេយ្យ របស់លោក ឈាន វ៉ម ប្រគល់ការកិច្ចអ្វីទាំងអស់នោះ បានត្រូវតែងតាំងជានាយករដ្ឋមន្ត្រី ជំនួសលោក ឈាន វ៉ម នៅថ្ងៃ ១៥ សីហា ឆ្នាំ ១៩៤៨ ប៉ុន្តែប្រាំមួយខែក្រោយមក ត្រូវរលំបាត់ទៅវិញទៅ ហើយ ដល់វេន លោក យ៉ែម សំបូ ម្ដងវិញ។ រដ្ឋាភិបាលលោកយ៉ែម សំបូ បាន ត្រូវតែងតាំងនៅថ្ងៃ ១២ កុម្ភៈឆ្នាំ ១៩៤៩។ សូមបញ្ជាក់ថា លោក អៀវ កើះ ដែលធ្វើ ជាប្រធានរដ្ឋសភា តាំងពីឆ្នាំ ១៩៤៦ មក ខិតខំធ្វើអ្វី គ្រប់បែបយ៉ាង ដើម្បីចៀស វាងកុំឲ្យមានទំនាស់ ជាមួយព្រះរាជា គឺសុខចិត្តនិយាយ នឹង អ្នកប្រជាធិបតេយ្យដូចគ្នា ឲ្យតែងតាំង លោក យ៉ែម សំបូ ធ្វើជានាយករដ្ឋមន្ត្រី តាមសេចក្ដីស្នើ របស់ព្រះមហាក្សត្រ ដោយ យោងទៅតាម មាត្រា ទី ២១ នៃ រដ្ឋធម្មនុញ្ញ។ ប៉ុន្តែ លោកយ៉ែម សំបូ បានត្រូវសិស្សវិទ្យាល័យស៊ីសុវត្ថិ ប្រឆាំង យ៉ាងសម្បើម នៅ ពេលនោះ ព្រោះលោក បានបើក កាស៊ីណូ មួយ ដែលជាហេតុធ្វើឲ្យខូចកិត្យានុភាព របស់ គណបក្សប្រជាធិបតេយ្យ យ៉ាងដំណំ ។ នៅពេលនោះ សិស្សវិទ្យាល័យ ស៊ីសុវត្ថិ នាំគ្នាស្រែកជេរថា : «មាស សាអែម យ៉ែម សំបូ បើក កាស៊ីណូ បិទ



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

វិទ្យាល័យ»។ នៅទីបំផុត គណបក្សប្រជាធិបតេយ្យ បានត្រូវអ្នកឱកាសនិយម យកទៅធ្វើ ជាឈ្នាន់ធ្វើព្រងើយ ។ នៅថ្ងៃ ១៨ កញ្ញា ឆ្នាំដដែលព្រះមហាក្សត្រខ្មែរ ព្រះបាទ នរោត្តម សីហនុ បានរំលាយរដ្ឋសភា ចោលតែម្ដង។ ទោះយ៉ាងនេះក្ដី ក៏ លោក អៀវ កើះ ខិតខំធ្វើការតវ៉ា ប្រឆាំងយ៉ាងអង់អាច នឹង របៀបកំណត់ ឯករាជ្យរបស់ បារាំងដែរ គឺ ឯករាជ្យដែលគ្មានលក្ខណៈ បរិបូរ អ្វីទាល់តែសោះ ។ លោក អៀវ កើះ ត្រូវគេធ្វើឃាត នៅថ្ងៃ ១៤ មករាឆ្នាំ ១៩៥០ ។ នៅ ថ្ងៃ ៣ ឧសភា ឆ្នាំ ១៩៥០ ព្រះមហាក្សត្រ នរោត្តម សីហនុ ទទួលការកិច្ចដឹកនាំរដ្ឋាភិបាល ជា បណ្ដោះអាសន្នសិន ហើយមួយខែក្រោយមក គឺ នៅថ្ងៃ ១ មិថុនា ឆ្នាំ ១៩៥០ ព្រះអង្គ ប្រគល់ការកិច្ចរៀបចំ រដ្ឋាភិបាលថ្មី មួយទៀត ទៅឲ្យព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីពង្ស ។

## វិបត្តិ រដ្ឋាភិបាល នៅចន្លោះ ឆ្នាំ ១៩៤៨-១៩៥០

### Crise ministérielle de 1948–1950

បន្ទាប់ពី រដ្ឋាភិបាលរបស់ គណបក្ស ប្រជាធិបតេយ្យ ដឹកនាំដោយ លោក ឈានវ៉ម ត្រូវបញ្ចប់ ព្រោះតែរដ្ឋមន្ត្រីម្នាក់ ជាប់ពាក់ព័ន្ធក្នុង រឿងឡូត៍នេសាទ នៅខ្ញាគ្រហឹម ហើយបន្ទាប់ពី រដ្ឋាភិបាល លោក ប៉ែន នុត ត្រូវរលំបះជើង ៦ ខែ ក្រោយមកទៀត លោក អៀវ កើះ ប្រធានរដ្ឋសភា ត្រូវបង្ខំចិត្តនិយាយសម្រុះសម្រួល ជាមួយអ្នកតំណាងរាស្ត្រ គណបក្សប្រជាធិបតេយ្យ ឲ្យតែងតាំងលោក យ៉ែម សំបូ ជានាយករដ្ឋមន្ត្រី ជំនួស លោក ប៉ែន នុត តាម សេចក្ដីស្នើសុំ របស់ព្រះមហាក្សត្រ ព្រះបាទ នរោត្តម សីហនុ ។ លោក អៀវ កើះ ជា វរជន អ្នកប្រជាធិបតេយ្យមួយរូប ដែលមានគុណសម្បត្តិច្រើន ។ ជាពិសេស លោក ជាអ្នកដែលប្រកាន់ ជំហរ ទៀងត្រង់ ហើយ

មធ្យ័តបំផុត ចំពោះគោលការណ៍ឯករាជ្យជាតិ ។ ប៉ុន្តែការដែលលោក សុខចិត្តនិយាយ ឲ្យអ្នកតំណាងរាស្ត្រ តំណាងមតិភាគច្រើន បោះឆ្នោត តែងតាំង លោក យ៉ែម សំបូ ជាប្រមុខរដ្ឋាភិបាល គឺ មកពី លោក យល់ថា ទំនាស់ ជាមួយ ព្រះមហាក្សត្រ ជាយុទ្ធសាស្ត្រមិនល្អសោះ នៅក្នុងកាលៈទេសៈមួយ ដែលប្រទេសកម្ពុជា កំពុង ទាមទារ ឯករាជ្យ ឲ្យបានបរិបូរ គ្រប់ជ្រុងជ្រោយ។ ប៉ុន្តែ សម្រេចសម្រួលទៅ គណបក្ស និង រដ្ឋាភិបាលប្រជាធិបតេយ្យ បានត្រូវទទួលថ្ម បាក់ទៅវិញ។ រដ្ឋាភិបាល លោក យ៉ែម សំបូ បានធ្វើ អំពើខុសឆ្គងមួយ ដែលមិន គួរកើតមាន ទាល់តែសោះ គឺបានបើកកាស៊ីណូ ដែលជាហេតុនាំឲ្យសិស្សានុសិស្ស ធ្វើបាតុកម្មយ៉ាងគគ្រឹកគគ្រេង ហើយ បានជំរុញឲ្យ លោក មាស សាអែម ដែលជារដ្ឋមន្ត្រីអប់រំជាតិ បិទវិទ្យាល័យស៊ីសុវត្ថិ តែម្តង។ នៅពេលនោះ សិស្សានុសិស្ស ស្រែកជេរប្រទេចផ្តាសា រដ្ឋាភិបាល លោក យ៉ែម សំបូ ដោយប្រើ ពាក្យស្លោក ជាប្រវត្តិសាស្ត្រមួយថា : «មាស សាអែម, យ៉ែម សំបូ បើក កាស៊ីណូ បិទវិទ្យាល័យ ហ៊ុយ ម៉ោង! ហ៊ុយ ម៉ោង!» ។ សូមបញ្ជាក់ថា នៅពេលនោះ លោក ហ៊ុយ ម៉ោង ជា រដ្ឋមន្ត្រីការពារជាតិ ។ គឺ នៅពេលនោះហើយ ដែលព្រះមហាក្សត្រ នរោត្តម សីហនុ ចេញធ្វើអន្តរាគមន៍តែម្តង ។ នៅថ្ងៃ ១៨ កញ្ញា ឆ្នាំ១៩៤៩ នោះ ព្រះមហាក្សត្រ ប្រកាសរំលាយរដ្ឋសភាចោល ហើយតែងតាំង ដោយផ្ទាល់ព្រះអង្គ លោកយ៉ែម សំបូ ជានាយករដ្ឋមន្ត្រី ម្តងទៀត ដោយ យោងទៅតាម អត្ថបទ រដ្ឋធម្មនុញ្ញ ដែលផ្តល់សិទ្ធិបែបនេះទៅឲ្យព្រះមហាក្សត្រ គឺថាព្រះមហាក្សត្រមានសិទ្ធិ ធ្វើអន្តរាគមន៍ គ្រប់ពេលវេលា នៅក្នុងករណីដែលព្រះអង្គយល់ថា ជាការចាំបាច់ ។ មួយវិញទៀត ព្រះមហាក្សត្រព្រះបាទ នរោត្តម សីហនុ បានសំអាងថា ការដែលព្រះអង្គ តែងតាំង រដ្ឋាភិបាល ដោយគ្មានរដ្ឋសភាដូច្នេះ គឺ មកពីប្រទេសកម្ពុជា កំពុងឆ្លងកាត់គ្រោះភ័យ ព្រោះនៅពេលនោះ ពួកឥស្សរៈខ្មែរ និង សម្ព័ន្ធមិត្រ របស់គេ កំពុង តែបង្កើត អសន្តិសុខ នៅក្នុងទូទាំងប្រទេស ។ សូមបញ្ជាក់ថានៅឆ្នាំ ១៩៤៩ នោះ គឺនៅ ចន្លោះ ខែមិនា និង ខែ មិថុនា ក្រុមឥស្សរៈនានា កំពុងតែទាស់ទែងគ្នា យ៉ាងខ្លាំង គឺ បន្ទាប់ ពី





ចលនាឥស្សរៈខ្មែរ ក្រោមការដឹកនាំ របស់លោក ប៉ុក ឃុន បានផ្តាច់ខ្លួនចេញពី ក្រុមវៀតមិញ នៅខែកម្ភៈ ឆ្នាំដដែលនោះ ។

ដើម្បីរៀបចំ រដ្ឋាភិបាលថ្មី ព្រះមហាក្សត្រ បានស្នើសុំឲ្យ គណបក្ស នយោបាយ នីមួយៗ ផ្តល់សមាជិក ២ រូបដើម្បី ឲ្យព្រះអង្គយកទៅតែងតាំងធ្វើជារដ្ឋមន្ត្រី ។ បក្ស នយោបាយនៅពេលនោះ មាន ចំនួនទាំងអស់ ៨ គឺ ៖ «គណបក្ស ប្រជាធិបតេយ្យ» ហៅ គណបក្ស «ក្បាលដំរី», «គណបក្សសេរីភាព» (Parti libéral) របស់ព្រះអង្គម្ចាស់ នរិនដេត «គណបក្សវឌ្ឍនភាព» (Parti progressiste) ដឹកនាំដោយព្រះអង្គម្ចាស់នរោត្តម ម៉ុង តាណា «គណបក្សខេមរៈ» ហៅ «រ៉េណូ» (Rénovation) ដឹកនាំដោយ លោក ញឹក ជូឡុង និង លោក លន់ នល់, គណបក្ស របស់ លោក យ៉ែម សំបូ, «គណបក្សប្រជារាស្ត្រ» របស់លោក សម ញ៉ាន «គណបក្សរួបរួមជាតិ» របស់ លោក ឃឹម ទិត និង «គណបក្ស ឧត្តរមានជ័យ» របស់ ដាប ឈួន ដឹកនាំដោយលោក ម៉ៅ ចយ។ នៅទីបំផុត ភារកិច្ចរៀបចំរដ្ឋាភិបាល បានត្រូវ ប្រគល់ទៅឲ្យលោក អៀវ កឹះ ។ ប៉ុន្តែ រដ្ឋាភិបាលលោក អៀវ កឹះ មាន ថេរវេលា តែ ៩ ថ្ងៃប៉ុណ្ណោះ ។ នៅពេលដែលគណរដ្ឋមន្ត្រី ផ្លាស់ប្តូរ ឥតឈប់ឈរ គឺ រដ្ឋាភិបាល ៨ ក្នុងរយៈពេល ២ ឆ្នាំ អ្នកនយោបាយខ្មែរ ត្រូវប្រឈមមុខ នឹងបញ្ហានយោបាយ ដ៏ ចម្បងមួយ គឺការទាមទារឯករាជ្យ បរិបូណ៌ មកឲ្យខ្មែរ ។ នៅចុងឆ្នាំ ១៩៤៩ តាមរយៈសន្ធិសញ្ញា ថ្ងៃ ៨ វិច្ឆិកា បារាំងទទួលស្គាល់ឯករាជ្យ របស់ខ្មែរ ប៉ុន្តែ គឺ គ្រាន់តែជាឯករាជ្យមួយ ដែលគ្មានន័យ អ្វីទាំងអស់ ព្រោះកងទ័ពខ្មែរត្រូវដាក់ឲ្យស្ថិត នៅក្រោមបញ្ជាការរបស់ បារាំង ដដែល គឺ រហូតដល់ពេល មានសន្តិភាពនៅ ឥណ្ឌូចិន ។ អំណាចជាងពាក់កណ្តាលទៀត ក៏ត្រូវបារាំងរក្សាទុកដដែល ។ អ្នកដឹកនាំ គណបក្សប្រជាធិបតេយ្យ ជាពិសេស លោក អៀវ កឹះ នាំគ្នាប្រឆាំង នឹង លក្ខន្តិកៈប្រគល់ឯករាជ្យ ដ៏គ្មានន័យនេះ របស់បារាំង។ ប៉ុន្តែ ទាល់តែ ២ ឆ្នាំក្រោយមក ទើបព្រះមហាក្សត្រ ចាប់ផ្តើម ទាមទារឯករាជ្យបរិបូរ យ៉ាងពេញទំហឹង គឺ ចលនា មួយដែល មានឈ្មោះថា «ព្រះរាជ

បូជនីយកិច្ច ដើម្បីឯករាជ្យ» (Croisade royale pour l’Indépendance)។ ប៉ុន្តែ មុននឹងឈានទៅដល់ ដំណាក់ការនោះអ្នកដែល ប្រឆាំង នឹងសន្ធិសញ្ញា ថ្ងៃ ៨ វិច្ឆិកា ត្រូវប្រឈមមុខ នឹង ស្ថានភាពមួយ ដ៏ពិបាក ។ អ្នកដែលប្រឆាំងខ្លាំងជាងគេ គឺអ្នកដឹកនាំគណបក្សប្រជាធិបតេយ្យជាពិសេស លោក អៀវ កើះ ដែលបានត្រូវបាត់បង់ជីវិត នៅក្នុងការផ្ទុះគ្រាប់បែកមួយនៅទីស្នាក់ការ គណបក្សប្រជាធិបតេយ្យនៅថ្ងៃ ១៤ មករា ឆ្នាំ១៩៥០។ ឃាតកម្មនេះ ជា អាថ៌កំបាំងមួយ ដែលរកមុខ ឲ្យបានច្បាស់ ពុំឃើញ រហូត។ ប៉ុន្តែ អ្វីដែលគេដឹងច្បាស់ គឺថា នៅពេលនោះ ស្រុកខ្មែរស្ថិតនៅក្នុង អសន្តិសុខ ហើយអ្នកណា ក៏អាចឆ្លៀតឱកាស បានដែរ ដើម្បី ធ្វើការបំបែកបំបាក់ផ្ទៃក្នុង ។ ទោះជាយ៉ាងណាក្តី បន្ទាប់ពីអគ្គស្នងការ សាធារណរដ្ឋ បារាំង ស្ហង់ ដឺរ៉ៃ ម៉ុងដ៏ (Jean de Raymond) បានត្រូវអ្នកបម្រើវៀតមិញម្នាក់ ធ្វើឃាត នៅថ្ងៃ ២៩ តុលាឆ្នាំ ១៩៥១ ភាពប្របូកប្របល់ កាន់តែមាន សភាពស្មុគស្មាញថែមទៀត ព្រោះបារាំងចាប់ផ្តើមចោទប្រកាន់ថាមាន អ្នកដឹកនាំខ្លះ នៃ គណបក្ស ប្រជាធិបតេយ្យ មាន ទំនាក់ទំនង ជាមួយ អង្គការ ទាមទារឯករាជ្យ របស់ វៀតមិញ ។

# ការកកើតឡើង នៃ អ្នកប្រជាធិបតេយ្យ ខ្មែរ

## ជំនាន់ ឆ្នាំ ១៩៥០-១៩៦០

## Les Démocrates khmers de la nouvelle génération (1950 – 1960)

នៅឆ្នាំ ១៩៤៩ បន្ទាប់ពី ព្រះមហាក្សត្រ ព្រះបាទ នរោត្តម សីហនុ បាន រំលាយរដ្ឋសភា គេសង្កេតឃើញថា ស្ថាប័ននយោបាយ ប្រជាធិបតេយ្យខ្មែរ ចាប់ផ្តើម





មានដំណើរការរកេតរកូត។ រដ្ឋាភិបាល លោកអៀវ កើះ ដែលបានត្រូវតែង តាំង នៅថ្ងៃ ២០ កញ្ញា មានជីវិតតែ ៩ ថ្ងៃ ប៉ុណ្ណោះ ព្រោះនៅថ្ងៃ ២៩ ខែដដែល ព្រះមហាក្សត្រ ទ្រង់សព្វព្រះរាជហឫទ័យ ដាក់រដ្ឋាភិបាលមួយថ្មីទៀតរបស់លោក យ៉ែម សំបូឲ្យជំនួសវិញ ។ នៅពេលដែល ចលនាឥស្សរៈ កំពុងបាក់បែកគ្នា មេខ្មែរឥស្សរៈ ដាប ឈួន ហៅ ឈួន ម្ជូលពេជ្រ បានសុំចុះចូលមកក្នុងជួររាជរដ្ឋាភិបាលនៅថ្ងៃ ១ តុលា ប៉ុន្តែ ពុំមែនជា ការចុះចូលធម្មតាទេ ព្រោះរាជរដ្ឋាភិបាល បានសុខចិត្ត ប្រគល់ខេត្តសៀមរាប ទាំងមូល ទៅឲ្យ មេខ្មែរឥស្សរៈ រូបនេះ កាន់កាប់ដោយអំណាច ផ្តាច់ការ របស់ គេផ្ទាល់តែម្តង។  ជាង ១ ខែក្រោយមក គឺ នៅថ្ងៃ ៨ វិច្ឆិកា បារាំង និង ខ្មែរ បានចុះហត្ថលេខា ទៅលើ សន្ធិសញ្ញាមួយ ដែលទទួលស្គាល់ថា ប្រទេសកម្ពុជា ជារដ្ឋ ឯករាជ ប៉ុន្តែ ដែលស្ថិតនៅក្នុង សហភាពបារាំង ។ យោងទៅតាមសន្ធិសញ្ញានោះ ប្រទេសកម្ពុជា នៅតែរក្សាសិទ្ធិ របស់ ខ្លួន ជានិច្ច ក្នុងការទាមទារ ទឹកដី កូសាំងស៊ីន ។ គួរកត់សំគាល់ផងដែរថា នៅពេលមុននេះ គឺ នៅថ្ងៃ ៤ មិថុនា ឆ្នាំ ១៩៤៩ ដដែលនោះ បារាំងបានប្រគល់ កម្ពុជាក្រោម ទៅឲ្យវៀតណាម ដោយពុំបានសាកសួរមតិ ខ្មែរកម្ពុជាក្រោមអ្វីឡើយ ។ នេះបើយោងតាមឯកសារ របស់ ខ្មែរកម្ពុជាក្រោម ។ ៨ ខែ បន្ទាប់ពីការចុះហត្ថលេខា ទៅលើ សន្ធិសញ្ញា ទទួលស្គាល់ថា រដ្ឋកម្ពុជា ជារដ្ឋឯករាជ / នៅទីក្រុងប៉ារីស៍ឯនោះវិញ គឺនៅខែមិថុនាឆ្នាំ ១៩៥០ និស្សិតខ្មែរមួយក្រុមបានបង្កើត ចលនានយោបាយ ម៉ាក្សនិយមមួយ។ សមាជិកសំខាន់ៗ នៃចលនានោះ មានជាអាទិ៍ : លោក អៀង សារី លោកស្រី ខៀវ ធីរិទ្ធ លោក ហ៊ូ យន់ លោក កេង វ៉ាន់សាក់ លោក ជួន មុម្ម  និង សាឡុត សរ ដែលក្រោយមក មានឈ្មោះថា ប៉ុល ពត លោក ម៉ី ម៉ាន់ លោក ម៉ី ផាត លោក រតន៍ សាមឿន ។ នៅពេលដដែលនោះ នៅក្នុងព្រៃប្រទេសកម្ពុជាឯនោះវិញ រណសិរ្សរួបរួមគ្នារបស់ខ្មែរឥស្សរៈប្រកាសថា ពួកគេកាន់កាប់មួយភាគបី នៃ ទឹកដី កម្ពុជា។ នៅថ្ងៃ ១៩ មិថុនាឆ្នាំ ១៩៥០ នោះ តាងនាម រណសិរ្សឥស្សរៈ និង តាងនាម ឲ្យ«គណកម្មាធិការខ្មែរ រំដោះប្រជាជន» ផងដែរ សឺង ង៉ុក មិញ

ប្រកាស ឯករាជ្យខ្មែរតែម្តង។ នៅប្រទេសបារាំងឯនោះវិញ ៥ ខែក្រោយ ព្រឹត្តិការណ៍ នេះ គឺ នៅថ្ងៃ ទី ១ វិច្ឆិកា «សមាគម និស្សិតខ្មែរ» ដែលបានត្រូវបង្កើត តាំងពីខែ កញ្ញា ឆ្នាំ១៩៤៦ បានតែងតាំងលោក វ៉ាន់ មូលីវ៉ាន់ ជាប្រធាន ។ សូមបញ្ជាក់ថា ពីឆ្នាំ ១៩៤៦ មកឆ្នាំ ១៩៥០ សមាគម និស្សិតខ្មែរនេះ ស្ថិតនៅក្រោមការដឹកនាំ របស់ លោក អៀវ ស៊ីចូវ ដោយមាន លោក យ៉ែម សារុង ជាអគ្គលេខាធិការ។ យោង ទៅ តាម ប្រវត្តិវិទូមួយចំនួន ជាពិសេស យោងទៅតាម លោកស្រី ម៉ារី អាឡេប ស្ហង់ឌ្រីន ម៉ារតាំង (Marie Alexandrine Martin) ដែលបាននិពន្ធសៀវភៅ មួយមាន ចំណង ជើងថា *Le Mal cambodgien* លោក អៀវ ស៊ីចូវគ្រាន់ តែជា អ្នកជាតិនិយម សុទ្ធ សាធ ប៉ុណ្ណោះ រីឯ លោក យ៉ែម សារុង មាន និន្នាការប្រជាធិបតេយ្យ និយមខ្សែ កណ្តាល។ ចំណែកឯលោក វ៉ាន់ ម៉ូលីវ៉ាន់ ប្រធាន «សមាគម និស្សិតខ្មែរ» ឆ្នាំ ១៩៥០ នោះ ក៏ ជាអ្នកកណ្តាលនិយមដែរ ។

«សមាគមនិស្សិតខ្មែរ» នាឆ្នាំ ១៩៥០ ដែលមានលោក វ៉ាន់ ម៉ូលីវ៉ាន់ ជា ប្រធាន ហើយដែលមាន លោក កេង វ៉ាន់សាក់ ជាអនុប្រធាន មាន សមាសភាព ដូចតទៅ : លោក សិន ខេមកូ អគ្គលេខាធិការ លោក ជូ បូពិន អគ្គលេខាធិការរង លោក អ៊ុង ប៉ោឡេង ហិរញ្ញិក លោក ហូ តុង លីប បណ្ណារក្ស។ នៅចុងឆ្នាំ ១៩៥០ នោះ នៅក្នុងព្រៃ ប្រទេសកម្ពុជា ឯនោះវិញ បន្ទាប់ពីការជួបសន្ទនា រវាង លោក សៀវ ហេង មេឥស្សរៈខ្មែរ និងព្រះអង្គម្ចាស់សុផានុវង្ស មេចលនាតស៊ូ លាវ ជាមួយ លោក តុង ឌឹក ថាំង តំណាងអង្គការវៀតមិញ / បក្សកុម្មុយនីស្តឥណ្ឌូចិន ត្រូវត្រៀមខ្លួន បែងចែក ជាបីបក្ស ដែលមានស្វ័យភាព រៀងៗខ្លួន ប៉ុន្តែ ដែលរក្សាទំនាក់ទំនងគ្នា ជា និច្ច ។ នៅពាក់កណ្តាលឆ្នាំ ១៩៥០ នោះ ដោយ រដ្ឋាភិបាលបេះ តែផ្លាស់ប្តូរ ជាញឹក ញាប់ពេក គណបក្សប្រជាធិបតេយ្យ ក៏ស្នើសុំឲ្យព្រះមហាក្សត្រដឹកនាំរដ្ឋាភិបាល របស់ ព្រះអង្គផ្ទាល់តែម្តង។ នៅទីបំផុតព្រះអង្គ ក៏ ទ្រង់យល់ព្រម ប៉ុន្តែ រដ្ឋាភិបាលដែល ព្រះ អង្គ ជានាយករដ្ឋមន្ត្រី ត្រូវបញ្ចប់ បេសកកម្មទៅវិញ មួយខែក្រោយមក។ នៅ ថ្ងៃ ៣១





ឧសភា ឆ្នាំ ១៩៥០ ព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីពង្ស បានត្រូវតែងតាំងជា នាយក រដ្ឋ មន្ត្រី ។ សូមបញ្ជាក់ថា រដ្ឋាភិបាលដែល ព្រះមហាក្សត្រ ព្រះបាទនរោត្តម សីហនុ ជាប្រមុខ មានសមាសភាព ដូចតទៅ : លោក តាន់ ម៉ៅ ទេសរដ្ឋមន្ត្រីគ្មានក្រសួង លោក ប៉ែន នុត ទេសរដ្ឋមន្ត្រី និង រដ្ឋ មន្ត្រីការពារប្រទេស លោកវេជ្ជ បណ្ឌិត សុន ម៉ម រដ្ឋមន្ត្រីការបរទេស សាធារណ ការ និង គមនាគមន៍ លោក យិត ស្រុន មហាផ្ទៃ លោក អ៊ូ ឈឿន ហិរញ្ញវត្ថុ លោក ឃួន ណៃ សេដ្ឋកិច្ចជាតិ លោក ចាន់ ណាក់ យុត្តិធម៌ លោក ពីទូ ដឺ ម៉ុងតេរ៉ូ អប់រំជាតិ លោក នាល ផ្លុង សុខាភិបាល ការងារ និង សង្គមកិច្ច លោក អិន ងិន ធម្មការ ។ រីឯ រដ្ឋាភិបាលទី ១ របស់ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីពង្ស ដែលត្រូវបញ្ចប់បេសកកម្ម នៅចុងឆ្នាំ ១៩៥០ មាន លោក សុន វ៉ុនសៃ ជា រដ្ឋ មន្ត្រីការពារប្រទេស លោក វ៉ាយ ល្ហុត សេដ្ឋកិច្ច និង ផែនការ លោក អ៊ូ ឈឿន ហិរញ្ញវត្ថុ លោក ចាន់ ណាក់ យុត្តិធម៌ លោក ទឹម កេន សាធារណការ និង គមនាគមន៍ លោក ពីទូ ដឺ ម៉ុងតេរ៉ូ អប់រំជាតិ និង យុវជន លោក ឃួន ណៃ កសិកម្ម លោក នាល ផ្លុង សង្គមកិច្ច លោក មាស ហ៊ែល វិចិត្រសិល្បៈ លោក សឺន សាន ការបរទេស លោក ជា ជិនកុក ឧស្សាហកម្ម និង ពាណិជ្ជកម្ម។ នៅឆ្នាំ បន្ទាប់មក នៅពេល បោះឆ្នោតសភា នា ខែកញ្ញា ឆ្នាំ ១៩៥១ គណបក្ស ប្រជាធិប តេយ្យ បានទទួលជោគជ័យ ដ៏ត្រចះត្រចង់ សាជាថ្មីទៀត គឺ យកបាន ៥៤ អាសនៈ ឯ ខាងគណបក្ស «សេរីភាព» បានតែ ១៨ អាសនៈប៉ុណ្ណោះ។ គណបក្ស រ៉េណូ «ខេមរៈ» របស់លោក ញឹក ជូឡុង និង លន់ នល់ បាន ២ អាសនៈ «គណបក្សឧត្តរមានជ័យ» របស់ លោក ម៉ៅ ចយ ៤ អាសនៈ ។ «គណបក្សហនុមាន» របស់លោក យ៉ែម សំបូ យក តែមួយអាសនៈមិនបានផង ហើយ គណបក្សឯទៀតៗ ដូចជា «គណបក្សវឌ្ឍន ភាព» , «គណបក្សប្រជាជន», «គណបក្សអ្នកឯករាជ» ក៏ ដូចគ្នាអ៊ីចឹងដែរ។ នៅ ថ្ងៃ ១២ តុលា ឆ្នាំ ១៩៥១ លោក ហ៊ុយ កន្ធុល ត្រូវតែង តាំងជានាយករដ្ឋមន្ត្រី ។ នៅឆ្នាំ ១៩៥១ នោះ នៅប្រទេសបារាំង «សមាគមនិស្សិតខ្មែរ» បានតែងតាំងលោក ហ៊ូ យន់

ជាប្រធាន រី ឯ គណកម្មាធិការ នៅពេលនោះ មានជាអាទិ៍ : លោក អៀង សារី,
សាឡុត សរ, ជួន ម៉ុម្ម, ខៀវ សំផន, កេង វ៉ាន់សាក់ ។



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

# ការស្វែងរកតុល្យភាព ដ៏ពិបាក រវាង ប្រពៃណី និង ភាពសម័យទំនើប

## Equilibrage difficile entre tradition et modernité





# ជំពូក ៤

## ឆ្ពោះទៅរក របប «គណបក្សតែមួយ» ៖ ចលនា «សង្គមរាស្ត្រនិយម»

(Vers le monopartisme)

ការទំប្រឹងប្រែងទាំងប៉ុន្មាន ដែលគណបក្សប្រជាធិបតេយ្យ ជាពិសេស អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស បានធ្វើ នៅឆ្នាំ ១៩៤៦-១៩៤៧ ដើម្បីផ្តល់ទៅឲ្យប្រទេសកម្ពុជា នូវ របបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ (Monarchie constitutionnelle) ដែលមានសភាពីរ (système du bicamérisme) បានត្រូវរលាយអស់ទៅវិញ នៅឆ្នាំ ១៩៥២ ។ កាលនោះ មានការប្រឆាំងពីសំណាក់បញ្ញវន្តយ៉ាងខ្លាំង ព្រោះគេយល់ថា វាសនា របស់ប្រទេស មិនត្រូវប្រគល់ទៅឲ្យមនុស្សម្នាក់ឡើយ។ នៅឆ្នាំ ១៩៥៥ ព្រះមហាក្សត្រ នរោត្តម សីហនុ បានធ្វើការកែទម្រង់ រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ ដើម្បីក្តាប់យកអំណាចទាំងមូល។ ព្រះអង្គបានក្លាយទៅជាក្សត្រមួយអង្គដែលមានអំណាចដូច ក្សត្រខ្មែរសម័យទេវរាជដូច្នេះដែរ។ សាជាថ្មីទៀត ប្រទេសកម្ពុជា បានគេចវេះពីចលនា ទំនើបកម្ម ដែលប្រទេសកំពុងត្រូវការ ។ រីឯផលវិបាក បានស្តែងចេញឡើងយ៉ាងច្បាស់ នៅចុងឆ្នាំ ១៩៦០។ ការជួយស្តារប្រទេសឡើងវិញ នៅឆ្នាំ ១៩៥៩ ម្តង នៅឆ្នាំ ១៩៧០ ម្តង ពុំបាននាំប្រទេស ឆ្ពោះទៅរកតុល្យភាព នៃការប្រជែងកម្លាំង នៅក្នុងតំបន់បានឡើយ ព្រោះមុនការទម្លាក់ព្រះអង្គចេញពី អំណាច នៅថ្ងៃ ១៨ មិនាឆ្នាំ

១៩៧០ ប្រទេសទាំងមូលបានធ្លាក់ ទៅក្នុងដៃ អាណានិគមនិយមថ្មី បាត់ទៅហើយ។ គេអាចសន្និដ្ឋានបានថា ប្រសិនណាជាព្រះអង្គ មិនប្រឆាំង នឹង វិធានការនយោបាយ របស់រដ្ឋាភិបាល «ស្រោចស្រង់ជាតិ» របស់ ព្រះអង្គ ដើម្បីរក្សាមិត្តភាពមួយមិនច្បាស់លាស់ទេនោះ ប្រទេសកម្ពុជា ប្រហែលជាអាចគេចផុត ពីមហន្តរាយ គឺ យ៉ាងហោចណាស់ ក៏អាចរក្សាអធិបតេយ្យ និង ឯកភាពជាតិ បានដែរ។ រីឯ បដិវត្តន៍ខ្មែរក្រហម ពុំមែនជាបដិវត្តន៍ សង្គមឯណាដែរ តែជាការប្រែប្រួល នៃ ការប្រជែងកម្លាំងភូមិសាស្ត្រ-នយោបាយ តែប៉ុណ្ណោះ ។ ខ្ញុំនឹងលើកឡើង ពី បដិវត្តន៍ កុម្មុយនិស្តរបស់ខ្មែរក្រហម នៅជំពូក ៦ ។ យ៉ាងណាមិញ ការរលំរលាយ នៃ របបសេរីនិយម ឬ មូលធននិយម របស់ សាធារណរដ្ឋខ្មែរ ក៏បណ្តាលមកពី ការកេណ្ឌមនុស្សប្រឆ្នំឲ្យគាំទ្រ សម្តេច នរោត្តម សីហនុ និង ការវាយប្រហារយោធា របស់ ពួកខ្មែរក្រហមដែរ គឺ មិនមែនមកពីឆន្ទៈ របស់ប្រជាជន ឬវណ្ណៈកម្មករ-កសិករ អ្វីទេ ។ គេ អាចនិយាយពី បដិវត្តន៍ នៅក្នុងសង្គមមួយ លុះណាតែមនុស្សជាច្រើននៅក្នុងសង្គមនោះមានការភ្ញាក់រឭក អំពីមូលហេតុដែលនាំឲ្យសង្គមទាំងមូលមានវិបត្តិសង្គម និងសេដ្ឋកិច្ចទ្រាំទ្រមិនបាន ដូចការបះបោរដែលកើតមានឡើង នៅពេលដែលរបប «កម្ពុជាប្រជាធិបតេយ្យ» របស់ ខ្មែរក្រហម បានឈានទៅដល់ទីបញ្ចប់។

វិលមកនិយាយពី ការរលំរលាយ នៃ ស្ថាប័ន ប្រជាធិបតេយ្យ នៅឆ្នាំ ១៩៥៥ វិញ វិបត្តិរដ្ឋាភិបាល នៅសម័យ «សង្គមរាស្ត្រនិយម» ជាការឆ្លុះឲ្យឃើញថា ការបញ្ចូលនិន្នាការ នយោបាយនានា មកក្នុង ចលនា ឬគណបក្សតែមួយ មិនអាចធានាស្ថិរភាពនយោបាយ បានឡើយ។ ដូចនៅក្នុងគណបក្សកុម្មុយនិស្ត ដែលកាន់អំណាចដូច្នេះដែរ គេឃើញតែការបែកខ្ញែក នៃនិន្នាការផ្សេងៗ យ៉ាងប្រត្យក្សដែលជាហេតុនាំទៅរក វិធានការផ្តាច់ការ ជាកំហិត ដើម្បី អាចរក្សាអំណាច ។ ដូចនេះ ការផ្លាស់ប្តូរអ្នកកាន់អំណាច (alternance) ជាការចាំបាច់ណាស់ ដើម្បីកុំឲ្យមានការបះបោរ និង អនាធិបតេយ្យ ដើម្បីអាចរក្សាតុល្យភាពសង្គម និងនយោបាយបាន។ គឺព្រោះតែ



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

អំណាចផ្តាច់ការ តាមរយៈការមានគណក្សតែមួយនេះហើយ ដែលបានជំរុញប្រទេសកម្ពុជា ទៅរកការផ្លាស់ប្តូរដោយខានមិនបាន នៅឆ្នាំ ១៩៧០។

# ព្រឹត្តិការណ៍ ដែល កើតមានឡើង មុន រាជបូជនីយកិច្ច ដើម្បី ឯករាជ្យ របស់ ព្រះបាទ នរោត្តម សីហនុ

## Avant « la Croisade royale pour l’Indépendance »

នៅឆ្នាំ ១៩៥១ «សមាគមនិស្សិតខ្មែរ» អា អឺ កា (A.E.K.) នៅទីក្រុងបារីស៍ បានតែងតាំង លោក ហ៊ូ យន់ ឲ្យធ្វើជាប្រធាន រីឯគណកម្មាធិការ ដឹកនាំ មានជាអាទិ៍ : អៀង សារី, សាឡុត ស, ជួន ម៉ុម្ម, កេង វ៉ាន់សាក់, ខៀវ សំផន, ក្អួង តុន។ គឺ នៅពេលនោះហើយ ដែល «សមាគមនិស្សិត ខ្មែរ» អា អឺ កា បែកចេញជា ៣ និន្នាការ ៖ និន្នាការនិយមកណ្តាល តំណាងដោយ វ៉ាន់ ម៉ូលី វ៉ាន់, យ៉ែម សារ៉ុង, ហង់ ធុនហាក់, តាន់ គឹម ហួន ។ និន្នាការសេរីនិយម រួមមាន ៖ មៅ សាយ, សម សារី, លី ជិនលី, ឌុក រ៉ាស៊ី ឌុក ផាណា, ឡុង ប៉ែត, ព្រុំ ថុស ។ ដោយអ្នកទាំងនេះ ជា អ្នកប្រឆាំងនឹងមនោគមវិជ្ជា មាក្សនិយម គេ ក៏បាននាំគ្នាបង្កើត សមាគមមួយទៀត មានឈ្មោះថា «សមាគមមិត្តខ្មែរនៅប្រទេសបារាំង» ឬ «l’Amicale des Cambod-giens en France » ។ សូមបញ្ជាក់ថា ៦ ឆ្នាំក្រោយមក សមាជិកមួយចំនួន នៃ សមាគមនេះ បានចូលរួមចំណែកជាមួយ សមាគមមួយទៀតដែលមានឈ្មោះថា អា កា «A. K.» (សមាគមខ្មែរ: Association khmère) ដើម្បីបង្កើត សមាគមមួយថ្មី ទៀតដែលមាន

ឈ្មោះថា «សេកុម» (CKOM) ឬ«សមាគម ខ្មែរ នៅ នាយសមុទ្រ» (Communauté des Cambodgiens d’Outre-Mer ) នៅឆ្នាំ ១៩៦១ ។ សមាគម ខ្មែរ អា កា (A.K.) ដែលបង្កើតនៅថ្ងៃ ២៧ កុម្ភះ ឆ្នាំ ១៩៥៥ បានតែងតាំងលោកចៅ សេង អួ ជាប្រធាន រីឯសមាជិកផ្សេងៗ ទៀត មានជាអាទិ៍ ៖ ឌី បាឡែន, រ៉ូហ្ស កុសល, សាមែរ ផល គុន, ស្រី ប៉ុង ។ ដើមឡើយ សមាគមនេះ គាំទ្រព្រះមហាក្សត្រខ្មែរ ព្រះបាទនរោត្តម សីហនុ ដោយមាន លោក ញឹក ជូឡុង ជាអ្នកឧបត្ថម្ភផងទៀត ។ ប៉ុន្តែ ការបញ្ចូល និន្នាការ អភិរក្សនិយម ជាមួយ និន្នាការ សេរីនិយម ពុំបាននាំទៅរក ភាពរឹងប៉ឹង ដូច ការគ្រោងទុក របស់ ព្រះមហាក្សត្រនោះឡើយ ។ លោក ញឹក ជូឡុង ជាអ្នកដែលមាន គំនិតស្មោះត្រង់ នឹង ព្រះមហាក្សត្រ ប៉ុន្តែ សមាជិក នៃ សមាគម «សេកុម» សឹង តែទាំងអស់ សុទ្ធតែជាអ្នកដែលមាននិន្នាការ សាធារណរដ្ឋនិយម គឺ បើមិនច្រើន ក៏ មិនតិចប៉ុន្មានដែរ ។ សមាជិកសំខាន់ៗ នៃ សមាគម « សេកុម » មាន ជាអាទិ៍ ៖ ជា ថៃ សេង, ឡុង ប៉ែត, អ៊ុយ ផាត់ ណា, កូ ស៊ី អ៊ុយ, បូរ៉ាមី ជូឡុង, នុត ណារ៉ង, ចំរើន សំអឿន។ សមាគម «សេកុម» (CKOM) មានជីវិត តែបួនឆ្នាំប៉ុណ្ណោះ ។ ដោយឃើញ ថា សមាជិកភាគច្រើន នៃ សមាគម «សេកុម»នេះ ពុំសូវមាននិន្នាការ រាជានិយម ព្រះ មហាក្សត្រ ក៏ពុំសូវជា សព្វព្រះរាជហឫទ័យ គាំទ្រ សមាគមនេះ ប៉ុន្មានដែរ ។ នៅឆ្នាំ ១៩៦៥ សមាគមមួយទៀត មានឈ្មោះថា : Association Générale des Cambodgiens en France ហៅ A.G.C.A. F. ឬ «សមាគមទូទៅ នៃជនជាតិខ្មែរ នៅប្រទេស បារាំង» បានត្រូវបង្កើតឡើង ដើម្បីធ្វើយ៉ាងណាសាកល្បង រំលាយសមាគម «សេកុម» (CKOM) និន្នាការស្តាំ និង សមាគម «អ៊ុយ អឺ កា» និន្នាការឆ្វេងចោលតែម្តង។ នេះជាព្រឹត្តការណ៍ ទាក់ទង នឹង និស្សិតខ្មែរ នៅស្រុកបារាំង ចាប់ពីឆ្នាំ ១៩៦១ ប៉ុន្តែ មុននឹង លើកឡើងអំពី ការវិវត្តន៍ នៃសភាពការណ៍នេះ ខ្ញុំសូមវិលមកនិយាយ អំពី សភាពការណ៍មួយចំនួន ដែលកើតមានឡើងនៅឆ្នាំ ១៩៥១-១៩៥២ សិន គឺ ជាព្រឹត្តិ ការណ៍ មួយចំនួន ដែលកើតមាន មុន «រាជបូជនីយកិច្ចដើម្បីឯករាជ្យ» (Croisade



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

royale pour l’Indépendance) របស់ ព្រះមហាក្សត្រខ្មែរ។ នៅពេលបោះឆ្នោតសកា នាខែកញ្ញាឆ្នាំ ១៩៥១ គណ បក្សប្រជាធិបតេយ្យ បានទទួលជោគជ័យ ដ៏អស្ចារ្យសា ជាថ្មីម្តងទៀត គឺ ដណ្តើមយកបាន ៧០ ភាគរយ នៃ អាសនៈ ។ នៅថ្ងៃ ១២ តុលា លោក ហ៊ុយ កន្ថុល បានត្រូវតែងតាំងជា នាយករដ្ឋមន្ត្រី រីឯ គណរដ្ឋមន្ត្រី ទាំងមូល មានសុទ្ធតែអ្នកប្រជាធិបតេយ្យ។ គឺ នៅខែតុលាឆ្នាំ ១៩៥១ នោះដែរ ដែលព្រះមហា ក្សត្រខ្មែរ នរោត្តម សីហនុ សុំឲ្យបារាំង ដោះលែង លោក សឺង ង៉ុក ថាញ់ ឲ្យវិល ត្រឡប់មកស្រុកខ្មែរវិញ។ តាមការពិតទៅ លោក សឺង ង៉ុក ថាញ់ គ្រាន់តែជា អ្នកជាតិ និយមម្នាក់ ដែលមានឥទ្ធិពល ប្រជាប្រិយ តែប៉ុណ្ណោះ ក៏ប៉ុន្តែ លោក ក៏ បានត្រូវ អ្នកប្រជាធិបតេយ្យ គោរពដូចវិរបុរសម្នាក់ ដូច្នេះដែរ ។ នៅពេលនោះ ព្រះមហាក្សត្រ មាន យុទ្ធសាស្ត្រ ពិសេសមួយ គឺ សព្វព្រះរាជហឫទ័យ តែងតាំង លោក សឺង ង៉ុក ថាញ់ ឲ្យធ្វើជានាយករដ្ឋមន្ត្រី។ ប៉ុន្តែពេលមកដល់ស្រុកខ្មែរ ជាមាតុប្រទេសវិញ លោក ប្រកែកពុំព្រម ធ្វើជានាយករដ្ឋមន្ត្រីទេ ។ មិត្តភក្តិ របស់ លោកជាច្រើន បាននាំគ្នាមក ទទួលលោក យ៉ាងពពាក់ពពូន ដូចគេមកទទួល វិរបុរសម្នាក់ ដូច្នេះដែរ ជាហេតុធ្វី ឲ្យ លោក សឺន ង៉ុក ថាញ់ មាន ការក្រែងរអែង យ៉ាងខ្លាំង ខ្លាច ព្រះមហាក្សត្រ អាក់ អន់ព្រះរាជហឫទ័យ។ ទោះជាយ៉ាងណាក្តី នៅ ថ្ងៃ ១១ មករា គឺ ២ ខែ ក្រោយមក លោក សឺន ង៉ុក ថាញ់ បានបង្កើត កាសែតមួយ ឈ្មោះ «ខ្មែរក្រោក» ហើយតាម រយៈសារពត៌មាននោះ លោកសឺង ង៉ុក ថាញ់ ទាមទារឲ្យធ្វើការកែទម្រង់ជាមូលដ្ឋាន តែម្តង ហើយនៅថ្ងៃ ៩ មិនា លោក សឺង ង៉ុក ថាញ់ រត់ចូលព្រៃរួបរួមជាមួយ ចលនា ឥស្សរៈមួយ ដែលមាន និន្នាការស្តាំ ហើយ ដែលមានទស្សនៈនយោបាយ ស្របនឹង ទីតាំងយុទ្ធសាស្ត្រ ភូមិសាស្ត្រ-នយោបាយ របស់ ប្រទេសថៃ។ គឺ នៅ ពេលនោះដែរ ដែលចលនា ខ្មែរឥស្សរៈដែលមានឈ្មោះថា «គណកម្មាធិការរំដោះ ប្រជាជន» ដឹកនាំ ដោយ លោក សឺង ង៉ុក មិញ បានប្រែឈ្មោះ មកជា «រដ្ឋាភិបាលតស៊ូ» តែម្តង។ រដ្ឋាភិបាល ខ្មែរឥស្សរៈ នៅក្នុងព្រៃនោះ មានសមាជិក ថ្នាក់ដឹកនាំ ផ្សេងៗទៀត ដូច

ជា ៖ ចាន់ សម័យ អនុប្រធាន, ទូ សាមុត ទទួលបន្ទុកខាងមហាផ្ទៃ, កែវ មុន្នី ការបរទេស, ជូ ឈិន អប់រំ, សៀវ ហេង ការពារប្រទេស, លាវ កែវមុន្នី ខាងជនជាតិស្បួស មន ខាងកិច្ចការសាសនា ។ នៅពេលនោះ នៅទីក្រុងភ្នំពេញ គណបក្សប្រជាធិបតេយ្យ បាននាំគ្នា សំដែងបដិហារ ប្រឆាំង នឹង វត្តមានរបស់បារាំង យ៉ាងខ្លាំងក្លា ។ នៅថ្ងៃ ៦ ឧសភាឆ្នាំ ១៩៥២ ក្រោមការដឹកនាំ របស់ លោក ហ៊ូ នឹម គណបក្ស ប្រជាធិបតេយ្យ បានធ្វើបាតុកម្មមួយយ៉ាងគគ្រឹក គគ្រេងប្រឆាំងនឹងបារាំង នៅចំកណ្ដាលទីក្រុងភ្នំពេញ តែម្ដង ហើយ ២ សប្ដាហ៍ ក្រោយមក បានធ្វើ បាតុកម្ម មួយទៀត នៅបាត់ដំបង ដឹកនាំ ដោយ វន វ៉េត ។ នៅថ្ងៃ ២៦ ឧសភា បាតុកម្មមួយទៀត ក្រោមការដឹកនាំ របស់ គណបក្សប្រជាធិបតេយ្យ ដដែលបានផ្ទុះឡើង នៅកំពង់ចាម ។ សូមកត់សំគាល់ថា នៅពេលដែលប្រទេសកម្ពុជា ស្ថិតនៅក្រោមការដឹកនាំ របស់ រដ្ឋាភិបាល លោក ហ៊ុយ កន្ធុល  អ្នកនយោបាយ មួយចំនួន មានជាអាទិ៍ ៖ លោក យ៉ែម សំបូ ដែល មានការគាំទ្រ ពីកងទ័ព បានស្នើសុំ ឲ្យរដ្ឋាភិបាល ប្រជាធិបតេយ្យ លោក ហ៊ុយ កន្ធុល ចុះចេញ ពីមុខ តំណែង ហើយសុំឲ្យរំលាយរដ្ឋសភាចោលផងទៀត។ នៅដើមខែមិថុនា ឆ្នាំ ១៩៥២ នោះ រដ្ឋាភិបាល ប្រជាធិបតេយ្យ បានចាប់ ពួកអ្នកនយោបាយទាំងនោះ យកទៅឃុំ ឃាំង។ នៅពេលនោះ គឺ នៅពេលដែលកងទ័ពបារាំងធ្វើចលនានៅ ទីក្រុងភ្នំពេញ ព្រះមហាក្សត្រ ក៏ឆ្លៀតយកឱកាសនោះ ទម្លាក់រដ្ឋាភិបាល ប្រជាធិបតេយ្យ លោក ហ៊ុយ កន្ធុល ចោលតែម្ដង ហើយ យកអំណាចទាំងអស់ មកកាន់ផ្ទាល់ព្រះអង្គ ជាហេតុធ្វើឲ្យមតិខ្លះ ចាត់ទុកថាព្រះរាជាធ្វើ «រដ្ឋប្រហារមួយដែលស្របច្បាប់»។ នៅ ខែ កក្កដា ឆ្នាំ ១៩៥២ នោះ និស្សិតខ្មែរនៅទីក្រុងប៉ារីស៍ បានសំដែង ការប្រឆាំងរបស់គេ យ៉ាងខ្លាំង នឹង ព្រះមហាក្សត្រ ដោយបានផ្ញើសារលិខិតមួយទៅថ្វាយព្រះរាជាដើម្បី ថ្កោលទោសព្រះអង្គ។ អត្ថបទ នៃ លិខិតជាប្រវត្តិសាស្ត្រ នោះ ដែលបានត្រូវសរសេរ ដោយ លោក កេង វ៉ាន់សាក់ បានត្រូវលោក ហ៊ូ យន់ ប្រធាន «សមាគមនិស្សិតខ្មែរ»ចុះហត្ថលេខា។ គឺនៅក្នុងរយៈពេលនោះដែរដែលទស្សនាវដ្ដី «និស្សិតខ្មែរ»





បានចាប់ផ្ដើមចុះផ្សាយអត្ថបទ របស់ សាឡុត សរ ក្រោមឈ្មោះថា «ខ្មែរដើម» ប៉ុន្តែដែលនិយាយ រិះគន់ របប រាជានិយម យ៉ាងចាស់ដៃ និង លើកឡើង ជាពិសេស អំពីបដិវត្តន៍ នានា នៅក្នុងសកលលោក ។

## ព្រះរាជបូជនីយកិច្ច ដើម្បី ឯករាជ្យ ខ្មែរ របស់ ព្រះបាទ នរោត្តម សីហនុ

### « La Croisade royale pour l’Indépendance »

នៅពេលដែល គណបក្សប្រជាធិបតេយ្យ កំពុងដើរតួនាទីយ៉ាងសំខាន់ នៅក្នុងឆាកនយោបាយខ្មែរ នៅចុងទសវត្សរ៍ ៤០ និង នៅដើមទសវត្សរ៍ ៥០ និស្សិតខ្មែរនៅទីក្រុងប៉ារីស៍ ទោះជា អ្នកមាននិន្នាការស្ដាំ ឬ ឆ្វេងក្ដី គេនាំគ្នាគាំទ្រគណបក្ស ប្រជាធិបតេយ្យយ៉ាងសកម្ម។ មុនពេល ដែលលោកសឺន ង៉ុក ថាញ់ ត្រឡប់មកស្រុកខ្មែរវិញ នៅខែតុលាឆ្នាំ ១៩៥១ និស្សិតខ្មែរទាំងនោះ តែងតែនាំគ្នាទៅសួរសុខទុក្ខ លោក សឺន ង៉ុក  ថាញ់ ដែលជាប់ឃុំឃាំង នៅព័តជេ (Poitiers) ជារឿយៗ។ បញ្ហា ដែលចោទឡើងនៅពេលនោះ គឺការទាមទារឯករាជ្យ ប៉ុន្តែការខ្វែងគំនិតគ្នា រវាងនិស្សិតឆ្វេងនិយម និងនិស្សិតស្ដាំនិយម ក៏ស្ដែងឡើង នៅពេលនោះដែរ។ អ្នកប្រកាន់ឆ្វេងយល់ថា ការទាមទារឯករាជ្យត្រូវប្រព្រឹត្តទៅតាមផ្លូវអាវុធ ដោយមានការ គាំទ្រពីប្រជាកសិករ។ រីឯអ្នកប្រកាន់ស្ដាំវិញ គេមានការស្ទាក់ស្ទើរ។ ទោះបីគេមាន និន្នាការស្ដាំ ឬ ឆ្វេង ក្ដី និស្សិតខ្មែរភាគច្រើន នៅសម័យឆ្នាំ ៥០ នោះ ពុំមែនជាអ្នកគាំទ្រ របប រាជានិយម ឡើយ ។ គេគាំទ្រ គណបក្សប្រជាធិបតេយ្យ ស្ទើងតែទាំងអស់។ នៅពេលដែល លោក សឺន ង៉ុក ថាញ់ ត្រឡប់មកកម្ពុជាវិញ ហើយរត់ចូលព្រៃបង្កទ័ពឥស្សរៈ ជាមួយ លោក អៀវ ស៊ុ ចូវ និស្សិតទាំងនោះ ក៏គាំទ្រ លោក សឺន ង៉ុក ថាញ់ ទៀត ។ នៅពេល

*ដែលព្រះមហាក្សត្រខ្មែរ ព្រះបាទ នរោត្តម សីហនុ ប្រកាសទាមទារឯករាជ្យបរិបូរ នៅខែ មិថុនាឆ្នាំ ១៩៥២ ពួកគេ ក៏ចង់បែរ មកគាំទ្រ សកម្មភាព របស់ ព្រះអង្គវិញ ដែរ ព្រោះនៅថ្ងៃ ១៥ មិថុនា ឆ្នាំ ១៩៥២ នោះ ព្រះបាទនរោត្តម ស៊ីហនុ បានធ្វើសារមួយសន្យា ចំពោះប្រជាជាតិខ្មែរថា ព្រះអង្គ នឹង ទាមទារឯករាជ្យ បរិបូរ ពី បារាំង ឲ្យទាល់តែបានសម្រេច ។ ប៉ុន្តែ ដោយព្រះមហាក្សត្រ ទម្លាក់រដ្ឋាភិបាលប្រជាធិបតេយ្យរបស់ លោក ហ៊ុយ កន្ធុល ហើយរំលាយ រដ្ឋសភាចោល នៅក្នុងពេលជាមួយគ្នា ផងដែរ បណ្ឌិតនិស្សិតខ្មែរ នៅប្រទេសបារាំង មានការខកចិត្តយ៉ាងខ្លាំង ជាពិសេស នៅពេលដែល ព្រះមហាក្សត្រខ្មែរក្តាប់យក អំណាចទាំងអស់ ហើយ តែងតាំង រដ្ឋាភិបាលមួយ ដោយផ្ទាល់ព្រះអង្គ តែម្តង។ នៅ ថ្ងៃ ៦ កក្កដាឆ្នាំ ១៩៥២ ដដែលនោះ សមាគមនិស្សិតខ្មែរ អា អឺ កា* (AEK) *ក្រោមការដឹកនាំរបស់ លោក ហ៊ូ យន់ បានផ្ញើ សារលិខិតមួយទៅព្រះមហាក្សត្រ តែម្តងដើម្បីថ្កោលទោសព្រះអង្គ អំពីអ្វី ដែលទិន្នានុប្បវត្តិ បារាំង ឡឺម៉ុងដ៍* « Le Monde » *នៅពេលនោះហៅថា : «រដ្ឋប្រហារស្របច្បាប់ របស់ ព្រះមហាក្សត្រ» ។ នៅដើមឆ្នាំបន្ទាប់មក គឺនៅ ថ្ងៃ ១៤ មករា ឆ្នាំ ១៩៥៣ សមាជិកសមាគមនិស្សិត ខ្មែរ អា អឺ កា* (A.E .K.) *ម្នាក់ គឺសាឡុត សរ ដែលក្រោយមក មានឈ្មោះថា ប៉ុល ពត បានត្រឡប់មកស្រុកខ្មែរវិញ ហើយ ២៥ ថ្ងៃបន្ទាប់មក គឺនៅថ្ងៃ ៩ កុម្ភៈឆ្នាំ ១៩៥៣ ព្រះមហាក្សត្រទ្រង់យាងទៅប្រទេសបារាំង ជាមួយលោក ប៉ែន នុត ដើម្បី សុំធ្វើការចរចា ទាមទារ ឯករាជ្យ ដែលជា ធាតុដំបូងបង្អស់ នៃ ព្រះរាជបូជនីយកិច្ច ដើម្បី ឯករាជ្យរបស់ព្រះអង្គ ។ ប៉ុន្តែ គឺនៅថ្ងៃ ៩ កុម្ភៈ ឆ្នាំ ១៩៥៣ នោះហើយដែល «សមាគមនិស្សិតខ្មែរ» អា អឺ កា* (A.E.K.) *ត្រូវរដ្ឋាភិបាលបារាំងប្រកាសឲ្យបិទ តាមសេចក្តីស្នើរបស់ព្រះមហាក្សត្រខ្មែរ។ ៦ ខែ ក្រោយមក នៅប្រទេសកម្ពុជា សាឡុត សរ និង យ៉ុន សឿន បានធ្វើដំណើរទៅ កន្លែងបញ្ជាការទ័ព «រណសិរ្សខ្មែរឥស្សរៈ» នៅកំពង់ចាម ដើម្បីរៀបចំ សង្គ្រាមទ័ពព្រៃ។ រដ្ឋាភិបាលដែលព្រះមហាក្សត្រខ្មែរ បានតែងតាំងនៅ ថ្ងៃ ១៦ មិថុនា ឆ្នាំ ១៩៥២ ហើយ ដែល*





*មាន ព្រះអង្គជាប្រមុខ មានសមាសភាពដូចតទៅ ៖ ព្រះអង្គម្ចាស់ នរោត្តម សុងដេត រដ្ឋ មន្ត្រីការបរទេស អ្នកអង្គម្ចាស់ក្សត្រី នរោត្តម ប៉េងប៉ោះ យុគន្ធរ អប់រំជាតិ កីឡា និង យុវជន លោក តុង អួន ម៉ម មហាផ្ទៃ និង ធម្មការ លោក ជី ឡូប៉េស យុត្តិធម៌ លោក ជាញ់ សួន ហិរញ្ញវត្ថុ លោក ស៊ុម រ៉ា សេដ្ឋកិច្ចជាតិ លោក នូ ហាច រដ្ឋលេខាធិការ ខាងសាធារណការ និង គមនាគមន៍ អ្នកអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ការពារប្រទេស លោក អ៊ុំ សម សុខាភិបាល និង សង្គមកិច្ច។ រដ្ឋាភិបាលនេះ បានត្រូវបញ្ចប់បេសកកម្ម នៅថ្ងៃ ២៣ ខែ មករាឆ្នាំ ១៩៥៣ ។ មុននឹង យាងទៅប្រទេសបារាំង ព្រះមហាក្សត្រ បានរៀបចំរដ្ឋាភិបាល មួយទៀត ដែលមានព្រះអង្គជាប្រមុខដដែល។ រដ្ឋាភិបាលនោះ មានសមាសភាពដូចតទៅ : លោក ប៉ែន នុត រដ្ឋមន្ត្រីទី ១ រាជប្រតិភូទទួលបន្ទុកកិច្ចការរដ្ឋាភិបាល និង ជារដ្ឋមន្ត្រី កីឡា និង យុវជន, លោក អ៊ូ ឈឺន រដ្ឋមន្ត្រីទី ១ ត្រៀម និង ជារដ្ឋមន្ត្រីការបរទេស និង ធម្មការ, អ្នកអង្គម្ចាស់ក្សត្រី នរោត្តម ប៉េងប៉ោះ យុគន្ធរ ទេសរដ្ឋមន្ត្រីសិក្សាធិការ និង វិចិត្រសិល្បៈ អ្នកអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈរដ្ឋមន្ត្រីការពារប្រទេស ប្រៃសនីយ និង ទូរគមនាគមន៍, លោក តុង អួន ម៉ម យុត្តិធម៌, លោក ស៊ុម រ៉ា សេដ្ឋកិច្ច និង សាធារណការ, លោក ជាញ់ សួង ហិរញ្ញវត្ថុ, លោក ប្រាក់ សារិន មហាផ្ទៃ និងស្វ័យការពារ, លោក សំសុង ហ្វៃរណង់ដេស៍ សុខាភិបាល សង្គមកិច្ច និងការ ងារ។ គឺ នៅពេលដែលព្រះអង្គ ដឹកនាំ រដ្ឋាភិបាលនេះ ហើយដែលព្រះមហាក្សត្រ ព្រះបាទនរោត្តម សីហនុ ចាប់ផ្តើមធ្វើព្រះ រាជបូជនីយកិច្ចដើម្បឯករាជ្យ ។ នៅខែកុម្ភៈ ឆ្នាំ ១៩៥៣ នោះ ព្រះអង្គយាងទៅប្រទេសបារាំងជាមួយ លោក ប៉ែន នុត ក្នុងគោលដៅមួយយ៉ាងច្បាស់ គឺធ្វើការចរចាជាមួយ អ្នកដឹកនាំបារាំង ដើម្បីទាមទារ ឯករាជ្យបរិបូរ ។ សូមបញ្ជាក់ផងដែរថា អ្នកដែលបានធ្វើវិភាគទានមួយផ្នែកធំ ក្នុងការ រៀបចំសំណុំរឿង ដ៏ស្មុគស្មាញនេះ គឺ លោក សម សារី ដែលជាឪពុក របស់ លោក សម រង្ស៊ី ។ លោក សម សារី ដែលត្រូវតែងតាំងជា រដ្ឋមន្ត្រីអប់រំជាតិ និងទទួលបន្ទុក ខាងសន្តិសុខ នៅក្នុងរដ្ឋាភិបាល*

របស់ព្រះរាជា ពីខែកក្កដាឆ្នាំ ១៩៥៣ ដល់ថ្ងៃ ២២ វិច្ឆិកាឆ្នាំដដែល ជាបញ្ញវន្តខ្មែរម្នាក់ដ៏សំខាន់ ដែលបានប្រើទេពកោសល្យ របស់ ខ្លួន យ៉ាងពេញទំហឹង ដើម្បីបុព្វហេតុឯករាជ្យខ្មែរ ជាពិសេស នៅក្នុង ការចរចា កិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ ដើម្បីផ្តាច់ពួកវៀតមិញចេញ ពី ចលនាឥស្សរៈខ្មែរ។ នៅពេលដែលព្រះអង្គយាង ទៅដល់ប្រទេស បារាំង ព្រះមហាក្សត្រខ្មែរ ទៅគង់នៅ ឡា ណាពូល (La Napoule) ដែលនៅទីនោះ ព្រះអង្គទ្រង់ ព្រះនិពន្ធលិខិតមួយយ៉ាងវែង ស្តីពីឯករាជ្យបរិបូររបស់ខ្មែរ ផ្ញើចំពោះទៅលោក វ៉ាំងសង់ អូរីយ៉ូល (Vincent Auriol) ប្រធានាធិបតីបារាំង។ ដោយលោក អូរីយ៉ូល ពុំបានឆ្លើយ នឹងលិខិតជាប្រវត្តិសាស្រ្ត ចុះថ្ងៃ ទី ៥ មិនា ឆ្នាំ ១៩៥៣ នោះ ព្រះអង្គ ក៏ទ្រង់និពន្ធលិខិតជាច្រើនទៀត ។ នៅទីបំផុតលោក វ៉ាំងសង់ អូរីយ៉ូល បានឆ្លើយតបមកវិញ តាមរយៈលិខិតមួយចុះថ្ងៃ ទី ១៩ មិនា ឆ្នាំ១៩៥៣ ។ លោក ប្រធានាធិបតីបារាំង បានយាងព្រះរាជា ទៅសោយ ភោជនាហារ ពេលថ្ងៃត្រង់ នៅ វិមានអេលីស្សេ (Elysée)។ នៅ ថ្ងៃពុធ ទី ២៥ មិនា ឆ្នាំ១៩៥៣ ព្រះមហាក្សត្រខ្មែរ បានជួបលោកប្រធានាធិបតីបារាំង វ៉ាំងសង់ អូរីយ៉ូល ដូចការកំណត់ ប៉ុន្តែព្រះរាជា ពុំបានទទួលលទ្ធផលអ្វី ជាវិជ្ជមាន ទាំងអស់ ពីបារាំង ។

# ព្រះរាជបូជនីយកិច្ច ទាមទារ ឯករាជ្យ ដំណាក់ការ ទី ២ របស់ ព្រះបាទ នរោត្តម សីហនុ

## 2éme étape de la Croisade royale pour l’Indépendance de S.M. Norodom Sihanouk



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

បន្ទាប់ពីបាន សោយភោជនាហារថ្ងៃត្រង់ ជាមួយ លោកប្រធានាធិបតីបារាំង វ៉ាំងសង់ អូរីយ៉ូល នាថ្ងៃ ២៥ មិនានោះមក ព្រះមហាក្សត្រខ្មែរ ពុំបានទទួល នូវ ការយោគយល់អ្វីទាំងអស់ពីបារាំង។ ក្រោយនោះបន្តិច ព្រះអង្គ ក៏យាងទៅគង់ នៅហ្វុងតែនឹប្លូ (Fontainebleau) ដែលនៅទីនោះ ព្រះអង្គទ្រង់បានសរសេរសំបុត្រ ជាច្រើនច្បាប់សាជាថ្មីទៀត ទៅលោកវ៉ាំងសង់អូរីយ៉ូល។ ដោយព្រះអង្គមាន សេចក្តីសង្ឃឹមយ៉ាងមាំថា បារាំងត្រូវតែ បើកការចរចា ជាមួយ ព្រះអង្គ នៅពេលខាងមុខដោយខានមិនបាន ព្រះអង្គ ក៏ទ្រង់យាងមកគង់នៅទីក្រុងប៉ារីសតែម្តង គឺ នៅសណ្ឋាគារ ដឺគ្រីយ៉ុង (De Crillon) ជាមួយ អ្នកអមដំណើរ របស់ ព្រះអង្គ ។ លោក ស្ហង់ ឡឺតួរណូ (Jean Letourneau) រដ្ឋមន្ត្រី បារាំងទទួលបន្ទុកខាងសហព័ន្ធ ហើយដែលបានត្រូវតែងតាំង ជាអគ្គស្នងការឥណ្ឌូចិន ក៏បានអញ្ជើញ មកសន្ទនាជាមួយព្រះអង្គនៅសណ្ឋាគារនោះ។ ព្រះមហាក្សត្រខ្មែរ ទ្រង់មាន ការខកព្រះរាជហឫទ័យយ៉ាងខ្លាំង ព្រោះ លោកស្ហង់ឡឺតួរណូ បានបញ្ជាក់ថា ៖ កាលៈទេសៈដែលព្រះអង្គ ទាមទារឯករាជ្យបរិបូណ៌នេះ ជាកាលៈទេសៈមិនល្អសោះ ចំពោះបារាំង ក៏ដូចជាចំពោះ ប្រទេសកម្ពុជា។ សូមបញ្ជាក់ថា នៅពេលនោះ បារាំងកំពុងតែជាប់ប្រយុទ្ធ ជាមួយវៀតមិញ គឺថា បើបារាំងដកកងទ័ពចេញពីកម្ពុជា តើប្រទេសកម្ពុជាមានអ្វីសម្រាប់ទប់ទល់នឹងកងទ័ពវៀតមិញ ដែលមានការគាំទ្រយ៉ាងពេញទំហឹង ពី សំណាក់កុម្មុយនីស្ត ? នៅចំពោះមុខការប្រកាន់ទីតាំង យ៉ាងរឹងមាំនេះ របស់ បារាំង ព្រះមហាក្សត្រ ក៏សម្រេចយាង ទៅប្រទេសកាណាដា និង សហរដ្ឋ អាមេរិក ដើម្បីផ្តល់ទៅឲ្យព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ របស់ ព្រះអង្គ នូវទ្រង់ទ្រាយមួយដែលមានលក្ខណៈអន្តរជាតិ។ បន្ទាប់ពីបានដឹង អំពីសេចក្តីសម្រេចនេះ របស់ ព្រះមហាក្សត្រខ្មែរភ្លាម លោក ស្ហង់ឡឺតួរណូ មានការបារម្ភយ៉ាងខ្លាំង ព្រោះមិនដឹងថា តើព្រះមហាក្សត្រខ្មែរ ព្រះបាទនរោត្តម សីហនុមានយុទ្ធសាស្រ្ត បែបណា ។ លោក ឡឺតួរណូ ក៏យាងព្រះអង្គម្ចាស់មុនីពង្ស ព្រមទាំងកោះហៅ អគ្គស្នងការបារាំង នៅកម្ពុជា ឲ្យមកទីក្រុងប៉ារីស ជា

*បន្ទាន់ ដើម្បីសាកសួរ អំពីគោលបំណង របស់ព្រះមហាក្សត្រខ្មែរ ។ បន្ទាប់ពីបាន សន្ទនា អស់រយៈពេល ៣ ម៉ោង ជាមួយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីពង្ស និង អគ្គស្នងការបារាំងនៅកម្ពុជា ឡឺតួរណូ ក៏បានផ្ដាំផ្ញើទៅព្រះមហាក្សត្រខ្មែរថា ឲ្យមានការប្រយ័ត្នប្រយែង ព្រោះថា បើមានបញ្ហាអ្វី ព្រះអង្គអាច នឹងបាត់បង់រាជ្យសម្បត្តិ តែម្ដង។ នៅថ្ងៃ១០ មេសាឆ្នាំ ១៩៥៣ ព្រះមហាក្សត្រខ្មែរ ព្រះបាទ នរោត្តម សីហនុ ក៏បានចាកចេញពីទីក្រុងប៉ារីស៍ឆ្ពោះទៅប្រទេសកាណាដា។ នៅពេលដែលព្រះអង្គ មកដល់ប្រទេសកាណាដា ព្រះបាទនរោត្តម សីហនុ ទ្រង់បានថ្លែង តាមរយៈវិទ្យុកាណាដាថា : នៅកម្ពុជា បញ្ហាចលនា កុម្មុយនិស្តនៅឥណ្ឌូចិន មិនមែនជាបញ្ហាសំខាន់ ដូចនៅប្រទេសវៀតណាមទេ ពីព្រោះប្រជាជនខ្មែរ ជាអ្នកកាន់លិទ្ធិពុទ្ធសាសនា ហើយកសិករខ្មែរសុទ្ធតែមានដីធ្លី របស់គេគ្រប់គ្រាន់ សម្រាប់ចិញ្ចឹមជីវិតគេផងទៀត។ ប៉ុន្តែផ្ទុយទៅវិញ ប្រជាជនខ្មែរគ្រប់រូប តែងតែប្រាថ្នាចង់បានឯករាជ្យរបស់គេ។ បន្ទាប់ពីប្រទេសកាណាដា ព្រះមហាក្សត្រខ្មែរ បានយាងទៅ សហរដ្ឋអាមេរិក ។ នៅទីក្រុងវ៉ាស៊ីងតោន ព្រះបាទនរោត្តមសីហនុ បានជួបសន្ទនា ជាមួយ លោក ហ្វ៊ស្ទែរ ឌឹលឡេស* (Foster Dulles) *រដ្ឋមន្ត្រី កាបរទេសសហរដ្ឋអាមេរិក។ លោក ហ្វ៊ស្ទែរ ឌឹលឡេស យល់ថា បារាំងគួរតែ ផ្ដល់ឯករាជ្យបរិបូណ៌ ទៅឲ្យប្រទេស អាណានិគមរបស់គេយ៉ាងឆាប់រហ័សដែរ ប៉ុន្តែ លោករដ្ឋមន្ត្រី ការបរទេស អាមេរិក ក៏បានគូសបញ្ជាក់ផងដែរថា លោកគ្មានជំនឿទាល់តែសោះថា ប្រទេស ដែល បារាំង នឹង ផ្ដល់ឯករាជ្យទៅឲ្យ អាចនឹងមាន កម្លាំងគ្រប់គ្រាន់សម្រាប់ទប់ទល់ នឹងកុម្មុយនីស្ត ព្រោះថាកម្លាំង នៃ គំនិតជាតិនិយម តែមួយមុខ មិនគ្រប់គ្រាន់ ទាល់តែសោះ ។ ចំពោះប្រទេសកម្ពុជា លោកហ្វ៊ស្ទែរ ឌឹលឡេស ទាយទុក ជាមុនថា ពេលបារាំង ដកខ្លួនចេញពីកម្ពុជា ប្រទេសកម្ពុជានឹងធ្លាក់ទៅក្នុងកណ្ដាប់ដៃកុម្មុយនិស្ត ដោយគេចពុំផុត។ ដូច្នេះឃើញថា ឯករាជ្យបរិបូណ៌របស់ខ្មែរ មានការទាក់ទង យ៉ាងជិតស្និទ្ធ ជាមួយ នឹងការប្រឈមមុខគ្នា រវាងមហាអំណាច ទាំង ២ គឺ កុម្មុយនិស្ត មួយចំណែក ហើយ*





*មួយចំណែកទៀតលោកសេរី ។ អង្គការវៀតមិញ មានការគាំទ្រយ៉ាងរឹងមាំ ពីសំណាក់កុម្មុយនិស្ត ដូចនេះ តើប្រទេសកម្ពុជា តែម្នាក់ឯង ទប់ទល់ នឹង កុម្មុយនិស្ត របៀបណាទៅ? ទោះជាយ៉ាងណាក្ដី ព្រះមហាក្សត្រខ្មែរនៅតែរក្សាជំហររបស់ ព្រះអង្គជានិច្ច ។ បន្ទាប់ពីបានចុះផ្សាយនិក្ខេបបទ របស់ព្រះអង្គ នៅក្នុងកាសែត អាមេរិក ញូវយ៉ក ថែម* *(New York Times)* *ចេញផ្សាយនៅថ្ងៃអាទិត្យទី ១៩ មេសា ឆ្នាំ ១៩៥៣ ព្រះមហាក្សត្រខ្មែរ ក៏យាងទៅទីក្រុងតូក្យូ* (Tokyo) *ទៀត ដើម្បីរង់ចាំ លទ្ធផល នៃ ការចរចា រវាង បារាំង និងខ្មែរ នៅទីក្រុងប៉ារីស៍ ។ នៅថ្ងៃ ៩ ឧសភា ឆ្នាំ ១៩៥៣ គណប្រតិភូខ្មែរមួយដឹកនាំដោយលោក ប៉ែន នុត, លោក សម សារី និង ព្រះអង្គម្ចាស់មុនីរ៉េត បានធ្វើការចរចា យ៉ាងមមាញឹក ជាមួយ មន្ត្រីជាន់ខ្ពស់ បារាំង ។ ប៉ុន្តែលទ្ធផល នៃការចរចានោះ ពុំបានធ្វើឲ្យព្រះមហាក្សត្រសព្វព្រះរាជហឫទ័យទេ ដោយហេតុថា បារាំងនៅតែរក្សា កាន់កាប់ កងទ័ពខ្មែរ ដដែល ទោះបី មានតួនាទីត្រឹមទីប្រឹក្សាក៏ដោយ។ នៅក្នុងវិស័យយុត្តិធម៌ ជនជាតិបារាំង និង ជនភាគតិច ផ្សេងៗទៀត នៃប្រទេសទាំង ៣ នៅ«ឥណ្ឌូចិនបារាំង» ព្រមទាំងជនជាតិ ចិន ផងដែរ មិនបានត្រូវដាក់ឲ្យ ស្ថិតនៅក្រោម យុត្តិធម៌ របស់ ខ្មែរទេ គឺ បានត្រូវដាក់ ឲ្យ ស្ថិតនៅក្រោម តុលាការបម្រុះទៅវិញ ។ ខាងផ្នែករូបិយវត្ថុ មាន បញ្ហាជាច្រើនដែល ខ្មែរពុំអាចទទួលយកបាន ។ ដោយមិនសព្វព្រះរាជហឫទ័យ នឹងកិច្ចចរចា ថ្ងៃ ៩ ឧសភា នៅទីក្រុងប៉ារីស៍ ព្រះមហាក្សត្រខ្មែរ ក៏ទ្រង់សម្រេច ធ្វើការទាមទារ ឯករាជ្យបរិបូរបន្តទៅទៀត ជាពិសេសនៅក្នុងទ្រង់ទ្រាយ មួយដ៏ធំតែម្ដង ។*

# កំណែន កម្លាំង ប្រជាជាតិទាំងមូល
# នៅ ថ្ងៃ ២៨ មិថុនា ឆ្នាំ ១៩៥៣

## La mobilisation des forces vives de la Nation le 28 juin 1953

ដោយការចរចា នៅទីក្រុងបារីស៍ ពុំបានហុច នូវលទ្ធផលល្អ ហើយ ដោយសហរដ្ឋអាមេរិក បានសំដែង នូវការព្រួយបារម្ភ របស់គេ ស្តីពី ឯករាជ្យខ្មែរនៅ ចំពោះមុខកម្លាំងកុម្មុយនិស្ត ព្រះមហាក្សត្រក៏យាងត្រឡប់មកកម្ពុជាវិញ នៅថ្ងៃ ១៤ ឧសភា ឆ្នាំ ១៩៥៣ ដដែលនោះ បន្ទាប់ពី បានស្នាក់អាស្រ័យ នៅទីក្រុងតូក្យូ អស់មួយរយៈពេល។ ចំពោះព្រះមហាក្សត្រខ្មែរ ទិសដៅអំណឹះតទៅ មានតែមួយគត់ គឺ ធ្វើយ៉ាងណាប្រមូលកម្លាំងប្រជាជាតិ ទាំងមូលឲ្យបាន ទើបអ្វីៗ អាចសម្រេចទៅបាន ។ ព្រះអង្គមានជំនឿថា ព្រះអង្គ នឹងអាចធ្វើកិច្ចការនេះបាន ព្រោះក្រុមខ្មែរឥស្សរៈកំពុងបែកបាក់គ្នា ហើយខិតខំរើបម្រះខ្លួនចេញ ពី ចលនាវៀតមិញ ។ មេឥស្សរៈ ដាប ឈួន ហៅ ឈួន មូ្លពេជ្រ ក៏បានចុះចូល រាជរដ្ឋាភិបាល តាំងពី ថ្ងៃ ទី ១ តុលា ឆ្នាំ ១៩៤៩ មក ហើយដែរ ។ រីឯ ពុត ឆាយ និង និល ពេជ្រ ក៏ បានមកសុំជ្រកកោន នឹងព្រះបិតា របស់ព្រះអង្គទៀត។ ដូច្នេះឃើញថា ក្រៅពីគណបក្សប្រជាធិបតេយ្យ ដែល កំពុងតែផ្លាស់ប្តូរ អ្នកដឹកនាំរបស់គេ ព្រះអង្គអាចនឹងធ្វើការបង្រួបបង្រួមជាតិ បានដោយងាយ ព្រោះ អំណាចបានធ្លាក់ មកក្នុងកណ្តាប់ដៃ របស់ព្រះអង្គអស់ទៅហើយ ។ សូមបញ្ជាក់ថា នៅពេលនោះ ទោះបីក្រុមខ្មែរឥស្សរៈ ដូចជា ក្រុមចន្ទរង្សី / សាវ៉ាង វង់ និងសឺន ង៉ុក ថាញ់ ជាដើម ពុំទាន់ចុះចូលព្រះអង្គក៏ដោយ ក៏ពួកគេពុំអាចធ្វើការតស៊ូនៅក្នុងព្រៃ បន្តទៅទៀតឡើយ នៅក្នុងករណីដែលព្រះអង្គអាចធ្វើការបង្រួបបង្រួមជាតិបាន ព្រោះថាបើព្រះអង្គគ្រប់គ្រងកម្លាំង ទាំងនោះបាន / បារាំងច្បាស់ជា មានការទុកចិត្ត ទៅលើរូបព្រះអង្គ





ហើយ ច្បាស់ជាត្រូវបន្ធូរចិត្ត ប្រគល់ឯករាជ្យ មកឲ្យខ្មែរ ជាពុំខាន ហើយទន្ទឹមនោះ ក៏អាចរក្សាឥទ្ធិពល របស់គេ នៅកម្ពុជាបានទៀតផង ។ តាមការពិតទៅ កត្តាសំខាន់បំផុតគឺសាមគ្គីភាពផ្ទៃក្នុង។ បើបាន សាមគ្គីផាពផ្ទៃក្នុងហើយ តើមានអ្វីអាចមកជ្រៀតជ្រែកបានទៀត គឺនៅសល់តែការគ្រប់គ្រងសង្គមទាំង មូល ទៅតាមគតិយុត្តិធម៌តែប៉ុណ្ណោះ។ លក្ខខណ្ឌចុងក្រោយនេះ ជាការពិបាក ក៏ពិតមែន ប៉ុន្តែគេអាចនិយាយបានថា ព្រះបាទនរោត្តម សីហនុ នៅពេលនោះ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទាំងអស់ ដើម្បីធ្វើ កិច្ចការទាំងអស់នោះ។ គ្រោះថ្នាក់មានតែមួយគត់ គឺការធ្លាក់ដោយមិនដឹងខ្លួនទៅក្នុងកណ្តាប់ដៃ ពួកអាណានិគមនិយម ម្ខាងទៀត ដែលកំពុងរង់ចាំឱកាស ចូលតាមទ្វារក្រោយ។ បន្ទាប់ ពីទ្រង់បានព្រះតម្រិះដូច្នេះហើយ ព្រះមហាក្សត្រខ្មែរ បានប្រកាសនៅ ថ្ងៃ ទី ២២ មិថុនាថា ព្រះអង្គ នឹង ទៅតាំងសេនាធិការដ្ឋាន របស់ ព្រះអង្គ នៅខេត្តសៀមរាប គឺខេត្តដែលស្ថិតនៅក្រោម ការគ្រប់គ្រងរបស់ អតីត មេឥស្សរៈខ្មែរ ឈួន មូ្លពេជ្រ ហើយដែលគ្មានវត្តមាន នៃ កងទ័ពបារាំង ។ បន្ទាប់មក នៅថ្ងៃ ១៤ មិថុនា ឆ្នាំ ១៩៥៣ ដដែលនោះ ព្រះអង្គ ក៏ទ្រង់យាងទៅទីក្រុងបាងកក ។

នៅពេលដែលព្រះអង្គយាងមកដល់ទីក្រុងបាងកក ព្រះបាទនរោត្តម សីហនុ ពុំបានទទួលនូវ បដិសណ្ឋារកិច្ចកក់ក្តៅអ្វីពីប្រទេសថៃទេ ព្រោះប្រទេសថៃ ចង់រក្សាទំនាក់ទំនងល្អជាមួយបារាំង។ ព្រះមហាក្សត្រថៃ ភូមិបុល ពុំបានទទួលជួបសន្ទនាអ្វី ជាមួយព្រះអង្គទេ ។ រីឯរដ្ឋមន្ត្រី ទី ១ ថៃ ភិបុលសង្គ្រាម ក៏បានបញ្ចេញ នូវ ឥរិយាបទយ៉ាងស្ងួតដាក់ព្រះអង្គ ហើយថែមទាំងហាមឃាត់ព្រះអង្គ មិនឲ្យជួបអ្នកកាសែត នៅលើទឹកដីថៃ ផងទៀត គឺ ចាត់ទុកព្រះអង្គ ជាអ្នកជ្រកកោននយោបាយរូបជាស្រេច។ នៅក្នុងពេលដដែលនោះ សារពត៌មាន អន្តរជាតិ បានបញ្ចេញនូវប្រតិកម្ម ផ្សេងៗ របស់គេខុសពីនេះ។ ប្រទេសឥណ្ឌា និងប្រទេស ភូមា គាំទ្រ គំនិតរបស់ ព្រះមហាក្សត្រខ្មែរ។ នៅប្រទេសបារាំង ឯនោះវិញ ក្រៅពីសារពត៌មាន «ហ្វ្រង់ទៀរ័រ» (Franc Tireur) សារពត៌មានឯទៀត បានបញ្ចេញនូវ ការពេបជ្រាយ របស់គេ ចំពោះសកម្មភាព របស់

ព្រះបាទ នរោត្តម សីហនុ ។ សារពត៌មានអង់គ្លេស «ដែលី តេឡេក្រាហ្វ» (Daily Télégraph) បានសរសេរ ដាក់ផ្តៃផ្ការថា : បើគ្មានវត្តមាន បារាំងទេនោះ ប្រទេសកម្ពុជា ប្រហែលជា ក្លាយទៅជា ប្រទេសឯករាជ្យមួយ ដែលរណបប្រទេសចិន តាំងពីយូរណាស់ បាត់ទៅហើយ ។ ដូច្នេះឃើញថា ចំពោះព្រះមហាក្សត្រខ្មែរ ប្រកមានតែមួយទេ គឺ សាមគ្គីភាពផ្ទៃក្នុង។ បន្ទាប់ពី ទីក្រុងបាងកក ព្រះមហាក្សត្រ ក៏ធ្វើព្រះរាជដំណើរឆ្ពោះទៅសេនាធិការដ្ឋាន របស់ ព្រះអង្គ នៅទីក្រុងសៀមរាប។ ក្រោយមកទៀត នៅថ្ងៃ ២៨ មិថុនាឆ្នាំ ១៩៥៣ ដដែល ព្រះអង្គ ក៏ យាងទៅខេត្របាត់ដំបង។ គឺនៅទីនោះហើយ ដែលព្រះអង្គប្រកាសប្រមែប្រមូល កម្លាំងដើម្បីព្រឈមមុខ នឹង ស្ថានការណ៍ដ៏ពិបាកនេះ។ ព្រះបាទនរោត្តម សីហនុ បាន ប្រកាសថា : នឹង ធ្វើការតស៊ូ ប្រឆាំង នឹង សត្រូវ គ្រប់ប្រភេទ ដើម្បីបុព្វហេតុ ឯករាជ្យ ជាតិ។ ការប្រកាសនេះ បានទទួលជោគជ័យមួយ ដ៏អស្ចារ្យ ព្រោះអ្នកណាក៏សុខចិត្ត គាំទ្រព្រះអង្គដែរ រួមបញ្ចូលទាំងខ្មែរដែលជាទាហានបារាំងទៀតផង ។ ពួកខ្មែរឥស្សរៈជាច្រើន ក៏បាននាំគ្នាមកគាំទ្រ ព្រះអង្គដែរ ប៉ុន្តែកម្លាំងចិត្តមិនគ្រប់គ្រាន់ទេ ព្រោះ ត្រូវរៀបចំអង្គការបាត់តាំង ឲ្យបានល្អ ត្រឹមត្រូវសិន ទើបអាចគេច ពីផលវិបាកមិនល្អបាន ។ ដោយខ្វះ នូវ អង្គការបាត់តាំង ត្រឹមត្រូវ អ្នកខ្លះឆ្លៀតយកឱកាសនោះ បង្កើត ការរំជើបរំជួល ពេញទីក្រុងភ្នំពេញ ដូចជាការគប់គ្រាប់បែក នៅតាមរង្គសាលជាដើម។ នៅទីបំផុត ចាប់តាំងពីថ្ងៃ ៣ កក្កដា មក បារាំង ក៏បន្ទន់ឥរិយាបថ ។ គួរកត់សំគាល់ផងដែរថា : កត្តាសំខាន់ៗ នៃ ជោគជ័យនេះ គឺ ការបេះប្រមូលកម្លាំងសាមគ្គីភាព នៃប្រជាជាតិទាំងមូលរឹងការរួបរួមជាតិ ជាធ្លុងមួយ អាចធ្វើទៅបាន លុះណាតែមាន ទិសដៅនិងមូលហេតុ ទាក់ទង នឹងប្រយោជន៍ប្រទេសជាតិពិតប្រាកដ ហើយនៅក្នុងករណីនេះ គឺ ឯករាជ្យទាំងមូលរបស់ជាតិ តែម្តង។ កាលណា ប្រជាជាតិទាំងមូល នាំគ្នា ក្រោកឈរ ដូចមនុស្សតែម្នាក់ គឺ ជាការធានាមួយ ដ៏ធំ ព្រោះអ្វីដែលគេ ខ្លាច បំផុត គឺការប្រឈមមុខ ដាក់គ្នាឯងទៅវិញទេ ដែលជាហេតុ ធ្វើឲ្យសត្រូវអាចឆ្លៀត ឱកាសបង្កើតសង្គ្រាមផ្ទៃក្នុង ។ នៅខែសីហា ឆ្នាំ ១៩៥៣





ដដែលនោះ ការចរចា រវាង បារាំង និងខ្មែរក៏ចាប់ផ្តើម ហើយនៅថ្ងៃ ២៩ មិថុនា បារាំង ក៏ប្រគល់ ឯករាជ្យ ផ្នែកយុត្តិធម៌ និង ផ្នែកសន្តិសុខ មកឲ្យខ្មែរ ។ នៅថ្ងៃ១៧ តុលា ឆ្នាំដដែល ប្រទេសកម្ពុជា បានទទួលឯករាជ្យ បរិបូរខាងផ្នែកយោធា ។ ប៉ុន្តែគេត្រូវ រង់ចាំ សន្និសីទនៅទីក្រុង ហ្សឺណែវ ទៀត ទើបអាចដោះស្រាយ បញ្ហាវត្តមានកងទ័ពវៀតមិញ នៅលើទឹកដីខ្មែរបាន ។

# សន្និសីទ ទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤

## La Conférence de Genève de 1954

នៅថ្ងៃ ៩ វិច្ឆិកា ឆ្នាំ ១៩៥៣ បន្ទាប់ពី បារាំងបានប្រគល់សមត្ថកិច្ច ផ្នែក តុលាការ ហិរញ្ញវត្ថុ និង យោធាមកឲ្យខ្មែរសព្វគ្រប់ហើយ ព្រះមហាក្សត្រខ្មែរ ក៏បានប្រកាសឯករាជ្យជាតិ ដោយឥតបង្អង់ ។ នេះជាព្រឹត្តិការណ៍មួយ ដ៏ សំខាន់នៅក្នុង ប្រវត្តិសាស្ត្រខ្មែរ។ តាំងពីពេលនោះមក ព្រះបាទ នរោត្តម សីហនុ បានត្រូវគេទទួលស្គាល់ ថាជាវិរបុរសជាតិ ជាព្រះបិតា នៃ ឯករាជ្យជាតិ ។ ទោះជាយ៉ាងនេះក្តី ក៏ព្រះអង្គ នៅតែ បន្តទទួលការរិះគន់ ពីសំណាក់ វរជននយោបាយខ្មែរមួយចំនួនដែរ ដោយហេតុថា ប្រទេសកម្ពុជា នៅតែស្ថិតនៅក្នុងសហភាពបារាំង ដដែល។ ដូចនេះ ឯករាជ្យខ្មែរនៅពុំទាន់មានលក្ខណៈបរិបូណ៌នៅឡើយ។ មួយវិញទៀត ការដែលព្រះមហាក្សត្រខ្មែរហាក់បីដូចជាពុំសូវ ផ្តល់តម្លៃ ប៉ុន្មានទៅឲ្យស្មារតី នៃ រដ្ឋធម្មនុញ្ញខ្មែរ ឆ្នាំ ១៩៤៧ វរជន ទាំងនោះ ក៏នាំគ្នាធ្វើការតស៊ូបន្តមកទៀត ដោយចាត់ទុកថា ឯករាជ្យ ដែលព្រះមហាក្សត្រ បានប្រកាសនៅថ្ងៃ ៩ វិច្ឆិកា ជា ឯករាជ្យក្លែងបន្លំ ផងទៀត ។ បញ្ញវន្តខ្មែរ មួយចំនួន ដូចជាលោក កេង វ៉ាន់សាក់, ជួន មុម្ម, លោក សុក ជួក, សាឡុត ស ជាដើម ដែលបានវិលត្រឡប់មក ពីស្រុកបារាំងជាបន្តបន្ទាប់ ចាប់ តាំងពី ឆ្នាំ ១៩៥២ មក ក៏បាននាំគ្នា បង្កើត

ជាក្រុមប្រឆាំងមួយ។ ទន្ទឹមគ្នានោះដែរ បញ្ញវន្ត មួយចំនួនទៀតព្រមទាំងអ្នកនយោបាយ អភិរក្សខ្មែរសំខាន់ៗយល់ឃើញថាដោយព្រះមហាក្សត្រខ្មែរមាន កិត្យានុភាពល្បីល្បាញ និងមានអំណាចដ៏ខ្លាំងក្លាបែបនេះ គេពុំអាចលុបតួនាទី ឬដណ្ដើមយកអំណាច ពីព្រះអង្គបាន ដោយងាយ នោះទេ។ យុទ្ធសាស្ត្រល្អ មានតែមួយប៉ុណ្ណោះ គឺគាំទ្រ ព្រះមហាក្សត្រ ហូតដល់ពេលឱកាសល្អ ហុចឲ្យតែម្ដង ។

គឺនៅក្នុងន័យ នេះហើយ ដែលលោក សម សារី សម្រេចរួបរួមជាមួយ លោក ញឹក ជូឡុង, លោក លន់ នល់ និង អ្នកអង្គម្ចាស់សិរិមតៈ ដែលសុទ្ធតែ ជាអ្នកដែលត្រូវគេចាត់ទុក នៅពេលនោះ ថា មានភក្ដីភាព ១០០ ភាគរយចំពោះព្រះ មហាក្សត្រ។ លោក សម សារី ជាបញ្ញវន្តខ្មែរមួយរូប ដែលមានចំណេះវិជ្ជា ដ៏ខ្ពស់ ហើយដែលមានគោលជំហររឹងប៉ឹងបំផុត ក្នុងការស្វែងរក ឯករាជ្យបរិបូណ៌ ពិតប្រាកដមកឲ្យខ្មែរ គឺធ្វើអ្វីគ្រប់បែបយ៉ាងដើម្បីផ្ដាច់ ប្រទេសកម្ពុជាឲ្យដាច់ចេញ ពី សហភាព បារាំងតែម្ដង ហើយក្នុងពេលជាមួយគ្នានោះ ដេញអ្នកតស៊ូវៀតមិញ ឲ្យចេញអស់ពីទឹកដីខ្មែរផងទៀត។ នៅថ្ងៃ ៧ មេសា ឆ្នាំ ១៩៥៤ គឺ ជាងមួយខែក្រោយពេល ដែលមេឥស្សរៈខ្មែរ អ្នកអង្គម្ចាស់ នរោត្តម ចន្ទរង្សី និង សាវ៉ាង វង់ បានចុះចូល រដ្ឋាភិបាល/ ព្រះមហាក្សត្រខ្មែរ បានបង្កើត រដ្ឋាភិបាលថ្មីមួយដែលមាន ព្រះអង្គជា  ប្រមុខ។ នៅពេលនោះ កងទ័ពវៀតមិញ បានធ្វើសកម្មភាពយ៉ាងខ្លាំង ព្រោះ នៅ ឯ សមរភូមិ ឌៀន បៀន ភូ ប្រទេសវៀតណាម, បារាំង កំពុងតែទន់ដៃ យ៉ាងខ្លាំង ។ នៅថ្ងៃ ១២ មេសា ឆ្នាំ១ ៩៥៤ នោះកងទ័ពព្រៃ វៀតមិញ បានវាយប្រហារ ទៅលើ រថភ្លើងភ្នំពេញ-បាត់ដំបង យ៉ាងឃោរឃៅ ប៉ុន្តែ គឺនៅពេលនោះដែរ ដែលព្រះមហាក្សត្រខ្មែរ ព្រះបាទនរោត្តម សីហនុ ដឹកនាំ ប្រតិបត្តិការសឹក រុញច្រានកងទ័ពវៀតមិញ។ ប្រតិបត្តិការសឹកនោះ មានឈ្មោះថា «ប្រតិបត្តិការសាមគ្គី» (Opération-Samakki)។ ប៉ុន្តែ ទាល់តែក្រោយកិច្ចព្រមព្រៀងទីក្រុង ហ្សឺណែវ ទើបបញ្ហានេះ បានត្រូវដោះស្រាយ ។





សន្និសីទទីក្រុងហ្សឺណែវ ដែលបានចាប់ផ្ដើម ពីថ្ងៃ ២៦ មេសា រហូតដល់ថ្ងៃ ២១-២២ កក្កដា ឆ្នាំ១៩៥៤ បានយកសំណុំរឿងសំខាន់ៗ មកដោះស្រាយ គឺ បញ្ហាប្រទេសកូរ៉េទាំង ២ និងបញ្ហាឥណ្ឌូចិន។ ប្រទេស ដែលបានចូលរួមក្នុងអង្គប្រជុំ មានជាអាទិ៍ : សហរដ្ឋ អាមេរិក, ប្រទេសអង់គ្លេស, សហភាព សូវៀត, ប្រទេសចិន, ប្រទេស បារាំង ព្រមទាំងប្រទេសទាំងឡាយ ដែលជាប់ទាក់ទិន ។ រីឯ បញ្ហា នីតិវិធីស្ដីពី ការតំណាងចលនា តស៊ូសំខាន់ៗនៅក្នុងប្រទេសទាំង ៣ នៅឥណ្ឌូចិន បានចោទឡើងជាបញ្ហា ដ៏ពុះកញ្ជ្រោល។ សូមបញ្ជាក់ថា សន្និសីទនេះ បានត្រូវបើកឡើងនៅពេលដែលកងទ័ពវៀតមិញ កំពុងមានប្រៀប ទៅលើ កងទ័ពបារាំង នៅ ឌៀន បៀន ភូពោល គឺសន្និសីទ អន្តរជាតិមួយ ដែលសាកល្បង ដោះស្រាយការប្រជែងកម្លាំង រវាងលោកទាំងពីរ គឺ លោកកុម្មុយនិស្ត និង លោកសេរី ។ នៅ ថ្ងៃ ៧ ឧសភា ឆ្នាំ ១៩៥៤ កងទ័ព បារាំង ទទួលបរាជ័យ ទាំងស្រុង ជាហេតុបណ្ដាលឲ្យ លោក ម៉ង់ដេស ហ្វ្រង់ (Pierre Mendès France) ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រីបារាំងនៅសម័យ ប្រធានាធិបតី រ៉ឺណេកូទី បានចុះហត្ថលេខាទៅលើកិច្ចព្រមព្រៀង យុទ្ធសន្តិភាព (Armistice) មួយឲ្យបានមុនថ្ងៃ ២០ កក្កដាឆ្នាំដដែល។ ប៉ុន្តែ ការទាមទារនេះ បានធ្វើឲ្យមាន ការខ្វែងគំនិតគ្នាមួយយ៉ាងធំ រវាង លោក អង់ ថូនី អេដេន (Anthony Eden) រដ្ឋមន្ត្រីការបរទេសអង់គ្លេស នៅពេលនោះ និងរដ្ឋមន្ត្រីការបរទេស អាមេរិក ហ្វូស្ទែរ ឌិលឡេស (Foster Dulles) ។ នៅមុនពេលបើក សន្និសីទ ទីក្រុងហ្សឺណែវ សហរដ្ឋ អាមេរិក ចង់ផ្ដល់ជំនួយយោធា ទៅឲ្យបារាំង នៅក្នុងករណីដែលប្រទេសអង់គ្លេសយល់ព្រមផងដែរ ប៉ុន្តែប្រទេសអង់គ្លេសពុំព្រម ព្រោះ ខ្លាចសង្គ្រាមរាលដាល ហួសព្រំដែន។ សូមបញ្ជាក់ថា នៅពេលដែល សន្និសីទ ទីក្រុងហ្សឺណែវ ឈាន ទៅដល់ទីបញ្ចប់ អ្នកតំណាងសហរដ្ឋ អាមេរិក គ្មានវត្តមាននៅក្នុងអង្គប្រជុំទេ ហើយនៅពេលអង្គប្រជុំឈានមកដល់ទីបញ្ចប់ គឺនៅថ្ងៃ ទី ២១ កក្កដា សហរដ្ឋ អាមេរិក ក៏ពុំព្រមចុះហត្ថលេខា ទៅលើកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវទៀត ។ លោក ហ្វូស្ទែរ ឌិលឡេស (Foster Dulles) ដកខ្លួនទៅ

រៀបចំផែនការមួយ គឺ រៀបចំប្រព័ន្ធ ការពារមួយ នៅអាស៊ី ដើម្បីទប់ទល់នឹង កុម្មុយនិស្ត គឺ អង្គការសន្ធិសញ្ញា អាស៊ី អាគ្នេយ៍ ដែលមានឈ្មោះថា អូតាស្ហ៍ ។ សន្ធិសញ្ញាអូតាស្ហ៍ (O. T. A. S. E) បានត្រូវ ចុះហត្ថលេខានៅថ្ងៃ ៨ កញ្ញា ឆ្នាំ ១៩៥៤ ដដែល នៅទីក្រុងម៉ានីល។ ស្តីពី បញ្ហាទាក់ទង នឹង ប្រទេសកម្ពុជា / ដោយ លោក សម សារី មានស្មារតី រឹងប៉ឹង មិនខ្លាច នឹងប្រឈមមុខដាក់ ប្រទេសមហាអំណាច ដោយត្រង់ៗ ប្រទេសកម្ពុជា ក៏ បានទទួលឯករាជ្យពេញលក្ខណៈ គឺ បានទទួល សិទ្ធិស្វ័យសម្រេច គ្រប់គ្រាន់ទាំងអស់។ លោក សម សារី ជាអ្នកចរចាខ្មែរម្នាក់ ដ៏ ស្ទិតស្ទាញបំផុត ក្នុងការទាមទារសិទ្ធិ ដ៏សំខាន់នេះ សម្រាប់ ឯករាជ្យ បរិបូរពិត របស់ខ្មែរ ។ តាមរយៈ សិទ្ធិនេះ ខ្មែរអាចជ្រើសរើស យកប្រទេសណា ជាសម្ព័ន្ធមិត្រ ក៏បានដែរ គឺ មិនរណបអ្វីទាំងអស់ទៅនឹង យុទ្ធសាស្ត្រ របស់ បារាំង ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ដោយប្រការផ្សេងៗ ការប្រឹងប្រែង របស់ លោក សម សារី បាន ត្រូវលាយសាបសូន្យ អស់ទៅវិញនៅ ពេលក្រោយមកទៀត ។ នៅក្នុងរដ្ឋាភិបាល សម្តេច នរោត្តម សីហនុ នា ថ្ងៃ ២៩ កក្កដា ឆ្នាំ១៩៥៣ ដល់ ថ្ងៃ ២២ វិច្ឆិកា ឆ្នាំដដែល លោកធ្វើជារដ្ឋមន្ត្រីខាងសន្និសីទ ។ នៅឆ្នាំ ១៩៥៩-១៩៦០ លោក ក្លាយទៅជាអ្នកប្រឆាំង នឹង នយោបាយ របស់ សម្តេច នរោត្តម សីហនុ ដែលរេទៅរកលោកកុម្មុយនិស្ត។

## បរិយាកាស នៃ សន្និសីទ ទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤

## L’ambiance de la Conférence de Genève de 1954





សន្និសីទទីក្រុងហ្សឺណែវ ឆ្នាំ១៩៥៤ ដែលចាប់ផ្តើមបើកសម័យប្រជុំ នៅថ្ងៃ ២៦ មេសា បានយកសំណុំរឿង ឥណ្ឌូចិន មកជជែកពិភាក្សានៅថ្ងៃ ៨ ឧសភា គឺ បន្ទាប់ពីការចរចា ស្តីពីបញ្ហា ប្រទេសកូរ៉េទាំង ២ បានទទួលបរាជ័យ ។ ការពិនិត្យ សំណុំរឿងឥណ្ឌូចិន បានចាប់ផ្តើមប្រព្រឹត្តទៅមួយថ្ងៃ ក្រោយការដកថយចុះចាញ់ នៃកងទ័ពបារាំង នៅចំពោះមុខ កងទ័ព វៀត មិញ នៅ ឌៀន បៀន ភូ។ ដោយផ្អែក ទៅលើឯកសារ របស់ លោក ហ្វីលីព ដឺវីលីយេ (Philippe Devilliers) និង លោកស្ហង់ ឡាគូតួរ (Jean La Couture) ខ្ញុំសូមធ្វើការពិពណ៌នា អំពី ដំណើរ ប្រព្រឹត្តទៅ នៃ អង្គសន្និសីទ ហ្សឺណែវ ឆ្នាំ ១៩៥៤ ដូចតទៅ ៖

លោកប៊ីដូលត៍ (Bidault) រដ្ឋមន្ត្រីការបរទេសបារាំង នៅពេលនោះ បានស្នើ សុំឲ្យបញ្ចប់ការប្រយុទ្ធគ្នា ដោយមាន ការធានាត្រឹមត្រូវ ប៉ុន្តែការអនុវត្តន៍ កិច្ចព្រម ព្រៀង ត្រូវស្ថិតនៅ ក្រោមការត្រួតពិនិត្យ របស់ គណកម្មាធិការ អន្តរជាតិនានា ។ ទទឹមនោះ លោក ប៊ីដូលត៍ (Bidault) ក៏ បានស្នើសុំ ឲ្យរដ្ឋ ២ ទៀត នៃ ឥណ្ឌូចិន ដែលបានមកចូលរួមក្នុងអង្គសន្និសីទ ធានាការអនុវត្តន៍ កិច្ចព្រមព្រៀងនោះដែរ ។ ខាងអ្នកចរចា បារាំង គេសុខចិត្តលើកឡើង តែពីបរាជ័យបារាំង ខាងផ្នែកយោធា តែមួយមុខ ។ ខាងផ្នែកនយោបាយ បារាំង ទទួលស្គាល់ តែរដ្ឋវៀតណាម ដែលបានត្រូវទទួលស្គាល់ ជាផ្លូវ ការប៉ុណ្ណោះ គឺ មិនព្រមធ្វើការចរចា ដោយផ្ទាល់ជាមួយ អង្គការ វៀតមិញទេ ទោះបី មានវត្តមាន នៃ អ្នកតំណាងអង្គការនេះ នៅក្នុងអង្គប្រជុំ ក្តី ។ លោក ផាំ វ៉ាន់ ដុង អ្នកតំណាង អង្គការវៀតមិញ បានស្នើសុំឲ្យអ្វីដែលលោកហៅថា រដ្ឋាភិបាលប្រជាធិបតេយ្យ នៃប្រទេសទាំងពីរទៀត គឺ ខ្មែរឥស្សរៈ និង អង្គការ ប្រទេសលាវ ចូលរួមក្នុងអង្គប្រជុំផងដែរ ដោយសំអាងថា រដ្ឋាភិបាលទាំងនោះ បានរំដោះ ទឹកដី នៃ ប្រទេសរបស់គេ បានជាច្រើនតំបន់រួចទៅហើយ។ លោក ផាំ វ៉ាន់ ដុង បានបញ្ជាក់ថា : គេមិនអាចនិយាយ ពីអនាគត នៃប្រទេសកម្ពុជា និង ប្រទេស លាវដោយគ្មានរដ្ឋាភិបាលទាំងនោះទេ។ នៅពេលនោះ លោក ម៉ូឡូតុហ្វ (Molotov) រដ្ឋមន្ត្រី ការបរទេស សហភាព

សូវៀត និង លោក ជូ អេនឡាយ រដ្ឋមន្ត្រី ការបរ ទេសប្រទេសចិន ប្រជាមានិត្តគាំទ្រសេចក្តីស្នើ របស់អ្នកតំណាងអង្គការវៀតមិញទាំងស្រុង ។ ប៉ុន្តែ លោក បេដែល ស្មីត (Bedell Smith) ខាងអ្នកតំណាង សហរដ្ឋ អាមេរិក ច្រានចោលសំណើ របស់ លោក ផាំ វ៉ាន់ ដុង ទាំងស្រុងដែរ ដោយ សំអាងថា បញ្ហា អ្នកតំណាង នៅក្នុងអង្គសន្និសីទ បានត្រូវសម្រេចមុនរួចអស់ហើយ។ នៅពេលនោះ ការប្រេបូកប្របល់ មួយ បានស្តែងចេញឡើង ។ លោក ប៊ីដូល (Bidault) អ្នកតំណាងបារាំង បាននិយាយថា: តើអង្គប្រជុំត្រូវនិយាយចរចាជាមួយ រដ្ឋាភិបាលខ្មោច ឬ ក៏យ៉ាងណា? លោក ផាំ វ៉ាន់ ដុង ឆ្លើយតប នឹង លោក ប៊ីដូល វិញថា : កាលពីមុន លោក ប៊ីដូល ក៏ តែងតែចាត់ទុកថា រដ្ឋាភិបាល នៃ សាធារណរដ្ឋ ប្រជាធិបតេយ្យវៀតណាម ជា រដ្ឋាភិបាលខ្មោច ដូច្នេះដែរ ។ បន្ទាប់មកលោក សម សារី អ្នកតំណាង ប្រទេសកម្ពុជា បានថ្លែងបញ្ជាក់ថា : «រដ្ឋាភិបាលប្រជាធិបតេយ្យ» ប្រទេសកម្ពុជា ពោលគឺ ចលនាខ្មែរឥស្សរៈ ដែល លោក ផាំ វ៉ាន់ដុង បានលើក ឡើងនោះ មាននៅតែក្នុងអារម្មណ៍ របស់ បណ្តារដ្ឋមន្ត្រី នៃ ប្លុក (Bloc) ខាងកើតតែប៉ុណ្ណោះ។ នៅក្នុងបរិយាកាសអាប់អួ នៃ អង្គប្រជុំ ទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ នោះ ឧត្តមសេនីយ៍ បេដែល ស្មីត (Bedell Smith) ខាងភាគី សហរដ្ឋ អាមេរិក និង លោក អង់ថូនី អេដេន (Anthony Eden) អ្នកតំណាង ប្រទេសអង់គ្លេស បានស្នើឲ្យយកបញ្ហានេះទៅជជែកនៅក្នុងអង្គប្រជុំ នៃបណ្តា ប្រទេស មហា អំណាច នៅទីក្រុងប៊ែរឡាំង (Berlin) ។ ប៉ុន្តែ លោក ម៉ូឡូតុហ្វ (Molotov) ខាង សហភាព សូវៀត ឆ្លើយថា : បើយកបញ្ហានេះទៅជជែក រវាង ប្រទេសមហាអំណាច នៅទីក្រុងប៊ែរឡាំង គឺ មិនមែនជជែក រវាងមហាអំណាច ៤ ប៉ុណ្ណោះទេ តែត្រូវមាន ប្រទេស មហាអំណាច ៥ ព្រោះ ប្រទេសចិន ប្រជាមានិត្ត ក៏ មានចែងយ៉ាងច្បាស់ នៅក្នុងអត្ថបទ ទីក្រុងប៊ែរឡាំងដែរ ហើយប្រទេសចិន ជាប្រទេសមហាអំណាចដែលបាន អញ្ជើញ សាធារណរដ្ឋ ប្រជាធិបតេយ្យ វៀតណាមឲ្យចូលរួមក្នុងអង្គប្រជុំផងដែរ។ ដោយការជជែករកច្រកចេញមិនឃើញ លោក អង់ថូនី អេដេន (Anthony





Eden) ក៏ ប្រកាស បិទអង្គប្រជុំសិន ហើយ ការជជែកបន្ត នឹងប្រព្រឹត្តទៅ នៅថ្ងៃ ១០ ខែ ឧសភាដដែល។ ទោះបីមានការខ្វែងគំនិតគ្នា អំពី នីតិវិធីក្តី ក៏ អង្គប្រជុំបានប្រព្រឹត្តបន្តទៅទៀត រហូតដល់ថ្ងៃ ២១ កក្កដា ។ ប៉ុន្តែ នៅរាត្រីថ្ងៃ ទី ២១-២២ កក្កដានោះ លោក សម សារី បានធ្វើការតវ៉ា យ៉ាងតឹងតែង ដើម្បីផ្តល់ ទៅឲ្យ ឯករាជ្យខ្មែរ នូវចំណុចសំខាន់ៗ ថែមទៀត គឺ ឯករាជ្យ ដែលអន្តរជាតិទាំងមូលត្រូវទទួលស្គាល់ ។ មួយឆ្នាំក្រោយមក គឺនៅថ្ងៃ ១៤ កញ្ញា ឆ្នាំ ១៩៥៥ប្រទេសកម្ពុជា បានត្រូវអនុញ្ញាតឲ្យចូលទៅក្នុង អង្គការ សហប្រជាជាតិ ។ រីឯ នយោបាយអព្យាក្រឹតភាព របស់ព្រះមហាក្សត្រ ព្រះបាទ នរោត្តម សីហនុ ក៏បានត្រូវគេទទួលយល់ព្រមផងដែរ នៅពេលជាមួយគ្នានោះ ។ សូមបញ្ជាក់ថា សន្និសីទ ទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ បានកំណត់នូវកិច្ចព្រមព្រៀង សំខាន់ៗ មានជាអាទិ៍ ៖ បំពោះឥណ្ឌូចិន ការរៀបចំការបោះឆ្នោតសកា ការបែងចែកប្រទេសវៀតណាម ជារដ្ឋ ២ ដាច់ពីគ្នា ដោយ កម្រិត យកត្រង់ខ្សែស្របទី ១៧ ។ កងទ័ពវៀតមិញទាំងអស់ ដែលបានធ្វើប្រតិបត្តិការ នៅកម្ពុជា ត្រូវដកចេញ ពី ទឹកដីកម្ពុជា ទាំងអស់ ក្នុងថេរវេលា ៣ ខែ រី ឯ កងទ័ពវៀតមិញ ដែលធ្វើប្រតិបត្តិការ នៅវៀតណាមខាងត្បូង ត្រូវដាក់អាវុធ ហើយ ចូលរួមរស់ ក្នុងសង្គមជាជនស៊ីវិល ។ សូមកត់សំគាល់ថា កិច្ចព្រមព្រៀង ទីក្រុងហ្សឺណែវ ទោះបីពុំបានត្រូវសហរដ្ឋអាមេរិក ចុះហត្ថលេខាក្តី ក៏ជា ការដោះបញ្ហា ការប្រជែងកម្លាំង រវាង មហាអំណាច ខាងលិច និង មហាអំណាច ខាងកើត បានមួយរយៈពេលដែរ ព្រោះ តាមការពិតទៅ គឺគ្រាន់តែជា ការឈប់សម្រាកមួយពេល តែប៉ុណ្ណោះទេ។ ទោះជា យ៉ាងនេះក្តី គេសង្កេតឃើញថា បញ្ហាដកកងទ័ពបរទេស, បញ្ហា ឯករាជ្យ ឬ អព្យាក្រឹតភាព អាចត្រូវដោះស្រាយទៅបាន គឺទាល់តែមាន ការចរចា រវាង ប្រទេស មហាអំណាច ពោលគឺ ការយល់ព្រមពីអ្វីដែល នៅក្នុងរឿងបុរាណខ្មែរ គេតែងតែ ហៅថា ពពួកទេវៈ «ព្រះឥន្ទ្រ, ព្រះព្រហ្ម» ម្ខាង និង ម្ខាងទៀត ពពួក អសុរា គឺ ពពួកយក្សា ដូចជា ក្រុងរាពណ៍ ឬ ទសមុខ ជាដើម ។

# ដំណើរឆ្ពោះទៅរក ភាពរណប នឹង អាណានិគមនិយមថ្មី

## Dans l’orbite du nouveau colonialisme





# ជំពូក ៥

## ស្រុកខ្មែរធ្លាក់ទៅក្នុងអន្ទាក់ របស់លោកកុម្មុយនិស្ត

ក្រោយពេលបានឯករាជ្យ ពីបារាំង សហប្រតិបត្តិការ វប្បធម៌ និង បច្ចេកទេស រវាងប្រទេសទាំងពីរ នៅតែមានបន្តទៀតៗ ប៉ុន្តែ ចលនាខ្មែរកុម្មុយនិស្ត បន្តវាយប្រហារ ទៅលើឥទ្ធិពលបារាំង កាន់តែខ្លាំងថែមទៀតៗ នៅដើមដំបូង ពួកគេបានបំផុសចលនាជាតិនិយម បន្ទាប់មក រិះគន់ប្រព័ន្ធសេដ្ឋកិច្ចមូលធននិយម និង អំពើពុករលួយ ព្រមទាំងរបៀបរស់នៅបែបសក្តិភូមិ របស់ មន្ត្រីរាជការ ។ ទន្ទឹមនោះ សៀវភៅ ទស្សនាវដ្តី ព្រមទាំងខ្សែភាពយន្ត មកពី ប្រទេសកុម្មុយនិស្ត បានត្រូវផ្សព្វផ្សាយ នៅក្នុងរាជធានីៗ និស្សិត និង បញ្ញវន្តដែលចេញមកពី ស្រទាប់សង្គមអ្នកក្រីក្រ ធ្វើការឃោសនា គំនិតឆ្វេងនិយម តាមលទ្ធភាព ដែលគេអាចធ្វើទៅបានៗ រីឯមូលបទ គឺ យុត្តិធម៌សង្គម និង ការវិលទៅរកវប្បធម៌ជាតិវិញ ដោយរិះគន់ ការសិក្សាវប្បធម៌បារាំងតាមរយៈអ្នកនិពន្ធបវេណីបារាំងធំៗ (les grands auteurs classiques français) យ៉ាងចាស់ដៃ ហើយឲ្យរៀនត្រឹម របៀបរស់នៅ ប្រចាំថ្ងៃ របស់ បារាំង តាមរយៈ សៀវភៅ Mauger ប៉ុណ្ណោះៗ នៅវិទ្យាល័យ សិស្សដែលបានត្រូវគេអប់រំឲ្យស្អប់ខ្ពើមបារាំង បាននាំគ្នារកលេសគ្រប់បែបយ៉ាង ដើម្បីចាប់ទោសកំហុស ពួកសាស្ត្រាចារ្យបារាំង ទោះបីអ្នកទាំងនោះ ជាអ្នកឆ្វេងនិយមក្តីៗ អ្នកសិក្សាភាសាបារាំង ដែលធ្លាប់បានដឹងពី បដិវត្តន៍បារាំងនាសតវត្សរ៍ ទី ១៨ ក៏យល់ថា ការរិះគន់ របស់ពួកខ្មែរក្រហម មិនខុសដែរៗ តាម ការ

ពិត នៅពីក្រោយ សកម្មភាពទាំងនោះ គឺ មាន ការបង្កើត ចលនានយោបាយមួយដ៏ធំៗ ចលនា «ខេមរយានកម្ម» និងការលុបផ្នែករៀនខាងទស្សនវិជ្ជានៅថ្នាក់បញ្ចប់វិទ្យាល័យ ក៏ចាប់ផ្ដើមនៅពេលនោះដែរ។ កម្រិតពិចារណារកហេតុផល តាមបែបបទសកល តាមរបៀប របស់បស្ចិមប្រទេសក៏ចាប់ផ្ដើមចុះថយបន្តិចម្ដងៗ។ ខាងវិស័យសេដ្ឋកិច្ច របៀបរស់នៅ សេរីនិយម (comportement libéral) ដែលផ្អែកទៅលើសមត្ថភាពបុគ្គល បាន ត្រូវជំនួសដោយរបៀបរស់នៅ តាម បែបបទសង្គមនិយម គឺ បេះជួយយកអាសាគ្នា ទៅវិញទៅមក ។ នៅទីបំផុត ការមានទំនុកទុកចិត្តទៅលើការខំប្រឹងប្រែង ដោយខ្លួនឯង និង ការផ្ដួចផ្ដើគំនិតផ្សេងៗ (initiatives) បានត្រូវគេចាត់ទុកថាជា គំនិតបុគ្គលនិយម ឬអាត្មានិយម។ ផុតពីការអប់រំដែលបារាំងបានទុកឲ្យ គេឃើញមានតែការបង្កើតក្រុមបក្សពួកប៉ុណ្ណោះ។ ចាស់ៗ ខ្លះដែលដឹងរឿងនេះ ក៏ រកគ្រូបង្រៀនកូនបន្ថែម ពី ការសិក្សានៅសាលា ឬក៏ទូន្មានកូនឲ្យខំតស៊ូដោយខ្លួនឯង គឺរៀនឲ្យបានច្រើនបំផុត ដើម្បីខ្លួនឯង និង ដើម្បីអាចផ្ដល់វិភាគទានឲ្យបានត្រឹមត្រូវ ដល់សង្គមជាតិ នៅពេលអនាគត។ គឺនៅពេលនោះដែរ ដែលសម្ដេច នរោត្តម សីហនុ ប្រមុខរដ្ឋ នៃ ប្រទេសកម្ពុជា រឹតចំណងមេត្រីភាព យ៉ាងខ្លាំង ជាមួយ បណ្ដា ប្រទេសសង្គមនិយម ជាពិសេស ជាមួយប្រទេសចិនប្រជាមានិត្ត ហើយប្រើប្រាស់បញ្ញជនឆ្វេងនិយមដែលបានធ្វើការសិក្សានៅស្រុកបារាំង។ អ្នកអភិរក្ស និង អ្នកស្ដាំនិយមអភិរក្ស បានចុះឥទ្ធិលយ៉ាងខ្លាំងព្រោះតែនយោបាយប្រជាភិថុតនេះ របស់អ្នកឆ្វេងនិយម។ រីឯអ្នកស្រឡាញ់សេរីភាព ក៏ត្រូវគេចាត់ទុកថាជា អ្នកមិនចុះចំណោម នឹងគេឯងទៀតផង។ ពេលនោះ អ្នកដឹកនាំឆ្វេងនិយម យល់ថា ប្រទេសចិន កាលសម័យ ម៉ៅនិយមនោះ មានអនាគតល្អ ជាងបស្ចិមប្រទេស។ ការពិត បន្ទាប់ពីប្រទេសចិន កុម្មុយនិស្ដបានសម្រេចបែរទៅរកលទ្ធិមូលធននិយមវិញសិន ហើយបន្ទាប់ពីសេដ្ឋកិច្ច សហភាព សូវៀតដួលរលំ ទើបគេបានយល់ថា អ្វីៗសុទ្ធតែប្រជាភិថុតទាំងអស់។ បដិវត្តន៍ សង្គមនិយម ជា ឧត្តមគតិ ប៉ុន្តែ ការពិត គឺ ជា ឧត្តមគតិ ដែលមិនអាចឈានដល់ឡើយ ដរាបណា មនុស្សពុំទាន់មានឧត្តមគតិ





នេះគ្រប់ៗគ្នានោះទេ ជាពិសេស អ្នកដឹកនាំកុម្មុយនិស្ដនេះតែម្ដង ដែលយល់ដោយក័ន្តប្រឡំថា ការបំបិទសិទ្ធិសេរីភាពបុគ្គល អាចធ្វើឲ្យមានការរីកចម្រើនផ្នែកសង្គមបាន។ គេអាចនិយាយបានថា សេរីភាព ជាអុកស៊ីហ្សែន នៃការរីកចម្រើន ហើយជា ថាមពលដ៏ខ្លាំងក្លា ប៉ុន្តែបើប្រើថាមពលនេះមិនត្រូវ គឺ ការបណ្ដោយតាមកម្លាំង របស់វាដោយគ្មានការត្រួតពិនិត្យ (dérapage non contrôlé) ក៏អាចមានការអន្តរាយដែរ។ រីឯអំណាចផ្ដាច់ការ ការបំបិទសិទ្ធិ នៃ ការគិត និង ការបញ្ចេញគំនិត គឺប្រៀបបានទៅ នឹង ការខ្ទប់ដង្ហើមបញ្ញា។ បញ្ញា ជា ចលករ សំខាន់បំផុត នៃ អរិយធម៌ របស់ មនុស្សជាតិ។

## នយោបាយ នៅក្នុង ប្រទេសកម្ពុជា ក្រោយ កិច្ចព្រមព្រៀង ទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤

## Situation politique interne après les Accords De Genève de 1954

៨ ថ្ងៃក្រោយការចុះហត្ថលេខាទៅលើកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ព្រះមហាក្សត្រខ្មែរព្រះបាទនរោត្តម សីហនុ បានតែងតាំង រដ្ឋាភិបាលមួយថ្មីទៀតដឹកនាំដោយ លោក ប៉ែន នុត ដដែល ប៉ុន្តែដែល សមាជិកមួយចំនួន នៃ រដ្ឋាភិបាលមុន បានត្រូវដកចេញ។ នៅក្នុងរដ្ឋាភិបាល នាថ្ងៃ ១ សីហាឆ្នាំ ១៩៥៤ នោះ គេពុំឃើញមាន ឈ្មោះ លោក ញឹក ជូឡុងទេ។ ភារកិច្ចខាងការពារប្រទេសដែលនៅក្នុងរដ្ឋាភិបាល លោក ប៉ែន នុត មុន បានត្រូវប្រគល់ទៅឲ្យលោក ញឹក ជូឡុង និងលោក ឃឹម ទិត បានធ្លាក់ទៅក្នុងការទទួលខុសត្រូវរបស់ លោក ង៉ោ ហ៊ូ ដែលនៅពេលជាមួយគ្នានោះ ក៏ជារដ្ឋមន្ត្រីទទួលបន្ទុក ខាងសុខាភិបាលផងដែរ ។ រីឯអ្នកអង្គម្ចាស់ នរោត្តម ម៉ុងតាណាដែលមានតួនាទីជា រដ្ឋមន្ត្រីសុខាភិបាល និង សង្គមកិច្ច និង អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ

ឥស្សរ៉ូ ដែលនៅក្នុងរដ្ឋាភិបាលលោក ប៉ែន នុត នាថ្ងៃ ៨ មេសា ជា រដ្ឋមន្ត្រីអប់រំជាតិ និង ឃោសនាការ ក៏បានត្រូវដកចេញដែរ ។ រីឯ លោក សម សារី ក៏ ពុំឃើញ មាន ឈ្មោះនៅក្នុងរដ្ឋាភិបាល នាថ្ងៃ ១ សីហា ឆ្នាំ ១៩៥៤នោះដែរ។ អ្នកដែលដើរតួសំខាន់ៗ នៅក្នុងរដ្ឋាភិបាលនោះមានជាអាទិ៍ : លោក ទេព ផន ដែល ត្រូវទទួលបន្ទុក ខាងមហាផ្ទៃផង ខាងការបរទេសផង ខាងសន្តិសីទផង។ អ្នកអង្គម្ចាស់នរោត្តម វិរិយ៉ា ទទួលនាទីជារដ្ឋលេខាធិការ ការពារជាតិ និង ការពារ ផ្ទៃប្រទេសដដែល ។ លោក យ៉ែម សំបូ ទទួលបន្ទុកខាង ថវិកា ពាណិជ្ជកម្ម លោក ប៉ុក ឌួន យុត្តិធម៌ លោក ស៊ឹម វ៉ា សាធារណការ គមនាគមន៍ និង កសិកម្ម លោក ផូ ព្រឿង អប់រំជាតិ និង វិចិត្រសិល្បៈ លោក អ៊ូ ឈឺន ទទួលបន្ទុកខាងសេដ្ឋកិច្ច បន្តមកទៀត។ នៅក្នុងរដ្ឋាភិបាលនេះ ក្រៅពីអ្នកអង្គម្ចាស់ នរោត្តម វិរិយ៉ា គេសង្កេត ឃើញមានរដ្ឋលេខាធិការ ៥ទៀត គឺ លោក ប៉ាល់ ឌួន លោក អេង ហ៊ុន, លោក ទេព យុត និង លោក យូ ឈើន ។ នៅក្នុងរយៈពេល ៥ ខែចុងឆ្នាំ ១៩៥៤ នោះ មានព្រឹត្តិការណ៍ ៦ ដែលគួរឲ្យកត់សំគាល់ ។ នៅថ្ងៃ ១២ សីហា គណកម្មាធិការចម្រុះ ត្រួតពិនិត្យព្រំប្រទល់ បានមកតាំងទី នៅខេត្តស្វាយរៀង ។ ១៥ ថ្ងៃក្រោយមក គឺ នៅ ថ្ងៃ ទី ២៧ ខែ សីហា ទីក្រុង វ៉ាស៊ីងតោន (Washington) បានបញ្ជូនអ្នកជំនាញការ ខាងយោធា, ខាង ហិរញ្ញវត្ថុ-សេដ្ឋកិច្ច និង ខាងវប្បធម៌ ជាច្រើនរូប មកទីក្រុងភ្នំពេញ ដើម្បីមកជួយ រៀបចំ ប្រទេសខ្មែរ ជំនួសបារាំង។ សហរដ្ឋ អាមេរិក នៅពេលនោះ មាន ការព្រួយបារម្ភយ៉ាងខ្លាំង ខ្លាចក្រែងប្រទេសកម្ពុជា ធ្លាក់ទៅក្នុងកណ្ដាប់ដៃ ប្លុកកុម្មុយនិស្ត (Bloc communiste) ។ បីខែក្រោយការចុះហត្ថលេខា ទៅលើកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ បក្សប្រជាជនបដិវត្តខ្មែរ ដែលគេហៅថា P.P. R.K. គឺចលនាខ្មែរឥស្សរៈដែលមួយផ្នែកបានទទួលការហ្វឹកហ្វឺនពីអង្គការវៀតមិញ បានបែកចេញជា បីក្រុម។ ក្រុមទី ១ ដែលមាន សឺង ង៉ុក មិញ, កែវ មុន្នី, ម៉ី ផូ, រតន៍ សាមឿន និង ប៉ែន សុវណ្ណ ព្រមទាំងយុទ្ធជន ចំនួន ពីរពាន់ប្រាំរយនាក់ផងដែរ បានត្រូវបញ្ជូនទៅទីក្រុងហាណូយ ប្រទេសវៀតណាម ក្រោម ការ





ត្រួតពិនិត្យ របស់ គណកម្មាធិការត្រួតពិនិត្យអន្តរជាតិ។ ក្រុម ទី ២ ដែលមានជាអាទិ៍ : ទូ សាមុត, សៀវ ហេង, នួន ជា, សោ ភឹម, ណី សារ៉ន ជាដើម បាននាំគ្នាគេចខ្លួនទៅបង្កើត ចលនា លួចលាក់មួយទៀត នៅលើ ទឹកដីកម្ពុជា ។ គឺអ្នកទាំងនោះហើយ ដែលជាស្នូលមុនដំបូងបង្អស់ នៃ ចលនាខ្មែរក្រហម។ ក្រុម ទី ៣ ដែលមាន នង សួន, កែវ មាស និង ប៉ែន យុទ្ធ ជាដើម បាននាំគ្នាបង្កើត គណបក្សនយោបាយ ត្រឹមត្រូវតាមច្បាប់មួយ ដែលមានឈ្មោះថា «គណបក្សប្រជាជន» ហើយ ដែលត្រៀមលក្ខណៈ ចូលរួម ក្នុងការបោះឆ្នោតសភា នៅពេលខាងមុខ គឺ ការបោះឆ្នោតសភា ដែលបានត្រូវកំណត់ ដោយ កិច្ចព្រមព្រៀង ទីក្រុងហ្សឺណែវ ហើយ ដែលទាល់តែមកដល់ខែ កញ្ញា ឆ្នាំ ១៩៥៥ ទើបបានត្រូវរៀបចំ។ សូមបញ្ជាក់ថា នៅក្នុងពេលដដែលនោះ ចលនា លួចលាក់ ដែលដឹកនាំដោយ ទូ សាមុត, សៀវ ហេង, នួន ជា, សោ ភឹម និង ណី សារ៉ន បានបង្កើតគណកម្មាធិការ ចំនួន ១៨ គឺ ១៧ នៅ តាមខេត្តនានា ហើយ គណកម្មាធិការ មជ្ឈិម បណ្ដោះអាសន្នមួយ ដឹកនាំដោយ សៀវ ហេង ។ គណកម្មាធិការ ទាំង ១៧ ដែលបង្កប់ខ្លួននៅតាមខេត្ត-តំបន់ នានា ហើយ ដែលគេហៅថា «គណកម្មាធិការជនបទ» ស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ ទូ សាមុត។ អ្នកដែលធ្វើប្រតិបត្តិការ នយោបាយលួចលាក់ ទាំងនោះ ដែលនៅរក្សា ឈ្មោះ «បក្សប្រជាជនបដិវត្តកម្ពុជា» ដដែល ក៏ មាន ទំនាក់ទំនងជិតស្និទ្ធ នឹង «គណបក្សប្រជាជន» ដែរ ។ នៅ ឆ្នាំ ១៩៥៤ ដដែលនោះ នៅថ្ងៃ ៣១ តុលា លោក នេហរុ រដ្ឋមន្ត្រី ទី ១ ប្រទេសឥណ្ឌាបានអញ្ជើញមកធ្វើ ទស្សនកិច្ច នៅកម្ពុជា ដើម្បី លើកទឹកចិត្ត ឲ្យព្រះមហាក្សត្រខ្មែរ ជ្រើសរើសយក ខ្សែបន្ទាត់ អព្យាក្រឹតភាពហើយ មិនចូលបក្សសម្ព័ន្ធណាទាំងអស់ គឺខ្សែបន្ទាត់នយោបាយ ដែលបស្ចិមប្រទេសគ្មានជំនឿទាល់តែសោះថា អាចមាន ជំហររឹងប៉ឹងទៅកើត នៅចំពោះមុខ ឥទ្ធិពល ដ៏ខ្លាំងក្លារបស់ ប្លុកកុម្មុយនិស្ត (Bloc communiste) នៅពេលនោះ។ ទោះជាយ៉ាងនេះក្ដី ក៏ ប្រទេសកម្ពុជា គ្មានជម្រើសអ្វី ក្រៅពីនយោបាយ អព្យាក្រឹតភាពនេះដែរ ។ ប៉ុន្តែ ប្រការគួរឲ្យសោកស្ដាយ គឺ ថា នៅពេល

នោះ ចលនាកុម្មុយនិស្ត មានកម្លាំង ឥទ្ធិពលដ៏ខ្លាំង នៅក្នុងតំបន់ ជាហេតុធ្វើឲ្យប្រទេសកម្ពុជា ធ្លាក់ទៅក្នុងរណ្តៅដ៏ សែនជ្រៅ នៃការទូត របស់ ប្រទេសកុម្មុយនិស្ត ទាំងស្រុង ។ ទោះបីបស្ចិមប្រទេស ខិតខំខ្នះខ្នែង ជួយស្តារយ៉ាងណាក្តី ក៏ជា ការឥតប្រយោជន៍។ ម្យ៉ាងទៀត នៅក្នុងសង្គ្រាម រវាងប្រទេសវៀតណាមកុម្មុយនិស្ត និង សហរដ្ឋ អាមេរិក នៅឥណ្ឌូចិន សហរដ្ឋ អាមេរិក ក៏ត្រូវទទួលបរាជ័យ ជាបន្តបន្ទាប់ដែរ នៅពេលក្រោយមកទៀត ។

## ព្រឹត្តិការណ៍ សំខាន់ៗ នៅ ឆ្នាំ ១៩៥៥

មុននឹងឈាន ទៅដល់ព្រឹត្តិការណ៍សំខាន់ៗ នៃ ឆ្នាំ ១៩៥៥ ខ្ញុំសូមរំឭកឡើងវិញថាមេខ្មែរឥស្សរៈជាច្រើនបានចុះចូលរាជរដ្ឋាភិបាល សឹងតែទាំងអស់ រួមបញ្ចូលទាំងលោក សឺន ង៉ុក ថាញ់ ដែលព្រះមហាក្សត្របានដោះលែង ឲ្យត្រឡប់ពីស្រុកបារាំង មកវិញនៅខែតុលា ឆ្នាំ ១៩៥១ ប៉ុន្តែ ដែលបានរត់ចូលព្រៃនៅថ្ងៃ ៩ ខែមិនាឆ្នាំ ១៩៥២ ក្នុងគោលដៅ ដឹកនាំ ចលនាឥស្សរៈ នៅភ្នំដងរែកជាមួយ លោក អៀវ ស៊ីចូវ, កក្កុ ខៀវ ជុំ, លោក យូ ហៀង, លោក ហង្ស ធុន ហាក់, លោក អ៊ីវ យ៉ាង លោក ប៉េង គិត លោក ឃី តាំង លឹម, លោក ឌួង ចាន់ សាភាត និង លោក លាវទានស៊ឺ។ នៅពេលសុំចុះចូលរាជរដ្ឋាភិបាល លោក សឺន ង៉ុក ថាញ់ បានសុំចូល គាល់ព្រះមហាក្សត្រ ប៉ុន្តែនៅថ្ងៃ ២ វិច្ឆិកា ព្រះមហាក្សត្រ បានទាត់ចោល សេចក្តីស្នើសុំនេះ ។ ព្រឹត្តិការណ៍មួយទៀត នៅចុងឆ្នាំ ១៩៥៤ នោះ គឺ ការបង្កើត ធនាគារ កណ្តាលខ្មែរមួយដែលមានឈ្មោះថា *ធនាគារជាតិ កម្ពុជា* ។ សូមកត់សំគាល់ថា ការប្រែប្រួលសំខាន់ៗ ក្រោមការដឹកនាំដោយផ្ទាល់ របស់ព្រះបាទ នរោត្តម សីហនុ ចាប់ផ្តើមពីឆ្នាំ ១៩៥៥។ នៅដើមឆ្នាំ ១៩៥៥ នោះ លោក ជួន ម៉ុម្ន, លោក កេង វ៉ាន់ សាក់ និង





លោក អៀវ ស៊ីចូវ បានក្លាយទៅជាអ្នកដឹកនាំសំខាន់ នៃ គណបក្សប្រជា ធិបតេយ្យ។ មុនការវិវត្តន៍មកដល់ដំណាក់ការនេះ មានព្រឹត្តិការណ៍មួយចំនួនទៀត គួរឲ្យកត់សំគាល់ផងដែរ។ នៅពេលដែល ព្រះមហាក្សត្រខ្មែរព្រះបាទនរោត្តម សីហនុ ទ្រង់យាងត្រឡប់មក ពីបរទេសវិញ រដ្ឋាភិបាល ដែលដឹកនាំ ដោយលោក ប៉ែន នុត នៅពេលនោះបានបែកចេញជា ២ ក្រុមបដិបក្ខ នឹង គ្នា គឺក្រុមមួយរបស់ លោក ប៉ែន នុត ហើយក្រុមមួយទៀត ជាក្រុម របស់ លោក ចាន់ ណាក់ ដែលមាន ចរិតឯករាជ គ្មាន បក្សពួក ប៉ុន្តែ ដែលស្មោះ នឹង ព្រះមហាក្សត្រ។ នៅថ្ងៃ ១៤ វិច្ឆិកា ឆ្នាំ នោះ លោក ប៉ែន នុត ត្រូវបង្ខំចិត្ត លាលែងពីមុខតំណែង ហើយនៅថ្ងៃ ១៦ វិច្ឆិកា ព្រះមហាក្សត្របានតែងតាំង រដ្ឋាភិបាលថ្មីមួយទៀត ដឹកនាំដោយ លោក ចាន់ ណាក់ ហើយដែលមានលោក សឺន សាន ជាអនុប្រធាន។ ប៉ុន្តែ ២ ថ្ងៃ ក្រោយមក រដ្ឋាភិបាលនេះ ហាក់បី ដូចជាហៀប តែរលាយទៅវិញ ព្រោះលោក សឺន សាន បានសុំលាលែង ពី មុខតំណែងឧបនាយករដ្ឋមន្ត្រី។ ប៉ុន្តែសម្រេចសម្រួលទៅ រដ្ឋាភិបាល លោក ចាន់ ណាក់ រក្សាខ្លួនបានវិញដដែល រីឯ អ្នកតំណាង គណបក្សប្រជាធិបតេយ្យ មួយចំនួន ក៏ មានមុខជាសមាជិករដ្ឋាភិបាល នោះដែរ ។ ប៉ុន្តែ បញ្ហាដែលចោទ ឡើងនៅពេលនោះ គឺ ទំនាស់រវាង អ្នកប្រជាធិបតេយ្យឆ្វេងនិយម ជឿនលឿននិយម និង អ្នកប្រជាធិបតេយ្យ សេរីនិយម ជាពិសេសទំនាស់រវាង លោក ហាក់ ម៉ុង សេង ឆ្វេងនិយម និង លោក យ៉ែម សំបូ ស្តាំនិយម ។

ដោយរដ្ឋាភិបាលរួបរួមបក្ស របស់លោក ចាន់ ណាក់ មានវិបត្តិ ព្រោះតែអ្នកប្រជាធិបតេយ្យ មិនយល់ព្រម ពី វត្តមាន របស់លោក ឃឹម ទិត នៅក្នុង រដ្ឋាភិបាលៗ នោះក៏ត្រូវរលាយទៅវិញ។ នៅដើមឆ្នាំ ១៩៥៥ គឺនៅ ថ្ងៃ ២៥ មករា ព្រះមហាក្សត្រ បានតែងតាំងរដ្ឋាភិបាលមួយទៀត ដឹកនាំដោយលោក ឡេង ង៉ែត។ ភាគច្រើន នៃសមាជិក រដ្ឋាភិបាលនេះ សុទ្ធតែជាអ្នកដែលត្រូវគេចាត់ទុក នៅពេលនោះ ថាជាអ្នកស្មោះត្រង់ នឹង ព្រះរាជា ដូចជាលោក ផូ ព្រឿង, លោក ប្រាក់ ប្រា ព្រឿង,

អ្នកអង្គម្ចាស់ សិរិមតៈ, លោក នាល ផេង, លោក ជួប សំឡូត លោក ម៉ៅ ចយ, លោក យ៉ែម សំបូ, អ្នកអង្គម្ចាស់ ម៉ុងតាណា, លោក អ៊ុំ ឈឿង ស៊ុន, លោក ម៉ី ណោសី ជាដើម ។ គឺនៅក្នុងសម័យរដ្ឋាភិបាល លោក ឡេង ង៉ែត នេះ ហើយ ដែល ព្រះមហាក្សត្រខ្មែរ ព្រះបាទ នរោត្តម សីហនុ បានរៀបចំប្រជាមតិមួយ ដើម្បីសាកសួរ ប្រជារាស្ត្រខ្មែរថា តើព្រះរាជបេសកកម្ម ទាមទារឯករាជ្យរបស់ ព្រះអង្គ មានការពេញ ចិត្ត ពីសំណាក់ ប្រជានុរាស្ត្រឬទេ ? យោងទៅតាម ប្រជាមតិនៅថ្ងៃ ៧ កុម្ភៈនោះ ប្រជាជនខ្មែរចំនួន ៩៩,៨០ % បានសំដែងការពេញចិត្ត របស់ គេ ។ ប៉ុន្តែនៅក្នុងរយៈ ពេល ៦ ខែដើមឆ្នាំ ១៩៥៥ នោះ គឺ មុនការបោះឆ្នោតសភា នាថ្ងៃ ទី ១១ កញ្ញា មាន ព្រឹត្តិការណ៍ មួយចំនួន ដែលបានរុញច្រាន ឲ្យមាន ការប្រែប្រួល ជាមូលដ្ឋាន នៅក្នុង ស្ថាប័ន នយោបាយខ្មែរ ។ នៅ ថ្ងៃ ១៩ កុម្ភៈ គឺ ២ សប្តាហ៍ ក្រោយការបោះឆ្នោត ប្រជាមតិ ព្រះមហាក្សត្រខ្មែរ ព្រះបាទនរោត្តមសីហនុ បានរៀបចំធ្វើការកែទម្រង់ស្ថាប័ន ដឹកនាំសំខាន់ៗ នៅក្នុងប្រទេស ។ ប៉ុន្តែ ផែនការកែទម្រង់ នោះ ពុំបានទទួលការយល់ ព្រម ពីគណបក្ស ប្រជាធិបតេយ្យទេ ។ ដោយការកែទម្រង់ ជាប្រវត្តិសាស្ត្រនោះ មាន សារៈសំខាន់ យើងនឹងលើកអំពីសំណុំរឿងនេះ នៅទំព័រក្រោយ ។ គឺនៅពេលនោះ ដែរ ដែល ចលនា ខ្មែរសេរី ចេញរូបរាងឡើងនៅព្រំប្រទល់ថៃ គឺ ចលនាដែលមាន សហរដ្ឋ អាមេរិក គាំទ្រ ហើយដែលមាន លោក សឺន ង៉ុក ថាញ់ ជាអ្នកដឹកនាំ។ ចលនាខ្មែរសេរី នៅពេលនោះ មានកងទ័ព ប្រមាណ ២ ពាន់ នាក់ ។ នៅ ថ្ងៃ ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៥៥ ដដែល នោះ លោក ហ្វូស្ទែរ ឌុលឡេស (Foster Dullès) រដ្ឋមន្ត្រី ការបរទេស អាមេរិក បានមក ធ្វើទស្សនកិច្ចនៅកម្ពុជា ដើម្បីបញ្ចុះបញ្ចូលឲ្យ ព្រះមហា ក្សត្រខ្មែរ ព្រះបាទនរោត្តម សីហនុ ចូលទៅក្នុងអង្គការ អូតាស្ហ៍ (O.T.A.S.E.) គឺ បក្សសម្ព័ន អាមេរិក ប្រឆាំងនឹង កុម្មុយនិស្តនៅអាស៊ី ។ ប៉ុន្តែព្រះបាទនរោត្តម សីហនុ បានប្រកែកដាច់អហង្ការ។ ពីរ-បី ថ្ងៃ ក្រោយមក ព្រឹត្តិការណ៍មួយ ដែលបានធ្វើឲ្យមាន ការភ្ញាក់ផ្អើល យ៉ាង ខ្លាំង បានស្តែងចេញឡើង។ ព្រះបាទ នរោត្តម សីហនុ ព្រះមហា





ក្សត្រ នៃ ប្រទេស កម្ពុជា បានសម្រេចចុះចេញពីរាជបល្ល័ង្គ ហើយ ប្រគល់រាជសម្បត្តិ ថ្វាយទៅព្រះបិតា និងព្រះមាតា របស់ព្រះអង្គ។ តាំងពីពេលនោះមក ព្រះបាទ នរោត្តម សុរាម្រិត និង ព្រះមហាក្សត្រីយានី កុសមៈបានទទួលតួនាទី ជាព្រះមហាក្សត្រ នៃ ប្រទេសកម្ពុជា ។ រី ឯព្រះបាទ នរោត្តម សីហនុវិញ ព្រះអង្គ រៀបចំធ្វើការប្រយុទ្ធ នយោបាយ ជាមួយគណបក្សនយោបាយ នានាឯទៀត នៅពេលបោះឆ្នោតសភា នៅ ពេលខាងមុខ ។ នៅ ថ្ងៃ ២៣ ខែ មិនា ឆ្នាំ ១៩៥៥ ព្រះអង្គ បានបង្កើត ចលនា នយោបាយ មួយ មានឈ្មោះថា «សង្គមរាស្ត្រនិយម» ។

# គម្រោងការ កែទម្រង់ រដ្ឋធម្មនុញ្ញខ្មែរ

## Le Projet de Réforme de la Constitution

ចាប់តាំងពីខែកុម្ភៈឆ្នាំ ១៩៥៥ ព្រះមហាក្សត្រខ្មែរ ព្រះបាទ នរោត្តម សីហនុ ខិតខំ ពង្រឹងអំណាច របស់ព្រះអង្គ ដោយកាត់បន្ថយជាបឋម នូវតួនាទី និងឥទ្ធិពល របស់ រដ្ឋសភា ។ គឺចាប់តាំងពីពេលនោះ មកហើយ ដែល រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ បានត្រូវរៀបចំកែប្រែ។ ក្រោយការបោះឆ្នោតប្រជាមតិ នាថ្ងៃ ៧ កុម្ភៈបន្តិច ប្រជា ជនខ្មែរ នៅតាមភូមិ-ឃុំនានា បានចាត់តាំង គណប្រតិភូរបស់គេ ឲ្យធ្វើដំណើរ មក ទីក្រុងភ្នំពេញដើម្បីស្នើសុំ ឲ្យព្រះរាជា ដឹកនាំប្រទេស ដោយផ្ទាល់ព្រះអង្គ តែម្តង។ ព្រះបាទនរោត្តម សីហនុ ទ្រង់ប្រកែកនឹងសេចក្តីស្នើសុំនេះ ប៉ុន្តែព្រះអង្គ បាន សន្យាថា នឹង រៀបចំតាក់តែង រដ្ឋធម្មនុញ្ញមួយទៀត ព្រោះព្រះអង្គឈ្វេងយល់ថា របៀបរបប នៃ ប្រព័ន្ធលទ្ធិប្រជាធិបតេយ្យ តាមបែបបស្ចិមប្រទេស ពុំស្របទៅនឹង សង្គមខ្មែរទេ។ នៅថ្ងៃ ១៩ កុម្ភៈ ឆ្នាំដដែលនោះ ព្រះមហាក្សត្រ ទ្រង់បានអញ្ជើញ អង្គទូត គណ កម្មាធិ ការត្រួតពិនិត្យអន្តរជាតិ តែងតាំងដោយកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ សមាជិក

វដ្ឋាភិបាល និង ទីប្រឹក្សារាជបល្ល័ង្កទាំងអស់ ឲ្យមកចូលរួមប្រជុំ ។ អស់រយៈពេល ៣ ម៉ោង ព្រះមហាក្សត្រខ្មែរ ព្រះបាទ នរោត្តម សីហនុ ទ្រង់បានឧទ្ទេស គម្រោងការ ជាប្រវត្តិសាស្ត្រមួយ ស្តីពី ការកែទម្រង់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ ។ ព្រះអង្គទ្រង់មានព្រះរាជបន្ទូលជាអាទិ៍ថា : ព្រះអង្គ នឹងប្រែក្លាយរបប នយោបាយ ដែលមាន បក្សនយោបាយប្រកួតប្រជែងគ្នាកាន់អំណាច ឲ្យទៅជាលទ្ធិប្រជាធិបតេយ្យ មួយបែប ដែលប្រជាជនខ្មែរ អាចយល់បានយ៉ាងស្រួល។ ចំពោះ គម្រោងការ នៃ ការកែទម្រង់នេះ មតិខ្លះយល់ថា គឺ ជាការកាន់អំណាចផ្តាច់ការតែម្តង ព្រោះថា បើ គ្មាន គណបក្សនយោបាយសម្រាប់តំណាងផលប្រយោជន៍ និន្នាការ និង ទស្សនៈផ្សេងៗ របស់ប្រជាជន និងមជ្ឈដ្ឋាននានា នៃ សង្គមទេនោះ គឺគ្មានអ្វីក្រៅពី របប ប្រជានិយមទេ (populisme) ។ តាមធម្មតា ប្រជាជនអាចសំដែងឆន្ទៈ របស់គេ តែតាមគោលការណ៍ នៃ ប្រព័ន្ធទស្សនវិជ្ជា និងកម្មវិធីនយោបាយផ្សេងៗ តែប៉ុណ្ណោះ បើពុំនោះសោតទេ គឺជា ការប្របូកប្របល់ មួយ ដ៏ធំ ។ ប៉ុន្តែ ចំពោះរឿង នេះ ព្រះមហាក្សត្រខ្មែរ ព្រមទាំង លោក សម សារី និង លោក យ៉ែម សំបូ បាន រៀបចំកម្មវិធីមួយជាស្រេច ដើម្បីផ្តល់ទៅឲ្យប្រទេសកម្ពុជា នូវ មូលដ្ឋាន នយោបាយ និង ស្ថាប័នផ្សេងៗ សម្រាប់ដឹកនាំប្រទេសតាមរយៈ ចលនាមួយ ដែលមានឈ្មោះ ថា «សង្គមរាស្ត្រនិយម» ។

តាមការពិតទៅ គោលគំនិត ជាមូលដ្ឋាន មាន លក្ខណៈ វិសេសវិសាល ល្អណាស់ ព្រោះថា ជា ការសាកល្បង ទប់ទល់ នឹង អ្នកនយោបាយ ដែលតែងតែឆ្មៀតយកស្ថាប័នប្រជាធិបតេយ្យ ទៅបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ហើយធ្វើទុក្ខបុកម្នេញដល់ប្រជាជន ដោយសំអាងទៅលើគោលការណ៍ផ្សេងៗ ដែលផ្ទុយស្រឡះ ពីរបៀបរស់នៅរបស់ខ្មែរ។ ប៉ុន្តែបើគេទាត់ចោលនូវកត្តាសំខាន់ៗ ជាសត្យានុម័ត ដែលកំណត់ការអភិវឌ្ឍន៍នោះ សង្គមទាំងមូល ក៏បាត់ថាមពល របស់វា ដែរ ។ រីឯកត្តាជាសត្យានុម័ត នោះ គឺផលប្រយោជន៍ របស់ មជ្ឈដ្ឋានផ្សេងៗទៀត ដែលជាសរសៃទ្រូងនៃសេដ្ឋកិច្ចជាតិ ។ ចំពោះមជ្ឈដ្ឋានទាំងនោះ រវាង យុត្តិធម៌សង្គម និង ការកេង





ប្រវ័ញ្ចកម្លាំង ពលកម្ម គេច្បាស់ជា ពុំព្រមយក យុត្តិធម៌ និង ស្មារតីសាមគ្គីភាពសង្គម ជាគោលការណ៍សំខាន់ឡើយ ។ ក្រឹត្យក្រម នៃការរីកចម្រើន ជាក្រឹត្យក្រមដែលច្រើនតែផ្ទុយ ពីឧត្តមគតិ ។ ប៉ុន្តែដោយយល់ច្បាស់ អំពី ក្រឹត្យក្រមនេះ គោលការណ៍ នៃ *សង្គមរាស្ត្រនិយម* ក៏ មិនមានលក្ខណៈ ដូចគោលការណ៍ កុម្មុយនិស្តពេកដែរ តែជា គោលការណ៍ សេរីនិយមថ្មីមួយ ដែលសាកល្បងប្រជែង នឹង ទ្រឹស្តីកុម្មុយនិស្តទៅវិញ។ តាមរយៈការកែទម្រង់ស្ថាប័ន នយោបាយ និង សេដ្ឋកិច្ច របស់ព្រះមហាក្សត្រ គេនឹងសង្កេតឃើញថា សង្គមខ្មែរ អាចផ្តល់ ស្ថិរភាពផ្ទៃក្នុងល្អ ប៉ុន្តែការរីកចម្រើនផ្នែកសេដ្ឋកិច្ច មានដំណើរយឺតក្រៃលែង បើប្រៀបធៀបទៅ នឹង សន្ទុះនៃប្រទេសនានាឯទៀត ដោយហេតុថា ការលូតលាស់ផ្នែកសេដ្ឋកិច្ច វា មិនសូវចុះសម្រុងប៉ុន្មាន នឹងឧត្តមគតិទស្សនវិជ្ជា និងមាគ៌ានយោបាយឡើយ ។ ប៉ុន្តែអ្វីដែលជាគុណូបការ នៃរបបនេះ គឺថា ប្រជាជនរក្សាបាន នូវ ភាពថ្លៃថ្នូរ របស់គេ នៅក្នុងកម្រិតមួយដែលគេអាចទ្រាំទទួលយកបាន។ នៅក្នុងសម័យនោះ ប្រាក់កាសមិនអាចយកទៅទិញ ឧត្តមគតិបានទាំងអស់ទេ។ គ្រូបង្រៀនមានប្រាក់ខែច្រើនជាង ចៅហ្វាយខេត្តទៅទៀត គឺ អាចរក្សាឧត្តមគតិ របស់ គេបាន បើប្រៀបធៀបទៅនឹង របបផ្សេងៗទៀត ដែលបញ្ញវន្ត ត្រូវឱបជើងអ្នកមាន អ្នកខ្លាំងទើបអាចរស់បាន។ នៅក្នុងសង្គមមួយដែល ជំហរឧត្តមគតិមានអត្ថិភាព អំពើអយុត្តិធម៌ អំពើហឹង្សា និង គំនិតប្រាកដនិយមជ្រុល ក៏ អន់ថយបន្តិចដែរ ។ អ្នកខ្សោយអាចរស់បាន ហើយ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ សម្រាប់ បង្កើនសមត្ថភាព របស់គេផងទៀត។ ទោះបីមានការលំបាកលំបិន យ៉ាងណាក្តី វិទ្យាល័យ និង អនុវិទ្យាល័យ កើតឡើងព្រោងព្រាតនៅតាមខេត្ត-ខណ្ឌ។ បណ្ណាគារមានលក់សៀវភៅ វប្បធម៌ខ្មែរ និងសៀវភៅ មកពីបរទេសគ្រប់ប្រភេទ ។ យ៉ាងណាមិញ ការខិតខំរៀនសូត្រ បានត្រូវលើកទឹកចិត្ត យ៉ាងខ្ពស់។ ប៉ុន្តែបើយោង ទៅតាមមតិខ្លះ បើ គណបក្សប្រជាធិបតេយ្យ បានគ្រប់គ្រងប្រទេស ការរីកចម្រើន ខាងផ្នែកសិក្សាធិការជាតិ ក៏ដូចជាការរីកចម្រើន ផ្នែកសេដ្ឋកិច្ច

អាចនឹងមានកម្រិតខ្ពស់ជាងនេះទៅទៀត ព្រោះកម្មវិធី នយោបាយរបស់ ចលនា សង្គមរាស្ត្រនិយម ក៏ពុំមានអ្វីខុសប្លែក ពីកម្មវិធី របស់ គណបក្សប្រជាធិបតេយ្យប៉ុន្មានដែរ។ យោងទៅតាមយោបល់ របស់ អ្នកខ្លះទៀត នេះជាភ័ព្វសំណាង ម្យ៉ាងរបស់ប្រជាជនខ្មែរដែរ។ ប៉ុន្តែ បើគ្មានការប្រណាំងប្រជែងរវាង គណបក្សនយោបាយទេនោះ អំណាចផ្ដាច់ការ អំពើព្រៃផ្សៃ និងការមើលងាយមើលថោក ប្រជានុរាស្ត្រ ក៏ពុំអាចឈានជាសន្សឹមៗ ទៅរកទីអវសានបានដែរ។ ជាអកុសល ប្រទេសកម្ពុជានៅពេលនោះ ស្ថិតនៅចំកណ្ដាលលានប្រយុទ្ធ រវាង ពិភពលោក ២ គឺ ពិភពកុម្មុយនិស្ត នឹង ពិភពលោកសេរី ផងទៀត ជាហេតុ ធ្វើឲ្យគណបក្សនយោបាយ ម្ខាងៗ ធ្លាក់ទៅក្នុងការក្ដោបក្ដាប់ របស់ ប្រទេសមហាអំណាច បដិបក្ខ ។ បទពិសោធន៍ នៃ ការអនុវត្តន៍មនោគមវិជ្ជាពីរ ផ្ទុយគ្នានៅពេលក្រោយមកទៀត បានបញ្ជាក់ថា នៅស្រុកខ្មែរ ក្រឹត្យក្រម នៃការរីកចម្រើនបានសង្កត់សង្កិនយ៉ាងធ្ងន់ធ្ងរ ទៅលើប្រជាជនខ្មែរ ដែលខិតខំ ថែរក្សាប្រពៃណី របស់ ខ្លួនដោយពិបាក ។ រីឯរបបមួយទៀត ដែលតាំងខ្លួន ជាអ្នករកយុត្តិធម៌ ឲ្យប្រជាកសិករ ក៏រលំបះជើង រកតែអាហារបរិភោគ សឹងមិនបាន ។ ខ្ញុំសូមវិលត្រឡប់មក សម័យ មុនការបោះឆ្នោត ខែ កញ្ញា ឆ្នាំ ១៩៥៥ វិញសិន មុននឹងនិយាយ អំពីសភាពការណ៍ នៅសម័យសង្គមរាស្ត្រនិយម បន្តទៅទៀត នៅពេលក្រោយ។ នៅពេលដែល ចលនា «សង្គមរាស្ត្រនិយម» បានចាប់បដិសន្ធិ ជនកុម្មុយនិស្តខ្មែរមានការប្រុងប្រយ័ត្នខ្ពស់ ព្រោះថា បើ ចលនា «សង្គមរាស្ត្រនិយម» ឈ្នះ គេអាច នឹង បាត់ឥទ្ធិពលរបស់គេ ដោយហេតុថា ព្រះមហាក្សត្រខ្មែរប្រហែលជា នឹងធ្វើអ្វីគ្រប់បែបយ៉ាង ដើម្បីកសាងសង្គមមួយថ្មី ដោយខិតខំ លុបបំបាត់ កាកសំណល់ នៃ របបអាណានិគមនិយម តាមបែបបស្ចិម ប្រទេសឲ្យបានច្រើនបំផុត ។ ដូចនេះ ជនកុម្មុយនិស្ត នៅស្រុកខ្មែរ នឹងគ្មានតួនាទី អ្វីទៀតឡើយ។ មួយវិញទៀត បើ ព្រះបាទនរោត្តម សីហនុ ពង្រឹង អំណាចបាន ដោយខ្លួនព្រះអង្គ នយោបាយ អព្យាក្រឹតភាព របស់ ព្រះអង្គ ក៏អាចនឹងផ្អៀង ទៅខាង បស្ចិមប្រទេសវិញដែរ ។ ប៉ុន្តែការពិត សម្ដេចនរោត្តម សីហនុ បែរជាជ្រើសរើសយកលោកកុម្មុយនិស្តជាបង្អែកទៅវិញ ដោយព្រោះតែព្រះអង្គ ខ្លាចពួកគហបតី កងទ័ព និង បញ្ញវន្ត ផ្ដួលរំលំ ពួកអភិជន តាមរយៈប្រព័ន្ធប្រជាធិបតេយ្យ សេរីនិយម។





# ការបោះឆ្នោត សភា ខែ កញ្ញា ឆ្នាំ ១៩៥៥

## Les législatives de Septembre 1955

ការបោះឆ្នោតសភា ដែលបានត្រូវកំណត់ ក្នុងកិច្ចព្រមព្រៀង ទីក្រុងហ្សឺណែវ បានត្រូវប្រកាស និង ពន្យាពេល ជាច្រើនដង តាំងពីពេលដែល ព្រះបាទ នរោត្តម សីហនុ ទ្រង់បានដាក់រាជ្យសម្បត្តិ។ នៅទីបំផុត គឺនៅថ្ងៃ ១១ កញ្ញា ឆ្នាំ១៩៥៥ ដដែល នោះ ការបោះឆ្នោតនោះ ក៏បានចេញជារូបរាង។ ប៉ុន្តែ ម្ដងនេះ គណបក្សប្រជាធិបតេយ្យ ដែលមានបេក្ខជន ចំនួន ៩១ រូប ដូច ចលនា សង្គមរាស្ត្រនិយម ដែរនោះ បានចុះ ឥទ្ធិពល យ៉ាងខ្លាំង ។ រីឯ យុទ្ធនាការ ឃោសនា បោះឆ្នោត ក៏ មាន លក្ខណៈខុសពីធម្មតាទៀត ដោយហេតុថា គណបក្សនានា ពុំសូវនិយាយ ឲ្យបានច្បាស់លាស់ អំពី កម្មវិធីនយោបាយ របស់ ខ្លួនទេ ។ ចលនា សង្គមរាស្ត្រនិយម ផ្អែក ការឃោសនា របស់គេជាពិសេស ទៅលើ ការទាមទារឯករាជ្យ របស់ អតីតព្រះមហាក្សត្រខ្មែរ។ ខាងគណបក្ស ប្រជាធិបតេយ្យឯនោះវិញ គេនាំគ្នាធ្វើការវាយប្រហារ ទៅលើ របបរាជានិយមតែម្ដង ជាហេតុធ្វើ ឲ្យលោក កេង វ៉ាន់សាក់ ដែលជាអ្នកពូកែខាង វោហារ និង លោកសារិន តុង ត្រូវនគរបាល ចាប់យកទៅ ឃុំឃាំង ។ នៅក្នុងឱកាសយុទ្ធនាការឃោសនាបោះឆ្នោត នោះមានព្រឹត្តិការណ៍មួយ ដ៏ចម្លែក : លោក កេង វ៉ាន់សាក់ បានត្រូវគេប៉ុនប៉ងបាញ់សម្លាប់ ប៉ុន្តែគ្រាប់កាំភ្លើង បានទៅត្រូវចំ អ្នកបើកបររថយន្ត របស់ លោកសំសុង ហ្វែរណាន់ដេស៍ ទៅវិញ ។ ការប៉ុនប៉ងនោះ បានត្រូវ គេទម្លាក់ទោស ទៅលើអ្នកដឹកនាំ ចលនាសង្គមរាស្ត្រនិយម ប៉ុន្តែ បើតាមលោក កេង វ៉ាន់សាក់ លោកមាន

ការសង្ស័យទៅលើលោក សឺន ង៉ុក ថាញ់ទៅវិញ។ លោកសឺន ង៉ុក ថាញ់ ជាគូប្រជែងម្នាក់ ដ៏សំខាន់ របស់ លោក កេង វ៉ាន់សាក់ នៅក្នុង គណបក្សប្រជាធិបតេយ្យ ។ ទោះជាយ៉ាងណាក្តី រឿងនេះ ស្ថិតនៅក្នុង ភាពអាថ៌កំបាំង រហូតមកទល់សព្វថ្ងៃនេះ។ ប្រការដែលគួរឲ្យកត់ សំគាល់ គឺថានៅពេលនោះលោក កេង វ៉ាន់សាក់ ដែលបានជាប់ បរិញ្ញាប័ត្រផ្នែកទស្សនវិជ្ជា នៅសាកលវិទ្យាល័យ ស័របូន (La Sorbonne) ប្រទេសបារាំង ជាអ្នកប្រជាធិបតេយ្យម្នាក់ ដែលមាន ឥទ្ធិពល ដ៏ខ្លាំង ព្រោះលោកមាន ទេពកោសល្យខ្ពស់ ចេះរកចំណុចខ្សោយ នៃរបបរាជានិយម។ ប៉ុន្តែ ពួកអ្នកធ្វើការឃោសនា ឲ្យគណបក្ស ប្រជាធិបតេយ្យ មានជាអាទិ៍ លោក កេង វ៉ាន់សាក់ នេះ ដែលបាននិយាយប៉ះពាល់ ដល់ របបរាជានិយម បានត្រូវរដ្ឋអំណាច ចាប់យកទៅឃុំឃាំងទាំងអស់ គឺ ដោយសំអាងទៅលើ មាត្រា ២៩៧ និង ៣០១ នៃ ក្រមព្រហ្មទណ្ឌ គឺច្បាប់ដែលមាននៅសល់តាំងពីឆ្នាំ ១៩១២ មក ហើយដែលហាមដាច់ខាត មិនឲ្យប៉ះពាល់ ដល់ របបរាជានិយម។ គណបក្សនយោបាយ ដែលចូលរួម ក្នុងការបោះឆ្នោតសភា នាថ្ងៃ ១១ កញ្ញា ឆ្នាំ ១៩៥៥ នោះ មានចំនួនទាំងអស់ ៨ គណបក្ស រួមបញ្ចូល ទាំងចលនា *សង្គមរាស្ត្រនិយម*ផងដែរ។ ចលនា *សង្គមរាស្ត្រនិយម* ដែលមាន ព្រះឆាយាល័ក្ខណ៍ សម្តេច នរោត្តម សីហនុ ជាសញ្ញាសំគាល់ បានទទួលសន្លឹកឆ្នោត ច្រើនជាងគេបង្អស់ គឺ ៨៣ ភាគរយ ព្រោះ នគរបាល បានធ្វើការគាបសង្កត់ឥត ត្រាប្រណីទៅលើ គណបក្សផ្សេងៗទៀត។ គណបក្ស «ប្រជាធិបតេយ្យ» ដែលមាន រូបក្បាលដំរីជាសញ្ញាសំគាល់ បានតែ១២ ភាគរយប៉ុណ្ណោះ។ គណបក្ស «ប្រជាជន» ដែលមានរូបនង្គ័ល ជាសញ្ញាសំគាល់ បាន ៤ ភាគរយ។ ក្រៅពីនោះ គណបក្ស ឯទៀត ៗ ដូចជាគណបក្ស «សេរីភាព», គណបក្ស «ហនុមាន», គណបក្ស «ខ្មែរឯករាជ», គណបក្ស «ពលករខ្មែរ» និង គណបក្ស «អ្នកឯករាជ» ប្រមូលសំឡេង បូកចូលគ្នា បានត្រឹមតែ ១ ភាគរយប៉ុណ្ណោះ។ សូមកត់សំគាល់បន្ថែមថា គណបក្ស «សេរីភាព» ដែលនៅពេលនោះ មានលោក នាល ផ្លែង ជាអ្នកដឹកនាំ បានកំណត់ យកប្រាសាទអង្គរវត្ត ជា





សញ្ញាសំគាល់ ។ គណបក្ស «ហនុមាន» របស់ លោក យ៉ែម សំបូ មានរូប ហនុមានជា សញ្ញាសំគាល់ រីឯគណបក្ស «ខ្មែរឯករាជ» មាន រូបផ្កាឈូក ជាសញ្ញាសំគាល់។ គណបក្ស «ពលករ» បានជ្រើសរើសយករូបកម្រង ផ្កា ជា និមិត្តរូប ហើយ គណបក្ស «អ្នកឯករាជ» បានយករូបសៀវភៅ រដ្ឋធម្មនុញ្ញ ដាក់ នៅលើជើងពាន ជានិមិត្តរូប។ ដូច្នេះឃើញថា ការបោះឆ្នោតខែកញ្ញា ឆ្នាំ ១៩៥៥ បានផ្តល់ជ័យជំនះទៅឲ្យចលនា «សង្គមរាស្ត្រនិយម» ទាំងស្រុង គឺបានដល់ទៅ ៦៣ ម៉ឺន ៦២៥ សំឡេង ក្នុងចំនួនអ្នកដែលបានទៅ បោះឆ្នោតទាំងអស់ ៧៦ ម៉ឺន ១៩៥៨ នាក់។ រដ្ឋសភា ដែលបានត្រូវបាត់តាំងឡើង មានសុទ្ធតែ សមាជិកចលនា «សង្គមរាស្ត្រនិយម» ទាំងអស់។ រីឯភារកិច្ចប្រមុខរដ្ឋាភិបាល បានត្រូវប្រគល់ថ្វាយ ទៅសម្តេច នរោត្តម សីហនុ ។ ប៉ុន្តែ ជាង ៣ ខែក្រោយមក គឺនៅ ថ្ងៃ ៣ មករាឆ្នាំ ១៩៥៦ សម្តេចនរោត្តម សីហនុ ទ្រង់ប្រគល់ភារកិច្ចនេះទៅឲ្យលោក អ៊ុំ ឈាង ស៊ុន វិញ លោកអ៊ុំ ឈាងស៊ុន ដែលកាលនោះបានត្រូវតែងតាំង ជា ប្រធានរដ្ឋសភា។ ប៉ុន្តែ មុននឹងឈានទៅដល់ ឆ្នាំ ១៩៥៦ ខ្ញុំ សូមលើកឡើង នូវព្រឹត្តិការណ៍សំខាន់ៗ ដែលកើតមានឡើងនៅឆ្នាំ ១៩៥៥ គឺ ក្នុងរយៈពេល ៤ ខែក្រោយការបោះឆ្នោត។ នៅថ្ងៃ ១៤ កញ្ញា ប្រទេស កម្ពុជាបានត្រូវទទួលស្គាល់ជាសមាជិកពេញសិទ្ធិ នៃអង្គការ សហប្រជាជាតិ។ តាំងពីពេលនោះមក សម្តេច នរោត្តម សីហនុ បានពង្រឹង នយោបាយ អព្យាក្រឹតភាពខ្មែរ នៅលើឆាកអន្តរជាតិ ឥតឈប់ឈរ។ សម្តេច នរោត្តម សីហនុ មានកិត្តិនាមល្បីល្បាញ នៅលើឆាកនយោបាយអន្តរជាតិនៅពេល នោះ ហើយនេះ ទោះបី ពាក្យអព្យាក្រឹតភាព មិនចូលបក្សសម្ព័ន្ធហាក់បីដូចជា មានលក្ខណៈ ពិបាកនឹងជឿថា អាចមានជំហររឹងប៉ឹងទៅកើតក្តី ។ នៅក្នុងប្រទេសឯនេះវិញ រដ្ឋាភិបាលសង្គមរាស្ត្រនិយម ជាបន្តបន្ទាប់ ដែលប្រសូត្រចេញពីរដ្ឋសភា ដែលមានសុទ្ធតែអ្នកតំណាងរាស្ត្រជាសមាជិក *សង្គមរាស្ត្រនិយម* នោះ បានជួប នឹងវិបត្តិ មួយដ៏ធំ ។ ខ្ញុំ នឹង និយាយរៀបរាប់ អំពី វិបត្តិ ទាំងនោះ ជាបន្តបន្ទាប់នៅទំព័រក្រោយ។ ទោះជាយ៉ាងណាក៏ដោយគេសង្កេតឃើញថា គូប្រជែងសំខាន់ៗរបស់

ចលនា *សង្គមរាស្រ្តនិយម* មិនមែន គណបក្សប្រជាធិបតេយ្យទេ តែគឺ ចលនា កុម្មុយនិស្តទៅវិញ។ នៅថ្ងៃ ១៨ តុលា គឺ ២ សប្តាហ៍ ក្រោយសមាជជាតិ លើកទី ២ នៃ ចលនា *សង្គមរាស្រ្តនិយម* សម្តេច នរោត្តម សីហនុ បានធ្វើការទស្សន៍ទាយទុកជាមុនថា បើបក្សកុម្មុយនិស្តឡើងកាន់អំណាច គឺ ច្បាស់ជាអន្តរធានតែម្តង ។ ២០ ឆ្នាំក្រោយមក អ្វីៗដែល សម្តេច នរោត្តម សីហនុ បានទស្សន៍ទាយនៅពេលនោះ បានក្លាយទៅជាការពិតទាំងអស់។ ប៉ុន្តែដោយមូលហេតុផ្សេងៗ ព្រះអង្គ បែរជា ជ្រើសរើស បណ្តាប្រទេសកុម្មុយនិស្ត ធ្វើជាបង្អែកទៅវិញ ។ មិត្តភាព របស់ព្រះអង្គ ជាមួយលោកកុម្មុយនិស្ត បានអូសទាញព្រះអង្គឲ្យធ្លាក់ទៅក្នុងរណ្តៅមរណៈដ៏ មហា សែនជ្រៅ គ្មានពេលវិលត្រឡប់វិញរហូត ។ ឥស្សរជនខ្មែរ ដែលបានខិតខំអូសទាញព្រះអង្គឲ្យចេញផុត ពីគ្រោះ ថ្នាក់នេះ បានត្រូវ ព្រះអង្គចោទប្រកាន់ទោសថា ជា «ជនក្បត់ជាតិ » ហើយខ្លះ បានត្រូវបាត់បង់ជីវិត នៅក្នុងស្ថានភាព ដ៏ក្រៀមក្រំបំផុត។

## ចលនា «*សង្គមរាស្រ្តនិយម*» និង ចលនា ខ្មែរ កុម្មុយនិស្ត

## Le « Sangkum Reastr Niyum » et les Khmers communistes

បន្ទាប់ពីបាន ទទួលជោគជ័យ ក្នុងការបោះឆ្នោតសភា ឆ្នាំ១៩៥៥ ចលនា «សង្គមរាស្រ្តនិយម» ត្រូវប្រឈមមុខនឹងចលនាកុម្មុយនិស្តខ្មែរជាបឋម ព្រោះ បន្ទាប់ ពីបរាជ័យ នៃ គណបក្ស «ប្រជាជន» ក្នុងការបោះឆ្នោត ពួកខ្មែរកុម្មុយនិស្ត ត្រូវប្រើយុទ្ធសាស្រ្ត បង្កើត «ស្នូល» របស់ គេ នៅគ្រប់ទីកន្លែង ជាពិសេស នៅក្នុងគណបក្ស





«ប្រជាធិបតេយ្យ» ដែលមាននិន្នាការដល់ទៅ ៣ គឺ និន្នាការឆ្វេងនិយម, និន្នាការកណ្តាលនិយម និងស្តាំនិយម។ នៅពេលនោះ សាឡុត ស ដែលក្រោយមក មានឈ្មោះថា ប៉ុល ពត បានខិតខំទាក់ទង អ្នកដែលមាន និន្នាការឆ្វេងនិយម ជាពិសេសអ្នកដែលធ្លាប់បាន ស្គាល់គ្នាតាំងពីនៅស្រុកបារាំងមក។ ប៉ុន្តែ បន្ទាប់ពី លោក កេង វ៉ាន់សាក់ ដែលជាអគ្គលេខាធិការរង នៃ គណបក្ស «ប្រជាធិបតេយ្យ» បានត្រូវគេចាប់យកទៅឃុំឃាំង អ្នកប្រជាធិបតេយ្យនានាឯទៀត ក៏ត្រូវទទួល ការគាបសង្កត់ពី នគរបាល។ ដោយទ្រាំតស៊ូតទៅទៀតមិនបាន លោកជួន ម៉ុម្ម ក៏ត្រឡប់ ទៅស្រុកបារាំងវិញ។ ប៉ុន្តែ សាឡុត ស វិញ ដែលធ្វើសកម្មភាព ដោយមិនចេញ មុខក៏បានត្រូវរួចខ្លួន ។ នៅពេលដែលពួកកុម្មុយនិស្តខ្មែរ បន្តសកម្មភាពលួចលាក់ របស់គេ ដោយធ្វើជាគ្រូបង្រៀន និង ជាអ្នកកាសែតនៅទីក្រុងភ្នំពេញ ចលនា «សង្គមរាស្រ្តនិយម» ក្តាប់អំណាច បានទាំងស្រុង ។ តាំងពីជ័យជំនះ របស់ ចលនា «សង្គម រាស្រ្តនិយម» នៅពេលបោះឆ្នោតសភា ឆ្នាំ១៩៥៥ មក របប ពហុបក្ស ក៏ រលាយសាបសូន្យបាត់ទៅ ។ របប «សង្គមរាស្រ្តនិយម» ដឹកនាំប្រទេស តែម្នាក់ឯង។ នៅដើមឆ្នាំ ១៩៥៦ គឺនៅ ថ្ងៃ ១៤ មករា សម្តេច នរោត្តម សីហនុ បានធ្វើការកែទម្រង់ រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ជាបណ្តើរៗ។ គឺ នៅពេលនោះហើយ ដែលប្រទេសកុម្មុយនិស្តនានា បានចាប់ផ្តើមអូសទាញ ប្រទេសកម្ពុជា ឲ្យចូលទៅក្នុងប្លុក (Bloc) របស់ពួកគេ។ នៅពាក់កណ្តាល ខែកុម្ភៈ ឆ្នាំ ១៩៥៦ នោះ សម្តេច នរោត្តមសីហនុ ទ្រង់ យាងទៅធ្វើ ព្រះរាជទស្សនកិច្ច នៅ ប្រទេសចិនប្រជាមានិត្ត និងនៅប្រទេសឆេកូស្លូវ៉ាគី (Tchécoslovaquie) ។ មិត្តភាព រវាង ប្រទេស ចិន និង ប្រទេសកម្ពុជា ក៏បាន ត្រូវចាប់ផ្តើម ពង្រឹង តាំងពីពេលនោះមកដែរ ។ មួយខែក្រោយទស្សនកិច្ចនេះ គណបក្ស «ប្រជាជន» បានសុំមកចូលរួមក្នុងចលនា «សង្គមរាស្រ្តនិយម» ប៉ុន្តែ សម្តេច នរោត្តម សីហនុ ព្រះអង្គទ្រង់ពុំយល់ព្រមឡើយ ពីព្រោះនៅពេលនោះ ព្រះអង្គប្រឆាំង ដាច់ខាត នឹង តួនាទី របស់ គណបក្សកុម្មុយនិស្តនៅក្នុងប្រទេសកម្ពុជានៅឡើយ។ ព្រះអង្គនឹកស្មានថា ព្រះអង្គអាចរក្សាមិត្តភាព ជា

មួយ ប្រទេសកុម្មុយនិស្តផង ហើយរក្សាឯករាជ្យ និងនយោបាយ អព្យាក្រឹតភាព របស់ខ្មែរផង ។ ទោះជាយ៉ាងណាក្តី នៅក្នុងដំណាក់ការនោះ បណ្តាប្រទេសកុម្មុយនិស្ត បាននាំ គ្នាខិតខំលើកទឹកចិត្តសម្តេច នរោត្តម សីហនុ ឲ្យរក្សានយោបាយអព្យាក្រឹតភាពនោះជាបណ្តោះអាសន្នសិន។ រីឯ គណបក្ស «ប្រជាជន» ក៏នាំគ្នាគាំទ្រ នយោបាយនេះយ៉ាងសកម្មផងដែរ ។ យុទ្ធសាស្ត្រ ដែលខ្មែរកុម្មុយនិស្ត និង ប្រទេសកុម្មុយនិស្ត បានកំណត់នៅពេលនោះ គឺជាបឋមធ្វើយ៉ាងណា ឲ្យប្រទេសកម្ពុជាប្រកាន់នយោបាយប្រឆាំងនឹងសហរដ្ឋ អាមេរិកតែប៉ុណ្ណោះ ជាពិសេសកុំឲ្យសហរដ្ឋ អាមេរិក ដាក់ មូលដ្ឋានទ័ពនៅកម្ពុជាពោលគឺធ្វើយ៉ាងណា មិនឲ្យចូលទៅក្នុងបក្សសម្ព័ន្ធអូតាស្ស៊ (O.T.A.S.E) ។ សូមបញ្ជាក់ថា មុនពេល បោះឆ្នោតសកា ឆ្នាំ ១៩៥៥ គឺ នៅខែ ឧសភា សម្តេចនរោត្តម សីហនុ បានសុខចិត្តទទួលជំនួយពី សហរដ្ឋអាមេរិករួចទៅហើយ ។ ដូចនេះ ប្រទេសកុម្មុយនិស្ត គេត្រូវតែជំរុញសម្តេច នរោត្តម សីហនុ ឲ្យធ្វើយ៉ាងណា ដកប្រទេសកម្ពុជាឲ្យចេញផុតពីឥទ្ធិពលរបស់អាមេរិក។ សូមបញ្ជាក់ថា ទោះបី សម្តេចនរោត្តម សីហនុ ចងមិត្តភាព ជាមួយប្រទេសកុម្មុយនិស្តក្តី ក៏ព្រះអង្គ ប្រយុទ្ធដាច់ខាត នឹង ចលនាកុម្មុនិស្តខ្មែរ នៅកម្ពុជាដែរ ព្រោះព្រះអង្គទ្រង់ឈ្វេងយល់ យ៉ាងច្បាស់ថា គឺ ពួកនេះហើយ ដែលកំពុងធ្វើ សកម្មភាពវិទ្ធង្សនា បំបាត់តួនាទី របស់ ព្រះអង្គចេញ ពីឆាកនយោបាយខ្មែរ។ ចលនា កុម្មុយនិស្ត ជា ចលនា នៃ បដិវត្តន៍ អន្តរជាតិ ដែលនៅពេលនោះ មានឥទ្ធិពលដ៏ខ្លាំងក្លានៅវៀតណាម។ ទោះបី ពួកកុម្មុយនិស្តខ្មែរ នៅពេលនោះ ហាក់បីដូចជាមិនសូវមាន ការយកចិត្តទុកដាក់ប៉ុន្មាន ពីសំណាក់អ្នកដឹកនាំ ប្រទេសកុម្មុយនិស្ត នានាក្តី ក៏ព្រះអង្គយល់យ៉ាងច្បាស់ថា ជនកុម្មុយនិស្តខ្មែរ អាចនឹង ដណ្តើមយកអំណាច ពីព្រះអង្គបានដែរ ព្រោះពួកគេចេះបំផុសបំផុល ប្រជាជន យុវជន និងបញ្ញវន្ត យ៉ាងប៉ិនប្រសប់ ហើយបង្កើត ស្នូលនយោបាយ របស់គេ នៅគ្រប់ទីកន្លែង ។ ហេតុដូច្នេះហើយ បានជា នៅឆ្នាំ ១៩៥៥-១៩៥៧ នោះ សម្តេច នរោត្តម សីហនុ ធ្វើការគាបសង្កត់ទៅលើអ្នកទាំងនោះឥតត្រាប្រណី ។ មិនតែប៉ុណ្ណោះសោត ព្រះអង្គបាន





បំបែកបំបាក់ពួកកុម្មុយនិស្តខ្មែរទាំងនោះ បានផងទៀត ។ មេកុម្មុយនិស្តខ្លះ ដូចជា សៀវ ហេង ជាដើម ក៏ បានក្បត់ នឹង ចលនា របស់គេ ហើយ សុខចិត្តធ្វើជាភ្នាក់ងារសម្ងាត់ របស់ព្រះអង្គថែមទៀតនៅឆ្នាំ ១៩៥៩។ នៅឆ្នាំ ១៩៥៩ នោះ សៀវ ហេង បានបំផ្លាញ ចលនា របស់គេ បោលអស់ ជិត ៩០ ភាគរយ ដើម្បីចូលបម្រើ សម្តេច នរោត្តម សីហនុ។ នៅពេលនោះ ខ្មែរកុម្មុយនិស្ត ជាច្រើនបានត្រូវ ក្រសួងសម្ងាត់ របស់ សម្តេច នរោត្តម សីហនុ ចាប់ជាបន្តបន្ទាប់ ហើយមួយ ចំនួនទៀត រត់គេចរត់គោយ បែកបាក់គ្នាអស់។ តាមការពិត សម្តេច នរោត្តម សីហនុ មិនមែនទើប នឹង ចាប់ផ្តើមកំចាត់ពួកខ្មែរកុម្មុយនិស្តនៅឆ្នាំ ១៩៥៦ នោះទេ។ តាំងពីពេលដែល ចលនា *សង្គមរាស្ត្រនិយម* បានទទួលជោគជ័យ លើសលុប នៅពេល បោះឆ្នោតសកា ឆ្នាំ ១៩៥៥ មក នគរបាល របស់ សម្តេច នរោត្តម សីហនុ បាន ចាប់ផ្តើមប្រយុទ្ធ នឹងពួកនេះ រួចបាត់ទៅហើយ ។ គេអាចនិយាយបានថា ចាប់តាំងពី ឆ្នាំ ១៩៥៦ នោះមក ចលនា របស់ ខ្មែរកុម្មុយនិស្ត នៅតាម ជនបទ បានស្រុតរលំ ស្ទើរតែទាំងអស់ គឺ នៅសល់តែ អ្នកដែលពួនសម្ងំធ្វើ សកម្មភាពនៅទីក្រុង ដូចជា ប៉ុល ពត ជាដើម តែប៉ុណ្ណោះ ប៉ុន្តែ គឺអ្នកទាំងនោះហើយ ដែលក្រោយមក បានខិតខំ ស្តារចលនាកុម្មុយនិស្តខ្មែរ បានឡើងវិញ ។

# ការកែទម្រង់ ស្ថាប័ន នយោបាយ តាម រយៈការប្រកាសឲ្យប្រើ នីតិក្រម ចុះថ្ងៃ ១៥ ធ្នូ ឆ្នាំ ១៩៥៦

La Loi du 15 décembre 1955 fut promulguée le 14 Janvier 1956

នៅដើមឆ្នាំ ១៩៥៦ សម្តេចនរោត្តម សីហនុ មេដឹកនាំចលនា សង្គមរាស្ត្រនិយម បានចាប់ផ្តើមធ្វើការកែទម្រង់រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ ។ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ ជា រដ្ឋធម្មនុញ្ញ ដែលរដ្ឋសភា និងបក្សនយោបាយនានា មាន តួនាទី ដ៏សំខាន់។ នៅ ថ្ងៃ ១៤ មករាឆ្នាំ ១៩៥៦ នីតិក្រមចុះថ្ងៃ ១៥ ធ្នូ ឆ្នាំ១៩៥៥ បានត្រូវប្រកាសឲ្យប្រើ ដោយក្រម លេខ៦៥ ន.ស.។ តាមការពិត នីតិក្រមនេះ មិនមែនជា វិសោធនកម្ម ធម្មតាទេ តែគឺជា រដ្ឋធម្មនុញ្ញ ថ្មីមួយទៀត តែម្តង ។ ទោះបី សម្តេច នរោត្តម សីហនុ ទ្រង់បាន គូសបញ្ជាក់ថា នីតិក្រមនេះ ជាការបញ្ចូលមកក្នុង រដ្ឋធម្មនុញ្ញចាស់ នូវ របៀបប្រជាធិបតេយ្យមួយបែប ដែលប្រជាជនម្ចាស់អំណាច អាចកាន់កាប់អំណាច ដោយផ្ទាល់តែម្តងក្តី ក៏មានមតិខ្លះរិះគន់ថា ជារបបផ្តាច់ការមួយ ដែលដឹកនាំប្រទេស ដោយ គណបក្សនយោបាយតែមួយ ហើយដែលផ្អែកទាំងស្រុងទៅលើ មនុស្សតែម្នាក់ដែរ ។ រីឯបញ្ហាដែលចោទ គឺថា តើ ប្រជាជន កាន់អំណាច ដោយផ្ទាល់ របៀបណាទៅ បើគ្មានគោលទ្រឹស្តី ជាមូលដ្ឋាននោះ ។ តាមគោលការណ៍ ប្រជាធិបតេយ្យ តាមបែបបស្ចិមប្រទេស ប្រជាជនសំដែងឆន្ទៈរបស់គេ តាមរយៈ គណបក្សនយោបាយ គឺជ្រើសរើសយកគណបក្សណាមួយ ដែលគេពេញចិត្ត នឹង ទ្រឹស្តី ទស្សនវិជ្ជា ជាមូលដ្ឋាន នឹងកម្មវិធីនយោបាយផ្សេងៗ។ ប៉ុន្តែ តាមគោលការណ៍ នៃ របប សង្គមរាស្ត្រនិយម ប្រជាជនចាត់អ្នកតំណាងរបស់គេតាមខេត្រ នីមួយៗ ឲ្យមកចូលរួមប្រជុំ ក្នុងស្ថាប័នមួយដែលមានឈ្មោះថា «សមាជជាតិ»។ យោងទៅតាមមតិខ្លះ នេះ គឺ ជាលិទ្ធិប្រជាធិបតេយ្យពិតប្រាកដ ព្រោះតាមរយៈអ្នកតំណាងរបស់គេ ប្រជាជន អាចធ្វើការព្រមានរដ្ឋាភិបាល និង មន្ត្រីរាជការ ដោយផ្ទាល់តែម្តង។ ការអនុវត្តន៍ គោលការណ៍នេះ បានបង្កើតឡើង នូវវិបត្តិរដ្ឋាភិបាលជាច្រើន។ រដ្ឋាភិបាល សង្គមរាស្ត្រនិយម ត្រូវផ្លាស់ប្តូរជាញឹកញាប់ ជាហេតុធ្វើឲ្យកម្មវិធី និង នយោបាយ របស់ រដ្ឋាភិបាល នីមួយៗ រកពេលយកទៅអនុវត្ត សឹងមិនបានតែម្តង ក៏អាចថាបាន។ ប៉ុន្តែ មន្ត្រីរាជការពុករលួយ ឬទុច្ចរិត ក៏រកពេលពុករលួយ ឬ ធ្វើបាបសង្កត់សង្កិន ប្រជាជន សឹងតែមិនបានដែរ



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

ព្រោះសម្តេច នរោត្តម សីហនុ ដែលដឹកនាំអង្គសមាជជាទៀងទាត់ មានមុខនាទី ជាអ្នករកយុត្តិធម៌ ជូនប្រជាជនតែម្តង ។ នៅក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ មន្ត្រីរាជការមានច្បាប់ និង ប្រព័ន្ធច្បាប់ ជាច្រើន សម្រាប់ការពារ ផលប្រយោជន៍ របស់ គេ ប៉ុន្តែនៅក្នុងអង្គសមាជ ដែលបើកអង្គប្រជុំ យ៉ាងហោចណាស់ ក៏ ២ ដងដែរក្នុង ១ ឆ្នាំ គ្មានគោលការណ៍ច្បាប់អ្វី ដែលរាំង មិនឲ្យដោះស្រាយ បញ្ហាជាក់ស្តែង និង ចំពោះមុខរបស់ ប្រជាជនទេ ទោះការដោះស្រាយបញ្ហា នានា ច្រើនតែប៉ះពាល់ដល់ ប្រយោជន៍សេដ្ឋកិច្ច គោលការណ៍ ពាណិជ្ជកម្ម និង ទស្សនវិជ្ជា នៃ មជ្ឈដ្ឋាននានាក្តី ។ នីតិក្រមដែលប្រកាសឲ្យប្រើ ដោយក្រម លេខ ៦៥ ន.ស. ចុះថ្ងៃ ១៤ មករា ឆ្នាំ ១៩៥៦ តម្រូវឲ្យបង្កើត សភាប្រជាជន តាមខេត្ត និង សភាប្រជាជន នៅក្នុងរាជធានី ហើយចាត់តាំងឲ្យមាន «សមាជជាតិ» មួយ (Congré national) ដែលចេញសេចក្តីសម្រេចផ្សេងៗ ។ ប្រជាជនត្រូវដឹង អំពី កិច្ចការរដ្ឋផ្សេងៗ។ ស្ថាប័ននេះតែងតាំងរដ្ឋមន្ត្រី និងបោះឆ្នោតទៅលើ សំណូមពរផ្សេងៗ ដែលត្រូវស្នើទៅ រដ្ឋាភិបាល និង ទៅលើសេចក្តីសម្រេចចិត្ត នានាសម្រាប់ឲ្យ រដ្ឋសភាធ្វើតាម។ ប៉ុន្តែ រដ្ឋសភា អាចរៀបចំការបោះឆ្នោតប្រជាមតិ ស្តីពីបញ្ហាផ្សេងៗ ទាក់ទង នឹងសេចក្តីសម្រេចចិត្ត របស់ សមាជជាតិ។ ខាង ផ្នែកតុលាការជាន់ខ្ពស់ ច្បាប់មួយចុះ ថ្ងៃ ១៥ ធ្នូ ឆ្នាំ ១៩៥៥ ហើយដែលប្រកាសឲ្យប្រើ នៅថ្ងៃ ១៤ មករាឆ្នាំ ១៩៥៦ បានប្រែក្លាយអត្ថបទ ថ្ងៃ ២៧ ធ្នូ ឆ្នាំ ១៩៤៩ ឲ្យមានលំនាំ ដូចតទៅ ៖ ប្រធាន នឹង អនុប្រធាន សាលាកាត់ក្តី ពុំមែនចាំបាច់ជាចៅក្រមទេ។ ព្រះមហាក្សត្រ ជាអ្នកតែងតាំង ប្រធាន និង អនុប្រធាន នៃ ស្ថាប័នទាំងនោះ ក្នុងចំណោមសមាជិក ៥ នាក់ ជាសាមីជន។ គណកម្មាធិការ អង្កេត ត្រូវដឹកនាំដោយ អ្នកតំណាងរាស្ត្រ គឺ មិនមែន ដោយចៅក្រមទេ ។ អត្ថបទនេះ មានជាលំអិតទៀត ប៉ុន្តែ ខ្ញុំសូមលើកឡើងតែ ២-៣ ចំណុចប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក្តី គេអាច និយាយបានថា រដ្ឋធម្មនុញ្ញឆ្នាំ ១៩៥៦ នោះ រក្សារបបសភាដដែល។ ប៉ុន្តែ របប សភានិយម តាមបែបបស្ចិមប្រទេស បានក្លាយទៅជា របប សភានិយមផ្ទាល់

ពាក់កណ្ដាល (correspondant à une sorte de démocratie semi-directe) ។ នៅក្នុង រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ គេឃើញមាន សិទ្ធិធ្វើបដ្ឋនាលិខិត ។ សិទ្ធិនេះ បាន ត្រូវរក្សាទុកនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ ១៩៥៦ គឺត្រង់មាត្រា ១៤។ សិទ្ធិរបស់ ប្រជាជន នៅ ក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៥៦ មានច្រើនជាង នៅក្នុងរដ្ឋធម្មនុញ្ញមុន ព្រោះ ប្រជាជន មានសិទ្ធិ ដកហូតអ្នកតំណាង របស់គេ នៅរដ្ឋសភា និង នៅសភាប្រជាជន (មាត្រា ៥១ និង ៨៥)។ ប៉ុន្តែ នេះ មិនមែនជារឿង ដែលគ្មានផលវិបាក ប៉ះពាល់ដល់ គោល ការណ៍ ធំៗនោះទេ ។ នៅពេលដែល ចលនា *សង្គមរាស្ត្រនិយម* ក្ដាប់អំណាច យ៉ាង ណែន ហើយ នៅពេលដែល ចលនាកុម្មុយនិស្ត ធ្វើសកម្មភាពលួចលាក់ នៅក្នុង ទីក្រុងភ្នំពេញ រដ្ឋាភិបាលសង្គមរាស្ត្រនិយម បានផ្លាស់ប្តូរ ៤ ដងនៅក្នុងឆ្នាំ ១៩៥៦ នោះ ៖ រដ្ឋាភិបាលរបស់ សម្ដេច នរោត្តម សីហនុ តែងតាំងនៅថ្ងៃ ១ មិនា ត្រូវ ប្រគល់ទៅឲ្យ លោក ឃីម ទិត វិញ នៅថ្ងៃ ៣ ខែ មេសា ។ នៅថ្ងៃ ១៥ សីហា ដល់វេន សម្ដេច នរោត្តម សីហនុ ម្ដងទៀត ហើយ នៅថ្ងៃ ២៥ តុលា លោក សាន យុន បានត្រូវតែងតាំងជាប្រមុខរដ្ឋាភិបាល។ នៅខែតុលានោះ មានព្រឹត្តិការណ៍ធំមួយ ៖ ប្រទេសថៃ បានដាក់កងទ័ពរបស់គេ ជំនួស កងនគរបាលនៅព្រះវិហារ។ នេះ ជារឿង មួយ ដ៏ចម្រូងចម្រាស ។ នៅ ថ្ងៃ ២២ វិច្ឆិកា ឆ្នាំ ១៩៥៦ ដដែល លោក ជូ អេនឡាយ បានអញ្ជើញមកធ្វើទស្សនកិច្ចនៅកម្ពុជា។ នៅទីក្រុងប៉ារីស៍ ឯនោះវិញ នៅថ្ងៃ ២៦ វិច្ឆិកា សមាគម សហភាព និស្សិត ខ្មែរ *អ៊ុយ អឺ កា* (UEK) បាន ចាប់បដិសន្ធិ ។ រីឯ អ្នកដឹកនាំសំខាន់ៗ មានជាអាទិ៍ : អៀង សារី, ខៀវ សំផន, ជួន ម៉ុម្ម ។





# «សង្គមរាស្ត្រនិយម» : ការប្រទាញប្រទង់គ្នា រវាង និន្នាការស្ដាំអភិរក្ស និង និន្នាការឆ្វេង

## Le Sangkum entre la Droite conservatrice et la Gauche

នៅឆ្នាំ ១៩៥៦ នៅពេលដែលរដ្ឋាភិបាល «សង្គមរាស្ត្រនិយម» ផ្លាស់ប្តូរ ឥត ឈប់ឈរ ហើយនៅពេលដែល សាឡុត ស ធ្វើសកម្មភាពបង្កើត ស្តូល កុម្មុយ និស្តនៅភ្នំពេញ – ជាពិសេស នៅក្នុងមជ្ឈដ្ឋាន សិស្សានុសិស្ស មជ្ឈដ្ឋានអ្នកកាសែត និង នៅក្នុង ចំណោមកម្មករ – នៅប្រទេសបារាំង ឯនោះវិញ អៀង សារី, ជួន ម៉ុម្ម, ខៀវ សំផន ក៏ ខិតខំ បង្កើតស្តូលកុម្មុយនិស្ត របស់គេដែរ។ នៅថ្ងៃ ២៦ វិច្ឆិកា ចុងឆ្នាំ ១៩៥៦ នោះ នៅទីក្រុងប៉ារីស៍ គេបាននាំគ្នាបង្កើតសមាគម និស្សិត មួយមានឈ្មោះថា *អ៊ុយ អឺ កា* (U.E.K. : Union des Etudiants Khmers) ។ មួយខែក្រោយមក គឺ នៅថ្ងៃ ២៨ ធ្នូ អិន សូកាន បានត្រូវជ្រើសតាំងជាប្រធាន នៃ សមាគមនោះ ដែលមាន ឥស្សរជន ខ្មែរកុម្មុយនិស្តជាច្រើន ចូលរួម ដូចជា ខៀវ ធិរិទ្ធ ករិយា របស់អៀង សារី និង លោក ឌី ផុន ជាដើម។ យោងទៅតាម ការស្រាវជ្រាវ របស់ លោកស្រី ម៉ារី អាឡេចសង់ឌ្រីន ម៉ារតាំង (Marie Alexandrine Martin) សមាគមនិស្សិតខ្មែរ *អ៊ុយ អឺ កា* (U.E.K.) ដែលបង្កើតនៅចុងឆ្នាំ ១៩៥៦ នោះ មានការឯកភាពគ្នា ច្រើន ជាង សមា គម *អា អឺ កា* (A..E.K.) គឺ សមាគមដែលត្រូវ រដ្ឋាភិបាលបារាំង លុប បោលនៅខែកុម្ភៈ ឆ្នាំ ១៩៥៣ តាម សេចក្ដីស្នើ របស់ ព្រះមហាក្សត្រខ្មែរ ។ នៅឆ្នាំ ១៩៥៦ នោះ និស្សិតខ្មែរ ដែល គ្មាននិន្នាការកុម្មុយ និស្ត បាននាំគ្នាទៅចូលរួម ជាមួយ សមាគមមួយទៀត គឺ សមាគម *អា កា* (A.K.) ឬ «សមាគមខ្មែរ» ដែលបាន

ត្រូវបង្កើតនៅថ្ងៃ២៧ កុម្ភៈឆ្នាំ ១៩៥៥ ហើយ ដែលមានលោក ចៅ សេង អួ ជាប្រធាន ។ សមាជិក មួយចំនួន នៃ «សមាគមខ្មែរនៅ ប្រទេសបារាំង» ហៅ អា សេ អេហ្វ (A.C.F) គឺ សមាគម ដឹក នាំដោយលោក ម៉ៅ សាយ ហើយបន្ទាប់មក ដោយលោក ឌុក រ៉ាស៊ី និង លី ជិនលី ក៏ នាំគ្នាចូលមកក្នុង សមាគម អា កា នេះដែរ ប៉ុន្តែ ទាល់តែ ៥ ឆ្នាំ ក្រោយ មក គឺនៅខែមករា ឆ្នាំ ១៩៦១ ទើបសមាគម អា កា និង អា សេ អេហ្វ (A.C.F) ត្រូវរំលាយចូលគ្នា ដើម្បីបង្កើត សមាគមមួយទៀត មានឈ្មោះថា សេកុម (CKOM : Communauté des Cambodgiens d’Outre-mer ឬ សមាគមជនជាតិខ្មែរ នៅ នាយសមុទ្រ) ។ តាំងពី សមាគមនេះ បានត្រូវបង្កើតឡើង សមាគមទាំង ២ នេះ ប្រណាំងប្រជែងគ្នា យ៉ាងខ្លាំង ដើម្បីប្រមែប្រមូល សមាជិក រៀងៗ ខ្លួន។ សមាគមអ៊ុយ អឺ កា (U.E.K) បានត្រូវបង្កើតនៅថ្ងៃ ២៦ វិច្ឆិកា ឆ្នាំ ១៩៥៦ គឺជាង ១ ឆ្នាំ ក្រោយ សមាគម អា កា ហើយ ៥ ឆ្នាំ មុន សមាគម សេកុម ។ ៩ ខែ ក្រោយពេល ដែលសមាគម អ៊ុយ អឺ កា (U.E.K) បានត្រូវបង្កើត «ផ្ទះខ្មែរ» (Pavillon du Cambodge) នៅ បុរីសកលវិទ្យាល័យ ទីក្រុងប៉ារីស៍ (Cité Universitaire de Paris) បានត្រូវសម្ពោធនៅថ្ងៃ ២០ សីហា ឆ្នាំ ១៩៥៧ ក្រោមអធិបតីភាព របស់សម្តេច នរោត្តម សីហនុ។ សមាគម បដិបក្ខទាំង ២ គឺសមាគម អ៊ុយ អឺ កា (U.E.K.) និង អា កា - ហើយ ក្រោយមក សមាគម សេកុម (C.K.O.M.) - ក៏បានត្រូវចាត់ទុកជាអ្នកតំណាង ផ្លូវការ នៅ «ផ្ទះខ្មែរ» តែម្តងទៅ។ នៅប្រទេសកម្ពុជាឯនោះវិញ នៅឆ្នាំ ១៩៥៧ រដ្ឋាភិបាលសង្គមរាស្ត្រនិយម នៅតែបន្តផ្លាស់ប្តូរ ជា ច្រើនដង។ អស់ពីរដ្ឋាភិបាល លោក សាន យុន ដល់វេន សម្តេច នរោត្តម សីហនុ វិញ។ អស់ពីសម្តេច នរោត្តម សីហនុ ដល់ វេន លោក ស៊ឹម វ៉ា ។ វិបត្តិ រដ្ឋាភិបាលនេះបញ្ជាក់ឲ្យឃើញថា ចលនារួបរួមជាតិ ជាចលនាដែលមាន និន្នាការ នយោបាយ និងមនោគមវិជ្ជាចម្រុះ ហើយ ដូចនេះ មិនងាយនឹងឯកភាពគ្នា ទៅលើ កម្មវិធីនយោបាយរួមមួយបានទេព្រោះមានប្រយោជន៍ខុសគ្នាទាំងអស់ ជាពិសេសទំនាស់រវាង ប្រយោជន៍





ជាតិ រវាង វប្បធម៌ជាតិ និង គោលការណ៍ មនោគមវិជ្ជា អន្តរជាតិ។ គឺនៅឆ្នាំ ១៩៥៧ នោះហើយ ដែលអ្នកនិពន្ធ សូវៀត បូរីស ប៉ាស្ទើណាក់ (Boris Pastenak) បានចេញសៀវភៅមួយ ដែលមានចំណងជើងថា វេជ្ជបណ្ឌិត ស៊ីវ៉ាហ្គោ (Le Doteur Jivago)។ នៅថ្ងៃ ៩ មេសា ឆ្នាំ ១៩៥៧ រដ្ឋាភិបាល លោក សាន យុន ត្រូវបញ្ចប់បេសកកម្ម ព្រោះការប្រយុទ្ធ នឹង អំពើពុករលួយ តាំងពី រដ្ឋាភិបាល របស់ សម្តេច នរោត្តម សីហនុ ថ្ងៃ ១៥ កញ្ញា ឆ្នាំ ១៩៥៤ មកនោះ បានទទួលបរាជ័យទាំងស្រុង។ នៅក្នុងរដ្ឋាភិបាលសម្តេច សីហនុ ថ្ងៃ ១៥ កញ្ញានោះព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត ជាព្រះបិតុលា បានត្រូវតែងតាំង ជារដ្ឋមន្ត្រី ការពារប្រទេស និង ខាងការបោសសំអាតអំពើពុករលួយ នៅក្នុងជួរកងទ័ព ប៉ុន្តែ បេសកកម្ម របស់ ព្រះអង្គ ពុំបានទទួលជោគជ័យទេ ។ មួយវិញទៀត ការបង្កើត ក្រសួងបោសសំអាត អំពើ ពុករលួយ បានត្រូវគេចាត់ទុកថាពុំស្រប តាមគោលការណ៍ រដ្ឋធម្មនុញ្ញផងទៀត។ ប៉ុន្តែ តាមការពិត គឺព្រោះតែព្រះអង្គម្ចាស់ មុនីរ៉េត ចង់បញ្ជូននាយទាហាន ដែលត្រូវជាប់ចោទ ពី បទពុករលួយ ទៅឲ្យតុលាការសើកកាត់ទោស តែប៉ុណ្ណោះ ។ គេសង្កេតឃើញថា នៅពេលនោះ នយោបាយ របស់សម្តេច នរោត្តម សីហនុ ជួបឧបសគ្គជាច្រើន នៅក្នុងវិស័យច្បាប់ ក៏ដូចជានៅក្នុង វិស័យ គោលការណ៍ សេដ្ឋកិច្ច ។ រដ្ឋាភិបាលចុងក្រោយ របស់លោក សាន យុន ក៏ បានជួបឧបសគ្គ បែបនេះដែរ។ រដ្ឋាភិបាល ទី ១ របស់ លោក សាន យុន បាន ត្រូវរុះរើសាជាថ្មី ព្រោះតែនីតិវិធី ស្តីពី ការបញ្ចូលអតីតអ្នកតំណាងរាស្ត្រម្នាក់មក ក្នុងរដ្ឋសភាវិញ។ រីឯ បដិវាទកម្ម រវាងច្បាប់ និង នយោបាយសេដ្ឋកិច្ច ក៏ជា មូល ហេតុមួយ នៃ វិបត្តិ រដ្ឋាភិបាល សង្គមរាស្ត្រនិយម នោះដែរ។ ព្រោះតែត្រូវអនុវត្ត មាត្រា ៩៩ ថ្មី នៃ រដ្ឋធម្មនុញ្ញដែលតម្រូវ ឲ្យមាន នយោបាយ ការពារ ផលិតផល ក្នុងប្រទេស រដ្ឋាភិបាល លោក សាន យុន ត្រូវពាណិជ្ជករ វាយប្រហារ យ៉ាងខ្លាំង។ នៅឆ្នាំ ១៩៥៧ នោះ មានព្រឹត្តិការណ៍ ៣ សំខាន់ៗ ៖ នៅថ្ងៃ ១២ មករា សមាជជាតិលើកទី ៤ បានអនុម័ត សេចក្តីសម្រេចចិត្តមួយ ដែលប្រកាស នយោបាយ

អព្យាក្រឹតភាព នៃ ប្រទេសកម្ពុជា ។ នៅថ្ងៃ ២៥ មេសា កងទ័ព វៀតណាម ខាងត្បូងបានឆ្លងព្រំដែនខ្មែរ ចូលមកដល់ ចន្ទ្រា ខែត្រស្វាយរៀង ដោយ សំអាងថា ពួកវៀតណាមកុម្មុយនិស្ត បានមកតាំងទីប្រយុទ្ធ របស់គេនៅក្នុងទឹកដីខ្មែរ។ នេះ ជា បញ្ហាប្រជែងកម្លាំងគ្នាមួយ ដ៏ធំរវាង លោកសេរី និង លោកកុម្មុយនិស្ត ដែលកើតចេញជាវិបត្តិសំខាន់មួយ នៅឆ្នាំក្រោយៗ មកទៀត។ ទោះជាយ៉ាងណាក្តី គេកត់សំគាល់ថា ការរក្សា នយោបាយអព្យាក្រឹតភាព នៅក្នុង តំបន់ភូមិសាស្ត្រ-នយោបាយ ដ៏ សំខាន់ នេះ ជាការមួយ ដ៏ពិបាក ក្រៃលែង។ យ៉ាងណាមិញ វាសនា របស់ ប្រទេសកម្ពុជានៅពេលនោះ ក៏មានទំនាក់ទំនង យ៉ាងជិតស្និទ្ធ នឹង ស្ថានភាពភូមិសាស្ត្រ-នយោបាយនោះដែរ។

## បញ្ហា អព្យាក្រឹតភាព ខ្មែរ

### Le problème de neutralité du Cambodge

មុននឹងនិយាយ អំពីសភាពការណ៍ នៅឆ្នាំ ១៩៥៨ ខ្ញុំសូមបញ្ជាក់ថា តាំងពីខែទី ៤ ឆ្នាំ១៩៥៧ មក ការប្រជែងកម្លាំង រវាងវៀតណាម ខាងត្បូង និង វៀតណាម ខាងជើង កាន់តែមានលក្ខណៈធ្ងន់ធ្ងរទៅៗ នៅឥណ្ឌូចិន។ នៅថ្ងៃ ២៥ មេសា កងទ័ព វៀតណាម ខាងត្បូង បានឈ្លានពានព្រំដែនខ្មែរ ចូលមកដល់ចន្ទ្រា ខែត្រស្វាយរៀងដោយ សំអាងថា កងទ័ពវៀតមិញ បានជ្រៀតជ្រែក ចូលមកក្នុងទឹកដីខ្មែរ ។ របប ង៉ោ ឌិញ យាម (Ngô Dinh Diem) នៅពេលនោះ មានបង្អែកមួយយ៉ាងមាំ គឺសហរដ្ឋ អាមេរិកដែលមានការខកចិត្តយ៉ាងខ្លាំង នៅចំពោះមុខឥរិយាបទរបស់ សម្តេច នរោត្តម សីហនុ ។ លោក ង៉ោ ឌិញ យាម ដែលបានត្រូវ បារាំងតែងតាំង ឲ្យធ្វើជានាយករដ្ឋមន្ត្រី នៅខែមិថុនាឆ្នាំ ១៩៥៤ ក្រោមការគាបសង្កត់ របស់ សហរដ្ឋ អាមេរិក ហើយដែលពុំព្រមចុះហត្ថលេខា ទៅលើកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវពុំបានរៀបចំ ឲ្យមាន ការបោះឆ្នោត





ជ្រើសតាំង រដ្ឋាភិបាល រួបរួមជាតិ ដូចការកំណត់ទុក របស់ កិច្ចព្រមព្រៀង ទីក្រុងហ្សឺណែវទេ គឺសុខចិត្ត ដើរតាមនយោបាយ របស់ អាមេរិកវិញ។ នៅពេលនោះ ប្រធានាធិបតីអាមេរិក អាយស្ហិនណូវើរ (Eisenhower) និង រដ្ឋមន្ត្រី ការបរទេស ហ្វូស្ទែរ ឌឹលឡេស (Foster Dulles) មានជំនឿថា ការបង្រួបបង្រួមជាតិ នៅវៀតណាម គ្មានអ្វីក្រៅពីការប្រគល់ប្រទេសវៀតណាមទាំងមូល ទៅឲ្យកុម្មុយនីស្តនោះទេ។ នៅប្រទេសកម្ពុជា ទោះបីសម្តេចនរោត្តម សីហនុ ខិតខំរក្សា គោលជំហរអព្យាក្រឹត យ៉ាងណាក្តី ក៏នយោបាយក្រៅប្រទេស របស់ ព្រះអង្គ ងាករេ ទៅខាងកុម្មុយនិស្ត យ៉ាងច្បាស់ដែរ ព្រោះព្រះអង្គទ្រង់ឈ្វេង យល់ថា អាមេរិក ពុំអាចយកឈ្នះ កុម្មុយនិស្តបានឡើយ ។ នៅ ថ្ងៃ ១៨ ដល់ ថ្ងៃ ២៤ មេសា ឆ្នាំ ១៩៥៥ សម្តេច នរោត្តម សីហនុ បានយាងទៅចូលរួមក្នុងសន្និសីទ ទីក្រុងបាងឌុង (Bangdung) ដើម្បីបង្កើត មាគ៌ានយោបាយ «មិនចូលបក្សសម្ព័ន» (M.N.A.) ។ ព្រះអង្គបានជួប វរជន សំខាន់ៗ ដូចជា ជូអេនឡាយ (Chou En Lay), នេហរុ (Nérhu), ទីតូ (Tito), ណាស្សែរ (Nasser) ជាដើម។ នៅថ្ងៃ ១៣ កុម្ភៈឆ្នាំ ១៩៥៦ ព្រះអង្គបានយាង ទៅប្រទេសចិន ប្រជាមានិត ។ នៅចុងឆ្នាំ ១៩៥៦ ដដែលនោះ ព្រះអង្គបានយាងទៅជួប លោក ទីតូ នៅប្រទេសយូហ្គោស្លាវី (Yougoslavie) ទៀត។ ទោះជាយ៉ាងនេះក្តី ក៏ ព្រះអង្គ នៅតែមាន ទំនាក់ទំនងមិនល្អជាមួយ គណបក្សប្រជាធិបតេយ្យ ទៀត ទោះបី នៅពេលនោះ និន្នាការឆ្វេងនិយម នៅក្នុងគណបក្សនេះ កំពុងមានឥទ្ធិពលខ្លាំងក្តី ។ នៅ ថ្ងៃ ១១ សីហា ឆ្នាំ ១៩៥៧ សម្តេច នរោត្តម សីហនុ បានបើក ការតតាំងគ្នាមួយ តាមវិទ្យុជាតិ រវាងព្រះអង្គ និង មេដឹកនាំ គណបក្ស ប្រជាធិបតេយ្យ។ ពេលចេញ ពី ការ តតាំងនោះ អ្នកប្រជាធិបតេយ្យ ៥ រូប បានត្រូវរាជង្គរក្ស របស់ សម្តេច នរោត្តម សីហនុ វាយត្រូវរបួសយ៉ាងដំណំ។ បន្ទាប់ពី អំពើហឹង្សា បានបន្តទៅទៀត អស់រយៈពេល ៣ ថ្ងៃ គណបក្សប្រជាធិបតេយ្យ ក៏បាត់ស្រមោលតែម្តងទៅ គឺនៅសល់តែ អ្នកប្រជាធិបតេយ្យខ្លះ ដែលក្រោយមក គឺ នៅឆ្នាំ ១៩៧០ បានចេញមុខ ជា អ្នកសាធារណរដ្ឋនិយម តែម្តង ។

នៅឆ្នាំ ១៩៥៨ ការប្រជែង កម្លាំងរវាងកងទ័ពវៀតមិញ និង កងទ័ព ង៉ោ ឌិន យ៉ាម នៅលើទឹកដីខ្មែរ កាន់តែស្តែងចេញឡើងយ៉ាងច្បាស់ៗ រីឯ សម្តេច នរោត្តម សីហនុ ក៏បានចាប់ផ្តើមបន្ទរ ការវាយប្រហារ ទៅលើ ចលនាកុម្មុយនិស្តខ្មែរ បន្តិចមកវិញដែរៗ មួយវិញទៀត ដោយ សមាជិករដ្ឋាភិបាល *សង្គមរាស្រ្តនិយម* មាន និន្នាការ អភិរក្សពេក ព្រះអង្គ ក៏ បែរទៅរក មនុស្សថ្មីៗ មកដាក់ជំនួស ។ ក្រោយការបោះ ឆ្នោតសកាថ្ងៃ ២៣ មិនា ឆ្នាំ ១៩៥៨ សម្តេច នរោត្តម សីហនុ ចាប់ផ្តើមជ្រើសរើស រដ្ឋមន្រ្តីដោយខ្លួនព្រះអង្គ ។ គឺ នៅពេលនោះហើយ ដែលគេឃើញលោក ហ៊ូ យន់ និង លោក ហ៊ូ នឹម ដែលជាអ្នកនិយមឆ្វេង មានមុខនៅក្នុងរដ្ឋាភិបាល លោក ប៉ែន នុត ។ ប៉ុន្តែ លោក កែវ មាស អ្នកតំណាងរាស្រ្ត កុម្មុយនិស្ត នៃ គណបក្សប្រជាជន នៅតែត្រូវប៉ូលីសរបស់ សម្តេច នរោត្តម សីហនុ ធ្វើការគាបសង្កត់បន្តមកទៀតៗ នៅពេលនោះ សម្តេច នរោត្តម សីហនុ បញ្ចេញ នូវ នយោបាយប្រឆាំង នឹង សហរដ្ឋអាមេរិក យ៉ាងខ្លាំង ប៉ុន្តែគឺនៅពេលនោះដែរ ដែលទីក្រុងវ៉ាស៊ីងតោន (Washington) ធ្វើការគាបសង្កត់យ៉ាងខ្លាំងទៅលើ សម្តេច នរោត្តម សីហនុៗ នៅ ថ្ងៃ ៨ មិថុនា ឆ្នាំ ១៩៥៨ នោះ កងវរសេនាធំ វៀតណាមខាងត្បូង បានចូលមក ក្នុងខេត្តស្ទឹងត្រែង ក្នុងជម្រៅ ១៥ គ.ម. ប៉ុន្តែ នៅថ្ងៃ ២៥ ខែ មិថុនា ដដែល ក៏ ដកថយទៅវិញៗ ការគំរាមកំហែងនេះ ពុំបានធ្វើឲ្យសម្តេច នរោត្តម សីហនុ ងាករេ ទៅរកសហរដ្ឋ អាមេរិកវិញទេៗ ទោះជាយ៉ាងនេះ ក៏ដោយ  ក៏សហរដ្ឋ អាមេរិក នៅតែខិតខំរិះរកមធ្យោបាយ ផ្សេងៗទៀត ដើម្បីកាត់បន្ថយឥទ្ធិពល របស់ កុម្មុយនិស្ត នៅក្នុងប្រទេសកម្ពុជាដែរៗ នៅឆ្នាំបន្ទាប់មកទៀត គឺ ឆ្នាំ ១៩៥៩ អាមេរិក និង រដ្ឋាភិ បាល ង៉ោ ឌិន យ៉ាម បានសម្រេចវាយរំលំសម្តេច នរោត្តម សីហនុ តែម្តងៗ នៅ ចំពោះមុខឥរិយាបទនេះ សម្តេចនរោត្តម សីហនុ បានសម្រេចចិត្ត ចាប់ដៃលោកកុម្មុយនិស្ត យកតែមែនទែន ។ នៅ ថ្ងៃ ២៤ កក្កដា ឆ្នាំ ១៩៥៨ នោះ ប្រទេសកម្ពុជា ដាក់ទំនាក់ទំនងទូត ជាមួយ ប្រទេសចិនកុម្មុយនិស្ត ប៉ុន្តែ ប៉ុន្មានសប្តាហ៍ក្រោយមក គឺនៅថ្ងៃ ១៦ សីហា ឆ្នាំ ១៩៥៨  កងទ័ព





ថៃ បានចូលមកក្នុង ប្រាសាទព្រះវិហារ ។ នៅពេលនោះ រដ្ឋាភិបាលថៃ ប្រកាសមិនទទួលស្គាល់ សន្ធិសញ្ញាឆ្នាំ ១៩០៧ ទេ គឺ ចាត់ទុកថា ព្រះវិហារ ស្ថិតនៅក្នុងទឹកដីរបស់គេៗ ដើម្បីសំដែងប្រតិកម្ម របស់ព្រះ អង្គ នៅថ្ងៃ ២៨ វិច្ឆិកា ឆ្នាំ ១៩៥៨ សម្តេច នរោត្តម សីហនុ ក៏ សម្រេចផ្តាច់ ទំនាក់ទំនងទូត ជាមួយ ទីក្រុងបាងកក ។ នៅក្នុងប្រទេសឯនេះវិញ អ្នកនយោបាយខ្មែរដែលមិនយល់ស្រប នឹងនយោបាយក្រៅប្រទេសថ្មី របស់ សម្តេច នរោត្តម សីហនុ  បាននាំគ្នា បញ្ចេញប្រតិកម្ម យ៉ាងខ្លាំង សម្បើមអស្ចារ្យៗ នៅ ថ្ងៃ ៣០ ធ្នូ ឆ្នាំ ១៩៥៨ ដដែល លោក សម សារី អតីតឯកអគ្គរាជទូតខ្មែរ ប្រចាំ ទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស បានបង្កើត សារពត៌មានប្រឆាំងមួយ មានឈ្មោះ ថា  *រាស្រ្តាធិបតី* ដើម្បីប្រមែប្រមូលអ្នកប្រជាធិបតេយ្យ បង្កើតគណបក្សប្រឆាំងៗ ប៉ុន្តែនេះ ជាបញ្ហាមួយ ដ៏ ស្មុគស្មាញ នឹង ប្រកបទៅដោយគ្រោះថ្នាក់ៗ ក្រោយនោះបន្តិច បើយោងទៅ តាមឯកសារខ្លះ លោក សម សារី បានភៀសខ្លួន ទៅទីក្រុងសាយហ្គន (Saïgon) ដែលកាលនោះ ជារដ្ឋធានី នៃ ប្រទេស វៀតណាម ខាងត្បូង ។

# ការប៉ុនប៉ង វាយរំលំ របប

# សម្តេច នរោត្តម សីហនុ នៅ ឆ្នាំ ១៩៥៩

## Tentative de renversement du régime de Sihanouk en 1959

ព្រឹត្តិការណ៍ ដែលកើតមានឡើង នៅឆ្នាំ ១៩៥៩ បញ្ជាក់ឲ្យឃើញថា នយោបាយក្រៅប្រទេសថ្មី របស់ សម្តេច នរោត្តម សីហនុ ធ្វើឲ្យ របប ង៉ោ ឌីន យ៉ាម មានការពិបាកយ៉ាងខ្លាំង ក្នុងការប្រយុទ្ធ នឹង ពួកវៀតមិញៗ នៅដើម  ឆ្នាំ១៩៥៩ នោះ

គឺនៅថ្ងៃ ១៣ មករា សម្តេច នរោត្តម សីហនុ បានប្រកាសថា នៅទីក្រុងបាងកក មានចលនាមួយ កំពុងធ្វើសកម្មភាពក្បត់ព្រះអង្គ។ លោក សម សារី ក៏បានត្រូវចោទប្រកាន់ថា បានចូលរួមចំណែកដែរ លោក សម សារី ដែល កាល ពី សម័យទាមទារឯករាជ្យ និង ពេលកសាង ចលនា *សង្គមរាស្ត្រនិយម* ជាសហការី ជិតស្និទ្ធ របស់ព្រះអង្គ សោះនោះ ។ មួយអាទិត្យក្រោយមកទៀត គឺនៅថ្ងៃ ទី ២០ មករា លោកសាំង សារ៉ាត បានត្រូវគេធ្វើឃាត ។ លោកសាំង សារ៉ាត ជាអ្នកនិពន្ធ ខ្មែរមួយរូបដែលគាំទ្រលោក សឺង ង៉ុក ថាញ់ ហើយ ដែលបានសរសេរ ប្រលោមលោកមួយមានចំណងជើងថា «*មហាចោរនៅទល់ដែន*»។ សូមកត់សំគាល់ថា គឺ នៅដើមឆ្នាំ ១៩៥៩ នោះដែរ ដែលព្រលានយន្តហោះ *ពោធិចិន្តុង* ដែលបារាំងបាន កសាងឲ្យបានត្រូវសម្ពោធ ។ នៅថ្ងៃ ១៧ កុម្ភៈ រដ្ឋាភិបាល បានត្រូវប្រគល់ ទៅថ្វាយ សម្តេច នរោត្តម សីហនុ ម្តងទៀត។ ៣ ថ្ងៃក្រោយមក ប្រទេសកម្ពុជា បានដាក់ ទំនាក់ទំនងទូតជាមួយ ប្រទេសថៃ ឡើងវិញ ដោយមាន អង្គការ សហប្រជាជាតិ ជាអន្តរការី ។ សហរដ្ឋ អាមេរិក នៅពេលនោះ បានបង្កើនសកម្មភាពរបស់គេ យ៉ាងខ្លាំងនៅកម្ពុជា។ បើយោងទៅ តាមឯកសារ ផ្សេងៗ គោលបំណង របស់ សហរដ្ឋ អាមេរិក នៅពេលនោះ គឺ វាយរំលំ សម្តេចសីហនុ តែម្តង។ នៅថ្ងៃ ២២ កុម្ភៈ គេបានដឹងថា ដាប ឈួន ហៅ ឈួន ម្ចុលពេជ្រ ដែលជាស្តេចត្រាញ់ នៅ សៀម រាប បម្រុង នឹងផ្តាច់យកខេត្តសៀមរាបទាំងមូល ដោយមាន ជំនួយពីអង្គការ *សេ អ៊ី អា* (C.I.A) និង ពី របប ង៉ោ ឌិន យាម។ ពត៌មាននេះ បានត្រូវបញ្ជាក់ បន្ថែម ទៀតនៅថ្ងៃ ៤ កក្កដា។ ឧត្តមសេនីយ៍ លន់ នល់ បានត្រូវចាត់តាំងឲ្យរៀបចំកងទ័ព ទៅចាប់ឈួន ម្ចុលពេជ្រជាបន្ទាន់ ។ នៅ ខែ វិច្ឆិកា នៅពេលដែល ឧត្តមសេនីយ៍ លន់ នល់ ចូលទៅដល់ទីក្រុងសៀមរាប ដាបឈួន បានភៀសខ្លួន បម្រុងទៅពួន នៅក្នុងព្រៃ ភ្នំគូលែន ។ ប៉ុន្តែពេលនោះ ដាប ឈួន ដើរយ៉ាងត្រដាបត្រដួស ព្រោះបាន សេពគ្រឿងញៀនច្រើនពេក ហើយ អូសយករូប *នាងបេក នាងចម* ជា របស់ស័ក្តិសិទ្ធិ ទៅជាមួយ





មិនរួច។ ដោយយល់ថា គ្រោះដល់ជីវិតរបស់ ដាប ឈួន បានមកដល់ហើយ អង្គរក្សផ្ទាល់ របស់ ដាប ឈួន ដែលទៅជាមួយ ក៏ ផ្តាច់ជីវិត ដាប ឈួន តែម្តងទៅ ។ មុនព្រឹត្តិការណ៍នេះ មានព្រឹត្តិការណ៍ ដ៏គួរឲ្យរន្ធត់មួយទៀត បានកើតឡើងនៅក្នុង ព្រះបរមរាជវាំង។ នៅ ថ្ងៃ ៣១ សីហា ឆ្នាំ ១៩៥៩ ដដែលនោះ ព្រះមហាក្សត្រ ព្រះបាទសុរាម្រិត ព្រះមហាក្សត្រីយានី កុសមៈ ព្រមទាំង សម្តេច នរោត្តម សីហនុ បាន គេចផុត ពីការប៉ុនប៉ងធ្វើឃាតដោយគ្រាប់បែកមួយគ្រាប់ ដាក់បង្កប់នៅក្នុងប្រអប់អំណោយមួយ ។ ព្រះអង្គម្ចាស់ វ៉ាគ្រីវ៉ាន់ ចាងហ្វាង ព្រះរាជវាំង ដែល ជាអ្នកបើកប្រអប់នោះ ក៏សុគត នៅពេលដែលគ្រាប់ បែកផ្ទុះឡើងហើយមនុស្ស ២ នាក់ទៀត ដែលនៅជិតនោះក៏បាត់បង់ជីវិត ជាមួយដែរ ។ ព្រឹត្តិការណ៍ ទាំង ២ ខាងលើនេះ បញ្ជាក់ឲ្យឃើញថាការវិវាទ រវាងប្លុកធំៗទាំង ២ បានជ្រៀត ចូលមកក្នុងទឹកដីខ្មែរ។ ការរក្សាជំហរ នយោបាយអព្យាក្រឹតភាព នៅក្នុងដែនប្រយុទ្ធ រវាង កុម្មុយនិស្ត និង អាមេរិក ជាការមួយដែលពុំអាចធ្វើទៅកើតឡើយ។ មួយចំណែក កម្លាំងកុម្មុយនិស្ត រំលោភទឹកដីខ្មែរ យកទៅប្រើប្រាស់ ជាកំហិត ទោះគេត្រូវប្រើមធ្យោបាយ បែបណាក្តី ។ មួយចំណែកទៀត សហរដ្ឋ អាមេរិក ជាពិសេស វៀតណាម ខាងត្បូង ត្រូវតែរាំងស្កាត់ដំណើរកងទ័ព ហូជីមិញ នៅលើទឹកដីខ្មែរឲ្យទាល់តែបាន។ តាមការពិតទៅ ទោះបី ប្រទេសកម្ពុជា ផ្អៀងទៅខាងណា ក៏ដោយ ក៏ នឹងត្រូវម្ខាងទៀត វាយប្រហារដូចតែគ្នា ។ រីឯពាក្យ មិត្តភាពគ្រាន់តែជារូបភាពទន់ភ្លន់ នៃការវាយប្រហារ តែប៉ុណ្ណោះ។ ការដែលគួរឲ្យ កត់សំគាល់ គឺថា គ្មានមហាអំណាចណា ឬ ប្រទេសណាមួយ បានគោរព លក្ខន្តិកៈអព្យាក្រឹតភាពរបស់ខ្មែរទេ នៅពេលនោះ។ នៅ ខែ កុម្ភៈ ឆ្នាំ ១៩៥៩ នោះ មេចលនា កុម្មុយនិស្តខ្មែរសៀវ ហេង លួចធ្វើការឲ្យសម្តេច នរោត្តម សីហនុ ។ គឺនៅពេលនោះហើយ ដែលជនកុម្មុយនិស្តខ្មែរ ដែលធ្វើសកម្មភាព នៅជនបទ និងជនកុម្មុយនិស្តខ្មែរ ធ្វើសកម្មភាពនៅទីក្រុងភ្នំពេញ បានត្រូវផ្តាច់ចេញពីគ្នា ព្រោះពួកអ្នកតស៊ូ នៅជនបទ បាក់បែក ខ្ចាត់ខ្ចាយ អស់ទៅហើយៗ ទោះបីសៀវ ហេង ពុំបានក្បត់ ដោយចេញមុខ នឹង ចលនា

បដិវត្តន៍ខ្មែរ ដែលដឹកនាំ ដោយ នួន ជា ឪពុកមា របស់គេក្តី ក៏ចលនា ប្រជាជនបដិវត្ត កម្ពុជា (PRPK) នៅពេលនោះ ចុះស្រុតយ៉ាងខ្លាំងដែរ។ រីឯ អៀង សារី ដែលត្រឡប់មកពីស្រុកបារាំងវិញ តាំងពីឆ្នាំ ១៩៥៧ មក ក៏បានមកចូលរួម ធ្វើសហប្រតិបត្តិការជាមួយ សាឡុត សរ នៅទីក្រុងភ្នំពេញដែរ។ ក្រុមកុម្មុយនិស្ត របស់ អៀង សារី និង សាឡុត សរ ដែលធ្វើសកម្មភាពមិនចេញមុខ នៅទីក្រុងភ្នំពេញ យល់ឃើញថា គេមិនអាចប្រឈមមុខ នឹងរដ្ឋាភិបាល របស់ ម្តេច នរោត្តម សីហនុ ដោយត្រង់ៗ បានទេ។ យុទ្ធសាស្ត្រដែលគេបានកំណត់ នៅពេលនោះ គឺ វាយបន្ទន់ជំហរ របស់ រដ្ឋាភិបាល តាមរយៈ សារព័តមាន ហើយ បញ្ចូលគ្នាគេ មកក្នុងជួរ រដ្ឋាភិបាល របស់ សម្តេច នរោត្តម សីហនុ តែម្តង។ ហេតុដូច្នេះហើយ បានជានៅឆ្នាំ ជាបន្តបន្ទាប់មកទៀត ជនកម្មុយនិស្តខ្មែរមួយចំនួន ដូចជា ហ៊ូ យន់, ហ៊ូ នឹម, ខៀវ សំផន, ចៅ សេង ជាដើម មានតួនាទី ដ៏សំខាន់ នៅក្នុងជួររាជរដ្ឋាភិបាលខ្មែរ។ ប៉ុន្តែ មុន នឹងទៅដល់ពេលនោះ សូមបញ្ជាក់ថា នៅ ថ្ងៃ ២២ កញ្ញា ឆ្នាំ ១៩៥៩ នោះ សារពត៌មាន សរសេរជាភាសាបារាំង «ឡុបសែរវ៉ាទ័រ» («l’Observateur») របស់ ខៀវ សំផន បានចេញផ្សាយ លេខទី ១ របស់គេ ។ ២ សប្តាហ៍ក្រោយមក គឺ នៅ ថ្ងៃ ៩ តុលា ណុប បូផាន់ អ្នកនិពន្ធនាយក នៃ កាសែត កុម្មុយនិស្ត «ប្រជាជន» បានត្រូវគេបាញ់សម្លាប់ ប៉ុន្តែ ទាល់តែ ២ ថ្ងៃ ក្រោយមក ទើបទទួលមរណភាព។

# សភាពការណ៍ នយោបាយ នៅឆ្នាំ ១៩៦០

## Situation politique en 1960

មុននឹងឈានទៅដល់ព្រឹត្តិការណ៍សំខាន់ៗ នៅឆ្នាំ១៩៦០ សូមបញ្ជាក់ ថា នៅក្នុងសប្តាហ៍ដែលឆ្លង ពីថ្ងៃ ៣០ កញ្ញា ទៅថ្ងៃ ៦ តុលា ឆ្នាំ ១៩៥៩ រដ្ឋាភិបាលខ្មែរ





បានដាក់ពាក្យ ប្តឹងតុលាការ អន្តរជាតិ ស្តីពី ការដែលប្រទេសសៀម បានដាក់កងទ័ព របស់គេនៅព្រះវិហារ ។ នៅខែតុលានោះ សឺន ង៉ុក ថាញ់ ដែលបានទៅតាំងទី នៅទីក្រុងសាយហ្គន (Saigon) បានផ្សព្វផ្សាយ និវេទនប័ណ្ណ ស្តីពី ការបង្កើត ចលនា «ខ្មែរសេរី» ។ នៅឆ្នាំ ១៩៥៩ មុនពេលដែលការប៉ុនប៉ង របស់ ដាប ឈួន ហៅ ឈួន ម្ជុលពេជ្រ បានទទួលបរាជ័យ មាន ព្រឹត្តិការណ៍មួយ ដែលគួរឲ្យកត់សំគាល់ផងដែរ។ នៅដើមឆ្នាំ ១៩៥៩ នោះ គឺ នៅថ្ងៃ ១ មករា សារព័តមានខ្មែរ រាស្ត្រាធិបតី របស់ លោក សម សារី បាន ចុះផ្សាយ លិខិតមួយ ដែល លោក សម សារី បានផ្ញើទៅ សម្តេច នរោត្តមសីហនុ នៅថ្ងៃ ៣០ ធ្នូឆ្នាំ ១៩៥៨ ។ នៅក្នុងលិខិតនោះ លោក សម សារី បានបញ្ជាក់ អំពីការដែល លោកបានស្នើសុំបង្កើត គណបក្សប្រឆាំងមួយ ដែលក្រៅពីរូបលោក មាន អ្នកដឹកនាំ ២ នាក់ទៀត គឺ ចៅ បូរី និង នាត ចន្ទា ។ នេះជាព្រឹត្តិការណ៍ ដ៏សំខាន់មួយ ដែលបញ្ជាក់ថា អ្នកនយោបាយខ្មែរ ដែលមាន និន្នាការសេរីនិយម ពោលគឺ ប្រឆាំង នឹង កុម្មុយនិស្ត បញ្ចេញប្រតិកម្មយ៉ាងខ្លាំងចំពោះ នយោបាយក្រៅប្រទេសថ្មី របស់សម្តេច នរោត្តម សីហនុ ។ ប៉ុន្តែលោក សម សារី នៅពេលនោះ ត្រូវប្រឈមមុខ នឹង បញ្ហា ២ គឺ មួយចំណែក លោក ក្លាយទៅ ជា គូប្រជែង របស់ លោក សឺន ង៉ុក ថាញ់ មេចលនា «ខ្មែរសេរី» ហើយ មួយចំណែកទៀត ពុំមានលទ្ធភាព គ្រប់គ្រាន់ឡើយ ដើម្បីប្រមូលបង្អែក នយោបាយ សំខាន់ៗ នៅក្នុងប្រទេស ជាពិសេស បន្ទាប់ពីមានរឿងទំនាស់ ជាមួយសារពត៌មានមួយ ដែលបានកើតឡើង នៅទីក្រុងឡុងដ៍ នៅពេលដែលលោក ធ្វើជា ឯកអគ្គរាជទូតខ្មែរ ប្រចាំប្រទេសអង់គ្លេស ។ នៅដើមឆ្នាំ ១៩៥៩ នោះ ទោះបី លោក សម សារី ចុះផ្សាយ សេចក្តី ស្នើសុំ របស់ លោក នៅក្នុង សារពត៌មាន ក្តី ក៏សម្តេច នរោត្តម សីហនុ ទ្រង់ពុំព្រមជាដាច់ខាត។ ផ្ទុយទៅវិញព្រះអង្គ កាន់តែពង្រឹងនយោបាយ របស់ ព្រះអង្គ ថែមទៀត។ យ៉ាងណាមិញ រដ្ឋសភា ដែលបានត្រូវចាត់តាំង ក្រោយពេលបោះឆ្នោតសកា នាខែមិនាឆ្នាំ ១៩៥៨ ក៏ ពុំមាន គណបក្សប្រឆាំងដែរ ។

នៅចុងឆ្នាំ ១៩៥៩ ប្រទេសកម្ពុជារៀបចំការបោះឆ្នោតប្រជាមតិមួយស្ដី ពីការរក្សាទុកឬព្យួរទុកសិន នូវសភាតំណាងប្រជាជន នៅតាមខេត្តៗ តាមរយៈ ប្រជាមតិនោះ សភាតំណាងប្រជាជនត្រូវព្យួរទុកសិន ប៉ុន្តែពេលក្រោយបន្ទាប់មក ស្ថាប័ននេះ បាត់រហូតតែម្ដង ។ នៅដើមឆ្នាំ ១៩៦០ គឺ នៅ ថ្ងៃ ៣ មិនា រដ្ឋាភិបាលវៀតណាមខាងត្បូង ទាមទារយក កោះឆ្នេរសមុទ្រ មួយចំនួន ដូចជា កោះ ថ្មី, កោះ សេះ, កោះអន្ទាយ, កោះតាកែវ និង កោះពោរ ។ គឺនៅឆ្នាំ ១៩៦០ នោះដែរ ដែលកំពង់ផែក្រុងព្រះសីហនុ បានត្រូវសម្ពោធ។ កំពង់ផែនោះជាអំណោយរបស់បារាំង ដែលខិតខំធ្វើយ៉ាងណា ជួយកុំឲ្យប្រទេសកម្ពុជា រណបនឹង កំពង់ផែ នៅវៀតណាមខាងត្បូង។ ព្រឹត្តិការណ៍សំខាន់មួយទៀតនៅឆ្នាំ៦០នោះ គឺការចូលជីវង្គត នៃ ព្រះមហាក្សត្រខ្មែរ ព្រះបាទនរោត្ដម សុរាម្រិត នៅថ្ងៃ ៣ មេសា។ នេះជាបញ្ហាមួយ ដ៏ ចម្រូងចម្រាស។ នៅថ្ងៃ ៩ មេសា រដ្ឋសភា បានតែងតាំងក្រុមប្រឹក្សារាជានុសិទ្ធិ ដើម្បីដោះស្រាយការស្នងរាជ្យ។ សម្ដេចនរោត្ដម សីហនុ ទ្រង់ពុំព្រមទទួលភារកិច្ច ជា ព្រះមហាក្សត្រទេ ព្រោះព្រះអង្គចង់មាន តួនាទី ជាប្រមុខរដ្ឋវិញ គឺអ្នកតំណាងស្ថាប័នមួយ ដ៏ខ្ពស់ដែលពុំមានចែងសោះ នៅក្នុងរដ្ឋធម្មនុញ្ញ។ ខ្ញុំនឹងលើកឡើង អំពីបញ្ហានេះ នៅក្នុងចំពូកក្រោយ មួយដោយឡែក ។ ប៉ុន្តែ មុននឹងឈានទៅដល់នោះ សូមបញ្ជាក់ថា នៅថ្ងៃ ៥ មិនា តាមរយៈប្រជាមតិមួយ សម្ដេច នរោត្ដម សីហនុ បានត្រូវអ្នកបោះឆ្នោតយល់ស្របថ្វាយតួនាទី ជាព្រះប្រមុខរដ្ឋ ដល់ព្រះអង្គ ហើយនៅថ្ងៃ ១៤ មិនាឆ្នាំ ១៩៦០ ដដែលនោះ រដ្ឋសភាបានតែងតាំងព្រះអង្គ ជាប្រមុខរដ្ឋ នៃ ប្រទេសកម្ពុជាតែម្ដង។ ៦ ថ្ងៃបន្ទាប់មក សម្ដេច នរោត្ដម សីហនុ ព្រះប្រមុខរដ្ឋ នៃ ប្រទេស កម្ពុជា បានថ្លែងនៅចំពោះមុខរដ្ឋសភាថា ព្រះមាតារបស់ព្រះអង្គគឺព្រះមហាក្សត្រិយានីកុសមៈ ជា អ្នកតំណាង ព្រះរាជវង្ស នៃ ក្សត្រខ្មែរ ។ ក្រៅពីមានការប្រែប្រួល នៅក្នុង ស្ថាប័ននយោបាយ មាន ព្រឹត្តិការណ៍មួយចំនួន ដែលបញ្ជាក់ថា ចលនា «ខ្មែរ ក្រហម» ចាប់ផ្ដើមមានសន្ទុះមួយថ្មីទៀត ។ សម្ដេច នរោត្ដម សីហនុ ទ្រង់មានកង្វល់យ៉ាងខ្លាំង ព្រោះ



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

អ្នកដែលចេញមុខ រិះគន់ព្រះអង្គ គឺសុទ្ធតែជា បញ្ញវន្តដែលមានសញ្ញាប័ត្រធំៗ ដែលគេបានមកពីប្រទេស បារាំង។ គឺនៅពេលនោះហើយ ដែលទំនាស់មួយបានកើតឡើង រវាងអ្នកស្មោះត្រង់ នឹង សម្ដេច នរោត្ដម សីហនុ នឹង ក្រុមបញ្ញវន្ត «ជឿនលឿននិយម»។ តាមការពិតទៅ បញ្ញវន្តទាំងនោះ បានបោះយកចំណុចខ្សោយ នៃ នយោបាយ របស់ព្រះអង្គ មកលាតត្រដាង ដូចជា បញ្ហាសេដ្ឋកិច្ច ឥរិយាបថសក្ដិភូមិ របស់ នាម៉ឺនខ្មែរ ដែលចេះតែមាន បន្តមកទៀត នៅពេលមួយ ដែល របនាសម្ព័ន្ធវប្បធម៌ កំពុងវិវត្តឆ្ពោះទៅរកភាពសម័យទំនើប ទៅហើយនោះ ព្រោះនៅតាមសាលារៀន ដែលទើប នឹងបានត្រូវបង្កើតឡើង ជាន្តបន្ទាប់ នៅតាមខេត្ត-ក្រុង ឥទ្ធិពលមកពីបរទេស ក៏មានការរីកចម្រើនយ៉ាងខ្លាំងដែរ នៅក្នុងប្រទេសទាំងមូល។ នៅថ្ងៃ ១៥ សីហា ឆ្នាំ ១៩៦០ ខៀវ សំផន និង អ្នកកាសែតឆ្វេងនិយម ១៧ រូប បានត្រូវគេរបាលចាប់ខ្លួន ។ កាលនោះ រដ្ឋមន្ត្រីមហាផ្ទៃ គឺលោក គូ រុន។ ក្រោយនោះបន្តិច លោក គូ រុន បានដោះលែងអ្នកទាំងនោះ ឲ្យមានសេរីភាពវិញ ។ ប៉ុន្តែ នៅថ្ងៃនោះឯង ខៀវ សំផន បានត្រូវមនុស្សមិនស្គាល់មុខម្នាក់ ចាប់សម្រាត ខោអាវ នៅកណ្ដាលថ្នល់។ គឺ នៅឆ្នាំ ១៩៦០ នោះហើយ ដែលបក្សកុម្មុយនិស្តខ្មែរ រៀបចំកម្មវិធីថ្មីរបស់គេ ។ នៅចន្លោះ ថ្ងៃ ២៨ និង ៣០ កញ្ញា បក្ស ប្រជាជន បដិវត្ត កម្ពុជាបានបើកមហាសន្និបាតរបស់គេ គឺ អង្គប្រជុំសម្ងាត់មួយ ដែលប្រព្រឹត្តិទៅនៅក្នុងទូរទេះភ្លើងនៅ ស្ថានីយរថភ្លើង ទីក្រុងភ្នំពេញ។ គឺ នៅពេលនោះ ហើយ ដែល*បក្សប្រជាជនបដិវត្តកម្ពុជា* បានប្ដូរ ឈ្មោះ របស់គេ មកជា *បក្ស ពលករ* វិញ ។

# បញ្ហាតែងតាំងសម្តេចនរោត្តម សីហនុ ជាប្រមុខរដ្ឋ នៃប្រទេសកម្ពុជានៅឆ្នាំ ១៩៦០

## Problème relatif à la nomination du prince Norodom Sihanouk au poste de Chef de l'Etat du Cambodge en 1960

នៅខែមេសាឆ្នាំ ១៩៦០ បន្ទាប់ពី ព្រះបាទសុរាម្រិត បានចូលជីវង្គតទៅ ការបន្តរាជ្យសម្បត្តិចោទឡើងជាបញ្ហាមួយ ដ៏ស្មុគស្មាញ។ ដោយគោរពពាក្យសន្យា របស់ព្រះអង្គ កាលពីឆ្នាំ ១៩៥៥ សម្ដេច នរោត្តម សីហនុ ទ្រង់ពុំព្រមឡើងសោយរាជ្យវិញទេ។ ប៉ុន្តែ រដ្ឋធម្មនុញ្ញខ្មែរនៅពេលនោះ អនុញ្ញាតឲ្យតែរយៈពេល ៣ ថ្ងៃ ប៉ុណ្ណោះ ដើម្បីចាត់តាំងព្រះមហាក្សត្រថ្មី ។ ដោយសម្ដេចឧបយុវរាជ នរោត្តម សីហនុ ទ្រង់ពុំសព្វព្រះរាជហឫទ័យ ដាក់ព្រះមាតា របស់ ព្រះអង្គព្រះមហាក្សត្រិយានីកុសមៈ ឲ្យទទួលបន្ទុកដ៏ធ្ងន់ធ្ងរ បែបនេះ រយៈពេល ៣ ថ្ងៃ ក៏ កន្លងផុតបាត់ទៅ។ នៅ ចំពោះមុខស្ថានភាពនេះ រដ្ឋសភា ក៏ សម្រេចបង្កើត ក្រុមប្រឹក្សារាជានុសិទ្ធិមួយ ដើម្បីជំនួស ជាបណ្ដោះអាសន្នសិន។ នៅថ្ងៃ ៥ មេសា នីតិក្រមចុះ ថ្ងៃ ៤ មេសា បានត្រូវប្រកាសឲ្យប្រើ ដោយក្រមលេខ ៣៨៤ ន.ស. របស់ប្រធានរដ្ឋសភា ដែលកាន់មុខនាទី ជាប្រមុខរដ្ឋស្ដីទី នៅពេលអវត្តមាន នៃ ប្រមុខរដ្ឋ។ នីតិវិធីនេះ មានចែងយ៉ាងច្បាស់នៅក្នុងមាត្រា ៣៤ នៃ រដ្ឋធម្មនុញ្ញ ។ នីតិក្រម ថ្ងៃ ៤ មេសា បានជំរុញឲ្យមាន ការប្រែប្រួល នៅក្នុង រដ្ឋធម្មនុញ្ញ ព្រោះ គេបានបញ្ចូលមាត្រា ៣០ស្ទួន មកជាមួយ ហើយកែប្រែ អត្ថបទ មាត្រា ៣១ និង ៣៣ ។ នៅថ្ងៃ ៧ មេសា ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត ព្រះបិតុលា របស់ សម្ដេច នរោត្តម សីហនុ បានត្រូវក្រុមប្រឹក្សារាជបល្ល័ង្ក តែងតាំងជា ប្រធានក្រុមប្រឹក្សា



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

រាជានុសិទ្ធិ។ រីឯសមាជិក ២ រូបទៀត គឺ លោក ផូ ព្រឿង និង លោក ទ្រឿង កាង។ ក្រុមប្រឹក្សានោះ មានសមាជិកត្រៀម ពីររូបទៀត គឺ លោក ទេព ផន និង លោក ពីទូដឹ ម៉ុងតេរ៉ូ។ គួរកត់សំគាល់ថា ប៉ុន្មានខែ មុនពេល ដែលបញ្ហានេះ កើតឡើង គឺនៅ ខែសីហា ឆ្នាំ ១៩៥៩ សម្ដេច នរោត្តម សីហនុ បានយាងទៅ ប្រទេសវៀតណាម ខាងត្បូង ។ ការនេះ បានធ្វើឲ្យអ្នកប្រឆាំង ដែលមាននិន្នាការ កុម្មុយនិស្ត បញ្ចេញ ការមិនពេញចិត្តរបស់គេ ។ បន្ទាប់ពី បានរៀបចំរដ្ឋាភិបាលមួយថ្មីទៀត នៅថ្ងៃ ២៥ កក្កដា ឆ្នាំ ១៩៥៩ ដដែលនោះ សម្ដេច នរោត្តម សីហនុ បានសម្រេចពង្រឹង រដ្ឋាភិបាល របស់ព្រះអង្គ នៅចំពោះមុខអ្នកប្រឆាំង ទាំងសងខាង។ ព្រះអង្គ បានស្នើសុំឲ្យរដ្ឋសភា រៀបចំការបោះឆ្នោត ប្រជាមតិមួយ ដើម្បីឲ្យប្រជាជនខ្មែរ ជ្រើសរើសរវាងនយោបាយអព្យាក្រឹត របស់ ព្រះអង្គ និង អ្នកដឹកនាំស្ដាំនិយម ដូចជា លោក សឺន ង៉ុក ថាញ់ និង លោក សម សារី ជាដើម ។ នៅថ្ងៃ  ៧ តុលា ឆ្នាំ ១៩៥៩ រដ្ឋសភា យល់ព្រមរៀបចំការបោះឆ្នោតប្រជាមតិ ហើយនៅ ខែមិថុនា ឆ្នាំ ១៩៦០ ការបោះឆ្នោតប្រជាមតិ ក៏បានប្រព្រឹត្តទៅ ។ លោក សឺន ង៉ុក ថាញ់ អ្នកដឹកនាំ ចលនា «ខ្មែរសេរី» បានទទួលត្រឹម ១៣៣ សំឡេងប៉ុណ្ណោះ ។ អ្នកនិយមកុម្មុយនិស្ត ក៏បានទទួល ១៣៣ សំឡេងដែរ ប៉ុន្តែ ក្រោយមក បានសម្រេចបោះឆ្នោត ឲ្យសម្ដេច សីហនុ តែម្ដង។ ចំណែក សម្ដេច សីហនុ វិញ ព្រះអង្គទ្រង់ទទួលបាន ដល់ទៅ ២ លាន ២ ម៉ឺន ៥៤៩ សំឡេង។ នៅថ្ងៃ ១១ មិថុនា ឆ្នាំ ១៩៦០ ក្រុមប្រឹក្សារាជាណាចក្រ និង រដ្ឋសភា បានអនុម័ត  សេចក្ដីសម្រេចចិត្តមួយ សុំឲ្យសម្ដេចនរោត្តម សីហនុ ទទួលយក មុខនាទីជា ព្រះប្រមុខរដ្ឋ។ កងទ័ព និង នគរបាល បាននាំគ្នា គាំទ្រសេចក្ដីសម្រេចចិត្តនោះ យ៉ាងផុសផុល។ នៅទីក្រុងកែប ក៏ដូចជានៅទីក្រុងភ្នំពេញប្រជាជន បាននាំគ្នាធ្វើ បាតុកម្មយ៉ាងគគ្រឹកគគ្រេង ដើម្បីសំដែងការគាំទ្រ របស់គេ។ រីឯ នៅក្នុងសេចក្ដីសម្រេចចិត្ត របស់ រដ្ឋសភានោះ គេបានសំអាងថា ៖ ដោយ បញ្ហាស្នងរាជ្យ ដោះស្រាយមិនបាន នៅក្នុង កាលៈទេសៈ បច្ចុប្បន្ន គឺមានតែ ការប្រគល់អំណាចទៅឲ្យអ្នកដឹកនាំម្នាក់ ដែលមាន លក្ខណសម្បត្តិ

គ្រប់គ្រាន់ប្រកែកមិនបានតែប៉ុណ្ណោះ។ សម្តេចន រោត្តម សីហនុ ទ្រង់ទទួលយល់ព្រម ហើយនៅថ្ងៃ ១៣ មិថុនា ក្រុមប្រឹក្សារាជានុសិទ្ធិ ក៏ ប្រកាសរំសាយ។ នៅក្នុងពេល ជាមួយគ្នានោះ រដ្ឋសភា បានបើកសម័យប្រជុំ ដើម្បីពិនិត្យសេចក្តីព្រាងច្បាប់មួយដែលបន្ថែមអត្ថបទខ្លះ ជាចាំបាច់ទៅក្នុងរដ្ឋធម្មនុញ្ញ ពោលគឺមាត្រា ១២២ ថ្មី ។ រដ្ឋសភាបានអនុម័ត សេចក្តីព្រាងច្បាប់នោះ បន្ទាប់មក ក្រុមប្រឹក្សារាជាណាចក្រ ក៏បានអនុម័តទៀត។ នៅថ្ងៃ ១៤ មិនាឆ្នាំ ១៩៦០ លោក ប្រធានរដ្ឋសភា ជួប ហ៊ែល ដែលបានត្រូវតែងតាំងជា ប្រមុខរដ្ឋស្តីទី នៅពេលដែល សម្តេច នរោត្តម សីហនុ យាងទៅបរទេសប្រកាសឲ្យប្រើ នីតិក្រម ស្តីពីការបញ្ចូលអត្ថបទពិសេសថ្មីតែម្តង។ ការសំអាងនេះអាចធ្វើទៅបាន ដោយផ្អែកទៅលើមាត្រា ៣៤ ប៉ុន្តែ ក៏ព្រោះតែក្រុមប្រឹក្សារាជានុសិទ្ធិទាំងមូល បានប្រកាសរំសាយផងដែរ។ ទោះជាយ៉ាងណាក្តី ក៏គេសង្កេតឃើញថារដ្ឋធម្មនុញ្ញទាំងមូល មិនបានត្រូវពិនិត្យឡើងវិញទេ ព្រោះ មាត្រា ១១១ ចែងយ៉ាងច្បាស់ថា គេ មិនត្រូវប៉ះពាល់ ដល់របបរាជានិយមឡើយ ។ នៅក្នុងន័យនេះ គេអាចបកស្រាយបានថា របបនយោបាយ ក៏មិនអាចផ្លាស់ប្តូរបានដែរ គឺ អនុញ្ញាតឲ្យបង្កើតតែ ប្រព័ន្ធពិសេសមួយដែលស្ថានការណ៍ តម្រូវឲ្យធ្វើតែប៉ុណ្ណោះ ហើយនេះ ទម្រាំ ក្រុមប្រឹក្សារាជបល្ល័ង្ក តែងតាំង ព្រះមហាក្សត្រថ្មីសម្រាប់បន្តរាជ្យ ។ គួរកត់សំគាល់ថា ព្រះប្រមុខរដ្ឋ សម្តេច នរោត្តម សីហនុ បានស្បថថា ព្រះអង្គស្មោះត្រង់ជានិច្ច នឹង រាជបល្ល័ង្ក ហើយបន្តប្រពៃណី នៃអំណាច រាជានិយមជាដរាប។ រីឯមហាក្សត្រិយានីកុសមៈ ក៏បន្តតំណាង រាជបល្ល័ង្ក ជានិមិត្ត រូបដែរ គឺ គង់នៅក្នុងព្រះរាជវាំងបន្តទៅទៀត ។





# តុល្យភាព ដ៏ ពិបាក រវាង

# ចលនា កុម្មុយនិស្ត និង ចលនា ខ្មែរសេរី

## La corde raide : l’équilibre impossible entre le mouvement des Khmers communistes et les « Khmers Sérei »

នៅឆ្នាំ ១៩៦២-១៩៦៣ សម្តេច នរោត្តម សីហនុ បានពង្រឹង ទំនាក់ទំនងការទូតយ៉ាងជិតស្និទ្ធ ជាមួយប្រទេសចិនកុម្មុយនិស្ត ប៉ុន្តែទន្ទឹមនោះ ក៏ ប្រយុទ្ធកំចាត់ជនកុម្មុយនិស្តខ្មែរដោយឥតត្រាប្រណីដែរ។ នៅ ខែឧសភា ឆ្នាំ ១៩៦២ អ្នកដឹកនាំចលនាកុម្មុយនិស្តខ្មែរ ៣ រូប គឺ នង សួន, កែវ មាស និង ជូ ចិត្ត អ្នកនិពន្ធនាយកកាសែត «ប្រជាជន» បានត្រូវចាប់ខ្លួន ។ អ្នកកាសែតម្នាក់ទៀត នៃ សារពត៌មាន «បញ្ចសីលា» ក៏បានត្រូវចាប់ខ្លួនដែរ ព្រោះតែបានចុះផ្សាយកំណាព្យ របស់កវីបារាំងម្នាក់ នៃ សតវត្សរ៍ ទី ១៨ ដើម្បីអំពាវនាវដល់មន្ត្រីសាលាកាត់ក្តី សុំកុំឲ្យធ្វើបាបមនុស្ស តាមរបៀបសក្តិភូមិ។ នៅឆ្នាំ ១៩៦២ នោះដែរ មានព្រឹត្តិការណ៍ ២ ដែលបញ្ជាក់ថា ប្រទេសថៃ ក៏ដូច ជាប្រទេសវៀតណាម ខាងត្បូង កាន់តែគំរាមកំហែងខ្លាំងទៅៗទៅលើបូណ៌ភាពដែនដី នៃ ប្រទេសកម្ពុជា ប៉ុន្តែ ដោយសារកម្លាំង នៃ សហគមន៍អន្តរជាតិ ប្រទេសជិតខាងទាំង២ ពុំអាចឈ្លានពានទឹកដី ខ្មែរ បន្តទៅទៀតបានឡើយ។ នៅថ្ងៃ ១៥ មិថុនាឆ្នាំ ១៩៦២ ដដែល តុលាការ អន្តរជាតិ ទីក្រុង ឡា អេ (La Haye) បានកាត់ក្តីរឿង ព្រះវិហារ ឲ្យខ្មែរឈ្នះ ។ ប៉ុន្តែ នៅថ្ងៃ ២ តុលា ឆ្នាំ ១៩៦២ អ្នកតំណាងថៃនៅអង្គការ សហប្រជាជាតិ បានទាមទារយកទឹកដី បាត់ដំបង កំពង់ធំ និង សៀមរាប ពីខ្មែរ ហើយ ២៣ ថ្ងៃ បន្ទាប់មក យន្តហោះ ប្រទេសវៀត

ណាមខាងត្បូង បានទម្លាក់គ្រាប់បែកទៅលើភូមិខ្មែរជាច្រើន នៅតាមជាយដែន ព្រោះកងទ័ពវៀតកុង ប្រមាណ ៨ ម៉ឺននាក់ បានមកបោះទីតាំងជាអចិន្ត្រៃយ៍ នៅក្នុងទឹកដីខ្មែរ បន្ទាប់ពីផ្លូវលំ ហូ ជី មិញ រីកពាលដាល ពាសពេញផ្ទៃកបូព៌ា នៃ ប្រទេសកម្ពុជា។ នៅចំពោះមុខស្ថានភាពនេះ សម្ដេច នរោត្ដម សីហនុ បានខិតខំអំពាវនាវសុំឲ្យមានការធានាលក្ខន្តិកៈអព្យាក្រឹតភាព នៃ ប្រទេសកម្ពុជា ឲ្យបានត្រឹមត្រូវ។ នៅថ្ងៃ ២០ សីហា ឆ្នាំ ១៩៦២ ដដែល សម្ដេច នរោត្ដម សីហនុ បានផ្ញើសារលិខិតទៅប្រមុខរដ្ឋចំនួន ១២ ប្រទេសដើម្បីស្នើសុំឲ្យទទួលស្គាល់ និងធានា អព្យាក្រឹតភាព និង បូរណភាពដែនដីខ្មែរ។ ប្រទេសបារាំង, ប្រទេសចិន, សហភាព សូវៀត, និង ប្រទេសវៀតណាមខាងជើង បានសំដែងការគាំទ្រ របស់គេ យ៉ាងពេញទំហឹង ចំពោះសេចក្ដីស្នើនេះ ។ សូមបញ្ជាក់ថា គឺនៅបណ្ដាឆ្នាំ ១៩៦២-១៩៦៣ នោះហើយដែល សម្ដេច នរោត្ដម សីហនុ បានខិតខំកសាង ភូមិ-ឃុំ យ៉ាងសស្រាក់សស្រាំ ដើម្បីបន្ស្រាបឥទ្ធិពល ដ៏ខ្លាំងក្លានៃមនោគមវិជ្ជាកុម្មុយនិស្ត ជាពិសេស ទ្រឹស្ដី របស់ ពួកកុម្មុយនិស្តខ្មែរ ។ ការពិត នៅក្នុងជួរពួកអ្នកដឹកនាំខ្មែរកុម្មុយនិស្ត មានការប្រែប្រួលមួយ ដ៏សំខាន់ កំពុងកើតមានឡើង បន្ទាប់ពី ទូ សាមុត បាត់ខ្លួននៅថ្ងៃ ២០ កក្កដា ឆ្នាំ ១៩៦២។ ៧ ខែបន្ទាប់មក គឺ នៅថ្ងៃ ២០-២១ កុម្ភៈ ឆ្នាំ ១៩៦៣ នៅក្នុង ឱកាសមហាសន្និបាត «បក្សពលករខ្មែរ» សាឡុត ស ដែលក្រោយមក មានឈ្មោះ ថា ប៉ុល ពត បានត្រូវតែងតាំង ជាអគ្គលេខាធិការបក្ស ដោយគ្មានការបោះឆ្នោតជ្រើសតាំងអ្វីទាំងអស់។ តាមការពិត នេះជារឿងមួយពោរពេញទៅដោយអាថ៌កំបាំង ព្រោះតាមលំនាំរឿង គឺ សោ ភឹម ទេ ដែលត្រូវទទួលមុខតំណែងនេះ ។ បន្ទាប់ ពីបានទទួលមុខតំណែង ដ៏សំខាន់នេះ សាឡុត ស ហៅប៉ុល ពត បានតែងតាំង អៀង សារី, នួន ជា, សោ ភឹម និង វន វេត ជាសមាជិក គណអចិន្ត្រៃយ៍ នៃបក្ស រីឯ តា ម៉ុក ក៏បានចូលមក ជាសមាជិក នៃគណកម្មាធិការមជ្ឈិមបក្ស នៅពេលនោះ ដែរ។ ប្រការដែលគួរឲ្យកត់សំគាល់ គឺថា សាឡុត ស ហៅ ប៉ុល ពត ត្រឡប់ ពីស្រុកបារាំងវិញពុំទាន់បាន



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

៧ ឆ្នាំផង ក៏ស្រាប់តែក្លាយខ្លួនទៅជាអ្នកដឹកនាំ ចលនា កុម្មុយនិស្តខ្មែរទាំងមូលតែម្ដង។ ប្រការដែលគួរ ឲ្យកត់សំគាល់មួយទៀត គឺថា នៅពេលដែល សាឡុត ស បានទទួលមុខតំណែងនេះយុទ្ធជនកុម្មុយនិស្តខ្មែរ ដែលបានធ្វើសហការជិតស្និទ្ធជាមួយគណបក្សកុម្មុយនិស្តវៀតណាម បានចុះថយចំនួន នៅក្នុងអង្គការ សំខាន់ៗនៃចលនា។ ជាង ២ ខែបន្ទាប់មក នៅ ខែឧសភា គឺ ក្រោយ ពេលដែល លោក ប្រធានាធិបតី ប្រទេសចិន ប្រជាមានិតុ លូ ចៅ ជី មកធ្វើទស្សនកិច្ច នៅប្រទេសកម្ពុជា សាឡុត ស ហៅ ប៉ុល ពត និង អៀង សារី បានបោះបង់ ការតស៊ូ នៅទីក្រុងភ្នំពេញ ហើយរត់ចូលព្រៃបាត់ទៅ។ អ្នកទាំងពីរនាក់នេះ បានមកតាំងទីនៅកន្លែងសម្ងាត់មួយនៅជិតស្រុកក្រូចឆ្មារ ខេត្រកំពង់ចាម ហើយធ្វើសហការ ជាមួយ សោ ភឹម បន្តមកទៀត ។ សូមបញ្ជាក់ថា ទីតាំងសម្ងាត់ នោះដែលមានឈ្មោះថា «ការិយាល័យលេខ ១០០» ស្ថិតនៅ នៅពេលនោះក្នុងតំបន់ ការពារ ដ៏ម៉ឺងម៉ាត់ របស់ ពួកកុម្មុយនិស្តវៀតណាម។ ប៉ុន្តែទន្ទឹមនោះ នួន ជា និង សុន សេន ធ្វើសកម្មភាពលួចលាក់ នៅទីក្រុងភ្នំពេញ។ គឺនៅពេលនោះហើយដែល ក្រុមយកពត៌មានសម្ងាត់ របស់ ឧត្ដមសេនីយ៍ លន់ នល់ រិះរកមធ្យោបាយកាត់ផ្ដាច់ បណ្ដាញសំខាន់ៗ នៃ ពួកកុម្មុយនិស្ត នៅក្នុងចំណោមបញ្ញាជន ។ នៅ ថ្ងៃ ៨ មិនាឆ្នាំ ១៩៦៣ ដដែលនោះ សម្ដេច នរោត្ដម សីហនុ បានកោះហៅបញ្ញវន្តឆ្វេងនិយម ៣៤ រូប ដើម្បីឲ្យអ្នកទាំងនោះ រៀបចំគណរដ្ឋមន្ត្រីមួយ ។ ក្នុងចំណោម «វរជន» ទាំង ៣៤ រូបនោះ មានបញ្ញវន្តដែលមានឈ្មោះល្បី ១២ នាក់ គឺ ៖ លោក គាត ឆុន, លោក កេង វ៉ាន់សាក់, លោក ខៀវ សំផន, លោក ទេព ឈីវ ខេង, លោក ហ៊ូ នឹម, លោក ហ៊ូ យន់, លោកចៅ សេង, លោក សាឡុត ស, លោក អៀង សារី, លោក សុន សេន, លោក ជួន ប្រសិទ្ធ ,លោក ឱក សាគុន។ ប៉ុន្តែ ដោយដឹងថា ជាអន្ទាក់មួយប្រកបដោយគ្រោះថ្នាក់ អ្នកទាំង ៣៤ រូបនោះ ក៏បានប្រកែកជាដាច់ខាត។ ទោះជាយ៉ាងនេះក្ដី ក៏បញ្ញវន្ត ឆ្វេងនិយម មួយចំនួន ស្ថិតនៅក្នុងរដ្ឋាភិបាល របស់ សម្ដេចនរោត្ដម សីហនុ ស្រេចបាត់ទៅហើយ តួយ៉ាងលោក ហ៊ូ យន់ ជាដើម។ ទន្ទឹមគ្នា នឹង បញ្ហា

នេះដែរ វិទ្យុ «ខ្មែរសេរី» ដែលផ្សាយចេញពី ទឹកដីថៃ និង ពីប្រទេស វៀតណាមខាងត្បូង ថ្កោលទោស សម្ដេច សីហនុ ដោយគ្មានសំចៃ។ សូមបញ្ជាក់ថា គឺនៅឆ្នាំ ១៩៦៣ នោះហើយ ពោលគឺ នៅថ្ងៃ ១ វិច្ឆិកា ដែលមានរដ្ឋប្រហារមួយ នៅវៀតណាមខាងត្បូង វាយរំលំរបប ង៉ោ ឌីន យាម និង ប្អូនឈ្មោះ ង៉ោ ឌីន ញូ ដែលបានត្រូវគេសម្លាប់ចោលតែម្ដង ។

# ការផ្ដាច់ ជំនួយយោធា និង សេដ្ឋកិច្ច សហរដ្ឋ អាមេរិក នៅ ឆ្នាំ ១៩៦៣

## Rejet du prince Sihanouk de toutes les aides militaires et économiques des Etats-Unis en 1963

ព្រឹត្តិការណ៍ដែលកើតមានឡើងនៅឆ្នាំ ១៩៦៣ បញ្ជាក់យ៉ាងច្បាស់ថា សហរដ្ឋអាមេរិកព្រមទាំង ចលនា «ខ្មែរសេរី» បន្តវាយ ជំហរនយោបាយ របស់ សម្ដេចនរោត្តម សីហនុ ដោយឥតប្រណី ព្រោះព្រះអង្គត្រូវគេចោទប្រកាន់ថា ចូលដៃ ជាមួយពួកវៀតណាមកុម្មុយនិស។ គឺនៅពេលនោះហើយ ដែលទីក្រុងវ៉ាស៊ីងតោនកំពុងត្រៀមលក្ខណៈ ចូលទៅក្នុង តំណាក់ការទី ២ នៃ សង្គ្រាមនៅវៀតណាម ។ សូមបញ្ជាក់ថា ពីឆ្នាំ ១៩៥៦ ដល់ឆ្នាំ ១៩៦៤ សហរដ្ឋ អាមេរិក បានអនុវត្ត យុទ្ធសាស្ត្រសង្គ្រាមទ្រង់ទ្រាយតូច ប៉ុន្តែចាប់ពីឆ្នាំ ១៩៦៤គេបានកំណត់យកយុទ្ធសាស្ត្រសង្គ្រាមទ្រង់ទ្រាយធំតែម្ដង គឺ មិនត្រឹមតែប្រយុទ្ធ កំទេចកម្លាំងវៀតកុង ប៉ុណ្ណោះទេ។ នៅក្នុង





តំណាក់ការ ទី ២ នេះ សហរដ្ឋ អាមេរិក ប្រកាស វាយវៀតណាម ខាងជើងតែម្ដង ព្រោះគេយល់ថា បើគេ បង្ក្រាបវៀតណាមខាងជើង មិនបានទេនោះ គេក៏ ពុំអាចបង្ក្រាបកងទ័ពព្រៃ របស់ វៀតកុង បានដែរ ។ មុននឹង ឈាន ទៅដល់តំណាក់ការទី ២ ទីក្រុងវ៉ាស៊ីងតោន បានវាយរំលំ របប ង៉ោ ឌីន យាម ហើយ ដាក់ឧត្តមសេនីយ៍ ឌួង វ៉ាន់ មិញ ជំនួសវិញ ។ នៅឆ្នាំបន្ទាប់ គឺនៅឆ្នាំ ១៩៦៤ នៅចំពោះមុខ យុទ្ធ សាស្ត្រថ្មីរបស់ អាមេរិក ពោលគឺ សង្គ្រាមទ្រង់ទ្រាយធំ អ្នកដឹកនាំ ទីក្រុងហាណូយ ពុំបានដកថយ ឬ បន្ធូរបន្ថយ ហើយក៏បានត្រៀមលក្ខណៈ ប្រយុទ្ធ នឹង កងទ័ពអាមេរិកយ៉ាងខ្លាំងក្លាទៅវិញគឺដោយបញ្ជូលកងទ័ពជាច្រើនទៅជួយវៀតកុង នៅវៀតណាមខាងត្បូង ហើយដោយអំពាវនាវ សុំជំនួយ សម្ភារយោធាសម្រាប់ ធ្វើសង្គ្រាមសម័យទំនើប ពីប្រទេសចិនកុម្មុយនិស្ត និងពីសហភាពសូវៀត ទៀតផង។ ប្រទេសទាំង ២ នេះ ទោះបីមានទំនាស់ នឹងគ្នាក៏ដោយ ក៏បានឆ្លើយតប នឹង ការអំពាវនាវនេះដែរ ។ មុន នឹងបរិយាយ អំពីសភាពការណ៍ នៅឆ្នាំ ១៩៦៤ សូមកត់សំគាល់ថានៅ ឆ្នាំ ១៩៦៣ នៅប្រទេស កម្ពុជា មាន ព្រឹត្តិការណ៍មួយចំនួន ដែលបញ្ជាក់ថា សម្ដេច នរោត្តម សីហនុ ក៏ ត្រៀមលក្ខណៈកាត់ផ្ដាច់ទំនាក់ទំនង ជាមួយ សហរដ្ឋ អាមេរិក ដែរ។ នៅថ្ងៃ ៩ វិច្ឆិកា ឆ្នាំ ១៩៦៣ នោះ សម្ដេច នរោត្តម សីហនុ បានប្រានចោល នូវជំនួយយោធា និង សេដ្ឋកិច្ច របស់ សហរដ្ឋ អាមេរិក ហើយ ៣ ថ្ងៃ បន្ទាប់មក ចាត់តាំងព្រះរាជបុត្រ របស់ព្រះអង្គ នរោត្តម ណារ៉ាឌីប៉ូ ជាអ្នកដែលត្រូវស្នងព្រះ អង្គជាអ្នកដឹកនាំ ចលនា *សង្គមរាស្ត្រនិយម* ។ ព្រះអង្គម្ចាស់ណារ៉ាឌីប៉ូ ជាបុត្ររបស់ សម្ដេច នរោត្តម សីហនុ ជាមួយព្រះអង្គ ម្ចាស់ក្សត្រី ស៊ីសុវត្ថិ មុនីកេសាន។ នៅខែ វិច្ឆិកា ឆ្នាំ ១៩៦៣ នោះ មានព្រឹត្តិការណ៍ ២ ទៀត ដែលគួរឲ្យកត់សំគាល់ គឺ ឃាតកម្ម ដ៏អាថ៌កំបាំង ផ្ដាច់ជីវិត លោកប្រធានាធិបតី សហរដ្ឋ អាមេរិក យ៉ូន កិណ្ណឺឌី នៅថ្ងៃ ២២ វិច្ឆិកា និង ការកាត់ទោសប្រហារជីវិតខ្មែរសេរី ឈ្មោះ ព្រាប អ៊ិន ។ លោក អ៊ិន តាំ ដែលកាលនោះ ជាអភិបាលខេត្តតាកែវ បានជួយសុំឲ្យ ព្រាប អ៊ិន ចូលមកក្នុងប្រទេស

កម្ពុជា ដោយថែមទាំងមាន ការអនុញ្ញាតិពី នាយករដ្ឋមន្ត្រី នរោត្តម កន្តុល ទៀតផង។ ទោះជាយ៉ាងនេះក្តី ក៏ ព្រាប អ៊ិន បានត្រូវគេប្រហារជីវិត ជាសាធារណៈ នៅត្រពាំងក្រឡឹងដែរ។ នេះជាបទពិសោធន៍មួយដ៏ជូរចត់បំផុត សម្រាប់អ្នកនយោបាយខ្មែរ ហើយដែលប្រវត្តិវិទូ បានចារទុកនៅក្នុងទំព័រប្រវត្តិសាស្ត្រ ទុកជាមេរៀន។ នៅចុងឆ្នាំ ១៩៦៣ ដដែលនោះ សម្តេច នរោត្តម សីហនុ បានត្រូវអ្នកនយោបាយខ្មែរ ដែលប្រឆាំង នឹងកុម្មុយនិស្ត រិះគន់យ៉ាងខ្លាំង។ លោក ឌុក រ៉ាស៊ី ទិតៀននយោបាយ សេដ្ឋកិច្ច របស់ព្រះអង្គ រហូតដល់ព្រះអង្គទ្រាំតទៅទៀតលែងកើត ។ ទោះជាយ៉ាងនេះក្តី ក៏ព្រះអង្គខិតខំរក្សាទុករដ្ឋាភិបាលចម្រុះ ដឹកនាំ ដោយព្រះអង្គម្ចាស់ នរោត្តម កន្តុល បន្តមកទៀតដែរ គឺ រដ្ឋាភិបាល ដែលបានត្រូវតែងតាំងនៅខែតុលាឆ្នាំ ១៩៦២ ។ នៅទីបំផុត រដ្ឋាភិបាលចម្រុះ របស់ព្រះអង្គម្ចាស់ នរោត្តម កន្តុល បានត្រូវរុះរើ នៅថ្ងៃ ២៥ ធ្នូឆ្នាំ ១៩៦៤ ដើម្បីដកសមាជិកឆ្វេងនិយមសំខាន់ៗ ចេញហើយ យកអ្នកស្តាំនិយម មកជំនួសវិញ ។ នៅក្នុងរដ្ឋាភិបាលទី ១ របស់ ព្រះអង្គម្ចាស់ នរោត្តម កន្តុល ខៀវ សំផន និង ហ៊ូ យន់ មានតួនាទី ដ៏សំខាន់ ។ ខៀវ សំផន នៅពេលនោះ បានខិតខំរៀបចំ សេដ្ឋកិច្ចខ្មែរ ដោយយកចិត្តទុកដាក់ ជាទីបំផុត ជាហេតុធ្វើឲ្យអ្នកខ្លះ ជឿងចូលថា ហេតុដូចម្តេចបាន ជាខៀវ សំផន បែរជាទៅជួយ របប សម្តេច នរោត្តម សីហនុ ដូច្នេះ គឺ គួរតែធ្វើយ៉ាងណា បង្ហាញឲ្យឃើញថា មានតែលទ្ធិកុម្មុយនិស្ត ប៉ុណ្ណោះ ដែលអាចដោះស្រាយបញ្ហាសង្គមខ្មែរបាន ដោយជោគជ័យ។ ការពិត ខៀវ សំផន អនុវត្ត ទ្រឹស្តី «ម្ចាស់ការ» កាត់បន្ថយឥទ្ធិពលបស្ចិមប្រទេសជាសន្សឹមៗ ប៉ុន្តែនេះក៏ជាក្រឹត្យក្រមសេដ្ឋកិច្ច ការពារផលិតផល ក្នុងប្រទេស ដ៏ត្រឹមត្រូវមួយដែរ។ ខៀវ សំផន ខិតខំ កាត់បន្ថយចំណាយសាធារណៈ ដើម្បីបន្ថយអត្រា អតិផរណា រក្សាតុល្យភាព ការនាំចេញ និងការនាំចូល ហើយដាក់អាករ យ៉ាងធ្ងន់ធ្ងរចំពោះផលិតផលល្អប្រណិតដែលនាំចូលមកក្នុងប្រទេស។ ទោះជាយ៉ាងនេះក្តី ក៏ ធនាគារ ពិភពលោក រក្សាជានិច្ចនូវការប្រុងប្រយ័ត្ន របស់ គេដែរ ព្រោះ ខៀវ សំផន បានបញ្ចូល នូវការកែទម្រង់មួយ ដែលមិនស្របទៅនឹង ក្រឹត្យក្រម



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

នៃ ការអភិវឌ្ឍន៍ នៅក្នុងគោលការណ៍ សេដ្ឋកិច្ច សេរីនិយម ពោលគឺ នយោបាយជាតូបនីយកម្ម ដែលសាកល្បង កាត់បន្ថយអំណាច ដ៏ ខ្លាំងក្លា នៃ សហគ្រិន ឯកជន។ ប៉ុន្តែនេះ ក៏ជាកត្តា នៃបរាជ័យ នៃដំណើរសេដ្ឋកិច្ច ប្រទេសទាំងមូលដែរ។ ទោះជាយ៉ាងណាក៏ដោយ ក៏ពុំមានន័យថា ការអនុវត្តន៍ គោលការណ៍ សេដ្ឋកិច្ច សេរីនិយម ជាការធានាឲ្យមាន ការរីកចម្រើន គ្រប់រចនាសម្ព័ន្ធដែរ ជាពិសេស ការរីកចម្រើន នៃ រចនាសម្ព័ន្ធសង្គម នៅក្នុងករណី ដែលពួក សហគ្រិន គ្មានទិសដៅពង្រីកនិង ធានា គុណភាព ផលិតកម្ម ក្នុងប្រទេស ដើម្បីនាំចេញ និង រក្សាតុល្យភាព ពាណិជ្ជក្រៅប្រទេស។ ទោះបី អ្នកសេដ្ឋកិច្ចសេរីនិយម បានត្រូវយកមកដាក់ ជំនួសអ្នកឆ្វេងនិយម នៅពេលក្រោយមកទៀតក្តី ក៏សេដ្ឋកិច្ចខ្មែរ នៅពេលនោះ នៅតែចុះស្រុតដដែល ។ នៅក្នុងរដ្ឋាភិបាល ទី ២ របស់ ព្រះអង្គម្ចាស់ នរោត្តម កន្តុល គឺ រដ្ឋាភិបាលដែលគ្រប់គ្រងប្រទេស ពីថ្ងៃ ២៥ ធ្នូ ឆ្នាំ ១៩៦៤ មកទល់ ថ្ងៃ ៧ ឧសភា ឆ្នាំ ១៩៦៥ លោក ហ៊ូ យន់ រដ្ឋមន្ត្រី ក្រសួងផែនការ បានត្រូវដកចេញ ហើយជំនួសដោយលោក ម៉ៅ សាយ វិញ។ ប៉ុន្តែ ខាងក្រសួងពាណិជ្ជកម្ម លោក ខៀវ សំផន បានត្រូវជំនួស ដោយ លោក សូណែម ដែលជាអ្នកឆ្វេងនិយមដូចគ្នា។

## សេដ្ឋកិច្ច ប្រទេសកម្ពុជា សម័យសង្គមរាស្ត្រនិយម

## L’Economie du Cambodge des années 60

បន្ទាប់ពីបាន ប្រានចោល ជំនួយ ផ្នែកយោធា និង សេដ្ឋកិច្ច របស់ សហរដ្ឋអាមេរិក ប្រទេសកម្ពុជា មាន ការលំបាកលំបិន យ៉ាងខ្លាំង ក្នុងការរក្សាតុល្យភាព នៃថវិកាជាតិ ជាពិសេស ក្នុងនយាបាយ លើកកម្ពស់ជីវភាព ប្រជាកសិករ ។ ដើម្បីបន្ត

នយោបាយនេះ ដែលមាន ការគាំទ្រ ពី សំណាក់ អ្នកឆ្វេងនិយម សម្តេច នរោត្តម សីហនុ បានកាត់បន្ថយ ឥណ្ឌទាន ខាងផ្នែកយោធាតែម្តង ជាហេតុធ្វើឲ្យ កងទ័ពខ្មែរ នៅពេលនោះ មានកំហឹង ដ៏មហិមា ។ ប៉ុន្តែ បន្ទាប់ពីរដ្ឋាភិបាល ទី ២ របស់ ព្រះអង្គម្ចាស់ នរោត្តម កន្តុល បានដាក់អ្នកស្តាំនិយម ឲ្យជំនួសអ្នកឆ្វេងនិយមវិញ គឺ ចាប់តាំងពី ថ្ងៃ ២៥ ធ្នូ ឆ្នាំ ១៩៦៤ មក អ្នកនយោបាយស្តាំនិយម ដែលមាន កងទ័ព ជាបង្អែក បានកាត់បន្ថយថ្លៃទិញស្រូវ ពីកសិករវិញម្តង ជាហេតុនាំឲ្យ រដ្ឋបង្ខិតបង្ខំ ប្រជាកសិករ ឲ្យបង្កើនទំហំដីធ្វើ ស្រែ ១ ជា ២ ដើម្បីលក់ស្រូវឲ្យរដ្ឋ និង ឈ្មួញផង ហើយដើម្បីចិញ្ចឹមគ្រួសារផង។ ប៉ុន្តែ ការកំហិតនេះ ជាការឥតប្រយោជន៍ ។ សម្រេចសម្រួលទៅ ខាងណា ក៏មិនពេញចិត្ត នឹង រដ្ឋាភិបាលដែរ គឺ ទាំងខាងកងទ័ព ទាំងខាងប្រជាកសិករ ។ ប៉ុន្តែ ទោះបី សម្តេច នរោត្តម សីហនុ ស្ថិតនៅក្រោមការគាបសង្កត់ របស់អ្នកនយោបាយស្តាំនិយមយ៉ាងណាក្តី ក៏ព្រះអង្គនៅតែ បន្តនយោបាយ តាមបែបសង្គមនិយម របស់ព្រះអង្គទៀត ។ អ្នកដែលមានជំនឿ ទៅលើគោលការណ៍ សេដ្ឋកិច្ច សេរីនិយម រិះគន់យ៉ាងខ្លាំងដល់ នយោបាយធ្វើជាតូបនីយកម្ម វិស័យសំខាន់ៗ នៃ សេដ្ឋកិច្ចខ្មែរ របស់ ព្រះអង្គ ជាពិសេស ការដែលព្រះអង្គ ការពារសហគ្រាសជាតិ យ៉ាងស្វិតស្វាញ នៅចំពោះមុខការប្រកួតប្រជែង របស់បរទេស ។ គេអាចនិយាយបានថា នៅពេលនោះ សម្តេច នរោត្តម សីហនុ ក៏ ដូចជា អ្នកនយោបាយ ឆ្វេងនិយមដែរ មានគោលដៅតែមួយគឺទប់ទល់ នឹង ឥទ្ធិពលរបស់បស្ចិមប្រទេសផង ហើយ លើកតម្កើងកម្រិតជីវភាព របស់ប្រជាជនផង ប៉ុន្តែ នេះជាការមួយ ដ៏ពិបាក ព្រោះថា អាចបង្កើនកម្រិតជីវភាព ប្រជាជនបាន គឺទាល់តែមានជំនួយ ពីបរទេស ជាពិសេស ពី បស្ចិមប្រទេសតែម្តង។ ប៉ុន្តែ គឺ ជំនួយពីបស្ចិមប្រទេសនេះ តែម្តង ដែល សម្តេច នរោត្តម សីហនុ និង ខៀវ សំផន មិនចង់បាន ដោយមូលហេតុ នយោបាយ ជាតិនិយម និងមនោគមវិជ្ជាកុម្មុយនិស្តផង និងការត្រូវទប់ទល់ នឹងឥទ្ធិពលបស្ចិមប្រទេសផង ហើយនៅក្នុងនោះ ការរីកចម្រើន នៃ ឥទ្ធិពល របស់ ពួក គហបតី ដែលអាច ជ្រៀតជ្រែក





ចូលក្នុងកិច្ចការ ដឹកនាំនយោបាយ ផងទៀត។ ត្រង់ចំណុចនេះ ទស្សនៈ របស់ សម្តេច សីហនុ និង ទស្សនៈរបស់ ខៀវ សំផន មិន ខុសពីគ្នាប៉ុន្មានឡើយ។ នៅក្នុង និក្ខេបបទ បណ្ឌិត ដែលមាន ចំណងជើងថា «Les difficultés d’industrialisation au Cambodge» (« *ឧស្សាហូបនីយកម្ម ដ៏ពិបាក នៃ ប្រទេសកម្ពុជា* ») ខៀវ សំផនចង់ផ្តាច់ការរណប នឹងបស្ចិមប្រទេស ហើយកសាង សេដ្ឋកិច្ចជាតិមួយ ដោយខ្លួនឯង។ ចំពោះ អ្នកសេដ្ឋកិច្ច ភាគច្រើន នេះជាការស្រមើស្រមៃមួយ ដ៏ធំ ។ នៅក្នុងការកសាងសេដ្ឋកិច្ច នៃ ប្រទេសកម្ពុជា បញ្ហាដែលស្មុគស្មាញបំផុត គឺ ការខ្វះសង្ខារណៈ និងហេដ្ឋារចនាសម័ន្ធ ដែលត្រូវការទុន សម្រាប់ធ្វើវិនិយោគ ដ៏ ច្រើនសន្ធឹកសន្ធាប់ ហើយតាមការពិតទៅ គឺមានតែ បស្ចិមប្រទេស ប៉ុណ្ណោះ ដែលអាចជួយបាន។ មួយវិញទៀតមិនត្រឹមតែ ហេដ្ឋារចនា សម្ព័ន្ធសេដ្ឋកិច្ច ដូចជាផ្លូវថ្នល់ ស្ពាន, កំពង់ផែ ប៉ុណ្ណោះទេដែលប្រទេសកម្ពុជា ត្រូវកសាងដើម្បីនាំប្រទេស ឆ្ពោះទៅរក ភាពសម័យទំនើប និងការលូតលាស់សេដ្ឋកិច្ច ។ ទន្ទឹមនោះ គេត្រូវសាងសង់ ហេដ្ឋារចនាសម្ព័ន្ធ ផ្នែកជីវភាពសង្គម ដូចជាមន្ទីរពេទ្យ និងសាលារៀនផងដែរ។ ដូច្នេះឃើញថា ការរីកចម្រើន ទាំងផ្នែកសេដ្ឋកិច្ច ទាំងផ្នែកសង្គម នៃ ប្រទេសកម្ពុជា នៅពេលនោះ បានជួប នឹង ឧបសគ្គមួយ ដ៏ធំ ។ ប៉ុន្តែ មិនមែន តែប្រទេសកម្ពុជា ប៉ុណ្ណោះទេ ប្រទេសតតិយលោក ឬប្រទេសកំពុងអភិវឌ្ឍ សឹងតែទាំងអស់ដែលស្អប់ខ្ពើម ឥទ្ធិពលបស្ចិមប្រទេស ពោលគឺលទ្ធិសេរីនិយម សេដ្ឋកិច្ច ក៏មានបញ្ហា ដូចគ្នានេះដែរ ។ រីឯ មហាអំណាចកុម្មុយនិស្តក៏គ្មានលទ្ធភាពគ្រប់គ្រាន់ សម្រាប់ជំរុញការលូតលាស់ប្រទេសទាំងនោះទៅទៀត ព្រោះតាមកាពិត គោលការណ៍សេដ្ឋកិច្ច សង្គមនិយម ជាការស្រមើស្រមៃមួយ ដ៏ធំ ដោយហេតុថា គេនាំគ្នាជឿថា សមូហភាពជាកម្លាំង រីឯបុគ្គលគឺគ្មានតម្លៃអ្វីទាំងអស់។ នៅក្នុងករណី នៃ ប្រទេសកម្ពុជា ជំនួយបរទេសមានតួនាទី ដ៏ធំ នៅក្នុងការអភិវឌ្ឍន៍ សេដ្ឋកិច្ចនៃ ប្រទេសទាំងមូល។ ក្រៅពីការសាងសង់ ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច និងសង្គមជំនួយបរទេស នៅពេលនោះ ជាកត្តាស្ថិរកម្មមួយ ដ៏ចម្បង នៃថវិកាជាតិ នៃរូបិយវត្ថុ

នៃពាណិជ្ជកម្មក្រៅប្រទេស និង ដំណើរការ នៃហិរញ្ញវត្ថុសាធារណៈ។ ជំនួយបរទេស នៅពេលនោះ ជាកត្តា នៃតុល្យភាពប្រាក់រៀល ដែលជារូបិយវត្ថុមួយ មាន លំនឹង ល្អ ប្រៀបធៀបទៅរូបិយវត្ថុ នៃ ប្រទេសជិតខាង នានា។ ជំនួយ ដែល បរទេស ផ្តល់មកឲ្យកម្ពុជា នៅពេលនោះ សុទ្ធតែជាជំនួយដែលគ្មានគ្រោះថ្នាក់។ ភាគច្រើន ជាសម្ភារបរិក្ខា និង ការសាងសង់សុទ្ធសាធ ។ តាមធម្មតា ជំនួយជារូបិយប័ណ្ណ ច្រើនតែនាំឲ្យខូចរូបិយវត្ថុ ព្រោះវាច្រើននាំទៅរក កំណើន អាត្រា អតិផរណា ។ ប៉ុន្តែ ជំនួយដែលបានត្រូវកាត់ផ្តាច់ នៅឆ្នាំ ១៩៦៣ នោះ សុទ្ធតែជាជំនួយដែលមិនប៉ះពាល់ ដល់សុខភាព នៃសេដ្ឋកិច្ចជាតិទេ។ ទោះជាមានការពិបាករក្សាតុល្យភាពថវិកា និងរូបិយវត្ថុក្តី ក៏សេដ្ឋកិច្ចខ្មែរនៅឆ្នាំ ១៩៦៤-១៩៦៥ បេះតែមានដំណើរការទប់ទល់បាន ជាពិសេស រក្សាបាននូវ ផែនការប្រាំឆ្នាំ ទី ១ របស់ សម្តេច នរោត្តម សីហនុ ដែលចាប់ផ្តើម ពីឆ្នាំ ១៩៦០ ទៅដល់ ឆ្នាំ ១៩៦៤ ។ ផែនការប្រាំឆ្នាំ ទី ១ នេះ មាន លក្ខណៈវិជ្ជមាន ល្អ ត្រឹមត្រូវ តាមវិធីសាស្ត្ររបស់វា ព្រោះគោលដៅ គឺការបង្កើន ផលិតផលក្នុងប្រទេស ក្នុងកម្រិត ៣ ភាគរយ សម្រាប់ម្នាក់ៗ និង ក្នុងមួយឆ្នាំៗ ហើយ ដើម្បីសម្រេចបាន គេបានគ្រោងទុកជាមុន នូវ បរិមាណ នៃ វិនិយោគ ដែលបែងចែកជា ២ ប្រភេទ គឺ ៣៣ ភាគរយ សម្រាប់ វិនិយោគ ឯកជន ហើយ ៦៧ ភាគរយ សម្រាប់វិនិយោគសាធារណៈ។

# បញ្ហាអព្យាក្រឹតភាព និង បូរណភាព ដែនដីខ្មែរ នៅឆ្នាំ ១៩៦៤

## Le problème de neutralité et d'intégrité territoriale khmères en 1964

នៅក្នុងឆ្នាំ ១៩៦៣-១៩៦៤ និង ឆ្នាំជាបន្តបន្ទាប់ មកទៀត សហរដ្ឋ អាមេរិក ធ្វើការគាបសង្កត់យ៉ាងខ្លាំងទៅលើ ប្រទេសកម្ពុជា ។ នៅ ថ្ងៃ ១៩ កុម្ភៈ ឆ្នាំ ១៩៦៤



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

សម្តេច នរោត្តម សីហនុ បានស្នើសុំបើកសន្និសីទ ចតុភាគីមួយ ដើម្បីការពារអព្យាក្រឹតភាព របស់ ប្រទេសកម្ពុជា។ សម្តេច នរោត្តម សីហនុ បានស្នើសុំឲ្យប្រទេសលាវ, ប្រទេស ថៃ និងប្រទេស វៀតណាម គោរពបូរណភាពដែនដីខ្មែរ។ ប៉ុន្តែ ១៧ ថ្ងៃក្រោយមក គឺនៅ ថ្ងៃ ៦ មិនា ក្រសួងការបរទេស សហរដ្ឋ អាមេរិក បែរជាគាំទ្រការទាមទារ របស់ ប្រទេសថៃ និង ប្រទេស វៀតណាមខាងត្បូងដែលជាសម្ព័ន្ធមិត្តរបស់គេទៅវិញ។ នៅថ្ងៃ ១១ មិនា បាតុកម្មមួយចំនួន បានត្រូវរៀបចំឡើងដោយអាជ្ញាធរខ្មែរ ដើម្បីថ្កោលទោស សហរដ្ឋអាមេរិក ។ បន្ទាប់មក នៅថ្ងៃ ២៦ មិនា យន្តហោះអាមេរិក និងរថក្រោះ ប្រទេសវៀតណាមខាងត្បូង ក្រោមបញ្ជាការ របស់ នាយទាហាន អាមេរិក បានកំទេច ភូមិចន្ទ្រា ហើយ ធ្វើបាបប្រជាជនខ្មែរយ៉ាងខ្លោចផ្សា។ ជាងមួយខែក្រោយមក គឺនៅថ្ងៃ ៧ ឧសភា ភូមិ តាអី នៅក្នុងខេត្តស្វាយរៀង និងភូមិធ្លក បានត្រូវកងទ័ព និង រថក្រោះ ១៣ គ្រឿង របស់កងទ័ពវៀតណាម ខាងត្បូងវាយប្រហារ ដោយឥតត្រាប្រណី។ នៅពេលនោះ សហរដ្ឋ អាមេរិក ចាត់ទុក ប្រទេសកម្ពុជាជាជម្រកមួយ ដ៏ធំ របស់ កម្លាំងតស៊ូវៀតកុង ។ នៅថ្ងៃ ៧ ឧសភានោះ ប្រទេសកម្ពុជា បានដាក់ពាក្យប្តឹងអង្គការ សហប្រជាជាតិ ជាបន្ទាន់។ នៅថ្ងៃ ១៩ ឧសភា ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហប្រជាជាតិ បានយកសំណុំរឿងនោះ មកពិនិត្យ។ ប្រទេសបារាំង ដែលជាសមាជិកនៃក្រុមប្រឹក្សា បានទាមទារឲ្យគេរកយុត្តិធម៌ ឲ្យប្រទេសកម្ពុជា។ នៅ ថ្ងៃ ២៨ ឧសភា ឆ្នាំ ១៩៦៤ ដដែល ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហប្រជាជាតិ បានបញ្ជូន បេសកជន របស់គេមកឲ្យ ពិនិត្យ ហេតុផល នៅកន្លែងកើតហេតុ ។ នៅទីបំផុត គឺនៅថ្ងៃ ៦ មិថុនា ឆ្នាំដដែល ក្រុមប្រឹក្សាសន្តិសុខ បានសម្រេច ឲ្យខ្មែរឈ្នះ គឺ ឲ្យសហរដ្ឋ អាមេរិក សងជម្ងឺចិត្ត និង ថ្លៃខូចខាតទាំងអស់ ។ នៅក្នុងពេលជាមួយគ្នានោះ ក្រុមប្រឹក្សាសន្តិសុខ បានស្នើឲ្យ រដ្ឋ និង អជ្ញាធរទាំងអស់ នៅក្នុងលោកទទួលស្គាល់ និងគោរពអព្យាក្រឹតភាព ព្រម ទាំងបូរណ៌ភាព ទឹកដីខ្មែរ។ នៅថ្ងៃ ២៤ មិនា នៅពេលដែល សម្តេច នរោត្តម សីហនុ យាងទៅធ្វើទស្សនកិច្ច នៅប្រទេសបារាំង

ឧត្តមសេនីយ៍ សាក ដឺ ហ្គោល (Charles De Gaulle) គាំទ្រយ៉ាងពេញទំហឹង នូវសេចក្តីស្នើ របស់ ប្រទេសកម្ពុជា សុំឲ្យគេទទួលស្គាល់អព្យាក្រឹត្យភាព និង បូណ៌ភាពដែនដី របស់ខ្លួន ។ បន្ទាប់ពីរឿងរ៉ាវ ទាំងឡាយខាងលើនេះ សម្តេច នរោត្តមសីហនុ ទ្រង់បានសម្រេចរឹតចំណងមិត្តភាព ជាមួយ ប្រទេសចិនតែម្តង។ ខាងសហភាព សូវៀតឯណោះ នេះ ក៏ជា ឱកាសមួយ ដ៏ ល្អដែរ សម្រាប់ពង្រឹងទំនាក់ទំនង ជាមួយប្រទេសកម្ពុជា។  នៅ ថ្ងៃ ២០ កញ្ញា ឆ្នាំ ១៩៦៤ ដដែលនោះ វិជាស្ថានបច្ចេកទេស ជាន់ខ្ពស់ ខ្មែរ-សូវៀត ដែលជាអំណោយ របស់ សូវៀត បានត្រូវសម្ពោធ ហើយមួយសប្តាហ៍ក្រោយមក សម្តេច នរោត្តម សីហនុ ក៏យាងទៅធ្វើ ព្រះរាជទស្សនកិច្ចនៅប្រទេសចិន។ គឺនៅក្នុងឱកាស នោះហើយ ដែលប្រទេសចិន បានសម្រេច ផ្តល់ជំនួយយោធា ទៅឲ្យប្រទេស កម្ពុជា ដោយគូសបញ្ជាក់បន្ថែមថា ប្រទេសចិន ត្រៀមលក្ខណៈ ជាស្រេចដើម្បី ជួយប្រទេសកម្ពុជា នៅក្នុងករណី ដែលមាន ការឈ្លានពាន ។ នៅក្នុងឱកាសទស្សនកិច្ចនោះ អ្នកតំណាងប្រទេសកម្ពុជាក៏បានធ្វើការចរចា ស្តីពី ការគោរពបូណ៌ភាពដែនដីខ្មែរជាមួយ អ្នកតំណាងរណសិរ្ស រំដោះជាតិ វៀតណាមផងដែរ ព្រោះថាទឹកដីខ្មែរ ១ ភាគ នៅ ពេលនោះ បានត្រូវ កងទ័ពវៀតកុងប្រើប្រាស់ដើម្បី ធ្វើជាលានប្រយុទ្ធរបស់ គេ។ ទោះជាយ៉ាងណាក្តី គ្មានអ្វីដែលអាចធានាថា ប្រទេសវៀតណាម កុម្មុយនិស្ត នឹង គោរពពាក្យ របស់គេបានទេ ជាពិសេសនៅក្នុងបរិបទ នៃសង្គ្រាមមួយ ដែលកំពុងឆេះយ៉ាងសន្ធោសន្ធៅ នៅក្នុង តំបន់ឥណ្ឌូចិនទាំងមូល ។ នៅថ្ងៃ ២០ តុលា ឆ្នាំ ១៩៦៤ ដដែលនោះ យន្តហោះអាមេរិកបានទម្លាក់គ្រាប់បែកទៅលើភូមិ អន្លង់ ក្រែស នៅក្នុងខេត្រកំពង់ចាម បណ្តាលឲ្យប្រជាជនខ្មែរ ៨ នាក់បាត់បង់ជីវិត ។ ៤ ថ្ងៃក្រោយ មក ប៉ុស្តិ៍ នៅដាក់ដាំ នៅក្នុងខេត្ត មណ្ឌលគិរី បានត្រូវឧទ្ធម្ភាគចក្រអាមេរិក បាញ់រះ ដោយឥតត្រាប្រណី ។ សូមបញ្ជាក់ដែរថា កងទ័ពវៀតកុង ដែលបន្ត បន្តប់ខ្លួនពាសពេញផ្ទៃកបូពា៌ នៃ ប្រទេស កម្ពុជា បានត្រូវកងទ័ពអាមេរិក និង កងទ័ពវៀតណាម ខាងត្បូងដេញតាមកំទេច យ៉ាងសាហាវ ប៉ុន្តែ អ្នកទទួលរងគ្រោះ គឺ ប្រជាជនខ្មែរ ទៅវិញទេ។





នៅ ក្នុងបរិបទ នៃសង្គ្រាមនេះ បើប្រទេសកម្ពុជារុញច្រានទ័ពវៀតណាម កុម្មុយនិស្ត ឲ្យចេញផុតពី ទឹកដីខ្មែរមិនបានទេ ប្រទេសកម្ពុជា នឹងក្លាយទៅជា សមរភូមិមួយ ដ៏ធំរវាង មហាអំណាច មនោគមវិជ្ជាទាំង ២ ។ ប៉ុន្តែ ប្រទេសកម្ពុជា គ្មានមធ្យោបាយ អ្វីដើម្បីបណ្តេញ កងទ័ពវៀតកុងទាល់តែសោះ ។ ម្យ៉ាងទៀត ប្រទេសកម្ពុជា បានជ្រើសរើសយក លោកកុម្មុយនិស្ត ធ្វើជាបង្អែកទៅហើយ។ គឺ ដោយហេតុ នេះហើយ បានជាការចរចាផ្សេងៗ រវាងប្រទេសកម្ពុជា និង ប្រទេសវៀតណាមខាងជើងស្តីពី បញ្ហាបូណ៌ភាពដែនដី បានក្លាយទៅជា រឿងកំប្លែងទាំងអស់។ នៅទីបំផុត នៅថ្ងៃ ៣ ឧសភា ឆ្នាំ ១៩៦៥ ប្រទេសកម្ពុជា គ្មានជម្រើសអ្វីទៀត ក្រៅពីផ្តាច់ទំនាក់ទំនងទូត ជាមួយ សហរដ្ឋអាមេរិកទេ។ គឺ នៅឆ្នាំ ១៩៦៥ នោះហើយ ដែលសាឡុត ស, កែវ មាស និង អ្នកដឹកនាំខ្មែរកុម្មុយនិស្ត នានាឯទៀត បានចាកចេញពី «ការិយាល័យ លេខ១០០» ដើម្បីធ្វើដំណើរ ទៅទីក្រុងហាណូយ ប៉េកាំង និង ព្យុងយ៉ាង តាមផ្លូវលំ ហូ ជីមិញ។ ដំណើរនេះមាន រយៈពេល ៩ ខែ ។

## ទីបញ្ចប់ នៃ អព្យាក្រឹតភាព របស់ ប្រទេសកម្ពុជា នៅឆ្នាំ ១៩៦៥

## 25 novembre 1965 : la neutralité khmère tire à sa fin

ចាប់តាំងពីថ្ងៃ ២៧ កញ្ញាឆ្នាំ ១៩៦៤ មក គឺចាប់ពីព្រះរាជទស្សនកិច្ចរបស់ សម្តេច នរោត្តម សីហនុ នៅទីក្រុងប៉េកាំង អព្យាក្រឹតភាព នៃ ប្រទេសកម្ពុជា បានត្រូវប៉ះពាល់ជាទម្ងន់។ នៅក្នុងឱកាសទស្សនកិច្ចនោះ ព្រះប្រមុខរដ្ឋ នៃប្រទេសកម្ពុជា

*បានទទួលការធានាជាមូលដ្ឋាន ពីសំណាក់ ប្រទេសចិនប្រជាមានិតុ និង ពីសំណាក់ «រណសិរ្សរំដោះ ប្រទេសវៀតណាមខាងត្បូង» ។ នៅពេលនោះ ប្រទេសចិន ប្រជាមានិតុ បានផ្តល់ការគាំទ្រ ផ្នែកយោធា របស់គេទៅឲ្យប្រទេសកម្ពុជា ក្នុងករណីដែលមានការឈ្លានពាន។ រីឯរណសិរ្សរំដោះជាតិ របស់ វៀតកុង ក៏ សន្យាថា នឹង គោរពបូណ៌ភាពដែនដីខ្មែរដែរ។ មួយឆ្នាំក្រោយមក គឺ នៅខែមិថុនា ឆ្នាំ ១៩៦៥ ប្រទេស វៀតណាមខាងជើង បានសាកល្បងប្រើ ចលនា កុម្មុយនិស្តខ្មែរ ឲ្យប្រយុទ្ធ នឹង សហរដ្ឋអាមេរិក ជាមួយខ្លួនថែមទៀត។ គឺនៅខែមិថុនា ឆ្នាំ ១៩៦៥ នោះហើយ ដែលសាឡុត សរ, កែវ មាស និង អ្នកដឹកនាំ ចលនា កុម្មុយនិស្តខ្មែរមួយចំនួន បានធ្វើដំណើរតាមផ្លូវលំ ហូ ជីមិញទៅកាន់ ទីក្រុងហាណូយ។ នៅទីក្រុងហាណូយ សាឡុត សរ និង កែវ មាស បានជួប នឹងខ្មែរម្នាក់ដែលជាជនកុម្មុយនិស្តឥណ្ឌូចិន ឈ្មោះ កែវ មុន្នី។ កែវ មុន្នី ស្ថិតនៅ ទីក្រុងហាណូយ តាំងពី ឆ្នាំ ១៩៥៤ មក។ នៅក្នុងឱកាស ពេលស្នាក់អាស្រ័យនៅទីក្រុងហាណូយ សាឡុត សរ និង កែវ មាស បានធ្វើការចរចា ជាសម្ងាត់មួយ ជាមួយ ឡេ យ៉ន* (Le Duon) *ប៉ុន្តែ ការចរចានោះ ពុំបានធ្វើឲ្យ សាឡុត សរ មានទស្សនៈសុទិដ្ឋិនិយម ចំពោះ ចលនា កុម្មុយនិស្តខ្មែរទេ។ ក្រោយការចរចានោះ សាឡុត សរ បានធ្វើដំណើរទៅទីក្រុងប៉េកាំង ហើយ បានជួបពិភាក្សាជាមួយ ម៉ៅ សេ ទុង, លីវ ជី និង តេង ស៊ាវ ពីង ។ សាឡុត សរ ដែលក្រោយមកមានឈ្មោះថា ប៉ុល ពត បានស្នាក់អាស្រ័យនៅប៉េកាំង អស់រយៈពេល ២ ខែ មុននឹងធ្វើដំណើរ ទៅទីក្រុងព្យុងយ៉ាង ប្រទេសកូរ៉េខាងជើង ។ នៅពេលដែលសម្តេច នរោត្តម សីហនុ យាងទៅទីក្រុងប៉េកាំង និង ទីក្រុងព្យុងយ៉ាង ព្រះអង្គពុំបានដឹងថា សាឡុត សរ ស្ថិតនៅទីនោះដែរទេ ។ និយាយ ពីទីក្រុងម៉ូស្គូ ឯនោះវិញ កាលបើដឹងថា សម្តេច នរោតម សីហនុ មានទំនាក់ទំនង ជិតស្និទ្ធ ជាមួយចិនប្រជាមានិតុ ក៏មានការទោមនស្សយ៉ាងខ្លាំង ព្រោះនៅពេលនោះ ប្រទេសចិន ប្រជាមានិតុ និងសហភាព សូវៀត ទាស់ទែងគ្នាយ៉ាងខ្លាំង។ នៅថ្ងៃ ៨ តុលា ឆ្នាំ១៩៦៥ ដដែលនោះ នៅពេលដែល សម្តេច នរោត្តម សីហនុ*





*បម្រុងយាងទៅ សហភាព សូវៀត / ទីក្រុងម៉ូស្គូ ក៏លុបទស្សនកិច្ច របស់ព្រះអង្គចោលតែម្តង។ នៅថ្ងៃ ១៥ តុលា ឆ្នាំ ១៩៦៥ នោះ កងទ័ព សហរដ្ឋ អាមេរិក ធ្វើការវាយប្រហារទៅលើភូមិខ្មែរ បាជូ គឺភូមិ ១ ដែលស្ថិតនៅក្នុងខេត្តស្វាយរៀង បណ្តាលឲ្យមនុស្ស ៧ នាក់ បាត់បង់ជីវិត ។ ជាងមួយខែក្រោយព្រឹត្តិការណ៍នេះ ឧត្តមសេនីយ៍ លន់ នល់ បានចុះហត្ថលេខាទៅលើ សន្ធិសញ្ញាយោធាមួយ ជាមួយ មេបញ្ជាការអគ្គសេនាធិការដ្ឋានចិន។ សន្ធិសញ្ញានោះតម្រូវឲ្យ ប្រទេសកម្ពុជា ទទួលហើយ ការពារអ្នកតស៊ូ កុម្មុយនិស្តវៀតណាម នៅតាមតំបន់ ជាយដែន ហើយថែមទាំងសន្យាថា កម្ពុជា នឹង អនុញ្ញាតឲ្យប្រទេសចិន ដឹកសម្ភារយោធា ឆ្លងកាត់ ប្រទេសកម្ពុជា ទៅឲ្យអ្នកតស៊ូព្រៃ វៀតណាមផងទៀត ។ គឺ សន្ធិសញ្ញា នេះហើយ ដែលធ្វើ ឲ្យលក្ខន្តិកៈអព្យាក្រឹតភាព តាមផ្លូវច្បាប់ របស់ ខ្មែរ ក្លាយទៅជា គ្មានន័យអ្វីទៀត ទាំងអស់ គឺបាត់បង់ សុពលភាពទាំងស្រុង។ មិនតែប៉ុណ្ណោះសោត មានកិច្ចព្រមព្រៀងសម្ងាត់ មួយទៀត រវាងសម្តេច នរោត្តម សីហនុ និង ពួកវៀតណាមកុម្មុយនិស្ត ។ តាមរយៈកិច្ចព្រមព្រៀងសម្ងាត់នោះ កងទ័ពខ្មែរ អាចរក្សាទុក ១០ ភាគរយ នៃ ជំនួយយោធា ដែលប្រទេស ចិនត្រូវផ្តល់ ទៅឲ្យចលនាកុម្មុយនិស្ត វៀតណាម ។ គឺ តាំងពីពេលនោះមក ហើយដែលសហរដ្ឋអាមេរិក ចោទប្រទេសកម្ពុជាថា បានផ្តល់ជម្រក ទៅឲ្យ ពួកតស៊ូវៀតកុង។ ចាប់តាំងពីថ្ងៃ ២១ ធ្នូ ឆ្នាំ ១៩៦៥ នោះមក អាជ្ញាធរ យោធាអាមេរិកាំង បានបញ្ជាឲ្យធ្វើការវាយប្រហារ ទៅលើប្រទេសកម្ពុជាតែម្តង ។ នៅឆ្នាំបន្ទាប់មក គឺនៅខែមករាឆ្នាំ ១៩៦៦ វៀតណាមខាងជើង បានបង្កើតអង្គភាពយោធាមួយ ដើម្បីបង្ហាត់ហ្វឹកហ្វឺន កងទ័ពព្រៃខ្មែរ។ អង្គភាពយោធានោះ ដែលមានឈ្មោះថា ប៉េ ៣៦* (P 36) *បានត្រូវដាក់ ឲ្យស្ថិតនៅក្រោម ការគ្រប់គ្រងផ្ទាល់ របស់ ឡែ ដឹក ថូ ។ ២ - ៣ ខែបន្ទាប់មក គឺចាប់តាំងពីថ្ងៃ ១៩ មិនា សហភាព សូវៀត ចាប់ផ្តើមបញ្ជូន ជំនួយយោធាទៅឲ្យ ប្រទេសកម្ពុជា ។ គួរកត់សំគាល់ផងដែរថា នៅពេលនោះ កងទ័ពខ្មែរ ក៏បានដេញរុញច្រាន កងទ័ពថៃដែលចូលមកព្រះវិហារ ឲ្យដកថយទៅវិញ ។ កងទ័ពថៃ ដែល*

ចូលមក ព្រះវិហារ នៅថ្ងៃ ៣ មេសា បានត្រូវកងទ័ពខ្មែរ ដេញទៅវិញអស់ នៅថ្ងៃ ៦ មេសា ។

# ជ័យជំនះ របស់ អ្នកអភិរក្សនៅ ក្នុងការបោះឆ្នោតសភា ឆ្នាំ ១៩៦៦

## La victoire des conservateurs aux législatives de 1966

បន្ទាប់ពី បានចុះហត្ថលេខា ទៅលើ សន្ធិសញ្ញាយោធា ជាមួយប្រទេសចិនប្រជាមានិត្ត នៅថ្ងៃ ២៥ វិច្ឆិកា ឆ្នាំ ១៩៦៥ ប្រទេសកម្ពុជា បានវិវត្តឆ្ពោះទៅរក ស្ថានភាពនយោបាយមួយថ្មីទៀត។ សម្ដេចនរោត្ដម សីហនុ ហាក់បីដូចជា មាន ការនឿយណាយ យ៉ាងខ្លាំង នៅចំពោះមុខ ការរិះគន់របស់អ្នកនយោបាយស្តាំនិយម ។ មួយវិញទៀត មិត្តភាព ជាមួយទីក្រុងប៉េកាំង ក៏ហាក់បីដូចជា កំពុងតែប្រែក្លាយ ប្រទេស កម្ពុជា ឲ្យទៅជាលានប្រយុទ្ធមួយដ៏ធំ តទល់នឹង សហរដ្ឋ អាមេរិក ផងទៀត។ នៅឆ្នាំ ១៩៦៦ អ្នកនយោបាយស្តាំ ដែលនិយម សហរដ្ឋ អាមេរិក ចាប់ផ្តើមធ្វើការគាបសង្កត់យ៉ាងខ្លាំង ទៅលើព្រះអង្គ ។ នៅក្នុងពេលដដែលនោះ សាឡុត សរ និង គណប្រតិភូ បក្សពលករ ដែលបានទៅធ្វើ ទស្សនកិច្ចសម្ងាត់ នៅ ទីក្រុងហាណូយ ទីក្រុងប៉េកាំង និង ទីក្រុងព្យុងយ៉ាង បានវិលត្រឡប់មក «ការិយាល័យលេខ ១០០» របស់គេ នៅ ក្រុបថ្នារវិញ។ នៅខែកញ្ញាឆ្នាំ ១៩៦៦នោះ ពេលត្រឡប់មកដល់ មូលដ្ឋានរបស់គេ «បក្សពលករកម្ពុជា» បានបើកអង្គប្រជុំ សំខាន់មួយ ដើម្បីកំណត់ កម្មវិធីប្រយុទ្ធ របស់ គេ ហើយ ដើម្បីប្រែឈ្មោះ មកជា «បក្សកុម្មុយនិស្តកម្ពុជា» (PCK) ដូច្នេះវិញ។ គឺតាំងពីពេលនោះមក ហើយដែល «បក្សកុម្មុយនិស្តកម្ពុជា» មានស្វ័យភាព របស់គេ ។ ក្រោយនោះបន្តិច នៅ





ពេលដែល សង្គ្រាមនៅវៀតណាម កំពុងឆេះសន្ធោសន្ធៅ បក្សកុម្មុយនិស្តខ្មែរ បានចាកចេញពី «ការិយាល័យលេខ១០០» នៅកំពង់ចាម ដើម្បីទៅតាំងទី នៅ រតនគិរី ផ្នែកឦសាន នៃ ប្រទេសកម្ពុជា ។ នៅថ្ងៃ ១ កញ្ញាឆ្នាំ ១៩៦៦ ដដែលនោះ ឧត្តមសេនីយ៍ សាក ដឺ ហ្គោល (Charles De Gaulle) បានអញ្ជើញ មកធ្វើទស្សនកិច្ច ជាប្រវត្តិសាស្ត្រមួយ នៅ កម្ពុជា ។ នៅក្នុងសន្ទរកថា ដ៏ ល្បីល្បាញមួយ ឧត្តមសេនីយ៍ ដឺ ហ្គោល បានគាំទ្រយ៉ាងមុឹងម៉ាត់ ដល់ សិទ្ធិស្វ័យសម្រេច របស់ ប្រជាជនដែលបានទទួលឯករាជ្យ គឺ មានន័យថា សហរដ្ឋ អាមេរិក ត្រូវតែគោរព គោលការណ៍នេះ។ នៅថ្ងៃ ១១ ខែកញ្ញាឆ្នាំ ១៩៦៦ នោះ ប្រទេសកម្ពុជា រៀបចំធ្វើ ការបោះឆ្នោតតែងតាំងអ្នកតំណាងរាស្ត្រថ្មី។ ខុសប្លែកពីពេលមុនៗ ការបោះឆ្នោត នៅពេលនោះ ហាក់បីដូចជាមាន លក្ខណៈអនាធិបតេយ្យយ៉ាងខ្លាំង គឺ អ្នកណា ក៏ ឈរឈ្មោះ ជាបេក្ខជនបានដែរ ជាហេតុធ្វើឲ្យ អ្នកមានប្រាក់កាស អាចទិញសន្លឹកឆ្នោត ដោយស្រួលបំផុត ។

ដើម្បីដណ្តើម អាសនៈ ចំនួន ៨២ បេក្ខជនដែលចុះឈ្មោះ ក្នុងបញ្ជីគណបក្ស *សង្គមរាស្ត្រនិយម* មានចំនួនដល់ ទៅ ៤១៥ រូប។ ទោះជាយ៉ាងនេះក្តី ក៏ ហ៊ូ យន់ និង ខៀវ សំផន បានជាប់ឆ្នោតសាជាថ្មីទៀតដែរ នៅក្នុងមណ្ឌលរបស់គេ ។ រីឯ លទ្ធផល គឺ ពួកអ្នកអភិរក្សនិយម បានទទួលជោគជ័យ ដ៏ច្រើនលើសលុប។ បន្ទាប់ ពីជ័យជំនះ របស់អ្នកអភិរក្សនៅក្នុងការបោះឆ្នោត ឆ្នាំ ១៩៦៦ នោះ ឧត្តមសេនីយ៍ លន់ នល់ បានត្រូវតែងតាំងជារដ្ឋមន្ត្រី ទី ១ រី ឯ លោក ស៊ឹម វ៉ា និង លោក ម៉ៅ សាយ ដែលជាអ្នកមិនពេញចិត្ត នឹង មាគ៌ានយោបាយ របស់ សម្តេច នរោត្តម សីហនុ ដែរនោះ បានត្រូវតែងតាំង ជា ឧបនាយករដ្ឋមន្ត្រី។ អ្នកអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ មិនទាន់មានមុខ ក្នុងរដ្ឋាភិបាលនោះ នៅឡើយទេ គឺ ទាល់តែ នៅក្នុង រដ្ឋាភិបាល លន់ នល់ តែងតាំងនៅថ្ងៃ ១៤ សីហា ឆ្នាំ ១៩៦៩ ហើយ ដែលបានត្រូវប្រសិទ្ធនាម ខ្លួនឯងថា «រដ្ឋាភិបាលស្រោចស្រង់ជាតិ» ទើបទ្រង់សិរិមតៈចេញមុខ។ គេអាចនិយាយបានថា នៅឆ្នាំ ១៩៦៦ នោះ ប្រទេសកម្ពុជាបានចូល ទៅក្នុងដំណាក់ ការមួយថ្មីទៀត។ ជាការពិតហើយដែលថា

ឧត្តមសេនីយ៍ លន់ នល់ នៅតែរក្សាការស្មោះត្រង់របស់លោក ចំពោះសម្តេច នរោត្តម សីហនុ ដដែល នៅពេលនោះ ប៉ុន្តែ សេចក្តីស្មោះត្រង់ក្តី ពាក្យសន្យាក្តី ពុំអាចស្ថិតស្ថិរចីរកាលបានទេ កាលណាស្ថានភាព កាលៈទេសៈ មានការប្រែប្រួលព្រោះ តាមការពិតទៅ អ្នកនយោបាយគ្រាន់តែជា ឧបករណ៍ នៃ ស្ថានការណ៍នីមួយៗ តែប៉ុណ្ណោះ ។ យ៉ាងណាមិញ អ្នកអង្គម្ចាស់ ស៊ិសុវត្ថិ សិរិមតៈ ដែលមានលំអៀង ទៅរក សហរដ្ឋ អាមេរិក នឹង ខិតខំធ្វើអ្វីៗ គ្រប់បែបយ៉ាងទាំងអស់ ដើម្បីពន្យល់ ឧត្តមសេនីយ៍ លន់ នល់ ថា អំណឹះតទៅ ស្ថានការណ៍ បានប្រែប្រួលអស់ទៅហើយ។ នៅចំពោះមុខស្ថានភាពនេះ សម្តេច នរោត្តម សីហនុ ដែលស្ថិតនៅក្រោម ការគាបសង្កត់ ដ៏ ខ្លាំងក្លាពីសំណាក់ ទីក្រុងហាណូយ ក៏ខិតខំធ្វើយ៉ាងណា ដើម្បីរក្សា នូវ អ្វីដែលព្រះអង្គ ឈ្វេងយល់ថា ជាមូលដ្ឋាន នៃអំណាច ឥទ្ធិពលរបស់ព្រះអង្គដែរ។ ដោយមានជំនឿថា កុម្មុយនិស្ត ពិតជាមានអនាគតល្អនៅឥណ្ឌូចិន ព្រះអង្គក៏បានបើកដៃ ឲ្យកងទ័ព កុម្មុយនិស្តប្រើកំពង់ផែ ព្រះសីហនុ នៅកំពុងសោមតែម្តង ព្រោះ នៅឆ្នាំ ១៩៦៧ ខាងមុខ កងទ័ពព្រៃរបស់វៀតណាមកុម្មុយនិស្ត មានគម្រោងការ រៀបចំត្រៀមលក្ខណៈវាយលុក ប្រទេសវៀតណាមខាងត្បូង នៅពេលបុណ្យចូលឆ្នាំចិនឆ្នាំ ១៩៦៨ ។ សម្តេច នរោត្តម សីហនុ មានជំនឿថា បើពួកវៀតកុង បានទទួលជ័យជំនះ ព្រះអង្គ ក៏មុខជា នឹង ចេញផុតពីការគំរាមកំហែង របស់ សហរដ្ឋ អាមេរិក ជាពុំខាន ។ មុននឹងឈាន ទៅដល់ពេលនោះ សូមបញ្ជាក់ថានៅថ្ងៃ ១៨ វិច្ឆិកាឆ្នាំ ១៩៦៦ ដដែលនោះ សម្តេច នរោត្តម សីហនុ បានចាប់ផ្តើមផ្តល់ឈ្មោះមួយថ្មីទៀត ទៅឲ្យពួកខ្មែរកុម្មុយនិស្ត។ គឺ ចាប់តាំងពីពេលនោះមកហើយ ដែលពួកខ្មែរកុម្មុយនិស្ត មានឈ្មោះថាៈ «ខ្មែរក្រហម» ។ ព្រឹត្តិការណ៍គួរឲ្យកត់សំគាល់មួយទៀត នៅចុងឆ្នាំ ១៩៦៦ នោះ គឺ ការប្រហារជីវិត លោក មធុរា និង លោក ចៅ បូរី ដែលបានត្រូវចោទប្រកាន់ថាជា «ខ្មែរសេរី»។ លោក មធុរា បានត្រូវចាប់ខ្លួន នៅថ្ងៃ ២៤ វិច្ឆិកា ហើយ លោក ចៅ បូរី នៅថ្ងៃ ២ ធ្នូ ។ អ្នកទាំងពីរ បានត្រូវ ប្រហារជីវិត នៅខែធ្នូ ឆ្នាំដដែល ។



*សុបិន និង ការពិត ភាគ ១*- Rêves et réalités –Tome 1

# *ការបះបោរ ប្រជាកសិករ*

# *នៅ សម្លូត នៅថ្ងៃ ២ មេសា ឆ្នាំ ១៩៦៧*

## Soulèvement de Samlaut en avril 1967

បន្ទាប់ពីអ្នកអភិរក្ស បានទទួលជោគជ័យ នៅក្នុងការបោះឆ្នោតសកា ថ្ងៃ ១១ កញ្ញា ឆ្នាំ ១៩៦៦ រដ្ឋាភិបាល របស់ ឧត្តមសេនីយ៍លន់ នល់ បានត្រូវតែងតាំង នៅថ្ងៃ ២៥ តុលា ឆ្នាំ ១៩៦៦ ដដែលនោះ ។ ប៉ុន្តែ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ដែលជាអ្នកប្រឆាំង នឹង នយោបាយ របស់ សម្តេច នរោត្តម សីហនុ មិនទាន់ចេញមុខនៅឡើយទេ នៅពេលនោះ។ ឧត្តមសេនីយ៍ លន់ នល់ ខិតខំធ្វើយ៉ាងណា ដើម្បីបញ្ជាក់ថា លោកនៅតែមានភក្តិភាពចំពោះ សម្តេច នរោត្តម សីហនុ ជានិច្ច រីឯ បេសកកម្មជាចម្បង របស់លោក គឺរុញច្រាន កងទ័ពវៀតកុង ឲ្យចេញផុតពី ទឹកដីខ្មែរ តែប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ក៏សម្តេច នរោត្តម សីហនុ មាន ការបារម្ភយ៉ាងខ្លាំង ខ្លាចក្រែង នយោបាយសម្ព័ន្ធភាព របស់ ព្រះអង្គ ជាមួយប្រទេសកុម្មុយនិស្ត ត្រូវរង្គោះរង្គើ ហើយប្រានព្រះអង្គឲ្យរបូតចេញពីអំណាច។ មួយវិញទៀតការ ដែលឧត្តមសេនីយ៍ លន់ នល់ បានត្រូវតែងតាំងជា នាយករដ្ឋមន្ត្រី ពុំបានធ្វើឲ្យអ្នកឆ្វេងនិយម ដូចជា លោក ហ៊ូ យន់ លោក ហ៊ូ នឹម និង លោក ខៀវ សំផន ទទួលយកបានទេ ជាហេតុ ធ្វើឲ្យមានការប្រទាញប្រទង់គ្នាមួយ យ៉ាងធំ ។ រីឯ សភាពការណ៍ នៅឆ្នាំ ១៩៦៧ មានដំណើរដូចតទៅ ៖ នៅ ថ្ងៃ ទី ៦ មករា ឆ្នាំនោះឯង សម្តេច នរោត្តម សីហនុ ទ្រង់យាងទៅប្រទេសបារាំង ហើយស្ថិតនៅទីនោះ អស់រយៈពេល ២ ខែ ។ នៅពេលអវត្តមាន របស់ សម្តេច នរោត្តម សីហនុ ឧត្តមសេនីយ៍ លន់ នល់ បាន ឲ្យកងទ័ពទិញស្រូវពីប្រជាជនដោយឲ្យថ្លៃថោកបំផុត ប្រៀបធៀបទៅថ្លៃ នៅក្នុងផ្សារ សេរី គឺ ១ ភាគ បី នៃ

ថ្ងៃស្រូវក្នុងផ្សារសេរី។ ការទិញស្រូវរបៀបនេះ បាន ជួប នឹង វិបល្លាសមួយ ដ៏ធំ ព្រោះមានពេលខ្លះ គេបានប៉ះពាល់ ដល់ជីវិត ប្រជាជន ផងទៀត។ នៅពេលនោះ កងទ័ពអាមេរិក និង វៀតណាមខាងត្បូង បានមកតាំងទី នៅ ប្រកក្រាញ នៅក្នុងខេត្តកំពង់ចាម ដោយដេញប្រជាជនខ្មែរចេញអស់ពីភូមិ។ នៅថ្ងៃ ៩ មិនា ឆ្នាំ ១៩៦៧ ដដែលនោះ សម្ដេច នរោត្ដម សីហនុ បានវិលត្រឡប់ មកកម្ពុជា វិញ ហើយ រិះគន់ នយោបាយរបស់ឧត្ដមសេនីយ៍ លន់ នល់យ៉ាងខ្លាំង។ នៅថ្ងៃ ១១ មិនា ខៀវ សំផន និង អ្នកឆ្វេងនិយម នៅក្នុងចលនា សង្គមរាស្ត្រនិយម នាំគ្នាធ្វើបាតុកម្ម យ៉ាងគគ្រឹកគគ្រេង នៅទីក្រុងភ្នំពេញ ដើម្បីទាមទារ ឲ្យឧត្ដមសេនីយ៍ លន់ នល់ លាលែងពីមុខតំណែង។ ទន្ទឹមនោះ នៅថ្ងៃ ៣០ មិនា រដ្ឋមន្ត្រី ២ រូប នៃ រដ្ឋាភិបាល របស់ លោក លន់ នល់ គឺ លោក ម៉ៅ សាយ ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រី ទំនាក់ទំនងសេដ្ឋកិច្ច ព្រមទាំង លោក ឌុក រ៉ាស៊ី រដ្ឋលេខាធិការក្រសួង ផែនការ បានត្រូវរដ្ឋសភា ដេញដោលចាប់ថ្នាក់អំពីនយោបាយ សេដ្ឋកិច្ច របស់ រដ្ឋាភិបាល ។ ២ ថ្ងៃក្រោយមក ស្រាប់តែមាន ការបះបោរមួយនៅសំឡូត។ នេះជាព្រឹត្តិការណ៍មួយ ដ៏សំខាន់ ដែលធ្វើឲ្យ សម្ដេច នរោត្ដម សីហនុ ត្រូវប្រឈមមុខ នឹងសត្រូវ ២ តែម្ដង ។ ព្រឹត្តិការណ៍បះបោរ ប្រជាកសិករ នៅសំឡូត ក្នុងខេត្ត បាត់ដំបង នៅថ្ងៃ ២ មេសាឆ្នាំ ១៩៦៧ បានធ្វើឲ្យ សម្ដេច នរោត្ដម សីហនុ យល់យ៉ាងច្បាស់ថា ពួកខ្មែរកុម្មុយនិស្ដ ដែលព្រះអង្គហៅថា «ខ្មែរក្រហម» ត្រៀមលក្ខណៈ ជាស្រេច ដើម្បីវាយរំលំ របបសង្គមរាស្ត្រនិយម របស់ ព្រះអង្គ។ គេសង្កេតឃើញម៉្យាង ទៀតថា សម្ដេច នរោត្ដម សីហនុ មិនត្រឹមតែ វាយប្រហារ ទៅលើពួកខ្មែរកុម្មុយ និស្ដប៉ុណ្ណោះទេ តែព្រះអង្គ ក៏ដាក់ទោសយ៉ាងធ្ងន់ធ្ងរទៅលើជន ដែលព្រះអង្គតែងតែហៅថា «ខ្មែរសេរី» ផងដែរ។ នៅថ្ងៃ ២២ មេសា ឆ្នាំ ១៩៦៧ សៅ ង៉ុយ បានត្រូវគេប្រហារជីវិត។ នៅថ្ងៃ ១៣ ឧសភា «ខ្មែរសេរី» ពីររូបទៀត ក៏ត្រូវប្រហារជីវិត ដូច ព្រាប អ៊ិន, មធុរា, ចៅ បូរី និង សៅ ង៉ុយ ដូចគ្នាដែរ។ នៅថ្ងៃ ២២ មេសា ព្រះអង្គចោទប្រកាន់ ហ៊ូ យន់, ហ៊ូ នឹម និងខៀវ សំផន ថាជាអ្នកបង្កើត «ព្រឹត្តិ



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

ការណ៍សំឡូត» ហើយគំរាមកំហែងជាសាធារណៈថា នឹង បញ្ជូនអ្នកឆ្វេងនិយម ទាំង ៣ រូបនោះ ទៅឲ្យតុលាការសឹកកាត់ទោស។ នៅថ្ងៃ ២៤ មេសា ហ៊ូ យន់ និង ខៀវ សំផន រត់ចូលព្រៃតែម្ដង ។ នៅថ្ងៃនោះឯង អ្នកតំណាងរាស្ត្រអភិរក្សស្ដាំនិយម បាននាំគ្នាដកអភ័យឯកសិទ្ធិ ពីលោក ហ៊ូ នឹម ប៉ុន្តែ ជាការឥតប្រយោជន៍ ជាហេតុធ្វើ ឲ្យឧត្ដមសេនីយ៍ លន់ នល់ លាលែងពី មុខតំណែងនាយករដ្ឋមន្ត្រី នៅថ្ងៃ ៣០ មេសា ឆ្នាំ ១៩៦៧ ដដែលនោះ។ មុខតំណែងនេះ បានត្រូវប្រគល់ទៅថ្វាយសម្ដេច នរោត្ដម សីហនុ វិញ ។ នៅក្នុងរដ្ឋាភិបាលនេះ សម្ដេច នរោត្ដម សីហនុ ទ្រង់ បានតែងតាំង លោក សឺន សាន ជា ឧបនាយករដ្ឋមន្ត្រី ជំនួសលោក ម៉ៅ សាយ ហើយ តែងតាំង ឧត្ដមសេនីយ៍ ដួង សំអុល ជារដ្ឋមន្ត្រីការពារប្រទេស ជំនួសលោក ឱប គឹម អាង ។ ខាងសេដ្ឋកិច្ច លោក ចៅ សេង និង លោក ទូច គឹម ជំនួសលោក ម៉ៅ សាយ និង លោក ឌុក រ៉ាស៊ី ។ នៅក្នុង ជួររដ្ឋលេខាធិការ លោក គាត ឈុន បានត្រូវតែងតាំង ជារដ្ឋលេខាធិការសេដ្ឋកិច្ចជាតិ ទទួលបន្ទុកខាងឧស្សាហកម្ម។ នៅឆ្នាំ ១៩៦៧ នោះ គឺ នៅខែមិថុនា លោក ជា ស៊ីម និង លោក ហេង សំរិន បានចូលទៅក្នុងជួរ អ្នកតស៊ូ កុម្មុយនិស្ដ នៅក្នុងព្រៃ រីឯពួកវៀតកុង ក៏បានបើក ការិយាល័យតំណាងរបស់ គេ នៅទីក្រុងភ្នំពេញ នៅខែមិថុនា ឆ្នាំ ១៩៦៧ នោះដែរ ពោលគឺ នៅថ្ងៃទី ២២ មិថុនា ប៉ុន្តែ ២ ថ្ងៃក្រោយមក គឺ នៅថ្ងៃទី ២៤ មិថុនា បានឈានទៅដល់កម្រិតស្ថាន ទូតតែម្ដង។ នៅពេលនោះនិស្សិតខ្មែរធ្វើសកម្មភាពប្រឆាំង នឹង អ្នកអភិរក្សស្ដាំនិយម យ៉ាងខ្លាំង ។ នៅថ្ងៃ ២៨ មិថុនា និស្សិតខ្មែរដែលមាន អ្នកឆ្វេងនិយមគាំទ្រ បាននាំគ្នា វាយកំទេច ទីស្នាក់ការ កាសែត «ខ្មែរឯករាជ» របស់លោក ស៊ឹម វ៉ា យ៉ាងព្រៃផ្សៃ។ គឺ នៅក្នុងរដ្ឋាភិបាល របស់ សម្ដេច នរោត្ដម សីហនុ នាឆ្នាំ ៦៧ នេះហើយ ដែល កម្មវិធី «ខេមរយានកម្ម » បានត្រូវរៀបចំឡើងជាលើកដំបូងបង្អស់ រីឯ រដ្ឋមន្ត្រី អប់រំជាតិ នៅពេលនោះ គឺ លោក វ៉ាន់ មូលីវ៉ាន ់។ នៅក្នុងរដ្ឋាភិបាល របស់ ព្រះអង្គ ពីថ្ងៃ ១ ឧសភាឆ្នាំ ១៩៦៧ ដល់ថ្ងៃ ៣១ មករា ឆ្នាំ ១៩៦៨ សម្ដេច នរោត្ដម សីហនុ បញ្ចេញប្រតិកម្មយ៉ាងខ្លាំង ចំពោះអ្នកឆ្វេង

និយម ដូចជាលោក ហ៊ូ យន់ លោក ខៀវ សំផន លោក ហ៊ូ នឹម និង លោក កោគ ឆាយ ជាដើម ទោះបីមាន សមាជិកសំខាន់ៗ ជាអ្នកឆ្វេងនិយម នៅក្នុងរដ្ឋាភិបាល របស់ ព្រះអង្គក្តី តួយ៉ាង លោក ចៅ សេង លោក គាត ឈុន ជាដើម ។ នៅថ្ងៃ ២ កញ្ញា ឆ្នាំ ១៩៦៧ ព្រះអង្គ បិទសមាគម មិត្តភាព ខ្មែរ-ចិន របស់ លោក ហ៊ូ នឹម និង កោគ ឆាយ ព្រោះតែសមាគមនេះ ចែកផ្សព្វផ្សាយ «សៀវភៅក្រហម» របស់ ម៉ៅ សេទុង ។ ១០ ថ្ងៃក្រោយមកទៀត សេរីភាព ក្នុងការបញ្ចេញមតិ ត្រូវប៉ះពាល់ជាទម្ងន់ ។ កាសែត ឯកជនត្រូវបិទទ្វារទាំងអស់។ នៅទីបំផុត នៅថ្ងៃ ៧ តុលា លោក ហ៊ូ នឹម រត់ចូល ព្រៃ បន្ទាប់ពីបានត្រូវសម្តេច នរោត្តម សីហនុ ចោទថាជា ជនក្បត់ជាតិ ។ គឺនៅ ពេលនោះ ហើយ ដែលនិស្សិត និង សាស្ត្រាចារ្យជាច្រើនបាត់ខ្លួន ហើយខ្លះបានត្រូវ គេសម្លាប់ ចោលតែម្តង។ ការពិត មិនត្រឹមតែ អ្នកឆ្វេងនិយម ប៉ុណ្ណោះទេ ដែលត្រូវរងគ្រោះ អ្នកស្តាំនិយម ក៏ទទួលរងគ្រោះដូចគ្នាអ៊ីចឹងដែរ។ សំរេចសំរួលទៅ រដ្ឋាភិបាល លោក ប៉ែន នុត ដែលបន្ត បេសកកម្ម ពីសម្តេច នរោត្តម សីហនុ ពីថ្ងៃ ៣១ មករាឆ្នាំ ១៩៦៨ ដល់ថ្ងៃ ១៣ សីហាឆ្នាំ ១៩៦៩ បានសុខចិត្តទទួលជំនួយ ពីសហរដ្ឋ អាមេរិកវិញ ។

## ការជ្រើសរើស ដ៏ ពិបាក របស់ សម្តេច នរោត្តម សីហនុ រវាង លោកកុម្មុយនិស្ត និង លោកសេរី

## Le prince Norodom Sihanouk en 1968 : le dilemme



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

នៅឆ្នាំ ១៩៦៧ និង ឆ្នាំបន្តបន្ទាប់មកទៀត សហរដ្ឋ អាមេរិក បានបង្កើន ការទម្លាក់គ្រាប់បែក និង ការវាយប្រហារទៅលើប្រទេសកម្ពុជាយ៉ាង សំបើមអស្ចារ្យ បើប្រៀបធៀបទៅឆ្នាំ ១៩៦៥។ គេអាចនិយាយបានថា នៅពេលនោះ សហរដ្ឋ អាមេរិក បានរំលោភច្បាប់អន្តរជាតិ ដោយកម្រោល រួមបញ្ចូលទាំង កិច្ចព្រមព្រៀង ទីក្រុង ហ្សឺណែវ ឆ្នាំ១៩៥៤ និង រដ្ឋធម្មនុញ្ញ របស់ សហរដ្ឋ អាមេរិក ទៀតផង ។ ប៉ុន្តែ ទន្ទឹម នោះ កងទ័ពកុម្មុយនិស្ត វៀតណាម មិនត្រឹមតែមិនគោរពបូរណ៍ភាព ដែនដីខ្មែរ ប៉ុណ្ណោះ ទេ គឺ បានប៉ះពាល់ជាទម្ងន់ ដល់អធិបតេយ្យរបស់ខ្មែរទៀតផង ។ នៅក្នុង ពេល ជាមួយគ្នានោះ បន្ទាប់ពីការផ្ទុះឡើង នៃ ព្រឹត្តិការណ៍ «បដិវត្តន៍វប្បធ៌ម» នៅប្រទេស ចិននៅឆ្នាំ ១៩៦៦ សម្តេច នរោត្តម សីហនុ ត្រូវប្រឈមមុខ នឹង ឥទ្ធិពល នៃ «សៀវភៅក្រហម» របស់ ម៉ៅ សេទុង នៅប្រទេសកម្ពុជា ផងដែរ។ នៅថ្ងៃ២ កញ្ញាឆ្នាំ ១៩៦៧ សម្តេច នរោត្តម សីហនុ បានសម្រេចបិទសមាគម មិត្តភាព ចិន-ខ្មែរ របស់ កោគ ឆាយ និង ហ៊ូ នឹម តែម្តង។ ប៉ុន្តែ ដោយ បដិវត្តន៍វប្បធម៌ចិន បានរាលដាល ដល់មជ្ឈដ្ឋានផ្សេងៗទៀត ដូចជានៅក្នុងមួយភាគធំ នៃមជ្ឈដ្ឋាននិស្សិត និង មួយផ្នែកធំ នៃ មជ្ឈដ្ឋាន អ្នកសារពត៌មាន សម្តេច នរោត្តម សីហនុ គ្មានជម្រើសអ្វីទៀត ក្រៅពីបិទ សមាគម និស្សិតខ្មែរ របស់ កោគ ឆាយ និង កាសែតមួយ ចំនួនទេ។ នៅក្នុងពេល ដដែលនោះ បន្ទាប់ពី ហ៊ូ នឹម រត់ទៅពួនលាក់ខ្លួន នៅក្នុងព្រៃភ្នំក្រវាញ នៅថ្ងៃ ៧ តុលា ប៉ូលីស របស់ សម្តេច នរោត្តម សីហនុ បានចាប់សាស្ត្រាចារ្យ និង និស្សិតជាច្រើនរូប ហើយនិស្សិតមួយចំនួន បាត់ខ្លួនតែម្តង។ នៅថ្ងៃ ២៥ តុលាឆ្នាំ ១៩៦៧ ដដែលនោះ សម្តេច នរោត្តម សីហនុ ថ្កោលទោស យ៉ាងខ្លាំង ដល់អ្វី ដែលព្រះអង្គហៅថា «ខ្មែរ ក្រហម» និង «ខ្មែរខៀវ»។ គឺនៅពេលនោះហើយដែល និស្សិត, គ្រូបង្រៀន, សាស្ត្រាចារ្យ ជាច្រើនពាន់នាក់ នាំគ្នារត់ ចូលព្រៃ។ ដូច្នេះឃើញថា ចាប់តាំងពីចុងឆ្នាំ ១៩៦៧ នោះមក សម្តេច នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ នៃ ប្រទេសកម្ពុជា ត្រូវប្រឈមមុខ នឹង សត្រូវផ្ទៃក្នុង ដល់ទៅ ២ ប្រភេទ គឺ ទាំងអ្នកដែលមានលំអៀងទៅរក សហរដ្ឋ

*អាមេរិក ទាំងអ្នកដែលប្រឆាំង នឹងសហរដ្ឋ អាមេរិក។ ការបះបោរប្រជាកសិករ នៅសម្លូត ក្នុងខេត្តបាត់ដំបង ជារូបភាពមួយ នៃ ការប្រយុទ្ធរវាង ខ្មែរកុម្មុយនិស្ត និង រដ្ឋាភិបាល របស់លោក លន់ នល់ យ៉ាងប្រត្យក្ស ។ ប៉ុន្តែ លក្ខណៈស្មុគស្មាញ មិនអាចដោះស្រាយបាន មិនមែនមកតែពី «បញ្ហាខ្មែរ» សុទ្ធសាធនោះទេ តែវាជារឿងទំនាស់ រវាងប្រទេស ដែលនៅពីក្រោយក្រុមខ្មែរនីមួយៗ ។ ហេតុដូច្នេះហើយបានជាទាល់តែមាន សន្និសីទអន្តរជាតិទីក្រុងប៉ារីស៍ នៅឆ្នាំ ១៩៨៩ ដែលប្រទេសជាប់ពាក់ព័ន្ធសម្រេចបញ្ចប់ ទំនាស់ របស់ គេ ក្រោយ ការរលំរលាយ នៃសហភាព សូវៀត ទើបបញ្ហាខ្មែរ អាចដោះស្រាយបាន។ រឿង ដែលនាំឲ្យមានទំនាស់ រវាង ខ្មែរ និង ខ្មែរ គឺការដែលកងទ័ពវៀតកុង បាននាំគ្នាមកតាំងទី នៅលើ ទឹកដី កម្ពុជា ពោលគឺ អ្នកនាំភ្លើងសង្គ្រាម មកក្នុងទឹកដីខ្មែរ ដោយបំផុសទាំងអ្នកនយោបាយ ទាំងបញ្ញវន្តខ្មែរ ។ នៅទីបំផុត សម្តេច នរោត្តម សីហនុ មិនអនុញ្ញាត ឲ្យអាមេរិកកាំងទម្លាក់គ្រាប់បែក បេ ៥២* (B 52) *ដើម្បី កំទេចទីតាំងវៀតកុង នៅលើទឹកដីខ្មែរដែរ ព្រោះព្រះអង្គជឿជាក់ថា អ្នកទទួលរងគ្រោះ គឺប្រជាជនខ្មែរតែប៉ុណ្ណោះ។ ប៉ុន្តែ អ្វីៗក៏ វាជ្រុលពេលអស់ ទៅហើយ។ នៅដើមឆ្នាំ ១៩៦៨ សហរដ្ឋ អាមេរិក ចាប់ផ្តើមយល់ថា សម្តេច នរោត្តម សីហនុ គ្មានជម្រើសអ្វីទៀត ក្រៅពីដេញ កងទ័ពកុម្មុយនិស្ត វៀតណាមឲ្យចេញអស់ ពីប្រទេសកម្ពុជាទេ ហើយម្យ៉ាងទៀត ព្រះអង្គ ក៏ពុំមែនចង់ឲ្យ ប្រទេសកម្ពុជា ក្លាយទៅជា កុម្មុយនិស្ត ឯណាដែរ។ ប៉ុន្តែ មិត្តភាព របស់ ព្រះអង្គ ជាមួយបណ្តាប្រទេសកុម្មុយនិស្ត ជាចំណងមួយ ដែលមិនអនុញ្ញាតឲ្យព្រះអង្គវេីខនរួច ទាល់តែសោះ គឺ បើវេីខនតែបន្តិច អំណាចរបស់ ព្រះអង្គ នឹងត្រូវរង្គោះរង្គើមួយរំពេច ហើយនៅពេលនោះ ខ្មែរក្រហម មុខជានឹងវាយរំលំព្រះអង្គ ជាមិនខាន។ មួយចំណែកទៀត បើបាត់បង្អែក ពីខ្មែរក្រហម ពីបណ្តាប្រទេស កុម្មុយនិស្ត នានា ព្រះអង្គ នឹងត្រូវ អ្នកអភិរក្សស្តាំនិយម ធ្វើរដ្ឋប្រហាររំលំព្រះអង្គ ដោយគេចពុំផុត។ គឺនៅពេលនោះ ហើយដែលបេសកកម្ម របស់ លោក ចេសស្ទែរបូវ* (Chester Bowl) *ឯកអគ្គរដ្ឋទូត អាមេរិក ប្រចាំប្រទេសឥណ្ឌា និង*



*សុបិន និង ការពិត ភាគ ១*- Rêves et réalités –Tome 1

*របស់ លោក អាកាស៊ី* (Akashi) *បេសកជនពិសេស របស់ អង្គការ សហប្រជាជាតិ បានទទួលបរាជ័យទាំងស្រុង នៅដើមឆ្នាំ១៩៦៨។ នៅពេលនោះ ពួកខ្មែរក្រហមចាប់ផ្តើមប្រយុទ្ធ នឹង កងទ័ព របស់ ឧត្តមសេនីយ៍ លន់ នល់ យ៉ាងខ្លាំង គឺហាក់បីដូចជាសម្តេច នរោត្តម សីហនុ គ្មានឥទ្ធិពល អ្វីទៀតទាំងអស់។ នៅថ្ងៃ ១៧ មករា ឆ្នាំ ១៩៦៨ នោះ ខ្មែរ ក្រហម បានធ្វើការវាយលុក ទៅលើទីតាំង រដ្ឋាភិបាលនៅ បាណន់ ក្នុងខេត្របាត់ដំបង ហើយ យកកាំភ្លើងបាន ៣២ ដើម។ នេះ ជាការវាយប្រហារផ្លូវអាវុធលើកដំបូងបង្អស់ នៃ អ្វីដែលខ្មែរក្រហមហៅថា «កងទ័ពរំដោះប្រជាប់អាវុធ បដិវត្ត»។ សកម្មភាពយោធា របស់ ខ្មែរក្រហម ចេះតែមានបន្តមកទៀត តាំងពីពេលនោះមក។ ជនជាតិ ភាគតិចនៅតំបន់ព្រៃភ្នំ រតនគីរី និង មណ្ឌលគីរី បាននាំគ្នា ចូលខ្មែរក្រហម យ៉ាងក្រាស់ក្រែល។ នៅថ្ងៃ ៣១ មករា រដ្ឋាភិបាលបានត្រូវប្រគល់ទៅឲ្យលោក ប៉ែន នុត ។ រដ្ឋាភិបាលនេះ បានត្រូវប្រសិទ្ធិនាមថា «រដ្ឋាភិបាលផ្សងសំណាងចុងក្រោយ»* («Gouvernement de la dernière chance ») *។ នៅទីបំផុត នៅថ្ងៃ ១៩ កុម្ភៈ ប្រទេសកម្ពុជា បានសុខចិត្តទទួលជំនួយសេដ្ឋកិច្ច និង យោធា ពីសហរដ្ឋ អាមេរិកវិញ ។ នៅថ្ងៃ ៣០ កក្កដាឆ្នាំ ១៩៦៩ ឧត្តមសេនីយ៍ ញឹក ជូឡុង មេបញ្ជាការកងទ័ព ខេមរភូមិន្ទ អ្នកស្មោះត្រង់ នឹងសម្តេច នរោត្តម សីហនុ ប្រគល់ បញ្ជាការកងទ័ព ទាំងមូល ទៅឲ្យ ឧត្តមសេនីយ៍ លន់ នល់ ។ ពីរថ្ងៃក្រោយមក គឺ នៅថ្ងៃ ១៤ សីហា ឆ្នាំ ដដែល លោក ប៉ែន នុត ក៏សុំលាលែង ពី មុខតំណែង នាយករដ្ឋមន្ត្រី ។*

# « រដ្ឋាភិបាល ស្រោចស្រង់ជាតិ »

## « Le Gouvernement de sauvetage»

នៅដើមឆ្នាំ ១៩៦៨ បន្ទាប់ពីរដ្ឋាភិបាល របស់លោក ប៉ែន នុត សុខចិត្តយល់ព្រមទទួល ជំនួយសេដ្ឋកិច្ច និង យោធា ពីសហរដ្ឋ អាមេរិក ពួកខ្មែរក្រហម បានបង្កើនសកម្មភាពយោធា របស់គេយ៉ាងខ្លាំង ។ នៅថ្ងៃ ២៥ កុម្ភៈ កងប្រដាប់អាវុធរបស់ចលនាបដិវត្តន៍ខ្មែរ បានវាយប្រហារទៅលើទី តាំងសំខាន់ៗ របស់ រដ្ឋាភិបាល នៅក្នុងខេត្ត ចំនួន ៦ នៅក្នុងថ្ងៃតែមួយ គឺ បាត់ដំបង, កំពង់ឆ្នាំង, កំពង់ស្ពឺ, តាកែវ, កំពត, កោះកុងៗ អ្នកភូមិប្រមាណ ១ ម៉ឺននាក់បាននាំគ្នាទៅចូលរួមក្នុង ចលនាកុម្មុយនិស្តខ្មែរៗ គឺ នៅពេលនោះហើយ ដែលការរំដើបរំជួល នៅឈូក និង ឡាបានសៀកបានផ្ទុះឡើង ។ ប៉ុន្តែ គឺនៅក្នុង បរិយាកាសវឹកវរនេះដែរ ដែលនៅថ្ងៃ ១៣ ឧសភា ឧត្តមសេនីយ៍ លន់ នល់ បានត្រូវតែងតាំង ជារដ្ឋមន្ត្រី ការពារ ប្រទេសសាជាថ្មីទៀត នៅក្នុងរដ្ឋាភិបាល របស់ សម្តេច ប៉ែន នុត មុននឹង ត្រូវដឹកនាំរដ្ឋាភិបាលតែម្តង ៧ ខែក្រោយមក គឺពីថ្ងៃ ៥ ធ្នូឆ្នាំ ១៩៦៨ មកៗ រដ្ឋាភិបាល លោក លន់ នល់ ដែលបានត្រូវតែងតាំង នៅថ្ងៃ ១៤ សីហា ឆ្នាំ ១៩៦៩ ហើយដែលបានត្រូវប្រសិទ្ធិនាមថា «រដ្ឋាភិបាលស្រោចស្រង់ជាតិ» ជារដ្ឋាភិបាល ដែលមានលំអៀង ទៅរកសហរដ្ឋ អាមេរិកៗ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ដែលនៅក្នុងរដ្ឋាភិបាល របស់ ព្រះអង្គម្ចាស់ នរោត្តម កន្តុល ឆ្នាំ ១៩៦៥-១៩៦៦ ជា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកខាងអប់រំជាតិ បានត្រូវរដ្ឋាភិបាលទី ២ របស់ លោក លន់ នល់ តែងតាំងជា ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកក្រសួងជាច្រើនមានជាអាទិ៍ : ក្រសួងមហាផ្ទៃ, ក្រសួង អប់រំជាតិ និង ក្រសួងសន្តិសុខជាតិ ។ រីឯលោក លន់ នល់ វិញ លោកទទួលបន្ទុក ខាងក្រសួង ការពារប្រទេសផ្ទាល់តែម្តងៗ មុនការតែងតាំង «រដ្ឋាភិបាលស្រោចស្រង់ជាតិ» នេះ ដែលមាន





និន្នាការ ចម្រុះនៅឡើយ សម្តេច នរោត្តម សីហនុ បានទទួលស្គាល់ថា កងទ័ពព្រៃរបស់វៀតណាមខាងជើង មានវត្តមាន និង ទីតាំង របស់គេ នៅក្នុង ទឹកដីខ្មែរ ពិតប្រាកដមែន ។ នៅថ្ងៃ ២៨ មិនា ឆ្នាំ ១៩៦៩ សម្តេច នរោត្តម សីហនុ បានបង្ហាញទីតាំងទាំងនោះ នៅក្នុងផែនទី ។ ព្រះអង្គទ្រង់បានបញ្ជាក់ថា កងទ័ពព្រៃ វៀតណាមខាងជើង និង វៀតកុង ដែលស្ថិតនៅលើទឹកដី ប្រទេសកម្ពុជា មានចំនួន លើស ពី ៤ ម៉ឺននាក់ទៅទៀតៗ ទោះជាយ៉ាងនេះក៏ដោយ ក៏ព្រះអង្គ មិនប្តូរ នយោបាយ របស់ព្រះអង្គដែរ គឺព្រះអង្គគ្រាន់តែខិតទៅជិត សហរដ្ឋ អាមេរិក បន្តិចវិញប៉ុណ្ណោះ ។ ទោះជាយ៉ាងនេះក្តី ក៏នៅថ្ងៃ ១៣ មិថុនា ឆ្នាំ ១៩៦៩ ដដែលនោះ សម្តេច នរោត្តម សីហនុ បានទទួលស្គាល់ រដ្ឋាភិបាល បដិវត្ត បណ្តោះអាសន្ន របស់វៀតណាមខាងត្បូងដែរៗ ដូច្នេះ ឃើញថា រដ្ឋាភិបាល របស់ លោក លន់ នល់ និង អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ស្ថិតនៅក្នុងស្ថានភាពមួយ ដ៏សែនពិបាកៗ នៅថ្ងៃ ២៣ តុលា ឆ្នាំ ១៩៦៩ ដដែលនោះ ឧត្តមសេនីយ៍លន់ នល់ បានសម្រេចចិត្តទៅព្យាបាលរោគ នៅ ប្រទេសបារាំង ហើយទុកឲ្យអ្នកអង្គម្ចាស់ សិរិមតៈ ដឹកនាំ «រដ្ឋាភិបាល ស្រោចស្រង់ជាតិ» ជំនួសតែម្តងៗ នៅចុងឆ្នាំ ១៩៦៩ នោះ អង្គភាពជាច្រើន របស់អង្គការខ្មែរសេរី បានត្រូវរំសាយ ហើយសមាជិកជាច្រើន នៃ ចលនា «ខ្មែរសេរី» បាន នាំគ្នាចូលមកក្នុងជួរកងទ័ព របស់ ឧត្តមសេនីយ៍ លន់ នល់ៗ នៅក្នុងពេលជាមួយគ្នានោះ សាឡុត សរ មេដឹកនាំបក្សកុម្មុយនិស្តខ្មែរ បានដឹកនាំគណប្រតិភូមួយ ទៅទីក្រុងហាណូយ និង ទីក្រុងប៉េកាំង ដោយឆ្លងកាត់តាម ផ្លូវលំ ហូ ជី មិញៗ នេះជាលើកទី ២ ហើយ ដែលអ្នកដឹកនាំកុម្មុយនិស្តខ្មែរ បាននាំគ្នា ទៅជួបអ្នកដឹកនាំកុម្មុយនិស្តវៀតណាម និង ចិនៗ នៅលើកនេះ សាឡុត សរ បានជួបប្រស្រ័យជាមួយលោក ឡែ យ៉ន់ លោក ឡែ ឌឹកថូ ឧត្តមសេនីយ៍ វ៉ៅ ង្វៀន យ៉ាប់ និង ង្វៀន ឌុយ ទ្រិញៗ មុនពេលដែល កងទ័ព បដិវត្តខ្មែរចាប់ផ្តើមប្រយុទ្ធ នឹងកងទ័ព របស់ឧត្តមសនីយ៍ លន់ នល់ ក្រុម កុម្មុយនិស្តខ្មែរនេះ ពុំមានកងទ័ពច្រើនប៉ុន្មានទេ គឺ មានយោធាត្រឹម ១ ពាន់ ៥ រយ នាក់ប៉ុណ្ណោះ ។

នៅចុងឆ្នាំ ១៩៦៩ នោះដែរ អ្នកអង្គម្ចាស់សិរិមតៈនាយករដ្ឋមន្ត្រីស្ដីទី នៃ «រដ្ឋាភិបាល ស្រោចស្រង់ជាតិ» បានចាប់ផ្ដើម កែប្រែរបៀបច្បាប់គ្រប់គ្រងប្រទេស ឲ្យត្រឡប់មករក ភាពដើម របស់ វាវិញ គឺ យាងទាំងស្រុង ទៅតាម និយាម សេរីនិយម បវេណី (Libéralisme classique) របស់ បស្ចិមប្រទេស ។ ចាប់តាំងពី ខែធ្នូ ឆ្នាំ ១៩៦៩ នោះ មក សេចក្ដីសម្រេចផ្សេងៗ ត្រូវចេញពី រដ្ឋសភាសិន ទើបបានត្រូវរដ្ឋាភិបាល យកទៅ អនុវត្ត ។ សម្ដេច នរោត្ដម សីហនុ មាន ការអាក់អន់ ព្រះរាជហឫទ័យ យ៉ាងខ្លាំង ហើយ អ្វីដែលព្រះអង្គ អាចធ្វើបាន នៅពេលនោះ គឺបានត្រឹមបន្តសកម្មភាពប្រឆាំង នឹង រដ្ឋាភិបាល តាមរយៈ អង្គការមួយ ដែលមានឈ្មោះថា «បររដ្ឋាភិបាល» ពោលគឺ អង្គការ ប្រឆាំង នឹង រដ្ឋាភិបាល (« Le Contre-gouvernement ») គឺ អង្គការដែល ព្រះអង្គបានបង្កើតនៅថ្ងៃ ២៦ តុលាឆ្នាំ ១៩៦៦ ដើម្បីរិះគន់ សកម្មភាព របស់ រដ្ឋាភិ បាល ។ ក្រៅពីនោះ ព្រះអង្គ គ្រាន់តែ ស្នើឲ្យ រដ្ឋាភិបាល ប្រយ័ត្នប្រយែង ក្នុងការបើក ធនាគារ ឯកជន និង ការអនុញ្ញាតិឲ្យ ធនាគារបរទេស មកតាំងទី នៅក្នុងប្រទេស តែ ប៉ុណ្ណោះ ។ គឺ នៅពេលនោះហើយ ដែលអ្នកអង្គម្ចាស់ សិរិមតៈ សើរើ ការអនុវត្តន៍ គោលការណ៍ រដ្ឋធម្មនុញ្ញ ឡើងវិញ គឺ គោលការណ៍ «ប្រមុខរដ្ឋដឹកនាំប្រទេស ប៉ុន្តែមិន គ្រប់គ្រងទេ» ។

# សមិទ្ធិ សំខាន់ៗ នៃ របប «សង្គមរាស្ត្រនិយម»

## Les principales réalisations du Sangkum Reasts Niyum

មុន នឹងឈានទៅនិយាយពី ការវិវត្តន៏នៃ «រដ្ឋាភិបាល ស្រោចស្រង់ជាតិ» ឆ្ពោះទៅរកការទម្លាក់ សម្ដេច នរោត្ដម សីហនុ ពីអំណាចនៅថ្ងៃ ១៨ មិនាឆ្នាំ ១៩៧០





ខ្ញុំសូមលើកឡើង អំពី សមិទ្ធិសំខាន់ៗ នៃ របប «សង្គមរាស្ត្រនិយម» តាំងពីឆ្នាំ ១៩៥៥ មកទល់ ឆ្នាំ១៩៦៩។ បើប្រៀបធៀប ទៅនឹង របប នានាឯទៀត ជាពិសេស របប ប្រជា ធិបតេយ្យ តាមបែបបស្ចិមប្រទេស និង របបសង្គមនិយម ឬ របបកុម្មុយនិស្ត គេ ឃើញថា របប «សង្គមរាស្ត្រនិយម» ដែលសម្ដេច នរោត្ដម សីហនុ និង សហការី របស់ ព្រះអង្គបានបង្កើត នៅថ្ងៃ ២៣ មិនា ឆ្នាំ ១៩៥៥ ហើយដែលបានត្រូវចាប់ ដំណើរការ នៅថ្ងៃ ១៣ មិថុនា ឆ្នាំដដែល គឺថ្ងៃដែល សមាជជាតិ លើកដំបូងបង្អស់ បានបើកសម័យប្រជុំ គឺ ជារបបនយោបាយមួយ ដែលអ្នកខ្លះចាត់ទុកថា ជារបប ប្រជា ធិបតេយ្យ «ផ្ទាល់ពាក់កណ្ដាល» « démocratie semi-directe»។ ចំពោះមតិខ្លះទៀត គេមិនអាចនិយាយពី របបប្រជាធិបតេយ្យបានទេ កាលណាគ្មាន គណបក្ស នយោបាយ ផ្សេងៗទៀតចូលរួម ក្នុងជីវិតនយោបាយ។ ហើយនេះ ជាករណី នៃ របប «សង្គមរាស្ត្រ និយម» តែម្ដង ។ តាមការពិតទៅ គឺគ្មានអ្វីក្រៅពី របបរាជានិយម តាមរូបភាពសម័យ ទំនើបទេ ឬមួយ ក៏ជារបបមួយ ដែលអាចប្រៀបបាន ទៅនឹង របៀបគ្រប់គ្រងប្រទេស របស់ ព្រះចៅអធិរាជ រ៉ូម៉ាំង ស្ទើហ្សាតែម្ដង (Césarisme) ក៏សឹងថាបាន ។ ប៉ុន្តែ ទោះនៅក្នុងករណីណាក្ដី ការដែលសម្ដេច នរោត្ដម សីហនុ បាន បង្កើតស្ថាប័ន «ប្រមុខ រដ្ឋ» នៅឆ្នាំ ១៩៦០ ក៏អាចចាត់ទុកថា ជាការបើកផ្លូវមួយយ៉ាងធំ សម្រាប់បញ្ចប់ របប រាជានិយម ដែលមានកន្ទងមកបានដែរ ។ ទោះជា របប ប្រជាធិបតេយ្យ ឬ ក៏ជារបប ប្រជានិយម (populisme) ឬ «ស្នួសារនិយម» ក្ដី ក៏ របប *សង្គមរាស្ត្រនិយម* ជា របបមួយដែលសាកល្បង សម្រេចឲ្យបានច្រើនបំផុត ទៅនឹង តថភាព ទៅនឹង ភាពជាក់ ស្ដែង នៃ សង្គមខ្មែរនៅពេលនោះ ដែលប្រជាកសិករ មានចំនួនជាង ៨០ ភាគរយ ហើយ ដែលមានការលំបាកលំបិនយ៉ាងខ្លាំង ក្រោមការគ្រប់គ្រងមួយបែប ដែលយោង ទៅ តាម ច្បាប់ចាស់ របស់ បារាំង ហើយ ដែលឈ្មួញ បរទេស ក្ដាប់សេដ្ឋកិច្ច យ៉ាង ណែន ។ នៅក្នុងវិស័យសេដ្ឋកិច្ច សម្ដេច នរោត្ដម សីហនុ មានគោលបំណងមួយ ដ៏ ចម្បង គឺរំដោះប្រជាកសិករឲ្យចេញផុតពីក្រញាំដៃ របស់ ពួកឈ្មួញ ពោលគឺដូចគោល

ដៅរបស់ពួកកុម្មុយនិស្តដូច្នេះដែរ។ ប៉ុន្តែនេះ ជាទំនាស់មួយដ៏ធំ នៅក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ព្រោះថា គឺ ពួកគហបតី, ពួកឈ្មួញនេះហើយ ដែលជាអ្នកជំរុញ ឲ្យមានការរីកចម្រើន ផ្នែកសេដ្ឋកិច្ច ជាពិសេស ផ្នែក ឧស្សាហកម្ម ។ នៅពេលមួយដែលប្រទេសកម្ពុជា ត្រូវបោះជំហាន យ៉ាងស្វាហាប់ ឆ្ពោះទៅរក ភាពសម័យទំនើប ការគាបសង្កត់ទៅលើពួកគហបតី ជាការផ្ទុយនឹងក្រឹត្យក្រមរីកចម្រើន ។ ប៉ុន្តែ បើបណ្ដោយឲ្យពួកឈ្មួញ ចាត់ចែងការអភិវឌ្ឍន៍ដោយត្រង់ៗ តែម្ដងនោះ របបរាជានិយម ឬ ឥទ្ធិពលរបស់ អ្នកដឹកនាំ នយោបាយ ក៏ នឹងត្រូវរង្គោះរង្គើ ដោយចៀសមិនផុតដែរ ព្រោះថាទោះចង់ ឬ មិនចង់ក្ដី តាមរយៈក្រឹត្យក្រមនេះ អ្នកនយោបាយ គ្រាន់តែជាឧបករណ៍ ឬតុក្កតា របស់ ពួកសេដ្ឋីតែប៉ុណ្ណោះ។ គេ អាចនិយាយបានថា អស់រយៈពេល ១៤ ឆ្នាំ គឺពីឆ្នាំ ១៩៥៥ មកទល់ឆ្នាំ ១៩៦៩ សម្ដេច នរោត្តម សីហនុ បានសាកល្បង ធ្វើអ្វី គ្រប់បែប យ៉ាង ដើម្បី ពន្យាពេល ការវិវត្តន៍ជាសត្យានុម័តនេះ ពោលគឺ«បដិវត្តន៍ឧស្សាហកម្ម» របស់ ពួកគហបតីដែល អាចយកអំណាច ពីពួកអភិជន បានដោយងាយ។ ប៉ុន្តែនៅទីបំផុត ឆ្លៀតឱកាស ភាពទាល់ច្រក នៃ ស្ថានភាពនយោបាយ របស់ សម្ដេច នរោត្តម សីហនុ ពួកគហបតី បានជំរុញឲ្យ ឧត្តមសេនីយ៍ លន់ នល់ និងសិរិមតៈ វាយរំលំ របប *សង្គមរាស្ត្រនិយម* តែម្ដងទៅ ។ នៅក្នុងការប្រឹងប្រែង របស់ ព្រះអង្គដើម្បីតទល់ នឹងអំណាច ដ៏ធំធេង របស់ពួកគហបតីផង ហើយដើម្បីកាត់ ផ្ដាច់ការវិវត្តន៍របស់ពួក កុម្មុយនិស្តផងដែរ សម្ដេច នរោត្តម សីហនុ ក៏ទ្រង់បានសម្រេច នូវសមិទ្ធិសំខាន់ៗដែរ ដើម្បីនាំប្រទេសជាតិ ឆ្ពោះទៅរក ភាពសម័យទំនើប ។ ជាបឋម ព្រះអង្គត្រូវធានាសន្តិភាព និងសន្តិសុខ ក្នុងប្រទេសឲ្យបាន ។ បន្ទាប់មក គឺការលើកតម្កើងកម្រិតជីវភាព និង កម្រិតវប្បធម៌ របស់ប្រជាជន។ នៅឆ្នាំ ១៩៥៥ សាលា បឋមសិក្សាមានចំនួនតែ ២៧៣១ ប៉ុណ្ណោះ នៅឆ្នាំ ១៩៦៨ សាលាបឋមសិក្សាបានកើនមកដល់ចំនួន ៥៨៥៧។ វិទ្យាល័យ និង អនុវិទ្យាល័យ ដែលកាលពីឆ្នាំ ១៩៥៥ មានចំនួនតែ ១២ ប៉ុណ្ណោះ បានកើនមកដល់ ចំនួន ១៨០ នៅឆ្នាំ ១៩៦៨ ។ រី ឯសាលា បច្ចេកទេស និង





មុខរបរ បានកើនពី ៥ នៅឆ្នាំ ១៩៥៥ មកចំនួន ៩៩ នៅឆ្នាំ ១៩៦៨។ មហាវិទ្យាល័យដែលមានតែ ២ នៅឆ្នាំ ១៩៥៥ បានកើនមកដល់ចំនួន ៤៨ នៅ ឆ្នាំ១៩៦៨។ នៅក្នុងវិស័យសុខាភិបាល មន្ទីរពេទ្យមានតែ ១៦ ប៉ុណ្ណោះ ប៉ុន្តែនៅឆ្នាំ ១៩៦៨ មន្ទីរពេទ្យនៅក្នុងប្រទេសកម្ពុជា មានដល់ទៅ ៥៩ ។ នៅក្នុងវិស័យកសិកម្ម ផលិតផលស្រូវក្នុងមួយឆ្នាំ មានត្រឹម ១ លាន ៤ សែន ៨ ម៉ឺន ៤ ពាន់ តោនប៉ុណ្ណោះ ។ មកដល់ឆ្នាំ ១៩៦៩ ផលស្រូវ ដែលផលិតបាន បានកើនមកដល់ ៣ លាន ២ សែន ៥ ម៉ឺន ១ ពាន់ តោន។ ខាងផ្នែកសង្ហារណៈបរិក្ខារ ហេដ្ឋារចនាសម្ព័ន្ធ គ្រប់ប្រភេទ ផ្លូវគមនាគមន៍ បានកើន ពី ៤ ពាន់ ៨ រយ ៥ គ.ម. នៅឆ្នាំ ១៩៥៥ មក ១ ម៉ឺន ៦ ពាន់ ៦ រយ ៩៧ គ.ម.នៅ ឆ្នាំ ១៩៦៩ ។ ស្ពានធ្វើពី បេតុង បានកើន ពី ចំនួន ៨៧៥ មកចំនួន ១ ពាន់ ៥ រយ នៅក្នុងរយៈពេល ១៣ ឆ្នាំ។ ក្នុងរយៈពេលដដែលនោះ ប្រលានយន្តហោះ ប្រើក្នុងប្រទេស បានកើនចំនួន ៤ ថែមទៀត គឺ ព្រលានយន្តហោះ កំពង់ចាម, បាត់ដំបង, ស្ទឹងត្រែង, ក្រុងព្រះសីហនុ។ នៅឆ្នាំ ១៩៥៥ ប្រទេសកម្ពុជា គ្មានរោងចក្ររដ្ឋ និង រោងចក្រ ចម្រុះរដ្ឋ និង ឯកជនទេ ប៉ុន្តែ ១៣ ឆ្នាំ ក្រោយមក រោងចក្ររដ្ឋ មានចំនួនទាំងអស់ ២៨ រីឯ រោងចក្ររដ្ឋចម្រុះជាមួយឯកជន មានចំនួន ២៩។ ខាងវិស័យ ថាមពលអគ្គីសនី ដោយសារការសាងសង់ វារីអគ្គីសនី នៅឆ្នាំ ១៩៦៨ ប្រទេសកម្ពុជា បានឈាន ពី ១ ម៉ឺន ១ ពាន់ ៥៥ គីឡូវ៉ាត់ មកដល់ ៧ ម៉ឺន គីឡូវ៉ាត់។

# ការវិវត្តន៍ ឆ្ពោះទៅរក ព្រឹត្តិការណ៍

# ថ្ងៃ ១៨ មិនា ឆ្នាំ ១៩៧០

## Les évènements qui précèdent la destitution du prince Sihanouk en mars 1970

រដ្ឋាភិបាល ស្រោចស្រង់ជាតិ ដឹកនាំដោយ ឧត្តមសេនីយ៍ លន់ នល់ និងអ្នកអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ដែលបានត្រូវតែងតាំង នៅថ្ងៃ ១៤ សីហា ឆ្នាំ ១៩៦៩ នៅមាននិន្នាការ ចម្រុះ នៅឡើយ ទោះបី រដ្ឋមន្ត្រីមួយចំនួន បានត្រៀមខ្លួនជាស្រេចដើម្បីរេទៅតាមខ្យល់ ក៏ដោយក្តី ។ ក្រៅពី ឧត្តមសេនីយ៍ លន់ នល់ និង អ្នកអង្គម្ចាស់ សិរិមតៈ ដែលមានលំអៀងយ៉ាងខ្លាំងទៅរក សហរដ្ឋ អាមេរិក សមាសភាពទាំងអស់មានដូច តទៅ ៖ លោក អ៊ីង ហុង សាធ ឧបនាយករដ្ឋមន្ត្រី ទី ២ ទទួលបន្ទុក ខាងសុខាភិបាល សង្គមកិច្ច និង ការងារ ខាងការអភិវឌ្ឍន៍ សហគមន៍ ខាងលំនៅស្ថានជនបទ និង ខាងឃោសនាការ លោក ឱប គីម អាង ឧបនាយករដ្ឋមន្ត្រី ទី ៣ ទទួលបន្ទុកខាងហិរញ្ញវត្ថុ និងផែនការ លោក យ៉ែម សំបូ ដែលជាមនុស្សទុកចិត្តម្នាក់ របស់សម្តេច នរោត្តម សីហនុ ដូចលោក អ៊ីង ហុង សាធ ដូច្នេះដែរ ទទួលបន្ទុក ខាងយុត្តិធម៌និង ទំនាក់ទំនង ជាមួយសភា អ្នកអង្គម្ចាស់ នរោត្តម ភូរិស្សរា ក្រសួង ការបរទេសលោក ផ្ទែក ភីន សាធារណការ និង គមនាគមន៍ លោក ជួន សៅឌី កសិកម្ម។ រដ្ឋាភិបាលនេះ មានរដ្ឋលេខាធិកា ៨ រូបទៀត ដែលមួយចំនួនរក្សាការ ស្មោះត្រង់ នឹងសម្តេច នរោត្តម សីហនុ ដដែល ។ រដ្ឋលេខាធិការទាំង ៨ រូបនោះ គឺ លោក អ៊ឹង មឹងរដ្ឋលេខាធិការ ទេសចរណ៍ លោក អ៊ុំ ម៉ាណូរីន មហាផ្ទៃ ទទួលបន្ទុកខាងកិច្ចការការពារផ្ទៃប្រទេស លោក សូស្តែន ហ្វែរណង់ដេស រដ្ឋលេខាធិការ មហាផ្ទៃ ទទួលបន្ទុកខាងសន្តិសុខជាតិ លោក ស្រី ប៉ុង ឧស្សាហកម្មលោក ព្រំ ថុស ពាណិជ្ជកម្ម, លោកទេព ឈីវ ខេង រដ្ឋលេខាឃោសនាការ, លោក ឌី ទូច រដ្ឋលេខា មហាផ្ទៃទទួលបន្ទុកខាងធម្មការ និង លោក ឡុង បុត្តា រដ្ឋលេខាធិការអប់រំជាតិ។ ប៉ុន្តែ នៅចុងឆ្នាំ ១៩៦៩ ដដែលនោះ ពោលគឺនៅ ថ្ងៃ ២៦ ធ្នូ ដើម្បី សំដែងការស្មោះត្រង់ របស់ខ្លួន ចំពោះនយោបាយ ប្រឆាំងនឹង សហរដ្ឋ អាមេរិក របស់ សម្តេច នរោត្តម សីហនុ រដ្ឋមន្ត្រីមួយចំនួន បានសុំលាលែងពីមុខតំណែង។ ទោះជាយ៉ាងនេះក្តី ក៏រដ្ឋាភិបាល របស់ ឧត្តមសេនីយ៍ លន់ នល់ នៅតែមានជំហរដដែល។ ទន្ទឹមគ្នានោះដែរ សមាជជាតិ លើកទី ២៨





ក៏បើកអង្គប្រជុំ របស់ ខ្លួននៅថ្ងៃទី ២៨ ឆ្នាំ ១៩៦៩ ដដែលនោះទៀត ដើម្បីសាកល្បងដករដ្ឋាភិបាល របស់ លោក លន់ នល់ ចេញ។ ប៉ុន្តែ សម្រេចសម្រួលទៅ គឺជាការឥតប្រយោជន៍ ។ នៅថ្ងៃ ៦ មករា ឆ្នាំ ១៩៧០ សម្តេច នរោត្តម សីហនុ បានចាកចេញពីប្រទេសកម្ពុជា ឆ្ពោះទៅប្រទេសបារាំង ។ បន្ទាប់ ពីសម្តេច នរោត្តម សីហនុ យាងទៅស្រុកបារាំងបាត់ទៅ នៅក្នុងមជ្ឈដ្ឋានអ្នក នយោបាយ គេនាំគ្នាយល់ថា សម្តេច នរោត្តម សីហនុ ប្រហែលជា នឹងជួបឧត្តមសេនីយ៍ លន់ នល់ ដែលនៅពេលនោះ កំពុងព្យាបាលរោគនៅមន្ទីរពេទ្យ *ណឺយយី* (Neuilly) នៅប្រទេសបារាំង។ គេនាំគ្នាសន្និដ្ឋានថា វរជនទាំង ២ រូបនេះ ច្បាស់ជា ជជែកពិភាក្សាគ្នា អំពីវត្តមាន កងទ័ពព្រៃវៀតកុងនៅក្នុងប្រទេសកម្ពុជាជាពុំខាន។ ប៉ុន្តែ យោងទៅតាមការសន្និដ្ឋានខ្លះទៀត ឧត្តមសេនីយ៍ លន់ នល់ ដែលកំពុង ព្យាបាលរោគ នៅក្នុងមន្ទីរពេទ្យអាមេរិក នៅ *ណឺយយី* (Neuilly) ប្រទេសបារាំង ប្រហែលជា កំពុងរៀបចំធ្វើរដ្ឋប្រហារទម្លាក់សម្តេច នរោត្តម សីហនុផងក៏មិនដឹង។ រីឯ ទំនាក់ទំនង រវាងឧត្តមសេនីយ៍ លន់ នល់ នឹង សម្តេច នរោត្តម សីហនុក៏ ប្រហែលជាបានឈាន មកដល់ទីបញ្ចប់ទៅហើយដែរ ។ ចំពោះអ្នកខ្លះ គេជឿថា បើសម្តេចនរោត្តម សីហនុ យាងត្រឡប់មកកម្ពុជាវិញ ព្រះអង្គ នឹង ស្ថិតនៅជាប្រមុខរដ្ឋបន្តទៅទៀត គឺ ព្រះអង្គ គ្រាន់តែ ប្តូរនយោបាយ បែរទៅរក សហរដ្ឋអាមេរិក វិញតែប៉ុណ្ណោះ ។ តាមការពិតទៅ សម្តេច នរោត្តម សីហនុ នៅពេលនោះ ពុំមានជំនឿទាល់តែសោះថា ព្រះអង្គអាច នឹងធ្វើសហការ ជាមួយ ឧត្តមសេនីយ៍ លន់ នល់ និង អ្នកអង្គម្ចាស់ សិរិមតៈដូចកាលពីពេលមុន ព្រោះស្ថានការណ៍ បានប្រែប្រួលអស់ទៅហើយ។ នៅក្នុងករណីនេះ ព្រះអង្គ នឹងក្លាយទៅជា តុក្កតា របស់រដ្ឋាភិបាលរបស់ ឧត្តមសេនីយ៍ លន់ នល់ តែប៉ុណ្ណោះ។ ប៉ុន្តែ ព្រះអង្គយល់យ៉ាងច្បាស់ថា បើ រដ្ឋាភិបាលឧត្តមសេនីយ៍ លន់ នល់-សិរិមតៈ ពិត ជាដើរត្រូវខ្យល់មែន ព្រះអង្គ នឹង ក្លាយទៅជាឧបសគ្គមួយដ៏ធំជាមិនខាន។ ដូច្នេះគេអាចនិយាយបានថា ពេលដែលសម្តេច នរោត្តម សីហនុ យាងទៅប្រទេសបារាំង ព្រះអង្គទ្រង់ឈ្វេងយល់យ៉ាងច្បាស់ថាទោះបី ឧត្តមសេ

នីយ៍ លន់ នល់ នៅស្មោះត្រង់ នឹងព្រះអង្គ ក៏ដោយ ក៏ ស្ថានការណ៍ មិនអនុញ្ញាតឲ្យឧត្តមសេនីយ៍រូបនេះ ក្បត់នឹងគោលដៅ របស់ រដ្ឋាភិបាលបានដែរ ។ យ៉ាងណាមិញ ឥរិយាបថ របស់ អ្នកអង្គម្ចាស់ សិរិមត: ក៏ បានធ្លុះបញ្ចាំងយ៉ាងច្បាស់ រួចមកហើយ ដែរថា ព្រះអង្គគ្មានតួនាទី អ្វីទៀតទេ នៅក្នុងប្រទេសកម្ពុជា ។ ចំពោះ សម្តេច នរោត្តម សីហនុ ព្រះអង្គ ក៏យល់ដូច្នេះដែរ ប៉ុន្តែព្រះអង្គចង់ទតឃើញថា តើ រដ្ឋាភិបាល របស់ ឧត្តមសេនីយ៍ លន់ នល់ ហ៊ានទម្លាក់ព្រះអង្គ ឬ ក៏ មិនហ៊ាន ។ ចំពោះ អ្នកអង្គម្ចាស់ សិរិមត:វិញ ការឈានទៅទម្លាក់ សម្តេច នរោត្តម សីហនុ ជាការមួយ ដែលគ្រោងទុកជាស្រេច ព្រោះអ្នកអង្គម្ចាស់ សិរិមត:ជឿច្បាស់ថា បើ សម្តេច នរោត្តម សីហនុ ត្រឡប់មកវិញមែននោះ ផ្លូវមានតែ ២ ប៉ុណ្ណោះ ៖ ឬមួយ រដ្ឋាភិបាលឧត្តមសេនីយ៍ លន់ នល់ ត្រូវប្រែក្លាយទៅជារដ្ឋាភិបាលក្បត់ ឬមួយ ក៏ បញ្ច្រាសមកវិញ។ នៅក្នុងករណីនេះ ការបង្ហូរឈាម ពុំអាចចៀសផុតបានឡើយ ។

នៅដើមឆ្នាំ ១៩៧០ នៅពេលដែលសម្តេច នរោត្តម សីហនុ យាងទៅព្យាបាលរោគ នៅប្រទេសបារាំង នៅទីក្រុងភ្នំពេញឯនេះវិញ រដ្ឋាភិបាល ឧត្តមសេនីយ៍ លន់ នល់ ដឹកនាំ ដោយអ្នកអង្គម្ចាស់សិរិមត: ត្រូវប្រឈមមុខ នឹង សកម្មភាព របស់កងទ័ពវៀតណាមខាងជើង នៅលើទឹកដីខ្មែរផង ហើយ ប្រយុទ្ធ នឹង បណ្តាញ ដឹកនាំស្បៀង និង អាវុធ របស់ចិនទៅឲ្យកងទ័ព វៀតណាមខាងជើងផង ។ នេះ ជាការមួយ ដ៏ ស្មុគស្មាញបំផុត ព្រោះនៅ ពេលនោះ ប្រទេសកម្ពុជា បានក្លាយទៅជាមូលដ្ឋានពស្តុភារ ដ៏សំខាន់មួយ របស់កងទ័ពព្រៃ វៀតណាម។ នៅថ្ងៃ ៣ កុម្ភៈ អ្នកអង្គម្ចាស់ សិរិមត: បញ្ជាឲ្យគេចាប់ក្រណាត់ចំនួន ៧ កេស ដែលមកពី ហុងកុង ហើយ ដែលត្រូវផ្ញើទៅលោក អ៊ុំ ម៉ាណូរីន រដ្ឋលេខាធិការ ខាងកិច្ចការការពារផ្ទៃប្រទេស។ នៅពេលមុននេះបន្តិច គឺនៅចុងខែ មករា ឆ្នាំ ១៩៧០ នោះ រដ្ឋាភិបាលខ្មែរ ចាប់បានថ្នាំពេទ្យជាច្រើនតោន ព្រមទាំងមាសចំនួន ៥០០ គីឡូ និង ក្រដាសប្រាក់ខ្មែរ ជាច្រើនបាច់ នៅព្រលានយន្តហោះពោធិចិន្តុង។ របស់របរ ទាំងអស់ នេះត្រូវបញ្ជូន ទៅឲ្យកង





ទ័ពវៀតកុង ដែលបង្កប់ខ្លួននៅលើទឹកដីខ្មែរ។ បន្ទាប់ ពីទ្រង់បានដឹង ពីរឿង នេះ សម្តេច នរោត្តម សីហនុ ដែលកំពុង ព្យាបាលរោគ នៅ ប្រទេសបារាំង នៅ មន្ទីរពេទ្យ របស់វេជ្ជបណ្ឌិត ប៉ាតេ នៅទីក្រុងក្រាស្ស (Grasse, Alpes-Maritimes) ក៏ បានចេញបញ្ជាឲ្យរដ្ឋាភិបាល ឧត្តមសេនីយ៍ លន់ នល់ ប្រគល់របស់ រត់គយទាំង នោះ ទៅឲ្យវៀតកុងជាបន្ទាន់។ រីឯ អ្នកតំណាង «រដ្ឋាភិបាល បដិវត្តបណ្តោះអាសន្ន វៀតណាម» ហ្សេ អ៊ែរ ប៉េ (G.R.P.) និង «រណសិរ្សរំដោះជាតិវៀតណាម» ក៏ បានទាមទារ ឲ្យរដ្ឋាភិបាលខ្មែរ ប្រគល់ របស់របរ ទាំងនោះទៅឲ្យ ខ្លួនវិញដែរ។ ប៉ុន្តែ អ្នកអង្គម្ចាស់សិរិមត: មិនព្រមដាច់អហង្ការ។ តាមការពិតទៅ ទោះបី សម្តេច នរោត្តម សីហនុ មានជំនឿថា រដ្ឋាភិបាល លន់ នល់ - សិរិមត: មិនញញើត នឹងធ្វើរដ្ឋប្រហារ ទម្លាក់ព្រះអង្គក្តី ក៏ ព្រះអង្គទ្រង់ឈ្វេងយល់ថា មិនយូរមិនឆាប់ រដ្ឋាភិបាល នេះ ក៏ដូចជា រដ្ឋាភិបាល ប្រទេសវៀតណាម ខាងត្បូងដែរ ច្បាស់ជា ពុំអាចទប់ទល់ នឹង កម្លាំង កុម្មុយនិស្ត បានឡើយ ។ យ៉ាងណាមិញ តាំងពីលោក រីស្សា និចសុន បាន ត្រូវតែងតាំងជា ប្រធានាធិបតី សហរដ្ឋ អាមេរិក នៅខែមករាឆ្នាំ ១៩៦៩ មក ការវាយប្រហារ របស់ កម្លាំងកុម្មុយនិស្ត កាន់តែមានលក្ខណ:ខ្លាំងក្លាជាលំដាប់។ ប៉ុន្តែសម្រេចសម្រួលទៅ លោក និចសុន យល់ឃើញថា ត្រូវតែធ្វើការចរចា។ នៅពេលនោះ លោក និចសុន បម្រុងនឹងដក កងទ័ពអាមេរិកទាំងអស់ ចេញពី វៀតណាមខាងត្បូង ដើម្បីប្តូរយក ឈ្លើយសង្គ្រាម អាមេរិក ហើយ ដើម្បីឈាន ទៅដល់ការ ឈប់បាញ់គ្នាទៀតផង។ គឺនៅចំពោះមុខស្ថានភាព នេះ ហើយ ដែលសម្តេច នរោត្តម សីហនុ ខិតខំ រក្សា នយោបាយ អែបកុម្មុយនិស្តជានិច្ច ។ ប៉ុន្តែ បញ្ហាតែមួយគត់ ដែលធ្វើឲ្យសម្តេច នរោត្តម សីហនុ មានកង្វល់ គឺ ឥរិយាបថ របស់ ទីក្រុងហាណូយ ក៏ដូចជា របស់ ទីក្រុងប៉េកាំង និង ម៉ូស្គូ នៅពេលដែលកម្លាំងកុម្មុយនិស្ត បានទទួលជ័យជំនះ ជាស្ថាពរ នៅពេលខាងមុខ ។

នៅថ្ងៃ ១៨ កុម្ភៈ ឧត្តមសេនីយ៍លន់ នល់ វិលត្រឡប់ មកកម្ពុជាវិញ ។ ១០ ថ្ងៃក្រោយមក នៅទីក្រុងប៉ារីស៍ ឯនោះវិញ - ពោល គឺនៅថ្ងៃ ២៧ កុម្ភៈឆ្នាំ ១៩៧០

*ដដែលនោះ - សម្ដេច នរោត្ដម សីហនុ បានប្រាប់ឲ្យដឹងថា ព្រះអង្គ មានគោលបំណងយាង ទៅទីក្រុងប៉េកាំង និង ទីក្រុងម៉ូស្គូ ដើម្បីស្នើ ឲ្យដកកងទ័ពកុម្មុយនិស្ដវៀតណាម ចេញពីទឹកដីខ្មែរ ។ នៅពេលនោះ សម្ដេច នរោត្ដម សីហនុ គ្មានតួនាទី និងអំណាចអ្វីទាំងអស់។ ព្រះអង្គចាប់ផ្ដើមយល់បន្ដិចម្ដងៗ អំពី ភាពទាល់ច្រក របស់ ព្រះអង្គ។ មួយវិញទៀត ព្រះអង្គ ក៏កាន់តែមានជំនឿផងដែរថា បើ កម្លាំងកុម្មុយនិស្ដ ឈ្នះ គឺ ខ្មែរក្រហម ឯនោះទេ ដែលនឹងឡើងមកកាន់អំណាច នៅកម្ពុជា តែបើព្រះអង្គ យាងមកស្រុកខ្មែរវិញ មុនការប្រែប្រួល នៃ ស្ថានការណ៍ ព្រះអង្គ ក៏មិនប្រាកដថា នឹងអាចបង្វិលស្ថានការណ៍ បានដែរ។ មិនតែប៉ុណ្ណោះ ព្រះអង្គអាច នឹង ទទួលគ្រោះថ្នាក់ថែមទៀត ព្រោះអ្វីៗ ជ្រុលហួសអស់ទៅហើយ ។ អ្នកអង្គម្ចាស់ សិរិមតៈ ប្រាកដជាមិនដកថយជាដាច់ខាត ព្រោះថា បើដកថយ សម្ដេច នរោត្ដម សីហនុ ក៏ច្បាស់ជាមិនអត់ឱនឲ្យដែរ។ គួរកត់សំគាល់ផងដែរថា នៅពេលនោះ ឧត្ដមសេនីយ៍ លន់ នល់ នៅមានការស្ទាក់ស្ទើរនៅឡើយ ចំពោះជោគវាសនា របស់ សម្ដេច នរោត្ដម សីហនុ។ មុខព្រួញសំខាន់បំផុត របស់ ឧត្ដមសេនីយ៍ លន់ នល់ នៅពេលនោះ គឺ ដេញកងទ័ពវៀតណាមកុម្មុយនិស្ដ ចេញពីទឹកដីខ្មែរ តែប៉ុណ្ណោះទេ ។ នៅថ្ងៃ ៨ និង ៩ មិនា បាតុកម្ម ប្រឆាំង និង វៀតណាម រៀបចំដោយ មជ្ឈដ្ឋានកងទ័ព បានផ្ទុះឡើង នៅ ខេត្តស្វាយរៀង ។ ១ ថ្ងៃក្រោយមក ស្ថានទូត វៀតណាម ខាងជើង និង ស្ថានតំណាងរដ្ឋាភិបាលបដិវត្ត បណ្ដោះអាសន្ន ហ្សេ អ៊ែរ ប៉េ* (G.R.P.) *នៅភ្នំពេញ បានត្រូវបាតុករជាច្រើនដុតបំផ្លាញ ហើយជនជាតិវៀតណាម ជាង ១០០ នាក់ បាន ត្រូវគេសម្លាប់ ។*

## *មហាបាតុកម្ម នាថ្ងៃ ១១*
## *និង ១៦ មិនាឆ្នាំ ១៩៧០*

### La grande manifestation du 11 et du 13 Mars 1970





*បាតុកម្មនាថ្ងៃ ១១ មិនានៅទីក្រុងភ្នំពេញ ដើម្បីសំដែងការប្រឆាំង នឹង វត្តមានកងទ័ពកុម្មុយនិស្ដ វៀតណាមនៅលើទឹកដីខ្មែរ បានរីករាលដាលយ៉ាងធំ ។ ទីស្នាក់ការនៃ អ្នកតំណាង រណសិរ្សជាតិ រំដោះវៀតណាមខាងត្បូង ព្រមទាំងទីស្នាក់ការ ការធារីវៀតណាមខាងជើង បានត្រូវឆេះឆាប ដោយអគ្គីភ័យ។ នៅពេលនោះ គេចាប់បាន ឯកសារមួយដ៏សំខាន់។ យោងទៅតាមសៀវភៅមួយ របស់លោក ហ្សង់ ម៉ូរីស ដែលមានចំណងជើងថា ប្រទេសកម្ពុជា ពីភាពញញឹមរស់រាយដល់ភាពគួរឲ្យខ្ពើមរអើម* (*Cambodge, du sourire à l’horreur*, Editions France-empire, Paris, 1977, p. 191) *ក្នុងចំណោម ឯកសារជាច្រើន ដែលគេចាប់បាន មានឯកសារមួយដែលបញ្ជាក់ថា នៅពេលក្ដាប់ប្រទេសកម្ពុជាបាន ហើយសម្ដេច នរោត្ដម សីហនុ ត្រូវបញ្ចប់តួនាទី។ ប៉ុន្ដែ សម្ដេច នរោត្ដម សីហនុ ទ្រង់ពុំបានដឹងអំពីរឿងនេះទេ។ នៅថ្ងៃ ១២ មិនា ព្រះអង្គ ទ្រង់បានផ្ញើ ទូរលេខ មួយទៅព្រះមហាក្សត្រីយានី ជាព្រះមាតា ដើម្បីថ្កោលទោសពួកបាតុករ ដែលព្រះអង្គចោទថា សុទ្ធតែជាអ្នកដែលមានគោលបំណង បំផ្លាញមិត្តភាពរវាង ប្រទេសកម្ពុជា និងបណ្ដាប្រទេសកុម្មុយនិស្ដ គឺ ដើម្បីជំរុញប្រទេស ឲ្យធ្លាក់ទៅក្នុង កណ្ដាប់ដៃ សហរដ្ឋ អាមេរិក ។ នៅថ្ងៃ ដដែលនោះ ឧត្ដមសេនីយ៍ លន់ នល់ នាយករដ្ឋមន្ត្រី «រដ្ឋាភិបាលស្រោចស្រង់ជាតិ» បានផ្ញើទូរលេខមួយទៅសម្ដេច នរោត្ដម សីហនុ ដើម្បីទូលព្រះអង្គថា: « ព្រឹត្តិការណ៍ដែលកើតមានឡើង នៅថ្ងៃ ១១ មិនា គឺជាការផ្ទុះកំហឹង របស់ ប្រជាជន ដែលមាន ការឈឺចាប់អស់រយៈពេលរាប់ឆ្នាំមកហើយៗ ដែលយល់យ៉ាងច្បាស់ អំពី គ្រោះថ្នាក់ចំពោះមុខ របស់ ប្រទេសជាតិ» ។ ប៉ុន្ដែ នៅក្នុងទូរលេខនោះ ឧត្ដមសេនីយ៍ លន់ នល់ ក៏ បានគូសបញ្ជាក់ ផងដែរថា: « លោក នឹងរិះរក គ្រប់មធ្យោបាយ ដើម្បីរកផ្លូវមួយដែលត្រឹមត្រូវស្របច្បាប់ ហើយស្រប នឹងសេចក្ដីប៉ងប្រាថ្នា របស់ ប្រជាជនខ្មែរ» ។ ឧត្ដមសេនីយ៍ លន់ នល់ បញ្ជាក់បន្ថែមទៀតថា : «គ្មានរឿងអ្វី ដែលប្រទេសកម្ពុជា ត្រូវចូលទៅក្នុងអង្គការ សន្ធិសញ្ញា អាស៊ី*

អាគ្នេយ៍ (Otase, Seato) ទេ ដោយហេតុថា បើធ្វើដូច្នេះ គឺខុសពីមាគ៌ា របស់សម្តេចឪទាំងស្រុង។ នៅថ្ងៃ ១៣ មិនា ព្រះមហាក្សត្រិយានី ទ្រង់បានកោះហៅ លោក ចេង ហេង ប្រធានរដ្ឋសភា និង លោកនាយករដ្ឋមន្ត្រី ព្រមទាំង សមាជិក រដ្ឋាភិបាលមួយចំនួន ដើម្បី ចាត់វិធានការបញ្ឈប់បាតុកម្ម។ គឺនៅពេលនោះហើយ ដែលឧត្តមសេនីយ៍ លន់ នល់ រៀបចំបញ្ជូន គណប្រតិភូមួយ ដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តម កន្តុល និង លោក យ៉ែម សំបូ ឲ្យទៅចូលគាល់ សម្តេច សីហនុ នៅទីក្រុងប៉ារីស៍ ដើម្បីសាកល្បង ស្ថានការណ៍ ។ នៅថ្ងៃ ១៤ មិនា ព្រះអង្គម្ចាស់ នរោត្តម កន្តុល និង លោក យ៉ែម សំបូ ទៅជួប ឧត្តមសេនីយ៍ លន់ នល់ នៅផ្ទះ របស់ លោក នៅ «ទំនប់ទឹក» ដើម្បីរៀបចំដំណើរ ទៅប្រទេសបារាំង ។ ពេលចេញ ពីផ្ទះ ឧត្តមសេនីយ៍ លន់ នល់ បានបន្ថិច ស្រាប់តែ ឧត្តមសេនីយ៍ លន់ នល់ បោយដៃហៅ ឲ្យគណប្រតិភូចូលមកក្នុងផ្ទះវិញ ព្រោះ លោកទើបនឹងបានទទួល ទូរលេខមួយ ពីសម្តេច នរោត្តម សីហនុ ដែលប្រាប់ថា ព្រះអង្គ មិនទទួលគណប្រតិភូនោះទេ ។

នៅ ថ្ងៃ ១៤ មិនា ដដែលនោះ ក្រសួងការបរទេសខ្មែរ បានផ្ញើកំណត់ហេតុមួយទៅឲ្យរដ្ឋាភិបាល បដិវត្ត បណ្តោះអាសន្ន វៀតណាម «ហ្គេ អែរ ប៉េ » (G.R.P.) និង ទៅឲ្យ«រណសិរ្សរំដោះជាតិ» (F.N.L.) ប្រទេសវៀតណាមខាងត្បូង ដើម្បីសំដែងការសោកស្តាយចំពោះព្រឹត្តិការណ៍ថ្ងៃ ១១ មិនា ប៉ុន្តែ ទន្ទឹមនោះ ក៏សុំឲ្យដកកង ប្រដាប់អាវុធទាំងអស់ចេញពីទឹកដីខ្មែរដែរ គឺសូមឲ្យគោរពច្បាប់អន្តរជាតិ។ អ្នកតំណាងអង្គការទាំងពីរនេះ សូមឲ្យរដ្ឋាភិបាលខ្មែរ ពន្យាពេលបន្តិចទៀត គឺ ហួស ពីថ្ងៃ ១៥ មិនា ដែលរដ្ឋាភិបាលខ្មែរ បានកំណត់ជាកំហិត ។ តាមការពិត តាមរយៈ ពាក្យទូតទាំងនេះ អង្គការ កុម្មុយនិស្តវៀតណាម នៅភ្នំពេញ បានប្រានចោលសេចក្តី ស្នើនេះទាំងស្រុង ។ នៅថ្ងៃ ១៥ មិនា សម្តេច នរោត្តម សីហនុ ធ្វើដំណើរ ពី ទីក្រុងប៉ារីស៍ ឆ្ពោះទៅ ទីក្រុងម៉ូស្គូ។ មួយថ្ងៃបន្ទាប់មក នៅប្រទេសកម្ពុជា រដ្ឋសភា បានបើកសម័យប្រជុំ ដើម្បីពិភាក្សាអំពីរឿងរត់ពន្ធ របស់លោក អ៊ុំ ម៉ាណូរីន តាមសេចក្តីស្នើ របស់ អ្នកតំណាង





រាស្ត្រ ស៊ិម វ៉ា ។ នៅពេលនោះ នៅ ខាងមុខ អាគាររដ្ឋសភា គេឃើញបាតុករ ជាច្រើនកុះករ មីរដេរដាស នាំគ្នាទារឲ្យវៀតណាមខាងជើង និង ពួកវៀតកុង ដកកងទ័ព របស់គេចេញ ពីទឹកដីខ្មែរ ។ នៅពេលដែលបាតុករ កំពុង ចែកលិខិតបណ្ណ ប្រឆាំងនឹងសម្តេច នរោត្តម សីហនុ ស្រាប់តែជនជាតិវៀតណាម ពីរនាក់ បានបោះ លិខិតបណ្ណនោះចោល ជាហេតុធ្វើឲ្យមាន ការប្រវាយប្រតប់គ្នា មួយរំពេច ។ យោងទៅតាមអ្នកវិភាគស្ថានការណ៍ នៅពេលនោះ នេះជាផែនការមួយ របស់ លោក អ៊ុំ ម៉ាណូរីន រដ្ឋលេខាធិការ ការពារផ្ទៃប្រទេស ដែលក្តាប់កម្លាំង នគរបាល ទាំងមូល ហើយដែលត្រៀមលក្ខណៈជាស្រេច ដើម្បីទប់ទល់ នឹង កងទ័ព របស់ ឧត្តមសេនីយ៍ លន់ នល់ នៅក្នុងករណីដែលសម្តេច នរោត្តម សីហនុ ត្រូវ រដ្ឋសភាទម្លាក់ចេញ ពីអំណាច។ នៅក្នុងពេល ដដែលនោះ មាន ពាក្យចចាមអារាមថា សម្តេច នរោត្តម សីហនុ នឹង យាងវិលត្រឡប់ មកកម្ពុជាវិញ នៅថ្ងៃ ២៤ ឬ ២៦ មិនា ដើម្បី រំលាយរដ្ឋសភាចោល ហើយដកហូត រដ្ឋាភិបាល ឧត្តមសេនីយ៍ លន់ នល់ ចេញ។

# បដិវត្តន៍ របស់ អ្នកអភិរក្ស

# La Révolution des conservateurs





# ជំពូក ៦

## ការចេញមិនរួច ពី រចនាសម្ព័ន្ធ ចាស់

## L’impossible restructuration

សាធារណរដ្ឋខ្មែរ បានចេញ ជារូបរាងឡើង នៅពេលមួយ ដែលអ្នកដឹកនាំខ្មែរ មិនទាន់ដកចិត្តគំនិត និង ទម្លាប់ ចេញពីរបប រាជានិយមនៅឡើយ ។ នៅក្នុងករណី នៃ របប រាជានិយមខ្មែរនេះ ដែលជា របបរាជានិយមជ្រើសតាំង(monarchie élective) របៀបគ្រប់គ្រង នៅតែមានលក្ខណៈឯកាធិបតេយ្យ (monocratie) ជដែល។ កាល សម័យព្រះបាទជ័យវរ្ម័ន ទី ៧ (១១៨១-១២១៨) ការផ្លាស់ប្តូរពី លទ្ធិទេវរាជ (De-varāja) ដែលមាន សីវលិង្គ ជានិមិត្តរូប មក លទ្ធិពុទ្ធសាសនា មហាយានដែលមាន លោកេស្វរៈ ជានិមិត្តរូប គេគោរពបូជា ព្រះមហាក្សត្រ ដូច ព្រះសីវ ជដែល ។ ម៉្យាង ទៀត ពី «កម្រាតេងអញជគតតរាជ្យ» (ម្ចាស់ទេវទាំងអស់ នៃចក្រវាឡ) មកដល់អ្នក «មកជួយសង្គ្រោះមនុស្សលោក» អំណាច នៅតែចេញមកពី ព្រះឥន្រ្ទាធិរាជជដែល ។ រី ឯ ពុទ្ធសាសនា ហិនយាន ឬថេរវាទ ដែលចាប់ផ្តើមចេញរូបរាងឡើងសាជាថ្មី នៅស្រុក ខ្មែរ នៅសម័យស្តេចឥន្រ្ទវរ្ម័ន ទី ៣ (១២៩៥-១៣០៨) ហើយដែលបន្ទាប់ ពីស្តេចពីរអង្គ ដែលគោរពបូជាព្រះសីវ (ឥន្រ្ទជ័យវរ្ម័ន និងជ័យវរ្ម័នទី ៩) និង ក្រោយ បដិវត្តន៍ ពុទ្ធ សាសនា (តាត្រសក់ផ្អែម) ចាប់ផ្តើមមាន ឥទ្ធិពល រហូត ជាពិសេស ចាប់តាំង ពីចុង សតវត្សរ៍ទី ១៥ មក ក្នុងរជ្ជកាលស្តេច ធម្មោរាជា (១៤៨៦-១៥០៤)។ ប៉ុន្តែ ព្រះមហា ក្សត្រ នៅតែមិនស្ថិតនៅ ក្រោមពុទ្ធសាសនា ជដែលជា គឺ មិនសូវ សំអាង សេចក្តី

*សម្រេចផ្សេងៗ ទៅតាម «មានវធម្មសាស្ត្រ»* (Mānava Dharmasāstra *ឬ* Loi de Manu) *ឡើយ។ លុះមកដល់ សម័យ រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ នៅ ឆ្នាំ ១៩៤៧ លទ្ធិប្រជាធិបតេយ្យ តាមបែបបទបារាំង នៅតែគ្របដណ្តប់ ទៅលើរបៀបរបបដឹកនាំ ពីសម័យមុនៗ មិនបានដដែល។ សម្តេចនរោត្តម សីហនុ បាននាំទស្សនៈ «កម្រាតេងអញ ជគតតរាជ»* (Maître de l’Univers) *មកដឹកនាំប្រទេស បន្តមកទៀត ទោះបី ព្រះអង្គបានយក ស្ថាប័ន ប្រទេសសង្គមនិយម មកបិទបាំង ក្តី ហើយធ្វើឲ្យ អ្នកជំនាន់ក្រោយៗ មកទៀត យល់ថា ជា របបប្រជាធិបតេយ្យ ផ្ទាល់ពាក់កណ្តាល* (démocratie semi-directe) *ក្តី។*

*នៅពេលដែល ឧត្តមសេនីយ៍ លន់ នល់ និង អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ប្រកាស របប «សាធារណរដ្ឋខ្មែរ» នៅថ្ងៃ ៩ តុលាឆ្នាំ ១៩៧០ ប្រជាជនខ្មែរភាគច្រើន និង អ្នកដឹកនាំ ពុំទាន់លុបបំបាត់ ពីអារម្មណ៍ របស់គេ នូវ លោកទស្សនៈ ពី បុរាណកាលនៅឡើយ* (représentations collectives) *គឺ មាន ទេវតា ព្រះឥន្ទ្រ អារក្ខអ្នកតា ជាអ្នកថែរក្សាទឹកដី ។ សាធារណរដ្ឋខ្មែរ បានត្រូវប្រកាស នៅពេលដែល បញ្ញវន្តមួយក្រុម បានធ្វើការគាបសង្កត់ទៅលើ អ្នកដែលបានទម្លាក់ សម្តេច នរោត្តម សីហនុ ពីតួនាទីប្រមុខរដ្ឋ របស់ ព្រះអង្គ ហើយដែលមាន ឧត្តមសេនីយ៍ លន់ ណុន ជាកត្តាឧបហេតុ* (catalyseur)*។ កាលនោះ ឧត្តមសេនីយ៍ លន់ ណុន ប្អូនប្រុស របស់ ឧត្តមសេនីយ៍ លន់ នល់ ចង់បណ្តើមអំណាច ពីអ្នកអង្គម្ចាស់សិរិមតៈ។ ដើម្បី រកការគាំទ្រសម្រាប់ធ្វើកិច្ចការនេះ លន់ ណុន បែរទៅរក បញ្ញវន្ត ដែលមិនមែនកុម្មុយនិស្ត ហើយដែលប្រាថ្នាចង់បាន របប សាធារណរដ្ឋសេរីនិយម។ មួយវិញ ទៀត កាលៈទេសៈដែលរបបនេះ ចាប់បដិសន្ធិ នៅស្រុកខ្មែរ ជាលើកដំបូងបង្អស់ នៅក្នុងប្រវត្តិសាស្ត្រ គឺ ពេលដែលអ្នកអភិរក្សស្តាំនិយម កំពុងធ្វើសង្គ្រាម ប្រឆាំង នឹង ការដាក់ទ័ព របស់ ប្រទេសវៀតណាមកុម្មុយនិស្ត នៅលើទឹកដីខ្មែរ ហើយប្រឆាំង នឹងប្រទេសចិនកុម្មុយនិស្ត ដែលជួយទីក្រុងហាណូយ កំចាត់ អាមេរិកចេញ ពី ឥណ្ឌូចិន ។ ទីក្រុងហាណូយ ទីក្រុង*





*ប៉េកាំង ព្រមទាំងបញ្ញវន្តឆ្វេងនិយម ជំទាស់ នឹងការទម្លាក់សម្តេច នរោត្តម សីហនុ យ៉ាងពេញទំហឹង ព្រោះខុសទាំងបក្សពួក ខុសទាំងមនោគមវិជ្ជា។ ដូច្នេះឃើញថា គឺជាបដិវត្តន៍នយោបាយសុទ្ធសាធ ព្រោះគ្មាន ការបះបោរ របស់ ប្រជាជនដើម្បីទាមទារការប្តូរស្ថាប័នគ្រប់គ្រងប្រទេស* ( projet de société)*។ ម្ល៉ោះហើយ មានតែច្បាប់ដែលនៅសល់ពី រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ ប៉ុណ្ណោះ ដែលអាចជា មូលដ្ឋាន នៃរបបសាធារណរដ្ឋខ្មែរ។ ប៉ុន្តែក្រោយរដ្ឋប្រហារ របស់ព្រះមហាក្សត្រ នរោត្តម សីហនុ នៅឆ្នាំ ១៩៥២ ម្តង (ការរំលាយរដ្ឋសភា ជំនាន់រដ្ឋាភិបាល លោក ហ៊ុយ កន្ធុល) នៅ ឆ្នាំ ១៩៥៥ ម្តង (ការបង្កើតចលនា សង្គមរាស្ត្រនិយម) ហើយ និង ការព្រមាន គណបក្សប្រជាធិបតេយ្យ នៅថ្ងៃ ១១ សីហាឆ្នាំ ១៩៥៧ ម្តងទៀត ប្រទេសកម្ពុជា បានវិលទៅរក របបឯកាធិបតេយ្យវិញ ហើយ របបនេះ គ្រប់គ្រង ស្រុកខ្មែររហូតដល់ឆ្នាំ ១៩៧០ ។ ស្ថាប័នប្រជាធិបតេយ្យ បានវិលមកវិញមែន តែ លោកទស្សនៈ ឥតមានការប្រែប្រួល ហើយអ្នកសាធារណរដ្ឋ ក៏ មានចំនួនតិចតួចក្រៃលែង ហើយនេះ ដោយមិននិយាយ ពីបញ្ញវន្តនិងយុវជនដែល បានត្រូវប្រជាភិបុតិ របស់កុម្មុយនិស្ត អូសទាញផងទេ។ អ្នកដឹកនាំខ្មែរ ព្រមទាំង មន្ត្រីរាជ(រដ្ឋ)ការ តាំងពីជំនាន់ណាមក ច្រើនប្រកាន់ អាកប្បកិរិយា ជាមេ ឬជាម្ចាស់ របស់ក្រុមបក្សពួក របស់គេដូចស្តេច ដូច្នេះដែរ ។ ម្ល៉ោះហើយ គេពុំសូវគោរពសិទ្ធិសេរីភាព របស់ ប្រជាពលរដ្ឋ ប៉ុន្មានទេ ។ ទោះជាយ៉ាងណាក្តី គេអាចសន្និដ្ឋានបានថា បើកុំតែខ្មែរក្រហមវាយរំលំរបបសាធារណរដ្ឋខ្មែរតាមផ្លូវយោធា សាធារណរដ្ឋខ្មែរ ក៏អាច នឹង ឈានទៅដល់ការរីកចម្រើនបានដែរ ព្រោះ វប្បធម៌ កាលសម័យនោះមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការវិវត្តន៍ ឆ្ពោះទៅរកគំរូមួយ នៃ សង្គមសម័យទំនើប ទោះជា ត្រូវឆ្លងកាត់ ភាពអនាធិបតេយ្យ មួយរយៈពេលសិនក្តី ព្រោះការយល់ដឹង អំពីលទ្ធិសេរីនិយម នៅមានកម្រិតនៅឡើយ រីឯការប្រកាន់ឥរិយាបថសេរីនិយម* (comportement libéral) *នៅពុំទាន់ផ្តាច់ចេញបានពី មតិក ដែលនៅសល់ពីមុនៗ។*

# ព្រឹត្តិការណ៍ថ្ងៃ ១៨ មិនា ឆ្នាំ១៩៧០: សភាទាំងពីរ ទម្លាក់ សម្តេច នរោត្តម សីហនុ ប្រមុខរដ្ឋ នៃ ប្រទេស កម្ពុជា ចេញ ពី អំណាច

## 18 mars 1970 : destitution du prince Norodom Sihanouk

បន្ទាប់ពីលោក អ៊ុំ ម៉ាណូរីន រដ្ឋលេខាធិការ ការពារផ្ទៃប្រទេស ដែលស្មោះត្រង់ នឹងសម្តេច នរោត្តម សីហនុ បានត្រូវគេយកទៅឃុំទុក នៅក្នុងផ្ទះ របស់លោកនៅថ្ងៃ ១៧ មិនា គឺ ក្រោយពេលដែលលោក ត្រូវបង្ខំចិត្ត លាលែង ពី មុខតំណែងបន្តិច រដ្ឋាភិបាល របស់ លោក ឧត្តមសេនីយ៍ លន់ នល់ ក្តាប់ស្ថានការណ៍បានទាំងស្រុង។ នៅ ថ្ងៃ ១៨ មិនា សភាទាំងពីរ ប្រកាសដាក់ប្រទេសកម្ពុជា ទាំងមូលឲ្យស្ថិតក្នុងភាពអាសន្ន ហើយបោះឆ្នោតទម្លាក់សម្តេច នរោត្តម សីហនុ ពីមុខតំណែងប្រមុខរដ្ឋតែម្តង។ លើកលែងចេញ តែអ្នកតំណាងរាស្ត្រ មួយចំនួន ដែលជាប់បំពេញបេសកកម្មពិសេស ជារដ្ឋមន្ត្រី អ្នកតំណាងសភាទាំងពីរ ចំនួន ៩២ រូប ដែលមានវត្តមាន បានបោះឆ្នោត ជាឯកច្ឆន្ទ ទម្លាក់សម្តេច នរោត្តម សីហនុ ។

នៅថ្ងៃនោះឯង នៅខាងក្រៅអាគារ រដ្ឋសភាជាតិ គេឃើញរថក្រោះ ជាច្រើនគ្រឿង ឡោមព័ទ្ធអាគារនោះជិតស្អូង ដើម្បីការពារសន្តិសុខ អ្នកតំណាងរាស្ត្រ។ បើតាមការវិភាគ របស់អ្នកឯកទេសច្បាប់ នៅពេលនោះ ការបោះឆ្នោតទម្លាក់ប្រមុខរដ្ឋ របៀបនេះ ជាការត្រឹមត្រូវតាមផ្លូវច្បាប់ ព្រោះ នីតិវិធីនេះ ផ្អែកទាំងស្រុង ទៅលើ មាត្រា ១៥ នៃ រដ្ឋធម្មនុញ្ញ ជាធរមាន ។ ដូច្នេះ គេមិនអាច ចាត់ទុកថា ជា រដ្ឋប្រហារ បានឡើយ ។ ប្រសិនណាជា សម្តេច នរោត្តម សីហនុ ស្ថិតនៅ ជាព្រះមហាក្សត្រ កិច្ចការនេះ ពិតជាពុំអាចធ្វើបានទេ។ ប៉ុន្តែ ចាប់តាំង ពីឆ្នាំ ១៩៦០ មក សម្តេច នរោត្តម សីហនុ បានត្រូវតែងតាំង ជាប្រមុខរដ្ឋ ដោយសភាទាំងពីរ តែប៉ុណ្ណោះ ហើយ សភាទាំងពីរនេះ ក៏





អាចដកហូត អំណាចពីព្រះ អង្គវិញបានដែរ។ នៅវេលា ម៉ោង ១ ថ្ងៃ រសៀលនាថ្ងៃ ១៨ មិនានោះ អ្នកតំណាងរាស្ត្រ បានបោះឆ្នោត ធ្វើការប្រែប្រួល ស្ថានភាព ប្រទេសកម្ពុជាទាំងស្រុង ហើយដាក់ លោក ចេង ហេង ប្រធានរដ្ឋសភា ឲ្យធ្វើជា ប្រមុខរដ្ឋជំនួសបណ្តោះអាសន្ន ។ នៅក្នុងពេល ដដែលនោះ សម្តេច នរោត្តម សីហនុ កំពុងធ្វើព្រះរាជ ដំណើរ ទៅ ទីក្រុងម៉ូស្គូ ដើម្បី ស្នើសុំឲ្យ សូវៀត ដកកងទ័ពវៀតណាម ចេញពីទឹកដីខ្មែរ ។ ព្រះអង្គ បានដឹងព្រឹត្តិការណ៍នេះ តាមរយៈអ្នកដឹកនាំសូវៀត ដែលត្រៀមលក្ខណៈជាស្រេចទទួលស្គាល់អ្នកដឹកនាំថ្មី នៃ ប្រទេសកម្ពុជា ។ ដើម្បី ចៀសវាង កុំឲ្យមានការខុសគ្នាងខាងការទូត ទីក្រុងម៉ូស្គូ ត្រូវតែធ្វើយ៉ាងណាឲ្យអតីតប្រមុខរដ្ឋខ្មែរ ដែលទើបនឹងត្រូវទម្លាក់ចេញពីអំណាច ចេញឲ្យផុតពី ទឹកដី សូវៀតយ៉ាងឆាប់រហ័សបំផុត។ នៅពេលចាកចេញពីទីក្រុងម៉ូស្គូ តាមយន្តហោះពិសេស របស់សូវៀត សម្តេច នរោត្តម សីហនុ ព្រមទាំងព្រះជាយា អ្នកម្នាង ម៉ូនិច និង លោក ប៉ែន នុត បានសម្រេច យាងទៅទីក្រុងប៉េកាំងតែម្តង។ នៅរដ្ឋធានីប្រទេសចិន ប្រជាមានិតុងណោះ កាលបើបានដឹងថា សម្តេច នរោត្តម សីហនុ ទ្រង់យាងមក ទីក្រុងប៉េកាំង អ្នកដឹកនាំចិន មានការបារម្ភយ៉ាងខ្លាំង ព្រោះគេខ្លាច មានការប៉ះពាល់ ដល់ការទូត របស់ គេដែរ ។ លោក ជូ អេនឡាយ រដ្ឋមន្ត្រី ការបរទេសចិន ចាយពេលអស់ពេញមួយយប់ ដើម្បី ជជែកពិគ្រោះជាមួយ លោក អេជេន ម៉ាណាស៍ ឯកអគ្គរដ្ឋទូតបារាំង អំពី ការដែលថា តើប្រទេសចិន ត្រូវទទួលអតីត ប្រមុខរដ្ឋខ្មែររបៀបណា ដើម្បីកុំឲ្យប៉ះពាល់ដល់ការទូត និង យុទ្ធសាស្ត្រ នយោបាយ របស់ គេ ។ នៅទីបំផុត ប្រទេសចិន បានសម្រេចទទួលសម្តេច នរោត្តម សីហនុ យ៉ាងអធិកអធមតែម្តង។ តាមការពិត ចិន និង បារាំង បានកំណត់យក នយោបាយផ្លូវ ទី ៣ តាំងពីយូរណាស់ រួចបាត់ទៅហើយ គឺ ទីតាំងមួយផ្សេងទៀតក្រៅពីការកំណត់ របស់ មហាអំណាច ទាំងពីរ គឺ សហភាព សូវៀត និង សហរដ្ឋអាមេរិក ។ នៅទីក្រុងភ្នំពេញ ឯនោះវិញ នៅថ្ងៃ ២២ មិនា រដ្ឋាភិបាល ឧត្តមសេនីយ៍ លន់ នល់ ស្នើសុំឲ្យសហប្រធានទាំងពីរ នៃ សន្និសីទ ទីក្រុងហ្សឺណែវ ធ្វើយ៉ាងណា

ឲ្យវៀតណាមខាងជើង ដកកងទ័ព របស់គេចេញពីប្រទេសកម្ពុជា ដោយសន្តិវិធី។ មួយថ្ងៃបន្ទាប់មកនៅទីក្រុងប៉េកាំងសម្តេច នរោត្តម សីហនុ ប្រកាសបញ្ចូលប្រទេស កម្ពុជាទៅក្នុង បក្សសម្ពន្ធ នៃ បណ្តាប្រទេសសង្គមនិយម ហើយថែមទាំងស្នើសុំឲ្យ កងទ័ពវៀតណាមខាងជើង និងវៀតកុង ធ្វើអន្តរាគមន៍ទៀតផង។ ប៉ុន្មានថ្ងៃក្រោយមក ព្រះអង្គបង្កើតរណសិរ្សមួយឈ្មោះថា «រណសិរ្សរួបរួមជាតិកម្ពុជា» (F.U.N.K.) ដើម្បីប្រយុទ្ធតទល់ នឹង របបរបស់ ឧត្តមសេនីយ៍ លន់ នល់-សិរិមតៈ ។ តាមរយៈ រណសិរ្សនេះព្រះអង្គ អំពាវនាវឲ្យអ្នកដែលគាំទ្រព្រះអង្គនៅក្នុងប្រទេស ងើបឡើងបះបោរផងទៀត។ គឺនៅពេលនោះហើយ ដែលកងទ័ពវៀតណាមខាងជើង ប្រមាណ ៥ កងពលតូច (5 divisions) ឆ្លៀតឱកាស វាយសម្រុកទៅលើកងទ័ពឧត្តមសេនីយ៍ លន់ នល់ តែម្តង ។ នៅពេលនោះ កងទ័ពខ្មែរ មានគ្នាត្រឹម ៣ ម៉ឺននាក់ ប៉ុណ្ណោះ ហើយពុំមានអាវុធ យុទ្ធភ័ណ្ឌគ្រប់គ្រាន់ទៀត ព្រោះពុំបានព្រាងស្ថានការណ៍ នេះ ទុកជាមុន ហើយ ខាងសហរដ្ឋអាមេរិក គេបានដឹងរឿងនេះ តែ ២ ឬ ៣ ថ្ងៃ មុនប៉ុណ្ណោះ គឺ គ្មានផែនការ គ្មានថវិកាសម្រាប់ធ្វើការប្រឈមមុខ នឹង បញ្ហាថ្មីនេះ ។ ប្រជាជនខ្មែរជាច្រើន បានត្រូវ កងទ័ពវៀតណាមខាងជើង និង កម្លាំងខ្មែរក្រហម កេណ្ឌយកទៅដាក់នៅជួរមុខ នៃ កងទ័ពរបស់ពួកគេ ដើម្បីឲ្យកងទ័ពឧត្តមសេនីយ៍ លន់ នល់ បាញ់រះទៅលើ ជាហេតុធ្វើឲ្យប្រទេសកម្ពុជា នៅខណៈនោះ ក្លាយទៅជា ថ្លុកឈាមមួយ ដ៏ធំ ។ ការប្រយុទ្ធគ្នា មានលក្ខណៈសាហាវអស្ចារ្យ រវាង កងទ័ព ឧត្តមសេនីយ៍ លន់ នល់ និង កងទ័ពវៀតណាមខាងជើង លាយឡំជាមួយកងទ័ពខ្មែរក្រហមផងដែរ ក្រោមទង់ នៃអ្វី ដែលគេហៅថា «កងទ័ពរំដោះ» ដឹកនាំដោយសម្តេច នរោត្តម សីហនុ អតីតប្រមុខរដ្ឋ នៃប្រទេសកម្ពុជា ។ នៅក្នុងការប្រយុទ្ធនេះ កងទ័ពឧត្តមសេនីយ៍ លន់ នល់ បាញ់សម្លាប់ប្រជាជនខ្មែរ ដែលកងទ័ពវៀតកុង និង ខ្មែរក្រហម បានយកមកដាក់ ពីមុខពួកគេយ៉ាងខ្លោចផ្សា ជាហេតុធ្វើឲ្យកាសែត អន្តរជាតិ យក ទស្សនីយភាព ដ៏គួរឲ្យរន្ធត់ ដែលគេថតបាន មកលាតត្រដាង ក្នុងពិភពលោកទាំងមូល ។





# ស្ថានភាព ប្រទេសកម្ពុជា
# ក្រោយ ការទម្លាក់ សម្តេច នរោត្តម សីហនុ

## Le Cambodge
## après la destitution de Sihanouk

បន្ទាប់ពីការបង្ហូរឈាម នា ថ្ងៃ ២៦ មិនា នៅខេត្តកំពង់ចាម ការប្រយុទ្ធ រវាង កងទ័ព របស់ឧត្តមសេនីយ៍ លន់ នល់ តទល់នឹង កងទ័ពព្រៃ វៀតណាម ខាងជើង កងទ័ពវៀតកុង នឹងកងទ័ពខ្មែរក្រហម បន្តទៅទៀត យ៉ាងខ្លាំងក្លារហូតដល់ថ្ងៃ ២៨-២៩ មិនា។ នាថ្ងៃ ២៨ មិនានោះ រថក្រោះ របស់ កងទ័ពឧត្តមសេនីយ៍ លន់ នល់ ដណ្តើមយកខេត្តកំពុងចាម បានមកវិញ ហើយរុញច្រាន កងទ័ពវៀតកុង បាក់បែកខ្ចាត់ខ្ចាយអស់។ កងទ័ពព្រៃវៀតណាមកុម្មុយនិស្ត បាននាំគ្នារត់ទៅពួននៅក្នុងព្រៃភ្នំ បូគោ គិរីរម្យ និងកំពង់ស្ពឺ។ នៅ ចំពោះមុខ សហគមន៍ អន្តរជាតិ ទោះបី របបរបស់ ឧត្តមសេនីយ៍ លន់ នល់-សិរិមតៈ បានត្រូវ អ្នកកាសែតឆ្វេងនិយម ថ្កោលទោស យ៉ាងណាក្តី ក៏នៅទីបំផុត បានត្រូវលោក អ៊ូ ថាន់ អគ្គលេខាធិការ អង្គការ សហប្រជាជាតិ ទទួលស្គាល់ថា ជារបបត្រឹមត្រូវតាមផ្លូវច្បាប់ដែរ។ ចំពោះស្ថាប័នអន្តរជាតិនេះ សង្គ្រាម ដែលកើតឡើងនៅក្នុងប្រទេសកម្ពុជា នៅពេលនោះ ជាសង្គ្រាមដែលរដ្ឋាភិបាល នៃ ប្រទេសមួយធ្វើឡើងដើម្បីប្រយុទ្ធតទល់ នឹងកងទ័ពឈ្លានពានបរទេស។ ដោយយោង ទៅតាមច្បាប់អន្តរជាតិ នៅ ថ្ងៃ ៦ មេសាឆ្នាំ ១៩៧០ ដដែលនោះ អង្គការ សហប្រជាជាតិចាត់ទុកថា របប របស់ ឧត្តម សេនីយ៍ លន់ នល់ ជា របបត្រឹមត្រូវតាមផ្លូវច្បាប់ដោយទាត់ចោល ការប្រកាស អំពាវនាវ របស់សម្តេច នរោត្តម សីហនុ ទាំងស្រុង។ នៅពេលមុននេះបន្តិច គឺ នៅ ថ្ងៃ ៣០ មិនា ឧត្តមសេនីយ៍ លន់ នល់ បានអំពាវនាវសុំឲ្យ សហគមន៍ អន្តរជាតិ ជួយធ្វើការទប់ទល់ នឹង កម្លាំង កងទ័ពវៀតកុង នៅក្នុងប្រទេស ព្រោះក្រោយពេល ដែលកងទ័ពឧត្តមសេនីយ៍ លន់ នល់ វាយយក កំពង់ចាម

*បានវិញ កងទ័ពវៀតកុង ត្រៀមលក្ខណៈវាយសម្រុកសាជាថ្មីទៀត នៅក្នុងទ្រង់ទ្រាយធំតែម្តងៗ នៅ ថ្ងៃ ៣០ មិនា ដដែលនោះ កងទ័ពនាវាចរ វៀតណាមខាងត្បូង បានចូលមកជួយធ្វើអន្តរា គមន៍ ប៉ុន្តែ អន្តរាគមន៍នោះ បានធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរ ដល់ ប្រជាពលរដ្ឋខ្មែរ ព្រោះ ពួកទាហានយួនប្រកាន់អាកប្បកិរិយាមិនគួរគប្បី ដូចជាការរំលោភ ទៅលើ ស្ត្រីភេទ ជាដើមៗ ទោះបីឧត្តមសេនីយ៍ លន់ នល់ បានបញ្ជាក់យ៉ាងច្បាស់ អំពីគោលជំហរ អព្យាក្រឹតភាពឥតលំអៀងរបស់រដ្ឋាភិបាលខ្មែរក្តី ក៏បន្តិចម្តងៗ ការប្រយុទ្ធទប់ទល់ នឹងការឈ្លានពាន របស់កងទ័ពវៀតណាម ខាងជើង បានក្លាយទៅជា សង្គ្រាមរវាង ប្លុកមនោគមវិជ្ជា ទាំងពីរដែរៗ ជាការពិតហើយ ដែលថា បន្ទាប់ពីសភាទាំងពីរបានទម្លាក់ សម្តេច នរោត្តម សីហនុ / យុវជន និង បញ្ញវន្តខ្មែរជាច្រើន បានសំដែងការអបអរយ៉ាងខ្លាំង ព្រោះនៅទីបំផុត រដ្ឋាភិបាលខ្មែរ ដឹកនាំដោយ ឧត្តមសេនីយ៍ លន់ នល់ និងសិរិមតៈ បានដេញកងទ័ពឈ្លានពាន ចេញពីស្រុក ហើយ មួយ ចំណែកទៀតប្រទេសកម្ពុជា នឹងប្រកាន់យក របបសាធារណរដ្ឋ គឺរបបមួយ ដែលគេប្រាថ្នា ចង់បានតាំង ពិយូរមកហើយ ។ នៅ ថ្ងៃ ១១ មេសា នា ឆ្នាំ ១៩៧០ នោះ យុវជនចំនួន ១ ម៉ឺននាក់ បានមកជួបជុំគ្នានៅ ពហុកីឡាដ្ឋាន រៀបចំដំណើរព្យុហយាត្រាមួយ ដ៏អធិកអធមប្រារព្ធការស្រុះស្រួលមូលមតិ រួបរួមគ្នា ជាសំបាច់តែមួយ ។*

*ទោះបីរដ្ឋាភិបាល របស់ ឧត្តមសេនីយ៍ លន់ នល់ ស្ថិតនៅក្នុងភាពត្រឹមត្រូវតាមផ្លូវច្បាប់ក្តី ទោះបី មានការគាំទ្រ ពី មជ្ឈដ្ឋាន នានា ក្រៅពីប្លុកកុម្មុយនិស្តក្តី ហើយទោះបី កងទ័ព បានកើនពីចំនួនពីជាង ៣ ម៉ឺននាក់ មកចំនួន ១២ ម៉ឺននាក់ក្តី ក៏ប្រទេសទាំងមូល ស្ថិតនៅក្នុងកង្វល់មួយដ៏ធំដែរ ព្រោះត្រូវប្រឈមមុខ នឹង កងទ័ព វៀតណាមខាងជើង និង កងទ័ពខ្មែរក្រហម ដ៏ខ្លាំងមហិមាៗ ម្យ៉ាងទៀត សភាពការណ៍បែបនេះមិនអនុញ្ញាតឲ្យឧត្តមសេនីយ៍ លន់ នល់ អាចមានលទ្ធភាព គ្រប់គ្រាន់ សម្រាប់កសាងរបៀបរបបដឹកនាំថ្មី ដោយស្រួលបានឡើយ ។ ដោយព្រោះតែ សង្គ្រាម / សេដ្ឋកិច្ចជាតិទាំង មូលចុះស្រុតយ៉ាងខ្លាំងៗ មួយវិញទៀត នៅពេលនោះ ប្រទេសវៀតណាម កុម្មុយ*





*និស្ត និងប្លុកកុម្មុយនិស្តទាំងមូល កំពុងតែត្រូវសាធារណ មតិ ជាពិសេសយុវវ័យ គាំទ្រយ៉ាងសម្បើម ទៀតផង ដោយហេតុថាៈ ទី ១ សហរដ្ឋ អាមេរិក ធ្វើសង្គ្រាមឈ្លានពានប្រទេសវៀតណាម ហើយ ទី ២ នៅក្នុងពិភពលោកទាំងមូល នៅសម័យនោះ មនោគម វិជ្ជាកុម្មុយនិស្ត បានត្រូវយុវជន និង បញ្ញវន្ត មួយភាគធំ នាំគ្នាគាំទ្រ យ៉ាងពេញទំហឹងៗ បើកុំតែមាន សភាពការណ៍បែបនេះ សាធារណរដ្ឋខ្មែរ ដែលបានត្រូវប្រកាសនៅថ្ងៃ ៩ តុលា ឆ្នាំ ១៩៧០ ប្រហែលជាមានជំហរ រហូតមកដល់ សព្វថ្ងៃនេះៗ ដើម្បីវាយរំលំរបប ឧត្តមសេនីយ៍ លន់ នល់ សម្តេច នរោត្តម សីហនុ បានបង្កើត រដ្ឋាភិបាលនិរទេសខ្លួន មួយ* (gouvernement en exil) *នៅ ថ្ងៃ ៥ ឧសភា ឆ្នាំ ១៩៧០ ដដែលនោះ ដោយមានបង្អែកពី កងទ័ពខ្មែរក្រហម និង កងទ័ពវៀតណាម ខាងជើង ព្រមទាំងជំនួយ សព្វសារពើ ពី ប្រទេសចិនប្រជាមានិត ។ ដោយ រដ្ឋាភិបាល របស់ សម្តេច នរោត្តម សីហនុ មានបង្អែក ពីកុម្មុយនិស្តដូច្នេះ សហរដ្ឋ អាមេរិក ត្រូវតែជួយរដ្ឋាភិបាល ឧត្តមសេនីយ៍ លន់ នល់ ជាកំហិត បើពុំនោះសោតទេ ប្រទេសកម្ពុជាមុខជាធ្លាក់ទៅក្នុងកណ្តាប់ដៃ កុម្មុយនិស្ត យ៉ាងឆាប់រហ័ស ជាពុំខានៗ ប៉ុន្តែ ទាល់តែថ្ងៃ ១៥ កញ្ញាឆ្នាំ ១៩៧០ ទើបទីក្រុងវ៉ាស៊ិងតោន មានផែនការ ជួយប្រទេសកម្ពុជា ជាដុំកំភួន ក៏ ប៉ុន្តែ គឺចាប់តាំង ពីពេលនោះមកដែរ ដែលប្រទេសកម្ពុជា ក្លាយទៅជា លានប្រយុទ្ធមួយ ដ៏ខ្លោចផ្សា រវាងកម្លាំងកុម្មុយនិស្ត នឹង កម្លាំង របស់ សហរដ្ឋ អាមេរិកៗ*

## *ការប្រកាស របប សាធារណរដ្ឋខ្មែរ*
## *នៅ ថ្ងៃ ៩ តុលា ឆ្នាំ ១៩៧០*

## Proclamation de la République khmère le 9 octobre 1970

នៅឆ្នាំ ១៩៧០ នៅពេលដែល កងទ័ពកុម្មុយនិស្តវៀតណាមខាងជើង បង្កើត អសន្តិសុខពេញទូទាំង ប្រទេសកម្ពុជា សហរដ្ឋ អាមេរិក រិះរកគ្រប់មធ្យោបាយ ដើម្បី ជួយកងទ័ព ឧត្តមសេនីយ៍ លន់ នល់ ។ នៅ ទីក្រុងវ៉ាស៊ីងតោន នៅ ថ្ងៃ ១៥ កញ្ញា លោក ហង់រី គីស្ស៊ីងហ្គែរ (Henry Kissinger) ទីប្រឹក្សារបស់លោក ប្រធានាធិបតី និចសុន បានបើកអង្គប្រជុំមួយ ដើម្បីសាកសួរយោបល់ របស់អ្នកវិភាគ ស្ថានការណ៍ ចំណានៗ។ មួយខែក្រោយមក នៅ ថ្ងៃ ១៦ តុលា គឺ ១ សប្តាហ៍ ក្រោយការប្រកាស របបសាធារណរដ្ឋខ្មែរ លោក គីស្ស៊ីងហ្គែរ បានបើកអង្គប្រជុំ អ្នកវិភាគស្ថានការណ៍ សាជាថ្មីទៀត ហើយ បានសំរេច អនុវត្ត យុទ្ធសាស្រ្ត លេខ ៣ តែម្តង ។ ប៉ុន្តែ ចំពោះ លោក ប្រធានាធិបតីអាមេរិក រីកឈិត និចសុន (Richard Nixon) ការធ្វើអន្តរា គមន៍យោធា នៅប្រទេសកម្ពុជា វាជារឿងមួយ ដ៏ស្មុគស្មាញ ដោយហេតុថា សង្រ្គាម នៅប្រទេសកម្ពុជា ជាសង្រ្គាមដែលឥតបានព្រាងទុកជាមុន។ ណាមួយ ត្រូវព្រឈមមុខ នឹង រដ្ឋសភា ណាមួយត្រូវ សាធារណមតិ ថ្កោលទោស ណាមួយ ថវិកា សម្រាប់ ជួយប្រទេសកម្ពុជា ក៏គ្មានទៀត។ នៅទីបំផុត លោក និចសុន បានសំរេច អនុញ្ញាត ឲ្យ ក្រសួងការពារប្រទេស សហរដ្ឋអាមេរិក ប្រើប្រាស់ ធនធាន ថវិកាលេខ ៥០៦ តែម្តង ហើយឲ្យបង្វិលប្រាក់ សម្រាប់ឲ្យខ្ចីធ្វើការអភិវឌ្ឍន៍ ទៅប្រើប្រាស់សិន ព្រោះ នៅពេល នោះ សេដ្ឋកិច្ចប្រទេស កម្ពុជា ត្រូវស្ទះដំណើរការទាំងស្រុង ដោយសង្រ្គាមឥតព្រាង ទុក ។ នៅក្នុងពេល ដដែលនោះ ឧត្តមសេនីយ៍ លន់ នល់ ដែលទើប នឹងបាន ត្រូវ តែងតាំងជា សេនាប្រមុខ កាលពីខែមេសា ត្រូវរិះរកគ្រប់មធ្យោបាយដើម្បីរៀបចំ របប សាធារណរដ្ឋផង ហើយទប់ទល់ នឹងកងទ័ពព្រៃ វៀតណាមកុម្មុយនិស្ត នៅក្នុងប្រទេស ផង។ នៅឆ្នាំ ១៩៧០នោះ កងទ័ពខ្មែរក្រហម បានក្លាយទៅជា កងទ័ពប្រយុទ្ធមួយ ដ៏ ខ្លាំងក្លា។ រវាង ឆ្នាំ ១៩៧០-១៩៧១ កងទ័ព សាធារណរដ្ឋខ្មែរ បានវាយយកខែត្រ មួយចំនួនបានមកវិញ គឺ ខែត្រ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និង មួយភាគធំ នៃ ខែត្រក្រចេះ ។ ប្រជាជនខ្មែរ ប្រមាណ ១០ ភាគរយ ក៏ បានត្រូវរំដោះមកវិញដែរ ។





ប៉ុន្តែដោយ កម្លាំងកងទ័ព វៀតណាមខាងជើង ខិតខំការពារ ផ្លូវលំ ហូ ជី មិញ យ៉ាង ស្វិតស្វាញ តំបន់មួយចំនួន នៃ ខែត្រកំពង់ធំ ទាំងមូល និង ផ្នែកត្រើយខាងឆ្វេង ទន្លេ មេគុង ក្នុងខែត្រកំពង់ចាម ព្រមទាំងផ្នែកខាងជើង និងផ្នែកឦសាន នៃ ខែត្រសៀមរាប បានធ្លាក់ យ៉ាងឆាប់រហ័សទៅវិញ ទៅក្នុងកណ្តាប់ដៃ បច្ចាមិត្ត ។

ការកសាង សាធារណរដ្ឋខ្មែរ បានប្រព្រឹត្តិទៅជាផ្លូវការ ចាប់តាំង ពី ថ្ងៃ ៥ កញ្ញា ឆ្នាំ ១៩៧០ គឺ ថ្ងៃដែល លោក សេនាប្រមុខ លន់ នល់ បានសន្យានៅចំពោះមុខ ប្រជាជាតិថា នឹង ប្រកាសរបបសាធារណរដ្ឋ នៅក្នុងរយៈពេល ២ ខែ ខាងមុខ ។ នៅ ថ្ងៃ ៦ តុលា ឆ្នាំ ១៩៧០ ដដែលនោះ សភាទាំងពីរ បានសម្រេចប្រកាស របប សាធារណរដ្ឋ នៅ ថ្ងៃ ៩ តុលាឆ្នាំនោះឯង។ នៅ ថ្ងៃ ៩ តុលា របបសាធារណរដ្ឋ បាន ត្រូវប្រកាសដូចការកំណត់ ។ នៅថ្ងៃ ៩ តុលានោះ រដ្ឋាភិបាល ប្រគល់ភារកិច្ចចាត់ចែង ការតាក់តែង រដ្ឋធម្មនុញ្ញថ្មី ទៅឲ្យរដ្ឋសភា។ នៅ ថ្ងៃ ១៩ តុលា រដ្ឋសភា បានចាត់តាំង លោក អ៊ឹង មឹង ឲ្យទទួលភារកិច្ចនេះ។ ថ្ងៃ ២៣ វិច្ឆិកា អាណត្តិ សមាជិកសភា ត្រូវ ពន្យាពេលមួយឆ្នាំ បន្តទៀត ។

មួយឆ្នាំក្រោយមក នៅថ្ងៃ ១៦ តុលា ឆ្នាំ ១៩៧១ លោក ចេង ហេង ដែល បាន ត្រូវ សភាតែងតាំងជាប្រមុខរដ្ឋ រហូតដល់ពេលមាន ប្រធានាធិបតី បានប្រកាសរំលាយ សភាទាំងពីរ ហើយប្រែក្លាយ សមាជិកសភាឲ្យទៅជា សភាធម្មនុញ្ញ តែម្តង ។ បន្ទាប់ពី រដ្ឋធម្មនុញ្ញ បានតាក់តែងរួចហើយ គេត្រូវយកទៅដាក់សូមការយល់ព្រម ពីប្រជាជន។ នៅ ថ្ងៃ ១០ ឧសភា ឆ្នាំ ១៩៧២ តាមរយៈ ការបោះឆ្នោតប្រជាមតិ រដ្ឋធម្មនុញ្ញថ្មីបាន ទទួលជោគជ័យ ដ៏ធំ ។ ក្នុងចំណោមប្រជាជន ដែលបានទៅបោះ ឆ្នោត ចំនួន ១ លាន ៦ សែន នាក់ / ប្រជាជន ១លាន ៥ សែន ៥ ម៉ឺន ៦ ពាន់នាក់ បានសំដែងការពេញចិត្ត របស់គេ ចំពោះរដ្ឋធម្មនុញ្ញថ្មី។ បន្តមកទៀត គេរៀបចំ ការបោះឆ្នោតជ្រើសរើសប្រធា នាធិបតី នៃ សាធារណរដ្ឋខ្មែរ ។ បេក្ខជន ដែលឈរ ឈ្មោះ មាន ៣ រូប គឺ លោក សេនាប្រមុខ លន់ នល់ លោក អ៊ិន តាំ និង លោក កែវ អន ។ ការបោះឆ្នោត ប្រជា

នាធិបតី បានប្រព្រឹត្តិទៅ នៅថ្ងៃ ៤ មិថុនា ឆ្នាំ ១៩៧២ ដដែល ។ លោកសេនាប្រមុខ លន់ នល់ ដែលតំណាង ចរន្ត មួយប្រភេទ ប្រៀបបាន ទៅ នឹង ចរន្ត ប្រជាធិបតេយ្យសេរីនិយម ពោលគឺ និន្នាការស្តាំ បានទទួល សន្លឹកឆ្នោត ច្រើនជាងគេ គឺ ៥ សែន ៧ ម៉ឺន ៨ ពាន់ ២០៣ សំឡេង។ បើគិត ជាភាគរយ គឺ ៥៤ ក្បៀស ៩៣ ភាគរយ ។ បន្ទាប់មក លោក អ៊ិន តាំ ដែលជា អ្នកសាធារណរដ្ឋនិយម តំណាងនិន្នាការកណ្តាល ហើយដែល ជាអ្នកបានចូលរួមចំណែក យ៉ាងសកម្ម ក្នុងការទម្លាក់សម្តេច នរោត្តម សីហនុ បានទទួល ២ សែន ៥ ម៉ឺន ៧ ពាន់ ៣២០ សំឡេង ពោល គឺ ២៤ ក្បៀស ៤៤ ភាគរយ។ រីឯ លោក កែវ អន វិញ ដែលតំណាងនិន្នាការឆ្វេង ហើយដែលមានលំអៀងទៅរក អតីតប្រមុខរដ្ឋ សម្តេច នរោត្តម សីហនុ និង ខ្មែរក្រហម បានទទួល ២ សែន ១ ម៉ឺន ៧ ពាន់ ៣៤១ សំឡេង ពោល គឺ ២០ ក្បៀស ៦១ ភាគរយ ។

## ការកកើតឡើង នៃ របប សាធារណរដ្ឋ ខ្មែរ

### Genèse du régime républicain khmer

ការប្រកាស របប សាធារណរដ្ឋខ្មែរ នៅថ្ងៃ ៩ តុលាឆ្នាំ ១៩៧០ ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រមួយ ដ៏សំខាន់ ចំពោះប្រជាពលរដ្ឋខ្មែរ ក៏ដូចជាចំពោះយុវជន និង បញ្ញវន្តខ្មែរដែរ។ តួអង្គសំខាន់ៗ មិនមែន មានតែ ឧត្តមសេនីយ៍ លន់ នល់ និង អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ លោក អ៊ិន តាំ និង សភាទាំងពីរប៉ុណ្ណោះទេ។ តួអង្គសំខាន់ ម្នាក់ទៀត ដែលគេពុំសូវ យកមកនិយាយ និង សរសេរ ប៉ុន្តែដែលជា អ្នករុញច្រានប្រទេសកម្ពុជា ឆ្ពោះទៅរកការប្រកាស របបសាធារណរដ្ឋខ្មែរ គឺ វរសេនីយ៍ឯក លន់ ណុន ប្អូនប្រុស របស់ឧត្តមសេនីយ៍ លន់ នល់ ។ បើគ្មាន លន់ ណុន ព្រមទាំង បញ្ញវន្ត ខ្មែរមួយភាគធំនោះទេ ការប្រកាស របបសាធារណរដ្ឋ នៅថ្ងៃ ៩ តុលាឆ្នាំ ១៩៧០ ក៏ ពុំអាចប្រព្រឹត្តិទៅបានដែរ ព្រោះនៅពេលដែលសម្តេច នរោត្តម សីហនុ បានត្រូវទម្លាក់ ចេញ





ពីអំណាច ដោយសភាទាំងពីរ នៅថ្ងៃ ១៨ មិនាឆ្នាំ ១៩៧០ ឧត្តមសេនីយ៍ លន់ នល់ នៅ មានការស្ទាក់ស្ទើរនៅឡើយ ។ រីឯ អ្នកអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ ដែលជាមិត្ត របស់ ឧត្តមសេនីយ៍ លន់ នល់ តាំងពីនៅកុមារ ក៏ មិនដែលបានគិត អំពីរឿងនេះទេ ។ យោងទៅតាមមតិខ្លះ ក្រៅពីការដេញកងទ័ពវៀតណាមកុម្មុយនិស្តចេញពីទឹកដីខ្មែរ មូលហេតុដែលបានជំរុញ ឲ្យអ្នកអង្គម្ចាស់សិរិមតៈទម្លាក់សម្តេច នរោត្តម សីហនុ គឺការស្អប់ខ្ពើមខ្សែព្រះរាជវង្ស នរោត្តម ដែលបានត្រូវបារាំងដាក់ឲ្យឡើងសោយរាជ្យសម្បត្តិជំនួសព្រះអង្គម្ចាស់ស៊ីសុវត្ថិ មុនីរ៉េត ដែលជាឪពុកមារបស់ព្រះអង្គ។ ការពិត គឺជា ទំនាស់មួយ ដ៏ស្រួចស្រាវ នៅក្នុងការកំណត់នយោបាយ ក្រៅប្រទេស ។ សម្តេច នរោត្តម សីហនុ ជំរុញប្រទេសកម្ពុជា ឲ្យចូល កុម្មុយនិស្ត ជាពិសេសប្រទេសចិន។ រីឯ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ លោកចង់យក បស្ចិមប្រទេស ធ្វើជាមូលដ្ឋានយុទ្ធសាស្ត្រ ។ អ្នកវិភាគប្រវត្តិសាស្ត្រមួយចំនួន កត់សំគាល់ដូច្នេះថា បុត្រទាំងពីរអង្គ របស់ ព្រះបាទអង្គ ដួង គឺ នរោត្តម និង ស៊ីសុវត្ថិ មាន ចក្ខុនិម្មិត (vision) ខុសគ្នា។ ព្រះបាទ នរោត្តម តែងតែយក ចលនាបះបោរ ប្រឆាំង នឹង បារាំង ធ្វើជាធំ រីឯ ព្រះបាទស៊ីសុវត្ថិ លោកមានជំនឿថា មានតែបារាំងទេ ដែលអាចនាំប្រទេស ឆ្ពោះទៅរកភាពសម័យទំនើប។ អ្នកវិភាគទាំងនោះ ធ្វើការសន្និដ្ឋានថា ខ្សែស៊ីសុវត្ថិ រក្សាគោលដៅ របស់ ព្រះបាទអង្គ ដួង បានរឹងមាំជាង។ នៅពេលក្រោយមកទៀត អ្នកអង្គម្ចាស់សិរិមតៈ មានជំហរដូច ព្រះបាទស៊ីសុវត្ថិ ដូច្នេះដែរ ។ សម្តេច នរោត្តម សីហនុ បាន ត្រូវបារាំង ដាក់ឲ្យ សោយរាជ្យក៏ពិតមែន ប៉ុន្តែ ព្រះអង្គ បែរជាជ្រើសរើសយក ចិនកុម្មុយនិស្ត ជាបង្អែកទៅវិញ ។ នេះគ្រាន់តែជា ការសន្និដ្ឋាន កត់សំគាល់ ប៉ុណ្ណោះ ។ នៅឆ្នាំ ១៩៧០ នោះ អ្នកអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ យល់ឃើញថា ការទម្លាក់ សម្តេច នរោត្តម សីហនុ ជា ឱកាសមួយដ៏ល្អ សម្រាប់បែរទៅរកបស្ចិមប្រទេសវិញ។ ព្រះអង្គយកចិត្តទុកដាក់ជាពិសេស អំពីបញ្ហានេះ ទោះជាត្រូវកសាង របបសាធារណរដ្ឋ ឬ ស្តាររបបរាជានិយមឡើងវិញក្តី។ ព្រះអង្គ ចង់កសាង របប រាជានិយម ប៉ុន្តែ ស្ថានការណ៍ មិនអនុញ្ញាតិ ព្រោះកងទ័ព

បញ្ញវន្ត និង យុវជន ប្រាថ្នាចង់បាន របប សាធារណរដ្ឋ ។ លន់ ណុន បានឆ្លៀតយកស្ថានភាពនេះ ដើម្បីដណ្ដើមយកអំណាច សម្រាប់ខ្លួនតែម្ដងទៅ ។ នៅទីបំផុត អ្នកអង្គម្ចាស់ សិរិមតៈ ក៏បណ្ដោយឲ្យ លន់ ណុន និង បញ្ញវន្ត ប្រកាសរបបសាធារណរដ្ឋ ។ អ្នកសាធារណរដ្ឋនិយមខ្មែរ មានតាំងពីយូរណាស់មកហើយ ប៉ុន្តែច្រើនតែជាអ្នកដែលបានរៀនវប្បធម៌ បារាំង។ ចលនានេះ ចាប់ផ្ដើមចេញរូបរាង ជាស្នូលនយោបាយ មួយដ៏សំខាន់ នៅឆ្នាំ ១៩៦០ ជាមួយនិស្សិតខ្មែរមួយចំនួនដែល នៅឆ្នាំ ១៩៦១ បានបង្កើតសមាគម «សកុម» នៅប្រទេសបារាំង ។ នៅពេលដែលពួកកុម្មុយនិស្ត វៀតណាមបង្កប់ទ័ព នៅក្នុង ប្រទេសកម្ពុជា នៅបណ្ដាឆ្នាំ ៦០ ដដែលនោះ អ្នកសាធារណរដ្ឋនិយមចាប់កើតជា ក្រុមតូចៗ នៅតាមមហាវិទ្យាល័យ ក្នុងចំណោម អ្នកសិក្សាអក្សរសាស្ត្របារាំង ។ ចាប់តាំង ពី ឆ្នាំ ១៩៦០ ពួកអ្នកសាធារណរដ្ឋនិយម ប្រមាណ ១៧ ឬ ១៨ រូប តែងតែនាំគ្នា មកប្រជុំ ជាសម្ងាត់ នៅផ្ទះមួយ របស់ វរសេនីយ៍ឯក លន់ ណុន នៅជិត វត្ត ហា ក្បែរ ស្ទឹងកន្ទួត ចម្ងាយប្រមាណ ២០ គ. ម. ពី ទីក្រុងភ្នំពេញ ។ ក្រៅពីបញ្ញវន្ត មួយចំនួនធំដែលពុំស្គាល់គ្នាទាំងអស់នោះទេ ព្រោះ បញ្ហាសន្តិសុខ និង បញ្ហាលាក់មុខ ចោទឡើងយ៉ាងខ្លាំង គេសង្កេតឃើញមានមនុស្ស ៣ នាក់ ដែលនៅ ជាប់ នឹង វរសេនីយ៍ឯក លន់ ណុន។ អ្នកទាំង ៣ នាក់នោះ គឺ វរសេនីយឯក ឈឹម ឈួន លោក ថោង លឹម ហួង លោក លឿង វ៉ែន និង លោក ហួត ហៀម ដែលជាអ្នកដឹកបញ្ញវន្តមួយក្រុម តាមរថយន្ត រ៉ឺណូត៍ (Renault 4 L) កញ្ចាស់ របស់ គាត់ ទៅចូលរួមប្រជុំ ជាមួយ វរសេនីយ៍ឯក លន់ ណុន។ ក្រុមដែលលោក ហួត ហៀម តែងតែនាំទៅជួប វរសេនីយ៍ឯក លន់ ណុន មានជាអាទិ : សង្គមវិទូ រស់ ចន្ទ្រាបុត្រ សង្គមវិទូ ម៉ន តេង សុន ព្រមទាំង អ្នកកាសែត មួយចំនួន ផងដែរ ។

ក្រោយព្រឹត្តិការណ៍ ១៨ មិនា គេបានដឹង បន្តិចម្ដងៗថា អ្នកដែលបានខិតខំពង្រឹងស្នូលអ្នកសាធារណរដ្ឋនិយម មានជាច្រើនឥតគណនា ប៉ុន្តែ មុនព្រឹត្តិការណ៍នេះ គេឥតបានស្គាល់គ្នាទាំងអស់ទេ ព្រោះគេត្រូវ ការពារអ្នកទាំងនោះ កុំឲ្យពួក ខ្មែរក្រហម





ឬ ក៏ចារកម្ម ប្រទេសកុម្មុយនិស្ត ជាពិសេស ពួករាជានិយម ព្រមទាំងក្រុមអ្នកអង្គម្ចាស់ សិរិមតៈ ធ្វើឲ្យខកដំណើរបាន។ ទោះបីគ្មានអ្វីដែលបញ្ជាក់ឲ្យច្បាស់ថា អ្នកអង្គម្ចាស់ សិរិមតៈ ចង់ស្ដាររបបរាជានិយមឡើងវិញក្ដី (របបរាជានិយមខ្មែរដែលតាំងពីឆ្នាំ ១៩៥៥ មក បានត្រូវ សម្ដេច នរោត្តម សីហនុ រក្សាទុក សម្រាប់តែធ្វើជា និមិត្តរូប ប៉ុណ្ណោះ) ក៏អ្វីដែលមិនអាចប្រកែកបាននៅពេលនោះ គឺការដែលអ្នកដែលបានទម្លាក់សម្ដេចនរោត្តម សីហនុ បែកគ្នាជា ២ ក្រុម : ក្រុមអ្នកអភិរក្ស និង ក្រុមអ្នកសាធារណរដ្ឋនិយម របស់ វរសេនីយ៍ឯក លន់ ណុន ដែលក្រោយមក បានឡើងឋានៈជា ឧត្តមសេនីយ៍ ។ ក្រុមទាំងពីរ នេះ ប្រយុទ្ធគ្នា យ៉ាងស្វិតស្វាញ ។ រីឯ បញ្ហាដែលចោទឡើង នៅពេលនោះ គឺ សុខភាព របស់ ឧត្តមសេនីយ៍ លន់ នល់ ។ ដោយលោក មានជម្ងឺប្រចាំកាយ យ៉ាងធ្ងន់ធ្ងរ គឺ ស្លាប់មួយកំណាត់ខ្លួន តើ វរជនណា នឹង ត្រូវដឹកនាំ សាធារណរដ្ឋខ្មែរ ? តើ ឧត្តមសេនីយ៍ លន់ ណុន ជាប្អូន ឬ អ្នកអង្គម្ចាស់សិរិមតៈ? មួយវិញទៀត នៅក្នុងសង្គមខ្មែរ នៅពេលនោះ អ្នកឱកាសនិយម មានច្រើនជាង អ្នកប្រកាន់ជំហរ គំនិតជាក់លាក់។ អ្វីដែលសំខាន់ គឺ បុណ្យសក្តិ កិត្តិយស មុខមាត់ និង ការអែបអប បោកប្រាស់យកអំណាច ដែលជាហេតុនាំ ប្រទេសទៅរកអន្តរាយ។ ការបែកគ្នាជាពីរក្រុមនេះ បាននាំមកនូវការប្របូកប្របល់ មួយ ដ៏ធំ ។ នៅទីបំផុត អំពើពុករលួយ ការប្រកាន់បក្សពួក ក៏ រីករាលដាលពេញប្រទេស រីឯយុវជន ក៏បែកគ្នា ជាពីរក្រុមទៀត ។ បញ្ញវន្ត និង យុវជន ដែលសង្ឃឹម ទៅលើរបបថ្មី មានការខកចិត្តយ៉ាងខ្លាំង ហើយក្រោយការប្រយុទ្ធគ្នាយ៉ាង ខ្លាំងនៅថ្ងៃ ២៧ មេសា ឆ្នាំ ១៩៧២ រវាង យុវជន និយមអ្នកអង្គម្ចាស់សិរិមតៈ និង យុវជនប្រកាន់ជំហរ សាធារណរដ្ឋនិយម តាម ឧត្តមសេនីយ៍ លន់ ណុន អ្នកដែលគាំទ្រ របប សាធារណរដ្ឋ ពិតប្រាកដ គ្មានជំរើសអ្វីទៀត ក្រៅពីផ្ដាច់ខ្លួនចេញពី របបនោះឡើយ ។

# ឆ្នាំ ១៩៧៣ : សហរដ្ឋ អាមេរិក បោះបង់ «សាធារណរដ្ឋខ្មែរ» ចោល

## 1973 : les Etats-Unis abandonnent la République khmère

នៅខែមេសា ឆ្នាំ ១៩៧០ នៅពេលដែល កងទ័ពវៀតណាមកុម្មុយនិស្ត ចាប់ផ្ដើមធ្វើការវាយប្រហារ ទៅលើ កងទ័ព ឧត្ដមសេនីយ៍ លន់ នល់ នៅក្នុងទ្រង់ទ្រាយមួយដ៏ធំ លោក និចសុន បានថ្លែងថា ៖ «ជំនួយដែលសហរដ្ឋ អាមេរិក ផ្ដល់ទៅឲ្យ ប្រទេសកម្ពុជា គឺគ្រាន់តែ ដើម្បី ឲ្យខ្មែរការពារ អព្យាក្រឹតភាពរបស់ខ្លួន តែប៉ុណ្ណោះ គឺ មិនមែនសម្រាប់ឲ្យខ្មែរ ចូលប្រយុទ្ធ ក្នុងបក្សសម្ព័ន្ធណាមួយនោះទេ»។ តាមការពិត ទីក្រុងវ៉ាស៊ីងតោន បានជ្រើសរើសយកយុទ្ធសាស្ត្រចុងក្រោយនេះ រួចស្រេចទៅហើយ ។ លោក ហង់រ៉ី គីស៊ីង្ស៊ែហ្គែរ (Henry Kissinger) ទីប្រឹក្សារបស់ លោក ប្រធានាធិបតី និចសុន ជាអ្នកដែលគូសវាស និង អនុវត្តយុទ្ធសាស្ត្រនេះ។ ដើម្បី ធ្វើកិច្ចការនេះ សេតវិមានដឹកនាំ សង្គ្រាមនៅក្នុងប្រទេសកម្ពុជា ដោយផ្ទាល់តែម្ដង ក្រោមបញ្ជាការ របស់ លោក គិស៊ីង្ស៊ែហ្គែរ ។ សូម្បីតែ លោក វីលាម រ៉ូហ្សេ (William Roger) រដ្ឋមន្ត្រី ការពារប្រទេសអាមេរិក ក៏នៅ ស្រពេចស្រពិលដែរ ។ សហរដ្ឋ អាមេរិក ក៏ ចាប់ផ្ដើមផ្ដល់អាវុធទៅឲ្យកងទ័ពខ្មែរនៅពេលនោះ ហើយ បង្កើនចំនួន កងទ័ពខ្មែរ រហូតដល់ទៅ ២២ ម៉ឺននាក់។ ឧត្ដមសេនីយ៍ អាឡេចសង់ឌ័រ ហេក (Alexander Haig) ដែលបានធ្វើដំណើរមក ប្រទេសកម្ពុជានៅពេលនោះ ពុំមែនមកមើលសភាពការណ៍ទេ តែគឺ ដើម្បីរុញច្រានដំណើរការ ប្រយុទ្ធតែម្ដង។ ប៉ុន្តែ គឺចាប់តាំងពីពេលនោះមកដែរ ដែលអំពើពុករលួយ រីករាលដាល យ៉ាងធំ នៅក្នុងជួរកងទ័ព គឺនៅពេលមួយដែលកងទ័ព ខ្មែរក្រហម បានកើនចំនួន ដល់ទៅ ២ ម៉ឺន នាក់ ហើយ បានទទួល ការហាត់ហ្វឹកហ្វឺន យ៉ាងមាំទាំ ពីសំណាក់ កងទ័ព វៀតណាមកុម្មុយនិស្ត ព្រមទាំង ជំនួយ ជាសម្ភារយោធា ដ៏ សន្ធឹក





សន្ធាប់ ពីប្រទេសចិនប្រជាមានិត្ ។ ទន្ទឹមនោះ ការឃោសនា បញ្ចុះបញ្ចូល ផ្នែកនយោបាយ របស់ខ្មែរក្រហម ក៏កាន់តែមាន ប្រ សិទ្ធិភាពខ្លាំងថែមទៀត ។ បើគេបែរមកមើលខាងកងទ័ព របស់ ឧត្ដមសេនីយ៍ លន់ នល់ វិញ កងទ័ពពិតប្រាកដ មានចំនួនកាន់តែតិចទៅៗ។ នៅចុងឆ្នាំ ១៩៧១ «កង ទ័ពខ្មោច» មានចំនួន ដល់ទៅ ២ ម៉ឺន ២ ពាន់នាក់ រីឯកងទ័ពចំនួន ៤ ម៉ឺន ៦ ពាន់នាក់ បាត់ខ្លួនមិនដឹងទៅទីណា។ នៅដើមឆ្នាំ ១៩៧៣ សន្និសីទទីក្រុងប៉ារីស៍ រវាង សហរដ្ឋ អាមេរិក និង វៀតណាមកុម្មុយនិស្ត តម្រូវឲ្យកងទ័ពវៀតណាម ខាងជើង និងវៀតកុង ដកចេញ ពីប្រទេសកម្ពុជា។ ទីក្រុងហាណូយ ក៏សុខចិត្តយល់ព្រម ព្រោះ កងទ័ពខ្មែរក្រហម ក៏ មានលទ្ធភាពគ្រប់គ្រាន់ ដើម្បីវាយយកភ្នំពេញ ដោយខ្លួនឯងបានដែរ តែកងទ័ពវៀតណាមកុម្មុយនិស្ត ត្រៀម ធ្វើអន្តរាគមន៍ ជានិច្ច នៅផ្នែកខាងជើង និង ផ្នែកបូព៌ា ។ នៅពេលដែលកងទ័ពខ្មែរក្រហម រុលយ៉ាងឆាប់រហ័ស ឆ្ពោះទៅទីក្រុងភ្នំពេញ ដោយកាត់ផ្ដាច់ផ្លូវដឹកស្បៀង អស់គ្មានសល់ ប្រជាជននៅជនបទ ក៏នាំគ្នារត់ចូលទីក្រុងភ្នំពេញយ៉ាងច្រើន ជាហេតុធ្វើឲ្យប្រជាជនក្នុងរដ្ឋធានីកើនចំនួនដល់ទៅ ២ លាន ៥ សែននាក់។ បើកុំតែ សហរដ្ឋ អាមេរិក ដឹកស្បៀង មកឲ្យតាមយន្តហោះ អ្នកទីក្រុងប្រហែលជាត្រូវដាច់ពោះស្លាប់ ឬប្រកាប់ប្រចាក់គ្នា ដណ្ដើមអង្ករ ដោយគេចពុំផុតឡើយ។

នៅឆ្នាំ ១៩៧៣-១៩៧៤ ដោយសំអាងទៅលើសន្ធិសញ្ញាទីក្រុងប៉ារីស៍ សហរដ្ឋ អាមេរិក រៀបចំខ្លួនបោះបង់សាធារណរដ្ឋខ្មែរចោលតែម្ដង ហើយប ង្ខំឲ្យ ឧត្ដមសេនីយ៍ លន់ នល់ ធ្វើការចរចា ជាមួយ រដ្ឋាភិបាលរួបរួមជាតិ របស់ សម្ដេច នរោត្តម សីហនុ។ នៅ ថ្ងៃ ២២ តុលា ឆ្នាំ ១៩៧២ លោក ហង់រ៉ី គីស៊ីង្ស៊ែហ្គែរ មកទីក្រុងភ្នំពេញ ដើម្បី លើកឡើងពីការចរចានោះ។ នៅថ្ងៃ ១ មករា ឆ្នាំ ១៩៧៣ ឧត្ដមសេនីយ៍ លន់ នល់ ប្រកាសមិនព្រមចរចា។ ពីរ-បី ថ្ងៃ ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ដែលបានត្រូវចុះហត្ថលេខា នៅថ្ងៃ ២៧ មករា ឆ្នាំ ១៩៧៣ ឧត្ដមសេនីយ៍ អាឡេច សង់ឌ័រ ហេក មកជួប ឧត្ដមសេនីយ៍ លន់ នល់ នៅភ្នំពេញ។ លោក អាឡេចសង់ឌ័រ ហេក ប្រាប់ ឧត្ដម

*សេនីយ៍ លន់ នល់ ថា លោក ប្រធានាធិបតី និចសុន បានសម្រេច បន្ថយ អន្តរាគមន៍ យោធា របស់ អាមេរិក នៅក្នុងប្រទេសកម្ពុជាហើយ។ នៅក្នុងសៀវភៅមួយ របស់ លោក* (*Une tragédie sans importance*) *វិលាម សាវក្រូស* (William Shawcross) *សរសេរដូច្នេះថា :* « *នៅពេលនោះ បន្ទាប់ពីបានស្ដាប់ ឧត្តមសេនីយ៍ អាឡេច សង់ឌ័រ ហេក ហើយ ឧត្តមសេនីយ៍ លន់ នល់ ធ្លាក់ទឹកភ្នែកប្រោក រូបបែរខ្នងដាក់ ឧត្តមសនីយ៍ អាឡេចសង់ឌ័រ ហេក រួច ក៏យំ តែម្ដង។* » *ប៉ុន្តែ គឺចាប់តាំង ពី ខែ មករា ឆ្នាំ ១៩៧៣ នោះដែរ (មក ដល់ថ្ងៃ ១៥ សីហា ឆ្នាំដដែល) ដែល សហរដ្ឋ អាមេរិក ចាប់ផ្ដើមទម្លាក់ គ្រាប់បែក យ៉ាងខ្លាំងក្លា ផ្ដាច់ព្រ័ត្រទៅលើទីតាំងកងទ័ពកុម្មុយនិស្ត នៅ ក្នុង ប្រទេសកម្ពុជា។ នៅខាងខ្មែរក្រហម ឯនោះវិញ គេពុំព្រមចរចា សន្តិភាព ជាមួយ សាធារណរដ្ឋខ្មែរ ជាដាច់ខាត ព្រោះ ទីក្រុងប៉េកាំង ចង់ឲ្យខ្មែរក្រហម កាន់កាប់អំណាច ក្នុងគោលដៅ ទប់ទល់ នឹងវៀតណាម ។ សូមបញ្ជាក់ថា បងប្អូនកុម្មុយនិស្តទាំងពីរនេះ តាមការពិតទៅ មិនត្រូវគ្នាទេ : ប្រទេសចិន ទាស់ទែង នឹង សហភាព សូវៀត យ៉ាង ខ្លាំង សហភាព សូវៀត ដែលគាំទ្រទីក្រុងហាណូយ ។ បន្ទាប់ពីខ្មែរក្រហម ប្រកាសមិន ចរចា ជាមួយទីក្រុងភ្នំពេញ / នៅ ខែកុម្ភៈឆ្នាំ ១៩៧៣ ទីក្រុងហាណូយ ក៏ផ្ដាច់ជំនួយ ដែលគេធ្លាប់ផ្ដល់ទៅ ឲ្យខ្មែរក្រហមតែម្ដង ។ នៅ ទីក្រុងប៉េកាំង ឯនោះវិញ ខៀវ សំផន បានត្រូវគេទទួល យ៉ាងអធិកអធម ដូច ជាប្រមុខរដ្ឋ នៃប្រទេស កម្ពុជា រួចជាស្រេច។ រី ឯ សម្ដេច នរោត្តម សីហនុ វិញ ក៏បានត្រូវខ្មែរក្រហម អនុញ្ញាត ឲ្យយាងមកក្នុងតំបន់ រំដោះដែរ។*





# *ការប្រេះឆា នៃ សាធារណរដ្ឋ ខ្មែរ*

## La dislocation de la République khmère

*ចាប់តាំងពី ខែកុម្ភៈ ឆ្នាំ ១៩៧១ មក យុវជនដែលគាំទ្រ របប សាធារណរដ្ឋ បែកចេញ ជាពីរបក្សពួក។ របបសាធារណរដ្ឋខ្មែរ កើតឡើង ស៊ីងតែឥតបានព្រាងទុក ជាមុន។ រីឯអ្នកសាធារណរដ្ឋនិយម ក៏ ពុំបានត្រៀមលក្ខណៈ ផ្សព្វផ្សាយ ដល់ប្រជា ពលរដ្ឋ អំពី សារៈសំខាន់ នៃ របបនេះដែរ។ ខុសប្លែក ពី បដិវត្តន៍ បារាំង ដែលមាន ទស្សនវិទូ កវី និង អ្នកនិពន្ធ ជាបង្អែកយ៉ាងរឹងមាំ របប សាធារណរដ្ឋខ្មែរ តាមបែប បស្ចិមប្រទេស មានតែបញ្ញវន្ត មួយក្រុមតូចប៉ុណ្ណោះ ដែលយល់ដឹង អំពី ឧត្តមគតិ នៃ របបនេះ ។ បើ គ្មានបញ្ហា វៀតកុងយកទឹកដីខ្មែរទៅប្រើប្រាស់ ដើម្បី ធ្វើសង្គ្រាមតទល់ នឹង អាមេរិកទេនោះ គឺបើគ្មានការទម្លាក់ សម្ដេច នរោត្តម សីហនុ ទេនោះ ជាពិសេស បើគ្មានបញ្ញវន្តខ្មែរ ដែលស្អប់ខ្ពើម របបរាជានិយម ហើយ ដែលប្រឆាំង នឹងកុម្មុយនិស្ត ទេនោះ របបសាធារណរដ្ឋ ក៏ប្រហែលជាមិនបានត្រូវប្រកាស ៧ ខែ ក្រោយការទម្លាក់ សម្ដេច នរោត្តម សីហនុ ដែរ ។ ជាការពិតហើយ ដែលថា នៅពេលនោះ បញ្ញវន្តភាគ ច្រើន នាំគ្នាគាំទ្រ ពួកកុម្មុយនិស្ត ដែលមាន ការឧបត្ថម្ភ ពី សម្ដេច នរោត្តម សីហនុ ក៏ ប៉ុន្តែ នៅចំពោះមុខការបាត់បង់ អធិបតេយ្យ និង បូរណភាពដែនដី ដោយប្រកែកពុំបាន ពួកអ្នកសាធារណរដ្ឋនិយម តាមបែបបស្ចិមប្រទេស ក៏បានទទួលតួនាទី ប្រវត្តិសាស្ត្រ មួយ ដ៏សំខាន់ នៅពេលនោះតែម្ដងទៅ។ រីឯទំនាស់ ដែលស្ដែងឡើងយ៉ាងច្បាស់ នៅថ្ងៃ ២៧ មេសា ឆ្នាំ ១៩៧២ ជាទំនាស់ រវាង និស្សិតប្រកាន់ របបសាធារណរដ្ឋ ដែលមាន ឧត្តមសេនីយ៍ លន់ ណុន នៅពីក្រោយ និង និស្សិតប្រកាន់ អ្នកអង្គម្ចាស់សិរិមតៈ ក្នុងនាមជា អ្នកសាធារណរដ្ឋ ដូចគ្នា គឺ មិនមែនជាទំនាស់ រវាងអ្នកសាធារណរដ្ឋ នឹង អ្នករាជានិយម ឡើយ ទោះបី មាន ស្នូលអ្នកអភិរក្ស ជំនាន់ក្រោយ នៅក្នុង ក្រុមបុង ក្រោយនេះក្ដី ។ អ្នកខ្លះទៀត តួយ៉ាង លោក ឈៀង គឹម ស្ួរ អតិតប្រធាន សមាគម*

« អា ហ្សេ កាហ្វ » ( A.G. C..A.F.) នៅ ប្រទេសបារាំងជាដើម ជាអ្នកដែលប្រាថ្នាចង់ឲ្យខ្មែរវិលមករក អត្តសញ្ញាណវប្បធម៌ ដ៏ រុងរឿង របស់ខ្លួនវិញ ។ បើនិយាយឲ្យចំទំនាស់នា ថ្ងៃ ២៧ មេសា ឆ្នាំ ១៩៧២ ជាទំនាស់ ដណ្ដើមអំណាច រវាង ក្រុមអ្នកនយោបាយ សាធារណរដ្ឋ ប្រឆាំងនឹង កុម្មុយនិស្ត ដូចគ្នាតែប៉ុណ្ណោះ ។ តាមទម្លាប់ របស់អ្នកនយោបាយខ្មែរ មេក្លោងម្នាក់ៗ តែងតែខិតខំប្រមែប្រមូល យុវជន និង បញ្ញវន្ត ឲ្យមកគាំទ្រ ប្រយោជន៍ផ្ទាល់ខ្លួន របស់ពួកគេ ។ ប៉ុន្តែ ចំពោះអ្នកដែលមានគំនិតទៀងត្រង់ហើយ ចង់បាន របប សាធារណរដ្ឋ ពិតប្រាកដ វិញ ជាពិសេស អ្នកដែលមាន គោលជំហរ ឯករាជ មិនចូលចិត្ត ការប្រកាន់បក្សពួក គេបានក្លាយខ្លួនទៅជាជនទទួលរងគ្រោះដោយសាររបបនេះទៅវិញ ព្រោះតែពួកគេហ៊ាន រិះគន់ទិតៀន អាកប្បកិរិយា មិនគួរគប្បីនៃ ពួកអ្នកឱកាសនិយម ដែលបានឆ្លៀតយក របប សាធារណរដ្ឋ ធ្វើជាឈ្នាន់ ។ ឧត្តមគតិ ដែលជាគោលដៅ  កាលបើបានអំណាចហើយ តែងតែក្លាយទៅជា កាំបិតមុខពីរ។ អ្នកអន្ទ្រើសខ្លះ បានប្លន់យកសមិទ្ធិផល ប្រវត្តិសាស្ត្រនេះ ទៅបម្រើ ក្រុមគ្រួសារ បក្សពួក របស់គេ ធ្វើព្រងើយ ។ មួយចំណែកទៀត ការកសាងសាធារណរដ្ឋ  បានត្រូវ រាំងស្ទះព្រោះតែសង្គ្រាម។ សេដ្ឋកិច្ច ធ្លាក់ចុះដុនដាប។ អំពើពុករលួយ រីករាលដាល នៅក្នុងរដ្ឋបាល។ នៅខែកុម្ភៈ ឆ្នាំ ១៩៧១ នៅពេលដែលឧត្តមសេនីយ៍ លន់ នល់ ទៅព្យាបាលរោគ នៅ ហូណូលូលូ យុវជនពីរក្រុម ចេញប្រយុទ្ធគ្នាដោយត្រង់ៗ តែម្ដង។ ក្រុមមួយដឹកនាំ ដោយ ឈៀង គឹម ស្គួរ ជាអ្នកការពារ ផលប្រយោជន៍ របស់ អ្នកអង្គម្ចាស់សិរិមតៈ ។ ក្រុមមួយទៀត ដែលមាន អ៊ឹម យូ ហៃ និង សន ថាត ជាអ្នកការពារបក្សពួក របស់ ឧត្តមសេនីយ លន់ ណុន ។ ឈៀង គឹម ស្គួរ ជា អតីតប្រធានសមាគមនិស្សិតខ្មែរ អា ហ្សេ កាហ្វ (A.G.C.A.F.) នៅ ប្រទេសបារាំង និង ជា រដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និង គមនាគមន៍ ។  រីឯ អ៊ឹម យូ ហៃ ជាប្រធាន សមាគមនិស្សិតនៃ «រដ្ឋាភិបាលស្រោចស្រង់ជាតិ» ហើយ សន ថាត ជាប្រធាន និស្សិត មហាវិទ្យាល័យច្បាប់ ។ បើគេមើលពីក្រៅទៅ គឺ ហាក់បីដូចជា និស្សិតខ្មែរ នៅពេលនោះ



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

ទាស់ទែងខ្វែងគំនិតគ្នា ។ តាមការពិត នេះគ្រាន់តែជាបច្ចេកទេស របស់ អ្នកនយោបាយខ្មែរតែប៉ុណ្ណោះ ។ ឧត្តមសេនីយ៍ លន់ ណុន ដែលនៅពេលនោះ ពុំបានទទួលតួនាទី ដឹកនាំអ្វីសំខាន់ នៅក្នុងរដ្ឋាភិបាលដូចក្រុមអ្នកអង្គម្ចាស់សិរិមតៈទេ គឺមានតែ កម្លាំងយុវជននិងការគាំទ្រពីសំណាក់បញ្ញវន្តសាធារណរដ្ឋនិយម គ្មានជម្រើសអ្វីទៀតក្រៅពី ការវាយប្រហាររដ្ឋាភិបាលតែម្ដង នោះទេ។ ក្រុមឧត្តមសេ នីយ៍ លន់ ណុន ចោទប្រកាន់ថា អ្នកអង្គម្ចាស់ សិរិមតៈ ចង់ដណ្ដើមយក ចង្កូត សាធារណរដ្ឋខ្មែរ ដើម្បី ដឹកនាំប្រទេសឆ្ពោះទៅរករបប រាជានិយមវិញ។ ចាប់តាំង ពីខែ មិនាឆ្នាំ ១៩៧២ គឺ ចាប់តាំង ពីពេលដែលឧត្តមសេនីយ៍ លន់ ណុន បើកយុទ្ធនា ការវាយប្រហារ អ្នកអង្គម្ចាស់សិរិមតៈដោយចេញមុខ ការរំជើបរំជួល និង បាតុកម្ម ចេះតែកើតមានឡើង ឥតឈប់ឈរ នៅក្នុងមជ្ឈដ្ឋានគ្រូបង្រៀន និងនិស្សិត ។ នៅទីបំផុត បាតុកម្មមួយ ដ៏ធំ បានផ្ទុះឡើង នៅ ខែមេសា ឆ្នាំ ១៩៧៣ ។ បាតុកម្មនេះ បានត្រូវបញ្ចប់ នៅក្នុ ងសោកនាដ្យកម្ម ។ ដើម្បីធ្វើការគាបសង្កត់ទៅលើ បាតុករ អ្នកអង្គ ម្ចាស់សិរិមតៈ នាយករដ្ឋមន្ត្រី ស្ដីទី បានបញ្ជូនកម្លាំងទៅបង្ក្រាបទាំងកម្រោលតែម្ដង ។

សោកនាដ្យកម្មធំមួយទៀត ដែលបានកើតឡើង នៅថ្ងៃ ៤ មិថុនា ឆ្នាំ ១៩៧៤ គឺឃាតកម្ម ដ៏អាថ៌កំ បាំងមួយ ទៅលើរូប លោក កែវ សង្គឹម ដែលនៅពេលនោះ ជារដ្ឋមន្ត្រីអប់រំជាតិ និង លោក ថាច់ ជា ដែលជាទីប្រឹក្សារបស់លោក កែវ សង្គឹម។ វរជនសាធារណរដ្ឋនិយមទាំងពីរនាក់នេះ បានត្រូវគេបាញ់សម្លាប់ នៅក្នុងរបង នៃ វិទ្យាល័យ ១៨ មិនា អតីតវិទ្យាល័យយុគន្ធរ។ រីឯ ដំណើរ នៃសោកនាដ្យកម្មនោះ មានដូចតទៅ ៖ មួយខែមុនព្រឹត្តិការណ៍នេះ និស្សិត ៥ រូប បានត្រូវអាជ្ញាធរ នៃ សា ធារណរដ្ឋចាប់ខ្លួនដោយហេតុតែបានបើកអង្គប្រជុំសម្ងាត់មួយ  នៅក្នុងវិទ្យាល័យ  គឺ  អង្គប្រជុំដែលត្រូវច្បាប់ជាធរមាន នៅពេលនោះ ហាមឃាត់ដាច់ខាត។ បន្ទាប់មក និស្សិតឯទៀតៗ បាននាំគ្នាទាមទារ ឲ្យរដ្ឋាភិបាល ដោះលែងនិស្សិតទាំង ៥ នាក់នោះ ។ ប៉ុន្តែរដ្ឋាភិបាលពុំព្រមដាច់អហង្ការ។ នៅថ្ងៃ ៣ មិថុនា ឆ្នាំ ១៩៧៤ នោះ លោក ទ្រិញ វ៉ាញ ដែលជាបក្សពួក

របស់ អ្នកអគ្គម្ចាស់ សិរិមតៈ ហើយជារដ្ឋមន្ត្រីក្រសួង ឃោសនាការ បាននិយាយ តាមវិទ្យុជាតិ ដាក់ទោសកំហុស អំពីការមិនព្រមដោះលែង ទៅលើ លោករដ្ឋមន្ត្រីអប់រំជាតិ។ ព្រឹកឡើង គឺនៅថ្ងៃ ៤ មិថុនា សិស្សរាប់រយនាក់ បាននាំគ្នាចូលមកក្នុងទីស្តីការរដ្ឋមន្ត្រីអប់រំជាតិ ហើយ ចាប់លោករដ្ឋមន្ត្រី កែវ សង្គីម និង លោក ថាច់ ជា ធ្វើជាចំណាប់តែម្តង ហើយនាំអ្នកទាំងពីរ ទៅក្នុងវិទ្យាល័យ ១៨ មិនា ។ យោងទៅតាមសៀវភៅមួយ របស់ លោក រស់ ចន្ទ្រា បុត្រ (*La République khmère*, Ros Chantrboth, Paris, l'Harmattan, 1993, p. 65-66 ) នៅពេលដែលពួកសិស្សនាំ លោក កែវ សង្គីម និង លោក ថាច់ ជា តាមផ្លូវថ្នល់ ពី ទីស្តីការរដ្ឋមន្ត្រីអប់រំជាតិ ឆ្ពោះទៅវិទ្យាល័យ ១៨ មិនា កងកម្លាំង សន្តិសុខមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីធ្វើអន្តរាគមន៍ ប៉ុន្តែផ្ទុយទៅវិញ គេពុំបានធ្វើអ្វីទាំងអស់ ដើម្បីជួយរំដោះលោក កែវ សង្គីម និងលោក ថាច់ ជា ។ ពេលដែល ចំណាប់ទាំងពីរ ស្ថិតនៅក្នុងរបង វិទ្យាល័យ ស្រាប់តែស្នូរកាំភ្លើង បានលាន់ឮឡើង ហើយលោក កែវ សង្គីម និងលោក ថាច់ ជា ក៏ដួលស្លាប់មួយរំពេច ។ ឃាតកម្មនេះ ស្ថិតនៅក្នុង អាថ៌កំបាំង រហូតមកដល់សព្វថ្ងៃនេះ ។

## ឆ្ពោះ ទៅរក ការរលំរលាយ នៃ របប «សាធារណរដ្ឋ ខ្មែរ»

## Vers l'effondrement de la «République khmère»

នៅពេលដែល របបសាធារណរដ្ឋខ្មែរចុះស្រុតបន្តិចម្តងៗ ដោយសង្គ្រាម អំពើពុករលួយ និងការខ្វះសមត្ថភាពប្រឈមមុខនឹងស្ថានការណ៍ នៅខាងរដ្ឋាភិបាលនិរទេសរបស់សម្តេច នរោត្តម សីហនុ ឯនោះវិញ អតីតប្រមុខរដ្ឋខ្មែរចាប់ផ្តើមយល់យ៉ាងច្បាស់





ថា ព្រះអង្គគ្មានតួនាទីអ្វី ក្រៅពីការបណ្តោយ ឲ្យទីក្រុងប៉េកាំង ប្រើប្រជាប្រិយភាពរបស់ ព្រះអង្គ ដើម្បីទាក់ទាញប្រជាជនខ្មែរឲ្យចូលរួមប្រយុទ្ធ ក្នុងជួរខ្មែរក្រហមឡើយ។ ដោយប្រជាជនខ្មែរ អស់មានជំនឿ ទៅលើ របបសាធារណរដ្ឋ ខ្មែរ របស់ ឧត្តមសេនីយ៍ លន់ នល់ ទៅហើយ ពួកខ្មែរក្រហម រង់ចាំតែពេលចូលមក ទីក្រុងភ្នំពេញប៉ុណ្ណោះ។ រីឯសហរដ្ឋ អាមេរិក ក៏អស់លទ្ធភាពជួយ សាធារណរដ្ឋខ្មែរ បន្តមកទៀតដែរ ។ បន្ទាប់ពីរឿងអាស្រូវ «វ៉ាទែរហ្គេត» (Watergate) បានផ្ទុះឡើង លោកប្រធានាធិបតី អាមេរិក និចសុន បានសុំលាលែងពីមុខតំណែង នៅ ថ្ងៃ ៨ សីហា ឆ្នាំ ១៩៧៤ ។ ផុតពីលោក និច សុន ទៅ អ្នកដឹកនាំសាធារណរដ្ឋខ្មែរ បាត់បង្អែកមួយដ៏ធំ។ រីឯបង្អែក ដ៏ធំ មួយទៀត ដែលសាធារណរដ្ឋខ្មែរ បាត់បង់ដែរ នោះ គឺការគាំទ្រ របស់ ប្រជាជន ជាពិសេសពីសំណាក់ យុវជន និង បញ្ញវន្ត ។ ចំពោះអ្នកដែលបានក្លាយទៅជា អ្នកសាធារណរដ្ឋ ព្រោះតែគេចង់បានត្រឹមតួនាទីជា រដ្ឋមន្ត្រី ឬ លាភសក្ការផ្សេងៗ តែប៉ុណ្ណោះនោះ គេក៏ចាប់ផ្តើមកិតភ័យកក្កមា នៅចំពោះមុខការវាយប្រហារ ចូលមកក្នុងទីក្រុង ជាយថាហេតុរបស់ ពួកខ្មែរក្រហម។ ដូចជានៅក្នុង របប នយោបាយនានា កន្លងមកដូច្នេះដែរ អ្នកទាំងនោះ ដែលតាំងខ្លួនគេថាជា «អ្នកឆ្លាតគ្រប់រដូវ» ខិតខំរិះរកគ្រប់មធ្យោបាយ ដើម្បីរៀបចំខ្លួន រក្សាតួនាទី និង ទ្រព្យសម្បត្តិ របស់គេ ជាមួយអ្នកឈ្នះបន្តមកទៀត។ ប៉ុន្តែទោះជាឆ្លាត យ៉ាងណាក្តី ដោយខ្វះប្រាជ្ញាទស្សនវិជ្ជាជ្រៅជ្រះ និង ការចេះដឹង ប្រវត្តិសាស្ត្រសកលលោក សម្រាប់វិភាគស្ថានការណ៍ គេក៏នៅតែចាញ់បោកការឃោសនារបស់ពួកខ្មែរ ក្រហម និង ទីក្រុងប៉េកាំងដែរ។ ពួកគេជឿដោយឆោតល្ងង់ថា សម្តេច នរោត្តម សីហនុ ជាមេ របស់ ពួកខ្មែរក្រហម ។ ដូចនេះ គេយល់ថា ត្រូវតែធ្វើការចរចាជាមួយ រដ្ឋាភិបាលរួបរួមជាតិ របស់សម្តេច នរោត្តម សីហនុ និង ខ្មែរក្រហម។ គេ ឥតយល់ទាល់តែសោះថា តាំងពីថ្ងៃ ១៨ មិនា ឆ្នាំ ១៩៧០ មក សម្តេច នរោត្តម សីហនុ គ្រាន់តែជាឧបករណ៍ ឬ «អ្នកទោសរបស់ ខ្មែរក្រហម» និង ចិន តែប៉ុណ្ណោះ។ ទោះបីនៅពេលក្រោយមកទៀតក្តី ទោះបី សម្តេច នរោត្តម សីហនុ បាននិពន្ធ សៀវភៅមួយ

មានចំណងជើងថា « *Prisonnier des Khmers rouges* », Hachette, Paris, 1986 («អ្នកទោសខ្មែរក្រហម») ក្តី ក៏ពួកគេ នៅតែជឿថា សម្តេច នរោត្តម សីហនុ មាន សេរីភាពគ្រប់គ្រាន់ ដើម្បីយាងវិលមកយកអំណាច របស់ព្រះអង្គបានវិញ ហើយ គ្រប់គ្រងប្រទេស ដូចពីពេលមុន វិញទៀត ។ ព្រះអង្គថា ព្រះអង្គជា «អ្នកទោស របស់ ពួកខ្មែរក្រហម» តែតើមានអ្វីខុសប្លែក រវាងខ្មែរក្រហម និង អ្នកដែលបាន ឧបត្ថម្ភ ចលនានេះ ? តាមការពិតទៅ របប សាធារណរដ្ឋខ្មែរ នៅពេលនោះ ជារបបមួយដែលដឹកនាំ ដោយ អ្នកនយោបាយអភិរក្ស និង អ្នកឱកាសនិយម ព្រមទាំងអ្នក ដែលពឹងផ្អែកទាំងស្រុងទៅលើ សហរដ្ឋ អាមេរិក តែប៉ុណ្ណោះ ។ រីឯយុវជន និង បញ្ញវន្ត សាធារណរដ្ឋនិយមវិញ គេគ្មានតួនាទីដឹកនាំអ្វីសំខាន់ ក្នុងការកសាង របបថ្មី ឡើយ។ បើពួកគេ ហ៊ានរិះគន់ពួកអ្នកអន្រ្ទើសដែលបានទទួលបុណ្យសក្តិ ដោយការអែបអប ឬ ដោយបណ្តាញមិត្តភក្តិ (La République des camarades) គេច្បាស់ជាគ្មាន ជម្រើសអ្វីទៀត ក្រៅពីការរត់ចោលស្រុក ឲ្យបានឆាប់រហ័សបំផុតនោះទេ។ ពេលដែលគេហៅ អ្នកទាំងនោះ ឲ្យមកជួយទប់ទល់ នឹង ខ្មែរក្រហមវិញ គឺ វាជ្រុលពេលអស់ទៅហើយ។ ប៉ុន្តែ ដោយក្តីចង់ជួយស្រុកពេក ខ្លះក៏បានវិលមកស្រុកវិញដែរ ប៉ុន្តែគឺគ្រាន់តែ សម្រាប់ឲ្យខ្មែរក្រហមយកទៅធ្វើទារុណកម្ម យ៉ាងខ្លោចផ្សា និង វាយសម្លាប់ចោល នឹងត្បូងចបតែប៉ុណ្ណោះ។ អ្នកវិភាគខ្លះយល់ថា ដោយបញ្ញវន្តប្រើភាសាបារាំង និង ស្នេហាវប្បធម៌ជាតិ ជាឧបសគ្គនៃ របបថ្មី ជាអ្នកដែលបែរមុខឆ្ពោះទៅរក បស្ចិមប្រទេស អ្នកដែលនៅពីក្រោយ ខ្មែរក្រហមយល់ថា ពួកគេត្រូវតែគាស់ រំលើង អ្នកទាំងនោះ ចោល ទាំងឫស តែម្តង។

នៅដំណាច់ ឆ្នាំ ១៩៧៤ អ្នកដឹកនាំ សាធារណរដ្ឋខ្មែរឱកាសនិយម យល់ដោយក័ន្តប្រឡំថា ការចរចា ជាមួយ សម្តេច នរោត្តម សីហនុ ដើម្បីនាំប្រទេសទៅរក សន្តិភាពវិញ ជាការចាំបាច់ ។ ពួកគេមើលឃើញតែ សម្តេច នរោត្តម សីហនុ «ដែលគ្មានចំណង» គឺ ឥតមើលឃើញ ខ្មែរក្រហម និងមហិច្ឆតា របស់អ្នកដែលនៅ ពីក្រោយទាល់តែសោះ។ គេយល់ដោយក័ន្តប្រឡំថា នៅក្នុងវិស័យនយោបាយ អ្នកណា មានមុខ





តំណែង ធំ សុទ្ធតែជាអ្នកកាន់អំណាច ពិតប្រាកដទាំងអស់។ ទស្សនៈនេះ ក៏ពុំខុសដែរ នៅក្នុងបរិបទ នៃ ប្រទេសមួយ ដែលមានអធិបតេយ្យ មាន ឯករាជ្យគ្រប់គ្រាន់ ។ ប៉ុន្តែនេះ មិនមែនជាករណី នៃ ប្រទេស កម្ពុជា នៅពេលនោះទេ ព្រោះ ប្រទេសទាំងមូលដែលបែកចេញជាពីរក្រុម បានត្រូវប្រទេសជិតខាង និង ប្រទេសមហាអំណាច តូចធំ យកទៅធ្វើ ជាលានប្រយុទ្ធ របស់គេ តាមរយៈក្រុមនយោបាយខ្មែរ នីមួយៗ ។ បើមានបរទេសនៅពីក្រោយ គឺគ្រាន់តែជាធាកល្ហោនមួយ ប៉ុណ្ណោះ។ កូន អុក របស់ចិន នៅ ពេលសម័យបដិវត្តន៍ វប្បធម៌ ចិននោះ គឺ មិនមែន សម្តេច សីហនុ ដូចដែល សម្តេច សីហនុ តែងតែជឿនោះទេ តែគឺ ខ្មែរក្រហម ។ ប៉ុន្តែ ទាល់តែ ខ្មែរក្រហម ឡើងមកកាន់អំណាច នៅឆ្នាំ ១៩៧៥-១៩៧៩ ទើបការពិត បានស្តែងចេញឡើងយ៉ាងច្បាស់។ នៅដើមឆ្នាំ ១៩៧៥ នោះ សម្តេចនរោត្តម សីហនុ ដែលស្ថិតនៅក្នុងតង្កៀបចិន និង ខ្មែរក្រហម ពុំអាចធ្វើអ្វី បានទាំងអស់ ដើម្បីបន្ថយកម្លាំងខ្មែរក្រហម។ ផ្ទុយទៅវិញ ព្រះអង្គនៅតែរក្សាគំនិតថា ខ្មែរក្រហមមុខជា នឹងលើកព្រះអង្គ ឲ្យដឹកនាំប្រទេសជាពុំខាន ទោះបី នៅពេលខ្លះ គឺជ ការសង្ស័យ ដ៏ស្រពិចស្រពិលក្តី ។ តើអ្នកណា ជាកម្លាំងបង្អែកពិតប្រាកដ របស់ ព្រះអង្គ ? លន់ នល់ ឬ ខ្មែរក្រហម ? ទោះជាយ៉ាងណាក្តី នៅ ថ្ងៃ ៦ មករា ឆ្នាំ ១៩៧៥ សម្តេច នរោត្តម សីហនុ ដែលមានការក្រេវក្រោធ នឹង ឧត្តមសេនីយ៍ លន់ នល់ ពេក ក៏បានអំពាវនាវ ឲ្យប្រជាពលរដ្ឋខ្មែរ និង អ្នកដឹកនាំ សាធារណរដ្ឋខ្មែរមួយចំនួន ក្រៅពី ឧត្តមសេនីយ៍ លន់ នល់ និង អ្នកអង្គម្ចាស់ សិរិមតៈ ចូលមករួបរួមក្នុងចលនា របស់ ព្រះអង្គ ដើម្បី នាំសន្តិភាពមកឲ្យប្រទេសវិញ។ តាមការពិត ចំពោះខ្មែរក្រហម គ្មានទេការផ្សះផ្សាបែបនេះ។ ការប្រកាសសន្តិភាព គឺ គ្រាន់តែសម្រាប់សម្រួល ដល់យុទ្ធសាស្ត្រវាយយកភ្នំពេញ តែប៉ុណ្ណោះ ។ នៅចុងឆ្នាំ ១៩៧៤ នោះ ខ្មែរក្រហម មានមុខព្រួញមួយ យ៉ាងច្បាស់ គឺ កាត់ផ្តាច់ការដឹកស្បៀង តាមទន្លេមេគុង និង តាមប្រលានយន្តហោះ ពោធិចិន្តុង ពោលគឺ បង្អត់អាហារ អ្នករស់នៅក្នុងទីក្រុង ។ នៅក្នុងរាត្រី ថ្ងៃ ៣១ ធ្នូ ឆ្នាំ ១៩៧៤ នោះ ប្រតិបត្តិការ វាយប្រហារ របស់

ខ្មែរក្រហម បានចាប់ផ្តើម ពីត្រើយខាងកើត នៃ ទន្លេ មេគុង។ នៅពេលដដែលនោះ ពួកខ្មែរក្រហម បានបាញ់គ្រាប់រ៉ុកកែត យ៉ាងសន្ធឹកសន្ធាប់ ទៅលើស្ថានីយ អាកាសចរអន្តរជាតិ ពោធិចិន្តុង ព្រមទាំងទៅលើ ទីក្រុងភ្នំពេញ ជាបណ្តើរៗ ។

## សភាពការណ៍ នៅ ប្រទេសកម្ពុជា មុនថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥

### Avant le 17 avril 1975

នៅខែមករា ឆ្នាំ ១៩៧៥ កងទ័ព ខ្មែរក្រហម ដែល បានកើនចំនួន ដល់ទៅ ៦ ម៉ឺននាក់ បានឡោមព័ទ្ធ ទីក្រុងភ្នំពេញ ហើយនៅ ខែកុម្ភៈ បានកាត់ផ្តាច់ ផ្លូវដឹកស្បៀងទាំងអស់គឺទាំងផ្លូវទឹក ផ្លូវរទេះភ្លើង និង ផ្លូវថ្នល់។ ចាប់ពីពេលនោះមកខ្មែរ ក្រហម បានបាញ់គ្រាប់រ៉ុកកែត ឥតស្រាកស្រាន្ត ចូលទីក្រុងភ្នំពេញ។ អ្នកនៅក្នុងទីក្រុងភ្នំពេញ រស់នៅក្នុងការភិតភ័យកក្កមាព្រោះមួយថ្ងៃៗ គ្រាប់ផ្លោង ផ្តាច់ជីវិតមនុស្សគ្មានដាច់ ។ ប្រជាជន ស្លូតត្រង់ ក៏ ទទួលការរងគ្រោះ ដោយសារ ការវាយលុកនេះដែរ។ ប្រជាជន នៅទីក្រុងទាំងអស់ ត្រូវពួកខ្មែរក្រហមចាត់ទុកថា ជាខ្មាំង ឬ ជាពួក សេ អ៊ី អា ( C.I.A.) ខ្ញុំកញ្ជះអាមេរិក រីឯពួកគេវិញ គេចាត់ទុកខ្លួនគេ ថាជាអ្នករំដោះ ជាអ្នកតំណាងសីលធម៌ដ៏ខ្ពង់ខ្ពស់ ជាអ្នកស្រឡាញ់ប្រជាជនឯង គ្មានអ្នកណាដល់ គឺ ជាង ប្រជាជនខ្លួនឯង ទៅទៀត ប៉ុន្តែបើកុំតែអាមេរិក ដឹកស្បៀង មកឲ្យតាមយន្តហោះនោះ ប្រជាជនខ្មែរដែលជាទីស្នេហា របស់ ពួកខ្មែរក្រហម ប្រហែល ជាត្រូវដាច់ពោះស្លាប់អស់ គ្មានសល់។ រីឯសហរដ្ឋ អាមេរិកវិញ ទោះបី លោក ឡេ ឌឹក ថូ បានប្រាប់លោក គីស្សីងហ្គែរ នៅក្នុងអង្គសន្និសីទ ទីក្រុងប៉ារីស៍ ចុងក្រោយបង្អស់ថា ទីក្រុងហាណូយ គ្មានលទ្ធភាពអ្វី ទាំងអស់ ដើម្បីនិយាយជាមួយ ពួកខ្មែរក្រហមក្តី ក៏សហរដ្ឋ អាមេរិក នៅតែជឿថា ខ្មែរ





ក្រហម អាចចរចា សន្តិភាព ជាមួយសាធារណរដ្ឋខ្មែរដែរ ។ តាមការពិត នៅ សហរដ្ឋអាមេរិក នៅពេលនោះ ព្រឹទ្ធសភាអាមេរិក បានកាត់ផ្តាច់មូលនិធិទាំងអស់ មិនឲ្យ ប្រធានាធិបតី ហេរ៉្យាល់ ហ្វ័ដ ប្រើសម្រាប់ ធ្វើអន្តរាគមន៍ នៅកម្ពុជាឡើយ។ នៅទីក្រុងភ្នំពេញ នៅពេលដែល ខ្មែរក្រហមវាយសម្រុកយកទីក្រុង គេនាំគ្នាជឿថា ខ្មែរក្រហម ពិតជានាំមក នូវ សន្តិភាពជាពុំខាន។ ឧត្តមសេនីយ៍ មួយចំនួន នៃ សាធារណរដ្ឋខ្មែរ ថែមទាំងត្រៀមលក្ខណៈជាស្រេច ដើម្បីទទួលអបអរសាទរ ពួកខ្មែរក្រហម ទៀតផង ។ គ្មានអ្នកណាម្នាក់ ប៉ាន់ស្មានស្ថានការណ៍ពិតប្រាកដត្រូវទេ គឺសូម្បីតែក្រសួងការសម្ងាត់ ក៏ឥតបានដឹងថា ទីក្រុងប៉េកាំង ដែលគាំទ្រខ្មែរក្រហម មិនដែលគិត ពីសន្តិភាព ម្តងណាឡើយ ។

នៅ ថ្ងៃ ១ មេសា ឆ្នាំ ១៩៧៥ លោក សេនាប្រមុខ លន់ នល់ បាន ត្រូវឯកអគ្គរដ្ឋទូត អាមេរិក យ៉ូន ហ្គន់ទើរ ឌិន បង្ខំឲ្យចាកចេញពី ប្រទេសកម្ពុជា ជាបន្ទាន់ ទៅរស់នៅក្នុងរដ្ឋហាវ៉ៃ ដើម្បីរៀបចំទុកកន្លែង ទទួល សម្តេច នរោត្តម សីហនុ វិញ ព្រោះទីក្រុងវ៉ាស៊ីងតោន ជឿនៅពេលនោះ ថា សន្តិភាព នៅកម្ពុជា នឹង មានឡើងវិញ ហើយសម្តេច នរោត្តម សីហនុ នឹងវិលមកគ្រប់គ្រងស្រុកខ្មែរដូចកាលពីមុន នៅពេលដែលខ្មែរក្រហមទទួលជ័យជំនះ។ នៅក្នុងពេលដដែលនោះ លោក ឡុង បូរ៉េត រដ្ឋមន្ត្រី ទី ១ នៃសាធារណរដ្ឋខ្មែរ និងឧត្តមសេនីយ៍ សូខាំ គយ ប្រកាសសន្តិភាព ជាមួយខ្មែរក្រហម ប៉ុន្តែ ឥតបានដឹងថា សម្តេច នរោត្តម សីហនុ និង ខ្មែរក្រហម នាំ គ្នាសើចចំអក នឹងសេចក្តីប្រកាសនេះ ទាល់តែសោះ ។ មួយវិញទៀត ខ្មែរក្រហម កំពុងមាន មោទនភាពយ៉ាងខ្លាំង អំពី ជោគជ័យយោធា និង នយោបាយ ជា ប្រវត្តិសាស្ត្រ របស់គេ ទៅលើអ្វីដែលគេហៅថា ពួកចក្រពត្តិអាមេរិកផង។ តើ គេអាចរក្សាទុកសត្រូវដែលគេជេរក្តែងៗរាល់ថ្ងៃឬទេ បើសូម្បីតែប្រជាជនខ្មែរ ស្លូតត្រង់ក្តី ក៏សុទ្ធតែត្រូវពួកគេចោទថា ជាខ្មាំងទាំងអស់ទៅហើយនោះ? តាមការពិត គឺគ្រាន់តែជា ការដេញខ្លាមួយ ហើយបញ្ចូលខ្លាមួយទៀតមកឲ្យត្របាក់ប្រជាជនខ្មែរ យ៉ាងខ្លោចផ្សាតែប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក្តី

គេអាចនិយាយបានថា គឺ ជា បរាជ័យ របស់ អាមេរិក នៅឥណ្ឌូចិន និង ជាជ័យជំនះ របស់ កម្លាំង កុម្មុយនិស្ត ដែលពេលបានជ័យជំនះកាលណា ក៏តាំងធ្វើបាបប្រជាជនខ្មែរស្លូតត្រង់ ដោយឥតត្រាប្រណី ។ នេះជាទំព័រ ប្រវត្តិសាស្ត្រមួយ ដ៏ខ្មៅងងិត នៃប្រទេស កម្ពុជា ដែលខ្មែរ និង ខ្មែរប្រយុទ្ធ គ្នាស្លាប់រស់ ហើយដែល បក្សពួកនីមួយៗ ស្រែកក្តែងៗ ដោយឥតអៀនខ្មាសថា ពួកគេជាអ្នកស្នេហាជាតិ ជា អ្នកជួយរំដោះប្រជាជនខ្មែរ ពី ការសង្កត់សង្កិន របស់ បរទេស ។ ខ្វះអួតអាងខ្លួនគេថា ជាអ្នកជាតិនិយម ប៉ុន្តែសម្រេចសម្រួចទៅ សម្លាប់តែខ្មែរគ្នាឯង បម្រើតែ មហិច្ឆតាបរទេស ហើយ បានធ្វើជាអ្នកអន្ទ្រើសដោយកម្លាំងទ័ពបរទេស។ តាមការពិតទៅ តាំងពីជំនាន់ណាមក ប្រជានុរាស្ត្រខ្មែរ មិនដែលមានសិទ្ធិជ្រើសតាំងអ្នកដឹកនាំរបស់ខ្លួនឡើយ គឺច្រើនតែត្រូវបរទេស ចាត់តាំងជំនួសជានិច្ច ទោះជា ចលនា តស៊ូក្តី ។ ហេតុដូច្នេះហើយ បានជា ពេលម្នាក់ សុំចុះញ៉ម ម្នាក់ទៀតគិតតែពីសម្លាប់ ។ ខ្មែរម្នាក់មើលឃើញខ្មែរម្នាក់ទៀតជាខ្មាំង ព្រោះតែម្នាក់ៗ បម្រើផលប្រយោជន៍ចៅហ្វាយ របស់គេ រៀងៗខ្លួន ។ អ្វីដែលម្នាក់ៗប្រាថ្នា គឺ ប្រែក្លាយម្នាក់ ទៀត ឲ្យទៅជា ខ្ញុំកញ្ជះ របស់ ខ្លួន គឺ មិនដែលសូវឃើញមាន ឆន្ទះ ចង់ ប្រែក្លាយប្រជាពលរដ្ឋ ឲ្យទៅជាអ្នកការពារ ឬអ្នកស្រឡាញ់សេរីភាពឡើយ។ នៅក្នុង ប្រវត្តិសាស្ត្រខ្មែរ គេតែងតែសង្កេតឃើញជារឿយៗ នូវការខ្វះគតិបណ្ឌិត ការខ្វះភាពចាស់ទុំ ផ្នត់គំនិតបែបនេះ នៅក្នុងវិស័យ នយោបាយ។ នេះជាដំបៅមួយ ដ៏ធំ នៅក្នុងការគ្រប់គ្រងប្រទេស ។ គេនិយាយនៅពេលនោះ ដូច្នេះទៀតថា គឺ គ្រាន់តែប្តូរម្ចាស់ទេតើ មិនគួរអ្វី រហូតដល់ថ្នាក់ ធ្វើបាបប្រជាជន ឯងបែបនេះសោះ ?

អ្នកដែលប្រមើមើលឃើញជាមុន នូវ ការវិវត្តន៍ ស្ថានការណ៍មិនស្រួល មុនថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ បាននាំគ្នារត់ឡើង ឧទ្ធម្ភាគចក្រ អាមេរិក យ៉ាងពពាក់ពពូន ព្រោះតែខ្លាចខ្មែរគ្នាឯង ។ ប៉ុន្តែ នៅទីបំផុត គឺជាការពិតៗ ដែលអ្នកមានវិចារណញ្ញាណ ស្មានមិនដល់ ។



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

# បដិវត្តន៍ ដែលគ្មាន ប្រជាជនគាំទ្រ ឬ មហាលោតផ្លោះ មហាអស់លក្ខ

## Une révolution sans soutien populaire ou Un grand bond dans le vide





# ជំពូក ៧

## ការកំទេចវប្បធម៌មួយ ដោយយក មនោគមវិជ្ជាមួយ មកជំនួស

បារាំង បានប្រើពេលជិតមួយសតវត្សរ៍ ដើម្បី នាំប្រទេសកម្ពុជា ឲ្យចូលទៅក្នុងពិភពសម័យទំនើបៗ វប្បធម៌បារាំង បានត្រូវបង្កាត់ជាមួយវប្បធម៌ខ្មែរ ដោយមាន ការពិបាកពន់ពេកក្រៃ (ការបង្កើតតំបន់រដ្ឋបាល ការកំណត់ច្បាប់គ្រប់ប្រភេទ មានជាអាទិ៍ ច្បាប់រដ្ឋប្បវេណី ច្បាប់ព្រហ្មទណ្ឌ ច្បាប់ហិរញ្ញវត្ថុ ច្បាប់កម្មសិទ្ធិឯកជន ច្បាប់សុរិយោដីៗលៗ) នៅទីបំផុត គេបានទទួលលទ្ធផលខ្លះដែរ ទោះជាពុំបានគ្រប់គ្រាន់ក្តី ព្រោះត្រូវប្រយុទ្ធ នឹង ចលនាស្នេហាជាតិ នឹង ទំនៀមទម្លាប់ប្រពៃណីខ្មែ នៃ អ្នកដឹកនាំដែលខ្លាចអ្នកជំនាន់ក្រោយ យកទ្រឹស្តី និងការចេះដឹង របស់បស្ចិមប្រទេស មកកសាងសង្គមមួយដែលមានលក្ខណៈសម័យទំនើប ហើយ ដែលអាចធ្វើឲ្យ ពួកគេ បាត់បង់អំណាច «ម្ចាស់ទាសាទាសី» របស់ ពួកគេ ពោលគឺ ការចាត់ទុក ប្រជាជន ជាទាសាទាសីៗ រី ឯ ពួកខ្មែរក្រហម ដែលមានទស្សនៈកុម្មុយនិស្តផង ទស្សនៈជាតិនិយមជ្រុលផង គេប្រើពេលតែមួយថ្ងៃប៉ុណ្ណោះ ដើម្បីប្តូររចនាសម្ព័ន្ធវប្បធម៌និងសេដ្ឋកិច្ច ហិរញ្ញវត្ថុ ដែលបារាំង បានបន្សល់ទុកឲ្យៗ តាមការពិត គឺជាការវាយកំទេចវប្បធម៌ខ្មែរ ដែលបានត្រូវផ្សាភ្ជាប់ ជាមួយ វប្បធម៌បារាំងៗ ពួកគេ បានយក មនោគមវិជ្ជាមួយទៀត ដ៏ចម្លែកអស្ចារ្យ ឬ ក៏ របស់ បដិវត្តន៍ម៉ៅនិយម មកជំនួស ព្រោះរក ប្រព័ន្ធគ្រប់គ្រង របស់ខ្មែរពុំឃើញ ក្រៅពី របបរាជានិយមទេវរាជ និង លទ្ធិពុទ្ធសាសនា ។ គេអាចនិយាយ

ម៉្យាងទៀតថា ប៉ុល ពត ចាញ់បោកចិន ដែលតាមរយៈបដិវត្តន៍វប្បធម៌ របស់ ម៉ៅ សេទុង មានគោលដៅកំទេចអ្នកកសាងស្រុកខ្មែរតាមបែបបទបស្ចិមប្រទេស។ ជាកិច្ចចាប់ផ្ដើម ប៉ុល ពត សម្លាប់អ្នកចេះដឹងខ្មែរ ស្ទើងតែអស់ផុតពូជ ព្រោះតែអ្នកទាំងនេះ បានទទួលកេរមតកផ្នែកបញ្ញាពីបារាំង។ សម្ដេច សីហនុ ត្រូវព្រឈមមុខ នឹងបញ្ញវន្ត ដែលមួយចំណែករេ ទៅរកមនោគមវិជ្ជាកុម្មុយនិស្ត ហើយមួយចំណែកទៀត ចង់កសាងលទ្ធិប្រជាធិបតេយ្យតាមបែបបស្ចិមប្រទេស។ បញ្ញវន្តទាំងពីរប្រភេទនេះ ដែលគ្មានអ្នកណាចេញ ពីស្រទាប់អ្នកក្រីក្រពិតប្រាកដ ហើយក៏ពុំមែនចេញមកពីស្រទាប់សេដ្ឋី ឯណាដែរ សុទ្ធតែប្រាថ្នា ចង់បានរបបសាធារណរដ្ឋ។ សម្ដេច នរោត្តម សីហនុ មានបង្អែកតែមួយប៉ុណ្ណោះ គឺប្រជាជននៅស្រែចម្ការ។ នៅពេលបានឯករាជ្យហើយ ព្រះអង្គ បានសម្រេចដាក់រាជ្យដើម្បីប្រយុទ្ធក្នុងឆាកនយោបាយ ដោយបង្កើតចលនា «សង្គមរាស្ត្រនិយម»។ ប្រាំឆ្នាំ ក្រោយបានឯករាជ្យពីបារាំង សម្ដេច សីហនុ កំចាត់អ្នកចេះដឹងខ្មែរអស់ជាច្រើន ព្រោះតែខ្លាចអ្នកទាំងនេះ ប្រឆាំង នឹង នយោបាយ ព្រមទាំងតួនាទីដឹកនាំប្រទេសរបស់ព្រះអង្គ។ សម្ដេច សីហនុ មានប្រជាជនតាមស្រែចម្ការស្រឡាញ់ ប៉ុន្តែមាន អរិភាពជាមួយអ្នកចេះដឹង។ ចំណែកឯ ប៉ុល ពត វិញ ដែលបានត្រូវគេចាត់ទុកថា ជាបញ្ញវន្តកុម្មុយនិស្តផង ជាអ្នកជាតិនិយមផង ក៏ពុំខុសពីអ្នកជាតិនិយមជ្រុលឯទៀតដែរ។ ប៉ុន្តែនេះ ក៏ជាបញ្ហាមួយ ដ៏ធំ ចំពោះអ្នកដឹកនាំកុម្មុយនិស្តគ្រប់ប្រទេសដែរ ព្រោះការកសាងវប្បធម៌ថ្មីស្រឡាងដាច់ស្រឡះពីវប្បធម៌ចាស់ទាំងស្រុងជា ការដែលពុំអាចធ្វើទៅបានឡើយ។ ការកកកើត នៃវប្បធម៌មួយ ប្រើពេលយូរណាស់ ហើយ ត្រូវឆ្លងកាត់បដិវាទកម្ម ជាច្រើនថែមទៀត។ មែនទែនទៅ បដិវត្តន៍កុម្មុយនិស្ត របស់ ប៉ុល ពត គឺជាការសងសឹកមួយដ៏ធំ និងដ៏កម្រោលតែប៉ុណ្ណោះ ដោយសម្លាប់ទាំងបញ្ញាជន ទាំងពួកគហបតី ទាំងអភិជន ទាំងអ្នកបដិវត្តដូចគ្នា ដែលមិនព្រមគោរព មហិច្ឆតា របស់ ម៉ៅ សេទុង។ តាមរយៈ បដិវត្តន៍ របស់ ម៉ៅ នៅពេលនោះ និងតាមរយៈលទ្ធិម៉ាក្ស លេនីន របស់សូវៀត អ្នកដឹកនាំចិន និង យួន មិនព្រមឲ្យប្រទេសបស្ចិមលោកណាមួយ មាន





ឥទ្ធិពលទៅលើ អតីតឥណ្ឌូចិនបារាំងឡើយ។ វៀតណាមវិញ គេក៏មានមហិច្ឆតា ជំនួសពួកអាណានិគមនិយមបារាំង ដូចចិន អ៊ីចឹងដែរ។ គឺនៅក្នុងន័យនេះហើយ ដែលចិន និង យួន ដណ្ដើមគ្នា ក្ដាប់ ទាំង សីហនុ ទាំង ប៉ុល ពត ដើម្បីប្រានឥទ្ធិពល បស្ចិមប្រទេសចេញពី តំបន់អាស៊ីអាគ្នេយ៍។

តើគោលដៅ របស់ ប៉ុល ពត ក្នុងនាមជាអ្នកដឹកនាំ ចលនាកុម្មុយនិស្តខ្មែរ នាឆ្នាំ ១៩៥០-១៩៧៥ មានអ្វីខ្លះ? ដូចយើងបានដឹងខ្លះៗ រួចមកហើយ កាលដើមឡើយ គឺជាចលនា ទាមទារឯករាជ្យ ដែលស្ថិតនៅក្នុង ចលនា របស់ វៀតមិញ។ ប៉ុន្តែក្រោយមក ដោយដឹងថា យួនមានគោលដៅមួយទៀត គឺ លេបទឹកដីខ្មែរតែម្ដង ក៏បែរទៅរកចិនវិញ នៅឆ្នាំ ១៩៦៦។ ប៉ុន្តែ នៅចន្លោះ ឆ្នាំ ១៩៦៦-១៩៧៥ ប៉ុល ពត ត្រូវបង្ខំចិត្តធ្វើការរួមជាមួយ កុម្មុយនិស្តយួនសិន ដើម្បីដេញអាមេរិកចេញពី ឥណ្ឌូចិន ហើយ ទាំងចិន ទាំង ប៉ុល ពត បានឆ្លៀតប្រើកម្លាំងយួនសិន ដើម្បីវាយរំលំសាធារណរដ្ឋខ្មែរដែលមានអាមេរិកជាបង្អែក។ ចាប់តាំងពីឆ្នាំ ១៩៥៣ មក ប៉ុល ពត ព្រមទាំងខ្មែរកុម្មុយនិស្តដែលស្ថិតនៅក្រោមការដឹកនាំ របស់ ប៉ុល ពត គ្មានតួនាទីជាអ្នកដឹកនាំ ការទាមទារឯករាជ្យទៀតឡើយ ព្រោះ ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ និង បញ្ញវន្ត អភិរក្សស្តាំនិយម បានទទួលជោគជ័យ ក្នុងការទាមទារឯករាជ្យ ពី បារាំង រួចទៅហើយ។ បញ្ហាដ៏ចម្រូងចម្រាសដែលកើតឡើងនៅខណៈនោះ គឺ បន្ទាប់ ពី បារាំងដកទ័ពចេញពី ឥណ្ឌូចិនទៅ ចិនដែលនៅជាសម្ព័ន្ធមិត្ត របស់ ប្រទេសវៀតណាមនៅឡើយ បានអូសទាញសម្ដេច នរោត្តម សីហនុ ឲ្យបន្ត ការតស៊ូប្រឆាំង នឹង អាមេរិកបន្តទៅទៀត។ ដើម្បីធ្វើកិច្ចការនេះ ចិនក្ដាប់ទាំងសម្ដេច សីហនុ ក្ដាប់ទាំង ប៉ុល ពត។ ចិនមិនទុកចិត្ត សម្ដេច សីហនុ ប៉ុន្មានទេព្រោះព្រះអង្គអាចប្រែប្រួលនៅពេលខាងមុខ។ ដោយដឹងថាចិន មានមហិច្ឆតាលេបយកឥណ្ឌូចិនទាំងមូល វៀតណាម តាមយុទ្ធសាស្ត្រ របស់ ហូ ជីមិញ ក៏បែរ ទៅរក សហភាព សូវៀតវិញ ។ សហភាព សូវៀត ដែលមានទំនាស់ ជាមួយចិនតាំងពីឆ្នាំ ១៩៥៩ ក៏ចាប់ផ្ដើមពង្រឹងតួនាទីរបស់គេនៅឥណ្ឌូចិន។ ទំនាស់ រវាង ចិន និង

យួន បានក្លាយទៅជាទំនាស់មួយ ជាមូលដ្ឋាន នៅក្នុងបក្សកុម្មុយនិស្តខ្មែរ ក្រោមការដឹកនាំ របស់ ប៉ុល ពត ។ និយាយមួយបែបទៀត ប្រទេសវៀតណាម មិនបណ្តោយឲ្យចិនយកប្រទេសទាំងបីនៅឥណ្ឌូចិនបានឡើយ ព្រោះនេះ ក៏ជាគោលដៅរបស់គេដែរ។ ខាងផ្នែកមនោគមវិជ្ជា ប៉ុល ពត យករបៀបបដិវត្តន៍ចិន។ តាមការពិត គឺមិនមែនជាបដិវត្តន៍ ដែលមានប្រជាជនគាំទ្រទេ ព្រោះនៅពេលនោះ ប្រទេសកម្ពុជា បានក្លាយ ទៅជាសមរភូមិមួយ ដ៏ក្តៅគគុក រវាង ចិន និង យួន ដែលមានរហូតមកដល់ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ ។ ប៉ុន្តែ ដោយ សហភាព សូវៀត ត្រូវរលំរលាយទៅ យួន ក៏អស់បង្អែក ដើម្បីប្រែក្លាយសុបិនរបស់គេ ឲ្យទៅជាការពិត ។ ការពិត គឺគ្រាន់តែជាការផ្អាកសង្គ្រាមប៉ុណ្ណោះសិនទេ ព្រោះទំនាស់រវាងយួន និងចិន មិនមែនជាទំនាស់មនោគមវិជ្ជា ប៉ុន្មានទេ តែជា ទំនាស់ ដណ្តើមឥណ្ឌូចិនគ្នា ។ ហេតុដូចម្តេច បានជាខ្មែរក្រហមសម្លាប់បញ្ញវន្តខ្មែរ ឲ្យផុតពូជដូច្នេះ? មុនពេលបារាំងចេញផុតទៅ បារាំង បានបង្កើតបញ្ញវន្ត សម្រាប់ បន្តវេន អភិក្រមទំនើបកម្ម ប្រទេសកម្ពុជាតាមបែបបទបស្ចិមប្រទេស រួមបញ្ចូលទាំងលទ្ធិប្រជាធិបតេយ្យសេរីនិយមផងដែរ។ ដើម្បីគ្រប់គ្រងខ្មែរបាន ចិនគ្មានជម្រើសអ្វីទៀត ក្រៅពីលុបបំបាត់តួនាទី របស់បញ្ញវន្តទាំងនោះឡើយ រួមបញ្ចូលទាំងអ្នកឆ្វេងនិយមផងដែរ ព្រោះផុតពី សីហនុ ទៅ នៅមានអ្នកទាំងនោះទៀត ដែលជា ឧបសគ្គក្នុងការបញ្ចូលស្រុកខ្មែរទៅវង្វង់ឥទ្ធិពលចិន ។ រីឯខ្មែរក្រហម មួយក្រុមទៀត ដែលមានយួនគាំទ្រ ចាប់តាំងពីការឈ្លានពាន របស់ យួននៅឆ្នាំ ១៩៧៩ មក ក៏ ធ្វើប្រហាក់ប្រហែលគ្នាដែរ គឺ យកអ្នកដែលគ្មានជាប់ នឹង វប្បធម៌បារាំង ឲ្យដឹកនាំប្រទេសដោយកណ្តាប់ដៃដែកតែម្តងគឺជាការស្រេច បន្ទាប់មក បង្កើតអំពើពុករលួយពាសពេញប្រទេស។ ប៉ុន្តែប្រទេសវៀតណាមក្តី របបខ្មែរក្រហមដែលមានយួនជាបង្អែកក្តី ត្រូវការប្រាក់កាសពីបស្ចិមប្រទេសដើម្បីទប់ទល់ នឹង ចិន ដែលបានក្លាយទៅ ជាប្រទេសមានការលូតលាស់ ដ៏ខ្លាំងមហិមា ។ ហេតុនេះ ខុសពីចិនបន្តិច យួនត្រូវបង្ខំចិត្តរក បស្ចិមប្រទេស មកធ្វើជាបង្អែកយុទ្ធសាស្ត្រ ។





# ព្រឹត្តិការណ៍ ថ្ងៃ ១៧ មេសាឆ្នាំ ១៩៧៥

## Le 17 Avril 1975

នៅថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ កងទ័ព ខ្មែរក្រហម ប្រដាប់ដោយកាំភ្លើង អាកា ៤៧ និង កាំភ្លើងសំរាប់បាញ់គ្រាប់បែក បេ ៤០ បាន ចូលមកដល់ទីក្រុងភ្នំពេញ។ ពួកគេប្រកាសថា «សង្គ្រាមចប់ហើយ» គឺ មានន័យ ថា ពួកគេនាំមក នូវ សន្តិភាព ។ ប៉ុន្តែ នៅថ្ងៃនោះឯង កងទ័ពខ្មែរក្រហម បានបន្ត ធ្វើការបោសសំអាត ទីតាំងសំខាន់ៗរបស់ កងទ័ព សាធារណរដ្ឋខ្មែរពាសពេញទីក្រុង ។ គេឃើញ សាកសព ជនជាតិខ្មែរដេកស្លាប់ស្តូកស្តឹង ដូចខ្មោចឆ្កែ ពាសពេញផ្លូវថ្នល់ ។ ប៉ុន្តែ គេឥតមានឃើញ សាកសព ជនជាតិ អាមេរិកាំង ឬ ក៏ សាកសព ជនជាតិវៀតណាមណាម្នាក់សោះ ។ ហាងទំនិញ មន្ទីរពេទ្យ សាលារៀន ព្រមទាំង សម្ភារៈបរិក្ខាទំនើបៗ បានត្រូវ ពួកអ្នកបដិវត្តជាប់ខាតទាំងនេះ កំទេចចោលអស់ ព្រោះតែ ពួកគេយល់ថា សុទ្ធតែ ជាកត្តា នៃ អំពើពុករលួយ ជាសត្រូវ របស់ បដិវត្តន៍ ។ នៅចំពោះមុខស្ថានការណ៍បែបនេះ ប្រជាជនទីក្រុងភ្នំពេញ ដែលបានត្រូវពួកនេះចាត់ទុកជាស្រេច ថាជាខ្មាំង របស់ បដិវត្តន៍ ជាខ្ញុំកញ្ជះ របស់ ពួកចក្រពត្តិអាមេរិក ឬ ជា អ្នកគាំទ្រ របបសាធារណរដ្ឋខ្មែរ ចាប់ផ្តើមយល់ថា ពួកខ្មែរក្រហម ពិតជាពួក ទមិឡអន្ធពាល គ្មានសាសនា គ្មាន ធម៌មេត្តា អ្វីទាំងអស់ ។ ក្រោយនោះបន្តិច ប្រជាជនទីក្រុងភ្នំពេញ ដែលនៅពេលនោះ មានចំនួនប្រមាណ ២ លាន៥ សែន នាក់ បានត្រូវពួកខ្មែរក្រហម ដេញចេញពីទីក្រុងទាំងអស់ គឺដោយប្រញាប់ប្រញាល់ តក់ក្រហល់ រកតែយកអ្វីទៅជាមួយ ឬ ប្រមែប្រមូល ប្រពន្ធកូនចៅបងប្អូន ឲ្យមកជុំគ្នាមិនទាន់ ។ គឺនៅពេលនោះហើយ ដែលអ្នករស់នៅក្នុងទីក្រុងទាំងប៉ុន្មានត្រូវបាក់បែកគ្រួសារ ។ ខ្លះបាត់ប្តី ខ្លះបាត់ប្រពន្ធ កូនចៅ រកមិនឃើញរហូតមកដល់សព្វថ្ងៃនេះ។ នៅថ្ងៃ ១៧-១៨ មេសា នោះ ពួកខ្មែរក្រហម ដែលដើរដេញប្រជាជនតាមផ្ទះ បានភូតភរថា «អង្គការ» ឲ្យចេញពីផ្ទះ តែបីថ្ងៃប៉ុណ្ណោះទេ គឺ ដើម្បី

ឲ្យគេចពីការទម្លាក់គ្រាប់បែក របស់ អាមេរិក ។ ពួកខ្លះប្រាប់ថា មិនបាច់ចេញទេ ជាហេតុធ្វើឲ្យគិតអ្វី ក៏មិនទាន់ ហើយមានការខ្វែងគំនិតគ្នាយ៉ាងខ្លាំង នៅក្នុងចំណោម ពួកខ្មែរក្រហម រហូតដល់ពួកនេះបាញ់គ្នាវា ទៅវិញទៅមក ទៀតផង ។ នៅទីបំផុត បញ្ជាចុងក្រោយ គឺ ត្រូវឲ្យប្រជាជន ចេញអស់ពីទីក្រុង ពោលគឺ ពី លំនៅឋាន របស់គេ ។ មនុស្សម្នា ត្រូវបង្ខំចិត្ត ចាកចេញពីផ្ទះដោយក្រៀមក្រំ ក្រោមការគំរាមកំហែងនៃកាំភ្លើង អា កា ៤៧ និង បេ ៤០ ដែលពួកវាហៅថា «ត្រយូងចេក» ។ កងទ័ពខ្មែរក្រហមដែលចូលមកទីក្រុងភ្នំពេញ ខ្លះខោអាវខ្មៅ ខ្លះទៀត ពាក់ឯកសណ្ឋានត្រីយីទាហាន ដើរដេញទាំងមនុស្សឈឺ ទាំងស្រីមានផ្ទៃពោះ ទាំងមនុស្សកំពុងព្យួរសេរ៉ូម ចេញអស់ ពី មន្ទីរពេទ្យៗ នៅតាមផ្លូវថ្នល់ គេឃើញពួកវា អូសទាំងមនុស្ស ទាំងគ្រែ ប្រវេងប្រវាង ដូចគេ អូសសត្វជ្រូក គួរឲ្យសង្វេគពន់ពេកក្រៃ ។

ក្នុងរយៈពេលតែ បួន-ប្រាំ ម៉ោង គឺប្រហែល ពី ម៉ោង ៩ ព្រឹក ដល់ម៉ោង ២ ថ្ងៃរសៀល អ្នករស់នៅក្នុងទីក្រុងភ្នំពេញ ប្រមាណជាង ២ លាន នាក់ បានត្រូវ ពួកខ្មែរក្រហម ដេញចេញ ពីទីក្រុងអស់គ្មានសល់ ។ ជនរងគ្រោះទាំងនោះ ត្រូវគេរុញច្រាន យ៉ាងពពាក់ពពូន ណែនណាន់តាន់តាប់ ចេញពី ទីក្រុងតាមផ្លូវជាតិទាំង ៤ ទិស ដោយមិនដឹងថា តើត្រូវទៅទីណា ។ អស្ចារ្យជាងនេះទៅទៀត អ្វី ក៏ពួកខ្មែរក្រហមមិនឲ្យយកទៅដែរ ប៉ុន្តែ ចំណីអាហារ បាយទឹក សម្រាប់ធ្វើដំណើរ ដែលគ្មានគោលដៅនេះ ក៏ពួកនេះ ឥតចែកចាយឲ្យទៀត ។ មនុស្ស រាប់សែននាក់ ដែលធ្វើដំណើរតាមផ្លូវជាតិ នីមួយៗ ក្នុងពេលតែមួយ ឆ្ពោះទៅរក ស្រែ ចំការ ព្រៃព្រឹក្សា ឬ ឆ្ពោះទៅរកមរណៈតែម្តង ក៏អាចថាបាន គ្មានអ្វីបរិភោគទេ ហើយស្រេកទឹកភ្នែក ដោយនឹកទៅដល់ប្តី ឬ ប្រពន្ធកូនចៅ ដែលមិនដឹងខ្ចាត់ព្រាត់ ទៅទីណា ។ ខែមេសា ជាខែក្តៅហួតហែងម្ល៉ោះហើយ ការធ្វើដំណើរបែបនេះ ជាពិសេស កូនខ្ចី ស្រីមានផ្ទៃពោះ កូនក្មេង មនុស្សចាស់ជរា មនុស្សមានជម្ងឺ ត្រូវខ្យល់ចាប់ ដួលស្លាប់ យកទៅកប់ សឹងមិនទាន់ ព្រោះត្រូវធ្វើដំណើរជាក្បួនបន្តទៅទៀត។ ក្លិនអសោច នៃសាកសពមនុស្ស ដែលខ្មែរក្រហម



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

បានសម្លាប់ចោល ធំស្អុយ ពេញបរិយាកាស ។ ថ្ងៃបន្ទាប់ៗមកទៀត ដោយខ្លះស្បៀងអ្នកទោស របស់ ពួកខ្មែរក្រហម រាប់សែននាក់ តាមផ្លូវជាតិនីមួយៗ ហើយ រាប់លាននាក់ នៅក្នុងប្រទេសទាំងមូល ចាប់ផ្តើមបាក់បែកគ្នា ឬ អត់ឃ្លានសម្រក់ទឹកភ្នែក ព្រោះតែទាស់ទែងដណ្តើមចំណីអាហារគ្នាបន្តិចបន្តួច គឺ ចំណី ដែលខ្លះមានគំនិត យកមកជាប់នឹង ខ្លួន ឬ ក៏ដោយយក គ្រឿងអលង្ការ ទៅដោះដូរជាមួយ «អ្នកមូលដ្ឋាន»[១៥]។ ចំពោះអ្នកខ្លះ ដំណើរគ្មានគោលដៅនេះ មានរយៈពេល ១ ឬ ២ សប្តាហ៍។ ចំពោះអ្នកខ្លះទៀត គេចាយពេលអស់ជាង ១ ខែ ទើបរកភូមិ ដែលគេអនុញ្ញាតឲ្យស្នាក់អាស្រ័យនៅបាន។ អ្នកដែលមានដើមកំណើត នៅភូមិ-ស្រុក ណា មិនហ៊ានទៅស្រុកនោះវិញទេ ព្រោះ តែបានធ្លាប់ធ្វើជាអ្នករដ្ឋការ ឬ ទាហាន។ រហូតមកទល់សព្វថ្ងៃនេះ គេនៅមិនយល់ថា ហេតុដូចម្តេច បានជាពួកខ្មែរហ្រោម ធ្វើបាបប្រជាជនឯងបែបនេះ ។ ខ្លះជឿថា គឺ ដើម្បីប្រែក្លាយ ប្រជាជនទីក្រុង ឲ្យទៅជាកសិករ ។ ខ្លះទៀតយល់ថា គឺ ជាការគំកួនអ្នកទីក្រុង។ ប៉ុន្តែ បើត្រូវប្រែក្លាយអ្នកទាំងនេះ ឲ្យទៅជាកសិករ ជាអ្នកបង្កបង្កើតផលមែន ហេតុដូចម្តេច បានជា ពួកគេ ពុំរង់ ចាំ ១ ខែ ឬ ២ ខែសិន ទម្រាំ រៀបចំ ឲ្យបានស្រួល? តើអ្នកដែលធ្វើដូច្នេះ ជាខ្មែរមែន ឬក៏ មានអ្នកណានៅពីក្រោយ ? ប៉ុន្តែ មានប្រការមួយទៀត ដែលអាចមានការទាក់ទង នឹង ការដេញប្រជាជនចេញពីទីក្រុងនេះ ៖ នៅពេលក្រោយនោះបន្តិច ពួកខ្មែរក្រហម បានអំពាវនាវ រកបញ្ញវន្ត ដែលគេសម្គាល់តាមសញ្ញាអ្នកពាក់វ៉ែនតា។ រីឯគោលដៅ គឺកំទេចអ្នកចេះដឹងខ្មែរចោលទាំងអស់។ ហេតុដូចម្តេច បានជាពួកគេ កំទេចបញ្ញវន្តចោល ? ជាការពិត ហើយដែលថា បញ្ញវន្ត

[១៥] អ្នកដែលរស់នៅ ជនបទ តាំងពីយូរមកហើយៗ ដែលបានចូលរួមចំណែក ប្រយុទ្ធជាមួយខ្មែរ ក្រហម នៅពេលតស៊ូ ។ ភាគច្រើន នៃ អ្នកទាំងនេះ មាន កូន ប្រុស ស្រី ធ្វើជា យោធា ខ្មែរក្រហម ។

*ជាអ្នកតំណាងវប្បធម៌សង្គមខ្មែរ ដែលពួកគេមិនចង់បាន ក៏ប៉ុន្តែបើគ្មាន អ្នកទាំងនេះទេ សង្គមខ្មែរ ក៏ពុំអាចជាសង្គមខ្មែរទៀតឡើយ។ តើនេះឬ ដែលជាគោលដៅ របស់អ្នកធ្វើ «បដិវត្តន៍វប្បធម៌» នោះ? ទោះជាយ៉ាងណាក្តី អ្វីដែលពុំអាចប្រកែកបាន គឺ អំពើ ឃោរឃៅ ដ៏សាហាវព្រៃផ្សៃបំផុត របស់ពួកខ្មែរក្រហម ទៅលើ ប្រជាជនឯង ការកាប់ សម្លាប់ខ្មែរគ្នាឯង តាំងពីពេលចូលមកដល់ទីក្រុង រហូតដល់ របៀបដាក់ទណ្ឌកម្ម កម្មាភិបាលខ្មែរក្រហមដូចគ្នា ដោយធ្វើទារុណកម្មយ៉ាងព្រៃផ្សៃ ។ នេះជា ទំព័រប្រវត្តិសាស្ត្រ មួយ ដ៏ ខ្មៅងងឹត ដែលខ្មែរជំនាន់ក្រោយ រកជឿសឹងពុំរួច ។ គឺ នៅក្នុងគោលដៅរក្សាទុកនូវ ការពិតនេះហើយ ដែលខ្ញុំខំសរសេរ រឿងរ៉ាវ ទាំងឡាយនេះ សម្រាប់ បញ្ជាក់ប្រាប់ខ្មែរ ជំនាន់ក្រោយ ។ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនេះ បានត្រូវ អ្នកប្រវត្តិសាស្ត្រក្នុង សកលលោក សរសេររួចអស់ហើយ ប៉ុន្តែខ្ញុំយល់ថា គួរតែសរសេរ ជាភាសាខ្មែរទៀត ដើម្បីទុកជា សារណា របស់ ខ្មែរ ឲ្យបានរហូតតរៀងទៅ ។*

## *អាកប្បកិរិយារបស់ ពួកខ្មែរ ក្រហម*

## Le comportement des Khmers rouges

*នៅពេលដែលពួកខ្មែរក្រហម ដេញប្រជាជនចេញពីទីក្រុងភ្នំពេញ និងពី ទីក្រុងនានាឲ្យចេញឆ្ពោះទៅជនបទ នៅទីក្រុងភ្នំពេញ ឯនោះវិញអ្នកដឹកនាំ របប សាធារណរដ្ឋខ្មែរ មួយចំនួន បានរត់ទៅ សុំជ្រកកោន នៅ ស្ថានទូតបារាំង ប៉ុន្តែ ជា ការឥតប្រយោជន៍។ ពួកខ្មែរក្រហម ដែលជាអ្នកជាតិនិយមចង្អៀតចង្អល់ ហើយ ដែលជា អ្នកស្អប់ខ្ពើមជនបរទេសក្រៅពី ចិនកុម្មុយនិស្ត និងកូរ៉េខាងជើង ជាពិសេស ជនស្បែកស នៃ បស្ចិមលោក មិនទទួលស្គាល់ បេសកកម្ម ការទូតអ្វី ទាំងអស់ ។ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិសិរិមតៈ អ្នកដឹកនាំម្នាក់ ដ៏ ំខាន់ នៃ របបសាធារណរដ្ឋខ្មែរ ដែល នាទីបំផុត បាន ទៅសុំជ្រកកោន នៅក្នុងស្ថានទូតបារាំង ក៏ពុំបាន ទទួលសិទ្ធិជ្រកកោនដែរ ព្រោះ ស្ថាន*





*ទូត មិនដឹងត្រូវចាត់ការរបៀបណា ៖ ណាមួយ ខ្លាចពួក «អាវខ្មៅ» ទាំងនោះ បាញ់ទៅលើស្ថានទូត ណាមួយ ខ្លាចខុសច្បងការទូត ព្រោះ នៅពេលនោះ ប្រទេសបារាំង ក្រោមការដឹកនាំ របស់ លោក ប្រធានាធិបតី វ៉ាឡេរី ហ្ស៊ីសស្កា ដេសស្តាំង* (Valéry Giscard d'Estaing) *គាំទ្រ សម្តេច នរោត្តម សីហនុ ដែលគេគិត ជាទូទៅ នៅពេលនោះថាជា អ្នកដឹកនាំ របស់ ពួកខ្មែរក្រហម។ ដូចនេះ គេមិនអាចទទួលស្គាល់ អ្នកដឹកនាំ របបសាធារណរដ្ឋខ្មែរ បានទេ រី ឯ ស្ថានទូតបារាំង នៅពេលនោះ គ្រាន់តែជាស្ថានកុងស៊ុល តែប៉ុណ្ណោះទេ។ មុន នឹង ត្រូវ ពួកខ្មែរក្រហម អូសយកទៅ ប្រហារជីវិត អ្នកអង្គម្ចាស់សិរិមតៈ ដែលពុំព្រមរត់ចេញពីស្រុក មុន ការរលំរលាយ នៃ សាធារណរដ្ឋខ្មែរ បាននិយាយសារភាពថា ៖ «ក្នុងមួយជីវិត របស់ ខ្ញុំនេះ ខ្ញុំមានកំហុសតែមួយគត់ គឺ ជឿទៅលើសហរដ្ឋ អាមេរិក» ។ ពួកខ្មែរក្រហម បានបន្ថែមថា ៖ «មិនមែនតែ សហរដ្ឋ អាមេរិក ប៉ុណ្ណោះទេ អ្នកណាទៀត ក៏មិនត្រូវជឿដែរ ដូចនៅក្នុងពេលនេះជាដើម អ្នកអង្គម្ចាស់ បានឃើញស្រាប់ហើយ»។ អ្នកដឹកនាំ សាធារណរដ្ឋខ្មែរ មួយចំនួនទៀត ដូចជា លោក ឡុង បូរ៉េត លោក លន់ ណុន ប្អូនរបស់ លោក សេនាប្រមុខ លន់ នល់ និង ជាមិត្តរួមថ្នាក់ របស់ ខៀវ សំផន ជាដើម ក៏បានត្រូវពួកខ្មែរក្រហម យកទៅ ប្រហារជីវិតចោលដែរ ។ សូមបញ្ជាក់ថា គឺ លោក លន់ ណុន នេះ ហើយដែលជាអ្នកជួយ ទំនុកបម្រុង សាលាឯកជន «ចំរើនវិជ្ជា» និង «កម្ពុជបុត្រ» ដែលជា សំបុក របស់ ពួកខ្មែរក្រហម កាលពីសម័យ ដែលពួកគេតស៊ូ នៅក្នុងទីក្រុងភ្នំពេញ។ នៅខណៈនោះ នៅក្នុងស្ថានទូតបារាំង មានការប្របូកប្របល់មួយដ៏ធំ ៖ នារីខ្មែរដែលមានប្តីបារាំង ត្រូវ ពួកខ្មែរក្រហមអនុញ្ញាត ឲ្យនៅក្នុងស្ថានទូត រីឯខ្មែរ ដែលមានប្រពន្ធបារាំង ត្រូវចេញ ពីស្ថានទូត ទាំងអស់ជាកំហិត ។ ពួកខ្មែរក្រហម គំរាម លោក អនុកុងស៊ុល បារាំងថា បើមិនព្រមប្រគល់ ជនជាតិខ្មែរ ទាំងនោះ ទៅឲ្យពួកគេទេនោះ ពួកគេនឹងបាញ់ លោក អនុកុងស៊ុល ចោលតែម្តង ព្រោះ ពួកគេ ឥតខ្លាច ឥតរណប នឹង ជនបរទេសណា ដែលស្ថិត នៅលើ ទឹកដីខ្មែរឡើយ។*

*នៅពេលដែលព្រឹត្តិការណ៍ ដ៏ចម្លែកនេះកើតមានឡើង នៅក្នុងពិភពលោកទាំងមូល គ្មាន អ្នកណា ជឿថា មានរឿង របៀបនេះទេ។ បើកុំតែមាន ជនជាតិបារាំង គឺ សង្ឃកាតូលិក ប៉ុងសូដ៍* (Père Ponchaud ) *ស្ថិតនៅក្នុងប្រទេសកម្ពុជា រហូត ដល់ ពេលចុងក្រោយ បង្អស់ ជាសាក្សី ពិភពលោក ទាំងមូល ក៏មិនអាច ជឿបានឡើយ ។ សង្ឃកាតូលិក បារាំង ប៉ុងសូដ៍ ដែល ពេលមកដល់ ស្រុកបារាំងវិញ បាននិពន្ធ សៀវភៅមួយ មានចំណងជើងថា ៖ Cambodge, Année zéro* («*ប្រទេសកម្ពុជា ឆ្នាំដែលធ្លាក់ ដល់ បាតាល*») *បានសរសេរ រៀបរាប់ ពីព្រឹត្តិការណ៍នេះ យ៉ាងពិស្តារ ។ នៅក្នុងប្រទេសកម្ពុជា នៅពេលនោះ គេចោទសួរថា ហេតុដូចម្តេច បានជាពួកខ្មែរ ក្រហម ធ្វើបែបនេះ ហើយ ប្រកាន់ អាកប្បកិរិយាបែបនេះ ? ហេតុដូចម្តេច បានជា ពួកគេស្អប់អ្នកទីក្រុង ដល់ថ្នាក់នេះ? ចំពោះ ពួកខ្មែរក្រហម គេឥតពិបាកឆ្លើយទេ ព្រោះ ចំពោះពួកគេ អ្នកនៅទីក្រុង សុទ្ធតែជាអ្នកពុករលួយ ជាអ្នកលក់ខ្លួន លក់ប្រទេសឲ្យបរទេស ហើយដើម្បីកសាងសង្គមថ្មីមួយទៀត ឲ្យបានស្អាតស្អំ មាន សេចក្តីស្នេហាជាតិ ដ៏មោះមុត ពួកគេ ត្រូវតែធ្វើដូច្នេះ ។ សូមកត់សម្គាល់ថា កាលណា ផលប្រយោជន៍ ឬ អំណាច របស់គេ ត្រូវប៉ះពាល់ អ្នកដឹកនាំខ្មែរមួយចំនួន តែងតែនិយាយបែបនេះ ទោះបីតាមការពិតទៅ ជាតិទាំងមូល ដែលគេតាំងខ្លួនគេ ថាជា អ្នកតំណាងនោះ ត្រូវបង្រួមមកត្រឹមបក្សពួក របស់ គេ ក៏ដោយ ។ ជាក់ស្តែង គេសង្កេតឃើញថា ដោយសំអាងទៅលើ ហេតុផលទាំងឡាយនេះ អ្នកដឹកនាំខ្លះ ធ្វើការសង្កត់សង្កិនប្រជាជនឯង ប្រហាក់ប្រហែល នឹង អ្វី ដែលពួកអាណានិគមនិយម និង ពួកចក្រពត្តិនិយម ធ្វើទៅលើប្រជាជន នៃ ប្រទេសដែលគេ ឈ្លានពាន ដូច្នេះដែរ។ ប៉ុន្តែ អាណានិគមនិយម បែបចុងក្រោយនេះ មានលក្ខណៈ ធ្ងន់ធ្ងរណាស់ ព្រោះថា ក្រនៅតែក្រ គ្មានចំណេះវិជ្ជា នៅតែ គ្មានចំណេះវិជ្ជា ដដែល ។ បើមិនផ្តល់ចំណេះវិជ្ជាគ្រប់គ្រាន់ ដល់ប្រជាជន តើគេរំដោះប្រជាជន តាមបែបណាទៅ? នៅក្នុងករណី នៃប្រទេសកម្ពុជា នៅសម័យដែល ខ្មែរក្រហម កាន់អំណាចនោះ គេសង្កេតឃើញថា សម្រេចសម្រួចទៅ ជន*





*បរទេស មួយប្រភេទទៀត នាំគ្នា ចូលមកតាមទ្វារក្រោយ យ៉ាងពពាក់ពពូន គឺ ខុសគ្នាតែ ពណ៌សម្បុរស្បែក តែប៉ុណ្ណោះ ។*

## *របប «កម្ពុជា ប្រជាធិបតេយ្យ»*
## Le « Kampuchéa démocratique »

*ព្រឹត្តិការណ៍ ថ្ងៃ ១៧ មេសាឆ្នាំ ១៩៧៥ បានត្រូវ ខ្មែរក្រហម ចាត់ទុកថា ជាថ្ងៃជោគជ័យមួយដ៏ធំ នៅក្នុងប្រវត្តិសាស្ត្រខ្មែរ ព្រោះ ជាថ្ងៃដែលពួកគេអះអាងថា បានវាយរំលំ ទាំង របបសក្តិភូមិ ទាំង វណ្ណៈគហបតី ទាំង ពួកអាណានិគមនិយម គ្រប់ប្រភេទ ។ ប៉ុន្តែចំពោះ សម្តេច នរោត្តម សីហនុ វិញ ព្រះអង្គ បានត្រូវពួកខ្មែរ កុម្មុយនិស្ត រក្សាទុកសិន ជាហេតុធ្វើឲ្យ ប្រជាជនខ្មែរ នៅពេលនោះ មានសេចក្តីសង្ឃឹមថា សភាពការណ៍ នឹង វិលទៅរក ភាពប្រក្រតី វិញជាពុំខាន ។ ប្រជាជនទីក្រុងដែលត្រូវជម្លៀស ឲ្យទៅរស់នៅ តាមភូមិ នៅជនបទ ហើយ ដែលអត់បាយ ក្រហាយទឹក ព្រាត់ប្រាសប្តីសី ប្រពន្ធកូនចៅ នាំគ្នាសម្លឹងមើលទៅ ឰដរអាកាស ក្រែងឃើញយន្ត ហោះដល «សម្តេច ឪ»*[១៦] *ត្រូវធ្វើដំណើរត្រឡប់ ពីប៉េកាំង មកមាតុប្រទេសវិញ ។ ១០ ថ្ងៃបន្ទាប់ពី យោធា ខ្មែរក្រហម បានចូលមកទីក្រុងភ្នំពេញ អ្នកដឹកនាំខ្មែរ ក្រហមបានបើក អង្គសន្និបាតមួយនៅ ពហុកីឡាដ្ឋាន ក្រោមអធិបតី របស់ ខៀវ សំផន។ សមាជិក រដ្ឋាភិបាល រួបរួមជាតិ កម្ពុជា ១៣ រូប ក៏ បានចូលរួមប្រជុំដែរ ។ អង្គសន្និបាតនាថ្ងៃ ២៥-២៧ មេសានោះ បានសំរេចរក្សាទុក សម្តេច នរោត្តម សីហនុ ឲ្យស្ថិតនៅ*

---

[១៦] *សម្តេច នរោត្តម សីហនុ សព្វព្រះទ័យ ឲ្យគេ ហៅ ព្រះអង្គ ថា «សម្តេច ឪ » ។*

*ជាប្រមុខរដ្ឋដដែល ហើយ លោក ប៉ែន នុត ក៏ស្ថិតនៅ ជានាយករដ្ឋមន្ត្រី បន្តមកទៀតដែរ។ ជាង ៤ ខែ ក្រោយមហាសន្និបាតនេះ គឺ នៅថ្ងៃ ៩ កញ្ញាឆ្នាំដដែល សម្តេច នរោត្តម សីហនុ ដែលគង់ នៅទីក្រុងប៉េកាំង បានត្រូវ ពួកខ្មែរក្រហម អនុញ្ញាតឲ្យវិលត្រឡប់មកស្រុកខ្មែរវិញ។ ប៉ុន្តែ ព្រះអង្គគង់នៅ ទីក្រុងភ្នំពេញ តែ មួយរយៈពេលតូចប៉ុណ្ណោះ ព្រោះត្រូវទៅបំពេញបេសកកម្ម នៅបរទេស និង នៅអង្គការ សហប្រជាជាតិ។ នៅខែកុម្ភៈ ឆ្នាំ ១៩៧៦ រដ្ឋធម្មនុញ្ញ របប «កម្ពុជាប្រជាធិបតេយ្យ» របស់ពួកខ្មែរក្រហម បានត្រូវប្រកាសឲ្យប្រើ ។ រដ្ឋធម្មនុញ្ញនោះ គឺ ជារដ្ឋធម្មនុញ្ញ កុម្មុយនិស្ត តែម្តង ព្រោះមធ្យោបាយ បង្កបង្កើតផលត្រូវយក ទៅដាក់រួម ជាទ្រព្យសម្បត្តិ របស់ សមូហភាពទាំងអស់ ។ វប្បធម៌ គ្រប់ប្រភេទ ទាំងវប្បធម៌ខ្មែរ ទាំងវប្បធម៌បរទេស ត្រូវគាស់រំលើងចោល ព្រោះ កេរដំណែល ផ្នែកបញ្ញា ២០ សតវត្សរ៍ របស់ មនុស្សជាតិ ទាំងមូល ត្រូវពួកខ្មែរក្រហម ចាត់ទុកថា ជាប្រភព  នៃ អំពើពុករលួយទាំងអស់ ។ នៅថ្ងៃ ២ មេសា ឆ្នាំ ១៩៧៦ សម្តេច នរោត្តម សីហនុ បានលាលែង ពីមុខតំណែង ប្រមុខរដ្ឋ ដើម្បី ផ្តល់តួនាទីនេះ ទៅឲ្យ ខៀវ សំផន វិញ ។ គឺ នៅពេលនោះហើយ ដែល ប៉ុល ពត ចេញមុខ ដឹកនាំ របបថ្មី ដោយមាន តួនាទី ជា នាយករដ្ឋមន្ត្រី ។*

*ថ្ងៃ ១៧ មេសា ដែលជាថ្ងៃជោគជ័យ របស់ ពួកខ្មែរក្រហម ក៏ ជា ថ្ងៃដែលប្រជាជនខ្មែរទាំងមូល ធ្លាក់ទៅក្នុងរណ្តៅមរណៈដែរ។ ថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ នោះ ដែលជា ថ្ងៃដែលជនបរទេស ចេញអស់ ពី កម្ពុជា ក៏ ជាថ្ងៃ បរាជ័យ របស់ ពួកខ្មែរក្រហមផងដែរ។ ចំណីអាហារ និង គ្រឿងឧបភោគបរិភោគ ដែល អាមេរិក ដឹកជញ្ជូនមកឲ្យប្រជាជនខ្មែរ នៅពេលដែល សាធារណរដ្ឋខ្មែរ ឈានមកដល់ ទីបញ្ចប់ នៅសល់សម្រាប់ តែ ១០ ថ្ងៃ ប៉ុណ្ណោះ រី ឯ នៅតាមស្រែចម្ការ ក៏គ្មានអ្វី សម្រាប់ចិញ្ចឹមប្រជាជន ទូទាំងប្រទេសដែរ ព្រោះតែ សង្គ្រាម ព្រោះតែពួកខ្មែរក្រហម គ្មានផែនការអ្វីទាំងអស់ ។ ពួកគេ គិតតែ ពី ជ័យជំនះ ជាប្រវត្តិសាស្ត្រ ដោយភ្លេចគិត ទាំងស្រុងថា ជ័យជំនះពិតប្រាកដ គឺចាប់ផ្តើម ពី ការមានអាហារបរិភោគសិន។ បើ នឹង ទៅរកជំនួយ*





*បរទេស ក៏ពុំកើតទៅទៀត ព្រោះពួកគេស្អប់បរទេស ។ ដូចនេះ ពួកគេ គ្មានជម្រើសអ្វីទៀតក្រៅពី ទុកឲ្យប្រជាជន ដាច់ពោះ ស្លាប់នោះទេ ។ បើពួកគេមិនប្រកាន់យុទ្ធសាស្ត្រម្ចាស់ការ មួយរយភាគរយ បែបនេះ ពួកគេ ក៏មិនចាំបាច់ដេញ ប្រជាជនចេញពីទីក្រុង ជាបន្ទាន់ពេកដូច្នេះដែរ។ តាមធម្មតា មុននឹង ទទួលជ័យជំនះ គេត្រូវគិត រឿង សេដ្ឋកិច្ចសិន គឺ ត្រៀមលក្ខណៈឲ្យបានស្រេច ។ ដូច្នេះឃើញថា ទន្ទឹម នឹង ជ័យជំនះ របស់គេ ពួកខ្មែរក្រហម ក៏ បានបង្កគ្រប់លក្ខណៈ ដើម្បីទទួលបរាជ័យ ទៅវិញដែរ ។ ជ័យជំនះ របស់ ខ្មែរក្រហម ជាជ័យជំនះ ផ្នែកយោធាសុទ្ធសាធ ។ ដោយពុំព្រមប្រែក្លាយវាឲ្យទៅជាជ័យជំនះផ្នែកនយោបាយផ្នែកសេដ្ឋកិច្ច និង សង្គម ជ័យជំនះនោះ ក៏ផុតរលត់បាត់ទៅវិញ ក្នុងពេលមួយដ៏ខ្លី។ ប៉ុន្តែ មុន នឹងរលាយសាបសូន្យ របបនេះ បានបង្កើតវិនាសកម្មមួយ ដ៏ធំសម្បើមអស្ចារ្យ នៅក្នុងសង្គមខ្មែរទាំងមូល ។ រហូត មកទល់ពេលបច្ចុប្បន្ននេះគេនៅតែចោទសួរថា ហេតុដូចម្តេច បានជាខ្មែរក្រហម ជ្រើសរើសយកប្រភេទ បែបនេះ ? ខ្ញុំយល់ឃើញដោយ សាមញ្ញថា គឺ មកពី អវិជ្ជា មកពី ការប្រមាថគតិបណ្ឌិត ទាំងផ្នែកនយោបាយ ទាំងផ្នែកសង្គមធម៌ និង ទស្សនវិជ្ជា ។*

# *ការកកើតឡើង នៃ ចលនា ខ្មែរក្រហម*

## Les origines des Khmers rouges

*មុន នឹង និយាយ អំពី របៀបគ្រប់គ្រងប្រទេស របស់ខ្មែរក្រហម នៅចន្លោះឆ្នាំ ១៩៧៥-១៩៧៩ ខ្ញុំសូមរៀបរាប់អំពីប្រភពដើម និង ប្រវត្តិ នៃ ចលនានេះ ។ កាលដើមឡើយ ចលនាខ្មែរក្រហមនេះ ចេញមកពី ចលនា ឥស្សរៈ ឬ ចលនា ទាមទារឯករាជ្យ ពីបារាំងនៅក្នុងលំហ ឥណ្ឌូចិនទាំងមូល ហើយដែលក្រោយមក បានក្លាយទៅជា ចលនា*

កុម្មុយនិស្ត ដោយគួបផ្សំ ចលនា ទាមទារឯករាជ្យជាតិ ជាមួយ និង ការតស៊ូ របស់វណ្ណៈអធន ។ ចំពោះក្រុមតស៊ូខ្មែរនេះ ដែលនៅ ខែវិច្ឆិកា ឆ្នាំ ១៩៦៦ សម្ដេច នរោត្តម សីហនុ បានដាក់ឈ្មោះឲ្យថា «ខ្មែរក្រហម»ដូច្នេះវិញ គឺ ជា ចលនាមួយ ដែលមាន ការទាក់ទងជិតស្និទ្ធ នឹង បញ្ញវន្តខ្មែរមួយក្រុម ដូចជា ខៀវ ប៉ុណ្ណារី, ខៀវ ធីរិទ្ធ, ហ៊ូ យន់, ហ៊ូ នឹម, ជួន មុម្ម, កេង វ៉ាន់សាក់, ខៀវ សំផន, សាឡុត សរ, អៀង សារី ជាដើម ។ រីឯគំនិតដើម របស់ក្រុមនេះ គឺ គំនិតជាតិនិយមមួយបែប ដែលចង់រំដោះប្រជាជនក្រីក្រ ជាពិសេសកសិករ និង កម្មករឲ្យចេញផុតពី ការសង្កត់ សង្កិន របស់ ឈ្មួញបរទេស និង ពួកអ្នកដឹកនាំខ្មែរអ្នកកាន់អំណាច ដែលពួកគេចាត់ទុកថា សុទ្ធតែជា អ្នកដែលបើកផ្លូវ ឲ្យ ពួកមូលធននិយម «កុំប្រាឌ័រ» ចូលមកធ្វើបាប ប្រជាជនខ្មែរ ។ គេអាចនិយាយម៉្យាងទៀតថា គឺ ជាចលនា អ្នកជាតិយមដាច់ខាតមួយដែលផ្អែក ទៅលើទ្រឹស្ដីកុម្មុយនិស្ត ។ តាមធម្មតា គំនិតជាតិនិយម ជាគំនិតរបស់ អ្នកអភិរក្សប្រកាន់និន្នាការស្ដាំ ប៉ុន្តែ នៅក្នុងករណី ខ្មែរក្រហមនេះ គឺ បែរជាផ្អែក ទៅលើ គំនិតឆ្វេងនិយម ទៅវិញ ។ នេះជាបដិវាទកម្មមួយដ៏ធំ នៅក្នុងមនោគមវិជ្ជាកុម្មុយនិស្ត រួចជាស្រេចទៅហើយ។ របបកុម្មុយនិស្ត គឺ ជាការកាន់អំណាចផ្ដាច់ការ របស់ វណ្ណៈ អធន ដែលផ្អែកទៅលើសាមគ្គីភាព នៃ វណ្ណៈអធនអន្តរជាតិ ដើម្បីវាយរំលំ របបមូលធននិយម ប៉ុន្តែ នៅពេលនោះ ដោយចលនា កុម្មុយនិស្ត នៅអាស៊ី ជាពិសេស នៅឥណ្ឌូចិន ច្រើនតែចេញមកពី ប្រភពអ្នកជាតិយម ដែលប្រឆាំង នឹង ពួកអាណានិគមនិយម ការប្រឫកប្រឫល់ ក៏គេចពុំផុត ។ ម៉្យាង ទៀត លេនីន (Lénine) បានបកស្រាយ ទ្រឹស្ដី របស់ ម៉ាក្ស សម្របទៅតាមការចាំបាច់ នៃ ការធ្វើបដិវត្តន៍សកលលោក ជាបន្ទាន់ គឺដោយមិនចាំតែ ដល់ពេលដែលប្រទេសនីមួយៗ មានកម្រិតឧស្សាហកម្ម ខ្ពស់នោះទេ ។ ដោយឡែក ចំពោះខ្មែរក្រហម គេបានផ្អែកការតស៊ូ របស់គេ ទៅលើគំនិតជាតិនិយមមួយ ដ៏ ស្រួចស្រាវ ដោយ កាត់ផ្ដាច់ ប្រទេសកម្ពុជា ចេញពី ចលនាកុម្មុយនិស្ត ឯទៀតៗ លើកលែងតែ ប្រទេសចិន ប្រទេសរូម៉ានី និង ប្រទេស យូហ្គោស្លាវី គឺ បណ្ដាប្រទេស កុម្មុយនិស្ត មួយចំនួន





ដែលមាន ទំនាស់ ជាមួយ សហភាព សូវៀតៗ ដែលគាំទ្របដិវត្តន៍ កុម្មុយនិស្តវៀតណាម ។ ការពិត ក្រោមទង់ មនោគមវិជ្ជា កុម្មុយនិស្ត ប្រទេសណា ក៏សុទ្ធតែមាន គំនិតជាតិនិយមដូចតែគ្នា ជាពិសេស ប្រទេសចិន និងប្រទេសរុស្ស៊ីនេះតែម្ដង ដែលចង់ឲ្យប្រទេសនានា យកពួកគេ ធ្វើជាគំរូផង ហើយ រណប នឹង ប្រទេសគេផង ។ នៅសម័យនោះ អ្នកដឹកនាំខ្មែរក្រហម យល់ឃើញថា ប្រទេសកម្ពុជា មានភោគទ្រព្យគ្រប់គ្រាន់ទាំងអស់ ដើម្បី កសាង ជីវភាព ប្រជាជនខ្មែរ គឺ មិនចាំបាច់ទាក់ទង នឹង ប្រទេសណា ទៀតឡើយ ។ នៅក្នុងគំនិត មោទនភាពជាតិ មួយ ដ៏ខ្លាំងក្លា អ្នកដឹកនាំខ្មែរក្រហម យល់ឃើញថា បុព្វបុរសខ្មែរបាន កសាងដល់ទៅ បុរីអង្គរ មួយ ដ៏ស្កឹមស្កៃ ហើយថែមទាំង បានកសាង ចក្រភពមួយ ដ៏ធំ នឹងគេដែរ ចុះហេតុអ្វី បានជាជំនាន់ក្រោយ មិនអាចធ្វើ បដិវត្តន៍មួយជាគំរូ បាននោះ ?

នៅឆ្នាំ ១៩៥៣ គឺ មុនកិច្ចព្រមព្រៀង ទីក្រុងហ្សឺណែវបន្តិច សាឡុត សរ ដែលក្រោយមកមានឈ្មោះថា ប៉ុល ពត បានត្រឡប់ពីស្រុកបារាំងមកវិញ ប៉ុន្តែ មិនទាន់ចូលមកប្រទេសកម្ពុជាភ្លាមទេ គឺ សាកល្បងទាក់ទង ចលនាឥស្សរៈខ្មែរ តាមរយៈខ្មែរវៀតមិញ នៅប្រទេសវៀតណាមសិន។ សាឡុត សរ បាននាំមកពី ស្រុកបារាំង នូវគំនិតអ្នកជាតិនិយមផង គំនិត កុម្មុយនិស្តផង ។ នៅពេលនោះ សាឡុត សរ ដែលមានអាយុប្រហែល ២៥ ឬ ២៨ ឆ្នាំ គ្រាន់តែជា និស្សិតម្នាក់ ប៉ុណ្ណោះ ប៉ុន្តែ ជានិស្សិត ដែលមានជំនឿថាគេអាច នឹងក្លាយទៅជា អ្នកដឹកនាំម្នាក់ដ៏សំខាន់ដែរ។ ពេលបាន ជួបនឹងអ្នកដឹកនាំ បដិវត្តន៍កុម្មុយនិស្តវៀតណាម សាឡុត សរ បែរជាត្រូវអ្នកទាំងនេះ យកទៅលុតដំ ដូចកូនក្មេង គឺ ឲ្យបោសផ្ទះ លាងបង្គន់ ចាក់សំរាម ហើយ រៀនសូត្រ នយោបាយ ដូចមនុស្សមិនចេះអក្សរ ។ សា ឡុត សរ មិនបានដឹងទាល់តែសោះថា គេនឹងក្លាយទៅជាមនុស្សបែបនេះ។ ប៉ុន្តែ ចំពោះអ្នកដឹកនាំ បដិវត្តន៍ វៀតណាម ការលុតដំនេះ ជាការចាំបាច់ ព្រោះតាមការពិត គឺ ជា វិធីលាងខួរក្បាលមួយបែប ដែលកុម្មុយនិស្ត ធ្វើជាប្រចាំ សម្រាប់ អ្នកដែលចង់ក្លាយខ្លួន ទៅជាអ្នកដឹកនាំ វណ្ណៈអធន នៅថ្ងៃមុខ ។ ពេល

ដែលសាឡុត សរ ចង់បានតួនាទីនេះ នៅក្នុងប្រទេសកម្ពុជា សភាពការណ៍ មានការប្រែប្រួល មួយដ៏ធំ ។ តាមរយៈការប្រឹងប្រែង របស់ បញ្ញវន្តខ្មែរ ដែលមាននិន្នាការអភិរក្ស និង ស្តាំនិយម ជាពិសេស ការប្រឹង ប្រែង របស់ ព្រះមហាក្សត្រខ្មែរ ព្រះបាទនរោត្តម សីហនុ ប្រទេសកម្ពុជា បានទទួលឯករាជ្យ តាមផ្លូវច្បាប់រួចស្រេចទៅហើយ។ ក្រោយកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ចលនា ឥស្សរៈខ្មែរ ត្រូវរំសាយចោល ទាំងអស់ ។ រីឯពួកវៀតមិញ ដែលបង្កប់ខ្លួន នៅក្នុងប្រទេសកម្ពុជា ក៏ត្រូវត្រឡប់ទៅស្រុកវិញ ជាកំហិតដែរ ក្រោមការត្រួតពិនិត្យ របស់ អង្គការ អន្តរជាតិ ។

## «បក្សប្រជាជន បដិវត្ត កម្ពុជា»

នៅថ្ងៃ ៨ កុម្ភៈឆ្នាំ ១៩៥១ អ្នកតស៊ូខ្មែរ ៩ នាក់ នៃ បក្សកុម្មុយនិស្ត ឥណ្ឌូចិន (PCI) បានរួមប្រជុំគ្នា ជាមួយលោក ឡែ ឌឹក ថូ ដើម្បីបង្កើតគណបក្ស កុម្មុយនិស្តខ្មែរមួយ ដែលមានស្វ័យភាពគ្រប់គ្រាន់ ប៉ុន្តែដែលរក្សា ទំនាក់ទំនង ជាមួយ បក្សកុម្មុយនិស្ត ទាំង ២ ទៀត ។ គណបក្ស កុម្មុយនិស្តខ្មែរនោះ មានឈ្មោះថា «បក្សប្រជាជនបដិវត្តកម្ពុជា»។ ចំពោះ កាលបរិច្ឆេទ ពិតប្រាកដ នៃ ការបង្កើតបក្សនេះ គឺមានការបកស្រាយ ខុសៗ គ្នា ព្រោះក្រុមខ្លះ បានកំណត់យក ថ្ងៃ ៣០ កញ្ញា ឆ្នាំ ១៩៦០ វិញ គឺថ្ងៃដែលមានអង្គប្រជុំសម្ងាត់មួយ ពីថ្ងៃ ២៨ ដល់ថ្ងៃ ៣០ កញ្ញា នៅក្នុងទូរទេះភ្លើង នៅក្នុងស្ថានីយរថភ្លើងទីក្រុងភ្នំពេញ ។ អ្នកដែលបានចូលរួមប្រជុំនៅ ពេលនោះ ដែលជាថ្ងៃមហាសន្និបាត បក្សប្រជាជន បដិវត្តកម្ពុជា លើកទី ២ មាន ទាំងអស់ ២១ នាក់នៅក្នុងនោះ មានវត្តមាន របស់ ទូ សាមុត អគ្គលេខាធិការបក្ស, នួន ជា និង សាឡុត សរ ដែលក្រោយមក មានឈ្មោះ ថា ប៉ុល ពត ។ អង្គប្រជុំនោះ បានប្រែឈ្មោះ «បក្សប្រជាជន បដិវត្ត កម្ពុជា» មកជា «បក្សពលករ កម្ពុជា» វិញ ។ គឺ ដោយយកថ្ងៃនោះ ជាសំអាង សាឡុត សរ បានបង្កើត «បក្សកុម្មុយនិស្តកម្ពុជា» ៦ ឆ្នាំក្រោយមក គឺ នៅខែកញ្ញា ឆ្នាំ ១៩៦៦ តាមរយៈអង្គប្រជុំមួយ ដែល ប៉ុល ពត បានបើកនៅការិយាល័យលេខ ១០០នៅ កំពង់ចាម ក្រោយពេលត្រឡប់ពីហាណូយ តាមផ្លូវលំ ហូ ជីមិញ





មកវិញ ហើយ មុនពេលដែលត្រូវទៅតាំងទី នៅ រតនគីរី ។ សូមកត់សំគាល់ថា នៅខែមិថុនា ឆ្នាំ ១៩៦៥ សាឡុត សរ, កែវ មាស និង អ្នកដឹកនាំខ្មែរ កុម្មុយនិស្ត មួយចំនួន បានចាកចេញ ពីការិយាល័យ លេខ ១០០ របស់គេ ដើម្បីធ្វើ ដំណើរថ្មើរជើងតាមផ្លូវលំ ហូ ជី មិញ ទៅហាណូយ បន្ទាប់មកទៅទីក្រុងប៉េកាំង និងព្យុងយ៉ាង។ នៅក្នុងការធ្វើដំណើរនេះ ដែលចាយពេលអស់ ៩ ខែ គណប្រតិភូខ្មែរ ដឹកនាំដោយ ប៉ុល ពត បានជួបសន្ទនាជាមួយ ឡែ យ៉ង, ម៉ៅ សេ ទុង, លូ ចៅ ជី និង តេង ស៊ាវពីង។ ការបង្កើត «បក្សកុម្មុយនិស្តកម្ពុជា» នេះ ជាការកំណត់ បែងចែកឲ្យដាច់ នូវ ភាពរណបនឹង បក្សកុម្មុយនិស្តវៀតណាមតែម្តង ព្រោះ ក្រុម របស់ ប៉ុល ពត យល់ថា មិនត្រូវបណ្តោយ ឲ្យវៀតណាម ចាត់ចែង បដិវត្តន៍ ខ្មែរ ឡើយ ។ ចំពោះក្រុមមួយទៀត ដែលយល់ថា ត្រូវធ្វើសហការ ជាមួយ បដិវត្តន៍ វៀតណាម ការកំណត់ថ្ងៃបង្កើតបក្ស ពោលគឺ ថ្ងៃបើកមហាសន្និបាតលើកទី ១ ក៏កំណត់ មិនបានច្បាស់ដែរ ។ យោងតាមឯកសារខ្លះ ថ្ងៃ ៨ កុម្ភៈ ឆ្នាំ ១៩៥១ ជាថ្ងៃបើក មហាសន្និបាត ទី ២ នៃ «បក្សកុម្មុយនិស្តឥណ្ឌូចិន» ប៉ុន្តែ គឺ នៅថ្ងៃនោះដែរ ដែលបក្សកុម្មុយនិស្តឥណ្ឌូចិន បានត្រូវរំសាយ ដោយសម្រេចផ្តល់ស្វ័យភាព ទៅឲ្យបក្សទាំងបី ។ រីឯ ថ្ងៃ ដែលបើកមហាសន្និបាត ទី ១ នៃ បក្សប្រជាជនបដិវត្ត កម្ពុជា មានកាលបរិច្ឆេទពីរ ។ ខ្លះ កំណត់ថា ថ្ងៃ ២៨ មិថុនា ខ្លះថា ថ្ងៃ ៣០ កញ្ញា ។ រីឯ ប៉ុល ពត កំណត់យកថ្ងៃ ៣០ កញ្ញា ឆ្នាំ ១៩៦០ ប៉ុន្តែ បែរជាកំណត់ថា ជាថ្ងៃកំណើត «បក្សកុម្មុយនិស្ត» ទៅវិញ ។ តាមការពិត ថ្ងៃ ៣០ កញ្ញា ឆ្នាំ ១៩៦០ ជាថ្ងៃ មហាសន្និបាត នៃ «បក្ស ប្រជាជនបដិវត្តកម្ពុជា» លើកទី ២ គឺ ថ្ងៃដែលសាឡុត សរ ហៅ ប៉ុល ពត ចូលជា សមាជិកមជ្ឈិមបក្ស ប៉ុណ្ណោះ ។ រីឯ «បក្សកុម្មុយនិស្ត» ដែល ប៉ុល ពត បានលើកឡើងតាម វិទ្យុកម្ពុជាប្រជាធិបតេយ្យនៅថ្ងៃ ២៧ កញ្ញា ឆ្នាំ ១៩៧៧ នៅ ឱកាសការប្រារព្ធបុណ្យ ខួបកំណើតបក្សកុម្មុយនិស្ត តាមការពិត ទើបនឹង ត្រូវបង្កើត នៅខែ កញ្ញា ឆ្នាំ ១៩៦៦ ប៉ុណ្ណោះទេ ។

## បក្សប្រជាជន បដិវត្ត កម្ពុជា បែក ជា ៣ ក្រុម

ក្រោយកិច្ចព្រមព្រៀង ទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ បក្សប្រជាជន បដិវត្ត កម្ពុជា បែកខ្ញែកជាបីក្រុម ។ ក្រុមមួយដឹកនាំដោយ សឺង ង៉ុក មិញ, កែវ មុន្នី, ម៉ី ផូ, រត្ត សាមឿន ហើយ ដែលមាន យុទ្ធជនប្រមាណ ២ ពាន់ ៥០០ នាក់ បានវិលត្រឡប់ ទៅ វៀតណាមវិញ ក្រោមការត្រួតពិនិត្យ របស់គណកម្មាធិការត្រួតពិនិត្យអន្តរជាតិ។ លោក ប៉ែន សុវណ្ណ ដែលកាលនោះ មានអាយុប្រហែល ១៨ [១៧] ឆ្នាំ ក៏ស្ថិតនៅក្នុងក្រុម នោះដែរ។ ក្រុមមួយទៀតដឹកនាំដោយ នង សួន, កែវ មាស, ប៉ែន យុទ្ធ បានបង្កើតគណបក្សនយោបាយ ស្របច្បាប់មួយ នៅក្នុងប្រទេសកម្ពុជា។ យោងទៅ តាមឯកសារមួយចំនួន / នៅពេលនោះ កែវ មាស ជាលេខាទទួលបន្ទុក ទីក្រុងភ្នំពេញ។ គោលដៅ នៃក្រុមទី ២ នេះ គឺ ចូលប្រកួតក្នុង ការបោះឆ្នោតសភា ឆ្នាំ ១៩៥៥។ ក្រុមទី ៣ គឺ ជាក្រុមដែលដឹកនាំ ដោយ ទូ សាមុត, សៀវ ហេង, នួន ជា, សោ ភឹម និង ណៃ សារ៉ន។ ក្រុមចុងក្រោយនេះ មាន ការប៉ិនប្រសប់ ខ្ពស់ ក្នុងការធ្វើសកម្មភាពលួចលាក់ ។ ពួកគេ បានចាត់តាំង គណកម្មាធិការ បណ្តោះអាសន្ន មួយនៅទីក្រុងភ្នំពេញដឹកនាំដោយ ទូ សាមុត ព្រមទាំង គណកម្មាធិការ ជនបទ ចំនួន ១៧ ដើម្បីធ្វើ សកម្មភាព នយោបាយ នៅតាមខេត្ត។ គណកម្មាធិការតំបន់នេះ ស្ថិតនៅក្រោមការទទួលខុសត្រូវ របស់ សៀវ ហេង។ ប៉ុន្តែ ឯកសារខ្លះអះអាងថា គឺ ទូ សាមុតទេ ដែល ទទួលខុសត្រូវខាង ជនបទ។

---

[១៧] ប៉ែន សុវណ្ណ កើតនៅ ថ្ងៃ ១៥ មេសា ឆ្នាំ ១៩៣៦ នៅ ច័ន្ទ ទាប ស្រុកត្រាំកក់ ខេត្តតាកែវ ។ ចូលជាសមាជិក ចលនាឥស្សរៈនៅឆ្នាំ ១៩៥១ (បក្សកុម្មុយនិស្ត ឥណ្ឌូចិន បន្ទាប់មក បក្សប្រជាជនបដិវត្ត កម្ពុជា)។ លោក ប៉ែន សុវណ្ណ មានតួនាទី ជលេខាបក្ស ប្រជាជន បដិវត្ត កម្ពុជា នៅឆ្នាំ ១៩៧៩ និង ជានាយករដ្ឋមន្ត្រី បេប កម្ពុជាប្រជាមានិតុនៅឆ្នាំ ១៩៨១ ។ នៅខែធ្នូ ឆ្នាំដដែល លោក បានត្រូវគេដកហូតចេញ ពីអំណាច ហើយយកទៅ ឃុំឃាំង នៅ ប្រទេសវៀតណាម ។



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

តាមការពិត ទូ សាមុត ជាមេកើយ ផ្ទាល់ របស់ សាឡុត ស ហើយ អ្នកទាំងពីរនេះ ក្តាប់ទីក្រុងភ្នំពេញ ជាមួយគ្នា។ ដូច្នេះឃើញថា ក្រោយកិច្ចព្រមព្រៀង ទីក្រុងហ្សឺណែវ បក្សប្រជាជន បដិវត្តកម្ពុជា នៅតែមានវត្តមាន នៅក្នុងប្រទេសបន្តមកទៀត។ ដោយនៅពេលនោះ ប្រទេសកម្ពុជា បានទទួលឯករាជ្យ បរិបូណ៌ទៅហើយនោះ សកម្មភាព របស់ពួកគេ គឺ គ្មានអ្វីទៀត ក្រៅពី ប្រែក្លាយ ប្រទេសកម្ពុជា ឲ្យទៅជាប្រទេសកុម្មុយនិស្ត ដូចប្រទេស នានា ឯទៀត នៅឥណ្ឌូចិនឡើយ។ នេះជា ចលនា មួយដ៏ធំ របស់ ចលនាកុម្មុយនិស្ត អន្តរជាតិ ដែលតាមរយៈ ហូ ជីមិញ បានបង្កើតបក្សកុម្មុយនិស្តឥណ្ឌូចិន តាំងពី ឆ្នាំ ១៩៣០ មក។ ហូ ជី មិញ ដែលនៅពេលនោះ មានឈ្មោះមួយទៀត នៅពេលទាមទារឯករាជ្យ ថា ង្វៀង អាយ គក់ បានត្រូវ បដិវត្តន៍ អន្តរជាតិ ចាត់តាំងឲ្យដឹកនាំ បដិវត្តន៍ នៅឥណ្ឌូចិន ។ នៅក្នុងគោលដៅនេះ ហូ ជីមិញ មានភារកិច្ច វាយរំលំរបបមូលធននិយម នៅ ប្រទេសវៀតណាមខាងត្បូង និង នៅកម្ពុជា ឲ្យទាល់តែបានពោល គឺ ប្រទេស ដែលមាន សហរដ្ឋ អាមេរិក ជាបង្អែក ឬ ដែល សហរដ្ឋ អាមេរិក អាចដាក់ មូលដ្ឋានកងទ័ព ដែល ជាឧបសគ្គ នៃ ការវាតទី របស់ពួកគេ ។ គេ អាចនិយាយបានថា ទោះជាមានទំនាស់ផ្ទៃក្នុង យ៉ាងណាក្តី បដិវត្តន៍ទាំងបី នៅឥណ្ឌូចិន ត្រូវតែសម្រេចនូវគោលដៅនេះ របស់ បដិវត្តន៍ កុម្មុយនិស្ត សកលលោក ។ គឺ ជាសង្គ្រាមមួយដ៏ស្រួចស្រាវ រវាង លោកសេរី និង លោកកុម្មុយនិស្ត នៅទីលានប្រយុទ្ធឥណ្ឌូចិន។ នៅក្នុងន័យនេះ ក្រុម របស់ នង សួន ក៏ដូចជាក្រុមរបស់ ទូ សាមុត, សៀវ ហេង មានបង្អែកមួយ ដ៏ រឹងមាំ អាចស៊ីសងបាន ជាមួយ សម្តេច នរោត្តម សីហនុ។

នៅ ខែ សីហា ឆ្នាំ ១៩៥៣ គឺ ជិតមួយឆ្នាំ មុនកិច្ចព្រមព្រៀង ទីក្រុងហ្សឺណែវ សាឡុត ស តាមរយៈអ្នកដឹកនាំ បដិវត្តន៍ វៀតណាម ម្នាក់ឈ្មោះ ផាំ វ៉ាន់បា បានចូលមកក្នុង ប្រទេសកម្ពុជា ។ សាឡុត ស បានធ្វើដំណើរ ជាមួយខ្មែរ ម្នាក់ឈ្មោះ យន់ សឿនឆ្ពោះ ទៅទីបញ្ជាការរណសិរ្សឥស្សរៈ នៃប្រទេសទាំងបី ដែលតាំងទី នៅក្នុងខេត្តកំពង់ចាម ដើម្បី ហាត់ហ្វឹកហ្វឺន ធ្វើសង្គ្រាមព្រៃ។ សាឡុត ស ស្ថិតនៅទីនោះ អស់

រយៈពេល ១ ឆ្នាំ ។ នៅថ្ងៃ ៣ ឧសភា ឆ្នាំ ១៩៥៤ សឺង ង៉ុក មិញ ដោយមានការគាំទ្រ ពីវៀតមិញ បានទាមទារ ចូលរួមក្នុងសន្និសិទទីក្រុងហ្សឺណែវ ដោយសំអាងថា ឥស្សរៈ ខ្មែរដែលមានទ័ពប្រមាណ ៣ ពាន់ ៥ រយនាក់ បានគ្រប់គ្រង ១ ភាគ ៣ នៃ ទឹកដី កម្ពុជា រួចស្រេចទៅហើយ។ ប៉ុន្តែ ខាងប្រទេសចិន ឯនោះវិញ ដែលខ្លាចអាមេរិក ដាក់មូលដ្ឋានទ័ព នៅកម្ពុជា គេពុំគាំទ្រ សេចក្តីស្នើនេះទេ គឺ សុខចិត្តរក្សាទុកព្រះមហាក្សត្រខ្មែរ ជាអ្នកតំណាង តែមួយគត់ នៃ ប្រទេសកម្ពុជា នៅ ក្នុងអង្គសន្និសិទ ទីក្រុងហ្សឺណែវ។ ក្រោយកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ដែលតម្រូវ ឲ្យចលនា ឥស្សរៈ ទាំងអស់ នៅកម្ពុជា ចូលទៅរួបរួម ជាមួយ រដ្ឋាភិបាល របស់ ព្រះមហាក្សត្រ នរោត្តម សីហនុ ក្រុម របស់ ទូ សាមុត នៅតែបន្ត សកម្មភាពលួចលាក់ របស់គេ នៅក្នុងប្រទេសកម្ពុជា បន្តមកទៀត ។ តាំងពីពេលនោះមក ពួកគេធ្វើការ តស៊ូ ដើម្បី វាយរំលំ ព្រះមហាក្សត្រខ្មែរតែម្តង ព្រោះគេចាត់ទុកថា ព្រះមហាក្សត្រខ្មែរ ជាបង្អែក របស់ពួកប្រឆាំង នឹងកុម្មុយនិស្ត ។ ប៉ុល ពត ធ្វើសហការ យ៉ាងជិតស្និទ្ធ ជាមួយ នួន ជា ដែលមានឈ្មោះដើម ថា ឡុង ប៊ុន គន ។ នៅពេលនោះ សៀវ ហេង បានទៅពួននៅ ទីក្រុងហាណូយ ប៉ុន្តែ សាឡុត សរ និង ឡុង ប៊ុន គន គឺ នួន ជា ធ្វើសកម្មភាព របស់ គេ នៅក្នុងប្រទេស បន្តមកទៀត ។ សកម្មភាព ចលនា កុម្មុយនិស្តខ្មែរ នៅពេលនោះ មានមុខពីរ គឺគណបក្សប្រជាជន ដែលធ្វើសកម្មភាពស្របច្បាប់ ចាប់តាំងពីការបោះឆ្នោតសភា ឆ្នាំ ១៩៥៥ និង ក្រុមបក្សប្រជាជន បដិវត្ត កម្ពុជា ដែលធ្វើសកម្មភាពដោយសម្ងាត់ ។

## ចលនា ម៉ាក្សនិយម ឆ្នាំ ១៩៥០ នៅ ប្រទេស បារាំង

ចលនាខ្មែរកុម្មុយនិស្ត ដែលបានកកើតឡើង នៅក្នុង ប្រទេសកម្ពុជា ក្រោយកិច្ចព្រមព្រៀង ទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ មានទំនាក់ទំនង ជិតស្និទ្ធ រវាង បញ្ញវន្តខ្មែរមួយក្រុមមានជាអាទិ៍ សាឡុត សរ, នួន ជា និង អ្នកតស៊ូប្រឆាំង នឹងបារាំង





មួយចំនួនដូចជា ទូ សាមុត, សៀវ ហេង ជាដើម ដែលមាន ខ្សែរយៈ ជាមួយអង្គការវៀតមិញ។ ប៉ុន្តែ សាឡុត សរដែលជាអតីតសមាជិកម្នាក់ នៃសមាគមនិស្សិតខ្មែរនៅស្រុកបារាំងនាឆ្នាំ ១៩៥០ នឹងដើរតួនាទីមួយដ៏សំខាន់នៅចន្លោះឆ្នាំ ១៩៦២-១៩៧៩ ។ នៅពេលដែល សាឡុត សរ ស្នាក់អាស្រ័យនៅប្រទេសបារាំង នៅ ចន្លោះឆ្នាំ ១៩៤៩ -១៩៥៣ តួអង្គប្រវត្តិសាស្ត្រ ដ៏ពោរពេញ ទៅដោយ អាថ៌កំបាំងនេះ មានទំនាក់ទំនង ជាមួយបញ្ញវន្តខ្មែរមួយក្រុម ដែលមាន និន្នាការបម្រើននិយម និង កុម្មុយនិស្តតែម្តង ក៏អាចថាបាន។ នៅឆ្នាំ ១៩៤៩ សាឡុត សរ ធ្វើដំណើរទៅប្រទេសបារាំង តាមកប៉ាល់មួយឈ្មោះ «ហ្សាម៉ាអ៊ីក» («La Jamaïque») ជាមួយនិស្សិតខ្មែរចំនួន ២១ នាក់។ នេះបើយោងទៅតាម សៀវភៅមួយ របស់ លោក ដេវីដ ចេនឌ្លែរ មានចំណងជើងថា « ប៉ុល ពត បង ទី ១ » [១៨] ។ ឯកសារនេះ បានបញ្ជាក់ថា : នៅពេលធ្វើដំណើរជិតមួយខែ សាឡុត សរ បានពង្រឹង មិត្តភាពជាមួយខ្មែរ ៤ រូប គឺ ចៅ សេង [១៩] ម៉ី ម៉ាន់, ម៉ី ផាត និង អ៊ុច វ៉ែន ។ ពេលនៅស្រុកបារាំង ក្រៅពីគ្រូឧបជ្ឈាយ៍ធំៗ ដូចជា លោក កេង វ៉ាន់សាក់ (ទស្សនវិទូ) និង លោក ជួន មុម្ម (បណ្ឌិតគណិតវិទ្យា សាលា ពហុបច្ចេកទេស) សាឡុត សរ បានជួប នារីបញ្ញវន្តខ្មែរម្នាក់ឈ្មោះ ខៀវ ប៉ុណ្ណារី [២០] នៅឆ្នាំ

[១៨] David P. Chandler : *Pol Pot, Frère Numéro Un* , Paris, Plon,1993.

[១៩] ពេលត្រឡប់មក ពីស្រុក បារាំងវិញ ចៅ សេង បានក្លាយ ជា រដ្ឋមន្ត្រី ដ៏ មានឥទ្ធិពល ម្នាក់ របស់ សម្តេច នរោត្តម សីហនុ រវាង ឆ្នាំ ១៩៦២ -១៩៦៩ ។

[២០] សាឡុត សរ (ប៉ុល ពត) រៀបអាពាហ៍ពិពាហ៍ ជាមួយ ខៀវ ប៉ុណ្ណារី នៅស្រុកខ្មែរ នៅ ខែកក្កដា ឆ្នាំ ១៩៥៦។

១៩៥១ ។ ខៀវ ប៉ុណ្ណារី បានមកប្រទេសបារាំង ជាមួយប្អូនស្រីម្នាក់ ឈ្មោះ ខៀវ ធីរិទ្ធ ដែលនៅឆ្នាំ ១៩៥១ នោះ បានរៀបការជាមួយ អៀង សារី។ យោងទៅតាម ការស្រាវជ្រាវ របស់ ប្រវត្តិវិទូ ដេវីដ ចេនដ្លែរ ដដែល គឺ នៅស្រុកបារាំងនាឆ្នាំ ១៩៥១ នោះហើយ ដែល អៀង សារី និង រត្ន សាមឿន បានបង្កើតក្រុមនយោបាយមួយ ប៉ុន្តែ ខៀវ ប៉ុណ្ណារី បានត្រឡប់មកស្រុកខ្មែរវិញ នៅឆ្នាំ ១៩៥១ ដដែលនោះ ហើយ ប្រកបមុខរបរជាសាស្ត្រាចារ្យអក្សរសិល្ប៍ខ្មែរ នៅអនុវិទ្យាល័យតាកែវ។ ក្រុមនយោបាយនេះ តែងតែបើកអង្គប្រជុំជារឿយៗ ប៉ុន្តែមិនស្ថិតនៅក្នុងក្របខ័ណ្ឌ នៃ បក្សកុម្មុយនិស្តបារាំង (P.C.F.) ទេ ។ អ្នកដែលបានចូលរួមប្រជុំ បើយោងទៅតាមលោក ដេវិដ ចេនដ្លែរ ដដែល មានជាអាទិ៍ ៖ សៀន អាន, យុន សឿន, ម៉ី ម៉ាន់, ជី គឹម អាន ។ លោក ដេវិដ ចេនដ្លែរ បានបញ្ជាក់ទៀតថា លោក កេង វ៉ាន់ សាក់ និង លោក ជួន មុម្ម ក៏បានចូលរួមប្រជុំដែរ ប៉ុន្តែគឺ ដើម្បីរក្សាទំនាក់ទំនង ជាមួយ យុវជនកុម្មុយនិស្តខ្មែរ តែប៉ុណ្ណោះ។ តាមការពិតទៅ លោក កេង វ៉ាន់សាក់ និង លោក ជួន មុម្ម គ្រាន់តែ ជាអ្នកជាតិនិយមដែលមាន និន្នាការប្រជាធិបតេយ្យ ចំរើននិយម ឬ ឆ្វេងនិយម ប៉ុណ្ណោះ។ លោក កេង វ៉ាន់សាក់ ជាអ្នកប្រឆាំង នឹងរបបរាជានិយម យ៉ាងស្រួចស្រាវ ជាពិសេសប្រឆាំង នឹងសម្តេច នរោត្តម សីហនុ។

នៅក្នុងសម័យតស៊ូ ឆ្នាំ ១៩៥៣-១៩៦០ គឺពេលដែល សាឡុត សរ ត្រឡប់មកពីប្រទេសបារាំងវិញ ចលនា កុម្មុយនិស្តខ្មែរ បានកំណត់យក យុទ្ធសាស្ត្រមួយយ៉ាងសាមញ្ញ ប៉ុន្តែ ក៏ប្រកបទៅដោយគ្រោះថ្នាក់ដែរ គឺអូសទាញបញ្ញវន្ត និងវរជនសំខាន់ៗ ឲ្យចូលទៅក្នុង ចលនា របស់ ពួកគេ ។ អ្នកដែលបានស្គាល់ សាឡុត សរ ពុំដែលនឹកស្មានឃើញ ទាល់តែសោះថា បុរសនេះ នឹងក្លាយ ទៅជាមនុស្សម្នាក់ទៀត ដែលមានគំនិតបដិវត្ត ដាច់ខាតបែបនេះ ព្រោះសាឡុត សរ ដែលក្រោយមក មានឈ្មោះថា ប៉ុល ពត ជាមនុស្សម្នាក់ មានចរិយាមារយាទស្លូតបូត ហើយ ឆោតល្ងង់ទៀតផង។ អ្នកដែលធ្លាប់បានធ្វើជាសិស្ស របស់ សាឡុត សរ នៅ សាលា «ចំរើនវិជ្ជា» តែងនិយាយថា





ប៉ុល ពត ចេះប្រើពាក្យទន់ភ្លន់ ហើយមិនដែលតាំងខ្លួនថាជា អ្នកចេះដឹងអ្វីឡើយ។ ខ្លះទៀតនិយាយថា សាឡុត សរ មាន ចរិត សុភាពរាបសា ដូចសំពត់នៅក្នុងផ្នត់ មិនគួរអ្វីក្លាយទៅជា មនុស្សឃោរឃៅដូច្នេះសោះ នៅពេលឡើងមកកាន់អំណាច។ ម្យ៉ាងទៀត វាមិនគួរឲ្យជឿសោះថា សាឡុត សរ ដែលជាមនុស្ស ពុំសូវពូកែ ពុំសូវឆ្លាតក្នុងជីវិត អាចក្លាយខ្លួនទៅជា មេដឹកនាំ បដិវត្តន៍ម្នាក់ ដ៏ មានកលល្បិចខ្ពស់ និង ដ៏សាហាវអស្ចារ្យបែបនេះ។ សំនួរនេះ នៅមានរហូតមកទល់សព្វថ្ងៃនេះ។ អ្វីដែលគេ អាចសាកល្បងយល់បាន គឺប្រហែលជា មកពី ប៉ុល ពត ស្អប់ខ្ពើម ពពួក «មនុស្សឆ្លាត» នេះតែម្តង ។ បើពុំនោះសោតទេ គឺ ស្ថានការណ៍តែម្តង ដែលតម្រូវឲ្យ ប៉ុល ពត ប្រកាន់អាកប្បកិរិយាបែបនេះ ព្រោះមនុស្ស ដែលគ្មានភាពរឹងប៉ឹង គ្រាន់តែជា ឧបករណ៍ របស់ស្ថានការណ៍នីមួយៗតែប៉ុណ្ណោះ។ យ៉ាងណាមិញ នៅក្នុងករណី នៃបដិវត្តន៍កុម្មុយនិស្តខ្មែរនេះ ក្រឡា របស់វា មានលក្ខណៈស្មុគស្មាញ ពន់ពេកក្រៃ ជាពិសេស ការប្រទាញប្រទង់គ្នា ការក្បត់គ្នាយ៉ាងសម្បើម នៅក្នុងចលនា កុម្មុយនិស្ត ទាំងមូល ។ នៅចន្លោះឆ្នាំ ១៩៥៣-១៩៦០ នោះ ចលនា កុម្មុយនិស្តខ្មែរ ក៏ដូចជា ចលនា កុម្មុយនិស្តនានាឯទៀតដែរ បានកំណត់យកយុទ្ធសាស្ត្រ ប្រមូលសម្ព័ន្ធមិត្តឲ្យបានច្រើនបំផុត ដើម្បីឯកោអ្នកដែលមានឥទ្ធិពលខ្លាំងៗ ហើយដែលអាចប្រឆាំង នឹង ចលនា របស់ ពួកគេ ។ នៅពេលនោះ ចលនា កុម្មុយនិស្តខ្មែរ ចាត់ទុក សហរដ្ឋ អាមេរិក ថាជាសត្រូវទី ១ ហើយដោយសម្តេច នរោត្តម សីហនុ មិនត្រូវ នឹង សហរដ្ឋ អាមេរិក ពួកគេ ក៏ចាត់ទុកព្រះអង្គថា ជាមិត្ត ឬជាសម្ព័ន្ធមិត្ត របស់ ពួកគេដែរ នៅពេលក្រោយមកទៀត។ ជនកុម្មុយនិស្តខ្មែរខ្លះ ដូចជា ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម, ចៅ សេង ជាដើម បានសំដែងការគាំទ្រ របស់គេ ដោយចំហ ចំពោះ នយោបាយ របស់ សម្តេច នរោត្តម សីហនុ។ បញ្ញវន្តឆ្វេងនិយម មួយចំនួន ថែមទាំង បានទទួលមុខតំណែងសំខាន់ៗ នៅក្នុងរដ្ឋាភិបាល សម្តេច សីហនុ ទៀតផង ។

*ខ្ញុំ នឹងលើកឡើង អំពី ការវិវត្តន៍ នៃ ចលនាខ្មែរក្រហមនេះ បន្តទៅទៀត នៅពេលការអនុវត្តន៍ កិច្ចព្រមព្រៀង ទីក្រុងប៉ារីស៍ ឆ្នាំ១៩៩១។*

# ចលនា កុម្មុយនិស្ត ខ្មែរ ពី ឆ្នាំ ១៩៥៧ ដល់ ឆ្នាំ ១៩៦៩

## Le Mouvement communiste khmer entre 1957 et 1969

នៅចន្លោះឆ្នាំ ១៩៥៤-១៩៦០ អ្នកដឹកនាំ ចលនា កុម្មុយនិស្តខ្មែរ ខិតខំប្រមែប្រមូល សមាជិក របស់គេ នៅតាម ស្រែ ចម្ការ និងក្នុងទីក្រុង ប៉ុន្តែ កិច្ចការនេះ ពុំបានហុចឲ្យនូវលទ្ធផលល្អ ប៉ុន្មានទេ ព្រោះមួយចំណែក ប្រទេសកម្ពុជា បានទទួលឯករាជ្យបរិបូណ៌ របស់ ខ្លួនទៅហើយ ។ មួយចំណែកទៀត ព្រះមហាក្សត្រខ្មែរព្រះបាទ នរោត្តម សីហនុ ដែលបានដាក់រាជ្យសម្បត្តិនៅឆ្នាំ ១៩៥៥ ដើម្បីធ្វើការតស៊ូ នយោបាយផ្ទាល់ព្រះអង្គតែម្តង ក៏មានកិត្យានុភាព ដ៏ត្រដែតផងទៀត។ គឺនៅពេលនោះហើយដែល មេកុម្មុយនិស្តខ្មែរ សៀវ ហេង មានការអស់សង្ឃឹមយ៉ាងខ្លាំង ហើយចង់ឈប់ ធ្វើការតស៊ូបន្តទៅទៀត។ ម៉្យាងទៀត សៀវ ហេង ដែលជា អ្នកស្រឡាញ់ជីវិត ចង់រស់នៅ ដោយសប្បាយ ដូចគេឯង យល់ឃើញថា ប្រទេសកម្ពុជា នឹងមាន អនាគតល្អ ជាមួយសម្តេច នរោត្តម សីហនុ  ដូច្នេះ គេមិនចាំបាច់ធ្វើការតស៊ូ អ្វីទៀតទេ ។ ប៉ុន្តែ បញ្ញវន្តខ្មែរ ឆ្វេងនិយមមួយក្រុម ពុំយល់ដូច្នេះឡើយ ។ គេយល់ថា ប្រជាកសិករ រស់នៅដោយ លំបាកលំបិន ក្រោមការគាបសង្កត់ របស់ ពួកឈ្មួញបរទេស ដែលបម្រើតែ ប្រយោជន៍របស់ពួកមូលធននិយម។ គឺនៅក្នុងន័យនេះហើយ ដែលគេសុខចិត្ត បណ្តោយខ្លួន ដើរតាមចលនា កុម្មុយនិស្ត តែម្តង ។ ពួកសកម្មជន នៃ ចលនានេះ ដែលគេឲ្យឈ្មោះ ថា





«អ្នកជឿនលឿននិយម» ខិតខំដើរទាក់ទាញ យុវជន បញ្ញវន្ត មាន សិស្ស និស្សិតសាស្ត្រាចារ្យ ជាដើម ឲ្យជ្រើសរើសយក មាគ៌ាកុម្មុយនិស្ត ហើយ ធ្វើការតស៊ូ ប្រឆាំងនឹង សម្តេច នរោត្តម សីហនុ ផង ហើយ វាយអែបព្រះអង្គផង នៅចំពោះមុខសត្រូវរួម គឺ បស្ចិមប្រទេស ជាពិសេសសហរដ្ឋ អាមេរិក ។ គោលដៅយុទ្ធសាស្ត្រចម្បង នៅពេលនោះ គឺ បំបេះព្រះអង្គចេញពី អ្នកស្តាំអភិរក្សនិយមដែល កាលនោះ ជាបង្អែកដ៏សំខាន់ របស់ ព្រះអង្គ។ ហេតុដូច្នេះហើយ បានជា នៅពេលនោះ សម្តេច នរោត្តម សីហនុ ម្តងរេ ទៅខាងឆ្វេង ម្តងរេ ទៅខាងស្តាំ។ រីឯ លទ្ធផល គឺ អ្នកតស៊ូ ទាំងឆ្វេងទាំងស្តាំ ជាច្រើនរូប បានត្រូវ នគរបាល ចាប់យកទៅ ដាក់គុក ឬ សម្លាប់ចោលដោយសម្ងាត់ ។ ប៉ុន្តែ នៅទីបំផុត ដោយអ្នកស្តាំនិយម ជាពិសេសប្រទេសវៀតណាម ខាងត្បូង និង សហរដ្ឋ អាមេរិក បានរៀបចំធ្វើរដ្ឋប្រហារ ទម្លាក់សម្តេច នរោត្តម សីហនុ អ្នកឆ្វេងនិយម ក៏បានទទួល ការរាប់អាន ពី សម្តេច នរោត្តម សីហនុ រហូតមកទល់សព្វថ្ងៃនេះ ដោយឆ្លងកាត់ ភាពរកាំរកូស ជាមួយ របបខ្មែរក្រហមអស់ មួយរយៈពេលធំផងដែរ។ ចាប់តាំងពីឆ្នាំ ១៩៥៩ មកកាសែត ឆ្វេងនិយម ទាំងអស់ ដូចជា កាសែតចេញផ្សាយ ជា ភាសាបារាំង «*ឡូបសែរវ៉ាទ័រ*» (L’observateur) របស់ លោក ខៀវ សំផន កាសែត «*ឡាឌេប៉ែស ឌុយ កាំបូដស៍*» (La dépêche du Cambodge) ដែលលោក ចៅ សេង បានដណ្តើមយកការដឹកនាំ ពី លោក ស៊ឹម វ៉ា ព្រមទាំងកាសែតចេញផ្សាយ ជាភាសាខ្មែរ ដូចជា កាសែត *ឯកភាព* របស់ ពឹង សយ កាសែត *មិត្តភាព* កាសែត *ប្រជាជន* ដឹកនាំ ដោយ លោក ជូ ចិត្ត ជាដើម មិនត្រឹមតែគាំទ្រ ខ្សែបន្ទាត់ នយោបាយ ប្រឆាំង នឹង សហរដ្ឋ អាមេរិក របស់ សម្តេច នរោត្តម សីហនុ ប៉ុណ្ណោះទេ គឺថែមទាំងគាំទ្រ នយោបាយផ្សេងៗទៀត របស់ ព្រះអង្គផងទៀត។ សម្តេច នរោត្តម សីហនុ សព្វព្រះរាជហឫទ័យយ៉ាងខ្លាំង នឹងអ្នកនយោបាយឆ្វេងនិយមខ្មែរ ទាំងនោះ ជាហេតុ ធ្វើឲ្យព្រះអង្គ ចាត់ទុក អ្នកទាំងនោះ ថាជា អ្នកស្នេហាជាតិ យ៉ាងសម្បើមអស្ចារ្យទៀតផង ។

នៅពេលដែល ជនកុម្មុយនិស្តខ្មែរ មានទីតាំងយុទ្ធសាស្រ្ត យ៉ាងល្អ ចាប់តាំង ពីឆ្នាំ ១៩៥៩ នោះមក អ្នកប្រកាន់ស្តាំ ក៏ខិតខំធ្វើការតស៊ូ របស់គេ យ៉ាងសកម្មដែរ ប៉ុន្តែជាការឥតប្រយោជន៍ ។ មិនតែប៉ុណ្ណោះសោត  អ្នកទាំងនេះ បានត្រូវរដ្ឋអំណាច ធ្វើបាបហើយយកទៅសម្លាប់ចោលផងទៀត។ នៅឆ្នាំ ១៩៥៨ លោក សាំង សារ៉ាត ចាងហ្វាងកាសែត *ខ្មែរថ្មី* បានត្រូវគេលួចសម្លាប់ នៅ គីរីរម្យ ។ នៅថ្ងៃ ១ មករា ឆ្នាំ ១៩៥៩ បន្ទាប់ពីបានបង្កើត កាសែតមួយ ឈ្មោះ *ពស្ត្រាធិបតី* លោក សម សារី ត្រូវរត់ចោលស្រុក។ នៅឆ្នាំ ១៩៦៦ លោក ឱុក រ៉ាស៊ី ដែលបានបង្កើតកាសែត ជាភាសាបារាំងមួយ ឈ្មោះ *ភ្នំពេញ ប្រេស* (Phnom Penh Presse ) ក៏ បានត្រូវគេ បរិហារកេរ្តិ៍ដែរ។ តាមការពិតទៅ ទោះបីសម្តេច នរោត្តម សីហនុ មានលំអៀង ទៅខាងឆ្វេង ក៏ដោយ ក៏ព្រះអង្គទ្រង់យល់ យ៉ាងច្បាស់ផងដែរថា អ្នកទាំងនោះ នៅតែរក្សា គោលដៅមួយ ជាចម្បងដដែល គឺ ដណ្តើមអំណាច ពីព្រះអង្គ ដូចអ្នកប្រកាន់ស្តាំដែរ។ ហេតុដូច្នេះហើយ បានជានៅពេល ដែលឱកាសហុចឲ្យ ព្រះអង្គ មិនញញើត នឹង វាយប្រហារ អ្នកឆ្វេងនិយមគ្រាក់ៗ ដូចជា លោក ខៀវ សំផន ទេ។ ម៉្យាងទៀត ខៀវ សំផន នៅពេលនោះមាន ប្រជាប្រិយភាព គ្រាន់បើដែរ នៅក្នុងចំណោមបញ្ញវន្ត ឆ្វេងនិយម។ នៅឆ្នាំ ១៩៦០ សម្តេច នរោត្តម សីហនុ បានជំរុញឲ្យមាន បាតុកម្មមួយ ប្រឆាំង នឹង កាសែតឆ្វេងនិយមទាំងអស់ នៅក្នុងប្រទេសកម្ពុជា គឺទាមទារ ឲ្យបិទកាសែត ទាំងអស់នោះតែម្តងហើយ ចាប់ អ្នកដឹកនាំ យកទៅ ឃុំឃាំង ផងទៀត។ ខៀវសំផន អ្នកដឹកនាំកាសែត «ឡូបសែរវ៉ាទ័រ» ក៏បានត្រូវ យកទៅ ឃុំឃាំងដែរ (ថ្ងៃ ១៥ សីហា ឆ្នាំ ១៩៦០) បន្ទាប់ពី បានត្រូវមនុស្សមិនស្គាល់មុខ សម្រាត ខោអាវ នៅកណ្តាលថ្នល់ (ថ្ងៃ ១៣ កក្កដាឆ្នាំ ១៩៦០) ។





# ការប្រែក្លាយ ពី បក្សពលករ ទៅ បក្ស កុម្មុយនិស្ត កម្ពុជា

## Du «Parti des Travailleurs » ou «Parti communiste du Kampuchéa»

នៅឆ្នាំ ១៩៦០ គឺនៅ ថ្ងៃ ២៨-២៩ កញ្ញា «បក្ស ប្រជាជន បដិវត្តកម្ពុជា» បើកមហាសន្និបាតទី ២ របស់គេ នៅក្នុងទូរទេះភ្លើងមួយក្នុងស្ថានីយរថភ្លើង ទីក្រុងភ្នំពេញ។ ចំពោះ កាលបរិច្ឆេទ នៃ មហាសន្និបាត ទី ១ គឺ បានប្រព្រឹត្តិទៅ នៅថ្ងៃ ២៨ មិថុនាឆ្នាំ ១៩៥១។ គឺ ថ្ងៃ ២៨ មិថុនា ឆ្នាំ ១៩៥១ នេះហើយ ដែល«បក្សប្រជាជនកម្ពុជា» ដែលឡើងកាន់អំណាច លើកដំបូងបង្អស់ នៅឆ្នាំ ១៩៧៩ បានកំណត់យកជា ថ្ងៃកំណើតបក្សរបស់គេ [២១] ។ ចំពោះ បញ្ហានេះ ឯកសារខ្លះ បែរជា សរសេរយក ថ្ងៃ ១៩ កុម្ភៈឆ្នាំ ១៩៥១ ទៅវិញគឺ ១១ ថ្ងៃក្រោយអង្គសន្និបាតទី ២ នៃបក្សកុម្មុយនិស្តឥណ្ឌូចិន (P.C.I.) ដែលនៅពេលនោះ បានប្រែឈ្មោះមកជា «បក្សពលករវៀតណាម» វិញ។ គឺ នៅពេលនោះដែរ ដែលបក្សកុម្មុយនិស្ត នៃប្រទេសនីមួយៗ នៅឥណ្ឌូចិន មាន ស្វ័យភាព របស់គេរៀងៗខ្លួន ។ ទោះជាយ៉ាងណាក៏ដោយ ចំពោះ ប៉ុល ពត ឬ សាឡុត សរ មហា

---

[២១] នៅថ្ងៃ ២៨ មិថុនា ឆ្នាំ ២០០២ «បក្ស ប្រជាជន កម្ពុជា» បានប្រារព្ធខួបកំណើត ទី ៥០ របស់គេ ។

សន្និបាត ខែកញ្ញា ឆ្នាំ ១៩៦០ នោះ គឺជាថ្ងៃ កំណើត បក្សកុម្មុយនិស្តខ្មែរ តែម្តង [២២] ។ គេ អាចសន្និដ្ឋានបានថា នៅឆ្នាំ ១៩៦៦ នោះ ប៉ុល ពត ដែលមាន តួនាទីជាលេខាបក្ស ពលករកម្ពុជា បានចាប់ផ្តើមរៀបចំបណ្តាច់បក្ស របស់ ខ្មែរ ពីបក្ស របស់ វៀតណាម បន្ទាប់ពីមានការប្រទាញប្រទង់គ្នា មួយដ៏ធំរវាងនិន្នាការពីរ គឺមួយ បន្តធ្វើសហប្រតិបត្តិការ ជាមួយបក្ស កុម្មុយនិស្ត វៀតណាម ដែលបានប្រែឈ្មោះមកជា «បក្សពលករវៀតណាម» ហើយ និន្នាការមួយទៀត ដែលផ្តាច់ខ្លួនចេញពី «បក្សពលករវៀតណាម»។ នៅឆ្នាំ ១៩៦០ នោះ ស៊ីង ង៉ុក មិញ ស្ថិតនៅទីក្រុងហាណូយ ហើយ ទូ សាមុត បានត្រូវតែងតាំង ជាលេខាបក្ស រីឯ សាឡុត ស រ ជាអ្នកជំនួយការ របស់ ទូ សាមុត ។ នៅពេលបើក អង្គប្រជុំសម្ងាត់ នៅក្នុងទូរទេះភ្លើង នៅភ្នំពេញ នៅថ្ងៃ ២៨-២៩ ខែកញ្ញា ឆ្នាំ

[២២] តាមការពិត ប៉ុល ពត បានបង្កើត «បក្សកុម្មុយនិស្តកម្ពុជា » ( P.C.K.) នៅ ខែកញ្ញា ឆ្នាំ ១៩៦៦ គឺ នៅពេល ដែលគណប្រតិភូ ជនកម្មុយនិស្តខ្មែរ ត្រឡប់មកពី ហាណូយ ប៉េកាំង ព្យុងយ៉ាង មក ការិយាល័យលេខ ១០០ របស់គេ នៅ កំពុងចាមវិញ។ កាលនោះ «បក្សពលករកម្ពុជា» ក្រោមការដឹកនាំផ្ទាល់ របស់ ប៉ុល ពត បានសម្រេចប្តូរឈ្មោះ «បក្សពលករកម្ពុជា» មកជា «បក្សកុម្មុយនិស្តកម្ពុជា» វិញ ហើយបោះបង់ការិយាល័យ លេខ ១០០ ដើម្បី ទៅតាំងទី នៅរតនគីរី ។





១៩៦០ ដដែល [២៣] នោះ ប៉ុល ពត បានត្រូវតែងតាំង ជាសមាជិកមជ្ឈិម បក្សប្រជាជនបដិវត្តកម្ពុជា ដែលនៅពេលអង្គប្រជុំនោះ កំពុងប្រែឈ្មោះ មកជា «បក្សពលករកម្ពុជា» វិញ។ ប៉ុន្តែ ប៉ុល ពត បានកំណត់ យកថ្ងៃនោះ ធ្វើជាថ្ងៃ កំណើត បក្សកុម្មុយនិស្តកម្ពុជាតែម្តង ។ គួរកត់សំគាល់ បន្ថែមថា កាលនោះ នួន ជា ដែលគេ ហៅថា «បង ទី ២» ជាលេខាបក្សរង រីឯ កែវ មាស និង សោ ភឹម ជាសមាជិកធម្មតា។ នេះ បើយោងទៅតាមការស្រាវជ្រាវ របស់ប្រវត្តិវិទូ ដេវីឌ ចិនដ្លែរ ដែលបានបញ្ជាក់បន្ថែមថា អ្នកទាំងពីរចុងក្រោយនេះ កាលពីមុន ជាសមាជិកបក្សកុម្មុយនិស្ត ឥណ្ឌូចិន (P.C.I.) ។ ប៉ុន្តែ ដេវីដ ចិនដ្លែរ ក៏បានបញ្ជាក់ផងដែរថា សមាជិកគណមជ្ឈិមបក្ស នៅពេលនោះ មានជាអាទិ៍ ៖ ស៊ីង ង៉ុក មិញ, ទូ សាមុត, សាឡុត ស រ, នួន ជា ហើយមានតែ អៀង សារី ម្នាក់ប៉ុណ្ណោះ ដែលជា សមាជិកមជ្ឈិមបក្ស ដែលមិនដែលធ្លាប់ធ្វើជា សមាជិក «បក្សកុម្មុយនិស្តឥណ្ឌូចិន»។ ត្រង់ចំណុចនេះ ដេវីដ ចិនដ្លែរ សរសេរបន្តមកទៀតថា៖ «កាលនោះ សាឡុត ស រ, អៀង សារី និង នួន ជា / ម្នាក់ៗ ពុំមាន អាយុលើស ពី ៣០ ឆ្នាំទេ ។ ពួកគេ មានសន្ទុះផ្លូវចិត្តយ៉ាងខ្លាំង ដោយបានទទួលការខុសត្រូវ កម្រិតខ្ពស់បែបនេះ » ។

[២៣] នៅថ្ងៃ ៣០ កញ្ញា ឆ្នាំ ១៩៧៧ តាមរយៈ វិទ្យុ ភ្នំពេញ គេបានឮ ប៉ុល ពត ប្រកាសថ្ងៃ ២៧-២៨ កញ្ញា ឆ្នាំ ១៩៦០ ជាថ្ងៃ កំណើត នៃបក្សកុម្មុយនិស្តកម្ពុជា។ គឺជា ការចាក់ផ្សាយសន្ទរកថា ដែល ប៉ុល ពត បានធ្វើ នៅ ឱកាសការប្រារព្ធខួបនៃបក្ស កុម្មុយនិស្ត កម្ពុជា នៅថ្ងៃ ២៧ ញ្ញា ឆ្នាំ ១៩៧៧ នោះ ។

*យោងទៅតាមឯកសារស្រាវជ្រាវ របស់ ដេវីដ ចិនដ្លែរ ដដែល គឺសៀវ ភៅដែលមានចំណងជើង ថា «ប៉ុល ពត បង ទី ១ » ( Pol Pot Frère Numéro Un ) ការតែងតាំង សឺង ង៉ុក មិញ ជាសមាជិកមជ្ឈិមបក្សនៅឆ្នាំ ១៩៦០ នោះ គឺ គ្រាន់តែជានិមិត្តរូបប៉ុណ្ណោះ គឺមានន័យថា ទីក្រុងហាណូយពុំអាចត្រួតពិនិត្យសកម្ម ភាព នៃបក្សថ្មីនេះបាន ដូចពីពេលមុនទេ ។ ឯកសារ ដដែលនេះ បញ្ជាក់ទៀតថា ទូ សាមុត បាត់ខ្លួននៅខែកក្កដា ឆ្នាំ ១៩៦២។ សមាជិកឯទៀតៗ នៃ បក្សប្រជាជន បដិវត្តកម្ពុជា នាំគ្នាចាត់ទុកជាទូទៅថា ទូ សាមុត បានត្រូវនគរបាល របស់ សម្ដេច នរោត្តម សីហនុ សម្លាប់ចោល។ ប៉ុន្តែត្រង់នេះ ចិនដ្លែរចោទសួរបន្តមកទៀតថា បើដូច្នេះមែន ហេតុដូចម្ដេច បានជាសមាជិកមជ្ឈិមបក្សឯទៀតៗ ពុំបានត្រូវនគរបាល របស់ សម្ដេច នរោត្តម សីហនុ ចាប់ផងទៅ? ដេវីដ ចិនដ្លែរ កត់សំគាល់បន្ថែមថា «រឿងទាំងនេះគ្មាន អ្វីច្បាស់លាស់ទេ ទោះបីតាំងពីឆ្នាំ ១៩៧៩ មក ខាងវៀតណាមឯណោះ គេបានអះអាងថា ទូ សាមុត បានត្រូវគេសម្លាប់ ដោយមាន ការចូលដៃជើង ពី ប៉ុល ពត ក្ដី ។ ចំពោះការសន្និដ្ឋាននេះ ប្រវត្តិវិទូ បេន គៀរណាន់* (Ben Kiernan) *ក៏យល់ស្របថា ដូច្នេះដែរ នេះបើយោងទៅតាម លោក ដេវីដ ចិនដ្លែរ ដដែល។ ចិនដ្លែរ ធ្វើការសន្និដ្ឋានថា ប៉ុល ពត អាចធ្វើដូច្នេះបាន ទាល់តែពេលនោះ ប៉ុល ពត មាន អំណាចធំ ណាស់ ហើយបើ ប៉ុល ពត សម្លាប់ ទូ សាមុត ចោល ព្រោះតែ ទូ សាមុត មានយុទ្ធសាស្ត្រ លំអៀង ទៅខាងវៀតណាម ក៏មិនត្រូវទៀត ព្រោះថាទាល់តែឆ្នាំ ១៩៦៧ ទើប ប៉ុល ពត បាន បោះបង់ វៀតណាមចោល ទាំងស្រុង ។ ទោះជាយ៉ាងនេះ ក៏ដោយ ក៏ នៅក្នុងរយៈពេល ឆ្នាំ ១៩៦៧ ទៅឆ្នាំ ១៩៧០ សាឡុត សរ ហៅ ប៉ុល ពត នៅតែបោះបង់វៀតណាម ចោល មិនទាន់បានដែរ ព្រោះ បដិវត្តន៍ កុម្មុយនិស្ត ទាំងចិន ទាំងវៀតណាម ត្រូវរួមកម្លាំងគ្នាសិន ដើម្បីវាយជំហរ របស់អាមេរិក នៅឥណ្ឌូចិន។ ប៉ុន្តែ អ្វីដែលគេពុំអាចប្រកែក បាន គឺថា បន្ទាប់ពី ទូ សាមុត បាត់ខ្លួនទៅ ប៉ុល ពត បានត្រូវតែងតាំងជា លេខាបក្សស្ដីទី ជំនួស ទូ សាមុត តែម្ដង រីឯ នួន ជា ស្ថិតនៅ ជា លេខាបក្សរង ដដែល ។*





# *ការវាយរំលំ វប្បធម៌ ខ្មែរដោយ របប ខ្មែរក្រហម*

## L’obolition des valeurs culturelles khmères par le régime des Khmers rouges

*នៅបណ្ដាឆ្នាំ ១៩៦០-១៩៦២ ប៉ុល ពត មានឋានៈ ជាមនុស្សខ្លាំង ទី ៣ នៅ ក្នុង «បក្សពលករកម្ពុជា»* [២៤]*។ នៅពេលនោះ សាឡុត សរ បង្កប់ខ្លួននៅភ្នំពេញ ដោយធ្វើ ជាសាស្ត្រាចារ្យភាសាបារាំង នៅ វិទ្យាល័យឯកជន «ចំរើនវិជ្ជា»។ នៅពេលនោះ និង ក្រោយពេលដែល មាន តួនាទី ជា លេខាបក្សទៅហើយនោះ សាឡុត សរ បានបើក សិក្ខាសាលាជាហូរហែ ដើម្បីវាយប្រហារ អំពើអយុត្តិធម៌ អំពើពុករលួយ នៅក្នុងសង្គម ខ្មែរ។ សាឡុត សរ ថ្កោលទោស របបសង្គមរាស្ត្រនិយម របស់សម្ដេចនរោត្តម សីហនុ ដោយឥតសំចៃ។ នេះជាការងាយស្រួលបំផុត ចំពោះ សាឡុត សរ ព្រោះ នាម៉ឺនខ្មែរ អនុវត្ត ច្បាប់ទម្លាប់ ប្រទេស មិនមែន ត្រឹមតែ ដើម្បីការពារ សណ្ដាប់ធ្នាប់ សង្គម ឬ*

---

[២៤] *នៅឆ្នាំ ១៩៦០ នៅក្នុង ឱកាសមហាសន្និបាត ទី ២ នៃ បក្សប្រជាជន បដិវត្ត កម្ពុជា នាថ្ងៃ ២៨-៣០ កញ្ញា នៅក្នុងទូរទេះភ្លើងមួយ នៃស្ថានីយរថភ្លើង ទីក្រុងភ្នំពេញ សាឡុត សរ ជា អ្នកដឹកនាំ ជួរទី ៣ គឺក្រោយ ទូ សាមុត និង នួន ជា។ ប៉ុន្តែ ក្រោយពេលដែល ទូ សាមុត បាត់ខ្លួន ដោយអាថ៌កំបាំង នៅថ្ងៃ ២០ កក្កដា ឆ្នាំ ១៩៦២ សាឡុត សរ (ប៉ុល ពត) បានត្រូវតែងតាំងជា លេខាបក្ស ជំនួស ទូ សាមុត ដោយគ្មាន ការបោះឆ្នោត នៅថ្ងៃ ២០-២១ កុម្ភៈឆ្នាំ ១៩៦៣ នៅឱកាសមហាន្និបាត «បក្សពលករកម្ពុជា» ។ នៅ ពេលនោះ សមាជិកការិយាល័យ នយោបាយ មានជាអាទ៏ ៖ នួន ជា, អៀង សារី, សោ ភឹម, វន វេត ។*

ពង្រឹងជំហរ រដ្ឋអំណាច ប៉ុណ្ណោះទេ តែគឺ ដើម្បី បំពេញ ផលប្រយោជន៍ផ្ទាល់ខ្លួន និង ក្រុមគ្រួសារ បក្សពួក របស់ គេជាពិសេសផងដែរ ។ នៅសម័យនោះ ក៏ ដូចជានៅ សម័យ ក្រោយៗ មកទៀតដែរ មេគ្រួសារខ្មែរ ម្នាក់ៗ មានភារកិច្ច ចិញ្ចឹម មិនត្រឹមតែ គ្រួសារ របស់ ខ្លួនប៉ុណ្ណោះទេ គឺ ត្រូវចិញ្ចឹមបងប្អូនសាច់ញាតិ ដែលមកពីស្រុកស្រែ រក ការធ្វើនៅទីក្រុងទៀតផង បន្ទាប់ពីបានលក់ដីស្រែ សងបំណុលគេ។ បើ មេគ្រួសារណា មានឋានៈមុខមាត់ជានាម៉ឺន គេត្រូវទទួលរ៉ាប់រង ឧបត្ថម្ភ ឬចិញ្ចឹម អ្នកទាំងនោះទៀតផង។ គឺ សភាពការណ៍ សង្គមបែបនេះហើយ ដែលជា កត្តាជំរុញអ្នកទាំងនោះ ឲ្យធ្លាក់ដោយ ងាយ ទៅក្នុងអំពើពុករលួយ។ ពួកនាម៉ឺន ទាំងនេះ បានបង្កើត បណ្ដាញ បក្សពួក យ៉ាង ស្មុគស្មាញ ជាហេតុធ្វើឲ្យប៉ះពាល់ យ៉ាងធ្ងន់ធ្ងរ ដល់គុណភាព សមត្ថភាពការងារ និង គុណូបការផ្សេងៗ ដែលជាគុណធម៌ និងជា សរសៃទ្រូង នៃ សង្គមខ្មែរ ។ មួយចំណែក ត្រូវសម្របទៅ តាមច្បាប់បារាំង ដែលផ្អែកទៅលើសទ្ធិ របស់ បុគ្គល និង ការអប់រំមួយ ដ៏ តឹងតែង ហើយមួយចំណែកទៀត ត្រូវរក្សា ការរាប់អាន ញាតិមិត្តជិតឆ្ងាយឲ្យបានល្អ ពោលគឺ របៀបរបបរបស់ខ្មែរ។ សំរេចសំរួចទៅ មេគ្រួសារនីមួយៗ គ្មានជំរើសអ្វីទៀត ក្រៅពី បម្រើ ក្រុមគ្រួសារ របស់ ខ្លួន ជាមុន សិនទេ ពោល គឺ ចៀសវាង កុំឲ្យគេនិន្ទា ថ្កោលទោសថា ជាមនុស្សឥតបានការក្នុងគ្រួសារ ជា មនុស្សឥតចេះគិតបងប្អូន។ គួរឲ្យ អកុសលជាងនេះទៅទៀត គឺ ផលវិបាកមិនល្អ ដែលច្រើនតែនាំទៅរកការរំលោភ សីល ធម៌ និងច្បាប់ជាធរមាន ពីសំណាក់បងប្អូនដែលគេចពុំផុត ពីអន្ទាក់ នៃ ជីវិតក្នុងទីក្រុង។ បងប្អូនញាតិសណ្ដានទាំងនោះ កាលបើមានបង្អែកហើយ តែងតែប្រើបង្អែកនោះ ដោយ ឥតអាសូរ គឺយកឈ្មោះ មន្ត្រីទាំងនោះទៅប្រើក្នុងផ្លូវខុស ដោយឥតកោតក្រែង ។ ខុស ប្លែកពី សីលធម៌ បស្ចិមប្រទេស ដែលចាត់ទុកថា ការផ្អែកវាសនា ទៅលើគ្រួសារ ជា គុណវិបត្តិមួយដ៏ធំ សង្គមខ្មែរផ្តល់តម្លៃជាពិសេស ទៅលើអ្នកដែល ចេះរាប់អានបងប្អូន ទោះបីបងប្អូនទាំងនោះ ប្រមាថច្បាប់នគរយ៉ាងណាក៏ដោយ។ ហេតុដូច្នេះហើយ បានជា នៅសម័យនោះ ព្រមទាំងសម័យក្រោយៗ មកទៀតដែរ អ្នកដែលយល់ អំពីទំនាស់រវាង





អារ្យធម៌ទាំងពីរនេះ គឺ របៀប បារាំង និង របៀបខ្មែរ តែងតែនិយាយថា ៖ «យល់ញាតិ ឃ្លាតច្បាប់» ។

ដោយព្រោះតែ វេទនាសម្ព័ន្ធសង្គមខ្មែរ មានបដិវាទកម្មបែបនេះ វាជា ការងាយស្រួល បំផុតចំពោះ សាឡុត សរ ដើម្បីវាយប្រហារ អំពើរពុករលួយ។ អ្នកដែលបាននាំគ្នា ចូលរួម ក្នុងសិក្ខាសាលា របស់ សាឡុត សរ ច្រើនតែមកពី មជ្ឈដ្ឋាន និស្សិត និង មជ្ឈដ្ឋាន ពុទ្ធសាសនា ពោលគឺ មួយផ្នែក អ្នកដែលបានរៀនច្បាប់ និង វប្បធម៌ បារាំង ហើយមួយផ្នែកទៀត  អ្នកដែលធ្លាប់បានយល់ដឹងថាព្រះសមណគោតម បានផ្ដាច់ចំណង គ្រួសារដើម្បីកសាង និងសម្រេច សម្ពោធិញ្ញាណ ។ អ្នកទាំងនេះសុទ្ធតែជាអ្នកដែលអ្នក ស្រឡាញ់ ឧត្តមគតិខ្ពង់ខ្ពស់ និង ភាពបរិសុទ្ធស្អាតស្អំ ហើយ មិនចូលចិត្តអាកប្បកិរិយា ក្រអឺតក្រទម របស់ ពួកអ្នកអន្រ្ទើសខ្មែរឡើយ។ គេតែងតែនិយាយថា សាឡុត សរ ជា មនុស្សឆោត ប៉ុន្តែក្នុងករណី សិក្ខាសាលានេះ គេហាក់បីដូចជាឃើញថា គឺជា យុទ្ធ សាស្រ្តមួយ ដ៏ ប៉ិនប្រសប់។ ហេតុដូច្នេះហើយ បានជា សាឡុត សរ ដែលក្រោយមក មានឈ្មោះថា ប៉ុល ពត បានក្លាយទៅជា លេខាបក្ស រីឯ នួន ជា នៅ តែជា លេខារង ដដែល ហើយ សោ ភឹម វិញ ក៏ដណ្ដើមយក តួនាទី ដ៏សំខាន់នេះ មិនបានទៀត។ បើគ្មាន សាឡុត សរ ជាអ្នកដឹកនាំ ទេនោះ បក្សកុម្មុយនិស្តខ្មែរ ក៏ ប្រហែល ជាគ្មាន ការវិវត្តន៍ ដូចដែលយើងបានឃើញ នៅពេលក្រោយមកទៀតឡើយ ។ នេះ ជា ចំណុច មួយ ដ៏សំខាន់ ដែលបញ្ជាក់ថា ពួកកុម្មុយនិស្តខ្មែរ នៅពេលនោះ បានឆ្លៀតយក ឱកាស ដ៏ល្អនេះយ៉ាងប៉ិនប្រសប់។ ក្រុមមួយទៀត គឺ ក្រុមបញ្ញវន្ត ឆ្វេងនិយមខ្មែរ មកពីប្រទេស បារាំង ដូច សាឡុត សរ នេះដែរ តែជា អ្នកដែលគិតពី មនោគមវិជ្ជា ជាបឋម តួយ៉ាង លោក ហ៊ូ យន់ លោក ខៀវ សំផន ជាដើម ។ ពេលមកស្រុកខ្មែរ ពួកគេក៏ បើក សិក្ខាសាលា របស ់គេដែរ ហើយ ផ្ដោតអារម្មណ៍ ជាពិសេស ទៅលើ ការកសាង សង្គមខ្មែរ តាមបែបបទ ម៉ាក្សនិយម។ នៅពេលនោះ អ្នកដែលរៀនច្បាប់បារាំង ដូចជា និស្សិត បញ្ញវន្ត ជាដើម គេស្អប់ខ្ពើម របៀបគ្រប់គ្រង របស់ សម្ដេច នរោត្តម សីហនុ

ណាស់ ហើយតែងតែប្រាថ្នាចង់បាន អ្នកគ្រប់គ្រងប្រទេស ដែលស្អាតស្អំ មានឧត្តមគតិត្រឹមត្រូវ។ គេអាចនិយាយបានថា នៅសម័យនោះ និន្នាការសំខាន់មាន ២ នៅក្នុងសង្គមខ្មែរ គឺអ្នកប្រជាធិបតេយ្យ និងអ្នកអភិរក្សស្តាំនិយម។ អ្នកអភិរក្សនិយម ច្រើនតែប្រកាន់អាកប្បកិរិយា សក្តិភូមិ ការពារ ទំនៀមទម្លាប់ខ្មែរ ប្រកាន់វណ្ណៈក្នុងការផ្សំគូស្រករ និងមាននិស្ស័យ ទោរេ របបមូលធននិយម រីឯ អ្នកប្រជាធិបតេយ្យ ច្រើនជាអ្នកជួយយកអាសារអ្នកទន់ខ្សោយ។ វប្បធម៌ មកពីបរទេស ជាពិសេស មកពី ប្រទេសបារាំង បានទទួលជោគជ័យមួយ ដ៏ធំនៅក្នុងចំណោមអ្នកចេះដឹងភាគច្រើន ព្រោះ មានឧត្តមគតិល្អៗ ដែល ទាក់ទាញ ចិត្តពួកគេ ជាង សណ្តាប់ធ្នាប់សង្គមមួយ ដែលធ្វើបាប អ្នកក្រ អ្នកទន់ខ្សោយ។ ដោយនៅពេលនោះ ប្រទេសកម្ពុជា កំពុងបោះជំហាន ឆ្ពោះទៅរក ភាពសម័យទំនើប និង ទស្សនៈជីវិតថ្មីៗទៀត ផងនោះ ជាពិសេសការជឿនលឿនផ្លូវគំនិត ពួកអ្នកអភិរក្ស ក៏បាត់បង់ ឥទ្ធិពលនិចម្តងៗ ជាលំដាប់ ។

# ការប្រែឈ្មោះ ពី«បក្ស ប្រជាជន បដិវត្ត កម្ពុជា» មកជា «បក្ស កុម្មុយនិស្ត កម្ពុជា» នៅឆ្នាំ ១៩៦៦

## 1966 : du «Parti du peuple Révolutionnaire du Kampuchéa» au «Parti communiste du Kampuchéa»

នៅដើមឆ្នាំ ១៩៦៦ សាឡុត សរ បានដឹកនាំគណប្រតិភូមួយ ធ្វើដំណើរ តាមផ្លូវលំ ហូ ជីមិញ ទៅហាណូយ ហើយ បន្ទាប់មក ទៅ ទីក្រុងប៉េកាំង ។ នៅពេលនោះ « បដិវត្តន៍វប្បធម៌» កំពុងតែគ្របដណ្តប់ទៅលើ ប្រទេសចិនយ៉ាងពេញទំហឹង។ លោក ម៉ៅ សេ ទុង «អគ្គមគ្គុទេសក៏ ដ៏ឆ្នើម» នៃ ប្រទេសចិន កុម្មុយនិស្ត បានឲ្យគេ បោះពុម្ពផ្សាយកូន «សៀវភៅក្រហម» ចំនួន ២ លាន ក្បាលថែមទៀត ។ នៅ ខែ កញ្ញាឆ្នាំ





ដដែលនោះ សាឡុត សរ បានវិលត្រឡប់មកក្នុងព្រៃ នៃប្រទេសកម្ពុជាវិញ។ នៅពេលមកដល់ការិយាល័យ លេខ ១០០ របស់ គេ នៅក្រូចឆ្មារ ប៉ុល ពត បើក អង្គប្រជុំមួយជាបន្ទាន់ ។ គឺ ជាអង្គប្រជុំមួយ ដែលមាន លក្ខណៈប្រវត្តិសាស្ត្រ ព្រោះ គឺ នៅក្នុងអង្គប្រជុំនា ខែ កញ្ញា ឆ្នាំ ១៩៦៦ នោះហើយ ដែល ប៉ុល ពត បានសម្រេច ប្តូរឈ្មោះ ពី «បក្សប្រជាជនបដិវត្តកម្ពុជា» មកជា «បក្សកុម្មុយនិស្តកម្ពុជា» ហើយ ប្តូរ សេនាធិការដ្ឋាន របស់គេ ពីការិយាល័យ លេខ ១០០ នៅក្រូចឆ្មារ មក រតនគិរី វិញ ព្រោះអាមេរិកទម្លាក់គ្រាប់បែក កាន់តែខ្លាំងទៅៗ នៅតាម ជាយដែន ។ តាមការពិត ប៉ុល ពត បានកំណត់យុទ្ធសាស្ត្រមួយថ្មីទៀត បន្ទាប់ពីបានជួបអ្នកដឹកនាំចិន នៅប៉េកាំង។ ទោះជាយ៉ាងនេះក្តី គ្មានឯកសារណាមួយដែលបញ្ជាក់ ឲ្យបានច្បាស់ ថា ប៉ុល ពត បានសម្រេចយក «បដិវត្តន៍វប្បធម៌» ចិន មកធ្វើជា មាគ៌ានោះទេ ទោះបី នៅពេលឡើងមកកាន់អំណាចនៅឆ្នាំ ១៩៧៥ ជាពិសេស នៅពេលដែល ប៉ុល ពត ពង្រឹងអំណាច របស់ ខ្លួនបាននៅឆ្នាំ ១៩៧៧ គេសង្កេត ឃើញមាន ទិដ្ឋភាពសំខាន់ៗ នៃ «បដិវត្តន៍វប្បធម៌» នេះក្តី ។ អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រខ្លះ កត់សំគាល់ថា ប៉ុល ពត មិនដែលបានបកប្រែ និងបោះពុម្ពផ្សាយ កូន «សៀវភៅក្រហម» របស់ ម៉ៅ សេ ទុង ទាល់តែសោះ ។ រឿងនេះអាចបណ្តាល មកពីមូលហេតុអ្វីផ្សេងទៀត ក៏ប៉ុន្តែ វាជាការមួយដ៏ គួរឲ្យចាប់អារម្មណ៍ដែរ។ បន្ទាប់ពី ប្តូរកន្លែង ពីកំពុងចាម មក រតនគិរី វិញ សាឡុត សរ ចាប់ផ្តើមដកសមាជិកសំខាន់ៗ ចេញអស់ ពីជនបទ ហើយ បញ្ជូន អ្នកទាំងនោះ ទៅតាមតំបន់ជនជាតិភាគតិចវិញ។ អ្នកវិភាគប្រវត្តិសាស្ត្រខ្មែរខ្លះ កត់សំគាល់ថា នៅពេលដែល បក្សកុម្មុយនិស្តឥណ្ឌូចិនស៊ី ត្រូវរលំរលាយទៅ បន្ទាប់ពីលោក ស៊ីការណូ ត្រូវទម្លាក់ចេញពីអំណាច សាឡុត សរ ចាប់ ផ្តើមមានការប្រុងប្រយ័ត្នខ្ពស់ ដោយហេតុថា ថ្ងៃណាមួយសម្តេច នរោត្តម សីហនុ ក៏ នឹងត្រូវអ្នកប្រកាន់ស្តាំ វាយរំលំ ជាពុំខាន ហើយ ដូចនេះបក្សកុម្មុយនិស្តខ្មែរ ក៏ នឹង បាត់បង្អែកយុទ្ធសាស្ត្រមួយ ដ៏សំខាន់ដែរ ។ បានជានៅពេលនោះ សាឡុត សរ អៀង សារី និង អ្នកដឹកនាំកុម្មុយនិស្តផ្សេងៗទៀត នាំគ្នាមក

តាំងទីនៅ រតនគិរី ព្រោះ ប្រជាជននៅទីនោះ រួមបញ្ចូល ទាំងប្រជាជន មណ្ឌលគិរី និង ក្រចេះ ផងដែរ ស្អប់ខ្ពើម រដ្ឋាភិបាលខ្មែរ យ៉ាងខ្លាំង ដោយពួករាជការ បានកាប់ព្រៃឈើ ធ្វើថ្នល់ ធ្វើចម្ការកៅស៊ូ ដោយឥតកោតក្រែងអ្វីទាំងអស់ ។

នៅថ្ងៃ ២ មេសា ឆ្នាំ ១៩៦៧ មានការបះបោរ ប្រជាកសិករមួយ យ៉ាងធំ នៅ សម្លូត ក្នុងខេត្របាត់ដំបង។ ប្រជាកសិករ បាននាំគ្នាងើបឡើងបះបោរប្រឆាំង នឹង រដ្ឋាភិបាល ព្រោះរដ្ឋាភិបាល ឧត្តមសេនីយ៍ លន់ នល់ បានបញ្ជូនក្រុមអន្តរាគមន៍ពិសេសៗ ជាច្រើនទៅឲ្យទិញស្រូវ ដោយឲ្យតម្លៃថោកពេក គឺ ថោកជាងថ្ងៃដែលវៀតណាម ឲ្យ ទៅទៀត ។ ប៉ុន្តែ សម្តេច នរោត្តម សីហនុ បែរជាទម្លាក់ទោស ទៅលើ ខ្មែរកុម្មុយនិស្ត ទៅវិញ។ ព្រះអង្គបានចោទ លោក ហ៊ូ យន់ ហ៊ូ នឹម ខៀវ សំផន ថា ជា អ្នកដែលបាន បំផុសបំផុល ឲ្យមាន ការបះបោរនេះ ។ នៅ ថ្ងៃ ២២ មេសា ឆ្នាំ ១៩៦៧ អ្នកតំណាងរាស្ត្រ ហ៊ូ យន់ និង ខៀវ សំផន គ្មានជម្រើសអ្វីទៀត ក្រៅពីនាំគ្នា រត់ចូលព្រៃឡើយ។ នៅថ្ងៃ ៧ តុលាឆ្នាំដដែល អ្នកតំណាងរាស្ត្រ ហ៊ូ នឹម ក៏រត់ ទៅលាក់ខ្លួននៅ ភ្នំក្រវាញ បាត់ដែរ ។ នៅពេលនោះឯង នៅទីក្រុងភ្នំពេញ និង នៅតាមខេត្តនានា និស្សិត និង សាស្ត្រាចារ្យ ជាច្រើន បានត្រូវរដ្ឋអំណាច ចាប់ខ្លួន យ៉ាងខ្លាចផ្សា ហើយ មួយចំនួនធំ ក៏ នាំគ្នារត់ចូលព្រៃ បាត់អស់។ តាំងពីពេលនោះមក ចលនា កុម្មុយនិស្តខ្មែរ កាន់តែ រីកធាត់ធំ ពីមួយថ្ងៃ ទៅមួយថ្ងៃ។ អស់រយៈពេលជាច្រើនខែ កងទ័ព ឧត្តមសេនីយ៍ លន់ នល់ បានធ្វើការបោសសំអាត តំបន់សម្លូត ដោយឥតត្រាប្រណី ។ ការប្រយុទ្ធ រវាងកងទ័ព និង ប្រជាកសិករ មាន លក្ខណៈ ខ្លាំងក្លា សម្បើម អស្ចារ្យ ជាពិសេសនៅត្រង់ ភ្នំវាយចាប ដែលជា សំបុកមួយយ៉ាងធំ របស់ ពួកអ្នកដែលត្រូវប៉ូលិស របស់ សម្តេច នរោត្តម សីហនុ ដេញចាប់។ ចំពោះសម្តេច នរោត្តម សីហនុ ការបះបោរ ប្រជាកសិករ នៅសម្លូត ជាបរាជ័យមួយ ដ៏ធំ នៃ នយោបាយ របស់ ព្រះអង្គ ។ មុនព្រឹត្តិការណ៍នេះ ព្រះអង្គត្រូវគេចាត់ទុកថា ជាបិតា នៃ កសិករខ្មែរ ប៉ុន្តែ ចាប់តាំងពី កុបកម្ម នៅ សម្លូតនា ឆ្នាំ ១៩៦៧ នោះមក ចលនា កុម្មុយនិស្ត ក្តាប់ប្រជាកសិករ បាន មួយចំណែកធំ ។





# ការកកើតឡើង នៃ កងប្រដាប់អាវុធ ខ្មែរក្រហម នៅ ចុងឆ្នាំ ១៩៦៧

## L’Armée khmère rouge

ការបះបោរ ប្រជាកសិករ នៅសម្លូត បានឈានមកដល់ ទីបញ្ចប់ នៅ ខែកញ្ញា ឆ្នាំ១៩៦៧ ប៉ុន្តែ ការវាយកំចាត់ បណ្តាញពួកខ្មែរក្រហម ដោយ ប៉ូលិស របស់ សម្តេច សីហនុ កាន់តែមានលក្ខណៈខ្លាំងក្លាថែមទៀត។ គឺនៅពេលនោះហើយដែល សាឡុត សរ គេចខ្លួនពី ការិយាល័យលេខ ១០០ នៅក្រូចឆ្មារ ហើយធ្វើដំណើរឆ្ពោះទៅ ភូមិភាគ ខាងជើង។ សាឡុត សរ ដើរឆ្លងព្រៃព្រឹក្សាអស់រយៈពេល ១៥ ថ្ងៃ ហើយ បានមកដល់ មូលដ្ឋានមួយដែលគេឲ្យឈ្មោះថា ការិយាល័យ លេខ ១០២ ។ នៅពេលនោះ សាឡុត សរ ចាប់ផ្តើមគ្រុនចាញ់យ៉ាងខ្លាំង។ យោងទៅតាមការស្រាវជ្រាវ របស់ ប្រវត្តិវិទូ ដេវីដ ចិនដ្លែរ ក្រោយនោះបន្តិច ឈឹម សាមោក បានធ្វើ ដំណើរមកទីនោះដែរ។ ការិយាល័យ លេខ ១០២ មានសភាពស្ងាត់ជ្រងំ ហាក់បីដូចជា កន្លែងមួយ ដែលគ្មានមនុស្សរស់នៅ។ សូម្បីតែពេទ្យម្នាក់ក៏គ្មានដែរ។ ដោយការខំប្រឹងប្រែង របស់ ឈឹម សាមោក សាឡុត សរ ក៏បានជាសះស្បើយ។ បន្ទាប់មក សាឡុត សរ ក៏ ធ្វើដំណើរ ឆ្ពោះទៅមូលដ្ឋាន មួយទៀត ដែលស្ថិតនៅ រតនគិរី ដដែល គឺ មូលដ្ឋានដែល មានឈ្មោះថា ការិយាល័យ លេខ ១០៤ ដែលជាទីតាំង របស់ សុន សេន, កែវ មាស និង អៀង សារី ។ មេខ្មែរក្រហមធំៗ មួយចំនួនដែលទទួលខុសត្រូវ ផ្នែកបូព៌ា ដូចជា សុខ ខ្មុល, សោ ភឹម, ណៃ សារ៉ន ជាដើម ក៏ ស្ថិតនៅទីនោះដែរ។ នៅពេលនោះ បើយោងទៅតាម ឯកសារ របស់ ដេវីដ ចិនដ្លែរ ដដែល បក្សកុម្មុយនិស កម្ពុជា កំពុងឆ្លងកាត់ ដំណាក់ការមួយ ប្រកប ដោយគ្រោះថ្នាក់ ព្រោះទាំងនៅក្នុងតំបន់សម្លូត ទាំងនៅតាមទីក្រុង ប៉ូលិស របស់សម្តេច សីហនុ ដេញចាប់ពួកខ្មែរក្រហម យ៉ាងមមាញឹក។ រីឯ ចលនាខ្មែរក្រហម នៅឆ្នាំ ១៩៦៧

នោះ គ្មាន មធ្យោបាយ យោធា សម្រាប់ទប់ទល់ នឹង កម្លាំងទ័ព និង ប៉ូលីស របស់ សម្ដេច សីហនុ ទាល់តែសោះ ។ លុះមកដល់ចុងឆ្នាំ ១៩៦៧ ទើប ចលនា ខ្មែរក្រហម សម្រេចបង្កើត កងប្រដាប់អាវុធរបស់ខ្លួន ដើម្បីប្រយុទ្ធតស៊ូផ្លូវអាវុធ ទន្ទឹម នឹងការតស៊ូ ផ្នែក នយោបាយ ។ ទោះជាមាន ការលំបាកលំបិន យ៉ាងណាក្ដី ក៏ក្រោយមក គឺ នៅឆ្នាំ ១៩៧៧ នៅពេលដែល ប៉ុល ពត ដណ្ដើមយកអំណាចបានទាំងស្រុង ប៉ុល ពត បែរជា បកស្រាយថា នៅសម័យនោះ ប៉ូលីស របស់ សម្ដេច នរោត្តម សីហនុ ចាប់ផ្ដើមមាន ការញាញើតញាញើម រហូតដល់ថ្នាក់ចង់បោះបង់ចោល ការគាបសង្កត់ទៅលើខ្មែរក្រហម តែម្ដង។ តាមការពិត នៅពេលនោះ សម្ដេច នរោត្តម សីហនុ កាន់តែ បង្កើន ការវាយ ប្រហារ យ៉ាងខ្លាំងក្លា ថែមទៀត ។ ប៉ុន្តែអ្វីដែលគេពុំអាចប្រកែក បានទៅវិញនោះ គឺ ថា ពួកមេខ្មែរក្រហម បានគេចផុត ពី ការចាប់ខ្លួន យ៉ាងប៉ិនប្រសប់ ហើយនេះ ដោយសារ តែពួកគេ បានបង្កើត កម្លាំង យោធា សម្រាប់ការពារខ្លួន បានទាន់ពេលដែរ ។ គឺតាំងពី ពេលនោះមកហើយ ដែលបដិវត្តន៍ ខ្មែរក្រហម មានជំនឿយ៉ាងមុតមាំថា កម្លាំងកងទ័ព ជា ការធានាមួយ យ៉ាងធំ សម្រាប់ការពារ ចលនា របស់ ពួកគេ ។

ចំពោះការបង្កើត កងប្រដាប់អាវុធខ្មែរក្រហមនៅចុងឆ្នាំ ១៩៦៧នោះ ដេវីដ ចិនដ្លែរ បានសរសេរថា នៅពេលនោះ បក្សកុម្មុយនិស្តកម្ពុជា មាន តួនាទីមួយយ៉ាងសំខាន់ នៅ ក្នុងចលនា កុម្មុយនិស្តទាំងមូល គឺ ត្រូវជួយគាំទ្រ សង្គ្រាម ព្រៃ វៀតណាម ដែលកំពុង ប្រយុទ្ធតស៊ូ យ៉ាងពេញទំហឹង តទល់ នឹង ការវាយប្រហារ ដ៏ សម្បើមអស្ចារ្យ របស់ កងទ័ពអាមេរិក។ ទោះជាយ៉ាងនេះក្ដី ក៏ តាមការពិត ប៉ុល ពត ក្ដាប់កងទ័ពខ្មែរក្រហម មិនបានទាំងអស់ដែរ ពីព្រោះនៅក្នុងតំបន់ផ្សេងៗ របស់ ខ្មែរក្រហម កងពលនីមួយៗ សុទ្ធតែមានមេកើយ របស់គេផ្ទាល់។ ប៉ុល ពត គ្មានជម្រើសអ្វីទៀត ក្រៅពីការត្រូវផ្ដល់ ស្វ័យភាពទៅឲ្យតំបន់ ឬ ភូមិភាគ ទាំងនោះសិនទេ ។ ស្ថានភាពនេះ មានរហូតដល់ ឆ្នាំ ១៩៧៧ គឺ ២ ឆ្នាំ ក្រោយពេលវាយដាច់ យកទីក្រុងភ្នំពេញបាន ទើប ប៉ុល ពត យក អំណាច យោធាបាន សឹងតែទាំងស្រុង ។ នេះជាចំណុចមួយ ដ៏សំខាន់សម្រាប់យល់អំពី





ព្រឹត្តិការណ៍ថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ព្រោះថា បន្ទាប់ពី ខ្មែរក្រហមវាយយកទីក្រុង ភ្នំពេញ បានហើយ ចលនា ខ្មែរក្រហម ទាំងមូល នៅតែត្រូវបែងចែក ជាតំបន់ ជា ភូមិភាគ ស្វ័យត របៀបនេះ ដដែល ជាហេតុធ្វើ ឲ្យ ប៉ុល ពត ត្រូវព្រួយមុខ នឹង ការប្រយុទ្ធ ផ្ទៃក្នុងមួយ ដ៏ធំធេង និង យ៉ាងគ្រាំគ្រា ផងទៀត ទម្រាំ នឹងក្ដាប់បាន កងទ័ព មួយភាគធំ។ ប៉ុន្តែ ការតស៊ូ ផ្ទៃក្នុងនេះ ចេះតែ មានជាបន្តបន្ទាប់ ឥតស្រាកស្រាន្ត។ នេះ ជា កត្តាមួយ ដែលធ្វើឲ្យ ចលនា ខ្មែរក្រហម ប្រេះឆា បាក់បែកគ្នា នៅពេលក្រោយមក ទៀត។ ខ្ញុំនឹងលើកឡើងអំពីបញ្ហានេះនៅក្នុង ជំពូកក្រោយៗមកទៀត ។ មុនទៅដល់នោះ ខ្ញុំសូមបញ្ជាក់បន្ថែមថា រវាង ឆ្នាំ ១៩៦៧-១៩៦៨ នោះ កងទ័ព ខ្មែរក្រហម មានការ លំបាកយ៉ាងខ្លាំង ក្នុងការប្រមែប្រមូលសព្វាវុធ។ ការប្រយុទ្ធតទល់នឹងកងទ័ពរដ្ឋាភិបាល ចាប់ផ្ដើមមុន ដំបូងបង្អស់នៅក្នុងខែត្របាត់ដំបង នៅចុងខែមករាឆ្នាំ ១៩៦៨ គឺ នៅពេល ដែលកងកម្លាំង កុម្មុយនិស្ត វៀតណាម ចាប់ផ្ដើម ធ្វើការវាយប្រហារ ទៅលើផ្នែកខាង ត្បូងប្រទេសវៀតណាម នៅពេលបុណ្យចូលឆ្នាំចិន ។

## សហប្រតិបត្តិការ យោធា រវាង កងទ័ព វៀតណាម និង កងទ័ព ខ្មែរក្រហម នៅឆ្នាំ ១៩៦៧-១៩៦៨

## Coopération militaire entre l'armée vietnamienne et l'armée khmère rouge en 1967-1968

នៅដើមឆ្នាំ ១៩៦៨ ការប៉ះទង្គិច ផ្នែកយោធា រវាង កងប្រដាប់អាវុធខ្មែរក្រហម និង កងទ័ពកងស្វ័យត្រាណ របស់ សម្ដេច សីហនុ ចេះតែកើតមានឡើងជារឿយៗ ។

នៅចុងខែមករា គឺ មុន ការវាយប្រហារ របស់វៀតណាមកុម្មុយនិស្ត ទៅលើផ្នែកខាងត្បូងនៃប្រទេសវៀតណាម នៅពេលចូលឆ្នាំចិន ការប៉ះទង្គិចរប៉េះរប៉ោះ រវាង កងទ័ពខ្មែរក្រហម និង កងទ័ពឧត្តមសេនីយ៍ លន់ នល់ បេះតែកើតមានជាហូរហែនៅក្នុងខែត្របាត់ដំបង ។ ការប្រយុទ្ធគ្នា នៅថ្ងៃ ១៧ មករា នៅ «បាយតម្រាំ» បានត្រូវខ្មែរក្រហម កំណត់យកធ្វើជាថ្ងៃសម្រាប់ប្រារព្ធខួបកំណើត នៃ កងប្រដាប់អាវុធ របស់គេ។ នៅពេលនោះ សម្ដេច នរោត្តម សីហនុ បានលើកទឹកចិត្តឲ្យឧត្តមសេនីយ៍ លន់ នល់ ធ្វើការវាយប្រហារយ៉ាងខ្លាំង ទៅលើ ពួកខ្មែរក្រហម ជាហេតុធ្វើឲ្យ សាឡុត ស មានជំនឿខ្លាំងថែមទៀតថា សម្ដេច នរោត្តម សីហនុ បានសម្រេចធ្វើសហប្រតិ បត្តិការជាមួយអាមេរិក។ ម្យ៉ាងទៀត នៅខែមករាឆ្នាំ ១៩៦៨ នោះ លោក ចេសស្ទែរ បោវឡេស (Chester Bowles) ឯកអគ្គរដ្ឋទូត អាមេរិក ប្រចាំប្រទេសឥណ្ឌា បានមកជួបប្រមុខរដ្ឋខ្មែរ នៅទីក្រុងភ្នំពេញ ដើម្បីស្នើសុំឲ្យ សម្ដេច សីហនុ អនុញ្ញាតឲ្យកងទ័ព វៀតណាមខាងត្បូង ដេញតាមកំទេចកងទ័ពវៀតមិញ និង វៀតកុងនៅលើទឹកដីខ្មែរ។ ប្រវត្តិវិទូ ដេវីដ ចិនដ្លែរ អះអាងថា សម្ដេច នរោត្តម សីហនុ នៅពេលនោះ បានអនុវត្តយុទ្ធវិធីមួយ គឺចង់ឲ្យមានការគាំទ្រខ្លះ ពីអាមេរិក ដើម្បីវាយកំទេចចលនា ខ្មែរក្រហម។ រីឯទីក្រុង វ៉ាស៊ីងតោន ក៏មានការព្រួយបារម្ភ យ៉ាងខ្លាំងណាស់ដែរ ដោយខ្លាច ទីក្រុងហាណូយ ធ្វើការវាយប្រហារ ទៅលើផ្នែកខាងត្បូង នៅឱកាស ចូលឆ្នាំចិន ដើម្បីជំរុញឲ្យប្រជាជន វៀតណាមទាំងមូល ងើបឡើង បះបោរ ប្រឆាំង នឹង អាមេរិក ព្រោះថានៅក្នុងករណីនេះ សហរដ្ឋ អាមេរិក នឹងត្រូវបង្ខំចិត្ត ចរចាសន្តិភាពជាពុំខាន។ តាមការពិត ផែនការនេះរបស់ ទីក្រុងហាណូយ ពុំបានសម្រេចទេ ព្រោះ កងទ័ពវៀតកុង បានត្រូវ អាមេរិក និង ទីក្រុងសាយហ្គន វាយកាត់ផ្តាច់ ជាកង់ៗ រប៉ាត់ រប៉ាយអស់ ទោះបីគេបានទទួលជោគជ័យ ខាង សង្គ្រាមផ្នែកចិត្តសាស្ត្រក្តី ។ គឺនៅពេលនោះហើយ ដែលកងទ័ពកុម្មុយនិស្ត វៀតណាមដែលបង្កប់ខ្លួននៅកម្ពុជា ធ្វើការគាបសង្កត់យ៉ាងខ្លាំង ទៅ



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

លើ កងទ័ពខ្មែរក្រហម ដើម្បី ឲ្យធ្វើសហប្រតិបត្តិការរួមគ្នា ។ រីឯមុខព្រួញ គឺ បង្កើនការវាយប្រហារ ទៅលើ កងទ័ព ឧត្តមសេនីយ៍ លន់ នល់ ។

នៅខែមករា ឆ្នាំ ១៩៦៨ សាឡុត ស ធ្វើដំណើរទៅទីក្រុងហាណូយ ហើយនៅចុងឆ្នាំ ១៩៦៩ បានជួប អ្នកដឹកនាំវៀតណាមកុម្មុយនិស្ត នៅទីនោះ ម្តងទៀត។ នេះជារឿងមួយដ៏ចម្លែក ដោយហេតុថា កាលពីដើមឆ្នាំ ១៩៦៦ គឺ ៦ ឆ្នាំ ក្រោយការបែកបាក់ និងការវិវាទ រវាងទីក្រុង ប៉េកាំង និង ទីក្រុង ម៉ូស្គូ នាឆ្នាំ ១៩៥៩ សាឡុត ស បានទៅជួប អ្នកដឹកនាំចិន នៅទីក្រុងប៉េកាំង ហើយនៅពេលនោះ បានត្រូវចិន លើកទឹកចិត្ត ឲ្យបំបែកខ្លួនចេញ ពីទី ក្រុងហាណូយ ដែលជា សម្ព័ន្ធមិត្ត របស់ សហភាពសូវៀត។ ទំនាស់ រវាងចិនប្រជាមានិតុ និងសហភាព សូវៀត ចាប់តាំងពី ឆ្នាំ ១៩៥៩ នោះមក ជាទំនាស់មួយធំណាស់ គឺ មានការខ្វែងគំនិតគ្នា ទាំងផ្នែកនយោបាយក្រៅប្រទេស ទាំងផ្នែកមនោគមវិជ្ជា។ ទំនាស់ រវាង បងប្អូន កុម្មុយនិស្ត ទាំង ២ នេះ ក៏ ជាទំនាស់មួយដ៏ធំ នៅក្នុងចលនា កុម្មុយនិស្តខ្មែរផងដែរ។ គេអាចនិយាយបានថា នៅឆ្នាំ ១៩៦៨-១៩៦៩ នោះ កងទ័ពបដិវត្តខ្មែរកុម្មុយនិស្ត ក៏ត្រូវការ ជំនួយយោធា ពីកងទ័ពកុម្មុយនិស្តវៀតណាមដែរ ដើម្បីទប់ទល់ នឹង កងទ័ព របស់ ឧត្តមសេនីយ៍ លន់ នល់ គាំទ្រ ដោយសហរដ្ឋ អាមេរិក។ រី ឯ កងទ័ព កុម្មុយនិស្ត វៀតណាម នៅក្នុងប្រទេសកម្ពុជា ក៏ ត្រូវការការគាំទ្រ ពីខ្មែរក្រហមដែរនៅពេលនោះ។ ដើម្បីបានការគាំទ្រ ពីចលនា កុម្មុយនិស្តខ្មែរ ទីក្រុងហាណូយ បានសុខចិត្ត ទទួលស្គាល់ ស្វ័យភាពរបស់បដិវត្តន៍ខ្មែរ ទោះបីទីក្រុងហាណូយដឹងយ៉ាងច្បាស់ថា សាឡុត ស បានសម្រេចដើរតាមមាគ៌ាម៉ៅនិយម របស់ ទីក្រុងប៉េកាំង ទៅហើយក្តី។ ទោះចង់ ឬ មិនចង់ក្តី គេត្រូវប្រយុទ្ធតទល់ នឹង សត្រូវរួមសិន រីឯការខ្វែងគំនិតគ្នា ត្រូវទុកមួយអន្លើសិន ។ ប៉ុន្តែនៅពេលក្រោយមកទៀត ប៉ុល ពត មានការពិបាកយ៉ាងខ្លាំង ក្នុងការបោសសំអាតឥទ្ធិពល របស់ វៀតណាម ចេញពី បក្សកុម្មុយនិស្ត ម៉ៅនិយម របស់គេ។

# ការប្រយុទ្ធ រវាង ខ្មែរក្រហម និង រដ្ឋាភិបាល របស់ សម្តេច នរោត្តម សីហនុ នៅឆ្នាំ ១៩៦៨-១៩៦៩

## Lutte entre les Khmers rouges et le Gouvernement de Sihanouk en 1968-1969

ការប្រយុទ្ធតស៊ូ របស់ ចលនាខ្មែរក្រហមនៅឆ្នាំ ១៩៦៨-១៩៦៩ មានការលំបាក លំបិន យ៉ាងខ្លាំង ចំពោះ ពួកខ្មែរក្រហម ៖ ណាមួយខ្វះ មធ្យោបាយយោធា គ្រប់បែប យ៉ាងណាមួយ កងទ័ពព្រៃវៀតណាមនៅក្នុងប្រទេសកម្ពុជា ធ្វើការគាបសង្កត់យ៉ាង ខ្លាំង ដើម្បីឲ្យខ្មែរក្រហម ជួយការពារ ខ្សែដឹកនាំស្បៀង ណាមួយ កងទ័ព របស់ឧត្តម សេនីយ៍ លន់ នល់ ធ្វើការវាយប្រហារ ដោយឥតសំចៃៗ គឺ តាំងពីឆ្នាំ ១៩៦៨ នោះ មកហើយ ដែលខ្មែរក្រហមទ្រាំទ្រ សហប្រតិបត្តិការ ជាមួយទីក្រុង ហាណូយ សឹងតែ មិនបានៗ នៅឆ្នាំ ១៩៧៧ គឺ នៅពេលដែល ខ្មែរក្រហម កាន់កាប់ ប្រទេសកម្ពុជាទាំង មូល ប៉ុល ពត បាន សារភាពថា នៅពេលនោះ ការតស៊ូ របស់ បដិវត្តន៍ កម្ពុជា បាន ប្រព្រឹត្តិទៅ ដោយបាតដៃទទេៗ ឯកសារជាច្រើន បានបញ្ជាក់ថា នៅអំឡុងឆ្នាំ ១៩៦៨ នោះ សម្តេច នរោត្តម សីហនុ ស្ថិតនៅ ក្នុងស្ថានភាពមួយដ៏ពិបាក ព្រោះ ព្រះអង្គគ្មាន ជម្រើសអ្វីទៀត ក្រៅពីជំរុញឲ្យរដ្ឋាភិបាល លន់ នល់ វាយកំទេច ចលនា កុម្មុយនិស្ត ទេៗ ប៉ុន្តែ ទីក្រុងភ្នំពេញ បែរជាទទួលផលវិបាក ផ្ទុយពីសេចក្តីប្រាថ្នាទៅវិញ ដោយ ហេតុថា ការប្រយុទ្ធ កំទេចខ្មែរក្រហម បានក្លាយ ទៅជាការគាបសង្កត់ ទៅលើ ប្រជា ជនខ្មែរទៅវិញៗ អ្នកស្រុក អ្នកភូមិជាច្រើន ដែលបានត្រូវ កងទ័ព របស់ ឧត្តមសេនីយ៍ លន់ នល់ រាតត្បាត យ៉ាងឃោរឃៅ ព្រៃផ្សៃ បាននាំគ្នាទៅ ជ្រកកោន ជាមួយ ចលនា បដិវត្ត របស់ខ្មែរក្រហមតែម្តង ជាហេតុ ធ្វើឲ្យពួកខ្មែរក្រហម កាន់តែមាន កម្លាំងថែម





ទៀតៗ ឆ្លៀតយកឱកាសនោះ ខ្មែរក្រហម បានបង្កើន ការឃោសនា របស់គេ ប្រឆាំង នឹង សម្តេច នរោត្តម សីហនុ ដោយត្រង់ៗ ។ សម្តេច នរោត្តម សីហនុ បានចុះប្រជា ប្រិយភាពយ៉ាងខ្លាំង នៅពេលនោះ ដោយសារ តរឿងនេះ ។ មួយវិញទៀត ព្រោះតែ សង្គ្រាម ក្នុងស្រុកនេះ សេដ្ឋកិច្ច ប្រទេសកម្ពុជា ទាំងមូល បានធ្លាក់ចុះដុនដាប ជា អតិ បរមាៗ ប្រាក់ចំណូលគ្រប់ប្រភេទ របស់ រដ្ឋាភិបាល បានចុះថយ ព្រោះ ទារពន្ធ ក៏មិន បាន ផលិតកម្មកៅស៊ូ ក៏ត្រូវរាំងស្ទះ ស្រូវអង្ករ ក៏មានចំនួន តិចតួចស្តួចស្តើង ប្រៀប ធៀបទៅនឹង ចំនួនប្រជាជន ដែលបានកើនឡើងយ៉ាងច្រើន នៅឆ្នាំ ១៩៦៨ គឺ បានកើន ពី ៥ លាន ២ សែន នាក់ នៅឆ្នាំ ១៩៦០ មក ៦ លាន ៦ សែននាក់ៗ

នៅឆ្នាំ ១៩៦៨ នោះ សម្តេច នរោត្តម សីហនុ បានត្រូវពួកខ្មែរក្រហម ចាត់ ទុកថាជាសត្រូវទី ១ របស់ ពួកគេ ដូច ឧត្តមសេនីយ៍ លន់ នល់ ដូច្នេះដែរ ដោយ ហេតុថា បន្ទាប់ពី ធ្វើការវាយប្រហារ ទៅលើ ប្រជាកសិករ នៅសម្លូត និង ទៅលើ និស្សិតឆ្វេងនិយម សម្តេច នរោត្តម សីហនុ បានងាករេទៅរកអាមេរិកវិញៗ ប្រទេស កម្ពុជានៅឆ្នាំ ១៩៦៨ នោះ បានឆ្លងកាត់ វិបត្តិសេដ្ឋកិច្ច និង សង្គមមួយ ដ៏ធំ គឺ ស្ថាន ភាពមួយ ដ៏ពិបាក ដែលប្រទេសជាតិ មិនធ្លាប់ដែលបានស្គាល់ តាំងពី ជំនាន់បារាំង មកៗ ដោយប្រាក់រៀលចុះថ្លៃ ហើយដោយរំពឹង ទៅលើប្រាក់ខែរបស់គេ មិន បានបន្ត ទៅទៀត មន្ត្រីរាជការ ក៏ធ្លាក់ទៅក្នុង អំពើពុករលួយមួយ ដ៏គ្មានកោះត្រើយៗ ចំណែក ឯ យុវជនវិញ គេ ក៏រកការងារធ្វើ ដោយពិបាក ។ នៅ រដូវក្តៅ ឆ្នាំ ១៩៦៩ សម្តេច នរោត្តម សីហនុ បានសម្រេច ដាក់ទំនាក់ទំនងទូត ជាមួយ អាមេរិកវិញ ។ អ្នកឆ្វេង និយម ក៏ឈប់ផ្តល់ការគាំទ្រ របស់គេ ។ មួយវិញទៀត សេចក្តីសង្ឃឹម របស់ សម្តេច នរោត្តម សីហនុ ថា ការងាករេទៅរក អាមេរិកវិញនេះ អាចនឹង ជួយប្រទេសជាតិឲ្យ ឆ្លងផុតពីអន្តរាយ ក៏បាត់រលត់ទៅវិញបន្តិចម្តងៗ ព្រោះអាមេរិកគ្មានផែនការនយោបាយ អ្វីទាំងអស់ សម្រាប់ជួយខ្មែរៗ លោកប្រធានាធិបតី និចសុន នៅពេលនោះ កំពុង តែរកកល់ ដកកងទ័ពអាមេរិក ចេញពី ប្រទេសវៀតណាមខាងត្បូងៗ គឺ នៅពេលនោះ

ហើយដែល សម្តេច នរោត្តម សីហនុ យល់ យ៉ាងច្បាស់ ថា សហរដ្ឋ អាមេរិក គ្មាន អនាគត នៅឥណ្ឌូចិន។ ប៉ុន្តែ ប្រការដែលគួរឲ្យកត់សំគាល់ គឺថា ចំពោះប្រទេស កម្ពុជា នៅពេលនោះ ក៏ ដូចជាពេលក្រោយៗ មកទៀតដែរ ការកំណត់ មាគ៌ា នយោបាយ សុទ្ធតែមាន លក្ខណៈផ្ទុយ នឹង ស្ថានការណ៍ នយោបាយ អន្តរជាតិ សឹងតែទាំងអស់ គឺ ហាក់បីដូច ជា គេមិនសូវផ្តល់សារសំខាន់ ទៅឲ្យសភាពការណ៍ នយោបាយ អន្តរជាតិតែម្តង។ នៅឆ្នាំ ១៩៦៩ សម្តេច នរោត្តម សីហនុ បានរេទៅ រកអាមេរិក នៅពេលដែលអាមេរិក ត្រៀមលក្ខណៈបោះបង់សង្គ្រាម នៅវៀតណាមចោល។ នៅឆ្នាំ ១៩៧០ ឧត្តមសេនីយ លន់ នល់ និង អ្នកអង្គម្ចាស់សិរិមតៈ ក៏ជួបនឹងបដិវាទកម្ម រវាង បរិបទ អន្តរជាតិ និង ការវិវត្តន៍ នៃ ស្ថានការណ៍ ក្នុងប្រទេសដែរ ។ ធ្ងន់ធ្ងរជាងនេះទៅទៀត គឺ ការបែកបាក់ផ្ទៃក្នុង ការដណ្តើមអំណាចគ្នា នៅពេលមួយដែលប្រទេសជាតិ ស្ថិតនៅក្នុងការគំរាមកំហែង។ គេអាចនិយាយថា អ្នកនយោបាយខ្វះបែងចែក មិនបានច្បាស់ រវាង ស្មារតីស្នេហាជាតិ និង កាលៈទេសៈ នៃ ការដណ្តើមអំណាចគ្នា ។

## បដិវត្តន៍ របស់ ខ្មែរក្រហម

## La révolution des « Khmers rouges »

ចាប់តាំងពីចុងឆ្នាំ ១៩៧១ មក គឺ មួយឆ្នាំ ក្រោយការទម្លាក់ សម្តេច នរោត្តម សីហនុ បដិវត្តន៍ ខ្មែរក្រហម បានឈានមកដល់ ភាពម្ចាស់ការ គឺ ឈប់រណប នឹង កងទ័ពវៀតណាមបន្តទៅទៀត។ នៅពេលដែលកងទ័ព វៀតណាមកុម្មុយនិស្ត ចំនួន ៤ ម៉ឺននាក់ ប្រយុទ្ធយ៉ាងស្វិតស្វាញ នឹង កងទ័ព ឧត្តមសេនីយ៍ លន់ នល់ សាឡុត សរ ដែលមានឈ្មោះបដិវត្ត ថា ប៉ុល ពត បានឆ្លៀតឱកាស បង្ហាត់ហ្វឹកហ្វឺន កងទ័ព របស់ ខ្លួនឥតឈប់ឈរ ។ នៅ ខែធ្នូឆ្នាំ ១៩៧១ នោះ កងទ័ព ឧត្តមសេនីយ៍ លន់ នល់



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

គាំទ្រដោយ សហរដ្ឋ អាមេរិក បានត្រូវកងទ័ព វៀតណាមកុម្មុយនិស្ត វាយបាក់បែកខ្ចាត់ខ្ចាយអស់ ។ ប្រតិបត្តិការសឹក «ចេនឡា២» បានទទួលបរាជ័យទាំងស្រុង ។ នៅពេលដែលការចរចា រវាង ទីក្រុងហាណូយ និង ទីក្រុងវ៉ាស៊ីងតោន នៅទីក្រុងប៉ារីស៍ បានឈានជាសន្សឹមៗឆ្ពោះទៅរក ការបញ្ចប់សង្គ្រាមនៅឥណ្ឌូចិន កងទ័ពខ្មែរក្រហម មាន លក្ខណៈគ្រប់គ្រាន់ល្មមគួរ ដើម្បី យកជ័យជំនះ ទៅលើ កងទ័ព សាធារណរដ្ឋខ្មែរ។ កិច្ចការសំខាន់ៗ របស់ ខ្មែរក្រហមនៅពេលនោះ គឺ វាយប្រមូលយក សញ្ញាវុធ ពីកងទ័ពឧត្តមសេនីយ៍ លន់ នល់ ឲ្យបានច្រើនបំផុត ជាពិសេស ឈានទៅក្តាប់ តំបន់សេដ្ឋកិច្ច ដែលជាប្រភពស្បៀង ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ ប៉ុល ពត ខិតខំពង្រឹងចិត្តសាស្ត្រ របស់ យុទ្ធជនខ្មែរក្រហម ឲ្យមានជំនឿជាមូលដ្ឋាន ទៅលើគោលជំហរ និង ទឹកចិត្តប្រយុទ្ធ ប្តូរផ្តាច់ ថែមទៀត ពីព្រោះ ខាង សាធារណរដ្ឋខ្មែរ គេមាន សញ្ញាវុធ យុទ្ធោបករណ៍ យ៉ាងសន្ធឹកសន្ធាប់ ដូចជា កប៉ាល់ចម្បាំង យន្តហោះ កាំភ្លើងធំជាដើម។ បើនិយាយមួយបែបទៀត សង្គ្រាមដែលខ្មែរក្រហមធ្វើ ដើម្បីវាយប្រហារ សាធារណរដ្ឋខ្មែរ ជាសង្គ្រាម ចិត្តសាស្ត្រ ច្រើនជាង ការប្រយុទ្ធតទល់ ផ្នែកយោធាសុទ្ធសាធ ដោយហេតុថា នៅខាងសាធារណរដ្ឋខ្មែរ កងទ័ព បាក់ទឹកចិត្តច្រើន ព្រោះតែ អំពើពុករលួយ របស់ ឧត្តមសេនីយ៍មួយចំនួនធំ និង ការធ្លាក់ចុះ នៃ សេដ្ឋកិច្ច ។ ទន្ទឹមនឹងការបំពាក់ស្មារតីប្រយុទ្ធដ៏អង់អាច ប៉ុល ពត សង្កត់ធ្ងន់ ទៅលើ មាគ៌ានយោបាយ និង បច្ចេកទេស សង្គ្រាមចិត្តសាស្ត្រ។ នៅឆ្នាំ ១៩៧២ មេខ្មែរក្រហម ប៉ុល ពត បានបើកអង្គប្រជុំជាច្រើនដើម្បីនិយាយ អំពីមាគ៌ានយោបាយ របស់ បដិវត្តន៍។ ប៉ុល ពត កត់សំគាល់ជាអាទិ៍ថា : ឥឡូវនេះ យើងមានទឹកចិត្តប្រយុទ្ធដ៏អង់អាចក៏ពិតមែន ប៉ុន្តែទឹកចិត្ត មិនគ្រប់គ្រាន់ទេ គឺ យើងត្រូវមាន មាគ៌ា នយោបាយ ឲ្យបានត្រឹមត្រូវ ហើយមាន វិធីសាស្ត្រឲ្យបានសមស្របថែមទៀត។ បើគ្មានមាគ៌ាដឹកនាំទេនោះ បដិវត្តន៍ នឹង ក្លាយ ទៅជាមនុស្សខ្វាក់ដែលដើរ ពីកន្លែងមួយ ទៅកន្លែងមួយទៀតតែប៉ុណ្ណោះ ។

នៅឆ្នាំ ១៩៧១ ប៉ុល ពត បានបង្កើត ទំបន់ រដ្ឋបាល ពិសេស ជាច្រើន នៅផ្នែក និរតី នៃ ទីក្រុងភ្នំពេញ គឺ បើគិតពី ផ្នែកខាងត្បូង ទៅផ្នែកបស្ចិម គេបានកសាងមូលដ្ឋានទី ១៥ ទៅ ទី ២៥។ ប៉ុល ពត បាន ប្រគល់ការគ្រប់គ្រងតំបន់ ទាំងនោះ ទៅឲ្យមិត្ត ជិតស្និទ្ធម្នាក់ របស់គេ ឈ្មោះ សុខ ធួក ដែល មានឈ្មោះ មួយទៀតថា វន វេត ។ ប៉ុន្តែក្រោយមក នៅពេលដែលក្តាប់ អំណាចបាន ទាំងមូលហើយ ប៉ុល ពត ត្រូវប្រឈមមុខ នឹង ការបះបោរ ក្នុងជួរបដិវត្តន៍ ។ សុខ ធួក បានត្រូវ ប៉ុល ពត យកទៅធ្វើទារុណកម្ម នៅគុកទួលស្លែង ។ នៅពេលនោះ ប៉ុល ពតកំពុងធ្វើការបោសសំអាតផ្ទៃក្នុង ដើម្បីកំចាត់ឥទ្ធិពលរបស់វៀតណាម នៅក្នុងផ្ទៃបក្សកុម្មុយនិស្ត កម្ពុជា។ បន្ទាប់ ពីបានរៀបចំ តំបន់ពិសេសមួយចំនួន នៅឆ្នាំ ១៩៧១ ប៉ុល ពត ចាប់ផ្តើមធ្វើការបំពាក់បំប៉ន មាគ៌ានយោបាយ របស់ បដិវត្តន៍ នៅក្នុងចំណោម ប្រជាជនតែម្តង ព្រោះ ប៉ុល ពត យល់យ៉ាងច្បាស់ថា បើគ្មានប្រជាជនគាំទ្រទេនោះ ចលនាខ្មែរក្រហម គ្រាន់តែជា ទ័ពចោរព្រៃតែប៉ុណ្ណោះ ។ ប្រការគួរឲ្យកត់សំគាល់ គឺថា ប៉ុល ពត សង្កត់ធ្ងន់ជាងគេទៅលើ កត្តាមនោគមវិជ្ជា និង កត្តានយោបាយ ព្រោះថា បើប្រជាជនគ្មានជំនឿទៅលើ បដិវត្តន៍ ទេនោះ បដិវត្តន៍ ក៏គ្មានជំហរដែរ ។ ចាប់តាំងពីឆ្នាំ ១៩៧២ នោះមក ប៉ុល ពត បានបង្កើត វគ្គសិក្សា នយោបាយ ជាច្រើន ដើម្បីពង្រឹងស្មារតីបដិវត្តន៍ ដល់ យុវជន ។ នៅពេលនោះ ខ្មែរក្រហម បានអូសទាញនិស្សិត សាស្ត្រាចារ្យ វិស្វករ និង សិស្សសាលាជាច្រើនឲ្យមកចូលរួម ក្នុងវគ្គសិក្សា នយោបាយទាំងនោះ ដែលរៀបចំ នៅតាម «តំបន់រំដោះ» ។ បន្ទាប់ ពីបានរៀនសូត្រ អ្នកទាំងនោះក៏ត្រឡប់ទៅភ្នំពេញវិញទាំងអស់ ដោយ ពាំនាំ មាគ៌ា មនោគមវិជ្ជា និង នយោបាយខ្មែរក្រហម ទៅឲ្យប្រជាជនខ្មែរ ដែលកំពុងរស់នៅ យ៉ាង លំបាកលំបិន នៅទីក្រុងភ្នំពេញ ។

ចាប់តាំងពីឆ្នាំ ១៩៧១ មក ឯកសារទាំងឡាយ របស់ បក្សកុម្មុយនិស្តកម្ពុជា បញ្ជាក់យ៉ាងច្បាស់ អំពី តួនាទី ដ៏សំខាន់ របស់ កសិករ ក្រ កសិករ មធ្យម និង





កម្មករ នៅក្នុងបដិវត្តន៍។ អ្នកដឹកនាំបដិវត្តន៍ ត្រូវចេញមកពី «វណ្ណៈ» ទាំងនេះ ។ ប៉ុល ពត យល់ឃើញថា ដើម្បី វាយរំលំ ពួក «សក្តិភូមិ» និង ពួក «មូលធននិយម» គេត្រូវផ្អែកទៅលើអ្វី ដែល ប៉ុល ពត ហៅថា «កសិករក្រ» ។ ប៉ុល ពត ក៏លើកឡើងផងដែរ អំពី ឧត្តមភាព នៃ លទ្ធិកុម្មុយនិស្ត ប៉ុន្តែ ពុំដែល លើកឡើង ម្តងណាឡើយ អំពី ទស្សនវិទូអាល្លឺម៉ង់ «កាលម៉ាក្ស» ដែលជាអ្នកបង្កើតទ្រឹស្តី  «វណ្ណៈអធន» ហើយ ក៏ មិនដែលនិយាយពី មេដឹកនាំបដិវត្តន៍ សង្គមនិយម រុស្ស៊ី «លេនីន» ទាល់តែសោះ។ នៅក្នុងគំនិត របស់ ប៉ុល ពត អ្នកទាំងនេះ សុទ្ធតែជា ជនបរទេស។ ដូចនេះ អាចធ្វើឲ្យប៉ះពាល ដល់ មោទនភាព ជាតិខ្មែរ ។ មួយវិញទៀត ប៉ុល ពត យល់ថា «ស្តាលីន» (Staline) ជាអ្នកបដិវត្ត ពិត ជាង លេនីន ។ ប៉ុន្តែដោយដឹងថា ចិនស្អប់ រុស្ស៊ី ប៉ុល ពត សុខចិត្ត យកតម្រាប់តាមចិនតែម្តង។ ហេតុដូច្នេះហើយបានជា ប៉ុល ពត លើកតម្កើងទ្រឹស្តី «មហាលោតផ្លោះ មហាអស្ចារ្យ» («le grand bond en avant ») របស់ ម៉ៅ សេ ទុង ជាងម្ចាស់ដើម នៃទ្រឹស្តី «បដិវត្តន៍អធន» (Révolution prolétarienne)។ ចំពោះអ្នកដឹកនាំបដិវត្តន៍ខ្មែរ ដែលគ្មានអ្នកណា ម្នាក់សោះ ចេញមកពីវណ្ណៈកសិករក្រ ប៉ុលពត បានដាក់កំហិត ឲ្យ«លត់ដំ»ខ្លួន ធ្វើយ៉ាងណា ឲ្យមានទស្សនៈ និងឥរិយាបថ ដូចកសិករក្រជាចាំបាច់។ អ្នកដែលមានដើមកំណើត ផ្សេងពីនេះ ត្រូវ «ក្បត់វណ្ណៈ»ដើម របស់គេជាដាច់ខាត ។ បើអ្នកណា ហ៊ាន ប្រមាថដល់សិទ្ធិអំណាច របស់កសិករក្រ គេត្រូវទទួលទោសជាទម្ងន់ រហូតដល់ បាត់បង់ជីវិតផង ក៏មាន។ នៅពេលវាយរំលំ របបសាធារណរដ្ឋខ្មែរ ទោះជា បក្សកុម្មុយនិស្តខ្មែរ មានអង្គការចាត់តាំងរបស់ខ្លួនទៅហើយក្តី ក៏គេនៅតែផ្អែក មួយចំណែកធំ ទៅលើ កម្លាំង កងទ័ពកុម្មុយនិស្តវៀតណាម ដែលស្ថិតនៅលើទឹកដីខ្មែរ ដដែល ព្រោះប៉ុល ពត មិនចង់ទប់ទល់ នឹងកងទ័ពឧត្តមសេនីយ៍ លន់ នល់ ដោយ ផ្ទាល់ទេ គឺ ចង់ឆ្លៀតប្រើកម្លាំង កងទ័ពវៀតណាមសិន ។

# ការឈប់បាញ់គ្នា រវាង កងទ័ព កុម្មុយនិស្ត វៀតណាម និង កងទ័ព សហរដ្ឋ អាមេរិក នៅឆ្នាំ ១៩៧៣

## Le cessez-le-feu entre les troupes communistes vietnamiennes et les troupes américaines en 1973

នៅដើមទសវត្ស ៧០ ការចរចារវាង ទីក្រុងហាណូយ និង ទីក្រុងវ៉ាស៊ីងតោន នៅទីក្រុងប៉ារីស៍ ដែលបានចាប់ផ្ដើមពីឆ្នាំ ១៩៦៨ មកចេះតែបន្តទៅទៀត ដើម្បីរកប្រក បញ្ចប់សង្គ្រាមនៅឥណ្ឌូចិន។ ទីក្រុងវ៉ាស៊ីងតោន ខិតខំធ្វើយ៉ាងណា ដើម្បីឈានឲ្យបាន ដល់ការឈប់បាញ់គ្នា យ៉ាងឆាប់រហ័ស គឺ មុនការបោះឆ្នោតប្រធានាធិបតី នៅ សហរដ្ឋ អាមេរិក ។ នៅពេលនោះ សហរដ្ឋ អាមេរិក បានត្រូវ ពិភពលោក ទាំងមូល ព្រមទាំង ប្រជាជន អាមេរិក ថ្កោលទោស យ៉ាងខ្លាំង ព្រោះតែ អាមេរិក ចូលឈ្លានពានប្រទេស វៀតណាម។ នៅពេលនោះឯង សហរដ្ឋ អាមេរិក បានដកកងទ័ព ជាបណ្ដើរៗ ចេញពី ឥណ្ឌូចិន ហើយ ទុកតែកងទ័ព មួយចំនួន ដែលត្រូវដកចេញ ក្រោយការឈប់បាញ់គ្នា ប៉ុណ្ណោះ។ នៅពេលដែល សហរដ្ឋ អាមេរិក ចាប់ផ្ដើម ដកកងទ័ព ខាងប្រទេសវៀត ណាម ឯនោះវិញ គេមានលទ្ធភាព គ្រប់គ្រាន់សម្រាប់ វាយសម្រុកយក ទីក្រុងសាយ ហ្គន ព្រោះ អាមេរិក មិនអាចបញ្ជូនកងទ័ព ត្រឡប់មកវិញ បានឡើយ ។ ប៉ុន្តែទោះជា យ៉ាងនេះ ក៏ដោយ ក៏ សហរដ្ឋ អាមេរិក អាចបន្ត ការទម្លាក់ គ្រាប់បែក របស់ គេ បន្ត ទៅ ទៀតបានដែរ ។ ទីក្រុងវ៉ាស៊ីងតោន គំរាមថា ប្រសិនណាជា ទីក្រុងហាណូយ មិន



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

ទទួលយក សេចក្ដីស្នើឈប់បាញ់គ្នា ទេនោះ អាមេរិក នឹង មិនបញ្ចប់ការទម្លាក់គ្រាប់ បែកដែរ។ ចំពោះទីក្រុងហាណូយ គេត្រូវរក្សាកងទ័ព របស់គេ សម្រាប់វាយយកទីក្រុង សាយហ្គន។ ដូចនេះ វាជាការល្អណាស់ ដែល អាមេរិក ឈប់ទម្លាក់គ្រាប់បែក។ នៅ ខែមករាឆ្នាំ ១៩៧៣ ទីក្រុងហាណូយ សុខចិត្តទទួលយក លក្ខខណ្ឌ របស់ អាមេរិក។ យោងទៅតាមសេចក្ដី នៃលក្ខខណ្ឌនោះ ទីក្រុងហាណូយ ក៏ ត្រូវដកកងទ័ព របស់គេ ចេញពី កម្ពុជា ផងដែរ ប៉ុន្តែ រក្សាទុក កងទ័ពមួយចំនួន នៅ តាមព្រំដែន។ គឺនៅពេល នោះហើយ ដែលបក្សកុម្មុយនិស្ត វៀតណាម ឈប់គាំទ្រសកម្មភាពរបស់ ខ្មែរក្រហម។ វៀតណាមក៏ បានស្នើផងដែរ ឲ្យខ្មែរក្រហម គោរព ការឈប់បាញ់គ្នា ប៉ុន្តែ ខ្មែរក្រហម ពុំព្រមដាច់ខាត ដោយហេតុថា ពួកគេ ក៏មានលទ្ធភាព វាយយក ទីក្រុងភ្នំពេញដែរ ។ ទោះជាយ៉ាងនេះ ក៏ដោយ ដើម្បី សម្រួលការវាយ យកទីក្រុងភ្នំពេញ ខ្មែរក្រហម ក៏ ប្រកាសសន្តិភាព ជាមួយ របប របស់ ឧត្តមសេ នីយ៍ លន់ នល់។ ខាង ឧត្តមសេនីយ៍ លន់ នល់ គេ ក៏ជឿកលល្បិចនេះ របស់ ខ្មែរក្រហមទៅទៀត។ ហេតុតែចង់បញ្ចេញ នូវ កម្លាំង កងទ័ព របស់គេ ខ្មែរក្រហម ក៏ វាយយក ទីក្រុងភ្នំពេញដោយត្រង់ៗតែម្ដង ហើយពុំព្រម ប្រគល់ការកិច្ច នយោបាយ ទៅថ្វាយសម្ដេច នរោត្ដម សីហនុ ដែលជា ប្រធានរណសិរ្ស នៃ ចលនា រួបរួមជាតិ កម្ពុជាទេ។ ម៉្យាងទៀត ប៉ុល ពត ចាត់ទុកថា កិច្ចព្រមព្រៀង រវាង ទីក្រុងហាណូយ និង ទីក្រុងវ៉ាស៊ីងតោន ថាជាអំពើក្បត់ផងទៀត។ ប៉ុន្តែពួកខ្មែរក្រហម គេឥតបានគិតទាល់តែសោះថា គេគ្មានមនុស្សគ្រប់គ្រាន់ទេសម្រាប់ រៀបចំ រដ្ឋអំណាចថ្មី ហើយ ក៏ គ្មានការគាំទ្រ ពីសំណាក់ អន្តរជាតិដែរ បើគ្មាន សម្ដេច នរោត្ដម សីហនុ ជាអ្នកបង្រួបបង្រួម។ ប៉ុល ពត ភ្លេចគិតទាំងស្រុង អំពី សុភាសិត នយោបាយមួយដែលពន្យល់ថា «ការយកអំណាច ជាការងាយស្រួល ប៉ុន្តែ គឺការរក្សាអំណាចឲ្យបានយូរ ទេ ដែលជាការពិបាក» នោះ ។

# ការវាយលុក ជាបី ដំណាក់ការ របស់ ខ្មែរក្រហម មុន ការវាយយក ទីក្រុងភ្នំពេញ ( ១៩៧៣, ១៩៧៤, ១៩៧៥ )

## Les 3 assauts successifs des Khmers rouges avant la prise de Phnom Penh

នៅចុង ខែកុម្ភៈ ឆ្នាំ ១៩៧៣ សម្តេច នរោត្តម សីហនុ និង ព្រះជាយា អ្នកម្នាង ម៉ូនិច បានយាង មកក្នុង «តំបន់រំដោះ» [២៥] កាន់កាប់ដោយពួកខ្មែរក្រហម ។ ព្រះរាជដំណើរ នេះបានត្រូវរៀបចំឡើងដោយទីក្រុងប៉េកាំង និង ទីក្រុងហាណូយ ហើយដែលមាន អៀងសារី ជាអ្នកអមដំណើរ ។ ចំពោះទីក្រុងប៉េកាំង គឺជាការផ្តល់សន្ទុះមួយថ្មីទៅឲ្យពួកខ្មែរក្រហម ដោយបញ្ជាក់ថា សម្តេច នរោត្តម សីហនុ ជាអ្នកដឹកនាំ ប្រទេសកម្ពុជាយូរអង្វែងទៅថ្ងៃមុខៗ ប៉ុន្តែ ចំពោះទីក្រុងហាណូយ គឺជាការបញ្ជាក់ប្រាប់ថា គេពុំយល់ស្រប នឹងនយោបាយ របស់ ខ្មែរក្រហម ដែលមាន គោលបំណង កាត់ផ្តាច់ សម្តេច នរោត្តម សីហនុ ចេញ ពីចលនាតស៊ូ របស់ ពួកគេ ។ នេះ បើយោង ទៅ តាមការសន្និដ្ឋាន របស់ប្រវត្តិវិទូ ដេវីដ ចិនដ្លែរ។ ពេលយាងមកដល់ ព្រំដែន ប្រទេសលាវ សម្តេច នរោត្តម សីហនុ និង អ្នកម្នាង ម៉ូនិច បានទទួលបដិសណ្ឋារកិច្ច ពី សំណាក់ ខៀវ សំផន, ហ៊ូ យន់ និង ហ៊ូ នឹម។ ពីរថ្ងៃក្រោយមក នៅទីបញ្ជាការ

[២៥] ពាក្យដែល ខ្មែរក្រហមប្រើ សម្រាប់សំគាល់ តំបន់ ដែលពួកគេ បានកាត់ផ្តាច់ ចេញពីការគ្រប់គ្រង របស់ សាធារណរដ្ឋខ្មែរ ។





ភូមិភាគខាងជើង របស់ ខ្មែរក្រហម អតីតប្រមុខរដ្ឋខ្មែរ និង ព្រះជាយា បានជួបសន្ទនា ជាមួយ ខៀវ ប៉ុណ្ណារី ភរិយា របស់ ប៉ុល ពត, សុន សេន និង កុយ ធួន។ ប៉ុល ពត ក៏បានមកចូលរួម ក្នុងជំនួប ជាប្រវត្តិសាស្រ្ត នោះដែរ ប៉ុន្តែ ប៉ុល ពត ពុំបានបញ្ចេញឲ្យដឹងថា គេជាមេដឹកនាំ ចលនាខ្មែរក្រហមទេ ហើយ ថែមទាំងបានរៀបចំធាកកំប្លែងមួយផងទៀត ដោយដើរតួ ជា ខ្មែរក្រហម ម្នាក់ ដែលគ្មាន តួនាទី សំខាន់ អ្វីទាំងអស់នៅក្នុង ចលនា ខ្មែរក្រហម។ គ្មានមេដឹកនាំខ្មែរក្រហមណាម្នាក់ ដែលបាន ត្រូវអនុញ្ញាតឲ្យ ចូលជួបសន្ទនា ដោយផ្ទាល់ ជាមួយ សម្តេច នរោត្តម សីហនុ និង ព្រះជាយា ទេ គឺ មានតែ ខៀវ សំផន ម្នាក់ ប៉ុណ្ណោះ ដែលហ៊ានទូល ព្រះអង្គ ដោយត្រង់ៗថា វៀតណាម បានបោះបង់សម្ព័ន្ធមិត្ត កុម្មុយនិស្ត របសគេចោល។ បន្ទាប់ ពីទស្សនកិច្ច ៣ សប្តាហ៍ របស់ សម្តេច នរោត្តម សីហនុ នៅ «តំបន់រំដោះ» ផ្នែកខាងជើង នៃប្រទេសកម្ពុជា នៅដើមឆ្នាំ ១៩៧៣ នោះ ប៉ុល ពត បានរៀបចំ ការវាយ ប្រហារទៅលើកងទ័ពឧត្តមសេនីយ៍ លន់ នល់ នៅក្នុងទ្រង់ទ្រាយមួយដ៏ធំ ប៉ុន្តែ ជាបីដំណាក់ការ។ រីឯគោលដៅ គឺវាយយក ទីក្រុងភ្នំពេញតែម្តង។ ការវាយលុក ដំណាក់ការទី១ ដែលបានប្រព្រឹត្តទៅនៅឆ្នាំ ១៩៧៣ ក្រោមបញ្ជាការរបស់ ប៉ុល ពត ផ្ទាល់ បានទទួលបរាជ័យទាំងស្រុង ព្រោះ យន្តហោះ អាមេរិក បានទម្លាក់គ្រាប់បែក កាត់ផ្តាច់ ការរុលទៅមុខ នៃ កងទ័ពខ្មែរក្រហម ដែលនៅពេលនោះ មានចំនួន ៦ ម៉ឺននាក់។ ការវាយលុក ទី ២ បម្រុងវាយយក ទីក្រុងកំពុងចាម ក៏ ទទួល បរាជ័យដូចគ្នា អ៊ីចឹងដែរ។

នៅខែ មិថុនា ឆ្នាំ ១៩៧៤ ប៉ុល ពត បានបើក អង្គប្រជុំ គណមជ្ឈិមបក្សមួយ ដើម្បីលើកឡើងនូវ ផែនការវាយយក ទីក្រុងភ្នំពេញ ឲ្យបាន នៅឆ្នាំ ១៩៧៥។ នេះ ជា ដំណាក់ការទី ៣ ដែលគេចាត់ទុកថា ជាដំណាក់ការផ្តាច់ព្រ័ត្រ ។ ពុ៉ល ពត បានថ្លែង នៅឱកាសនោះថា ៖ «យើងហ៊ានវាយយកទីក្រុងភ្នំពេញ ពីព្រោះ យើងបានវិភាគច្បាស់រួចហើយ អំពី ស្ថានភាព របស់ រដ្ឋាភិបាល លន់ នល់ » ។ ប៉ុល ពត បានគូសបញ្ជាក់ថា : ទី១ រដ្ឋាភិបាល លន់ នល់ កំពុងតែដកបង្កាមាន់ – ទី ២ អាមេរិក បានដក កង

*ទ័ពចេញ អស់ហើយ ។ នៅពេលនោះ ប៉ុល ពត ក៏ បាន បញ្ចេញ ឲ្យដឹងផងដែរថា : «ការវាយលុក យកទីក្រុងភ្នំពេញនេះ មិនមែនជាការងាយស្រួល ក៏ពិតមែន ប៉ុន្តែ គឺចំណុចនេះតែម្តង ដែលសំខាន់ ព្រោះថា គ្មានយុទ្ធវិទូណាម្នាក់ អាចកាត់ស្មានបានទេថា យើងអាចធ្វើដូច្នេះនោះ ព្រោះយើងខ្វះសម្ភារៈយោធា គ្រាប់រំសេវ គ្រប់បែបយ៉ាង» ។ នៅចុងឆ្នាំ ១៩៧៤ ជូ ចិត្ត លេខាបក្សភូមិភាគ នីរតី បានជួប ប៉ុល ពត នៅ កំពុងចាម ដើម្បីរៀបចំ ការវាយលុក ដែលត្រៀមធ្វើ នៅរដូវក្តៅ ឆ្នាំ ១៩៧៥។ យុទ្ធសាស្ត្រ របស់ ប៉ុល ពត នៅពេលនោះ គឺកាត់ផ្តាច់ទីក្រុងភ្នំពេញឲ្យនៅឯកោ គឺ កាត់ផ្តាច់ គមនាគមន៍ គ្រប់បែបយ៉ាងទាំងអស់។ កងទ័ពខ្មែរក្រហម បានកំទេច នាវាចម្បាំង របស់ ឧត្តមសេនីយ៍ លន់ នល់ ដែលធ្វើដំណើរ តាមទន្លេមេកុង អស់ជាច្រើនគ្រឿង។ នៅពេលដែលការវាយលុក កំពុងប្រព្រឹត្តទៅ គណៈមជ្ឈិម រៀបចំ ការគ្រប់គ្រងទីក្រុងភ្នំពេញ ជាបណ្តើរៗ  បើតាមការអះអាង របស់ ដេវីដ ចិនដ្លែរ គឺ នៅពេលនោះហើយ ដែលខ្មែរក្រហម បានសម្រេច ជម្លៀសប្រជាជន ឲ្យចេញអស់ ពីទីក្រុងភ្នំពេញ ហើយ លុបបំបាត់ រូបិយវត្ថុ និង ការដូរដោះ ផ្នែកសេដ្ឋកិច្ច ក្នុងពេលជាមួយគ្នានោះ ។*

(*តទៅភាគ ២*)



*សុបិន និង ការពិត ភាគ ១*- Rêves et réalités –Tome 1

# *កាលប្រវត្តិសង្ខេប*

***១២៣៨ :*** *ចៅហ្វាយខែត្រខ្មែរ នៅសុខោទ័យ បានត្រូវជនជាតិថៃ ផា មឿង និង បាងក្លាំង ថៅ (ស្រី-ឥន្ទ្រទិត្យាវរ្ម័ន ឡើងគ្រងរាជ្យ ពីឆ្នាំ ១២៣៨ ដល់ ឆ្នាំ ១២៧០) ដេញចេញពីសុខោទ័យ។ ឥន្ទ្រវរ្ម័នទី ២ (បុត្រ របស់ ជ័យវរ្ម័ន ទី ៧) ដកទ័ពចេញពីចម្ប៉ាហើយដាក់ក្សត្រចាម ជ័យបរមេស្វរវរ្ម័នទី ២ ឲ្យឡើងគ្រង រាជ្យនគរចម្ប៉ា។*

***១២៥០ :*** *សុខោទ័យ ផ្តាច់ចេញពី ចក្រភពខ្មែរ*

***១២៨៣ :*** *កងទ័ព ម៉ុងហ្គោល របស់ យូប៊ីឡៃ ខាន់ ចុលលុកលុយ រាជាណា ចក្រខ្មែរតាមព្រំដែនខាងកើត ។ ជ័យវរ្ម័ន ទី ៨ សម្រេចបញ្ជូនសួយសារអាករ ទៅ ឲ្យអធិរាជម៉ុងហ្គោល ដើម្បីចៀសវាងការប្រយុទ្ធ។*

***១២៩០ :*** *ប្រជាជន មន រំដោះខ្លួនចេញពីរាជាណាចក្រខ្មែរ។*

***១២៩៥ :*** *សុខោទ័យ រំដោះចេញពីភាពរណប នឹង ចក្រភពខ្មែរ។*

***១៣៥០ :*** *អាយុធ្យា រំដោះចេញពីចក្រភពខ្មែរ។*

***១៣៥២-១៣៥៧ :*** *សៀមចូលលុកលុយអង្គរ (ក្នុងរាជ្យស្តេចស្រី-លំពង្ស រាជា, ១៣៤៧-១៣៥៣) ។ អង្គរស្ថិតនៅក្រោមការកាន់កាប់ ជាបន្តបន្ទាប់ របស់ កូនបី នាក់ នៃ ស្តេច រាមាធិបតី ទី ១ ព្រះចៅ ក្រុងអាយុធ្យា គឺ ចៅ បាសាត (១៣៥៣-១៣៥៤) ចៅ បាអាត (១៣៥៤-១៣៥៥) និង ចៅ កំ្តបងពីសី (១៣៥៥ -៣៥៧) ។ នៅឆ្នាំ ១៣៥៧ ស្រីសុរិយោវង្ស (១៣៥៧-១៣៦៦) វាយយកអង្គរ បានវិញ។*

***១៣៩៣ :*** *សៀមវាយលុក ជាលើកទី ២។ នៅឆ្នាំ ១៣៩៤ បរមរាជា ទី ១ (ចៅ ពញា យ៉ាត) បានចាត់ឲ្យមហាត (អង្គរក្ស) ១៧ នាក់ទៅសម្លាប់ ពញាព្រែក (ក្រោមឈ្មោះ ថា ឥន្ទរាជា) គឺ កូនស្តេចសៀមដែលបានត្រូវ រាមាសួន ចាត់ឲ្យមកគ្រប់គ្រងអង្គរ។*

***១៤៣១ :*** *សៀមវាយយក អង្គរ កូរ៉ាត ចាន់តាប៊ុន ។*

***១៤៤៤ :*** *សៀមចូលលុកលុយ អង្គរ។*

***១៤៧៣ :*** *សៀមចូលលុកលុយខ្មែរទៀត។*

***១៥១២ :*** *យុនហ្វងកន បានវាយយកអំណាចពីស្តេចស្រីសុគន្ធបទ(១៥០៤-១៥១២)។*

***១៥២៥ :*** *ពញាចន្ទ (បរមរាជាទី ២ ហៅ ចន្ទរាជា) បានសម្លាប់ស្តេចកន។*

***១៥៨៣ :*** *សៀមចូលលុកលុយស្រុកខ្មែរ។*

***១៥៨៧ :*** *សង្គ្រាម រវាងខ្មែរ និង សៀម។*

***១៥៨៨ :*** *នៅឆ្នាំ១៥៨៨ នៅក្នុងរាជ្យស្តេចជ័យជេដ្ឋាទី១ បុត្ររបស់ព្រះសុត្ថា (បរមរាជា ទី ៤, ១៥៧៦-១៥៩៤) ដែលមានអាយុ ១១ ឆ្នាំ (ប៉ុន្តែ ដែលកិច្ចការ ប្រទេសស្ថិត នៅ ក្នុងដៃ ព្រះសត្ថាជដែល) សៀម បានវាយលុកម្តងទៀត ទោះបី កាលជំនាន់រាជ្យព្រះសត្ថា ស្តេចខ្មែរអង្គនេះ បានបញ្ជូនកងទ័ពខ្មែរចំនួន ២ ម៉ឺន នាក់ ទៅជួយសៀមនៅពេលដែល ទីក្រុងអាយុធ្យាច្បាំងតទល់ នឹង ភូមា រហូត ដល់ បានជ័យជំនះ ក៏ដោយ។*

***១៥៩៤ :*** *សៀមវាយយក បន្ទាយលង្វែកបាន បន្ទាប់ពី បានវាយលុក ៤ ដង (១៤៣២, ១៤៧៣, ១៥៨៣, ១៥៨៧) ក្រោយ ការលុកលុយ អង្គរ ឆ្នាំ ១៣៥២ និង ១៣៩៣ ។ ពី ១៥៩៤ រហូតដល់ពាក់កណ្តាលសតវត្សរ៍ទី ១៩ សៀមចូលមកក្នុងស្រុកខ្មែរ ៧ ដងទៀត បូករួមទាំងការវិវាទផ្សេងៗទៀត (១៦២២, ១៧១៤- ១៧១៧, ១៧៦៩-១៧៧៣, ១៧៧៩, ១៧៩៥, ១៨១១-១៨១២, ១៨៣១ -១៨៣៤) ។*





***១៧៣២ :*** *ប្រទេសវៀតណាមច្រឹបយកដីខ្មែរ ដែលសព្វថ្ងៃ គឺ មី ថូ និង វិញឡុង។*

***១៧៧៥ :*** *ប្រទេសវៀតណាម កាត់យកទឹកដីខ្មែរ ដែលសព្វថ្ងៃ ឈ្មោះ ត្រា វិញ ។*

***១៨០៦ :*** *អង្គ ចន្ទ ( ឧទ័យរាជា ) បានត្រូវស្តេចសៀមអភិសេក ជាស្តេចខ្មែរ។ អធិរាជយួន យ៉ា ឡុង បញ្ជូនប្រតិភូ ចាន់ ស៊ី ង៉ោ យកត្រាមាស រាងបួនជ្រុង ស្មើ ព្រមទាំងអ្នកបម្រើ ៥០០ នាក់ មកថ្វាយ អង្គ ចន្ទ ។*

***១៨០៨ :*** *អង្គ ចន្ទ បញ្ជូន ព្រះកែវដួង និង ឧកញ៉ាចក្រីកែប នាំសួយសារអាករ ទៅ ថ្វាយស្តេចសៀម ហើយ សុំឲ្យស្តេចសៀម អនុញ្ញាត ឲ្យព្រះអង្គម្ចាស់ អង្គ ពៅ អង្គ ម៉ែន និង អ្នកម្នាង បុប្ផាវត្តី ត្រឡប់មកស្រុកខ្មែរវិញ ។ នៅចុងឆ្នាំ ១៨០៨ នោះ អង្គ ចន្ទ បានបញ្ជូន ចៅហ៊្វា នួន ទៅចាប់ តេជោមឿង ចៅហ្វាយខេត្រ កំពង់ស្វាយ ប៉ុន្តែ តេជោមឿងភៀសខ្លួនទៅស្រុកសៀមទាន់។ ក្រោយនោះ បន្តិចនៅខែធ្នូ អង្គ ចន្ទ យាងទៅ ទីក្រុងបាងកក ហើយស្ថិតនៅក្នុងរាជធានីសៀម អស់រយៈពេល ៦ ខែ។*

***១៨១១ :*** *អង្គ ចន្ទ បញ្ជូន ឧកញ៉ាវង្សាអគ្គរាជ ឲ្យទៅចាប់ តេជោមឿង ម្តងទៀត ប៉ុន្តែ តេជោមឿងគេចបាត់សាជាថ្មីទៀត។*

***១៨១២ :*** *សៀមបញ្ជូនទ័ព មកដាក់នៅទឹកដីខ្មែរ ។ អង្គ ច័ន្ទទៅពឹងអធិរាជយួន យ៉ា ឡុងឲ្យជួយ។ សៀមបញ្ជូនទ័ពមកថែមទៀតព្រមទាំងយក អង្គ ស្ងួន មក ដាក់ប្រចាំការ នៅ ឧដុង្គផង។*

***១៨១៣ :*** *នៅដើមឆ្នាំ អង្គ ចន្ទ យាងទៅស្រុកយួន។ ថ្ងៃ ១០ មេសា : អធិ រាជយួន យ៉ា ឡុង បញ្ជាឲ្យ ឧត្តមសេនីយ៍ តា គុន ដឹកកងទ័ព តាមទន្លេ នាំ អង្គ ចន្ទ មកស្រុក ខ្មែរ។*

***១៨១៤ :*** *សៀមបញ្ជូនកងទ័ព មកដាក់នៅ ក្នុងខេត្តខ្មែរ ដែលស្ថិតនៅខាងជើង កំពង់ ស្វាយ ( ព្រែស ស្ទឹងប៉ាវ ម្លូព្រៃ និង ទន្លេ រពៅ) ។*

**១៨១៥ :** *ថ្ងៃ ១៤ ធ្នូ : យ៉ា ឡុង បេញបញ្ជា ឲ្យកេណ្ឌខ្មែរ ៤ ពាន់នាក់ ទៅឲ្យសង់បន្ទាយមួយ ដ៏ធំ នៅ «មាត់ជ្រូក» (ចូវ ឌឹក) ។ នៅឆ្នាំ ១៨១៥-១៨១៦ អធិរាជយួន យ៉ា ឡុង បានដាក់បញ្ជា ឲ្យកេណ្ឌខ្មែរ ចំនួន ៤ ពាន់នាក់ ទៅជីក ព្រែក «វិញ តេ» ។*

**១៨១៧ :** *ស្រុកខ្មែរ ត្រូវរងគ្រោះ ដោយទឹកជំនន់ បន្ទាប់ពី មាន ភាពរីងស្ងួតហួតហែង។ ទោះបី មានការខ្វះខាត ស្រូវ អង្ករ យ៉ាងណាក្ដី ប្រជាជន ត្រូវបង់ពន្ធច្រើនដដែល។ ការមិនសប្បាយចិត្ត កើតមានក្នុងនគរ។ អាចារ្យ កែ ដឹកនាំ ការបះបោរ ដេញយួនចេញពីស្រុក។*

**១៨២៤ :** *ព្រះអង្គម្ចាស់ អង្គ ស្ងួន សុគត នៅទីក្រុងបាងកក។*

**១៨៣១-១៩៣២ :** *អធិរាជយួន មីង ម៉ាង ប្រគល់សិទ្ធិឲ្យ ឧត្ដមសេនីយ៍ តា គុន ចាត់ចែងការងារ ទាំងអស់នៅស្រុកខ្មែរ។ តា គុន ប្រគល់អំណាចមួយ ចំណែកឲ្យនាម៉ឺនយោធាយួន ម្នាក់ឈ្មោះ ង្វៀង វ៉ាន់ ធុយ (ឯកសារខ្លះទៀត ថា ឈ្មោះ បា ហាវ) រៀបចំឲ្យស្រុកខ្មែរ ក្លាយទៅជា ខែត្រមួយ របស់ យួន ។ បា ហាវ ឲ្យគេកាប់ព្រៃឈើ នៅហាន់ជ័យ ហើយ សម្លាប់ អ្នកទទួលខុសត្រូវខ្មែរ នៅទីនោះ។*

**១៨៣៤ :** *<u>ថ្ងៃ ១៣ មេសា</u> : កងទ័ពយួននាំ អង្គ ចន្ទ ព្រមទាំងគ្រួសារទៅគង់ នៅរាជវាំង នៅ កោះស្លាកែត។*

**១៨៣៥ :** *អង្គ ចន្ទ ចូលជីវង្គត ។ អធិរាជយួន ដាក់ អង្គ មី ឲ្យឡើងសោយរាជ្យព្រោះ អង្គ ចន្ទ គ្មានកូនប្រុស ដើម្បីស្នងរាជ្យ។ ក្រៅពីនោះ ព្រះអង្គមាន ព្រះអនុជ ជាក្សត្រប្រុស ៣ អង្គទៀត គឺ អង្គ ស្ងួន (សុគតនៅឆ្នាំ ១៨២៤) អង្គ ឯម និង អង្គ ដួងដែលនៅខាងសៀមទាំងអស់ ។ រីឯ អង្គ ភឹម ជាព្រះអនុជប្រុស មួយអង្គទៀត ក៏សុគតបាត់តាំងពីឆ្នាំ ១៨០០ មកឯណោះ (អង្គ ភឹម ជាបុត្រ របស់ អង្គ អេង ជាមួយអ្នកម្នាងខែ។ អង្គ ស្ងួន មាន មាតាជាមួយ អង្គ ចន្ទ គឺ អ្នកម្នាងអ៊ុត។ ចំណែកមាតា របស់អង្គ*





*ដួង និង អង្គ ឯម គឺ អ្នកម្នាង រ៉ត) ។ មានក្សត្រីបួនអង្គដែលនៅក្នុងកណ្ដាប់ដៃយួន (អង្គ ប៉ែន អង្គ ពៅ អង្គ មី និង អង្គស្ងួន)។ អធិរាជយួន ចង់ឲ្យអង្គ ប៉ែន រៀបការជាមួយក្សត្រយួន ទ្រឿង គុន ប៉ុន្ដែ ដោយ អង្គ ប៉ែន ពុំព្រម ក៏ដាក់ អង្គ មី ដែលកាលនោះ មានអាយុ ២០ ឆ្នាំឲ្យគ្រងរាជ្យវិញ។ អំណាចទាំងអស់ ស្ថិតនៅក្នុង កណ្ដាប់ដៃទីក្រុង វ៉េ។ ទ្រឿង មិញ យ៉ាង ដែលជាអ្នកចាត់ការ គ្រប់គ្រងស្រុកខ្មែរ បាននាំប្រជាជន ស៊ីវិលយួន ឲ្យមកតាំងទី បន្ថែមទៀតនៅស្រុកខ្មែរ។*

**១៨៣៦ :** *ការបះបោរ ដឹកនាំដោយ នង នៅ កំពង់ស្វាយ ។ ទ្រឿង មិញយ៉ាង បញ្ជូនទ័ពមកទប់ទល់។*

**១៨៣៧ :** *នាម៉ឺនខ្មែរ ពីរនាក់ គឺ ជូ និង ជ័យ ដែលក្ដាប់ខែត្រ កំពង់សោម មិនព្រមស្ដាប់បង្គាប់យួន ។ ទ្រឿង មិញ យ៉ាង តាមចាប់ មេបះបោរ ទាំងពីរនេះ ប៉ុន្ដែ ជូ និង ជ័យរត់ទៅស្រុកសៀម តាមកប៉ាល់បាត់ទៅ ។ នៅឆ្នាំនោះដែរ ទ្រឿង មិញ យ៉ាង ប្រើ ឧបាយកលមួយ ដើម្បីបំបែកបំបាក់ ក្សត្រខ្មែរពីរអង្គ ដែលនៅខាង សៀម គឺ អង្គ ឯម និង អង្គ ដួង។ អង្គ ឯម នៅស្រុកសៀម ហើយ អង្គ ដួង នៅ ស៊ីសុផុន។ ទ្រឿង មិញ យ៉ាង បញ្ជូន នារសារ ឲ្យយកសំបុត្រមួយ ទៅថ្វាយ អង្គ ឯម ប្រាប់ថា ទីក្រុងវ៉េ មានគោលបំណង លើក អង្គ ឯម ឲ្យឡើង សោយរាជ្យនៅស្រុកខ្មែរ ជំនួស អង្គ មី ។ មកដល់ ស៊ីសុផុន នារសារ របស់ ទ្រឿង មិញ យ៉ាង និយាយប្រាប់ អង្គ ដួង ដូចដែលគេបានប្រាប់ អង្គ ឯម ដូច្នេះដែរ។ អង្គ ដួង យល់ថា ជាកលល្បិច របស់ យួន ប៉ុន្ដែ អង្គ ឯម ជឿ ថា យួន មានគោលបំណងល្អ ដូច្នេះមែន។ ក្រោយមក អង្គ ឯម មកស្រុកខ្មែរ តែត្រូវ ទ្រឿង គុន ចាប់បញ្ជូន ទៅដាក់គុក នៅស្រុកយួន រហូត ដល់ក្ស័យជីវិត (†១៨៤៣)។*

**១៨៤០ :** *<u>ខែកញ្ញា</u> :យួនចាប់ព្រះអង្គម្ចាស់ក្សត្រីខ្មែរទាំង ៤ អង្គ គឺ អង្គ ប៉ែន អង្គ មី អង្គ ពៅ និង អង្គ ស្ងួន បញ្ជូនទៅដាក់គុក នៅស្រុកយួន ។ រីឯ មូលហេតុ គឺ បណ្ដាល*

មក ពី អង្គ ប៉ែន បានសរសេរសំបុត្រ ទៅប្រាប់អ្នកម្នាងទេព ជាម្ដាយ នៅបាងកក អំពីការដែល យួនធ្វើបាប យ៉ាងខ្លាំង។ អ្នកម្នាងទេពសុំឲ្យ អង្គ កែវ ម៉ា ទៅជួយរំដោះ អង្គ ប៉ែន ប៉ុន្តែ ដោយបែកការដឹងដល់យួនៗ ក៏ ចាប់ក្សត្រទាំង ៤ អង្គ ទៅដាក់គុកនៅស្រុកយួនតែម្ដង។ ប្រទេសវៀតណាម ច្រឹបយកដីខ្មែរ សុកត្រាង។

**១៨៤៧** : រាជាភិសេកព្រះបាទ អង្គ ដួង នៅចំពោះមុខអ្នកតំណាងទីក្រុង វេ៉ និងអ្នកតំណាងទីក្រុងបាងកក។ ការប្រគល់ ទឹកដី មូព្រៃ ទន្លេរពៅ និង ទឹកដី មួយចំនួនទៀត ដែលថៃបានកាត់យកទៅ មកឲ្យខ្មែរវិញ។

**១៨៤៧** :(១ សីហា) បារាំង ទម្លាក់គ្រាប់បែក ទៅលើ ទូរ៉ានៗ នៅ ប្រទេសកម្ពុជា ជនជាតិ ចាមនៅខេត្តត្បូងឃ្មុំ ងើបឡើងបះបោរ។

**១៨៤៨** : ព្រះអង្គម្ចាស់ អង្គ ភឹម (កូន របស់ អង្គ ឯម) ចូលជីវង្គត ។ <u>វប្បធម៌</u> : ឧកញ៉ាធិបតីយ៉ែម និពន្ធរឿង *វិមានចន្ទ* ។ ពញាវិជិត្រស្រី និពន្ធ *ល្បើកស្រីវិជ័យ* ។

**១៨៥៤** : ព្រះបាទ អង្គ ដួង ផ្ញើលិខិតមួយទៅ ព្រះចៅអធិរាជបារាំង ណាប៉ូឡេអុង ទី ៣ ដើម្បីចងមេត្រីភាព ជាមួយបារាំង។

**១៨៥៦** : អរិយគាមនី ហ៊ីង និពន្ធ រឿង «*ព្រះជិនវង្ស*» ។

**១៨៥៦** : (ខែសីហា) ភ្នាក់ងារទូត ពេញសមត្ថភាព បារាំងម្នាក់ បានមកដល់ កំពត ។ អនុសញ្ញាសម្ងាត់ រវាង ព្រះបាទ អង្គ ដួង និង បារាំង លេចឮទៅដល់ស្ដេចសៀម។ ផែនការបម្រុង ដាក់អាណាព្យាបាល បារាំង នៅឆ្នាំនោះឯង ត្រូវអាក់ខាន ព្រោះតែខ្វះការប្រុងប្រយ័ត្ន ពី សំណាក់ រដ្ឋមន្ត្រី បារាំងម្នាក់ ។

**១៨៥៧** : ខ្មែរ នៅ តាយ និញ ងើបបះបោរ ។ <u>វប្បធម៌</u> : ធម្មបញ្ញា ម៉ែន និពន្ធ រឿង *ពេជតា* ។





**១៨៥៩** : ជនជាតិចាមដែលបានទៅជ្រកកោន នៅ ចូវ ឌឹក នាំគ្នាបង្កទ័ពប្រដាប់ អាវុធ ហើយឡើងមកទីក្រុងភ្នំពេញ ដើម្បីរំដោះជនជាតិចាមដូចគ្នា ដែលត្រូវគេ ដាក់ឃុំឃាំង ។

**១៨៥៩** : កងទ័ពខ្មែរ ដែលធ្វើប្រតិបត្តិការនៅ ចូវ ឌឹក បានបញ្ឈប់ប្រតិបត្តិការ របស់គេ ព្រោះព្រះមហាក្សត្រខ្មែរ ព្រះបាទ អង្គ ដួង ចូលជីវង្គត។ ឧកញ៉ា កែប នាំកងទ័ព ត្រឡប់មកស្រុកខ្មែរវិញ។ <u>វប្បធម៌</u> : ឧកញ៉ា សន្ធរ ម៉ុក និពន្ធ *រឿងទេវន្ត* និង *ល្បើកបបក* ។

**១៨៦១** : (ខែ មិនា) ឧត្តមនាវី បារាំង សាកនែរ (Charner) ដែលកាន់បញ្ជាការ នៅសាយហ្គន (Saïgon) បានបញ្ជូន លោក ឌូដា ដឺ ឡាគ្រេ ទៅទីក្រុង ឧដុង្គ ដើម្បី ចងមេត្រីភាព ជាមួយ ស្ដេចខ្មែរ ក្នុងគោលដៅ ផ្ដាច់ប្រទេសកម្ពុជា ចេញពីអំណាច ឥទ្ធិពលសៀម។ <u>ខែ សីហា</u> : ស្ដេចនរោត្តម យាងទៅ ខែត្របាត់ដំបង ដោយនាំ ព្រះខ័នរាជ្យទៅជាមួយផង ។ បន្ទាប់មក ព្រះអង្គ យាងទៅ ប្រទេសសៀម។

**១៨៦២** : <u>(ខែ មិនា )</u> ស្ដេច នរោត្តម ត្រឡប់មក ឧដុង្គវិញ ។ <u>(ខែ មេសា)</u> : ឌូដា ដឺ ឡាគ្រេ មកដល់ កំពង់ហ្លួង តាមកប៉ាល់។ គោលដៅ :ជួបស្ដេច នរោត្តម ម្ដងទៀត។

**១៨៦៣** <u>: (ខែ មិនា)</u> ហ្លួង នរោត្តម ឲ្យខែត្រពោធិសាត់ និង កំពង់ស្វាយទៅសៀម។ <u>(ខែកក្កដា)</u> : ឧត្តមនាវី ដឺ ឡាក្រង់ឌីយែរ (De La Grandière) ធ្វើដំណើរមកកំពង់ហ្លួង។

**១៨៦៣** : <u>(ថ្ងៃ ១១ សីហា)</u> : ការចុះហត្ថលេខា ទៅលើ «សន្ធិសញ្ញាអាណាព្យាបាលបារាំង» ។

**១៨៦៤** <u>(ថ្ងៃ ៣ ខែ មិថុនា)</u> រាជាភិសេក ស្ដេចនរោត្តម (ទី ១) ។

**១៨៦៥** : ការបះបោរដឹកនាំ ដោយពោធិកំបោរ (រហូតដល់ឆ្នាំ ១៨៦៧) ។ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មកគង់ នៅសាយហ្គន ដើម្បីជួយបារាំង បង្ក្រាបពោធិកំបោរ។

**១៨៦៦** : ព្រះបាទ នរោត្តម បោះបង់ ទីក្រុងឧដុង្គ ហើយ មកតាំងរាជធានី នៅ ចតុមុខវិញ ។

**១៨៦៧** : (១៥ កក្កដា) សន្ធិសញ្ញាបារាំង-សៀម។ ទីក្រុងបាងកក សុខចិត្ត បោះ បង់ការគ្របដណ្តប់ទៅលើប្រទេសកម្ពុជា ប៉ុន្តែ ទាមទាររក្សាទុកខេត្ត ៣ របស់ ខ្មែរ ដែលសៀមបានផ្តាច់យកទៅ។

**១៨៧៧** : ធម្មបញ្ញា អ៊ុក និពន្ធរឿង *មរណមាតា* ចប់សព្វគ្រប់ ។ ទាសភាព បានត្រូវលុបចោល។

**១៨៨១** : បវរកក្តី ព្រហ្ម និពន្ធ *សាស្ត្រាពោធិវង្ស* ចប់សព្វគ្រប់ ។

**១៨៨២** : ឧកញ៉ា វង្សាធិបតី អ៊ុក និពន្ធរឿង *សង្ខសិល្បជ័យ* ចប់សព្វគ្រប់ (យោងតាមឯកសារ របស់ លោក លី ធាម តេង)។

**១៨៨៤** : អនុសញ្ញាបារាំង-ខ្មែរ ចុះថ្ងៃ ១៧ មិថុនា ពង្រឹង អំណាច អាណាព្យាបាលបារាំង ដោយដកអំណាចពីស្តេចខ្មែរ ព្រះបាទនរោត្តម។

**១៨៨៥ – ១៨៨៦** : មហាកុបកម្ម ទូទាំងប្រទេស ប្រឆាំង នឹង បារាំង។

**១៨៨៦** : បារាំង បង្កើត «រ៉េស៊ីដង់ » នៅភ្នំពេញ និង នៅតាមខេត្ត ចំនួន ៤: កំពត កំពង់ធំ ក្រចេះ ពោធិសាត់។

**១៩៨៧** : យ៉ុន សន្ធរពិនិត្យ និពន្ធរឿង *ចៅ មាស* ។

**១៨៨៩** : សុត្តន្តប្រីជាឥន្ទ និពន្ធរឿង *អំបែងបែក* ចប់សព្វគ្រប់ ។

**១៨៩០** : រឿង *ព្រះលក្ខណវង្ស* បានត្រូវរៀបរៀង ចប់សព្វគ្រប់ ដោយ ចៅ អធិការវត្តព្រែកប្រណាក។

**១៨៩១** : ការបង្កើត ឲ្យមានឃ្លាំងប្រាក់តែមួយ នៅក្នុងរាជាណាចក្រ។

**១៨៩៧** : <u>នៅ ថ្ងៃ ៩ និង ១០ មករា</u> **:** រ៉េស៊ីដង់បារាំង ដឺ វែរណឺវិល (de Verneville) ដកយកអំណាច ពីស្តេចនរោត្តម ដោយកម្រោល។ <u>នៅ ខែ កក្កដា</u> ឆ្នាំ ដដែល





ដឺ វែរណឺវិល បានត្រូវផ្លាស់ចេញហើយជំនួសដោយអាឡេចសង់ដ្រ៏ ឌុយកុស (Alexandre Ducos)។ <u>(ខែ មិនា)</u> **:** ឌូមែរ បានត្រូវតែងតាំង ជាអគ្គទេសាភិបាលឥណ្ឌូចិន។ ឌូមែរ (Doumer) បានទទួលការអនុញ្ញាត ពីព្រះបាទ នរោត្តម ដើម្បីធ្វើការកែទម្រង់ (រាជក្រឹត្យថ្ងៃ ១១ កក្កដា)។ ចាប់តាំងពីពេលនោះ មក ប្រទេសកម្ពុជា ស្ថិតនៅក្រោមការដឹកនាំផ្ទាល់ របស់ បារាំង រហូតដល់ ឆ្នាំ ១៩៤៥ ។

**១៨៩៩** : ម៉ឺនកក្តីអក្សរ គន់ និពន្ធ រឿង *សព្វសិទ្ធិ* ។ អ្នកស្រីសិទរៀបរៀងរឿង *ពិគ្គាពិលាប* ។

**១៩០០** : ព្រះអង្គម្ចាស់ នរោត្តម យុគន្ធរ បុត្រ របស់ព្រះបាទ នរោត្តម យាងទៅទីក្រុងបារីស៍ដើម្បីចូលរួម ក្នុងពិធីបុណ្យ ពិពណ៌អាណានិគម ។ ព្រះអង្គឆ្លៀតឱកាសនោះ ដើម្បីតវ៉ាប្រឆាំង នឹង អនុសញ្ញាឆ្នាំ ១៨៩៧ ។ នៅឆ្នាំនោះដែរ ឌុយ កុស បិទបនល្បែង។

**១៩០៤** : ព្រះបាទ នរោត្តម ចូលជីវង្គត (២៥ មេសា) ។

**១៩០៦** <u>: (២៧ មេសា)</u> រាជាភិសេក ស្តេច ស៊ីសុវត្ថិ ។

**១៩០៧** : សៀមប្រគល់ខេត្ត បាត់ដំបង ស៊ីសុផុន សៀមរាបមកឲ្យខ្មែរវិញ តាមរយៈសន្ធិសញ្ញា បារាំង-សៀម ថ្ងៃ ២៣ មិនា។

**១៩០៩** : ការងើបឡើងបះបោរ របស់ វិសេសញូ <u>(១០ កុម្ភៈ-២៩ មិនា)</u> ។

**១៩១១** : <u>(៨ តុលា)</u> អ៊ែរណេស អ៊ូត្រី បានត្រូវតែងតាំងជា រ៉េស៊ីដង់។

**១៩១២** : ក្រមព្រហ្មទណ្ឌ បានត្រូវ អនុម័ត ។

**១៩១៣** : ការបះបោររបស់ អ៊ុច នៅ កំពុងស្វាយ និង បារាយណ៍ (ចេញរាតត្បាតយូរៗ ម្តង រហូតដល់ ឆ្នាំ ១៩១៦)។

**១៩១២-១៩១៣** : *បារាំងចាប់ផ្ដើម រៀបចំ រដ្ឋបាល ប្រទេសកម្ពុជា ដោយយករដ្ឋបាល បារាំង ធ្វើជាគំរូ។*

**១៩១៤** : *(៣១ មករា) ការបង្កើតសាលាក្រមការ ។ សាលានេះ បានក្លាយទៅជា សាលារដ្ឋបាល នៅឆ្នាំ ១៩១៧។*

**១៩១៦** : *(៦ មករា) បាតុកម្ម ប្រជាកសិករ រយៈពេលជាងមួយខែ ប្រឆាំង នឹង ការជិះជាន់សង្កត់សង្កិន របស់ពួកអាណានិគម។ បាតុកម្មនេះ បានដង្ហែក្បួនយ៉ាងគគ្រឹកគគ្រេង មក ដល់ ទីក្រុងភ្នំពេញ។* 

**១៩២០** : *ការបង្កើត សាលាបាលី ។ នូ កន និពន្ធរឿង ពិម្ពានិព្វាន ចប់។ សុត្តន ប្រីជាឥន្ទ និពន្ធ គតិលោក ចប់។*

**១៩២១** : *ការបង្កើត បណ្ណាល័យមួយ នៅភ្នំពេញ។ នៅថ្ងៃ ១៥ មករាឆ្នាំ ១៩២៥ បណ្ណាល័យនេះ ក្លាយទៅជា បណ្ណាល័យជាតិ ។*

**១៩២៤** : *ថ្ងៃ ៨ វិច្ឆិកា : កវី សត្ថន្តប្រីជាឥន្ទ ទទួលមរណភាព ។*

**១៩២៧** : *ព្រះបាទ ស៊ីសុវត្ថិ ចូលទីវង្គត (៩ សីហា) ។*

**១៩២៨** : *(ថ្ងៃ ២៣ កក្កដា) រាជាភិសេកព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស។*

**១៩៣០** : *ការសម្ពោធ វិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ ។ ហូ ជីមិញ បង្កើតបក្ស កុម្មុយនិស្តឥណ្ឌូចិន។*

**១៩៣៣** : *លោក គឹម ហាក់ និពន្ធរឿង សេកសោមបណ្ឌិត ។*

**១៩៣៦** : *សឺន ង៉ុក ថាញ់ បង្កើតកាសែត នគរវត្ត ជាមួយ ប៉ាច ឈឺន។ ថ្ងៃ ៥ ឧសភា : កូដកម្ម សិស្សវិទ្យាល័យ ស៊ីសុវត្ថិ។ លោក ញ៉ុក ថែម ចេញ ផ្សាយរឿង*





*កុលាបប៉ៃលិន ។ កវី ក្រម ង៉ុយ ទទួលអនិច្ចកម្មនៅឆ្នាំ ១៩៣៦ នៅក្នុងជន្មាយុ ៧១ ឆ្នាំ។*

**១៩៣៨** : *លោក រីម គីន និពន្ធរឿងសុផាត ។*

**១៩៤០** : *ទីក្រុងបាងកក ទាមទារឲ្យបារាំង ប្រគល់ ទឹកដីខ្មែរ និង ទឹកដី លាវ មួយភាគទៅឲ្យខ្លួន។ (ថ្ងៃ ១ ធ្នូ) រដ្ឋាភិបាលថៃ សម្រេច វាយលុក ស្រុកខ្មែរ តាម ការ ជំរុញ របស់ ជប៉ុន ។ បរាជ័យ នៃ កងទ័ពជើងគោកបារាំង ។ នៅ ខែ ធ្នូ នោះដែរ ប៉ុក យុន បង្កើត ចលនាឥស្សរៈខ្មែរ នៅទីក្រុងបាងកក។*

**១៩៤១** : *(ខែ មករា) : ជ័យជំនះ នៃកងទ័ពនាវាចរបារាំង ទៅលើកងទ័ព នាវាចរថៃ។ ថ្ងៃ ២៣ មេសា : ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស ចូលទីវង្គត ។ ឧត្តម នាវី ស្ហង់ ដឺគូ* (Jean Decoux) *អ្នកតំណាងបារាំង នៅកម្ពុជា បានជ្រើសរើស ព្រះអង្គម្ចាស់ នរោត្តម សីហនុ ដើម្បីស្នងរាជ្យបល្ល័ង្កមុនីវង្ស ដែលជាព្រះអយ្យកោ។ ថ្ងៃ ៩ ឧសភា : ការចុះហត្ថលេខា ទៅលើអនុសញ្ញា បារាំង-សៀមនៅទីក្រុងតូក្យូ។ តាមរយៈអនុសញ្ញានោះ បារាំងប្រគល់ ខេត្តសៀមរាប កំពង់ធំ និង ស្ទឹងត្រែង ទៅឲ្យថៃ ។ ថ្ងៃ ២៩ កក្កដា : តាមរយៈ កិច្ចព្រមព្រៀង ដាកឡង់ កាតូ ជប៉ុន មកតាំងទី នៅកម្ពុជា ។ ថ្ងៃ ២៨ តុលា : ពិធី រាជាភិសេក ព្រះមហាក្សត្រខ្មែរ ព្រះបាទ នរោត្តម សីហនុ។*

**១៩៤២** : *ថ្ងៃ ១៨ កក្កដា : អាចារ្យ ហែម ចៀវ និង លោក នួន ឌួង ត្រូវ បារាំង ចាប់ខ្លួនដោយអ្នកទាំងពីរនេះ បានធ្វើការឃោសនា ប្រឆាំងបារាំង ដល់ទាហានខ្មែរ នៅ ក្នុងកងទ័ពបារាំង។ នៅ ថ្ងៃ ២០ កក្កដា : ក្រោមការដឹកនាំ របស់ សឺន ង៉ុក ថាញ់ ការបះបោរ ប្រឆាំងបារាំងមួយ ដ៏ធំ ផ្ទុះឡើងនៅចំកណ្ដាល ទីក្រុងភ្នំពេញ។ បាតុករ ២ ពាន់នាក់ នៅក្នុងនោះ ព្រះសង្ឃ ៥ រយអង្គ បានត្រូវចាប់ខ្លួន។ អាចារ្យ ហែម ចៀវ, នួន ឌួង, ប៊ុន ចាន់ ម៉ុល ត្រូវបារាំងចាប់ យកទៅដាក់គុក នៅកោះត្រឡាច រីឯ សឺន ង៉ុក ថាញ់ បានរត់ ទៅដល់ ទីក្រុងតូក្យូ នៅថ្ងៃ ២៦ ធ្នូ ដោយឆ្លងកាត់ ទីក្រុងបាងកក ។*

វប្បធម៌: នូ កន បោះពុម្ព ផ្សាយរឿង ទាវឯក ។ លោក ញ៉ុក ថែម បេញផ្សាយ រឿង បិសាចស្នេហា ។

**១៩៤៥** :ថ្ងៃ ៧ កុម្ភ: : យន្តហោះ បេ ២៩ នៃ សម្ព័ន្ធមិត្ត បារាំង-អាមេរិក ទម្លាក់គ្រាប់បែក ទៅលើវត្តឧណ្ណាលោម នៅទីក្រុងភ្នំពេញដើម្បីកំទេចទីតាំង របស់ជប៉ុន។ ព្រះសង្ឃ ២០ អង្គ ត្រូវបាត់បង់ជីវិត ។ គឺ នៅពេលនោះហើយដែល ទូ សាមុត រត់ទៅ ប្រទេសវៀតណាម ហើយ បន្ទាប់មក ក្លាយទៅជាសមាជិក បក្សកុម្មុយនិស្តឥណ្ឌូចិន។ ថ្ងៃ ៩ មិនា : កងទ័ពជប៉ុនក្តាប់ឥណ្ឌូចិន។ ពួកគេបានចាប់បារាំង យកទៅឃុំឃាំងអស់។ នៅទីក្រុងភ្នំពេញ នៅថ្ងៃ ១២ មិនា ព្រះមហាក្សត្រខ្មែរព្រះបាទនរោត្តម សីហនុ ប្រកាស ឯករាជ្យខ្មែរ តាមបញ្ជា របស់ ជប៉ុន ។ ថ្ងៃ ២៤ មិនា : ឧត្តមសេនីយ៍ ដឺ ហ្គោល ប្រកាសបញ្ចូល ឥណ្ឌូចិន ទៅក្នុងសហភាពបារាំង។ ថ្ងៃ ៣០ ឧសភា : សឺន ង៉ុក ថាញ់ ត្រឡប់មកស្រុកខ្មែរវិញ ហើយបានត្រូវតែងតាំងជា រដ្ឋមន្ត្រីការបរទេស។ នៅ ខែ មិថុនា ពួកឥស្សរៈខ្មែរ បាននាំគ្នាបង្កើតចលនា របស់ គេមួយ នៅក្នុងខែត្របាត់ដំបង។ ថ្ងៃ ១៤ សីហា សឺន ង៉ុក ថាញ់ បានត្រូវតែងតាំង ជានាយករដ្ឋមន្ត្រី។ ថ្ងៃ ១៥ សីហា : ប្រទេសជប៉ុន ប្រកាសចុះចាញ់សង្គ្រាម បន្ទាប់ ពី សហរដ្ឋ អាមេរិក បានទម្លាក់ គ្រាប់ បែកបរមាណូ ទៅលើ ហៀរ៉ូស៊ីម៉ា នៅថ្ងៃ ៦ សីហា និង ណាហ្កាសា គឺ នៅថ្ងៃ ៩ សីហា ។ ថ្ងៃ ២៨ កញ្ញា : ព្រះបាទ នរោត្តម សីហនុ ផ្ញើលិខិតមួយទៅឧត្តមនាវីបារាំង ជែរី ដាកស្កង់ លីយើ (Theirry d’Argenlieu)) ដើម្បីធ្វើការចរចា ពី ឯករាជ្យខ្មែរ ។ ថ្ងៃ ១ តុលា : ឧត្តមសេនីយ៍បារាំង ឡឺ ក្លែរក៏ មកដល់ ទីក្រុងសាយហ្គន។ ថ្ងៃ ៨ តុលា : កងទ័ពសម្ព័ន្ធមិត្ត អង់គ្លេស ចូលមកក្នុងប្រទេសកម្ពុជា ។ ថ្ងៃ ១៥ តុលា : បារាំង ចាប់ សឺន ង៉ុក ថាញ់ រួបបញ្ជូនទៅដាក់គុក នៅ ប្រទេសបារាំង ។ ថ្ងៃ ១៧ តុលា : បារាំង តែងតាំង រដ្ឋាភិបាល ទ្រង់ស៊ីសុវត្ថិ មុនីរ៉េត។





**១៩៤៦** : (៧ មករា) :ការចុះហត្ថលេខា ទៅលើកិច្ចព្រមព្រៀងសម្រុះសម្រួល សិន (modus vivendi) រវាង បារាំង និងខ្មែរ។ ១ កញ្ញា) : ការបោះ ឆ្នោតសភា។ វប្បធម៌ : លោក អ៊ឹម ហ៊ី បេញផ្សាយរឿង មហាអភ័ព ។ ខែ មករា ៖ កំណើត សមាគមនិស្សិត ខ្មែរ អា អឺ កា (A.E.K.) ដឹកនាំដោយ លោក អៀវ ស៊ី ចូវ ។ ខែ មេសា : លោក ស៊ិម វ៉ា លោក ឈាន វ៉ម និង លោក អៀវ កឺះ បង្កើតគណបក្សប្រជាធិបតេយ្យ (គណបក្សនយោបាយ ទី ១ បង្កើតដោយ បញ្ញវន្តខ្មែរ) ។ (ខែ មិថុនា) : អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស ត្រឡប់មកស្រុកខ្មែរ។ ថ្ងៃ ៧ សីហា : ក្រុមខ្មែរឥស្សរៈ ដឹកនាំ ដោយ ដាប ឈួន អ្នកអង្គម្ចាស់ នរោត្តម ចន្ទរង្សី និង សឺន ង៉ុក មិញ នាំគ្នាមកតាំងទី ចំនួន ៦ ថ្ងៃ នៅសៀមរាប-អង្គរ។ បារាំង ៧ នាក់ បាត់បង់ជីវិត។ (ថ្ងៃ ១ កញ្ញា); ការបោះឆ្នោត តាមបែបបទ ប្រជាធិបតេយ្យ លើកដំបូងបង្អស់ នៅក្នុង ប្រវត្តិសាស្ត្រ ខ្មែរ។ ១៧ វិច្ឆិកា : អនុសញ្ញាទីក្រុងតូក្យូ ឆ្នាំ ១៩៤១ បានត្រូវ ចាត់ទុក ជាមោឃៈ។ ថ្ងៃ ១៥ ធ្នូ : រដ្ឋាភិបាល ទ្រង់យុត្តិវង្ស។

**១៩៤៧** : ថ្ងៃ ៦ឧសភា : ការប្រកាសឲ្យប្រើ រដ្ឋធម្មនុញ្ញខ្មែរលើកដំបូងបង្អស់។ ថ្ងៃ ១១ កក្កដា អ្នកអង្គម្ចាស់យុត្តិវង្សចូលជីវង្គត។ ថ្ងៃ ២៥ កក្កដា : រដ្ឋាភិបាល អ្នកអង្គម្ចាស់ វ៉ឌ្ឍាយាវង្ស ។ ថ្ងៃ ២១ ធ្នូ : ការបោះឆ្នោតសភា ។ គណបក្ស ប្រជាធិបតេយ្យ បាន ទទួលជោគជ័យ ដោយបានទទួលសំឡេង ច្រើនលើសលុប។ វប្បធម៌ : លោក នូ កន បេញផ្សាយ រឿងតុងឈិន ។ លោក នូ កន ទទួលមរណភាពនៅ ឆ្នាំ ១៩៤៧ នៅ កំពង់ចាម។

**១៩៤៨** : ២ មករា : រដ្ឋាភិបាល ឈាន វ៉ម។ ថ្ងៃ ១ កុម្ភ: :ខ្មែរឥស្សរៈបង្កើត គណ កម្មាធិការ រំដោះប្រជាជនខ្មែរ នៅខែត្របាត់ដំបង។ គណកម្មាធិការ នោះ ដែលដឹកនាំ ដោយ ដាប ឈួន មានគ្នា ៨០០ នាក់ ។ ថ្ងៃ ១៥ សីហា :រដ្ឋា កិបាល ប៉ែន នុត ។

**១៩៤៩** : ខែកុម្ភៈ : គណកម្មាធិការរំដោះប្រជាជនខ្មែរ បានត្រូវប្តូរឈ្មោះ មក ជាគណកម្មាធិការ ជាតិខ្មែរ រំដោះប្រជាជន ដែលមាន ប៉ុក ឃុន ជាអ្នកដឹកនាំ ។ ថ្ងៃ ១២ កុម្ភៈ : រដ្ឋាភិបាល យ៉ែម សំបូ។ ពី ខែមិនា ទៅ ខែ មិថុនា : ការបែកបាក់ ពួកខ្មែរឥស្សរៈ។ ថ្ងៃ ៤ មិថុនា : កម្ពុជាក្រោម បានត្រូវរដ្ឋាភិបាលអាណានិគម បារាំង ប្រគល់ទៅឲ្យវៀតណាមដោយគ្មានការយល់ព្រម ពី ខ្មែរ កម្ពុជាក្រោម។ ថ្ងៃ ១៨ កញ្ញា : ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ រំលាយ រដ្ឋសភា ។ រដ្ឋាភិបាល លោក អៀវ កើះ ទទួលការខុសត្រូវ តែនៅចំពោះមុខ ព្រះមហាក្សត្រប៉ុណ្ណោះ ។ ២៩ កញ្ញា : រដ្ឋាភិបាល លោក យ៉ែម សំបូ ។ ថ្ងៃ ១ តុលា : មេឥស្សរៈ ដាប ឈួន ចុះចូលរាជរដ្ឋាភិបាល។ ថ្ងៃ ៨ វិច្ឆិកា : ការចុះហត្ថលេខា ទៅលើសន្ធិសញ្ញា បារាំង-ខ្មែរ ទទួលស្គាល់ប្រទេសកម្ពុជា ជា រដ្ឋឯករាជ ប៉ុន្តែដែលស្ថិតនៅក្នុងសហភាពបារាំង ។ តាមរយៈសន្ធិសញ្ញានោះ ប្រទេសកម្ពុជាមិនបោះបង់សិទ្ធិ របស់ ខ្លួន លើទឹកដី កូសាំងស៊ីន ឡើយ ។ វប្បធម៌ : ការចេញផ្សាយ ប្រលោមលោក *ផ្កាស្រពោន* របស់ លោក នូ ហាច ជា លើកដំបូង បន្ទាប់ពីស្នាដៃនេះ បានត្រូវចេញ ជា ភាគនិទាន នៅក្នុងទស្សនាវដ្តី ប្រចាំសប្តាហ៍ *កម្ពុជា* នៅឆ្នាំ ១៩៤៧។

**១៩៥០** : ថ្ងៃ ១៤ មករា : លោក អៀវ កើះ អ្នកដឹកនាំ គណបក្សប្រជាធិបតេយ្យ និង ជា ប្រធានរដ្ឋសភា បានត្រូវគេធ្វើឃាត ។ ថ្ងៃ ១១ -១២ មិនា : សិក្ខាសាលា នៅ ហាទៀង នៃ គណប្រតិកូខ្មែរកុម្មុយនិស្ត ដែលមាន សឺន ង៉ុក មិញ ជាអ្នកដឹកនាំ និង គណប្រតិកូវៀតណាមកុម្មុយនិស្ត ដឹកនាំដោយ ឡែ ឌឹក ថូ។ ថ្ងៃ ១៧-១៩ មេសា : មហាសន្និបាត នៃអ្នកតស៊ូខ្មែរ ក្រោមការដឹកនាំ របស់ សឺន ង៉ុក មិញ ដើម្បីបង្កើត រណសិរ្សរួម ខ្មែរឥស្សរៈ ។ គឺ ជារណសិរ្សមួយបែប ដែលមាន លក្ខណៈដូចជា រដ្ឋាភិបាលមួយដូច្នេះដែរ គឺមាន សឺន ង៉ុក មិញ ជាប្រធាន ចាន់ សម័យ អនុប្រធាន សៀវ ហេង អនុប្រធាន និង ជារដ្ឋមន្ត្រី ការពារជាតិ ទូ សាមុត អនុប្រធាន។ រី ឯ អ្នកដឹកនាំ សំខាន់





មាន ពីរនាក់ គឺ សឺន កឿក រតនា និង នង សួន ។ ថ្ងៃ ៣ ឧសភា : រដ្ឋាភិបាល ដឹកនាំជាបណ្តោះអាសន្ន ដោយព្រះមហាក្សត្រ ។ ថ្ងៃ ១ មិថុនា : រដ្ឋាភិបាល មុនីពង្ស ។ ថ្ងៃ ១៩ មិថុនា: និស្សិតខ្មែរ នៅទីក្រុងប៉ារីស៍ បង្កើតក្រុមម៉ាក្សនិយមមួយ។ សមាជិក នៃក្រុមនេះ មានជាអាទិ៍ : អៀង សារី, ខៀវ ធិប្ញទ្ធ, ហ៊ូ យន់, កេង វ៉ាន់សាក់, ជួន មុម្ម, សាឡុត ស, មុី ម៉ាន់ មុី ផាត, រត្ន សាមឿន ។

**១៩៥១** : (១ មករា) : រដ្ឋាភិបាល មុនីពង្ស។ ថ្ងៃ ៨ កុម្ភៈ :កម្មាភិបាលខ្មែរ ៩ រូប នៃបក្សកុម្មុយនិស្តឥណ្ឌូចិន ប្រជុំជាមួយ ឡែ ឌឹក ថូ ហើយសម្រេចបង្កើត បក្ស ប្រជាជនបដិវត្តខ្មែរ ។ ថ្ងៃ ៣ មិនា : រដ្ឋាភិបាល អ៊ុម ឈាងស៊ុន ។ ថ្ងៃ ១៤ ឧសភា : រដ្ឋាភិបាលទី ២ របស់ អ៊ុម ឈាងស៊ុន។ ថ្ងៃ ២៩ តុលា : សឺន ង៉ុក ថាញ់ ត្រឡប់មកស្រុកខ្មែរវិញ បន្ទាប់ពីជាប់គុក នៅស្រុកបារាំង អស់រយៈពេល ជាង ៥ ឆ្នាំ ។ នៅថ្ងៃ ២៩ តុលា ដដែលនោះ លោក ស្សង់ ដឺ រ៉ៃម៉ុង (Jean de Raymond) រ៉េស៊ីដង់ស៊ុបេរីយ៉េរ បារាំង នៅភ្នំពេញ បានត្រូវ អ្នកបម្រើ យួន ធ្វើឃាត ។ ទំនាក់ទំនង រវាងអាជ្ញាធរ បារាំង និង រដ្ឋាភិបាល ប្រជាធិបតេយ្យខ្មែរ ស្ថិតនៅក្នុងភាពតានតឹង ។ នៅទីក្រុងប៉ារីស៍ ហ៊ូ យន់ ត្រូវបានជ្រើសតាំងជាប្រធាន សមាគមនិស្សិត អា អឺ កា ( A.E. K.) ។

**១៩៥២** : (ថ្ងៃ ១១ មករា) សឺន ង៉ុក ថាញ់ បង្កើតកាសែត «ខ្មែរក្រោក» ។ គឺ នៅឆ្នាំ ១៩៥២ នោះ ហើយ ដែលក្រុមខ្មែរឥស្សរៈ ដឹកនាំ ដោយ សឺន ង៉ុក មិញ បានប្រសិទ្ធិនាមខ្លួនគេ ថា «រដ្ឋាភិបាលតស៊ូខ្មែរ» ។

**១៩៥៣** : (ថ្ងៃ ១១ មករា) : ព្រះមហាក្សត្រ នរោត្តម សីហនុ សុំអំណាចទាំង មូលពីរដ្ឋសភា។ (ថ្ងៃ ១៣ មករា) : ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ រំលាយរដ្ឋសភាជា លើកទី ២។ គឺ ជាដំណាក់ការទី ២ នៃ « រដ្ឋប្រហារស្របច្បាប់» របស់ ព្រះមហាក្សត្រ ដែលបណ្តាលឲ្យមាន ការរដើបរំជួល នៅក្នុងសាលារៀន។ (ថ្ងៃ ១៤ មករា) :

សាឡូត សរ ត្រឡប់ ពីស្រុកបារាំង មកស្រុកខ្មែរ ។ (ថ្ងៃ ២៤ មករា) : រដ្ឋាភិបាល ដឹកនាំដោយព្រះមហាក្សត្រ។ (ថ្ងៃ ៩ កុម្ភៈ) :ការចាប់ផ្តើម នៃ រាជបូជនីយកិច្ច ដើម្បី ឯករាជ្យ របស់ ព្រះមហាក្សត្រ ដែលសម្រេចយាងទៅប្រទេសបារាំង។ គឺ នៅថ្ងៃនោះ ហើយដែលបារាំង រំលាយសមាគមនិស្សិត អា អឺ កា តាមសេចក្តីស្នើ របស់ព្រះមហាក្សត្រ។ ព្រះមហាក្សត្រ ជយបសន្ទនា ជាមួយលោក ប្រធានាធិបតីបារាំង វ៉ាំងសង់ អូរីយ៉ូល ប៉ុន្តែ ពុំបានទទួលលទ្ធផលអ្វីទាំងអស់ ។ ថ្ងៃ ១៣ មេសា: ព្រះអង្គយាង ទៅ ប្រទេសកាណាដា និង សហរដ្ឋ អាមេរិក ។ ថ្ងៃ ១៤ ឧសភា : ព្រះមហាក្សត្រ យាងវិលត្រឡប់មកស្រុកខ្មែរវិញ បន្ទាប់ពីបានស្នាក់អាស្រ័យ នៅប្រទេសជប៉ុន មួយរយៈពេល។ ថ្ងៃ ១២ មិថុនា : ព្រះអង្គយាងទៅតាំង សេនាធិការដ្ឋាន របស់ ព្រះអង្គ នៅខេត្រសៀមរាប។ ថ្ងៃ ១៤ មិថុនា : ព្រះអង្គ យាងទៅទីក្រុងបាងកក។ ថ្ងៃ ២៦ មិថុនា : ព្រះអង្គយាង មក ខេត្របាត់ដំបង ។ ពីទីនោះមក ព្រះមហាក្សត្រខ្មែរ បាន អំពាវនាវ កំណែនទូទៅ។ ប្រជាជនប្រមាណ ២០ ម៉ឺន នាក់ បាន ឆ្លើយតប។ ថ្ងៃ ៣ កក្កដា : បារាំងបញ្ជាក់ ឲ្យដឹងថា គេត្រៀមខ្លួន ជាស្រេច ដើម្បី សម្រួលឲ្យបានកាន់តែប្រសើរ ការផ្តល់ឯករាជ្យ និង អធិបតេយ្យទៅឲ្យខ្មែរ។ ថ្ងៃ ២៩ កក្កដា : រដ្ឋាបាល នរោត្តម សីហនុ។ ខែ សីហា : សាឡូត សរ និង យន់ សឿន មកដល់ទីបញ្ជាការណសិរ្ស សហភាព ឥស្សរៈ ដែលតាំងទី នៅ ផ្នែកបូព៌ា ខេត្រ កំពង់ចាម ហើយដែលកំពុងរៀបចំធ្វើសង្រ្គាមទ័ពព្រៃ ។ ថ្ងៃ ២៥ សីហា : ការចាប់ផ្តើម នៃ ការចរចារវាង បារាំង និង ខ្មែរ ។ ថ្ងៃ ២៩ សីហា :បារាំង ប្រគល់ សមត្ថកិច្ច ផ្នែកតុលាការ មកឲ្យខ្មែរ ។ ថ្ងៃ ១៧ តុលា :បារាំង ប្រគល់ សមត្ថកិច្ច ផ្នែកយោធា មកឲ្យខ្មែរ ។ ថ្ងៃ ៧ វិច្ឆិកា : បារាំង ប្រគល់ផ្នែក នានា នៃ អធិបតេយ្យមកឲ្យខ្មែរ ។ ថ្ងៃ ៩ វិច្ឆិកា : ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ ប្រកាសឯករាជ្យខ្មែរ ។ ថ្ងៃ ២៣ វិច្ឆិកា : រដ្ឋាភិបាល ចាន់ ណាក់។ ថ្ងៃ ១៧-៣០ ធ្នូ :« ប្រតិបត្តិការសាមគ្គី» (ប្រតិបត្តិការ យោធា ដឹកនាំ





ដោយ ព្រះមហាក្សត្រខ្មែរ ដើម្បី កំចាត់ទីតាំងវៀតមិញ ហើយដែលមាន អន្តរាគមន៍ ពីកងទ័ពអាកាសបារាំងផងដែរ) ។

**១៩៥៤** : ថ្ងៃ ២០ កុម្ភៈ :មេឥស្សរៈខ្មែរ ចុះចូលរាជរដ្ឋាភិបាល។ ថ្ងៃ៧ មេសា :រដ្ឋាភិបាល ដឹកនាំដោយ ព្រះមហាក្សត្រ នរោត្តម សីហនុ ។ ថ្ងៃ ១៨ មេសា : រដ្ឋាភិបាល លោក ប៉ែន នុត។ ថ្ងៃ ៧ ឧសភា : ការប្រយុទ្ធ នៅ ឌៀន បៀន ភូ ឈានមកដល់ទីបញ្ចប់ ។ ថ្ងៃ ៨ ឧសភា :សន្និសីទ អន្តរជាតិទីក្រុងស្ហឺណែវ បើកសម័យប្រជុំ។ ថ្ងៃ ២០ កក្កដា :ការចុះហត្ថលេខា កិច្ចព្រមព្រៀង ទីក្រុងហ្សឺណែវ ។ ថ្ងៃ ២១ កក្កដា : សហរដ្ឋអាមេរិក មិនព្រមចុះហត្ថលេខា ទៅលើ កិច្ចព្រមព្រៀងទីក្រុងហ្សណែវ ។ ថ្ងៃ ២៧ សីហា :រដ្ឋាភិបាល លោក ប៉ែន នុត។

ថ្ងៃ ៣១ តុលា : ទស្សនកិច្ច លោក នេហរុ នៅប្រទេសកម្ពុជា ដើម្បី លើកឡើង នូវមាគ៌ា សន្តិសហវិជ្ជមាន និង មិនចូលបក្សសម្ព័ន្ធ ។ ថ្ងៃ ២ ធ្នូ : មហាក្សត្រខ្មែរ មិនអនុញ្ញាតឲ្យលោក សឺន ង៉ុក ថាញ់ ចូលគាល់ ។ ថ្ងៃ ២៣ ធ្នូ : ការបង្កើតធនាគារ ជាតិ នៃ ម្ពុជា (ធនាគារកណ្តាល) ។

**១៩៥៥** : (ថ្ងៃ ២៥ មករា) : រដ្ឋាភិបាល លោក ឡេង ង៉ែត ។ ថ្ងៃ ៧ កុម្ភ:: ប្រជាមតិ សាកសួរ អំពី បេសកកម្ម ទាមទារ ឯករាជ្យ របស់ ព្រះមហាក្សត្រ។ អ្នកទៅបោះឆ្នោត ៩៩,៨ ភាគរយ សំដែងការពេញចិត្ត ។ ថ្ងៃ ១៩ កុម្ភ: ព្រះមហាក្សត្រ នរោត្តម សីហនុ បង្ហាញគម្រោង កែសម្រួលស្ថាប័ន គ្រប់ក្រងប្រទេស ។ ខែ កុម្ភៈ : ខ្មែរសេរី បង្កើត មូលដ្ឋានទ័ពមួយ មានគ្នា ២ ពាន់នាក់ នៅលើទឹកដីថៃ ដោយមានលោក សឺន ង៉ុក ថាញ់ ជាអ្នកដឹកនាំ ។ ថ្ងៃ ៣ មិនា :ព្រះមហាក្សត្រ នរោត្តម សីហនុ ដាក់រាជ្យ ថ្វាយព្រះមាតា និង ព្រះបិតា របស់ ព្រះអង្គ ដើម្បី ចុះប្រយុទ្ធ ក្នុងឆាកនយោបាយ ។ ថ្ងៃ ២៣ មិនា : សម្តេច ឧបយុវរាជ នរោត្តម សីហនុ បង្កើត ចលនា «សង្គមរាស្ត្រនិយម» ។ ថ្ងៃ ១៦ ឧសភា :កិច្ចព្រមព្រៀង ទទួល ជំនួយការ យោធា ពី

សហរដ្ឋ អាមេរិក ។ ថ្ងៃ ១៤ កញ្ញា : ប្រទេសកម្ពុជា ចូលទៅក្នុងអង្គការ សហ ប្រជាជាតិ។

**១៩៥៦** : ថ្ងៃ ៥ មករា : រដ្ឋាភិបាល អ៊ុម ឈាង ស៊ុន (រដ្ឋាភិបាលសង្គមរាស្ត្រនិយម ទី ២)។ ថ្ងៃ ១៣ - ២១ កុម្ភៈ : សម្តេច នរោត្តម សីហនុ ធ្វើ ទស្សនកិច្ច នៅប្រទេសចិន នៅ សហភាព សូវៀត និង នៅ ឆេកូស្លូវ៉ាគី ។ ថ្ងៃ ១ មិនា: រដ្ឋាភិបាល នរោត្តម សីហនុ (រដ្ឋាភិបាល សង្គមរាស្ត្រនិយម ទី ៣) ។ សម្តេច នរោត្តម សីហនុ មិន ព្រមចូលអង្គការ អូតាស្ស៊ (O.T.A.S.E. ) ។ ថ្ងៃ ៣ មេសា : រដ្ឋាភិបាល ឃីម ទីត (រដ្ឋាភិបាលសង្គមរាស្ត្រនិយមទី ៤ ) ។ ថ្ងៃ ១៥ កញ្ញា : រដ្ឋាភិបាលសីហនុ (រដ្ឋាភិបាលសង្គមរាស្ត្រនិយម ទី ៥) ។ ខែ តុលា : ប្រទេសថៃ ដាក់កងទ័ព ជំនួសកងនគរបាល នៅ ព្រះវិហារ។ ថ្ងៃ ២៥ តុលា : រដ្ឋាភិបាល សាន យុន (រដ្ឋាភិបាលសង្គមរាស្ត្រនិយមទី ៥)។ ថ្ងៃ ២២ -២៧ វិច្ឆិកា : ទស្សនកិច្ច របស់ ជូ អេន ឡាយ រដ្ឋមន្ត្រី ការបរទេសចិន ប្រជាមានិត្ នៅកម្ពុជា ។ ថ្ងៃ ២៦ វិច្ឆិកា :និស្សិតខ្មែរ នៅទីក្រុងប៉ារីស៍ បង្កើតសមាគម អ៊ុយ អឺ កា។ ១៩៥៧ : រដ្ឋាភិបាល សាន យុន (រដ្ឋាភិបាលសង្គមរាស្ត្រនិយមទី ៧) ។ ថ្ងៃ១២ មករា : សមាជលើក ទី ៤ ដែលនៅឱកាសនោះ បានធ្វើសេចក្តីសម្រេចចិត្ត ប្រកាស អព្យាក្រឹតភាព នៃ ប្រទេសកម្ពុជា។ ថ្ងៃ ៩ មេសា : រដ្ឋាភិបាល សីហនុ (រដ្ឋាភិបាលសង្គមរាស្ត្រនិយម ទី ៨) ។ ថ្ងៃ ២៥ មេសា : ប្រទេសវៀតណាមខាងត្បូង ចោទប្រទេសកម្ពុជាថាផ្តល់ ជម្រកឲ្យ ទ័ពព្រៃកុម្មុយនិស្ត វៀតណាម ។ ថ្ងៃ ២ ឧសភា : កងទ័ពវៀតណាមខាងត្បូង ចូលមក ភូមិបន្ទ្រោ ខេត្រស្វាយរៀង ។ ថ្ងៃ ១៥ កក្កដា : សមាជជាតិលើកទី ៥។ ថ្ងៃ ២៦ កក្កដា : រដ្ឋាភិបាល ស៊ិម វ៉ា (រដ្ឋាភិបាលសង្គមរាស្ត្រនិយមទី ៩)។ ថ្ងៃ ១១ សីហា : ការតតាំងជាសាធារណៈ រវាង សម្តេច នរោត្តម សីហនុ នឹង មេដឹកនាំ គនបក្សប្រជាធិបតេយ្យ ។ ថ្ងៃ ២០ សីហា : សម្តេច នរោត្ត សីហនុ សម្ពោធ «ផ្ទះខ្មែរ» (Pavillon du Cambodge) នៅក្នុង សកលវិទ្យាល័យ ទីក្រុងប៉ារីស៍ ។





**១៩៥៨** : ថ្ងៃ ៤-៦ មករា : សមាជលើកទី ៦ ។ ថ្ងៃ ២៦ មករា : ប្រជាមតិ ស្តីពី ច្បាប់បោះឆ្នោតរបស់ស្ត្រី ។ ៩៩, ៩៥ ភាគរយ យល់ព្រម។ ថ្ងៃ ២៣ មិនា : ការបោះឆ្នោតសកា។ ថ្ងៃ ២៩ មេសា : រដ្ឋាភិបាល ស៊ិម វ៉ា (រដ្ឋាភិបាលសង្គមរាស្ត្រនិយម ទី១១) ។ ថ្ងៃ ៩- ២៦ មិថុនា : កងទ័ព វៀតណាមខាងត្បូង មួយកង វរសេនាធំ បានចូល ១៥ គ. ម. មកក្នុងទឹកដីខ្មែរ នៅក្នុងខែត្រស្ទឹងត្រែង។ ថ្ងៃ ១០ កក្កដា : រដ្ឋាភិបាលសីហនុ (រដ្ឋាភិបាលសង្គមរាស្ត្រនិយមទី ១២) ។ គឺ នៅក្នុងរដ្ឋាភិបាល នេះហើយដែល លោក ហ៊ូ យន់ និង លោក ខៀវ សំផន ចូលរួមចំណែក។ ថ្ងៃ ២៤ កក្កដា : ប្រទេសកម្ពុជា ដាក់ទំនាក់ទំនងទូត ជាមួយ ប្រទេសចិនប្រជាមានិត្ ។ ថ្ងៃ ១៦ សីហា : ទាហានថៃ មួយក្រុម បានចូលមកក្នុង ប្រាសាទព្រះវិហារ ។ ពី ថ្ងៃ ១៨ សីហា មកដល់ ថ្ងៃ ៣ កញ្ញា : ការចរចា រវាងខ្មែរ និង ថៃ នៅទីក្រុងបាងកក ស្តីពីព្រះវិហារ។ ប្រទេសថៃ មិនព្រមទទួលស្គាល់ ផែនទីដែលភ្ជាប់ជាមួយ និងសន្ធិសញ្ញា ឆ្នាំ ១៩០៧ ។ ថ្ងៃ ២៨ វិច្ឆិកា : ទំនាក់ទំនងការទូត រវាងកម្ពុជា និង ថៃ ត្រូវផ្អាកមួយរយៈសិន។ ថ្ងៃ ៣០ ធ្នូ : កាសែត «រាស្ត្រាធិបតី» របស់ លោក សម សារី ចេញផ្សាយលេខ ទី ១ របស់ ខ្លួន។

**១៩៥៩** : ថ្ងៃ ១៣ មករា : សម្តេច នរោត្តម សីហនុ ប្រាប់ឲ្យដឹង ជា សាធារណៈថា មានគេរៀបចំគម្រោងការក្បត់ព្រះអង្គ នៅទីក្រុងបាងកកដោយមាន បង្អែក ពីលោក សម សារី។ ថ្ងៃ ១៩ មករា : ពិធីសម្ពោធ ប្រលានយន្តហោះ អន្តរជាតិ ពោធិចិន្តុង ដែលជាអំណោយ របស់ បារាំង។ ថ្ងៃ ២០ កុម្ភៈ : ការដាក់ ទំនាក់ទំនងទូត ជាមួយថៃ ឡើងវិញ ដោយមាន អង្គការ សហប្រជាជាតិ ជាអន្តរការី ។ ថ្ងៃ ២២ កុម្ភៈ : អំពើក្បត់ របស់ ដាប ឈួន បែកការ ហើយត្រូវ រំងស្កាត់ទាន់ពេល។ ថ្ងៃ ១៣ មិថុនា : រដ្ឋាភិបាលនរោត្តម សីហនុ (រដ្ឋាភិបាលសង្គមរាស្ត្រនិយម ទី ១៤) ។ ថ្ងៃ ២២ កក្កដា : ផ្លូវមិត្តភាព ខ្មែរ-អាមេរិកភ្នំពេញ-កំពង់សោម (ក្រុងព្រះសីហនុ ) បានត្រូវសម្ពោធ។ ថ្ងៃ ៣ សីហា : ការសន្ទនា រវាងសម្តេច នរោត្តម សីហនុ និង ង៉ោ ឌិញ យាម ដែលទាមទារ យកកោះ

ខ្មែរមួយចំនួន។ ថ្ងៃ ៣១ សីហា : ព្រះមហាក្សត្រ នរោត្តម សុរាម្រិត និង មហាក្សត្រីយានី កុសមៈ ប្រមទាំង សម្តេច នរោត្តម សីហនុ បានគេចផុតពី ការប៉ុនប៉ងធ្វើឃាតដោយគ្រាប់បែក នៅក្នុងព្រះរាជវាំង។ ថ្ងៃ ៣០ កញ្ញា ដល់ ថ្ងៃ ៦ តុលា : រដ្ឋាភិបាលខ្មែរបញ្ជូនសំណុំរឿង ព្រះវិហារ ប្តឹងតុលាការ អន្តរជាតិ ។ ខែ តុលាៈ សឺន ង៉ុក ថាញ់ ចេញផ្សាយនិវេតនប័ណ្ណ ចលនាខ្មែរសេរី។ ថ្ងៃ ១១ តុលា : ណុប បុផាន់ នាយកកាសែតកុម្មុយនិស្ត «ប្រជាជន» ត្រូវគេធ្វើឃាត។ ខែ វិច្ឆិកា : កងទ័ពខេមរភូមិន្ទ ដឹកនាំដោយឧត្តមសេនីយ៍ លន់ នល់ ធ្វើប្រតិបត្តិការចាប់ ដាប ឈួន ហៅ ឈួន ម្ជុលពេជ្រ នៅសៀមរាប។ ដាប ឈួន ត្រូវអង្គរក្សដែលរត់ទៅភ្នំគូលែនជាមួយ ផ្តាច់ជិវិតចោលតែម្តង។

**១៩៦០** : ថ្ងៃ ២ មេសា **:** ពិធីសម្ពោធ កំពង់ផែកំពង់សោម ដែលជាអំណោយរបស់បារាំង។ ថ្ងៃ ៣ មេសា : ព្រះមហាក្សត្រ ព្រះបាទសុរាម្រិត ចូលជីវង្គត ។ ថ្ងៃ ៩ មេសា : សម្តេច នរោត្តមសីហនុ មិនព្រមឡើងគ្រងរាជ្យ ។ រដ្ឋសភាបង្កើត ក្រុមប្រឹក្សារាជានុសិទ្ធិ។ ថ្ងៃ ១៩ មេសា : រដ្ឋាភិបាល ផូព្រឿង (រដ្ឋាភិបាលសង្គមរាស្ត្រនិយម ទី ១៥) ។ ថ្ងៃ ៥ មិថុនា : សម្តេចន រោត្តម សីហនុ បានត្រូវប្រជាមតិ ជ្រើសតាំង ជាព្រះប្រមុខរដ្ឋ។ ថ្ងៃ ២៨ - ៣០ កញ្ញា : មហាសន្និបាត ទី ២ នៃ បក្សប្រជាជន បដិវត្តកម្ពុជា នៅក្នុង ទូរទេះភ្លើង នៅ ស្ថានីយរថភ្លើងទីក្រុង ភ្នំពេញ។ គឺនៅពេលនោះហើយដែលបក្សប្រជាជនបដិវត្តកម្ពុជា ប្តូរឈ្មោះមកជា «បក្សពលករកម្ពុជា» ។ ខែ កញ្ញា : ផូវលំ ហូ ជី មិញ រីករាលដាល ចាក់ស្រេះ ពេញផ្ទៃកបូពាំ នៃ ប្រទេសកម្ពុជា ។

**១៩៦១** : ថ្ងៃ ២៨ មករា : រដ្ឋាភិបាល នរោត្តម សីហនុ (រដ្ឋាភិបាលសង្គមរាស្ត្រនិយមទី ១៦)។ ថ្ងៃ ២៦ ឧសភា : តុលាការ យុត្តិធម៌ អន្តរជាតិ ប្រកាសថា គេមានសមត្ថកិច្ចគ្រប់គ្រាន់ ដើម្បីកាត់ក្តីសំណុំរឿង ព្រះវិហារ ។ ខែ កក្កដា : រដ្ឋាភិបាលខ្មែរលើកឡើង អំពី ការសង្កត់សង្កិន ពូជសាសន៍ និងសាសនាទៅលើ ខ្មែរកម្ពុជាក្រោម។





ថ្ងៃ ២៣ តុលា : កម្ពុជា ផ្តាច់ទំនាក់ទំនងទូត ជាមួយប្រទេសថៃ។ ថ្ងៃ ១៧ វិច្ឆិកា : រដ្ឋាភិបាល សីហនុ (រដ្ឋាភិបាលសង្គមរាស្ត្រនិយមទី ១៧) ។

**១៩៦២** : ១០ មិថុនា **:** ការបោះឆ្នោតសភា។ ខែ ឧសភា : អ្នកដឹកនាំគណបក្ស ប្រជាជនជាច្រើន ត្រូវចាប់ខ្លួន (នង សួន, កែវ មាស,...)។ ថ្ងៃ ១៥ មិថុនា : តុលាការ អន្តរជាតិ ទីក្រុងឡាអេ (La Haye) កាត់ក្តីឲ្យខ្មែរឈ្នះក្នុងរឿងព្រះវិហារ ។ ថ្ងៃ ២០ កក្កដា : មេកុម្មុយនិស្ត គណបក្ស ប្រជាជន បដិវត្ត កម្ពុជា ទូ សាមុត ត្រូវ គេធ្វើឃាតនៅក្នុងភាពដ៏អាថ៌កំបាំង។ ថ្ងៃ ៦ សីហា : រដ្ឋាភិបាល ចៅ សែនកុសល (រដ្ឋាភិបាលសង្គមរាស្ត្រនិយមទី ១៨)។ ថ្ងៃ ២០ សីហា : សម្តេច នរោត្តម សីហនុ ផ្ញើសារលិខិត ទៅប្រមុខរដ្ឋ ចំនួន ១២ ប្រទេស ដើម្បីសុំ ឲ្យទទួលស្គាល់ និង ធានាអព្យាក្រឹតភាពខ្មែរ។ ថ្ងៃ ២ តុលា : អ្នកតំណាងប្រទេសថៃ នៅ អង្គការ សហប្រជាជាតិ ទាមទារយកខែត្របាត់ដំបង កំពង់ធំ និង សៀមរាប ។ ថ្ងៃ ៦ តុលា : រដ្ឋាភិបាល នរោត្តម កន្តុល (រដ្ឋាភិបាលសង្គមរាស្ត្រនិយម ទី ១៩)។ ថ្ងៃ ២៥ តុលា : កងអាកាសចរ វៀតណាមខាងត្បូង ទម្លាក់គ្រាប់បែក លើភូមិខ្មែរ។

**១៩៦៣ :** ថ្ងៃ ២០-២១ កុម្ភៈ មហាសន្និបាត បក្សពលករខ្មែរ ។ សាឡុត សរ ត្រូវបានតែងតាំងជាអគ្គលេខាធិការបក្ស។ តាមការពិត តួនាទីនេះ ត្រូវបានមក សោ ភឹម ។ ថ្ងៃ ៨ មិនា : សម្តេច សីហនុ កោះហៅ បញ្ញជន ៣៤ រូប ឲ្យរៀបចំ បង្កើតរដ្ឋាភិបាល។ អ្នកទាំងនេះពុំព្រម ព្រោះដឹងថា ជាអន្ទាក់។ ថ្ងៃ ១ ឧសភាៈ ទស្សនកិច្ចផ្លូវការ នៅកម្ពុជា នៃប្រមុខរដ្ឋ ចិន លូ ចៅ ជី ។ ថ្ងៃ ១៥ សីហា : វិទ្យុខ្មែរសេរី ចាប់ផ្តើមធ្វើសកម្មភាពប្រឆាំង នឹង សម្តេច នរោត្តម សីហនុ។ ថ្ងៃ ២៧ សីហា : កម្ពុជា ផ្តាច់ទំនាក់ទំនងទូត ជាមួយប្រទេសវៀតណាម ខាងត្បូង ។ ថ្ងៃ ១ វិច្ឆិកា : រដ្ឋប្រហារ នៅវៀតណាមខាងត្បូង ។ ថ្ងៃ ២ វិច្ឆិកា : លោក ប្រធានា ធិបតី ង៉ោ ឌិញ យាម និង ប្អូន ង៉ោ ឌិន ញូ ព្រមទាំងភរិយាត្រូវគេសម្លាប់។ ថ្ងៃ ៩ វិច្ឆិកាៈ សម្តេចនរោត្តម សីហនុ ប្រកាស

ប្រាប់ផែនការកែទម្រង់សេដ្ឋកិច្ច (ជាតូបនីយកម្មធនាគារ និងពាណិជ្ជកម្មក្រៅប្រទេស) ។ ព្រះអង្គ ក៏ទាត់ចោល ជមនួយ អាមេរិកផងដែរ ។ ថ្ងៃ ១៩ វិច្ឆិកា : សម្តេច នរោត្តម សីហនុ ផ្តាច់ជំនួយ យោធា និង សេដ្ឋកិច្ច របស់ សហរដ្ឋ អាមេរិក។ ថ្ងៃ ២២ វិច្ឆិកា : លោកប្រធានាធិបតី សហរដ្ឋ អាមេរិក យ៉ូន កិណ្ណឺឌី ត្រូវគេធ្វើឃាត។ ថ្ងៃ ២៥ វិច្ឆិកា : ខ្មែរសេរី ឈ្មោះ ព្រាប អ៊ិន បានត្រូវកាត់ទោស ប្រហារជីវិត ។ ថ្ងៃ ២៩- ៣០ ធ្នូ : ការបើកអង្គសមាជ សង្គមរាស្ត្រនិយម ទី ១៦ ។

**១៩៦៤ :** ខែ មករា **:** បាតុកម្មយុវជន ប្រឆាំង នឹង សហរដ្ឋ អាមេរិក។ ជាតូបនីយកម្មធនាគារ ក្រុមហ៊ុនធានារ៉ាប់រង និងផ្នែកជីកចេញនាំចូល។ ថ្ងៃ ២០ មករា**:** ព្រាប អ៊ិន បានត្រូវប្រហារជីវិត នៅ ត្រពាំងក្រឡឹង។ ថ្ងៃ ៦ មិនា : ក្រសួងការបរទេស សហរដ្ឋ អាមេរិក លើកឡើងពី បញ្ហា ព្រំប្រទល់ ខ្មែរ -ថៃ និង ខ្មែរ-វៀតណាមខាងត្បូង ដោយ គាំទ្រប្រទេសជិតខាង ទាំងពីរនេះ ដែលជា សម្ព័ន្ធមិត្ត របស់គេ ។ ថ្ងៃ ១១ មិនា : បាតុកម្ម រៀបចំឡើង ដោយអាជ្ញាធរខ្មែរ វាយកំទេចស្ថានទូត អាមេរិក និង ប្រទេសអង់គ្លេស ដើម្បីសំដែងការប្រឆាំង នឹងការគាំទ្រ ប្រទេសជិតខាងទាំងពីរ ដោយ ស. រ អ.ស្តី ពី បញ្ហា ព្រំដែននេះ។ ថ្ងៃ ២៦ មិនា : យន្តហោះ និង រថក្រោះ ប្រទេសវៀតណាមខាងត្បូង ក្រោម បញ្ជាការ របស់ នាយទាហាន អាមេរិកាំងម្នាក់ បាន វាយប្រហារ ទៅលើភូមិចន្ទ្រា ក្នុងខេត្តស្វាយរៀង។ ថ្ងៃ ៧ ឧសភា : ភូមិ តា អី ត្រូវកងទ័ពវៀតណាមខាងត្បូង វាយប្រហារ ដោយឥតត្រាប្រណី ដោយយន្តហោះ និង រថក្រោះ។ រដ្ឋាភិបាលខ្មែរ ប្តឹងអង្គការ សហប្រជាជាតិ។ ថ្ងៃ ៨ ឧសភា : ភូមិ ធ្លក ត្រូវទទួល រងគ្រោះ ដូចភូមិចន្ទ្រា និង តា អី ដូច្នេះដែរ ។ ថ្ងៃ ២៨ ឧសភា : អង្គការសហប្រជាជាតិតម្រូវឲ្យអាមេរិក សងការខូចខាត។ ថ្ងៃ ២៤ មិថុនា : សម្តេច នរោត្តម សីហនុ ជួបសន្ទនា ជាមួយឧត្តមសេនីយ៍ ដឺ ហ្គោល នៅ ទីក្រុងប៉ារីស៍។ ថ្ងៃ ២០ កញ្ញា : ពិធីសម្ពោធ វិជ្ជាស្ថាន បច្ចេកទេស មិត្តភាព ខ្មែរ-សូវៀត នៅភ្នំពេញ។ ថ្ងៃ ២៧ កញ្ញា : ទស្សនកិច្ច របស់ សម្តេច នរោត្តម សីហនុ នៅទីក្រុងប៉េកាំង ។ ប្រទេសចិន





ប្រជាមានិត្ត ផ្តល់ជំនួយយោធា ឲ្យ ប្រទេស កម្ពុជា។ ថ្ងៃ ២០ តុលា : អាមេរិក ទម្លាក់គ្រាប់បែកទៅលើ ភូមិអន្លុង ក្រែស ខេត្តកំពង់ចាម។ ថ្ងៃ ២៤ តុលា :អាមេរិក ទម្លាក់គ្រាប់បែក លើ ប៉ុស្តិ៍ ទល់ដែន ដាក់ ដាំ ខេត្តមណ្ឌលគិរី។ ថ្ងៃ ២៥ វិច្ឆិកា : សកលវិទ្យាល័យ ៤ បានត្រូវបង្កើត ៖ សកលវិទ្យាល័យ ភូមិន្ទបច្ចេកទេស សកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ សកលវិទ្យាល័យភូមិន្ទ កំពង់ចាម និង សកលវិទ្យាល័យ តាកែវ-កំពត។ ថ្ងៃ ១២ ធ្នូ : ពហុកីឡាដ្ឋានភ្នំពេញ បានត្រូវសម្ពោធ ។ ថ្ងៃ ២៥ ធ្នូ : រដ្ឋាភិបាល នរោត្តម កន្តុល (រដ្ឋាភិបាលសង្គមរាស្ត្រនិយម ទី ២០)។

**១៩៦៥** : ថ្ងៃ ១០ មករា **:** ស្ថានទូតបារាំង បានបញ្ជូន កំណត់ហេតុ មួយមក រដ្ឋាភិបាលខ្មែរ សុំឲ្យ ប្រទេសវៀតណាមខាងត្បូង ប្រគល់ទឹកដីកូសាំងស៊ីន មកឲ្យខ្មែរវិញ។ ថ្ងៃ ១៤ កុម្ភៈ សន្និសីទ ប្រជាជន នៃបណ្តាប្រទេស នៅឥណ្ឌូចិន លើកទី១ នៅ ទីក្រុងភ្នំពេញ។ ថ្ងៃ ២៦ មេសា **:** បាតុកម្ម ប្រឆាំង នឹង សហរដ្ឋ អាមេរិក នៅមុខស្ថានទូត អាមេរិក។ ថ្ងៃ ៣ ឧសភា **:** ប្រទេសកម្ពុជា ផ្តាច់ទំនាក់ ទំនងទូត ជាមួយសហរដ្ឋ អាមេរិក។ ថ្ងៃ ៧ ឧសភា : រដ្ឋាភិបាល នរោត្តម កន្តុល ទី ២ (រដ្ឋាភិបាលសង្គមរាស្ត្រនិយមទី ២១) ។ ខែ មិថុនា : សាឡុត ស, កែវ មាស និង អ្នកដឹកនាំ បក្សកុម្មុយនិស្តមួយចំនួន បានចាកចេញ ពី ការិយាល័យលេខ ១០០ ធ្វើដំណើរ ទៅហាណូយ តាមផ្លូវលំ ហូ ជីមិញ។ ពួកគេស្ថិតនៅ តាមផ្លូវលំ ហូ ជី មិញ អស់រយៈពេល ៩ ខែ។ ថ្ងៃ ៨ តុលា : សហភាព សូវៀត លុបទស្សនកិច្ច ដែលសម្តេច នរោត្តម សីហនុ បម្រុងធ្វើនៅ ទីក្រុងម៉ូស្គូបោល បន្ទាប់ពី ប្រទេសកម្ពុជា ពង្រឹងមេត្រីភាព ជាមួយទីក្រុងប៉េកាំង ។ ថ្ងៃ ១៥ តុលា : កងទ័ព អាមេរិក វាយប្រហារ ទៅលើភូមិ បា ធូ ខេត្តស្វាយរៀង។ ថ្ងៃ ២៥ វិច្ឆិកា : នៅទីក្រុងប៉េកាំង ឧត្តមសេនីយ៍ លន់ នល់ មេសេនាធិការដ្ឋាន កងពលខេមរភូមិន្ទ ចុះហត្ថលេខា ជាមួយ សហភាគីចិន ទៅលើ សន្ធិសញ្ញាយោធាសម្ងាត់មួយ សន្យាថា ទទួល និង ការពារ យុទ្ធជន កុម្មុយនិស្ត វៀតណាម

នៅតាមជាយ ដែនកម្ពុជា ។ ថ្ងៃ ២១ ធ្នូ :រដ្ឋាភិបាល សហរដ្ឋ អាមេរិក ចោទ ប្រទេសកម្ពុជា ថា បានផ្តល់ជម្រក ឲ្យវៀតកុង។

**១៩៦៦** :គឺនៅ ឆ្នាំ ១៩៦៦ នោះហើយ ដែល វៀតណាម ខាងជើង បង្កើត អង្គភាពមួយ សម្រាប់បង្ហាត់ហ្វឹកហ្វឺន កងទ័ពព្រៃខ្មែរ។ អង្គភាពនោះ មានឈ្មោះ ថា ប៉េ ៣៦ (P 36)។ ថ្ងៃ ១៤ មករា ប្រទេសកម្ពុជា ថ្កោលទោស សហរដ្ឋ អាមេរិក អំពីការដែល ស. រ. អ. ទម្លាក់គ្រាប់បែក ទៅលើទឹកដីខ្មែរ ហើយ ដែលបណ្តាល ឲ្យខ្មែររាប់រយនាក់ បាត់បង់ជីវិត ។ ថ្ងៃ ៥ កុម្ភៈ : ការិយាល័យ អាមេរិក នៅស្រុកខ្មែរ ទាំងប៉ុន្មានដែលគេសង្ស័យថា មានទំនាក់ទំនង ជាមួយ អង្គការ សេ អ៊ី អា បិទទ្វារទាំងអស់។ ថ្ងៃ ១៩ មិនា :សហភាព សូវៀត ចាប់ផ្តើម ផ្តល់ជំនួយយោធាមកឲ្យខ្មែរ។ ថ្ងៃ ៣ មេសា : ថៃ ដាក់កងទ័ព នៅព្រះវិហារ ។ ប៉ុន្តែ នៅ ថ្ងៃ ៦ មិនា កងទ័ពខ្មែរ ដេញកងទ័ពថៃចេញទៅវិញ។ ថ្ងៃ ១២ មិថុនា :រថភ្លើង បាត់ដំបង ប៉ោយ ប៉ែត បានត្រូវកងទ័ពព្រៃខ្មែរ វាយប្រហារ។ ពី ថ្ងៃ ៣១ កក្កដា ទៅទល់នឹង ថ្ងៃ ៣ សីហា :ឧទ្ធម្ភាគចក្រអាមេរិកវាយប្រហារ ទៅលើភូមិ ឃ្មោក ត្រាច ។ នៅ ខែ កក្កដា ការចរចា រវាង ខ្មែរ និងវៀតណាម ស្តីពីបញ្ហា កំណត់ព្រំដែន បានទទួលបរាជ័យទាំងស្រុង។ ខែ កញ្ញា: សាឡុត សរ និង អ្នក ដឹកនាំខ្មែរកុម្មុយនិស្ត បានត្រឡប់មក ការយាល័យលេខ ១០០ របស់គេវិញ។ ពួកគេបានបើកអង្គប្រជុំមួយ ហើយប្រែឈ្មោះបក្សពលករ របស់គេមកជា «បក្សកុម្មុយនិស្តខ្មែរ» វិញ។ ថ្ងៃ ១ កញ្ញា :ឧត្តមសេនីយ៍ សាក ដឺ ហ្គោល ធ្វើ សន្ទរកថា ដ៏ល្បីល្បាញមួយ នៅ ពហុកីឡាដ្ឋាន នៅ ទីក្រុងភ្នំពេញ ទាមទារឲ្យ ប្រទេសដែលទើបនឹងបានឯករាជ្យ មាន សិទ្ធិស្វ័យសម្រេច របស់គេ។ ថ្ងៃ ១១ កញ្ញា :ការបោះឆ្នោតសកា។ ជ័យជំនះ របស់ អ្នកអភិរក្សស្តាំនិយម ។ ថ្ងៃ ២៥ តុលា :រដ្ឋាភិបាល ឧត្តមសេនីយ៍ លន់ នល់ (រដ្ឋាភិបាលសង្គមរាស្ត្រនិយម ទី ២២)។ ថ្ងៃ ២៦ តុលា :សម្តេចនរោត្តម សីហនុ បង្កើត អង្គការ «បររដ្ឋាភិបាល» (ប្រឆាំង នឹងរដ្ឋាភិបាល) ។ ថ្ងៃ ១៨ វិច្ឆិកា :សម្តេច នរោត្តម សីហនុ ផ្តល់ឈ្មោះ «ខ្មែរក្រហម» ទៅឲ្យពួកខ្មែរកុម្មុយនិស្ត។





ខែ ធ្នូ : មធុរា និង ចៅ បូរី ដែលត្រូវ ចោទពីបទខ្មែរសេរីក្បត់ជាតិ បានត្រូវយកទៅប្រហារជីវិត នៅ ត្រពាំងក្រឡឹង។

**១៩៦៧** :ថ្ងៃ ៦ មករា : សម្តេច នរោត្តម សីហនុ យាងទៅប្រទេសបារាំង។ ព្រះអង្គស្ថិតនៅទីនោះ អស់រយៈពេល ២ ខែ។ នៅក្នុងរយៈពេលនោះ ឧត្តមសេនីយ៍ លន់ នល់ បានរៀបចំប្រព័ន្ធទិញស្រូវប្រជាជន ដោយ ឲ្យកំណត់តម្លៃ ១ ភាគ ៣ នៃថ្លៃទីផ្សារសេរី ។ ភាពច្របូកច្របល់មួយ បានកើតមានឡើង ។ ការបង្ក្រាបបណ្តាលឲ្យមានការប៉ះពាល់ដល់ជីវិត ប្រជាជន ។ ពី ថ្ងៃ ២៤ កុម្ភៈ ដល់ ថ្ងៃ ៣ មិនា : កងទ័ពវៀតណាមខាងត្បូង និងអាមេរិក មកតាំងទី នៅ ប្រក ក្រាញ ខេត្តកំពង់ចាម ។ ថ្ងៃ ៩ មិនា : សម្តេច នរោត្តម សីហនុ ត្រឡប់មកកម្ពុជាវិញ។ គឺ នៅពេលនោះហើយ ដែលគេឃើញមាន ខិត្តប័ណ្ណ ថ្កោលទោស នយោបាយទិញស្រូវ និងការខិតទៅជិត សហរដ្ឋអាមេរិក របស់ ឧត្តមសេនីយ៍ លន់ នល់។ ថ្ងៃ ១១ មិនា : បាតុកម្មរៀបចំឡើង ដោយ ខៀវ សំផន និង អ្នកឆ្វេងនិយម ប្រមទាំង អ្នកប្រកាន់ឆ្វេង នៅក្នុងចលនា សង្គមរាស្ត្រនិយម ទាមទារ ឲ្យឧត្តមសេនីយ៍ លន់ នល់ លាលែង ពីតំណែង នាយករដ្ឋមន្ត្រី ។ ថ្ងៃ ៣០ មិនា : សមាជិករដ្ឋាភិបាល ពីរ រូប គឺលោក ម៉ៅ សាយ (សេដ្ឋកិច្ច) និង លោក ឌុក រ៉ាស៊ី (ផែនការ) ត្រូវរដ្ឋសភាដេញដោលចាប់ថ្នាក់។ ថ្ងៃ ២ មេសា : ការ បះបោរ នៅ សម្លូត។ ថ្ងៃ ២២ មេសា : សម្តេច នរោត្តម សីហនុ ចោទប្រកាន់ជា សាធារណៈថា លោក ហ៊ូ យន់ និង ខៀវ សំផនជា អ្នកនាំឲ្យមាន ការបះបោរ ប្រជាកសិករ នៅ សម្លូត។ ព្រះអង្គ គំរាមថា នឹង យកអ្នកទាំងនោះ ទៅឲ្យតុលាការសឹកកាត់ទោស ។ ថ្ងៃ ២២ មេសា : សៅ ង៉ុយ ដែលត្រូវគេចោទថាជា ខ្មែរសេរី បានត្រូវយកទៅប្រហារជីវិត នៅត្រពាំងក្រឡឹង ដូច ព្រាប អ៊ិន, មធុរា និង ចៅ បូរី ដូច្នេះដែរ ។ ថ្ងៃ ២៤ មេសា : ហ៊ូ យន់ និង ខៀវ សំផន រត់ចូល ព្រៃ។ នៅពេលដដែលនោះ មានការសាកល្បង ដកអភ័យឯកសិទ្ធិ តំណាងរាស្ត្រ ពីលោក ហ៊ូ នឹម ប៉ុន្តែ ពុំបានសម្រេច។ ថ្ងៃ ៣០ មេសា: ឧត្តមសេនីយ៍ លន់ នល់ លាលែង ពីមុខតំណែង នាយករដ្ឋមន្ត្រី ។

ថ្ងៃ ១ ឧសភា : រដ្ឋាភិបាល នរោត្តម សីហនុ (រដ្ឋាភិបាលសង្គមរាស្ត្រនិយមទី ២៣) ។ និស្សិត ប្រមាណ ១ ម៉ឺន ៥ ពាន់នាក់ នាំគ្នាធ្វើបាតុកម្ម នៅទីក្រុងភ្នំពេញ ប្រឆាំង នឹង ឃាតកម្ម ទៅលើ រូបលោក ខៀវ សំផន និង ហ៊ូ យន់ ព្រោះ នៅពេលនោះ គេនាំគ្នាយល់ថា ខៀវ សំផន និង ហ៊ូ យន់ បានត្រូវគេធ្វើឃាត (វិទ្យុប៉េកាំង)។ ថ្ងៃ ៩ ឧសភា : ប្រទេសកម្ពុជាស្នើសុំ ឲ្យសហគមអន្តរជាតិ ទទួលស្គាល់ ការកំណត់ព្រំដែន ប្រទេសកម្ពុជា តាមផែនទី ជាធរមាន ឆ្នាំ ១៩៥៤ ។ ថ្ងៃ ១៣ ឧសភា : ខ្មែរពីររូបទៀត ដែលត្រូវចោទប្រកាន់ថា ជាខ្មែរសេរី បានត្រូវប្រហារជីវិត ។ ថ្ងៃ ៣១ ឧសភា : រណសិរ្ស រំដោះជាតិ វៀតណាម ទទួលស្គាល់ ផែនទី ឆ្នាំ ១៩៥៤ នោះ។ ថ្ងៃ ៨ មិថុនា : សាធារណរដ្ឋ ប្រជាធិបតេយ្យ វៀតណាម ទទួលស្គាល់ផែនទី ឆ្នាំ ១៩៥៤ នោះដែរ។ ថ្ងៃ ២២ មិថុនា : ការបើកស្ថានតំណាងអចិន្ត្រៃយ៍ រណសិរ្សរំដោះជាតិវៀតណាម នៅទីក្រុងភ្នំពេញ។ ថ្ងៃ ២៤ មិថុនា : ស្ថានតំណាង សាធារណរដ្ឋ ប្រជាធិបតេយ្យ វៀតណាម (វៀតណាមខាងជើង) ឡើងឋានៈ ជាស្ថានទូត។ ថ្ងៃ ២៨ មិថុនា : ពួកនិស្សិតនាំគ្នាវាយកម្ទេច ទីស្នាក់ការកាសែត «ខ្មែរឯករាជ្យ» របស់ លោក ស៊ឹម វ៉ា ។ ថ្ងៃ ១៣ កក្កដា : រដ្ឋាភិបាល សម្រេច អនុវត្ត ផែនការ «ខេមរយានកម្ម» ជាបណ្ដើរៗ ។ ថ្ងៃ ២ កញ្ញា : សម្ដេច នរោត្តម សីហនុ បិទសមាគមចិន-ខ្មែរ របស់ លោក ភោគ ឆាយ និង ហ៊ូ នឹម បន្ទាប់ពីសមាគមនេះ ចែក «សៀវភៅក្រហម» របស់ ម៉ៅ សេ ទុង ។ ថ្ងៃ ៧ តុលា : ហ៊ូ នឹម រត់ចូលព្រៃ។ និស្សិត និង សាស្ត្រាចារ្យជាច្រើន បានត្រូវចាប់ខ្លួន។ ខ្លះបានត្រូវគេសម្លាប់តែម្ដង ។

**១៩៦៨** : ថ្ងៃ ៨-១២ មករា : ទស្សនកិច្ច របស់ លោក ចេស្ទែរ បោវ ឯកអគ្គរដ្ឋទូត សហរដ្ឋ អាមេរិក ប្រចាំប្រទេសឥណ្ឌា និង ជាបេសកជន ពិសេស របស់ លោក ប្រធានាធិបតី យ៉ូនសុន បានមកជួបសម្ដេច នរោត្តម សីហនុ ស្ដីពីបញ្ហា ការទម្លាក់គ្រាប់បែក បេ ៥២ ទៅលើទីតាំងវៀតកុង នៅលើទឹកដីខ្មែរ ។ សម្ដេច នរោត្តម សីហនុ ទ្រង់មិនយល់ព្រម។ ថ្ងៃ ១៥ មករា : បេសកកម្ម របស់ លោក អាកាស៊ី អ្នកតំណាង



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

អង្គការ សហប្រជាជាតិ ទាក់ទង នឹង ការ ដាក់ទំនាក់ទំនងល្អ ជាមួយ ប្រទេសថៃ ក៏ទទួលបរាជ័យដែរ។ ថ្ងៃ ១៧ មករា : ពួកខ្មែរក្រហម វាយប្រហារ ទៅលើទីតាំង រដ្ឋាភិបាលមួយ នៅ បាណន់ ក្នុងខេត្ត បាត់ដំបង។ ថ្ងៃ ១៧ មករា នោះ បានត្រូវខ្មែរក្រហម ចាត់ទុកថា ជាថ្ងៃចាប់ ផ្ដើមប្រយុទ្ធផ្លូវយោធា របស់ ពួកគេ។ ថ្ងៃ ៣១ មករា : រដ្ឋាភិបាល ប៉ែន នុត (រដ្ឋាភិបាលសង្គមរាស្ត្រនិយមទី ២៤)។ ថ្ងៃ ១៩ កុម្ភៈ : ប្រទេសកម្ពុជា សុខចិត្តទទួលយក ជំនួយសេដ្ឋកិច្ច និងយោធា របស់ សហរដ្ឋ អាមេរិកវិញ។ ថ្ងៃ ២៥ កុម្ភៈ : ពួកខ្មែរក្រហម វាយប្រហារ នៅក្នុងខេត្តចំនួន ៦ ក្នុងថ្ងៃតែមួយ (បាត់ដំបង កំពង់ឆ្នាំង កំពង់ស្ពឺ តាកែវ កំពត កោះកុង)។ ភូមិចំនួន ១ ម៉ឺនភូមិ បានចូលខ្មែរក្រហម។ ថ្ងៃ ១៣ ឧសភា : ឧត្តមសេនីយ៍ លន់ នល់ បានត្រូវ តែងតាំង ជារដ្ឋមន្ត្រី ការពារប្រទេស និង ជាអ្នកត្រួតពិនិត្យកងទ័ព នៅក្នុងរដ្ឋាភិបាល លោក ប៉ែន នុត ។ ថ្ងៃ ៣១ តុលា : សកលវិទ្យាល័យ បាត់ដំបង បានត្រូវសម្ពោធ ។ ថ្ងៃ ៥ ធ្នូ : ឧត្តមសេនីយ៍ លន់ នល់ ត្រូវតែងតាំង ជានាយករដ្ឋមន្ត្រី ។

**១៩៦៩** : ថ្ងៃ ២ មិនា : សម្ដេច នរោត្តម សីហនុ លើកឡើង ជាលើកដំបូង បង្អស់ អំពី ការដែលពួកវៀតកុង ដាក់ទីតាំង របស់គេ នៅក្នុងតំបន់ជាយដែន ប្រទេសកម្ពុជា។ ថ្ងៃ ៩ កុម្ភៈ : អាមេរិក ចាប់ផ្ដើមទម្លាក់គ្រាប់បែក បេ ៥២ នៅលើទឹកដីខ្មែរ។ ពួកខ្មែរកុម្មុយនិស្ត វាយយកបាន ទីតាំង រមាស ហែក ក្នុងខេត្តស្វាយរៀង ។ ថ្ងៃ ២៩ មិនា : សម្ដេច នរោត្តម សីហនុ បង្ហាញក្នុងផែនទី នូវ ទីតាំងសំខាន់ៗ របស់ ពួកវៀតកុង និង វៀតមិញនៅលើទឹកដីខ្មែរ ។ ថ្ងៃ ១១ មេសា : ការដាក់ទំនាក់ទំនងទូត ជាផ្លូវការឡើងវិញ ជាមួយសហរដ្ឋ អាមេរិក ។ ថ្ងៃ ២៦ មេសា : កងទ័ពខេមរភូមិន្ទ វាយប្រហារ ទៅលើទីតាំងខ្មែរក្រហម នៅក្នុងខេត្ត រតនគិរី ។ ថ្ងៃ ២៨ កក្កដា : ប្រទេសកម្ពុជា ចូលជាសមាជិក អង្គការ មូលនិធិ រូបិយវត្ថុ អន្តរជាតិ។ ថ្ងៃ ៣០ កក្កដា : ឧត្តមសេនីយ៍ឯក ញឹក ជូឡុង ប្រគល់ បញ្ជាការកងទ័ពខេមរភូមិន្ទ ទៅឲ្យ ឧត្តមសេនីយ៍ លន់ នល់ ។ ថ្ងៃ ១៤ សីហា : រដ្ឋាភិបាល លន់ នល់ (រដ្ឋាភិបាលសង្គមរាស្ត្រនិយម ទី ២៥

និង ចុងក្រោយបង្អស់)។ គឺនៅក្នុង រដ្ឋាភិបាល នេះហើយ ដែលអ្នកអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈចេញមុខប្រឆាំង ដោយត្រង់ៗ តែម្តង នឹងនយោបាយផ្អែកវាសនា របស់ ប្រទេសកម្ពុជា ទៅលើ ប្រទេសកុម្មុយនិស្ត។ ថ្ងៃ ២៣ តុលា : ឧត្តមសេនីយ៍ លន់ នល់ ប្រមុខរដ្ឋាភិបាល ចេញទៅព្យាបាលរោគ នៅប្រទេសបារាំង ។ ទ្រង់សិរិមតៈ ដឹក នាំ រដ្ឋាភិបាលជំនួស។ ថ្ងៃ ២៦ ធ្នូ :រដ្ឋមន្ត្រីខ្លះ នៅក្នុងរដ្ឋាភិបាលនេះ បានសុំលាលែង ពីមុខតំណែង ដើម្បីសំដែងការស្មោះត្រង់ របស់គេ ចំពោះសម្តេច នរោត្តម សីហនុ។ ថ្ងៃ ២៨ ធ្នូ : សមាជជាតិ ទី ២៨ និង ចុងក្រោយបង្អស់។

**១៩៧០:** ថ្ងៃ ៦ មករា សម្តេច នរោត្តម សីហនុ ប្រមុខរដ្ឋ នៃ ប្រទេសកម្ពុជា យាង ទៅប្រទេសបារាំង។ ថ្ងៃ ១១ មិនា : បាតុកម្មប្រជាជន ខែត្រស្វាយរៀង ប្រឆាំង នឹង វត្តមាន កងទ័ពវៀតកុង នៅលើទឹកដីខ្មែរ ។ ថ្ងៃ ១៨ កម្ភៈ: ឧត្តមសនីយ៍ លន់ នល់ ត្រឡប់ មកកម្ពុជាវិញ ។ ថ្ងៃ ២៧ កុម្ភៈ: នៅទីក្រុងប៉ារីស៍ សម្តេច នរោត្តម សីហនុ ប្រាប់ថា ព្រះអង្គ មានគោលបំណង យាងទៅ ទីក្រុងម៉ូស្គូ និង ប្រទេសចិន ដើម្បសុំឲ្យ វៀតណាម កុម្មុយនិស្ត ដកទ័ពចេញពី ប្រទេសកម្ពុជា ។ ថ្ងៃ ៨-៩ មិនា : បាតុកម្ម ប្រឆាំង នឹង វៀតណាមកុម្មុយនិស្តនៅស្វាយរៀង។ ។ ថ្ងៃ ១១-១៦ មិនា : បាតុកម្ម ប្រឆាំង នឹង វៀតណាមកុម្មុយនិស្ត នៅទីក្រុងភ្នំពេញ។ ស្ថានទូតវៀត ណាមខាងជើង និង រដ្ឋាភិបាលបដិវត្តបណ្តោះអាសន្ន (G.R.P.) ត្រូវបាតុករ វាយកំទេច។ ថ្ងៃ ១២ មិនា : សម្តេច នរោត្តម សីហនុ ផ្ញើទូរលេខមួយ មកភ្នំពេញ សំដែងការមិនយល់ស្រប នឹង បាតុកម្មនោះ។ រដ្ឋាភិបាលឧត្តមសេនីយ៍ លន់ នល់ ស្នើសុំឲ្យទីក្រុងហាណូយ ដក កងទ័ពចេញពីស្រុកខ្មែរ យ៉ាងយូរបំផុតនៅថ្ងៃ ១៥ មិនា។ ថ្ងៃ ១៣ មិនា : សម្តេច នរោត្តម សីហនុ ធ្វើដំណើរចេញពីប្រទេសបារាំង ឆ្ពោះទៅទីក្រុងម៉ូស្គូ។ មុនការចេញ ដំណើរនេះ ព្រះអង្គ ពុំព្រមទទួល គណប្រតិភូមួយ នៃ រដ្ឋាភិបាលឧត្តមសេនីយ៍ លន់ នល់ ដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តម កន្តុល ទេ ។ ថ្ងៃ ១៥ មិនា : ឧត្តសេនីយ៍ លន់ នល់ សុំជំនួយ ពីកងទ័ពវៀតណាម ខាងត្បូង។ ថ្ងៃ ១៦ មិនា : សម្តេច នរោត្តម



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

សីហនុ សម្រេច មិនវិលត្រឡប់ មកកម្ពុជាវិញ បន្ទាប់ពី វរសេនិយឯក អ៊ុំ ម៉ាណូរីន មិនបានសម្រេចផែន ការដក ឧត្តមសេនីយ៍ លន់ នល់ ចេញពី រដ្ឋាភិបាល។ ថ្ងៃ ១៧ មិនា : វរសេនិយឯក អ៊ុំ ម៉ានូរីន ត្រូវរដ្ឋាភិបាល លន់ នល់ ចាប់បង្ខំឲ្យលាលែងពីមុខ តំណែង ។ ថ្ងៃ ១៨ មិនា : សភាទាំងពីរ បានទម្លាក់ សម្តេច នរោត្តម សីហនុ ចេញពី តំណែងប្រមុខរដ្ឋ នៃ ប្រទេសកម្ពុជា ហើយ ចាត់តាំងលោក ចេង ហេង ប្រធានរដ្ឋ សភា ជាប្រមុខរដ្ឋ ជំនួស ។ ថ្ងៃ ១៩ មិនា : រដ្ឋាភិបាល ឧត្តមសេនីយ៍ លន់ នល់ ប្រកាសដាក់ប្រទេសកម្ពុជា ក្នុងភាពអាសន្ន ។ សហរដ្ឋ អាមេរិក បញ្ជាក់ថា ការទម្លាក់ សម្តេច នរោត្តម សីហនុ មានកល្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ ។ នៅទីក្រុងភ្នំពេញ យុវជន និងបញ្ញវន្ត សំដែងការពេញចិត្តចំពោះព្រឹត្តិការណ៍នេះ។ សម្តេច នរោត្តម សីហនុ ចេញដំណើរ ពីទីក្រុងម៉ូស្គូ ឆ្ពោះទៅទីក្រុងប៉េកាំង ក្នុងគោលដៅធ្វើការតស៊ូ ជា មួយខ្មែរក្រហម ។ យុវជនរាប់ម៉ឺននាក់ នាំគ្នាចូលក្នុងជួរកងទ័ព ដើម្បីប្រយុទ្ធ នឹង កម្លាំងឈ្លានពាន ជាហេតុធ្វើឲ្យ ចំនួនកងទ័ពឧត្តមសេនីយ៍ លន់ នល់ កើន ពី ៣ ម៉ឺន ៥ ពាន់ នាក់ ទៅ ១៥ ម៉ឺននាក់។ ថ្ងៃ ២៣ មិនា : នៅទីក្រុងប៉េកាំង សម្តេច នរោត្តម សីហនុ ប្រកាសប្រាប់ថា ព្រះអង្គបង្កើត រណសិរ្សមួយ ឈ្មោះថា «រណសិរ្សរួបរួមជាតិ កម្ពុជា» (F.U.N.K.) ដោយមានការគាំទ្រ ពីប្រទេសចិន និង ប្រទេសវៀតណាមខាង ជើង ។ ថ្ងៃ ២៤ មិនា : សម្តេច នរោត្តម សីហនុ អំពាវនាវ ឲ្យ ប្រជាជនខ្មែរ ងើប ឡើងបះបោរ ប្រឆាំង នឹង របប លន់ នល់ ។ ថ្ងៃ ២៥ មិនា : ក្រសួងការបរទេសខ្មែរ ស្នើបើកការចរចា ជាមួយ ទីក្រុងហាណូយ បន្តទៀត នៅថ្ងៃ ២៧ មិនា ។ ថ្ងៃ ២៦ មិនា :នៅក្នុងខែត្រកំពង់ចាម មនុស្ស ប្រមាណ១ ម៉ឺននាក់ បានត្រូវខ្មែរក្រហម និងពួក វៀតកុងបង្កប់ខ្លួន បង្ខំឲ្យនាំគ្នាធ្វើ បាតុកម្មគាំទ្រ សម្តេច នរោត្តម សីហនុ។ ថ្ងៃ ២៧ មិនា : ប្រទេស វៀតណាមខាងជើង និង អង្គការវៀតកុង ប្រចាំទីក្រុងភ្នំពេញដកខ្លួន ចេញពីប្រទេសកម្ពុជា។ ថ្ងៃ ២៧-២៨ មិនា : នៅភ្នំពេញ សៀមរាប កំពង់ចាម និង តាកែវ មាន បាតុកម្មដ៏ធំប្រឆាំង នឹង របប ឧត្តមសេនីយ៍ លន់ នល់ ។ ការបង្ក្រាប

បាតុកម្មនេះ ធ្វើឲ្យមានការបង្ហូរឈាមមួយ ដ៏ធំ សម្បើមអស្ចារ្យ ។ ហ៊ូ យន់ និង ខៀវ សំផន ប្រកាសគាំទ្រ សម្តេច នរោត្តម សីហនុ ។ ថ្ងៃ ២៩ មិនា : កងទ័ពវៀតកុង និង វៀតណាមខាងជើង វាយប្រហារ ទៅលើ កងទ័ព ឧត្តមសេនីយ៍ លន់ នល់ ដោយគ្មានការប្រកាសសង្គ្រាម។ ដើមខែមេសា : សង្គ្រាមរវាង ប្រទេសវៀតណាម ខាងជើង និងវៀតកុងចាប់ផ្តើម ។ កងទ័ពវៀតណាមខាងជើង និង វៀតកុង វាយសម្រុកឆ្ពោះទៅទីក្រុងភ្នំពេញ។ ថ្ងៃ ២០ មេសា : ឧត្តសេនីយ៍ លន់ នល់ ស្នើសុំជំនួយយោធា ជាផ្លូវការពីសហរដ្ឋ អាមេរិក ។ ថ្ងៃ ២៣ មេសា : ផែនការវាយយក ទីក្រុងភ្នំពេញ ដោយកម្លាំង កងទ័ពវៀតណាមខាងជើង និង វៀតកុង បានទទួលបរាជ័យទាំងស្រុង ។ ថ្ងៃ ២៩ មេសា : កងទ័ពវៀតណាមខាងត្បូង និងអាមេរិក ចូលមកក្នុងទឹកដីខ្មែរ ។ ថ្ងៃ ១ ឧសភា : កងទ័ពអាកាស និង រថក្រោះ អាមេរិក ធ្វើការវាយប្រហារ ទៅលើមេមត់ និងស្នួល ក្នុងខែត្រកំពង់ចាម ។ ថ្ងៃ ៥ ឧសភា : នៅទីក្រុងប៉េកាំង សម្តេច នរោត្តម សីហនុ បង្កើត រដ្ឋាភិបាល និរទេស ប្រសិទ្ធិនាមថា «រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា» (G.R.U.N.K.)។ ប្រទេសថៃ និង ប្រទេសកម្ពុជា ដាក់ចំណងទូតឡើងវិញ។ ថ្ងៃ ១៦-១៧ មិនា : សន្និសីទអន្តរជាតិមួយ នៅទីក្រុងយាការតា ប្រទេសឥណ្ឌូណេស៊ី ទាមទារឲ្យដកកម្លាំង កងទ័ព បរទេសទាំងអស់ ចេញពីប្រទេសកម្ពុជា។ នៅថ្ងៃនោះឯង យន្តហោះ ប្រទេសវៀតណាមខាងត្បូង បានទម្លាក់គ្រាប់បែកទៅលើសកលវិទ្យាល័យ កំពង់ចាម។ ថ្ងៃ ២០ ឧសភា : កាសែត «ប្រទេសចិនថ្មី» បានចុះផ្សាយ ពត៌មានមួយ ប្រាប់ថា លោក ហ៊ូ យន់ ដឹកនាំការតស៊ូ នៅផ្នែកឧត្តរ ហើយ លោក ខៀវ សំផន នៅផ្នែកបូព៌ា ។ ថ្ងៃ ២៦ ឧសភា : សហរដ្ឋ អាមេរិក ផ្តល់ជំនួយ ជាសម្ភារយោធា ទៅឲ្យខ្មែរ គិតជាទឹកប្រាក់ ប្រមាណ ៧ លាន ៥ សែន ដុល្លារ ។ ថ្ងៃ ៣០ ឧសភា : រដ្ឋាភិបាល លន់ នល់ ប្រកាសច្បាប់សឹក បន្ថែមពីលើ ការប្រកាស ដាក់ប្រទេស នៅក្នុង ភាពអាសន្ន ។ ខែ មិថុនា : សាឡុត សរ វិលពីទីក្រុងហាណូយ មក រតនគីរី វិញ ហើយទៅតាំងសេនាធិការដ្ឋាន នៅស្រុកសន្ទុក ខែត្រកំពង់ធំ ដែលគេកំណត់ហៅថា តំបន់ ៣១។



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

ថ្ងៃ ១៧ មិថុនា : ស៊ឺន ង៉ុក ថាញ់ មេខ្មែរសេរី មកទីក្រុងភ្នំពេញ ហើយត្រូវតែង តាំងជាទីប្រឹក្សា របស់នាយករដ្ឋមន្ត្រី។ ថ្ងៃ ៥ កក្កដា : តុលាការសឹក ទីក្រុងភ្នំពេញ កាត់ទោស សម្តេច នរោត្តម សីហនុ ដោយកំបាំងមុខ។ ថ្ងៃ ២៣ កក្កដា : ឧត្តមសេនីយ៍ លន់ នល់ សុំជុំនួយ យោធាពីប្រទេសថៃ។ ថ្ងៃ ៣១ កក្កដា :យន្តហោះអាមេរិក ទម្លាក់គ្រាប់បែកណាប៉ាល់ ទៅលើខ្ពង់រាប និង ទីក្រុងគីរីរម្យ។ នេះជាការចាប់ផ្តើមការប្រយុទ្ធ នៃ កងទ័ពអាមេរិក នៅប្រទេសកម្ពុជា។ ថ្ងៃ ១០ សីហា : «រណសិរ្សរួបរួមជាតិកម្ពុជា» ប្រកាសប្រាប់ថា ពួកគេ គ្រប់គ្រង ៥០ ភាគរយ នៃ ទឹកដីខ្មែរ ។ ថ្ងៃ ១៧ សីហា : តុលាការសឹកទីក្រុង ភ្នំពេញ កាត់ទោស អ្នកម្នាងម៉ូនិច ភរិយារបស់ សម្តេច នរោត្តម សីហនុ ដោយ កំបាំងមុខ ឲ្យជាប់ទោសមួយជីវិត ពី បទក្បត់ជាតិ ។ ថ្ងៃ ២០ សីហា : ការផ្លាស់ប្តូរ គណៈរដ្ឋមន្ត្រី នៅក្នុង រដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដើម្បី បញ្ចូលពួកខ្មែរក្រហម។ ខែកញ្ញា :ប្រតិបត្តិការសឹក «ចេនឡា» ដើម្បីបើកផ្លូវជាតិលេខ៦ ឲ្យកងទ័ព ឧត្តមសេនីយ៍ លន់ នល់។ ថ្ងៃ ៩ តុលា: ថ្ងៃប្រកាស របប «សាធារណរដ្ឋខ្មែរ» ។ ខែ វិច្ឆិកា : ឥស្សរៈខ្មែរ ដែលបានត្រូវបញ្ជូនទៅវៀតណាម ក្រោយកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ ត្រូវទីក្រុងហាណូយ បញ្ជូន មកស្រុកខ្មែរវិញ តាមផ្លូវលំ ហូ ជី មិញ។

**១៩៧១ :** ថ្ងៃ ១៣ កុម្ភ: : ឧត្តមសេនីយ៍ លន់ នល់ ដែលមានជម្ងឺស្ទាប់មួយចំហៀងខ្លួន ចេញដំណើរ ទៅព្យាបាលរោគ នៅ ហាវ៉ៃ ។ ថ្ងៃ ២ មេសា : ឧត្តមសេនីយ៍ លន់ នល់ ត្រឡប់មកស្រុកខ្មែរវិញ។ ថ្ងៃ ២១ មេសា : រដ្ឋាភិបាល ឧត្តមសេនីយ៍ លន់ នល់ លាលែងពីមុខតំណែង ហើយឧត្តមសេនីយ៍ លន់ នល់ បានទទួលងារ ជាសេនាប្រមុខ។ ថ្ងៃ ៣ ឧសភា : រដ្ឋាភិបាលថ្មី របស់ ឧត្តមសេនីយ៍ លន់ នល់ ប៉ុន្តែ អំណាចទាំងអស់ត្រូវប្រគល់ ទៅឲ្យអ្នកអង្គម្ចាស់ សិរិមតៈ ។ ខែ កក្កដា : «អង្គការ» ខ្មែរក្រហម រៀបចំគណៈកម្មាធិការ មជ្ឈិមបក្សថ្មី ។ គឺ ចាប់តាំងពីពេលនោះមកហើយ ដែលបក្សកុម្មុយនិស្តកម្ពុជា ដាក់ឈ្មោះតំបន់ដែលគេកាន់កាប់ ជាលេខសំគាល់តែម្តង។ ថ្ងៃ ២០ សីហា :

ការចាប់ផ្ដើម ប្រតិបត្តិការសឹក «ចេនឡា ទី ២» ។ ថ្ងៃ ៣០ សីហា : មហាសន្និបាតទី ៣ នៃ «បក្សកុម្មុយនិស្ដកម្ពុជា» ។ គឺនៅពេលនោះហើយ ដែល «បក្សកុម្មុយនិស្ដកម្ពុជា» បានកំណត់យក ប្រទេសវៀតណាម ជា សត្រូវទី ១ ។ ថ្ងៃ ១៦ តុលា : ប្រមុខរដ្ឋ នៃ ប្រទេសកម្ពុជា ប្រែក្លាយ រដ្ឋសភា ដែលតែងតាំងនៅឆ្នាំ ១៩៦៦ ឲ្យទៅជាសភាធម្មនុញ្ញ តាមរយៈក្រឹត្យមួយ ។ ថ្ងៃ ២០ តុលា : ការប្រកាសដាក់ប្រទេស ក្នុងភាពអាសន្ន សាជាថ្មីម្ដងទៀត ។ ប្រទេសទាំងមូលត្រូវគ្រប់គ្រង ដោយការចេញក្រឹត្យត្រង់ៗ តែម្ដង។ សេរីភាព ជាមូលដ្ឋាន បានត្រូវកាត់បន្ថយ ។ ថ្ងៃ ៣ ធ្នូ : ប្រតិបត្តិការសឹក ចេនឡា ទី ២ បានទទួល បរាជ័យទាំងស្រុង។

**១៩៧២ :** ថ្ងៃ ៥ កុម្ភៈ : របាយការណ៍មួយ របស់ ព្រឹទ្ធសភា សហរដ្ឋ អាមេរិក ស្ដីពី សភាពការណ៍ នៃ ជនភៀសខ្លួនខ្មែរ បញ្ជាក់ថា ជនភៀសខ្លួនខ្មែរ ដែលគ្មានជម្រក មាន ចំនួន ២ លាននាក់។ ថ្ងៃ ១០ មិនា : បាតុកម្មនិស្សិត បំផុស បំផុល ដោយ លន់ ណុន ប្អូន ប្រុសរបស់ ឧត្ដមសេនីយ៍ លន់ នល់ ទាមទារឲ្យ អ្នកអង្គម្ចាស់សិរិមតៈ លាលែង ពីមុខតំណែង នាយករដ្ឋមន្ត្រី ។ ថ្ងៃ ១២ មិនា : អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ លាលែង ពីមុខតំណែង ។ ថ្ងៃ ១៦ មិនា : អ្នកអង្គម្ចាស់ សិរិមតៈ ប្រកាសដកខ្លួនចេញពី ជីវិតនយោបាយ។ ថ្ងៃ ២០ មិនា : រដ្ឋាភិបាល សឺន ង៉ុក ថាន់។ ថ្ងៃ ២៦-២៧ : បាតុកម្ម និស្សិត សំដែងការមិនពេញចិត្ត នឹង នយោបាយ របស់ រដ្ឋាភិបាល ដែលបានសម្លាប់ និង ធ្វើឲ្យមនុស្ស ជាង ៣០ នាក់ ស្លាប់ និង ត្រូវរបួស ហើយដែលធ្វើឲ្យ យុវជន មួយ ចំនួន រត់ទៅចូលរណសិរ្ស រួបរួមជាតិកម្ពុជា។ ថ្ងៃ ៣០ មេសា : ប្រជាមតិ សាកសួរ ប្រជាជនថា តើពេញចិត្ត នឹងរដ្ឋធម្មនុញ្ញ នៃ របបថ្មី ឬក៏មិនពេញចិត្ត បានត្រូវរៀបចំ ឡើង។ ថ្ងៃ ១០ ឧសភា : ការប្រកាស ឲ្យប្រើរដ្ឋធម្មនុញ្ញថ្មី។ អ្នកអង្គម្ចាស់ សិរិមតៈ ត្រូវតែងតាំង ជាទីប្រឹក្សាពិសេស របស់ សេនាប្រមុខ លន់ នល់។ ថ្ងៃ ៤ មិថុនា : ការបោះឆ្នោត ប្រធានាធិបតី ។ សេនាប្រមុខ លន់ នល់ បានទទួល ៥៥ ភាគរយ នៃ សន្លឹកឆ្នោត។ លោក  អ៊ិន តាំ ២៤ ភាគរយ លោក កែវ អន ២១ ភាគរយ។ ខែ





មិថុនា : ការបង្កើត គណបក្ស នយោបាយ ដើម្បីរៀបចំ ការបោះឆ្នោតសភា ។ លោក សេនាប្រមុខ លន់ នល់ បង្កើតគណបក្ស «សង្គមសាធារណរដ្ឋ» អ្នកអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈបង្កើត «គណបក្សអ្នកសាធារណរដ្ឋ» លោក អ៊ិន តាំ និង ចៅ សៅ បង្កើត «គណបក្ស ប្រជាធិបតេយ្យ» ។ លោក អ៊ិន តាំ និង ចៅ សៅ មិនព្រមចូលរួមក្នុងការ បោះឆ្នោត ព្រោះមិនយល់ស្រប នឹងច្បាប់បោះឆ្នោត ដែលត្រៀមឲ្យលោក សេនាប្រមុខ លន់ នល់ ឈ្នះមុន ការបោះឆ្នោត ទៅទៀត។ ខែ កក្កដា : បក្សកុម្មុយនិស្ដកម្ពុជា ដែល បានដាក់ឈ្មោះខ្លួនគេ ថា «អង្គការ» តាំងពី ថ្ងៃ ១៩ មិនា ឆ្នាំ ១៩៧១ មក តម្រូវឲ្យ ប្រជាជន នៅក្នុងតំបន់ ដែលគេកាន់កាប់ ស្លៀកពាក់ ខោអាវពណ៌ខ្មៅ ។ មានតែតំបន់ ដែល សោ ភឹម គ្រប់គ្រង ប៉ុណ្ណោះ ដែលមិនព្រមអនុវត្ត បទបញ្ជានេះ របស់ អង្គការ។ ថ្ងៃ ២១ សីហា : លោក សឺន ង៉ុក ថាន់ ត្រូវគេប៉ុនប៉ងធ្វើឃាត ។ ថ្ងៃ ៣ កញ្ញា : ការ បោះឆ្នោតសភា ។ គណបក្ស «សង្គមសាធារណរដ្ឋ» របស់ លោក សេនាប្រមុខ លន់ នល់ បានទទួល ១២៦ អាសនៈ។ ថ្ងៃ ១៧ កញ្ញា : ការបោះឆ្នោតព្រឹទ្ធសភា។ គណបក្ស «សង្គមសាធារណរដ្ឋ» យកបានអាសនៈទាំងអស់ ៤០។ ឧត្ដមសេនីយ៍ សូ ខាំគយ បាន ត្រូវតែងតាំង ជាប្រធាន នៃ អង្គការនេះ។ ថ្ងៃ ៦-៧ តុលា : ស្ពាន ««ជ្រោយចង្វា» បានត្រូវកងកុម្មង់ដូមួយ របស់ ពួកវៀតណាម ខាងជើង ដាក់គ្រាប់បែកបំផ្លាញ ។ ថ្ងៃ ១៤ តុលា : រដ្ឋាភិបាល សឺន ង៉ុក ថាញ់ លាលែងពីមុខតំណែង។ ថ្ងៃ ១៧ តុលា : លោក ហង្ស ធុន ហាក់ អតីតអ្នកតស៊ូក្នុំដងរែក ជាមួយលោក សឺន ង៉ុក ថាញ់ បានត្រូវតែងតាំង ជានាយករដ្ឋមន្ត្រី ។ ថ្ងៃ ២២ តុលា : លោក ហង់រី គីស្ស៊ីងហ្គែរ ទីប្រឹក្សារបស់ លោក ប្រធានាធិបតី អាមេរិក មកទីក្រុងភ្នំពេញ។ ថ្ងៃ ២២ ធ្នូ : មេ កុម្មុយនិស្ដ គណបក្ស «ប្រជាជនបដិវត្តកម្ពុជា» ទទួលមរណភាព នៅទីក្រុងប៉េកាំង។ អៀង សារី និង ករិយា ក៏បានទៅចូលរួម ក្នុងពិធីបុណ្យខ្មោចដែរ ។

**១៩៧៣ :** ថ្ងៃ ១ មករា : លោកប្រធានាធិបតី លន់ នល់ ប្រានចោល ការចរចា ជាមួយ សម្ដេច នរោត្ដ សីហនុ។ ថ្ងៃ ២១-២៧ មករា : ជំនួប រវាងបក្សកុម្មុយនិស្ដ កម្ពុជា

និងបក្សកុម្មុយនិស្តវៀតណាម ។ បក្សកុម្មុយនិស្ត វៀតណាម ប្រាប់បក្សកុម្មុយនិស្តកម្ពុជា អំពី អត្ថន័យ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ រវាងវៀតណាម និង សហរដ្ឋ អាមេរិក។ ប៉ុន្តែ បក្សកុម្មុយនិស្តកម្ពុជា ពុំយល់ព្រម ធ្វើការចរចា ជាមួយ អាមេរិក តាមសេចក្តីស្នើ របស់ វៀតណាមទេ ។ វៀតណាម សម្រេចឈប់ផ្តល់សម្ភារយោធា ទៅឲ្យខ្មែរក្រហមទៀត។ ថ្ងៃ ២៧ មករា : ការចុះហត្ថលេខា កិច្ចព្រមព្រៀង ទីក្រុងប៉ារីស៍ ស្តីពី ប្រទេសវៀតណាម។ តាមរយៈកិច្ចព្រមព្រៀងនោះ ប្រទេសវៀតណាមខាងជើងសន្យាថា នឹង ដកកងទ័ព បន្តិចម្តងៗ ចេញពីប្រទេសកម្ពុជា ។ ថ្ងៃ ៨ កុម្ភៈ : អាមេរិក ចាប់ផ្តើមទម្លាក់គ្រាប់បែក យ៉ាងខ្លាំង រហូតដល់ ថ្ងៃ ១៥ សីហា ។ ខែ កុម្ភៈ : សម្តេច សីហនុ យាងមក ទីក្រុងហាណូយ បន្ទាប់មក ទៅតំបន់រំដោះ នៅស្រុកខ្មែរ ។ ថ្ងៃ ១៧ មិនា : វិមានប្រមុខរដ្ឋ «ចំការមន» បានត្រូវយន្តហោះមួយ ទម្លាក់គ្រាប់បែក ។ អ្នកបើកយន្តហោះនោះជាព្រះធីតុបតី (កូនប្រសាប្រុសា) របស់សម្តេចនរោត្តម សីហនុ។ មនុស្ស ៤៧ នាក់ បាត់បង់ជីវិត ប៉ុន្តែ លោកប្រធានាធិបតី លន់ នល់ បានគេចផុតពីគ្រោះថ្នាក់។ មនុស្សត្រូវជាប់សង្ស័យ ជាច្រើន បានត្រូវចាប់ខ្លួន ជាពិសេសសមាជិក រាជវង្សានុវង្ស។ ថ្ងៃ ២៣ មិនា : សម្តេច សីហនុ, អ្នកម្នាង ម៉ូនិច, លោក ហ៊ូ យន់, ហ៊ូ នឹម, ខៀវ សំផន, សុន សេន, សាឡុត សរ ជួបជុំគ្នានៅភ្នំគូលែន ដើម្បីប្រារព្ធខួបទី ៣ នៃ រណសិរ្សរួបរួមជាតិកម្ពុជា។ ថ្ងៃ ១៧ មេសា : រដ្ឋាភិបាល ហង្ស ធុន ហាក់ លាលែង ពីមុខតំណែង ។ ថ្ងៃ ១៥ ឧសភា : រដ្ឋាភិបាល អ៊ិន តាំ ។ ថ្ងៃ ១២ សីហា : នៅក្នុងបទសម្ភាសន៍មួយ ជាមួយ អ្នកកាសែត អូរីយ៉ាណា ហ្វាលឡាស៊ី (Oriana Fallaci) នៃ សារពត៌មាន ញូវយ៉កថែម (New york Times) សម្តេច នរោត្តម សីហនុ បានថ្លែងថា : «ពេលខ្មែរប្រហម លែងត្រូវការខ្ញុំ គេនឹងខ្ទាក់ខ្ញុំចោល ដូចខ្ទាក់គ្រាប់ផ្លែសឺរីស៍អ៊ីចឹង»។ ថ្ងៃ ១៥ សីហា : អាមេរិក ឈប់ទម្លាក់គ្រាប់បែក។ ខែ កញ្ញា : នៅទីក្រុងប៉ារីស៍ លោក ស៊ិម វ៉ា បង្កើតចលនា ««មូលខ្មែរ» ។ ថ្ងៃ ២២ តុលា : រដ្ឋាភិបាល ទី ២ របស់ លោក អ៊ិន តាំ ។ ថ្ងៃ ៥ វិច្ឆិកា : មហាក្សត្រីយានី កុសមៈ យាងទៅទីក្រុងប៉េកាំង។ ថ្ងៃ





៥ ធ្នូ :អង្គការ សហប្រជាជាតិ ពន្យាពេលមួយឆ្នាំ ការជជែកពិភាក្សា ស្តីពី ការផ្តល់អាសនៈទៅឲ្យប្រទេសកម្ពុជា។ ថ្ងៃ ៧ ធ្នូ : រដ្ឋាភិបាល អ៊ិន តាំ លាលែងពីមុខតំណែង។ ថ្ងៃ ២៦ ធ្នូ : រដ្ឋាភិបាល ឡុង បូរេត។

**១៩៧៤ :** ថ្ងៃ ២៦ មករា :គ្រាប់រ៉ូកែតចាប់ផ្តើមធ្លាក់ជារឿយៗ ទៅលើទីក្រុង ភ្នំពេញ។ ថ្ងៃ ១១ កុម្ភៈ : ពួកកុម្មុយនិស្ត ដែលគេហៅថា «កម្លាំងកងទ័ព ប្រជាជន រំដោះជាតិកម្ពុជា» (F.A.P.L.N.K.) បានផ្ទោងគ្រាប់កាំភ្លើងធំ ទៅលើ ទីក្រុងភ្នំពេញ ។ ថ្ងៃ ១៨ មិនា : កងទ័ពខ្មែរក្រហម ក្រោមបញ្ជាការ របស់តា ម៉ុក និង កែ ពោក វាយយកទីក្រុងឧដុង្គ បាន ។ ថ្ងៃ ២១ ឧសភា : គ្រូបង្រៀន សាស្រ្តាចារ្យ និង និស្សិត ជាច្រើន ដែលធ្វើបាតុកម្ម ប្រឆាំង នឹងរដ្ឋាភិបាល បានត្រូវចាប់ខ្លួន។ ថ្ងៃ ៤ មិថុនា : រដ្ឋមន្ត្រីអប់រំជាតិ កែវ សង្គឹម និង លោក ថាច់ ជា ទីប្រឹក្សារបស់លោក បានត្រូវគេធ្វើឃាត នៅក្នុងរបង «វិទ្យាល័យ ១៨ មិនា» អតីតវិទ្យាល័យយុគន្ធរ ។ ថ្ងៃ ១៦ មិថុនា : រដ្ឋាភិបាល ទី ២ របស់ លោក ឡុង បូរេត។ ថ្ងៃ ៩ កក្កដា : កងទ័ព សាធារណរដ្ឋខ្មែរ វាយ យកឧដុង្គ បានវិញ។ ឯកអគ្គរដ្ឋទូត សហរដ្ឋ អាមេរិក យ៉ូន ហ្គុនទែរឌីន ទទូច ឲ្យលោកប្រធានាធិបតី លន់ នល់ ចរចាជាមួយខ្មែរម្ខាងទៀត ដោយគ្មានដាក់ លក្ខខណ្ឌអ្វីជាមុនទាំងអស់។ នៅទីបំផុត លោក លន់ នល់ យល់ព្រមស្នើ ឲ្យមានការចរចា។ ប៉ុន្តែ សម្តេច សីហនុ មិនទទួលយក សេចក្តីស្នើនេះ ជាដាច់ខាត ។ សម្តេច នរោត្តម សីហនុ ថ្លែងថា : ព្រះអង្គ នឹង វិលមកភ្នំពេញវិញ លុះណាតែ ដេញប្រជាជនចេញឲ្យអស់ ពីភ្នំពេញសិន (d’après Raoul M. Jennar, *Les clés du Cambodge*, Edit. Maisonneuve & Larose, Pais 1995, p. 75)។ ថ្ងៃ ៩ តុលា : លោក ប្រធានាធិបតី លន់ នល់ បញ្ជាក់ពី ការរក្សាគោលជំហរ របស់ លោក នា ថ្ងៃ ៩ កក្កដា ដដែល។ ថ្ងៃ ២៨ វិច្ឆិកា : អាសនៈប្រទេសកម្ពុជា នៅអង្គការ សហប្រជាជាតិ បានត្រូវរក្សាទុកឲ្យសាធារណរដ្ឋខ្មែរដដែល។ ថ្ងៃ ៣០ វិច្ឆិកា : លោក ប្រធានាធិបតី លន់ នល់ បញ្ជាក់ពីគោលជំហរ ចរចា របស់ លោក នាថ្ងៃ ៩ កក្កដា និង ៩ តុលា សា ជាថ្មីទៀត ។ ថ្ងៃ

១៦ ធ្នូ : លោក ប្រធានាធិបតី បារាំង វ៉ាឡេរី ស្ហីស្ការដ៍ ដេស ស្តាំង អំពាវនាវសុំឲ្យគូភាគីខ្មែរទាំងពីរ ធ្វើការចរចា ។

**១៩៧៥** : ខែ មករា : ការចាប់ផ្តើម វាយលុក ទីក្រុងភ្នំពេញ ដោយ ពួកកុម្មុយនិស្ត ពោលគឺ ««កម្លាំងកងទ័ពប្រជាជន រំដោះជាតិកម្ពុជា» ។ ថ្ងៃ ៥ កុម្ភៈ : ពួកខ្មែរក្រហម កាត់ផ្តាច់ផ្លូវទឹក ទន្លេមេកុង ដើម្បីផ្តាច់ស្បៀងអ្នករស់នៅទីក្រុងភ្នំពេញ។ ថ្ងៃ ២៤-២៥ កុម្ភៈ : មហាសន្និបាត រណសិរ្សរួបរួមជាតិ កម្ពុជា ជាមួយ បក្សកុម្មុយនិស្តកម្ពុជា។ អង្គប្រជុំ មានការវែងគំនិតគ្នា ចំពោះ វិធានការមួយចំនួន ដែលត្រូវអនុវត្ត នៅពេលយកភ្នំពេញបាន ដូចជា ការលុបរូបិយវត្ថុចោល បញ្ហាប្រទេសវៀតណាម ជាដើម។ នៅក្នុងបញ្ជីវរជន ដែលត្រូវចាត់ទុកជាខ្មាំង ហើយ ត្រូវកាត់ទោសប្រហារជីវិត មាន ឈ្មោះ ៖ លន់ នល់, សិរិមតៈ, អ៊ិន តាំ, ចេង ហេង សុស្តែន ហ្វែរណង់ដេស, លន់ ណុន, ឡុង បូរេត។ ថ្ងៃ ២១ មិនា : រដ្ឋាភិបាល ឡុង បូរេត ទី ៣ ។ ថ្ងៃ ២៧ មិនា : សហភាព សូវៀត ផ្តាច់ការទូត ជាមួយសាធារណរដ្ឋខ្មែរ ។ ថ្ងៃ ១ មេសា : លោកសេនាប្រមុខ លន់ នល់ ព្រមទាំងគ្រួសារ ចាកចេញពី ប្រទេសកម្ពុជា ។ លោក សូ ខាំគយ ប្រធានព្រឹទ្ធសភា ត្រូវតែងតាំងជាប្រមុខរដ្ឋស្តីទី។ នៅថ្ងៃ ដដែលនោះ កម្លាំង កងទ័ពប្រជាជន រំដោះជាតិកម្ពុជា និយាយឲ្យចំ គឺពួកខ្មែរក្រហម វាយយក អ្នកលឿង បាន។ ថ្ងៃ ២ មេសា : ស្ថានីយយន្តហោះ ពោធិចិន្តុង ត្រូវគ្រាប់ផ្លោងធ្លាក់ចំជាប់រហូត។ ថ្ងៃ ១២ មេសា : ឯកអគ្គរដ្ឋទូត សហរដ្ឋ អាមេរិក យ៉ូន ហ្គុនទែរ ឌីន ព្រមទាំង បុគ្គលិកស្ថានទូត ទាំងអស់ នាំគ្នារត់ឡើងឧទ្ធម្ភាគចក្រ ចាកចេញ ពីទីក្រុងភ្នំពេញ។ មនុស្សប្រមាណ ជាង ១០ នាក់ នៅ ក្នុងនោះមាន ឧត្តមសេនីយ៍ សូ ខាំគយ ផងដែរ ក៏ទៅជាមួយដែរ។ រដ្ឋាភិបាលទាំងមូល ត្រូវជំនួសដោយគណៈកម្មាធិការ ជាន់ខ្ពស់មួយ ដឹកនាំ ដោយ ឧត្តមសេនីយ៍ សាក់ស៊ុត សាខន។ ថ្ងៃ ១៣ មេសា : ពួកខ្មែរក្រហម វាយយកស្ថានីយយន្តហោះ ពោធិចិន្តុងបាន។ ថ្ងៃ ១៥ មេសា : តាខ្មៅ ធ្លាក់ទៅក្នុងដៃ ពួកកុម្មុយនិស្ត។ ថ្ងៃ ១៧ មេសា : ពួកខ្មែរក្រហម វាយយកទីក្រុងភ្នំពេញបាន។ ប្រជាជនត្រូវជម្លៀសចេញ ពីទី





ក្រុងទាំងអស់គ្មានសល់។ ថ្ងៃ ២៤ មេសា : ប៉ុល ពត មកដល់ភ្នំពេញ បន្ទាប់ពីបានចាកចេញ ពី ទីក្រុងនេះ កាលពី ១២ ឆ្នាំមុន (១៩៦៣) ។ ថ្ងៃ ២៥-២៧ មេសា : មហាសន្និបាតជាតិ ពិសេស នៃ បក្សកុម្មុយនិស្ត កម្ពុជា ។ ប្រតិភូ ៣១១ នាក់ បានចូលរួម។ ប្រទេសកម្ពុជាមាន ឈ្មោះជាផ្លូវការថា«កម្ពុជាប្រជាធិបតេយ្យ»។ មុខនាទីប្រមុខរដ្ឋ បានត្រូវប្រគល់ មក សម្តេច នរោត្តម សីហនុ ។ សមាសភាព រាជរដ្ឋាភិបាលរួបរួមជាតិ ត្រូវរក្សា ទុកសិន ហើយមាន លោក ប៉ែន នុត ជាប្រមុខ។ ថ្ងៃ ២៧ មេសា : ព្រះមហាក្សត្រីយានីកុសមៈ ចូលទីវង្គត នៅទីក្រុងប៉េកាំង ។ ថ្ងៃ ២៧ មេសា : នៅទីក្រុងប៉ារីស៍ សមាគមមួយ មានឈ្មោះថា «សមាគមខ្មែរ» បាបត្រូវបង្កើត ហើយមាន លោក សឺន សាន ជាប្រធាន និង លោក ទ្រៀង មាលី ជាអគ្គលេខាធិការ ។ ថ្ងៃ ៣០ មេសា : នៅវៀតណាម ពួកកុម្មុយនិស្ត វាយយកទីក្រុងសាយហ្គនបាន។ នៅប្រទេសកម្ពុជា មនុស្សចំនួន ៦០០ នាក់ ដែលបានទៅសុំជ្រកកោន នៅស្ថានទូតបារាំង បានត្រូវ ដឹកតាម រថយន្ត កាម៉ុង ឆ្ពោះទៅ ប្រទេសថៃ។ ថ្ងៃ ៤ ឧសភា : ខ្មែរក្រហម វាយប្រហារទៅលើកោះភូ កុក។ ថ្ងៃ ៨ ឧស ភា : ខ្មែរក្រហម វាយប្រហារទៅលើ ខែត្រវៀតណាម ២ គឺ ៖ ហា ទៀន និង តាយ និញ ។ ថ្ងៃ ១០ ឧសភា : ខ្មែរក្រហម វាយប្រហារ ទៅលើកោះ ថូ ជូ ។ ថ្ងៃ ១២ ឧសភា : ខ្មែរក្រហម ចាប់កប៉ាល់ ««ម៉ាយ៉ាហ្គេស» របស់អាមេរិក។ ថ្ងៃ ១៩ ឧសភា : សម្តេច សីហនុ យាងទៅគង់នៅទីក្រុងព្យ៉ុងយ៉ាង ប្រទេសកូរ៉េខាងជើង។ ថ្ងៃ ២០-២៥ ឧសភា : ម៉ីទីង នៅ បុរីកីឡា ទីក្រុងភ្នំពេញ ដើម្បីទទួលយក មាគ៌ា ៨ ចំណុច របស់ បដិវត្តន៍ ៖ ១) ជម្លៀសប្រជាជន ជា អចិន្ត្រៃយ៍ ឲ្យចេញអស់ ពី ទីក្រុង - ២) បែងចែកប្រជាជនជា ២ ប្រភេទ - ៣) លុបរូបិយវត្ថុចោល - ៤) ផ្សឹកព្រះសង្ឃ ហើយបង្ខំ ឲ្យធ្វើការបង្កបង្កើតផល - ៥) សម្លាប់មន្ត្រី នៃរបប «សាធារណរដ្ឋខ្មែរ» ចោលទាំងអស់-៦) បង្កើតសហករណ៍ នៅក្នុងទូទាំងប្រទេស - ៧) ដេញជនជាតិវៀតណាម ឲ្យចេញអស់ពីស្រុកខ្មែរ-៨) ធ្វើសកម្មភាព កងទ័ព នៅតាមទល់ដែន ជាពិសេសទល់ដែនវៀតណាម។ ថ្ងៃ ២១ ឧសភា : ការប្រយុទ្ធគ្នាមួយនៅ

កោះកុង រវាង កងទ័ពព្រៃ រណសិរ្ស រួបរួមជាតិ មួយក្រុម នឹង កងទ័ព អង្គការខ្មែរក្រហម។ ថ្ងៃ ២៥ ឧសភា : កងទ័ពវៀតណាម វាយយកកោះ ថូ ជូ វិញ។ ពួកខ្មែរក្រហម វាយយកកោះកុង ប៉ុន្តែ កងទ័ពព្រៃ ដឹកនាំ ដោយ ទៀ បាញ់ ប្រឆាំង នឹង អង្គការ របស់ ប៉ុល ពត បានតស៊ូប្រយុទ្ធ រហូតដល់ ថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩។ ថ្ងៃ ២១ មិថុនា : ជំនួបសម្ងាត់ រវាង ម៉ៅ សេទុង និង សាឡុត សរ នៅទីក្រុងប៉េកាំង ។ ថ្ងៃ ៥ មិថុនា : កងទ័ពវៀតណាម មកតាំងទី នៅ កោះ ពូឡូវៃ ។ ថ្ងៃ ១៨ កក្កដា : លោក សារីន ឆាក និង លោក ជួន ប្រសិទ្ធិ ធ្វើដំណើរ ទៅទីក្រុងព៉្យងយ៉ាង ដើម្បីយាងសម្តេច សីហនុ មកស្រុកខ្មែរវិញ ប៉ុន្តែ សម្តេច សីហនុ មិនព្រមដាច់ខាត។ ខែ សីហា : ទំនាស់ រវាង លោក ហ៊ូ យន់ និង ប៉ុល ពត ស្តីពី បញ្ហា វាយប្រហារ ប្រទេសវៀតណាម។ ថ្ងៃ ២ សីហា : វៀតណាម ប្រគល់កោះ ពូឡូវៃ មកឲ្យខ្មែរវិញ។ ថ្ងៃ ៥ សីហា : ទស្សនកិច្ចផ្លូវការ របស់ អៀង សារី និង ខៀវ សំផន នៅទីក្រុងប៉េកាំង ។ ថ្ងៃ ១០ សីហា :លោក ឡេ យ៉ង់ អគ្គលេខាធិការបក្សកុម្មុយនិស្តវៀតណាមមកទីក្រុងភ្នំពេញ។ បញ្ហាព្រំប្រទល់ បានត្រូវដោះស្រាយ ។ ថ្ងៃ ១៨ សីហា : លោក ប៉ែន នុត និង ខៀវ សំផន មកទីក្រុងប៉េកាំង។ ចិន សន្យាផ្តល់ជំនួយជាច្រើន មកឲ្យរបបខ្មែរក្រហម។ ថ្ងៃ ១៩ សីហា : លោក ប៉ែន នុត និង ខៀវ សំផន មកទីក្រុងព៉្យងយ៉ាង ហើយស្នើសុំឲ្យ សម្តេច សីហនុ ធ្វើជាប្រមុខរដ្ឋ អស់មួយជីវិត ។ ម្តងនេះ សម្តេច សីហនុ ទទួលយល់ព្រម។ ថ្ងៃ ២ កញ្ញា : សម្តេច នរោត្តម សីហនុ យាងមកទីក្រុងហាណូយ។ ថ្ងៃ ៩ កញ្ញា : សម្តេច នរោត្តម សីហនុ យាងមកភ្នំពេញ ហើយ ដឹកនាំ អង្គប្រជុំ ក្រុមប្រឹក្សារដ្ឋមន្ត្រីខ្មែរក្រហម។ ព្រះអង្គស្នើសុំអង្គការខ្មែរក្រហម យកជាតុព្រះមហាក្សត្រីយានី ទៅតម្កល់នៅ អង្គរ ប៉ុន្តែ ពុំបានទទួលការអនុញ្ញាតឡើយ ។ ថ្ងៃ ២០ កញ្ញា : ជនភៀសខ្លួន ដែលបានមកដល់ប្រទេសថៃ នាំគ្នាប្តឹងអង្គការ សហប្រជាជាតិ អំពីអំពើយង់ឃ្នង របស់ពួកខ្មែរក្រហម។ នៅថ្ងៃដដែលនោះ សម្តេច នរោត្តម សីហនុ យាងទៅទីក្រុងញីវយ៉ក ចូលរួមអង្គប្រជុំ អង្គការ សហប្រជាជាតិ ។ បន្ទាប់ពីធ្វើទស្សនកិច្ចនៅក្នុងប្រទេស ចំនួន





ជាង ១០ រួមបញ្ចូល ទាំងប្រទេសបារាំងផង ព្រះអង្គ យាងទៅទីក្រុងព៉្យងយ៉ាងតែម្តង។ ថ្ងៃ ៣០ កញ្ញា : នៅប្រទេសកម្ពុជា ម៉ី ផូ អ្នកបដិវត្តជើងចាស់ម្នាក់ បានត្រូវចាប់ខ្លួន។ ខែ វិច្ឆិកា : អ្នកការទូត របស់ «រណសិរ្សរួបរួមជាតិកម្ពុជា» នៅក្រៅប្រទេស ទាំងប៉ុន្មាន បានត្រូវអង្គការខ្មែរក្រហម ហៅឲ្យចូលមកស្រុកវិញ។ ភាគច្រើនបាត់ខ្លួនរហូត។ ខែ ធ្នូ : ទំនាស់ព្រំប្រទល់ ជាមួយថៃ ។ ថ្ងៃ ១៤-១៩ ធ្នូ : សន្និបាតជាតិលើក ទី ៣ របស់ បក្ស កុម្មុយនិស្ត កម្ពុជា។ ថ្ងៃ ៣១ ធ្នូ : សម្តេច នរោត្តម សីហនុ យាងមកស្រុកខ្មែរវិញ។

**១៩៧៦ :** ថ្ងៃ ៥ មករា : រដ្ឋធម្មនុញ្ញ នៃ របបកម្ពុជា ប្រជាធិបតេយ្យ ត្រូវប្រកាសឲ្យប្រើ ។ ខែ មករា : ទស្សនកិច្ច របស់ សម្តេច សីហនុ អ្នកម្នាង ម៉ូនិច និង ខៀវ សំផន នៅខែត្រកំពង់ចាម។ ថ្ងៃ ៦ កុម្ភៈ : ការចុះហត្ថលេខា ទៅលើកិច្ចព្រមព្រៀងយោធាសម្ងាត់ រវាង របបកម្ពុជា ប្រជាធិបតេយ្យ និង ប្រទេសចិន ។ ថ្ងៃ ២ មេសា : សម្តេចនរោត្តម សីហនុ លាលែង ពីមុខតំណែង ប្រមុខរដ្ឋ។ ខៀវ សំផន ត្រូវតែងតាំងជាប្រមុខរដ្ឋ ។ ចំណែក សម្តេច សីហនុ ត្រូវខ្មែរក្រហម ដាក់ឃុំឃាំង ក្នុងរាជវាំង។ ថ្ងៃ ៦ មេសា : លោក ប៉ែន នុត លាលែងពីមុខតំណែង នាយករដ្ឋមន្ត្រី។ ថ្ងៃ ១៤ មេសា : រដ្ឋាភិបាល ប៉ុល ពត។ ខែ មេសា-ឧសភា : ការប៉ុនប៉ង វាយរំលំ ប៉ុល ពត បានត្រូវ ប៉ុល ពត ដឹងទាន់ ។ ថ្ងៃ ២០ សីហា : គណៈតំបន់ ភូមិភាគបូព៌ា ឈ្មោះ ឈូក ត្រូវចាប់ខ្លួន។ ថ្ងៃ ៣០ សីហា : កិច្ចព្រមព្រៀងពាណិជ្ជកម្ម ជាមួយប្រទេសថៃ។ ខែ កញ្ញា : ការចាប់ផ្តើម បោសសំអាត ជនក្បត់ នៅក្នុង ផ្ទៃបក្ស កុម្មុយនិស្ត កម្ពុជា ។ ថ្ងៃ ២៥ កញ្ញា : កែវ មាស ត្រូវចាប់ខ្លួន ហើយ ស្លាប់នៅ គុក ទួល ស្លែង មួយខែក្រោយមក ។ ថ្ងៃ ២៧ កញ្ញា : ប៉ុល ពត ធ្វើពុតជាឈឺ ហើយ តែងតាំង នួន ជា ឲ្យធ្វើជា នាយករដ្ឋមន្ត្រី ជំនួស ។ ថ្ងៃ ១៥ តុលា : កែវ មុនី ត្រូវចាប់ខ្លួន ។ ប៉ុល ពត វិលមកកាន់ តួនាទី ជានាយករដ្ឋមន្ត្រីវិញ ។ ថ្ងៃ ១ វិច្ឆិកា : នង សួន រដ្ឋមន្ត្រីកសិកម្ម

ត្រូវចាប់ខ្លួន ។ ថ្ងៃ ២៩ ធ្នូ : សៀន អាន អតីតឯកអគ្គរដ្ឋទូត រដ្ឋាភិបាល រួបរួមជាតិ កម្ពុជា ប្រចាំទីក្រុងហាណូយ និងប៉េកាំង ត្រូវចាប់ខ្លួន។

**១៩៧៧ :** ថ្ងៃ ៤-១១ មករា : កងទ័ពខ្មែរក្រហម វាយប្រហារ ទៅលើភូមិវៀតណាម មួយចំនួន នៅក្នុងខេត្រ ឡុង អាន, គៀន យ៉ាង, តាយ និញ, ដាក់ ឡាក់ និង ដុង ថាប់ ។ ថ្ងៃ ១៥-១៨ មករា : កងទ័ពខ្មែរក្រហម វាយប្រហារ ទៅលើភូមិ វៀតណាម នៅក្នុងខេត្រ ទាំង ៥ ខាងលើនេះ ប្រមទាំង ក្នុងខេត្រ អាន យ៉ាង ផងដែរ។ ថ្ងៃ ២៥ មករា : កុយ ធួន រដ្ឋមន្ត្រីហិរញ្ញវត្ថុ និង ពាណិជ្ជកម្ម ត្រូវចាប់ខ្លួន។ ថ្ងៃ ២៦ មករា : រដ្ឋមន្ត្រី សាធារណការ ទូច ភឿន ត្រូវចាប់ខ្លួន ។ ថ្ងៃ ២៨-២៩ មករា : កងទ័ពខ្មែរក្រហម វាយប្រហារទៅលើភូមិថៃ បាអាន នងដោ, បាអាន កូងកោ និង បាអាន ណយ ប៉ារ៉ៃ ក្នុងស្រុក អរញ្ញប្រាថេត ។ ខែ កុម្ភៈ : មានការប៉ុនប៉ង វាយរំលំ ប៉ុល ពតម្តងទៀត ។ រឿងនេះ បណ្តាលឲ្យមាន ការបោសសំអាត ជនក្បត់ផ្ទៃក្នុង យ៉ាងខ្លាំងក្លាថែមទៀត ។ រដ្ឋមន្ត្រីម្នាក់ ឈ្មោះ សឿ ឌឿម បានត្រូវចាប់ខ្លួន។ ថ្ងៃ ១៤ មិនា : លោក កោគ ឆាយ អតីតប្រធាន សមាគម មិត្តភាព ចិន-ខ្មែរ ត្រូវចាប់ខ្លួន។ ថ្ងៃ ១០ មេសា : លោក ហ៊ូ នឹម រដ្ឋមន្ត្រីឃោសនាការត្រូវចាប់ខ្លួន។ ថ្ងៃ ៦ មិថុនា : ទីវ អុល ត្រូវចាប់ខ្លួន។ ខែ វិច្ឆិកា : សោ ភឹម គណៈភូមិភាគបូព៌ា រៀបចំផែនការ ប្រឆាំង នឹង ប៉ុល ពត ។ ថ្ងៃ ២៥ ធ្នូ : ការវាយប្រហារ នៃ កងទ័ពវៀតណាម។ ថ្ងៃ ៣១ ធ្នូ : ប៉ុល ពតផ្តាច់ ទំនាក់ទំនងការទូត ជាមួយ វៀតណាម។ ចិន បញ្ជូនសម្ភារយោធា ដ៏សន្ធឹកសន្ធាប់មកឲ្យខ្មែរក្រហម។

**១៩៧៨:** ថ្ងៃ ៦ មករា : ខ្មែរក្រហមវាយបក ទៅលើប្រទេសវៀតណាមវិញ។ កងទ័ពវៀតណាម ដកថយ ទុកតែកន្លែងខ្លះប៉ុណ្ណោះ។ ជនជាតិខ្មែរប្រមាណ ១០ ម៉ឺននាក់ នាំគ្នារត់ទៅវៀតណាម។ ថ្ងៃ ១៨ មករា : លោកស្រី តេង យីនចៅ ភរិយាម៉េម៉ាយ របស់ លោក ជូ អេន ឡាយ មកប្រទេសកម្ពុជា ដើម្បីប្រាប់ ខ្មែរក្រហមថា ឲ្យបន្ធូរដៃ





បន្តិច។ នៅក្នុងឱកាសនោះ ប៉ុល ពត មិនឲ្យលោកស្រី ជួប សម្តេច សីហនុ ទេ ។ ថ្ងៃ ២៦ មិនា : ជូ ចិត្ត លេខាតំបន់បស្ចិម ត្រូវចាប់ខ្លួន ។ នេះជា ការចាប់ផ្តើមចាប់ខ្លួន កម្មាភិបាលធំៗ ជាខ្សែស្រឡាក់ នៅតាមភូមិភាគបស្ចិម ឧត្តរ និង បូព៌ា។ ថ្ងៃ ២៩ មិនា : កងទ័ពវៀតណាម វាយចូលមកដល់ តាកែវ និង កំពត ដោយមាន រថក្រោះ ជាជំនួយថែមទៀត។ ថ្ងៃ ៣ មេសា : វិទ្យុទីក្រុងហាណូយ ជាភាសាខ្មែរ អំពាវនាវ ឲ្យខ្មែរងើបឡើងបះបោរ ប្រឆាំង នឹងខ្មែរក្រហម។ ថ្ងៃ ២២ មេសា : វៀតណាម រៀបចំ កងពលតូច សម្រាប់ វាយប្រហារខ្មែរក្រហម។ ថ្ងៃ ២៤ ឧសភា : ប៉ុល ពត បញ្ជូនកងទ័ពដោយមានថេក្រោះ ជាជំនួយផង ទៅចាប់អ្នកប្រឆាំង នៅភូមិភាគបូព៌ា។ គឺ នៅពេលនោះហើយ ដែលមាន ការបង្ហូរឈាមមួយ ដ៏ធំសម្បើម។ អ្នកបាត់បង់ជីវិត មានចំនួន ១០ ម៉ឺននាក់។ ថ្ងៃ ៣ មិថុនា : សោ ភឹម ធ្វើអត្តឃាត ។ លោក ហេង សំរិន រត់ទៅវៀតណាម។ ថ្ងៃ ១១ មិថុនា : លោក ញឹម រស់ អ្នកទទួលខុសត្រូវភូមិភាគពាយ័ព្យ ត្រូវចាប់ខ្លួន។ ថ្ងៃ ១២ មិថុនា : អៀងសារី មកទីក្រុងតូក្យូ ថ្កោលទោសថា អង្គការ សេ អ៊ី អា និង វៀតណាម រៀបចំកំទេច របបកម្ពុជា ប្រជាធិបតេយ្យ។ ថ្ងៃ ២៦-២៨ មិថុនា : វៀតណាម ធ្វើការវាយលុកមួយ ដ៏ សំខាន់ មកក្នុងប្រទេសកម្ពុជា ។ ថ្ងៃ ៨ កញ្ញា : ការវាយប្រហារ នៃ កងទ័ពអាកាស វៀតណាម ។ ខែ វិច្ឆិកា : វន វេត ឧបនាយករដ្ឋមន្ត្រីត្រូវចាប់ខ្លួន។ ថ្ងៃ ២ ធ្នូ : ខ្មែរក្រហមប្រឆាំង នឹង ប៉ុល ពត មកជួបជុំ គ្នានៅស្នួល ហើយ បង្កើត «រណសិរ្សសង្គ្រោះជាតិកម្ពុជា» ក្រោមការដឹកនាំ របស់ លោក ហេង សំរិន ។ ថ្ងៃ ២២ ធ្នូ : ឃាតកម្ម ទៅលើអ្នកស្រាវជ្រាវ អង់គ្លេសម្នាក់ឈ្មោះ ម៉ាល់ខុម កាដវែល (Malcom Cadwell) ដែលបានមក ប្រទេសកម្ពុជា ជាមួយអ្នកកាសែតអាមេរិក ២ នាក់ គឺ លោកស្រី អេលីស្សាបែត បេគែរ (Elisabeth Becker) និង ដាយ ឌុតម៉ាន់ (Dick Dudman) ។ ម៉ាល់ខុម កាដវែល ជា មិត្តម្នាក់ របស់ ប៉ុល ពត។ ឃាតកម្មនេះ ជាអាថ៌កំបាំងមួយដ៏ធំ ត្បិត ប៉ុល ពត និង ម៉ាល់ខុម ពុំមានទំនាស់អ្វី នឹងគ្នាឡើយ។ ថ្ងៃ ២៥ ធ្នូ : វៀតណាម ធ្វើការវាយប្រហារ ក្នុងទ្រង់ទ្រាយមួយ ដ៏ធំ

ទៅលើ កងទ័ពខ្មែរក្រហម ដោយមាន កងទ័ព ១០ ម៉ឺន នាក់ ខាងវៀតណាម បូករួមជាមួយកម្លាំង «រណសិរ្ស សង្គ្រោះជាតិកម្ពុជា» ដែលមាន យុទ្ធជន ២ ម៉ឺននាក់។ ថ្ងៃ ៣០ ធ្នូ : ខេត្តក្រចេះ បានត្រូវរំដោះចេញពី ខ្មែរក្រហម។

**១៩៧៩ :** ថ្ងៃ ១ មករា : នៅពេលដែល កងទ័ពវៀតណាម វាយសំដៅ យក ទីក្រុងភ្នំពេញ ពួកខ្មែរក្រហម បាននាំ សម្តេច នរោត្តម សីហនុ ទៅលាក់ទុក នៅបាត់ដំបងបន្ទាប់មក នៅស៊ីសុផុន។ ថ្ងៃ ២ មករា : កងកុម្មង់ដូ វៀតណាម ដែលមាន បេសកកម្មរំដោះសម្តេច នរោត្តម សីហនុ ពី កណ្តាប់ដៃ ខ្មែរក្រហម បានទទួលបរាជ័យ ។ ថ្ងៃ ៣ មករា : ខេត្តស្ទឹងត្រែង បានត្រូវរំដោះចេញពីខ្មែរក្រហម។ ថ្ងៃ ៤ មករា : កងទ័ពវៀតណាម កាន់កាប់ត្រើយខាងកើត នៃ ទន្លេ មេគុង ទាំងអស់។ ថ្ងៃ ៥ មករា : ខេត្តតាកែវបានត្រូវរំដោះចេញពី ខ្មែរក្រហម។ សម្តេច នរោត្ត សីហនុ យាងមកភ្នំពេញវិញ។ នៅ ល្ងាចថ្ងៃ ដដែលនោះ ព្រះអង្គ ជួបសន្ទនា ជាមួយ ប៉ុល ពត នៅវិមានរដ្ឋាភិបាល។ នៅមេមត់ សមាជិកនានា នៃ «រណសិរ្សសង្គ្រោះជាតិកម្ពុជា» បើក មហាសន្និបាត មួយដែលគេចាត់ទុកថាជា មហាសន្និបាតទី ៣ នៃ ចលនា កុម្មុយនិស្តខ្មែរ ។ ថ្ងៃ ៦ មករា : ខេត្តកំពង់ចាម បានត្រូវរំដោះចេញពី ខ្មែរក្រហម ។ ការចាកចេញដំណើររបស់ សម្តេច នរោត្តម សីហនុ ព្រមទាំងគ្រួសារ និងលោក ប៉ែន នុត ឆ្ពោះទៅ ទីក្រុងប៉េកាំង តាមយន្តហោះចិនមួយ ដែល រដ្ឋាភិបាលចិន បានបញ្ជូនមក ជាបន្ទាន់ ។ ថ្ងៃ ៧ មករា : កងទ័ពវៀតណាម និងរណសិរ្សសង្គ្រោះជាតិកម្ពុជា បានមកដល់ទីក្រុងភ្នំពេញ។ របប ខ្មែរក្រហម ត្រូវរលំរលាយ។ ពួកមេខ្មែរក្រហម រត់ទៅប្រទេសថៃ តាមរទេះភ្លើង និង តាមឧត្តម្កាគបក្រ។ ការវាយរំលំ របបខ្មែរក្រហមនេះ ត្រូវសហគមន៍អន្តរជាតិ ចាត់ទុកថាជា ការឈ្លានពាន របស់ វៀតណាម មកលើទឹកដីខ្មែរ។ ថ្ងៃ ៨ មករា : ដោយមានការគាំទ្រពីកងទ័ពវៀតណាមរណសិរ្សសង្គ្រោះជាតិកម្ពុជា បង្កើតរដ្ឋាភិបាលបណ្តោះអាសន្នមួយ មានឈ្មោះថា «ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា» ដែលមាន លោក ហេង សំរិន ជាប្រធាន និង លោក ប៉ែន សុវណ្ណ ជាអនុប្រធាន។ ថ្ងៃ ១១ មករា : សម្តេច





នរោត្តម សីហនុ ចេញធ្វើអន្តរាគមន៍ នៅអង្គការ សហប្រជាជាតិ តាងនាមឲ្យ របប «កម្ពុជាប្រជាធិបតេយ្យ»» របស់ ខ្មែរក្រហម។ ថ្ងៃ ១២ មករា: ការចាប់កំណើត នៃ របប «សាធារណរដ្ឋប្រជាមានិតកម្ពុជា»។ ថ្ងៃ ១៣ មករា : ក្រុមប្រឹក្សាសន្តិសុខអង្គការ សហប្រជាជាតិ តម្រូវឲ្យមាន ការដកកងទ័ពបរទេសទាំងអស់ ចេញពីប្រទេសកម្ពុជា ហើយ ចាត់ទុកថា របបកម្ពុជា ប្រជាធិបតេយ្យ របស់ ខ្មែរក្រហម ជារដ្ឋាភិបាលត្រឹមត្រូវ នៃប្រទេសកម្ពុជា ។ ថ្ងៃ ១៤ មករា : សម្តេច នរោត្តម សីហនុ គេចចេញ ពីការឃ្លាំមើល របស់ គណប្រតិភូ ខ្មែរក្រហម ហើយ ស្នើសុំ សទ្ធិជ្រកកោននយោបាយពី សហរដ្ឋ អាមេរិក។ ប៉ុន្តែ សហរដ្ឋ អាមេរិក ពុំហ៊ានផ្តល់សទ្ធិនេះថ្វាយសម្តេចសីហនុ ឡើយ ព្រោះ ខ្លាចធ្វើឲ្យប៉ះ ពាល់ ដល់ទំនាក់ទំនង ការទូត ជាមួយចិន។ នៅ អូតាប៉ាវ ប្រទេសថៃឯនោះវិញ ចិន និង ថៃ ចុះកិច្ចព្រមព្រៀងសម្ងាត់មួយ ដើម្បីគាំទ្រសកម្មភាព ខ្មែរក្រហម។ ថ្ងៃ ២៥ មករា: សម្តេច សីហនុ បានថ្លែងថា ព្រះអង្គ បានផ្តាច់ខ្លួន ចេញពី ខ្មែរក្រហម។ ចុងខែកុម្ភៈ : លោក តេង ស៊ាវ ពីង យាងសម្តេចនរោត្តម សីហនុ ឲ្យវិលទៅគង់ នៅទីក្រុងប៉េកាំង វិញ ។ ថ្ងៃ ១៥-១៩ សីហា : រដ្ឋាភិបាលបណ្តោះអាសន្ន «ក្រុមប្រឹក្សាប្រជាជន បដិវត្តកម្ពុជា» គាំទ្រដោយ ទីក្រុងហាណូយបង្កើត តុលាការ កាត់ទោសដោយកំបាំងមុខ ប៉ុល ពត, អៀង សារី ពី បទប្រល័យពូជសាសន៍។ ថ្ងៃ ៩ តុលា : ការបង្កើត «រណសិរ្សជាតិ រំដោះ ពលរដ្ឋខ្មែរ» (F.N.L. P.K.) ដែលមាន លោក សឺន សាន ជាអ្នកដឹកនាំ ។ ថ្ងៃ ១២ តុលា : ជំនួប នៅទីក្រុងម៉ូស្គូ រវាង លោក ប៉ែន សុវណ្ណ អនុប្រធាន ក្រុមប្រឹក្សា ប្រជាជន បដិវត្ត កម្ពុជា និង លោក ប្រេសណេហ្វ លេខាទី ១ នៃ បក្សកុម្មុយនិស្ត សហភាព សូវៀត ។

**១៩៨០ :** ថ្ងៃ ៥ មិនា : ការចរចា រវាង សម្តេច សីហនុ និងខៀវ សំផន។ សម្តេចសីហនុ ស្នើឲ្យបង្កើតរណសិរ្សតែមួយប្រឆាំងនឹងវៀតណាម។ ខ្មែរក្រហម ពុំព្រម ព្រោះសម្តេច សីហនុ ក៏បានស្នើ ឲ្យក្រុមខ្មែរទាំងអស់ ដាក់អាវុធផងដែរ នៅពេលដែលវៀតណាម ដកកងទ័ព។ ថ្ងៃ ២០ មិនា : ប្រាក់រៀលបានត្រូវដាក់ឲ្យប្រើសាជាថ្មី នៅប្រទេស

កម្ពុជា។ ថ្ងៃ ២២ មិថុនា : កងទ័ព វៀតណាម វាយប្រហារទៅលើតំបន់ដែល ខ្មែរក្រហមកាន់កាប់ ហើយឆ្លងកាត់ទល់ដែនថៃ ។ ថ្ងៃ ៧ កក្កដា : ប្រទេសឥណ្ឌា ទទួលស្គាល់ សាធារណរដ្ឋប្រជាមានិតុកម្ពុជា។ ថ្ងៃ ២២ តុលា : មហាសន្និបាតអង្គការ សហប្រជាជាតិ អនុម័ត សេចក្តីសេចក្តីសម្រេចចិត្ត របស់ អាស៊ាន ដែលតម្រូវឲ្យវៀតណាមដកកងទ័ពចេញពីស្រុកខ្មែរ ដោយ ៩៧ សំឡេង (២០ សំឡេងប្រឆាំង ២២ សំឡេងអនុប្បវាទ) ។

**១៩៨១ :** ថ្ងៃ ៨ កុម្ភៈ : សម្តេច នរោត្តម សីហនុ ថ្លែងថា ព្រះអង្គ ត្រៀមលក្ខណៈជាស្រេច ដើម្បីដឹកនាំ កម្លាំងទាំងអស់ ដែលប្រឆាំង នឹង វត្តមាន កងទ័ពវៀតណាមនៅលើ ទឹកដីខ្មែរ ។ ថ្ងៃ ២៦ មិនា : ការបង្កើត ចលនា រាជានិយម «ហ៊្វុនស៊ិនប៉ិច» (F.U.N.C.I.N.P.E.C.) នៅទីក្រុងប៉ារីស៍ ។ ថ្ងៃ ១ ឧសភា : របប សាធារណរដ្ឋប្រជាមានិតុកម្ពុជា បោះឆ្នោតជ្រើសតាំងរដ្ឋសភា (១១៧ អសនៈ ១៤៨ បេក្ខជន)។ ថ្ងៃ ២៦-២៩ ឧសភា : មហាសន្និបាតទី ៤ នៃ បក្សប្រជាជន បដិវត្ត កម្ពុជា ។ លោក ប៉ែន សុវណ្ណ បានត្រូវតែងតាំងជា អគ្គលេខាធិការបក្ស។ ថ្ងៃ ២៤ មិថុនា : ប្រជុំពេញអង្គលើកដំបូងបង្អស់ នៃ រដ្ឋសភា នៃ របបសាធារណរដ្ឋ ប្រជាមានិតុកម្ពុជា ។ លោក ជា ស៊ីម បានត្រូវតែងតាំង ជាប្រធានរដ្ឋសភា លោក ហេង សំរិន ជា ប្រធានក្រុមប្រឹក្សារដ្ឋ និង លោក ប៉ែន សុវណ្ណ ជារដ្ឋមន្រ្តីទី ១ ។ ថ្ងៃ ៩ កក្កដា : ការចេញផ្សាយ រដ្ឋធម្មនុញ្ញ នៃ របបសាធារណរដ្ឋ ប្រជាមានិតុ កម្ពុជា។ ថ្ងៃ ៤ ធ្នូ : លោក ប៉ែន សុវណ្ណ ត្រូវដកចេញ ពីមុខតំណែង រដ្ឋមន្រ្តីទី ១ និង ពី មុខតំណែង អគ្គលេខាធិការ បក្ស ប្រជាជន បដិវត្ត កម្ពុជា។

**១៩៨២ :** ថ្ងៃ ១ កុម្ភៈ : មុននឹងចាកចេញពីប្រទេសបារាំង សម្តេច នរោត្តម សីហនុ បានថ្លែងថាៈ ព្រះអង្គឈប់បន្ត ការប្រឹងប្រែងដើម្បីរកផ្លូវចរចា ជាមួយ ទីក្រុងហាណូយទៀតហើយ។ ព្រះអង្គត្រៀមលក្ខណៈជាស្រេចដើម្បី ដឹកនាំ ចលនាតស៊ូ ប្រឆាំង នឹង



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

វៀតណាម។ ថ្ងៃ ៥-១១ កុម្ភៈ : អង្គប្រជុំលើក ទី ២ នៃ រដ្ឋសភា។ លោក ចាន់ ស៊ី ត្រូវត្រូវតែងតាំង ជា រដ្ឋមន្រ្តី ទី ១ ជំនួសលោក ប៉ែន សុវណ្ណ ដែលត្រូវបញ្ជូនទៅឃុំឃាំងនៅវៀតណាម។ ថ្ងៃ ២៧ កុម្ភៈ : នៅទីក្រុងហ្សឺណែវ គណៈកម្មការសិទ្ធិមនុស្ស អង្គការសហប្រជាជាតិ ថ្កោលទោស ការឈ្លានពានទឹកដីខ្មែរ ដោយ កងទ័ពវៀតណាម ហើយចាត់ទុកថា ជាការរំលោភសទ្ធិមនុស្ស ។ ថ្ងៃ ១៦ ឧសភា : ទីក្រុងហាណូយ និង ទីក្រុងភ្នំពេញ ស្នើឲ្យដាក់អាសនៈកម្ពុជា នៅអង្គការ សហប្រជាជាតិ នៅទំនេរ។ ថ្ងៃ ៧ កក្កដា : ការចុះហត្ថលេខា នៅទីក្រុង ហូ ជិមិញ ទៅលើ សន្ធិសញ្ញា «ដែន សមុទ្រ»» រវាងសាធារណរដ្ឋប្រជាមានិតុកម្ពុជា និង ប្រទេសវៀតណាម។ ថ្ងៃ ១៥ កក្កដា : វៀតណាមដកកងទ័ពមួយផ្នែក ចេញពីប្រទេសកម្ពុជា ។ ថ្ងៃ ១៩ កក្កដា : ការចាប់ផ្តើមកសាង «កំផែង ក ៥ » ដែលកេណ្ឌមនុស្ស យ៉ាងសន្ធឹកសន្ធាប់ ទៅកសាង ប្រព័ន្ធការពារទប់ទល់ នឹង ខ្មែរក្រហម។

**១៩៨៣ : ថ្ងៃ ៦ មិនា** : សម្តេច នរោត្តម សីហនុ ថ្កោលទោស ចលនា មិនចូលបក្សសម្ព័ន្ធ ដែលបានស្នើសុំ ឲ្យទុក អាសនៈកម្ពុជា នៅ អង្គការ សហប្រជាជាតិ នៅទំនេរ។ ថ្ងៃ ៣០ មិនា : ការវាយប្រហារ រដូវក្តៅ នៃ កងទ័ព វៀតណាម ទៅលើកងទ័ពរំដោះខ្មែរ ជាពិសេស ទៅលើជំរំ អូ ស្មាច់ ខាងក្រុម របស់ សម្តេច សីហនុ និង នៅតំបន់ ភ្នំ ឆាត ជំរំ ខ្មែរក្រហម លេខ ៥១៩ ព្រមទាំង តំបន់ របស់ «រណសិរ្សជាតិរំដោះពលរដ្ឋខ្មែរ» របស់ លោក សឺន សាន ផងដែរ ។ ថ្ងៃ ១២ មេសា : អង្គប្រជុំវិសាមញ្ញ នៃរដ្ឋមន្រ្តីការបរទេស ប្រទេស ទាំង ៣ នៅ ឥណ្ឌូចិន ដើម្បីអំពាវនាវស្នើឲ្យមានការជជែកគ្នា ជាមួយ បណ្តាប្រទេស អាស៊ាន ។ ថ្ងៃ ២៨ មេសា : ជំនួប រវាងសម្តេច នរោត្តម សីហនុ និង លោក ហ្វ្រង់ស្វា មីត្តេរ៉ង់ នៅទីក្រុងប៉ារីស៍ ។ ថ្ងៃ ១៣ មិថុនា : សម្តេច សីហនុ បញ្ជាក់ប្រាប់ លោក ខៀវ សំផន អំពី ការសុំលាលែង ពីមុខតំណែង របស់ ព្រះអង្គ ពីរដ្ឋាភិបាលចម្រុះ។

***១៩៨៤ :*** *ថ្ងៃ ២៦ កក្កដា : លោក ហ៊ុន សែន នាយករដ្ឋមន្ត្រី សាធារណរដ្ឋ ប្រជាមានិតុកម្ពុជា ថ្លែងថា សម្តេច សីហនុ និងលោក សឺន សាន អាចនឹងមានតួនាទី នយោបាយ ប្រសិនណាជាអ្នកទាំងពីរ ត្រឡប់មកវិញ ហើយ សន្យាថា នឹង គោរពរដ្ឋធម្មនុញ្ញ សាធារណរដ្ឋ ប្រជាមានិតុ កម្ពុជា ។ ថ្ងៃ ៣ សីហា : ភ្នាក់ងារពត៌មាន បារាំង អា អេហ្វ ប៉េ* (AFP) *ជូនដំណឹងថា លោក ជួន ជុំ អតីតរដ្ឋមន្ត្រី ហិរញ្ញវត្ថុខ្មែរក្រហម និងលោក គាត ឆុន រដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការ ទីស្តីការ ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី របប កម្ពុជាប្រជាធិបតេយ្យ បានរំដោះខ្លួនចេញ ពី របបនេះ ។ ថ្ងៃ ៨ សីហា : ជំនួប រវាងសម្តេច សីហនុ និង ប្រធានាធិបតីបារាំង មីត្តេរ៉ង់។ ថ្ងៃ ១៤ សីហា : នៅទីក្រុងអូស្លូ សម្តេច សីហនុ ប្រកាសមិនឲ្យ អ្នកដឹកនាំ សាធារណរដ្ឋប្រជាមានិតុកម្ពុជា ចូលក្នុងរដ្ឋាភិបាល ចតុភាគី។ ថ្ងៃ ២៤ ធ្នូ :អ្នកតំណាងរាស្ត្រអាមេរិក ស្តេហ្វែន សូឡា មក ជួបលោក ហ៊ុន សែន នៅទីក្រុងភ្នំពេញ។ ថ្ងៃ ២៧ ធ្នូ : កងទ័ព សាធារណរដ្ឋ ប្រជាមានិតុ កម្ពុជា រួមជាមួយកងទ័ពវៀតណាម វាយយកមូលដ្ឋានសំខាន់ៗ របស់ កងទ័ព រំដោះ ដូចជា បក្សី, សុក សាន, នង សាមេត ជាដើម។ ថ្ងៃ ៣១ ធ្នូ : លោក ចាន់ ស៊ី នាយករដ្ឋមន្ត្រី របប សាធារណរដ្ឋ ប្រជាមានិតុ កម្ពុជា ទទួលមរណភាព នៅក្នុង មន្ទីរពេទ្យមួយ នៅទីក្រុងម៉ូស្គូ។*

***១៩៨៥ :*** *ដើមខែ មករា : កងទ័ព សាធារណរដ្ឋ ប្រជាមានិតុ កម្ពុជា រួមជាមួយ កងទ័ពវៀតណាម វាយយកទីបញ្ជាការ នៃ កងទ័ពរំដោះ នៅអំពិល និង មូលដ្ឋាន កងទ័ព ខ្មែរក្រហម នៅ ណាំ យុន និង ចុង បុក ។ ថ្ងៃ ១៤ មករា : លោក ហ៊ុន សែន ត្រូវតែងតាំង ជានាយករដ្ឋមន្ត្រី ជំនួស លោក ចាន់ ស៊ី។ ការបង្កើតជំរំ ខ្មែរក្រហមមួយ នៅ ខៅ តា ង៉ុក ។ មូលដ្ឋាន តាទុំ ធ្លាក់ទៅក្នុង ដៃ កងទ័ព សាធារណរដ្ឋ ប្រជាមានិតុ កម្ពុជា និង វៀតណាម ។ ថ្ងៃ ៩ មិនា : ការរៀបចំផ្លាស់ប្តូរ នៅក្នុង រដ្ឋាភិបាល ហ៊ុន សែន។ ថ្ងៃ ១២ មិនា : លោក ហ៊ុន សែន ស្នើលក្ខខណ្ឌ ៦ ដើម្បីដោះស្រាយ អធិ*





*ករណ៍ខ្មែរ ។ ថ្ងៃ ២៣ មេសា : សម្តេច សីហនុ សុំលាលែងពីមុខតំណែង ប្រធានរដ្ឋាភិបាលចម្រុះ កម្ពុជាប្រជាធិបតេយ្យ ដោយ មូលហេតុសុខភាព។ ថ្ងៃ ២៥ មេសា : សម្តេច សីហនុ ដកពាក្យសុំលាលែង ពីមុខតំណែងវិញ។ ថ្ងៃ ១៨ មេសា : លោក ប៉ែន នុត ទទួលមរណភាពនៅក្នុង ជន្មាយុ ៨១ ឆ្នាំ។ ថ្ងៃ ១៣-១៦ តុលា : មហាសន្និបាត ទី ៥ នៃ បក្សប្រជាជនបដិវត្តកម្ពុជា ។ ១៨ តុលា : សេនាប្រមុខ លន់ នល់ ទទួលមរណភាព នៅក្នុងជន្មាយុ ៧២ ឆ្នាំ នៅ កាលីហ្វ័រនី ។*

***១៩៨៦ :*** *ថ្ងៃ ៧ កុម្ភ: : រដ្ឋសភា សាធារណរដ្ឋ ប្រជាមានិតុ កម្ពុជា បន្ត នីតិកាលមួយអាណត្តិទៀត ។ ថ្ងៃ ១៧ មិនា : សេចក្តីស្នើ ៨ ចំណុច របស់ ទីក្រុងប៉េកាំង ដើម្បីបញ្ចប់អធិករណ៍ ខ្មែរ។*

***១៩៨៧ :*** *ថ្ងៃ ២-ធ្នូ : ជំនួបទី ១ រវាង លោក ហ៊ុន សែន និង សម្តេច នរោត្តម សីហនុ នៅ ហ្វែរ អង់តារដឺន័រ ប្រទេសបារាំង។*

***១៩៨៨ :*** *ថ្ងៃ ២០-២១ មករា : ជំនួប ទី ២ រវាង លោក ហ៊ុន សែន និង សម្តេច នរោត្តម សីហនុ នៅ សាំង ស្ហែរម៉ាំង អង់ឡេ ប្រទេសបារាំង។ ថ្ងៃ ៣០ មករា : សម្តេច នរោត្តម សីហនុ ប្រកាសលាលែងពីមុខតំណែងប្រធានរដ្ឋាភិបាលចម្រុះ ហើយ ប្រគល់ ការដឹកនាំ ចលនា្តនស៊ីនប៉េច ទៅឲ្យ ព្រះអង្គម្ចាស់ រណឫទ្ធិ ជាព្រះរាជបុត្រ ។*

***១៩៨៩ :*** *ថ្ងៃ ២៤ វិច្ឆិកា : ផែនការសន្តិភាព របស់ លោក ហ្គារេត អ៊ីវេន្ស រដ្ឋមន្ត្រីការបរទេស ប្រទេសអូស្ត្រាលី ។*

# ស្តេច ដែលគ្រងរាជ្យនៅស្រុកខ្មែរ*

## ស្តេច នគរភ្នំ (ហ៊្វូ ណាន់)

- លីវ យី (ពាក់កណ្ដាលសតវត្សរ៍ ទី ១ នៃ គ្រីស្តសករាជ)
- ហ៊្វីនទៀន [កៅណ្ឌិន្យ ទី ១] (គ. ស. ៦៨)
- ហ៊្វីន ប៉ាន់ ហ្វាង (ពាក់កណ្ដាល ទី ២ នៃ សតវត្សរ៍ ទី ២)
- ប៉ាន់ ប៉ាន់ (ដើមសតវត្សរ៍ ទី ៣)
- ហ្វាន់ ឆេ ម៉ាន់ [ស្រី មារ] (២០៥-២២៥)
- ហ្វាន់ ជិង សេង (២២៥- ?)
- ហ្វាន់ ចាន់ (២២៥-២៤០)
- ហ្វាន់ ស៊ីយុន (២៤០-២៨៧)

ពី ឆ្នាំ ២៨៧ មក ឆ្នាំ ៣៥៧ : ស្តេច ពុំស្គាល់ឈ្មោះ

- ចាន់ តាន់ ឬ ចណ្ឌណ (៣៥៧-?)

---

*ឯកសារដែលបានយកមកផ្គូរផ្គង (recoupements): *Les Etats hindouisés d'Indochine et d'Indonésie*, George Coedes, Paris 1964 –*Inscrip-tions du Cambodge*, VI,George Coedes, Paris, Ecole Française d'Extrême-Orient, 1954 - *Monarques du Cambodge*, Wikipédia, 2011 – *La vie quotidienne dans la Péninsule indochinoise à l'époque d'Angkor (800 à1300)*, Louis Frédéric, Hachette, Paris, 1981 – *Essai de Tableau chronologique des rois du Cambodge de la période post-angkorienne*, Mak Phoeun, Journal asiatique, p. 101-161 – *Le Cambodge entre le Siam et le Viêtnam* (1775 à1860), Khin Sok, Paris, Pub. EFEO, 1991 – Les chroniques royales - *Histoire du Cambodge*, Adhémard Leclère, Paul Geuthner, Paris, 1914 - *Histoire du Cambodge*, A. Dauphin-Meunier, Que sais-je , 1968, et d'autres documents (sources indiennes, chinoises, etc…)- Certaines transcriptions en caractères khmers sont de l'auteur.





- កៅណ្ឌិន្យ ទី ២ (៤២០-៤៣៤)
- ស្រី-ឥន្ទ្រវរ្ម័ន ទី ១ (៤៣៤-៤៣៥)
- ? (៤៣៥-៤៨៧)
- ជ័យវរ្ម័ន-កៅណ្ឌិន (៤៧០/៤៧៨ -៥១៤)
- គុណវរ្ម័ន (៥១៤-៥១៤) ; បុត្រ របស់ ជ័យវរ្ម័ន-កៅណ្ឌិន ត្រូវ រុទ្រវរ្ម័ន (បងប្អូន មាតាផ្សេងពីគ្នា ) ធ្វើគុតៗ មាតារបស់ គុណវរ្ម័ន គឺព្រះមហាក្សត្រិយានី កុលាព្រះភវត្តីៗ
- រុទ្រវរ្ម័ន (៥១៤-៥៣៩ ? ៥៤៥ ? ៥៥០ ?), ស្តេចជ្រែករាជ្យ

ពី ឆ្នាំ ៥៥០ មក ឆ្នាំ ៦២៧ : សង្គ្រាម រវាង ហ៊្វូណាន់ នឹង ចេន-ឡា

## ស្តេច រាជាណាចក្រ ចេន ឡា

- កម្ពុជារាជលក្ស្មី (៥៤៥-៥៥០) រាជនី (បុត្រី របស់ ស្រេស្ថាវរ្ម័ន)
- ភវវរ្ម័ន ទី ១ (៥៥០-៦០០)
- មហេន្ទ្រវរ្ម័ន [ចិត្រាសេនា] (៦០០-៦១៦)
- ឦសានវរ្ម័ន ទី ១ (៦១៦-៦៣៥)
- ភវវរ្ម័ន ទី ២ (៦៣៩-៦៥៧)
- ជ័យវរ្ម័ន ទី ១ (៦៥៧-៦៨១)
- ជ័យទេវី (៦៨១-៧១៣) រាជនី

ពី ឆ្នាំ ៧០៦ មក ឆ្នាំ ៨០២ ចេន-ឡា បែងចែកជារាជាណាចក្រ ពីរ គឺ ចេន-ឡា ទឹក និង ចេន-ឡា ដីគោក ។ ពីឆ្នាំ ៧៧៤ មក ឆ្នាំ ៨០២ កងទ័ពជ្វា ចូល លុកលុយៗ

## សម័យអង្គរ

- ជ័យវរ្ម័ន ទី ២ (៨០២-៨៥០)
- ជ័យវរ្ម័ន ទី ៣ (៨៥០-៨៧៧)

- ឥន្ទ្រវរ្ម័ន ទី ១ (៨៧៧-៨៨៩)
- យសោវរ្ម័ន ទី ១ (៨៨៩-៩១០)
- ហស៌វរ្ម័ន ទី ១ (៩១០-៩២១)
- ឦសានវរ្ម័ន ទី ២ (៩២២ / ២៥ -៩២៨)
- ជ័យវរ្ម័ន ទី ៤ (៩២១ / ២៨-៩៤១ )
- ហស៌វរ្ម័ន ទី ២ (៩៤១-៩៤៤)
- រាជេន្ទ្រវរ្ម័ន ទី ២ ( ៩៤៤-៩៦៨ )
- ជ័យវរ្ម័ន ទី ៥ (៩៦៨-១០០១)
- ឧទយាទិត្យវរ្ម័ន ទី ១ ( ១០០១-១០០២)

* ជ័យវីរវរ្ម័ន ( ១០០២-១០១១) នៅ យសោធបុរី

* សុរិយាវរ្ម័ន ទី ១ ( ១០០២-១០៥០) ស្តេចជ្រែករាជ្យ

- ឧទយាទិត្យវរ្ម័ន ទី ២ (១០៥០- ១០៦៦)
- ហស៌វរ្ម័ន ទី ៣ ( ១០៦៦-១០៨០)

* ទ្រិបតីន្ទ្រវរ្ម័ន (១០៨០-១១១៣) អង្គរ

* ជ័យវរ្ម័ន ទី ៦ (១០៨០-១១០៧ ) មហីធរបុរី, ស្តេចជ្រែករាជ្យ

- ធរនិន្ទ្រវរ្ម័ន ទី ១ ( ១១០៧-១១១២)
- សុរិយវរ្ម័ន ទី ២ (១១១២ / ១១១៣ - ១១៥០/ ១១៥២)
- ធរនិន្ទ្រវរ្ម័ន ទី ២ (១១៥០-១១៦០)
- យសោវរ័ន ទី ២ ( ១១៦០-១១៦៦)

* ត្រីភូវនាទិត្យវរ្ម័ន ( ១១៦៦-១១៧៧)

បន្ទាប់ពី កងទ័ពចម្ប៉ា ចូលលុកលុយ (១១៧៧-១១៨១)

- ជ័យវរ្ម័ន ទី ៧ (១១៨១-១២១៨)
- ឥន្ទ្រវរ្ម័ន ទី ២ ( ១២១៨-១២៤៣)





- ជ័យវរ្ម័ន ទី ៨ (១២៤៣-១២៩៥)
- ឥន្ទ្រវរ្ម័ន ទី ៣ (១២៩៥-១៣០៨ )
- ឥន្ទ្រជ័យវរ្ម័ន (១៣០៨-១៣២៧ )
- ជ័យវរ្ម័ន បរមេស្វរ ឬ ជ័យវរ្ម័ន ទី ៩ (១៣២៧-១៣៣៦)
- នាយ ត្រសក់ផ្អែម ( ១៣៣៦-១៣៤០)

[កាលបរិច្ឆេទភាគច្រើនយកតាម ការស្រាវជ្រាវរបស់ បណ្ឌិត ម៉ក់ ភឺន, *Essai de tableau chronologique des rois du Cambodge de la période post-angkorienne, op. cit* ]

- បរមនិព្វានបទ (១៣៤៦-១៣៥១ /២ )
- សិទ្ធានរាជា (១៣៥១ / ២)
- បរមលំពង្សរាជា (១៣៥១/២-១៣៥៣/៤)

* ចៅ បាសាត (១៣៥៣/៤ -១៣៥៥/៦ ), សៀម

* ចៅ បាអាត (១៣៥៥/៦ -១៣៥៧), សៀម

* ចៅ ក្តុំបងពីសី (១៣៥៧/ ៨), សៀម

- ស្រីសុរិយោវង្ស (១៣៥៧/ ៨ -១៣៦៦/ ៧ )
- បរមរាមា (១៣៦៦/៧ -១៣៧០/១ )
- ធម្មាសោករាជ (១៣៧០/១ -១៣៩៣/៤)
- បរមរាជា ទី ១ [ ពញាយ៉ាត ] ( ១៣៩៣ / ៤-១៤៣៣)
- សៀមចូលលុកលុយ លើកទី ២ (១៣៩៣)

* ឥន្ទរាជ ឬ ពញាព្រែក (១៣៩៣/៤), សៀម

## <u>ស្តេចដែលបានគ្រងរាជ្យ នៅ បាសាន និង ចតុមុខ (ភ្នំពេញ)</u>

- បរមរាជា ទី ១ [ចៅ ពញាយ៉ាត] (១៣៩៣/៤ -១៤៣៣/៤)

- នារាយណ៍រាជា ទី ១ (១៤៣៣/៤ -១៤៣៧/៨ )
- ស្រីរាជា (១៤៣៨/៩ -១៤៧៦/៧)
- ស្រីសុរិយោទ័យ (១៤៣៨/៩ -១៤៧៦/៧ )
- ធម្មរាជា [ចៅ ពញា ធម្មរាជា] (១៤៦៨/៩ -១៥០៤/៥ )
- ស្រីសុគន្ធបទ (១៥០៤/៥ -១៥១២/៣)
- កន [ហ្លួងព្រះស្តេចកន, ស្តេចកន, ស្រីជេដ្ឋា, ព្រះស្រីជេដ្ឋាក្រុងស្រឡប់ ពិជ័យព្រៃនគរ ] (១៥១២/៣ -១៥២៥/៦ ), ស្តេចជ្រែករាជ្យ

## ស្តេចដែលបានគ្រងរាជ្យ នៅ លង្វែក

- បរមរាជា ទី ២ [ចៅ ពញាចន្ទ, ចន្ទរាជា] (១៥១៦/៧ -១៥៦៦)
- បរមរាជា ទី ៣ (១៥៦៦ -១៥៧៦)
- បរមរាជា ទី ៤ [សដ្ឋា] (១៥៧៦ -១៥៩៤)
- ជ័យជេដ្ឋា ទី ១ (១៥៨៤/៥ -១៥៩៤)
- បរមរាជា ទី ៥ [ចៅពញាតន់] (១៥៨៤/៥ -១៥៩៤) រជ្ជកាល ទី ១

## ស្តេចដែលបានគ្រងរាជ្យ នៅ ស្រីសន្ធរ

- រាម ទី ១ [រាមាធិបតី, រាមជើងព្រៃ, រាមបពិត្រ] (១៥៩៤-១៥៩៦)
- រាម ទី ២ [ចៅពញានូរ, រាមរាជា ] (១៥៩៦-១៥៩៧)
- បរមរាជា ទី ៥ [ចៅពញាតន់ ] (១៥៩៧-១៥៩៩), រជ្ជកាល ទី ២
- បរមរាជា ទី ៦ [ចៅពញាអន, ចៅពញានង] (១៥៩៩-១៦០០/១)
- កែវហ្វា ទី ១ [ចៅពញាញោម ] (១៦០០/១ -១៦០២)

## ស្តេចដែលបានគ្រងរាជ្យនៅ កោះ ស្លាកែត បន្ទាប់មក នៅ ល្វាឯម





- បរមរាជាទី ៧ [ស្រីសុរិយោពម៌, Srī Soriyobarm, ស្រីសុពណ៌, Srī Su- barn.] (១៦០២ -១៦១៩)

## ស្តេចដែលបានគ្រងរាជ្យនៅ ឧដុង្គ

- ជ័យជេដ្ឋា ទី ២ [ជ័យចេស្តា ] (១៦១៩ -១៦២៧ )
- ស្រីធម្មរាជា ទី ១ [ ចៅពញាតូ , ព្រះរាជសម្ភារ] (១៦២៧ -១៦៣២) គង់នៅកោះឃ្លោក
- អង្គ ទងរាជា [ចៅពញានូរ , អង្គ ទង] (១៦៣២ -១៦៤០)
- បទុមរាជា ទី ១ [អង្គ នន់] ] (១៦៤០-១៦៤២)
- រាមាធិបតី ទី ១ [ ចៅ ពញាចន្ទ, សដ្ឋា, រាម, រាមរាជា, រាម ចូលសាស(ន) ] (១៦៤២-១៦៥៨)
- បរមរាជា ទី ៨ [អង្គ សូរ, បទុមរាជា] (១៦៥៩ -១៦៧២)
- បទុមរាជា ទី ២ [ស្រីជ័យជេដ្ឋ, បទុមសុរិវង្ស ] ] (១៦៧២-១៦៧៣)
- កែវហ្វា ទី ២ [អង្គ ជី, អង្គ ធី, អង្គ នី] ] (១៦៧៣ -១៦៧៧)
- ជ័យជេដ្ឋា ទី ៣ [ អង្គ សូរ , ជ័យចេស្តា, ស្រីធម្មរាជា] ] (១៦៧៧ -១៦៩៥), រជ្ជកាល ទី ១, គង់នៅ ទួនំជ្រីង
- រាមាធិបតី ទី ២ [ អង្គ យ៉ង, ឧទ័យ, ឧទ័យរាជា, នារាយណ៍ រាមាធិបតី ] (១៦៩៥ -១៦៩៦)
- ជ័យជេដ្ឋា ទី ៣ [ អង្គ សូរ] (១៦៩៦ -១៧០០/១) , រជ្ជកាល ទី ២
- កែវហ្វា ទី ៣ [អង្គ អិម ], (១៧០០/១- ១៧០១ /២) រជ្ជកាល ទី ១
- ជ័យជេដ្ឋា ទី ៣ [ អង សូរ] (១៧០១/២ -១៧០២/៣), រជ្ជកាល ទី ៣, អង់នៅពោធិសាត់ បន្ទាប់មកនៅ ឧដុង្គ បន្ទាប់មកទៀត នៅពោធិសាត់
- ស្រីធម្មរាជា ទី ២ [អង្គ នូរ] (១៧០២/៣ -១៧០៤/៥), រជ្ជកាល ទី ១, គង់នៅពោធិសាត់ បន្ទាប់មកនៅ ឧដុង្គ

- ជ័យជេដ្ឋា ទី ៣ {អង្គ សូរ]  (១៧០៤/៥ -១៧០៧), រជ្ជកាលទី ៤

- ស្រីធម្មរាជា ទី ២ [អង្គ នូរ]  (១៧០៧-១៧១៥), រជ្ជកាល ទី ២

- កែវហ៊្វា ទី ៣ [អង្គ អិម ] ] (១៧១៥-១៧២២/៣ ), រជ្ជកាល ទី ២

- សត្ថា [ អង្គជី] ] (១៧២២/៣ -១៧២៩), រជ្ជកាល ទី ១

- ជ័យជេដ្ឋា ទី ៤ [កែវហ៊្វា ទី ៣] ] (១៧២៩), រជ្ជកាលទី ៣

- បរមរាជា ទី ៩ [សត្ថា ]  (១៧២៩ -១៧៣៧), រជ្ជកាល ទី ២, គង់នៅ លង្វែក

- ជ័យជេដ្ឋា ទី ៥ [ស្រីធម្មរាជា ទី ២]  (១៧៣៨ -១៧៥០), រជ្ជកាល ទី ៣

- ស្រីធម្មរាជា ទី ៣ [អង្គ អិម ]  (១៧៥០)

- រាមាធិបតី ទី ៣ [អង្គ តន់ ] (១៧៥០ -១៧៥១), រជ្ជកាល ទី ១

- បរមរាជា ទី ៩ [សត្ថា ]  (១៧៥១), រជ្ជកាល ទី ៣

- ស្រី ជ័យជេដ្ឋ [អង្គ ស្ងួន (១៧៥១ -១៧៥៧ )

- រាមាធិបតី ទី ៣ [អង្គ តន់ ]  (១៧៥៨-១៧៦០), រជ្ជកាល ទី ២

- នារាយណ៍រាជា ទី ២ [អង្គ តន់, ឧទ័យរាជា] (១៧៦០-១៧៧៥)

- រាមាធិបតី ទី ៤ [អង្គនង , អង្គនន់ព្រះរាម, អង្គនន់រាមា, រាមរាជា, រាមស្រី ជ័យជេដ្ឋ] ] (១៧៧៥ -១៧៧៩)

- នារាយណ៍រាមា [អង្គ អេង ]  (១៧៧៩ -១៧៩៧)

- ឧទ័យរាជា  [អង្គ ចន្ទ] (១៧៩៧ -១៨៣៥), គង់នៅភ្នំពេញ និង កោះ ស្លាកែត

- អង្គ ម៉ី [អង្គ ម៉ី ក្សត្រី ], (១៨៣៥ -១៨៤៧) គង់នៅ កោះ ស្លាកែត បន្ទាប់មកនៅមាត់ជ្រូក

- ហរិរក្ស រាមា [អង្គ ដួង, នាមបច្ឆាមរណ : បរមកោដ្ឋ]  (១៨៤១ -១៨៦០)

## ស្តេចដែលបានគ្រងរាជ្យនៅ ភ្នំពេញ

- នរោត្តម [អង្គ ប្រឡឹង, អង្គវតី, រាជាវតី, នាមបច្ឆាមរណ : សុវណ្ណកោដ្ឋ], (១៨៦០ -១៩០៤)



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

- ស៊ីសុវត្ថិ [សំអូរ/ ស្រអូរ, ហរិរាជ, សេរីសុវត្ថិ, នាមបច្ឆាមរណៈ : បរម-រាជជានុកោដ្ឋ ] (១៩០៤ -១៩២៧)

- ស៊ីសុវត្ថ មុនីវង្ស [ នាមបច្ឆាមរណ : បរមខត្តិយកោដ្ឋ ] (១១៩២៧-១៩៤១)

- នរោត្តម សីហនុ (១៩៤១-១៩៥៥), រជ្ជកាល ទី ១

- នរោត្តម សុរាម្រិត [នាមបច្ឆាមរណៈ មហាកញ្ចនកោដ្ឋ]  (១៩៥៥- ១៩៦០) - ស៊ីសុវត្ថិ កុសមៈ (១៩៥៥ -១៩៧០)

- នរោត្តម សីហនុ (១៩៩៣ -២០០៤), រជ្ជកាល ទី ២

- នរោត្តម សីហមុនី (២០០៤ - )

## I) Essai de classification des rois ayant régné au Fou-nan depuis le 1er siècle à l'époque angkorienne

( Recoupements des documents et inscriptions)

| | | |
|---|---|---|
| 2ème moitié du 1er siècle | Liu-Ye | |
| 68 | Houen tien (Kaundinya I) | |
| 2ème moitié du IIème siècle | Houen p'an houang | |
| Début du 2ème siècle | P'an-pan | |

### IIème -IIIème Siècle

| | | |
|---|---|---|
| 205-225 | Fan Che-man [ Çrī māra] (Général) | |
| 225 | Fan Chin-Sheng | |
| 225-240 | Fan Chan | |
| 240-287 | Fan Siun | |
| 287-357 | Roi (s) inconnu (s) | |

### IVème et Vème Siècle

| | | |
|---|---|---|
| 357 | Tchan-t'an ou Chandan | |

### V ème Siècle
### Seconde dynastie de Kaundinya

| | | |
|---|---|---|
| 420-434 | Kaundinya II | |
| 434-435 | Çrī Indravarman I | |

### Vème et VIème Siècle

| | | |
|---|---|---|
| 470/478-514 | Jayavarman-Kaundinya | |
| 514-514 | Gunavarman | |
| 514-539 (550) | Rudravarman | Usurpa.teur dernier roi du Fou-nan |





| | |
|---|---|
| 550-627 | Guerre entre le Fou-nan et le Chen-La : fin du Fou-nan |

## II) Les rois du Chen-La
## (Période pré-angkorienne)

| Chen-La | | |
|---|---|---|
| 545-550 | Kambujarajalakhmī | Fille de Çrestha-varman |
| 550-600 | Bhavavarman I | |
| 600-616 | Mahendravarman (Chitraséna) | |
| 616-635 | ĪÇānavarman I | |
| 639-657 | Bhavavarman II | |
| 657-681 | Jayavarman I | |
| 681-713 | Jaydevi (reine) | |
| 706-802<br><br>774-802 | Deux royaumes : Chen-La d'eau et Chen-La de terre<br><br>Invasion javanaise | |

## III) Royauté angkorienne

| | | |
|---|---|---|
| 802-850 | Jayavarman II | |
| 850-877 | Jayavarman III | |
| 877-889 | Indravarman I | |
| 889-910 | Yaçovarman I | |
| 910-921 | Harshvarman I (Angkor) | |

| | | |
|---|---|---|
| 925-928 | Īçānavarman II | |
| 928-941 | Jayavarman IV | |
| 941-944 | Harshvarman II | |
| 944-968 | Rajendravarman II | |
| 968-1001 | Jayavarman V | |
| 1001-1002 | Udayadidyāvarman | |
| ■ 1002-1011 | Jayaviravarman (yaçodhapura) | |
| ■ 1002-1050 | Suryavarman I (usurpateur) | |
| 1050-1066 | Udayadidyāvarman II | |
| 1066-1080 | Harshvarman III | |
| ■ 1080-1113 | Nripatīndravarman | |
| ■ 1080-1107 | Jayavarman VI | |
| 1107-1112 | Dharanindravarman I | |
| 1113-1150 | Suryavarman II | |
| 1150-1160 | Dharanindravarman II | |
| 1160-1166 | Yaçovarman II | |
| 1166-1177 | Tribhuvanādityavarman (mandarin) | |
| 1177-1181 | Occupation des Chams | |
| 1181-1218 | Jayavarman VII | |
| 1218-1243 | Indravarman II | |
| 1243-1295 | Jayavarman VIII | |
| 1295-1308 | Indravarman III | |
| 1308-1327 | Indrajayavarman | |
| 1327-1336 | Jayavarman XIX | |
| 1336-1340 | Ta Trâsak Phaèm | Ponhea Chey |





| | | |
|---|---|---|
| 1346-1351/52 | Nippeanbât | |
| 1351/52 | Sitheanreachéa | |
| 1351/52-1353/54 | Lompongreachéa | |
| 1353-1357 | Prise et occupation d'Angkor par les Siamoix | |
| ■ 1353-1354 | Chau Bassat | |
| ■ 1354-1355 | Chau Baat | |
| ■ 1355-1357 | Chau Kdombâng Pisey | |
| 1357/58- 1366/67 | Srei Soryovong | |
| 1366/67-1370/71 | Borom Reachéa | |
| 1370/71 -1393/94 | Thammasokreach | |
| ■ 1393/94 | Ponhea Prèk ( Indr Reachea) | |

## IV) Rois ayant régné à Basan et à Chadomuk

| | | |
|---|---|---|
| 1393/94 – 1433/34 | Borom Réachea I | Chau Ponhea yāt |
| 1433/34 - 1437/38 | Neareay Reachéa | |
| 1438/39 - 1476/77 | Srei Reachéa | Roi rival |
| 1438/39-1476/77 | Srei Soriotey | Roi rival |
| 1468/69-1504/5 | Thomreachéa | Roi rival |
| 1504-/5-1512/13 | Srei Sokundhabât | |
| 1512/13-1525/26 | Sdach Kân | |

## V) Rois ayant régné à Longvèk

| | | |
|---|---|---|
| 1516/17-1566 | Borom Réachéa II | Chau Pnhea Chan, Chan Réachéa |
| 1566-1576 | Borom Réachéa III | |
| 1576-1594 | Borom Réachéa IV | Sattha |
| 1584/85-1594 | Chetchetha I | |
| 1584/85-1594 | Borom Réachéa V | Chau Ponhea Tân (roi rival) |

## VI) Rois ayant régné à Srei Santhor

| | | |
|---|---|---|
| 1594-1596 (usurp.) | Rām I | Ream Choeung Prey |
| 1596-1597 | Rām II | Chau Ponhea Nou |
| 1597-1599 | Borom Réachéa V | Chau Ponhea Tân |
| 1599-1600/1 | Borom Réachéa VI | Chau Ponhea Ân, Chau Ponhea Nong |
| 1600/1-1602 | Keav Huā I | Chau Ponhea Ñom |

## VII) Rois ayant régné à Koh Slakêt puis à Lovea Em

| | | |
|---|---|---|
| 1602-1619 | Borom Réachéa VII | Srei Soriopor |

## VIII) Rois ayant régné à Oudong et à Phnom Penh

| | | |
|---|---|---|
| 1619-1627 | Chey Chettha II | Chey Chesda |
| 1627-1632 | Srei Thomma Réachéa I | Chau Ponhea To |
| 1632-1640 | Ang Tong Reachéa | Chau Ponhea Nou |
| 1640-1642 | Botum Réachéa I | Ang Non |
| 1642-1658 | Reameathippatey | Chau Ponhea Chan, Ream Chaul sasn |
| 1659-1672 | Borom Réachéa VIII | Ang Saur |
| 1672-1673 | Botum Réachéa II | Srei Cheycheth, Botum Sorivong |
| 1673-1677 | Keav Huā II | Ang Chi |
| 1677-1695 | Cheychettha III | Ang Saur , Chetchesda (1$^{\text{ème}}$ régne) |
| 1695-1696 | Reameathippatey II | AngYâng, Outeyreachéa |
| 1696-1700/1 | Chetchettha III | Ang Saur (2$^{\text{ème}}$ règne) |
| 1701/2-1702/3 | Keav Huā III | AngIm, Borom Reachéa Ang Em, Ang Non |
| 1702/3-1704/5 | Srei Thommareachea II | Ang Nou, Rājavāmn Kdār |





| | | |
|---|---|---|
| 1704/5- 1707 | Chetchettha III | Ang Saur ( 4$^{\text{ème}}$ règne) |
| 1707-1715 | Srei Thommareachea II | Ang Nou (2$^{\text{ème}}$ règne) |
| 1715-1722/3 | Keav Huā III | Ang Im ( 2$^{\text{ème}}$ règne) |
| 1722/23 -1729 | Satha | Ang Chi (1$^{\text{er}}$ règne) |
| 1729 | Cheychettha IV | Keav Huā III ( 3$^{\text{ème}}$ règ.) |
| 1729-1737 | Borom Reachéa XIX | Sattha (2$^{\text{ème}}$ règne) |
| 1738-1750 | Cheychettha V | Srei Thommareach II (3$^{\text{ème}}$ règne) |
| 1750 | Srei Thommareach III | Ang Im |
| 1750-1751 | Reameathippadey III | Ang Tân (1$^{\text{er}}$ règne) |
| 1751 | Borom Réachéa XIX | Sattha (3$^{\text{ème}}$ règne) |
| 1751-1757 | Srei Cheycheth | Ang Sgnuon |
| 1758-1760 | Reameathippadey III | Ang Tân (2$^{\text{ème}}$ règne) |
| 1760-1775 | Neareayreachéa II | Ang Tân, Outeyreachéa |
| 1775-1779 | Reameathippadey IV | Ang Nân |
| 1779-1797 | Ang Éng | Neareayramea |
| 1797-1835 | Ang Chan | Outey Reachéa |
| 1835-1847 | Ang Mey | |
| 1841-1860 | Ang Duong | |
| 1860-1904 | Norodom | |
| 1904-1927 | Sisowath | |
| 1927-1941 | Sisowath Monivong | |
| 1941-1955 | Norodom Sihanouk | 1$^{\text{er}}$ rigne |
| 1955-1960 | Norodom Suramrith | |
| 1955-1970 | Sisowath Kossamak | |
| 1993-2004 | Norodom Sihanouk | 21 / 09 / 93 à 7 /10/ 2004 (2$^{\text{ème}}$ règne) |
| 2004 - | | Depuis 10 / 10 / 2004 |

# Bibliographie

ALBERTI J-B : *L'Indochine d'autrefois et d'aujourd'hui,* Paris, Société d'Etudes géographiques maritimes et coloniales, 1934.
AVIMOR Shimon : *Histoire contemporaine du Cambodge d'un point de vue israélien 1949-1975*, thèse de doctorat, Université d'Aix-Marseille, 1982.
AYMONIER Etienne : *Notice sur le Cambodge*, Paris, Leroux, 1875.
AYMONIER Etienne : *Géographie du Cambodge*, Paris, 1876.
AYMONIER Etienne : *Le Cambodge*, III volumes, Paris (1900-1904).
AYMONIER Etienne, *Chronique des anciens rois du Cambodge,* in Excur-sions et Reconnaissances n°4, pp. 149-184.
AYMONIER Etienne, *Chronique royale du Cambodge,* in Revue de Cochin-chine, 1880-1883.
AYMONIER Etienne, *Critique du " Royaume du Cambodge " de M. Moura,* in Excursion et Reconnaissances, n° 5, pp. 207- 220.
AZIS Philippe : *Angkor et les civilisations birmane et thaie,* Genève, Famot, 1976.
BARTHELEMY P. : *En Indochine, 1894-1895 : Cambodge, Cochin-chine, Laos, Siam méridional*, Paris, Plon, 1899, tome I.
BATZ (lieutenant) : *Histoire de l'occupation militaire du Cambodge par les troupes françaises, de 1855 à 1910*, B.S.E.I. , 1931, t.6, fasc. 1-2.
BAUDOIN François : *Le Cambodge pendant et après la Grande guerre (1914-1927)*, Phnom Penh, Société d'Editions khmères, 1927.
BAUDOIN François : *Monographie de la circonscription résidentielle de Kompong Cham*, Saïgon, Publication de la Société d'Editions khmères, 1927.
BAULMONT : *La première insurrection cambodgienne Pu Kom Bo, mars 1866 – 3 décembre – 1867*, R.I. 15 juin 1905.
BECKER Elisabeth : *Les larmes du Cambodge*, 1986, Les Presses de la Cité, 1988 pour la traduction française
BENISTI Mireille, *Rapports entre le premier art khmer et l'art indien*, Mémoire archéologique, Paris, EFEO, 1970.





BERNADINI Pierre *: le caodaïsme au Cambodge*, thèse de doctorat en histoire, Paris VII, 1974.
BITARD Pierre : *Les membres de la Famille royale du Cambodge et leurs titres d'après l'ordonnance de S.M. An Duon*, BEFEO XL VIII, 1957.
BIZOT François *: La guirlande de joyaux*, E.F.E.O. , Paris - Chiang Mai – Phnom Penh – Vientiane, 1994.
BOISSELIER J. : *Le Cambodge*, Picard, Paris, Manuel d'archéologie d'Extrême-Orient 1/1, 1966.
BONGERT Yvonne : *La monarchie cambodgienne*, in *La monocratie* I, Bruxelles, Société Jean Bodin, 1970.
BOUDILLON A. : *Le regime de la propriété foncière en Indochine (rapport au Ministère des Colonies)*, Hanoï, 1915.
CARR Earl A. : *Origin of the Khmer Revolution*, PhD thesis, S. Illinois University, 1977.
C.E. Bouilleveaux : *Voyage dans l'Indochine* 1848-1856, Paris, 1858.
C.E. Bouilleveaux : *L'Annam et le Cambodge. Voyages et notices historiques*, Paris, Victor Palmé, 1874.
BITARD P., *Mission d'assistance technique auprès de l'Office national de Coopération (OFFINACO*), B.D.P.A., 1969.
BIZOT F., *Le Figuier à cinq branches, Recherches sur le bouddhisme khmer*, Paris,Ec. Fran. Ext. Orient, CVII, 1976.
BOURDILLON A., *Le régime de la propriété foncière en Indochine (rap-port au Ministère des Colonies),* Hanoï, 1915.
BOURDILLON A., *La réforme du régime de la propriété foncière en Indochine (rapport au Gouverneur général)* 1927.
BRIGGS L.P., *Siamese attacks on Angkor before 1430,* in Far Eastern Quarterly, VIII, 1948.
BRIGGS L. Palmer, *Spanish intervention in Cambodia : 1593 – 1603,* in, TP , vol.XXXLX, livre 1 –3, pp. 132 – 160, 1949.
BRIGGS L. Palmer, *Les missionnaires portugais et espagnols au Cambodge (1555 – 1603)* in BSEI, n° sp., 1$^{er}$ trimestre, vol. 25, fasc. 1, pp. 5 – 29, 1950 .
COEDES G., *La fondation de Phnom Penh au XV ème siècle d'après la Chronique Cambodgienne,* in BEFO, t. XIII, fasc. 6, pp. 6-11, 1913.
COEDES G., *Histoire du Cambodge par A Leclère,* compte-rendu in BEFEO, t. XIV, fasc. 9, pp. 47-54, 1914.

COEDES G., *Essai de classification des documents historiques cambodgiens conservés à la bibliothèque de l'EFEO,* in BEFEO, t. XVIII, fasc. 9, pp. 15-28, 1918.
COEDES G**,** *L'origine du cycle des douze animaux au Cambodge,* in TP, vol. XXXI, pp. 315-320, 1934.
COEDES G., *L'ancienne civilisation khmère,* in France-Asie, t. l, n° 7, pp. 398-405, t II, n° 8, pp. 476-482, 1946.
COEDES G., *Les langues de l'Indochine,* Extrait des conférences de l'Institut de linguistique de l'Uni-versité de Paris VII, année 1940-1948, pp. 63-81 ., 1949.
COEDES G., *Les règles de la succession royale dans l'ancien Cam-bodge*, in BSEI, n° sp., t. XXVI, n° 2, pp. 117 – 131.
COEDES G., *Les Etats hindouisés d'Indochine et d'Indonésie,* Paris, DE Boccard, 1964.
COEDES G**.**, *Les peuples de la pénisule indochinois*, Paris, Dunod, 1962.
CHANDA Nayan**,** *Les frères ennemis. La péninsule indochinois après Saïgon,* Paris, CNRS, 1987.
CHANDLER David : *Cambodia before the French : politics in a tributary kingdom 1794-1848,* University of Michigan (Ph. D in history, modern), 1973.
CHANDLER David : *Pol Pot, frère Numéro Un*, Plon, Paris 1992.
CHAU Séng : *Education et Développement au Cambodge,* thèse 3 ème cycle, Paris, Faculté des Lettres, 1970.
CHHAY Hoc Phéng : *Le conflit armé au Cambodge* , thèse de doctorat en droit public, Paris II, 1980.
CHHIM Khet : *Les Khmers rouges et le développement politique au Cambodge*, Mémoire DES, Paris I , 1975.
CHUT Khay : *Comment j'ai menti aux Khmers rouges,* Paris, L'Har-mattan, 2004.
COMTE Maurice : *Economie, idéologie et pouvoir : la société cambod-gienne (1863-1886),* Lyon II, 1980.
CORFIELD Justin : *The political Machinations of the Khmer Republic,* BA (Hons) thesis, University of Hull, 1989.
CLAIRON Marcel *: Droit civil khmer,* Phnom Penh, 1960.
CLAIRON Marcel : *Notions essentielles de droit civil khmer,* Phnom Penh, E.K.L.I.P., 1963.



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

COLANY Madeleine, Recherches sur le préhistorique indochinois, B.E.F.O., XXX, Hanoï, 1930
CROCHET Soizick : *Le Cambodge*, Karthala, Paris, 1997.
DELVERT Jean : *Le paysan cambodgien*, thèse, Paris, 1961, Mouton & CO La Haye, 1961.
DELVERT Jean : *Le Cambodge*, Paris, P.U.F. et Collection Que sais-je, Paris, 1963.
Documentation française, *La situation économique du Cambodge* (19 pages), Paris. Notes et études documentaires n° 2823, 1961.
DUPONT Pierre**,** *La dislocation du Tchen-La et la formation du Cam-bodge angkorien,* B.E.F.E.O., XLIII.
DUPONT Pierre, *Les débuts de la royauté angkorienne,* B.E.F.E.O., XLVI.
FABRICIUS Pierre, *Prolégomènes à l'Histoire khmère*, in France-Asie, t. 17, n° 164, pp. 1451 – 1472., 1960., n° 164, pp. 1451 – 1472., 1960.
FERAY Pierre-Richard**,** *Le Vietnam,* Paris, PUF " Que sais-je ", 1984.
FOREST Alain : *Le Cambodge et la colonisation française*, L'Harmat-tan, Paris, 1980.
FOREST Alain : *Le culte des génies protecteurs au Cambodge*, Paris, L'Harmattan, 1992.
FREDERIC Louis *: La vie quotidienne de la péninsule indochinoise à l'époque d'Angkor* (800-1300), Hachette, Paris, 1981.
GITEAU Madeleine, *Histoire du Cambodge*, Paris, 1962
GITEAU Madeleine, *Les Khmers, cultures khmères, reflets de la civilisation d'Angkor,* Fribourg, Office du Livre , Paris 1972.
GOUR Claude Gilles : *Institutions constitutionnelles et politiques du Cambodge,* Dalloz,Paris, 1965.
GROSLIER Bernard-Philippe**,** *Indochine carrefour des arts,* Paris, Albin Michel, 1961.
GROSLIER B. Ph.**,** *Angkor et le Cambodge au XVI ème siècle d'après les sources portugaises et espagnoles,* Paris, 1958.
GROSLIER B. Ph., *Agriculture et religion dans l'empire angkorien,* in Etudes rurales, 1974.
GROSLIER B. Ph., *Angkor Hommes et Pierres,* Paris, Arthaud, 1965 ; Grenoble, 1968.

GROSLIER B. Ph., *Pour une géographie historique du Cambodge,* cahier d'Outre-mer ; Bordeaux, 1973.
GROSLIER B. Ph., *Inscriptions du Bayon,* Paris, E.F.E.O., 1973.
GROSLIER B. Ph., *Recherche sur les Cambodgiens d'après les textes et les documents,* Paris, Challamel, 1921.
HAMEL Bernard : *De sang et de larmes,* Albin Michel, Paris, 1977.
HAMEL Bernard : *Sihanouk et le drame cambodgien,* Paris, L'Harmattan, 1993.
HEDUY Philippe : *Histoire de l'Indochine la perle de l'Empire 1624-1954,* Paris, Albin Michel, 1998.
HOU Yuon : *La paysannerie du Cambodge et ses projets de modernisation,* Paris, thèse de droit, 1955.
IMBERT Jean : *Histoire des institutions khmères,* Annales de la Faculté de Droit de Phnom-Penh, II, 1961.
JENNAR Raoul : *Les Constitutions du Cambodge 1953-1993,* La Documentation française, Paris, 1994.
JENNAR Raoul : *Les clés du Cambodge,* Paris, Maisonneuve & Larose, 1995.
KAO Kan : *Les relations sino-cambodgiennes (1963-1970).* Thèse pour le doctorat de 3 ème cycle, EPHE, VI ème section, Paris, 1973.
KEM Chhoeun, *Le rôle des entreprises publiques du Cambodge (1969-1973),* thèse de doctorat en sciences économiques, Montpellier I, 1976.
KENG Vannsak : *Recherche d'un fond culturel khmer,* thèse de 3 ème cycle en Lettres, Paris-Sorbonne, 1971.
KE Khi You *: L'Insurrection générale de 1885-1886 au Cambodge*, Paris, Mémoire de maîtrise sous la direction de J. Chesneaux, Université Paris VII, 1971.
KHIEU Samphân : *L'économie du Cambodge et ses problèmes d'industrialisation*, thèse pour le doctorat en sciences économiques, Paris, 1959.
KHIM Y : *Le Cambodge et le problème de l'extension des espaces maritimes dans le Golfe de Thailande,* thèse de doctorat en droit public, Paris II, 1978.
KHIN SOK : *Le Cambodge entre le Siam et le Vietnam de 1775 à 1860,* thèse de doctorat en ethnologie, Paris, EHESS, 1987.
KHIN Sok : *les Vietnamiens au XIX ème siècle d'après les deux poèmes du vénérable Bâtum Baramey Pich,* Editions You-Feng, Paris, 2002.





KHIN Sok : *Les chroniques royales khmères,* Mon-khmer Studies VI : 191-215
KHING Hoc Dy : *Ecrivains et expressions littéraires du Cambodge au XX ème siècle*, L'Harmattan, Paris, 1993.
KHING Hoc Dy : *Aperçu général sur la littérature khmère* (en khmer), Paris, L'Harmattan, 1997.
KHING Hoc Dy : *Anthologie de la littérature khmère du XIX ème siècle* (en khmer), P.Penh, 2003.
KHING Hoc Dy : *Anthologie de la littérature khmère au XX ème siècle* (en khmer), Paris, Editions de la plus haute tour, 2002.
KHING Hoc Dy : *Un épisode du Ramayana khmer* (en khmer), Librairie Angkor, Phnom penh, 2004.
KHING Hoc Dy *: Dav Ek, introduction, traduction annotée et textes khmers* (en khmer), Librairie Angkor, Phnom penh, 2005.
KHY Phanra *: La communauté vietnamienne au Cambodge à l'époque du Protectorat français (1863-1953),* thèse de doctorat en études indiennes et extrême-orientales, Paris III, 1974.
LAMANT Pierre : *L'Affaire Duong Chakr*, Revue française d'Histoire d'Outre-Mer, LXVII, n° 246-7, 1er et 2 ème trimester,1980.
LAMANT Pierre : *L'Affaire Yukanthor, autopsie d'un scandale colo-nial.* , Société française d'Outre-Mer, Paris, 1989.
LECLERE Adhémard : *Histoire du Cambodge.*, Paul Geutthner, Paris,1914.
LECLERE Adhémar : Recherches sur la législation cambodgienne, Droit privé, Paris, 1890.
LECLERE Adhémar : *Recherches sur le droit public des Cambodgiens, Paris, Augustin Challamel*, 1894.
LUCIOLLI Esmeralda : *Le mur de bambou,* Régine Deforges Medecins sans Frontières, Paris, 1988.
LTTAYE Edouard : *Les pratiques institutionnelles sous Sihanouk,* thèse de doctorat du 3 ème cycle, Faculté des Lettres et des Sciences Humaines, Paris, 1971.
MAK Phoeun : *Les Chroniques royales du Cambodge (de 1594 à 1677),* thèse de 3 ème cycle, Paris, 1975.
MAK Phoeun : *Histoire du Cambodge de la fin du XVIII ème siècle (1554-1700),* thèse de doctorat en études indiennes et extrême-orientales, Paris VII, 1992.

MAK Phoeun, *Essai de tableau chronologique des rois du Cambodge de la période post-angkorienne*, Journal asiatique, 290.1 (2002): 101-161
MARTIN Marie-Alexandrine : *La riziculture et la maîtrise de l'eau dans le Kampuchéa démocratique*, Etudes rurales, Paris, 1981.
MARTIN Marie- Alexandrine : *L'Industrie dans le Kampuchéa démo-cratique*, Etudes rurales, Paris, 1983.
MARTIN Marie-Alexandrine : *La politique alimentaire des Khmers rouges*, Etudes rurales, Paris, 1985
MARTIN Marie-Alexandrine : *Vietnamised Cambodia. A silent Ethno-cide*, Singapour, Indochina Reports, 1986.
MARTIN Marie-Alexandrine : *Le mal cambodgien*, Hachette, Paris, 1989.
MASPERO Georges, *L'Empire khmer*, histoire et documents, Paris, 1921, et articles articles divers in B.E.F.E.O.
MAU Say : *La monnaie cambodgienne à l'heure du Fonds Monétaire International*, Phnom Penh, Faculté de Droit et de Sciences écono-miques, 1960.
MEAS Yang : *Le bouddhisme au Cambodge*, Paris, Etudes orientales, 1978.
MEYER Charles *: Insurrections nationales du siècle dernier*, Phnom Penh, Etudes Cambodgiennes, janvier-Mars 1967, n °9 ; avril-juin 1967 n° 10 ; Juillet-Septembre 1967 n° 11 ;Octobre-Décembre 1967 n°12.
MEYER Charles : *Derrière le sourire khmer*, Plon, Paris, 1971.
MEYER Roland : *Saramani danseuse khmère*, , Albert Portail, Saïgon, 1919.
M.E. Osborne : *Notes on early Cambodian provincial history*, France-Asie, été 1966, vol. XX, n° 186.
M.E. Osborne : *The French presence in Cochinchina and Cambodia : rule and response (1859-1905)*, Inthaca /London, Cornell University Press, 1969.
MIGOZZI J. : *Cambodge, faits et problèmes*, Paris, Edit. du C.N.R.S., 1973.
MORICE Jean : *Cambodge : du sourire à l'horreur*, France-Empire, Paris, 1977.
MOURA Jean : *Le royaume du Cambodge*, Paris, 1883**.**
NAYAN Chanda : *Les frères ennemis*, Presses du CNRS, Paris, 1987.
NEPOTE Jacques : *Le palais du roi Norodom I. Histoire et description suivies de l'analyse structurale de la symbolique du palais royal de Phnom Penh*, Thèse 3ème cycle d'Etnologie, Université de Paris X Nanterre,1973.





NEPOTE Jacques : *Parenté et organisation sociale dans le Cambodge moderne et contemporain. Quelques aspects et quelques applications du modèle les régissant*, Genève : Olizane ( Etudes Orientales) & Cédoreck (Bibiothèque khmère), 1992.
NEPOTE Jacques et SISOWATH Ravivaddhana Monipong, *Etat présent de la Maison Royale du Cambodge*, Institut de la Maison Royale du Cambodge, Courbevoie, France, 1994.
NORODOM Rannariddh : *Le domaine maritime du Cambodge*, Aix-en-Provence, Faculté de droit, thèse d'Etat, 1976.
NORODOM Sihanouk : *Souvenirs doux et amers*, Hachette, Paris, 1981.
NORODOM Sihanouk : *Prisonnier des Khmers Rouges*, Hachette, Paris, 1986.
NORODOM Sihanouk : *Chronique de guerre et…d'espoir*, Hachette, Paris, 1986.
OSBORNE M.E.: *History and Kingship in contemporary Cambodia*, Journal of South East Asian History, mars, 1966, vol. VII, n° 1.
OSBORNE M.E. : *King-making in Cambodia : from Sisowath to Sihanouk*, Journal of South East Asian Studies, sept. 1973, vol. IV, n° 2.
PANNETIER A. (Dr) : *Notes cambodgiennes. Au cœur du Pays Khmer*, Paris, Payot, 1921, Réimp.Paris, Cedoreck,1983.
PELLIOT Paul : *Mémoires sur les coutumes du Cambodge de Tchéou Ta-K ouan*,Paris, Maisonneuve, 1951.
PHOUK Chhay : *Les élites khmères*, thèse de droit, Phnom Penh, Faculté de droit,1965.
PHUNG Ton : *La crise cambodgienne*, Paris, thèse de droit, 1954.
PICQ Laurence : *Au delà du ciel, cinq ans chez les Khmers Rouges*, Bernard Barrault, Paris, 1984.
POMONTI Jean-Claude et Serge THION: *Des courtisans aux parti-sans, la crise cambodgienne*, Gallimard, Paris, 1971.
PONCHAUD François : *Le Cambodge, année zéro*, Paris, Julliard , 1977.
PRESCHEZ Philippe : *Essai sur la démocratie au Cambodge*, Paris, C.E.R.I. Série C, Recherche n° 4, 1961.
PRUD'HOMME Rémy : *L'économie du Cambodge*, P.U.F., Paris, 1969.
REGAUD Nicolas : *Le Cambodge dans la tourmente*, Paris, L'Harmat-tan, 1992.

ROS Chantraboth *: La République khmère*, Paris, L'Harmattan, Paris, 1993.
SAHAI Sachchidanand : *Les institutions politiques et l'organisation administrative du Cambodge ancien ( VI °-XIII ° siècles)*, EFEO ( PEFEO LXXV), Paris, 1970.
SAINT-LOUP Gérard : *Phnom penh, la douceur assassine*, L'Harmat-tan, Paris, 1997.
SARIN Chhak : *Les frontières du Cambodge*, tome I, Paris, Dalloz, 1966.
SAY Bory : *L'administration rurale au Cambodge et ses projets de réforme*, thèse 3ème cycle en sciences administratives, Paris II, 1974.
SCALABRINO C. : *Cambodge – Histoire et enjeux 1945- 1985*, Paris, L'Harmattan, 1985.
SENG Ly Try : *Le bouddhisme dans la société khmère contemporaine*, Paris, mémoire de DEA, 1986.
SHAWCROSS William : *Une tragédie sans importance*, Balland, 1979 (pour la traduction française). Titre original : *Shideshow*, Simon et Schuster, New York.
SHAWCROSS William : *Le poids de la pitié*, Paris, Balland,1985.
SIN Kim Suy : *Les Chinois du Cambodge*, Etude sociologique, thèse de doctorat de 3 ème cycle, Paris, INALCO, 1986.
SOLA Richard : *Communismes d'Asie, le crépuscule de l'espoir*, Sudestasie, Paris, 1992.
SOU Chamroeun : *Achar Sva* (en khmer), Phnom Penh, 1968.
SOU Chamroeun : *Po Kambor*, Diffusion de La Bibliothèque de la Culture khmère, Phnom Penh, 1971.
STERN Philippe, Le Temple-montagne khmèr le culte du Linga et le Devārāja, B.E.F.E.O., 1934.
TAN Kim Huon : *Géographie du Cambodge, de l'Asie des Moussons et des Principales Puissances*, Phnom Penh, 1963.
THAI Sok : *Traités de morale des Cambodgiens, du XIV au XIX ème siècle*, thèse pour le doctorat de l'université de Paris,1964.
THIERRY Solange : *Les Khmers*, Paris, Seuil, 1964.
THIOUNN Thioum : *Le pouvoir monarchique au Cambodge*, Paris, these de droit, 1952.
THION Serge : *Watching Cambodia* , Bangkok, White Lotus, 1993.





THION Serge, KIERNAN Ben : *Khmers rouges. Matériaux pour l'Histoire du communisme au Cambodge*, Paris, Hallier- Albin Michel, 1981.
TICHIT L. : *L'agriculture au Cambodge*, Agence de Coopération culturelle et technique, 1981.
TITH Huon : *Problème de l'assainissement dans la fonction publique cambodgienne*, thèse pour le doctorat en sciences administratives, Paris II, 1976.
VANDY Kaonn : *Cambodge 1940-1991 : la politique sans les Cambodgiens*, L'Harmattan, Paris, 1993.
VANDY Kaonn : *Réflexion sur la littérature khmère*, Institut de Sociologie de Phnom Penh, 1981.
VANDY Kaonn : *Contribution à l'étude de l'histoire de Thnenh Chey*,
(1 ère édition : Phnom Penh, 1973) ; ( 2 ème édition : Association Cambodge-Asie, France 2008 ).
VANDY Kaonn : *Contribution à l'étude du Cambodge et de ses difficultés d'insertion au monde moderne*, thèse pour le doctorat d' Histoire, Faculté des Lettres et Sciences Humaines de l'Université de Nice-Sophia Antipolis, Première partie, 1998.
VANDY Kaonn : *Eléments d'Economie*, Paris, 2008.
VICKERY M. : *Kampuchéa – Politics, economics and society*, Sidney, Allen & Unwin, Australia, 1986.
VICKERY Michael : *Cambodia after Angkor : the Chronicular Evidence for the Fourteenth to Sixteenth Centuries*, PhD, dissertation, Yale University, 2 vol., 1977.

## Méthodologie

ALTHUSSER Louis : *Montesquieu. La politique et l'histoire*, Paris, P.U.F., 1981, p. 15).
ANDERSON Bnedict : *L'imaginaire national, Réflexions sur l'origine et l'essor du nationalisme*, Ed. La Découverte & Syros, Paris, 2002
ATTALI Jacques : *1492*, Paris, Arthème Fayard, 1991 ; col. livre de poche, Edit. 4 , 2004
BLOCH Marc : *Apologie pour l'histoire ou Métier d'historien*, Paris, Armand Colin, 2007.

BRAUDEL Fernand : *Ecrits sur l'histoire*, Paris, Flammarion, 1969.
COLLIOT-THERESE Catherine : *Max Weber et l'histoire*, Paris, P.U.F., 1990, p. 13.
DOSSE François : *L'histoire*, Paris, Armand Colin, 2 000
FOUCAULT Michel : *Les mots et les choses. Une archéologie des sciences humaines*, Paris, Gallimard, 1966.
HARTOG François : *Le XIX è siècle et l'histoire. Le cas de Fustel de Coulanges*, Paris, P.U.F., 1988.
HEGEL : *La Raison dans l'histoire*, Paris, 10/18, 1965.
LEVI-STRAUSS Claude : *Anthropologie structurale*, Paris, Plon, 1958, p. 3-4.
LEVI- STRAUSS Claude : *La pensée sauvage*, Paris, Plon, 1962, p. 345.
MICHELET Jules : *Histoire de France*, dans *Œuvres complètes*, IV, Paris, Flammarion, 1974, p.11.
MONTESQUIEU( Charles-Louis de Secondat, baron de la Brède et de ) : *De l'esprit des lois*, 1748, XIX, 4, Les Belles-Lettres, Paris, 1950-1961.
MONTESQUIEU : *Considération sur les causes de la grandeur et de la décadence des Romains*, 1737.

## Faits historiques et documents

( Alain Forest : *Le Cambodge et la colonisation française : Histoire d'une colonisation sans heurts (1897-1920*), L'Harmattan, 1980.)
- H. de Vernrville propose le prince Sisowath comme successeur à Norodom et dénonce Yukanthor (Cf. Lettre du Résident supérieur au Gouverneur Général en date du 30 janvier 1896, AOM, NF 587.).
- Relation impossible entre Norodom et de Verneville ( Cf. Lettre du Résident Supérieur au Gouverneur Général en date du 16 mai 1896, AOM, Aix 24673.).
- Création du Conseil des ministres par le Gouverneur Général (Cf. Rapport du Gouverneur Général du 31 Août 1897, AOM, carton 8.).
- Pouvoir conféré au Résident Supérieur comme chef de gouvernement (de fait et de droit) du Cambodge (Cf. Paul Doumer, L'Indochine française : souvenirs, Paris, Vuibert et Nony, 1905, p. 236.).



សុបិន និង ការពិត ភាគ ១- Rêves et réalités –Tome 1

- Le Roi du Cambodge ne consulte ni ne conseille plus le Conseil des ministres (Cf. Rapport du Gouverneur Général du 24 novembre 1897, AOM, carton 8.).
- Le roi Norodom porte plainte contre Ducos (Cf. Lettre de Norodom au Gouverneur Général en date du 21 Août 1899, AOM, Aix 5820. C'est une lettre dans laquelle Norodom accepte aussi l'Union française).
- Le roi est élu par ses ministres. Les membres de la Famille Royale sont exclus des délibérations et du vote (Cf. A. Leclère, Droit public, pp 19-20).
-Tentative de Khun Than de faire couronner son fils Phanouvong Cf.Lettre de M. Calan au Gouverneur Général Rousseau, 10 juin 1896, AOM, Aix 5820.).
- De Verneville présente favorablement le prince Sisowath (Cf. Rapport du Résident Supérieur au Gouverneur Général, 26 janvier 1897, AOM, Aix 5820.).
- Sisowath doit prendre à sa charge toute la solde de ses dignitaires (Cf. Rapport du Gouverneur Général, 1 er trimestre 1904, AOM, carton 9.).
- Par le Conseil des ministres, Doumer veut imposer l'autorité coloniale aux gouverneurs de provinces (Cf. Rapport du Gouverneur Général, 4 ème trimestre 1898, AOM, carton 8.).
- Limogeage des « partisans tièdes » du Protectorat. Ducos a reçu de Poc l'accord d'une action concertée (Cf. Rapport du Gouverneur Général, 3 ème trimestre, 1899, AOM, carton 8.).
- Refus de payer l'impôt à Kompong Cham et Tbaung Khmum (Cf. Rapport du Gouverneur Général, Juillet 1897, AOM, carton 8.).
- Tout passe par le Résident Supérieur (O.R. du 11 août 1901).
- L'administrateur est aussi le juge (O.R. du 11 juillet 1897.).
- Abolition des cérémonies de *Châng day tra* ( 25 janvier 1897).
- Réforme de la Justice ( O.R. 1902) ; voir aussi : Collard *: Cambodge et Cambodgiens. Métamorphose du Royaume khmer par une méthode française du Protectorat*, Paris, Société d'Editions géographiques maritimes et coloniales, 1925.
- Mariage des princes et princesses : pour les princes et les pricesses qui voulaient se marier à leur guise avec les gens du commun, ils doivent renoncer à leurs droits, honneurs et prérogatives (O.R. du 1er janvier 1907.).

- Sisowath propose Monivong comme son successeur (Cf. Lettre de Sisowath adressée au Résident Supérieur Luce et au Gouverneur Général Klobukowski, 2 février 1909.). Outrey n’est pas d’accord (Cf. Lettre du Résident Supérieur au Gouverneur Général, 9 novembre 1902, AOM, carton 15). Albert Sarrault est d’accord avec Outrey (Cf. Lettre du Gouverneur Général au Ministre des Colonies, 3 septembre 1913, AOM, NF 579.).
- Interdiction aux fonctionnaires de fumer l’opium et le chanvre indien (Loi du 6 décembre 1907.).
- Etablissement de la propriété ( O.R. du 24 janvier 1908 et du 8 janvier 1912.).

V -10-11

វ៉ាន់ឌី កាអុន

# សុបិន និង ការពិត

## ភាគ ២






បន្ទាប់ពី របប « សាធារណរដ្ឋខ្មែរ » ត្រូវប្រទេសកុម្មុយនិស្ត នៅក្នុងតំបន់ វាយរំលំ នៅថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ប្រទេសកម្ពុជា បានធ្លាក់ទៅក្នុងវិនាសកម្មមួយ ដ៏គ្រៀមក្រំ ៗ នៅក្នុង របប ខ្មែរក្រហម ដឹកនាំដោយ ប៉ុល ពត ហើយដែលមាន ប្រទេសចិនកុម្មុយនិស្តជាបង្អែក ប្រជាជនខ្មែរជាង ១ លាន នាក់ បានត្រូវគេសម្លាប់នៅក្នុងស្ថានភាព គួរឲ្យសង្វេគគត់ពេកក្រៃ ។ នៅដើមឆ្នាំ ១៩៧៩ កងទ័ពវៀតណាម ដែលមានជំនួយ ពីសហភាព សូវៀត បានចូលមកក្នុងស្រុកខ្មែរវាយរំលំ របបកម្ពុជា ប្រជាធិបតេយ្យ។ អធិករណ៍ រវាងកុម្មុយនិស្តចិន និង កុម្មុយនិស្ត វៀតណាម តាមរយៈអ្នកដឹកនាំខ្មែរ នៅតែមានបន្តទៀត។ កិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស៍ ឆ្នាំ ១៩៩១ និង អន្តរាគមន៍ របស់អង្គការសហប្រជាជាតិ នៅឆ្នាំ ១៩៩២ បានរៀបចំ ការបោះឆ្នោតសេរី ដែលបានផ្តល់ជ័យជំនះទៅឲ្យគណបក្សរាជានិយម ដឹកនាំដោយព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ។ ប៉ុន្តែ រដ្ឋប្រហារ ខែកក្កដា ឆ្នាំ ១៩៩៧ បានបើកផ្លូវ ឲ្យបក្សប្រជាជនកាន់អំណាចបន្តទៀត។ សុបិន របស់ប្រទេសដែលដណ្តើមគ្នាលេបទឹកដីខ្មែរ កំពុងតែក្លាយទៅជាការពិត ។ អ្នកដឹកនាំខ្មែរ ព្រមទាំងប្រទេសជាប់ពាក់ព័ន្ធ ពុំព្រម អនុវត្តកិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស៍ឡើយ ហើយរុញច្រាន ស្រុកខ្មែរឲ្យធ្លាក់ជ្រៅទៅៗ ទៅក្នុងមហន្តរាយមួយ ដ៏ ធំធេង សាជាថ្មីទៀត។

**Cambodge : rêves et réalités**

**Vandy Kaonn**

ភាគ ២ សុបិន និង ការពិត វ៉ាន់ឌី កាអុន

វ៉ាន់ឌី កាអុន

**Vandy Kaonn**

# សុបិន និង ការពិត

## ភាគ ២




**Cambodge : rêves et réalités**

វ៉ាន់ឌី កាអុន

**Vandy Kaonn**

# សុបិន និង ការពិត

## ភាគ ២

## ប្រទេសកម្ពុជា : ១៨៦៣-១៩៩២
## ពី សម័យអាណានិគមចាស់
## មកសម័យ អាណានិគមថ្មី

# CAMBODGE : rêves et réalités
## Tome II

សមាគម កម្ពុជា-អាស៊ី ឆ្នាំ ២០១២

**(Association Cambodge-Asie France - 2012)**

រក្សាសិទ្ធិ គ្រប់បែបយ៉ាង



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

# មាតិកា

-មាតិកា.......................................................................................... ៣

-អារម្ភកថា......................................................................... ... ...... .៩

-លំនាំដើម ........................................................................................១៩

**- មនោគមវិជ្ជា របស់ «ម៉ាក្ស» និង បដិវត្តន៍ នៃ វណ្ណៈអធន** ........................................................៣៩

Le marxisme et la révolution prolétarienne

<u>ជំពូក ៨</u> : ចុះទឹកក្រពើ ឡើងលើខ្លា ..........................................៤៥

-ពី ម៉ាក្ស មកដល់ ប៉ុល ពត - បដិវត្តន៍ បារាំង -ភាពប្រឫកប្រហល់ នៃ ជ័យជំនះ របស់ខ្មែរក្រហម - បញ្ហាសំខាន់ៗដែល ប៉ុល ពត ត្រូវដោះស្រាយក្រោយ ព្រឹត្តិការណ៍ ថ្ងៃ ១៧ មេសា - ការបង្កើតរដ្ឋបដិវត្ត របស់ ខ្មែរក្រហម - ការគូសវាសខ្សែបន្ទាត់ នយោបាយក្រៅប្រទេស របស់ ខ្មែរក្រហម - ការបោសសំអាត «ជនក្បត់» នៅក្នុង ផ្ទៃបក្ស-ការពង្រឹងទំនាក់ទំនង រវាង របបកម្ពុជាប្រជាធិបតេយ្យ និង ប្រទេសចិនប្រជាមានិតុ - ជីវភាព របស់ ប្រជាជនខ្មែរ នៅក្រោមរបបខ្មែរ ក្រហម - សង្គ្រាមរវាង ចិន និង សហភាពសូវៀត : ឆ្ពោះ ទៅរកការរលំរលាយ នៃ របប ខ្មែរក្រហម - សភាពការណ៍ នៅក្នុងរបបខ្មែរក្រហម នៅឆ្នាំ ១៩៧៨ - ការឈានទៅរក ទីអវសាន នៃ របប ខ្មែរក្រហម -ព្រឹត្តិការណ៍សំខាន់ៗ នៅឆ្នាំ ១៩៧៨ នៅសម័យខ្មែរក្រហម - ការវាយលុក នៃ កងទ័ពវៀតណាម ទៅលើប្រទេសកម្ពុជានៅឆ្នាំ ១៩៧៨-១៩៧៩ - ការប្រយុទ្ធតស៊ូ នយោបាយ រវាង ចិន និង វៀតណាមនៅឆ្នាំ ១៩៧៩-ការប្រជែងកម្លាំង រវាង ប្រទេសមហាអំណាច - ការតស៊ូដេញកងទ័ពវៀតណាមចេញពីប្រទេសកម្ពុជា -សភាពការណ៍ ប្រទេសកម្ពុជា ក្រោយព្រឹត្តិការណ៍ ថ្ងៃ ៧ មករាឆ្នាំ ១៩៧៩ - ពីរដ្ឋាភិបាល ហេង សំរិន ទៅរដ្ឋាភិបាល ប៉ែន សុវណ្ណ - ការបំពាក់បំប៉ន លទ្ធិកុម្មុយនិស្ត ដល់ កម្មាភិបាលខ្មែរ នៅជំនាន់ របប ហេង សំរិន - ការកសាងរបប សាធារណរដ្ឋ ប្រជាមានិតុកម្ពុជា -អំពីក្រុមសាមគ្គី បង្កបង្កើតផល ប្រភេទទី ៣ - អំពីក្រុមសាមគ្គីបង្កបង្កើតផល ប្រភេទទី ២ និង ទី ១ - បរិបទអន្តរជាតិ នៃ សង្គ្រាម នៅក្នុងប្រទេសកម្ពុជា រវាង ឆ្នាំ ១៩៧៩-១៩៨៩ - ស្ថានភាពប្រទេសកម្ពុជា នៅ ឆ្នាំ ១៩៨២ - រដ្ឋាភិបាល លោក ចាន់ ស៊ី - តម្រុយ នៃការប្រែប្រួល ស្ថានភាពនយោបាយ នៅឆ្នាំ ១៩៨៣ - ការតែងតាំង លោក ហ៊ុន សែន ជានាយករដ្ឋមន្ត្រី នៃ របប សាធារណរដ្ឋប្រ  ជាមានិតុកម្ពុជា នៅថ្ងៃ ១៤ មករា ឆ្នាំ ១៩៨៥

**- រូបភាពមួយទៀត នៃ សង្គ្រាម** ..........................................៨៦

La guerre par d’autres moyens

<u>ជំពូក ៩</u>: ឃ្នាប ......................................................១៤០

- ដំណើរឆ្ពោះ ទៅរកការចរចា សន្តិភាព នៅឆ្នាំ ១៩៨៥ - ការប្រែប្រួល នៃ ការប្រជែងកម្លាំងអន្តរជាតិនៅឆ្នាំ ១៩៨៦- ព្រឹត្តិការណ៍មុនជំនួបលើកដំបូងបង្អស់ រវាងសម្តេច នរោត្តម សីហនុ និង លោក ហ៊ុន សែន នៅ ហ្វែរ អង់តាកដឺន័រ ប្រទេសបារាំង - ដំណើរឆ្ពោះទៅរកការផ្សះផ្សា រវាងគូភាគីនយោបាយខ្មែរទាំង ៤ នៅឆ្នាំ ១៩៨៧ - ជំនួប រវាងសម្តេច នរោត្តម សីហនុនិងលោក ហ៊ុន សែន នៅហ្វែរអង់តាកដឺន័រ ប្រទេស បារាំង នៅឆ្នាំ ១៩៨៧ - ការខ្វែងគំនិតគ្នា រវាង សម្តេច នរោត្តម សីហនុ និង រដ្ឋាភិបាលចម្រុះ កម្ពុជាប្រជាធិបតេយ្យ -ជំនួបក្រៅផ្លូវការ រវាងភាគីខ្មែរទាំង ៤ នៅបូហ្គ័រ នៅខែកក្កដា ឆ្នាំ ១៩៨៨ - ឆ្ពោះទៅរក ការបើកសន្និសីទអន្តរជាតិ នៅទីក្រុងប៉ារីស៍ - ការដក កងទ័ពវៀតណាម ជាឯកតោភាគី ចេញពីកម្ពុជា នៅខែមេសា ឆ្នាំ ១៩៨៩ - យុទ្ធសាស្ត្រនយោបាយ ទីក្រុងបាងកក ចំពោះ អធិក្រម សន្តិភាពនៅ ប្រទេស កម្ពុជា- ទីតាំងរបស់ ប្រទេសវៀតណាម និងសហភាព សូវៀតនៅក្នុងការផ្សះផ្សារវាង គូបដិបក្ខខ្មែរ ទាំង ៤ - សង្គ្រាមផ្ទៃក្នុង នៅកម្ពុជា នៅពេលក្រោយសន្និសីទ ទីក្រុងប៉ារីស៍ឆ្នាំ ១៩៨៩ - សង្គ្រាមផ្ទៃក្នុងមួយ ដែលគ្មានគោលដៅ ច្បាស់លាស់ - ការវាយយកតំបន់

ប៉ៃលិន ដោយ ពួក ប៉ុល ពតនៅថ្ងៃ ២២ តុលាឆ្នាំ ១៩៨៩ - ការវិវត្តន៍ឆ្ពោះទៅរក ការបញ្ចប់សង្គ្រាមផ្ទៃក្នុង នៅឆ្នាំ១៩៨៩- ផែនការសន្តិភាព របស់ លោក ក្លារេត អ៊ីវេន្ស

- **អ្នកស្អប់សេរីភាព** ............................................................. ១៧៥

Les ennemis de la Liberté

ជំពូក ១០ : ការផ្សាំ អារ្យធម៌ខ្មែរ ជាមួយ វប្បធម៌បារាំង........... ១៧៩

- ការបង្កើតអាជ្ញាធរបណ្ដោះអាសន្ន របស់ អង្គការ សហប្រជាជាតិ នៅកម្ពុជា (អាប្រូនុច) -ដំណាក់កាលថ្មី របស់ បក្សប្រជាជនបដិវត្តកម្ពុជា នៅឆ្នាំ ១៩៩០ -អភិក្រមសន្តិភាព នៅប្រទេសកម្ពុជានៅឆ្នាំ ១៩៩០ - ផែនការក្របខ័ណ្ឌ នៃ កិច្ចព្រមព្រៀងរួម នៃ គូភាគីខ្មែរ របស់ គណអចិន្ត្រៃយ៍ នៃ ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហប្រជាជាតិ - ទីតាំង របស់ គូភាគីខ្មែរទាំង ៤ នៅចំពោះមុខផែនការ ក្របខ័ណ្ឌ របស់ ក្រុមប្រឹក្សា សន្តិសុខ អង្គការ សហប្រជាជាតិ - ការមិនយល់ ព្រម របស់ «រដ្ឋកម្ពុជា» អំពីផែនការក្របខ័ណ្ឌ របស់ ក្រុមប្រឹក្សា សន្តិសុខ អង្គការសហប្រជាជាតិ - ការប្រយុទ្ធគ្នារវាង គូភាគីខ្មែរបដិបក្ខ ក្រោយអង្គប្រជុំ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ នៅទីក្រុងប៉ារីស៍ នៅខែធ្នូ ឆ្នាំ១៩៩០ -សម្ដេច នរោត្តម សីហនុ ឯកោក្រុមខ្មែរក្រហមខាង ប៉ុល ពត ហើយហុចដៃតោងលោក ហ៊ុន សែន វិញ - ការវិលមកវិញ នៃអ្នកដឹកនាំចាស់នៅក្នុង បរិបទនយោបាយថ្មី - ឆ្ពោះទៅរកការបញ្ចប់អធិករណ៍ខ្មែរ ដោយរក្សាទុក នូវម៉ាគានយោបាយក្រៅប្រទេស មុនពេលសង្គ្រាម - សម្ដេច នរោត្តម សីហនុ សាកល្បង បង្កើតរដ្ឋាភិបាល ចម្រុះ រវាងគណបក្ស ហ្វ៊ុនស៊ិនប៉ិច និង គនបក្សប្រជាជន - យុទ្ធសាស្ត្រ របស់ លោក ហ៊ុន សែន នៅពេលអង្គការ សហប្រជាជាតិ ចាប់ផ្ដើមចូល មកធ្វើអន្តរាគមន៍នៅឆ្នាំ ១៩៩២-សភាពការណ៍ នៃ គណបក្ស នយោបាយ នានា មុន ការបោះឆ្នោតសេរីលើកដំបូងបង្អស់ រៀបចំដោយ អ. ស. ប. នៅ ឆ្នាំ ១៩៩៣ - បេសកកម្ម ៧ យ៉ាង របស់ អង្គការ «អាប្រូនុច» - ទិតាំង របស់ ខ្មែរក្រហម នៅឆ្នាំ ១៩៩២ - បរិយាកាស មុន ការបោះឆ្នោត ឆ្នាំ ១៩៩៣ - រដ្ឋាភិបាលក្បាលពីរ ក្រោយការបោះឆ្នោតឆ្នាំ ១៩៩៣ - ព្រឹត្តិការណ៍ នៅខែមិថុនា ឆ្នាំ ១៩៩៣ - ការប្រឈមមុខ ដាក់គ្នា រវាង ព្រះអង្គម្ចាស់ចក្រពង្ស និង ព្រះអង្គម្ចាស់រណឫទ្ធិ - ការបែកអំណាចគ្នា រវាង «គណបក្សប្រជាជន» និង «គណបក្ស ហ៊្វុនស៊ិនប៉ិច» នៅឆ្នាំ ១៩៩៣- បញ្ហាខ្មែរក្រហម នៅពេលបង្កើតរដ្ឋាភិបាលបណ្ដោះអាសន្ន នៅឆ្នាំ ១៩៩៣ - ការគាបសង្កត់ របស់ខ្មែរក្រហម ទៅលើរដ្ឋាភិបាលបណ្ដោះអាសន្ន ថ្ងៃ ៣០ មិថុនាឆ្នាំ ១៩៩៣ - រដ្ឋធម្មនុញ្ញខ្មែរ ដែលបានត្រូវប្រកាសឲ្យប្រើ នៅថ្ងៃ ២៤ កញ្ញាឆ្នាំ ១៩៩៣ -លទ្ធិប្រជាធិបតេយ្យ នៅប្រទេសកម្ពុជាក្រោយការបោះឆ្នោត ឆ្នាំ ១៩៩៣ - ខ្លឹមសារ នៃ រដ្ឋធម្មនុញ្ញ នៃ ប្រទេសកម្ពុជា នៅឆ្នាំ ១៩៩៣ - អំណាច នីតប្បញ្ញត្តិ និង អំណាច នីតិប្រតិបត្តិ នៅក្នុង រដ្ឋធម្មនុញ្ញខ្មែរ ឆ្នាំ ១៩៩៣

- «**ល្បើកចចក**» ............................................................... ២៤១

La fable du loup

ជំពូក ១១ : ឆ្ពោះទៅរក របប «គណបក្សតែមួយ»............... ២៤២

ស្ថានភាព នយោបាយ នៃ ប្រទេសកម្ពុជា នៅឆ្នាំ ១៩៩៣ - អំពីការវិលត្រឡប់ មកវិញ នៃ របបរាជានិយម នៅឆ្នាំ ១៩៩៣ -ទស្សនកិច្ច របស់ លោកនាយករដ្ឋមន្ត្រី ថៃ នៅប្រទេសកម្ពុជា នៅ ខែមករា ឆ្នាំ ១៩៩៤ - មួយឆ្នាំក្រោយ ការបង្កើតរដ្ឋាភិបាលឆ្នាំ ១៩៩៣ - របបនយោបាយខ្មែរ - វិបត្តិ នយោបាយ ឆ្នាំ ១៩៩៤ - បញ្ហាលើកលែងទោស ឲ្យមេខ្មែរក្រហម អៀង សារី -ការបែកបាក់សាមគ្គី នៅក្នុងចលនាខ្មែរក្រហម នៅ ឆ្នាំ ១៩៩៦ - អំពីគណបក្ស «ជាតិខ្មែរ» របស់ លោក សម រង្ស៊ី -សភាពការណ៍សង្គមខ្មែរនៅឆ្នាំ ១៩៩៦-ព្រឹត្តិការណ៍ថ្ងៃ ៥ កក្កដាឆ្នាំ ១៩៩៧ - ការគាបសង្កត់ របស់សហគមន៍ អន្តរជាតិ ទៅលើលោក ហ៊ុន សែន ក្រោយ ព្រឹត្តិការណ៍ ថ្ងៃ ៥ កក្កដា ឆ្នាំ ១៩៩៧ - ការរៀបជើងព្រួល បោះឆ្នោត សម្រាប់ នីតិកាលទី ២ - ទីអវសាន នៃ ចលនាខ្មែរក្រហម នៅឆ្នាំ ១៩៩៧-១៩៩៨ -អំពី ចលនាកុម្មុយនស្តខ្មែរ ដែលស្ថិតនៅក្រោមការដឹកនាំ របស់ ប៉ុល ពត - ការបោះ ឆ្នោតសកានៅ ខែកក្កដា ឆ្នាំ ១៩៩៨ - អំពីយុទ្ធសាស្ត្រ នៃ ការកសាងប្រទេសឡើង វិញ ពីឆ្នាំ ១៩៩២ មកដល់ឆ្នាំ ១៩៩៨

- «**អ្នកទទួលមត៌ក** ........................................................................ ៣២៥

Les héritiers

*អំពីរបបសេដ្ឋកិច្ច នៃ ប្រទេសកម្ពុជា នៅក្នុងរយៈពេល ៥ សតវត្សរ៍កន្លងមក - អំពី ឧបសគ្គផ្សេងៗ នៅក្នុងការអភិវឌ្ឍន៍ -ស្ថានភាពសង្គម និង សេដ្ឋកិច្ច នៃ ប្រទេសកម្ពុជា ៧ ឆ្នាំក្រោយអន្តរាគមន៍ របស់អង្គការ សហប្រជាជាតិ -អំពីបញ្ហាកាត់ទោសអតីតមេខ្មែរក្រហម- ការបូកសរុប ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខ្មែរ តាំងពី ឆ្នាំ ១៨៦៣ មកដល់ ឆ្នាំ ២០០០-ប្រទេសកម្ពុជា មុនពេល វត្តមាន របស់បារាំង -ឆ្ពោះទៅរកការបញ្ចប់សង្គ្រាម-បរិបទអន្តរជាតិ និង ភូមិសាស្ត្រ នយោបាយ -វាស នាដ៏អាក្រក់ នៃ គណបក្សប្រជាធិបតេយ្យ - អភិក្រមទំនើបកម្ម ប្រទេសកម្ពុជា ចាប់តាំងពីដើមសតវត្សរ៍ ទី ២០ -របបនយោបាយ កាលពីជំនាន់ «សង្គមរាស្ត្រនិយម» - ការប្រយុទ្ធ ក្នុងឆាកនយោបាយ របស់ សម្តេច នរោត្តម សីហនុ -*

**កាលប្បវត្តិ សង្ខេប** ..................................................................៣៧៥

**គន្ថនិទ្ទេស** .........................................................................៤១៩

**ឧបសម្ពន្ធ** ..........................................................................៤៣២



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

# អំពីអក្ខរាវិរុទ្ធ និង វេយ្យាករណ៍ខ្មែរ

ពាក្យពេចន៍ ដែលប្រើ ក្នុងសិក្សាកថានេះ តម្រូវទៅតាម វចនានុក្រមខ្មែរ ដែលបោះពុម្ពផ្សាយ នៅឆ្នាំ ១៩៦៧ ដោយពុទ្ធសាសនបណ្ឌិត្យ។ គឺជាវចនានុក្រម ដែលរៀបរៀង ដោយក្រុមជំនុំខ្មែរ ពោលគឺ គណៈកម្មការដ៏ធំមួយ ក្រោមការដឹកនាំ របស់សម្តេចព្រះសង្ឃរាជ **ជួន ណាត** ហើយដែលបោះពុម្ពផ្សាយនៅគ្រាទី ៥ ។ ពាក្យខ្លះ សរសេរ ជា ពីរបែប ពាក្យខ្លះ សរសេរបានតែមួយបែប។ ដើម្បីសម្រួលដល់ ការអាន ខ្ញុំបានសរសេរ ជា ពីរបែប តែម្តង ហើយ ពាក្យខ្លះ សរសេរ ដោយគ្មានតម្រួតតាមទម្លាប់ ដែលអ្នកប្រើភាសាខ្មែរក្រោយៗមកទៀត បានសរសេរ ដូចជាពាក្យ **ចំរើន សំរាប់**, **សំគាល់** ជាដើម។ ចំពោះពាក្យខ្លះទៀត ដូចជា **បដិវត្តន៍**, **អភិវឌ្ឍន៍** ជាដើម ដែលប្រើជា កិរិយាសព្ទ ឬ គុណនាម ខ្ញុំ សរសេរ **បដិវត្ត, អភិវឌ្ឍ** គឺ គ្មាន តួអក្សរ **ន** និង សញ្ញាទណ្ឌឃាត (- ន៍) នៅខាងចុង តាមក្បួនវេយ្យាករណ៍ខ្មែរ ។ ប៉ុន្តែ ដើម្បីស្រួលសំគាល់ ការប្រើ នាម ឬ គុណនាម នៅក្នុងសៀវភៅនេះ ខ្ញុំ សរសេរ បដិវត្ត ឬ អភិវឌ្ឍ ដោយគ្មាន **ន** និង ទណ្ឌឃាត តែនៅក្នុងករណី មនុស្ស តែប៉ុណ្ណោះ។ ឧ. : **អ្នកបដិវត្ត**, **ពួកបដិវត្ត**, **អ្នកអភិវឌ្ឍ** ។ ក្រៅពីនោះ ខ្ញុំសរសេរជា នាម ទាំងអស់ ដូចជា **ចលនា បដិវត្តន៍**, **គណៈកម្មការ បដិវត្តន៍** ។ល។ ទោះបី មានការពិនិត្យច្រើនដងក្តី ក៏ តែងតែ នៅមានពាក្យសរសេរខុសខ្លះដោយអចេតនា នៅក្នុងការសរសេរ លើ អ័រឌីណាទ័រ។ អាស្រ័យហេតុនេះ សូមលោកស្រីអស់លោកអ្នកអាន មេត្តាអភ័យទោស។

# អារម្ភកថា

នៅក្នុងភាគ ២ នៃ សុបិន និង ការពិត នេះ ខ្ញុំសាកល្បង ពន្យល់ហេតុផល ដែលបាននាំឲ្យស្រុកខ្មែរ វិលទៅរករបបចាស់វិញ ក្រោយអន្តរាគមន៍របស់អង្គការ សហប្រជាជាតិនៅឆ្នាំ ១៩៩២ និង ការវិលមកវិញ នៃ អ្នកដឹកនាំចាស់ ដែលបានគ្រប់គ្រងប្រទេស មុនរបបសាធារណរដ្ឋខ្មែរ។ នៅក្នុងភាគទី១ ខ្ញុំបានលើកឡើងអំពី ព្រឹត្តិការណ៍ ដែលមានជាហូរហែ តាំងពីឆ្នាំ ១៩៥២ («រដ្ឋប្រហារស្របច្បាប់ របស់ ព្រះមហាក្សត្រ) រួចមកហើយមក។ នៅក្នុងភាគទី ២ នេះ ខ្ញុំសាកល្បងឆ្លុះបញ្ចាំង នូវ សភាពការណ៍ ទាំងឡាយដែលចេញមក ពីនយោបាយប្តូរទិស នៃ អភិក្រមប្តូរ របនាសម្ព័ន្ធ សង្គម-វប្បធម៌ ដែលបានចាប់ផ្តើមជាសន្សឹមៗ តាំងពីឆ្នាំ ១៩០៥មក ជាពិសេសចាប់តាំង ពីឆ្នាំ ១៩៤៦។ ដូចយើងបានដឹងរួចមកហើយ ការវិត្តន៍ឆ្ពោះ ទៅភាពសម័យទំនើប តាមបែបបទ បស្ចិមលោក បានត្រូវកាត់បន្ថយជាសន្សឹមៗ ក្រោយពេលដែលស្រុកខ្មែរ បានឯករាជ្យពីបារាំង (១៩៥៣) ។ នៅឆ្នាំ ១៩៥៥ ការត្រៀមលក្ខណៈ កែប្រែស្ថាប័នរដ្ឋ ដើម្បីឈានទៅរករបប «បក្សតែមួយ» តាមរបៀបប្រទេសកុម្មុយនិស្ត ក៏បានចាប់ផ្តើម នៅទសវត្សរ៍ ១៩៥០ នោះ ដែរ គឺ ២ ឆ្នាំក្រោយពេលដែលបារាំង ប្រគល់ឯករាជ្យបិបូរ មកឲ្យខ្មែរ ។ នៅដើម ទស វត្សរ៍ ១៩៥០ បារាំងដែលកំពុងប្រយុទ្ធ នឹង វៀតមិញ មានការបារម្ភខ្លាចគណបក្ស ប្រជាធិបតេយ្យ របស់បញ្ញវន្តខ្មែរ មានទំនាក់ទំនង ជាមួយចលនា វៀតមិញ។ ហេតុដូច្នេះ ហើយបានជាបារាំង - ដែលជាអ្នកនាំធ្វើ ការកែប្រែស្ថាប័នរដ្ឋ ទៅតាមបែបបទប្រជាធិបតេយ្យបារាំង - បែរជាជំរុញ ឲ្យព្រះមហាក្សត្រខ្មែរ ក្តាប់អំណាចវិញដោយប្រើមាត្រា ២១ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧។ ម៉្យាងទៀតគណបក្ស «សេរីនិយម» របស់ ព្រះអង្គម្ចាស់ នរិនដេត ដែលបារាំងបានបង្កើត ក៏ទទួល បរាជ័យទាំងស្រុង ទៅ





ទៀត នៅ ចំពោះមុខគណបក្ស ប្រជាធិបតេយ្យ ។ នៅពេលបោះឆ្នោត សភាធម្មនុញ្ញ ឆ្នាំ ១៩៤៦ គណបក្ស សេរី និយម បានតែ ៤ អាសនៈ ហើយ គណក្សប្រជាធិបតេយ្យ បានរហូតទៅ ៥០ អាសនៈ ក្នុងអាសនៈទាំងអស់ ចំនួន ៦៧ ។ រីឯ ការបោះឆ្នោតសភានាខែធ្នូ ឆ្នាំ ១៩៤៧ ក៏ ផ្តល់ ជ័យជំនះទៅឲ្យគណបក្ស ប្រជាធិបតេយ្យ ដែរ (២១ អាសនៈ ទល់ នឹង ៥៤ អាសនៈ) ។ នៅឆ្នាំ ១៩៩៣ ប្រជាជនខ្មែរ បានបោះឆ្នោតឲ្យគណបក្សរាជានិយម ហ៊្វុនស៊ិនប៉ិច។ គេ សង្កេតឃើញថា គណបក្សដែលមាន បាវចនានាំប្រទេស ទៅរក ការប្តូររបនាសម្ព័ន្ធ បានទទួលសន្លឹកឆ្នោតតិចណាស់ បើប្រៀបធៀបទៅឆ្នាំ ១៩៤៧ ។ បើផ្អែកទៅលើទិន្នន័យ ទាំងនេះ គេអាចនិយាយបានថា ប្រជាជនខ្មែរភាគច្រើន ក្រោយ របប កុម្មុយនិស្តពីរ (១៩៧៥-១៩៩៣) មាន ទស្សនៈនយោបាយ អភិរក្សនិយម ។ រីឯ មូលហេតុ មាន ២ គឺ ១) ក្រៅពី ការស្អប់ របបកុម្មុយនិស្ត ខ្មែរភាគច្រើន ចង់វិលទៅរក របបចាស់វិញ តាមរយៈព្រះមហាក្សត្រ នរោត្តម សីហនុ ដែលគេពុំបានដឹង ឬ ដឹងដោយស្រពេចស្រពិលថា ជាអ្នកដែល គាំទ្រ របបកុម្មុយនិស្ត តាំងពីដើមឆ្នាំ ១៩៦០ មក។ ២) ស្ហូល ទស្សនៈសម័យទំនើប ដែលបញ្ញវន្ត ប្រជាធិបតេយ្យខ្មែរ បានបង្កើតនៅឆ្នាំ ១៩៤៦ តាមបែបបទបារាំង ហើយដែលមាន ខ្សែរយៈបន្តរហូត ដល់ឆ្នាំ ១៩៦៧ (ចលនា ខេមរយានកម្ម និង មិត្តភាពពិសេស ជាមួយប្រទេសចិន កុម្មុយនិស្ត ម៉ៅនិយម) បានត្រូវបាត់បន្តិចម្តងៗ អស់ទៅវិញ ជាបន្តបន្ទាប់ រហូតដល់ឆ្នាំ ១៩៧០-១៩៧៥។ នៅក្នុងរយៈពេល ៥ ឆ្នាំ នៃ របបសាធារណរដ្ឋខ្មែរ ការនិយមវប្បធម៌បស្ចិមលោក បានវិលមកវិញខ្លះៗ តាមរយៈអ្នកចេះភាសាបារាំង ស្ទាត់ជំនាញ បូករួមជាមួយ អ្នកចេះភាសាអង់គ្លេសផង ប៉ុន្តែ ពីឆ្នាំ ១៩៧៥ មក របប ប៉ុល ពត បានផ្តាច់ខ្សែរយៈអ្នកចេះដឹង សឹងតែអស់រលីង ហើយ អ្នកសល់ពីការកាប់សម្លាប់ បាននាំគ្នាទៅជ្រកកោន នៅ បរទេស ជាពិសេស នៅប្រទេសបារាំង ។ នៅក្នុងការបោះឆ្នោតឆ្នាំ ១៩៤៧ អ្នកអង្គម្ចាស់យុត្តិវង្ស ដែលជា ក្សត្រមួយអង្គដែរនោះ បានដើរតួនាទីមួយដ៏សំខាន់ បន្ថែមពីលើកម្មវិធី នយោបាយ របស់ គណបក្ស ប្រជាធិបតេយ្យ ។ ទិន្នន័យខាងលើនេះ ក៏បញ្ជាក់ឲ្យឃើញ ផងដែរថា ទស្សនៈទេវនិយម ស្ថិតនៅជាប់ ជានិច្ចក្នុង

អារម្មណ៍ របស់ប្រជាជនក៏ពិតមែន តែទន្ទឹមនោះ ការចង់បានយុត្តិធម៌ និង សិទ្ធិសេរីភាព នៅក្នុងចំណោមយុវជនដែលរៀននៅតាមវិទ្យាល័យ ក៏មានខ្លាំងណាស់ដែរ។ អ្នកដែលចេះធ្វើឲ្យគេយល់ថា ខ្លួនគេជាអ្នក «មានបុណ្យ» ជាអ្នកតំណាងព្រះឥន្ទ្រាធិរាជ នៅតែមានឥទ្ធិពលទៅលើប្រជាជនដដែល។ នយោបាយបន្ថយការចេះដឹង និង ការបិទ បាំងមិនឲ្យស្គាល់ តថភាពសង្គម និង វឌ្ឍនភាព ផ្នែកទស្សនវិជ្ជា នៅក្នុងពិភពលោក បានហុច នូវលទ្ធផល ដ៏កក់ក្ដៅ ចំពោះអ្នកដឹកនាំអភិរក្សជាតិយម និង«អ្នកបដិវត្តកុម្មុយនិស្ត អភិរក្សនិយម»។ នេះជាផ្លូវបែកមួយ ប្រកបដោយគ្រោះថ្នាក់ ក្នុងការនាំ ប្រទេស ឆ្ពោះទៅរកការរីកចម្រើន គ្រប់វិស័យ (accroissement des difficultés d'insertion du pays dans le monde moderne)។ បទពិសោធន៍ របស់ប្រជាជនដើម នៅសហរដ្ឋអាមេរិក បានបញ្ជាក់ យ៉ាងច្បាស់នូវ គ្រោះថ្នាក់នេះ ព្រោះ វាជាការងាយស្រួល សម្រាប់ឲ្យ អ្នកដែលមានវិទ្យាសាស្ត្រ និង បច្ចេកវិជ្ជាខ្ពស់ ព្រមទាំងបញ្ញត្តិ (concepts) នយោបាយដែលផ្អែកទៅលើ វិចារណញ្ញាណ និងទិន្នន័យវិទ្យាសាស្ត្រ អាចជិះជាន់នឹងសង្កត់សង្កិនអ្នកប្រភេទទីមួយ គឺអ្នកដែលមានជំនឿ ទៅលើកម្លាំងអច្ឆរិយៈ និង ទៅលើការឈឺឆ្អាល របស់ ពពួកទេវ ចំពោះវាសនា របស់ ខ្លួនគេម្នាក់ៗ ។ នៅក្នុងប្រវត្តិសាស្ត្រ នៃ ប្រទេសអភិវឌ្ឍ គេសង្កេត ឃើញថា ចរន្តវិទ្យាសាស្ត្រ និង ទស្សនវិជ្ជាថ្មីៗ បានយកឈ្នះ ទៅលើជំនឿទាំងឡាយ ដែលគ្មានមូលដ្ឋាន ។ តាមរយៈការចេះដឹងទាំងនោះ គេយល់ឃើញថា គឺ មនុស្សទេ ដែល កំណត់ជោគវាសនា របស់ មនុស្សជាតិ ។ ប៉ុន្តែនៅក្នុងន័យដដែលនេះ បើពួកមនុស្សពាលឈ្នះ គឺអ្នកទាំងនេះហើយ ដែលដឹកនាំពិភពលោក។ ហេតុដូច្នេះហើយ បានជាទន្ទឹមនឹង វឌ្ឍនភាព គេត្រូវមានគំនិតមនុស្សធម៌ ជាគោលមាគ៌ាផងទៀត។ បើពុំដូច្នេះទេ ការរីកចម្រើន ក៏ពុំមានន័យអ្វីដែរ គឺ ដូចពាក្យមួយឃ្លា របស់ម៉ុងតែញដូច្នេះដែរ ៖ «វិទ្យាសាស្ត្រដែលគ្មានមនសិកា គឺ គ្រាន់តែជា ការវិនាស សាបសូន្យ នៃ ចិត្តគំនិត ឧត្តមគតិ តែប៉ុណ្ណោះ» («science sans conscience n'est que ruine de l'âme») ។





ខុសប្លែកពី សៀវភៅ ប្រវត្តិសាស្ត្រ នៃ ប្រទេសកម្ពុជា ដែលជា ការលាតត្រដាង អំពី ដំណើរ ជាបន្តបន្ទាប់ នៃ ព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រ (étude factuelle) សុបិន និង ការពិត ជាការសិក្សាសង្គមសាស្ត្រ។ គឺជាការវិភាគដែលផ្អែកទៅលើគោលការណ៍ នៃ វិទ្យាសាស្ត្រ ដូចជា ឥរិយាបថ បណ្ដោយខ្លួនធ្វើអ្វី តាមគេឯង តាមការបំផុសបំផុលគំនិតផ្សេងៗ នៅក្នុងមជ្ឈដ្ឋាន ឬ ក្នុងសង្គមមួយ (mimétisme) ឬ ការកំណត់ ជោគវាសនាខ្លួន តាមការតម្រូវ របស់ មនុស្សភាគច្រើន នៅក្នុងសង្គមជាដើម (effets d'agrégation)។ បាតុភូតនេះ ដូចជា ការនាំគ្នាជ្រើសរើសមុខរបរ តែមួយ ដូចគ្នា តែងតែ នាំទៅរក ការប្រកួតប្រជែងគ្នាដោយឥតមេត្តា ពេញសង្គមទាំងមូល ហើយដែលជាកត្តា ដ៏សំខាន់ នៃ ការបាត់បង់មុខវិជ្ជាជីវៈផ្សេងៗទៀត និង ការកើនចំនួន អ្នកគ្មានអាជីពនៅក្នុងសង្គម។ បញ្ញត្តិ (concepts) បដិបក្ខ រវាង ឥរិយាបថ សម្របខ្លួនតាមរបៀបរស់នៅ នៃ សង្គម (conformisme) និង ការឃ្លាតចេញពី របៀបរបបរស់នៅដែលគេបានកំណត់ (déviance) ក៏បានត្រូវយកមកឆ្លុះបញ្ចាំងសង្គមខ្មែរ ទន្ទឹមនឹងការចូលរួមចំណែក ឬការមិនចូលរួមចំណែក របស់ប្រជាជន(consensus et rejet) ក្នុងនយោបាយ ឬ មនោគមវិជ្ជា ដែលពួកវរជន (les élites) បានយកមកដឹកនាំសង្គមផងដែរ។ ការសិក្សាសង្គមសាស្ត្រមិនអាចកាត់ផ្ដាច់ចេញពីការសិក្សាសេដ្ឋកិច្ច(Pareto) និង ប្រជាសាស្ត្រ បានទេ ។ បើយោងតាម ការបែងចែក របស់ បារាំង នរវិទ្យាសង្គម និង វប្បធម៌ (anthropologie sociale et culturelle) ពុំមានអ្វីខុសប្លែកពី ជាតិពន្ធវិទ្យា (ethnologie) ទេ ក៏ប៉ុន្តែ ខុសពីជាតិពន្ធវិទ្យា មុខវិជ្ជា នរវិទ្យានេះ មាន ទំនាក់ទំនងជិតស្និទ្ធ នឹង សង្គមវិទ្យាជាង ។ សង្គមវិទ្យាកើតឡើងនៅសតវត្សរ៍ ទី ១៩ ដើម្បីបំពេញ សេចក្ដីត្រូវការ នៃ ការវិភាគសង្គមសម័យទំនើប ក្រោយបដិវត្តន៍ នយោបាយ និង ឧស្សាហកម្ម ។ គោលការណ៍ជាតិពន្ធវិទ្យា ដែលសម្រាប់ប្រើក្នុងការវិភាគ «សង្គមខ្នាតតូច» ពុំអាចយកមកប្រើ សម្រាប់ ការសិក្សាសង្គមដែលកំពុងវិវត្ត បានទាំងអស់ទេ។ ហេតុដូច្នេះហើយ បានជាខ្ញុំធ្វើការសិក្សាសង្គមសាស្ត្រវិញព្រោះ តាំងពីឆ្នាំ ១៩៣៦ មក ជាពិសេសពីឆ្នាំ ១៩៤៧ សង្គមខ្មែរ ពុំមែនជាសង្គមដែលនៅទ្រឹងមួយកន្លែងឡើយ

ប៉ុន្តែ ដែលវិល តាមបាតុភូត ចក្រចលនា (cyclique) ដោយ កម្លាំង ចលករ វប្បធម៌ ពុំទាន់ចុងផុត ដំណាក់ការសំខាន់ៗ នៃ ការវិវត្តន៍ [1] ។ ទោះជាយ៉ាងណាក្តី គេសង្កេតឃើញថា ចំពោះ ជាតិពន្ធវិទ្យា ក៏ ដូចជា ចំពោះ សង្គមវិទ្យា ការសិក្សា រចនាសម្ព័ន្ធ (structure) និងការិយកម្ម (fonction) និង ការវិភាគក្រឹត្យក្រម ដែលកំណត់សកម្មភាពក្នុងសង្គម ជាកិច្ចការដ៏សំខាន់បំផុត។ សង្គមវិទ្យា មានបែបបទច្រើនយ៉ាង បើគិតពី វិធីសាស្ត្រ និងគោលដៅផ្សេងៗ នៃ វិទ្យាសាស្ត្រនេះ។ បើនិយាយពីការកកើតឡើងរបស់វា គឺចាប់ផ្តើម ពីសិក្សាកថា «លេខគណិតនយោបាយ» របស់ សេដ្ឋវិទូ អង់គ្លេស វិល្លាម ប៉េទី (Essais d’arithmétique politique de W. Petty, ១៦២៣-១៦៨៧) នៅសតវត្សរ៍ទី ១៧ និង ទី ១៨ ពី តារាងពណ៌នា របស់ យ៉ូហាន-ពីទែរ ស៊ូសមៀលស៍ (Tableaux descriptifs de Johann-Peter Süssmilch, ១៧០៧-១៧៦៧) ពី គណិតសាស្ត្រសង្គម របស់ កុងឌ័រសេ (mathématique sociale de Nicolas de Condorcet, ១៧៤៣-១៧៩៤ ) ។ ប៉ុន្តែ គេអាចនិយាយបានថា ការវិភាគសង្គម តាម

[1] អូហ្គូស កុង (Auguste Comte, ១៧៩៨-១៨៥៧ ) កំណាត់ថាការវិវត្តន៍ មានអាយុកាល ៣ គឺ អាយុកាល ទេវជំនឿ (âge théologique) អាយុកាល បរមត្ថ ឬ អរូបី (métaphysique ou abstrait) និង អាយុកាល វិជ្ជមាន (état positif) ។ អាយុកាល បរមត្ថ ឬ អរូបី មានបួនយ៉ាង គឺ ១) យោងតាមទស្សនៈ របស់ ស្ពីណូស្ហា ដែលយល់ថា សេរីភាពបុគ្គល មានអត្ថិភាព របស់វា នៅក្នុងធម្មជាតិ - ២) «ព្រះ» ជាអ្នកកំណត់ លោកធម្មភាព (Descartes, ១៥៩៦-១៦១៦៥០) - ៣) ទស្សនៈរូបធាតុនិយម (maté-rialisme) តាមការពន្យល់ របស់ ឌីដ៏រ៉ូ (Diderot, ១៧១៣-១៧៨៤) - ៤) ការវិភាគ ដែលឈរនៅលើ វិចារណញ្ញាណ តាមការតម្រូវ របស់ ទស្សនវិទូនាសតវត្សរ៍ ទី ១៨។ បន្ទាប់មក ដំណាក់កាលវិជ្ជមាន របស់ អូហ្គូស កុង (Auguste Comte, ១៧៩៨- ១៨៥៧) ដែលផ្អែកទៅលើ ការយកការសន្និដ្ឋាន ទៅពិសោធក្នុងតថភាព។





បែបបទសង្គមវិទ្យា ចាប់ផ្តើមមានមក តាំងពីម៉ុងតេសគីយើ (Montesquieu, ១៦៨៩-១៧៥៥) និង ហ្សង់-ហ្សាក់ រូស្សូ (J.J. Rousseau, ១៧១២-១៧៧៨) ។ មែនទែនទៅ សង្គមវិទ្យាសម័យទំនើប មានមូលដ្ឋាន របស់វាតាមរយៈ អូហ្គូស កុង និង ឌឺកខែម (Durkheim, ១៨៥៨-១៩១៧)។ សង្គមវិជ្ជា ពុំអាចចេញផុតពីទស្សនៈ របស់ ទស្សនវិទូទេ (Saint-Simon, Fourier, Proudhon, Marx) ហើយ ក៏ មិនអាចផ្តាច់ចេញពីវិទ្យាសាស្ត្រ សេដ្ឋកិច្ច (Pareto) និង ប្រជាសាស្ត្របានដែរ (Alfred Sauvy, E. Duprerel, D. Riesman, Stoetzel ) ។ សង្គមវិទូខ្លះ ធ្វើការសិក្សា អំពី សង្គម ប្រជាធិបតេយ្យដែលពុំចេញមកពីបដិវត្តន៍ វាយរំលំ ពួកវណ្ណៈអភិជន (les démocraties qui ne sont pas issues des révolutions, dont l’abolition de l’aristocratie) ដូចជា សហរដ្ឋ អាមេរិក ជាដើម (Alexis de Tocqueville) ហើយសង្គមវិទូខ្លះទៀត ដូចជា ម៉ាលីណូវស្គី (Malinowski) ជាដើមធ្វើការសិក្សា អំពីដំណើរការសង្គម និង បញ្ហា ដែលធ្វើឲ្យរាំងស្ទះ ដំណើរការនោះ ព្រោះគេយល់ថា សង្គម មានស្ថិរភាពគ្រប់គ្រាន់ មិនប្រែប្រួលឡើយ គឺផុតពីការរាំងស្ទះ មួយពេលៗ តែងតែវិល ទៅរកសភាពដើមវិញ (fonctionnalisme)។ ប៉ុន្តែ មែរតុន (R.K. Merton) និង សង្គមវិទូផ្សេងៗទៀត ដូចជា តាល់កុត ប៉ារសុន (Talcott Parsons) ដែលជាអ្នកការិយនិយម (fonctionnalistes) ដែរនោះ ក៏មិនយល់ស្របនឹងទស្សនៈការិយនិយម (analyse fonctionnelle) បែបនេះទាំងស្រុងឯណាដែរ។ រីឯ ទស្សនៈ រចនាសម្ព័ន្ធ-ការិយការ (analyse structurelle fonctionnelle) របស់ មែរតុន ក៏ពុំបានត្រូវគេរិះគន់ដែរ ទោះបីគេយល់ថា សង្គម ឬ សណ្តាប់ធ្នាប់សង្គម មាន ការប្រែប្រួលជានិច្ច ហើយ ទស្សនៈ របស់ មែរតុន នៅតែឈរនៅលើ បញ្ញត្តិ «វិលទៅរកតុល្យភាព នៃសណ្តាប់ធ្នាប់សង្គមនឹងថ្កល់តែមួយដដែល»។ ចំពោះសង្គមវិទូមួយចំនួន បដិវត្តន៍គ្រាន់តែជា «គ្រោះថ្នាក់» ជាចៃដន្យមួយ ប៉ុណ្ណោះប៉ុន្តែ សង្គមវិទូ ជាច្រើនទៀត យល់ថា បដិវត្តន៍ ជាក្រិត្យក្រម នៃ សង្គមនីមួយៗ ព្រោះគេបានឃើញថា ការវិវត្តន៍ ទៅរក សណ្តាប់ធ្នាប់ថ្មីៗ មានជា អចិន្ត្រៃយ៍ ទោះជានាំទៅរក ការប្របូកប្របល់ក៏ដោយ ។ ប្រវត្តិសាស្ត្រ ជាស្នាដៃ របស់ មនុស្ស គឺមិនមែនជា ធន្ទះរបស់ ពពួកទេវ គឺ អ្នកដែលស្ថិតនៅក្រៅទុក្ខសោក របស់

មនុស្សនោះទេ ។ ទុក្ខវេទនា របស់ មនុស្ស ជា ប្រភព នៃ បដិវត្តន៍ ហើយទស្សនវិជ្ជា ដែលផុសចេញពីការយល់ដឹង ពី មូលហេតុ នៃ ទុក្ខវេទនានោះ ជាកត្តាមួយ ដ៏សំខាន់ នៃ បដិវត្តន៍ ឬ ការប្រែប្រួលសណ្តាប់ធ្នាប់ នៃ ការរស់នៅ ទោះ ជាទស្សនៈនោះ ពុំមាន លក្ខណៈគ្រប់គ្រាន់សម្រាប់កសាងសង្គមថ្មីក៏ដោយ។ តែនេះជាដំណើរ នៃប្រវត្តិសាស្ត្រ ដែលគ្មានសង្គមណាមួយ អាចគេចផុតនោះទេ លើកលែងតែសង្គម ដែលបិទជិតស្លុង មិន ឲ្យមានទស្សនៈថ្មីៗ ចូលមកបាន។ ប៉ុន្តែសង្គមបែបនេះ ក៏មិនអាច គេចផុត ពីការផ្តាច់ខ្លួនចេញពី ពីភពលោកដែរ ហើយនៅទីបំផុត នឹងត្រូវសង្គមនានាទៀត ដែល មានប្រៀប ជាង សង្កត់សង្កិន ជដែលជាជដែល បើ សង្គមនោះ ពុំផ្ទុះខ្លួនឯងនោះទេ (implosion) ព្រោះជាសង្គមដែលគ្មានអ្វី ដែលប្រទេស ឯទៀតគេមាន ហើយដែល យុវជនតែងតែចង់ បានដែរនោះ ដូចជា សេរីភាពជាដើម។ នៅអឺរ៉ុប ជាពិសេស នៅ ប្រទេសបារាំង ចាប់តាំង ពីឆ្នាំ ១៨៨០ មក លោកទស្សនៈ មាន ការប្រែប្រួលរហូត ព្រោះ ការស្វែងរកសច្ចធម៌ ទស្សនវិជ្ជា (vérité philosophique) ចេះតែមានបន្ត ឥតមានដាច់ ។ លោកទស្សនៈ ដែលគេបានណែនាំ ឲ្យយើងស្គាល់ តាមរយៈកវី អ្នកនិពន្ធ និង តាមទស្សនវិជ្ជា សាសនា នានា មានការប្រែប្រួលជានិច្ច ។ តាំងពី កូពែរនិច ហ្គាលីឡេ មក គេបានដឹងថា ផែនដីមូល ហើយ វិលជុំវិញ ព្រះអាទិត្យ ។ ហ្គាលីឡេ បានធ្វើឲ្យ មូលដ្ឋានទស្សនវិជ្ជា របស់ អារីស្តូត រលំរលាយអស់។ ចាប់តាំង ពីចុងសតវត្សរ៍ ទី ១៩ មក គេយល់កាន់តែបានច្បាស់ អំពីអាថ៌កំបាំង របស់មនុស្ស ហើយទាំងកវី ទាំងវិចិត្រករ និងទស្សនវិទូ គេនាំគ្នា ស្វែងយល់អំពី ជម្រៅ នៃ ពិភពលោក គឺ មិនទទួលយកទស្សនៈចាស់ ដែលបង្ហាញ តែរូបរាងដែលយើងឃើញ តាមចក្ខុវិញ្ញាណនោះឡើយ (les apparences)។ ម្យ៉ាងទៀត កិច្ចការនេះបានក្លាយទៅ ជាភារកិច្ច របស់អ្នកថតរូប (photographes) វិញ ទៅហើយ ។ វិចិត្រករ សេហ្សាន (Cézanne, ១៨៣៩-១៩០៦) វ៉ាន់ ហ្គោក (Van Gogh, ១៨៥៣- ១៨៩០) និង ហ្គូហ្គាំង (Gauguin, ១៨៤៨-១៩០៣) មិនយល់ស្រប នឹង ចក្ខុនិម្មិតន៍ (visions) របស់បណ្តាវិចិត្រករ អារម្មណ៍និយម (les impressionnistes) និងប្រាកដនិយម(les





réalistes) ឡើយ។ វិចិត្រករទាំងបីនាក់នេះ ជាអ្នកដែលបានបើកផ្លូវវិចិត្រកម្ម សម័យទំនើបឆ្ពោះទៅរក ការសាកល្បងស្វែងរក ទស្សនៈយល់ដឹង អំពី តថភាព មែន ទែន នៃពិភពលោកសាជាថ្មី ឡើងវិញ (reconstruction mentale du réel) ។ ចលនាហ្វូវិស (fauvisme), ហើយក្រោយមកចលនា«ទស្សនិយម» (expression-nisme : Dongen, Dairan, Vlaminck) ស្វែងរក តថភាពពិភពលោក ដោយ ចាប់ ផ្តើម ពីទស្សនៈផ្ទាល់ របស់វិចិត្រករ។ ចលនា គុយប៊ីស (cubisme : Picasso, Braque) បែរ ទៅរកការកាត់ តថភាព ជាប្លង់រេខាគណិត ទំហំបី គឺបណ្តោយ ទទឹង និង ជម្រៅ ហើយ ដាក់បញ្ចូលទៅក្នុងលំហ។ វិចិត្រករខ្លះដែលជាសាវក នៃចលនា និមិត្តរូបនិយម (symbolisme) ដូចជាម៉ូរ៉ូ (Moreau, ១៧៩០-១៨៦២) រ៉េដុង (Redon, ១៨៤០-១៩១៦) ឬ គ្លីម (Klimt, ១៨៦២-១៩១៨) មិនយល់ថា វិញ្ញាណទាំងប្រាំ អាចនាំទៅរកការយល់ដឹង ពី តថភាព បានទេ ។ គឺពីពេលនោះមកហើយ ដែល ក្រោមឥទ្ធិពល របស់ កង់ឌិនស្គី (Kandinski, ១៨៦៦-១៩៤៤) ម៉ាឡេវិច( Malevitch, ១៨៧៩-១៩៣៥) គូបកា (Kupka, ១៨៧១-១៩៥៧) វិចិត្រកម្ម អរូបី (peinture abstraite ou non-figura-tive) បានចាប់បដិសន្ធិ។ នៅក្នុងវិស័យតូរ្យតន្ត្រី វ៉ាក់នែរ (Wagner, ១៨១៣-១៨៨៣) មូស្សូរស្គី (Moussorgski, ១៨៣៩-១៨៨១) ម៉ាលែរ (Malher, ១៨៦០-១៩១១) និង ឌេប៊ូស្ស៊ី (Debussy, ១៨៦២-១៩១៨) ជាពិសេស ស៊ុនប៊ែរ (Musique sérielle ou dodécaphonique de Schönberg, ១៨៧៤-១៩៥១) បាន រំដោះតូរ្យតន្ត្រី ចេញរួចពី របៀប របស់ បាក់ (Bach, ១៦៨៥-១៧៥០) ដែលជាបែបបទគំរូ តែមួយគត់ នៅអឺរ៉ុប (l’harmonie) ។ នៅឆ្នាំ ១៨៤៧ ទស្សនវិទូ និង គណិតវិទូអង់គ្លេស ហ្សក ប៊ូល (George Boole, ១៨១៥-១៨៦៤) បាន សាកល្បងបង្កើត ពីជគណិតមួយបែប (L’analyse mathématique de la logique, ១៩៤៧) ដែលអាចយកទៅធ្វើជា ភាសា សកល នៅក្នុងវិស័យផ្សេងៗ ទៀត នៃ វិទ្យាសាស្ត្រ ។ ទោះបី នៅឆ្នាំ ១៨៥៤ លោក បានជួប នឹង ការខ្វះខាតជាច្រើន ដើម្បីឈាន ឲ្យបានដល់ គោលដៅ ដ៏ ធំធេងនេះក្តី ក៏ ពីជគណិត របស់លោក

ជាការចាប់ផ្ដើមមួយដ៏សំខាន់សម្រាប់ការវិភាគផ្សេងៗ នៅក្នុង វិស័យ វិទ្យាសាស្ត្រខ្លះ នៅ សតវត្សរ៍ ទី ២០ ដែរ ជាពិសេស ជាមូលដ្ឋាន ដ៏សំខាន់ សម្រាប់ការស្រាវជ្រាវ តក្កវិទ្យា និងគណិតសាស្ត្រ របស់ ហ្វ្រេស្ស (Frege, ១៨៤៨- ១៩២៥) និង ប៊ែរត្រង់ រ៉ូស្សែល (Bertrand Russel, ១៨៧២-១៩៧០)។

ដើម្បីយល់ឲ្យបានច្បាស់ ពី លក្ខណៈ នៃ ព្រឹត្តិការណ៍ ដែលកើតមានឡើង នៅ សតវត្សរ៍ ទី ១៩ និង ទី ២០ គេត្រូវដឹងថា ទស្សនវិជ្ជា របស់ម៉ាក្ស (le marxisme) មួយចំណែក ហើយមួយចំណែកទៀត ទស្សនវិជ្ជាមួយចំនួនទៀត ដែលខុសពី ទស្សនវិជ្ជា របស់ ម៉ាក្ស ដូចជា ទស្សនវិជ្ជា របស់ នីត្ស (le nietzschéisme) ជាដើម បានជះឥទ្ធិពលទៅលើ អ្នកចេះដឹងយ៉ាងខ្លាំងក្លា។ ប៉ុន្តែដើម្បីយកទស្សនវិជ្ជាទាំងពីរ ប្រភេទនេះទៅប្រើ ក្នុងគោលដៅ ប្រយុទ្ធ នយោបាយ គេបាននាំគ្នា ធ្វើការបកស្រាយខុសពីទស្សនវិជ្ជាដើម ដោយឥតកោតក្រែង។ អ្នកដែលយកទ្រឹស្ដី ម៉ាក្សនិយម ទៅបកស្រាយ ដើម្បី បុព្វហេតុនយោបាយ មានជាអាទិ៍ លេនីន, ម៉ៅ សេ ទុង, ប៉ុល ពត ។ ល។ រីឯ ទស្សនវិជ្ជា របស់ នីត្ស (Nietzsche) ក៏ត្រូវគេយកទៅបកស្រាយខុស ដូចគ្នាអ៊ីចឹងដែរ (le nazisme)។ ជាការពិតណាស់ដែលថា ទស្សនវិជ្ជា របស់ ម៉ាក្ស មានឥទ្ធិពលដ៏ខ្លាំងក្លា ហើយមានប្រជាប្រិយភាពជាង ទស្សនវិជ្ជា របស់ នីត្ស ប៉ុន្តែអ្វីដែលបានធ្វើឲ្យពិភពលោក មានការប្រែប្រួល គឺ ចំណុចពីរសំខាន់ ៖ ចំពោះម៉ាក្ស គឺ ទស្សនវិជ្ជារូបធាតុនិយម (le matérialisme) ហើយចំពោះ នីត្ស គឺ មនុស្សត្រូវឈានទៅដល់កម្រិតបញ្ញាមួយដ៏ខ្ពស់បំផុត (le surhomme) ដើម្បីដើរតួនាទីជំនួសព្រះដែលគេចាប់ផ្ដើមយល់ថាជា ជំនឿដែលគ្មានមូលដ្ឋាន។ ចំពោះ នីត្ស គេត្រូវបែងចែកឲ្យច្បាស់ រវាង ទស្សនវិជ្ជា *ឥតន័យនិយម* (le nihilisme) ដែលមនុស្សអស់សង្ឃឹមយ៉ាងខ្លាំង កាលបើដឹងថា ពិភពលោកគ្មានព្រះគ្រប់គ្រង និង ជួយយកអាសា មនុស្សលោក។ ទស្សនវិជ្ជា របស់ អ្នកឥតន័យនិយម អាចនាំទៅរកភាពអនាធិបតេយ្យ។ ប៉ុន្តែចំពោះ នីត្ស មនុស្សត្រូវវិលទៅរក តថភាពដើម (មុនគ្រិស្ដសាសនា) វិញ ពោលគឺ ជីវិតពិតប្រាកដ («l’éternel retour» និង «volonté de puissance») គឺ ការដើរឲ្យហួសពី ការបង្រួម





មនុស្សមកត្រឹមការុញ្ញភាព របស់គេ។ នីត្ស យល់ថា គឺគ្រិស្ដសាសនានេះហើយ ដែលបានធ្វើមនុស្សចុះខ្សោយបាត់ថាមពលមែនទែន របស់ខ្លួនអស់ ហើយសីលធម៌ (របស់គ្រិស្ដសាសនា) ជា សីលធម៌ អាណិតអាសូរនិយម របស់ អ្នកខ្សោយតែប៉ុណ្ណោះ។ មនុស្សត្រូវហាត់ខ្លួនរស់នៅក្នុងការពិត ហើយមិនត្រូវត្អូញត្អែរ ពីការឈឺចាប់ របស់ ខ្លួនឡើយ (stoïcisme) តែត្រូវកសាងខ្លួនដើម្បីក្លាយទៅជា មនុស្សដែលត្រូវដើរឲ្យហួសពី លក្ខណៈមនុស្ស ដែលសាសនា កំហិតឲ្យ ហើយ ឈានទៅធ្វើអ្វី ដែលជាធាតុពិត របស់ មនុស្ស (le devenir : «deviens ce que tu es», volonté de puissance ou volonté vers la puissance › *wille zur Matcht*) ។ ទស្សនៈ របស់ នីត្ស បានត្រូវគេចាត់ទុកថាជាទស្សនវិជ្ជា «ឥតន័យនិយមសកម្ម» (le nihilisme actif) ។ នីត្សមិនយល់ស្របនឹង ទស្សនវិជ្ជា សម័យទំនើបទេ ជាពិសេសទស្សនវិជ្ជា «ឥតន័យនិយមអសកម្ម» (nihilisme passif) ព្រោះលោកយល់ថា ជាការនាំទៅរកភាពចុះដុនដាប នៃ បស្ចិមលោក។ លោក មិនយល់ស្រប នឹងរាល់ទស្សនវិជ្ជា ដែលពុំព្រមទទួលយកជីវិត ហើយដែលនាំឲ្យមនុស្ស ចុះខ្សោយ។ ទស្សនវិជ្ជានេះ ដែលចាប់ផ្ដើមពីការយល់ថា ព្រះបានទទួលមរណកាលបាត់ទៅហើយ (Dieu est mort) បានជះឥទ្ធិពលទៅលើទស្សនវិទូ មួយចំនួន នៅឆ្នាំ ១៩៦០ ។ ទន្ទឹមនោះ ទស្សនវិទូ នៃ «ជីវិតគ្មានអាទិទេពគ្រប់គ្រង» ឬ «ជីវិត ជាស្នាដៃ របស់ មនុស្សខ្លួនឯង» ដូចជា សាត្រ (J.P. Sartre), កាមុស (Albert Camus), ហ្វ៊ូកូល (Michel Foucault), ហ្សីត (André Gide), អាដ្លែរ (A. Adler) យុង (Carl Jung) ហៃដឺហ្គែរ (Heidegger), ម៉ាល់រ៉ូ (André Malreaux), វ៉ាល់ឡេរី (Valéry ) ម៉ាន់ (Thomas Mann), ហ្វ្រយ (Freud ជាដើម ក៏បានជះឥទ្ធិពល ទៅលើយុវជនជំនាន់ក្រោយ យ៉ាងខ្លាំងក្លាណាស់ដែរ។ នៅឆ្នាំ ១៩៣០ ទស្សនវិជ្ជា របស់ នីត្សបានត្រូវគេយល់ច្រឡំដោយពួកណាហ្ស៊ី បានយកទ្រឹស្ដីនេះ ទៅបកស្រាយ ខុសពីគំនិតដើម។ ប៉ុន្តែ បន្ទាប់ពី អត្ថបទទាំងមូល បានត្រូវបកប្រែហើយ បោះពុម្ពផ្សាយ នៅឆ្នាំ ១៩៦០ ទើប បញ្ញវន្ត បារាំង យល់ទស្សនវិជ្ជា

*នេះ បានត្រឹមត្រូវវិញហើយ យកទៅធ្វើជាមូលដ្ឋានដើម្បីប្រឆាំងនឹងទស្សនវិជ្ជាហេហ្គិលនិយម* (hégélianisme) *ដែលកំពុងពេញនិយម តែម្តង ។*





# *លំនាំដើម*

*ចាប់តាំងពីទសវត្សរ៍ ១៩៣០ មក ប្រលោមលោកខ្មែរបានត្រូវបោះពុម្ពផ្សាយ។ គឺជាលើកដំបូងហើយដែលបញ្ញវន្តខ្មែរសម័យទំនើប បានបញ្ចេញស្នាដៃរបស់គេ ។ អ្នកទាំងនេះ សុទ្ធតែបានសិក្សានៅសាលា ដែលបារាំង បានបង្កើតនៅស្រុកខ្មែរ។ សាលាព្រះស៊ីសុវត្ថិដែលបានត្រូវបង្កើតនៅឆ្នាំ ១៨៧៣ បានក្លាយទៅជាវិទ្យាល័យស៊ីសុវត្ថិ នៅឆ្នាំ ១៩៣៣ ហើយ ជាជម្រក របស់ អ្នកប្រឆាំង នឹង រដ្ឋអំណាច។ អនាគតបញ្ញវន្តខ្មែរសំខាន់ៗច្រើន តែចេញពីវិទ្យាល័យនេះ។ សាលាទាំងនេះ បានបើកផ្លូវឲ្យអ្នកដែលបានបញ្ចប់មធ្យមសិក្សា អាចទៅ បន្តវិជ្ជាឧត្តមសិក្សា នៅទីក្រុងហាណូយ និង នៅស្រុកបារាំង។ គឺចាប់ តាំងពីសម័យនោះ មកហើយដែលអ្នកចេះដឹងខ្មែរជំនាន់ក្រោយ បានកកើតឡើង ហើយចាប់ផ្តើមធ្វើសកម្មភាព កសាង សង្គមខ្មែរសម័យទំនើបយ៉ាង ខ្លាំងក្លា។ នៅឆ្នាំ ១៩៣៦ ស៊ឺន ង៉ុក ថាន់ បង្កើត កាសែត* នគរវត្ត *ហើយ នៅឆ្នាំដដែលនោះ សិស្ស វិទ្យាល័យស៊ីសុវត្ថិ បាននាំគ្នា ធ្វើបាតុកម្ម ប្រឆាំង នឹង រដ្ឋបាលបារាំង។ នៅឆ្នាំ ១៩៤២ បាតុកម្ម ដេញបារាំង ចេញពីស្រុកបានផ្ទុះឡើង ក្រោមការដឹកនាំ របស់ ស៊ឺន ង៉ុក ថាញ់ ។ អ្នកដែលបានចូលរួមក្នុងបាតុកម្មនោះ មានជាអាទិ៍ ៖ អាចារ្យហែម ចៀវ លោក ប៉ាច ឈឿន លោក ប៊ុន ចាន់ ម៉ុល ជាដើម។ នៅស្រុកបារាំង និស្សិតខ្មែរធ្វើសកម្មភាពនយោបាយ យ៉ាងមមាញឹក។ គេអាចនិយាយបានថានៅពេលនោះ សង្គមខ្មែរចាប់ផ្តើមប្តូរបេចនាសម្ព័ន្ធសង្គម និងវប្បធម៌ ជាពិសេសវប្បធម៌ និង ស្ថាប័នរដ្ឋខ្មែរ។ នៅក្នុងន័យនេះ គេអាចប្រៀបធៀបការវិត្តន៍ ដ៏ខ្លាំងនេះ ទៅសភាពការណ៍ នៅប្រទេសបារាំង នាសតវត្សរ៍ ទី ១៨ បានខ្លះ ដែរ ប៉ុន្តែ តាមរូបភាពមួយដោយឡែក នៃ បរិបទនៃសង្គមមួយដែលវិវត្តតាមសម្រួល។ បដិវត្តន៍ នៃ ការប្តូររចនាសម្ព័ន្ធវប្បធម៌ និង ការផ្លាស់ប្តូរស្ថាប័នដឹកនាំ បានប្រព្រឹត្តទៅ ដោយគ្មានការប្រឆាំងអ្វី ជាដុំកំភួន ក្រៅពីទំនាស់*

និង ការប្រឈមមុខដោយមិនបេញមុខ រវាង អ្នកទំនៀមទម្លាប់និយម និង អ្នកសម័យទំនើប។ រីឯអ្នកដឹកនាំតាមបែបបទប្រពៃណី ក៏មិនទាត់ចោលការវិវត្តន៍នេះទាំងស្រុងដែរ នៅក្នុងករណីដែលគ្មានការជណ្តើមអំណាច។ ទោះជាយ៉ាងនេះក្តី ក៏ នៅទីបំផុត ការប៉ះទង្គិច ក៏ ជាការគេចពុំផុតដែរ ចាប់តាំងពីឆ្នាំ ១៩៥២ មក ជាពិសេស នៅឆ្នាំ ១៩៦៧។

នៅក្នុងការវិវត្តន៍ នៃ វប្បធម៌ ព្រះសង្ឃនៅតាមវត្តអារ៉ាម មានតួនាទីដ៏ សំខាន់ មិនត្រឹមតែក្នុងការការពារវប្បធម៌ជាតិ និង ការរីកចម្រើន នៃអក្សរសាស្ត្រខ្មែរប៉ុណ្ណោះទេ គឺថែមទាំងចូលរួមចំណែក ក្នុងការប្រឆាំងនឹងបារាំង ព្រមទាំងអំពើអយុត្តិធម៌នៅក្នុងសង្គមផងទៀត។ ប្រការដែលគួរឲ្យកត់សំគាល់ គឺគេពុំឃើញមានអារិកាពអ្វី រវាង ព្រះសង្ឃ និង បញ្ញវន្តសម័យទំនើបឡើយ លើកលែងចេញតែ ករណីពិសេស ប៉ុណ្ណោះ ដែលទាក់ទង នឹង ទស្សនាទាន ភាសាខ្មែរ។

ការសិក្សាអំពីសង្គមខ្មែរ តាមវិធីសាស្ត្រ ជាតិពន្ធវិទ្យា (ethnologie) ពុំអាចមានលក្ខណៈគ្រប់ជ្រុងជ្រោយ និង ប្រាកដនិយមទេ ។ បើនឹងប្រើវិធីសាស្ត្រ រចនាសម្ព័ន្ធវិធី តាមបែប ក្លូត ឡេវីស្ត្រូស ក៏ឃើញថា មានលក្ខណៈ នឹងថ្កល់ (statique) ពេកដែរ។ ចាប់តាំងពីឆ្នាំ ១៩០៥ មក ជាពិសេស ចាប់តាំងពីឆ្នាំ ១៩៣០ មក សង្គមខ្មែរចាប់ផ្តើម មាន ការប្រែប្រួល ជាសន្សើមៗ ។ ដូចនេះ គេគួរ ធ្វើការសិក្សា តាមមុម ការវិវត្តន៍ វិញ (dynamique)។ នៅក្នុងករណី នៃ ការសិក្សាសង្គមខ្មែរ ចាប់តាំងពីឆ្នាំ ១៩៣០ នោះ មក ខ្ញុំយល់ថា វិធីសាស្ត្រ របស់ សង្គមវិទូ និង អ្នកនិពន្ធ បារាំង ហ្សង់ ឌុយវីញ៉ូ (Jean Duvignaud, ១៩២១-២០០៧) គឺ វិធីសាស្ត្រ «ជំនោរអារម្មណ៍សង្គមសាស្ត្រ» («imagination sociologique») មានកល្ខណៈសមស្របជាង ។ តាមការពិត គឺជា សិល្បារម្មណ៍វិធី ដែល មីស្សឺឡេ (Michelet) បាល់ហ្សាក់ (Balzac) ហ្គុយស្តាវ ផ្លូប៊ែរ (Gustave Flaubert) ម៉ារសែល ព្រូស្ត (Marcel Proust) បានប្រើដោយជោគ ជ័យរួចមកហើយៗ ដែល ឌុយវញ្ញូ យកមកប្រើជាវិធីសាស្ត្រសង្គមវិទ្យាតែម្តង។ ម៉្យាង ទៀត សង្គមវិទូអាមេរិក សាក រ៉ាយមៀល (Charles Wright Mills, ១៩១៦-១៩៦២) បានយកកុងសិប នេះមកធ្វើ វិសាលភាព





ថែមទៀត [២] (កុងសិប ស្តីពី ការកកើត និង ការត្រួតត្រា នៃ វរជនដែលកាន់អំណាចនៅក្នុងសង្គមអាមេរិក, អំណាច នៃ ស្ថាប័ន) ។

## សង្គមខ្មែរ : ការផ្លាស់ប្តូរ រចនាសម្ព័ន្ធវប្បធម៌ និង ស្ថាប័ននយោបាយ នៅក្នុងអភិក្រមទំនើបកម្ម

នៅចុងរាជ្យ ហ្វូងស៊ីសុវត្ថិ លោក សឺន ឌៀប (១៨៥០-១៩២០?) ដែលបានទៅចូលរួម ក្នុងពិពណ៌ នៅទីក្រុងប៉ារីស៍ ឆ្នាំ ១៩០០ បាននិពន្ធ ស្នាដៃមួយ មានចំណងជើងថា ល្បើកពីស្រុកព្រៃន៍គរ ទៅគ្រុងបារាំងស្រេ នៅទីត្យាំតុះ [៣] និយាយរៀបរាប់ពីសម្ភស្ស នៃរដ្ឋធានីបារាំង ។ ប្រលោមលោកផ្នែកការស៊ើបអង្កេតខ្មែរ លើកដំបូងបង្អស់ ក៏ ចេញជារូបរាង នៅឆ្នាំ ៤០ នោះដែរ ។ នៅឆ្នាំ ១៩៤១ លោក ហែល ស៊ុំផា ដែលប្រកបមុខរបរ ជាចៅក្រម បានចេញស្នាដៃមួយ មានចំណងជើងថា បោរបិទមុខ ។ មួយ ឆ្នាំក្រោយមក ប្រលោមលោកខ្មែរចាប់ផ្តើមផ្តោតអារម្មណ៍ ទៅលើសង្គមខ្មែរ តាមរយៈ រឿងស្នេហា តែតាមការពិត គឺជា ការសិក្សាសង្គមសាស្ត្រ មួយបែប ដ៏សំខាន់ ។ គឺនៅ ក្នុងន័យនេះហើយ ដែលនៅឆ្នាំ ១៩៤២ លោក រីម គីន (១៩១១-១៩៥៩) អតីតសិស្សសាលា បារាំង-ខ្មែរ ឌូដា ឌឺឡាគ្រេ (École Doudart de Lagrée) និង អនុវិទ្យាល័យ ស៊ីសុវត្ថិ បានសរសេរ ប្រលោមលោកមួយ មានចំណងជើងថា សូផាត ។

---

[២] Concepts de Charles Wright Mills : Formation et domination de l’élite du pouvoir dans la société américaine, le pouvoir institutionnel, …

[៣] សរសេរ ជាអក្ខរាវិរុទ្ធ បច្ចុប្បន្ន : ល្បើកពីស្រុកព្រៃនគរ ទៅទីក្រុងបារាំងសេស នៅទីតាំងតុ ។ សូមអាន មាលីបទអក្សរសិល្ប៍ខ្មែរសតវត្ស ទី ២០ របស់លោក ឃីង ហុកឌី ទំព័រ ៥៩។

ទន្ទឹមនោះ លោកបាននិពន្ធរឿង ជាច្រើនទៀត និង បកប្រែរឿងបារាំងមួយចំនួន [៤] ដូចជា Le Cid របស់ កវី បារាំងក័រណី, Sans famille របស់ ហេចទ័រ ម៉ាឡូ ជាដើម។ អតីតសិស្ស អនុវិទ្យាល័យ ស៊ីសុវត្ថិ ម្នាក់ទៀត ឈ្មោះ នូ ហាច (១៩១៦-១៩៧៥) បានបេញផ្សាយ ប្រលោមលោកមួយទៀត ដ៏ល្បី គឺរឿង ផ្កាស្រពោន នៅឆ្នាំ ១៩៤៩។ នៅទសវត្សរ៍ ១៩៤០ នោះដែរ លោក ញ៉ុក ថែម (១៩០៣-១៩៧៤) អ្នកប្រាជ្ញអក្សរសាស្ត្រខ្មែរម្នាក់ ដែលបានសិក្សាពុទ្ធសាសនា យ៉ាងជ្រៅជ្រះ នៅទីក្រុងបាងកក បានបេញផ្សាយប្រលោមលោកពីរ មួយមាន ចំណងជើងថា បិសាចស្នេហា (១៩៤២) ហើយមួយទៀតមានចំណង ជើងថា កុលាបប៉ៃលិន (១៩៤៣) ។ ប្រលោមលោក ទាំងពីរនេះ ក្រោមរូបភាពនៃ រឿងស្នេហាជា ប្រលោមលោកសង្គមសាស្ត្រ ដ៏សំខាន់ ដែលឆ្លុះបញ្ចាំងសង្គមខ្មែរនៅក្នុងរាជ្យហ្លួង មុនីវង្ស និងដើមរជ្ជកាល ហ្លួង នរោត្តម សីហនុ។ នៅសម័យនោះ សង្គមខ្មែរកំពុងបោះជំហានយ៉ាងសកម្ម ចូលទៅក្នុងអភិក្រម ទំនើបកម្មតាមរយៈវប្បធម៌បារាំង ជាពិសេស ការនិយម កវីរ៉ូម៉ង់ទិក (ប៉ូល និង វៀរហ្សីនី របស់ ប៊ែរណាដាំង ដឺ សាំងពៀរ) កវីធម្មជាតិនិយម (អក្ខរា នៃម៉ាស៊ីនកិនស្រូវ របស់ ខ្ញុំ របស់ អាល់ហ្វុងស៍ ដូដេ) ព្រមទាំង កវី វិចារណនិយម (ឡឺស៊ីត របស់ ពៀរ ក័រណី) និង កវី ដែលរិះគន់ របៀបរស់នៅ នៃ សង្គមព្រេណិតនិយម នៅស្រុកបារាំងនាសតវត្សរ៍ទី ១៧ (ស្នាដៃមួយចំនួន របស់ ម៉ូលៀរ) ។ ចិត្តគំនិតយុវជនខ្មែរ នៅពេលនោះចាប់ផ្ដើមមានការប្រែប្រួល។ តាមទំនៀមទម្លាប់ខ្មែរតាំងពីដើមមក នារីត្រូវកសាងជីវិតតាមការកំហិត របស់ឪពុកម្ដាយ ប៉ុន្តែ ចាប់តាំងពីសម័យឆ្នាំ ១៩៣០-៤០ នោះមក នារីទាមទារ សិទ្ធិរើសគូស្រករដោយខ្លួនឯងបណ្ដាលឲ្យមានទំនាស់ក្នុងគ្រួសារ។ សេចក្ដីប៉ងប្រាថ្នា របស់ឪពុកម្ដាយនៅពេលនោះ គឺចង់ឲ្យកូនស្រី រៀបការ ជាមួយអ្នកមានមុខ

[៤] សូមអាន សៀវភៅ មាលីបទអក្សរសិល្ប៍ខ្មែរ សតវត្សទី ២០ របស់ បណ្ឌិត ឃីង ហុក ឌី Éditions de la plus haute tour, ២០០២, បោះពុម្ព ដោយបណ្ណាគារ «អង្គរ», ភ្នំពេញ។



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

មានមាត់ នៅក្នុងសង្គម ពោលគឺ អ្នកមានអំណាច បន្តិចបន្តួច ដែលស្ដេចបានប្រទានឲ្យ បើពុំនោះសោត គឺ សេដ្ឋីដែលជា អ្នកមានប្រាក់កាស សន្ធឹកសន្ធាប់ ដោយមិនដឹងបានមក ពីណា ។ ប៉ុន្តែ អ្នកដែលបានរៀនសូត្រ ប្រឆាំង នឹង ទស្សនៈនេះ យ៉ាងពេញទំហឹង។ អ្នកនិពន្ធខ្មែរនៅសម័យនោះ ដូច ជា លោក រីម គីន ឬ លោក នូ ហាច ឬ ក៏លោក ញ៉ុក ថែមជាដើម ទោះជានៅមាន ការញញើតញញើម នៅឡើយ ក្នុងការរិះគន់ទស្សនៈនេះ ក៏ជាអ្នកដែលមិនយល់ស្របនឹង ទស្សនៈនេះដែរ ។ នៅក្នុង រឿង សូផាត លោក រីម គីន មិនយល់ថា ពួកគហបតី សុទ្ធតែ មានចិត្តឫស្យា ទាំងអស់ នោះទេ រីឯអ្នកដែលចេញមក ពី ប្រកពគ្រីក្រ ក៏មិនមែន នៅក្រីក្រគោកយ៉ាករហូតនោះដែរ បើគេខំប្រឹងប្រែងរៀនសូត្រ និងមានការព្យាយាមក្នុងការងារ។ នៅក្នុងរឿង កុលាបប៉ៃលិន លោក ញ៉ុក ថែម ផ្សះផ្សា យុវជន នឹង សេដ្ឋី តាមរយៈ សេចក្ដីស្នេហា រវាង យុជនក្រីក្រ ឈ្មោះចៅចិត្រ និង នាង យុននារី កូនស្រី របស់ សេដ្ឋី រតនសម្បត្តិ ហើយជឿទៅលើការចេះដឹង និង ការព្យាយាមក្នុងការងារ ជាងការប្រើអំណាច របស់ កូនមន្ត្រី។ នៅក្នុងរឿង បិសាចស្នេហា លោកវិភាគយ៉ាងប្រាកដនិយម អំពី ឧត្តមភាព នៃ សេចក្ដីស្នេហា ទៅលើមនោសញ្ចេតនាបងប្អូន ។ ប្រលោមលោកក្រោយមកទៀត ចាប់ពីឆ្នាំ ១៩៥០មក ធ្វើការរិះគន់ទស្សនៈ «នំឲ្យមិនធំជាងនាឡិ» នេះយ៉ាងខ្លាំង ជាពិសេសអំពើអយុត្តិធម៌ និង ទស្សនៈខុសឆ្គង របស់រដ្ឋបាល និង អាកប្បកិរិយា «សក្តិភូមិ» របស់នាម៉ឺន។ នៅឆ្នាំ ១៩៥២ អ្នកស្រី ស៊ុយ ហៀង (កើតនៅឆ្នាំ ១៩២៩) បានបេញផ្សាយស្នាដៃមួយមានចំណងជើងថា វាសនា នៃ នាងណាគ្រី ។ គឺជា ប្រលោមលោកមួយនិយាយពី សោកនាដកម្ម នៃគ្រួសារ របស់ នាងនៅពេលដែល «កងទ័ពសម្ព័ន្ធ មិត្ត» [អាមេរិក-បារាំង-អង់គ្លេស] ទម្លាក់គ្រាប់បែក កំទេចមូលដ្ឋាន យោធាជប៉ុន នៅឆ្នាំ ១៩៤៥ ព្រមទាំងការលើកឡើង នូវ ទស្សនៈថ្មីមួយ សម្រាប់សង្គមខ្មែរ ដើម្បីកសាងប្រទេសឡើងវិញ។ អ្នកស្រីស៊ុយ ហៀង អំពាវនាវ ឲ្យយុវជនខ្មែរ នាំគ្នាប្រកបមុខរបរជាពាណិជ្ជករ (ដែលមានន័យថា កុំឲ្យនាំគ្នាធ្វើតែនាម៉ឺន)។ នៅឆ្នាំ ១៩៤៧ លោក នូ កន ដែលបាននិពន្ធរឿងទាវឯក នៅឆ្នាំ ១៩៤២ បានបេញផ្សាយ ប្រលោមលោកមួយ មាន

ចំណងជើងថា តុងឈិន ដែលជារឿងប្រវត្តិសាស្ត្រ ទាក់ទង នឹង រឿងស្នេហា (ការត្រូវជ្រើសរើស របស់ស្តេច រវាង ស្នេហា និង ប្រទេសជាតិ) ។ លោក កេង វ៉ាន់សាក់ ដែលកាលពីនៅជាសិស្សវិទ្យាល័យស៊ីសុវត្ថិ បានតែង រឿងល្ខោន ពីរ -សាច់ពុំបានស៊ី យកភ្លឺងព្យួរក (១៩៤៤) និង អន្ទិតគោលោត (១៩៤៥) - បាននិពន្ធបទកំណាព្យ មួយចំនួន នៅពេលដែលលោកត្រឡប់មកពីសិក្សានៅប្រទេសបារាំង គឺ ចិត្តក្រមុំ (១៩៥៤) គុកកាមកិលេស (១៩៥៦) ។ លោក កេង វ៉ាន់សាក់ ជាព្រឹទ្ធបុរស មហាវិទ្យាល័យអក្សរសាស្ត្រ និងមនុស្សសាស្ត្រ និង ជានាយក វិជ្ជាស្ថានគរុកោសល្យ នាឆ្នាំ ១៩៥៨-១៩៦០ ។ នៅឆ្នាំ ១៩៦៤ លោកបានសរសេរ សិក្សាកថាមួយ ដ៏សំខាន់ មានចំណងជើងថា មូលភាព នៃ ការបង្កើតពាក្យថ្មី ដើម្បីផ្តល់វិសាលភាពទៅឲ្យភាសាខ្មែរ ដែលខ្វះកច្ចេកសព្ទសម្រាប់នាំមកនូវ បញ្ញត្តិ (concepts) ដែលជា ភាសាសកល។ ចាប់តាំងពីឆ្នាំ ១៩៥០ រហូតដល់ ឆ្នាំ ១៩៧៥ ប្រលោមលោកខ្មែរ បានត្រូវគេនិយមច្រើននៅក្នុងចំណោម សាធារណជន ដែលស្រឡាញ់អក្សរសាស្ត្រ។ អ្នកនិពន្ធ នាឆ្នាំ ៥០ បានជ្រើសរើសយកមូលបទ ប្លែកៗទៀត [៥] ដូចជា ប្រវត្តិសាស្ត្រ ការស៊ើបអង្កេតចារកម្ម និង សង្គមសាស្ត្រ ព្រមទាំងរឿងវិនាដកម្ម ជាច្រើនប្រភេទ (ស្នេហា និង ការប្រកាន់អ្នកមានអ្នកក្រ, ចិត្តរបស់ស្ត្រី ដែលស្ថិតនៅ រវាង ស្នេហ៍ពិត និង ការកំហិតរបស់ ឪពុកម្តាយ រវាងការស្មោះត្រង់ និងការកសាងជីវិតមួយថ្កុំថ្កើង, ជីវិត រកាំរកូសក្នុងគ្រួសារ ។ល។)។ នៅទសវត្ស ១៩៥០ នោះ លោក ប៊ីវ ឆៃ លាង បាននិពន្ធរឿងប្រវត្តិសាស្ត្រជាច្រើន ដែលមានលក្ខណៈ ប្រហាក់ប្រហែល នឹង រឿងផ្សងព្រេងរបស់ អ្នកនិពន្ធបារាំង អាឡេចសង់ដ្រ៍ ឌុយម៉ាស៍។ នៅទសវត្សរ៍ ១៩៦០ អក្សរ

[៥] អ្នកនិពន្ធប្រជាប្រិយ មានជាច្រើន ឥតគណនា ដូចជា ៖ គីម សែត, ជូ ថានី, ចៅគ្រីស្នា (នរោត្តម ចន្ទរង្សី ), ភីលី ថុន, គង្គ ប៊ុនឈឿន, រីវង្ស គោវិទ ។ល។ សុំអានសៀវភៅ មាលីបទអក្សរសិល្ប៍ខ្មែរសតវត្សទី ២០ របស់ បណ្ឌិត ឃីង ហុក ឌី, Éditiond de la plus haute tout, ២០០២, បោះពុម្ព ដោយបណ្ណាគារ «អង្គរ», ភ្នំពេញ។





សាស្ត្រខ្មែរ មានការរីកចម្រើនដ៏ខ្លាំងក្លា ។ ព្រឹត្តិការណ៍ ដ៏ សំខាន់មួយ គឺ ការបោះពុម្ពផ្សាយគ្រាទី ៤ (ឆ្នាំ ១៩៦៧) នៃ វចនានុក្រមខ្មែរ ដោយវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិត្យ។ វចនានុក្រមនេះ បានចាប់កំណើតឡើង នៅឆ្នាំ ១៩០៥ តាមរយៈ គណកម្មការមួយក្រុមធំ ក្រោមការដឹកនាំ របស់ សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ ជួន ណាត។

## និស្សិតខ្មែរដែលបានចេញទៅធ្វើការសិក្សា នៅប្រទេសបារាំងមុនដំបូងបង្អស់

នៅចន្លោះឆ្នាំ ១៩០៥-១៩០៧ សាលា បារាំង-ខ្មែរ ចាប់ផ្តើម កកើតឡើង ជាបន្តបន្ទាប់ ហើយ មាននៅសឹងគ្រប់មណ្ឌល [៦]។ នៅឆ្នាំ ១៩០៧ មានចំនួនទាំងអស់ ១៨ ។ នៅភ្នំពេញ មានសាលាបែបនេះ ចំនួន ៣ (សាលា នរោត្តម, ឌូដា ឌឺឡាគ្រេ, ហ្វ្រង់ស៊ីហ្គារញេ ) ។ នៅឆ្នាំ ១៩១១ មាន សាលាឯកជនពីរ សម្រាប់នារី គឺ សាលា សុត្តារតនិង ម៉ាលិកា ។ ចំពោះ សាលា ស៊ីសុវត្ថិ អាឡាំង ហ្វូរ៉េស្ត សរសេរថា ពីឆ្នាំ ១៩១៣ មកឆ្នាំ ១៩២០ សិស្ស មានចំនួន ប្រហែលពី ១០១ នាក់ (ឆ្នាំ១៩១៣) មក ១២៩ នាក់ (ឆ្នាំ១៩២០) [7]។ សាលា បារាំង-ខ្មែរដែលមានសិស្សច្រើនជាងគេ គឺ សាលា ឌូដា ដឺ

[៦] យោងទៅតាមសៀវភៅ *Le Cambodge et la colonisation française* របស់ អាឡាំង ហ្វូរេស្ត, L'Harmattan, Paris, 1980, . p. 152.

[៧] ពី ឆ្នាំ ១៩០៧ មក ឆ្នាំ ១៩២០ នៅតាមខេត្រ ៖ កំពត (ប្រុស : ពី ២០ នាក់ មក ១៧០ នាក់; នារី : ពីឆ្នាំ ១៩១៨ មក ១៩២០ មាន ពី ២៥ នាក់ មក ៣០ នាក់), កំពង់ស្ពឺ (ប្រុស : ពីឆ្នាំ ១១៩១០ មក ឆ្នាំ ១៩២០ : ពី ១០ នាក់ មក ១២០ នាក់ ) កំពង់ចាម (ប្រុស : ពី ៨៥ មក ២០៥ នាក់; នារី : ពី ៧ នាក់ មក ១៦ នាក់) ព្រៃវែង (ប្រុស ពី ២៦ នាក់ មក ៧៤ នាក់ ) បាត់ដំបង ( ប្រុស : ពី ១៤០នាក់ នៅឆ្នាំ ១៩០៧

ឡាគ្រេ ( សិស្សមានចំនួន ៤៥០ នាក់ នៅឆ្នាំ ១៩១១ )។ បើបូកសរុបចំនួនសិស្ស ទាំងអស់ នៅឆ្នាំ ១៩២១ គឺ ស្រី មានចំនួន ៤៩៥ នាក់ ប្រុសមាន ៥៣៥១ នាក់។ នៅឆ្នាំ ១៩១២ សិស្សដែលត្រូវបញ្ជូនឲ្យទៅធ្វើការសិក្សា នៅប្រទេសបារាំង មានចំនួន ៥ នាក់ នៅក្នុងនោះ កូនមន្ត្រី មាន ២ នាក់។ អ្នកដែលត្រូវគេបញ្ជូនមក ស្រុកបារាំង នៅពេលក្រោយមកទៀត ច្រើនតែជាកូនអភិជន ដូចជា ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីវង្ស (ព្រះមហាក្សត្រខ្មែរ ពី ឆ្នាំ ១៩២៧ មក ឆ្នាំ ១៩៤១), ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ វឌ្ឍឆាយាវង្ស (នាយករដ្ឋមន្ត្រី ឆ្នាំ ១៩៤៧ ) ព្រះអង្គម្ចាស់ នរិនដេត ព្រះអង្គម្ចាស់ រិត្ថារាស៊ី ជាដើម។ នៅឆ្នាំ ១៩៣១ អ្នកអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្សទៅធ្វើការសិក្សានៅស្រុកបារាំង (រហូតដល់ឆ្នាំ ១៩៤៦)។ នៅស្រុកបារាំង អ្នកអង្គម្ចាស់យុត្តិវង្ស រៀនបាន សញ្ញាបត្របណ្ឌិតរដ្ឋខាងវិទ្យាសាស្ត្រ ហើយចូលជាសមាជិកគណបក្សសង្គមនិយមបារាំង។ ពេលត្រឡប់មកស្រុកខ្មែរនៅឆ្នាំ ១៩៤៦ ស៊ីសុវត្ថិ យុត្តិវង្ស ជាអ្នកដឹកនាំគណបក្សប្រជាធិបតេយ្យ។ អ្នកដែលបាន មកសិក្សានៅប្រទេសបារាំង ពីររូបទៀត នៅជំនាន់នោះ គឺលោក ឈាន វ៉ែម លោក ថុន អ៊ុក។ នៅឆ្នាំដដែលនោះ ជួន មុម្ម ចេញដំណើរទៅសិក្សា នៅប្រទេសបារាំង រហូតបានសញ្ញាបត្របណ្ឌិតគណិតសាស្ត្រ សាលាពហុបច្ចេកទេស (École Polytechnique) ។ នៅ ឆ្នាំ ១៩៥១ លោក ប្រហែលជាបានចូលជាសមាជិក គណបក្សកុម្មុយនិស្តបារាំង នេះបើតាមការប៉ាន់ស្មានរបស់ ប្រវត្តិវិទូ ដេវីដ ចិនដ្លែរ (David P. Chandler, *Pol Pot Frère Numéro Un*, Plon, 1992, p. 52) ។ លោក កេង វ៉ាន់សាក់ ក៏មករៀននៅស្រុកបារាំងនៅឆ្នាំ ១៩៤៦ នោះដែរ ។ លោក មានគំនិតជឿនលឿននិយម (progressiste) ប៉ុន្តែ មិនចូលគណបក្សកុម្មុយនិស្តទេ។ គឺនៅឆ្នាំ ១៩៤៦ នោះដែរដែលលោក សម សារី មកសិក្សានៅប្រទេសបារាំង។ លោកបានទទួលសញ្ញា

មក ១៥០ នាក់ នៅឆ្នាំ ១៩១៦ ; ចំនួននារី ចុះថយពី ២៧ នាក់ នៅឆ្នាំ ១៩១៣ មក ១៩ នាក់ នៅឆ្នាំ ១៩១៥) ។





បត្រជាច្រើន មានជាអាទិ៍សញ្ញាបត្រខាងច្បាប់ និង វិទ្យាសាស្ត្រនយោបាយ។ នៅពេលដែលទ្រង់យុត្តិវង្សត្រឡប់មកស្រុកខ្មែរ បញ្ញវន្ត ២ រូប គឺ លោក ឈាន វ៉ែម ថុន អ៊ុក ក៏ត្រឡប់មកវិញដែរ ដើម្បីពង្រឹងគណបក្សប្រជាធិបតេយ្យ។ នៅខែ សីហាឆ្នាំ ១៩៤៩ សាឡុត ស រ ដោយ មានការឧបត្ថម្ភ ពីគណបក្ស ប្រជាធិបតេយ្យ [៨] បានធ្វើដំណើរតាមកប៉ាល់ ឡា ហ្សាម៉ាអ៊ីក (La Jamaïque) មករៀននៅស្រុកបារាំង [៩]។ សាឡុត ស រ បានជួប យុវជនមួយក្រុម នៅលើកប៉ាល់ *La Jamaïque* នោះ គឺ ចៅ សេង, ម៉ី ម៉ាន់, ម៉ី ផាត, អ៊ុច វ៉ែន។ លោក ឌុក រ៉ាស៊ី ដែលមករៀននៅស្រុកបារាំងនៅដើមឆ្នាំ ១៩៥០ បានត្រឡប់មក ស្រុកខ្មែរវិញ នៅឆ្នាំ ១៩៥៧ បន្ទាប់ពីបាន ទទួលសញ្ញាបត្របណ្ឌិតរដ្ឋ ខាងច្បាប់នៅឆ្នាំ ១៩៥៧។ នៅឆ្នាំ ១៩៥០នោះ លោកបានបង្កើតសមាគម «មិត្តខ្មែរនៅប្រទេសបារាំង» (L’Amicale des Cambodgiens en France) ជាមួយលោក ម៉ៅ សាយ លោក សម សារី [១០] លោក ព្រំ ថុស, លោក ឡុង ប៉ែត, លី ចិនលី ។ គឺជា សមាគម ដែលជាគូប្រជែង របស់ សមាគម «សម្ព័ន្ធនិស្សិតខ្មែរ» U. E. K . ដែលត្រូវបង្កើតនៅឆ្នាំ ១៩៥៦ បន្ទាប់ពី «សមាគមនិស្សិតខ្មែរ» A.E.K. បាន

[៨] គណបក្ស ប្រជាធិបតេយ្យ នៅពេលនោះ ត្រូវបារាំងគាបសង្កត់យ៉ាងខ្លាំងជាពិសេសលោក ឃីន ឆែ ដែលជាមិត្តរួមថ្នាក់ លោក ហែម ចំរើន។ សមាជិកគណបក្ស ប្រជាធិបតេយ្យ ខ្លះទៀត មានជាអាទិ៍ លោក សឺន សាន (ត្រឡប់ពីស្រុក បារាំងនៅឆ្នាំ ១៩៣៥ បន្ទាប់ពី បានសញ្ញាបត្រ វិជ្ជាជាន់ខ្ពស់ ខាង ពាណិជ្ជកម្ម, HEC ) លោក សុន វ៉ុនសៃ (ទៅសិក្សាវិជ្ជា វិស្វកម្ម École centrale នៅឆ្នាំ ១៩៣០ ត្រឡប់មកស្រុកខ្មែរវិញ នៅឆ្នាំ ១៩៣៩ )

[៩] *Pol Pot Frère Numéro Un*, David P. Chandler, Plon, Paris, 1992, p. 50

[១០] លោក សម សារី ទៅរៀននៅស្រុក បារាំង នៅឆ្នាំ ១៩៤៦ ហើយត្រឡប់មកមាតុប្រទេសវិញ នៅឆ្នាំ ១៩៥០។

ត្រូវបារាំងបិទចោល នៅឆ្នាំ ១៩៥២ តាមសេចក្តីស្នើសុំរបស់ ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ [11] (សមាគមនេះបានត្រូវបង្កើត នៅ ឆ្នាំ១៩៤៦ ដែលកាលនោះ មាន លោក អៀ ស៊ីចូវ ជាប្រធាន និង លោក យ៉ែម សារ៉ុង ជាអគ្គលេខាធិការ)។ «សមាគម និស្សិតខ្មែរ» កាលដើមឡើយ ជាសមាគម ដែលមានអ្នកជាតិនិយម (អៀ ស៊ីចូវ) និងអ្នកប្រជាធិបតេយ្យ (យ៉ែម សារ៉ុង) ជាអ្នកដឹកនាំ ប៉ុន្តែ ចាប់តាំងពីពេលដែលលោក អៀ ស៊ីចូវ ត្រឡប់ទៅស្រុកខ្មែរបាត់ទៅ បានក្លាយទៅជា សមាគមម៉ាក្សនិយម ដោយមាន លោក ហ៊ូ យន់ ជាប្រធាន។ សមាគម «សម្ព័ន្ធនិស្សិតខ្មែរ» ដែលបង្កើតនៅឆ្នាំ ១៩៥៦ ជាសមាគមដែលមាននិន្នាការកុម្មុយនិស្ត។ មុនព្រឹត្តិការណ៍នេះ គឺនៅឆ្នាំ ១៩៥០ និស្សិតខ្មែរមួយក្រុម ដែលមាននិន្នាការ ម៉ាក្សនិយម និង កុម្មុយនិស្ត តែម្តង ក៏អាចថាបាន បានបង្កើតក្លឹបម៉ាក្សនិយមមួយដែលមាន ហ៊ូ យន់, ជួន មុម្ម, កេង វ៉ាន់សាក់, ប៉ុល ពត ជាដើមជាសមាជិក។ នៅទសវត្សរ៍ ១៩៥០ យុវជនខ្មែរ មួយចំនួនដែលបានបញ្ចប់ ការសិក្សាមធ្យមសិក្សានៅស្រុកខ្មែរ ក៏មកសិក្សានៅប្រទេសបារាំងដែរ។ អ្នកដែលល្បី ជាងគេ មានជាអាទិ៍ ខៀវ សំផន ហ៊ូ យន់ ដែលជា អ្នកបង្កើតក្លឹប ម៉ាក្សនិយម នៅ ប្រទេសបារាំង។ នៅឆ្នាំ ១៩៥១ សឺន ង៉ុកថាញ់បានត្រូវបារាំងដោះលែងឲ្យត្រឡប់មក មាតុភូមិវិញ ប៉ុន្តែ រត់ទៅ តស៊ូក្នុងព្រៃ នៅឆ្នាំ ១៩៥២ ជាមួយលោក អៀ ស៊ីចូវ លោក ហង្ស ធនហាក់។ នៅឆ្នាំ ១៩៥០-១៩៦០ យុវជនខ្មែរជាច្រើន បានទៅបំពេញវិជ្ជានៅស្រុកបារាំង។ ដើម្បីចៀសវាងកុំឲ្យនិស្សិតខ្មែរ ទៅស្នាក់អាស្រ័យនៅ «ផ្ទះសំណាក់ សម្រាប់និស្សិតមកពីឥណ្ឌូចិន» ដែលកាលនោះជា សំបុកនិស្សិតកុម្មុយនិស្ត (Maison d’Indochine) រដ្ឋខ្មែរបានសាងសង់ផ្ទះ សំណាក់មួយសម្រាប់និស្សិតខ្មែរ នៅ បុរីសកល វិទ្យាល័យទីក្រុងប៉ារីស៍ (Pavillon du Cambodge) ។

---

១១ ទាក់ទង នឹងបញ្ហានិស្សិតខ្មែរនៅស្រុកបារាំង សូមអានសៀវភៅ របស់ លោកស្រី ម៉ារី អាឡេចសង់ឌ្រីន ម៉ារតាំង (*Le Mal cambodgien*, Marie Alexandrine Martin, Hachette, Paris, 1989) ។





«ផ្ទះខ្មែរ» បានត្រូវសម្ពោធនៅថ្ងៃ ២០ សីហាឆ្នាំ ១៩៥៧ ក្រោមអធិបតី សម្តេច នរោត្តម សីហនុ ។ នៅឆ្នាំ ១៩៦០ «សមាគមមិត្តខ្មែរនៅប្រទេសបារាំង» (ម៉ៅ សាយ, ឌុក រ៉ាស៊ី ) បាន រំលាយចូល ជាមួយ «សមាគមខ្មែរ» (A.K.) ដើម្បីបង្កើតសមាគមមួយទៀតមាន ឈ្មោះថា C.K.O.M. (Communauté des Cambodgiens d’Outre- mer, សហគមន៍ខ្មែរ នាយសមុទ្រ) ។ «សមាគមខ្មែរ» បានត្រូវបង្កើតឡើង នៅថ្ងៃ ២៧ កុម្ភៈឆ្នាំ ១៩៥៥ ។ នៅពេលនោះ សមាគម អា កា (A.K.) មាន លោក ចៅ សេង អួ ជា ប្រធាន ។ រី ឯ សមាជិក ផ្សេងៗទៀត មាន ជាអាទិ៍ ៖ ឌី បាឡែន, រ៉ូហ្សេ កុសល, សាម៉ែរ ផលគុន, ស្រី ប៉ុង។ សមាគមនេះ ដែលមានអាយុ ៥ ឆ្នាំប៉ុណ្ណោះ មាន ការគាំទ្រពីលោក ញឹក ជូឡុង ដែលជាសេនាឯក របស់ សម្តេច សីហនុ។ រីឯសមាគមសេកុម (C.K.O.M.) ដែលមានអាយុ ៦ ឆ្នាំ មាន សមាជិកសំខាន់ៗ ដូចតទៅ ៖ ជា ថៃ សេង (ប្រធាន), ឡុង ប៉ែត, អ៊ុយ ផាត់ណា, ភូ ស៊ីអ៊ុយ, បូរ៉ាមី ជូឡុង, នុត ណារ៉ាង, ចំរើន សំអឿន ។ នៅឆ្នាំ ១៩៦៥ បន្ទាប់ពី សម្តេច នរោត្តម សីហនុ មកស្រុកបារាំង នៅខែ សីហាឆ្នាំ ១៩៦៧ សាមាគមមួយទៀត ឈ្មោះ «សមាគមទូទៅ នៃ ជនជាតិខ្មែរ នៅស្រុកបារាំង» A.G.C.A.F.(Association Générale des Cambodgiens en France) បានចាប់បដិសន្ធិ (១៩៦៥)។ គោលដៅ នៃ សមាគមនេះ គឺបញ្ចូលសមាគម «សេកុម» មកជាមួយ សមាគម «សម្ព័ន្ធនិស្សិតខ្មែរ» (U.E.K.) ដែលមាន និន្នាការ កុម្មុយនិស្ត ។ មុនដំបូង ដោយសមាគម A.G. C.A.F. មាន សម្តេច សីហនុ ជាអ្នកបង្រួបបង្រួម សមាគម «សម្ព័ន្ធនិស្សិតខ្មែរ» (U.E.K.) ក៏សុខចិត្ត។ ប៉ុន្តែនៅទីបំផុត បែរជារកលេសគេចបាត់ទៅវិញទៅ (កាលនោះ អ៊ុយ អឺ កា មានលោក សៀង ហាក់ ជាអ្នកដឹកនាំ) ។ តាមការពិត សមាគម អាហ្សេក្រាហ្វ មាន ការកិច្ចគាំទ្រ ចលនា សង្គមរាស្ត្រនិយម នៅប្រទេសបារាំង។ ក្រោយមក ចរន្តស្តាំ នៃ សមាគម អាហ្សេក្រាហ្វ (ឡុង ប៉ែត) ក៏លែងមានមុខ ហើយ ត្រូវ ជំនួសដោយ ឈៀង គឹម ស្អូរ ដែលជាអ្នកកណ្តាលនិយម។

ចាប់តាំងពីដើមឆ្នាំ ១៩៥០ នោះដែរ និស្សិតខ្មែរមួយចំនួន ដែលបានទៅរៀននៅស្រុកបារាំងនៅទសវត្សរ៍ ១៩៤០ ហើយ ដែលមាននិន្នាការឆ្វេងនិយម (អ្នកចម្រើននិយម ឬជឿនលឿននិយម) និងកុម្មុយនិស្ត បានត្រឡប់មកស្រុកខ្មែរវិញជាបន្តបន្ទាប់។ ខៀវ ប៉ុណ្ណារី ភរិយា របស់សាឡុត សរ ដែលមកដល់ស្រុកខ្មែរនៅឆ្នាំ ១៩៥១ ប្រកបមុខរបរជាសាស្ត្រាចារ្យ។ លោក កេង វ៉ាន់សាក់ ត្រឡប់មកវិញនៅឆ្នាំ ១៩៥២ លោក ជួន មុម្ម នៅឆ្នាំ ១៩៥៤ សុន សេន នៅឆ្នាំ ១៩៥៦ អៀង សារី នៅឆ្នាំ ១៩៥៧ ។ និស្សិតខ្មែរខ្លះ ដែលមាននិន្នាការសេរីនិយម ក៏វិលមកវិញ នៅទសវត្សរ៍ ១៩៥០ នោះដែរ។ អ្នកម៉ាក្សនិយមខ្មែរជំនាន់ទី ២ ដែលទៅបំពេញវិជ្ជានៅស្រុកបារាំងនៅឆ្នាំ ១៩៥៥ បានត្រឡប់មកវិញនៅចុងទសវត្សរ៍ ៥០។ ខៀវ សំផន ដែលបានទៅសិក្សាខាងវិទ្យាសាស្ត្រសេដ្ឋកិច្ចនៅម៉ុងប៉េលល្យេ បន្ទាប់មក នៅទីក្រុងប៉ារីស៍នៅឆ្នាំ ១៩៥៥ បានវិលមកស្រុកវិញ នៅឆ្នាំ ១៩៥៩ ហើយចូលជាសមាជិក ចលនា *សង្គមរាស្ត្រនិយម* របស់សម្តេច នរោត្តម សីហនុ នៅឆ្នាំដដែល។ ប៉ុន្តែ មួយឆ្នាំក្រោយមក ខៀវ សំផន បានបង្កើតកាសែតជាភាសាបារាំង *L'Observateur* (*អ្នកសង្កេតការណ៍*)។ បន្ទាប់ពីបានត្រូវ ជាប់គុក ជាងមួយខែ សំផន ចូលជា សកម្មជន នៃ «បក្សកុម្មុយនិស្តកម្ពុជា» [១២] (P.C. K.) ៖ នៅឆ្នាំ ១៩៦៧។

ភាគច្រើន នៃ អ្នកដែលបានធ្វើការសិក្សា នៅប្រទេសបារាំង ហើយដែលបានត្រឡប់មកកម្ពុជាវិញ តាំងពីឆ្នាំ ១៩៤៦ មក បាននាំគ្នាទាមទារឯករាជ្យពីបារាំង យ៉ាងស្វិតស្វាញ។ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស និង បញ្ញវន្តមួយចំនួនដូចជាលោកស៊ីម វ៉ា លោក អៀវ កឺះ ជាដើម ធ្វើការតស៊ូ តាមរយៈគណបក្ស *ប្រជាធិបតេយ្យ* ដែល

[១២] «បក្សកុម្មុយនិស្តកម្ពុជា» ជា បក្សដែល សាឡុត សរ ហៅ ប៉ុល ពត បានបង្កើតនៅឆ្នាំ ១៩៦៦ បន្ទាប់ពីបានផ្តាច់ខ្លួនបន្តិចម្តងៗ ពី«បក្សប្រជាជនបដិវត្តកម្ពុជា» ដែលបានត្រូវបង្កើតនៅឆ្នាំ ១៩៥១ ហើយដែលកាលនោះ មាន សឺន ង៉ុក មិញ, ទូ សាមុត, សៀវ ហេង ជាអ្នកដឹកនាំ។





បានទទួលជោគជ័យ ដ៏ត្រចះត្រចង់ ក្នុងការបោះឆ្នោតសភាធម្មនុញ្ញ ដែលបារាំងបានបង្កើត ហើយដែលបាននាំមកឲ្យ ប្រទេសកម្ពុជា នូវ របបមួយថ្មី (រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ)។ នៅពេលបោះឆ្នោតសភា ក្រោយមកទៀត គណបក្ស *ប្រជាធិបតេយ្យ* ក៏ទទួលជ័យជំនះដែរ ជាហេតុធ្វើឲ្យបារាំង មានមានការបារម្ភយ៉ាងខ្លាំង ខ្លាចក្រែង គណបក្ស *ប្រជាធិបតេយ្យ* មានទំនាក់ទំនង ជាមួយពួកវៀតមិញ ដែលជាសត្រូវរបស់គេនៅពេលនោះ។ ម៉្យាងទៀត គណបក្ស *សេរីភាព* ដែលបារាំងបានបង្កើតហើយដែលស្ថិត នៅក្រោមការដឹកនាំ របស់ ព្រះអង្គម្ចាស់ នរិនដេត ក៏ទទួលបរាជ័យទៀត ។ តាមរយៈសភាពការណ៍នេះ គេអាចនិយាយបានថា កិត្យានុភាព របស់ គណបក្ស *ប្រជាធិបតេយ្យ* នៅពេលនោះ មានកត្តាពីរសំខាន់ គឺមួយ កិត្យនុភាពផ្ទាល់ របស់ អ្នកអង្គម្ចាស់ យុត្តិវង្ស ហើយ កត្តាមួយទៀត គឺ កម្មវិធីនយោបាយ និងលក្ខណសម្បត្តិ របស់ សមាជិក នៃ គណបក្សនេះ។ អ្នករាជការ ដែលចាប់ផ្តើម មានការចេះដឹង និង ចាប់ផ្តើមគិតគូរឿង ប្រទេសជាតិ តាមបែបបទប្រជាធិបតេយ្យ បាននាំគ្នាបោះឆ្នោតឲ្យអ្នកប្រជាធិបតេយ្យយ៉ាងសន្ធឹកសន្ធាប់។ នេះជាចំណុចមួយដ៏សំខាន់សំរាប់ការសិក្សាសង្គមសាស្ត្រ។ ប្រទេសកម្ពុជាកំពុងតែផ្លាស់ប្តូររចនាសម្ព័ន្ធវប្បធម៌ និង នយោបាយជាសន្សឹមៗ តាំងពីពេលនោះមក។ នៅឆ្នាំ ១៩៤៧ អ្នកអង្គម្ចាស់យុត្តិវង្ស ចូលជីវង្គត ហើយ នៅដើមឆ្នាំ ១៩៥០ លោក អៀវ កឺះ ត្រូវគេគប់គ្រាប់បែកធ្វើឃាត នៅទីស្នាក់ការគណបក្ស។ តាំងពីពេលនោះមក គណបក្សប្រជាធិបតេយ្យ បានបាត់បង់ នូវថាមពលដើមរបស់ខ្លួន។ សូមកត់សំគាល់ថា ទន្ទឹមនោះដែរ មានចលនាតស៊ូ ទាមទារ ឯករាជ្យពីបារាំង បីទៀត គឺ ចលនា របស់ សឺន ង៉ុក មិញ ហៅអាចារ្យមានដែលមាន វៀតមិញនៅពីក្រោយ ចលនា របស់លោក សឺន ង៉ុក ថាន់ ដែលបានដឹកនាំ មហាបាតុកម្មដេញបារាំង នៅខែកក្កដាឆ្នាំ ១៩៤២ ហើយដែលរត់ទៅប្រទេសជប៉ុន នៅពេលដែលបារាំង ចាប់អាចារ្យ ហែម ចៀវ លោក ប៊ុន ចាន់ ម៉ុល និង អ្នកតស៊ូមួយចំនួនទៀតទៅដាក់គុកនៅកោះត្រឡាច។ ចលនាមួយទៀត គឺ ចលនា របស់អ្នកអង្គម្ចាស់ នរោត្តម ចន្ទរង្សី ដែលការពារ របប រាជានិយមជាពិសេស រាជវង្ស នរោត្តម។ នៅឆ្នាំ ១៩៤៥ សឺន ង៉ុក

ថាញ់ ឡើងធ្វើជា នាយករដ្ឋមន្ត្រី នៅពេលដែល ជប៉ុនក្តាប់អំណាច នៅស្រុកខ្មែរ ។ ប៉ុន្តែ ក្រោយបរាជ័យ របស់កងទ័ពជប៉ុន នៅក្នុងសង្គ្រាមលោក លើកទី ២ បារាំង ក៏ត្រឡប់មកវិញ ហើយ ដាក់ព្រះមហាក្សត្រ នរោត្តម សីហនុ ឲ្យស្ថិតនៅក្រោម អាណាព្យាបាល របស់ បារាំង បន្តមកទៀត ។ នៅពេលដែលគណបក្ស *ប្រជាធិបតេយ្យ* បាត់បង់ អ្នកដឹកនាំ សំខាន់ៗ សមាជិកខ្លះ ចង់រេទៅរក ព្រះមហាក្សត្រខ្មែរវិញ ។ នៅឆ្នាំ ១៩៥២ ដោយមាន ការជំរុញ ពីបារាំង ព្រះមហាក្សត្រខ្មែរ វិលមកក្តាប់អំណាចវិញ តាមរយៈមាត្រា ២១ នៃ រដ្ឋធម្មនុញ្ញ (កាសែត ឡឺ ម៉ុងដ៍ ចាត់ទុក ការវិលមកកាន់អំណាចវិញ របស់ ព្រះមហាក្សត្រ នេះ ថាជា «រដ្ឋប្រហារស្របច្បាប់» : («Coup d’Etat légal») ។ នៅពេលដែល ព្រះមហាក្សត្រ ទម្លាក់រដ្ឋាភិបាល ប្រជាធិបតេយ្យ លោក ហ៊ុយ គន្ធុល និស្សិតខ្មែរនៅស្រុក បារាំង បាននាំគ្នា ថ្កោលទោសព្រះមហាក្សត្រយ៉ាងខ្លាំង (ជាពិសេស លោក ហ៊ូ យន់ និង លោក កេង វ៉ាន់សាក់) ។ លុះបានអំណាច មកវិញហើយ ព្រះមហាក្សត្រខ្មែរ ក៏ ចាប់ផ្តើមទាមទារ ឯករាជ្យពីបារាំង ដោយឥតបង្អង់ ដោយមាន ការចូលរួមចំណែកយ៉ាង សកម្ម ពី បញ្ញវន្តស្តាំអភិរក្សនិយម មួយចំនួនដូច ជា លោក ញឹក ជូឡុង និង លោក សម សារី ជាដើម។ នៅចុងឆ្នាំ ១៩៥៣ បារាំងបានប្រគល់ឯករាជ្យមកឲ្យខ្មែរ។ សន្និសីទអន្តរជាតិទីក្រុងហ្សឺណែវ បានបញ្ជាក់ពី លក្ខណៈអន្តរជាតិ នៃ ឯករាជ្យខ្មែរ។ លោក សម សារី ដែលយល់ច្បាស់ពី ការគំរាមកំហែង ពី សំណាក់ប្រទេសកុម្មុយនិស្ត បានស្នើឲ្យប្រទេសមហាអំណាចធានាឯករាជ្យនេះ ឲ្យបានត្រឹមត្រូវ ជាពិសេស សុំឲ្យខ្មែរមាន សទ្ធិបរិបូរក្នុងការជ្រើសរើស សម្ព័ន្ធមិត្ត របស់ខ្លួន។ ការតស៊ូ ដ៏សំខាន់នេះ ចំពោះប្រវត្តិសាស្ត្រខ្មែរ បានប្រព្រឹត្តទៅ អស់ពេញមួយយប់ ។ នៅទីបំផុត លោក ម៉ូឡូតុហ្វ អ្នកតំណាង សហភាព សូវៀត ក៏យល់ព្រម ។ ប៉ុន្តែ គឺ ការទាមទារចុងក្រោយនេះតែម្តងដែលធ្វើឲ្យ ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ អាក់អន់ស្រពន់ចិត្ត ហើយបង្កើតរដ្ឋាភិបាលមួយទៀត ដែលគ្មានវត្តមាន លោក សម សារី ។ គេអាចនិយាយបានថា គឺតាំងពី ពេលនោះមកហើយ ដែលស្តេចខ្មែរអង្គនេះ មានគោល បំណងចង់ ផ្តាច់ស្រុក



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ខ្មែរពីបស្ចិមប្រទេស ដើម្បីយកប្រទេសចិនកុម្មុយនិស្ត ធ្វើជាមហាមិត្តពិសេស។ នៅឆ្នាំ ១៩៥៥ ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ បានដាក់រាជ្យ ថ្វាយទៅ ព្រះមាតា និងព្រះបិតា ដើម្បីចូលប្រឡូកដោយផ្ទាល់ ក្នុងឆាកនយោបាយ។ នៅឆ្នាំ ១៩៥៩ ទំនាស់រវាង ព្រះ មហាក្សត្រ និង លោក សម សារី ស្តែងចេញឡើងយ៉ាងច្បាស់ ។ ឆ្លៀតឱកាសលោក សម សារី មានបញ្ហាគ្រួសារ នៅទីក្រុងឡុងដ៍ (សម្តេច នរោត្តម សីហនុ បាននិរទេស លោក សម សារី ឲ្យមកធ្វើជា ឯកអគ្គរាជទូត នៅប្រទេសអង់គ្លេស) សម្តេច នរោត្តម សីហនុ ដកខ្លួនឲ្យបានឆ្ងាយ បំផុតពី វរជនខ្មែររូបនេះ ដែលព្រះអង្គដឹងយ៉ាងច្បាស់ថា ខុសពីព្រះអង្គ សម សារី ជាអ្នកដែលមិនត្រូវ នឹងប្រទេសកុម្មុយនិស្ត ឡើយ ។ ចាប់ តាំងពីឆ្នាំ ១៩៥៩ មក លោក សម សារី បានត្រូវ *របបសង្គមរាស្ត្រនិយម* (ដែល លោក សម សារី បានខិតខំជួយបង្កើត) ចោទលោកថាជាជនក្បត់ជាតិតែម្តង។ ក្រោយ មក លោក សម សារី ចូលទៅ ក្នុង ចលនា *ខ្មែរសេរី* របស់ លោកសឺន ង៉ុក ថាញ់ ដែលបានរត់ចូលព្រៃនៅឆ្នាំ ១៩៥២។ ប៉ុន្តែ ជាអកុសសលោកត្រូវគេលួចធ្វើឃាត នៅក្នុងស្ថានភាពមួយ ដ៏ អាថ៌កំបាំង។

ចាប់តាំង ពី ឆ្នាំ ១៩៦០ មក ឆ្នាំ ១៩៧០ ប្រទេសកម្ពុជា ក្រោមការដឹកនាំ របស់សម្តេច នរោត្តម សីហនុ ដែលបានត្រូវតែងតាំង ជាប្រមុខរដ្ឋ ដោយសភាទាំងពីរ នៅឆ្នាំ ១៩៦០នោះមក បានចងមិត្តភាពពិសេស ជាមួយប្រទេសចិនកុម្មុយនិស្តដែលកាលនោះស្ថិតនៅក្រោមការដឹកនាំ របស់ ម៉ៅ សេទុង។ អតីតនិស្សិតខ្មែរនៅស្រុកបារាំង នាទសវត្សរ៍ ១៩៤០ ដែលបានត្រឡប់មកមាតុប្រទេសវិញ នៅឆ្នាំ ៥០-៦០ ចាប់ផ្តើមធ្វើសកម្មភាពនយោបាយ យ៉ាងសកម្ម ។ នៅឆ្នាំ ១៩៥៤ លោក កេង វ៉ាន់សាក់ ចូលជាសមាជិក គណបក្ស *ប្រជាធិបតេយ្យ* បន្ទាប់មក បានត្រូវតែងតាំងជា អគ្គលេខាធិការរង នៃគណបក្សនោះ ។ នៅពេលបោះឆ្នោតសភា ឆ្នាំ ១៩៥៥ លោក កេង វ៉ាន់សាក់ វាយប្រហារ របបរាជានិយម យ៉ាងខ្លាំង ហើយ ត្រូវគេចាប់ដាក់គុក អស់ជិតមួយខែ។ នៅឆ្នាំ ១៩៦៨ ក្រោយ ការបះបោរ នៅសម្លូត (២ មេសា ឆ្នាំ ១៩៦៧ ) លោក បានត្រូវប៉ូលីស របស់ សម្តេច សីហន ចោទប្រកាន់ថា ជា អ្នកបំបះបំបោរ សិស្ស ឲ្យ

បង្កើតកោលាហល ហើយត្រូវគេដាក់ឃុំ នៅក្នុងលំនៅឋានរបស់លោក ហើយ ហាមជាដាច់ខាត មិនលោកជឿនតទៅទៀត។ នៅពេលប៉ូលីស ឆែកឆេរផ្ទះលោក គេបានរកឃើញ សៀវភៅ ដែលសរសេរពី កាល ម៉ាក្ស និង ម៉ៅ សេទុង ។ ដោយព្រោះតែសៀវភៅទាំងឡាយនេះ លោក វ៉ាន់សាក់ បានត្រូវគេចាប់ដាក់គុក សាជាថ្មីទៀត ។ ទាល់តែមកដល់នៅពេល ដែលឧត្តមសេនីយ៍ លន់ នល់ ឡើងកាន់អំណាចនៅខែ មិនា ឆ្នាំ ១៩៧០ ទើបលោកបានចាកផុត ពីទុក្ខវេទនា ដែលសម្តេច សីហនុ បានកំហិតទៅលើរូបលោក។ ឧត្តមសេនីយ៍ លន់ នល់ បានតែងតាំងលោក ជា អ្នកតំណាងប្រទេសកម្ពុជា នៅអង្គការ យូណេសស្កូ នៅឆ្នាំ ១៩៧១ បន្ទាប់មក ជា ភារធារី ប្រចាំប្រទេសបារាំង ។ ខាងបញ្ញជន ដែលមិននិយម លទ្ធិម៉ាក្សវិញ គេក៏បង្កើនសកម្មភាព របស់គេយ៉ាងខ្លាំងក្លាដែរ ។ នៅឆ្នាំ  ១៩៦៣ លោក ឌុក រ៉ាស៊ី បង្កើតកាសែត ជាភាសាបារាំងមួយ ឈ្មោះ «ភ្នំពេញប្រេស» (Phnom Penh Press) ។ គឺជាកាសែតដែលមាននិន្នាការស្តាំនិយមដែលរិះគន់ នយោបាយ របស់ សម្តេច សីហនុ យ៉ាងចាស់ដៃ ហើយជា គូប្រជែង របស់សារពត៌មាន ជាភាសាបារាំងមួយទៀតឈ្មោះ «ឡា ដេប៉ែស ឌុយកាំបូដស្ជ» ( La Dépêche du Cambodge) ដឹកនាំ ដោយ ចៅ សេង មិត្តម្នាក់ របស់ សាឡុត សរ ហើយដែលជា រដ្ឋមន្ត្រី ជំនិតម្នាក់ របស់សម្តេច នរោត្តម សីហនុ។ ឆ្លៀតឱកាស មានឥទ្ធិពល ចៅ សេង បានដណ្តើម ការដឹកនាំកាសែតនេះ ពីលោក ស៊ិម វ៉ា នៅ ឆ្នាំ ១៩៦៨ ។ សហការី របស់លោក ឌុក រ៉ាស៊ី នៅកាសែត «ភ្នំពេញ ប្រេស » មានជាអាទិ៍ លោក ប៉ូលី តែ សួន ( ព្រឹទ្ធបុរសវិទ្យាល័យ អក្សរសាស្ត្រ និង មនុស្សសាស្ត្រ) លោក ចៅ បាន លោក គន្ធថាវ ជី ម៉ុងតឺរ៉ូ ។ ប្រវត្តិសាស្ត្រ បានចារទុកថា លោក ឌុក រ៉ាស៊ី ជាអ្នកប្រឆាំង ចេញមុខម្នាក់ តទល់ នឹង សម្តេច នរោត្តម សីហនុ តាំងពីពេលនោះមក។ អ្នកប្រឆាំងចេញមុខផ្សេងទៀត ដែលមាននិន្នាការសេរីនិយម មាន ជាអាទិ៍ លោក សឺន ង៉ុក ថាញ់ ថាន់ លោក សម សារី លោកចៅ បូរី លោក



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

សៅ ង៉ុយ លោកព្រាប អ៊ិន លោក មធុរា ។ លោក សៅ ង៉ុយ លោក ព្រាប អ៊ិន លោក ចៅ បូរី បានត្រូវគេយកទៅប្រហារជីវិត នៅត្រពាំងក្រឡឹង [១៣] ។ នៅពេលដែលអ្នកអភិរក្សនិយមស្មោះត្រង់ និងសម្តេច នរោត្តម សីហនុ ដឹកនាំប្រទេស បញ្ញវន្តឆ្វេងនិយម ក៏បានត្រូវគេធ្វើឃាតដែរ។ នៅថ្ងៃ ១១ តុលា ឆ្នាំ ១៩៥៩ អ្នកកាសែតកុម្មុយ និស្ត ណុប បូផាន់ បានត្រូវគេធ្វើឃាត ។ នៅឆ្នាំ ១៩៦៣ នៅពេលដែលនៅក្នុងព្រៃ ប៉ុល ពត ដណ្តើមយក ការដឹកនាំ បក្សប្រជាជនបដិវត្តន៍ ពី សោ ភឹម បាន (មហាសន្និបាត បក្សពលករ កម្ពុជា ថ្ងៃ ២០-២១ កុម្ភៈ) បន្ទាប់ពី ទូ សាមុត ត្រូវបាត់ខ្លួន (២០ កក្កដា ១៩៦២) នៅភ្នំពេញ ឯណេះវិញ សម្តេច នរោត្តម សីហនុ ប្រើ កលល្បិចហៅ បញ្ញវន្ត ឆ្វេងនិយមចំនួន ៣៤ រូប ឲ្យចូលមករៀបចំគណៈរដ្ឋមន្ត្រី ។ ក្នុង ចំណោមបញ្ញវន្ត ៣៤ នាក់នោះ មាន ឈ្មោះ គាត ឈុន, កេង វ៉ាន់សាក, ខៀវ សំផន, ទេព ឈីវ ខេង, ហ៊ូ នឹម, ហ៊ូ យន់, ចៅ សេង, សាឡុត សរ, អៀង សារី, ស៊ុន សេន, ជួន ប្រាសិទ្ធ, ឌិក សាគុន។ ប៉ុន្តែ ដោយដឹងថា ជាអន្ទាក់ ពួកអ្នកទាំងនោះ ក៏មិនព្រមទទួល សេចក្តីស្នើ នោះ។ នៅពេលដែល សម្តេច សីហនុ បង្ក្រាបបញ្ញវន្តសាស្ត្រាចារ្យឆ្វេងនិយម ដែល ចេញពី មហាវិទ្យាល័យគរុកោសល្យ ជាច្រើន បានបាត់បង់ជីវិត។ នៅឆ្នាំ ៦០-៧០ នោះការប្រយុទ្ធគ្នា រវាង បញ្ញវន្ត ឆ្វេងនិយម និង ស្តាំនិយមអភិរក្ស បានប្រព្រឹត្តទៅតាម រយៈកាសែត និង នៅក្នុងរដ្ឋសភា ។ ក្រោយ ការបះបោរ ប្រជាកសិក នៅសំឡូត (២ មេសាឆ្នាំ ១៩៦៧ ) និង ក្រោយ ការគំរាមកំហែង របស់ សម្តេច សីហនុ ថា នឹងយកអ្នកនាំឲ្យមានការបះបោរនោះ ទៅឲ្យតុលាការសឹក កាត់ទោស ខៀវ សំផន និង ហ៊ូ យន់ ក៏រត់ចូលព្រៃ (ថ្ងៃ ២៤ មេសាឆ្នាំ ១៩៦៧) ។ កាលនោះ គេចោទប្រកាន់ថា អ្នកតំណាង រាស្ត្រឆ្វេងនិយម ទាំងពីររូបនេះ

[១៣] ព្រាប អ៊ីន ត្រូវសម្តេច នរោត្តមសីហនុ ឲ្យគេប្រហារជីវិត នៅត្រពាំងក្រឡឹង នៅថ្ងៃ ២០ មករាឆ្នាំ ១៩៦៤ លោក មធុរា និង ចៅ បូរី នៅខែធ្នូ ឆ្នាំ ១៩៦៦ លោក សៅ ង៉ុយ នៅថ្ងៃ ២២ មេសាឆ្នាំ ១៩៦៧។

បានត្រូវប៉ូលីស របស់ សម្តេច សីហនុ សម្លាប់ចោល។ តាមការពិត គឺ ក្រសួងសម្ងាត់ចិន ដែលបានបង្កើត ការសង្ស័យនេះ ព្រោះ កាសែតចិន បាននិយាយ រៀបរាប់យ៉ាងច្បាស់ អំពីរឿងនេះ ដែលពុំពិតទាល់តែសោះ ។ រីឯគោលដៅ នយោបាយ គឺ ប្រហែលជា ដើម្បី ទម្លាក់ទោសទៅលើ ឧត្តមសេនីយ៍ លន់ នល់។ ប៉ុន្តែ ការសន្និដ្ឋាន មួយទៀត គឺ ចិន ការពារជីវិត អ្នកទាំងពីរនាក់នោះ ដើម្បីពង្រឹង ចលនា ខ្មែរក្រហម ដែលគេសម្រាំងជាស្រេច ដើម្បី សម្រេចគោលដៅ អនុត្តរភាពចិន នៅ កម្ពុជា ព្រោះ សម្តេច សីហនុ គ្រាន់ តែជាយុទ្ធវិធី ប៉ុណ្ណោះ។ នៅ ថ្ងៃ ១៣ កក្កដាឆ្នាំ ១៩៦៧ ដដែល នោះ ក្រសួងអប់រំជាតិ បានចាប់ផ្តើម អភិក្រម ខេមរយានកម្ម។

# ការវិវត្តន៍ នៃ សង្គមខ្មែរ ពីសម័យអង្គរ មក បច្ចុប្បន្នកាល

សង្គមខ្មែរ មានការប្រែប្រួលច្រើន តាំងពីសម័យអង្គរមក ប៉ុន្តែ គឺជាការវិវត្តន៍ ចក្រចលនា (évolution cyclique)។ នៅចុងសតវត្សរ៍ទី ១២ ប្រទេសកម្ពុជា បាន ផ្លាស់ប្តូរពីការគោរពបូជាព្រះសីវលិង្គ (ពហ្មញ្ញសាសនា) មកការគោរព លោកេស្វរ (តួអង្គពោធិសត្វ នៃ ពុទ្ធសាសនា មហាយាន) ។ ក្រោយបដិវត្តន៍ពុទ្ធសាសនា នៅសតវត្សរ៍ទី១៤ (១៣៣៦) ខ្មែរបែរមកកាន់ លទ្ធិពុទ្ធសាសនាហិនយាន (ថេរវាទឬ បុរាណ)។ ទោះជាមានការផ្លាស់ប្តូរ ឧបរិរចនាសម្ព័ន្ធ (superstructure) ដូច្នេះក៏ដោយ ក៏របៀប គ្រប់គ្រងប្រទេស នៅតែមាន លក្ខណៈ ទេវរាជ ដដែល។ ទោះបីរបបរាជានិយមខ្មែរ ជារបប ជ្រើសតាំងមហាក្សត្រក្តី (monarchie élective) ក៏ការបន្តរាជ្យពុំមានច្បាប់ ច្បាស់លាស់ ដដែល។ អ្នកខ្លាំង អាចយកអំណាចពេលណាក៏បាន។ ពីចុងសតវត្ស៍ ទី ១៩ មកដល់ ពាក់កណ្តាលសតវត្សរ៍ ទី ២០ វប្បធម៌បារាំង បានត្រូវផ្សាភ្ជាប់ជាមួយ អារិយធម៌ខ្មែរ ហើយនៅឆ្នាំ ១៩៤៧ របបរាជានិយមប្រពៃណី បានត្រូវប្តូរមកជារបប





រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ (ព្រះមហាក្សត្រសោយរាជ្យសម្បត្តិ តែមិនគ្រប់គ្រង ឡើយ)។ នៅឆ្នាំ ១៩៥២ ព្រះមហាក្សត្រខ្មែរ នរេត្តម សីហនុ ចាប់ផ្តើមវិលមករករបប ទេវរាជ វិញដដែល ប៉ុន្តែ តាមរូបភាពទំនើប។ នៅឆ្នាំ ១៩៥៥ ព្រះមហាក្សត្រ វិលមក គ្រប់គ្រងប្រទេស ដោយ ផ្ទាល់ព្រះអង្គ ដោយចូលប្រយុទ្ធ ក្នុងឆាកនយោបាយ តទល់ នឹង គណបក្ស នយោបាយនានា។ នៅឆ្នាំ ១៩៦០ ព្រះអង្គ បានបង្កើតស្ថាប័នគ្រប់គ្រង មួយថ្មីទៀត គឺស្ថាប័ន «ព្រះប្រមុខរដ្ឋ» ដែលមានលក្ខណៈ ពាក់កណ្តាល របបរាជា និយម ពាក់កណ្តាលរបបសាធារណរដ្ឋ តាមបែបប្រទេសសង្គមនិយម នៅពេលនោះ។ នៅ ឆ្នាំ ១៩៧០ ស្រុកខ្មែរផ្លាស់ប្តូរ ពីរបប ទេវរាជ តាមបែបសម្តេច នរោត្តម សីហនុ មកជារបបសាធារណរដ្ឋ តាមបែបបស្ចិមប្រទេស។ កាលពីឆ្នាំ ១៩៤៧ ប្រទេសកម្ពុជា កំពុងឈានជាដំណាក់ការ ឆ្ពោះមករករបប សាធារណរដ្ឋ ប៉ុន្តែអភិក្រមនេះត្រូវកាត់ ផ្តាច់ទៅវិញនៅឆ្នាំ ១៩៥២ រហូតដល់ ឆ្នាំ ១៩៧០ ។ ពីឆ្នាំ ១៩៧៥ មកដល់ឆ្នាំ ១៩៩៣ ប្រទេសកម្ពុជា បានយករបបកុម្មុយនិស្តមកគ្រប់គ្រង ៖ តាមបែបម៉ៅនិយម (១៩៧៥-១៩៧៩) និងតាមបែបសូវៀត (១៩៧៩-១៩៩៣)។ ពីឆ្នាំ ១៩៩៣ មកឆ្នាំ ១៩៩៧ ប្រទេសកម្ពុជា បានវិលមករករបបឆ្នាំ ១៩៤៧ ដដែល គឺ របប រាជានិយមអាស្រ័យរដ្ឋ ធម្មនុញ្ញ ។ ចាប់ពី ឆ្នាំ ១៩៩៧ មក ស្រុកខ្មែរបានធ្លាក់ទៅដល់របបមួយដែលដកស្រង់ ចេញពីរបប ទេវរាជ វិញដដែល។ គេអាចពន្យល់ ការផ្លាស់ប្តូរ របបនយោបាយ ពីឆ្នាំ ១៩៤៧ មក ដោយផ្អែកទៅលើ ការប្រជែងកម្លាំង នៅក្នុងពិភពលោក និង នៅក្នុងតំបន់ ប៉ុន្តែគេក៏អាចពន្យល់ បាតុភូត ចក្រចលនា នេះ ទៅតាម រចនាសម្ព័ន្ធ វប្បធម៌ បានដែរ នៅក្នុងករណីដែលជំហរ នៃ គំនិតថ្មី ពុំមានលក្ខណៈរឹងមាំ ហើយ ជំហរនេះ បានត្រូវ ជួប នឹង ភាពរកាំរកូស ព្រោះតែអ្នកដឹកនាំខ្មែរ ខ្លាចបាត់បង់អំណាចរបស់គេ ពោលគឺ គេបានយកគំនិតជាតិនិយមតាមបែបបទទំនៀមទម្លាប់ចាស់និយម មកធ្វើជាលេស [១៤]។ តាម ការពិត គំនិតជាតិនិយមវិជ្ជមាន (nationalisme positif) គឺ ការជំរុញស្រុក

[១៤] សូមអាន Vandy Kaonn : *Le Cambodge et ses difficultés d'insertion dans le monde moderne, un siècle d'Histoire sociale et politique*, 1998.

ឲ្យមាន ការរីកចំរើនគ្រប់វិស័យ ជាពិសេស វិស័យការបេះដឹង ស្មើនឹង ប្រទេសនានា ជាអាទិ៍ ប្រទេសជិតខាង។



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

# មនោគមវិជ្ជា របស់ ម៉ាក្ស និង បដិវត្តន៍ នៃ វណ្ណៈ អធន

## Le marxisme et la révolution prolétarienne

# សកម្មភាព បញ្ញវន្តខ្មែរ មុនពេល បានឯករាជ្យ

លទ្ធិម៉ាក្សនិយម បានចូលមកក្នុងស្រុកខ្មែរ តាមរយៈបញ្ញវន្តខ្មែរ មួយក្រុម ដែលមកពីប្រទេសបារាំង នៅពេលដែលចលនាវៀតមិញ ជ្រៀតជ្រែកចូលមកស្រុកខ្មែរ ដើម្បីជួយខ្មែរដេញបារាំងចេញពីស្រុក។ ប៉ុន្តែ ក្រុមអ្នកម៉ាក្សនិយមខ្មែរមានប្រភពជាច្រើនទៀត។ ខ្លះស្ថិតនៅក្នុងចលនាប្រជាធិបតេយ្យ ខ្លះទៀត មកពីមជ្ឈដ្ឋាន «អ្នកចំរើននិយម» (les progressistes) ។ ប៉ុន្តែចំណុចរួម នៃ ចលនាទាំងនោះ គឺ គំនិតជាតិនិយម និង ការប្រឆាំងនឹង របបរាជានិយមផ្តាច់ការ ជាពិសេសប្រឆាំងនឹងព្រះមហាក្សត្រ នរោត្តម សីហនុ ដែលបារាំងដាក់ឲ្យឡើងសោយរាជ្យ នៅឆ្នាំ ១៩៤១។ គោលដៅរួមនៅពេលនោះ គឺ ការដេញបារាំងចេញពីស្រុក។ គណបក្សប្រជាធិបតេយ្យ ដែលបានត្រូវបង្កើតនៅឆ្នាំ ១៩៤៦ ដោយលោក ស៊ីម វ៉ា លោក អៀវ កើះ និង អ្នកប្រឆាំង នឹង វត្តមាន បារាំងនៅក្នុងស្រុក មួយចំនួន មាននិន្នាការយ៉ាងហោចណាស់ ក៏ ៣ ដែរ គឺ ៖ អ្នកសេរីនិយម អ្នកអភិរក្សនិយម និង «អ្នកចំរើននិយម» ។ លោក សឺន សាន ជា អ្នកប្រជាធិបតេយ្យ ប៉ុន្តែលោកយល់ថា ប្រទេសកម្ពុជា មិនអាចអត់ ព្រះមហាក្សត្រ នរោត្តម សីហនុ បានឡើយ ។ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស ដែលជាប្រធានគណបក្សប្រជាធិបតេយ្យ ក៏ជា«អ្នកចំរើននិយម» ដែរ។ លោក កេង វ៉ាន់សាក់ ដែល នៅពេលបោះឆ្នោតសភា នា ឆ្នាំ ១៩៥៥ ជាអគ្គលេខាធិការង នៃ គណបក្សប្រជាធិបតេយ្យ ក៏គ្រាន់ជាអ្នកឆ្វេងនិយម ប៉ុណ្ណោះ ពោលគឺ អ្នកប្រជាធិបតេយ្យឆ្វេងនិយម ប៉ុន្តែ មិនមែនជាជនកុម្មុយនិស្តសឡើយ។ ដោយលោកប្រឆាំងយ៉ាងពេញ ទំហឹង នឹងរបបរាជានិយម ជាពិសេសព្រះមហាក្សត្រ នរោត្តម សីហនុ លោក បានក្លាយ ទៅជាអ្នកសាធារណរដ្ឋនិយមនៅក្នុង របបឧត្តមសេនីយ៍លន់ នល់ (សាធារណរដ្ឋ សេរីនិយមខ្មែរ) ។ ការកកើតឡើង នៃ ក្រុមអ្នកម៉ាក្សនិយម ចេញមកពីច្រើន ប្រភព ហើយវិវត្ត ទៅតាម ឥស្សរជនម្នាក់ៗ ។

នៅឆ្នាំ ១៩៣១ គឺ មួយឆ្នាំក្រោយ ការបង្កើតបក្សកុម្មុយនិស្ត ឥណ្ឌូចិន (PCI) អ្នកអង្គ ម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស ចេញទៅសិក្សានៅប្រទេស បារាំង។ យុត្តិវង្សស្ថិតនៅ





ស្រុកបារាំង អស់រយៈពេល ១៥ ឆ្នាំ ។ លោក បានចូលជា សមាជិក គណបក្ស សង្គមនិយម បារាំង ហើយ រៀនបានសញ្ញាប័ត្របណ្ឌិតរដ្ឋ ខាងគណិតសាស្ត្រ។ ១៥ ឆ្នាំក្រោយមក គឺ នៅឆ្នាំ ១៩៤៦ លោក កេង វ៉ាន់សាក់ ទៅសិក្សា ទស្សនវិជ្ជា នៅប្រទេសបារាំងដែរ (La Sorbonne) ។ នៅឆ្នាំដដែលនោះ លោក ជួន មុម្ម ក៏ ចេញទៅសិក្សា នៅប្រទេសបារាំងដែរ បន្ទាប់ពីបានធ្វើការសិក្សា នៅ សកលវិទ្យាល័យ ទីក្រុងហាណូយ (ឆ្នាំ ១៩៤៥)។ នៅស្រុកបារាំង លោកសិក្សា គណិតវិទ្យា នៅសាលាពហុបច្ចេកទេស (Ecole Polytechnique) ហើយ បានសញ្ញាប័ត្រគណិតវិទ្យា។ លោកចូលជា សមាជិកគណបក្សកុម្មុយនិស្ត បារាំង នៅឆ្នាំ ១៩៥១ ។ នៅ ប្រទេសវៀតណាម និង កម្ពុជា អាចារ្យ មាន ហៅ សឺន ង៉ុក មិញ ចាប់ផ្តើមរដើរតួនាទី មួយដ៏សំខាន់ តាំងពីឆ្នាំ ១៩៤៩ មក។ នៅក្នុងមហាសន្និបាត ទី ២ នា ថ្ងៃ ១១-១៩ កុម្ភៈ ឆ្នាំ ១៩៥០ បក្សកុម្មុយនិស្ត ឥណ្ឌូចិន (PCI) សម្រេចឲ្យ ប្រទេស នីមួយៗ នៅឥណ្ឌូចិន បង្កើតកងទ័ព របស់ ខ្លួនផ្ទាល់ ។ នៅទីក្រុងប៉ារីស៍ ខ្មែរមួយក្រុម មាន ជាអាទិ៍ អៀង សារី ខៀវ ធីរិទ្ធ, ហ៊ូ យន់, កេង វ៉ាន់សាក់, ជួន មុម្ម, សាឡូត សរ, មុី ម៉ាន់, មុី ផាត, រត្ន សាមឿន បានបង្កើត ក្លឹប ម៉ាក្ស និយមមួយ នៅឆ្នាំ ១៩៥០ ដដែលនោះ ។ នៅស្រុកខ្មែរ នៅថ្ងៃ ២៨ មិថុនាឆ្នាំ ១៩៥១ [១៥] ក្រោយមហាសន្និបាតទី ២ នៃ បក្សកុម្មុយ និស្ត ឥណ្ឌូចិន ខ្មែរមួយ ក្រុមបានបង្កើត គណបក្សកុម្មុយនិស្តមួយ មានឈ្មោះថា «បក្សប្រជា ជន បដិវត្ត កម្ពុជា» (P.P.R.K.) ដែលកាលនោះ មាន សៀវ ហេង ជាអ្នកដឹកនាំ ។

[១៥] ចំពោះ ការកំណត់ថ្ងៃបង្កើត «បក្សប្រជាជនបដិវត្ត កម្ពុជា» នេះ មានការខ្វែងគំនិតគ្នា ៖ ខ្លះ ថា ថ្ងៃ ១៩ កុម្ភ ឆ្នាំ ១៩៥១ : (គឺ ថ្ងៃបើក មហាសន្និបាត បក្សកុម្មុយនិស្តឥណ្ឌូចិន) ខ្លះថា ថ្ងៃ ១៨ មិថុនា ១៩៥១ ខ្លះទៀត ថា ថ្ងៃ ៣០ កញ្ញា ឆ្នាំដដែល។

# អ្នកម៉ាក្សនិយម និង ទ្រឹស្តី របស់ ម៉ាក្ស

ពីឆ្នាំ ១៨៨៩ មកដល់ពេលសង្គ្រាមលើកទី១ ទ្រឹស្តីដើម របស់ ម៉ាក្ស បាន ទទួល ការពេញនិយមយ៉ាងពេញទំហឹង ទោះបី មានការបកស្រាយទ្រឹស្តីនេះ តាមបែបផ្សេងក្តី ។ នៅប្រទេសអ៊ីតាលី អង់តូញ៉ូ ឡាព្រីយ៉ូឡា (Antonio Labriola, ១៨៤៣-១៩០៤) បាន បក ស្រាយ គោលការណ៍ «រូបធាតុនិយម ប្រវត្តិសាស្ត្រ» មិនដាច់ខាតពេក ដូចកាល កូតស្គី (Karl Kautsky, ១៨៥៤-១៩៣៨) ឡើយ។ កាល កូតស្គី យល់ អំពី ការកសាង របប «សង្គមនិយមវិទ្យាសាស្ត្រ» (socialisme scientifique) ដូចគំនិតដែលអង់ហ្គែល បានយក គំនិត របស់ ម៉ាក្ស មកធ្វើសំយោគ ។ រីឯ អង់តូញ៉ូ ឡាព្រីយ៉ូឡា ដែលបាន យកគំនិតរបស់ ម៉ាក្ស កាលពីនៅជាយុវជន មកធ្វើជាមូលដ្ឋាន បានត្រូវគេចាត់ទុកថា ជា អ្នកកសាង របប សង្គមនិយមម្នាក់ ដែលមាន លក្ខណៈមនុស្សធម៌ ដូច គំនិតខ្លះ របស់ ហេហ្គិល (Hegel)។ អ្នកម៉ាក្សនិយមជំនាន់ក្រោយ ដែលដើរតាម ឡាព្រីយ៉ូឡា មានជា អាទិ៍ អ្នកម៉ាក្សនិយម អ៊ីតាលី អង់តូញ៉ូ ក្រាមស៊ី (Antonio Gramsci, ១៨៩១-១៩៣៧) និង ជនជាតិ ហុងគ្រី លុយកាស (GyÖrgy Lukács, ១៨៨៥-១៩៧១) ។

## ការបកស្រាយគំនិត កសាងសង្គមនិយម តាម ក្រាំស៊ី (Gramsci)

អ្នកម៉ាក្សនិយម អ៊ីតាលី ក្រាំស៊ី យល់ថា នៅក្រោម របបមូលធននិយម សម័យថ្មី វណ្ណៈគហបតី អាច រក្សាការត្រួតពិនិត្យផ្នែកសេដ្ឋកិច្ច ដដែល ដោយបណ្តោយ ឲ្យសង្គម នយោបាយ សុខចិត្តឆ្លើយតប នឹង ការទាមទារខ្លះៗ របស់ សហជីព និង គណបក្ស នយោបាយ របស់ មហាជន ។ បើធ្វើយ៉ាងដូច្នេះ ពួកគេ បណ្តោយឲ្យមានរូបភាពមួយ នៃ បដិវត្តន៍ដែរ ប៉ុន្តែជា បដិវត្តន៍មួយបែប ដែលបន្ថយថាមពល នៃ បដិវត្តន៍ មែនទែន។ ពួក គេ បាត់បង់ តែផលប្រយោជន៍ចំពោះមុខ របស់គេ តែប៉ុណ្ណោះ ប៉ុន្តែ គឺជា ការរក្សាអនុត្តរ ភាព របស់គេដដែល តាមរយៈការផ្លាស់ប្តូរ រូបភាពផ្សេងៗ ដូចជា ការកែទម្រង់និយម របប ហ្វា ស៊ីស និង ការបន្ថែមបៀវត្ស ជំរុញផលិតកម្ម (តៃល័រវិធី) ជាដើម ។ ក្រាំស៊ី យល់ឃើញថា បក្ស នៃចលនា បដិវត្តន៍ ត្រូវមានបញ្ញាជន ដើម្បីតស៊ូប្រឆាំង នឹង អនុត្តរ





ភាព (hégémonie) របស់ ពួកវណ្ណៈដែល ក្តាប់សង្គមស៊ីវិល ។ នៅក្នុង សង្គមសម័យ ទំនើប ការប្រឈមមុខ ការរំលំ អនុត្តរភាព នៃ វណ្ណៈគហបតី ដោយចំមុខត្រង់ៗ តែម្តង ដើម្បីនាំសង្គម ទៅរករបបសង្គមនិយម ជាការមួយ ដែលពុំអាចសម្រេចបានទេ ។ ចំពោះ ក្រាំស៊ី ការកសាងរបបសង្គមនិយម មិនអាចធ្វើតាមរូបភាពណាមួយ នៃ រដ្ឋប្រហារ ឬ ការប្រឈម មុខដោយត្រង់ៗតែម្តងបានទេ គឺមានតែការប្រយុទ្ធ តាមផ្នែកវប្បធម៌ តទល់ នឹង បញ្ញវន្ត នៃវណ្ណៈគហបតី ប៉ុណ្ណោះ ដែលអាចនាំ ទៅរកការសម្រេចបាន។

## ទស្សនៈរបស់ លុយកាស (Lukács) ស្តីពី «លក្ខណៈសត្យានុម័ត» (objectivité) នៃ វិទ្យាសាស្ត្រ

ចំពោះ លុយកាស មនោគមវិជ្ជា គ្រាន់តែជា ការឆ្លុះបញ្ចាំងអារម្មណ៍ របស់ វណ្ណៈ គហបតី ដើម្បីរាំងស្កាត់កុំឲ្យវណ្ណៈអធន អាចឈានទៅដល់ ការយល់ដឹង អំពី ទីតាំង នយោបាយ និងតួនាទីធ្វើបដិវត្តន៍ របស់គេតែប៉ុណ្ណោះ។ លុយកាស យល់ថា ការចេះដឹង វិទ្យាសាស្ត្រ អាចមានកល្ខណៈសត្យានុម័តបាន លុះណាតែគេបានដើរដល់ ភាពជាក់ស្តែង ទាំងមូល («totalité concrète») បានសព្វគ្រប់។ សង្គមវិទូ ហុងគ្រី នេះដែលជាអ្នក លើកតម្លៃ លក្ខណៈប្រាកដនិយម នៅក្នុងអក្សរសិល្ប៍ យល់ថា ការពិតផ្នែកសេដ្ឋកិច្ច នៅ ក្នុងសម័យកាលមួយ នៃ ប្រវត្តិសាស្ត្រ ពុំអាចជាការពិត ដែលមានតម្លៃ រហូតនោះ បាន ទេ។

## ទស្សនៈ «សេរីនិយម» របស់បែនស្តែង ( le révisionnisme de d’Eduard Bernstein)

ទស្សនៈសេរីនិយម របស់ បែនស្តែង បានត្រូវអ្នកសង្គម-ប្រជាធិបតេយនៅអ៊ឺរ៉ុប យកមកពិភាក្សាយ៉ាងមមាញឹក ប៉ុន្តែ ក៏បានត្រូវ អ្នកម៉ាក្សនិយមប្រកាន់ក្បួនដើម ដូចជា លេនីន (Lénine) កូតស្គី (Kautsky) និង រ៉ូហ្សា លុចសំបួរ (Rosa Luxemburg) ជា

ដើម រិះគន់យ៉ាងចាស់ដៃដែរ។ បែនស្តែង យល់ថា អ្នកម៉ាក្សនិយម គួរបោះបង់ចោលនូវគំនិត អំណាចផ្តាច់ការ របស់វណ្ណៈអធន (la dictature du prolétariat) និង ការធ្វើបដិវត្តន៍ដើម្បីឈានទៅកសាង របបសង្គមនិយម ហើយត្រូវការពារសេរីភាពបុគ្គល គំនិតសីលធម៌ និងគំនិត សមហេតុសមផល ឲ្យបានចប់ចុងចប់ដើមវិញ។ ពួកអ្នកសេរីនិយមយល់ថា តាមរយៈ ការកែទម្រង់ គេអាចផ្លាស់ប្តូរ របបមូលធននិយម ជាបណ្តើរៗបាន។





# ជំពូក ៨
# ចុះទឹកក្រពើ ឡើងលើខ្លា
## Entre la peste et le choléra

ក្រោយពេលដែល របប «កម្ពុជាប្រជាធិបតេយ្យ» ពោលគឺ ពួកខ្មែរក្រហម គាំទ្រដោយប្រទេសចិនកុម្មុយនិស្ត ត្រូវកងទ័ព វៀតណាម ដែលមានសហភាព សូវៀត នៅពីក្រោយ វាយរំលំចោល នៅដើមឆ្នាំ ១៩៧៩ ប្រជាជនខ្មែរ ត្រូវរស់ក្រោមរបបកុម្មុយនិស្តមួយទៀត។ ប៉ុន្តែ ម្តងនេះ ខ្មែរត្រូវស្ថិតនៅក្រោមនឹម របស់ កងទ័ពបរទេស គឺ ពួកយួនកុម្មុយនិស្ត។ ខ្មែរដែលនៅសល់ពីស្លាប់ ជាពិសេស ទាហាន របស់ លន់ នល់ និង អ្នករដ្ឋការ មានចំនួន តិចណាស់ ព្រោះត្រូវពួកខ្មែរគ្នាឯង សម្លាប់ សឹងតែ ផុតពូជទៅហើយ។ រីឯខ្មែរអ្នកចេះដឹង ដែលជាសត្រូវ ដ៏ធំបំផុត របស់ របបនេះ ក៏ បានត្រូវ ប៉ុល ពត ស្វែងរកឃើញ ហើយសម្លាប់ចោល សឹង តែគ្មាននៅសល់ ព្រោះ ជាគោលដៅសំខាន់បំផុត នៃរបប ប៉ុល ពត។ ទន្ទឹមនឹងការផ្សឹកព្រះសង្ឃ ពួក «ឈ្លប» [16] ស្វែងរកបញ្ញវន្ត តាមគ្រប់មធ្យោបាយ ដើម្បីយកទៅសម្លាប់ចោល។ កាលពេលនោះ សញ្ញាសំគាល់បញ្ញវន្ត គឺ អ្នកពាក់វ៉ែនតា។ ម្ល៉ោះហើយ ពួកឈ្លបទាំងនោះ សម្លាប់អ្នកពាក់វ៉ែនតា ដោយគ្មានសួរហេតុ

[16] ពួកយុវជន នៅតាមភូមិដែល បានត្រូវអង្គការ របស់ ប៉ុល ពត អប់រំឲ្យដើរយកការរកអ្នកដែលក្បត់មាគ៌ា របស់ បដិវត្តន៍ ។ និយាយមួយបែបទៀត គឺ នគរបាល នយោបាយ ( police politique) ។

ផលអ្វីឡើយ ព្រោះ ប៉ុល ពត បានដាក់គោលការណ៍មួយ ដ៏កម្រោល គឺ ដើម្បីកុំឲ្យអ្នកណា ម្នាក់ រត់រួច ត្រូវសម្លាប់ជនជាប់សង្ស័យ ទាំងអស់តែម្តង។ ពេលកងទ័ពវៀតណាមកាន់កាប់ទឹកដីខ្មែរ បញ្ញវន្តខ្មែរខិតខំលាក់ខ្លួនបន្តទៀត ប៉ុន្តែ ជាការឥតប្រយោជន៍ព្រោះត្រូវអ្នកស្គាល់គ្នា ដឹងអស់ទៅហើយ ។ ម្តងនេះ ពួកយួន ចាប់បញ្ជូន អ្នកទាំងនោះ ទៅឲ្យរៀនសូត្រ នៅតាមសាលានយោបាយ នៅក្នុងស្រុក រួចបញ្ជូន ឲ្យទៅរៀនថែមទៀតនៅ ទីក្រុងហូ ជីមិញ ឬ នៅទីក្រុងហាណូយតែម្តង ។ ទន្ទឹម នឹង ពេលនោះដែរ កងទ័ពយួនកុម្មុយនិស្ត បានបង្កើតរដ្ឋបាលមួយ ដឹកនាំដោយ គណ បក្សកុម្មុយនិស្តខ្មែរ ដែលមាន សមាសភាពចម្រុះ គឺពួកខ្មែរក្រហមដែលបះបោរប្រឆាំង នឹង របប ប៉ុល ពត ដូចជា ហេង សំរិនជា សុីម ហ៊ុន សែន ជាដើម ព្រមទាំងពួកខ្មែរ ដែលធ្លាប់ធ្វើសហការ ជាមួយ វៀតមិញដូចជា ប៉ែន សុវណ្ណ រស់ សមយ័ ជា សុទ្ធ ចាន់ សុី ជាដើម និង ពួកដែលទទួលរង គ្រោះតាំងពីថ្ងៃ ១៧ មេសាឆ្នាំ ១៩៧៥ មក ដោយពួក ប៉ុល ពត នៅក្នុងនោះមានបញ្ញវន្តមួយចំនួនដែរ គឺអ្នកដែលត្រូវគេរកឃើញ ហើយ ត្រូវបញ្ជូនទៅឲ្យរៀន នយោបាយ នៅស្រុកយួន ។ សមាសភាពចម្រុះបែបនេះ បាននាំមក នូវ បញ្ហា ដ៏ស្មុគស្មាញ ប៉ុន្តែ នៅទីបំផុត ក៏មានដំណើរការជាបន្តបន្ទាប់។ បញ្ហាសំខាន់បំផុត ដែលចោទឡើង នៅពេលនោះ គឺការដែលខ្មែរស្ថិតនៅក្រោមការកាន់កាប់ របស់ យួន ។ ការរើបម្រាសចេញ ពីអាណានិគមកិច្ចយួន បេះតែមានជានិច្ច តាមមធ្យោបាយដែលអាចធ្វើទៅបាន ប៉ុន្តែ អ្នកតស៊ូ បានត្រូវយួនចាប់យកទៅដាក់គុក រហូតមកទល់ពេលនេះ ឬ ក៏ដកហូតចេញ ពីរដ្ឋាភិបាល និងបក្ស បើអ្នកបះបោរ ទាំងនោះ មាន តួនាទីសំខាន់ នៅក្នុងស្ថាប័ន ទាំងនោះ ។ រវាង ខ្មែរក្រហម ទាំងពីរក្រុមនេះ ខ្មែរដែលរស់នៅ ក្នុងស្រុកស្ថិតនៅក្នុង ការប្រ ទាញប្រទង់ពីរ ៖ គឺ ១) រំដោះខ្លួនចេញពីយួន ២) កុំឲ្យខ្មែរក្រហមវិលមកវិញ។ ការប្រយុទ្ធ នៅឆ្នាំ ១៩៧៩-១៩៨៩ រវាងខ្មែរទាំងពីរក្រុម គឺក្រុមមួយ មានសហភាព សូវៀត ជាបង្អែក ហើយក្រុមមួយទៀត ដែលមាន ការជួយជ្រោមជ្រែង ពីចិន ពីប្រទេសខ្លះ នៃ សមាគមអាស៊ាន និងពី សហរដ្ឋ អាមេរិក -ដែលសង្ឃឹមតែទៅលើកងទ័ពខ្មែរក្រហម- បានឈានមកដល់ភាពទាល់ប្រក ។ នៅទីបំផុត ចិន ក៏សុខចិត្តឲ្យមានដំណោះស្រាយ តាមការចរចា នៅក្នុងក្រប





ខណ្ឌ អន្តរជាតិ តែម្តង ។ ប្រទេសវៀតណាម សុខចិត្ត ឲ្យមានការចរចា ព្រោះនៅពេលនោះ គេបាត់បង្អែកមួយ ដ៏ធំ គឺ សហភាព សូវៀត ។ នៅឆ្នាំ ១៩៨៩ មានបើកសន្និសីទអន្តរជាតិ មួយ នៅទីក្រុងប៉ារីស៍ ដែលតម្រូវ ឲ្យប្រទេសដែលជាប់ពាន់ព័ន្ធ ក្នុងអធិករណ៍ខ្មែរឈប់ធ្វើសកម្មភាព គាំទ្រ ចលនាខ្មែរ ដែល ប្រយុទ្ធគ្នា ។ នៅឆ្នាំ ១៩៩០ ក្រុមប្រឹក្សាសន្តិសុខនៃ អង្គការ សហប្រជាជាតិសម្រេចធ្វើអន្តរាគមន៍ នៅស្រុកខ្មែរដើម្បីនាំសន្តិភាពមកវិញ។ នៅថ្ងៃ ២៣ តុលាឆ្នាំ ១៩៩១ ប្រទេសចំនួន ១៨ បានចុះហត្ថលេខា ទៅលើកិច្ចព្រមព្រៀង សន្តិភាព នៅទីក្រុងប៉ារីស៍។ នៅដើមឆ្នាំ ១៩៩២ អង្គការ សហប្រជាជាតិចាប់ផ្តើមធ្វើ អន្តរាគមន៍ នៅកម្ពុជា។ បេសកកម្ម របស់ អង្គការ សហប្រជាជាតិ បានជួបនឹង ការពិបាកពន់ពេកក្រៃ ប៉ុន្តែ នៅទីបំផុត បានរៀបចំ ការបោះឆ្នោតសេរីបាន នៅឆ្នាំ ១៩៩៣ ។ ការចរចានេះ អាចចេញ ជារូបរាង បាន ព្រោះតែ សហភាព សូវៀត ត្រូវរលំរលាយទៅ ដោយវិបត្តិសេដ្ឋកិច្ច ប៉ុណ្ណោះ។ យួនក៏គ្មានជម្រើសអ្វីទៀត ក្រៅពី ការដកទ័ពសិនជាផ្លូវការ នោះឡើយ ទម្រាំរកបង្អែកបានថ្មីទៀត ។ ប៉ុន្តែ តាមការពិត គ្មានការដកទ័ពទេ គឺ មានតែការប្តូរ ខោអាវប៉ុណ្ណោះទេ។ រីឯកងទ័ពខ្មែរ របស់ ហ៊ុន សែន-ហេង សំរិន ក៏ជាកងទ័ពដែល យួន បានបង្ហាត់ហ្វឹកហ្វឺនដែរ។ យួនយល់យ៉ាងច្បាស់ថា បស្ចិមប្រទេសទោះជា ធ្វើមិនសូវអើពើ នឹង ឥណ្ឌូចិនទៀតក្តី ក៏ មិនទាន់បោះបង់ តំបន់ភូមិសាស្ត្រនោះបោលទាំងស្រុង ទុកឲ្យចិនដែរ នៅក្នុងករណីដែលគេមានឱកាសល្អ និង ជំហរមាំទាំ អាចការពារតំបន់នោះ មិនឲ្យចិនយកបាន។ ក្រោយអន្តរាគមន៍ របស់ អង្គការ សហប្រជាជាតិ បស្ចិមប្រទេស ផ្តល់ជំនួយ ជាច្រើន ដើម្បីកុំឲ្យ ខ្មែរធ្លាក់ ទៅក្នុងភាពរណប នឹង ចិនខ្លាំងពេក។ គេជួយចិន និងខ្មែរក្រហមនៅឆ្នាំ ១៩៧៩-៨៩ ព្រោះគេត្រូវការពារកុំឲ្យ សហភាព សូវៀត យកតំបន់នោះតែប៉ុណ្ណោះ ។ លុះ សហភាព សូវៀត រលំរលាយទៅ សហរដ្ឋ អាមេរិក ត្រូវទប់កុំឲ្យចិន មកជំនួស សហភាព សូវៀត ម្តងវិញ។ ខាងសហភាព សូវៀតឯណោះវិញ ទោះជាមានវិបត្តិ យ៉ាងណាក្តី ក៏គេ មិនចង់ឲ្យ ចិន យក តំបន់នោះដែរ ។ ដើម្បីយកជ័យជំនះទៅលើយួនបាន ចិនគ្មានជម្រើសអ្វីទៀត ក្រៅពីរកដំណោះស្រាយអន្តរជាតិ សិនឡើយ ។ ពេលបោះឆ្នោតសេរី នៅឆ្នាំ ១៩៩៣ បក្សរាជានិយម ដែលមានចិន

គាំទ្រ បានទទួលជ័យជំនះ ប៉ុន្តែ នៅតែដណ្តើមយកអំណាចពី យួនមិនបានដដែល។ ប៉ុន្តែ ដោយគេ ពុំចង់ឲ្យបស្ចិមប្រទេសត្រឡប់មកវិញ ចិនព្យាយាមត្រូវរ៉ូវជាមួយយួនវិញដោយសង្ឃឹមថា យួនមិនអាចគេច ពីចិនបានទេ។ ប៉ុន្តែ ទំនាស់ រវាង យួន និង ចិន ស្តីពីកោះស្ប្រាតឡេ និង ប៉ារ៉ាសែល មិនមែនត្រឹមតែជា ឧបសគ្គមួយ ដ៏ធំ នៅក្នុងទំនាក់ទំនង រវាង យួន និងចិនប៉ុណ្ណោះទេ។ កោះទាំងនោះ ក៏ជាតំបន់យុទ្ធសាស្ត្រមួយ ដ៏សំខាន់ របស់បស្ចិមប្រទេសផងដែរ ។ ម្យ៉ាងទៀត ហូ ជីមិញ បានផ្តាំថា កុំឲ្យទុកចិត្តចិនឲ្យសោះ ហើយ ត្រូវរកមិត្តពីទីឆ្ងាយវិញ ទើប ធានា បូរណភាពដែនដីយួនបាន។ គឺ នៅក្នុងយុទ្ធសាស្ត្រ របស់ចិន ដែលមានគោលបំណងក្តាប់អតីតឥណ្ឌូចិនបារាំង និង តំបន់ទាំងមូល នេះហើយ បានជាសម្តេច នរោត្តម សីហនុ ចង់ឲ្យលោក ហុន សែន និង ព្រះអង្គម្ចាស់រណឫទ្ធិ រួបរួមគ្នាទប់ទល់ នឹង ការវិលមកវិញ របស់ពួកបស្ចិមប្រទេស តាមរយៈគណបក្សបស្ចិមប្រទេសនិយមណាមួយនៅក្នុងការបោះឆ្នោតត្រឹមត្រូវ។ ទីក្រុងប៉េកាំង បានជំរុញឲ្យសម្តេចនរោត្តម សីហនុ ដើរតួជា អ្នកបង្រួបបង្រួមក្រុមខ្មែរបដិបក្ខ ទាំងអស់ ជាពិសេសធ្វើយ៉ាងណា ក្តាប់លោក ហ៊ុន សែន ឲ្យបាន ។ ទីក្រុងប៉េកាំង ក៏ខិតខំធ្វើការទូត ជាមួយ លោក ហ៊ុន សែន យ៉ាងខ្លាំងណាស់ដែរ ដោយអញ្ជើញ លោក ហ៊ុន សែន ឲ្យទៅ ធ្វើទស្សនកិច្ចជាផ្លូវការនៅប៉េកាំង ។ គឺតាំងពីពេលនោះមកហើយ ដែលកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ឆ្នាំ ១៩៩១ បានដើរមកដល់ ផ្លូវបត់មួយទៀត ព្រោះ អ្នកដឹកនាំខ្មែរ ពុំព្រមយកលទ្ធផល នៃការបោះឆ្នោតជាធំ។ ដោយខ្លាចចិនដណ្តើមយកអំណាចបាន តាមរយៈព្រះអង្គម្ចាស់រណឫទ្ធិ រដ្ឋប្រហារមួយ បានផ្ទុះឡើង នៅខែកក្កដា ឆ្នាំ ១៩៩៧ ។ គឺនៅពេលនោះហើយ ដែលយួនក្តាប់យកស្រុកខ្មែរបាន សាជាថ្មីទៀត។ ប៉ុន្តែ យួនអាចក្តាប់ស្រុកខ្មែរបាន លុះណាតែមានបង្អែកសេដ្ឋកិច្ច មួយដ៏មាំ។ បើពុំនោះសោតទេ គឺ ពុំអាចធ្វើទៅបានឡើយ ព្រោះចិនជាប្រទេសមួយ ដែលមានកម្លាំងខ្លាំងក្លា ។ តាមការពិត ចិន ក៏ដូចជា សម្តេច នរោត្តម សីហនុ ដែរ មានអរិភាព ជាមួយបស្ចិមប្រទេស ជាង ជាមួយយួនទៅទៀត។ ហេតុដូច្នេះហើយ បានជាចិនសុខចិត្តត្រូវជាមួយ ហ៊ុន សែន ជាងត្រូវជាមួយគណបក្សនយោបាយរបស់ បញ្ញជនខ្មែរ ដែលខ្មែរក្រហម បានខិតខំសម្លាប់ ស្ទើងតែផុតពូជអស់នៅឆ្នាំ ១៩៧៥-





១៩៧៩។ យុទ្ធសាស្ត្រជាមូលដ្ឋានរបស់ចិន គឺ យកតំបន់ទាំងមូល មកដាក់ក្រោម ឥទ្ធិពលរបស់គេ។ រីឯឧបសគ្គ គឺ បញ្ញវន្តទាំងនោះ ដែលសុទ្ធសឹងជា អ្នកនិយមលទ្ធិប្រជាធិបតេយ្យ តាមបែបបស្ចិមប្រទេស និង ជាអ្នកស្រឡាញ់ ការពារសិទ្ធិមនុស្ស ដូចយុវជនចិនដែល រដ្ឋអំណាចចិន បានបង្ក្រាប យ៉ាងព្រៃផ្សៃ នៅ ទីវាល តៀន អាន់ ម៉េន កាលពីឆ្នាំ ១៩៨៩ ដូច្នេះដែរ។

# បដិវត្តន៍ ល្បីៗ នៅក្នុង សកលលោក

## Les révolutions les plus célèbres dans le monde

បដិវត្តន៍ មានន័យថា ការប្តូររបបនាសម្ព័ន្ធ នៃ របៀបគ្រប់គ្រងប្រទេស ដើម្បីឈានទៅ ធ្វើការផ្លាស់ប្តូររបបដឹកនាំ និង របៀបរស់នៅ ចាស់ចេញ ហើយ កសាង របបមួយថ្មីទៀត ដែលប្រសើរជាង ។ បដិវត្តន៍ កន្លងមក ដែលយើងបានដឹងតាមរយៈប្រវត្តិសាស្ត្រ ច្រើនតែនាំមក នូវការបង្ហូរឈាម និងសង្គ្រាមផ្ទៃក្នុង ហើយត្រូវចាយពេលជាច្រើន មុននឹងឈាន មកដល់ស្ថិរភាព ។ ទំនាស់នេះ បណ្តាលមកពី ការប្រើ អំពើហិង្សា ដែលគេយល់ថា ជាផ្លូវតែមួយគត់ ដែលនាំទៅរក ការសម្រេចគោលដៅ។ កត្តាមួយទៀត នៃ ការបង្ហូរឈាម គឺការដែលអ្នកកាន់អំណាច ប្រើអំពើហិង្សា យ៉ាងខ្លាំងក្លា ដើម្បីបង្ក្រាប អ្នកបះបោរ។ តាមការពិត សង្គម វិវត្ត ជារៀងរាល់ថ្ងៃ ប៉ុន្តែ ដោយវិបត្តិសង្គម និងស្ថាប័ន មានលក្ខណៈធ្ងន់ធ្ងរពេក ហើយ ដោយការគាបសង្កត់ ពី សំណាក់ អ្នកកាន់អំណាច ពុំអាចឲ្យអ្នកបដិវត្ត ទ្រាំទ្របាន បដិវត្តន៍ ក៏ផ្ទុះឡើងដោយគ្មានអ្វីអាចទប់ទល់បានឡើយ។ រីឯការប្តូររបនាសម្ព័ន្ធ ក៏ជួបនឹង ការខ្វែងគំនិតគ្នា នៅក្នុងជួរអ្នកបដិវត្តផងទៀត។

# បដិវត្តន៍ បារាំង ឆ្នាំ ១៧៨៩

បដិវត្តន៍បារាំង នាឆ្នាំ ១៧៨៩ ចាយពេលអស់ ១០ ឆ្នាំ (១៧៨៩-១៧៩៩) ហើយ ប្រល័យជីវិតមនុស្ស អស់ជាច្រើនរយពាន់នាក់ ទើបបានរកផ្លូវឃើញ។ គ្រាន់តែអ្នកដែល ត្រូវគេយកទៅកាត់កចោល នៅក្នុងការប្រយុទ្ធទប់ទល់ នឹង អ្នកប្រឆាំងបដិវត្តន៍ នៅ វ៉ង់ឌេ (guerre de Vendée) មានចំនួន ១៦.៥៩៤ នាក់ ។ បដិវត្តន៍ បារាំងនាឆ្នាំ ១៧៨៩ ជា ការ វាយរំលំ របបរាជានិយមផ្តាច់ការដែលបាននាំប្រទេស ឲ្យធ្លាក់ទៅក្នុង វិបត្តិ ហិរញ្ញវត្ថុ និង ទុរ្ភិក្សមួយដ៏ធំ។ ទោះជាយ៉ាងនេះក្តី របបរាជានិយម បានវិលមកវិញនៅឆ្នាំ ១៨១៥ ក្រោយ រដ្ឋប្រហារ របស់ ណាប៉ុឡេអុង (ទី១) ឆ្នាំ ១៨៩៩ (coup d’Etat du 18 Brumaire) និង ក្រោយការរលំរលាយ នៃចក្រភពបារាំងនៅឆ្នាំ ១៨១៥ គឺ ចក្រភពដែល ណាប៉ូឡេអុង បានបង្កើតនៅឆ្នាំ ១៨០៤ ។ បើគិតពី ការប្រែប្រួល ដែលមានជាហូរហែ តាំង ពីឆ្នាំ ១៧៨៩ មកដល់ ឆ្នាំ ១៧៩៩ តែម្តង បដិវត្តន៍ បារាំង បានឆ្លងកាត់ដំណាក់ការ ជាច្រើន ។

នៅឆ្នាំ ១៧៨៨ អំណាច ដែលគ្រប់គ្រងប្រទេសបារាំង ជា របបរាជានិយមផ្តាច់ការ ទេវសិទ្ធិ (monarchie absolue de droit divin) មានន័យថា ស្តេចបានទទួលអំណាច ពីព្រះ គឺខុសពី របបរាជានិយម អង់គ្លេស ដែលអំណាច របស់ ស្តេច ត្រូវដើរទន្ទឹម នឹង អំណាច របស់រដ្ឋសភាដែលបានត្រូវជ្រើសតាំង ដោយប្រជាពលរដ្ឋ ។ ទស្សនវិទូ ហ្សង់-ហ្សាក់ រូស្សូ (Jean-Jacque Rousseau, ១៧១២-១៧៧៨) យល់ឃើញថា អំណាច របស់ អ្នកដឹកនាំ ត្រូវចេញពីប្រជាជាតិ។ ទស្សនៈនេះ របស់ រូស្សូ ខុសទាំងស្រុងពី ទស្ស នៈ របស់ វ៉ុលទែរ (Voltaire, ១៦៩៤-១៧៧៨) ដែលយល់ថា អំណាចស្តេចត្រូវឈរ នៅលើ វិចារណញ្ញាណ (despotisme éclairé) ។ ដូច្នេះឃើញថា វ៉ុលទែរមិនចង់បំបាត់ ស្តេចទេ ក៏ ប៉ុន្តែ ដោយលោក មិនទទួលស្គាល់ តួនាទី របស់ សាសនា ក៏បានត្រូវ គេចាត់ទុក ថាជាទស្សនវិទូ នៃក្រុម ទស្សន វិទូ វិចារណញ្ញាណនិយម នៃ «សតវត្សរ៍ពន្លឺ» (un des philosophes des Lumières) ផងដែរ ។ គំនិត របស់ ទស្សនវិទូ នៃ «សតវត្សរ៍ពន្លឺ » ជាមូលដ្ឋានមួយ ដ៏សំខាន់ នៃ ការវាយរំលំ របបរាជានិយម ប៉ុន្តែ កត្តាឧបហេតុ គឺ ស្ថាន





ភាពសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលបានធ្លាក់ចុះដុនដាបយ៉ាងខ្លាំង ជាពិសេស គំនិត អយុត្តិធម៌ ស្តីពីការទារពន្ធដារ។ ពួកអភិជន មិនបង់ពន្ធឡើយ តែត្រូវចេញទៅធ្វើសង្គ្រាម បម្រើរាជាណាចក្រ បារាំង (« l’impôt du sang ») ។ រីឯពលរដ្ឋ តតិយរដ្ឋ (le Tiers Etats) គឺពលរដ្ឋ ដែលមិនមែនជាអភិជន ឬ មិនមែនជា មន្ត្រីខាងសាសនា ហើយដែលមានចំនួន ៩៥ % នៃ ប្រជាជន ត្រូវបង់ពន្ធយ៉ាងធ្ងន់ធ្ងរ ទោះបី ពួកគេជាអ្នកផលិតទ្រព្យសម្បត្តិ ឲ្យ សង្គមក្តី ។ ចំពោះ ពន្ធមុខរបរ ក៏ខុស គ្នាដែរនៅតាមខេត្រមួយចំនួន។ ការកែទម្រង់នានា ក៏ពុំបានហុច នូវលទ្ធផលអ្វីទាំងអស់។ ទោះបីកាលនោះ ប្រជាជន បារាំងមានជំនឿទៅលើ តួនាទី របស់ស្តេចក៏ដោយ ក៏គេយល់ ឃើញថាត្រូវតែកែប្រែរបទាសម្ព័ន្ធ នៃអំណាច និង សង្គម ប៉ុន្តែ គេក៏ពុំដែលនឹកស្មានថា ការកែប្រែនេះ នាំទៅរក អំពើហឹង្សាយ៉ាងខ្លាំង ដូច្នេះ ឡើយ។ ស្តេច ល្វី ទី ១៥ និង ល្វី ទី ១៦ ក៏យល់ថា គំនិត របស់បណ្តាទស្សនវិទូ ក៏មិន ខុសដែរ ប៉ុន្តែស្តេចទាំងពីរអង្គនេះ គ្មានកម្លាំងគ្រប់គ្រាន់ដូចល្វីទី ១៤ ឡើយ ដើម្បីបញ្ជា ឲ្យពួកអភិជន ធ្វើការកែប្រែរបទាសម្ព័ន្ធ ឲ្យស្របនឹង វិចារណញ្ញាណ។ បើគិតពីដំណើរ ច្បាប់ បដិវត្តន៍បារាំង ចាប់ផ្តើមពីចុងខែឧសភា និង ដើមខែកក្កដាឆ្នាំ ១៧៨៩ គឺពេល បើកអង្គប្រជុំ សភាប្រជាជាតិ «អេតា ហ្សេណេរ៉ូ » (Etats-généraux) ។ នៅ ថ្ងៃ ១ ឧសភាឆ្នាំ ១៧៨៩ តាមការកោះហៅ របស់ ស្តេចល្វីទី ១៦ ពួកអ្នកតំណាងរាស្ត្រ បាន មកដល់ រាជវាំងវែរសាយ។ អ្នកតំណាងពួកអភិជន ដែលមានចំនួន ២៧០ នាក់ ហើយ ពួកមន្ត្រីសាសនា ដែលមានចំនួន ២៩១ នាក់ បានត្រូវទទួលយ៉ាងឱឡារិក រីឯ ពួកតតិយរដ្ឋ ដែលមានចំនួនដល់ទៅ ៥៨៤ នាក់ ពុំបានត្រូវគេយកចិត្តទុកដាក់ឡើយ។ ប្រជាជន បារាំង មានសេចក្តីសង្ឃឹមខ្លាំងណាស់ទៅលើអង្គប្រជុំ នៃ សភាប្រជាជាតិនេះ ។ ពួកគេ សង្ឃឹមថា ជីវភាពរបស់ពួកគេ មុខជានឹងបានធូរស្រាល។ ខ្លះថែមទាំង ជឿថា បុព្វសិទ្ធិ របស់ ពួកម្ចាស់ដី នឹង ត្រូវលុបចោលទៀតផង ។ ពួកវណ្ណៈគហបតី (la bourgeoisie) គេជឿរហូតដល់ទៅថា អង្គប្រជុំនេះ នឹងនាំមក នូវសមភាព និងការបង្កើតរបបរាជានិយម អាស្រ័យសភា (monarchie parlementaire) ទៀតផង។ ប៉ុន្តែពេលបើកអង្គប្រជុំ នៅថ្ងៃ ៥ ឧសភា ល្វី ទី ១៦ គំរាមថា នឹងមិនឲ្យមាន គំនិតថ្មី អ្វីទាំងអស់។ រីឯ ណេចកែរ ទេស

រដ្ឋមន្ត្រីហិរញ្ញវត្ថុ ពុំលើកឡើងអំពី ការកែទម្រង់អ្វីទាំងអស់ ។ ពួកអ្នកតំណាង តតិយរដ្ឋ (៥៨៤ នាក់) ពុំព្រមឲ្យមាន ការបោះឆ្នោត តាមក្រុមវណ្ណៈទេ ហើយ ទាមទារឲ្យ មានការបោះឆ្នោតចូលគ្នាតែម្តង។ គ្មានសេចក្តីសម្រេចអ្វីទាំងអស់ ពីបញ្ហានេះ។ ពួក តតិយរដ្ឋ រង់ចាំអស់រយៈពេល មួយខែ រួច នៅថ្ងៃ ១៧ មិថុនា ក៏ ប្រកាសពួកគេ ថាជា រដ្ឋសភាតែម្តង តាមសេចក្តីស្នើ របស់ ស្បេយ៉េស (Sieyes) ។ ពួកអភិជន និង ពួកអ្នកតំណាងសាសនា មួយចំនួន ក៏ បានចូលរួមផងដែរ ។ ប៉ុន្តែ នៅថ្ងៃ ២០ មិថុនា ស្តេច ល្វីទី ១៦ បញ្ជាឲ្យគេបិទបន្ទប់ប្រជុំ ប៉ុន្តែ ពួកតតិយរដ្ឋ នាំគ្នាទៅរកបន្ទប់ប្រជុំមួយទៀត ។ ពួកគេ ថែមទាំងសន្យាថា នឹង មិនចេញពី អង្គប្រជុំឡើយ ដរាបណា ពួកគេ ធ្វើរដ្ឋធម្មនុញ្ញ មួយជាលាយលក្ខណ៍អក្សរ ឲ្យប្រទេសបារាំង មិនបានទេនោះ។ នៅថ្ងៃ ២៣ មិថុនា ស្តេច ល្វីទី ១៦ បើកអង្គប្រជុំមួយដែលមានអ្នកតំណាងទាំងបីគណៈ (អភិជន អ្នកតំណាងសាសនា និង តតិយរដ្ឋ) ប៉ុន្តែ ឲ្យប្រជុំគ្នាក្នុងបន្ទប់ផ្សេងពីគ្នា។ ពួកអភិជន និងអ្នកតំណាង សាសនា ធ្វើតាមបញ្ជា របស់ ស្តេច ប៉ុន្តែ ពួកអ្នកតំណាងតតិយរដ្ឋ និង ពួកអ្នកតំណាងសាសនាថ្នាក់ទាប ពុំព្រមធ្វើតាមឡើយ ។ អ្នកតំណាងតតិយរដ្ឋ (Bailly) ថ្លែងថា ៖ ពួកយើង ដែលជាអ្នកតំណាងប្រជាជាតិបារាំងទាំងមូល គ្មានត្រូវទទួលបញ្ជាអ្វី ពី ស្តេចទេ។ មៀរ៉ាបូ (Mirabeau) និយាយបន្ថែមទៀតថា ៖ «ពួកយើងមកទីនេះ ដោយធ្វើតាមឆន្ទៈ របស់ប្រជាពលរដ្ឋ ហើយយើងនឹងចេញពីទីនេះ បើគេប្រើកាំបិទ បៃយ៉ូណែត ដេញពួកយើង» ។ ពួក អភិជនប្រមាណជាង ៥០ នាក់ និង ពួកអ្នកតំណាងសាសនាថ្នាក់ទាប ចូលរួមចំណែក ជាមួយពួកតតិយរដ្ឋ។ នៅចំពោះមុខសភាពការណ៍នេះ ល្វីទី ១៦ ក៏ សុខចិត្ត ឲ្យគណៈទាំងបី ចូលរួមប្រជុំ ជាមួយគ្នា ។ ទោះជាយ៉ាងនេះក្តី ដោយ ពួកតតិយរដ្ឋមាន ចំនួន ច្រើនជាង គេក៏ប្រែក្លាយ សភា ប្រជាជាតិនេះ ឲ្យទៅជា សភាធម្មនុញ្ញ (Constituante) តែម្តង។ នៅក្នុង រយៈពេលប៉ុន្មានថ្ងៃនោះ សភាប្រជាជាតិ បានសម្រេចការធ្វើ បដិវត្តន៍ មួយជំហាន ដ៏ធំ ពុំអាច បកក្រោយមកវិញ បានឡើយ ។ ដោយមានការភិតភ័យ អ្នកតំណាងរាស្ត្រ នៃ គណៈទាំងពីរទៀត គ្មានជម្រើសអ្វីទៀត ក្រៅពីសុំដកខ្លួនថយ ហើយសុំលាលែង ពីមុខតំណែងឡើយ។ គេអាចនិយាយបានថា ព្រឹត្តិការណ៍នេះ



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ជាការសម្រេច នៃ ការអនុវត្តន៍ គោលការណ៍ អធិបតេយ្យ របស់ ប្រជាជាតិ (souveraineté nationale) តាមទស្សនទាន របស់ ឌីដ្រូ (Diderot, ១៧១៣-១៧៨៤)។ ស្តេច ល្វីទី ១៦ នៅពេលនោះ ហាក់បីដូចជា បណ្តោយឲ្យ អ្នកតំណាង តតិយរដ្ឋ បន្តកិច្ចការ របស់ ពួកគេ ប៉ុន្តែ ស្រាប់តែនៅថ្ងៃ ២៦ មិថុនា បានហៅឲ្យកងទ័ពបរទេសចំនួន ២ ម៉ឺន នាក់ ចូលមកក្នុងរាជធានី តែម្តង ។ ពួកគហបតី មានការខកចិត្តយ៉ាងខ្លាំង ។ នៅដើមខែ កក្កដា ការរំជើបរំជួល កើតមានឡើង នៅកន្លែង ទារពន្ធ [១៧] (barrières d’octroi) ។ ល្វីទី ១៦ ដកហូត រដ្ឋមន្ត្រីដែលមានគំនិតសេរីនិយម ដូចជា ណេចកែរ ជាដើម ចេញពីមុខតំណែង ។ នៅពេលថ្ងៃរសៀល នាថ្ងៃ ១១ កក្កដា អ្នកកាសែត កាមីយ ឌេមូឡាំង (Camille Desmoulin.) បានបំផុសបំផុល ឲ្យប្រជាជន ត្រៀម លក្ខណៈការពារខ្លួន ។ នៅពេលដដែលនោះ នៅក្នុង ឧទ្យាន ទ្វីឡឺរី និង អាំងវ៉ាលីដ ប្រជាជនទីក្រុងប៉ារីស៍ ពើបប្រទះ នឹង កងទ័ពបរទេស ដែលមកជួយស្តេចបារាំង។ នៅថ្ងៃ ១៣ កក្កដា ប្រជាជន បាននាំគ្នាដុតកំទេច ការិយាល័យទារពន្ធ ចំនួន ៤០ ។ ពួកគហបតី បានបង្កើត កងស្វ័យត្រាណមួយ សម្រាប់ធ្វើប្រតិបត្តិការទប់ទល់ ។ ការផ្ទុសផ្តុល កាន់តែមានទំហំ ធំឡើងៗ ។ នៅ ព្រឹកថ្ងៃ ១៤ កក្កដា ឆ្នាំ ១៧៨៩ ពួកអ្នកបះបោរនាំគ្នាទៅរកអាវុធ នៅក្នុងអាគារអាំងវ៉ាលីដ បន្ទាប់មក ធ្វើដំណើរទៅរកគ្រាប់រំសេវ នៅ ពន្ធនាគារបាស្ទីយ៍ ហើយជួប នឹងក្រុមអ្នកបះបោរមួយក្រុមធំទៀត។ ពួកអ្នកបះបោរ បាននាំគ្នា កំទេចគុកបាស្ទីយ៍ ដែលជានិមិត្តរូប នៃអំពើអយុត្តិធម៌ របស់ ស្តេច។ ការប្រយុទ្ធគ្នាមានលក្ខណៈ ដ៏ខ្លាំងក្លា។ មនុស្សជាច្រើន បានបាត់បង់ជីវិត។ បន្ទាប់មក ពួកបះបោរនាំគ្នាដើរទៅ សាលាក្រុងប៉ារីស៍ ហើយ កាត់កចៅហ្វាយក្រុងឈ្មោះផ្លេស្សែល (Flesselles)។ ការវាយកំទេចគុកបាស្ទីយ៍ នៅថ្ងៃ

[១៧] នៅឆ្នាំ ១៧៨៥ ស្តេចល្វី ទី ១៦ បានឲ្យបើកកន្លែងយកពន្ធ (barrières d’octroi) ចំនួន ៥៧ នៅជុំវិញទីក្រុង។ ការទារពន្ធបែបនេះកាន់តែមានលក្ខណៈតឹងរ៉ឹងឡើងៗ នៅឆ្នាំ ១៧៨៩ ហើយដែលជាហេតុ នាំទៅរកការបះបោរ ដែលកើតមាន ពីរ-បី ថ្ងៃ មុនការវាយបន្ទាយ បាស្ទីយ៍ (La Bastille)។

១៤ កក្កដាឆ្នាំ ១៧៨៩ ដោយប្រជាជនទីក្រុងប៉ារីស៍ បានត្រូវគេចាត់ទុកថា ជា ការរលំរលាយ នៃ របបរាជានិយមផ្ដាច់ការ ហើយជា ការចាប់ផ្ដើម នៃ បដិវត្តន៍បារាំង ។ ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនេះ បានត្រូវប្រជាជននៅតាមខេត្រ ដឹងគ្រប់គ្នា ហើយអ្នកស្នេហាជាតិក៏នាំគ្នា បង្កើត គណកម្មាធិការបដិវត្តន៍ ជាបន្ទាន់ ។ នៅទីក្រុងខ្លះ ពួកគេ បានវាយយកអំណាច តាមខេត្រ-ក្រុង បានផងទៀត ។ នៅក្នុងរាត្រីថ្ងៃ ៤ សីហា សភាធម្មនុញ្ញដែលបានត្រូវចាត់តាំងនៅថ្ងៃ ៩ កក្កដាឆ្នាំ ១៧៨៩ ដដែលនោះ ប្រកាសលុបចោល បុព្វសិទ្ធិ និង សិទ្ធិ នានា របស់ ពួកស្ដេចត្រាញ់ សក្ដិភូមិ ព្រមទាំង វិសមភាព ក្នុងការទារពន្ធដារ ដោយរក្សាទុកសិទ្ធិ របស់ ពួកម្ចាស់ដី និង កម្មសិទ្ធិ របស់ កសិករអ្នកមាន ។ នៅថ្ងៃ ២៦ សីហា សភាធម្មនុញ្ញ បានអនុម័តសេចក្ដីថ្លែងការណ៍ សិទ្ធិមនុស្ស និង សិទ្ធិ របស់ពលរដ្ឋ (Déclaration des Droits de l’Homme et du Citoyen) ដោយយកតាមគំនិត របស់ទស្សនវិទូ «ពន្លឺ នៃ វិចារណញ្ញាណ» (philosophes des Lumières) នាសម័យនោះ។ របបរាជានិយមផ្ដាច់ការ បានក្លាយទៅជា របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ។ អំណាចស្ដេច ចុះខ្សោយជាលំដាប់ ។ពួក្ខគហបតី (la bourgeoisie) ឡើងកាន់កាប់អំណាច ។ ការភៀសខ្លួន របស់ល្វីទី ១៦ ទៅវ៉ារ៉ែន នៅថ្ងៃ ២០ មិថុនាឆ្នាំ ១៧៩១ និង ការប្រកាសសង្គ្រាម របស់ ប្រទេសអូទ្រីសនាថ្ងៃ ២០ មេសាឆ្នាំ ១៧៩២ ការទទួលបរាជ័យ ស្ថានភាពចុះដុនដាប នៃ សេដ្ឋកិច្ច និង សង្គម បានជំរុញឲ្យអ្នកបដិវត្ត ដកហូតអំណាចពីស្ដេចប្រគល់ទៅឲ្យគណកម្មាធិការប្រតិបត្តិ បណ្ដោះអាសន្ន ដឹកនាំដោយ ដង់តុង ។ នៅថ្ងៃ ២០ កញ្ញាឆ្នាំ ១៧៩២ បន្ទាប់ពី កងទ័ពប្រទេសព្រុស (Prusse) ដកចេញពី វ៉ាល់មី រដ្ឋសភាប្រគល់ អំណាច ទៅឲ្យ សភាធម្មនុញ្ញ កុងវ៉ង់ស្យុង (La Convention) ដែលប្រកាសរបប សាធារណរដ្ឋ ដោយគ្មានបង្អង់ (ថ្ងៃ ២១ កញ្ញាឆ្នាំ ១៧៩២)។ ជ័យជំនះរបស់ កងទ័ពបដិវត្តន៍ នៅ វ៉ាល់មី បានលើកទឹកចិត្ត ឲ្យបដិវត្តន៍ វាយលុកប្រទេសជិតខាង ដើម្បីពាំនាំគំនិតថ្មី ទៅផ្សព្វផ្សាយ នៅក្នុងប្រទេសទាំងនោះ ។ ប៉ុន្តែនៅដើមឆ្នាំ ១៧៩៣ សភា កុងវ៉ង់ស្យុង ហៀប តែនឹងធ្វើឲ្យរបបសាធារណរដ្ឋ បារាំងរលាយទៅវិញ ព្រោះតែមាន ទំនាស់ផ្ទៃក្នុង រវាង ក្រុមហ្យាក់កូបាំង (Jacobins) ដែលជាអ្នកសាធារណរដ្ឋនិយមដាច់ខាត និង





ក្រុម ហ្សៀរ៉ុងដាំង (Girondins) ដែលមានគំនិតមិនច្បាស់លាស់ (ម្ដង វាយរំលំរបបរាជានិយមផ្ដាច់ការ ម្ដងចង់ជួយស្ដេច )។ បន្ទាប់ពីគេយកស្ដេច ល្វី ទី ១៦ ទៅកាត់ក នៅថ្ងៃ ២១ មករាឆ្នាំ ១៧៩៣ ការបះបោរនៅផ្នែកបស្ចិម និងនៅផ្នែកអាគ្នេយ៍ក៏ផ្ទុះឡើង។ ប្រទេសអង់គ្លេស និង ប្រទេសដែលមានស្ដេចដូចគ្នា ចងសាមគ្គីភាពគ្នា បង្កើតកម្លាំងចម្រុះ ដើម្បីវាយប្រហារ បដិវត្តន៍បារាំង ។ នៅប្រទេសបារាំង ឯនេះវិញ បន្ទាប់ពីចាញ់សង្គ្រាម ពួកហ្យាក់កូបាំង យកឈ្នះទៅលើ ពួកហ្សៀរ៉ុងដាំង បាន ហើយ ក៏ បង្កើត រដ្ឋាភិបាលបដិវត្តមួយ (Comité du Salut public) ។ គឺនៅពេលនោះហើយ ដែលពួកគេបង្កើតបរិយាកាសភេរវកម្ម ពេញប្រទេស ហើយ ឲ្យលុបបំបាត់ សាសនាគ្រឹស្ត ជាបណ្ដើរៗផងទៀត។ ប៉ុន្តែ នៅថ្ងៃ ២៧ កក្កដា ឆ្នាំ ១៧៩៤ ពួកឆ្វេងហ្យាក់កូបាំង ក៏អស់ខ្យល់ ហើយ រ៉ូបេសព្យែរ ក៏ឡើងមកកាន់អំណាច នៅគណកម្មការបដិវត្តន៍ បន្ទាប់ពីបានយកដង់តុង ទៅកាត់ក នៅថ្ងៃ ៥ មេសាឆ្នាំ ១៧៩៤។ រ៉ូបេសព្យែរ បាននាំសាសនាគ្រឹស្តមកវិញ។ ប៉ុន្តែ ដោយអ្នកតំណាង នៅសភាបដិវត្តន៍ កុងវ៉ង់ស្យុង ដែលមាន មតិភាគច្រើនក្នុងចំណោម អ្នកតំណាងទាំងអស់ចំនួន ៧៤៩ នាក់ ចង់ប្ដូរនយោបាយ ភេរវកម្មចេញ រ៉ូបេសព្យែរក៏ បានត្រូវគេយកទៅកាត់ក នៅថ្ងៃ ២៨ កក្កដា ឆ្នាំ ១៧៩៤ ដដែលនោះ វិញដែរ ។ សភាធម្មនុញ្ញបដិវត្តន៍ ក្រោយការប្រហារជីវិត រ៉ូបេសព្យែរ (ថ្ងៃ ២៧ កក្កដាឆ្នាំ ១៧៩៤ ត្រូវនឹង ថ្ងៃ ៩ ទែរមីឌ័រ តាមប្រតិទិន សាធារណរដ្ឋ ) បាន អនុវត្ត នយោបាយប្រឆាំង នឹង អំពើភេរវកម្មប្រឆាំងនឹងទស្សនៈ របស់ពួកហ្យាក់កូបាំង។ ពីឆ្នាំ ១៧៩៥ ដល់ឆ្នាំ ១៧៩៩ ប្រទេសបារាំងស្ថិតនៅក្រោម ការដឹកនាំ របស់អង្គការ ប្រតិបត្តិមួយ (le Directoire) ដែលមាន សមាជិក ៥ នាក់។ នៅក្រោមការដឹកនាំរបស់ អង្គការ ឌៀរេចទ័រនេះ អំពើពុករលួយ កើតមានឡើងក្នុងទូទាំងប្រទេស ។ មានតែកងទ័ពបារាំងប៉ុណ្ណោះ ដែលក្រោមការដឹកនាំ របស់ឧត្តមសេនីយ៍ ណាប៉ូឡេអុង បូណាប៉ាក រក្សា កិត្យានុភាពបាន ។ ណាប៉ូឡេអុង បូណាប៉ាកជាឧត្តមសេនីយ៍ម្នាក់ដ៏ពូកែ ហើយ បានទទួលជ័យជំនះ ស្ទើរតែនៅគ្រប់សមរភូមិ ។ អ្នកដឹកនាំ ឌៀរ៉េចទ័រ ម្នាក់ឈ្មោះ សេយៀស (Sieyès) បានឆ្លៀតប្រើឥទ្ធិពល របស់ បូណាប៉ាក ដើម្បីធ្វើរដ្ឋប្រហារ រំលំអង្គការ ឌៀរ៉េចទ័រ នោះចោលតែម្ដង (coup d’Etat du 19

brumaire an VIII) ។ ប៉ុន្តែ ណាប៉ូឡេអុង ដែលជា អ្នកដឹកនាំរដ្ឋប្រហារនេះ បានក្លាយទៅជាម្ចាស់ នៃ រដ្ឋប្រហារនោះតែម្តង។ នៅក្នុងរាត្រី ថ្ងៃ ២៧ កក្កដា ឆ្នាំ១៧៩៤ (19 brumaire An VIII) នោះ ណាប៉ូឡេអុង បូណាប៉ាក់ បានឲ្យគេ តែងតាំងខ្លួនជា កុងស៊ុលទី ១ នៃសាធារណរដ្ឋបារាំង ដោយគ្មានបង្អង់។ សាធារណមតិ អបអរសាទរ ចំពោះសេចក្តីសម្រេចនេះ ហើយមានសំណូមពរតែពីរ ប៉ុណ្ណោះ គឺ សន្តិភាព និងសណ្តាប់ធ្នាប់។ ណាប៉ូឡេអុង កាន់អំណាច ដោយប្រើអាជ្ញា យ៉ាងតឹងរ៉ឹង ប៉ុន្តែ កិត្យានុភាព របស់អនាគតព្រះចៅអធិរាជបារាំងនេះ បានត្រូវពង្រឹងនៅលើជំហរ ៥ យ៉ាង គឺ ៖ ១) ការចុះហត្ថលេខាទៅលើ អនុរូបសញ្ញា ជានាជាមួយ គ្រិស្តសាសនា (concordat du 6 juillet 1801) - ២) សន្តិការូបនីយកម្ម នៅ រ៉ែនៈឌូ សន្តិភាពជាមួយប្រទេស អូទ្រីស ជាពិសេសជាមួយប្រទេសអង់គ្លេស។ សមិទ្ធិ របស់ ណាប៉ូឡេអុង មានច្រើនឥតគណនា ក្នុងការកសាងប្រទេសបារាំង ជាពិសេស ជ័យជំនះផ្នែកយោធា នៅប្រទេសមួយចំនួន នៅអឺរ៉ុប។ នៅថ្ងៃ ១៨ ឧសភាឆ្នាំ ១៨០៤ ណាប៉ូឡេអុង ត្រូវតែងតាំងជាព្រះចៅអធិរាជ នៃប្រជាជនបារាំង។

## បដិវត្តន៍ នៅប្រទេស រុស្ស៊ី ឆ្នាំ ១៩១៧

ព្រឹត្តិការណ៍ ទាំងឡាយ ដែលកើតមាន ជាហូរហែ ប៉ុន្មានខែ មុន ខែតុលាឆ្នាំ ១៩១៧ ហើយ ដែលបាននាំ មកដល់ព្រឹត្តិការណ៍ ខែតុលាឆ្នាំ ១៩១៧ បានត្រូវគេកត់សម្គាល់ថាជាបដិវត្តន៍ នៅប្រទេសរុស្ស៊ី ។ នៅឆ្នាំ ១៩១៧ នោះ មាន បដិវត្តន៍ ពីរ បានផ្ទុះឡើង នៅទីក្រុងប៉េត្រូក្រាត ៖ ១) បដិវត្តន៍ នាថ្ងៃ ២៣-២៨ កុម្ភៈ (ប្រតិទិន ស៊ីលល្យាង ត្រូវនឹងថ្ងៃ ៨-១៣ មិនា តាមប្រតិទិនក្រេក្រូរ្យាង) ក្រោមការដឹកនាំ របស់ កេរ៉ែនស្គី ដែលបានត្រូវគេចាត់ទុកថាជា អ្នកតំណាង វណ្ណៈគហបតី។ បដិវត្តន៍មួយទៀត គឺ ការវាយលុកចូលក្នុង «រាជវាំងសិសិររដូវ» (Palais d’hiver) ដោយពួកកុម្មុយនិស្ត បុលឆេវិក នៅក្នុងរាត្រី ថ្ងៃ ២៥ តុលាឆ្នាំ ១៩១៧ ដដែល (ប្រតិទិនស៊ីលល្យាង ត្រូវនឹងថ្ងៃ ៧ វិច្ឆិកា ឆ្នាំ ១៩១៧ តាមប្រតិទិនក្រេក្រូរ្យាង) ។ មកទល់ពេលនេះ គេនៅមិនទាន់មាន ទស្សនៈស្របគ្នា នៅឡើយ





អំពី ការឆ្លើយនឹង សំនួរ ថា តើបដិវត្តន៍ ទាំងពីរនេះ មានទំនាក់ទំនងគ្នាជិតស្និទ្ធ ឬក៏យ៉ាងណានោះ។ តើជារដ្ឋប្រហារ ឬ ជាបដិវត្តន៍ ? ពួកបុលឆេវិកខ្លះ ពុំមាន ទស្សនៈឯកភាពគ្នាទាំងស្រុងឡើយ ។ នៅក្នុង ការនិទានជីវប្រវត្តិ របស់លោកដោយខ្លួនលោកផ្ទាល់ ត្រុតស្គី (Trotsky) ប្រើពាក្យ ម្តងថា «កុបកម្ម» (insurrection) ម្តងថា «ការយកអំណាចបាន» (conquête du pouvoir) ម្តងថា រដ្ឋប្រហារ (coup d’Etat) ។ នារីកុម្មុយនិស្ត អាល្វីម៉ង់ រ៉ូហ្សា លុចសំបួរ ក៏ប្រើពាក្យ «រដ្ឋប្រហារ» នេះដែរ («coup d’Etat d’Octobre») ។ ម៉ាក់ហ្វែររ៉ូ ប្រើពាក្យ putsch (ការបះបោរដោយអាវុធ របស់ ក្រុមនយោបាយមួយ)។ ទោះជាយ៉ាងណាក្តី ការវាយយក «រាជវាំងសិសិររដូវ» នា ថ្ងៃ ២៥ តុលា ឆ្នាំ ១៩១៧ នោះពុំមានការប្រឆាំង ពីប្រជាជន រុស្ស៊ីឡើយ ។ មុនឆ្នាំ ១៩១៧ ប្រទេសរុស្ស៊ី ស្ថិតនៅក្រោមរបប ស្តេចត្សារ៍ (régime tsariste) ដែលប្រើអំណាចផ្តាច់ការ សង្កត់សង្កិន ប្រជាជន។ ប៉ុន្តែ នៅឆ្នាំ ១៨៦១ ស្តេចត្សារ៍ អាឡេចសង់ដ្រ៍ ទី ២ បានលុបបំបាត់ ទាសភាពចោល ។ បន្ទាប់ពីបានទទួល សេរីភាព ពួកសេវកជន ក៏នាំគ្នាចូលទៅប្រកបមុខរបរ ជាកម្មករនៅទីក្រុង ព្រោះសម័យនោះនៅប្រទេសរុស្ស៊ី ឧស្សាហកម្ម កំពុងមាន ការរីកចម្រើនយ៉ាងខ្លាំងក្លា ។ បដិវត្តន៍ឧស្សាហកម្ម បានធ្វើឲ្យ របៀបរស់នៅ ជាប្រពៃណី មាន ការប្រែប្រួលជាមូលដ្ឋាន។ ប៉ុន្តែ ការរីកចម្រើនដល់កំពូល នៃ ឧស្សាហកម្ម ពុំបានធ្វើឲ្យ ជីវភាពកម្មករ និងប្រជាជនរុស្ស៊ី មាន លក្ខណៈប្រសើរឡើយ ។ បែបផែនផលិតកម្ម នៅតែមានលក្ខណៈចាស់គំរិល ដដែល។ ប្រទេសរុស្ស៊ី នៅតែ ស្ថិតនៅជា ប្រទេសកសិកម្មដដែល (៨៥%)។ កសិករមួយចំនួន ដែលជាម្ចាស់ដី សុទ្ធតែជាអ្នកមាន (les Koulaks) ហើយជាអ្នកគាំទ្ររបបស្តេចត្សារ៍។ ប៉ុន្តែ កសិករដែលគ្មានដីធ្លី មានចំនួនច្រើនលើសលុប ហើយកកើតជាអ្វី ដែលគេអាចហៅថា «ស្រទាប់កសិករអធន» ដែលជឿទៅលើ គំនិតបដិវត្តន៍ របស់ វណ្ណៈអធន។ គាប់ជួននៅចន្លោះ សតវត្សរ៍ ទី ១៩ និង ទី ២០ នោះ មានការកកើតឡើង នៃ ចលនាមួយ ដើម្បី វាយរំលំ របប ស្តេចត្សារ៍ នៅតាមស្រទាប់ នានា នៃសង្គមរុស្ស៊ី ជាពិសេសនៅក្នុងមជ្ឈដ្ឋាន និស្សិត កម្មករ កសិករក្រ និង នៅក្នុងចំណោមពួកអភិជន ផងដែរ ព្រោះ របបរបស់ ស្តេចត្សារ៍ ពុំព្រមវិវត្តឆ្ពោះទៅរក វឌ្ឍនភាពសោះ។

ទោះជាយ៉ាងនេះក្តី ក៏ ការប៉ុនប៉ងផ្សេងៗ ដើម្បីវាយរំលំស្តេចត្សារ៍ ពុំបានសម្រេចឡើយ។ អង្គការប៉ូលីស អូក្រាណា (Okhrana) របស់ស្តេចត្សារ៍ ធ្វើការបង្រ្កាបអ្នកបះបោរ ដោយឥតអាសូរ។ ខ្លះត្រូវគេចាប់ដាក់គុក ខ្លះទៀតរត់ទៅជ្រកកោននៅបរទេស។ នៅឆ្នាំ ១៩០៥ បន្ទាប់ពី ប្រទេសរុស្ស៊ី ទទួលបរាជ័យ ក្នុងសង្គ្រាម ជាមួយ ប្រទេសជប៉ុន បដិវត្តន៍ លើកដំបូងបង្អស់បានផ្ទុះឡើង។ នៅថ្ងៃ ២២ មករា ឆ្នាំ ១៩០៥ នោះ ប្រជាជនរុស្ស៊ី បាននាំគ្នាធ្វើបាតុកម្មមួយ ដ៏ធំ ទាមទារឲ្យ ស្តេចត្សារ៍ ដោះលែងអ្នកបដិវត្ត ដែលបានត្រូវចាប់ដាក់គុក។ ពួកគេក៏ទាមទារ ឲ្យស្តេចត្សារ៍កែសម្រួលស្ថានភាពការងារឲ្យបានល្អប្រសើរ ៖ ប្រគល់ដីធ្លីមកឲ្យកសិករវិញ និងលុបការត្រួតពិនិត្យការបញ្ចេញមតិចោលផងដែរ។ មហាបាតុកម្មនោះបានត្រូវបង្រ្កាបនៅក្នុងការបង្ហូរឈាមមួយដ៏ធំសម្បើមអស្ចារ្យ («Dimanche rouge»)។ គឺនៅពេលនោះហើយ ដែលអង្គការតំណាងកម្មករ កសិករ និង ទាហានលើកដំបូងបង្អស់ បានត្រូវចាត់តាំងឡើង (les Soviet)។ ប៉ុន្តែ បដិវត្តន៍ នាខែកុម្ភៈ ឆ្នាំ ១៩១៧ បណ្តាលមកពី បរាជ័យ ជាបន្តបន្ទាប់ របស់ប្រទេសរុស្ស៊ី ក្នុងសង្គ្រាមលោកលើកទី១ ដែលមានមនុស្សស្លាប់ ចំនួន ១ លាន ៧ សែននាក់ និងអ្នករបួសចំនួនជិត ៦ លាននាក់។ ស្ថានភាពនេះ បាននាំឲ្យមាន ទុរ្ភិក្ស ក្នុង ទូទាំងប្រទេស។ សភា ឌូម៉ា ដែលមានសុទ្ធតែអ្នកសេរីនិយម តំណាងវណ្ណៈគហបតី និង អ្នកជឿនលឿននិយម បានតម្រូវឲ្យស្តេចត្សារ៍ចាត់តាំងរដ្ឋាភិបាលបណ្តោះអាសន្នមួយ។ ប៉ុន្តែនៅពេលនោះ ស្តេចត្សារ៍ នីកូឡាទី ២ ពុំបានដឹងអ្វីទាំងអស់ ព្រោះកំពុងវង្វេងស្មារតី ដាច់ចេញពី ការពិតជាក់ស្តែង នៃ ស្ថានភាពសង្គមរុស្ស៊ីទាំងស្រុង។ ម្យ៉ាងទៀត អធិរាជនីអាឡេចសង់ដ្រា ហ្វេអូឌ័រូវ៉ូហ្វណា (Alexandra Feodorovna) ដែលជាជាយារបស់ស្តេចអង្គនេះ ហើយដែលមានដើមកំណើតអាល្លឺម៉ង់ បានត្រូវប្រជាជនរុស្ស៊ី ស្អប់ខ្ពើមយ៉ាងខ្លាំង ។ គឺនៅក្នុងគំនិតអារិកាពនេះហើយ ដែល រ៉ាស្ពូទីន (Raspoutine) ទីប្រឹក្សាដ៏មានឥទ្ធិពល របស់ អាឡេចសង់ដ្រា បានត្រូវភ្នាក់ងារចារបុរស អង់គ្លេសម្នាក់ សម្លាប់នៅក្នុងអំពើក្បត់មួយ របស់ ពួករាជានិយមដាច់ខាតមួយក្រុម ក្រោមការដឹកនាំ របស់ក្សត្រ យូស៊ូប៉ូហ្វ (Youssoupoff) ដែលជាសាច់ថ្លៃរបស់ នីកូឡាទី ២។ នៅឆ្នាំ ១៩១៥-១៩១៦ «គណៈ កម្មការ សូវៀត» តាមរូបភាពផ្សេងៗ



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ដូចជា សហជីព សហករណ៍ ជាដើម កើតឡើង ជាច្រើននៅក្នុងប្រទេសរុស្ស៊ី ហើយដើរ តួជាអំណាចមួយទៀត ទន្ទឹមនឹង អំណាច របស់ រាជការ ដែលបាត់បង់បន្តិចម្តងៗ នូវការក្តាប់ អំណាចពិតប្រាកដ (la réalité du pouvoir) របស់ខ្លួន ។ នៅពេលដែលសិសិររដូវ មកដល់ គឺពេលដែលការខ្វះចំណីអាហារ និង ការលំបាកលំបិន ក្នុងជីវភាពគ្រប់បែបយ៉ាង ស្តែងចេញឡើង ពួកបដិវត្ត បានប្រមូល លក្ខណៈសម្បត្តិ បានគ្រប់គ្រាន់ទាំងអស់ សម្រាប់ធ្វើការវាយប្រហារ (បាតុកម្ម កូតកម្ម ) ។ បន្ទាប់ ពីកូដកម្ម ដែលកើតមាន ជាបន្តបន្ទាប់ នៅថ្ងៃ ២៣ កុម្ភៈ ជាពិសេស កូដកម្ម របស់ស្ត្រី នៅ ប៉េត្រូក្រាត កូដកម្មជាច្រើនទៀត ក៏ស្តែងចេញឡើង ពាសពេញប្រទេសតែម្តង ។ រីឯពាក្យ ស្លោកដែលពួកគេប្រើនៅពេលនោះ មានជាអាទិ៍ ៖ «កំចាត់សង្គ្រាម», «កំចាត់របប អត្តាធិបតេយ្យ»។ ស្តេចត្សារ៍ បញ្ជាឲ្យកងទ័ពបង្រ្កាប បាតុកម្ម។ ការប្រយុទ្ធគ្នា បណ្តាលឲ្យមនុស្សទាំងសងខាង ស្លាប់អស់ជាច្រើន។ ប៉ុន្តែ ចំនួនពាក់កណ្តាលនៃកងទ័ព បាននាំគ្នាចូលដៃពួកបះបោរ។ នៅចំពោះមុខ ស្ថានការណ៍នេះ ស្តេចត្សារ៍ ក៏ រំលាយសភា ឌូម៉ា ចោលហើយ ចាត់តាំង គណកម្មាធិការមួយ ជាបណ្តោះអាសន្ន ដើម្បីទប់ទល់ ។ ប៉ុន្តែ នៅពេលនោះកងទ័ពយោធភូមិទាំងមូល (garnison) បាននាំគ្នាចូលប្រយុទ្ធក្នុងជួរអ្នកបះបោរ អស់ទៅហើយ។ ដោយពួកយុទ្ធជនបដិវត្ត មានប្រៀបទៅលើ កងទ័ពរាជការ សេនាធិការដ្ឋានកងទ័ពប្រទេសរុស្ស៊ី បានបង្ខំឲ្យស្តេចនីកូឡា ចុះចេញពីអំណាច (ថ្ងៃ២ មិនាឆ្នាំ ១៩១៧) ។ ព្រឹត្តិការណ៍ ទាំងឡាយនេះ បានត្រូវកត់ត្រាថា ជា ដំណាក់ការទី ១ នៃ បដិវត្តន៍ រុស្ស៊ី ។ ការទម្លាក់ស្តេចត្សារ៍ ចេញពីអំណាច បានត្រូវប្រជាជនរុស្ស៊ី ចាត់ទុកថាជា ការរំដោះមួយដ៏ធំ ហើយបានបើកផ្លូវឲ្យ ចលនាបដិវត្តន៍ ធ្វើសកម្មភាពរបស់គេយ៉ាងពេញទំហឹង។ ប៉ុន្តែ អំណាច បានធ្លាក់ទៅក្នុងដៃ រដ្ឋាភិបាលបណ្តោះអាសន្ន ដឹកនាំដោយអតីតមន្ត្រីរាជានិយម និងពួកគហបតី។ នៅខែមិនា រដ្ឋអំណាចនេះត្រូវរួបរួមជាមួយ អង្គការ សូវៀត ហើយត្រូវអង្គការបដិវត្តន៍នេះ ដកហូតចេញប៉ុន្មានខែក្រោយមក។ អង្គការសូវៀត បានដាក់ឲ្យអនុវត្តកម្មវិធីមួយ ដែលតម្រូវឲ្យរៀបចំសន្តិភាពឲ្យបានវិញ ឲ្យកសាង របបសាធារណរដ្ឋ ប្រជាធិបតេយ្យ ហើយឲ្យសងដី ទៅឲ្យប្រជាជនវិញ ព្រមទាំង កំហិតឲ្យធ្វើការ តែ ៨ ម៉ោង

ប៉ុណ្ណោះ ក្នុងមួយថ្ងៃ ។ ដោយកម្មវិធីនេះ យកមកអនុវត្តពុំកើត ពួកគហបតី ក៏ឡើងកាន់អំណាចវិញ ដោយទាមទារឲ្យមាន ការបោះឆ្នោត ប៉ុន្តែ ការបោះឆ្នោត ក៏ធ្វើទៅមិនកើត ព្រោះ ពួកបដិវត្ត រាប់លាននាក់ពុំព្រមទៅបោះឆ្នោត។ កាលនោះ ចលនា បដិវត្ត មានពួក ម៉េនឆេវិក (សង្គមនិយមបដិវត្តន៍) ច្រើនជាងពួក បុលឆេវិក ដែលមានន័យថា «ភាគច្រើន» ប៉ុន្តែ ដែលតាមការពិតមាន សមាជិក តិចជាងពួក ម៉េនឆេវិក ដែលមានន័យថា «ភាគតិច»។ ទោះជាយ៉ាង នេះក្តី ទាំងពួក ម៉េនឆេវិក ទាំងពួក បុលឆេវិក សុទ្ធតែជាអ្នកដែលផ្អែកទៅលើ ទ្រឹស្តីម៉ាក្សនិយម ទាំងអស់ ។ ភាគច្រើន នៃ អ្នកទាំងនេះ ក៏យល់ផងដែរថា ចលនាបដិវត្តន៍ ពុំទាន់មាន បទពិសោធន៍ គ្រប់គ្រាន់ឡើយ ដើម្បីកាន់អំណាច។ ម្យ៉ាងទៀត វណ្ណៈអធននៅក្នុងសង្គមរុស្ស៊ីនៅពេលនោះ ពុំមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នៅឡើយ។ ប្រទេសរុស្ស៊ីកាលនោះ ជាប្រទេសកសិកម្ម រីឯ ឧស្សាហកម្ម ក៏ស្ថិតនៅក្នុងកម្រិតអន់ថយទៀត។ បញ្ហាសំខាន់ ដែលចោទឡើងនៅខណៈនោះ គឺ ការបញ្ចប់សង្គ្រាម។ ប្រជាជនរុស្ស៊ី សុំឲ្យ រដ្ឋាភិបាល បញ្ចប់សង្គ្រាម ។ ប៉ុន្តែ ជាការឥតប្រយោជន៍ ។ កម្មករ និងទាហាន ក៏នាំគ្នា ធ្វើបាតុកម្ម យ៉ាងគគ្រឹកគគ្រេង ខ្លះប្រឆាំង នឹង រដ្ឋាភិបាល ខ្លះទៀត គាំទ្ររដ្ឋាភិបាល ដែលធ្វើការបង្ក្រាបយ៉ាងខ្លាំងក្លា ។ គឺជាការប្រយុទ្ធគ្នាមួយ ដ៏ធំសម្បើម និងលើកទី ១ ដោយប្រើអាវុធ ។ អ្នកសង្គមនិយមកណ្តាលនិយម ចូលធ្វើសហការ ជាមួយរដ្ឋាភិបាល ដើម្បី គាបសង្កត់រដ្ឋាភិបាល ឲ្យបញ្ចប់សង្គ្រាម ។ គឺនៅពេលនោះហើយ ដែល លេនីន ត្រឡប់មក រុស្ស៊ីវិញ ។ នៅក្នុងនិក្ខេបបទ ខែមេសា របស់លោក លេនីន ពន្យល់ថា «ចក្រពត្រនិយម ជាដំណាក់ ការចុងក្រោយ របស់ មូលធននិយម» [១៨]។ ខុស

---

[១៨] «ចក្រពត្រនិយម» ចំពោះ លេនីន មានកត្តាកំណត់ប្រាំ ៖ ១) ការប្រមូលផ្តុំ មូលធន និង ការស្តែងចេញឡើង នៃ ការផ្តាច់មុខ(monopoles) - ២) ការនាំចេញ នៃ មូលធន- ៣) ការបង្កើតប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ដោយមនុស្សមួយក្រុម (oligarchie financière) -៤) ការកកើតឡើង នៃសហគ្រាសអន្តរជាតិ - ៥) ការបែងចែកពិភពលោក ដោយពួក មូលធននិយម។



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ពីទស្សនៈរបស់ រ៉ូហ្សា លុចសំបួរ (Rosa Luxemboug) លេនីន មិនយល់ថា មូលធននិយម ត្រូវរលាយ ដោយខ្លួនឯង នោះឡើយ ព្រោះ ប្រព័ន្ធសេដ្ឋកិច្ចនេះ មានលក្ខណៈសម្បត្តិបេះ សម្របខ្លួន ទៅតាម ស្ថានការណ៍ ។ នៅក្នុងនិក្ខេបបទ ខែមេសាឆ្នាំ ១៩១៧ នោះ លេនីន បានបញ្ជាក់ថា ពួកគហបតី រុស្ស៊ី គ្មានសមត្ថភាព និង តួនាទី ដឹកនាំបដិវត្តន៍ ដូចកាលពីមុនទៀតឡើយ ដូចនេះ ពួកគេ ត្រូវប្រគល់ តួនាទីនេះ មកឲ្យ ពួកសូវៀតវិញ ដើម្បីបន្ត ការធ្វើបដិវត្តន៍ ។ នៅខែមិថុនា ពួកបុលឆេវិក ក្រោមការដឹកនាំ របស់ លេនីន បានក្លាយទៅជា ក្រុមបដិវត្តន៍ ដែលមាន សមាជិកច្រើន ជាងគេ។ គឺនៅពេលនោះហើយ ដែល ត្រុតស្គី បានចូលមករួបរួមជាមួយ លេនីន។ រដ្ឋាភិបាលបណ្តោះអាសន្ន ធ្វើការគាបសង្កត់ទៅលើលេនីន ដែលត្រូវបង្ខំចិត្តរត់ទៅជ្រកកោន នៅប្រទេសស៊ុយអែត រីឯ ត្រុតស្គី ត្រូវគេចាប់ដាក់គុក ជាមួយពួកទាហាន ដែលពុំ ព្រមទៅសមរភូមិ។ ប៉ុន្តែ ក្រោយបរាជ័យ នៃ រដ្ឋប្រហារ របស់ ឧត្តមសេនីយ៍ គ័រនីឡូហ្វ ត្រុតស្គី បានត្រូវដោះលែងមកវិញ។ នៅពាក់កណ្តាល ខែកក្កដា ឧត្តមសេនីយ៍ គ័រនីឡូហ្វ បានទទួលបញ្ជា បាញ់រះ ទៅលើពួកទាហានបះបោរ ជាហេតុ បណ្តាលឲ្យ ទាហាន ជិត ៦ ម៉ឺន នាក់ បាត់បង់ជីវិត។ ប៉ុន្តែ ការបង្ក្រាប ដ៏សម្បើមអស្ចារ្យនេះ ពុំបានទទួលជោគជ័យឡើយ។ ផ្ទុយទៅវិញ អ្នកបដិវត្តបុលឆេវិក កាន់តែមាន ជំហរ ខ្លាំងថែមទៀត ហើយ បន្ទាប់ពីមាន ការតស៊ូមតិគ្នា ស្តីពីការដែលថា តើត្រូវវាយយកអំណាចតែម្តង ឬក៏យ៉ាងណានោះ ពួកបុល ឆេវិក ក៏សម្រេចវាយយកអំណាចតែម្តង តាមការពន្យល់ របស់ លេនីន។

ការវាយលុក បានប្រព្រឹត្តទៅ នៅក្នុងរាត្រី ថ្ងៃ ២៤-២៥ តុលា (គិតតាមប្រតិទិនស៊ុលល្យាង ត្រូវនឹង ថ្ងៃ ៦-៧ វិច្ឆិកា តាមប្រតិទិនក្រេក្រូរ្យាង) សឹងតែគ្មានការបង្ហូរឈាម ព្រោះពុំសូវមាន ការទប់ទល់ ប៉ុន្មាន ។ សឹងតែនៅក្នុងពេលតែមួយ ស្ពាន ស្ថានីយរថភ្លើង ធនាគារ ប៉ុស្តិ៍ទូរគមនាគមន៍ ជាដើម បានធ្លាក់ទៅក្នុងដៃ «ឆ្មាំក្រហម» បុលឆេវិក ទាំងអស់។ បន្ទាប់មក គឺការវាយលុកផ្តាច់ព្រ័ត្រ យក «រាជវាំង សិសិររដូវ»។ ប្រតិបត្តិការនេះ មិនពិបាកប៉ុន្មានទេ ព្រោះ កងទ័ពដែលគាំទ្រ រដ្ឋាភិបាល បណ្តោះអាសន្ន មានចំនួន តិចជាង កងទ័ពដែលប្រកាន់ ជំហរអព្យាក្រឹត គឺបណ្តោយឲ្យកងទ័ពបដិវត្តន៍ វាយយក «រាជ

រាំងសិសិរដូវ» ដោយស្រួល។ ការវាយប្រហារនេះប្រព្រឹត្តទៅដោយគ្មានការជ្រួលច្របល់អ្វីជាធំដុំឡើយ។ ចរាចរ នៅតាមផ្លូវថ្នល់ រោងល្ខោន ភណ្ឌាគារ ហាងលក់ទំនិញ មានសកម្មភាព ជាហូរហែ ឥតមានដាច់ ។ ព្រឹកឡើង នៅថ្ងៃ ២៥ តុលា ត្រុតស្គី ប្រកាសរំលាយរដ្ឋាភិបាល បណ្ដោះអាសន្នជាផ្លូវការ។ នៅពេលឡើងកាន់អំណាច នៅទីក្រុងប៉េត្រូក្រាត លេនីន និង ត្រុតស្គី មានគំនិត កសាង របប សង្គមនិយម មិនត្រឹមតែ នៅក្នុងប្រទេសរុស្ស៊ីប៉ុណ្ណោះទ ប្រទេសរុស្ស៊ី ដែលនៅពេលនោះជាប្រទេសឱនាភិវឌ្ឍនៅឡើយ។ អ្នកដឹកនាំ បុលឆេវិក ទាំងពីរនេះ ប្រាថ្នាចង់ប្រែក្លាយជ័យជំនះនេះ ឲ្យទៅជា ជ័យជំនះរបស់កម្មករ នៅបណ្ដាប្រទេសឧស្សាហកម្ម នៅអឺរ៉ុបទៀតផង ជាពិសេសប្រទេស អាល្លឺម៉ង់ ព្រោះមានតែផ្លូវនេះទេ ដែលអាច ធានា និរន្តភាព នៃ បដិវត្តន៍ រុស្ស៊ី បាន។ ត្រុតស្គី បានថ្លែងដូច្នេះថា ៖ «ឬមួយ បដិវត្តន៍រុស្ស៊ី នាំឲ្យមាន បដិវត្តន៍ នៅបស្ចិមប្រទេស ឬមួយបដិវត្តន៍រុស្ស៊ី នឹង ត្រូវប្រទេស មូលធននិយម ប្របាច់ក ឲ្យថប់ដង្ហើមតែម្ដង» ។ មួយឆ្នាំក្រោយមក បដិវត្តន៍ បានផ្ទុះឡើង នៅប្រទេសអាល្លឺម៉ង់ (១៩១៧-១៩១៨) ប្រទេស ហុងគ្រី (១៩១៩) នៅ ហ្វាំងឡង់ (ខែមិនាឆ្នាំ ១៩១៨) ប៉ុន្តែ បានត្រូវរដ្ឋអំណាច បង្ក្រាបយ៉ាងខ្លាំងក្លា ។ នៅប្រទេសអាល្លឺម៉ង់ កាល លីបណេច និង រ៉ូហ្សា លុចសំបួរ (Karl Liebkncht et Rosa Luxembourg) មេដឹកនាំ ចលនា បដិវត្តន៍ កុម្មុយនិស្ត ស្ប៉ារតាគូស (spartakisme) បានត្រូវគេធ្វើឃាត ។ នៅឆ្នាំ ១៩១៩-១៩២០ កុបកម្ម និង កូដកម្ម នៅប្រទេសអ៊ីតាលី នៅប្រទេសបារាំង អង់គ្លេស និង នៅ សហរដ្ឋ អាមេរិក ពុំបាននាំទៅរកបដិវត្តន៍កុម្មុយនិស្ត អ្វីទាំងអស់ ។ នៅចំពោះមុខ សភាពការណ៍បែបនេះ បដិវត្តន៍ បុលឆេវិក នៅរុស្ស៊ី ត្រូវស្ថិតនៅឯកឯង ហើយ ត្រូវកសាងប្រទេស ដោយខ្លួនឯង។

ក្រោយពេលយកអំណាចបានហើយ លេនីនក៏ចាប់ផ្ដើមកសាង របប សង្គមនិយម (លុបរបបកម្មសិទ្ធិដីធ្លី, លុបទោសប្រហារជីវិត ព្រមទាំងបុព្វសិទ្ធិនានា, ជាតូបនីយកម្មធនាគារ, តម្រូវឲ្យកសិករ ត្រួតពិនិត្យផលិតកម្ម, អធិបតេយ្យ និងសមភាព របស់ពលរដ្ឋរុស្ស៊ី)។ ទោះជាយ៉ាងនេះក្ដី ក៏សង្គ្រាមផ្ទៃក្នុងមួយ រវាងកងទ័ពក្រហម និងកងទ័ពស (រាជានិយម) ដែលមាន បរទេសគាំទ្រ បានផ្ទុះឡើងដែរ។ បដិវត្តន៍ ខែតុលា របស់រុស្ស៊ី នៅតែ



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ត្រូវសាធារណមតិ ចាត់ទុកថា ជារដ្ឋប្រហារ។ ចាប់ពីឆ្នាំ ១៩១៩ មក កងទ័ពក្រហមបានធ្វើ ឲ្យបស្ចិមលោក មានការព្រួយបារម្ភយ៉ាងខ្លាំង។ ចលនា មនោគមវិជ្ជា ប្រឆាំង នឹងកងទ័ពក្រហម ក៏កើតឡើងនៅពេលនោះដែរ (ហ៊ីត្លែរ, មូស្សូលីនី,...) ។ ប៉ុន្តែចំពោះប្រទេសដែលត្រូវ ប្រទេសបស្ចិមលោក ធ្វើអាណានិគម ហើយ ដែលចង់រំដោះខ្លួនចេញពី នឹមត្រួតត្រា បរទេស បដិវត្តន៍ខែតុលា របស់ រុស្ស៊ី ក៏បានផ្ដល់ សេចក្ដីសង្ឃឹមមួយដ៏ធំ ទៅឲ្យពួកគេដែរ។ តាំងពីពេលនោះមក ចលនាជាតិនិយមនៅក្នុងប្រទេសដែលត្រូវគេធ្វើអាណានិគមកិច្ច បានត្រូវគេយកមកផ្សាភ្ជាប់ ជាមួយ ចលនា កុម្មុយនិស្ត អន្តរជាតិ។ ប៉ុន្តែការផ្សាភ្ជាប់ គំនិត ជាតិនិយម និង «អន្តរជាតិនិយម នៃ វណ្ណៈអធន» បាននាំមកនូវបញ្ហា ដ៏ស្មុគស្មាញ។ រីឯ លទ្ធិកុម្មុយនិស្តដែលយកអំណាចបាន មុនពេលទំជោ នៃ របនាសម្ព័ន្ធសង្គម ក៏បាននាំមក នូវ បញ្ហាស្មុគស្មាញ ដូចគ្នាអ៊ីចឹងដែរ។ ដើម្បីទប់ទល់នឹងការបះបោរ បដិវត្តន៍ រុស្ស៊ីត្រូវបំបិទសិទ្ធិសេរីភាពគ្រប់បែបយ៉ាង ហើយ ដាក់ទោស ដ៏ធ្ងន់ធ្ងរដល់ពួកអ្នកប្រឆាំង រួមបញ្ចូល ទាំងអ្នកបដិវត្តន៍ដូចគ្នា និងប្រទេសកុម្មុយនិស្តដែលរណប នឹង ប្រទេសរុស្ស៊ី ផងទៀត ។ ទោះជាយ៉ាងនេះក្ដី ក៏លេនីន បានសម្រេច គោលដៅ របស់ខ្លួន បានដែរ ដោយធ្វើជាតូបនីយកម្ម នៃ ពាណិជ្ជកម្ម ធនាគារ ឧស្សាហកម្ម និងសិប្បកម្ម។ លំនៅឋាន បានត្រូវដាក់ជាសមូហភាព ដោយចែកចាយ ដោយឥតបង់ថ្លៃ។ ការដឹកជញ្ជូនសាធារណៈ ទឹក អគ្គីសនី ក៏ ឥតបង់ថ្លៃដែរ គឺ ស្ថិតនៅក្នុងការគ្រប់គ្រងរបស់រដ្ឋទាំងអស់។ ។ ប៉ុន្តែ រូបិយវត្ថុ ត្រូវរលំរលាយ ហើយជំនួសដោយការដោះដូរ និងការផ្ដល់ប្រាក់ខែ ជារបស់របរ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ការមិនសប្បាយចិត្ត ចាប់ផ្ដើមកើតមានឡើង នៅក្នុងជួរប្រជាជនដែរ ព្រោះ ផលិតកម្ម និង កម្រិតជីវភាព បានចុះថយយ៉ាងខ្លាំង។ ហើយការចែកចាយ ក៏មិនត្រឹមត្រូវ ទៅតាមគតិយុត្តិធម៌ថែមទៀត។ នៅខែមិនា ឆ្នាំ ១៩២១ នៅចំពោះមុខការក្ដាប់អំណាចផ្ដាច់មុខ និង អំពើហឹង្សា នៅតាមជនបទពីសំណាក់ ពួកបដិវត្តបុលឆេវិក ទាហានជើងទឹកនៅក្រុងស្តាត បាននាំគ្នាងើបឡើង បះបោរ ទាមទារឲ្យពួកសូវៀតវិលមកកាន់អំណាចវិញ ហើយ ឲ្យចាត់តាំងការបោះឆ្នោតសេរីផ្ដល់សេរីភាពមកឲ្យផ្សារសេរី ហើយលុបបំបាត់ នគរបាល នយោបាយ ឆេកា ផងទៀត។

ប៉ុន្តែ ការបះបោរនេះ បានត្រូវត្រុតស្តី បង្ក្រាបបានវិញ ។ ដោយមើលទៅឃើញថា របៀបធ្វើបដិវត្តន៍ បែបនេះ (communisme de guerre) ច្បាស់ជា នាំទៅរក ភាពទាល់ច្រកមិនខាន លេនីន ក៏សម្រេច វិលមករក របៀបមូលធននិយម សមស្របមួយ ជា បណ្តោះអាសន្នសិន នៅឆ្នាំ ១៩២១ ដដែលនោះ (La Nouvelle Politique Économique ou la NEP)។

## បដិវត្តន៍ ចិន

នៅ សតវត្សរ៍ ទី ១៩ នៅក្រោម រជ្ជកាល អធិរាជជីង ប្រទេសចិន បានចុះខ្សោយបន្តិចម្តងៗ ជាលំដាប់ៗ កោលាហល បេះតែកើតមានឡើង ឥតឈប់ឈរ នៅក្នុងសង្គមៗសេដ្ឋកិច្ច ក៏ជួបនឹងការរាំងស្ទះ ហើយចំនួនប្រជាជន បានកើនឡើងនៅក្នុង បរិមាណមួយ ដ៏ធំសម្បើមៗ ទន្ទឹមនោះ ប្រទេស មហាអំណាច បស្ចិមប្រទេស ក៏នាំគ្នា ចូលមកជ្រៀតជ្រែកក្នុង ប្រទេសផងទៀតៗ ជនជាតិអង់គ្លេស បាននាំគ្នា មកធ្វើពាណិជ្ជកម្មអាភៀនខុសច្បាប់ ជាហេតុ បណ្តាលឲ្យមាន ការប្រយុទ្ធ យោធាមួយ ដ៏ធំលើកដំបូងបង្អស់ រវាង អង់គ្លេស និង រាជការចិន (guerre de l’opium : ១៨៤០) ។ បរាជ័យ របស់ ចិនបានធ្វើឲ្យពួកបស្ចិមប្រទេស មានឥទ្ធិពលនៅក្នុងប្រទេសចិន ។ សន្ធិសញ្ញា ណង់កាំង នាថ្ងៃ ២៩ សីហាឆ្នាំ ១៩៤២ បានបើកផ្លូវឲ្យអង់គ្លេស យកទឹកដី ហុងកុង សម្រាប់ប្រើក្នុងរយៈពេលមួយជាកំណត់ ហើយបើក ទីតាំងរកស៊ី នៅក្នុងកំពង់ផែចំនួនប្រាំ (សៀមិន កង់តុង ហ្វូហ្ស៊ូ ណាំងបូ និង សៀង ហៃ) ។ មិនត្រឹមតែ អង់គ្លេសប៉ុណ្ណោះទេ សហរដ្ឋ អាមេរិក និង ប្រទេសជប៉ុន ក៏នាំគ្នាមកមក យកទឹកដីចិន ធ្វើជាទីតាំង ពាណិជ្ជកម្មដែរៗ ការបះបោរ នៃចលនា តៃពីង បាននាំឲ្យមាន សង្គ្រាមផ្ទៃក្នុងមួយដ៏យូរ (១៨៥១-១៨៦៤)ៗ ទាល់តែមានជំនួយ ពី ពួកបស្ចិមប្រទេស ទើបការបះបោរនេះ ត្រូវបង្ក្រាបបានៗ មិនតែប៉ុណ្ណោះសោតការរំដើប រំជួលនៅតាមខេត្រនៅជាយ ដែន ដូចជានៅ ជីង ចាង និង ម៉ុងហ្គោលី ជាដើម ដែលមាន ការបំផុសបំផុល ពីប្រទេស រុស្ស៊ី ក៏ជាមូលហេតុចម្បង ដែលបណ្តាលឲ្យ





ប្រទេសចិន ចុះខ្សោយ ជាអតិបរមា ដែរ ។ រាជវង្ស ជីង ក្រោមការដឹកនាំរបស់ អធិរាជនីអភិរក្សនិយមម្នាក់ ព្រះនាមត្សឺ ហ៊ី (Cixi) (១៨៦០-១៩០៨) បានធ្វើទំនើបកម្ម ប្រទេសចិនៗ ប៉ុន្តែ ដោយទទួលបរាជ័យ នៅក្នុងសង្គ្រាមជាមួយ បារាំង ដើម្បីយកទឹកដីឥណ្ឌូចិន (១៨៨៣-១៨៨៥) ហើយបន្ទាប់មកចាញ់សង្គ្រាម ជាមួយប្រទេសជប៉ុន ដើម្បីដណ្តើមយកប្រទេសកូរ៉េ (១៨៩៤-១៨៩៥) កងទ័ពចិន ក៏ចុះខ្សោយ ហើយបាក់ទឹកចិត្តយ៉ាងខ្លាំងៗ នៅដើមសតវត្សរ៍ ទី ២០ រាជវង្សជីង ត្រូវព្រឈមមុខនឹង បញ្ហាមួយដ៏សំខាន់ ៖ ឬមួយបន្តការកែទម្រង់ ដែលធ្វើឲ្យពួកអភិជន - ដែលមិនធ្វើអ្វី ទាំងអស់ ដើម្បីប្រទេសជាតិ - មិនសប្បាយចិត្ត ឬមួយ ក៏ត្រូវលើកទឹកចិត្តដល់ពួកបដិវត្ត តែម្តង ព្រោះនៅពេលនោះ បដិវត្តន៍ កំពុង បេញរូបរាង ជា អ្នកតំណាង អនាគត ប្រទេស កាន់តែច្បាស់ណាស់ទៅហើយៗ នៅពេលនោះ ពួកនាម៉ឺន និង ពួកនាយទាហានក្មេងៗ ព្រមទាំងនិស្សិត ដែលជ្រួតជ្រាបទៅដោយ គំនិតបដិវត្តន៍ របស់ ស៊ុន យ៉ាត់ សេន មិនយល់ស្រប នឹង ទស្សនៈអភិរក្សនិយម របស់ ពួកអភិជនឡើយ ។ ពួកគេចង់ ប្រែក្លាយចក្រភពចិន ឲ្យទៅជា សាធារណរដ្ឋ ហើយ ក៏នាំគ្នារៀបចំវាយរំលំ របបរាជានិយមតែម្តងៗ នៅថ្ងៃ ១០ តុលាឆ្នាំ ១៩១១ ការងើបឡើងបះបោរ នៅ វូ ចាង បានវាយរំលំ របបរាជានិយម ហើយ បង្ខំឲ្យអធិរាជពូយី (Aixinjueluo Puyi) ដាក់រាជ្យ ។ ស៊ុន យ៉ាត់ សេន បង្កើត រដ្ឋាភិបាលបណ្តោះអាសន្នមួយ នៅ ណង់កាំង នៅថ្ងៃ ១២ មិនាឆ្នាំ ១៩១២ ហើយប្រកាសរបប សាធារណរដ្ឋៗ បន្ទាប់មក ស៊ុន យ៉ាត់ សេន បានប្រគល់អំណាចទៅឲ្យ ឧត្តមសេនីយ៍ យ័ន ស៊ីកៃៗ ប៉ុន្តែ មិនយូរប៉ុន្មាន យ័ន ស៊ីកៃ បានលុបសភាជាតិ និង សភា តាមខេត្រចោលៗ ពួកអ្នកសាធារណរដ្ឋនិយម ដែលជាមេដឹកនាំ សំខាន់ៗ នាំគ្នា រត់ទៅលាក់ខ្លួននៅបរទេស ហើយ ស៊ុន យ៉ាត់ សេន ទៅជ្រកកោន នៅប្រទេសជប៉ុនៗ នៅឆ្នាំ ១៩១៥ យ័ន ស៊ីកៃ តែងតាំងខ្លួនឯង ជា អធិរាជ ប្រទេសចិនតែម្តង ។ ប៉ុន្តែ មហិច្ឆតា ដ៏ធំធេង របស់ យ័ន ស៊ីកៃ បានត្រូវនាយទាហាននៅក្រោមបង្គាប់ ប្រឆាំងយ៉ាងខ្លាំង ។ ឧត្តមសេនីយ៍ យ័ន ស៊ីកៃ ទទួលមរណភាព នៅខែមិថុនាឆ្នាំ ១៩១៦ ហើយ ទុកអំណាចចោលគ្មានអ្នកដឹកនាំៗ ការបែកបាក់គ្នា នៅក្នុងក្រុមអ្នកសាធារណរដ្ឋ បានជម្រុញឲ្យប្រទេសចិន ធ្លាក់ទៅក្នុងភាព

ប្របូកប្របល់មួយ ដ៏ធំ ។ ពួកមេទ័ព ដែលធ្វើសង្គ្រាមប្រយុទ្ធ នឹង គ្នាឯង រកប្រកបេញ មិនរួច។ នៅឆ្នាំ ១៩២០ ស៊ុន យ៉ាត់ សេន បង្កើត មូលដ្ឋានបដិវត្តន៍មួយ នៅភាគខាងត្បូង ដើម្បីរៀបចំប្រទេសឡើងវិញ ដោយមានជំនួយពី ប្រទេសរុស្ស៊ី និង ដោយចងសម្ព័ន្ធភាព ជាមួយបក្សកុម្មុយនិស្តចិន។ លោកបានបង្ក្រាប ពួកឧត្តមសេនីយ៍ ដែលបានធ្វើឲ្យប្រទេស ចិនធ្លាក់ទៅក្នុងអនាធិបតេយ្យ បានជាស្ថាពរ ។ វេជ្ជបណ្ឌិត ស៊ុន យ៉ាត់ សេន ដែលជា ស្ថាបនិក គណបក្សជាតិនិយមចិន (Kuomintang/Guomindang) ទទួលមរណភាព នៅឆ្នាំ ១៩២៥។ ចេន កាយ ចៀក (Tchang Kai-chek) ជាអ្នកបន្តវេន។ នៅឆ្នាំ ១៩២៧ គណបក្ស ក្កួមីងតាំង បានប្រឆាំង នឹងពួកកុម្មុយនិស្ត ដែលជាសម្ព័ន្ធមិត្ត ជាហេតុបណ្តាល ឲ្យមានសង្គ្រាមផ្ទៃក្នុងមួយដ៏ធំ។ នៅឆ្នាំ១៩៣១ កងទ័ពជប៉ុន ចូលលុកលុយប្រទេសចិន។ នៅឆ្នាំ ១៩៣៤ ពួកក្កួមិញតាំង បានដេញ ពួកកុម្មុយនិស្តចេញ ។ ពួកកុម្មុយនិស្ត បាននាំ គ្នាធ្វើដំណើរ ទៅតាំងទី នៅតាមទីភ្នំ ក្នុងតំបន់ពាយព្យ (la longue marche) ហើយ ទៅតាំងមូលដ្ឋានទ័ពនៅ យូណាន់ ដើម្បីធ្វើសង្គ្រាមព្រៃ ។ គឺនៅពេលធ្វើដំណើរ ដ៏លំបាក លំបិន ឆ្លងកាត់ តំបន់ដាច់ស្រយាល នេះហើយ ដែល ម៉ៅ សេទុង ពង្រឹងជំហរពួក កុម្មុយនិស្ត ឲ្យធ្វើការតស៊ូប្រឆាំង នឹង ពួកក្កួមិញតាំង ។ ទោះបី ពួកក្កួមិញតាំង និង បក្សកុម្មុយនិស្តចិន ប្រយុទ្ធគ្នា យ៉ាងខ្លាំងក្លា ក៏ដោយ ក៏ពួកគេ ពួតដៃគ្នា ប្រយុទ្ធដេញកង ទ័ពជប៉ុន ចេញពីស្រុកដែរ (សង្គ្រាមទី ២ រវាង ចិន និង ជប៉ុន) ។ ពេលដែលជប៉ុន ទទួលបរាជ័យនៅឆ្នាំ ១៩៤៥ (នៅក្នុងក្របខ័ណ្ឌ នៃ សង្គ្រាមលោកលើកទី ២) សង្គ្រាមផ្ទៃ ក្នុងកាន់តែមាន ទ្រង់ទ្រាយធំថែមទៀត ។ នៅឆ្នាំ ១៩៤៩ កម្លាំង របស់ កុម្មុយនិស្ត បាន ដណ្តើមយក ដីគោកបានទាំងអស់។ ចេន កាយ ចៀក បាននាំរដ្ឋាភិបាល ទៅតាំងទី នៅ កោះតៃវ៉ាន់ ហើយប្រកាស ទីក្រុងតៃប៉េះ ជា រដ្ឋធានី នៃ សាធារណរដ្ឋចិន ជាបណ្តោះ អាសន្ន។ នៅថ្ងៃ ១ ខែតុលាឆ្នាំ ១៩៤៩ ដដែលនោះ ពួកកុម្មុយនិស្ត ដែលមកតាំងទី នៅ ទីក្រុងប៉េកាំង (បីយីង) ក៏ប្រកាសសាធារណរដ្ឋ ប្រជាមានិតុចិន របស់គេដែរ។ នៅពេល ដែលពួកកុម្មុយនិស្ត កសាង រដ្ឋកុម្មុយនិស្តនៅអំឡុងឆ្នាំ ១៩៤៩-១៩៥៤ ពួកគេផ្តល់រូប ភាពមួយ ដែលមានលក្ខណៈជា របបពហុបក្ស ប៉ុន្តែ តាមការពិត គឺជា របបផ្តាច់ការមួយ





ដែលមិនមែនជា របបយោធានិយម ហើយដែលអនុវត្ត របបសេដ្ឋកិច្ចសេរីពាក់កណ្តាល។ នៅឆ្នាំ ១៩៥៨ ម៉ៅ សេ ទុង អនុវត្ត នយោបាយ «មហាលោតផ្លោះ» (grand Bond en avant) ហើយជំរុញ ឲ្យកសិករ កសាងរោងចក្រលោហធាតុ។ ប៉ុន្តែផែនការនេះ ទទួល បរាជ័យទាំងស្រុងនៅឆ្នាំ ១៩៦០។ កសិករចិនប្រមាណ ៥០ លាននាក់ ត្រូវបាត់បង់ជីវិត នៅក្នុងផែនការ ដ៏ មហិមានេះ។ ម៉ៅ សេ ទុង (១៨៩៣-១៩៧៦) ជាសមាជិក បក្សកុម្មុយ និស្តចិន នៅឆ្នាំ ១៩២១។ នៅពេលដែលពួកកុម្មុយនិស្ត បានត្រូវ ពួកក្កួមិញតាំង ដេញ ចេញពីមូលដ្ឋាន របស់គេ ហើយ ត្រូវធ្វើដំណើរ កាត់តំបន់ដាច់ស្រយាល យ៉ាងលំបាក លំបិនត្តោះទៅភាគខាងជើង (la longue marche) ម៉ៅ សេ ទុង បានក្លាយទៅជាអ្នកដឹកនាំ កំពូល នៃ បក្សកុម្មុយនិស្តចិន។ បន្ទាប់ ពីបានកំហិត របបសមូហភាព ក្នុងការបង្កបង្កើត ផល និងបានបង្កើតរបបដឹកនាំ ដោយ គណ បក្សតែមួយ តាមគំរូសូវៀត ហើយ បន្ទាប់ ពីបានរៀបចំ ផ្លាស់ប្តូរអ្នកដឹកនាំចាស់ នៃ គណបក្ស យកទៅដាក់នៅកន្លែងមិនសំខាន់ រួច រាល់ហើយ ម៉ៅ បានបំផុសឲ្យយុវជន បះបោរប្រឆាំង នឹង អ្នកដឹកនាំសំខាន់ៗ នៃ គណ បក្សកុម្មុយនិស្តចិនតែម្តង ។ កាលនោះ គោលដៅ នៃ គណបក្សកុម្មុយនិស្តចិន គឺ ត្រូវ ឆ្លងកាត់ ដំណាក់កាលប្រជាធិបតេយ្យសិន ហើយ បន្ទាប់មក ទើបកសាង របបសង្គម និយម។ ប៉ុន្តែ ម៉ៅ យល់ថា ត្រូវកសាង ឧស្សាហកម្ម សង្គមនិយមតែម្តង ព្រោះ ការ ឆ្លងកាត់ដំណាក់ការប្រជាធិបតេយ្យ អាចនាំទៅរកការវិលមកវិញ នៃ ពួកវណ្ណៈគហបតី ។ ប៉ុន្តែ តាមរយៈការឃោសនា ចលនា «ផ្កា១០០» (campagne des cents fleurs) នៅ ឆ្នាំ ១៩៥៧ ម៉ៅ លេងឆាកល្ខោនមួយ ដែលបាននាំ ទៅរកសោកនាដកម្មមួយដ៏ធំ ។ ម៉ៅ ធ្វើជាបើកឲ្យមាន សិទ្ធិរិះគន់។ អ្នកដែលហ៊ានរិះគន់ ចំនួនរាប់រយពាន់នាក់ បានត្រូវគេ ចាប់យកទៅញាត់គុក ជម្លៀសចេញពីស្រុក ឬ ក៏យកទៅ សម្លាប់ចោលតែម្តង ។ នៅឆ្នាំ ១៩៦២ លូ ចៅជី បានសម្រេចបញ្ចប់ នយោបាយ «មហាលោតផ្លោះ» របស់ ម៉ៅ សេ ទុង ដែលទទួលបរាជ័យទាំងស្រុង ។ តេង ស៊ាវ ពីង យល់ស្រប នឹងការកែទម្រង់ របស់ លូ ចៅជី ដែលបានហុចលទ្ធផលល្អ។ មេដឹកនាំគណបក្សកុម្មុយនិស្តចិន ទាំងពីរនាក់ នេះ ដកហូត ម៉ៅ ចេញបន្តិចម្តងៗ ពីកន្លែងសំខាន់ នៃ អំណាច ។ នៅឆ្នាំ ១៩៦៦ ម៉ៅ

បំផុសបដិវត្តន៍វប្បធម៌ ហើយក្តាប់អំណាចទាំងមូលវិញ។ លូ ចៅជី និង តេង ស៊ាវ ពីង បានត្រូវម៉ៅ ចាត់ទុកថា ជាអ្នកស្តាំនិយម ហើយ យកទៅដាក់ឃុំឃាំង នៅឆ្នាំ ១៩៦៨។ នៅឆ្នាំ ១៩៦៩ តេង ស៊ាវ ពីង និង គ្រួសារត្រូវ ម៉ៅ បញ្ជូនឲ្យទៅធ្វើជាកម្មករ នៅរោងចក្រគោយន្ត នៅ ចាំងស៊ី ។ កូនប្រុសរបស់ តេង ស៊ាវ ពីង បានក្លាយទៅជា មនុស្សពិការ បន្ទាប់ពីលោត ពីលើអាគារ សកលវិទ្យាល័យប៉េកាំង ព្រោះតែទ្រាំទ្រ នឹង ទារុណកម្ម ព្រមទាំងការប្រមាថកាតទាន បន្ទោកបន្ទាបគ្រប់បែបយ៉ាង ដែលពួកឆ្មាំក្រហម ធ្វើមកលើខ្លួន។ នៅខែសីហា ឆ្នាំ ១៩៧២ តេង ស៊ាវពីង ត្រូវបង្ខំចិត្តសរសេរសំបុត្រ សូមទោសលោកប្រធានម៉ៅ ដែលបន្ទាប់ពីធ្វើជា ប្រធានាធិបតី នៅឆ្នាំ ១៩៥៤-១៩៥៩ ហើយ ឡើងមកកាន់អំណាចវិញ ជាប្រធានបក្សផង ជា ប្រធានាធិបតីផង នៅឆ្នាំ ១៩៦៦ (បដិវត្តន៍វប្បធម៌) រហូតដល់ ពេលទទួលមរណភាពនៅឆ្នាំ ១៩៧៦។ មួយឆ្នាំក្រោយមក តេង ស៊ាវពីង បាន ត្រូវគេអនុញ្ញាត ឲ្យត្រឡប់មកប៉េកាំង ហើយ ចូលទៅក្នុងជួរគណបក្សកុម្មុយនិស្តចិនវិញ។ រី ឯ លូ ចៅ ជី វិញ ដោយត្រូវគេវាយដំប្រំពាក់ ខ្នាំងពេក លោក ក៏ទទួលមរណភាពនៅ ក្នុងគុកនៅថ្ងៃ ១២ វិច្ឆិកា ឆ្នាំ ១៩៦៩ ។ ចាប់តាំងពីឆ្នាំ ១៩៦៦ មក ដោយផ្អែកទៅលើកម្លាំងយុវជន ម៉ៅ ពង្រីកពង្រឹង គំនិតកសាង របបសង្គមនិយម ដោយមិនបាច់ឆ្លងកាត់ ដំណាក់ការប្រជាធិបតេយ្យ ហើយ ចាត់ទុកអ្នកដែលមានគំនិតខុសពីនេះ ថាជាពួក «សេរីនិយម» (« révisionnistes ») ចូលដៃ ពួកវណ្ណៈគហបតី ហើយក្បត់ឧត្តមគតិ កុម្មុយ និស្ត។ នៅឆ្នាំ ១៩៧១ លីន ពាវ អតីតអនុប្រធាន បក្សកុម្មុយនិស្តចិន បានត្រូវ ម៉ៅ ចោទថា មានគោលបំណងចង់ក្បត់ ដោយងាកទៅរកបង្អែកពី សហភាព សូវៀត នៅពេលដែល ម៉ៅ ចង់ជានា ជាមួយសហរដ្ឋអាមេរិកវិញ (នៅឆ្នាំ ១៩៥៩ ម៉ៅ ទាស់ទែង ជាមួយទីក្រុងម៉ូស្គូ) ។ ទំនាស់នេះ តាមការពិតមានមក តាំងពីឆ្នាំ ១៩៣០ មក គឺនៅពេលដែល ស្តាលីន ចង់ផ្តល់យោបល់ ឲ្យម៉ៅ ក្នុងការដឹកនាំបដិវត្តន៍) ។ ម៉ៅ បានអញ្ជើញលោកប្រធានាធិបតី អាមេរិក និចសុន ឲ្យមកធ្វើទស្សនកិច្ច នៅថ្ងៃ ១០ កក្កដាឆ្នាំ ១៩៧១។ នៅថ្ងៃ ១៣ កញ្ញា ឆ្នាំ ១៩៧១ ដដែល លិន ពាវ ទទួលមរណភាពនៅក្នុងការផ្ទុះយន្តហោះ។ នៅឆ្នាំ ១៩៧៦ បន្ទាប់ពី ជូ អេន ឡាយ ទទួលមរណភាព (៨





មករាឆ្នាំ ១៩៧៦) ជាពិសេស បន្ទាប់ ពីម៉ៅ បែកដ្ឋានទៅ (ថ្ងៃ ៩ កញ្ញា ឆ្នាំ ១៩៧៦) ប្រទេសចិន ធ្លាក់ទៅក្នុងវិបត្តិ មួយ ដ៏ធំ។ តេង ស៊ាវ ពីង និង ហ្វា កួ ហ្វឹង អ្នកដែលយល់ថា ប្រទេសចិន ត្រូវយកការរីកចម្រើន សេដ្ឋកិច្ច ជាធំ បានយក ជ័យជំនះទៅលើពួកអ្នកបន្តបដិវត្តន៍ វប្បធម៌ ដឹកនាំដោយ ភរិយាម៉េម៉ាយ របស់ ម៉ៅ («la Bande des quatre») ដែលត្រូវគេចាប់ នៅថ្ងៃ ៦ តុលាឆ្នាំ ១៩៧៦ ។ លោកស្រី ចាង ជីង ភរិយាម៉េម៉ាយ របស់ ម៉ៅ បានត្រូវគេយកទៅ កាត់ទោសប្រហារជីវិត។ ចាប់ពីពេលនោះមក តេង ស៊ាវ ពីង ក៏ចាប់ផ្តើមរៀបចំ ប្រទេសចិន ឡើងវិញ ដោយជ្រើសរើសយកការរីកចម្រើនសេដ្ឋកិច្ច ជាអាទិ៍ភាព។

## ភាពច្របូកច្របល់ នៃ ជ័យជំនះ របស់ ខ្មែរក្រហម នៅថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥

## La confusion de la victoire des Khmers rouges Le 7 avril 1975

នៅពេលដែលកងទ័ពខ្មែរក្រហម វាយសម្រុកចូលទៅក្នុងទីក្រុងភ្នំពេញ គណៈមជ្ឈិមបក្សខ្មែរក្រហម (បក្ស កុម្មុយនិស្ត កម្ពុជា) ក្រោមការដឹកនាំ របស់ ប៉ុល ពត បានសម្រេចជម្លៀសប្រជាជន ដែលរស់ នៅក្នុងទីក្រុង ចេញអស់ពីទីក្រុង ។ ប្រជាជនទីក្រុងភ្នំពេញ ចំនួន ពី ២ ទៅ ៣ លាន នាក់ ព្រមទាំងប្រជាជនដែលរស់នៅក្នុងទីរួមខេត្រ នានា បានត្រូវ បដិវត្តន៍ ខ្មែរក្រហមចាត់ទុកថា ជាខ្មាំងទាំងអស់។ ប៉ុន្តែការសម្រេចបែប នេះរបស់គណៈមជ្ឈិម ពុំបានត្រូវផ្សព្វផ្សាយដល់កម្មាភិបាល មុនពេល កងទ័ពចូលទៅដល់ភ្នំពេញទេ ជាហេតុ ធ្វើឲ្យមាន ភាពច្របូកច្របល់មួយ ដ៏ធំ ។ កម្មាភិបាលខ្មែរក្រហមខ្លះ ដែលបានទទួលបញ្ជា ពីពេលមុន បានកំហិតឲ្យ ប្រជាជន បោះបង់ចោលផ្ទះ

សំបែងរបស់គេ ក្រោមការគំរាមកំហែង នៃ កាំភ្លើង អា កា ៤៧ និងគ្រាប់ បេ ៤០ ។ ពួកខ្មែរក្រហម ដែលពុំទាន់បានទទួលបញ្ហាបែបនេះ នៅឡើយ មានការងឿងឆ្ងល់ យ៉ាងខ្លាំង ព្រោះថា វាពុំគួរឲ្យជឿសោះថា វាអាចមាន បញ្ហាបែបនេះ ពីថ្នាក់លើ ។ ពួកខ្មែរក្រហមទាំងនេះ ដែលមិនបានទទួល បញ្ហាចុងក្រោយនេះ បានខិតខំ ទប់ទល់កុំឲ្យ គេដេញប្រជាជនចេញពីទីក្រុង។ ប៉ុន្តែគឺនៅពេលនោះដែរ ដែលការបែកបាក់ ផ្ទៃក្នុងបក្ស បានចាប់ផ្តើម។ ប៉ុល ពត ចាត់ទុកអ្នកដែលប្រឆាំង នឹងវិធានការ របស់ខ្លួនថាជា ពួកក្បត់។ លោក សូ ណែម ដែលមិនយល់ព្រម ឲ្យលុបបំបាត់រូបិយវត្ថុ បានត្រូវ គេយកទៅសម្លាប់ចោល។ រីឯ អ្នកដែលប្រឆាំង នឹង ការវាយរំលំចោល ជាបន្ទាន់ នៃ របប កម្មសិទ្ធិឯកជន ក៏ ត្រូវ ប៉ុល ពត ចាត់ទុកថា ជាខ្មាំងផងដែរ ។ ប៉ុល ពត យល់ ដោយឆោតល្ងង់ថា គេអាចធ្វើអ្វី បានទាំងអស់ កាលណា គេក្តាប់អំណាច បានហើយ ។ ប៉ុល ពត ជឿថាគេអាចគ្រប់គ្រងប្រជាជនបាន ដោយ ប្រើអំណាចផ្តាច់ការ ។ ប៉ុល ពត គិតថា ដោយការភ័យខ្លាចប្រជាជនខ្មែរច្បាស់ជា នឹង ធ្វើអ្វីគ្រប់បែបយ៉ាងទាំងអស់ដើម្បី អនុវត្តបញ្ហា របស់បដិវត្តន៍ ។ វិធានការ ទីមួយនេះ របស់ ប៉ុល ពត ជា ការភ័ន្តច្រឡំ មួយ ដ៏ធំ ដែលជះឥទ្ធិពល ដ៏ សែនអាក្រក់ ដល់បដិវត្តន៍ នៅពេលក្រោយៗ មកទៀត ។ កុំថាឡើយតែពួកវណ្ណៈអភិជន និង គហបតី ដែលជា សត្រូវ ជាមូលដ្ឋាន របស់ បដិវត្តន៍ កុម្មុយនិស្តសូម្បីតែប្រជាជនសាមញ្ញ ដែលជាអ្នករងគ្រោះ ដោយសារ ពួកសេដ្ឋី ឬ ពួកកម្មាភិបាលខ្មែរក្រហម ក៏ នៅទីបំផុត នាំគ្នាក្បត់ ប៉ុល ពត ទាំងអស់ដែរ ។ នេះ មកពី សេរីភាព និងប្រយោជន៍ របស់ មនុស្សម្នាក់ៗ បានត្រូវគេយកមកជាន់ឈ្លី នឹងជើង ដោយឥតអាសូរ ។ ក្រោយមក ប៉ុល ពត បានដឹង អំពី បរាជ័យ នៃ វិធានការនេះដែរ ប៉ុន្តែអ្វីៗ ក៏ ជ្រុលហួសអស់ទៅហើយ គឺ មានតែផ្លូវធ្វើខុសបន្ត ទៅទៀតប៉ុណ្ណោះ ក្រែង អាចហុចលទ្ធផលវិជ្ជមាន (La fuite en avant) ។ ការពិត ផ្លូវខុស មិនអាចនាំទៅ រកត្រូវវិញបានឡើយ ។

ប៉ុល ពត បានចូលមកទីក្រុងភ្នំពេញ នៅថ្ងៃ ២ មេសា ឆ្នាំ ១៩៧៥ ដោយគ្មានអ្នកណាដឹងទាំងអស់ ពោលគឺ ២ សប្តាហ៍ មុនការក្តាប់យករដ្ឋធានីខ្មែរ បានទាំងស្រុង។ ទាល់តែមួយសប្តាហ៍ក្រោយថ្ងៃ ១៧ មេសា ទើបពួកខ្មែរក្រហម បានដឹងថា មេ របស់ ពួកគេ





ស្ថិតនៅទីក្រុងភ្នំពេញ។ សំណុំរឿង និង បញ្ហាធំៗ ដែល ប៉ុល ពត ត្រូវពិនិត្យ និង ដោះស្រាយ មានច្រើនឥតគណនា ដោយហេតុថាបដិវត្តន៍ ត្រូវកសាងរដ្ឋអំណាចមួយថ្មី ដោយបាតដៃទទេ។ នេះជាបញ្ហាមួយ ដ៏ស្មុគស្មាញ។ ប៉ុល ពត មិនត្រឹមតែ មិនបានប្រែក្លាយសត្រូវឲ្យទៅជាមិត្តទេ តែបានប្រែក្លាយ មិត្តជិតស្និទ្ធ ឲ្យទៅជា សត្រូវថែមទៀត ។ ត្រង់ចំណុចនេះ គេសង្កេតឃើញថា ប៉ុល ពត មិនទុកចិត្ត រហូតដល់ទៅក្បួនយុទ្ធសាស្ត្រដែលខ្លួនធ្លាប់បានរៀនផងទៀត ។ សំនួរដែលគេចោទសួរ គឺ ៖ តើគេអាច កសាងសង្គមជាតិ បានទេ បើគេមិនប្រើកម្លាំងគ្រប់ប្រភេទ កម្លាំង នៃ សង្គមទាំងមូលនោះ ? នេះ ជាចំណុចមួយដ៏សំខាន់ សម្រាប់អ្នកដឹកនាំ ក្រោយៗមកទៀត។ យុទ្ធវិទូ និង អ្នកនយោបាយដែលពូកែ គឺអ្នកដែលចេះប្រើ កម្លាំងសង្គមទាំងមូល ឲ្យដើរតាម គោលដៅមួយ ដែលគេបានត្រួសត្រាយ ហើយដែលមាន ប្រយោជន៍ សម្រាប់ទាំងអស់គ្នា ប៉ុន្តែ ដើម្បីដើរឲ្យបានដល់គោលដៅល្អ គេមិនត្រូវប្រើផ្លូវអាក្រក់ឡើយ ព្រោះ សុភមង្គល និង សេរីភាព របស់មនុស្សជាគោលដៅ តែមួយគត់ នៃ រាល់ការតស៊ូ។ សំខាន់ជាងនេះទៅទៀត គេត្រូវដឹងថាគេអាចគ្រប់គ្រង និងប្រើប្រាស់កម្លាំងសង្គម ដោយប្រសិទ្ធិភាពបាន កាលណា គេអាចគ្រប់គ្រង អ្នកមានសេរីភាព គឺ មិនមែន គ្រប់គ្រងទាសករ នោះឡើយ។

## បញ្ហា សំខាន់ៗ ដែលប៉ុល ពត ត្រូវដោះស្រាយ ក្រោយ ព្រឹត្តិការណ៍ ថ្ងៃ ១៧ មេសា

## Pol Pot face aux problèmes qui se posent après le 17 Avril 1975

នៅពេលដែល ខ្មែរក្រហម វាយយកទីក្រុងភ្នំពេញ បានហើយ ប៉ុល ពត ត្រូវប្រឈមមុខ នឹង បញ្ហាធំៗ ដូចជា ការបាក់បែកប្រេះឆាផ្ទៃក្នុង និងបញ្ហាការពារប្រទេសជាដើម ជាពិសេស ការកសាង រដ្ឋអំណាចបដិវត្តន៍។ នៅខែ មេសា និង ខែ ឧសភា ឆ្នាំ

១៩៧៥ ប៉ុល ពត បើកអង្គប្រជុំការងារឥតឈប់ឈរ។ បញ្ហាដែលត្រូវដោះស្រាយសុទ្ធតែជាបញ្ហាដែលគ្មានប្រេក ម្ល៉ោះហើយអង្គប្រជុំនីមួយៗ ប្រព្រឹត្តិទៅតាំង ពីព្រឹករហូតដល់ម៉ោង ១១ យប់ ឬ កណ្ដាលអាធ្រាតតែម្ដង។ បញ្ហាដែលស្មុគស្មាញជាងគេ គឺ ការដែល ពួកមេកងទ័ពខ្មែរក្រហម ពុំព្រមស្ថិតនៅ ក្រោមបញ្ជាការ របស់ អំណាចមជ្ឈិម គឺសុខចិត្ត គ្រប់គ្រងតំបន់ដែលគេកាន់កាប់ដោយខ្លួនគេផ្ទាល់តែម្ដង។ ហេតុដូច្នេះហើយ បានជា អំណាចទាំងមូលរបស់ បដិវត្តន៍ ត្រូវបែងចែក ជាភូមិភាគផ្សេងៗ ហើយ មេម្នាក់ៗ រក្សាស្វ័យភាព របស់គេ យ៉ាងម៉ឺងម៉ាត់។ នៅពេលដដែលនោះ ប៉ុល ពត បារម្ភខ្លាចក្រែងប្រទេសថៃ និងប្រទេសវៀតណាម ឆ្លៀតយកឱកាសនោះ វាយយកស្រុកខ្មែរតែម្ដង។ ទោះបីអាមេរិក បានដកកងទ័ពចេញពី ឥណ្ឌូចិនទៅហើយក្ដី ក៏ ប៉ុល ពត នៅតែខ្លាច អាមេរិក ទម្លាក់គ្រាប់បែក បន្តទៀតដែរ។ នៅខែ ឧសភាឆ្នាំ ១៩៧៥ កប៉ាល់ដឹកទំនិញអាមេរិក «ម៉ាយ៉ាហ្គេស» (Mayaguez) បានត្រូវយោធាខ្មែរក្រហម កាក់ទុក ជាហេតុធ្វើឲ្យអាមេរិក ទម្លាក់គ្រាប់បែកទៅលើទីតាំងកំពុងផែ ដើម្បីរំដោះនាវានោះ។ នៅទីបំផុត នាវា ««ម៉ាយ៉ាហ្គេស» ក៏បានត្រូវពួកខ្មែរក្រហម អនុញ្ញាតឲ្យចេញទៅវិញ។ គឺនៅពេលនោះហើយ ដែល ប៉ុល ពត ធ្លាក់ឈឺ ដាច់បាយដាច់ទឹក ហ៊ឹងត្រចៀក អស់រយៈពេល ៤ ថ្ងៃ។ នេះបើយោងទៅតាមការនិទាន របស់ ឈឹម សា មាក ដែលបានត្រូវប្រវត្តិវិទូ អាមេរិក ដេវីដ ចិនដ្លែរ យកមកសសេរ នៅក្នុងសៀវភៅមួយ ដែលមានចំណងជើងថា *ប៉ុល ពត បងទី ១* (David Chandler : *Pol Pot Frère Numéro Un*, Plon, Paris, 1992) ។ ក្នុងចំណោមបញ្ហា ចំពោះមុខសំខាន់ៗ ដែល ប៉ុល ពត ត្រូវដោះស្រាយ មានបញ្ហាពីរដែលធ្វើឲ្យ ប៉ុល ពត មាន ការប៉ះទង្គិចផ្លូវចិត្ត យ៉ាងខ្លាំង ព្រោះសុទ្ធតែ ជាបញ្ហាអតីតកាល ។ បញ្ហាទី ១ គឺ ការគាបសង្កត់ ពី សំណាក់ប្រទេសចិន បង្ខំ ឲ្យបដិវត្តន៍ខ្មែរ ទទួលយក សម្ដេច នរោត្តម សីហនុ ទៅថែរក្សាឲ្យបានសមស្រប។ ទោះបី នៅក្នុងគោលការណ៍ នៃបដិវត្តន៍ វណ្ណៈអធន សម្ដេច នរោត្តម សីហនុ ត្រូវបាត់ទុកថាជា សត្រូវក្ដី ក៏នៅទីបំផុត ប៉ុល ពត ត្រូវបង្ខំចិត្តធ្វើតាមសិនដែរ ព្រោះ





ចិន ជាបង្អែកតែមួយគត់ របស់ របប ខ្មែរក្រហម។ នៅខែ កញ្ញាឆ្នាំ ១៩៧៥ សម្ដេច នរោត្តម សីហនុ ដែលមានតួនាទីជាប្រមុខរដ្ឋ ដដែលបានវិល ត្រឡប់មកកម្ពុជាវិញ។

បន្ទាប់ពីបានដោះបញ្ហាទី ១ ហើយ ប៉ុល ពត ត្រូវដោះស្រាយបញ្ហា មួយទៀត។ ក្រោយពេលដែលសម្ដេច នរោត្តម សីហនុ យាងមកដល់ កម្ពុជាបន្តិច ប្រទេសវៀតណាម បានដាក់ស្ថានទូត របស់គេ នៅទីក្រុងភ្នំពេញ។ ប៉ុល ពត នៅពេលនោះ គ្មានជម្រើសអ្វីទៀតទាល់តែសោះ ព្រោះ មួយភាគ នៃ មេកងទ័ពខ្មែរក្រហម សុទ្ធតែជាអតីតសហការី របស់ វៀតណាម ដែលពុំទាន់ចុះសម្រុង នឹង ប៉ុល ពត នៅឡើយ ។ ដូចនេះ ទីក្រុងហាណូយ នៅតែមាន លទ្ធភាពគាបសង្កត់ អ្នកបដិវត្តខ្មែរជានិច្ច ។ ប៉ុល ពត មានការចំបែងចិត្តយ៉ាងខ្លាំងកាលបើបានដឹងថា ឯកអគ្គរដ្ឋទូតវៀតណាម គឺលោក ផាំ វ៉ាន់ បាតែម្ដង ។ កាលពីជាង ២០ ឆ្នាំ មុន លោក ផាំ វ៉ាន់ បា បាននាំ ប៉ុល ពត ឲ្យចូលមកក្នុងប្រទេសកម្ពុជា ដើម្បីឲ្យទៅហាត់ហ្វឹកហ្វឺន ធ្វើបដិវត្តន៍ ។ មួយវិញទៀត ការដែលប្រទេសវៀតណាម ប្រញាប់ដាក់ចំណងការទូត ជាមួយខ្មែរក្រហម ព្រោះ នៅខែមេសា និង ខែឧសភា កងទ័ពខ្មែរក្រហម បានទៅតាំងទី នៅក្នុងកោះជាច្រើន នៅឈូងសមុទ្រសៀម ដើម្បីគាបសង្កត់ ឲ្យវៀតណាមពិនិត្យឡើងវិញ នូវការកំណត់ដែនសមុទ្រ ដោយទទួលស្គាល់បូរណភាព ដែនដីខ្មែរ នៅត្រង់លើ ប្រកព ប្រេងកាតក្រោមសមុទ្រ ។ បញ្ហាសំខាន់ មួយទៀត គឺ ការបញ្ជូលប្រជាជន ១៧ មេសា ពោលគឺ អ្នកទីក្រុងប្រមាណ ពី ២ ទៅ ៣ លាន នាក់ ដែលត្រូវ ប៉ុល ពត បានចាប់បង្ខំ ឲ្យទៅធ្វើស្រែចម្ការ ឲ្យចូលមកក្នុងសង្គមបដិវត្ត។ នេះជាបញ្ហា ដ៏ស្មុគស្មាញ ព្រោះអ្នកទាំងនោះត្រូវ ប៉ុល ពត ចាត់ទុកថា សុទ្ធតែជាខ្មាំងទាំងអស់។

## ការបង្កើត រដ្ឋ បដិវត្តរបស់ ខ្មែរក្រហម

## La création d’un Etat révolutionnaire par les Khmers rouges

ដូចយើងបានដឹងរួចមកហើយ ខ្មែរក្រហមបានវាយយក ទីក្រុងភ្នំពេញបាន យ៉ាង ឆាប់រហ័ស។ ប៉ុន្តែពេលបានអំណាចហើយគេពុំដឹងត្រូវកសាងរដ្ឋអំណាចរបៀបណាទេ។ បញ្ហាដែលចោទឡើង ចំពោះមុខ គឺថា តើត្រូវបោះបង់ចោលកម្លាំង សង្គមចាស់ តែម្តង ឬក៏រក្សាទុកសិន។ ប៉ុល ពត បានសម្រេច យកការកសាងកម្លាំងថ្មី ដោយឥត រួញរា ទោះបី កម្លាំងថ្មី សម្រាប់កសាង ប្រទេសនោះ មាននៅតែ ក្នុងអារម្មណ៍ របស់ ប៉ុល ពត ក្តី។ នេះ ជាការស្រមើស្រមៃ របស់អ្នកដឹកនាំសឹងតែគ្រប់រូប ដែលតែងតែ ជឿថា គេអាច ប្តូរសតិអារម្មណ៍ របស់ មនុស្ស ក្នុងរយៈពេលមួយ ដ៏ខ្លី ដោយប្រើអំណាចផ្តាច់ ការនយោបាយតែមួយមុខប៉ុណ្ណោះ។ មួយវិញទៀត ប៉ុល ពត ជឿថាភោគទ្រព្យ សម្បត្តិ ធម្មជាតិ របស់ប្រទេស កម្ពុជា មានគ្រប់គ្រាន់ទាំងអស់ សម្រាប់ធ្វើឲ្យសេដ្ឋកិច្ច ប្រទេស ទាំងមូលមានដំណើរការល្អ ដូចពីពេលមុន ឬ ក៏ ប្រសើរជាងមុន ទៅទៀត ព្រោះតាម ការវិភាគ របស់ ប៉ុល ពត ក៏ ដូចជាមតិទូទៅ របស់ អ្នកម៉ាក្សនិយម ដូច្នេះដែរ នៅ ពេលដែលបដិវត្តន៍កុម្មុយនិស្ត ក្តាប់អំណាចបានហើយ ពួកមូលធននិយម ដែលគេចាត់ ទុកថាជាសភាវៈអាក្រក់នោះ ក៏ រលំរលាយ អស់ទៅដែរ។ ប៉ុន្តែ បញ្ហាដែលចោទ គឺ ថា តើ គេត្រូវកសាង របប សង្គមនិយមរបៀបណា ? ប៉ុល ពត រិះរកគ្រប់មធ្យោបាយ ដើម្បីរកវិធីសាស្ត្រមួយថ្មី សម្រាប់បង្កើតរដ្ឋបដិវត្តមួយ ឲ្យខុសប្លែកពីស្ថាប័ន ដែល ប្រទេសសង្គមនិយម បានបង្កើត កន្លងមក ។ ប៉ុន្តែ សម្រេចសម្រួចទៅ ដោយរកមិន ឃើញ ក៏សុខចិត្តរក្សាទុក នូវ វិធីសាស្ត្រ ដែល បណ្តាប្រទេសសង្គមនិយម បានកំណត់ ដោយបង្កើតរដ្ឋសភាមួយ និង រដ្ឋាភិបាលមួយ។ នៅខែ តុលា ឆ្នាំ១៩៧៥ ប៉ុល ពត បាន បែងចែកការកិច្ចផ្សេងៗ ទៅឲ្យអ្នកបដិវត្ត ១១ រូប ប៉ុន្តែ រក្សាទុក សម្រាប់ខ្លួនផ្ទាល់ នូវ វិស័យសំខាន់ៗ ២ គឺ សេដ្ឋកិច្ច និង ការការពារ ប្រទេស។ នួន ជា បានទទួលការកិច្ច ខាងអង្គការចាត់តាំង និង អប់រំជាតិ ហើយ អៀង សារី ត្រូវចាត់តាំងឲ្យទទួលបន្ទុក ខាងការបរទេស ទាំងក្នុងបក្ស ទាំងក្នុងរដ្ឋ។ ខៀវ សំផន ទទួលបន្ទុកខាងទំនាក់ទំនង ជា មួយរណសិរ្ស រួបរួមជាតិ កម្ពុជា ជាពិសេសជាមួយ សម្តេច នរោត្តម សីហនុ ។ ប៉ុន្តែ ទន្ទឹមនោះ ខៀវ សំផន មានការកិច្ចមួយទៀត គឺ អ្នកកាន់គណនេយ្យ និង អ្នក





កំណត់ថ្លៃទំនិញ។ រីឯ ការកិច្ចពាណិជ្ជកម្ម ក្នុង និងក្រៅប្រទេស បានត្រូវប្រគល់ទៅឲ្យ កុយ ធួន។ សុន សេន ទទួលបន្ទុក ខាងសន្តិសុខ ក្នុងប្រទេស និងអគ្គបញ្ជាការកងទ័ព។ វន វេត មានការកិច្ចទទួលខុសត្រូវ ខាងឧស្សាហកម្ម អយស្ម័យាន និងនេសាទ ។ នង សួន ទទួលខុសត្រូវ ខាងកសិកម្ម ហើយ ឈឹម សាមោក ជានាយខុទ្ទកាល័យ របស់ នាយករដ្ឋមន្ត្រី ។ សឹម សុង ដែលក្រោយមក បានត្រូវតែងតាំង ជាឯកអគ្គរដ្ឋទូត ប្រចាំ ប្រទេសកូរ៉េ ខាង ជើង បានទទួលការកិច្ចខាង គណៈឃោសនា មជ្ឈិមបក្ស។ ខៀវ ធីរិទ្ធ ភរិយា របស់ អៀង សារី បានត្រូវ ប៉ុល ពត ចាត់តាំងឲ្យទទួលខុសត្រូវខាងសង្គមកិច្ច ហើយ យុន យ៉ាត ភរិយា របស់ សុន សេន ទទួលបន្ទុក ខាង វប្បធម៌ អប់រំជាតិ និង ការឃោសនា មាគ៌ាបដិវត្ត។

តួនាទី របស់ សម្តេច នរោត្តម សីហនុ នៅឆ្នាំ ១៩៧៥នោះ គ្មានអ្វីច្បាស់លាស់ ទេ ។ នៅឆ្នាំ ១៩៧៦ ជូ អេនឡាយ អ្នកដឹកនាំចិន ដែលគាំទ្រ សម្តេច នរោត្តម សីហនុ ទទួលមរណភាព។ គឺ នៅពេលនោះហើយ ដែលរដ្ឋធម្មនុញ្ញ នៃ របប កម្ពុជា ប្រជាធិប តេយ្យ បានត្រូវប្រកាសឲ្យប្រើ។ នៅថ្ងៃ ២០ មិនា ឆ្នាំ ១៩៧៦ សម្តេច នរោត្តម សីហនុ បាន លាលែង ពីមុខតំណែងប្រមុខរដ្ឋ ដោយគ្មានការបង្ខិតបង្ខំអ្វី ទាំងអស់ ពីសំណាក់ បដិវត្តន៍ខ្មែរក្រហម។ ប៉ុន្តែ គឺនៅថ្ងៃនោះឯងតែម្តង ដែលខ្មែរក្រហមរៀបចំ ការបោះឆ្នោត ជ្រើសតាំង សភាប្រជាជន។ សូមបញ្ជាក់ថា បើយោងទៅតាមឯកសារ របស់ ដេវីដ ចិនឌ្លែរ នៅពេលដែល សម្តេច នរោត្តម សីហនុ លាលែង ពី មុខតំណែង ស្រាប់តែ ខ្មែរក្រហម បែរជាមាន ការក្រេវក្រោធទៅវិញ។ ការសង្កេតនេះ របស់ ដេវីដ ចិនឌ្លែរ ក៏ ត្រឹមត្រូវដែរ ព្រោះកាលពីឆ្នាំ ១៩៧៥ ប៉ុល ពត មាន ការទើសទែង នឹង សម្តេច នរោត្តម សីហនុ យ៉ាងខ្លាំង។ តាមការពិតទៅ ខ្មែរក្រហមយល់ថា ការលាលែង ពី មុខតំណែង នេះ គឺជាល្បែងនយោបាយមួយ ដែលធ្វើឲ្យ ខ្មែរក្រហមបាក់មុខ ។ ប៉ុន្តែ នៅពេលនោះ ស្ថានភាពរបស់សម្តេច នរោត្តម សីហនុ ក៏ មាន សភាពយ៉ាប់យ៉ឺន ទ្រាំទ្រសឹងមិនបានដែរ ចំពោះព្រះអង្គ ដែលធ្លាប់តែមានអំណាចពិតប្រាកដ។ ប៉ុល ពត បានបញ្ជូនខៀវ សំផន ឲ្យទៅនិយាយសម្រុះសម្រួលជាមួយសម្តេចនរោត្តម សីហនុ

ដើម្បីពន្យាពេលបន្តិចសិន។ ប៉ុន្តែសម្រេចសម្រួចទៅ គឺជាការឥតប្រយោជន៍ ។ នៅក្នុងឆាក នយោបាយ ល្បែងប្រើឥទ្ធិពលគ្នាទៅវិញទៅមកនេះ ជាយុទ្ធវិធីមួយដ៏សំខាន់។ តាមទម្លាប់ របស់ អ្នកនយោបាយ ការប្រើកិត្យានុភាព របស់ វរជនសំខាន់ៗ ដើម្បីបម្រើផលប្រយោជន៍ របស់ក្រុមបក្សពួកខ្លួន វាជារឿងមួយ សឹងតែទូទៅទៅហើយ ។ នៅក្នុងករណី នៃ បដិវត្តន៍ខ្មែរនេះ មិនថាឡើយតែ សម្តេច នរោត្តម សីហនុ ប៉ុណ្ណោះទេ ដែលត្រូវអ្នកខ្លាំងយកទៅប្រើបែបនេះ សូម្បីតែបញ្ញាជន ដែលមានប្រជាប្រិយភាពគ្រាន់បើ ក៏ត្រូវគេប្រមូលយក ទៅឲ្យគាំទ្រ របបមួយ ដែលកំពុង ចុះឥទ្ធិពល ដែរ ។ បើ ហ៊ានរើបម្រាស ពួកគេនឹង បន្ទុចកេរ្តិ៍ឈ្មោះ កុំឲ្យងើបមុខរួចតែម្តង ។

## ការគូសវាស ខ្សែបន្ទាត់នយោបាយ ក្រៅប្រទេស របស់ ខ្មែរក្រហម

## Esquisse de la ligne politique extérieure des Khmers rouges

នៅខែមករា ឆ្នាំ ១៩៧៦ ខ្មែរក្រហម ប្រកាសរដ្ឋធម្មនុញ្ញ របស់គេ ។ ប្រទេសកម្ពុជា នៅពេលនោះ មានឈ្មោះថា «កម្ពុជាប្រជាធិបតេយ្យ» ។ របបខ្មែរក្រហម ដែលកំណត់នៅ ក្នុងរដ្ឋធម្មនុញ្ញនោះ មានលក្ខណៈខុសឆ្ងាយណាស់ ពីកម្មវិធីនយោបាយ ដែល ពួកគេ បាន កំណត់ នៅខែឧសភា ឆ្នាំ ១៩៧០។ គោលការណ៍ ជាមូលដ្ឋាន នៃ របប កម្ពុជា ប្រជាធិបតេយ្យ គឺ របបសមូហភាពនិយម ពោលគឺ របបកុម្មុយនិស្តចំ តែម្តង។ ការអនុវត្តន៍គោល ការណ៍ របបសមូហភាពនិយមនេះ តម្រូវឲ្យ «ប្រជាជនព្រមទាំងទ្រព្យសម្បត្តិ និង មធ្យោ បាយបង្កបង្កើតផលទាំងអស់ ត្រូវ យកមកដាក់ជាសម្បត្តិរួម។ រីឯ វប្បធម៌ថ្មី ត្រូវប្រយុទ្ធ វាយកំទេចវប្បធម៌ ពុករលួយ នៃ សង្គមចាស់ ។ ជំនឿសាសនា គ្រប់ប្រភេទ ត្រូវហាម ឃាត់»។ នៅថ្ងៃ ២ មេសាឆ្នាំ ១៩៧៦ ដដែលនោះ ខ្មែរក្រហមសុខចិត្ត ទទួលការលាលែង ពីមុខតំណែង របស់ សម្តេច នរោត្តម សីហនុ





ហើយខៀវ សំផន បានត្រូវតែងតាំង ជា ប្រធានគណៈប្រធានរដ្ឋ។ បន្ទាប់ពីព្រឹត្តិការណ៍នេះ សម្តេច នរោត្តម សីហនុ បានត្រូវយកទៅដាក់ឃុំទុក នៅក្នុងរាជវាំង ។ នេះជាដំណាក់ការ ដ៏ពិបាកបំផុត របស់ សម្តេច នរោត្តម សីហនុ ដែលគ្មានសង្ឃឹមអ្វីទៀតក្រៅពីការវិវត្តន៍ នៃ ស្ថានការណ៍។ នៅក្នុងរាជវាំង ព្រះអង្គ មានតែវិទ្យុមួយសម្រាប់តាមដាន ព្រឹត្តិការណ៍អន្តរជាតិ ជារៀងរាល់ថ្ងៃ ។ មុនព្រឹត្តិការណ៍នេះបន្តិច គឺ មុនពេលដែលខ្មែរក្រហម សម្រេចសុខចិត្តទទួលយកការសុំលាលែងពីមុខតំណែង របស់ សម្តេច នរោត្តម សីហនុ គណៈមជ្ឈិមបក្ស កុម្មុយនិស្ត កម្ពុជា បានបើកអង្គប្រជុំមួយ ដើម្បីដោះស្រាយ បញ្ហា ប្រទេសវៀតណាមដែលនៅតែពុំ ព្រម ដកកងទ័ព របស់គេ ចេញពីទឹកដី ផ្នែកឦសាន នៃ ប្រទេសកម្ពុជា ។ នេះជាបញ្ហា មួយ ដ៏ស្មុគស្មាញបំផុត ចំពោះខ្មែរក្រហម គឺ ស្មុគស្មាញ ជាងបញ្ហា កំណត់ព្រំដែនទៅទៀត ព្រោះថា ជាបញ្ហា ចំពោះមុខ។ ទោះបី ប៉ុល ពត ជឿថា កងទ័ពខ្មែរក្រហម ជា កងទ័ព ដ៏អង់អាច អាចវាយយកទឹកដីខ្មែរ ដែលវៀតណាម បានក្តិចយកទៅ កាលពីពេលមុនក្តី ក៏ ប៉ុល ពត នៅតែបារម្ភ ខ្លាចក្រែងវៀតណាម វាយប្រហារមកលើស្រុកខ្មែរ នៅថ្ងៃណាមួយនៅពេលខាងមុខដែរ ។ ទោះនៅក្នុងករណីណាក្តី ក៏ ប៉ុល ពត ដឹង យ៉ាងច្បាស់ដែរ ថា ការរក្សាសន្តិភាព ជាការមួយដ៏ពិបាក។ នៅក្នុងស្ថានភាពបែបនេះ ការកំណត់ នយោបាយ ក្រៅប្រទេស ក៏កាន់តែពិបាកថែមទៀត ជាពិសេស នៅពេលមួយ ដែល សម្តេច នរោត្តម សីហនុ ពុំព្រមចូលរួមចំណែក ក្នុងបដិវត្តន៍ខ្មែរ។

នៅក្នុងអង្គប្រជុំគណៈមជ្ឈិម នាដើមឆ្នាំ ១៩៧៦ នោះ ខ្មែរក្រហមម្នាក់ បានថ្លែងថា សម្តេច នរោត្តម សីហនុ កំពុងតែត្រូវប្រទេសបារាំង សហរដ្ឋ អាមេរិក និង ប្រទេសចិន បោះបង់ចោល រីឯប្រទេសកម្ពុជា នៅពេលនេះ ក៏ជាប់កុនដូចគ្នាអ៊ីចឹងដែរ។ បើយោង ទៅតាម ការវិភាគផ្សេងៗ ឃ្លាចុងក្រោយនេះ សំដៅ ជាពិសេស ទៅប្រទេសវៀតណាម។ ខ្មែរក្រហម ដែលបញ្ចេញមតិ របស់គេ នៅក្នុងអង្គប្រជុំនោះ បានបន្ថែមទៀតថា : ទោះជា យ៉ាងណាក្តី ក៏យើង នឹងអាចមានមិត្តភក្តិ នៅអាហ្វ្រិកដែរ ព្រោះបន្តិចទៀតនេះ គេគង់ នឹងបានដឹងថា តើ បដិវត្តន៍យើង មានថាមពលខ្លាំង បែបណា ។

អ្នកដែលឡើងនិយាយ នោះ ដែលពុំយល់អ្វីទាំងអស់ ពីស្ថានការណ៍អន្តរជាតិ ព្រមទាំង ស្ថានការណ៍ នយោបាយ នៅក្នុងភូមិភាគ អាស៊ីអាគ្នេយ៍ បានកត់សំគាល់បន្ថែមទៀត អំពី ជំនឿ របស់គេថា បន្តិច ទៀតនេះ ចលនា បដិវត្ត នៅក្នុងប្រទេសទាំងឡាយ នៅ អាស៊ីអាគ្នេយ៍ អាចនឹងយកជ័យជំនះបាន ហើយដូចនេះ យើងនឹងក្លាយទៅជាគ្រូធំ របស់ គេជាពុំខាន។ កាលបើ បានស្តាប់ បទអន្តរាគមន៍នេះហើយ ប៉ុល ពត ដែលមិនដែល អានកាសែត ឬស្តាប់វិទ្យុអ្វីណាមួយ ក្រៅពីកាសែត និង វិទ្យុកុម្មុយនិស្ត ដើម្បីស្វែង យល់ដឹងអំពី សភាពការណ៍ពិភពលោក ក៏មានជំនឿយ៉ាងមាំថា ចលនាកុម្មុយនិស្ត នឹងត្រូវគ្រប់គ្រងពិភពលោកទាំងមូល ក្នុងពេលឆាប់ៗ ខាងមុខនេះ ។ នេះ ជាចំណុច ខ្សោយមួយដ៏ធំ របស់ ប៉ុល ពត និង ពួកខ្មែរក្រហម ហើយ ក៏ជា ចំណុចខ្សោយ របស់ អ្នកនយោបាយខ្មែរមួយចំនួនដែរ ដែលពុំជឿទៅលើការ វិភាគអ្វីណាមួយ ក្រៅពីការ ឃោសនា របស់ ក្រុមខ្លួន ។ យ៉ាងណាមិញ គ្មានគ្រោះភ័យអ្វីធំជាង ការដែលគេជឿ តែ ទៅលើ ការកុតករ របស់ ខ្លួនផ្ទាល់នោះទេ ។

## ការបោសសំអាត «ជនក្បត់» នៅក្នុង ផ្ទៃបក្ស

## Les purges de 1975-1977

នៅពេលដែល ប៉ុល ពត ប្រគល់តួនាទី នាយករដ្ឋមន្ត្រី មកឲ្យខ្លួនឯង នៅខែ មេសា ឆ្នាំ ១៩៧៦ កិច្ចការសំខាន់បំផុត គឺ ការកសាង របប សង្គមនិយម និង ការកំចាត់ខ្មាំង ដែល ប៉ុល ពត ជឿថាកំពុងបង្កប់ខ្លួននៅក្នុងជួរបក្ស។ ប៉ុល ពត សំដៅ ជាពិសេស ទៅ លើអ្នកដែលមានការជាប់ពាក់ព័ន្ធ ជាមួយ វៀតណាម ដែល ប៉ុល ពត ចាត់ទុក ថា ជាសត្រូវ ទី ១។ តាមការពិតទៅ ក្រៅពីទំនាស់ជាប្រពៃណី រវាងអ្នកដឹកនាំប្រទេស ទាំង ២ នៅគ្រប់ជំនាន់ គ្រប់របប នយោបាយ ខ្មែរក្រហម មាន ទំនាស់ពីរ ទៀត គឺ ៖ ១)





ទំនាស់ រវាងចិន នឹងវៀតណាមផ្នែកទឹកដី ដែលបានក្លាយទៅជាទំនាស់ រវាង កម្ពុជា និង វៀតណាមតែម្តង។ ២) ទំនាស់ខ្សែរយៈបដិវត្តន៍ មានន័យថា ខ្មែរក្រហម យកចិន ជា បង្អែក រីឯ វៀតណាម គេយក សហភាព សូវៀត ជាមេកើយ ។ តាំងពីឆ្នាំ ១៩៥៩ មក ចិន និង សហភាព សូវៀត មានការទាស់ទែង ខ្វែងគំនិតគ្នា យ៉ាងខ្លាំង គឺ ដណ្តើម តួនាទីគ្នា ដឹកនាំបដិវត្តន៍ នៅក្នុងពិភពលោក។ យ៉ាងណាមិញ ទំនាស់ដែលកើតឡើង នៅក្នុងបដិវត្តន៍ កុម្មុយនិស្តខ្មែរ ក៏មានប្រភពចេញពីទំនាស់នេះដែរ។ ពួកខ្មែរក្រហម ដែលស្ថិតនៅក្រោមការដឹកនាំ របស់ ប៉ុល ពត នាំគ្នាដើរតាម មាគ៌ាបដិវត្ត របស់ ចិន ដែលពួកគេចាត់ទុកថា ជាបដិវត្តន៍ វណ្ណៈអធន ពិតប្រាកដ។ ខាងវៀតណាម ឯនោះវិញ គេចាត់ទុកថាលទ្ធិម៉ៅនិយម ពុំបកស្រាយលទ្ធិម៉ាក្ស-លេនីនដោយត្រឹមត្រូវទេ។ ចិនបាន យកមាគ៌ា «មហាលោតផ្លោះមហាអស្ចារ្យ» (Le grand bond en avant) មកធ្វើជា គោលការណ៍ បដិវត្ត របស់គេ។ សម្រេចសម្រួចទៅ បក្សកុម្មុយនិស្ត កម្ពុជា ត្រូវបាក់ បែកគ្នាអស់ ហើយអ្នកដែលប្រឆាំង នឹង មាគ៌ានេះព្រមទាំង ប្រជាជនខ្មែរស្លូតត្រង់ ជិត ២ លាន នាក់ បានត្រូវគេយកទៅសម្លាប់ចោល យ៉ាងខ្លោចផ្សា នៅក្នុងនោះ ភាគច្រើន ជា «ប្រជាជន ១៧ មេសា »[១៩] ។ អ្នកទាំងនេះ ត្រូវគេចាត់ទុកថា ជាខ្មាំងសត្រូវ របស់ បដិវត្តន៍ ។ សម្រាប់កម្មាភិបាលធំៗ ប៉ុល ពត បានបង្កើត គុកមួយ គឺ «គុកទួលស្លែង» ដើម្បី ធ្វើទារុណកម្មសួរចម្លើយ អ្នកដែល ត្រូវជាប់សង្ស័យថា មាន គោលបំណង វាយ រំលំ ប៉ុល ពត។  បញ្ញាជន និង អ្នកដឹកនាំ បដិវត្តន៍ ជាច្រើន ដែលបានចាញ់បោក

[១៩] «ប្រជាជន ១៧ មេសា » ជាប្រជាជន ដែលរស់នៅក្នុងទីក្រុង ហើយ ដែលបានត្រូវ ខ្មែរក្រហម ដេញចេញ ពីលំនៅឋាន របស់គេ នៅថ្ងៃ ១៧ មេសាឆ្នាំ ១៩៧៥ ឲ្យទៅរស់ នៅជនបទវិញ ដើម្បីប្រកបមុខរបរជាកសិករ។ នៅក្នុងចំណោមអ្នកស្រែចម្ការ អ្នកទាំង នេះត្រូវ «ប្រជាជនមូលដ្ឋាន» គឺ ប្រជាជនដែល មានដើមកំណើតនៅជនបទ ចាត់ទុកថា ជា «អនុប្រជាជន »។

ខ្មែរក្រហមក៏បានត្រូវ ប៉ុល ពត បញ្ជូនទៅទីនោះដែរ ដើម្បីធ្វើទារុណកម្ម យ៉ាងឃោរឃៅ មុន នឹង ផ្ដាច់ជីវិតចោល ។

នៅខែកញ្ញា ឆ្នាំ១៩៧៦ អគ្គមគ្គុទេសក៍កុម្មុយនិស្ត «ដ៏ មហិមា» ចិន គឺ លោក ម៉ៅ សេ ទុង ទទួល មរណភាព ។ ប៉ុល ពត ដែលទៅចូលរួម ក្នុងពិធីបុណ្យសព លោកប្រធានម៉ៅ បានថ្លែងនៅក្នុងឱកាសនោះថា «ប្រទេស កម្ពុជា ជា ប្រទេស ដែលប្រកាន់លទ្ធិ ម៉ាក្ស-លេនីន ប៉ុន្តែ គំនិតដែលសម្បូណ៌ណ៌បែប ជាងគេ គឺ គំនិត របស់ លោកប្រធានម៉ៅ»។ ពីរថ្ងៃក្រោយមក នៅស្រុកខ្មែរ ណៃ សារ៉ន ហៅមិត្ត «យ៉ា» ដែលជាលេខាបក្ស តំបន់ឦសាន បានត្រូវចាប់ខ្លួន ដោយត្រូវជាប់ចោទពីបទ «ក្បត់បដិវត្តន៍» ។ បន្ទាប់មក កែវ មាស បានត្រូវចាប់ខ្លួននៅថ្ងៃ ២៥ កញ្ញា។ នៅពេលនោះ ប៉ុល ពត បានប្រកាសលាលែង ពីមុខតំណែង នាយករដ្ឋមន្ត្រី ដោយសំអាង លើមូលហេតុ សុខភាព។ ប៉ុល ពត បានប្រគល់មុខតំណែងនេះ ជាបណ្ដោះអាសន្នសិន ទៅឲ្យ នួន ជា។ ប៉ុន្តែ នៅខែតុលា ប៉ុល ពត ក៏បានវិលមកកាន់មុខតំណែងនេះវិញ។ តាមការពិត ការប្រគល់ មុខតំណែងនេះ ជាបណ្ដោះអាសន្ន ទៅឲ្យ នួន ជា គ្រាន់តែ ជា ល្បិច របស់ ប៉ុល ពត តែប៉ុណ្ណោះ។ ប៉ុល ពត ចង់ដឹងថា តើអ្នកណាខ្លះ ដែលមិនពេញចិត្តនឹងខ្លួន ។ មុនពេលដែល ប៉ុល ពត ត្រឡប់មកកាន់តួនាទី ជានាយករដ្ឋមន្ត្រីវិញ មាន រឿងមួយ បានកើតឡើង គឺ ការខ្វែងគំនិតគ្នា អំពី ការកំណត់ ថ្ងៃកំណើតបក្ស ។ ខ្លះថា ឆ្នាំ១៩៥១ ខ្លះទៀតថា ឆ្នាំ១៩៦០។ បន្ទាប់ពី ណៃ សារ៉ន និង កែវ មាស ត្រូវចាប់ខ្លួន ប៉ុល ពត បានបញ្ជាក់ថា ថ្ងៃកំណើតបក្ស គឺ ឆ្នាំ ១៩៦០។ អ្នកទាំងពីរនេះ ដែលជា ជនកុម្មុយនិស្តជើងចាស់ គឺជំនាន់បណ្ដាឆ្នាំ ៥០ ពុំព្រមទទួលស្គាល់ ប៉ុល ពត ទេ ព្រោះគេនៅតែមានជំនឿទៅលើវៀតណាមជាដរាប។ នៅខែកញ្ញា ឆ្នាំ ១៩៧៦ នោះ អៀង សារី បានលើកឡើងអំពីការប៉ុនប៉ងធ្វើរដ្ឋប្រហាររំលំ ប៉ុល ពត ប៉ុន្តែ អៀង សារី ក៏ បានបញ្ជាក់ ផងដែរថា កងទ័ព គ្មានជាប់ពាក់ព័ន្ធក្នុងរឿងនេះទេ។ គឺ ចាប់តាំងពីពេលនោះមកហើយ ដែលសកម្មភាពធំបំផុតរបស់ ប៉ុល ពត បាញ់មុខព្រួញ តែទៅលើអ្វី ដែល ប៉ុល ពត ហៅថា «ជនក្បត់បដិវត្តន៍» ។ ចំពោះ ប៉ុល ពត ខ្មាំង និង ជនក្បត់ស្ថិតនៅ គ្រប់ទីកន្លែងទាំងអស់





ជាហេតុ ធ្វើឲ្យកម្មាភិបាលជាច្រើន ត្រូវចាប់យកទៅសួរចម្លើយ នៅគុកទួលស្លែង។ ផ្ទុយពី ការយល់ឃើញ របស់ ប៉ុល ពត ថា ភេរវកម្ម ជា មធ្យោបាយ ដែលនាំទៅរក ការបញ្ចប់ នៃ អំពើក្បត់ វិធានការទាំងនេះ បែរទៅជា ការចាប់ផ្ដើមវិកាលដាល នៃអំពើក្បត់ ពេញផ្ទៃបក្ស ទៅវិញ។

# ការពង្រីង ទំនាក់ទំនង រវាង របប «កម្ពុជាប្រជាធិបតេយ្យ» និង ប្រទេសចិន ប្រជាមានិត្

## Développement des relations entre Le Kampuchée démocratique et la République Populaire de Chine

នៅ ថ្ងៃ ២៨ កញ្ញា ឆ្នាំ ១៩៧៧ ប៉ុល ពត បានទៅធ្វើទស្សនកិច្ច ជាផ្លូវការ នៅទីក្រុងប៉េកាំង។ អ្នកអមដំណើរ មានជាអាទិ៍ : អៀង សារី, វន វេត, ជួន ជឿន ព្រមទាំងមេដឹកនាំខ្មែរក្រហម មួយចំនួនផងដែរ។ ប៉ុល ពត បានទទួល បដិសណ្ឋារកិច្ច យ៉ាងអធិកអធម ពីសំណាក់ អ្នកដឹកនាំចិន ថ្នាក់កំពូល គឺ ហ្វា កួ ហ្វ៊ីង និង តេង ស៊ាវ ពីង។ នៅក្នុងឱកាសនោះ ប៉ុល ពត ធ្វើសន្ទថាជាច្រើន នៅក្នុងពិធីជប់លៀងនានា ដែលអ្នកដឹកនាំចិន បានរៀបចំ យ៉ាងមមាញឹក ទទួលជាកិត្តិយសដល់អ្នកដឹកនាំខ្មែរក្រហម។ ប៉ុល ពត បានសំដែង ការកោតស្ញែង ចំពោះលោក ប្រធានម៉ៅ ព្រមទាំង ទ្រឹស្ដី «តស៊ូវណ្ណៈជាអចិន្ត្រៃយ៍» របស់ «អគ្គមគ្គុទេសដ៏មហិមា» របស់ ចិន ។ ហ្វា កួ ហ្វ៊ីង ដែលជាអ្នកទទួលតំណែងបន្ត ពី លោក ម៉ៅ សេ ទុង បាននិយាយសរសើរយ៉ាងខ្លាំងអំពី អ្វី ដែលអ្នកដឹកនាំចិនរូបនេះ ហៅថា «មាគ៌ាដឹកនាំ ដ៏ ត្រឹមត្រូវ របស់ បដិវត្តន៍ខ្មែរ» ។ នៅពេលនោះ លោក តេង ស៊ាវ ពីង ដែលជា សហការី ហើយ ក្រោយមក ជាគូសត្រូវ របស់ម៉ៅ សេ ទុង បានត្រូវមហាសន្និបាតបក្ស ទី ១១ អនុញ្ញាត ឲ្យមានមុខមាត់សាជាថ្មី នៅក្នុងបក្សកុម្មុយនិស្តចិន ដោយមានឋានៈជា អ្នកដឹកនាំជួរទី ៣ ។ បន្ទាប់ពី ម៉ៅ សេ ទុង

ទទួលអនិច្ចកម្មទៅ ប្រទេសចិននៅឆ្នាំ ១៩៧៧ នោះ កំពុងតែស្ថិតនៅក្នុងដំណាក់ការមួយ មិនច្បាស់លាស់ ព្រោះមាគ៌ាបដិវត្ត របស់ ម៉ៅ សេ ទុង បានត្រូវ ប្រជាជន និង អ្នកដឹកនាំ មួយចំនួន រិះគន់យ៉ាងខ្លាំង។ ហួ កួ ហ្វឹង មិនដឹងថា ត្រូវធ្វើការកែទម្រង់បែបណាទេ ហើយ សម្រេចសម្រួចទៅ ក៏ទម្លាក់ទោសទៅលើ ម៉ៅ សេ ទុង និង ទៅលើ ក្រុមរបស់ភរិយាលោកប្រធានម៉ៅ ទាំងអស់ ( «la Bande des quatre» ) ដែលប្រជាជនចិនស្អប់ខ្ពើមជាអនេក។ ទោះជាយ៉ាងនេះក្តី ទោះជា ហួ កួ ហ្វឹង បានបញ្ជាគេឲ្យចាប់ក្រុមនេះក្តី ក៏ ហួ កួ ហ្វឹង ខិតខំរក្សាខ្សែបន្ទាត់នយោបាយ របស់លោកប្រធានម៉ៅដែរ។ តាមការលើកឡើង របស់ អ្នកកាសែត ណាយ៉ាន់ ចន្ទា នៅក្នុង ពិធី ជប់លៀង នៅឱកាសទស្សនកិច្ច របស់ ប៉ុល ពត នៅទីក្រុងប៉េកាំង នាឆ្នាំ ១៩៧៧ នោះ អ្នកដឹកនាំចិន នានា ខិតខំទ្រាំសរសើរ ប៉ុល ពត ដោយត្រដរ នៅពេលដែល ប៉ុល ពត សរសើរ មាគ៌ាម៉ៅនិយម ដោយឥតសំចៃ។ មួយវិញទៀត អ្វីដែលធ្វើឲ្យ អ្នកដឹកនាំចិនទាំងនោះ កាន់តែតឹងទ្រូងថែមទៀត គឺ ការប្តេជ្ញាចិត្ត របស់ ប៉ុល ពត ថា នឹងដើរតាម មាគ៌ា របស់ប្រធានម៉ៅ គឺ មាគ៌ាដែលអ្នកដឹកនាំចិន មើលឃើញ នៅពេលនោះថា កំពុងតែឈានទៅរកទីបញ្ចប់។

នៅក្នុងឱកាសទស្សនកិច្ច មួយសប្តាហ៍ នៅប្រទេសចិន នាខែ សីហា-តុលា ឆ្នាំ ១៩៧៧ នោះ ប៉ុល ពតបានលើកឡើង ក្រៅផ្លូវការ អំពី ទំនាស់របស់ខ្លួនជាមួយប្រទេសវៀតណាម ដោយសង្ឃឹមថាបក្សកុម្មុយនិស្តម៉ៅនិយមនានា នៅប្រទេសថៃ ប្រទេសភូមា ប្រទេសម៉ាឡេស៊ី និង ប្រទេសឥណ្ឌូណេស៊ី មុខជា នឹង ជួយជ្រោមជ្រែងបក្សកុម្មុយនិស្តកម្ពុជាជាពុំខាន ។ ម៉្យាងទៀត ប៉ុល ពត យល់ឃើញថា ទស្សនកិច្ចនោះ នឹង ប្រែក្លាយបដិវត្តន៍កម្ពុជា ឲ្យទៅជា កម្លាំងមួយ ដ៏ ខ្លាំងមហិមា ជាពុំខាន នៅពេលខាងមុខ។ បន្ទាប់ពីទស្សនកិច្ច នៅប្រទេសចិន ប៉ុល ពត ក៏ បានទៅធ្វើ ទស្សនកិច្ច នៅប្រទេសកូរ៉េ ខាងជើងទៀត។ លោក គីម អៀល ស៊ុង ក៏ បានទទួលគណៈប្រតិភូខ្មែរក្រហម យ៉ាង អធិកអធមណាស់ដែរ ។ នៅពេលដែលប៉ុល ពត ត្រឡប់មកស្រុកខ្មែរវិញ ប៉ុល ពត បានដឹងថា នៅពេល ទស្សនកិច្ច របស់គណប្រតិភូជាន់ខ្ពស់ខ្មែរក្រហម នៅប៉េកាំង និង នៅព្យុងយ៉ាង កងទ័ពវៀតណាម បានចូលមកក្នុងទឹកដីខ្មែរ ដើម្បីឆ្លើយតបទៅនឹងការវាយប្រហារ





របស់ ខ្មែរក្រហម ទៅលើ ខែត្រ តាយ និញ ។ តាមការពិត វៀតណាម ចង់សំដែង ជាពិសេស នូវការមិនពេញចិត្ត របស់គេ ចំពោះការរឹតចំណងមេត្រីភាពរវាង ខ្មែរ និង ចិន ដោយហេតុថា វៀតណាម ចង់អូសទាញរបបកម្ពុជា ប្រជាធិបតេយ្យ ឲ្យស្ថិតនៅជាមួយខ្លួន គឺ នៅក្នុងវង្វង់ បដិវត្តន៍ របស់ សហភាព សូវៀត ដែលជា សត្រូវ របស់ ចិន នៅពេលនោះ ។ ចិន ខឹង នឹង វៀតណាមណាស់ ព្រោះវៀតណាម មិនព្រមចូលជាមួយបដិវត្តន៍ចិន ហើយ បែរជាយក សហភាព សូវៀត ជាបង្អែកទៅវិញ។ នេះជាទំនាស់មួយដ៏ធំ ដែលបានធ្វើឲ្យបក្ស កុម្មុយនិស្តខ្មែរ បែកបាក់ប្រេះឆាអស់ ។

# ជីវភាព របស់ប្រជាជនខ្មែរ នៅក្រោម របប ខ្មែរក្រហម

## La vie des Cambodgiens sous le régime khmer rouge

ចាប់តាំងពីខែធ្នូឆ្នាំ ១៩៧៦ មក បដិវត្តន៍ខ្មែរក្រហមឆ្លងកាត់ស្ថានភាពមួយ ដ៏សែន ស្មុគស្មាញ ព្រោះមាន ការបាក់បែកផ្ទៃក្នុង មួយដ៏ធំ ។ នៅក្នុងពេលដដែលនោះ ប្រជាជនទូទាំងប្រទេសដែលបានត្រូវគេកេណ្ឌ យកទៅធ្វើស្រែដូចទាសករ រកអ្វីបរិភោគ សឹងមិនបាន។ បន្តិចម្តងៗ ទុរិក្សរីករាលដាល នៅគ្រប់ស្រុក បំបន់នានា នៃប្រទេសទាំងមូល។ ស្រែ ចម្ការ និង មធ្យោបាយបង្កបង្កើតផលផ្សេងៗ ត្រូវយកទៅដាក់រួម ទាំងអស់ គឺ ត្រូវប្រគល់ ទៅឲ្យ រដ្ឋ និង អង្គការ សមូហភាព នានា ចាត់ចែងចែកចាយ ។ ដោយផលិតផលស្រូវ អង្ករ ត្រី សាច់ និង បន្លែ សព្វសារពើ ធ្លាក់ចុះយ៉ាងខ្លាំង ប្រជាជន គ្មានអ្វីបរិភោគ ហើយ ក៏ ធ្លាក់ឈឺពេញប្រទេស ដោយខ្វះចំណីអាហារគ្រប់គ្រាន់ ។ នៅតាមភូមិនានា រដ្ឋអំណាច ដែលដឹកនាំ សកម្មភាពសេដ្ឋកិច្ច ដោយខ្លួនឯងផ្ទាល់ គ្មានលទ្ធភាព ចិញ្ចឹមប្រជាជន សោះ ឡើយ គឺ បានត្រឹមចែក បបរាវ មួយវែក ឬ ពីរវែកម្នាក់ ប៉ុណ្ណោះ ព្រោះត្រី សាច់ គ្មាន គ្រប់គ្រាន់ ។ ប្រជាជនខ្មែរ នៅពេលនោះ

ជាពិសេស «ប្រជាជន ១៧ មេសា» រស់នៅ យ៉ាងវេទនា ពន់ពេកក្រៃ ។ «ប្រជាជនមូលដ្ឋាន» ដែលបានត្រូវចាត់ទុកថា ជាប្រជាជនពេញសិទ្ធិ ក៏ពុំមានជីវភាព គ្រាន់បើជាង «ប្រជាជន ១៧ មេសា» ប៉ុន្មានដែរ ប៉ុន្តែ មានលទ្ធភាព ដោះស្រាយបញ្ហាដោយ មិនខ្វាច «អង្គការបដិវត្តន៍» ជ្រុលពេកដែរ ។ ពួក «អ្នក មូលដ្ឋាន» ទាំងនោះ មានកូនធ្វើជាយោធា ឬជាកម្មាភិបាលអង្គការខ្មែរក្រហម ហើយ មានបុព្វសិទ្ធិ ធ្វើសកម្មភាពខ្វះខុសពី «ប្រជាជនជម្លៀស»។ នៅក្នុងរបបមុនៗ ទោះបីគេមាន ជីវភាពទីទាល់ក្រ យ៉ាងណាក្តី ក៏គេមានអាហារ បរិភោគ បរិបូរណ៍ដែរ ។ ប៉ុន្តែ នៅក្នុង របបខ្មែរក្រហមនេះ គេកាន់តែធ្លាក់ក្រជាច្រើនកំរិតថែមទៀត ថ្វីបើគេជាអ្នកគ្រប់គ្រង ភូមិ-សង្កាត់ ក៏ដោយក្តី ។ ដោយផលិតផល នៃ ការបង្កបង្កើតផល ដូចជា ស្រូវ អង្ករ ពោត សណ្តែក ដំឡូង ជាដើម បេះតែចុះថយ ជាលំដាប់ដូច្នេះ ប្រជាជន មូលដ្ឋាន ដែល ភាគច្រើន ជា ឪពុកម្តាយ មាមីង របស់ យោធា និង កម្មាភិបាលធំៗ («គណៈតំបន់ » «គណៈភូមិភាគ») ក៏មានការទោមនស្ស យ៉ាងខ្លាំង ។ នៅតាមស្រែចំការ និង ការដ្ឋាន គេតែងតែឮសូរ អ្នកទាំងនេះ ត្អូញត្អែថា: «ធ្វើស្រែប្រវាស់ នឹងមេឃ ហូបបាយ ធ្វើស្រែ ប្រវាស់ នឹង ប្រឡាយ ហូបបបរាវ» ។ នៅសម័យ ប៉ុល ពតនេះ អង្គការបដិវត្តន៍ ឲ្យ លើកទំនប់ ជីកប្រឡាយ យ៉ាងសស្រាក់សស្រាំ ដើម្បីកុំឲ្យរណោប នឹង ទឹកភ្លៀងពេក ប៉ុន្តែ សម្រេចសម្រួចទៅ ស្រូវ អង្ករ កាន់តែខ្វះទៅៗ គួរឲ្យហួសចិត្តពន់ពេកក្រៃ។ ខ្វះដោយធ្វល់ពេក ក៏និយាយថា អង្គការប្រហែលជា ជីកស្រូវចេញទៅឲ្យចិនច្រើនពេក ក៏មិនដឹង។ នៅពេលនោះ ពួកខ្មែរក្រហម បានកេណ្ឌមនុស្ស ជាច្រើនសន្ធឹកសន្ធាប់ ទៅឲ្យលើកទំនប់ ជីកប្រឡាយ ដើម្បី កសាងហេដ្ឋារចនាសម្ព័ន្ធ បង្កបង្កើតផលស្រូវ ព្រោះតែពួកគេ ជឿថា «មានស្រូវ មានអ្វីៗគ្រប់បែបយ៉ាងទាំងអស់»។ ការពិត គឺថា ការបិទប្រកពាណិជ្ជកម្ម និង ការហាមឃាត់មិនឲ្យមានការដោះដូរ ដោយសេរី ជាមួយពិភពលោកទាំងមូល ដើម្បីអនុវត្ត មាគ៌ា «ម្ចាស់ការ» ជាមូលហេតុ ដ៏ចម្បង នៃ ទុរ្ភិក្ស ក្នុងទូទាំងប្រទេសនេះ។

នៅចំពោះមុខ ទុរ្ភិក្ស ដ៏ ធំធេងនេះ ទាំងប្រជាជនមូលដ្ឋាន ទាំងកម្មាភិបាល កាន់តែអស់ ជំនឿបន្តិចម្តងៗ ទៅលើបដិវត្តន៍ ទោះបីគេទទួលការបំពាក់បំប៉នផ្លូវមនោគមវិជ្ជា





និង មាគ៌ា នយោបាយ សឹងតែរៀងរាល់យប់ក្តី។ ប្រជាជនមូលដ្ឋាន តាមភូមិ ដែលអស់រយៈ ពេលជាច្រើនឆ្នាំមកហើយ ជាអ្នកគាំទ្របដិវត្តន៍ យ៉ាងខ្លាំងក្លា ក៏ចាប់ផ្តើមមានការធុញទ្រាន់ នឹងរបប កុម្មុយនិស្តនេះ ដែលកាន់តែនាំមក នូវបញ្ហាប្រចាំថ្ងៃ ច្រើនជាងពីសម័យ «សង្គម ចាស់» (l’ancien régime) ទៅទៀត។ នៅពេលថ្ងៃ គេត្រូវធ្វើពលកម្ម ដូចទាសករ ហើយ ពេលយប់ គេត្រូវចូលប្រជុំរៀនសូត្រ មាគ៌ា បដិវត្តន៍ ដោយខានមិនបាន។ ប្រជាជន មូលដ្ឋាន ក៏ដូចជា «ប្រជាជន ១៧ មេសា» គ្មានសិទ្ធិដើរហើរ ដោយសេរីទេ សូម្បីតែទៅសួរសុខទុក្ខ បងប្អូន កូនចៅ ញាតិមិត្តជិតឆ្ងាយ ក៏មិនបានដែរ ។ រីឯ សកម្មភាព គួបផ្សំផ្សេងៗទៀត ដូចជាការបង់ត្រី ការបរបាញ់សត្វ ក៏ ត្រូវហាមឃាត់ដែរ ព្រោះ កម្មសិទ្ធិឯកជន មិនត្រូវកកើតឡើងវិញជាដាច់ខាត ទោះនៅក្នុងកម្រិតណាក៏ដោយ។ អ្នកដែលភ្លាត់ស្នៀត បានរំលោភ ប៉ះពាល់ គោលការណ៍ ទាំងនេះ ត្រូវចាត់ទុកថា ក្បត់សមូហភាព ឬ ក្បត់មាគ៌ាបដិវត្តន៍តែម្តង។ របស់របរ សព្វសារពើ ព្រមទាំងទឹកស៊ីង បឹងបួ ព្រៃព្រឹក្សា លតាវល្លិ ចម្ការបន្លែ និង ធញ្ញជាតិផ្សេងៗ សុទ្ធតែជា របស់រដ្ឋ ។ អ្នកដែលប៉ះពាល់ ដល់សម្បត្តិធម្មជាតិ អស់ទាំងនេះ ត្រូវយកទៅ «កសាង» យ៉ាងចាស់ដៃ ហើយ សឹងតែ ជាទូទៅ ត្រូវប្រធានភូមិ យកទៅសម្លាប់ចោល ដោយឥតមេត្តា ។ ជនដែលទទួលរងគ្រោះ ដោយសារច្បាប់នេះ មាន ចំនួនច្រើន ណាស់ ដោយហេតុថា បើគេពុំប្រថុយខ្វះទេនោះ គេច្បាស់ជាអត់បាយក្រហាយទឹក ដាច់ពោះស្លាប់ដូចតែគ្នា។ «ប្រជាជន ១៧ មេសា» បាន បាត់បង់ជីវិតច្រើនជាងគេ ព្រោះតែរឿងនេះ ។ គ្មានអ្នកណា អាចគេចផុតពី «កងឈ្លប» ខ្មែរក្រហមបានទេ ព្រោះ «អង្គការភ្នែកម្នាស់» នេះ មាននៅគ្រប់ទីកន្លែងទាំងអស់។ រីឯ សំនួរ ដែលគេនាំគ្នាចោទសួរនៅពេលនោះ គឺថា ចុះហេតុដូចម្តេច បានជា អង្គការ ខ្មែរ ក្រហមធ្វើបាបប្រជាជនឯងដល់ថ្នាក់នេះ? តាមការពិតទៅ ចម្លើយមានច្រើនណាស់។ ប៉ុន្តែ អ្វីដែលគេពុំអាចប្រកែកបាន គឺ ការមានជំនឿផ្តាប់មុខ ទៅលើ ទ្រឹស្តីមួយ ដែល សង្គមវិទូ រ៉េម៉ុង អារ៉ុង (Raymond Aron) ហៅថា «អាភៀន របស់ បញ្ញវន្ត» («l’opium des intellectuels») ។ ច្បាប់ក្បួនដែលគ្រប់គ្រងសង្គមមនុស្ស ទោះចេញ មកពី ប្រភពណា

ក៏ដោយ មិនមែន សុទ្ធតែសម្រាប់ សម្រួល ដល់ជីវិតមនុស្សលោក នោះឡើយ។ នៅក្នុង ករណីខ្លះ គឺជាកាំបិទមុខពីរ ។ គឺនៅក្នុងន័យនេះហើយដែល ទស្សនវិទូ អាល់ប៊ែរ កាមូស (Albert Camus) សរសេរថា ៖ «ការពិចារណា ច្បាស់លាស់ត្រឹមត្រូវ ល្អឥតខ្ចោះ តាមប្រព័ន្ធគំនិតសីលធម៌ ឬឧត្តមគតិពេកតែងតែនាំទៅរកការបង្ហូរឈាម» («*Les sanglantes mathématiques qui ordonnent notre condition*») ។ ចម្លើយមួយទៀត គឺ ច្បាប់ អំណាចផ្តាច់ការ ពោលគឺ ការហួងហែង ការរំលោភទៅលើសេរីភាពរបស់មនុស្សច្រើន ហួសហេតុពេក ដើម្បីឈានឲ្យបានដល់ អ្វីដែលគ្មានទាំង អត្ថិភាពពិតប្រាកដផងនោះ ពុំមែនជាកត្តា នៃ ប្រសិទ្ធិភាពទេ ព្រោះ វាធ្វើឲ្យ កោសិកា សង្គម ពោលគឺ បុគ្គល និង គ្រួសារ ធេះខ្ទាច ឬ បាត់បង់ ថាមពល អស់ជាស្រេចទៅហើយ។ ការធ្វើច្បាប់ដោយ ឈរនៅលើមូលដ្ឋាន គ្មានទំនុកទុកចិត្ត ទៅលើប្រជាជនទុកជាមុនស្រេច តែងតែនាំមក នូវ ការមិនទុកចិត្តគ្នារហូត។ ច្បាប់កាច់បំបាក់មនុស្ស តែ មនុស្សក៏អាចកាច់បំបាក់ ច្បាប់ បានវិញដែរ នៅក្នុងករណី ដែលវានាំសង្គមទាំងមូលទៅរកការអន្តរាយ។ តាមការពិត គេត្រូវធ្វើអ្វីៗទាំងអស់ ដើម្បី មនុស្ស តែប៉ុណ្ណោះ ។ សុបិនរបស់ បុគ្គល ពីរ-បីនាក់ មិនមែន សុទ្ធតែជសុបិន របស់ មនុស្សរាប់លាននាក់ នោះទេ ទោះបីគេខិតខំ បញ្ចុះបញ្ចូល និង លាង ខួរក្បាលអ្នកដទៃ យ៉ាងណាក្តី។

## សង្គ្រាម រវាង ចិន និង សហភាព សូវៀត ៖ ឆ្ពោះទៅរក ការរលំរលាយ នៃ របប ខ្មែរក្រហម

## Guerre sino-soviétique : la chute du régime khmer rouge

បដិវត្តន៍ ខ្មែរក្រហម ដែលបានគ្រប់គ្រងប្រទេសកម្ពុជា ចាប់តាំង ពីថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ មកទល់ថ្ងៃ ៧ មករាឆ្នាំ ១៩៧៩ បានសាបព្រួសនូវវិនាសកម្មមួយដ៏ធំធេង។ សង្គម ខ្មែរទាំងមូលត្រូវបែកបាក់ រចនាសម្ព័ន្ធ យ៉ាងដំណំ ។ ប៉ុល ពត ដែលជា អ្នកដឹក





នាំ ចលនាកុម្មុយនិស្តខ្មែរ បានកំណត់មុខព្រួញជាមូលដ្ឋាន ពីរ ៖ ១) វាយរំលំ របបមូលធននិយម របបសក្តិភូមិ - ២) ការប្រឈមមុខ នឹង ប្រទេសវៀតណាម ។ រីឯយុទ្ធសាស្ត្រនេះសោត គឺ ផ្អែកទាំងស្រុង ទៅលើទ្រឹស្តី «ឯករាជ្យ-ម្ចាស់ការ» ។ តាមការពិតទ្រឹស្តីនេះ មានប្រភពមកពី សមាជិកការិយាល័យ នយោបាយ បក្សកុម្មុយនិស្តចិនម្នាក់ ឈ្មោះ ចិន យ៉ុងគី ។ នៅក្នុងការវាយរំលំ របប សក្តិភូមិ និង របប មូលធននិយម ប៉ុល ពត បាន ដេញប្រជាជន ចេញអស់ពីទីក្រុង ដើម្បីលុបបំបាត់ សកម្មភាព ពាណិជ្ជកម្ម គ្រប់រូបភាព ព្រមទាំងរូបិយវត្ថុ ដែលជាមូលដ្ឋាន នៃ ការដោះដូរ ហើយដែល ប៉ុល ពត យល់ថា ជា កត្តា នៃ ការកេញប្រវ័ញ្ចន៍ ដ៏ អាស្រូវ ។ ប្រាក់រៀលរបស់ខ្មែរ បានត្រូវយក ««អង្ករវាល់ កំប៉ុង»» មកធ្វើជា ឯកតារូបិយវត្ថុជំនួស ។ ដោយស្រូវ អង្ករមានតួនាទី ជាមូលដ្ឋាន តែមួយគត់ នៃ សេដ្ឋកិច្ច ប្រជាជនខ្មែរ ទាំងអស់ ត្រូវពួកប្រធានភូមិ បញ្ជូនឲ្យទៅធ្វើស្រែ ចម្ការ លើកទំនប់ ជីកប្រឡាយ ទាំងបង្ខំ ។ ដើម្បីអនុវត្តផែនការ ដ៏ ចម្លែកនេះ ប៉ុល ពត ប្រើអំពើភេរវកម្ម នៅគ្រប់ទីកន្លែង ក្នុងទូទាំងប្រទេស។ អ្នកដែលពុំព្រមអនុវត្តតាម ទោះ ជាប្រជាជនសាមញ្ញ ឬកម្មាភិបាលក្តី ត្រូវយកទៅវាយនឹងត្បូងចប សម្លាប់ចោល ដោយ ឥតស្តាយស្រណោះ។ នៅទីបំផុត សេដ្ឋកិច្ចប្រទេសទាំងមូល បានធ្លាក់ចុះមកក្រោមសូន្យជាច្រើនកម្រិត បង្កើតឡើងនូវទុរ្ភិក្ស ពេញប្រទេស។ ដោយខ្វះថ្នាំសង្កូវគ្រប់បែបយ៉ាង ប្រជាជនខ្មែរ បាត់បង់ជីវិត សឹងតែផុតពូជ រលត់ជាតិ ។ គឺ នៅពេលនោះហើយ ដែលប្រជាជនខ្មែរ និង កម្មាភិបាលខ្មែរក្រហមជាច្រើន បានត្រូវយកទៅ ប្រហារជីវិត សឹងតែ រៀងរាល់ថ្ងៃ ។ ប៉ុល ពត មើលឃើញសត្រូវនៅគ្រប់ទីកន្លែង ។ ដោយទទួលបានតែ លទ្ធផល អាក្រក់ដូច្នេះ ប៉ុល ពត ទម្លាក់ទោសកំហុសទៅលើ ការអនុវត្តន៍ ទាំងស្រុង ពោល គឺ ទៅលើ កម្មាភិបាលរបស់ ខ្លួន។

នៅពេលដែល ប្រទេស ទាំងមូល កំពុងធ្លាក់ចុះដុនដាបគ្រប់វិស័យ ប៉ុល ពត ត្រូវប្រឈមមុខ នឹងការវាយប្រហារ របស់ កងទ័ព វៀតណាម ដែលរង់ចាំតែ ឱកាសហុចឲ្យ ប៉ុណ្ណោះ ដើម្បីផ្តល់មេរៀនឲ្យ ប៉ុល ពត។ នៅ ខែធ្នូ ឆ្នាំ ១៩៧៧ នៅពេលដែល សមាជិក ការិយាល័យ បក្សកុម្មុយនិស្តចិន ឈ្មោះ ចិន យ៉ុងគី មកធ្វើទស្សន

កិច្ចនៅកម្ពុជា ប៉ុល ពត បានស្នើសុំ ជំនួយយោធាចិន ដើម្បីវាយទប់ទល់ នឹងកងទ័ពវៀតណាម ដែលបានលើកទ័ព ចូលមកក្នុងទឹកដីខ្មែរ នៅពេលដែល ប៉ុល ពត ទៅធ្វើទស្សនកិច្ច នៅ ប៉េកាំង កាលពីខែតុលា-កញ្ញា ឆ្នាំ ដដែលនោះ ។ ប៉ុន្តែ ចិន យ៉ុងគីពុំហ៊ានលើកឡើង ពីបញ្ហានេះទេ ទោះបីនៅពេលនោះ ទីក្រុងប៉េកាំង ចង់ផ្ដល់មេរៀនមួយ ដល់ទីក្រុងហាណូយក្ដី ។ ទំនាស់ រវាង ចិន នឹង សហភាព សូវៀត នៅពេលនោះ មានលក្ខណៈពុះកញ្ជ្រោល ខុសធម្មតា។ រីឯ ប៉ុល ពត មានសេចក្ដីសង្ឃឹមច្រើនទៅលើកម្លាំង របស់ ចិន ក្នុងការប្រយុទ្ធ តទល់ នឹងវៀតណាម។ ការពិត ចិន ក៏មានការញញើត សហភាព សូវៀតដែរ សហភាព សូវៀត ដែលជាបង្អែក ដ៏មាំ របស់វៀតណាម ។ រីឯបញ្ហាជាកូនសោក្នុងរឿងនេះ គឺ តើអ្នកណា ហ៊ានវាយអ្នកណាមុន ? នៅទីបំផុត សហភាព សូវៀត បានសម្រេចជួយវៀតណាម ឲ្យវាយរំលំ របប ខ្មែរក្រហមតែម្ដង បន្ទាប់ពីខ្មែរក្រហម បានបញ្ជូន អង្គភាពយោធាតូចៗ ដែលមានគ្នា ប្រមាណ ២ ឬ ៣ ពាន់នាក់ ឲ្យចូលទៅក្នុងទឹកដីវៀតណាម នៅដើម ខែធ្នូ ឆ្នាំ ១៩៧៧ ។ នៅថ្ងៃ ១៧ ធ្នូ ឆ្នាំដដែលនោះ កងទ័ព វៀតណាម ប្រមាណ ៥ ម៉ឺននាក់ - នេះ បើយោងទៅតាម «សៀវភៅខ្មៅ» របស់ខ្មែរក្រហម - បានចូលមក ក្នុងទឹកដីខ្មែរ ក្នុងជម្រៅ ២០ គ. ម.។ ប៉ុល ពត បានសម្រេចផ្ដាច់ទំនាក់ទំនងទូត ជាមួយ ទីក្រុងហាណូយ នៅចុងខែធ្នូឆ្នាំនោះឯង ។ ចំពោះប្រវត្តិវិទូ ដេវីដ ចិនដ្លែរ (D. Chandler) ហេតុដែលវៀតណាម លើកទ័ពចូលមកក្នុងទឹកដីខ្មែរ នៅខែធ្នូឆ្នាំ ១៩៧៧ នោះ គឺជា ការកំញើញបន្ទំ ឲ្យខ្មែរក្រហម ទទួលយកការឈប់បាញ់គ្នាតែប៉ុណ្ណោះ។ ប៉ុន្តែ ដេវីដ ចិនដ្លែរ ក៏ បានសរសេរ កត់ត្រាផងដែរថា ចំពោះ ទីប្រឹក្សាយោធា របស់ ប្រធានាធិបតី អាមេរិក ការវាយលុកនេះ ជាសង្គ្រាមរវាង សហភាព សូវៀត និង ប្រទេសចិន តាមរយៈវៀតណាម និង ខ្មែរក្រហម ដោយប្រកែកពុំបាន។





# សភាពការណ៍ នៅក្នុង របប ខ្មែរក្រហម នៅឆ្នាំ ១៩៧៨

## La situation interne du régime khmer rouge en 1978

ព្រឹត្តិការណ៍ ដែលកើតមានឡើង នៅ ឆ្នាំ ១៩៧៨ បញ្ជាក់យ៉ាងច្បាស់ថា របប ក្រហម បានឈានមកដល់ ទីអវសាន យ៉ាងឆាប់រហ័ស ព្រោះ ប៉ុល ពត ត្រូវប្រឈមមុខ នឹង ទុរ្ភិក្សផង នឹង ការបះបោរក្នុងប្រទេសផង ហើយត្រូវទប់ទល់ នឹង កងទ័ពដ៏ខ្លាំង មហិមា របស់វៀតណាម ផងទៀត ។ នៅថ្ងៃ ៦ មករាឆ្នាំ ១៩៧៨ កងទ័ព ខ្មែរក្រហម បានធ្វើការវាយប្រហារ តបត នឹង កងទ័ពវៀតណាម ដោយចូល ទៅក្នុងដែនដីប្រទេសវៀត ណាមតែម្ដង ។ ទីក្រុងហាណូយ បានបញ្ជាឲ្យ កងទ័ពរបស់គេ ដកថយគ្រប់ទីកន្លែង លើកលែងតែចំណុច មួយចំនួនប៉ុណ្ណោះ ដើម្បីផ្ដុំកម្លាំងវាយរុល ឲ្យបានជ្រៅបំផុតចូលទៅក្នុងទឹកដីខ្មែរ ហើយ បង្កើតស្នូលរដ្ឋបាលមួយ ធ្វើជាមូលដ្ឋាន សម្រាប់ជួយកម្លាំងខ្មែរ ក្រហម ដែលកំពុង បះបោរប្រឆាំង នឹង ប៉ុល ពត ។ គឺ នៅពេលនោះហើយដែលខ្មែរប្រមាណ ១ ម៉ឺននាក់ នៅភូមិភាគបូព៌ា បាននាំគ្នារត់ភៀសខ្លួនទៅប្រទេសវៀតណាម ដើម្បី គេចឲ្យផុត ពីការសម្លាប់រង្គាលរបស់ ប៉ុល ពត។ ១២ ថ្ងៃ ក្រោយពេលដែល កងទ័ពខ្មែរក្រហម វាយចូលទៅក្នុងដីវៀតណាម លោកស្រី តេង យីង ចាវ ភរិយាម៉េម៉ាយ របស់ លោក ជូ អេនឡាយ បានមកធ្វើទស្សនកិច្ច នៅកម្ពុជា ដើម្បីសាកល្បង ឲ្យខ្មែរក្រហម ប្ដូរនយោបាយ។ លោកស្រី តេង យិងចាវ ចង់ចូលគាល់សម្ដេច នរោត្តម សីហនុ ដែរ ប៉ុន្តែ ខ្មែរក្រហម ពុំព្រមអនុញ្ញាតឲ្យជួបទាល់តែសោះ។ នៅពេលនោះ ទីក្រុងប៉េកាំង មាន ការព្រួយបារម្ភ យ៉ាងខ្លាំង ព្រោះគេដឹងថា ប៉ុល ពត មិនអាចទប់ទល់ នឹង កម្លាំងទ័ពវៀត ណាម ដែលមានការគាំ ទ្រយ៉ាងរឹងមាំ ពី សហភាព សូវៀតបានឡើយ ។ មធ្យោបាយ មានតែមួយគត់ គឺ ត្រូវប្ដូរនយោបាយ ឬ

អ្នកដឹកនាំ តែម្តង ក៏អាចថាបាន ។ ប៉ុល ពត ជាអ្នកនយោបាយម្នាក់ ដែលធ្លាប់តែ បេះបត់បែន តាមសភាពការណ៍ យ៉ាងប៉ិនប្រសប់ ប៉ុន្តែ ម្តងនេះ ឥរិយាបថ របស់គេ រឹងត្អឹប គ្មានអ្វីអាចបន្ទន់ បានសោះ។ នៅពេលដែលលោក ស្រី តេង យឹងចាវ កំពុងស្ថិតនៅក្នុងប្រទេសកម្ពុជា កងទ័ព នៃ របប កម្ពុជាប្រជាធិបតេយ្យ បានប្រើកងកម្លាំងធំ បាញ់ចូលទៅក្នុងខែត្រវៀតណាម ចូវ ឌឹក និង តាយ និញ។ នៅចុងខែមករាឆ្នាំ ១៩៧៨ នោះ លោករដ្ឋមន្ត្រី ការបរទេសថៃ បានមក ធ្វើទស្សនកិច្ច នៅកម្ពុជា ដើម្បីធ្វើឲ្យទំនាក់ទំនងរវាង ប្រទេសទាំងពីរ មានលក្ខណៈប្រសើរឡើងវិញ។ ប្រទេសថៃ ជាប្រទេសមួយ នៃ សមាគម ប្រជាជាតិ អាស៊ីអាគ្នេយ៍ (អាស៊ាន) ដែលយល់ថា វៀតណាម ដែលមានសហភាព សូវៀតពីក្រោយ ជាការគំរាមកំហែងមួយ ដ៏ធំ ចំពោះ ប្រទេស នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។ ហេតុដូច្នេះហើយ បានជាថៃ សង្ឃឹមទៅលើខ្មែរ ក្រហម ដើម្បីទប់ទល់ នឹង វៀតណាម ។ ខាងវៀតណាមឯនោះវិញ នៅថ្ងៃ ៦ កុម្ភៈឆ្នាំ ១៩៧៨ នោះ គេបានស្នើ ឲ្យខ្មែរក្រហមទទួលយក ផែនការមួយ ដើម្បីដោះស្រាយ ទំនាស់ព្រំដែន ។ មួយថ្ងៃក្រោយមក គឺ នៅថ្ងៃ ៩ កុម្ភៈ ខ្មែរក្រហម បានបាញ់ផ្លោងយ៉ាងសម្បើមអស្ចារ្យ ទៅលើខែត្រ តាយ និញ ចូវ ឌឹក និង ហុង ងឺ ។

នៅពេលដែលខ្មែរក្រហម កំពុងជាប់ដៃធ្វើការវាយប្រហារ ទៅលើ ប្រទេសវៀតណាម នៅខាងព្រំដែនថៃ ឯណោះវិញ កងទ័ពខ្មែរក្រហម ក៏ត្រូវប្រយុទ្ធ នឹង កងទ័ពថៃថែមទៀត។ នៅក្នុងជួរអ្នកបដិវត្តន៍ខ្មែរ ភាពប្របូកប្របល់មួយ បានកើតឡើង ៖ បន្ទាប់ពី ជូ ចិត្ត អ្នកដឹកនាំ គណប្រធានភូមិភាគបស្ចិម បានត្រូវចាប់ខ្លួន អ្នកដឹកនាំភូមិភាគបស្ចិម មួយចំនួនទៀត និង អ្នកដឹកនាំភូមិភាគឧត្តរ និងបូព៌ា ក៏បានត្រូវ ប៉ុល ពត បញ្ជូនកងទ័ពឲ្យទៅ ចាប់ដែរ។ ២ ថ្ងៃក្រោយការចាប់ខ្លួន ជូ ចិត្ត គឺនៅថ្ងៃ ២៩ មិនា កងទ័ពវៀតណាម ប្រដាប់ដោយរថក្រោះ បានចាប់ផ្តើមវាយប្រហារមកក្នុងទឹកដីខ្មែរ គឺ នៅក្នុងខែត្រតាកែវ និងកំពត។ ទន្ទឹមនោះ ចាប់តាំងពីថ្ងៃ ៣ មេសា វិទ្យុទីក្រុងហាណូយ បានបំផុសបំផុលឲ្យ ប្រជាជនខ្មែរងើបឡើង បះបោរ វាយរំលំ ខ្មែរក្រហម ។ នៅថ្ងៃ ២២ មេសា ទីក្រុងហាណូយ ត្រៀមជាស្រេច រៀបចំកងទ័ព ពិសេសមួយ សម្រាប់ វាយរំលំខ្មែរក្រហម ក្នុង



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ទ្រង់ទ្រាយ មួយដ៏ធំតែម្តង។ ដោយជឿថា អ្នកដឹកនាំ ភូមិភាគបូព៌ាទាំងមូល មុខជា នឹងក្លាយ ទៅជា បង្អែក របស់វៀតណាម ប៉ុល ពត ក៏ចាប់ផ្តើមបញ្ជូនទ័ព ទៅចាប់អ្នកទាំងនោះទុកជាមុន ។ ប៉ុន្តែ ខ្មែរក្រហម នៃ ភូមិភាគបូព៌ា បានធ្វើការទប់ទល់វិញ យ៉ាងខ្លាំងក្លាជាហេតុបណ្តាល ឲ្យមាន ការបង្ហូរឈាមមួយ ដ៏ សម្បើមអស្ចារ្យ ។ នេះជាការប្រយុទ្ធផ្ទៃ ក្នុងមួយដ៏ធំជាងគេ ។ ខ្មែរក្រហម និង ខ្មែរក្រហម បានកាប់សម្លាប់គ្នាឯង ដោយឥតត្រាប្រណី។ នេះជាសក្ខីកម្មមួយដែលបញ្ជាក់ថា របបខ្មែរក្រហម បានឈានមកដល់ទីអវសាននៅទីបំផុត។ អ្វីៗក៏ បណ្តាលមកតែពី ការមិនទុកចិត្តគ្នាទៅវិញទៅមកដែរ ។ យ៉ាងណាមិញ ទីអវសាន នៃ របបមួយ ក៏ បណ្តាលមក ពីការបាត់ទំនុកចិត្តទៅលើ ការកំណត់មាគ៌ា នយោបាយ និង ទៅលើ អ្នកដឹកនាំដែរ។

## ការឈាន ទៅរក ទីអវសាន នៃ របប ខ្មែរក្រហម

## Vers la fin du régime khmer rouge

នៅពេលដែល របប កម្ពុជាប្រជាធិបតេយ្យរបស់ ខ្មែរក្រហមចាប់ផ្តើម ដឹងខ្លួនយ៉ាងច្បាស់ថា ទីក្រុងហាណូយ បាន ត្រៀមលក្ខណៈជាស្រេច ដើម្បីវាយប្រហារ មកលើខ្លួន ប៉ុល ពត ក៏តាំង ខិតខំស្វះស្វែង រកបង្អែក ជាបន្ទាន់ ។ នៅក្នុងក្របខណ្ឌ នៃ នយោបាយថ្មីនេះ គណប្រតិភូបរទេស ជាច្រើន បានមកធ្វើ ទស្សនកិច្ច នៅកម្ពុជា ដូចជា គណៈប្រតិភូប្រទេស ភូមា ប្រទេសម៉ាឡេស៊ី ប្រទេសថៃ ប្រទេសរូម៉ានី និងប្រទេសយូហ្គោស្លាវី ជាដើម ។ គណ ប្រតិភូ នៃបក្សកុម្មុយនិស្ត នៃប្រទេសជាបច្ចាមិត្ត ជាច្រើន ព្រមទាំងអ្នកកាសែតមួយចំនួន ក៏បានត្រូវអនុញ្ញាតឲ្យចូលមកដែរ។ ប៉ុល ពត បានទទួលគណៈប្រតិភូទាំងនោះ យ៉ាងរាក់ទាក់ ។ គឺ នៅក្នុងរយៈពេលនោះហើយ ដែល ប៉ុល ពត សុខចិត្តនិយាយរៀបរាប់ អំពី ជីវប្រវត្តិ របស់ខ្លួន ប្រាប់ក្រុមទូរទស្សន៍ ប្រទេស យូហ្គោ

ស្វារ៉ីដែល បានមកស្នាក់នៅ ១០ ថ្ងៃ ក្នុងស្រុកខ្មែរ។ ប៉ុន្តែ ដូចកាលពី ពេលធ្វើទស្សន
កិច្ច នៅប្រទេសកូរ៉េ ខាងជើង ដូច្នេះដែរ ប៉ុល ពត ពុំបាននិយាយ អំពីវណ្ណៈដើម ដ៏ ហ៊ំ
ហាន របស់ខ្លួនទេ ហើយ ក៏មិននិយាយ ទាល់តែសោះអំពី វិជ្ជា និង ការអប់រំ ដែលខ្លួន
បានទទួលនៅក្នុងសង្គមចាស់។ ប៉ុល ពត តាំងខ្លួនជាកសិករក្រីក្ររហូត។ សូម្បីតែឈ្មោះ
ពិតប្រាកដ របស់ខ្លួន ក៏ប៉ុល ពត មិនប្រាប់ដែរ ។ ជាលើកដំបូងបង្អស់ ប៉ុល ពត បាន
ធ្វើការសារភាព ប្រាប់អ្នកកាសែត ទូរទស្សន៍ យូហ្គោស្លាវី ថា ខ្លួនបានទៅរៀនសូត្រ នៅ
ប្រទេសបារាំងមែន ទោះបីការសារភាពចុងក្រោយនេះ ជាចំណុចខ្សោយមួយ ដ៏ធំ របស់
ខ្លួនក្តី ។ តាំងពីពេលមុនៗមក ប៉ុល ពត តែងតែសាកល្បង ចង់លុបបំបាត់ នូវ អតីត
កាលនេះ ដែលមិនស័ក្តិសម និង គុណូបការ របស់បដិវត្តន៍ នៃ វណ្ណៈអធន។ ប៉ុល ពត
ចង់យកប្រៀប ទៅលើអ្នកបដិវត្តផ្សេងៗទៀត ដលសុទ្ធតែជាអ្នកមានសញ្ញាបត្រគ្រាក់ៗ
មកពីប្រទេសបារាំង គឺសក្ខីភាព ដែលបញ្ជាក់ថា ជាអ្នកដែលមានបុព្វសិទ្ធិ ក្នុងសង្គម
ចាស់។ គឺអ្នកប្រភេទចុងក្រោយនេះហើយ ដែលប៉ុល ពត បង្ខំឲ្យកសាងខ្លួនឡើងវិញ
ក្នុងបដិវត្តន៍ មានន័យថា ត្រូវបោះបង់ចោលទាំងអស់ នូវអ្វីៗ ដែលខ្លួនបានរៀន ពីពេល
មុន ដើម្បីក្លាយ ទៅជា កសិករ ក្រ សុទ្ធសាធ ។ ចំពោះ អ្នកបដិវត្តន៍ ដែលបានទៅរៀន
សូត្រ នៅប្រទេសវៀតណាម «ទោស» របស់គេ កាន់តែធ្ងន់ធ្ងរថែមទៀត ។ អ្នកខ្លះក្នុង
ចំណោមអ្នកទាំងនេះ បានត្រូវបញ្ជូន ទៅឲ្យ គេសួរចម្លើយ នៅ គុកទួលស្លែង ហើយខ្លះ
ទៀត ដូចជា សោ ភឹម ជាដើម ក៏ដាច់ចិត្ត ធ្វើអត្តឃាត តែម្តង។ ខ្លះទៀត ដូចជា ប៊ូ ថង
ជាដើម ក៏រត់ទៅពួននៅផ្ទៃកព្វសាន ហើយមួយចំនួនទៀត ក៏រត់ទៅ វៀតណាមបាត់ទៅ។

ចាប់តាំងពីពាក់កណ្តាល ឆ្នាំ ១៩៧៨ មក ការបះបោរ នៅក្នុងជួរកម្មាភិបាលខ្មែរ
ក្រហម កាន់តែមានលក្ខណៈច្បាស់ទៅៗ ទោះបី អ្នកដឹកនាំមួយចំនួន ខំលាក់បំបាំងខ្លួន
យ៉ាង ណាក្តី។ អ្នកដែលត្រូវ ប៉ុល ពត កោះហៅម្តងៗ មានការភិតភ័យតក្កមាហើយខ្លះ
ក៏ សម្លាប់ខ្លួនដើម្បីគេចឲ្យផុត ពីទារុណកម្ម ដ៏សែនវេទនា ដូចជាយក ទៅដាក់នៅក្នុង
ទូមួយ ដែលរកដេកក៏ពុំបាន អង្គុយក៏ពុំបាន ឈរក៏ពុំបាន ជាដើម។ ទារុណកម្ម បែបនេះ
ខ្មែរពុំដែលប្រើទាល់តែសោះ ទោះនៅក្នុង សម័យកាល ណា ក៏ដោយ ។ ក្នុងមួយថ្ងៃៗ





ប្រធានភូមិ និងគណៈតំបន់ជាច្រើន បានត្រូវ ប៉ុល ពត ចាប់ យកទៅសម្លាប់ចោល
ដើម្បីយកអ្នកថ្មីមកជំនួស។ អ្នកដែលមានមុខនាទីសំខាន់ៗ រិះរកគ្រប់មធ្យោបាយ ដើម្បី
ទាក់ទាញអារម្មណ៍ ឲ្យប្រទេស ធំៗ ចូលមកធ្វើអន្តរាគមន៍ វាយរំលំ របបនេះ ចោលតែ
ម្តង។ នៅខែធ្នូ ឆ្នាំ ១៩៧៨ អ្នកកាសែត អាមេរិក ២ រូប គឺ លោកស្រី អេលីស្សាបេត
បេគែរ ( Elisabeth Becker) និង លោក រីឈិត ឌុតម៉ាន់ (Richard Dudman) ព្រម
ទាំង អ្នកស្រាវជ្រាវអង់គ្លេសម្នាក់ ឈ្មោះ ម៉ាល់ខុម កេតវែល (Malcom Cadwell)
បានចូលមកក្នុងស្រុកខ្មែរ ។ ម៉ាល់ខុម កេតវែល ដែលមានទំនាក់ទំនងល្អ ជាមួយ ប៉ុល
ពត បានត្រូវគេសម្លាប់ចោលនៅក្នុងភាព មួយដ៏អាថ៌កំបាំង រកមូលហេតុពុំឃើញ រហូត
មកដល់សព្វថ្ងៃនេះ ។ នៅពេលដែល នៅក្នុងប្រទេសទាំងមូល ការបះបោររបស់ កម្មាភិ
បាល ខ្មែរក្រហម បានផ្ទុះឡើង កងទ័ពវៀតណាម ក៏ចាប់ផ្តើម ធ្វើការវាយប្រហារផង
ដែរ។ នៅថ្ងៃ ២ ធ្នូ ឆ្នាំ ១៩៧៨ នោះ រណសិរ្សប្រឆាំងនឹង ប៉ុល ពត ក៏ បានត្រូវបង្កើត
ឡើងក្រោមការដឹកនាំ របស់ អតីតកម្មាភិបាលខ្មែរក្រហម ឈ្មោះ ហេង សំរិន និង ជា
ស៊ីម។ នៅ ថ្ងៃ ២៩ ធ្នូ ប៉ុល ពត បាននិយាយប្រាប់ គណៈប្រតិភូបក្សកុម្មុយនិស្ត
កាណាដាថា ប្រទេសវៀតណាម មានបង្អែកមួយយ៉ាងធំ ពីសំណាក់ប្រទេស ជា សមា
ជិក កតិកាសញ្ញា វ៉ារស្សូវី ពោលគឺ ពីសំណាក់ សហភាព សូវៀត ។ ម្តងនេះ ប៉ុល ពត
ឥតមានការភ័ន្តច្រឡំ ដូចសព្វដងទេ ព្រោះកងទ័ពវៀតណាម ធ្វើការវាយប្រហារ ទៅលើ
របប ប៉ុល ពត នៅក្នុងទ្រង់ទ្រាយមួយ ដ៏ធំសម្បើមអស្ចារ្យ ដោយប្រើ សម្ភារយោធា ដ៏
ទំនើបៗ ផងទៀត។

# ព្រឹត្តិការណ៍ សំខាន់ៗ នៅ ឆ្នាំ ១៩៧៨ នៅ សម័យ របប ខ្មែរក្រហម

## Quelques événements révélateurs en 1978

ព្រឹត្តិការណ៍ ដែលកើតមានឡើង នៅឆ្នាំ ១៩៧៨ មានច្រើន ឥតគណនា ប៉ុន្តែ ខ្ញុំសូមលើកឡើង តែ ចំណុចសំខាន់ៗ មួយចំនួនប៉ុណ្ណោះ ដើម្បីគូសបញ្ជាក់ អំពី ការឈានទៅរកទីអវសាន នៃ របបខ្មែរក្រហម ដែលឲ្យឈ្មោះ របប របស់ គេថា ប្រទេស «កម្ពុជាប្រជាធិបតេយ្យ»។ ព្រឹត្តិការណ៍ជាកត្តាកំណត់ គឺព្រឹត្តិការណ៍ ភូមិសាស្ត្រ- នយោបាយ ពោលគឺការប្រែប្រួល នៃ ការប្រជែងកម្លាំង (rapports de forces) រវាង មហាអំណាចទាំងពីរ នៅសម័យនោះ គឺ សហភាព សូវៀត និង សហរដ្ឋ អាមេរិកដែលកាលនោះ ជាអ្នកកំណត់ជោគវាសនា ពិភពលោក។ ចំពោះប្រទេសកម្ពុជា ផុតពី អាមេរិកទៅ គឺក្រោយពេលដែល សហរដ្ឋ អាមេរិក ដកកងទ័ពចេញ ពីឥណ្ឌូចិន សង្គ្រាមរវាង បងប្អូនកុម្មុយនិស្ត ទាំងពីរ («Les frères ennemis») ពោលគឺ ចិនកុម្មុយនិស្ត និង សហភាព សូវៀត ក៏កាន់តែមាន លក្ខណៈស្រួចស្រាវ។ ប្រទេសវៀតណាម បានជ្រើសរើសយកទីក្រុងម៉ូស្គូជាបង្អែក រីឯ ប៉ុល ពត បានជ្រើសរើសយកទីក្រុងប៉េកាំង ជាមេកើយ។ ហេតុដូច្នេះហើយ បានជាខ្មែរក្រហមដែលស្ថិតនៅ ក្រោមការដឹកនាំ របស់ ប៉ុល ពត ចាត់ទុកវៀតណាម និងបណ្តាប្រទេសហត្ថលេខី នៃ កតិកាសញ្ញា វ៉ារស្សូវី (Pacte de Varsovie)ជាសត្រូវ ដូចសហរដ្ឋ អាមេរិកដែរ។ ប៉ុន្តែអ្នកដឹកនាំ របប កម្ពុជាប្រជាធិបតេយ្យ ពុំចង់និយាយ អំពី ទំនាស់ ដ៏ធំ រវាង ចិន និង សូវៀតនេះទេ ព្រោះជាទំនាស់ រវាង កុម្មុយនិស្តដូចគ្នា ។ មួយវិញទៀត ប៉ុល ពត ចង់ ឲ្យមាន កុម្មុយនិស្តតែមួយ គឺ កុម្មុយនិស្ត ចិន ។ ប្រការដែលគួរកត់សំគាល់ គឺ ថា នៅពេលនោះ សហភាព សូវៀត ជាមហាអំណាច នុយក្លេអ៊ែរ ដូចអាមេរិកដែរ គឺ ពុំអាចសុខចិត្តបណ្តោយ ឲ្យប្រទេសចិន ដឹកនាំបដិវត្តន៍កុម្មុយនិស្ត តាមលទ្ធិម៉ៅនិយម នៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ទេ។ ដូចនេះ



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

គេត្រូវតែដាក់មូលដ្ឋានទ័ពឡោម ព័ទ្ធប្រទេសចិន។ ខាងប្រទេសចិនឯនាះវិញ គេក៏ពុំព្រមចុះញ៉ម នឹង សហភាព សូវៀត ជាដាច់ខាត ជាហេតុធ្វើឲ្យ ប៉ុល ពត យល់ថា បើមានចិនជាបង្អែក គេអាចវាយទប់ទល់ នឹងប្រទេសវៀតណាមបាន ហើយអាចនឹង ឈានទៅយកទឹកដីខ្មែរដែលវៀតណាម បានប្រើបយកតាំងពី ចុងសតវត្សរ៍ ទី ១៧ មកទៀតផង។ យោងទៅតាម ការស្រាវជ្រាវមួយ របស់ រ៉ាអ៊ូល ហ្សេណា (Raoul Jennar) ដែលមានចំណងជើងថា «កូនសោសម្រាប់យល់ដឹង អំពីប្រទេសកម្ពុជា» (« Les clés du Cambodge ») ប៉ុល ពត បានអនុវត្តគោលដៅនេះ តាំងពីឆ្នាំ ១៩៧៥ មក ។ មកទល់ឆ្នាំ ១៩៧៨ កងទ័ពខ្មែរក្រហម ក្រោមបញ្ជាការ របស់ ប៉ុល ពត បានកំទេចទីក្រុង របស់វៀតណាម ចំនួន ២៥, ភូមិចំនួន ៩៦ ជាហេតុធ្វើឲ្យប្រជាជន ចំនួន ២ សែន ៥ ម៉ឺន ៧ ពាន់នាក់គ្មានជម្រក។ នៅទីបំផុត នៅថ្ងៃ ៣ វិច្ឆិកាឆ្នាំ ១៩៧៨ ប្រទេសវៀតណាម ដែលកាលពី សម័យតស៊ូ ប្រឆាំង នឹង អាមេរិក ធ្លាប់បានទទួលជំនួយ ពី ប្រទេសចិន ក៏បានសម្រេចទទួល ជំនួយគ្រប់បែបយ៉ាង ពី សហភាព សូវៀតវិញ រួមបញ្ចូលទាំង ជំនួយយោធាផង។ នៅក្នុងសន្ធិសញ្ញា ចុះថ្ងៃ ទី ៣ វិច្ឆិកានោះ ប្រទេសទាំងពីរ បានសន្យាថា នឹង ជួយគ្នានៅក្នុងករណី ដែលប្រទេសណាមួយត្រូវគេឈ្លានពាន។

មុននឹងឈានទៅនិយាយ អំព ការវាយលុក ប្រទេសកម្ពុជា នៅចុងឆ្នាំ ១៩៧៨ និង ដើមឆ្នាំ ១៩៧៩ យើងវិលមកមើល សភាពការណ៍ នៅក្នុង របប «កម្ពុជាប្រជាធិបតេយ្យ» ម្តងទៀត ជាពិសេស សភាពការណ៍ ទាក់ទង នឹង ការបែកបាក់ផ្ទៃក្នុង ដែលបណ្តាលមកពីទំនាស់រវាង បដិវត្តន៍កុម្មុយនិស្តចិន និងបដិវត្តន៍របស់ សហភាព សូវៀត ហើយ ដែលបានក្លាយ ទៅជាទំនាស់ ដ៏ស្រួចស្រាវ រវាង បដិវត្តន៍ កុម្មុយនិស្តខ្មែរ និង បដិវត្តន៍កុម្មុយនិស្តវៀតណាមដែរ។ ដូចយើងបានដឹងរួចមកហើយ ចាប់តាំងពីឆ្នាំ ១៩៧៧ មក ប៉ុល ពត បាន ស្រាវជ្រាវរកអ្នកដែល ប៉ុល ពត សង្ស័យថាជាដៃជើង របស់វៀតណាម យកទៅដាក់គុក ឬសម្លាប់ចោលតែម្តង។ ប៉ុន្តែ អ្នកដែលជាប់សង្ស័យថា ជាចារបុរស ឬ ជាចារនារី របស់ អាមេរិក ក៏ត្រូវ ប៉ុល ពត យកទៅប្រហារជីវិតចោល ឬ យកទៅធ្វើទារុណកម្ម នៅគុកទួលស្លែង ដូចគ្នាដូច្នេះដែរ។ នៅឆ្នាំ ១៩៧៧ កម្មាភិបាល

ជាន់ខ្ពស់ ជាច្រើននាក់ បានត្រូវចាប់ខ្លួន ឬ សម្លាប់ចោលតែម្តង ។ នៅ ថ្ងៃ ២៥ មករា កុយ ធួន រដ្ឋមន្ត្រីហិរញ្ញវត្ថុ និង ពាណិជ្ជកម្ម បានត្រូវចាប់ខ្លួន។ មួយថ្ងៃបន្ទាប់មក គឺ ទូច កឿន រដ្ឋមន្ត្រីសាធារណការ។ នៅខែ កុម្ភៈ ដល់វេន រដ្ឋមន្ត្រី ម្នាក់ទៀត គឺ សៀ ឌឿម។ កោត ឆាយ អតីតប្រធាន សមាគម មិត្តភាពចិន-ខ្មែរ ក៏ បានត្រូវចាប់ខ្លួនដែរ គឺ នៅថ្ងៃ ១៤ មិនា។ បន្ទាប់មកទៀត ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងឃោសនាការ បានត្រូវចាប់បញ្ជូនទៅគុក ទួលស្លែង នៅថ្ងៃ ៦ កក្កដា គឺ ក្រោយ ទីវ អុល បន្តិច ព្រោះ ទីវ អុល ត្រូវចាប់ខ្លួន នៅថ្ងៃ ៦ មិថុនា ។ គឺនៅពេលនោះហើយ ដែលអនាគត នាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន បានភៀសខ្លួនចូលព្រៃ ជាមួយ អ៊ឹង ផន នៅថ្ងៃ ២០ មិថុនា។ កាលនោះ លោក ជា មេបញ្ជាការ យោធារង នៅតំបន់ ២១ នៃកងទ័ពខ្មែរក្រហម នៃភូមិភាគបូព៌ា។ ហ៊ុន សែន និង អ៊ឹង ផន រស់នៅក្នុងព្រៃ អស់រយៈពេល ជាច្រើនខែ មុននឹង រត់ទៅដល់ប្រទេស វៀតណាម ។

# ការវាយលុក នៃកងទ័ព វៀតណាម ទៅលើ ប្រទេសកម្ពុជា នៅឆ្នាំ ១៩៧៨- ១៩៧៩

## L'invasion vietnamienne en 1978-1979

នៅថ្ងៃ ២ ធ្នូ ឆ្នាំ ១៩៧៨ ខ្មែរក្រហម ដែលបះបោរ ប្រឆាំង នឹង ប៉ុល ពត បានមកជួបជុំគ្នានៅស្នួល ដើម្បីបង្កើត រណសិរ្សមួយ មានឈ្មោះថា «រណសិរ្សសង្គ្រោះជាតិកម្ពុជា» (Front pour le Salut du Kampuchéa) ។ រណសិរ្សនេះដែលស្ថិតនៅក្រោមការដឹកនាំ របស់ លោក ហេង សំរិន ជាការប្រមូលផ្តុំកម្លាំង នៃ ជនកុម្មុយនិស្តខ្មែរ ៤ ក្រុម គឺ ក្រុមខ្មែរក្រហម នៅភូមិភាគបូព៌ា ដឹកនាំដោយ ហេង សំរិន, ជា ស៊ីម, ហ៊ុន សែន ក្រុមរបស់ ប៊ូ ថង ដែលធ្វើការបះបោរប្រឆាំង នឹង ប៉ុល ពត នៅផ្នែកឦសាន នៃ ប្រទេសកម្ពុជា និងក្រុមរបស់ សាយ ភូថង, ទៀ បាញ់, ចា រៀង ដែលតាំងពី





នៅជិតព្រំ ប្រទល់ថៃ។ រីឯ ក្រុម ទី ៤ គឺ ក្រុម របស់ ប៉ែន សុវណ្ណ, រស់ សាម៉័យ, ជា សុទ្ធ, កែវ ចិន្តា ដែលតាំងពីឆ្នាំ ១៩៥៤ មក បានទទួលការហាត់ ហ្វឹកហ្វឺនយោធា នៅប្រទេស វៀត ណាម។ ២៣ ថ្ងៃ ក្រោយការបង្កើតរណសិរ្សនេះ ហើយ មួយថ្ងៃក្រោយពេល ដែលអ្នកកាសែត អាមេរិកាំង ២ រូប គឺលោកស្រី អេ លីហ្សាបេត បេគែរ (Elizabeth Becker) និង លោក ឌុតម៉ាន់ (Dudman) បាន ដឹកសព លោកម៉ាក់ខុម កាត់វែល (Macom Cadwell) ចេញពីប្រទេសកម្ពុជា កងទ័ពវៀតណាមចំនួន ១៤ កងពលតូច (14 divisions d'armée) គឺប្រមាណ ១០ ម៉ឺននាក់ បានធ្វើការវាយប្រហារទៅលើប្រទេសកម្ពុជា។ ការវាយលុកនេះ បានប្រព្រឹត្តទៅ នៅក្នុងទ្រង់ទ្រាយមួយដ៏ធំសំបើមអស្ចារ្យ ព្រោះមាន ទាំងយន្តហោះ ឧទ្ធម្ភាគចក្រ កងកាំភ្លើងធំ ព្រមទាំងរថក្រោះសូវៀត ដែលអាចទប់ទល់បានដោយស្រួល នឹងគ្រាប់បេ ៤០ របស់ ខ្មែរក្រហម ។ កងទ័ពខ្មែរក្រហម បានប្រយុទ្ធ តទល់ យ៉ាងស្វិតស្វាញ ប៉ុន្តែ ដោយកំទេចរថក្រោះសូវៀត នឹង គ្រាប់ បេ ៤០ មិនបាន យោធាខ្មែរក្រហម ក៏ បាក់ទឹកចិត្ត ហើយ រត់ភៀសខ្លួនរតាត់រតាយអស់។ កងទ័ព វៀត ណាម បានវាយសម្រុកចូល ទៅក្នុងទឹកដីខ្មែរ ជាច្រើនចំណុច ដោយ កាត់ផ្តាច់កងទ័ពខ្មែរ ក្រហម ជាកង់ ៗ ដាច់ ទំនាក់ទំនងគ្នាអស់។ នៅថ្ងៃ ២៩ ធ្នូ ឆ្នាំ ១៩៧៨ ដដែលនោះ ប៉ុល ពត បានប្រកាសប្រាប់គណៈប្រតិភូកាណាដាថា កងទ័ពវៀតណាម កំពុងតែទទួល បរាជ័យមួយ ដ៏ធំមហិមា។ គឺនៅពេលនោះហើយដែល ប៉ុល ពត បានដឹងថា កងទ័ព កតិកាសញ្ញា វ៉ារស្សូវី បានសម្រេចជួយ វៀតណាម យ៉ាងពេញទំហឹង។ នៅថ្ងៃ ១ មករាឆ្នាំ ១៩៧៩ គេឮស្នូរ ការបាញ់គ្នា ខ្ទរខ្ទារ នៅ ទីក្រុងភ្នំពេញ។ នៅពេលព្រឹកថ្ងៃ ២ មករា កងកុម្មង់ដូពិសេស វៀតណាម បាន ឆ្លងទន្លេមេកុង តាមកាណូតពោង ដើម្បី មករំដោះ សម្តេច នរោត្តម សីហនុ ប៉ុន្តែ កងទ័ពខ្មែរក្រហម បានធ្វើការទប់ទល់ យ៉ាងពេញទំហឹង ហើយពង្រត់ សម្តេច សីហនុ អតីតប្រមុខរដ្ឋខ្មែរ ទៅលាក់ទុកនៅខែត្របាត់ដំបងសិន។

បន្ទាប់ពី បានត្រូវ ពួកខ្មែរក្រហម យកមកដាក់ នៅផ្នែកពាយ័ព្យ នៃ ប្រទេសកម្ពុជា សម្តេច នរោត្តម សីហនុ ទ្រង់គង់ នៅទីនោះអស់រយៈពេល ៣ ថ្ងៃ មុន នឹង

យានត្រឡប់ មកទីក្រុងភ្នំពេញវិញ នៅថ្ងៃ ៥ មករា ។ នៅពេលដដែលនោះ កងទ័ពវៀតណាម បានវាយយកខេត្តចំនួន៧ គឺ ខេត្តដែលស្ថិតនៅផ្នែកបូព៌ា នៃ ទន្លេមេគង្គ។ នៅថ្ងៃដែលសម្តេច នរោត្តម សីហនុ យានមកដល់ ភ្នំពេញ ប៉ុល ពត បានថ្លែងសន្ទថាមួយ ថ្កោលទោស សហភាព សូវៀត យ៉ាងជូរចត់។ នៅពេលល្ងាចថ្ងៃ ដដែលនោះ គឺ ថ្ងៃ ៥ មករា ខៀវ សំផន ប្រមុខរដ្ឋ របប កម្ពុជា ប្រជាធិបតេយ្យ បានទៅជួបសម្តេច នរោត្តម សីហនុ ហើយ ទូលព្រះអង្គ ថា ប៉ុល ពត សូមយាងព្រះអង្គ ទៅសោយទឹកតែ នៅវិមាន រដ្ឋាភិបាល ។ ពេលដែល រថយន្ត មែរសីដេសមួយ ដឹកនាំសម្តេច នរោត្តម សីហនុ ទៅដល់ វិមាន រដ្ឋាភិបាល ប៉ុល ពត បានចេញ មកទទួលព្រះអង្គដោយលំអោនកាយបន្តិចផងដែរ។ យោងទៅតាមការកត់សំគាល់របស់ សម្តេច នរោត្តម សីហនុ ហើយដែលអ្នកកាសែត ណាយ៉ាន់ ចាន់ដា បានយកមកសរសេរបន្ទាប់មក «ប៉ុល ពត ជាមនុស្សក្រម្រោល ក៏ពិតមែន ប៉ុន្តែហាក់បីដូចជាមិនស្អប់ព្រះអង្គប៉ុន្មានទេ»។ ការសន្ទនារវាង ប៉ុលពត និង សម្តេច នរោត្តម សីហនុ បានប្រព្រឹត្តិទៅអស់រយៈពេល ៤ ម៉ោង ដោយមានទឹកក្រូច ជាភេសជ្ជៈ គឺមិនមែនទឹកតែទេ។ ម្តងនេះ ប៉ុល ពត ប្រើពាក្យ «ព្រះករុណា» ដើម្បី និយាយ ទៅរកសម្តេច នរោត្តម សីហនុ ។ បន្ទាប់ពី បានសុំទោសព្រះអង្គ អំពីការធ្វេសប្រហែសរបស់ខ្លួន ដែលពុំបានជួបព្រះអង្គនៅពេលមុន ប៉ុល ពត បានស្នើសុំឲ្យ សម្តេច នរោត្តម សីហនុ យាងទៅអង្គការសហប្រជាជាតិ នៅទីក្រុងញីវយ៉ក ដោយឆ្លងកាត់ទីក្រុងប៉េកាំង។ ប៉ុល ពត បានស្នើសុំផងដែរឲ្យសម្តេច នរោត្តម សីហនុ ថ្កោលទោសពួកឈ្លានពានទឹកដីខ្មែរ ហើយការពាររបបកម្ពុជា ប្រជាធិបតេយ្យផងទៀត។ នៅថ្ងៃ ៦ មករា ឆ្នាំ ១៩៧៩ នោះ យន្តហោះប្រតិកម្ម ចិនមួយ បានមកទទួល សម្តេច នរោត្តម សីហនុ ប្រមទាំង អ្នកហែហម ព្រះអង្គ យកទៅ ទីក្រុងប៉េកាំង។





# ការប្រយុទ្ធតស៊ូ ផ្នែកនយោបាយ វវាង ចិន និង វៀតណាម នៅ ឆ្នាំ ១៩៧៩

## Lutte politique entre la Chine et le Viet nam en 1979

នៅថ្ងៃ ៦ មករាឆ្នាំ ១៩៧៩ សម្តេច នរោត្តម សីហនុ ព្រមទាំងព្រះជាយា អ្នកម្នាង ម៉ូនិក និងព្រះរាជបុត្រ ៣ អង្គ របស់ព្រះអង្គ គឺព្រះអង្គម្ចាស់ សីហមុនី នរិន្ទ្រាពង្ស និង គិតារា បានយាងឡើងយន្តហោះ នៅព្រលានយន្តហោះពោធិចិន្តុង ។ អ្នកដែលបាន ហែហម និងបានរួមសុខទុក្ខ ជាមួយព្រះអង្គ ក្នុងគ្រា ដ៏ពិបាកនេះ ក៏បានត្រូវខ្មែរក្រហម អនុញ្ញាតឲ្យចេញទៅ ជាមួយព្រះអង្គដែរ។ ខៀវ សំផន អៀង សារី និងឯកអគ្គរដ្ឋទូត ចិន ក៏បាន ជូនដំណើរព្រះអង្គ មកដល់ជណ្តើរយន្តហោះផងទៀត។ រីឯអ្នកដែលបានអម ដំណើរ រហូត ដល់ទីក្រុងប៉េកាំង មានជាអាទិ៍ លោក គាត ឈុន លោក ជួន ប្រសិទ្ធិ និង នាងកញ្ញា ប៉ុក ម៉ូណា ។ ពេលដែល សម្តេច នរោត្តម សីហនុ យាងមកដល់ ទីក្រុង ប៉េកាំង លោក តេង ស៊ាវពីង អ្នកដឹកនាំខ្វាំងថ្មី នៃសាធារណរដ្ឋប្រជាមានិតចិន បាន អញ្ជើញមកទទួលព្រះអង្គ ដោយផ្ទាល់ នៅប្រលានយន្តហោះ ។ នៅក្នុងព្រះទីនាំង លីមូ ហ្ស៊ីនខ្មៅ ដែលដឹកនាំ ព្រះអង្គ មកទីក្រុង លោក តេង ស៊ាវ ពីង បាននិយាយសារភាពថា លោកពុំពេញចិត្តសោះ នឹង របៀប ដែលអ្នកដឹកនាំខ្មែរក្រហម បានប្រព្រឹត្ត ទៅលើព្រះអង្គ គឺជាឥរិយាបថមួយ ដែលមិនស័ក្តិសមនឹង ស្មារតីស្នេហាជាតិ របស់ ព្រះអង្គ បន្តិចបន្តួចឡើយ។ តាងនាមឲ្យសាធារណរដ្ឋប្រជាមានិតចិន លោក តេង ស៊ាវ ពីង បានសូមការព្រះរាជទានទោស ពី សម្តេច នរោត្តម សីហនុ ។ សូមកត់សំគាល់ថា លោក តេង ស៊ាវពីង ក៏ដូចជា លោក លូ ចៅជី ដូច្នេះដែរ បានត្រូវរបបម៉ៅនិយម ធ្វើទារុណកម្មយ៉ាងគ្រាំគ្រា ទម្រាំប្រទេសចិនបានរកផ្លូវត្រូវ ដ៏ សាមញ្ញឃើញវិញ។ នៅ ក្នុងសៀវភៅមួយដែលសម្តេច នរោត្តម

សីហនុ ទ្រង់បាននិពន្ធ ផ្ទាល់ព្រះអង្គ [២០] សម្តេច នរោត្តម សីហនុ បានរៀបរាប់យ៉ាងពិស្តារ អំពី បដិសណ្ឋារកិច្ច របស់លោក តេង ស៊ារ ពីង។ រីឯអត្ថបទ របស់ខ្ញុំ ត្រង់ចំណុចនេះ ក៏ផ្អែកទាំងស្រុងទៅលើឯកសារប្រវត្តិសាស្ត្រ ដ៏សំខាន់នេះដែរ ។ ទោះជាយ៉ាងណាក្តី ទោះជាលោក តេង ស៊ារពីង មិនបានចូលរួមក្នុងអ្វីៗ ដែលខ្មែរក្រហមបានធ្វើទៅលើប្រជាជនខ្មែរ កន្លងមកក្តី ក៏ចំពោះ ជនដែលបានទទួលការរងគ្រោះ អន្តរាគមន៍ ដ៏យឺតយ៉ាវនេះ ក៏ជាការគ្មានន័យអ្វីទាំងអស់ដែរ។ ប្រជាជនខ្មែរជិត ២ លាននាក់នៅក្នុងនោះ បញ្ញជនខ្មែរជាច្រើន និង ព្រះរាជវង្សានុវង្សផងដែរ បានត្រូវខ្មែរក្រហមធ្វើទារុណកម្ម ហើយផ្តាច់ជីវិត យ៉ាងសាហាវ ព្រៃផ្សៃបំផុត ដែលជាហេតុធ្វើឲ្យមានសំនួរចោទសួរថា តើហេតុអ្វី បានជា ខ្មែរក្រហម សម្លាប់ ពូជសាសន៍ឯង ដូច្នេះ ជាពិសេស ការរំលើងបញ្ញវន្ត ទាំងឫស ឲ្យរលត់ផុតពូជដូច្នេះ។ ខ្មែរជំនាន់ក្រោយ ច្បាស់ជាចោទសំនួរនេះ ជាពុំខាន។

នៅថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩ នោះឯង កងទ័ពវៀតណាម បានចូលមកដល់ ទីក្រុងភ្នំពេញ ។ ពួកអ្នកដឹកនាំខ្មែរក្រហម បាននាំគ្នារត់ចេញ ពីរដ្ឋធានីខ្មែរ តាមរទេះភ្លើង និងតាម ឧត្ដម្ភាគចក្រ ឆ្ពោះទៅទល់ដែនថៃ ។ ប៉ុន្តែនៅក្នុងពេលដដែលនោះ ខ្មែរក្រហមខ្លះទៀត បាននាំគ្នា កៀរ ហើយ ជម្លៀស ប្រជាជនខ្មែរ ជាច្រើនពាន់នាក់ យកទៅដាក់នៅផ្នែកពាយ័ព្យ នៃប្រទេសផងដែរ ។ នៅទីក្រុងភ្នំពេញ នៅថ្ងៃបន្ទាប់មក គឺនៅថ្ងៃ ៨ មករា កងទ័ពវៀតណាម បានដាក់ របបកុម្មុយនិស្តមួយទៀត មកឲ្យគ្រប់គ្រងស្រុកខ្មែរ។ មុនដំបូង គឺ រដ្ឋាភិបាល បណ្តោះអាសន្នមួយ ដែលមានឈ្មោះថា «ក្រុមប្រឹក្សាប្រជាជនបដិវត្តកម្ពុជា»។ រីឯអ្នកដឹកនាំសំខាន់ៗ ដែលប្រជាជនបានដឹងឈ្មោះខ្លះៗតាមវិទ្យុ ដែលគេចាប់បាន នៅចុងឆ្នាំ ១៩៧៨ បានត្រូវជ្រើសរើស ក្នុងចំណោម អតិតកម្មាភិបាលខ្មែរក្រហម ដែលបានរត់ទៅវៀតណាម នៅឆ្នាំ ១៩៧៧-១៩៧៨ និង ក្នុងចំណោម ជន

[២០] Norodom Sihanouk : *Prisonnier des Khmers rouges*, Hachette, Paris, 1986





កុម្មុយនិស្តផ្សេងៗទៀត និង ជនកុម្មុយនិស្ត ខ្មែរដែលបានទៅរស់នៅវៀតណាម តាំងពីឆ្នាំ ១៩៥៤ ។ ហេង សំរិន ដែលជាអតិតកម្មាភិបាលខ្មែរក្រហម ផ្នែកបូព៌ា ហើយដែលធ្លាប់ធ្វើជា មេទ័ព ដ៏សំខាន់ ម្នាក់ របស់ ប៉ុល ពត បានត្រូវតែងតាំង ជាប្រធានរដ្ឋាភិបាល បណ្តោះអាសន្ននោះ ពោលគឺ «ក្រុមប្រឹក្សាប្រជាជនបដិវត្ត»។ រីឯ ប៉ែន សុវណ្ណ អ្នកកុម្មុយនិស្តជើងចាស់ មកពី ហាណូយ បានទទួលមុខនាទី ជា អនុប្រធានក្រុមប្រឹក្សា។ សមាជិកផ្សេងៗទៀត នៃ រដ្ឋាភិបាលបណ្តោះអាសន្ន ដែលគាំទ្រដោយកងទ័ពវៀតណាមនោះ រួមមាន ៖ លោក ជា ស៊ីម រដ្ឋមន្ត្រី មហាផ្ទៃ លោក ហ៊ុន សែន រដ្ឋមន្ត្រី ការបរទេស លោក កែវ ចិន្តា រដ្ឋមន្ត្រី ឃោសនាការ និង វប្បធម៌ លោក ចាន់ វ៉ែន រដ្ឋមន្ត្រីអប់រំជាតិ លោក នូ បេង រដ្ឋមន្ត្រីសុខាភិបាល លោក ម៉ុក សាគុន រដ្ឋមន្ត្រីសេដ្ឋកិច្ច ។ រដ្ឋមន្ត្រីមួយចំនួនទៀត បានត្រូវតែងតាំងបន្ថែម នៅថ្ងៃ ១៤ តុលាឆ្នាំ ១៩៧៩ ដដែល ។ នៅថ្ងៃ ៨ មករា គឺ នៅពេលដែល រដ្ឋាភិបាល បណ្តោះអាសន្ន គាំទ្រដោយកម្លាំងទ័ពវៀតណាមបានត្រូវតែងតាំង នៅទីស្នាក់ការអង្គការ សហប្រជាជាតិ នៅទីក្រុងញូវយ៉ក ឯនោះវិញ សម្តេច នរោត្តម សីហនុ តាងនាមឲ្យ របបកម្ពុជា ប្រជាធិបតេយ្យ បានធ្វើការតវ៉ា ថ្កោលទោស កងទ័ពវៀតណាម ដែលចូលឈ្លានពាន ទឹកដីខ្មែរ ។ នៅ ទីក្រុងប៉េកាំង ឯនោះវិញ អៀង សារី បានទទួលប្រាក់ ពីចិន ចំនួន ៥ លាន ដុល្លារ ដើម្បីបន្តការតស៊ូ ដេញកងទ័ពវៀតណាម ពីទឹកដីខ្មែរ ។

## ការប្រជែង កម្លាំង
## រវាង ប្រទេស មហាអំណាច

## Les rapports de forces entre les Grandes Puissances

ព្រឹត្តិការណ៍ ថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩ នៅប្រទេសកម្ពុជា បានត្រូវអ្នកវិភាគប្រវត្តិ
សាស្ត្រ និង នយោបាយបកស្រាយខុសៗពីគ្នា។ ប៉ុន្តែ អ្វីដែលពុំអាចប្រកែកបាន គឺការ
វាយ ប្រហារយោធា នៃ ប្រទេសវៀតណាមទៅលើប្រទេសកម្ពុជា ដើម្បីវាយរំលំរបប
ខ្មែរក្រហម ហើយដាក់ របបនយោបាយមួយ ដែលរណប នឹង កងទ័ព របស់ខ្លួន
ជំនួស តែម្តង។ គឺ នៅក្នុងន័យនេះហើយ ដែលនៅថ្ងៃ ១៣ មករា ឆ្នាំដដែលនោះ
ក្រុមប្រឹក្សា សន្តិសុខ អង្គការ សហប្រជាជាតិ ទាមទារ ឲ្យប្រទេស ដែលចូលឈ្លាន
ពានស្រុកខ្មែរ ដកកងទ័ពរបស់គេចេញជាបន្ទាន់។ នៅក្នុងន័យនេះ អង្គការ សហ ប្រជា
ជាតិ គ្មានជម្រើសអ្វី ក្រៅពីត្រូវបង្ខំចិត្ត ទទួលស្គាល់ របប នៃ ប្រទេសដែលត្រូវ
ឈ្លានពាន នោះឡើយ ពោលគឺ របបកម្ពុជា ប្រជាធិបតេយ្យ របស់ពួកខ្មែរក្រហម ។
នេះជាបញ្ហាមួយ ដ៏ស្មុគស្មាញ ព្រោះថា បើរបបខ្មែរក្រហម មិនបានត្រូវវាយរំលំ ឲ្យ
បានធាប់រហ័ស ទេនោះ ប្រជាជនខ្មែរ នឹងត្រូវរងគ្រោះ នៅក្នុងរបបនេះបន្តទៅទៀត ។
ដោយយល់ច្បាស់ អំពី លក្ខណៈខុសច្បាប់ នៃ ការឈ្លាន ពាននេះ កងទ័ពវៀតណាម
ក៏ បានសាកល្បងរំដោះ សម្តេច នរោត្តម សីហនុ ដែរ គឺ ដោយសង្ឃឹមថា ក្សត្រខ្មែរ
អង្គនេះ អាចតំណាង និត្យានុកូលភាព ខ្លះៗ នៃ របបដែលគេ បម្រុងដាក់ជំនួសរបប
ខ្មែរក្រហម។ ការពិត តាមផ្លូវច្បាប់ សម្តេច នរោត្តម សីហនុ បាន ត្រូវសភាទាំងពីរ
ទម្លាក់តាំង ពីឆ្នាំ ១៩៧០ មកឯណោះ ហើយ អង្គការ សហប្រជាជាតិ ក៏បានទទួល
ស្គាល់ របបសាធារណរដ្ឋខ្មែរ រួចទៅហើយដែរ។ ទោះជាយ៉ាងនេះក្តី ក៏ទីក្រុងហាណូយ
ជឿថា ជាដំណោះស្រាយមួយដែរ សម្រាប់បន្ត ស្ថិរភាពនៅក្នុងប្រទេសកម្ពុជា ព្រោះថា
បើ សម្តេច នរោត្តម សីហនុ ស្ថិតនៅក្នុងកណ្តាប់ដៃចិនៗ ច្បាស់ជាបង្កទំនាស់ ដ៏ ស្មុគ
ស្មាញជាពុំខាន ហើយរបបថ្មី ក៏ នឹងត្រូវបាត់លំនឹង ។ កាលសម័យ សាធារណរដ្ឋខ្មែរ
បដិវត្តន៍ កុម្មុយនិស្ត បានប្រើ យុទ្ធសាស្ត្រនេះ ដោយជោគជ័យម្តងរួចមកហើយ។ ប៉ុន្តែ
កងកុម្ម៉ង់ដូ ដែលធ្វើប្រតិបត្តិ ការរំដោះ សម្តេច នរោត្តម សីហនុ ឲ្យបានមុនថ្ងៃ កងទ័ព
វៀតណាម ចូលទៅក្នុង ភ្នំពេញ បានទទួលបរាជ័យទាំងស្រុង ព្រោះទីក្រុងប៉េកាំង បាន
រំដោះអតិតប្រមុខរដ្ឋខ្មែរ មុនបាត់ទៅហើយ។ គេអាចសន្និដ្ឋានបានថាបើទីក្រុងហាណូយ



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

រំដោះ សម្តេច នរោត្តម សីហនុ បានមុនថ្ងៃ ៧ មករា សភាពការណ៍ នៅពេលនោះ
ប្រហែលជា មានលក្ខណៈផ្សេង ពីសេណារីយ៉ូ ដែលមានមកទល់សព្វថ្ងៃនេះ។ នៅក្នុង
ក្រខ័ណ្ឌ នៃការប្រជែងកម្លាំងអន្តរជាតិ ការវាយរំលំរបប ប៉ុល ពត ដោយកងទ័ពវៀត
ណាម គឺជា ជ័យជំនះ មួយ របស់ សហភាព សូវៀត ទៅលើចិន។ ប៉ុន្តែជ័យជំនះនេះ
ពុំអាចធ្វើឲ្យ ចិន និងសហរដ្ឋ អាមេរិក ទទួលយកបានឡើយ ព្រោះ សូវៀត ក្លាយទៅ
ជាកត្តា គំរាមកំហែង ដល់បណ្តាប្រទេស នៃ សមាគម ប្រជាជាតិ អាស៊ីអាគ្នេយ៍ ហៅ
កាត់ថា អាស៊ាន។ ទោះជាយ៉ាងនេះក្តី ប្រទេសជាសមាជិក សមាគមអាស៊ាន ទាំងអស់
ពុំមានទស្សនៈ ដូចគ្នា ទាំងអស់ទេ ។ ប្រទេសខ្លះយល់ថា គឺ ចិនទេ ដែលជាកត្តាគំរាម
កំហែង ហើយប្រទេសខ្លះទៀត យល់ថា គឺ សហភាពសូវៀតទៅវិញ ។ ទោះជាយ៉ាង
ណាក្តី នៅចំពោះមុខ ឥទ្ធិពល ដ៏ខ្លាំងក្លា របស់ វៀតណាម និង សហភាព សូវៀត
នៅក្នុងតំបន់ជាពិសេស នៅកម្ពុជា បស្ចិមលោកដែលនៅពេលនោះ បានកំណត់យក
សហភាព សូវៀត ជាសត្រូវយុទ្ធសាស្ត្រ ទី ១ គ្មានជម្រើសអ្វី ក្រៅពី ការចងសម្ព័ន្ធ
ភាពជាមួយ ចិនកុម្មុយនិស្តឡើយ ។ ទោះជាយ៉ាងនេះក្តី ក៏ សម្តេច នរោត្តម សីហនុ
បានសាកល្បង រកជំហរមួយទៀត ជាមួយអាមេរិកសិនដែរ ។ នៅថ្ងៃ ១៤ មករា គឺនៅ
ពេលដែលព្រះអង្គយាង ទៅធ្វើអន្តរាគមន៍ នៅអង្គការ សហប្រជាជាតិ នៅទីក្រុងញ៉ូវ
យ៉ក ដើម្បីការពាររបបខ្មែរក្រហម សម្តេច នរោត្តម សីហនុ បានសាកល្បងរត់ចេញ
ពីពួកខ្មែរក្រហម។ ប៉ុន្តែ ទោះបីព្រះអង្គ បានគេចផុតពីក្រញាំពួកនេះក្តី ក៏សហរដ្ឋ
អាមេរិក មិនហ៊ាន ទទួលយកព្រះអង្គឡើយ ព្រោះ សហរដ្ឋ អាមេរិក ខ្លាចខូច សម្ព័ន្ធ
ភាព របស់គេ ជាមួយចិន។ នៅចុងខែកុម្ភៈ ឆ្នាំ ១៩៧៩ លោក តេង ស៊ាវ ពីង
បានធ្វើដំណើរ មកសហរដ្ឋ អាមេរិក ហើយក៏យាង សម្តេច នរោត្តម សីហនុ ឲ្យទៅគង់
នៅ ទីក្រុងប៉េកាំងវិញ ។

បន្ទាប់ពី ទីក្រុងហាណូយ វាយយកប្រទេសកម្ពុជាបាន នៅថ្ងៃ ៧ មករា ឆ្នាំ
១៩៧៩ ទីក្រុងប៉េកាំង បានផ្តល់ជំនួយមួយពាន់លានដុល្លារ ទៅឲ្យពួកខ្មែរក្រហម ដើម្បី
បន្តការតស៊ូដេញកងទ័ពវៀតណាម ចេញពីទឹកដីខ្មែរ ។ នេះ បើយោងទៅតាមលោក

ណា យ៉ាន់ ចាន់ដា ដែលបានធ្វើការវិភាគមួយយ៉ាងពិស្តារ នៅក្នុងទស្សនាវដ្ដី « នយោបាយ បរទេស »[២១] របស់ វិជ្ជាស្ថានបារាំងខាងទំនាក់ទំនងអន្តរជាតិ ចេញផ្សាយនៅខែមេសាឆ្នាំ ១៩៨៩។ ព្រោះតែ ការប្រទាញប្រទង់គ្នា រវាង ចិន និង សហភាព សូវៀតនេះ អ្នកនយោបាយ និង បញ្ញវន្តខ្មែរ ត្រូវប្រឈមមុខដាក់គ្នារហូត គឺមិនឲ្យអ្នកណាឈរកណ្ដាល បានទេ ជាពិសេស ចំពោះ អ្នកដែលចង់បានអំណាច ឬ ចង់មានតួនាទីនយោបាយអ្វីមួយ។ រីឯ សមាសភាព នៃក្រុមបក្សពួកនីមួយៗក៏មានលក្ខណៈ ដ៏ចម្លែកផងទៀត។ ម្ខាងមានចិន មានខ្មែរក្រហម មានអ្នកប្រជាធិបតេយ្យ ឬ អ្នកនិយមបស្ចិមលោក លាយឡំគ្នា។ ម្ខាងទៀត មាន សហភាព សូវៀត មាន វៀតណាម ហើយមានពួកខ្មែរក្រហម មួយផ្នែកផងដែរ។ ក្រុមនីមួយៗ អូសទាញប្រជាជន បញ្ញវន្តខ្មែរឲ្យគាំទ្រពួកគេរៀងៗខ្លួន។ ក្រុមទាំងពីរនេះ ជេរប្រទេចផ្ដាសាគ្នា ដោយឥតសំចៃ ហើយស្អប់ខ្ពើមគ្នា រហូតមក ទល់សព្វថ្ងៃនេះ។ ខ្មែរកាន់តែបែកសាមគ្គីគ្នា ថែមទៀត ព្រោះតែទំនាស់របស់ បរទេសសោះនោះ។ នេះ ជាទំព័រប្រវត្តិសាស្ត្រមួយ ដ៏ខ្មៅងងិត និងប្រកបទៅដោយគ្រោះថ្នាក់។ បើខាងណាឈ្នះម្ដងៗ ខាងនោះជាអ្នកត្រូវហើយ អ្នកចាញ់ត្រូវគេយកទៅធ្វើបាប ធ្វើទារុណកម្ម យ៉ាងឃោរឃៅ ។ តាមរយៈទំព័រ ប្រវត្តិសាស្ត្រនេះ គេអាចធ្វើការសន្និដ្ឋាន ថាៈ ដរាបណាអ្នកដឹកនាំខ្មែរ នៅតែ រណបខាងនេះ ឬ ខាងនោះ ដោយជ្រុលហួសហេតុពេក ពោលគឺ គ្មានឯករាជ្យគ្រប់គ្រាន់ គ្មានការប្តូរបង្កួតប្រទេសតាមរយៈការជ្រើសរើស ដោយគ្មានលំអៀងដោយចៀសវាង ការបន្ទុប របស់ បរទេសទេនោះ ប្រជាជនខ្មែរ ពុំអាចចេញផុតពី សោកនាដ្យកម្ម បានឡើយ ។

---

[២១] Revue « Politique étrangère » n° 4 , Hiver 1989 : *Le Cambodge dans la guerre*.Un article de Nayan Chanda intitulé : *Le Cambodge et les Grandes Puissances*, p. 639, IFRI, Paris, 1989.





# ការតស៊ូ ដេញ កងទ័ព វៀតណាម ចេញពី ប្រទេស កម្ពុជា

## Le Front anti-vietnamien

ការវាយរំលំរបប «កម្ពុជាប្រជាធិបតេយ្យ» ដោយកងទ័ពវៀតណាមនៅឆ្នាំ ១៩៧៩ បានចោទឡើងជាបញ្ហាមួយ ដ៏ធំ ចំពោះ សហគមន៍ អន្តរជាតិ ព្រោះជាការរំលោភទៅលើ អធិបតេយ្យ នៃ ប្រទេសមួយ ដោយប្រទេសមួយទៀតយ៉ាងជាក់ស្ដែង។ នៅក្នុងន័យនេះ ប្រទេសវៀតណាម ត្រូវសហគមន៍អន្តរជាតិថ្កោលទោសយ៉ាងខ្លាំង ទោះបីអន្តរាគមន៍ ខុសច្បាប់អន្តរជាតិនេះ បានជួយជីវិតប្រជាជនខ្មែរ ដែលនៅសល់ពី ការសម្លាប់រង្គាល ក្រោមរបប ពួកខ្មែរក្រហមក្តី ។ ទោះបី មានការគាបសង្កត់យ៉ាងខ្លាំងពីសំណាក់ សហគមន៍ អន្តរជាតិក្ដី ជាពិសេស ពីសំណាក់ប្រទេសចិន និង បស្ចិមលោក ក៏វៀតណាម មិនព្រមដកកងទ័ព របស់គេ ចេញពីកម្ពុជាដែរ ដោយហេតុថារបប ហេង សំរិន ពុំទាន់មាន លទ្ធភាពគ្រប់គ្រាន់ សម្រាប់ទប់ទល់ នឹងពួកខ្មែរក្រហម។ បើគេមិន និយាយពី ច្បាប់អន្តរជាតិ ហើយ បែរទៅមើល ការប្រជែងកម្លាំង អន្តរជាតិវិញ គេឃើញថា ការវាតទី របស់វៀតណាមនេះ បានធ្វើឲ្យបាត់ តុល្យភាព យ៉ាងធ្ងន់ធ្ងរ។ គេមាន ការបារម្ភខ្លាចក្រែង ប្រទេសវៀតណាម ដែលមានសហភាព សូវៀត នៅពី ក្រោយ វាត ទី ចូលទៅ ដល់បណ្ដាប្រទេស អាស៊ានតែម្ដង។ ការរុលមួយកម្រិតទៅមុខ នៃ កម្លាំង របស់ សហភាព សូវៀតនេះ ពោលគឺ របស់ បក្សសម្ព័ន្ធយោធាវ៉ារស្សូវី ទាំងមូល រួមបញ្ចូលទាំងវៀតណាមផង មិនអាចឲ្យប្រទេសចិន និង ប្រទេសមួយចំនួន នៃ សមាគម ប្រជាជាតិ អាស៊ីអាគ្នេយ៍ ជាពិសេស ប្រទេសថៃ និង សិង្ហបុរី ព្រមទាំង បស្ចិម លោក ទទួលយកបានឡើយ។ នៅ ថ្ងៃ ២១ មករាឆ្នាំ ១៩៧៩ ដដែលនោះ ប្រទេសថៃ ដែលកាលពី ថ្ងៃ ៣១ មករា ឆ្នាំ ១៩៧៨ បានដាក់ទំនាក់ទំនងជាមួយ របបកម្ពុជា ប្រជាធិបតេយ្យ រួចស្រេចទៅហើយនោះ បានបញ្ជាក់ថា ទីក្រុង

បានកកគាំទ្ររបបខ្មែរ ក្រហមបន្តទៀត។ នៅក្នុងប្រទេសកម្ពុជាឯនោះ វិញ កងទ័ពវៀតណាម ដែលបានទទួល ការគាំទ្រគ្រប់វិស័យ ពីសហភាព សូវៀត និង ពីប្រទេសនានា នៃ កតិកាសញ្ញា វ៉ារស្សូវី ក៏ ពង្រឹងកងទ័ព របស់គេ ពាសពេញ ប្រទេសកម្ពុជា ដើម្បី គាំទ្រ របប ហេង សំរិន ទប់ទល់ នឹងខ្មែរក្រហមដែលមានការគាំទ្រ ពីប្រទេសចិន ។ ដើម្បីវាយរំលំ របប ហេង សំរិន ពួកខ្មែរក្រហម ដែលម្តងនេះ មានបង្អែកយ៉ាងមាំពី ចិនផង ពីបស្ចិមប្រទេស និង ពី បណ្តាប្រទេស អាស៊ាន ផង បានសុខចិត្ត រួមកម្លាំង ជាមួយក្រុមខ្មែរ ផ្សេងៗទៀត ។ ទោះបី នៅថ្ងៃ ២៥ មករាឆ្នាំ ១៩៧៩ សម្តេច នរោត្តម សីហនុ ទ្រង់បានប្រកាសផ្តាច់ ខ្លួនចេញពីខ្មែរក្រហមក្តី ក៏កងទ័ពខ្មែរក្រហម នៅតែស្ថិត នៅ ជាកម្លាំងសំខាន់ ជាងគេ ដដែល ។ ដើម្បីកាត់បន្ថយឥទ្ធិពល របស់ ខ្មែរក្រហម នៅក្នុងរណសិរ្សប្រឆាំង នឹង របប ហេង សំរិន លោក សឺន សាន បានបង្កើតក្រុម របស់ លោកមួយ ដែលមាន ឈ្មោះថា «រណសិរ្សជាតិរំដោះពលរដ្ឋខ្មែរ» នៅថ្ងៃ ៩ តុលា ឆ្នាំ ១៩៧៩ ដដែល នោះ ។ លោក សឺន សាន បានស្នើសុំឲ្យ សម្តេច នរោត្តម សីហនុ ដឹកនាំ ចលនានេះដែរ ប៉ុន្តែ ព្រះអង្គ ពុំព្រមទាល់តែសោះ ហើយ បានទាត់ ចោលសំណើនេះ នៅថ្ងៃ ២៥ វិច្ឆិកា គឺ នៅឱកាសដែលព្រះអង្គ ជួប នឹង លោក ប្រធានាធិបតី បារាំង ហ្ស៊ីស្កាដ៍ ដេស្តាំង នៅទីក្រុងប៉ារីស៍ ។

នៅថ្ងៃ ១៧ មករាឆ្នាំ ១៩៧៩ កងទ័ពវៀតណាម ដែលការពារ របប ហេង សំរិន បានរុល មកដល់ ទល់ដែនថៃ ហើយ បានវាយកំទេច កងទ័ពខ្មែរក្រហម ដែល មានគ្នាប្រមាណ ៤ ម៉ឺន នាក់ ។ នៅពេលដែលកងទ័ពខ្មែរក្រហម បែកខ្ចាត់ខ្ចាយគ្នា ខ្លះទៅពួនសម្ងំ នៅភ្នំក្រវាញ ខ្លះទៅលាក់ខ្លួន នៅភ្នំដងរែក ប៉ុន្តែដែលបានកៀរប្រជាជន ស៊ីវិល តាមភូមិ ប្រមាណ ១០ ម៉ឺននាក់ទៅជាមួយផង។ ដើម្បីបញ្ចប់សង្គ្រាមផ្ទៃក្នុងនេះ លោក ប្រធានាធិបតីបារាំង វ៉ាឡេរី ហ្ស៊ីស្កា ដេស្តាំង បានស្នើសុំឲ្យសម្តេច នរោត្តម សីហនុ យាងមកជ្រកកោននៅលើទឹកដីបារាំង។ ប៉ុន្តែព្រះអង្គចង់បង្កើត ចលនា មួយ របស់ព្រះអង្គ ដើម្បីវាយរំលំ របប ហេង សំរិន ។ នៅថ្ងៃ ១០ កុម្ភៈឆ្នាំ ១៩៧៩ ដដែលនោះ សម្តេច នរោត្តម សីហនុ បានស្នើសុំ ឲ្យប្រទេសចិន ឈប់គាំទ្រ ពួកខ្មែរ



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ក្រហម បន្តទៅទៀត។ មួយសប្តាហ៍ក្រោយមក គឺនៅថ្ងៃ ១៨ កុម្ភៈ ទីក្រុងហាណូយ ចាប់ផ្តើមធ្វើអាណានិគមកិច្ច ទៅលើប្រទេសកម្ពុជាតែម្តង ដោយបង្ខំឲ្យរបបហេង សំរិន ចុះហត្ថលេខា ទៅលើសន្ធិសញ្ញា មិត្តភាពមួយ រវាងរបបកុម្មុយនិស្តទាំងពីរ។ ចាប់តាំង ពី ពេលនោះមក ប្រទេសវៀតណាម គ្រប់គ្រងប្រទេសកម្ពុជា ទាំងមូល តែម្តង ព្រោះ គ្មានទំនុកទុកចិត្តទៅលើ អ្នកដឹកនាំខ្មែរ ដែលរកតែឱកាសល្អ ដើម្បីរំដោះខ្លួន ចេញពី អាណានិគមកិច្ចនេះ របស់ វៀតណាម ។ គឺនៅ ពេលនោះហើយ ដែលលោក ប៉ែន សុវណ្ណ បានតែងតាំងខ្លួនលោក ជាអគ្គលេខាធិការ «បក្សកុម្មុយនិស្តកម្ពុជា» ដែលនៅ ពុំទាន់ប្តូរ ឈ្មោះមកជា «បក្សប្រជាជន បដិវត្ត កម្ពុជា» នៅឡើយ ។

## ការប្រជែង កម្លាំង រវាង ប្រទេស មហាអំណាច និង ក្រុមខ្មែរ បដិបក្ខ នានា

នៅពេលដែល ពួកខ្មែរក្រហម បាក់ទ័ពនៅឆ្នាំ ១៩៧៩ ហើយ នាំគ្នាទៅតាំងទី នៅ ក្នុងព្រៃដែលស្ថិតនៅ ជាយដែន ប្រទេសថៃ ពួកគេ ក៏បានកេណ្ឌប្រជាជនខ្មែរ ជា ច្រើនម៉ឺននាក់ ទៅជាមួយផងដែរ។ បន្ទាប់ពីបានទទួលជំនួយសាជាថ្មីទៀត ពីប្រទេសចិន ព្រម ទាំងជំនួយ ដ៏ក្រាស់ក្រែល ពី សហរដ្ឋ អាមេរិក ជាពិសេស បន្ទាប់ពីបានត្រូវ មហាសន្និ បាត អង្គការ សហប្រជាជាតិ សម្រេចទទួលស្គាល់ថា កងទ័ពខ្មែរក្រហម ជា កងទ័ព ដែល មានកម្លាំងគ្រប់គ្រាន់ សម្រាប់ដេញ កងទ័ពវៀតណាម ពីទឹកដីខ្មែរ ប្រទេសកម្ពុជា បានក្លាយ ទៅជាសមរភូមិ សាជាថ្មីទៀត ។ នៅក្នុងក្របខ័ណ្ឌ នៃ ទំនាស់ រវាង កុម្មុយ និស្តទាំងពីរ ខ្មែរក្រហម ក៏ បែកចេញ ជាពីរក្រុមដែរ ។ ក្រុម មួយដឹកនាំ ដោយ ប៉ែន សុវណ្ណ, ហេង សំរិន, ជា ស៊ីម, ហ៊ុន សែន មាន ប្រទេសវៀតណាម និង សហភាព សូវៀត ជាបង្អែក។ ក្រុមខ្មែរក្រហមមួយទៀត ដឹក នាំដោយ ប៉ុល ពត អៀង សារី មានប្រទេសចិន ប្រទេសថៃ សិង្ហបុរី និង សហរដ្ឋ

អាមេរិក ជាបង្អែក ។ នៅថ្ងៃ ៣ សីហា ឆ្នាំដដែលនោះ អង្គការ សេ អ៊ី សេ អ៊ែរ (C.I.C.R.) និង អង្គការ យូនីសេហ្វ (U.N.I.C.E.F.) បានប្រកាសប្រាប់ ពិភពលោក ទាំងមូលឲ្យដឹងថា ប្រជាជនខ្មែរ ចំនួន ២ លាន ៥ សែន នាក់ បាក់កម្លាំង ឈឺ ទ្រុឌទ្រោមយ៉ាងខ្លាំង បន្ទាប់ពីបានរស់នៅ ក្នុងទុក្ករិក្ស អស់រយៈពេល ជាង ៣ ឆ្នាំ ក្រោម របបខ្មែរក្រហម ។ កិច្ចការដែលរបប ហេង សំរិន ត្រូវធ្វើជាអាទិ៍ភាព គឺបញ្ជាក់អំពីមូលហេតុ ដែលបានជំរុញឲ្យពួកគេវាយរំលំ របប ប៉ុល ពត។ នៅថ្ងៃ ១៥ សីហា ឆ្នាំ ១៩៧៩ របប ហេង សំរិន បានបើកតុលាការ កាត់ទោស មេខ្មែរក្រហម ប៉ុល ពត និង អៀង សារី ដោយ កំបាំងមុខ។ ខាងអ្នកប្រឆាំង នឹង របប ហេង សំរិន វិញ គេបាន នាំគ្នាបង្កើត ចលនាជាច្រើន ជាបន្តបន្ទាប់។ នៅចុងខែសីហា ឆ្នាំ ១៩៧៩ ដដែលនោះ លោក គង់ ស៊ីលាស់ អតីតអនុសេនីយ៍ ឯកម្នាក់ នៃ អតីតកងនាវាចរខ្មែរ និង លោក ញ៉ែម សុផុន អតីតនាយទាហាន កងចត្រយោងខ្មែរម្នាក់ទៀត បានបង្កើតចលនា រំដោះជាតិកម្ពុជាមួយ នៅស្រុកសៀង ខេត្របាត់ដំបង។ ចលនានេះ ដែលមានឈ្មោះថា «មូលីណាកា» (Moulinaka) មាននិន្នាការគាំ ទ្រសម្តេច នរោត្តម សីហនុ ។ មួយ សប្តាហ៍ក្រោយ ការកកើតឡើង នៃចលនារំដោះជាតិ «មូលីណាកា» នេះ ពួកខ្មែរក្រហម ចង់គ្រប់គ្រង ចលនា រំដោះខ្មែរទាំងអស់ ដែលប្រឆាំង នឹង របប ហេង សំរិន ដោយ បង្កើតរណសិរ្សមួយមាន ឈ្មោះថា «រណសិរ្សស្នេហាជាតិ ប្រជាធិបតេយ្យ» ។ ពួកខ្មែរក្រហមបង្កើត រណសិរ្សនេះ នៅពេលដែលប្រជាជនខ្មែរ ជាច្រើនពាន់នាក់ បាននាំគ្នាភៀសសង្គ្រាម រត់មកដល់ ប្រទេសថៃ នៅ ក្នុងតំបន់ ត្រាប្រាយ៉ា ខាងជើង អារញ្ញប្រថេត ។ ដើម្បីកសាង របបកុម្មុយនិស្តមួយថ្មី ទៀត នៅប្រទេសកម្ពុជា ប៉ែន សុវណ្ណ មេដឹកនាំកុម្មុយនិស្តខ្មែរ នៃ របប ហេង សំរិន  បានទៅជួបលោក ប្រេសណេហ្វ នៅទីក្រុងម៉ូស្គូ។

នៅពេលដែល ជំរំចំនួន ១៣ បើកឡើងនៅតាម ព្រំប្រទល់ថៃ និងលើទឹកដី ថៃ សម្រាប់ទទួល ជនភៀសសង្គ្រាម ប្រមាណ ៦៥ ម៉ឺននាក់ / នៅក្នុងប្រទេសកម្ពុជា ឯនោះវិញ ការកសាង របប កុម្មុយនិស្តថ្មីមួយ តាមនិយាម សហភាព សូវៀត បេះតែ





បន្តទៅទៀត ទោះបីមានទំនាស់រវាង ជនកុម្មុយនិស្តខ្មែរ នៅក្នុងស្រុក និង ជនកុម្មុយនិស្តខ្មែរមក ពីវៀតណាមក្តី។ ចំពោះពួកខ្មែរក្រហម ដែលបានបះបោរប្រឆាំង នឹង ប៉ុល ពត គេចង់កាត់បន្ថយ ការគាបសង្កត់ របស់ វៀតណាមដែរ ប៉ុន្តែ ជាការពិបាក ដោយ ហេតុថាបើគ្មាន ការគាំទ្រ ពីប្រទេស វៀតណាម និង ពី សហភាព សូវៀត ទេនោះ ពួកខ្មែរក្រហម ខាងប៉ុល ពត នឹង វិលត្រឡប់មកវិញ ជាពុំខាន ។ ម៉្យាងទៀត ពួកអ្នករាជានិយម និង ពួកអ្នកប្រជាធិបតេយ្យ ពុំមានកម្លាំងគ្រប់គ្រាន់ ដើម្បីក្តោបក្តាប់ ចលនា រំដោះទាំងមូល បានទៅទៀត ។ ការពិត សង្គ្រាមនេះ ជាសង្គ្រាម រវាង បងប្អូនកុម្មុយនិស្ត ដូចគ្នា ពោលគឺ រវាង ចិន នឹង សហភាពសូវៀត។ រីឯបស្ចិមប្រទេស គេមិនចូលប្រឡូក ដោយផ្ទាល់ ក្នុងសង្គ្រាមនេះទេ ។ ប៉ុល ពត ជាមេដឹកនាំខ្មែរ កុម្មុយនិស្ត ខាងចិន មានសម្ព័ន្ធមិត្តគ្រាក់ៗ ដូចជា សហរដ្ឋ អាមេរិក និង បណ្តាប្រទេស អាស៊ាន ជាដើម ។ ខាង របប ហេង សំរិន គេគ្មានជម្រើសអ្វីទៀត ក្រៅពី ការពង្រឹង ជំហរ របស់គេ ជាមួយ ប្រទេសវៀតណាម និង សហភាព សូវៀត ព្រមទាំង បណ្តាប្រទេស នៃ កតិកាសញ្ញា វ៉ារស្សូវី ឡើយ។ អ្នកវិភាគខ្លះយល់ថា ប្រសិនណាជាគ្មាន រណសិរ្ស វាយប្រហារ ដេញកងទ័ពវៀតណាម ចេញពីទឹកដីខ្មែរ នោះទេ វៀតណាម ច្បាស់ ជាពុំងាយនឹងដកទ័ព ចេញ ពីទឹកដីខ្មែរឡើយ។ ប៉ុន្តែ អ្នកវិភាគខ្លះទៀត យល់ថា បើគ្មានសហភាព សូវៀត ជាបង្អែកទេ កងទ័ពវៀតណាម ក៏ពុំអាចឈរជើង នៅលើដីខ្មែរបានឡើយ ហើយ បើកុំតែ សហភាព សូវៀត រលំរលាយបាត់ទៅ គ្មានថ្ងៃណា ប្រទេសកម្ពុជា អាចរំដោះខ្លួន ចេញពីវៀតណាម បានទេ ។ គឺ ការរលំរលាយ នៃ សហភាព សូវៀត នេះហើយដែលបាននាំទៅដល់ សន្និសីទអន្តរជាតិ ទីក្រុងប៉ារីស៍ ឆ្នាំ ១៩៨៩ ។

# សភាពការណ៍ ប្រទេស កម្ពុជា ក្រោយ ព្រឹត្តិការណ៍ ថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩

## Le Cambodge après le 7 janvier 1979

បញ្ហាដែលចោទឡើង ក្រោយការវាយរំលំរបប ប៉ុល ពត មានជាច្រើនឥត គណនា ។ ក្រៅពី ការកសាង ហេដ្ឋារចនាសម្ព័ន្ធ សេដ្ឋកិច្ច និង វប្បធម៌ ឡើងវិញ ដោយចាប់ផ្តើមពីសូន្យ របបថ្មីត្រូវធ្វើឲ្យប្រជាជន ដែលនៅសល់ពីការសម្លាប់រង្គាល ក្នុងរបបប៉ុល ពត រស់រាន មានជីវិតឡើងវិញ ។ ដើម្បីជួសជុល ហេដ្ឋារចនាសម្ព័ន្ធ ឲ្យមានដំណើរការឡើងវិញ របប ហេង សំរិន ខិតខំប្រមែប្រមូលបញ្ញវន្ត អ្នកបច្ចេកទេសខ្មែរ ដែលនៅសេសសល់ពីស្លាប់ ឲ្យមកជួយ កសាង រដ្ឋអំណាចថ្មី ពោលគឺ របប កុម្មុយនិស្តមួយថ្មី តាមបែប សហភាព សូវៀត វិញម្តង។ ប៉ុន្តែ ការប្រមែប្រមូលនេះ មិនមែនជា ការងាយស្រួល ឡើយ ដោយហេតុថា បញ្ញវន្តម្នាក់ៗ មាននិន្នាការនយោបាយ និងមនោគមវិជ្ជាខុសៗគ្នា ។ រីឯការអប់រំ និងកម្រិតវប្បធម៌ ក៏ខុសគ្នាទៀត។ តែបើពុំរួបរួមគ្នាសិនទេនោះ ពួកខ្មែរក្រហម ខាងចិន និង អាមេរិក នឹង វិលត្រឡប់ មកធ្វើទុក្ខទោស ប្រជាជនខ្មែរវិញ ជាពុំខាន ។ ម្យ៉ាងទៀត កម្លាំងអ្នករាជានិយម និង អ្នកប្រជាធិបតេយ្យ ទោះបូករួមគ្នាមក ក៏ មិនអាចក្តោបក្តាប់កម្លាំង រំដោះទាំងមូលបានដែរ។ ខ្មែរក្រហម ដឹកនាំដោយ ប៉ុល ពត មានការគាំទ្រយ៉ាងមាំ ពី ប្រទេសចិន។ ទោះបី សម្តេច នរោត្តម សីហនុ បានស្នើសុំឲ្យចិនឈប់ គាំទ្រខ្មែរក្រហមក្តី ក៏ចិនមិនព្រមដែរ ព្រោះ សម្តេច សីហនុ មិនមែនជាកូនអុក របស់ចិនឯណា គឺគ្រាន់តែជាសម្ព័ន្ធមិត្ត ឬជាឈ្នាន់ តែប៉ុណ្ណោះ។ នៅថ្ងៃ ២៦ មិនាឆ្នាំ ១៩៨១ នៅទីក្រុងប៉ារីស៍ ខ្មែរដែលមាន និន្នាការ រាជានិយម បានបង្កើត ចលនា តស៊ូមួយ របស់ ខ្លួនផ្ទាល់ មានឈ្មោះថា ហ្វុនស៊ីនប៉េច (F.U.N.C.I.N.P.E.C.) ហើយ ដែលមាន សម្តេច នរោត្តម សីហនុ ជាអ្នកដឹកនាំ ។





នៅឆ្នាំ ១៩៨១ ដដែលនោះ ប៉ុន្តែ នៅចុង ខែឧសភា នៅក្នុងប្រទេសកម្ពុជា ឯនោះវិញ ប៉ែន សុវណ្ណ មេខ្មែរកុម្មុយនិស្ត មកពី ហាណូយ បានត្រូវតែងតាំង សាជាថ្មីទៀតជាលេខា «បក្សកុម្មុយនិស្តកម្ពុជា» ដែលទើបនឹង បានប្តូរឈ្មោះ មកជា «បក្សប្រជាជន បដិវត្តកម្ពុជា» វិញ។ នាមហាសន្និបាតបក្សលើកទី ៤ ដែលប្រព្រឹត្តិទៅ ពីថ្ងៃ ២៦ ដល់ ថ្ងៃ ២៩ ឧសភា គណកម្មាធិការមជ្ឈិមបក្ស ដែលមានសមាជិកទាំងអស់ ២១ នាក់ បាន ត្រូវតែងតាំង។ ក្នុងពេលជាមួយគ្នានោះ សមាជិកការិយាល័យ នយោបាយ ៨ រូប ក៏បានត្រូវតែងតាំងផងដែរ។ គឺអ្នកទាំងនេះហើយ ដែលជាអ្នកដឹកនាំ របបហេង សំរិន រីឯអ្នកឯទៀតៗ គ្រាន់តែជាអ្នកដើរតាម ឬជាអ្នកអនុវត្តប៉ុណ្ណោះ។ ក្រុមសំខាន់ៗ ដែលជា សមាសភាព នៃ ថ្នាក់ដឹកនាំបក្ស និង រដ្ឋ នៅពេលនោះ មាន ៤ ក្រុមចេញ មកពីប្រភព ខុសគ្នា គឺ ៖ ១) ក្រុម ប៉ែន សុវណ្ណ, រស់ សាម៉័យ, ជា សុទ្ធ ដែលបាន ទទួលការហាត់ ហ្វឹកហ្វឺន នៅហាណូយ តាំងពី ក្រោយកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ – ២) ក្រុមខ្មែរក្រហម ក្នុងស្រុក ដែលបះបោរប្រឆាំង នឹង ប៉ុល ពត មានជា អាទិ៍ : ហេង សំរិន, ជា ស៊ីម, ហ៊ុន សែន - ៣ ) ក្រុមមាន ប្រភពមកពី ថៃ ដូចជា សាយ ភូថង, ទៀ បាញ់, ចា រៀង ជាដើម – ៤) ក្រុមជនជាតិ ទំពួន អ្នកតស៊ូ នៅស្ទឹងត្រែង មាន ប៊ូ ថង ជាដើម។ ៤ ឆ្នាំក្រោយពេលដែល ប៉ែន សុវណ្ណ ត្រូវ គេដកហូតចេញពីអំណាច (១៩៨១) ហើយបន្ទាប់ពី ចាន់ ស៊ី ទទួលមរណភាពទៅ លោក ហ៊ុន សែន ដែលបាន ត្រូវតែងតាំងជារដ្ឋមន្ត្រីទី ១ ជំនួស លោក ចាន់ ស៊ី នៅ ឆ្នាំ ១៩៨៥ បានបង្កើតក្រុមមួយ ទៀត ដែលមានទាំងអតីតខ្មែរក្រហម ភូមិភាគបូព៌ា ទាំងក្រុមបញ្ញាជនដែល ប៉ែន សុវណ្ណ និង អ្នកជំនាញការវៀតណាម បានប្រមែប្រមូល នៅឆ្នាំ ១៩៧៩-១៩៨១ ។ លោក ជា ស៊ីម ដែលជាមេក្រុមខ្មែរក្រហម ផ្នែកបូព៌ា ហើយដែលមានទំនាស់ជាមួយ ប៉ែន សុវណ្ណ បានទទួលតែតួនាទី កិត្តិយស ប៉ុណ្ណោះ បន្ទាប់ពីបានត្រូវគេដកហូត ពី ក្រសួងមហាផ្ទៃ នៅឆ្នាំ ១៩៨១។

# ពី រដ្ឋាភិបាល ហេង សំរិន ទៅ រដ្ឋាភិបាល ប៉ែន សុវណ្ណ

## Du Gouvernement Héng Samrin au Gouvernement Penn Sovan

របបសាធារណរដ្ឋ ប្រជាមានិត កម្ពុជា ដែលបានត្រូវប្រកាស នៅថ្ងៃ ១១ មករា ឆ្នាំ ១៩៧៩ ត្រូវប្រឈមមុខនឹងបញ្ហាសំខាន់ៗ ៥ យ៉ាង គឺ ៖១) ការមិនព្រមទទួលស្គាល់ពី សំណាក់ អង្គការ សហប្រជាជាតិ ព្រោះជារបបមួយ ដែលត្រូវគេចាត់ទុកជាជា របបបន្តុប ដោយកងទ័ពវៀតណាម ដែលឈ្លានពាន ទឹកដីខ្មែរ - ២) ការកសាងប្រទេសឡើងវិញ «ដោយបាតដៃទទេ» គឺ នៅលើ គំនរបាក់បែក ដែល របប ប៉ុល ពត បានបន្សល់ ទុកឲ្យ ជាពិសេសការកសាងជីវភាព សុខាភិបាល សេដ្ឋកិច្ច និង វប្បធម៌ សិក្សាធិការ ជាតិ សម្រាប់ប្រជាជន ដែលបានបាត់បង់ ទ្រព្យសម្បត្តិ វិជ្ជាជីវៈ ព្រមទាំង សមាជិក គ្រួសារ របស់គេ ស៊ឹងតែអស់ គ្មានសល់ ។ - ៣ ) អាណានិគមកិច្ច របស់ វៀតណាម - ៤) ការ ប្រជែងកម្លាំងគ្នា រវាងក្រុម ប៉ែន សុវណ្ណ មកពីហាណូយនិងក្រុម ជា ស៊ីម - ហេង សំរិន ខ្មែរក្រហមនៅក្នុងស្រុក ដែលបានបះបោរប្រឆាំង នឹង ប៉ុល ពត - ៥) ការប្រឈមមុខ នឹងកងទ័ពខ្មែរក្រហម ខាង ប៉ុល ពត ព្រមទាំង ចលនា តស៊ូរំដោះនានា ដែលប្រជែង ជាមួយ ពួកខ្មែរក្រហម ប៉ុល ពត ក្នុងការរំដោះប្រទេសកម្ពុជា ចេញពី វៀតណាម។

បន្ទាប់ពីរដ្ឋសភាលើកដំបូងបង្អស់ បានត្រូវតែងតាំង សម័យប្រជុំពេញអង្គលើក ទី ១ បានចាប់ដំណើរការ នៅថ្ងៃ ២៤ មិថុនា ឆ្នាំ ១៩៨១ ហើយ នៅ ថ្ងៃ ៧ ខែ ដដែល នោះ រដ្ឋធម្មនុញ្ញមួយ បានត្រូវប្រកាសឲ្យប្រើ ។ នៅក្នុងសម័យប្រជុំនោះ រដ្ឋសភា បាន តែងតាំង ស្ថាប័នរដ្ឋ សំខាន់ៗ ពីរ គឺ រដ្ឋាភិបាល និង ក្រុមប្រឹក្សារដ្ឋ។ ស្ថាប័នចុង ក្រោយនេះ មានតួនាទី ជាគណប្រធានរដ្ឋ ពោលគឺអង្គការ នីតិប្បញ្ញត្តិផង





ជាអង្គការនីតិ ប្រតិបត្តិផង។ លោក ហេង សំរិន បានត្រូវតែងតាំងជា ប្រធាន អង្គការនេះ ដែលមានសមាជិក ៧ រូប ។ លោក ជា ស៊ីម បានត្រូវតែងតាំងជាប្រធានរដ្ឋសភា។ លោក ប៉ែន សុវណ្ណ ដែលជា អគ្គលេខាធិការបក្ស បានត្រូវតែងតាំងជានាយករដ្ឋមន្ត្រី។ រដ្ឋាភិបាល លោក ប៉ែន សុវណ្ណ គ្រប់គ្រងប្រទេស បានត្រឹមជាង ៦ ខែប៉ុណ្ណោះ ព្រោះនៅខែធ្នូឆ្នាំ ១៩៨១ ដដែល នោះ លោក ប៉ែន សុវណ្ណ បានត្រូវគេដកហូត ពីមុខតំណែង ហើយ បញ្ជូនទៅប្រទេស វៀតណាមបាត់ទៅ បន្ទាប់ ពីមានទំនាស់មួយ ដ៏ធំ រវាង ខ្មែរក្រហម ក្រុមបូព៌ា និង អ្នកដែលមកពីហាណូយ ។ ការដកហូត ប៉ែន សុវណ្ណ ពីមុខតំណែង ដ៏សំខាន់នេះ បានត្រូវគេ ពិពណ៌នា ថា មកពី ប៉ែន សុវណ្ណ ប្រមាថ ទីក្រុងហាណូយ យ៉ាងខ្លាំង ដោយចង់មានទំនាក់ទំនងដោយផ្ទាល់ជាមួយទីក្រុងម៉ូស្គូ ដោយរំលង ទីក្រុង ហាណូយ ។ គេសង្កេត ឃើញម៉្យាងទៀតថា នៅពេលនោះ ប៉ែន សុវណ្ណ ប្រឆាំង នឹង នយោបាយអន្តោប្រវេសន៍ ទាក់ទង នឹង ជនជាតិវៀតណាម នៅក្នុងប្រទេសកម្ពុជាផង ហើយ ការប៉ុនប៉ងរំដោះ ប្រទេសកម្ពុជាពី ការគាបសង្កត់ របស់ វៀតណាមផង ។ ប៉ុន្តែ បើតាម ការបកស្រាយមួយទៀត គឺ មកពី ប៉ែន សុវណ្ណ ដែលជាអតីតខ្មែរវៀតមិញ ដណ្តើមតួនាទីដឹកនាំ របស់ ««ខ្មែរក្រហមក្នុងស្រុក»» ។

នៅក្នុងរដ្ឋាភិបាល ហេង សំរិន ដែលតែងតាំងនៅថ្ងៃ ៨ មករា ឆ្នាំ ១៩៧៩ លោក ជា ស៊ីម ទទួលបន្ទុកខាងមហាផ្ទៃ ។ ប៉ុន្តែ នៅក្នុងរដ្ឋាភិបាល ប៉ែន សុវណ្ណ នាថ្ងៃ ២ កក្កដាឆ្នាំ ១៩៨១ លោក ជា ស៊ីម ពុំមានតួនាទី ជាយុទ្ធសាស្ត្រនេះទៀតទេ។ តួនាទី ជារដ្ឋមន្ត្រីមហាផ្ទៃ បានត្រូវប្រគល់ទៅឲ្យ លោក ខាង សារីន វិញ។ បន្ទាប់ពីបាត់បង់ ក្រសួងមហាផ្ទៃ នៅឆ្នាំ ១៩៨១ នោះមក លោក ជា ស៊ីម ពុំបានទទួលមុខនាទីអ្វី ទាំង អស់ នៅក្នុងរដ្ឋាភិបាល ទោះជានៅក្នុងរដ្ឋាភិបាល លោក ហ៊ុន សែន នៅពេលក្រោយមកទៀត ក្តី ។ លោក ជា ស៊ីម បានទទួលមុខតំណែង ជាប្រធានរដ្ឋសភា រីឯលោក ហេង សំរិន លោកបានទទួល មុខនាទី ជា ប្រធានក្រុមប្រឹក្សារដ្ឋ ។ លោក ហ៊ុន សែន ដែល មានមុខនាទីជារដ្ឋមន្ត្រី ការបរទេស នៅក្នុងរដ្ឋាភិបាល ហេង

សំរិន បានរក្សាទុក មុខនាទីនេះដដែល នៅក្នុងរដ្ឋាភិបាលលោក ប៉ែន សុវណ្ណ ។ សមាជិក ភាគច្រើន នៃ រដ្ឋាភិបាល លោក ប៉ែន សុវណ្ណ សុទ្ធសឹងជាអ្នកដែលបានទទួលការហ្វឹកហ្វឺន នៅហាណូយ ក្រោយឆ្នាំ ១៩៥៤ ដូចជា លោក ចាន់ ស៊ី លោក ជា សុទ្ធ លោក ចាន់ ភីន ជាដើម ។ ក្រៅពីនោះ មានបញ្ញវន្តមួយចំនួន ដែលមានទំនាក់ទំនងជិតស្និទ្ធ ជាមួយលោក ប៉ែន សុវណ្ណ ផងដែរ ដូចជា លោក គង់ សំអុល លោក ចេង ផុន លោក យិត គឹម សេង លោក ប៉ែន ណាវុឌ្ឍ ជាដើម ។ នៅពេលនោះ កងទ័ពវៀតណាម ដែលឈរជើងនៅ លើទឹកដីខ្មែរ មានចំនួនប្រមាណ ២០ ម៉ឺននាក់ ដែលវាយគ្រប់ទីកន្លែង ដើម្បីទប់ទល់ នឹង កម្លាំងខ្មែរក្រហម ខាង ប៉ុល ពត ដែលមានការគាំទ្រយ៉ាងរឹងមាំ ពី ប្រទេសចិន និង សហរដ្ឋ អាមេរិក។ នៅក្នុងសន្និសិទអន្តរជាតិមួយនៅអង្គការ សហប្រជាជាតិ ដែលបើក សម័យប្រជុំ នៅថ្ងៃ ១៣ រហូតដល់ថ្ងៃ ១៧ កក្កដា ឆ្នាំ ១៩៨១ ដដែលនោះ អង្គប្រជុំ បានទទួលយកសេចក្តីស្នើមួយ របស់ប្រទេសចិន ដែលតម្រូវឲ្យប្រទេសវៀតណាម ដកកងទ័ពទាំងអស់ ចេញពី ទឹកដីខ្មែរ បន្ទាប់មក រៀបចំការបោះឆ្នោតមួយ ដែលស្ថិតនៅក្រោមឱវាទ របស់ អង្គការ សហប្រជាជាតិ ប៉ុន្តែ ដែលគ្មានការដកហូតអាវុធ ពីក្រុមខ្មែរក្រហម ដឹកនាំដោយ ប៉ុល ពត។

## ការបំពាក់បំប៉ន លទ្ធិកុម្មុយនិស្ត ដល់ កម្មាភិបាល ខ្មែរ នៅ ជំនាន់ របប ហេង សំរិន

## Le « lavage de cerveau » dans le régime de Héng Samrin

របប ហេង សំរិន ដែលប្រទេសវៀតណាម និង សហភាព សូវៀត បានបង្កើតឡើង ហើយគាំទ្រ យ៉ាងពេញទំហឹង ទាំងខាង ផ្នែកយោធា ទាំងផ្នែក នយោបាយ និង





សេដ្ឋកិច្ច ជា របបកុម្មុយនិស្តមួយ ដែលឈរ នៅលើគោលការណ៍ «សាមគ្គីភាពអន្តរជាតិ នៃវណ្ណៈអធន» គឺខុសពីរបប ប៉ុល ពត ដែលសង្កត់ធ្ងន់ទៅលើ ស្មារតីជាតិនិយមមួយបែប ដែលមានលក្ខណៈដាច់ខាត ។ អតីតកម្មាភិបាលខ្មែរក្រហម ដែលធ្លាប់ទទួលការអប់រំ ពី ប៉ុល ពត ក៏ដូចជាបញ្ញវន្តខ្មែរមួយចំនួន ពិបាក នឹង ទទួលគំនិតនេះណាស់ ជាពិសេស ពិបាកនឹងយល់ អំពីសាមគ្គីភាព ជាមួយវៀតណាម។ ទន្ទឹមនោះដែរ គោលការណ៍ «អំណាចផ្តាច់ការ នៃ វណ្ណៈអធន» ក៏ មិនដូចនៅជំនាន់ ប៉ុល ពត ដែរ ព្រោះបញ្ញវន្ត មានតួនាទី ដ៏ សំខាន់ ហើយ ការដោះដូរ តាមផ្សារផ្សេ ក៏មាន សកម្មភាពឡើងវិញដែរ ប៉ុន្តែនៅក្នុងទំហំមួយដ៏តូចៗ ទោះជាយ៉ាងនេះក្តី ក៏កម្មាភិបាលខ្មែរ ដែលធ្វើការតាមក្រសួង-មន្ទីរ នានា ជាពិសេស កម្មាភិបាលធំៗ បានត្រូវបញ្ជូន ទៅឲ្យរៀនសូត្រទ្រឹស្តីកុម្មុយនិស្ត ម៉ាក្ស-លេនីន នៅប្រទេសវៀតណាម ឬ នៅសហភាព សូវៀតដែរ។ នៅក្នុងពេលដដែលនោះ ការរៀបចំរដ្ឋបាលក្រសួង-មន្ទីរ ក៏ស្ថិតនៅក្រោមឱវាទរបស់ អ្នកជំនាញការវៀតណាម ទាំងអស់។

វគ្គសិក្សា នយោបាយដែល បានត្រូវរៀបចំឡើងទាំងក្នុងស្រុក ទាំងក្រៅស្រុក មានថេរវេលា ពី ២ ខែ ទៅ ៦ ខែ ហើយជួនកាលទៅ រាប់ឆ្នាំផង ក៏មាន។ គោលដៅសំខាន់ នៃ វគ្គសិក្សានយោបាយនេះ គឺផ្តល់របៀបពិចារណា ទស្សនវិជ្ជា និង នយោបាយ មួយថ្មី ទៅឲ្យអ្នកដឹកនាំគ្រប់រូប។ «វិធីលាងខួរក្បាល» នេះ មានគោលដៅ ជម្រះ «គំនិត អវិជ្ជមាន» ចេញពី «អារម្មណ៍ប្រតិកិរិយា» របស់ អ្នកទទួលខុសត្រូវគ្រប់ផ្នែកគ្រប់ជាន់ថ្នាក់។ ដោយលទ្ធិដែលគ្រប់គ្រងប្រទេសកុម្មុយនិស្តផ្អែកទៅលើ ទ្រឹស្តី ម៉ាក្ស-លេនីន គេត្រូវយល់ទស្សនវិជ្ជានេះ ឲ្យបានច្បាស់គ្រប់ៗគ្នា ។ កម្មវិធី មានជាអាទិ៍ ៖ ទស្សនវិជ្ជា សម្ភារនិយម វិចារវិទ្យា ឬ រូបធាតុនិយម វិចារវិទ្យា [២២] និង សម្ភារនិយម

---

[២២] Matérialisme dialectique

ប្រវត្តិសាស្ត្រ [២៣]។ គេបង្ហាត់ឲ្យពិចារណាថា គំនិតអ្វី ក៏ដោយកើតមកពី សម្ភារ ឬ រូបធាតុ (La matière) ពី ជីវិតជាក់ស្តែងទាំងអស់ គឺគ្មានព្រះអាទិទេពឯណា អាចច្នៃគំនិត របស់ មនុស្សនោះទេ។ ក្រៅពីទស្សនវិជ្ជានេះ គេបង្ហាត់មុខវិជ្ជាផ្សេងៗទៀត ដូចជាការគ្រប់គ្រង ការបាត់តាំង ការដឹកនាំប្រជាជន កម្មាភិបាល និង កងទ័ពជាដើម។ ចំពោះអ្នកមាន «កម្រិតវប្បធម៌» ទាបពីពេលមុន ការសិក្សាទ្រឹស្តីទស្សនវិជ្ជា កម្រិតខ្ពស់បែបនេះ ជាការមួយ ដ៏ ពិបាកពន់ពេកក្រៃ ។ អ្នកខ្លះត្អូញត្អែថា ការប្រយុទ្ធ នឹងអាវុធស្រួលជាង។ ប៉ុន្តែ សាស្ត្រាចារ្យ ប្រដៅវិញថា «គេពុំខ្លាចសត្រូវដែលប្រើអាវុធទេ តែគ្រោះថ្នាក់ធំ បំផុត គឺប្រាជ្ញា និងការចេះដឹង» ។ ការឆ្លងកាត់វគ្គសិក្សានេះ ជា វិញ្ញាសា សំខាន់ណាស់ ។ ហេតុដូច្នេះហើយ បានជាក្រោយពីបានសិក្សារួច បញ្ញវន្ត ជាច្រើន បានទទួលតួនាទីសំខាន់ៗ ជាងអ្នកតស៊ូជើងចាស់ទៅទៀត។ រីឯពាក្យស្លោកនៅពេលនោះ គឺ ៖ បដិវត្តន៍ ហ៊ានយក កម្មាភិបាលល្ងង់ ១០០ នាក់ទៅដូរយកអ្នកមានប្រាជ្ញាម្នាក់។ ទោះជាយ៉ាងណាក្តី អ្នកដែលបានរៀនសូត្ររួចហើយ នៅតែពុំយល់អំពីចំណុចជាច្រើន ដូចជាសាមគ្គីភាព នៃវណ្ណៈអធន និង ការកសាងសង្គមមួយ ដែលមានលក្ខណៈវិទ្យាសាស្ត្រ ដោយបោះបង់ចោល រាល់ជំនឿ ដែលគ្មានមូលដ្ឋានជាដើម។ ចំពោះអ្នកដែលចង់រក្សាទំនៀម ទម្លាប់ខ្មែរ គេមានការខកចិត្តយ៉ាងខ្លាំង ។ ពិបាកជាងនេះទៅទៀត គឺការកំចាត់ឲ្យអស់ពីអារម្មណ៍នូវរាល់គំនិតអត្តនោម័ត (subjectivisme) ពោល គឺ គិតផ្តេសផ្តាសតែខ្លួនឯង។ គេត្រូវធ្វើអ្វីដែលស្របនឹង ក្រិត្យក្រមសត្យានុម័ត (lois objectives) ជានិច្ច។

ទន្ទឹម នឹង ការរៀនសូត្រ ទ្រឹស្តី ទស្សនវិជ្ជា ទាំងឡាយនេះដែលត្រូវប្រើពេល រាប់ខែ កម្មាភិបាលខ្មែរត្រូវខិតខំកសាង និង ជួសជុលហេដ្ឋារចនាសម្ព័ន្ធ រៀបចំក្រសួងមន្ទីរ និង ស្ថាប័នផ្សេងៗ ។ ប៉ុន្តែ កិច្ចការនេះពិបាកក្រៃលែង ព្រោះខ្វះសព្វ ខ្វះគ្រប់ ខ្វះ

[២៣] Matérialisme historique





មធ្យោបាយគ្រប់គ្រាន់ ។ ម្យ៉ាងទៀត ដោយ ទស្សនវិជ្ជា កុម្មុយនិស្ត មិនទទួលស្គាល់គំនិតផ្តួចផ្តើម របស់បុគ្គល ព្រមទាំងកត្តាទាំងឡាយ ដែលគេចាត់ទុកថា អត្តនោម័ត ឬ ក៏ ប៉ះពាល់ដល់ ប្រយោជន៍ របស់វណ្ណៈអធន ការលូតលាស់ផ្នែកសេដ្ឋកិច្ច ត្រូវរាំងស្ទះ ព្រោះ តាមការពិតទៅ ដំណើរការ សេដ្ឋកិច្ច មានជាប់ពាក់ព័ន្ធ ជានិច្ច នឹង សតិអារម្មណ៍ របស់ មនុស្ស ។ បើអ្វីៗ ត្រូវយកទៅដាក់ ជា របស់រួមទាំងអស់ទៅហើយ បុគ្គលម្នាក់ៗ ធ្វើអ្វីៗ ឲ្យតែរួចពីដៃ ប៉ុណ្ណោះ គឺ គុណភាព ក៏គ្មាន បរិមាណ ក៏គ្មាន។

## ការកសាង របប

## សាធារណរដ្ឋ ប្រជាមានិត កម្ពុជា

## La construction de la République populaire du Kampuchéa

នៅពេលដែល របប ហេង សំរិន ចាប់ផ្តើមកសាងរដ្ឋអំណាចថ្មី ហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងទុនផ្នែកបញ្ញា ទាំងប៉ុន្មានដែលខ្មែរយើង ធ្លាប់មាន ពីពេលមុនៗ បានត្រូវរបបខ្មែរក្រហម កំទេចចោលខ្ទេចខ្ទីអស់ ដើម្បីអនុវត្តមាគ៌ា «បដិវត្តន៍វប្បធម៌» របស់ចិន ។ បន្ទាប់ពី បានបង្កើត រដ្ឋាភិបាលបណ្តោះអាសន្ន ដែលមានឈ្មោះថា «ក្រុមប្រឹក្សាប្រជាជន បដិវត្ត កម្ពុជា» នៅថ្ងៃ ៨ មករា ឆ្នាំ ១៩៧៩ របប នយោបាយថ្មី បានប្រកាស ឈ្មោះ របប របស់គេ ថា «សាធារណរដ្ឋ ប្រជាមានិតកម្ពុជា» នៅ ថ្ងៃ ១២ មករា ឆ្នាំ ដដែល។ កិច្ចការដែល របបថ្មីនេះ ត្រូវធ្វើ មាន ទំហំ ធំក្រៃលែង ។ គេត្រូវជួសជុល ប្រព័ន្ធចែកចាយទឹក ចែកចាយចរន្ត អគ្គីសនីផង ជួសជុលអាគារសាធារណៈផង ហើយ រៀបចំ មូលដ្ឋាន សេដ្ឋកិច្ចមួយ ដ៏ថ្មីស្រឡាងផង ។ ការរៀបចំស្ថាប័នរដ្ឋ ឲ្យមានដំណើរការសន្សឹមៗ សិន ក៏ បានជួប នឹង ឧបសគ្គ ច្រើនណាស់ដែរ ព្រោះកិច្ចការនេះ ទាមទារនូវទុនផ្នែកបញ្ញាយ៉ាងខ្លាំងក្លា ជាពិសេស សមត្ថកិច្ចបច្ចេកទេស ឯកទេសគ្រប់ប្រភេទ ។ នៅចំពោះមុខភារកិច្ច ដ៏ធំធេងបែបនេះ បញ្ញវន្តដែលនៅ

សល់ពីស្លាប់ ត្រូវបញ្ចេញ អស់កម្លាំងកាយ កម្លាំងចិត្ត កម្លាំងប្រាជ្ញា របស់គេ ដើម្បីស្តារប្រទេស ឡើងវិញ ដោយទុករឿង នយោបាយ មួយអន្ទើសិន ។ គេនាំគ្នានិយាយចំអក នៅពេលនោះថា : «ខាងណា ក៏ដូចខាងណាដែរ គឺតែរឿងដណ្តើមអំណាចគ្នា ធ្វើធំហ្នឹង ព្រោះពួកគេ ឥតចេះធ្វើអ្វីទៀតក្រៅពីនេះទេ» រីឯអ្វីដែលសំខាន់ គឺ ធ្វើឲ្យប្រជាជនរស់ឡើងវិញ រៀបចំការបង្កបង្កើតផល បង្កើន សមត្ថភាព ការចេះដឹងរបស់ គេឲ្យបានទាន់ពេល បើពុំនោះសោតទេ នឹង ត្រូវប្រទេសជិតខាង ប្រមាថមើលស្រាល ជាពុំខាន ជាពិសេស ដើម្បីកាត់បន្ថយចំនួន អ្នកជំនាញការវៀតណាម ទម្រាំមាន ឱកាសល្អ រំដោះប្រទេសឲ្យចេញផុត ពីនឹមអាណានិគម វៀតណាម ។ ដើម្បី កសាងមូលដ្ឋានសេដ្ឋកិច្ច គេត្រូវបង្កើត រូបិយវត្ថុ និង ប្រព័ន្ធហិរញ្ញវត្ថុ។ ជាបឋម គេត្រូវបង្កើត ប្រាក់រៀល ឲ្យមានដំណើរការឡើងវិញ ព្រោះ ប៉ុល ពត បានកំទេចចោលអស់ទៅហើយ។ នៅថ្ងៃ ២០ មិនាឆ្នាំ ១៩៨០ របបថ្មី បានចេញក្រដាសប្រាក់រៀល ឲ្យធ្វើ ចរាចរ ឡើងវិញ។ នៅក្នុងវិស័យនយោបាយ អ្នកដឹកនាំ ខ្មែរ និង អ្នកជំនាញការវៀតណាម បានប្រមែប្រមូលអ្នកច្បាប់ខ្មែរ ដែលនៅសល់ពី ការកាប់សម្លាប់ក្រោម របប ប៉ុល ពត ឲ្យមករៀបចំបង្កើត មូលដ្ឋានច្បាប់មួយ សម្រាប់ គ្រប់គ្រងប្រទេស ។ បន្ទាប់ពី បោះឆ្នោតជ្រើសតាំងសភា ធម្មនុញ្ញនៅឆ្នាំ ១៩៨០ រដ្ឋធម្ម នុញ្ញមួយ បានត្រូវអនុម័ត ដោយអង្គប្រជុំសភា លើកដំបូងបង្អស់ នាថ្ងៃ ២៧ មិថុនាឆ្នាំ ១៩៨១។ បន្ទាប់ពី បង្កើតស្ថាប័នរដ្ឋបាន ជាបន្តបន្ទាប់ ការចាប់ផ្តើមដំណើរការ បានជួប នឹង ឧបសគ្គជាច្រើន ដោយខ្វះកម្មាភិបាល និង អ្នកឯកទេស ។ ដើម្បីដោះស្រាយបញ្ហា អស់ទាំងនេះ គេបានរៀបចំឲ្យមាន វគ្គសិក្សាគ្រប់ផ្នែក ក្នុងប្រទេសទាំងមូល។ ប៉ុន្តែ ការស្តារសមត្ថកិច្ច ដ៏ច្រើនបែបនេះ មិនអាចធ្វើទៅបាន ដោយ គ្មានជំនួយ ពីក្រៅបានឡើយ ហើយ ក៏ត្រូវចាយពេលវេលា និងប្រាក់យ៉ាងសន្ធឹកសន្ធាប់ផងទៀត។ ដោយមានជំនួយពី អង្គការ មនុស្សធម៌ ដូចជា អង្គការ «កាកបាទក្រហម» អន្តរជាតិ ជាដើម និង អង្គការ ក្រៅរដ្ឋាភិបាល ប្រមាណ ១១ ព្រមទាំងជំនួយ ពីបណ្តាប្រទេស នៃ កតិកាសញ្ញា វ៉ារស្សូវី ផង ក្រសួងមន្ទីរមួយចំនួន ដែលទាក់ទង នឹង សេចក្តីត្រូវការជាបន្ទាន់ របស់ ប្រជាជន ដូចជា





ក្រសួងសុខាភិបាល ក្រសួង អប់រំជាតិ ក្រសួង កសិកម្ម ជាដើម ក៏មានដំណើរការ ជាសន្សឹមៗ។

នៅពេលដែល ស្ថាប័ន ក្រសួងមន្ទីរផ្សេងៗ ចាប់ផ្តើមមាន សកម្មភាព ជាបន្តបន្ទាប់ ការប្រយុទ្ធ នឹង ចលនាតស៊ូ ក៏ចេះតែបន្ត ឥតឈប់ឈរដែរ។ នៅខែ មករា ឆ្នាំ ១៩៨០ សហរដ្ឋអាមេរិក បានបង្ហូលប្រាក់ដោយសម្ងាត់ ទៅឲ្យ ចលនានេះ ជាពិសេស ដើម្បីកសាងកងទ័ពខ្មែរក្រហមរបស់ ប៉ុល ពត ឡើងវិញ ។ បើគិតពីឆ្នាំ ១៩៨០ មកទល់ នឹង ឆ្នាំ ១៩៨៦ ទឹកប្រាក់ដែល សហរដ្ឋ អាមេរិក បានផ្តល់ដោយលួចលាក់ ទៅឲ្យខ្មែរ ក្រហម មានចំនួន ប្រមាណ ៨៥ លានដុល្លារ ។ នៅថ្ងៃ ៥ មិនា ឆ្នាំ ១៩៨០ សម្តេច នរោត្តម សីហនុ ធ្វើការចរចា ជាមួយ ខ្មែរក្រហម ដើម្បី បង្កើតរណសិរ្សតែមួយ ។ ប៉ុន្តែ ខ្មែរក្រហមបានប្រានចោលសំណើនេះទាំងស្រុង ។ ក្រោយមកទៀត នៅថ្ងៃ ៤ កញ្ញា ឆ្នាំ ១៩៨១ បន្ទាប់ពី មានសេចក្តីស្នើ ពីប្រទេសចិន នៅអង្គការ សហប្រជាជាតិ សុំឲ្យមាន ការបោះឆ្នោត ដោយសេរីនៅកម្ពុជា / នៅ សឹង្ហបុរី ឯនោះវិញ សម្តេច នរោត្តម សីហនុ, ខៀវ សំផន និង លោក សឺន សាន បានឯកភាពគ្នា បង្កើតរណសិរ្សចម្រុះមួយ។ នៅពេលនោះ កងទ័ពវៀតណាម ចំនួន ២០ ម៉ឺននាក់ បានត្រូវយកមកដាក់ប្រចាំការ ជា ស្រេចនៅតាមព្រំប្រទល់ថៃ ។ យ៉ាងណាមិញ ការប្រជែងកម្លាំងគ្នា រវាង ខ្មែរក្រហម បដិបក្ខ ទាំងពីរក្រុម គឺក្រុមមួយ មានសហរដ្ឋ អាមេរិក ជាបង្អែក ហើយក្រុមមួយទៀត មាន សហភាព សូវៀត គាំទ្រ ជាសង្គ្រាមមួយ ដ៏សាហាវ បំផុត។ ការរីករាលដាល នៃ បដិវត្តន៍កុម្មុយនិស្ត សូវៀត នៅក្នុងតំបន់ មិនអាចឲ្យអាមេរិក ជាពិសេស ចិន អត់ឱនឲ្យបានឡើយ។ ប៉ុន្តែ ដូចជា សព្វដង ដូច្នេះដែរ កាលណាចិន និង វៀតណាម ទាស់ទែងគ្នា ខ្មែរយើងត្រូវតែ បែកចេញជាពីរក្រុមដូច្នេះ ជាកំហិត។

# អំពី ក្រុមសាមគ្គី បង្កបង្កើតផល ប្រភេទ ទី ៣

## Le groupe de solidarité de production agricole type 3

បន្ទាប់ពីចេញផុតពីរបប ប៉ុល ពត នៅដើមឆ្នាំ ១៩៧៩ ប្រជាជនខ្មែរត្រូវរៀបចំ ជីវភាពរបស់គេឡើងវិញ ។ ប៉ុន្តែនៅគ្រាដំបូង គេស្ថិតនៅក្នុងស្ថានភាព ខ្វះចំណីអាហារ ថ្នាំសង្កូវ បន្តមកទៀត។ ដោយបានជំនួយខ្លះៗ ពីអង្គការ មនុស្សធម៌ផង ពី សហភាព សូវៀត ពីវៀតណាម ផង កសិករខ្មែរ បានវិលត្រឡប់មករកដីធ្លី ពីពេលមុន របស់គេ ហើយ បានខិតខំរៀបចំ ស្រែចម្ការ របស់គេឡើងវិញ តាមបែបបទដូនតា។ ប៉ុន្តែ បញ្ហា ដែលចោទឡើងនៅពេលនោះ មិនមែនជា បញ្ហាកម្មសិទ្ធ ដីធ្លី អ្វីទេ គឺ បញ្ហាខ្វះសម្ភារ សម្រាប់បង្កបង្កើតផល។ រីឯមនុស្សប្រុសដែលនៅសេសសល់ពីស្លាប់ក្រោមរបប ប៉ុល ពត ក៏មានចំនួនតិច ក្រៃលែង ។ ដូច្នេះឃើញថា កម្លាំងផលិតកម្ម សុទ្ធសឹងជាស្ត្រី មេម៉ាយ ។ ដោយសង្គមខ្មែរយើងតាំងពីដើមមក ជាសង្គម មាតាធិបតេយ្យស្រាប់ ហើយ ដោយ នារីធ្លាប់ជាអ្នកដឹកនាំផ្ទះសម្បែង សេដ្ឋកិច្ចគ្រួសារតាំងពីសម័យអង្គរមក ការរៀប ចំ ផលិតកម្មផ្សេងៗ ក៏ចេះតែមាន ដំណើរការ ជាសន្សឹមៗ ។ ដើម្បីដោះស្រាយ បញ្ហា ខ្វះ សម្ភារសម្រាប់ បង្កបង្កើតកសិផល រដ្ឋអំណាចថ្មី បានបង្កើត អង្គភាពផលិតកម្ម បី បែប ដែលគេឲ្យឈ្មោះថា «ក្រុមសាមគ្គីបង្កបង្កើតផល»។ ដោយរបបថ្មីនេះ ជារបប កុម្មុយនិស្ត គេត្រូវលុបបំបាត់ របបកម្មសិទ្ធឯកជនជាបណ្ដើរៗនៅពេលដែលការកកើត ឡើងវិញ នៃ កម្មសិទ្ធិឯកជន ចាប់ផ្ដើមមានសន្ទុះសាជាថ្មី ។ នៅពេលដំបូង គេរក្សាទុក របៀប សេរីនិយមសិន ពោលគឺ ក្រុមសាមគ្គីប្រភេទទី ៣ ។ តាមបែបបទនេះ គេចែក ដី ឲ្យក្រុមគ្រួសារនីមួយៗ រៀបចំ បង្កបង្កើតផល និយាយឲ្យចំ គឺធ្វើស្រែ ។ ឧបករណ៍ សម្រាប់ធ្វើស្រែ ត្រូវយកមកដាក់រួម ដើម្បីចែកគ្នាប្រើប្រាស់ រីឯ ផលស្រូវ ត្រូវចែក តាមគ្រួសារ នីមួយៗ។ គ្រួសារនីមួយៗ ត្រូវទុកស្រូវមួយភាគ សម្រាប់លក់ឲ្យរដ្ឋ ។ បញ្ហាដែលចោទ នៅពេលនោះ គឺ រដ្ឋទិញស្រូវប្រជាជន ដោយឲ្យ តម្លៃថោកពេក ជា





ហេតុធ្វើឲ្យជីវភាព របស់គេ នៅតែដុនដាប ដដែលទោះបី កម្រិតទុរ្ភិក្សបានចុះថយបន្តិច ម្ដងៗ មកវិញក្ដី។ គ្រួសារណា ដែលមានស្រូវពុំគ្រប់គ្រាន់ សម្រាប់លក់ឲ្យរដ្ឋ ត្រូវគេ ចោទប្រកាន់ថា លួចលក់ស្រូវឲ្យខ្មាំង ពោលគឺ ពួកខ្មែរក្រហមម្ខាងទៀត ។ នៅក្នុង ករណីបែបនេះ គេពុំអាចទិញសម្លៀកបំពាក់ ឬ ក៏របស់ប្រើប្រាស់សព្វសារពើ ពីរដ្ឋ ដោយតម្លៃថោកបានទេ។ នៅក្នុងតំបន់ខ្លះម្នាក់ៗ រក្សាបានត្រឹម១៥០ គីឡូក្រោមប៉ុណ្ណោះ។ នៅក្នុងតំបន់ខ្លះទៀត ដែលពួកខ្មែរក្រហមខាង ប៉ុល ពត បានលួចចូលមកបង្កប់ខ្លួន អាជ្ញាធរ រឹបអូស យក ស្រូវ អង្ករ សឹងតែទាំងអស់ គឺទុកឲ្យតែបន្តិចបន្តួច ប៉ុណ្ណោះ ជាហេតុធ្វើឲ្យប្រជាជន មានការក្ដៅក្រហាយយ៉ាងខ្លាំង។ គេនាំគ្នាយកពាក្យប្រជាប្រិយ ខ្មែរមួយ កាលពីជំនាន់ អាណានិគមបារាំង មកនិយាយតៗគ្នា ដូច្នេះថា ៖ «ចុះទឹកក្រពើ ឡើងលើខ្លា ចូលព្រៃបន្លា ចូលផ្សារប៉ូលីស» ។ តាំងពីជំនាន់ណាមក ប្រជាជនខ្មែរ មានបញ្ហាជានិច្ច ជាមួយ ប្រព័ន្ធគ្រប់គ្រង។

ទោះបីបែបផែនផលិតកម្ម ក្រុមសាមគ្គីប្រភេទទី ៣ នេះ មានបញ្ហាបែបនេះក្ដី ក៏ តាមការពិត វាបានដោះស្រាយ បញ្ហាជីវភាព បានមួយកម្រិតតូចដែរ ព្រោះគេទទួល ផល តាមសមាមាត្រ ។ រីឯស្រូវអង្ករ ដែលលក់ឲ្យរដ្ឋជាទូទៅ គឺ សម្រាប់យកទៅ កសាង និងការពារប្រទេស ព្រោះសង្គ្រាមនៅតែមានបន្តជានិច្ច ទន្ទឹមគ្នា នឹងការកកើត ឡើង នៃ ការិយាធិបតេយ្យ ដ៏តូចមួយ។ នៅពេលនោះ បែបផែនផលិតកម្មប្រភេទ ទី ៣ នេះ ក៏ជា ការអនុគ្រោះមួយផងដែរ នៅក្នុងន័យថា របបហេង សំរិន ជា របប កុម្មុយនិស្ត ពោលគឺ របបសមូហភាពនិយម ដែលចូលចិត្តធ្វើការ សស្រាក់សស្រាំ ហើយ ដែលសម្រេចសម្រួចទៅ គ្រួសារនីមួយៗ រកអង្ករមួយកំប៉ុង ប្រកឆ្នាំងមិនបាន ផង គឺដូចពាក្យ ចាស់បុរាណ ខ្មែរតែងពោលថា «គ្នាច្រើនអន្សមខ្លោច គ្នាដូចស្រមោច អន្សមឆៅ»។ ទោះបីអ្នកដឹកនាំខ្មែរកាលជំនាន់នោះ យល់យ៉ាងដូច្នេះក្ដី ក៏គេត្រូវសម្រប ជាប់ខាត តាម របបកុម្មុយនិស្ត ជាធរមានដែរ បើពុំនោះសោតទេ នឹង ត្រូវគេបញ្ជូន ទៅរៀនសូត្រ នៅហាណូយ បែកកូន បែកចៅ បែកស្រុកបែកទេស ជាពុំខាន។ ចំពោះ លទ្ធិកុម្មុនិស្ត គេយល់ថា កម្មសិទ្ធឯកជន ជាកត្តា នៃ ការជិះជាន់សង្កត់សង្កិន វណ្ណៈ

អធន ជាការប្រឆាំង នឹងសមភាព សង្គម គឺ ថា បើក្រ ត្រូវក្រ ទាំងអស់គ្នា បើមាន ត្រូវមានទាំងអស់គ្នា។ បើរៀនពុំចេះទេ គឺបើក្លាយទៅជា ជនកុម្មុយនិស្ត ឬ អ្នកសមូហភាពនិយម មិនបានទេ គ្មានថ្ងៃណាគេបានវិលត្រឡប់មកស្រុកវិញ បានឡើយ។ គោលដៅ របស់ ពួកកុម្មុយនិស្ត នៅពេលនោះ គឺ ធ្វើយ៉ាងណា ដើម្បីពង្រឹងក្រុមសាមគ្គី ប្រភេទ ទី ២ បន្ទាប់មក ក្រុមសាមគ្គី ប្រភេទ ទី ១ តែម្តង ពោលគឺ ក្រុមផលិតកម្មសមូហភាព ទាំងស្រុង។

## អំពី ក្រុមបង្កបង្កើតផល ប្រភេទ ទី ២ និង ប្រភេទ ទី ១

## Les groupes de solidarité de production agricole type 2 et type 1

ក្រុមសាមគ្គី បង្កបង្កើតផល ប្រភេទ ទី ៣ ជាបែបផែន ផលិតកម្ម ដែលប្រជាជនខ្មែរចូលចិត្តជាងគេ ព្រោះ បានទទួល ចំណែក ផលស្រូវ តាមសមាមត្រ នៃ ការងារ របស់គេ។ ប៉ុន្តែ បែបផែនផលិតកម្មនេះ បានត្រូវ បក្សកុម្មុយនិស្តខ្មែរ នៅពេលនោះ រិះគន់យ៉ាងខ្លាំង ដោយគេចាត់ទុកថាជាពន្លក នៃលទ្ធិមូលធននិយម។ នៅក្នុងវគ្គសិក្សា នយោបាយ នានា កម្មាភិបាល ឃុំ-សង្កាត់ តែងតែទទួលការស្តីបន្ទោស ជារឿយៗ ព្រោះ គេពុំបានខិតខំ បង្កលក្ខណៈប្រែក្លាយ ក្រុមប្រភេទ ទី ៣ នេះ ឲ្យទៅជា ក្រុមប្រភេទ ទី ២ និង ទី ១ ដែលនាំទៅរក របបកុម្មុយនិស្ត។ នៅឆ្នាំ ១៩៧៩ ក្រុមសាមគ្គី បង្កបង្កើតផល ប្រភេទទី ៣ មានចំនួន ៧០ ភាគរយ ។ ប៉ុន្តែ ដោយមាន ការគាបសង្កត់ពី បក្សកុម្មុយនិស្ត ចំនួន នៃបែបផែនផលិតកម្មនេះ បានចុះថយជាលំដាប់ ។ នៅឆ្នាំ ១៩៨០ គេឃើញមាន នៅសល់តែ ៣៥ ភាគរយប៉ុណ្ណោះ ហើយ ៦ ឆ្នាំក្រោយមក បានចុះមកដល់ ១០ ភាគ រយតែម្តង។ នៅឆ្នាំ ១៩៨៦ ក្រុមសាមគ្គីប្រភេទ ទី ២ បានកើន មកដល់ ៦០ ភាគរយ។ តាមបែបផែន ទី ២ នេះ ដីស្រែ និង ឧបករណ៍



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ផលិតកម្ម ជា របស់សមូហភាព ប៉ុន្តែ គ្រួសារនីមួយៗ មានដីស្រែរបស់គេ ហើយ ទទួលផលដោយ ការងារ របស់ខ្លួន ។ អ្នកដែលមាន គោ ក្របី ពីពេលមុន អាចរក្សាទុកកម្មសិទ្ធិ របស់គេ បន្តមកទៀត ប៉ុន្តែ ត្រូវឲ្យគេខ្ចី ឧបករណ៍ទាំងនោះ នៅក្នុងករណីដែលមាន ការងាររួម ។ តែនេះគ្រាន់តែ ជាសភាពការណ៍ ចំពោះមុខតែប៉ុណ្ណោះ ព្រោះច្បាប់ជា គោលការណ៍បញ្ជាក់ថា ដីស្រែ ក្តី គោ ក្របី ក្តី នង្គ័ល ក្តី គឺសុទ្ធតែជាកម្មសិទ្ធិ របស់ប្រជាជន ទាំងអស់ គឺ មានន័យថា គ្មានកម្មសិទ្ធិឯកជនទេ ។ នៅឆ្នាំ ១៩៨២ ក្រុមសាមគ្គីប្រភេទទី ១ ដែលជាគំរូ បែបផែនផលិតកម្ម តាមលទ្ធិកុម្មុយនិស្ត មានចំនួនប្រមាណ ពី ៣០ ទៅ ៣៨ ភាគរយ ។ បើគិត ពីផលិតផល គឺមានចំនួនតិចណាស់ បើប្រៀបធៀប នឹង ក្រុមប្រភេទទី ៣ និង ប្រភេទទី ២ ។ តាមបែបផែន ផលិតកម្មនេះ គឺ រដ្ឋ ជាអ្នកក្តាប់ផលិតកម្មទាំងអស់ គឺទាំងកម្លាំងផលិតកម្ម ទាំង ឧបករណ៍ ផលិតកម្ម។ កសិករម្នាក់ៗ ទទួលពីរដ្ឋមកវិញ នូវរបប របស់ ខ្លួន ដែលគេបែងចែកទៅតាមកម្លាំងផលិតកម្ម ដែលមានទាំងអស់ បីប្រភេទ គឺ ប្រភេទ ទី ១ មនុស្សដែលមានអាយុ ពី ១៨ ទៅ ៥៥ ឆ្នាំ ។ ប្រភេទ ទី២ គឺ អ្នកដែលមានអាយុ ពី ១២ ទៅ ១៨ ឆ្នាំ ។ ប្រភេទទី ៣ កុមារ ដែលមាន អាយុ តិចជាង ១២ ឆ្នាំ ។ ក្រុម សាមគ្គីប្រភេទ ទី ១ នេះ ពុំមានលក្ខណៈខុសពី ជំនាន់ ប៉ុល ពត ប៉ុន្មានទេ។ គឺ នៅក្នុងន័យនេះហើយ ដែលនៅពេលនោះ អ្នកដឹកនាំខ្មែរ ចាប់ផ្តើមមាន ការរារែក ជាអតិបរមា ។ រីឯបញ្ហាដែលចោទ គឺថា តើសុខចិត្តឲ្យផលិតកម្មស្រូវ ចុះថយ ឬ ក៏បោះបង់បែបផែន ផលិតកម្មកុម្មុយនិស្តចោលវិញ។ គឺនៅត្រង់ចំណុចនេះហើយ ដែលមានការខ្វែងគំនិតគ្នា មួយយ៉ាងធំ រវាង អ្នកដឹកនាំខ្មែរ និង អ្នកជំនាញការ វៀតណាម ។ ការមិនចុះសម្រុងគ្នា ស្តីពីការពង្រឹង ឬការលុបចោល នៃ ក្រុមសាមគ្គីប្រភេទទី ១ នេះ បាននាំមក នូវ វិបត្តិ មួយ ដ៏ធំ នៅក្នុងជួរថ្នាក់ដឹកនាំ និង នៅតាមមូលដ្ឋានផលិតកម្ម។ ប៉ុន្តែនៅទីបំផុត គេក៏បានបណ្តោយ ទៅតាមដំណើរ របស់ វាសិន ពោលគឺ ទ្រឹស្តីផ្សេង ការអនុវត្តន៍ផ្សេង។ បន្ទាប់ពី ការតស៊ូមតិគ្នា អស់មួយរយៈពេល ក្រុមសាមគ្គីប្រភេទ ទី ១ បានត្រូវពង្រឹងឡើងវិញ ដោយមាន ការចុះផ្សាយ នូវ ស្ថិតិ ដែលបញ្ជាក់ថា ក្រុមសាមគ្គី ទី ១

បានទទួលផលច្រើនជាងគេ ។ ប៉ុន្តែ គឺនៅពេលនោះហើយ ដែលប្រជាជនខ្មែរ នាំគ្នារត់ទៅប្រទេសថៃ យ៉ាងសន្ធឹកសន្ធាប់ ជាហេតុធ្វើឲ្យ ខ្មែរក្រហម ខាងប៉ុល ពត បានឱកាស កេណ្ឌ ប្រជាជនខ្មែរទាំងនោះ ទៅឲ្យវាយខ្មែរម្ខាងទៀត។ ការស្រាវជ្រាវរកតួលេខពិតប្រាកដសត្យា នុម័ត អំពី ផលិតផលស្រូវ នៅពេលនោះ ជាការពិបាកក្រៃលែង ។ អ្វីដែលគេបានដឹងតាម រយៈរបាយការណ៍នានា គឺថា ១ ឆ្នាំក្រោយរបប ប៉ុល ពត ផលស្រូវ មិនបានមួយលាន តោនផង តែពេលនោះ ប្រជាជន មានចំនួនប្រមាណ ៥ លាន នាក់ ប៉ុណ្ណោះ។ នៅឆ្នាំ ១៩៨១ ១៩៨២ និង ១៩៨៣ ផលិតកម្ម ស្រូវបានកើន ១ ជា ២ គឺ ស្ថិតនៅក្នុងកម្រិត ១ លាន ៨ សែនតោន ។ ទោះជាយ៉ាងនេះក្តី ក៏ប្រជាជនខ្មែរទូទាំងប្រទេសពុំមានជីវភាពធូរធារ នៅឡើយដែរ ព្រោះ សង្គ្រាមត្រូវបន្ត ទៅទៀត ហើយការរៀបចំរដ្ឋបាល និង ការជួសជុល ហេដ្ឋារចនាសម្ព័ន្ធ ជួប នឹង ការខ្វះខាតគ្រប់បែបយ៉ាង ជាពិសេសការកសាង មូលដ្ឋានឧស្សាហកម្ម ។ ខាងផ្នែកអប់រំជាតិ ការខ្វះខាត មានទំហំមួយ ដ៏ធំមហិមា ៖ ណាមួយ កេរដំណែល ដ៏អាក្រក់ ដែលរបបខ្មែរក្រហមបានបន្សល់ទុកឲ្យ ពិបាកនឹងលុបបំបាត់ក្រៃលែង ណាមួយអ្នកចេះដឹងក៏មានចំនួនតិច ណាមួយ កម្មវិធីសិក្សា មិនស្រប ទៅ នឹង សភាពការណ៍ ។

## បរិបទ អន្តរជាតិ នៃ សង្គ្រាម នៅក្នុង ប្រទេស កម្ពុជា រវាង ឆ្នាំ ១៩៧៩-១៩៨៩

## Contexte international de la guerre au Cambodge entre 1979 et 1989

សង្គ្រាមដែលកើតមានឡើង នៅកម្ពុជា ពីឆ្នាំ ១៩៧៩ មកទល់ នឹងពេលចុះហត្ថលេខា ទៅលើកិច្ចព្រមព្រៀង ទីក្រុងប៉ារីស៍ឆ្នាំ ១៩៩១ ពុំមែនត្រឹមតែជាសង្គ្រាម រវាង របប ហេង សំរិន គាំទ្រ ដោយវៀតណាម និង ចលនាតស៊ូខ្មែរប៉ុណ្ណោះទេ តែជាសង្គ្រាម រវាងសហភាព សូវៀត និងសហរដ្ឋ អាមេរិក តាមរយៈការប្រជែងកម្លាំង





រវាង ចិន និង វៀតណាមនៅក្នុងតំបន់ផងដែរ។ ការវាយរំលំរបបខ្មែរក្រហមនៅថ្ងៃ ៧ មករាឆ្នាំ ១៩៧៩ ជា បរាជ័យមួយយ៉ាងធំ របស់ចិនកុម្មុយនិស្ត ដែលគាំទ្ររបបខ្មែរក្រហម។ ប៉ុន្តែ ការវាត ទឹកដី របស់ វៀតណាម និង សហភាព សូវៀត មកក្នុងទឹកដីខ្មែរ បានធ្វើឲ្យបណ្តាប្រទេស នៃ សមាគមអាស៊ាន ជាពិសេស ប្រទេសថៃ មានការភិតភ័យយ៉ាងខ្លាំង ព្រោះសង្គ្រាម អាចរាលដាល ចូលក្នុងប្រទេស របស់គេ ផងដែរ។ ចំពោះសហរដ្ឋ អាមេរិក ការគំរាម កំហែង របស់ សហភាព សូវៀត និង វៀតណាម ដែលបានចាប់ផ្តើមចេញរូបរាង សាជាថ្មីទៀត នៅឆ្នាំ ១៩៧៩ នៅក្នុង តំបន់ អាស៊ីអាគ្នេយ៍ ក៏អាចនឹងធ្វើឲ្យ សហរដ្ឋអាមេរិក បាត់បង់ឥទ្ធិពលរបស់គេនៅក្នុងតំបន់ដែរ ។ គឺ នៅពេលនោះហើយ ដែលទីក្រុងវ៉ាស៊ីងតោន ខិតខំពង្រឹង កតិកាសញ្ញាទីក្រុងម៉ានិលឡើងវិញ គឺ កតិកាសញ្ញាដែលដើរតួ បន្តពីកតិកា សញ្ញាអូតាស្ហ៍[១៥] ។ នៅ ខែ មិថុនា ឆ្នាំ ១៩៨០ សហរដ្ឋ អាមេរិក បានបញ្ជូនសព្វាវុធ យ៉ាងក្រាស់ក្រែល មកឲ្យប្រទេសជាសម្ព័ន្ធមិត្ត របស់គេ នៅក្នុងតំបន់ អាស៊ីអាគ្នេយ៍។ នៅចំពោះមុខ សភាពការណ៍នោះ ប្រទេសថៃ មានកង្វល់យ៉ាងខ្លាំង ដោយហេតុថា សហរដ្ឋ អាមេរិក មិនអាច ចុះមកប្រយុទ្ធដោយផ្ទាល់បានទេ។ មួយវិញទៀត បើប្រទេសថៃ សុខចិត្តធ្វើសហការ ជាមួយ អាមេរិក និង ចិន គឺ គេគេចពុំផុត ពីការប្រែក្លាយ ប្រទេសថៃ ឲ្យទៅជាសមរភូមិបានឡើយ។ យ៉ាងណាមិញសង្គ្រាមនេះ ជាសង្គ្រាម តទល់ នឹង សហភាព សូវៀត យ៉ាងជាក់ស្តែង ។ បើ សហរដ្ឋ អាមេរិក ចាញ់ សូវៀត នៅវៀតណាមទៅហើយនោះ សង្គ្រាមម្តងនេះ ក៏ មិនដឹងជា មានដំណើរ បែបណាដែរ ។ ប៉ុន្តែ បើ មិនទប់ទល់ នឹង

---

[១៥] កតិកាសញ្ញា អុតាស្ហ៍ ( O.T.A.S.E. ) ឬ អង្គការ កតិកាសញ្ញប្រទេសអាស៊ីអាគ្នេយ៍ បានត្រូវចុះហត្ថលេខានៅឆ្នាំ ១៩៥៤ នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន តាមការផ្តួចផ្តើមគំនិត របស់ សហរដ្ឋ អាមេរិក។ កតិកាសញ្ញានេះ ត្រូវលុបចោលវិញ នៅឆ្នាំ ១៩៧៧ ។

វៀតណាម ដែលមាន សូវៀត នៅពីក្រោយទេនោះ លទ្ធិកុម្មុយនិស្ត ក៏នឹង អាច រាលដាលចូលមកក្នុងភូមិភាគ ទាំងមូលដែរ ។ នៅទីបំផុត ដោយខ្លាចអាមេរិក យកប្រទេសខ្លួនធ្វើជារណប ដូចកាលពី ពេលក្រោយសង្គ្រាមលោក ដែលសហរដ្ឋ អាមេរិក បានបញ្ជូនកងទ័ព មកក្នុងប្រទេសគេ ទីក្រុងបាងកក ក៏ សម្រេច ចងសម្ព័ន្ធភាព ជាមួយចិន តែម្តងទៅ ។

ទោះបី ទីក្រុងបាងកកខិតខំពន្យល់ ប្រទេសជា សមាជិកសមាគមអាស៊ាននានា ថា សម្ព័ន្ធភាព ជាមួយចិន ជាកំផែងមួយសម្រាប់ការពារ តទល់ នឹង ការពង្រីកវាតទឹកដី របស់ វៀតណាម និង សូវៀតក្តី ក៏ នៅពេលនោះ ប្រទេសជាសមាជិកសមាគមអាស៊ាន មួយចំនួន ដូចជាប្រទេស ម៉ាឡាយូ និង ឥណ្ឌូណេស៊ីជាដើម គេនៅតែយល់ថា ចិន ដែលជាសម្ព័ន្ធមិត្ត របស់ អាមេរិក នៅក្នុងការប្រជែងកម្លាំងនេះ ក៏ជាគ្រោះថ្នាក់មួយចំពោះ ប្រទេសគេដែរ ។ មិនតែប៉ុណ្ណោះសោត គេយល់ថា សហភាពសូវៀត ជាកម្លាំងមួយសម្រាប់ទប់ទល់ នឹង ការវាតទឹកដី ជា យថាហេតុ របស់ចិន ទៅវិញ ។ ខាង សឹង្ហបុរី និង ប្រទេសថៃ គេជឿថា គ្រោះថ្នាក់ធំ ចំពោះ បណ្តាប្រទេសសមាគម ប្រជាជាតិ អាស៊ីអាគ្នេយ៍ ហៅកាត់ថា អាស៊ាន គឺ សហភាព សូវៀត តែម្តង។ ទោះជាមាន ការខ្វែងគំនិតគ្នាយ៉ាងនេះក្តី ក៏ចាប់តាំងពីឆ្នាំ ១៩៧៩ នោះមក ចិន សហរដ្ឋ អាមេរិក សឹង្ហបុរី និង ប្រទេសថៃ បាននាំគ្នាខិតខំជួយជ្រោមជ្រែង កម្លាំងតស៊ូខ្មែរ ដើម្បីដេញកងទ័ពវៀតណាម ចេញពីស្រុកខ្មែរ យ៉ាងសកម្មដែរ។ ប៉ុន្តែនៅក្នុងបរិបទ នៃ សង្គ្រាមនៅក្នុងប្រទេសកម្ពុជា កងទ័ពខ្មែរក្រហម ដឹកនាំដោយ ប៉ុល ពត មានតួនាទីសំខាន់ជាងគេ ជាហេតុធ្វើឲ្យ មតិ អន្តរជាតិ មានការអល់អែក ព្រោះនៅពេលនោះ គេបានដឹងយ៉ាងច្បាស់ថា របប ប៉ុល ពត ជារបបប្រល័យពូជសាសន៍ឯង។ ដើម្បីគ្របដណ្តប់ចំណុចខ្សោយនេះ គេបានបង្កើត ចលនាផ្សេងៗទៀត ដើម្បីធ្ចុះបញ្ចាំងឲ្យឃើញថា កងទ័ព របស់ ប៉ុល ពត គ្រាន់តែជា ចំណែកមួយប៉ុណ្ណោះ ។ ប៉ុន្តែកងទ័ពវៀតណាម ដែលស្ថិតនៅលើទឹកដីខ្មែរ មានជំនួយ ដ៏សន្ធឹកសន្ធាប់ ព្រោះ សហភាព សូវៀត ចាយប្រាក់យ៉ាងច្រើនដើម្បីទប់ទល់ នឹង ចលនា តស៊ូខ្មែរគាំទ្រដោយ





ប្រទេសចិន។ យុទ្ធសាស្រ្តដែលចិន និង អាមេរិក ប្រើនៅពេលនោះ គឺ ឯកោ ប្រទេសវៀតណាម តាមរយៈការផ្តាច់ទំនាក់ទំនងសេដ្ឋកិច្ច ។ ទោះបី ប្រទេសវៀតណាម មានសហភាព សូវៀត ជាបង្អែកក្តី ក៏គេត្រូវបាត់បង់ជំនួយ ដ៏ សន្ធឹកសន្ធាប់ ពីសំណាក់អតីតសម្ព័ន្ធមិត្ត ចិន របស់គេដែរ។

# ស្ថានភាព ប្រទេស កម្ពុជា នៅ ឆ្នាំ ១៩៨២

## Situation politique du Cambodge en 1982

បន្ទាប់ពី លោក ប៉ែន សុវណ្ណ បានត្រូវចាប់បញ្ជូន យកទៅដាក់ឃុំឃាំង នៅប្រទេសវៀតណាមនៅចុងឆ្នាំ ១៩៨១ បាត់ទៅ របប សាធារណរដ្ឋ ប្រជាមានិតុ កម្ពុជាត្រូវរៀបចំចាត់តាំងអ្នកដឹកនាំថ្មី ។ បញ្ហាដែលគេចោទសួរ នៅពេលនោះ គឺ ថាហេតុដូចម្តេចបានជា ទីក្រុងហាណូយសុខចិត្ត ឲ្យគេដកមនុស្សម្នាក់ដែលធ្លាប់បានទទួលការហ្វឹកហ្វឺន និង ការបំពាក់បំប៉ន មនោគមវិជ្ជា ជាច្រើនឆ្នាំ នៅប្រទេសវៀតណាមកុម្មុយនិស្តហើយដែលនៅឆ្នាំ ១៩៧៩-១៩៨០ ជាមនុស្សខ្លាំង នៃ របបថ្មីទៀតផងនោះ ? តាមការពិត គឺ ទីក្រុងហាណូយតែម្តង ដែលបានសម្រេចដកហូត លោក ប៉ែន សុវណ្ណ ចេញពីមុខនាទីនាយករដ្ឋមន្រ្តី និងជាលេខាបក្សប្រជាជនបដិវត្តកម្ពុជា។ ចំពោះទីក្រុងហាណូយលោក ប៉ែន សុវណ្ណ ដែលស្គាល់នយោបាយ វៀតណាមយ៉ាងច្បាស់ បានក្លាយទៅជាអ្នក ដឹកនាំខ្មែរម្នាក់ប្រកបទៅដោយគ្រោះថ្នាក់។ គេអាចនិយាយបានថា ខ្មែរវៀតមិញនៅពេល ក្តាប់អំណាចបានហើយ ពុំចង់រណបខ្លាំងហួសហេតុពេក នឹង បក្សកុម្មុយនិស្តវៀតណាម បន្តទៅទៀតឡើយ។ ទីក្រុងហាណូយ ដែលធ្លាប់មានបទពិសោធន៍ ជូរចត់ជាមួយ ប៉ុល ពត ម្តងរួចមកហើយ មិនចង់ឲ្យរឿងបែបនេះ កើតឡើងម្តងទៀតទេ។ ជាការពិតហើយ ដែលថា ខាងខ្មែរក្រហម បូព៌ា គេហៀបតែ មានរឿងបែបនេះ មុន

លោក ប៉ែន សុវណ្ណ ទៅទៀត កាលពីជាង១ ឆ្នាំមុន គឺពេលដែលកងទ័ពវៀតណាម ចូលទៅដល់ ទីក្រុងភ្នំពេញ នៅខែមករាឆ្នាំ ១៩៧៩។ លោកជា ស៊ីម ត្រូវដកចេញ ពី ក្រសួងមហាផ្ទៃ នៅឆ្នាំ ១៩៨១ ព្រោះ បានត្រូវទីក្រុងហាណូយ សង្ស័យថា បានបង្កប់ កម្លាំងលួចវាយឆ្មក់ កងទ័ពវៀតណាមជារឿយៗ ។ ការដាក់ ប៉ែន សុវណ្ណ ជា នាយក រដ្ឋមន្ត្រី ក៏ ពុំបានធ្វើឲ្យ «ក្រុមបូព៌ា» គឺ ខ្មែរក្រហមដែលបានបះបោរប្រឆាំង នឹង ប៉ុល ពត ទទួលយកបានដែរ ។ តាំងពីពេលដែល ប៉ុល ពត មានតួនាទីសំខាន់ ក្នុងជួរបក្ស ប្រជាជនបដិវត្តកម្ពុជា ទំនាស់ រវាង អ្នកបដិវត្តខ្មែរ និង អ្នកបដិវត្ត វៀតណាម ជា ទំនាស់មួយ ដ៏ធំៗ នៅឆ្នាំ ១៩៧៨ ខ្មែរក្រហម ភូមិភាគបូព៌ាម្នាក់ ឈ្មោះ អ៊ុក ប៊ុន ឈឿន បាននិយាយ ជាមួយវៀតណាម ទាមទារ ស្វ័យយភាព ឲ្យពួកខ្មែរក្រហម ប្រឆាំង នឹង ប៉ុល ពត គឺ មិនឲ្យវៀតណាម ជ្រៀតជ្រែក ក្នុងការបះបោរប្រឆាំង នឹង ប៉ុល ពតទេ ។ វៀតណាម មិនត្រឹមតែមិនព្រមប៉ុណ្ណោះទេ គឺ ថែមទាំងចាប់ អ៊ុក ប៊ុន ឈឿន យកទៅឲ្យរៀនសូត្រយ៉ាងយូរនៅ វៀតណាមផងទៀត។ រីឯ ប៉ែន សុវណ្ណ វិញ ទោះជា មានប្រវត្តិជាអ្នកតស៊ូ វៀតមិញក្តី ក៏ នៅពេលឡើងកាន់អំណាច លោកចង់ ផ្តាច់ខ្លួនចេញពីឥទ្ធិពល របស់វៀតណាមដែរ។ នៅ ថ្ងៃ ១២ តុលា ឆ្នាំ ១៩៧៩ លោក ប៉ែន សុវណ្ណ ទៅជួបលោក ប្រេសណេហ្វ នៅទីក្រុងម៉ូស្គូ ក្នុងគោលដៅរក បង្អែកពី សហភាព សូវៀត ផ្ទាល់តែម្តង ជាហេតុធ្វើឲ្យ ទីក្រុងហាណូយ ដែលមាន ការបត់ បែនច្រើន ផ្នែកនយោបាយ មានការអាក់អន់ចិត្តយ៉ាងខ្លាំង ។ ដូច្នេះ ឃើញថា ទោះជា មានគោលដៅដូចគ្នាក្តី ក៏ ប៉ែន សុណ្ណ មានទំនាស់ ជាមួយក្រុមលោក ជា ស៊ីម ដែរ ព្រោះ ជាក្រុមបដិបក្ខគ្នា តាំងពីដើមមកផង ហើយ ជាការដណ្តើមអំណាច ដណ្តើម ការដឹកនាំប្រទេសផង។ នៅពេលនោះ ទីក្រុងហាណូយ មានការអល់អែក យ៉ាងខ្លាំង ព្រោះ មិនដឹង ត្រូវផ្តល់ការទុកចិត្ត ទៅឲ្យអ្នកណា ? ទៅឲ្យខ្មែរក្រហម ប្រឆាំង នឹង ប៉ុល ពត ឬ ទៅឲ្យអតីតយុទ្ធជនដែលធ្លាប់តស៊ូក្នុងជួរវៀតមិញម្នាក់ទៀត? តាមការពិត ទៅ ប៉ុន្តែជាការពិត ដែលពិបាកនឹងជឿ អ្នកដែលធ្លាប់រស់នៅយូរ នៅវៀតណាម ពុំសូវ មានការកោតស្ញែង វៀតណាមប៉ុន្មានទេ ។ ពួកគេមានជំនឿទៅលើមាគ៌ា យុទ្ធសាស្ត្រ



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

របស់វៀតណាម ប៉ុន្តែ គេ ក៏ចង់ផ្តាច់ខ្លួនចេញពីមហិច្ឆតា ពីការត្រួតត្រាបាត់បែង របស់ សម្ព័ន្ធមិត្តនេះ របស់គេដែរ ។ ពេលឡើងកាន់អំណាចភ្លាម ប៉ែន សុវណ្ណ តែងតាំងខ្លួន លោកជា អគ្គលេខាធិការបក្សតែម្តង។ គ្មានអ្នកណា ហ៊ានប្រឆាំងលោកទេ នៅពេល នោះ ព្រោះលោក បានបញ្ជាក់ប្រាប់ រួចជាស្រេចថា លោក បានចូលបដិវត្តន៍ តាំងពី អាយុ ១៤ ឆ្នាំ ដូច្នេះ លោកជាអ្នកបដិវត្តជើងចាស់ជាងគេ។ នៅចន្លោះឆ្នាំ ១៩៧៩ - ១៩៨១ លោក ប៉ែន សុវណ្ណ ខិតខំប្រមែប្រមូលបញ្ញវន្ត និង អ្នកឯកទេសខ្មែរចំណានៗ ដែលនៅសល់ ពីស្លាប់ក្រោម របប ប៉ុល ពត ឲ្យមករៀបចំ កសាងប្រទេស ទៅតាម របៀបមួយ ខុសពី ការដាក់ទិស របស់ ទីក្រុងហាណូយ និង របស់គណមជ្ឈិមបក្ស ។ នៅពេលនោះ លោក ហ៊ុន សែន ជាអ្នកជំនិតម្នាក់ របស់ លោក ប៉ែន សុវណ្ណ ក្នុង ចំណោមបញ្ញវន្ត សំខាន់ៗ ដែលមិនសូវយល់ស្របប៉ុន្មាន នឹង មាគ៌ា ដ៏រឹងត្អឹប របស់ បក្ស កុម្មុយនិស្តកម្ពុជា នៅពេលនោះ ដែលពុំទាន់បានប្តូរឈ្មោះមកជា « បក្សប្រជាជន បដិវត្តកម្ពុជា» នៅឡើយ ។ នៅចំពោះមុខ ឥរិយាបថនេះ របស់ ប៉ែន សុវណ្ណ ទីក្រុង ហាណូយក៏សម្រេចដក ប៉ែន សុវណ្ណ ចេញពីអំណាច ហើយដាក់អតីត អ្នកតស៊ូវៀត មិញម្នាក់ទៀត គឺ លោក ចាន់ ស៊ី ជំនួសវិញ ។ ទន្ទឹមនោះ អ្នកជំនាញការវៀត ណាម បានដាក់បញ្ញវន្ត របបចាស់ នៅសឹងតែ គ្រប់កន្លែងសំខាន់ៗ ជំនួស អ្នកតស៊ូ ជើងចាស់ ដើម្បីផ្តល់សន្ទុះមួយថ្មីទៀតទៅឲ្យបដិវត្តន៍។ តាមការពិត ប៉ែន សុវណ្ណ បាន ធ្វើកិច្ចការនេះ ជាងពាក់កណ្តាល រួចទៅហើយ។ ដូចនេះ បញ្ញវន្ត ទាំងនោះ នៅតែរក្សា ទស្សនៈ របស់ ប៉ែន សុវណ្ណ ដដែល។

នៅក្នុងសម័យប្រជុំរដ្ឋសភាលើកទី ២ ដែលបានប្រព្រឹត្តិទៅ ពីថ្ងៃ ៥ រហូត ដល់ ថ្ងៃ ១១ កុម្ភៈឆ្នាំ ១៩៨២ អ្នកតំណាងរាស្ត្រ បានធ្វើវិសោធនកម្ម សំខាន់ៗ ដើម្បី សម្រួល ដល់ ការបកស្រាយច្បាប់ និង ការអនុវត្តន៍ គោលការណ៍រដ្ឋធម្មនុញ្ញ។ គឺនៅ ក្នុងសម័យ ប្រជុំនោះហើយដែលលោក ចាន់ ស៊ី បានត្រូវតែងតាំងជាផ្លូវការជានាយក រដ្ឋមន្ត្រី ជំនួសលោក ប៉ែន សុវណ្ណ បន្ទាប់ពីបានទទួលភារកិច្ចនេះ តាំងពីចុងឆ្នាំ ១៩៨១ មក គឺ ក្រោយពេលដែល ប៉ែន សុវណ្ណ បានត្រូវគេដកហូតចេញ ពីមុខតំណែងនេះ

នៅថ្ងៃ ៤ ធ្នូ ឆ្នាំ ១៩៨១។ នៅ ឆ្នាំ ១៩៨២ នោះ អាជ្ញាធរសាធារណរដ្ឋ ប្រជាមានិតកម្ពុជា បានកត់សំគាល់ថា អត្រាកំណើតបានកើន ក្នុងកម្រិត ៥ ក្បៀស ៥ ភាគរយ រីឯ អត្រាលូតលាស់ ប្រជាជន គឺ ៥ ក្បៀស ២៤ ភាគរយ។ នៅទីសមរភូមិ ឯនោះវិញ ការប្រយុទ្ធ តទល់ នឹង កងទ័ពខ្មែរក្រហម ខាង ប៉ុល ពត កាន់តែពិបាកទៅៗជាលំដាប់ ទោះបីវៀតណាម បានដាក់កងទ័ព របស់គេជាច្រើនកន្លែងក្តី ជាពិសេស នៅតាមជាយដែន ខ្មែរ-ថៃ ។ នៅថ្ងៃ ២២ មិថុនា ឆ្នាំ ១៩៨២ ដដែលនោះ នៅទីក្រុងគូឡាឡុមពួរ ប្រទេសម៉ាឡេស៊ី បន្ទាប់ ពីបានទទួលការគាបសង្កត់ ពីសំណាក់ប្រទេសសមាគមអាស៊ាន អស់ជាច្រើនខែសមាសភាព អ្នកតស៊ូខ្មែរប្រឆាំង នឹង ការដាក់កងទ័ពវៀតណាម ក្នុងប្រទេសកម្ពុជា បានជួបប្រជុំគ្នា ដើម្បីចុះហត្ថលេខា យល់ព្រមគ្នាបង្កើតរដ្ឋាភិបាលចម្រុះមួយ មានឈ្មោះថា «រដ្ឋាភិបាលចម្រុះ កម្ពុជាប្រជាធិបតេយ្យ» (G. C. K.D.) ។ សមាសភាព នៃ រដ្ឋាភិបាលនេះ មានទាំងអស់ ៣ ក្រុម គឺ ក្រុមខ្មែរក្រហម ដឹកនាំដោយ ប៉ុល ពត ក្រុមអ្នក និយមសីហនុ និង «រណសិរ្សជាតិ រំដោះពលរដ្ឋខ្មែរ» ដឹកនាំដោយលោក សឺន សាន ។ ពួកខ្មែរក្រហម មានប្រៀប ជាងក្រុមនានា ព្រោះជា កម្លាំងធំជាងគេ នៅក្នុងរដ្ឋាភិបាល ចម្រុះនោះ ។ ក្រុមខ្មែរក្រហមនេះមានកងទ័ពចំនួន ៣ ម៉ឺន ៥ ពាន់នាក់ ខាង លោក សឺន សាន ៨ ពាន់ នាក់ ហើយខាង សម្តេច នរោត្តម សីហនុ មានតែ ៣ ពាន់ នាក់ ប៉ុណ្ណោះ។

## រដ្ឋាភិបាល លោក ចាន់ ស៊ី

### Le Gouvernement Chan Si

រដ្ឋាភិបាលលោក ចាន់ ស៊ី ដែលបានត្រូវតែងតាំងជំនួសរដ្ឋាភិបាល លោក ប៉ែន សុវណ្ណ តាំងពីខែធ្នូឆ្នាំ ១៩៨១មក ត្រូវប្រឈមមុខ នឹង បញ្ហា ដ៏ចម្រូងចម្រាស។ បញ្ហា ដែលសំខាន់ជាងគេនៅពេលនោះ គឺការប្រយុទ្ធទប់ទល់នឹងចលនាតស៊ូខ្មែររំដោះប្រទេស ចេញពី កងទ័ពវៀតណាម នៅលើ ទឹកដីខ្មែរផង និង ទំនាស់ផ្ទៃក្នុង



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ជាមួយ កម្លាំង គាបសង្កត់ របស់ អាណានិគមនិយម វៀតណាមផង ។ មិនថាឡើយតែលោក ប៉ែន សុវណ្ណទេ សូម្បីតែលោក ចាន់ ស៊ី ក៏មានការពិបាកដូចតែគ្នា ព្រោះនៅក្នុងករណីខ្លះ ការកំហិត របស់ វៀតណាម ពុំអាចធ្វើទៅបានឡើយ។ កិច្ចការដែលរដ្ឋាភិបាល របស់ លោក ចាន់ ស៊ី ត្រូវដោះស្រាយ មានលក្ខណៈស្មុគស្មាញ ជាទីបំផុត ដោយហេតុថា ទំនាស់ រវាង លោក ប៉ែន សុវណ្ណ និង ទីក្រុងហាណូយ ក៏នៅតែស្ថិតនៅជាទំនាស់ របស់លោក ចាន់ស៊ី បន្តមកទៀតដែរ នៅពេលដែលលោក ចាន់ស៊ី ឡើងមកកាន់ អំណាច ។ ឆ្លៀតឱកាស វត្តមាន នៃ កងទ័ពវៀតណាម នៅលើទឹកដីខ្មែរ ព្រមទាំង ការចាំ បាច់ត្រូវប្រយុទ្ធ នឹង កម្លាំងខ្មែរ ម្ខាងទៀត ដែលមានការគាំទ្រយ៉ាងមាំ ពីសំណាក់ សហគមន៍ អន្តរជាតិ ទីក្រុងហាណូយ បានបង្ខំអ្នកដឹកនាំខ្មែរ ឲ្យសម្រួលដល់ កិច្ចការអាណានិគមកិច្ច របស់គេ ។ អ្នកដឹកនាំខ្មែរទាំងអស់ ទោះជាក្រុមណា ក៏ដោយ រក្សាជានិច្ច នូវ ជំហរប្រឆាំង នឹង អាណានិគមកិច្ច របស់ វៀតណាម បើមិនច្រើន ក៏បន្តិចបន្តួចដែរ លើកចេញ តែខ្មែរមួយចំនួន ដែលរស់ ដោយការអែបអប ដើម្បីឆ្លៀតធ្វើជា អ្នកមានមុខមានមាត់ មានអំណាចបុណ្យសក្តិ និងជា សេដ្ឋីតែម្តងក៏អាចថាបាន ។ គឺនៅពេលនោះហើយ ដែល ចលនាតស៊ូផ្ទៃក្នុង ចេញរូបរាងឡើងទាំងនៅក្នុងជួរថ្នាក់ដឹកនាំ ទាំងនៅក្នុងជួរកម្មាភិបាល។ ការតស៊ូនេះ ពុំមានលក្ខណៈមាំទាំជាខ្សែបង្វាក់ ឬជាទ្រង់ទ្រាយធំអ្វីទេ ។ នៅទីបំផុត អ្នកប្រយុទ្ធផ្ទៃក្នុងមួយចំនួនធំ បានត្រូវវៀតណាមចាប់អស់ ជាបន្តបន្ទាប់ នៅក្នុងចំណោមនោះ មានអនុរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃម្នាក់ឈ្មោះ ម៉ី កោគ ផងដែរ។ ម៉ី កោគ ជាអតីត មេកងពល ០៩ នៃ អតីតកងទ័ពខ្មែរក្រហម ដែលមានរបៀបរស់នៅតាមបែបសក្តិភូមិមួយ ដ៏ ចម្លែក ។ ការតស៊ូនេះ ជាការឥតប្រយោជន៍ ព្រោះវៀតណាម កាន់កាប់ប្រទេសកម្ពុជាយ៉ាងណែន រួចស្រេចទៅហើយ។ ផុតពី លោក ប៉ែន សុវណ្ណ ដល់ វេន លោក ជា ស៊ីម វិញម្តងដែលនៅពេលនោះ នៅតែបន្តក្តាប់ កម្លាំងផ្ទៃក្នុង មួយភាគធំ ដដែល ទោះបី ទីក្រុងហាណូយ បានធ្វើអ្វី គ្រប់បែបយ៉ាង ដើម្បី ឯកោលោក ចេញពីកិច្ចការរដ្ឋាភិបាល និង ពីទីតាំង យុទ្ធសាស្ត្រសំខាន់ៗ ក្តី ។ នៅក្នុងរយៈកាលនោះ នៅក្នុងគ្រប់វគ្គសិក្សានយោ

បាយ សាស្ត្រាចារ្យ វៀតណាម តែងតែថ្កោលទោស ដោយប្រយោលដល់ អ្វីដែលគេហៅថា «រដ្ឋអំណាចមុខពីរ» ។ គឺនៅក្នុងបរិបទនេះហើយ ដែលលោក ចាន់ ស៊ី គ្រប់គ្រងប្រទេស ។ លោក ចាន់ ស៊ី ក៏ដូចជាលោក ប៉ែន សុវណ្ណ និង អ្នកដែលស្មោះត្រង់ នឹង លោក ប៉ែន សុវណ្ណ ដែរ ដូចជាលោក រស់ សាម៉យ និង លោក ឡាយ សាម៉ុន ជាដើម ដែលបានត្រូវដកហូត ពីមុខតំណែង ជាបន្តបន្ទាប់។

នៅក្នុងរដ្ឋាភិបាល លោក ចាន់ ស៊ី ព្រឹត្តិការណ៍ ដែលសំខាន់ជាងគេ គឺ ការកសាងកំផែង «ក ៥» ដើម្បីប្រយុទ្ធទប់ទល់ នឹង កងទ័ព តស៊ូខ្មែរ ជាពិសេស ពួកខ្មែរក្រហមខាង ប៉ុល ពត ។ កំផែងការពារនោះ ដែលអ្នកសង្កេតការណ៍ បរទេស ហៅថា «កំផែងឫស្សី» (Mur de bambou) ដែលចាប់ផ្តើមពីការកេណ្ឌប្រជាជនខ្មែរ គ្រប់ទិសទី ទាំងក្នុងចំណោមប្រជាជន ទាំងក្នុងចំណោមកម្មាភិបាល ឲ្យទៅលើកទំនប់ ជីកប្រឡាយ ធ្វើស្ពានថ្នល់ កាប់ព្រៃឈើ គឺ ធ្វើយ៉ាងណា កុំឲ្យកងទ័ពខ្មែរក្រហម អាចលាក់ខ្លួនបាន ពោលគឺធ្វើជា រនាំងទប់ទល់ នឹង កងទ័ពពួកខ្មែរក្រហម ប៉ុល ពត ដែលនៅពេលនោះ ធ្វើការវាយលុក យ៉ាងខ្លាំងចូលមកក្នុងប្រទេស។ ប្រជាជន នឹង អ្នកដឹកនាំរដ្ឋការ រាប់សែននាក់ បានបាត់បង់ជីវិត នៅក្នុងការកសាង ប្រព័ន្ធការពារយុទ្ធសាស្ត្រ ដ៏ធំនេះ។ នៅ តាមក្រសួងមន្ទីរ នានា អ្នករដ្ឋការ បានត្រូវបណ្ដាញរដ្ឋអំណាចវៀតណាម នៅកម្ពុជា បង្ខំឲ្យព្រាត់ប្រាសប្តីប្រពន្ធ កូនចៅ ចេញទៅការពារ កំផែងនេះ ជាកំហិត ។ អ្នករកស៊ីតាមផ្សារផ្សា ព្រមទាំងនិស្សិត ក៏គេចពុំផុត ពី កំណែននេះដែរ ។ គឺ ជាការប្រយុទ្ធ រវាង ខ្មែរ នឹង ខ្មែរ ដ៏សាហាវអស្ចារ្យ។ ម្ខាងការពារបដិវត្តន៍យួន និង សហភាព សូវៀត ហើយ ម្ខាងទៀត ការពារមហិច្ឆតាចិន បណ្ដាប្រទេសអាស៊ាន នឹង បស្ចិមលោក។ ក្រៅពីអ្នកដែលបានបាត់បង់ជីវិត នៅទីសមរភូមិ គេឃើញមាន អ្នកដែលបានវិលត្រឡប់មកភូមិ កំណើតវិញដែរ ប៉ុន្តែ ដោយនាំមក ជាមួយផង នូវ ជម្ងឺគ្រុនចាញ់ជាប់ នឹង ខ្លួន ហើយ មកស្លាប់នៅស្រុករបស់ គេ នៅចំពោះមុខ ឪពុកម្ដាយ បងប្អូន យ៉ាងវេទនា ពន់ពេកក្រៃ។ គេឃើញ និង ឮភ្លេង ពិធីបោះខ្មោច សឹងតែរាល់ថ្ងៃ នៅក្នុងទីក្រុង។ គឺ ជាទស្សនីយ ភាពគួរឲ្យសង្វេគ ពន់ពេកក្រៃ ។ គេនាំគ្នានិយាយនៅ





ពេលនោះថា «ផុតពី ចិនដល់យួន ផុតពីយួនដល់ចិន គ្មានថ្ងៃណាមួយអាចស្គាល់សុខបានឡើយ ។ ប្រសិនណាជា សង្គ្រាម ចេះតែបន្តទៅទៀតនោះ ខ្មែរ នឹង ផុតពូជតែម្ដង» ។ ការពិត គឺដូច្នេះមែន បើ សហភាព សូវៀត ពុំរលំរលាយទាន់ពេលទេនោះ ខ្មែរពិតជាផុតពូជ រលត់ជាតិអស់គ្មានសល់ ឡើយ។

## តម្រុយ នៃការប្រែប្រួល ស្ថានភាព នយោបាយ នៅ ឆ្នាំ ១៩៨៣

## Vers une nouvelle donne politique En Asie du sud-est en 1983

នៅថ្ងៃ ១២ មករា ឆ្នាំ ១៩៨៣ សម្ដេច នរោត្តម សីហនុ បានប្រកាសប្រាប់ ថា ដោយព្រះរាជសុខភាព របស់ ព្រះអង្គ ពុំសូវល្អ ព្រះអង្គ ត្រូវបង្ខំព្រះរាជហឫទ័យផ្អាក ព្រះរាជសកម្មភាព របស់ ព្រះអង្គជាច្រើនខែ។ នៅពេលនោះ គេសង្កេតឃើញថា ខ្មែរក្រហម បានក្លាយទៅជាកម្លាំង ដ៏ធំជាងគេ នៅក្នុង រណសិរ្សប្រឆាំ នឹងវត្តមាន កងទ័ពវៀតណាម នៅកម្ពុជា ។ នៅពេលដែលកងទ័ពវៀតណាម ចូលមកក្នុងប្រទេសខ្មែរ ប្រជាជនខ្មែរ ប្រមាណ ៤ ម៉ឺន ៥ ពាន់នាក់ បាននាំគ្នា រត់ទៅប្រទេសថៃ ។ នេះគ្រាន់តែនៅរវាងដើម និងពាក់កណ្ដាលឆ្នាំ ១៩៧៩ ប៉ុណ្ណោះ។ នៅពេលនោះ កងទ័ពថៃ បានធ្វើការរុញច្រាន ជនភៀសខ្លួនទាំងនោះមកក្នុងស្រុកវិញ ជាពិសេស នៅម្តុំព្រះវិហារ។ នៅពេលដែលពួកគេរត់បកក្រោយមកវិញ ខ្មែរចំនួន ប្រមាណ ១ ម៉ឺន នាក់ បានត្រូវបាត់បង់ជីវិត ដោយជាន់គ្រាប់មីន។ ទោះជាយ៉ាងនេះក្តី ក៏នៅចុងឆ្នាំ ១៩៧៩ ដដែលនោះ ប្រជាជនខ្មែរចំនួន ២០ ម៉ឺននាក់ បាននាំគ្នារត់បន្ថែមមកទៀត ដោយខ្លាចមានគ្រោះទុរ្ភិក្ស នៅក្នុងរបប កុម្មុយនិស្តថ្មី ផង និងដើម្បីគេច ពីកងទ័ពឈ្លានពានផង ។ មួយវិញទៀត អ្នកដែលខ្លាចរបប កុម្មុយ និស្ត បានដឹងតាមវិទ្យុថា គឺ មិនមែនលោកសេរី ឯណាដែល មករំដោះពួកគេ ពី របប ប៉ុល ពតនោះ តែគឺ ពួកកុម្មុយនិស្ត ដដែលជាដដែល ទោះជា

កុម្មុយនិស្ត បដិបក្ខ នឹង គ្នាក្តី ។ ពួកគេ មិនអាចទ្រាំទ្រ របបកុម្មុយនិស្ត ២ ជង ដូច្នេះ ឡើយ ហើយក៏មិនអាចទុកចិត្ត ទៅលើរដ្ឋាភិបាលថ្មីបានដែរ។ សភាពការណ៍ នេះ បាន ត្រូវពួកខ្មែរក្រហម ប៉ុល ពត យកទៅធ្វើ ជាធ្នាក់បង្កើនកងទ័ព របស់ពួកគេបាន យ៉ាង ស្រួល ព្រោះនៅក្នុងរណសិរ្សរំដោះជាតិថ្មីនោះ គេបានដឹងថា មានឥស្សរជន នៃ របប ចាស់ផងទៀត ដូចជាលោក សឺន សាន និង សម្តេច នរោត្តម សីហនុ ផងទៀត ។ ពួកអ្នកវិភាគ ស្ថានការណ៍ក្នុងស្រុក នៅពេលនោះ ក៏ មិនមែន មិនដឹងថា មានពួកខ្មែរ ក្រហមដែរ ប៉ុន្តែ គេក៏មាន ខ្សែរយៈ របស់គេ ជាមួយ លោកសេរីដែរ។ ពួកខ្មែរក្រហម សង្ឃឹមថា បាតុភាព នេះអាចសម្រួល ឲ្យពួកគេ បង្កើនចំនួន ទ័ពរំដោះយ៉ាងស្រួល។ ប៉ុន្តែខ្មែរភៀសខ្លួន ១ ភាគ បានចេញរួចមកប្រទេសទី ៣ ដូចសេចក្តីប្រាថ្នា ។ បើគិត តាំងពីឆ្នាំ ១៩៧៥ មកទល់ ពេលនោះ ប្រជាជនខ្មែរ ដែលបានរត់ ពីរបបខ្មែរក្រហម មានចំនួន ២ ម៉ឺន ៦ ពាន់នាក់ រួចស្រេចទៅហើយៗ នេះ ដោយមិនគិតពីប្រជាជនខ្មែរ ចំនួនប្រមាណ ១០ ម៉ឺននាក់ ដែលបានត្រូវពួកខ្មែរក្រហម កៀរយកមកជាមួយ នៅ ពេលដែលកងទ័ពយួន វាយដាច់ គឺនៅពេលដែលពួកខ្មែរក្រហមបាក់ទ័ពនៅឆ្នាំ ១៩៧៩ ផងទេ។ ពួកអ្នកទាំងនេះ បានត្រូវ ពួក ប៉ុល ពត យកទៅ បង្ហាត់ហ្វឹកហ្វឺន ធ្វើទាហាន ទាំងអស់។ អ្នកភៀសខ្លួនខ្លះទៀត ដោយក្តាប់សភាពការណ៍ មិនបានច្បាស់ គឺ ដោយ យល់ថា គេអាចរត់ទៅជ្រកកោន នៅក្នុងជំរំ របស់ លោក សឺន សាន ឬ ក៏ ជំរំ របស់ ពួករាជានិយមតែម្តង ក៏បាន ត្រូវពួកខ្មែរក្រហម ប្រមូលយកបាន ទៅវិញអស់ ដែរ ។ ខាងប្រទេសថៃ ឯនោះវិញ ដោយគេភ័យខ្លាច កងទ័ពវៀតណាម វាយលុក ចូលមកក្នុងទឹកដីរបស់គេៗ ក៏ធ្វើការចរចា ជាសម្ងាត់ ជាមួយចិន ជាបន្ទាន់ ដើម្បីរៀបចំ បង្កើតផ្លូវលំមួយ ដែលមានឈ្មោះថា «ផ្លូវលំ តេង ស៊ាវពីង» ។ រីឯគោលដៅ គឺបញ្ជូន គ្រឿងសព្វាវុធ មកឲ្យកងទ័ពខ្មែរ ក្រហម។ គឺនៅពេលនោះហើយ ដែលកងទ័ពព្រៃខ្មែរ ក្រហម ខាង ប៉ុល ពត បានកើន ចំនួន ដល់ទៅ ៣ ម៉ឺន ៥ ពាន់ នាក់។

នៅថ្ងៃ ៧ មករាឆ្នាំ ១៩៨៣ នៅពេលដែល សមាជិករដ្ឋាភិបាលចម្រុះ កម្ពុជា ប្រជាធិបតេយ្យ (G.C.K.D.) បើកអង្គប្រជុំមួយ នៅភ្នំម៉ាល័យ សម្តេច នរោត្តម





សីហនុដែលជាអ្នដឹកនាំរណសិរ្សប្រឆាំង នឹង វត្តមានកងទ័ពវៀតណាមនៅ កម្ពុជា បាន ថ្លែងថា ព្រះអង្គប្រាថ្នាចង់ជួបអ្នកតំណាង របប ហេង សំរិន ពោលគឺ របប សាធារណ រដ្ឋ ប្រជាមានិតុ កម្ពុជា ។ ព្រះអង្គទ្រង់ឈ្វេងយល់ នៅពេលនោះ ថា សង្គ្រាម រវាង ចិន និងវៀតណាម ជាពិសេស រវាង សហរដ្ឋ អាមេរិក និង សហភាព សូវៀត ជា សង្គ្រាមមួយ ដ៏ធំមហិមា ដែលអាចប្រែក្លាយ ប្រទេសកម្ពុជា ទាំងមូល ឲ្យទៅជាផេះ តែ ម្តង ហើយ មួយវិញទៀត បើរណសិរ្ស របស់ ព្រះអង្គ យកជ័យជំនះបាន ពួកខ្មែរ ក្រហម ខាង ប៉ុល ពត ក៏ នឹង វិលត្រឡប់ ទៅកាន់អំណាចវិញ ដដែលជាដដែល រីឯ ខ្លួនព្រះអង្គវិញ ក៏នឹង ត្រូវខ្មែរក្រហម យកទៅឃុំទុក សាជាថ្មីទៀត ។ ព្រះអង្គឈ្វេង យល់ថា គួរតែបញ្ចប់សង្គ្រាម ប៉ុន្តែនៅពេលនោះ ទាំងខ្មែរក្រហម ទាំងរណសិរ្ស រំដោះ ពលរដ្ឋខ្មែរ របស់ លោក សឺន សាន ពុំអាចយល់ស្របបានទេ។ ទោះជាយ៉ាងនេះក្តី ក៏ នៅថ្ងៃ ៦ មិនា ឆ្នាំ ១៩៨៣ នោះ សម្តេច នរោត្តម សីហនុ បានធ្វើការថ្កោលទោស យ៉ាងខ្លាំងដល់ «ចលនាប្រទេសមិនចូលបក្សសម្ព័ន្ធ» ដែលបានសម្រេចទុក អាសនៈខ្មែរ នៅអង្គការ សហប្រជាជាតិ ឲ្យនៅទំនេរ។ តាំង ពី ឆ្នាំ ១៩៨៣ នោះមក សភាពការណ៍ នយោបាយ ទាំងខាងទីក្រុងហាណូយ ទាំងខាងបណ្តាប្រទេស នៃ សមាគម ប្រជាជាតិ អាស៊ីអាគ្នេយ៍ ហៅ អាស៊ាន ចាប់ផ្តើមមាន ការប្រែប្រួល ។ នៅថ្ងៃ ១២ មេសា ឆ្នាំ ១៩៨៣ ដដែលនោះ នៅ ក្នុងអង្គប្រជុំវិសាមញ្ញមួយ នៅទីក្រុងភ្នំពេញ អ្នកតំណាង ប្រទេសទាំងបី នៅឥណ្ឌូចិន បានធ្វើ ការអំពាវនាវ សុំឲ្យមាន ការចរចា ជាមួយ បណ្តា ប្រទេស សមាគម អាស៊ាន។

# ការតែងតាំង លោក ហ៊ុន សែន ជា នាយករដ្ឋមន្ត្រី នៃ របប សាធារណរដ្ឋ ប្រជាមានិត កម្ពុជា នៅ ថ្ងៃ ទី ១៤ មករា ឆ្នាំ ១៩៨៥

## L’avènement de Hun Sèn le 14 janvier 1985

ចាប់តាំងពីឆ្នាំ ១៩៨៣ ប្រជាជនខ្មែរ ទូទាំងប្រទេស បានចេញផុត បន្តិចម្តងៗ ពី គ្រោះទុរ្ភិក្ស។ ស្រូវ អង្ករ ចំណីអាហារ ព្រមទាំងគ្រឿងឧបភោគ បរិភោគផ្សេងៗ ទៀត មានសភាពកាន់តែល្អប្រសើរ ហើយគ្រប់គ្រាន់ផងទៀត។ ប៉ុន្តែ ចាប់តាំងពី ខែ កញ្ញា ឆ្នាំ ១៩៨៥ មក គឺ ចាប់តាំងពីពេលដែល ការកសាង «កំផែង ក៥» បាន ប្រព្រឹត្តិទៅ យ៉ាងគគ្រឹកគគ្រេង ស្ថានភាព ដ៏ល្អនេះ បានចុះស្រុតយ៉ាងខ្លាំងមកវិញ។ ផលិតកម្មព្រមទាំង ក្រសួង សាធារណៈទាំងអស់ ជួបប្រទះ នឹងការរអាក់រអួល ព្រោះ កម្លាំងផលិតកម្ម ដូចជា កម្មករ កសិករ ជាដើម បានត្រូវគេកេណ្ឌ យកទៅព្រំប្រទល់ ឲ្យកាប់ព្រៃឈើ សាង សង់ផ្លូវថ្នល់ លើកទំនប់ ជីកប្រឡាយ សឹងតែគ្មានសល់។ រីឯ មន្ត្រីរដ្ឋការ តាមក្រសួង មន្ទីរនានា ក៏ត្រូវគេកេណ្ឌ យកទៅការដ្ឋាន «ក ៥» ដូចគ្នាអ៊ី ចឹងដែរ។ នៅចំពោះមុខ ហេតុការណ៍បែបនេះ គ្រួសារជនរងគ្រោះចោទសួរថា ហេតុដូច ម្តេច បានជាគេបញ្ជូនប្រជាជន ឲ្យទៅធ្វើសង្គ្រាមទៀតហើយ ដូច្នេះ? អ្នកដែលកាន់ជើង របប ហេង សំរិន ឆ្លើយថា គឺដើម្បីទប់ទល់ នឹងពួកខ្មែរក្រហមម្ខាងទៀត កុំឲ្យពួកនេះ វិលត្រឡប់មក ធ្វើបាបប្រជាជនខ្មែរទៀត។ ខ្លះទៀតចោទសួរ បន្តមកទៀតថា ចុះហេតុ ដូចម្តេច បានជា ពួក ប៉ុល ពត កាប់សម្លាប់ខ្មែរ គ្នាឯងដូច្នេះ ? អ្នកដែលយល់ដឹង បន្តិចបន្តួចពីនយោបាយ ឆ្លើយប្រាប់វិញថា នេះគឺជាសង្គ្រាមមួយ ដ៏ធំ ព្រោះអ្នកដឹកនាំ





ខ្មែរ ទាំងសងខាង ត្រូវប្រទេសធំៗ ដែលទាស់ទែងគ្នា គេជំរុញឲ្យខ្មែរវាយខ្មែរគ្នាឯង រហូត ដល់ផុតពូជ រលត់ជាតិតែម្តង ប៉ុន្តែ ខាងណា ក៏គេតាំងខ្លួនគេថា គេជាអ្នកត្រូវ ជាអ្នកយកអាសាខ្មែរដែរ ។ នៅទីបំផុត សេរីភាព ក៏គ្មាន សមភាព ក៏ធ្វើពុំកើត គឺបាន ត្រឹមនៅសល់តែ ទឹកភ្នែក បែកបាក់ព្រាត់ប្រាសគ្រួសារ ហើយ ក្រ រហាម ជាងពីពេល មុនទៅទៀត ។ នៅទីបំផុត ដោយគ្មានចាញ់ គ្មានឈ្នះ ដោយមាន ការវិវត្តន៍ នៅក្នុង ការប្រជែងកម្លាំងអន្តរជាតិ និងនៅក្នុងតំបន់ខ្មែរ ដែលប្រហារគ្នាអស់ចិត្តអស់ចង់ ក៏បាន ត្រូវរូវគ្នាវិញ ហើយ ចែកចាយអំណាចបុណ្យសក្តិគ្នា ធ្វើប្រងើយទម្រាំទទួលបញ្ហា ត្រូវ វាយគ្នាសាជាថ្មីទៀត។ អ្នកដែលបាននាំប្រទេសឲ្យធ្លាក់ទៅក្នុង សោកនាដ្យកម្ម ក៏វិល មកវិញដែរ ហើយបង្កើត ចលាចល បន្តទៅទៀត ។ រី ឯមេរៀន គឺថា ប្រជាជនខ្មែរ ជាអ្នកចេញថ្លៃខូចខាតទាំងអស់ ឥតស្រាកស្រាន្ត ព្រោះតែកំហុស របស់ ពួកអ្នកដឹកនាំ ទាំងឡាយនោះ ដែលពុំដែលព្រមសារភាព កំហុស ឬការភ័ន្តច្រឡំ របស់ខ្លួន ម្តងណា ឡើយ។

នៅថ្ងៃ ៣១ ធ្នូ ឆ្នាំ ១៩៨៤ លោក ចាន់ ស៊ី ដែលជា នាយករដ្ឋមន្ត្រី នៃ របប សាធារណរដ្ឋ ប្រជាមានិត កម្ពុជា ទទួលមរណភាព នៅក្នុងមន្ទីរពេទ្យទីក្រុងម៉ូស្គូ សហ ភាព សូវៀត ។ នៅថ្ងៃ ១៤ មករាឆ្នាំ ១៩៨៥ លោក ហ៊ុន សែន បានត្រូវតែងតាំងជា នាយករដ្ឋមន្ត្រី ជំនួស ។ លោក ហ៊ុន សែន បានឡើង មកកាន់អំណាច នៅពេលមួយ ដែលប្រទេសកម្ពុជា កំពុងឆ្លងកាត់វិបត្តិ ដ៏ធំមួយ។ នៅពេលនោះ លោក ហ៊ុន សែន ដែលមានតួនាទី ជា រដ្ឋមន្ត្រីការបរទេស មានការរារែកបន្តិចដែរ ព្រោះ លោកពុំចង់ បោះបង់ចោលកិច្ចការ របស់ លោកនៅក្រសួងការបរទេសទេ ។ នៅទីបំផុត គេក៏បាន សុខចិត្ត ប្រគល់ភារកិច្ច ទាំងពីរនេះទៅឲ្យលោក តែម្តងទៅ ។ នៅពេលដែលរដ្ឋសភា ប្រកាសតែងតាំងលោក ជា នាយករដ្ឋមន្ត្រីជាផ្លូវការ លោក ហ៊ុន សែន បានឡើងមក កាន់វេទិកា ហើយថ្លែងថា លោកសូមអរគុណ ចំពោះការទុកចិត្តនេះ ក៏ ប៉ុន្តែលោក ក៏ ដឹងដែរថា គេបានប្រគល់ មកឲ្យលោក នូវភារកិច្ចមួយ ដ៏មានទម្ងន់ធ្ងន់មហិមា ហើយ ដែលពុំសុទ្ធ តែនាំមក នូវភ័ព្វវាសនា ដ៏ល្អ សម្រាប់លោកនោះឡើយ។ ២០ ថ្ងៃក្រោយ

ពេលដែលលោក បានត្រូវតែងតាំងជានាយករដ្ឋមន្ត្រី នៃរបបសាធារណរដ្ឋ ប្រជាមានិតកម្ពុជា គឺ នៅថ្ងៃ ៣ កុម្ភៈ រដ្ឋាភិបាលខ្មែរមួយ ទៀតនៅក្នុងព្រៃ គឺ «រដ្ឋាភិបាលចម្រុះកម្ពុជា ប្រជាធិបតេយ្យ» (G.C.K.D.) បានបើកអង្គប្រជុំមួយ នៅភ្នំម៉ាល័យ។ នៅថ្ងៃ ១១ កុម្ភៈ រដ្ឋាភិបាលនេះ បានចូលរួម ក្នុងអង្គប្រជុំមួយ នៃ បណ្តាប្រទេសសមាជិកសមាគម អាស៊ាន នៅទីក្រុងបាងកក។ ប៉ុន្តែ ២ ថ្ងៃបន្ទាប់មកទៀត នៅក្នុងស្រុក ឯនោះវិញ កងទ័ពវៀតណាម ប្រមាណ ១ ម៉ឺន ៨ ពាន់នាក់ បានវាយលុកយកមូលដ្ឋានកងទ័ពរបស់ ប៉ុល ពត នៅភ្នំ ម៉ាល័យបាន។ នៅដើមខែ មិនា ឆ្នាំ ១៩៨៥ ដដែលនោះ មូលដ្ឋានទ័ព របស់ «រណសិរ្ស រំដោះពលរដ្ឋខ្មែរ» របស់លោក សឺន សាន ក៏ បាន ធ្លាក់ទៅក្នុងកណ្តាប់ដៃ កងទ័ពវៀតណាម ហើយបន្ទាប់មកនៅថ្ងៃ ៨ មិនា មូលដ្ឋានទ័ព របស់ សម្តេច នរោត្តម សីហនុ នៅ តាទុំ ក៏ត្រូវបែកដែរ។

# ដំណើរឆ្ពោះទៅរក ការចរចា សន្តិភាព នៅឆ្នាំ ១៩៨៥

## Cambodge 1985 :
## vers les négociations de Paix

ការប្រយុទ្ធគ្នា រវាងកងទ័ពវៀតណាម និង កងទ័ពខ្មែរក្រហម ព្រមទាំង កងទ័ព របស់ ក្រុមខ្មែរនានា ឯទៀតដែលប្រឆាំង នឹង វត្តមានកងទ័ពវៀតណាម នៅកម្ពុជា ដែលបាន ចាប់ផ្តើមតាំងពីឆ្នាំ ១៩៧៩ មកជាសង្គ្រាមមួយ ដែលគ្មានច្រកចេញ ទាល់តែសោះ ព្រោះ តាមការពិតទៅ គឺជាសង្គ្រាម រវាង ប្រទេសមហាអំណាច ។ នៅថ្ងៃ ១ មិនាឆ្នាំ ១៩៨៣ ប្រទេសចិន បានស្នើឲ្យប្រទេសវៀតណាមទទួលយកផែនការសន្តិភាព មួយ ដែលមាន គោលការណ៍ ៥ ចំណុច ៖ ១) ប្រទេសវៀតណាម ត្រូវសន្យាថា នឹងដក កងទ័ពរបស់គេ ចេញពីប្រទេសកម្ពុជា ដោយឥតដាក់លក្ខខណ្ឌ- ២) សហភាពសូវៀត ត្រូវឈប់គាំទ្រ ការឈ្លានពាន របស់ កងទ័ព វៀតណាមនៅលើទឹកដីខ្មែរ -





៣) បន្ទាប់ពីវៀតណាម នឹង ដកកងទ័ពគេ មួយចំនួន ជាលើកដំបូង ចេញពីប្រទេសកម្ពុជា ចិន នឹង សុខចិត្ត ធ្វើការចរចា ជាមួយ វៀតណាម ក្នុងគោលដៅឈានទៅរក ប្រក្រតីកម្ម នៃ ទំនាក់ ទំនង រវាង ប្រទេសទាំងពីរ - ៤) នៅពេលដែលវៀតណាម ដកកងទ័ព របស់គេចេញអស់ពី កម្ពុជា ប្រទេសកម្ពុជាត្រូវដោះស្រាយបញ្ហាខ្លួន ដោយខ្លួនឯង គឺជ្រើសរើស ប្រព័ន្ធគ្រប់គ្រងសង្គម ដោយខ្លួនឯង នឹងជ្រើសរើសរដ្ឋាភិបាល ដែលគេប្រាថ្នាចង់បាន - ៥ ប្រទេសចិន និងប្រទេសនានាឯទៀត នៅក្នុងតំបន់ ត្រូវសន្យាថា នឹងមិនចូលជ្រៀតជ្រែក ក្នុងកិច្ចការផ្ទៃក្នុង របស់ កម្ពុជាទេ គឺត្រូវគោរពឯករាជ្យ និងអព្យាក្រឹតភាព នៃ ប្រទេសនេះ ព្រមទាំងលក្ខន្តិកៈនៃ បណ្តាប្រទេស មិនចូលបក្សសម្ព័ន្ធផងទៀត។ ទន្ទឹមនោះ គេត្រូវធ្វើយ៉ាងណា រៀបចំឲ្យមានការបោះឆ្នោតដោយសេរី ក្រោមការត្រួតពិនិត្យ របស់ អង្គការ សហប្រជាជាតិ ។ តាមរយៈ ផែនការសន្តិភាព របស់ ចិននេះ គេសង្កេតឃើញថា ចិនពុំបាននិយាយអំពី ការដកកងទ័ពខ្មែរក្រហមផងទេ ។ ដូចនេះ ពេលដែលវៀតណាម ដកកងទ័ពចេញទៅ ប៉ុល ពត នៅតែមានមុខនៅកម្ពុជា ដដែលទៀត ។ ដោយសំអាង ទៅលើហេតុការណ៍នេះ ទីក្រុងហាណូយ ក៏បានច្រាន ផែនការសន្តិភាព នោះចោល ។ នៅពេលនោះ សម្តេច នរោត្តម សីហនុ បានស្នើឲ្យដកអាវុធចេញពីក្រុមខ្មែរទាំង ៤ ដោយដាក់កងទ័ព អង្គការ សហប្រជាជាតិ ជាកម្លាំងរក្សាសន្តិភាព ហើយ បញ្ចប់សង្គ្រាមផ្ទៃក្នុង តែម្តង។ សម្តេច នរោត្តម សីហនុ ក៏បានស្នើសុំឲ្យរាប់បញ្ចូល ក្រុមលោក ហេង សំរិន ជាចំណែកមួយ នៃ អនាគតប្រទេស កម្ពុជាផងដែរ។ សូមកត់សំគាល់ថា កាលពីខែមករា ឆ្នាំ ១៩៨៥ ក្រោយអង្គប្រជុំមួយ នៃ រដ្ឋមន្ត្រីការបរទេស នៃ ប្រទេសទាំង៣ នៃ ឥណ្ឌូចិន លោក ហ៊ុន សែន បានថ្លែងថាលោក ត្រៀមលក្ខណៈជាស្រេច ដើម្បីជួប សម្តេច នរោត្តម សីហនុ និងលោក សឺន សាន នៅក្នុងករណី ដែលអ្នកនយោបាយខ្មែរ ទាំងពីររូប សុខចិត្តបោះបង់ ខ្មែរក្រហមចោល។

នៅថ្ងៃ ១២ មិនា ឆ្នាំ ១៩៨៥ ដដែលនោះ គឺ ៣ ខែ បន្ទាប់ពីបានត្រូវតែងតាំងជានាយករដ្ឋមន្ត្រី លោក ហ៊ុន សែន បានស្នើផែនការសន្តិភាពមួយ ដែលមានទាំងអស់

៦ ១ គឺ ៖១) រំសាយកងទ័ពខ្មែរក្រហមចោលទាំងអស់-២) លុះកងទ័ពខ្មែរក្រហម បាន ត្រូវរំសាយចោលអស់ហើយ វៀតណាម នឹងដកកងទ័ពគេ ចេញពីប្រទេសកម្ពុជា -៣) ការបាត់តាំង ការបោះឆ្នោត ដែលមាន ការត្រួតពិនិត្យ -៤) សន្និសហាវិជ្ជមាន រវាង ប្រទេសអាស៊ីអាគ្នេយ៍ នានា ដែលមាន ប្រព័ន្ធសង្គម និង នយោបាយខុសគ្នា -៥) បញ្ឈប់ រាល់ការជ្រៀតជ្រែក ពីប្រទេសនានា ដែលមិនស្ថិតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ -៦) បង្កើតឲ្យមានការធានាអន្តរជាតិ និង ការត្រួតពិនិត្យកិច្ចព្រមព្រៀងនានា ។ មួយសប្តាហ៍បន្ទាប់មក គឺ នៅថ្ងៃ ២ មេសា របប សាធារណរដ្ឋប្រជាមានិតុ កម្ពុជា បាន បង្កើត កម្មវិធីមួយ សម្រាប់ ទទួលយក អ្នកដែលបោះបង់ចោល ជួររដ្ឋាភិបាលចម្រុះ (G.C.K.D.)។ នៅក្នុងពេលជាមួយគ្នានោះ វៀតណាម បានប្រកាស ដកកងទ័ព របស់គេ មួយភាគទៀត ចំនួនប្រមាណ ១ ម៉ឺន ៥ ពាន់នាក់ ចេញពីកម្ពុជាជាលើកទី ៤។ មតិអន្តរជាតិ ពុំជឿថា វៀតណាម ដកកងទ័ពរបស់គេទេ។ តាមការពិត ប្រតិបត្តិការសឹក នៃកងទ័ព វៀតណាម ដែលបានចាប់ផ្តើមពីថ្ងៃ ១៨ វិច្ឆិកាឆ្នាំ ១៩៨៤ មកទល់ខែមេសា ឆ្នាំ ១៩៨៥ បានកំទេច កងទ័ពរដ្ឋាភិបាលចម្រុះ កម្ពុជាប្រជាធិបតេយ្យ ជាពិសេស កងទ័ពខ្មែរក្រហម យ៉ាងដំណំទៅហើយ។ នៅថ្ងៃ ២៣ មេសា ឆ្នាំ ១៩៨៥នោះ សម្តេច នរោត្តម សីហនុ បានសុំលាលែង ពីការកិច្ចប្រធានរដ្ឋាភិបាល ចម្រុះ ប៉ុន្តែ ២ ថ្ងៃ ក្រោយមក ព្រះអង្គ បានសុំដកពាក្យលាលែង នោះវិញ ។

សូមរំឭកឡើងវិញថា ក្រុមខ្មែរទាំង ៤ មាន ជាអាទិ៍ ៖ ១) ក្រុមខ្មែរក្រហម ដឹកនាំដោយ ប៉ុល ពត ២) ក្រុមរាជានិយមហ្វុនស៊ិនប៉េច (F.U.N.C.I.N. P.E.C.) ដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ រាជបុត្រ របស់សម្តេច នរោត្តម សីហនុ - ៣) ក្រុម អ្នកប្រជាធិបតេយ្យ នៃ «រណសិរ្សជាតិ រំដោះពលរដ្ឋ ខ្មែរ» ដឹកនាំដោយលោក សឺន សាន និង ៤) ក្រុមលោក ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ របប សាធារណរដ្ឋប្រជាមានិតុកម្ពុជា ពោលគឺ របប ហេង សំរិន គាំទ្រដោយវៀតណាម និង សហភាពសូវៀត។ ក្រុមទី ១ ទី ២ និងទី ៣ រួមគ្នា ជារដ្ឋាភិបាលចម្រុះមួយ គឺ «រដ្ឋាភិបាល ចម្រុះ





កម្ពុជាប្រជាធិបតេយ្យ» (G.C.K.D.) គាំទ្រដោយប្រទេសចិន និង បណ្តាប្រទេស នៃ សមាគម ប្រជាជាតិ អាស៊ីអាគ្នេយ៍ និង បស្ចិមលោក។

# រូបភាពមួយទៀត នៃ សង្គ្រាម

## La guerre par d’autres moyens





# ជំពូក ៩

## ឃ្នាប

L’étau

ប្រទេសកម្ពុជា ស្ថិតនៅត្រង់ ចំណុចភូមិសាស្ត្រ នយោបាយមួយ ដ៏ក្តៅ ។ កាលពីសម័យសង្គ្រាម រវាងវៀតណាម និង សហរដ្ឋ អាមេរិក ស្រុកខ្មែរត្រូវទប់ទល់ នឹងបណ្តា ប្រទេសអាស៊ាន ដែលជា សម្ព័ន្ធមិត្ត របស់ សហរដ្ឋ អាមេរិក ហើយត្រូវព្រឈម មុខ នឹង ប្រទេសវៀតណាមកុម្មុយនិស្ត ដែលជាសម្ព័ន្ធមិត្ត របស់ ចិន និង សហភាព សូវៀត។ នៅសម័យ សាធារណរដ្ឋខ្មែរ ប្រទេសកម្ពុជាត្រូវទប់ទល់ នឹងការវាយប្រហារ ពីសំណាក់ពួកយួនកុម្មុយនិស្ត ដែលមានជំនួយ ពីប្រទេសចិនប្រជាមានិត។ កាលនោះ គោលដៅ រួម នៃ ប្រទេសទាំងពីរនេះ គឺ បំបាត់ វត្តមាន បស្ចិមប្រទេសឲ្យអស់ពី តំបន់។ ពេល ប៉ុល ពត ឡើងមកកាន់អំណាច នៅឆ្នាំ ១៩៧៥ ចិន ប្រជាមានិត មានជំហរ ភូមិសាស្ត្រ នយោបាយមួយ នៅឥណ្ឌូចិន ជាហេតុ ធ្វើឲ្យវៀតណាមមិនសុខចិត្ត និង មានការបារម្ភ យ៉ាងខ្លាំង ខ្លាចទីក្រុងប៉េកាំង ជម្រុញឲ្យខ្មែរក្រហម វាយប្រទេសវៀតណាម។ នៅចំពោះមុខស្ថានភាពនេះ ទីក្រុងហាណូយ បានហៅឲ្យសហភាពសូវៀត មកជួយវាយរំលំ របប ប៉ុល ពត។ នៅ ថ្ងៃ ៧ មករាឆ្នាំ ១៩៧៩ កងទ័ពយួនកុម្មុយនិស្ត បានវាយលុក ប្រទេស កម្ពុជា ហើយ វាយរំលំ របបខ្មែរក្រហមដឹកនាំដោយ ប៉ុល ពត ។ ទាំងវត្តមាន របស់ ចិន ទាំងវត្តមាន របស់ វៀតណាម នៅកម្ពុជាបានត្រូវសហគមន៍ អន្តរជាតិចាត់ ទុកថា ជាការ បាត់តុល្យភាព ភូមិសាស្ត្រនយោបាយនៅក្នុងតំបន់ ។ បណ្តាប្រទេសអាស៊ាន មានការ បារម្ភយ៉ាងខ្លាំង ខ្លាចវៀតណាម និង

សូវៀត ចូលមកដល់ប្រទេស របស់ ពួកគេដែល មិនប្រកាន់មនោគមវិជ្ជា កុម្មុយនិស្ត ។ មានប្រទេសខ្វះ នៃ សមាគម ប្រជាជាតិអាស៊ី អាគ្នេយ៍ ហៅអាស៊ាន បែរជា យល់ថា ចិន ក៏ជាការគំរាមកំហែង ចំពោះ ប្រទេស គេ ដែរ។ ទោះជាយ៉ាងនេះក្តី គេត្រូវតែគាំទ្រចិន និង សហរដ្ឋ អាមេរិក ដែលនាំគ្នាពង្រឹង កម្លាំងខ្មែរក្រហម ដឹកនាំដោយ ប៉ុល ពត ឡើងវិញ ដើម្បី ដេញកងទ័ពវៀតណាម ចេញពីស្រុកខ្មែរ ។ នៅចុងទសវត្សរ៍ ១៩៨០ សហភាព សូវៀត ដែលមាន វិបត្តិយ៉ាងធំ ក៏ លំលាយបាត់ទៅ។ ទីក្រុងម៉ូស្គូ ត្រូវបង្ខំចិត្ត ប្តូរនយោបាយក្រៅប្រទេស គឺ ជានា ជាមួយ ចិនវិញ។ ដើម្បីបញ្ចប់សង្គ្រាមនេះ ចិន និង យួន ក៏ឈប់ប្រយុទ្ធ ហើយអង្គការ សហប្រជាជាតិ បានសម្រេចធ្វើអន្តរាគមន៍ នៅកម្ពុជា នៅឆ្នាំ ១៩៩២ ។ តាមរយៈ កិច្ច ព្រមព្រៀងទីក្រុងប៉ារីស៍ នាថ្ងៃ ២៣ តុលាឆ្នាំ ១៩៩១ ប្រទេសកម្ពុជា បានរំដោះខ្លួន ចេញពីសង្គ្រាម ។ ដោយសារ អន្តរាគមន៍ អន្តរជាតិនេះ ប្រទេសកម្ពុជា បានឃើញពន្លឺ សន្តិភាពវិញ។ ប្រទេសវៀតណាមដែលបាត់បង់ផ្អែកមួយដ៏ធំ ក៏គ្មានជម្រើសអ្វីទៀត ក្រៅពី ការដកកងទ័ពចេញ ពីស្រុកខ្មែរឡើយ។ តាមការពិត សង្គ្រាមយោធា ត្រូវបញ្ចប់មែន ប៉ុន្តែ សង្គ្រាមមួយទៀត បានចាប់ផ្តើម តាមរូបភាពផ្សេង គឺ ការប្រយុទ្ធនយោបាយមួយ ប្រកបដោយពិសពុល រវាង អ្នកដឹកនាំខ្មែរ ដែលមានចិនជាបង្អែក និង អ្នក ដឹកនាំខ្មែរ ដែលមាន យួនជាអ្នកកាន់ខ្សែញាក់។

# ការបង្កើត
# អាជ្ញាធរ បណ្តោះអាសន្ន
# របស់ អង្គការ សហប្រជាជាតិ
# នៅ ប្រទេស កម្ពុជា (អាប្រូនុច)

**( L'A.P.R.O.N.U.C.)**





ស្ថានភាព ប្រទេសកម្ពុជានាឆ្នាំ ១៩៨៩ ជា ស្ថានភាពទាល់ច្រក ចំពោះ ចលនា តស៊ូរំដោះប្រទេស ឲ្យចេញផុតពីរបប ដែលទីក្រុងហាណូយ បានបន្តុប អស់រយៈពេល ១០ ឆ្នាំ មកហើយ។ មួយវិញទៀត «រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ» (G.C.K.D.) ដឹកនាំដោយសម្តេច នរោត្តម សីហនុ គ្មានជម្រើសអ្វីទៀត ក្រៅពីធ្វើការចរចាឡើយ ទោះបីក្រុមខ្មែរក្រហម ចង់បន្តការប្រយុទ្ធ ផ្លូវយោធាទៀតក្តី ។ ការពិត ចំពោះ ក្រុមអ្នក តស៊ូ គឺការចរចា នៅក្នុងស្ថានភាព បែបនេះតែម្ត ដែលពួកគេសឹងតែមិនអាចទទួលយក បាន ។ នៅពេលនោះ របបហេង សំរិន ក្តាប់ ៩០ ភាគរយ នៃ ទឹកដី ហើយខ្មែរក្រហម ក៏ត្រូវ សហគមន៍អន្តរជាតិ ថ្កោលទោសពី បទប្រល័យពូជសាសន៍ឯងទៀតផង។ សមាស ភាពផ្សេងៗ ទៀតមានច្រក តែមួយប៉ុណ្ណោះ ដើម្បីបញ្ចប់សង្គ្រាម គឺ ការចរចា ជាមួយ របប ហេង សំរិន ទោះជាគេត្រូវធ្វើសម្បទានសំខាន់ៗ ក៏ដោយក្តី។ សម្រេចសម្រួចទៅ គឺ របប ខ្មែរក្រហម ទៅវិញទេ ដែលគូកាី ទាំងសងខាង ត្រូវកំចាត់ចេញ ពីឆាកនយោ បាយខ្មែរ។ ប៉ុន្តែ ដោយសហភាព សូវៀតត្រូវរលំរលាយ ហើយ ដោយវៀតណាម ត្រូវ ដកកងទ័ព ចេញពីកម្ពុជា គឺនៅសល់តែ របប ហេង សំរិន ប៉ុណ្ណោះ ដែលគ្រប់គ្រងទឹក ដី។ តាមការពិត មុន នឹង កកងទ័ព ចេញវៀតណាម និង សហភាព សូវៀត បានពង្រឹង រដ្ឋបាល នៃ បប ហេង សំរិន ទុករួចជាស្រេច ដើម្បីយកប្រៀបទៅលើ ភាគីផ្សេងៗ ទៀត ។ អ្នកវិភាគខ្វះយល់ថា វៀតណាម ដកកងទ័ព មែន តែវិលមក ជាស៊ីវិលវិញ ដដែលជាដដែល ។ វៀតណាម មិនបោះបង់ទឹកដីកម្ពុជាចោល ដោយស្រួលពេក ដូច្នេះ នោះទេ ព្រោះខ្លាចចិន ចូលមកកម្ពុជា ហើយ វាយយក ទឹកដី វៀតណាមទៀត នៅពេល អនាគត។ ប៉ុន្តែ នៅចំពោះមុខ ដោយសូវៀត រលំរលាយទៅហើយ គេត្រូវ ដកថយ ជាយុទ្ធសាស្ត្រ សិន ទម្រាំរកបង្អែកថ្មី បានទៀត ។ ដូច្នេះឃើញថា ចលនា តស៊ូខ្មែរ ពិបាកយកប្រៀបទៅលើ របប ហេង សំរិន ណាស់ បើគ្មានកងទ័ព ខ្មែរក្រហម ដែលជា កម្លាំងប្រយុទ្ធ ពិតប្រាកដ របស់ ចិនទេនោះ ។ មួយវិញទៀត សហរដ្ឋ អាមេរិក ក៏គ្មាន ប្រយោជន៍ អ្វី នឹងជួយចលនា តស៊ូឲ្យ បានពេញដៃពេញជើងដែរ គឺប្រគល់ភារកិច្ចនេះ ទៅឲ្យចិនតែម្តង។ ខាងរបប ហេង សំរិន ឯណោះ បើកុំតែវៀតណាម បែរទៅរកចិនសិន

បន្ទាប់ ពីសូវៀតប្តូរនយោបាយ គេសឹងមិនបាច់ ធ្វើការបរបាផង ។ ប៉ុន្តែអ្វី ដែលគេត្រូវការ គឺការទទួលស្គាល់ ពីអន្តរជាតិ ដើម្បី ទទួលយកជំនួយ និង វិនិយោគ សម្រាប់កសាងប្រទេស និង កម្លាំងគេ ឡើងវិញសិន។ ពេលដែលសហភាព រលំរលាយទៅ វៀតណាម មានតែចិនប៉ុណ្ណោះ ជាបង្អែក ដើម្បីកសាងប្រទេស ក្រោយសង្គ្រាម ។ ដោយហេតុប្រទេសវៀតណាម នៅតែក្សារបបកុម្មុយនិស្តដដែល សហរដ្ឋ អាមេរិក មិនអាចទទួលស្គាល់ របបនេះ ពេញមុខបានឡើយ។ សម្រេចសម្រួចទៅ ប្រទេសកម្ពុជា ស្ថិតនៅក្រោមឥទ្ធិពល របបកុម្មុយនិស នេះដដែល ឬ បើនិយាយឲ្យចំ ពុំអាចគេចផុតពីវប្បធម៌ ផ្តាច់ការនិយម បក្សពួកនិយម វិន័យ ដ៏តឹងតែងក្នុងជីវិតរស់នៅ និង គោលការណ៍គ្រួសារនិយម ដែលទាំងនេះសុទ្ធតែជា មូលដ្ឋាន នៃមោទនភាព របស់ អ្នកដឹកនាំនយោបាយ នៃបណ្តាប្រទេសអាស៊ី បានឡើយ។ បណ្តាប្រទេសទាំងនេះ ដែលមិនផ្តល់តម្លៃទៅឲ្យបុគ្គល មានការពិបាកច្រើន ក្នុងការគោរព គោលការណ៍ ប្រជាធិបតេយ្យ និងសទ្ធិមនុស្ស។ អ្នកវិភាគជាច្រើន យល់ឃើញ ថាម្តងនេះ ប្រទេសកម្ពុជា ពិបាក នឹងរំដោះខ្លួន ចេញពីប្រទេសកុម្មុយនិស្ត ទាំងពីរនេះណាស់ ព្រោះនៅពេលនោះ ចិន ខិតខំពង្រឹងចំណងមិត្តភាព ជាមួយ វៀតណាម ឲ្យបានស្អិតរមួត ដើម្បីកុំឲ្យវៀតណាម យកបស្ចិមប្រទេសធ្វើជាបង្អែកផង ហើយ ជាពិសេស ដើម្បីត្រៀមលក្ខណៈកំចាត់រាល់កម្លាំងដែលមានការគាំទ្រ ឬ អាចមានការគាំទ្រ ពី បស្ចិមប្រទេសផង ព្រោះ ប្រទេសចិន មានមហិច្ឆតាមួយដ៏ធំ គឺ គ្រប់គ្រងទ្វីប អាស៊ីទាំងមូល នៅអនាគតកាល។ ទោះជាយ៉ាងនេះក្តី ដើម្បីទុកមុខមាត់ របស់ខ្លួនខ្លះ បស្ចិមប្រទេស គ្មានជម្រើសអ្វីទៀត ក្រៅពីប្រគល់ការកិច្ចឲ្យ ក្រុមប្រឹក្សា សន្តិសុខ អង្គការ សហប្រជាជាតិ ធ្វើអន្តរាគមន៍ ដើម្បីរៀបចំឲ្យមានការបោះឆ្នោត ដោយសេរីឡើយ។ ម៉្យាងទៀត នេះក៏ជាប្រកមួយ ដ៏ សំខាន់ដែរសម្រាប់សម្រួល ឲ្យប្រទេសកម្ពុជា អាចមាន លទ្ធភាព ដកខ្លួនចេញពី ឥទ្ធិពល នៃប្រទេសកុម្មុយនិស្តទាំងពីរ នៅក្នុងតំបន់ នៅថ្ងៃណាមួយ។ ប៉ុន្តែ ការបោះឆ្នោត នាឆ្នាំ ១៩៩៣ បានបញ្ជាក់ថា ទោះបី គណបក្សរាជានិយម ឈ្នះ ក៏ដោយ ក៏ របប ហេង សំរិនដែលជាសម្ព័ន្ធភាព របស់កុម្មុយនិស្ត មិនសុខចិត្តដែរ ទោះបីត្រូវមាន នាយករដ្ឋមន្ត្រី





ដល់ទៅពីររូប ក្នុងពេលជាមួយគ្នាក្តី ។ ចំពោះប្រទេសចិន ក៏ដូចជា ចំពោះប្រទេសវៀតណាម ការបោះឆ្នោតនេះ គ្រាន់តែសម្រាប់ប្តឹងក្អែក សាធារណមតិ និង សម្រាប់ឲ្យមាន ការចូលរួមចំណែក ពីសំណាក់ អ្នកប្រជាធិបតេយ្យ តែប៉ុណ្ណោះ ហើយ បន្ទាប់មកគេ មានមធ្យោបាយ គ្រប់បែបយ៉ាង ដើម្បីបញ្ចូលអ្នក ទាំងនេះមកក្នុងសម្ព័ន្ធ របស់គេ។ ទោះជាយ៉ាងនេះក្តី ប្រទេសវៀតណាម មិនមែនជាប្រទេស ដែលអាចរក្សាសម្ព័ន្ធភាពនេះបានទេ ព្រោះ ប្រទេសវៀតណាមខ្លាច ប្រទេសចិន វាតទីយកទឹកដី របស់គេ ហើយនៅ ក្នុងន័យនេះ រង់ចាំតែ ឱកាសល្អ ដើម្បីរកបង្អែកណាមួយ ដែលគ្មានគ្រោះថ្នាក់ ដូចដែលគេ ធ្លាប់បានធ្វើកន្លងមក ជាមួយសហភាព សូវៀតដូច្នេះដែរ។ បស្ចិមប្រទេស ក៏រង់ចាំតែ ឱកាសនេះដែរ ។ មុននឹងឈានទៅ ដល់ដំណាក់ការនោះ ខ្ញុំសូមនិយាយរៀបរាប់អំពី ស្ថានភាព នៃ ប្រទេស កម្ពុជានៅឆ្នាំ ១៩៩០ ជាហូរហែ ដូចតទៅ ៖

ដើម្បីឈាន ទៅដល់ ការរៀបចំ បោះឆ្នោត ដោយសេរី ឲ្យបានឆាប់រហ័សប្រទេស មហាអំណាចទាំង ៥ នៃ ក្រុមប្រឹក្សា សន្តិសុខ អង្គការ សហប្រជាជាតិ បានរួមប្រជុំគ្នា យ៉ាងមមាញឹក ។ គ្រាន់តែនៅឆ្នាំ ១៩៩០ គេ បានបើកអង្គប្រជុំ ៧ ដង ៖ ទី ១ នៅ ថ្ងៃ ១៥-១៦ មករា; ទី ២ នៅថ្ងៃ ១១-១២ កុម្ភៈ នៅទីក្រុងញូវយ៉ក; ទី ៣ នៅថ្ងៃ ១២-១៣ មិនា នៅទីក្រុងប៉ារីស៍; ទី ៤ នៅថ្ងៃ ២៥-២៦ ឧសភានៅ ទីក្រុងញូវយ៉ក; ទី ៥ នៅថ្ងៃ ១៦-១៧ កក្កដា នៅទីក្រុងប៉ារីស៍ ទី៦ នៅថ្ងៃ ២៧-២៨ សីហា នៅទីក្រុងញូវយ៉ក; ទី ៧ នៅថ្ងៃ ២៥-២៦ វិច្ឆិកា ។ នៅថ្ងៃ ៣ កុម្ភៈ ក្រោយអង្គប្រជុំលើកទី ១ នៃក្រុមប្រឹក្សា សន្តិសុខ នាថ្ងៃ ១៥-១៦ មករា «រដ្ឋាភិបាលចម្រុះ កម្ពុជាប្រជាធិបតេយ្យ» (G.C.K.D.) បានប្តូរឈ្មោះមកជា «រដ្ឋាភិបាលជាតិ នៃ ប្រទេសកម្ពុជា» ដូច្នេះវិញ ។ នៅពេលនោះ ទង់ជាតិ របស់ខ្មែរក្រហម បានត្រូវជំនួសដោយ ទង់ជាតិ មុនឆ្នាំ ១៩៧០។ ក្រោយអង្គប្រជុំ នាថ្ងៃ១១-១២ កុម្ភៈ មានអង្គប្រជុំក្រៅផ្លូវការមួយ នៅទីក្រុង យ៉ាការតា ប្រទេសឥណ្ឌូណេស៊ី ដើម្បីពិភាក្សា អំពីរបៀបបែបបទធ្វើអន្តរាគមន៍ ស៊ីវិល និងយោធា របស់អង្គការ សហប្រជាជាតិ ពោលគឺអង្គការ «អាប្រូនុច» (APRONUC) ដែលមានន័យថា «អាជ្ញាធរ បណ្តោះអាសន្ន នៃ អង្គការ សហប្រជាជាតិ នៅប្រទេសកម្ពុជា» ។

បន្ទាប់ ពីអង្គប្រជុំក្រុមប្រឹក្សា សន្តិសុខ នាថ្ងៃ ១២-១៣ មិនា ប្រទេសមហាអំណាចទាំង ៥ បាន ស្នើឲ្យអាសនៈខ្មែរ នៅអង្គការ សហប្រជាជាតិ ត្រូវប្រគល់ទៅឲ្យ ក្រុមប្រឹក្សាជាតិ ជាន់ ខ្ពស់ ប៉ុន្តែសមាសភាព នៃ ក្រុមប្រឹក្សាជាតិ សម្រាប់ គ្រប់គ្រងប្រទេសកម្ពុជា ត្រូវកំណត់ ដោយភាគីខ្មែរទាំងបួន ។

## ដំណាក់កាលថ្មី របស់ បក្ស «ប្រជាជនបដិវត្ត កម្ពុជា» នៅ ឆ្នាំ ១៩៩០

## La nouvelle phase du Parti populaire révolutionnaire du Kampuchéa

ព្រឹត្តិការណ៍ ដែលកើតមានឡើង នៅឆ្នាំ ១៩៩០ មាន លក្ខណៈប្រឫកប្រឫស់ គួរឲ្យកត់សំគាល់។ នៅពេលដែលក្រុមប្រឹក្សា សន្តិសុខ អង្គការ សហប្រជាជាតិរៀបចំ អន្តរាគមន៍ នយោបាយ និង យោធា នៅកម្ពុជា យ៉ាងមមាញឹក បក្ស «ប្រជាជន បដិវត្តិកម្ពុជា» មានការប្រេះឆាមួយដ៏ធំ ។ លោក ហ៊ុន សែន ដែលនៅពេលនោះ កំពុងប្តូរឥរិយាបថ ពី ជនកុម្មុយនិស្ត មកជាអ្នកសេរីនិយម ដើម្បីសម្របខ្លួន ទៅតាមដំណើរពិភពលោក បានដណ្តើមយកចង្កូតដឹកនាំបក្ស «ប្រជាជនបដិវត្តកម្ពុជា» (P.P.R.K.) តែម្តង ជាហេតុធ្វើឲ្យអ្នកតស៊ូកុម្មុយនិស្ត នានាឯទៀត ធ្វើការគាបសង្កត់ យ៉ាងខ្លាំង ទៅលើលោក ហ៊ុន សែន នៅក្នុង «ការិយាល័យនយោបាយ» ។ យោងទៅតាម ឯកសារមួយ របស់ លោក រ៉ាអ៊ូល យ៉េណា (Raoul Jennar) ដែលមាន ចំណង ជើងថា *កូនសោនៃ ប្រទេសកម្ពុជា (Les clés du Cambodge)* ឥស្សរជន ប្រាំមួយរូប ដែលជិតស្និទ្ធ នឹង លោក ហ៊ុន សែន ហើយដែលបានត្រូវចោទប្រកាន់ថា កំពុងរៀបចំបង្កើតគណបក្ស នយោបាយថ្មីមួយ សម្រាប់ជំនួសគណបក្ស «ប្រជាជនបដិវត្តកម្ពុជា» បាន





ត្រូវគេចាប់ខ្លួន។ ខ្លះទៀត បានត្រូវគេបង្ខំឲ្យចូលនិវត្តន៍ តែម្តង។ តាមការពិត គឺ ជាការបែងចែក អំណាចគ្នា មិនបានច្បាស់លាស់តែប៉ុណ្ណោះ ។ ទោះជាយ៉ាងណាក្តី គេអាចនិយាយបានថា ក្រោយពេលនោះបន្តិច លោក ហ៊ុន សែន និងក្រុម របស់ លោក បាន ទទួលជោគជ័យមួយ ដ៏ធំ ក្នុងការដណ្តើមអំណាចនេះ ព្រោះកម្លាំងតស៊ូ ពីឆ្នាំ ១៩៧៩ មកទល់ឆ្នាំ ១៩៩០ បានឈានមកដល់ ទីអវសាន របស់គេ បាត់ទៅហើយ ដោយការផ្លាស់ប្តូរ ស្ថានការណ៍ ឬ បើនិយាយឲ្យចំ ការផ្លាស់ប្តូរយុទ្ធសាស្ត្ររបស់ ចលនា កុម្មុយនិស្ត នៅក្នុងពិភពលោក និង នៅក្នុងតំបន់ អាស៊ីអាគ្នេយ៍ ។ លោក ហ៊ុន សែន ដែលមានការគាំទ្រយ៉ាងពេញទំហឹង ពីចលនាកុម្មុយនិស្តតំបន់ មាន ភារកិច្ចមួយដ៏សំខាន់ នៅពេលនោះ គឺត្រូវដណ្តើមយកតួនាទី ពីអ្នកប្រជាធិបតេយ្យសេរីនិយមពិតប្រាកដឲ្យបាន។ និយាយមួយបែបទៀត គឺត្រូវវាយរណសិរ្សពីរ ៖ រណសិរ្សទី ១ គឺ ប្តូរបេចនាសម្ព័ន្ធ បក្សចាស់ចោល ហើយរណសិរ្សទី ២ គឺ កំទេចចលនាប្រជាធិបតេយ្យសេរីនិយម ដែលមានប្រវត្តិតស៊ូ តាំងពីឆ្នាំ ១៩៤៦ មក។ ចំពោះចលនានេះ ដែលមាន លោក សឺន សាន ជាអ្នកតំណាងនៅពេលចរចា គេសង្កេត ឃើញមានការប្រេះឆាមួយដ៏ធំរវាងលោក សឺន សាន ដែលជាអ្នកប្រជាធិបតេយ្យ ប៉ុន្តែដែលគាំទ្រឲ្យមានវត្តមាន សម្តេច នរោត្តម សីហនុ នៅក្នុងឆាក នយោបាយខ្មែរ និង លោក សាកស៊ុត សាខន ដែលជាអតីតអគ្គញ្ញាការសេនាធិការដ្ឋាន កងទ័ព ឧត្តមសេនីយ៍ លន់ នល់ ។ បន្ទាប់ ពីលោក ប្រធានាធិបតីអាមេរិក យ៉ក ប៊ូស [២៥] បានប្រកាស ប្តូរនយោបាយ របស់ សហរដ្ឋ អាមេរិក ចំពោះប្រទេសកម្ពុជា ។ នៅថ្ងៃ ២៤ ឧសភាឆ្នាំ ១៩៩០ ឧត្តមសេនីយ៍សាកស៊ុត សាខន បានបង្កើតគណបក្សនយោបាយមួយ មានឈ្មោះថាគណបក្ស «ប្រជាធិបតេយ្យសេរីនិយម»។ រីឯ លោក សឺន សាន វិញ លោកសុខចិត្ត រក្សាការស្មោះត្រង់ ចំពោះសម្តេចនរោត្តម សីហនុ ដែលជាអ្នកបង្កើត ចលនារាជានិយម «ហ៊្វុនស៊ីនប៉ិច» ។

---

[២៥] ឪពុក លោកប្រធានាធិបតី ដាប់ប៊្លិលយូ ប៊ូស ( George W. Bush)

ចំពោះ អង្គការ សហប្រជាជាតិ គោលដៅ មានតែមួយ ប៉ុណ្ណោះ គឺរៀបចំ ការបោះឆ្នោតដោយសេរី នៅប្រទេសកម្ពុជា ដើម្បីឈានជាជំហានៗ ឆ្ពោះទៅរក លទ្ធិប្រជាធិបតេយ្យ។ រី ឯ ចលនាកុម្មុយនិស្ត នៅក្នុងតំបន់ វិញ គឺ ធ្វើយ៉ាងណា ប្រែក្លាយ លោក ហ៊ុន សែន ឲ្យទៅជាអ្នកដឹកនាំខ្មែរម្នាក់ ដ៏ចំបង នៅក្នុងបរិបទនយោបាយថ្មី ពោល គឺ ក្រោយពេលការបោះឆ្នោត។ និយាយមួយបែបទៀត គឺជាយុទ្ធសាស្ត្រ សម្រាប់ ទប់ទល់ នឹង អ្នកនយោបាយដែល មានទំនោរ ទៅរកបស្ចិមប្រទេស។ បញ្ហាចំពោះមុខ គឺធ្វើយ៉ាងណា ឲ្យសម្តេច នរោត្តម សីហនុ ចូលរួមចំណែក សាជាថ្មីទៀត តែប៉ុណ្ណោះ។ រីឯ បញ្ហាមួយទៀត គឺធ្វើយ៉ាងណា ឲ្យគណបក្សរាជានិយម «ហ៊្វុនស៊ីនប៉ិច» ដឹកនាំដោយ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធ ស្ថិតនៅក្នុងវង្វង់ចលនា កុម្មុយនិស្តថ្មីឲ្យបាន ទោះបី ក្សត្រអង្គនេះ ដែលជាព្រះរាជបុត្រ របស់ សម្តេច នរោត្តម សីហនុ បានត្រូវទីក្រុងវ៉ាស៊ីងតោនសង្ឃឹមច្រើនយ៉ាងណាក្តី ។ ដូចនេះផែនការ ឬការកិច្ច របស់លោក ហ៊ុន សែន នៅពេលនោះ មានទំហំធំក្រៃលែង ព្រោះវណសិរ្សរបស់លោក ពោលគឺ បក្សប្រជែង បានឈានពី ពីរដល់ បី នៅឆ្នាំ ១៩៩៣ ពោលគឺ គណបក្សរាជានិយម «ហ៊្វុនស៊ីនប៉ិច» ដឹកនាំដោយព្រះអង្គម្ចាស់ រណឫទ្ធិ មួយថែមទៀត ។ ប៉ុន្តែនៅទីបំផុត ក្រឹត្យក្រម ភូមិសាស្ត្រ-នយោបាយ នៅតែជា កត្តាសំខាន់ដដែល។ ខ្ញុំនឹងលើកបញ្ហានេះ ទៅវិភាគថែមទៀតនៅចំពូកក្រោយ ហើយ សូមវិលមកនិយាយ អំពី សភាពការណ៍ នៅឆ្នាំ ១៩៩០ បន្តមកទៀត។ នៅថ្ងៃ ២៩ ឧសភា សម្តេចនរោត្តម សីហនុ បានយាងមកកាន់តួនាទី ជាប្រធាន «រដ្ឋាភិបាលជាតិ នៃ ប្រទេសកម្ពុជា» វិញ បន្ទាប់ពី បានសុំឈប់ មួយរយៈកាល ពីថ្ងៃ ៧ ឧសភា។ នៅថ្ងៃ ៤ មិថុនាឆ្នាំ ១៩៩០ ដដែល ព្រះអង្គបានយាងទៅជួបលោក ហ៊ុន សែន នៅទីក្រុងតូក្យូប្រទេសជប៉ុន ដើម្បីពិភាក្សាអំពីការបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់។





# អភិក្រម សន្តិភាព នៅ ប្រទេស កម្ពុជា នៅឆ្នាំ ១៩៩០

## La mise en place du processus de paix au Cambodge

នៅថ្ងៃ១២ កុម្ភៈ ឆ្នាំ ១៩៩០ ក្រុមប្រឹក្សាសន្តិសុខ បានសម្រេចបង្កើតកម្លាំង កងទ័ព សម្រាប់ធ្វើអន្តរាគមន៍ នៅកម្ពុជា ។ នៅក្នុងអង្គប្រជុំ នាថ្ងៃ ១៣-១៤កុម្ភៈ នៅទីក្រុងញូវយ៉ក ប្រទេសមហាអំណាចទាំង ៥ បានឈាន  មកដល់ កិច្ចព្រមព្រៀងមួយ ដែលមានទាំងអស់ ៤ ចំណុច ៖ ១) ការកំណត់បែបបទ សម្រាប់ពិនិត្យថា តើប្រទេសវៀតណាម បានដកកងទ័ព របស់គេ ចេញ ពីកម្ពុជា មែន ឬ ក៏យ៉ាងណា? - ២) ការបាំបាច់ឲ្យឈប់មានការបាញ់គ្នា- ៣) ការចាំបាច់ បញ្ឈប់រាល់ជំនួយយោធា ពីសំណាក់ប្រទេសជាប់ពាក់ព័ន្ធ ទៅឲ្យក្រុមខ្មែរនីមួយៗ - ៤) ការផ្តុំកងទ័ព នៃ ក្រុមខ្មែរនីមួយៗ នៅតាមកន្លែងផ្សេងៗ។ នៅថ្ងៃ ២១ កុម្ភៈ សម្តេច នរោត្តម សីហនុ និង លោក ហ៊ុន សែន បានមកជួបគ្នានៅទីក្រុងបាងកក ដើម្បីពិភាក្សា យល់ព្រមគ្នា អំពី ការដាក់កម្លាំងកងទ័ព អង្គការ សហប្រជាជាតិ នៅកម្ពុជាទៅតាមកម្រិតមួយ ឲ្យបានសមស្រប។ អ្នកដឹកនាំ បដិបក្ខទាំងពីរ ក៏បានពិភាក្សា គ្នាផងដែរ អំពី ការបង្កើត អង្គការ កំពូលមួយ សម្រាប់តំណាងអធិបតេយ្យ និងឯកភាពជាតិ នៃ ប្រទេសកម្ពុជា ។ ពីរថ្ងៃ បន្ទាប់មក សម្តេច នរោត្តម សីហនុ ទ្រង់បានប្រាប់ឲ្យដឹងថា ព្រះអង្គ នឹងទ្រង់យាងទៅគង់ ជាស្ថាពរ នៅក្នុង «ភូមិសេរីភាព» គឺ តំបន់រំដោះមួយ ដែលកាន់កាប់ដោយកងទ័ព របស់ព្រះអង្គ។ នៅថ្ងៃ ២៦-២៧ និង ២៨ ខែកុម្ភៈ ដដែលនោះ ប្រទេសឥណ្ឌូណេស៊ី បានបើកអង្គប្រជុំ អន្តរជាតិមួយ ក្រោមការដឹកនាំ របស់ អ្នកតំណាង សន្និសីទទីក្រុងប៉ារីស៍ ។ ក្រៅពីអ្នកតំណាង ខាង «រដ្ឋាភិបាលជាតិកម្ពុជា» និង ខាង «រដ្ឋកម្ពុជា» អ្នកតំណាងប្រទេស នៃ «សមាគម ប្រជាជាតិ អាស៊ីអាគ្នេយ៍ ចំនួន ៦ នៅពេលនោះ ព្រមទាំងប្រទេស ៤ ទៀត

គឺ ប្រទេសបារាំង ប្រទេសលាវ ប្រទេសវៀតណាម និងប្រទេសអូស្ត្រាលី ក៏ បានចូលរួមដែរ ។ រីឯ កម្មវត្ថុ នៃអង្គប្រជុំ គឺ ផែនការសន្តិភាព របស់ ប្រទេសអូស្ត្រាលី ។ នៅក្នុងអង្គប្រជុំនោះ ភាគីខ្មែរទាំងសងខាង នៅតែរក្សាទីតាំងរបស់គេ ពីពេលមុន រៀងៗខ្លួនដដែល ។ នៅ ថ្ងៃ ១២-១៣ មិនា អ្នកតំណាង ប្រទេសមហាអំណាចទាំង ៥ នៃ ក្រុមប្រឹក្សាសន្តិសុខ បានបើកអង្គប្រជុំមួយនៅទីក្រុងប៉ារីស៍ ដើម្បីស្រុះស្រួលគ្នា អំពីការរៀបចំការបោះឆ្នោត នៅកម្ពុជា ។ នៅថ្ងៃ ៣០ ខែ មិនា ដដែលនោះ អង្គការ សហប្រជាជាតិ បានបញ្ជូន បេសកជន បច្ចេកទេស របស់គេ មកប្រទេសកម្ពុជា ម្តងទៀត ដើម្បីពិនិត្យមើលទិដ្ឋភាព នៃ រដ្ឋបាលសម្រាប់ប្រតិបត្តិការ ជាយថាហេតុ របស់ អង្គការ សហប្រជាជាតិ នៅក្នុងប្រទេសកម្ពុជា។ សឹងតែពេញមួយខែ គឺ ពីថ្ងៃ ៨ ដល់ថ្ងៃ ២៥ មេសា ការប្រយុទ្ធគ្នា ផ្នែកយោធា រវាង ភាគីខ្មែរ មានលក្ខណៈ ខ្លាំងក្លា ខុសធម្មតា ។

នៅពេលដែល អង្គការ សហប្រជាជាតិ កំពុងរៀបចំ ដាក់ អភិក្រមសន្តិភាព នៅ កម្ពុជា ហើយនៅពេលដែលក្រុមខ្មែរ ទាំងសងខាង ប្រយុទ្ធគ្នា ផ្តាច់ព្រ័ត្រ ដើម្បីយកប្រៀប ធ្វើការចរចា ស្ថានភាពសេដ្ឋកិច្ច នៃក្រុមខ្មែរ ខាង «រដ្ឋកម្ពុជា» គឺ របបហេង សំរិន កាន់តែចុះទ្រុឌទ្រោមទៅៗ ជាលំដាប់ ។

នៅឆ្នាំ ១៩៩០ ហើយ ជាពិសេស នៅឆ្នាំបន្ទាប់ ដោយសហភាព សូវៀត កាត់ បន្ថយបីភាគបួន នៃ ជំនួយទៅឲ្យ របប ហេង សំរិន ស្ថានភាព សេដ្ឋកិច្ច នៃ ប្រទេសកម្ពុជាចុះស្រុតយ៉ាងខ្លាំង។ គេត្រូវទិញផលិតផលនាំចូល ទៅតាមការកំណត់ ថ្លៃផ្សារសេរី។ រីឯ ផលិតផលនាំចេញ ដូចជា កៅស៊ូ និង ឈើ ជាដើម ក៏ ចុះថយ ដែរ ។ ឧបករណ៍ សម្រាប់ ប្តូរផ្លាស់ម៉ាស៊ីន ការខ្វះខាត ជីរសម្រាប់ធ្វើស្រែ ការខ្វះ ប្រេងឥន្ធនៈ សឹងតែ ធ្វើឲ្យដំណើរការ កសិកម្ម និង ឧស្សាហកម្មរាំងស្ទះ។ នៅតាមជនបទ ប្រជាជន ខ្វះសព្វខ្វះ គ្រប់ ក្នុងការប្រកបអាជីវកម្ម របស់គេ ។ ជាការពិត ហើយដែលថានៅឆ្នាំ ១៩៨៩ របប ហេង សំរិន មាន ផលិតផលស្រូវ អង្ករ គ្រប់គ្រាន់ សម្រាប់ចិញ្ចឹម ប្រជាជន គឺ ២ លាន ៥ សែនតោន។ ទន្ទឹម នឹង ការកាត់ បន្ថយជំនួយ ពីសំណាក់សហភាព សូវៀត ថវិកាជាតិ ក៏មានឱនភាពដែរ គឺចុះ ៣៥ ភាគរយ នៅឆ្នាំ ១៩៩១ ជាហេតុធ្វើឲ្យ



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

អតិផរណា កើនក្នុងមួយឆ្នាំៗ នៅក្នុងកម្រិត ២០០ ភាគរយ។ បើនិយាយជាសរុបទៅ គឺ អន់ជាង ស្ថានភាពសេដ្ឋកិច្ច របស់ពួកខ្មែរក្រហមទៅទៀត។ ដោយសារគេកាន់កាប់តំបន់ប៉ៃ លិន ដែលសម្បូរទៅដោយត្បូង ពួកខ្មែរក្រហម មានប្រាក់រក្សាទុកដល់ទៅ ១០០ លាន ដុល្លារ ហើយបន្ថែមពីនោះ គេរកប្រាក់បាន ក្នុងមួយខែៗយ៉ាងតិចណាស់ ក៏ ៥ លាន ដុល្លារ ដែរ ។ ខាង របប ហេង សំរិន ប្រាក់ចំណូលបានមកពី ការនាំចេញ ក្នុងមួយឆ្នាំៗ គឺ ត្រឹម ៥០ លានដុល្លារប៉ុណ្ណោះ នៅក្នុងនោះ ប្រាក់បំណុល ស្ថិតនៅក្នុងកម្រិត ៤០ ភាគ រយ។ ប៉ុន្តែ ការផ្លោះប្តូរដោយសេរី មិនមែន នាំមកតែកត្តា អវិជ្ជមានប៉ុណ្ណោះទេ។ ទន្ទឹម នឹងស្ថានភាពនេះ គេក៏ សង្កេតឃើញផងដែរថា សហគ្រាស ផលិតកម្ម ឯកជន បានកើនចំនួន ហើយតាមរយៈនោះ ប្រទេសកម្ពុជាក៏ចាប់ផ្តើម រីកចម្រើនទៅតាមនោះ ដែរ ។

# ផែនការ ក្របខ័ណ្ឌ នៃ កិច្ចព្រមព្រៀងរួម នៃ គូភាគីខ្មែរ របស់ គណអចិន្ត្រៃយ៍ នៃ ក្រុមប្រឹក្សា សន្តិសុខ អង្គការសហប្រជាជាតិ

## Le Plan cadre des Accords politiques globaux conçu par les 5 Permanents du Conseil de sécurité de l'O.N.U.

នាអង្គប្រជុំថ្ងៃ ២៧-២៨ សីហា ឆ្នាំ ១៩៩០ នៅទីក្រុងញូវយ៉ក ពោលគឺ អង្គប្រជុំលើកទី ៦ ប្រទេសមហាអំណាច ទាំង ៥ បានបង្កើតផែនការមួយ គឺ ក្របខ័ណ្ឌ នៃកិច្ចព្រមព្រៀង នយោបាយរួមមួយ នៃអធិករណ៍ខ្មែរ ។ ផែនការនេះ ដែលបែកចេញជា ៥ ចំពូក លើកឡើង អំពីបញ្ហាសំខាន់ៗចាំបាច់ សម្រាប់ឈាន ឲ្យបានដល់ដំណោះស្រាយ នយោបាយ ៖ ១) ការស្រុះស្រួលគ្នាមួយ នៅក្នុងរយកាលឆ្លងកាត់ ស្តី ពី រដ្ឋបាល នៃប្រទេសកម្ពុជា នៅពេលមុនការបោះឆ្នោត។ ២) ការស្រុះស្រួលគ្នាផ្នែកយោធា នៅក្នុងរយកាលឆ្លងកាត់ ។ ៣) ការបោះឆ្នោត ក្រោមការឧបត្ថម្ភ របស់ អង្គការ សហប្រជាជាតិ ។ ៤) ការការពារសិទ្ធិមនុស្ស ។ ៥) ការធានាអន្តរជាតិ ។ ចំណុចសំខាន់ជាងគេ ដែលមានចែង នៅជំពូកទី ១ គឺការផ្តល់អំណាចជាបណ្តោះអាសន្ន របស់ ក្រុមប្រឹក្សាជាត ិជាន់ខ្ពស់ ទៅឲ្យ «អាជ្ញាធរ បណ្តោះអាសន្ន» នៃ អង្គការ សហប្រជាជាតិ ដែលគេហៅថា «អាប្រូនុច» (A.P.R.O.N.U.C.) ២៦ ។ នៅក្នុងផែនការក្របខ័ណ្ឌ នៃ ការស្រុះ ស្រួលគ្នានោះ ដែលមានទាំងអស់ ៣៦ មាត្រា គេសង្កេតឃើញមានចំណុចមួយដែរ គឺថាក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ត្រូវផ្តល់យោបល់ របស់ខ្លួន ទៅឲ្យ «អាប្រូនុច» ហើយ «អាប្រូនុច» នឹងសម្រេចតាម នៅក្នុងករណី ដែលមានការយល់ព្រមពី ក្រុមប្រឹក្សា ជាតិ ទាំងមូល ពោល គឺសមាជិក ទាំង ៤ នៃ ក្រុមប្រឹក្សាជាតិ ហើយ នៅក្នុងករណីដែលការផ្តល់ យោបល់នោះស្របទៅនឹងទិសដៅ នៃការដោះស្រាយរួម។ ចំណុចសំខាន់មួយទៀត នៃក្របខ័ណ្ឌ នៃ កិច្ចព្រមព្រៀង គឺត្រូវរៀបចំយ៉ាងណា បង្កើតនូវលក្ខណៈនយោបាយ អព្យាក្រឹតមួយ ឲ្យបានសម្រាប់ការបោះឆ្នោត ។ ដូចនេះ អង្គការនានា ដែលអាចធ្វើការគាបសង្កត់ ទៅលើ ដំណើរការបោះឆ្នោតត្រូវ ស្ថិតនៅក្រោមអំណាចរបស់អង្គការ សហប្រជាជាតិទាំងអស់ ។ នៅក្នុងន័យនេះ ក្រសួងការបរ ទេស ក្រសួងការពារជាតិ ហិរញ្ញវត្ថុ សន្តិសុខ សាធារណៈ និង ក្រសួងពត៌មាន ត្រូវស្ថិតនៅក្រោមអាជ្ញាធរ អង្គការ សហប្រជាជាតិ ជាកំហិត ។ ដូច្នេះឃើញថា បើយោងទៅតាមផែនការនេះ របប «រដ្ឋកម្ពុជា» ពោលគឺ របប ហេង សំរិនពុំអាចធ្វើអ្វី បានទេ ហើយ បាត់បង់នូវទីតាំងដើម និងការទាមទារ របស់គេសឹងតែទាំងអស់ ។ ផែនការក្របខ័ណ្ឌនេះ ទទួលស្គាល់ ជាផ្លូវការ នូវរបប នយោបាយរបស់ ខ្មែរក្រហម ទោះបីគេមានសមាជិកតែពីររូប នៅក្នុងក្រុមប្រឹក្សាជាតិក្តី ក្រុមប្រឹក្សាជាតិ ដែលមាន សមាជិកទាំងអស់ ១២ រូប។ ទន្ទឹមនោះ របប ហេង សំរិន ត្រូវបាត់សិទ្ធិ គ្រប់គ្រងទឹកដី ប្រមាណ ៩០ ភាគរយ និង ប្រជាជន ផងទៀត។ របប ហេង សំរិន នៅពេលនោះ គ្មានលេសអ្វីទៀត ក្រៅពីយកពាក្យ «អធិបតេយ្យ» មកសំអាងទេ ទោះបីការកកើតឡើង នៃ របបរបស់គេ បានចាប់ផ្តើមពីការបាត់អធិបតេយ្យនេះក្តី ហើយដូចនេះ ពុំអាចយកទៅប្រៀបធៀប នឹង ករណី នៃ ប្រទេស ណាមីប៊ី បានឡើយ ។

ជំពូកទី ២ នៃ ផែនការក្របខ័ណ្ឌ ទាក់ទង នឹងការស្រុះស្រួលគ្នា ផ្នែកយោធា។ យោងទៅតាមផែនការនោះ អង្គការ «អាប្រូនុច» ឬ « អាជ្ញាធរ បណ្តោះអាសន្ន នៃ អង្គការ សហប្រជាជាតិនៅកម្ពុជា» មានបេសកកម្មមួយចំនួន ដូចតទៅ ៖ ១) ត្រួតពិនិត្យការឈប់បាញ់គ្នា -២ ) ពិនិត្យការដកកងទ័ពវៀតណាម និងបញ្ឈប់ រាល់ជំនួយយោធា មកពីខាងក្រៅ - ៣) ការរាវរក និង ការដកហូត កន្លែងលាក់អាវុធ ផ្សេងៗរបស់គូភាគីខ្មែរនីមួយៗ ហើយទន្ទឹមនោះ បង្ហាត់ហ្វឹកហ្វឺនជនជាតិខ្មែរឲ្យបេះដក «មីន»។ បេសកកម្ម ដ៏ពិបាកមួយទៀត គឺការដកហូត អាវុធ ពីកងទ័ពរបស់ ភាគីខ្មែរនីមួយៗ។

---

២៦ Autorité Provisoire de l'O.N.U. au Cambodge

នេះ ជាការងារមួយ ដ៏ស្មុគស្មាញ ។ ចំពោះរបប ហេង សំរិន គ្មានការពិបាកទេ ប៉ុន្តែ ចំពោះកម្លាំងតស៊ូ ជាពិសេសចំពោះ ពួកខ្មែរក្រហម បញ្ហាចោទឡើង សឹងតែ ដោះមិនរួច ព្រោះថា ពួកនេះ បង្កប់កម្លាំង របស់ គេ នៅសឹងតែគ្រប់ ទីកន្លែង គឺ ប្រមាណ ២ ភាគ ៣ នៃ ទឹកដីខ្មែរ ជាពិសេសនៅក្នុងព្រៃ ដូចជា ព្រៃ ភ្នំក្រវាញ ជាដើម។ ដូចនេះ ការប្រមូល កងទ័ព ខ្មែរក្រហមទាំងអស់ យកមកដាក់ មួយកន្លែង ជាការមួយ ដែលពុំអាចធ្វើទៅបានទេ។ របប ហេង សំរិន បានយកសភាពការណ៍នេះ ធ្វើជាលេស តែម្តងដោយ អះអាងថា ខ្មែរក្រហម មានលទ្ធភាពគ្រប់គ្រាន់ ដើម្បីដណ្តើមយកអំណាច។ ជំពូកទី ៣ នៃ ផែនការក្របខ័ណ្ឌ លើកឡើង អំពីការបោះឆ្នោត ក្រោមការឧបត្ថម្ភ របស់ អង្គការ សហប្រជាជាតិ ។ ចំណុចសំខាន់ ដែលគេអាចដក ចេញពីចំណុចទី ៣ នេះ គឺថា អនាគតរដ្ឋធម្មនុញ្ញ នៃប្រទេសកម្ពុជា ត្រូវផ្អែកទៅលើ លទ្ធផល នៃ ការបោះឆ្នោត គឺមិនមែន ទៅលើ ការបរបា រវាង គូភាគីខ្មែរទេ ។ នៅចំពោះមុខ ផែនការក្របខ័ណ្ឌនេះ របប ហេង សំរិន ខិតខំធ្វើយ៉ាងណា ដើម្បីអាច មានវត្តមាន របស់គេ បន្តទៅទៀតនៅ ក្នុងការបោះឆ្នោតសេរីនេះ តែប៉ុណ្ណោះ ។





# ទីតាំង របស់ គូភាគីខ្មែរទាំង ៤ នៅចំពោះមុខ ផែនការ ក្របខ័ណ្ឌ របស់ ក្រុមប្រឹក្សា សន្តិសុខ អង្គការ សហប្រជាជាតិ

## Les quatre factions rivales cambodgiennes Face au Plan cadre des Accords proposé par les cinq Grands du Conseil de Sécurité de l’O.N.U.

ក្រៅពីការតម្រូវ ឲ្យដកហូតអាវុធពី គូភាគីខ្មែរ ផ្សេងៗ និង ការបញ្ឈប់រាល់ជំនួយយោធា មកពីខាងក្រៅ ជំពូកទី ៣ នៃផែនការកំណត់ បែបបទទូទៅ នៃ ការបោះឆ្នោត ប្រជាធិបតេយ្យ ដោយមាន ការទំនុកបម្រុង ពីអង្គការ សហប្រជាជាតិ។ ចំណុចដែលពិបាកបំផុត គឺ ការកំណត់ ចរិតលក្ខណៈ អំពី សញ្ជាតិ នៃ ពលរដ្ឋខ្មែរ ព្រោះត្រូវធ្វើយ៉ាងណា កុំឲ្យជនជាតិវៀតណាមដែលស្ថិតនៅលើទឹកដីខ្មែរ អាចចូលរួមក្នុងការបោះឆ្នោត។ បញ្ហា សំខាន់បំផុត នៅក្នុងស្មារតីនៃ ផែនការនោះ គឺ ការបង្កើតសភាធម្មនុញ្ញ ដើម្បីតាក់តែង រដ្ឋធម្មនុញ្ញមួយ ដែលឈរនៅលើលទ្ធផល នៃ ការបោះឆ្នោត ជាសេរី និង ជាទូទៅ គឺ មិនមែនឈរនៅលើ ការបរបាណាមួយ រវាង គូភាគីខ្មែរនោះទេ ។ គោលការណ៍នេះ បានធ្វើឲ្យភាគី ខ្មែរ នៃ «រដ្ឋកម្ពុជា» ពោល គឺ របប ហេង សំរិន មាន ការព្រួយបារម្ភយ៉ាងខ្លាំង ដូចភាគីខ្មែរ ក្រហមដែលមាន ចិនគាំទ្រ ដូច្នេះដែរ។ ប៉ុន្តែ ភាគីចុងក្រោយនេះ ដែលបានត្រូវរបប ហេង សំរិន ចោទប្រកាន់ទោស ពី បទប្រល័យពូជសាសន៍ ពុំ បានត្រូវ ផែនការក្របខ័ណ្ឌនោះ បញ្ជាក់ឲ្យបានច្បាស់ អំពី បញ្ហានេះទេ ជាហេតុធ្វើឲ្យរបប ហេង សំរិន មិនយល់ស្រប ព្រោះគេចង់ ឲ្យរបបនេះ បាត់អត្តិភាព របស់គេ តែម្តង ជាពិសេស អ្នកដឹកនាំ ធំៗ នៃ របបនេះ។ នៅក្នុងជំពូក

ស្តី ពី សិទ្ធិមនុស្ស ផែនការក្របខ័ណ្ឌ គ្រាន់តែចែង ដូច្នេះថា «ត្រូវចាត់វិធានការចាំបាច់ សម្រាប់ធានា ការគោរព សិទ្ធិមនុស្ស មិន ឲ្យនយោបាយ និង របៀបរបប បែបផែន ដែលមាន នៅអតីតកាល វិលមកវិញ បានប៉ុណ្ណោះ ។ ចំណុចសំខាន់មួយទៀត ដែល មានចែង នៅជំពូក ចុងក្រោយបង្អស់ គឺ ការតម្រូវឲ្យប្រទេសកម្ពុជាថ្មី រក្សា និង ការពារឲ្យបាន នូវ ឯករាជ្យ អធិបតេយ្យ និង បូរណភាពដែនដី នូវ ឯកភាពជាតិ និង អព្យាក្រឹតភាព ជានិច្ចនិរន្ត របស់ខ្លួន ។ ចំណុចទាំងឡាយនេះ ចាំបាច់ត្រូវ មានចែងនៅក្នុងរដ្ឋធម្មនុញ្ញ របស់ ប្រទេសកម្ពុជា ។ នៅក្នុងន័យនេះ ប្រទេសទាំងឡាយ ដែលបានចូលរួម ក្នុងសន្និសីទ អន្តរជាតិ ទីក្រុងប៉ារីស៍ ត្រូវចុះហត្ថលេខាទៅលើ កិច្ចព្រមព្រៀងមួយ ដើម្បី ទទួលស្គាល់ គោលការណ៍ ទាំងឡាយនេះ ។ តាមរយៈមាត្រាមួយក្នុងចំណោមមាត្រា ឯទៀតៗ ស្តីពី អព្យាក្រឹតភាព ប្រទេសកម្ពុជា ត្រូវលុបចោល ទាំងអស់ នូវ សន្ធិសញ្ញា និង កិច្ចព្រមព្រៀង ទាំងឡាយ ដែលប៉ះពាល់ ដល់ គោលការណ៍នេះ ។

ចំពោះអត្ថន័យ និង អត្ថបទជាក់ស្តែង ដែលបានត្រូវលើកឡើង នៅក្នុងផែនការក្របខ័ណ្ឌនេះ ស្តីពីអព្យាក្រឹតភាព របបហេង សំរិន មានការស្ទាក់ស្ទើរច្រើនៗ ដូចនេះ គេបានរកលេស ជាច្រើន ដើម្បីទាមទារឲ្យមាន ការកែលំអថែមទៀត ដោយអះអាងថាផែនការនេះ គ្រាន់តែជាឯកសារ ជាមូលដ្ឋាន ប៉ុណ្ណោះ។ ប៉ុន្តែខាងអ្នកតស៊ូ ដេញកងទ័ពវៀតណាម ឯនោះវិញ គេមានការពេញចិត្តទាំងអស់ ។ ទោះជាយ៉ាងណាក្តី នៅក្នុងអង្គប្រជុំមួយ នាថ្ងៃ ៩ និង ថ្ងៃ ១០ កញ្ញា នៅទីក្រុងយ៉ាកាតា ប្រទេស ឥណ្ឌូណេស៊ី អ្នកតំណាងគូភាគីខ្មែរទាំង ៤ ក៏ បានសុខចិត្តទទួលយក ឯកសារ ក្របខ័ណ្ឌ ដែលប្រទេសមហាអំណាចទាំង ៥ នៃ ក្រុមប្រឹក្សាសន្តិសុខ បានស្នើឡើងនោះដែរ ។ ចំពោះ ចំណុចមិនចុះសម្រុងគ្នា គេ នឹង យកទៅ ចរចា នៅពេលក្រោយទៀត ។ នៅក្នុងអង្គប្រជុំនោះ សំណើធំពីរ បានត្រូវគូភាគី ទាំងអស់ សុខចិត្តទទួលយក គឺ ការបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដែលមាន សមាជិកទាំងអស់ ចំនួន ១២ រូប គឺខាង របប ហេង សំរិន ៦ រូប ហើយ ពីររូប សម្រាប់ គណបក្សនីមួយៗ នៃចលនាតស៊ូ។ តាមរយៈការស្រុះ





ស្រួលគ្នា ត្រង់ចំណុចនេះ គេអាចនិយាយបានថា របប ប៉ុល ពត បានធ្វើសម្បទានមួយដ៏ធំ ។ ប៉ុន្តែដោយសម្តេច នរោត្តម សីហនុ បានស្នើឡើង នូវ ចំណុចមួយទៀត សុំឲ្យ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ មានអំណាច តែងតាំង សមាជិក ទី ១៣ ការចរចា ក៏រាំងស្ទះ អស់រយៈពេល ៦ ខែ គឺ តាំងពី អង្គប្រជុំ នាថ្ងៃ ១៧ កញ្ញា នៅទីក្រុងបាងកកមក ។ របប ហេង សំរិន យល់ឃើញដូច្នេះថា បើតែងតាំង សម្តេច នរោត្តម សីហនុ នៅក្នុងគណប្រធានក្រុមប្រឹក្សា ចលនាតស៊ូ អាចនឹងមានប្រៀបៗ ដើម្បីសម្រួលសំណើនេះ សម្តេច នរោត្តម សីហនុ ក៏ស្នើសុំ ឲ្យមាន សមាជិក ទាំងអស់ ១៤ រូប តែម្តង ហើយតែងតាំង លោក ហ៊ុន សែន ជាអនុប្រធានក្រុមប្រឹក្សា ។ ប៉ុន្តែសំណើនេះ បានត្រូវពួកប៉ុល ពត និង លោក សឺន សាន ប្រធាន «រណសិរ្សជាតិ រំដោះពលរដ្ឋខ្មែរ» ដែលជាអ្នកប្រជាធិបតេយ្យកណ្តាលនិយម ប៉ុន្តែ ដែលមាននិន្នាការទោរកសម្តេច នរោត្តម សីហនុ ច្រានចោលទៅវិញ ។

# ការមិនយល់ព្រម របស់ របប «រដ្ឋកម្ពុជា»[២៧] អំពី ផែនការ ក្របខ័ណ្ឌ របស់ ក្រុមប្រឹក្សា សន្តិសុខ អង្គការ សហប្រជាជាតិ

## Le refus du régime de l'Etat du Cambodge de souscrire au Plan du cadre des Accords des CinqGrands du Conseil de Sécurité de l'O.N.U.

ក្រោយអង្គប្រជុំ ទីក្រុងយ៉ាកាតា នាថ្ងៃ ៩ និង ១០ កញ្ញាឆ្នាំ ១៩៩០ ទោះបីភាគីខ្មែរ ទាំង ៤ សុខចិត្ត ទទួលយក ផែនការក្របខ័ណ្ឌ របស់ ប្រទេស មហាអំណាចទាំង ៥ នៃ គណអចិន្ត្រៃយ៍ ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហប្រជាជាតិក្តី ក៏របប «រដ្ឋកម្ពុជា» នៅមានការស្ទាក់ស្ទើរដែរ ព្រោះមានចំណុចមួយចំនួន ដែលខុសពីគោលដៅរបស់គេ។ លោក ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ របប «រដ្ឋកម្ពុជា» ពុំពេញចិត្ត នឹងតួនាទី របស់ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទេ ព្រោះលោកចង់ឲ្យ អង្គការនេះ គ្មានអំណាចអ្វីទាំងអស់ គឺ គ្រាន់តែស្ថិតនៅ ជានិមិត្តរូបប៉ុណ្ណោះ។ យោងទៅតាមផែនការក្របខ័ណ្ឌ ខ្មែរក្រហម ដែលមានអ្នកតំណាង របស់គេ ២ រូបនៅក្នុងក្រុមប្រឹក្សាជាតិ ក៏ បានត្រូវទទួលស្គាល់ផងដែរ។ ខាង «រដ្ឋាភិបាលជាតិ»[២៨] ដែលមានខ្មែរ ៣ ក្រុមជា សមាសភាព

[២៧] អង្គប្រជុំ វិសាមញ្ញរដ្ឋសភា នាថ្ងៃ ២៩-៣០ មេសា ឆ្នាំ ១៩៨៩ បានប្តូរឈ្មោះ របប សាធារណរដ្ឋ ប្រជាមានិតុ កម្ពុជា មក ជា «រដ្ឋកម្ពុជា» ដូច្នេះវិញ ។

[២៨] ឈ្មោះ រដ្ឋាភិបាល តស៊ូប្រឆាំង នឹង កងទ័ព វៀតណាមនៅលើទឹកដីខ្មែរ ។ រដ្ឋាភិបាលនេះ បានត្រូវបង្កើតឡើង នៅ ថ្ងៃ ២២ មិថុនា ឆ្នាំ ១៩៨២ នៅ ទីក្រុងគូឡាលំពួ ប្រទេសម៉ាឡេស៊ី ហើយដែល កាលនោះ មានឈ្មោះថា «រដ្ឋាភិបាលចម្រុះកម្ពុជា





គឺ ក្រុមខ្មែរក្រហម ខាង ប៉ុល ពត ក្រុមរាជានិយម របស់ សម្តេច សីហនុ និង ក្រុមអ្នកប្រជាធិបតេយ្យ ដឹកនាំដោយ លោក សឺន សាន គេមាន អ្នកតំណាងទាំងអស់ ៦ រូប គឺ អ្នកតំណាង ២ រូប សម្រាប់ក្រុមនីមួយៗ។ ខាង របប «រដ្ឋកម្ពុជា» គេ ក៏មាន អ្នកតំណាង ៦ រូបដែរ ។ បញ្ហាដែលចោទឡើង នៅពេលនោះ គឺ ការតែងតាំង សម្តេច នរោត្តម សីហនុ ដែលជា ប្រធានរដ្ឋាភិបាលចម្រុះ ជា សមាជិកទី ១៣ នៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដែលជាហេតុ ធ្វើឲ្យបាត់តុល្យភាព នៃក្រុមប្រឹក្សា។ ប៉ុន្តែ មិនមែនត្រឹមតែ តួនាទី នៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់នេះទេ ដែលរបបហេង សំរិន-ហ៊ុន សែន -ជា ស៊ីម ចង់ធ្វើការតវ៉ា ។ របប «រដ្ឋកម្ពុជា» ចង់ឲ្យក្រុមខ្មែរនីមួយៗ គ្រប់គ្រងតែទឹកដី ដែលខ្លួនកាន់កាប់ប៉ុណ្ណោះ ហើយ មិនឲ្យ រំលាយ របប របស់គេ មុនការបោះឆ្នោតឡើយ។ មុនពេលអង្គប្រជុំ បណ្តាអ្នកជំនាញការ នៅទីក្រុងយ៉ាកាតា នាថ្ងៃ ៩ វិច្ឆិកា របប ហេង សំរិន-ហ៊ុន សែន បានផ្ញើ អនុស្សរណៈ (mémorandum) មួយ ទៅឲ្យលោក រ៉ូឡង់ ឌុយម៉ាស៍ រដ្ឋមន្ត្រី ការបរទេស បារាំង។ របប ហេង សំរិន-ហ៊ុន សែន បានស្នើ ដូច្នេះថា : អង្គការ «អាប្រូនុច» មិនត្រូវមាន តួនាទី ជា អ្នករក្សាសន្តិភាពទេ គឺ គ្រាន់តែ ជា អង្គការ សម្រាប់រៀបចំ ការបោះឆ្នោតតែប៉ុណ្ណោះ ។ អង្គការនេះត្រួតពិនិត្យ ក្រសួងទាំង ៥ នៃ របប «រដ្ឋកម្ពុជា» តែនៅក្នុងវិស័យ ដែលទាក់ទង នឹងការបោះឆ្នោតប៉ុណ្ណោះ ។ ចំពោះការទុកស្តុកអាវុធ ( stocks d'armes) របប «រដ្ឋកម្ពុជា» ស្នើសុំឲ្យភាគី នីមួយៗ រក្សា និង ទុកអាវុធ របស់គេ ក្រោមការត្រួតពិនិត្យ របស់ អង្គការ «អាប្រូនុច» សិនទម្រាំ មាន រដ្ឋាភិបាលមួយ ក្រោយការបោះឆ្នោត ។ នៅក្នុង អនុស្សរណៈនោះ របប

ប្រជាធិបតេយ្យ» (G.C.K..D.) ។ គឺជារដ្ឋាភិបាល ក្រៅប្រទេស ដែលមានក្រុមខ្មែរក្រហម ក្រុមរណសិរ្សជាតិ រំដោះពលរដ្ឋខ្មែរ ដឹកនាំដោយ លោក សឺន សាន និង ក្រុម អ្នកសីហនុនិយម ចូលរួម ។ នៅថ្ងៃ ៣ កុម្ភៈឆ្នាំ ១៩៩០ រដ្ឋាភិ បាលចម្រុះក្រៅប្រទេសនេះ ប្តូរឈ្មោះ មកជា «រដ្ឋាភិបាលជាតិ នៃ ប្រទេសកម្ពុជា» វិញ ។

«រដ្ឋកម្ពុជា» គឺ របប ហេង សំរិន-ហ៊ុន សែន ក៏បាន ស្នើសុំផងដែរ ឲ្យវត្តមាន របស់ អង្គការ សហប្រជាជាតិ នៅកម្ពុជា មាន ថេរវេលាតែ ៩ ខែ ប៉ុណ្ណោះ ក្រោយការចុះហត្ថលេខា នៃ កិច្ចព្រមព្រៀង ។

ដើម្បី កុំឲ្យការអនុវត្តន៍ ផែនការក្របខ័ណ្ឌ រាំងស្ទះ ប្រទេសមហាអំណាចទាំង ៥ នៃ ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហប្រជាជាតិ បានបើក អង្គប្រជុំមួយទៀត នៅថ្ងៃ ២៥ និង ២៦ វិច្ឆិកា នៅទីក្រុងប៉ារីស៍ ។ អង្គប្រជុំ បានធ្វើការលំអិតថែមទៀត អំពី ការដោះស្រាយ ទំនាស់នយោបាយ ទូទៅ ដោយរក្សាខ្ជាប់នូវមូលដ្ឋាន នៃផែនការក្របខ័ណ្ឌ ដែលបានត្រូវកំណត់ នៅថ្ងៃ ២៨ សីហា។ បញ្ហាដកអាវុធ បញ្ហាការបោះឆ្នោត និង បញ្ហាស្តី ពីទំនាក់ទំនង រវាងក្រុមប្រឹក្សាជាតិ ជាន់ខ្ពស់ និង អង្គការ«អាប្រូនុច» ក៏បានត្រូវលំអិតបន្ថែមដែរ ។ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏ របប ហេង សំរិន-ហ៊ុន សែន នៅតែមិនយល់ស្របដែរ។ នៅពេលនោះ គេសង្កេតឃើញថា ប្រទេសវៀតណាម ក៏ មិនយល់ស្របដូចរបប ហេង សំរិន ដែរ ជាពិសេសត្រង់ចំណុចព្រមព្រៀងគ្នាមួយ ស្តី ពីការត្រូវ រំលាយ របប «រដ្ឋកម្ពុជា» មុនការបោះឆ្នោត ។ អស់រយៈ ពេល ជាច្រើនខែ របប ហេង សំរិន - ហ៊ុន សែន ខិតខំពង្រឹងទីតាំងរបស់គេ ដោយទាមទារ មិនឲ្យគេ ដកហូត អាវុធ ពី កងទ័ព របស់ ខ្លួន មុនការបោះឆ្នោត ហើយ មិនព្រមឲ្យអង្គការ សហប្រជាជាតិ ត្រួតពិនិត្យ ក្រសួងទាំង ៥ របស់ គេផងទៀត ដោយសំអាង ទៅលើ គោលការណ៏ អធិបតេយ្យ ។ ទន្ទឹមនោះ របប «រដ្ឋកម្ពុជា» ក៏ ទាមទារផងដែរ ឲ្យគេ បញ្ជូនពួកដឹកនាំ ខ្មែរក្រហម ខាង ប៉ុល ពត ទៅឲ្យតុលាការកាត់ទោស ពី បទប្រល័យ ពូជសាសន៍ គឺ មានន័យថា ត្រូវដកសមាសភាព ក្រុមនេះឲ្យចេញផុត ពី ការបោះ ឆ្នោត ។ នៅពេលដែល ទំនាស់នេះ ស្តែងចេញឡើង ពួកខ្មែរកុម្មុយនិស្ត ប្រកាន់គំនិត ចាស់ នាំគ្នាលើកឡើង អំពី គម្រោងការណ៍ ដ៏ចម្លែកមួយ គឺ ពួកគេចង់ឲ្យមាន សម្ព័ន្ធ ភាព រវាងជនកុម្មុយនិស្ត គាំទ្រដោយ ទីក្រុងប៉េកាំង និង ជនកុម្មុយនិស្ត គាំទ្រដោយ ទីក្រុងហាណូយ ។ គម្រោងការណ៍នេះ ដែលបានត្រូវរដ្ឋធានី ទាំងពីរនេះគាំទ្រ បាន ត្រូវ លោកហ៊ុន សែន រំលាយចោល អស់ទៅវិញ។





# ការប្រយុទ្ធគ្នា រវាង គូភាគីខ្មែរ បដិបក្ខ ក្រោយអង្គប្រជុំ ក្រុមប្រឹក្សាជាតិ ជាន់ខ្ពស់ នៅ ទីក្រុង ប៉ារីស៍ នាខែធ្នូ ឆ្នាំ ១៩៩០

## Lutte entre les factions rivales cambodgiennes après la réunion du CNS à Paris en décembre 1990

នៅថ្ងៃ ២១-២២ និង ២៣ ធ្នូ ឆ្នាំ ១៩៩០ សមាជិកក្រុមប្រឹក្សាជាតិ ជាន់ខ្ពស់ទាំង ១២ រូប បានមកចូលរួមប្រជុំនៅទីក្រុងប៉ារីស៍ ដោយមាន វត្តមាន នៃសហប្រធានទាំងពីរ នៃ សន្និសីទ ទីក្រុងប៉ារីស៍ និង អ្នកតំណាងអង្គការ សហប្រជាជាតិ រ៉ាហ្វីឌីន អាម៉េដ ។ នៅក្នុង អង្គប្រជុំនោះ សហប្រធានបារាំង បានខិតខំរុញច្រាន ឲ្យគូភាគីខ្មែរទាំង ៤ ស្រុះស្រួលមូលមតិគ្នា ដើម្បីកសាង សន្តិភាព និង សង្គមជាតិឡើងវិញ ដោយថ្លែងថា :បើ ខ្មែរគ្មាន ឆន្ទះខិតខំរកច្រកចេញនោះទេ សហគមន៍អន្តរជាតិ ក៏មិនអាចគិតគូរបញ្ហាខ្មែរ រហូតបានដែរ។ ខាងអ្នកតស៊ូ ទាំងបីក្រុម គេបានស្រុះស្រួលគ្នាទទួលយក ផែនការក្របខ័ណ្ឌ ទាំងស្រុង ប៉ុន្តែខាង «រដ្ឋកម្ពុជា» ដែលពុំបានសម្រេច នូវ គោលដៅ របស់គេ គេពុំពេញចិត្ត នឹង ផែនការនោះទេ ។ អ្នកតំណាង អង្គការសហប្រជាជាតិ បានចេញ កំណត់ហេតុ ក្រៅផ្លូវការមួយ បញ្ជាក់ថា : បញ្ហាដែលនៅសេសសល់ នឹង ត្រូវយក ទៅពិនិត្យ ស៊ីជម្រៅ នៅពេលក្រោយ ។ នៅពេលនោះ គឺ នៅ ពេលដែលអង្គប្រជុំ កំពុងតែប្រព្រឹត្តទៅ ស្រាប់តែលោក ហ៊ុន សែន អ្នកតំណាង «រដ្ឋកម្ពុជា» ខ្យល់គរ តែម្តង ហើយត្រូវគេដឹកទៅព្យាបាល ជាបន្ទាន់ នៅមន្ទីរពេទ្យ ។ សូមកត់សំគាល់ថា ផែនការក្របខ័ណ្ឌ មានទិសដៅមួយយ៉ាងច្បាស់ គឺផ្តាច់ប្រទេសកម្ពុជា ឲ្យចេញផុតស្រឡះ ពីបញ្ហាអន្តរជាតិ មានន័យថា បើខ្មែរដោះស្រាយ បញ្ហាខ្លួន មិនបានទេ គឺវាជា រឿង របស់ខ្មែរ សុទ្ធសាធ ។ បើ ផែនការនោះ ពុំទទួលស្គាល់ អត្តិភាព នៃ ពួកខ្មែរក្រហម

ទេនោះ ចិន ច្បាស់ ជាពុំសុខចិត្តឡើយ ហើយនៅក្នុងករណីនោះ ផែនការ សន្តិភាព ក៏ពុំអាចអនុវត្តបានដែរ។ អ្វីដែលគូភាគីខ្មែរ ត្រូវយល់ នៅពេលនោះ គឺថា ចាប់ពីពេលនោះតទៅ បើខ្មែរ រកប្រកបេញ ជាមួយគ្នាមិនឃើញទេ គឺមានតែការវាយគ្នារហូត ដល់ខ្សោះឈាមដាច់ខ្យល់ខ្លួនឯងតែម្ដង ហើយដោយប្រើមធ្យោបាយខ្លួនឯងផ្ទាល់។ ប្រទេសចិន គ្មានជម្រើសអ្វីទៀត ក្រៅពីជំរុញ ឲ្យខ្មែរក្រហមទទួល យកផែនការនោះទេ ព្រោះប្រទេសថៃ បានបិទច្រក មិនឲ្យ ចិនដឹកអាវុធ ទៅឲ្យខ្មែរក្រហមរួចទៅហើយ។ រីឯ ខាង «រដ្ឋកម្ពុជា» គឺ ជារបបមួយ ដែលអន្តរ ជាតិ ពុំអាចទទួលស្គាល់បានទេ បើយោងទៅតាមគោលការណ៍អន្តរជាតិ ។ និយាយមួយបែបទៀត ខាងខ្មែរក្រហមប៉ុល ពត និង ខាងខ្មែរក្រហម ហេង សំរិន ខាងណា ក៏ ត្រូវមតិ អន្តរជាតិ ថ្កោលទោស ដូចតែគ្នា ។ ម្ខាងត្រូវគេ ថ្កោលទោស ពីបទ ប្រល័យពូជសាសន៍ឯង ហើយម្ខាងទៀត កើតចេញពីការឈ្លានពាន របស់ កងទ័ពវៀតណាម ។

តាមការពិតទៅ ក្រៅពីក្រុមអ្នកប្រជាធិបតេយ្យ របស់ លោក សឺន សាន និង ក្រុមអ្នករាជានិយម ដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ គ្មានក្រុមណាមួយដែលគួរចេញមុខ នៅពេលបោះឆ្នោតទេ ក៏ប៉ុន្តែគេពុំអាចបំភ្លេចក្រុមកុម្មុយនិស្ត ទាំងពីរក្រុមនោះបានទេ ព្រោះជា ក្រុមដែលមាន កម្លាំងប្រយុទ្ធ ធំជាងគេផង ហើយដែលជាមូលដ្ឋាន នៃអធិករណ៍ខ្មែរទាំងមូលផង។ ទោះជាយ៉ាងណាក្ដី មានតែច្រកមួយ ប៉ុណ្ណោះសម្រាប់ឲ្យខ្មែរអាចចាប់ផ្ដើម កសាងប្រទេសសាជាថ្មី នោះ គឺការបោះឆ្នោត ដោយសេរី និង ប្រកបទៅ ដោយគតិយុត្តិធម៌ ។ ផែនការក្របខ័ណ្ឌ របស់ អង្គការ សហប្រជាជាតិ សង្កត់ ធ្ងន់ ទៅលើចំណុចនេះ ។ ដើម្បីអនុវត្តគោលការណ៍នេះ ដើម្បីលុបលាងកំហុសរបស់គេពីពេលមុន ប្រទេសមហាអំណាច ដែលធ្លាប់បានជាប់ពាក់ព័ន្ធក្នុងអធិករណ៍ខ្មែរ សុខចិត្តចាយប្រាក់ប្រមាណ ១ ពាន់ ៥០០លានដុល្លារ ដើម្បីរៀបចំ ការបោះឆ្នោត នៅកម្ពុជា។ នៅដើមឆ្នាំ ១៩៩១ ខ្មែរបន្តវាយគ្នា រប៉េះរប៉ោះទៀត ប៉ុន្តែ ម្ដងនេះ ដោយគ្មានជំនួយពីក្រៅ សង្គ្រាមក្នុងស្រុកនេះ ពុំមានទ្រង់ទ្រាយធំទេ ។ នៅចំពោះមុខ សភាពការណ៍នេះ ប្រទេសមហាអំណាចទាំងប្រាំ ធ្លាក់ទឹកចិត្តយ៉ាងខ្លាំង ។ មុនពេលដែលវៀត





ណាម និងចិន ខិតជិតគ្នាវិញ របប «រដ្ឋកម្ពុជា» ក៏ធ្វើ ការវាយលុក មួយ ដ៏ធំ ទៅលើកម្លាំងអ្នកតស៊ូ ។ ការវាយប្រហារនេះ ដែលបានប្រព្រឹត្តទៅ អស់រយៈពេល ៥ ខែ គឺពីខែមករា ដល់ខែឧសភា ពុំបានហុចនូវលទ្ធផល អ្វីទាំងអស់ ទោះបីខាងភាគី របប «រដ្ឋកម្ពុជា» ប្រើប្រាស់ ទ័ពរាប់ពាន់នាក់ ព្រមទាំងរថក្រោះ ឧត្តម្ភាគចក្រ និង យន្តហោះប្រដេញ ក្ដី ។

# សម្ដេច នរោត្តម សីហនុ ឯកោ ក្រុមខ្មែរក្រហម ខាង ប៉ុល ពត ហើយ ហុចដៃគោងលោក ហ៊ុន សែន វិញ

## Le prince Norodom Sihanouk tourne le dos aux Khmers rouges fidèles à Pol Pot et tend la main à Hun Sèn

ការប្រយុទ្ធក្រោយអង្គប្រជុំ ក្រុមប្រឹក្សាជាន់ខ្ពស់ នៅទីក្រុងប៉ារីស៍នាខែធ្នូឆ្នាំ ១៩៩០ រវាង កម្លាំង តស៊ូខ្មែរនឹងរបប «រដ្ឋកម្ពុជា» គាំទ្រដោយប្រទេសវៀតណាម បានបញ្ជាក់ឲ្យឃើញថា កងទ័ពខាង «រដ្ឋកម្ពុជា» មានប្រៀបជាង។ ជាការពិតហើយដែលថា ការវាយប្រហារ នៃ របបដែលកាន់អំណាចនៅទីក្រុងភ្នំពេញ ទៅលើកងទ័ពខ្មែរក្រហមខាងប៉ុលពត ពី ខែមករា ឆ្នាំ ១៩៩១ រហូតដល់ខែ ឧសភា ពុំបានយកទីតាំងណាមួយរបស់ ប៉ុល ពត បានជាស្ថាពរទេ គឺ ទាំង ស្វាយចេក ទាំង ថ្មពួក ទាំង ប៉ៃលិន ប៉ុន្តែកងកម្លាំងតស៊ូ ក៏គ្មានកម្លាំង និង សម្ភារគ្រប់គ្រាន់ ដើម្បីវាយសម្រុកទៅលើ កងទ័ពនៃរបប «រដ្ឋកម្ពុជា» ដែរ ទោះបីត្រូវប្រើពេលវេលាយូរ ក៏ដោយ។ នៅចំពោះមុខ ស្ថានភាពទន់ខ្សោយនេះ របស់ កងទ័ព នៃកម្លាំងតស៊ូ លោក ហ៊ុន សែន រដ្ឋមន្ត្រីទី ១ នៃ របប «រដ្ឋកម្ពុជា» ក៏ឆ្លៀតពង្រឹងទីតាំង របស់លោក ក្នុងការចរចា គឺបង្ខំឲ្យ កងទ័ពតស៊ូ

ធ្វើសម្បទាន បន្ថែមទៀត។ ដើម្បីឲ្យ ការចរចា អាចចេញជាផ្លែផ្កា សហប្រធានទាំងពីរ នៃសន្និ សីទទីក្រុងប៉ារីស៍ និង អគ្គលេខាធិការ អង្គការ សហប្រជាជាតិ បានអំពាវនាវ ឲ្យមាន ការឈប់បាញ់គ្នា ចាប់តាំង ពីថ្ងៃ ១ ឧសភា ទៅទល់នឹង ការបញ្ចប់អង្គប្រជុំ ក្រុមប្រឹក្សាជាតិ ជាន់ខ្ពស់ នៅទីក្រុងយ៉ាការតា ។ ភាគីខ្មែរទាំង ៤ ក៏យល់ព្រម ហើយ ក៏ បញ្ជូនអ្នកតំណាង របស់គេរៀងៗខ្លួន ឲ្យទៅចូលរួមប្រជុំ នៅទីក្រុង យ៉ាកាតា នាថ្ងៃ ២ និង ថ្ងៃ ៤ មិថុនា ឆ្នាំ ១៩៩១ ដដែល ។ ធ្លៀតឱកាសនោះ សម្តេចនរោត្តម សីហនុ អ្នកដឹកនាំ ចលនាតស៊ូខ្មែរ បានស្នើឲ្យលោក ហ៊ុន សែន សុខចិត្តទទួលយល់ព្រម ការរៀបចំរចនាសម្ព័ន្ធក្រុមប្រឹក្សាជាតិឡើងវិញ ដោយតែងតាំងប្រធានមួយរូបគឺសម្តេច នរោត្តម សីហនុ និង អនុប្រធានមួយរូប គឺ លោក ហ៊ុន សែន ។ ប៉ុន្តែ ខ្មែរក្រហមខាង ប៉ុល ពត ពុំព្រមទទួលយកសំណើនេះទេ។ ទោះជាយ៉ាងនេះក្តី ក៏ខ្មែរក្រហម ខាង ប៉ុល ពត ពុំអាច បង្អាក់ដំណើរការរៀបចំ រចនាសម្ព័ន្ធ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ បានដែរ ហើយ ថែមទាំងផ្តាច់ខ្លួនគេ ចេញពី ក្រុមខ្មែរផ្សេងៗផងទៀត។ នៅពេលនោះ គេឃើញ យ៉ាងច្បាស់ថា មានកិច្ចព្រមព្រៀងមួយយ៉ាងមាំ រវាង សម្តេច នរោត្តម សីហនុ និង លោក ហ៊ុន សែន។ រីឯ យុទ្ធសាស្ត្រ គឺ នាំគូភាគីខ្មែរទាំង ៣ ទៀត ឲ្យបោះបង់ចោល ភាគី ខ្មែរក្រហម ខាង ប៉ុល ពត ។ នៅថ្ងៃ ៤ មិថុនា គឺមួយថ្ងៃក្រោយ អង្គប្រជុំ នៅ យ៉ាកាតា មានការប្រយុទ្ធគ្នាមួយ យ៉ាងធំ នៅជុំវិញតំបន់ ប៉ៃលិន ។

នៅថ្ងៃ ៦ មិថុនា ឆ្នាំ ១៩៩១ សម្តេច នរោត្តម សីហនុ ត្រៀមលក្ខណៈជាស្រេច យាងទៅទីក្រុងភ្នំពេញ ដើម្បីទៅ តាំងទី ក្រុមប្រឹក្សាជាតិ ជាន់ខ្ពស់ នៅក្នុងរដ្ឋធានីខ្មែរ។ ដោយអ្វីៗ ក៏វិវត្ត ទៅរកការបញ្ចប់សង្គ្រាម ហើយ ដោយចិន និងវៀតណាម កំពុងខិត ចាប់ដៃគ្នា សាជាថ្មីទៀត លោក ឆង់ ជី ចេន រដ្ឋមន្ត្រី ការបរទេសចិន ក៏បញ្ចេញ ការរិះគន់យ៉ាងខ្លាំងចំពោះ ឥរិយាបថ របស់ ខ្មែរក្រហម ដែលជាសម្ព័ន្ធមិត្ត ជាប្រពៃណី របស់ខ្លួន ។ គឺ នៅពេលនោះ ហើយ ដែល ទីក្រុងប៉េកាំង បែរទៅរក លោក ហ៊ុន សែន តែម្តង។ ពីរសប្តាហ៍ បន្ទាប់ ពីអង្គប្រជុំ ក្រុមប្រឹក្សាជាតិ ជាន់ខ្ពស់នៅ ប៉ាតាយ៉ា ប្រទេសថៃ នាថ្ងៃ ២៤-២៦ មិថុនា គឺ អង្គប្រជុំលើកដំបូងបង្អស់ ដែលស្ថិតនៅក្រោម





អធិបតីភាព របស់ សម្តេចនរោត្តម សីហនុ / ប្រទេសចិន បានអញ្ជើញ លោក ហ៊ុន សែន ឲ្យទៅធ្វើទស្សនកិច្ច ជាផ្លូវការមួយ នៅ ទីក្រុងប៉េកាំង ។ ទស្សនកិច្ចនោះ បាន ប្រព្រឹត្តទៅ មួយសប្តាហ៍ មុនអង្គប្រជុំ នៅប៉េកាំង រវាង ប្រទេសមហាអំណាចទាំង ៥ នៃ គណៈអចិន្ត្រៃយ៍ ក្រុមប្រឹក្សាសន្តិភាព នៃ អង្គការ សហប្រជាជាតិ គឺ អង្គប្រជុំ នា ថ្ងៃ ១៨ កក្កដា ហើយ បួនថ្ងៃ មុនអង្គប្រជុំក្រៅផ្លូវការ នៃ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ នៅ ក្នុងរដ្ឋធានី ចិន។ នៅក្នុងអង្គប្រជុំ គណៈអចិន្ត្រៃយ៍ ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហ ប្រជាជាតិនាថ្ងៃ ១៨ កក្កដា ក្រុមប្រឹក្សាសន្តិសុខ បានសម្រេចបញ្ជូន បេសកកម្ម មួយ ទៅទីក្រុងភ្នំពេញ តាម សេចក្តីស្នើសុំ របស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ។ យោងទៅតាម ការពិភាក្សា នៅក្នុងអង្គប្រជុំនោះ ៧០ ភាគរយ នៃ កម្លាំងកងទ័ព របស់ គូភាគីខ្មែរ នីមួយៗ ត្រូវរំសាយចោល។ នៅថ្ងៃ ១៩ កក្កដា សមាគម ប្រទេសអាស៊ីអាគ្នេយ៍ ហៅ អាស៊ាន បានទទួលស្គាល់ ក្រុមប្រឹក្សាជាតិ ជាន់ខ្ពស់ ហើយនៅថ្ងៃ ២០ និង ២១ កក្កដា សម្តេច នរោត្តម សីហនុ និង លោក ហ៊ុន សែន ទៅធ្វើទស្សនកិច្ច ជាផ្លូវការនៅ ប្រទេសកូរ៉េខាងជើង។ នៅថ្ងៃ ២២-២៣ និង ២៤ កក្កដា ប្រទេសចិន បានទទួល លោក ហ៊ុន សែន យ៉ាងអធិកអធម នៅក្នុងក្របខ័ណ្ឌ នៃ ទស្សនកិច្ចជាផ្លូវការមួយ ។

## ការវិលមកវិញ នៃ អ្នកដឹកនាំចាស់ មកក្នុងបរិបទ នយោបាយ ថ្មី៖ ការកាត់បន្ថយ ឥទ្ធិពល អ្នកប្រជាធិបតេយ្យ និង អ្នករាជានិយម ដើម្បីទុកផ្លូវឲ្យ អតីតក្រុមកុម្មុយនិស្ត

## Le retour des anciens dirigeants dans le nouveau contexte politique : la mise au rancart des démocrates et des royalistes au profit des ex-communistes

ក្រោយអង្គប្រជុំ នៃ ប្រទេស មហាអំណាចទាំង ៥ នៃគណៈ អចិន្ត្រៃយ៍ ក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិ នៅទីក្រុងប៉េកាំង នាថ្ងៃ ១៨ កក្កដាឆ្នាំ ១៩៩១ អភិក្រមសន្តិភាព នៅប្រទេសកម្ពុជា បានចាប់ផ្តើមចេញជារូបរៀង។ ភាគីខ្មែរ នីមួយៗ បានសុខចិត្តរំសាយ ៧០ ភាគរយ នៃ ចំនួនកងទ័ព របស់គេ ។ អង្គការ សហប្រជាជាតិ ត្រៀមលក្ខណៈជាស្រេច ដើម្បីបញ្ជូន បេសកជន របស់គេ ទៅទីក្រុងភ្នំពេញ។ បណ្តាប្រទេស នៃសមាគម ប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅ អា ស៊ាន បានទទួលស្គាល់ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ខ្មែរនៅថ្ងៃ ១៩ កក្កដា ។ នៅពេលដែល លោក ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរបប ហេង សំរិន ធ្វើទស្សនកិច្ច ជាផ្លូវការ នៅប្រទេសចិន ប្រជាមានិត្ត នៅទីស្នាក់ការ អង្គការ សហប្រជាជាតិ ឯនោះ វិញ ទង់ជាតិខ្មែរ បានត្រូវផ្លាស់ប្តូរ។ សញ្ញាប្រាសាទកំពូល ៣ ដែលមាន នៅក្នុង ទង់ជាតិ ជំនាន់ របប សីហនុ របប លន់ នល់ និងរបបខ្មែរ ក្រហមបានត្រូវយកមកដាក់ជំនួស សញ្ញាប្រាសាទកំពូលប្រាំ នៃ ទង់ជាតិ នៃ របប ហេង សំរិន។ ទោះជាយ៉ាងនេះ ក៏ដោយ ក៏សហរដ្ឋ អាមេរិក នៅមានការបារម្ភខ្លាំងដែរ អំពី ការដែលអ្នកដឹកនាំធំៗ ជាប្រវត្តិសាស្ត្រ ដែលមានចិនជាបង្អែក ហើយ ដែលបានជួយ របប ប៉ុល ពត ឲ្យវាយ រំលំរបប «សាធារណរដ្ឋខ្មែរ» បានក្លាយទៅជាអ្នកដឹកនាំ ប្រទេសកម្ពុជា សាជាថ្មីទៀត។ និយាយឲ្យចំ គឺការវិលមកវិញ នៃ អ្នកដឹកនាំ នៃ របបចាស់ កាលជំនាន់កុម្មុយនិស្ត។ រីឯអ្នកប្រកាន់និន្នាការប្រជាធិបតេយ្យ និង អ្នកសាធារណរដ្ឋនិយម តាមបែប បស្ចិមប្រទេស ដែលនៅពេលនោះ មានលោក សឺន សាន ជាអ្នកតំណាង ក៏ពុំសូវមានកម្លាំងខ្លាំងក្លា ប៉ុន្មានទៅទៀត ទោះបី តាមការពិត គឺ ជាវេន របស់ ពួកគេក្តី បន្ទាប់ពី របបខ្មែរក្រហម បានត្រូវមតិអន្តរជាតិ ថ្កោលទោសយ៉ាងពេញទំហឹង។ គេអាចនិយាយបានថា គឺ ជាការវិលមកវិញ





នៃ អ្នកប្រឆាំង នឹងសហរដ្ឋ អាមេរិក កាលពីសម័យសង្គ្រាមឥណ្ឌូចិនលើកទី ២។ រីឯព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ប្រធាន ចលនារាជានិយម «ហ៊្វុនស៊ីនប៉ិច» (F.U.N. C.I.N.P.E.C.) ក៏ស្ថិតនៅក្រោមឃ្នាប របស់ អ្នកអតីតកុម្មុយនិស្តទៀត។ អ្វីដែលគេ អាចដោះស្រាយបាន នៅចំពោះមុខ គឺ ការឈានទៅរក ការឯកោពួកខ្មែរក្រហម ខាង ប៉ុល ពត តែប៉ុណ្ណោះ។ ការចាប់ដៃ រវាង សម្តេច នរោត្តម សីហនុ និង លោក ហ៊ុន សែន គឺជា ផលិតផល នៃការជានាគ្នាវិញ រវាង ទីក្រុងប៉េកាំង នឹង ទីក្រុងហាណូយ ដែលទើបនឹង បាត់បង្អែកមួយដ៏ធំ បន្ទាប់ពី សហភាព សូវៀតរលំរលាយបាត់ទៅ ។ នៅចំពោះមុខស្ថានភាពនេះ ទីក្រុងវ៉ាស៊ីងតោន បានបញ្ជាក់ នៅថ្ងៃ ២៤ កក្កដា ឆ្នាំ ១៩៩១ ដូច្នេះថា : ការដោះស្រាយ វិបត្តិខ្មែរ គឺ បានតែមួយភាគប៉ុណ្ណោះ ។ ដូចនេះ អ្វីដែលគេត្រូវ មានការប្រុងប្រយ័ត្នខ្ពស់ គឺធ្វើយ៉ាង ណាឲ្យការបោះឆ្នោត អាចប្រព្រឹត្តទៅ ដោយត្រឹមត្រូវ។ រីឯការពិត គឺថា នៅពេលបោះឆ្នោត ឆ្នាំ ១៩៩៣ គណបក្សរាជានិយម ក្រោមការដឹកនាំ របស់ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ បានទទួលជ័យជំនះ ក៏ពិតមែន ប៉ុន្តែ ពុំមានកម្លាំងគ្រប់គ្រាន់  ដើម្បីធ្វើការទប់ទល់ នឹង អតីតអ្នកដឹកនាំខ្មែរ ដែលមានការគាំទ្រ ពីប្រទេសកុម្មុយនិស្ត ទាំងពីរ នៅក្នុងតំបន់ ។

នៅពេលដែល ប្រទេសកុម្មុយនិស្ត ទាំងពីរ នៅក្នុងតំបន់ បានខិតជិតគ្នាសាជាថ្មីទៀតហើយ នៅពេលដែលគេខិតខំផ្សះផ្សា អ្នកនយោបាយខ្មែរឡើងវិញ ក្នុងគោលដៅពង្រីង ឥទ្ធិពល របស់គេ នៅឥណ្ឌូចិនឡើងវិញ ដើម្បីប្រឈមមុខ នឹង ការវិលមកវិញតាមគ្រប់រូបភាព នៃ លទ្ធិប្រជាធិបតេយ្យ តាមបែបបទ បស្ចិមប្រទេស «បក្សប្រជាជនបដិវត្ត កម្ពុជា» (Parti du peuple révolutionnaire du Kampuchea) ក៏ បានប្តូរឈ្មោះមកត្រឹម «បក្សប្រជាជន» (Parti du peuple du Kampuchea) វិញ គឺ បក្សកុម្មុយនិស្តខ្មែរដែលបានត្រូវសម្តេច នរោត្តម សីហនុ បិទបោលនៅឆ្នាំ ១៩៦២។ «បក្សប្រជា ជនបដិវត្តកម្ពុជា» នោះ បានត្រូវ ប៉ុល ពត ប្រែឈ្មោះ មកជា «បក្សពលករកម្ពុជា» នៅឆ្នាំ ១៩៦០ ហើយក្រោយមក នៅខែកញ្ញាឆ្នាំ ១៩៦៦ ប្រែឈ្មោះជា «បក្សកុម្មុយនិស្តកម្ពុជា» តែម្តង (Parti communiste du Kampuchea) ។ ក្រោយពេល

ដែលប្រទេសវៀតណាម លើកទ័ព ចូលមក ក្នុងស្រុកខ្មែរ វាយរំលំ របប ប៉ុល ពត នៅខែមករាឆ្នាំ ១៩៧៩ «បក្សកុម្មុយនិស្តកម្ពុជា» របស់ ប៉ុល ពត ដែលដើមឡើយ បេញមកពី «បក្សប្រជាជនបដិវត្ត កម្ពុជា» បានប្រែឈ្មោះមក ជាឈ្មោះដើមវិញ គឺ «បក្សប្រជាជនបដិវត្តកម្ពុជា» ។ ប៉ុន្តែ នៅពេលដែល ចលនា កុម្មុយនិស្ត នៅក្នុងតំបន់ ប្រែប្រួលយុទ្ធសាស្ត្រ របស់គេ ដើម្បីសម្របទៅតាម ស្ថានការណ៍ នាឆ្នាំ ១៩៩០ បក្សនេះ បានប្តូរឈ្មោះមកជា «បក្សប្រជាជន »។ ទោះបីលោក ហ៊ុន សែន មាន តួនាទី ជា អនុប្រធាន នៃ «បក្សប្រជាជន» នេះ ក្តី ក៏ តាមការពិត បក្សនេះ មានតែឈ្មោះ ប៉ុណ្ណោះ ព្រោះលោក ហ៊ុន សែន ជាមនុស្សខ្លាំងតែម្នាក់គត់ នៅក្នុងបក្សនេះ។ លោក ជា ស៊ីម ដែលបានត្រូវតែងតាំងជា ប្រធានបក្ស ជំនួសលោក ហេង សំរិន ក៏គ្មាន តួនាទី សំខាន់អ្វីដែរ ព្រោះលោក ហ៊ុន សែន បានបង្កើត របនាសម្ព័ន្ធ មួយទៀត គ្រប ដណ្តប់ ពីលើបាត់ទៅហើយ។ នៅក្នុងបរិបទ នៃ ការជានាគ្នា រវាង ទីក្រុងប៉េកាំង នឹង ទីក្រុងហាណូយនេះ លោក ហ៊ុន សែន មានភារកិច្ច ចាប់ដៃ សម្តេច នរោត្តម សីហនុ ជាចាំបាច់ ដើម្បីរាំងស្កាត់ កុំឲ្យអ្នកប្រជាធិបតេយ្យ ដែលមាន និន្នាការ និយមបស្ចិម លោក អាចវិល មកកាន់អំណាច បានវិញ ។

## ឆ្ពោះទៅរក ការបញ្ចប់ អធិករណ៍ ខ្មែរ ដោយរក្សាទុក នូវ មាគ៌ានយោបាយ ក្រៅប្រទេស មុនពេលសង្គ្រាម

## Vers la fin du conflit cambodgien et le retour à la politique extérieure des années 60





មួយសប្តាហ៍ ក្រោយអង្គប្រជុំ នៃ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ នៅ ប៉ាតាយ៉ា នាថ្ងៃ ២៦-២៩ សីហា ឆ្នាំ ១៩៩១ ប្រទេសចិនបានបញ្ជាក់ថា គេឈប់ផ្តល់ជំនួយ យោធា ទៅឲ្យខ្មែរក្រហមទៀតហើយ ប៉ុន្តែក្សាទុក ការផ្តល់ជំនួយ សេដ្ឋកិច្ច ដដែល។ កាសែត អាមេរិក វ៉ាស៊ីងតោន ប៉ុស្ត បានកត់សំគាល់ថា : ខ្មែរក្រហម នៅ ប៉ៃលិន លក់ត្បូង បាន ៣០០ លានដុល្លារ គ្រាន់តែក្នុងរយៈពេល ២ ឆ្នាំកន្លងមក។ នៅថ្ងៃ ១០ កញ្ញា រដ្ឋមន្ត្រីការបរទេសវៀតណាម និងរដ្ឋមន្ត្រីការបរទេសចិន បានជួបគ្នានៅទីក្រុងប៉េកាំង ដើម្បីនិយាយឲ្យបានច្បាស់ម្តងទៀត អំពីការដាក់ទំនាក់ទំនងគ្នាជាប្រក្រតីឡើងវិញ រវាង ប្រទេសកុម្មុយនិស្តទាំងពីរ ហើយ សុខចិត្តទទួលយក ផែនការសន្តិភាព នៅកម្ពុជា ។ នៅពេលនោះ ប្រទេសកម្ពុជា បានទទួលរងគ្រោះ ដោយ ទឹកជំនន់មួយ ដ៏ធំ សម្បើម អស្ចារ្យ ជាហេតុបណ្តាលឲ្យមនុស្ស ១១០ នាក់ បាត់បង់ជីវិត ហើយ ៧០ ម៉ឺននាក់គ្មាន ជម្រក ។ រី ឯ ដំណាំស្រូវ ខូចខាតអស់ ប្រមាណ ១៤ ម៉ឺន ហិកតា ។ នៅពេលបើក អង្គប្រជុំ មហាសន្និបាត អង្គការ សហប្រជាជាតិ នៅទីក្រុង ញូវយ៉ក នាថ្ងៃ ១៦ កញ្ញា សម្តេច នរោត្តម សីហនុ ទ្រង់ បានជួបសន្ទនា ជាមួយលោក ហ៊ុន សែន។ អាសនៈ កម្ពុជា នៅអង្គការ សហប្រជាជាតិ បានត្រូវប្រគល់ទៅឲ្យក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ហើយរបៀបបោះឆ្នោត ដែលធ្វើឲ្យមាន ការខ្វែងគំនិតគ្នា នៅអង្គប្រជុំនៅប៉ាតាយ៉ា បាន ត្រូវ គូភាគីខ្មែរ សុខចិត្ត ស្រុះស្រួលគ្នា គឺ ការបោះឆ្នោត សមាមាត្រ នៅតាមខេត្ត នីមួយៗ។ នៅទីក្រុងញូវយ៉ក នោះដែរ សម្តេច នរោត្តម សីហនុ បានជួបសន្ទនាជាមួយ លោក ប្រធានាធិបតី អាមេរិក យ៉ក ប៊ូស[២៩] (George Herbert Walker Bush) ។ ការសន្ទនាគ្នាផ្តោត ជាពិសេសទៅលើ ខ្មែរក្រហម គឺ អ្នកដឹកនាំ របប «កម្ពុជាប្រជាធិបតេយ្យ» កន្លងមក។ លោក យ៉ក ប៊ូស បានសំដែងនៅពេលនោះ នូវការព្រួយបារម្ភ

[២៩] លោក យ៉ក ប៊ូស ឪពុក របស់លោក យ៉ក វ៉ល់គើ ប៊ូស ជាប្រធានាធិបតី សហរដ្ឋ អាមេរិក ពីឆ្នាំ ១៩៨៩ ដល់ឆ្នាំ ១៩៩៣ ។ កូនរបស់លោក គឺ លោក យ៉ក វ៉ល់គើ ប៊ូស ជា ប្រធានាធិបតី សហរដ្ឋ អាមេរិក ពី ឆ្នាំ ២០០១ ដល់ឆ្នាំ ២០០៩ ។

របស់លោក ខ្វាចក្រែង អ្នកទាំងនោះវិលមក កាន់អំណាចសាជាថ្មីទៀត។ ប៉ុន្តែ សម្តេច នរោត្តម សីហនុ ទ្រង់បានថ្លែងថា គឺ លោក ហ៊ុន សែន ទេ ដែល នឹង ឈ្នះនៅក្នុង ការបោះឆ្នោត។ នៅថ្ងៃ ១៧-១៨ តុលាឆ្នាំ ១៩៩១ ដដែលនោះ បក្ស «ប្រជាជន បដិវត្ត កម្ពុជា» បានបើក មហាសន្និបាត វិសាមញ្ញ របស់ ខ្លួន ។ នៅក្នុង ឱកាសនោះ បក្ស «ប្រជាជនបដិវត្តកម្ពុជា» ( P.P.R.K.) បានកំណត់ កម្មវិធីថ្មី របស់គេ ហើយ ប្តូរឈ្មោះ មកជា «បក្សប្រជាជនកម្ពុជា» (P.P.C.) សព្វថ្ងៃនេះ។ បក្សកុម្មុយនិស្តខ្មែរនេះ បាន សម្រេច បោះបង់ចោល គោលការណ៍ សមូហភាពនិយម ហើយ កំណត់យក គោល ការណ៍ ពហុបក្ស និង សេដ្ឋកិច្ចផ្សារវិញ ព្រមទាំងគោលការណ៍ គោរព សទ្ធិមនុស្ស ផងទៀត។ នៅថ្ងៃ ២៣ តុលា បន្ទាប់ ពីក្រុមប្រឹក្សា សន្តិសុខអង្គការ សហប្រជា ជាតិ បានបង្កើត ក្រុមអន្តរាគមន៍ «មីប្រេនុច» (M.I.P.R.E.N.U.C.)[៣០] សន្និសីទ អន្តរជាតិមួយ បានប្រព្រឹត្តទៅ នៅទីក្រុងប៉ារីស៍ដើម្បី ឈានទៅដល់ កិច្ចព្រមព្រៀង នយោបាយ ជាសរុបមួយ សម្រាប់បញ្ចប់ អធិករណ៍ នៅកម្ពុជា ។ អ្នកតំណាងរដ្ឋាភិ បាល ប្រទេស ចំនួន ១៨ និងសមាជិក នៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ តំណាងអធិប តេយ្យប្រទេស កម្ពុជា បានចុះហត្ថលេខា ទៅលើ កិច្ចព្រមព្រៀងនោះ ។

នៅថ្ងៃ ១១ វិច្ឆិកា លោក ហ៊ុន សែន បានអញ្ជើញ ទៅទីក្រុងប៉េកាំង ដើម្បី យាងសម្តេច នរោត្តម សីហនុ មកភ្នំពេញ។ អតីតអ្នកដឹកនាំខ្មែរ សម័យឆ្នាំ ១៩៤១ - ១៩៧០ នេះ បានត្រឡប់មកមាតុភូមិវិញ នៅថ្ងៃ ១៦ វិច្ឆិកា។ សម្តេច នរោត្តម សីហនុ ប្រធាន នៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់ បានថ្លែង សន្ទរកថាមួយ នៅចំពោះមុខ ប្រជាជន ខ្មែរ ថ្កោលទោស ការឈ្លានពាន របស់ ប្រទេសវៀតណាម យ៉ាងខ្លាំង ប៉ុន្តែព្រះអង្គ ក៏ ទ្រង់បានកត់សំគាល់ផងដែរថា បើគ្មានវៀតណាមទេ យើងទាំងអស់គ្នា ក៏ពុំមានជីវិត រស់នៅ មកទល់សព្វថ្ងៃនេះដែរ។ សម្តេច នរោត្តម សីហនុ ទ្រង់បានបញ្ចេញឲ្យដឹង

[៣០] Mission préparatoire des Nations unies au Cambodge : បេសកកម្ម របស់ អង្គការ សហប្រជាជាតិ ត្រៀមលក្ខណៈ ធ្វើអន្តរាគមន៍ នៅ កម្ពុជា ។





ផងដែរថា ព្រះអង្គមិនយល់ទាស់ នឹង ការយកអ្នកដឹកនាំខ្មែរក្រហម ទៅកាត់ទោសទេ។ ចំពោះអ្នកដឹកនាំថ្មីព្រះអង្គទ្រង់បានលើកឡើងថា ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិប្រធាន គណបក្សរាជានិយម «ហ្វុនស៊ិនប៉ិច» និង លោក ហ៊ុន សែន ជាកូន របស់ ព្រះអង្គ ។ មួយសប្តាហ៍ក្រោយមក នៅពេលដែលគណប្រតិភូខ្មែរក្រហម ដឹកនាំដោយលោក សុន សេន មកដល់ ទីក្រុងភ្នំពេញ លោក ហ៊ុន សែន បានថ្លែង នៅក្នុងសន្និសីទកាសែត មួយថា : លោក ពុំយល់ទាស់ នឹងការផ្តល់ទៅឲ្យប្រទេសកម្ពុជា នូវ របបរាជានិយម មួយទេ។ លោកបានអះអាងថា : គណបក្ស «ហ្វុនស៊ិនប៉ិច» និង គណបក្ស «ប្រជា ជន» មានគោលដៅដូចគ្នា។ គឺនៅពេលនោះហើយ ដែលរដ្ឋមន្ត្រី ការបរទេសថៃ បាន ប្រាប់ឲ្យដឹងថា ប៉ុល ពត បានចាកចេញពី ត្រាត ទៅតាំងទី នៅក្នុងទឹកដីខ្មែរវិញ ។ ចំពោះការដែលលោក ហ៊ុន សែន បានថ្លែងថា គណបក្ស «ហ្វុនស៊ិនប៉ិច» និង គណ បក្ស «ប្រជាជន» មានគោលដៅដូចគ្នា គឺ ជាការបញ្ជាក់ទុកជាមុនថា បក្សរាជានិយម និង អតីតបក្សកុម្មុយនិស្ត ត្រូវដើរផ្លូវតែមួយ គឺ ត្រូវទប់ទល់ នឹង អ្នកប្រជាធិបតេយ្យ សេរីនិយម ដែលអាចមាននយោបាយក្រៅប្រទេសខុសពី ការគ្រោងទុក ឬ ការសង្ឃឹម របស់ អ្នកនយោបាយ ដែលបានជ្រើសរើសយក ប្រទេសចិន និង ប្រទេសវៀតណាម កុម្មុយនិស្ត ធ្វើជាសម្ព័ន្ធមិត្រ។ នៅថ្ងៃ ២០ វិច្ឆិកាឆ្នាំ ១៩៩១ ដដែលនោះបក្សប្រជាជន និងរដ្ឋាភិបាល របប «រដ្ឋកម្ពុជា» បានចេញផ្សាយសេចក្តីថ្លែងការណ៍មួយថ្កោលទោស យ៉ាងខ្លាំង ដល់អ្វីដែលអ្នកទាំងនោះ ហៅថា «រដ្ឋប្រហារ» ថ្ងៃ ១៨ មិនាឆ្នាំ ១៩៧០ ហើយទទួលស្គាល់ សម្តេច នរោត្តម សីហនុ ជាព្រះប្រមុខរដ្ឋ នៃ ប្រទេសកម្ពុជា ។

# អ្នកស្អប់សេរីភាព

# Les ennemis de la liberté

# ការគាបសង្កត់ ទៅលើ សេរីភាព បុគ្គល និង ការកំណត់ ព្រំដែន របស់វា នៅក្នុងសង្គម

អ្នកដែលស្អប់សេរីភាព មិនមែនត្រឹមតែជា អ្នកដែលកាន់អំណាចផ្ដាច់ការប៉ុណ្ណោះទេ តែជាជនគ្រប់រូប ដែលមិនព្រមទទួលស្គាល់ មិត្តិអ្នកដទៃ ហើយ ដែលពុំជឿថា អ្នកឯទៀតអាចរស់នៅ ឬ អាចធ្វើអ្វីមួយ ដោយគ្មានខ្លួន ។ អ្នកដែលយល់ថា ការពិតមានតែមួយ ព្រមទាំងអ្នកដែលយល់ថា ជីវិតរបស់បុគ្គលម្នាក់ៗ មានអ្នកគ្រប់គ្រង មានអ្នកថែរក្សាខ្លួន ហើយ មានជំនឿផ្ដាច់មុខ ទៅលើអ្នកទាំងនោះ ក៏ជា អ្នកដែលមិនស្រឡាញ់សេរីភាពដែរ ។ សេរីភាព ក្នុងការគិតជាមូលដ្ឋាន នៃសេចក្ដី ថ្លៃថ្នូរ របស់មនុស្ស ហើយជាកត្តា នៃការរំដោះខ្លួនចេញពីអ្វីៗ ដែលគេកំហិតឲ្យធ្វើ ឲ្យយល់តាមដោយងងឹតងងល់ គ្មានលក្ខណៈវិទ្យាសាស្ត្រ ជាពិសេស ជាការរំដោះខ្លួន ចេញពី ទាសភាព ។ អ្នកដែលស្រឡាញ់ សេរីភាពពិតប្រាកដ គឺ ជាអ្នកដែលហ៊ានធ្វើអ្វីមួយ តែហ៊ានទទួលខុសត្រូវ នៃអំពើរបស់ខ្លួន។ អ្នកនិពន្ធអ៊ីតាលីម្នាក់ឈ្មោះ អាល់ប៊ែរតូ ម៉ូរ៉ាវិយ៉ា (Alberto Moravia, ១៩០៧-១៩៩០) បានពន្យល់តាម រយៈប្រលោមលោក *La Noia (L'Ennui)* ដូច្នេះថា ៖ ជា ការភ័ន្តច្រឡំមួយ ដ៏ធំ កាលបើគេយល់ថា គេអាចក្ដាប់មនុស្សម្នាក់ ឬ របស់ អ្វីមួយបានរហូតនោះ ។ គេមិនអាចបង្រួម សេរីភាព មកត្រឹម ការមានលុយកាក់ សំរាប់ស៊ីចាយ ប៉ុណ្ណោះទេ ព្រោះអ្នកណា ក៏មាន សិទ្ធិប្រណាំងប្រជែង គ្រប់បែបយ៉ាងដែរ ។ សាមគ្គីភាព ជាកម្លាំងរួម សំរាប់ទប់ទល់ នឹង ស្ថានការណ៍ ដែលនាំមក នូវ គ្រោះថ្នាក់ចំពោះសង្គម ឬ មនុស្សជាតិទាំងមូល ប៉ុន្តែមិនអាចយកទៅ បម្រើប្រយោជន៍ របស់មនុស្សមួយក្រុមតូចបានឡើយ។ ដូចនេះ គេត្រូវពិនិត្យ អ្វីដែលគេហៅថា គ្រោះថ្នាក់នោះឲ្យបានត្រឹម ត្រូវសិន មុននឹងចូលរួមគ្នាធ្វើអ្វីមួយ ព្រោះថា អ្នកនយោបាយខ្លះបង្កើត ឲ្យមានគ្រោះថ្នាក់អ្វីមួយ ដើម្បីអាចឆ្លៀតយកឱកាសសម្រាប់ខ្លួន និង បក្សពួកខ្លួន តាមរយៈសាមគ្គីភាពមួយ ដែលគេចង់បាន ដើម្បីធ្វើអ្វីមួយ សម្រាប់គេ ។ សេរីភាពពិតប្រាកដ





គឺការស្វែងរកការពិត ឲ្យបានច្រើនបំផុត ជាពិសេស ការយល់ដឹង អំពី ពិភពលោក អំពីចក្រវាឡ តាមការចេះដឹង វិទ្យាសាស្ត្រ ។ តើចក្រវាឡជាអ្វី ? នៅក្នុងសៀវភៅ មួយ របស់ ប្រាយយ៉ាន់ គ្រីន មានចំណងជើងថា *The Elegant universe, 1999* (*L'Univers élégant* de Brian Green, Ed. Robert Laffont, 2000, Poche 2005) គេដឹងយ៉ាងច្បាស់ថា បើទ្រឹស្ដី យន្តកម្ម គ័ងទិក (Dynamique quantique) និង ទ្រឹស្ដី Théorie de la relativité générale របស់ អាល់ប៊ែរ អាញស្តាញ (Albert Einstein) ចូលគ្នាបាន គេនឹងអាចរកដើមកំណើត នៃ ចក្រវាឡឃើញ យ៉ាងច្បាស់។ បច្ចុប្បន្ននេះ តាមរយៈទ្រឹស្ដី Théorie des cordes គេមានសង្ឃឹមថា សេចក្ដីប៉ងប្រាថ្នា របស់ Einstein និង បានសម្រេច ។ នៅឆ្នាំ ១៥៤៣ សតវត្សទី ១៦ អ្នកប្រាជ្ញ វិទ្យាសាស្ត្រ ប៉ូឡូញ (ឬអល្លឺម៉ង់ ក៏អាចថាបាន) កូពែរនិច (Copernic, ១៤៧៣-១៥៤៣) បានរកឃើញថា ផែនដី វិលជុំវិញខ្លួនឯង និង ជុំវិញព្រះអាទិត្យ។

ពាក្យ «សេរីភាព» មានន័យ ដ៏ទូលំទូលាយ រីឯការកំណត់ វិសាលភាព និង ព្រំដែន នៃ សកម្មភាព របស់ មនុស្សនៅក្នុងសង្គម ជាបញ្ហាមួយ ដ៏ស្មុគស្មាញ។ យោងទៅតាមន័យទស្សនវិជ្ជា សេរីភាពរបស់ មនុស្សម្នាក់ៗ គឺ ការគោរពឆន្ទៈផ្ទាល់ របស់គេ ហើយ មិនបណ្ដោយឲ្យសង្គម ឬអ្នកណាម្នាក់ទៀត គាបសង្កត់បាន ឬ ក៏ យកទៅប្រើ ដើម្បីប្រយោជន៍ផ្ទាល់ របស់ បុគ្គលណាម្នាក់ ឬ ក្រុមមនុស្ស ណាមួយ (បញ្ញត្តិ ស្ដីពី អ្នកជា និង ទាសករ) ។ រដ្ឋ មានភារកិច្ច ការពារសិទ្ធិ របស់ បុគ្គល ដែលមានកំណត់ នៅក្នុង កិច្ចសន្យាសង្គម ។ ប៉ុន្តែ ដើម្បីអាចធានាសេរីភាព របស់ អ្នកដទៃទៀតនៅក្នុងសង្គម គេក៏ត្រូវកំណត់ព្រំដែន របស់វា ជាកំហិតដែរ៖ សេរីភាព របស់ បុគ្គលម្នាក់ មិនត្រូវប៉ះពាល់ដល់សេរីភាព របស់អ្នកដទៃឡើយ។ បើតាមន័យមួយទៀត សេរីភាពរបស់ បុគ្គល គឺការចេះដឹង អំពី ក្រឹត្យក្រមជីវិត ក្រិត្យក្រម សង្គម ហើយមិនបណ្ដោយឲ្យតណ្ហា ឬ បហិច្ឆតា ញាំញីបាន ដោយឈរ នៅលើ មូលដ្ឋាន វិចារណញ្ញាណ និង សច្ចធម៌។ បើតាមទស្សនវិជ្ជា «ជីវិតនិយម» (existentialisme) មនុស្ស មានសេរីភាព តែងតែរក្សា ឧត្តមគតិថ្លៃថ្នូរ របស់គេ ប៉ុន្តែ ក៏ត្រូវទទួលខុសត្រូវ អំពើអំពើ របស់ខ្លួនដែរ («L'homme est condamné à être libre»)។ នៅក្នុងវិស័យនយោបាយ សេរីភាព គឺ

សេរីភាពនៅក្នុង ការបញ្ចេញមតិ និងការគោរព មិតិអ្នកដទៃ ។ រដ្ឋមានភារកិច្ច ការពារ សេរីភាពនេះ ជាកំហិត នៅក្នុងករណី ដែលសេរីភាពនោះ មានលក្ខណៈស្របច្បាប់ (រដ្ឋធម្មនុញ្ញ) ។ បើពុំនោះសោតទេ គឺជាអំណាចផ្តាច់ការ ដែលមិនអាចប្រកែកបាន (ការបំបាត់សិទ្ធិបញ្ចេញ មតិនៅក្នុងរដ្ឋកុម្មុយនិស្ត និង រដ្ឋយោធានិយម ព្រមទាំងរដ្ឋដែលនគរបាល ការពារ តែសិទ្ធិ របស់ រដ្ឋាភិបាល ដោយខុសច្បាប់) ។





# ជំពូក ១០

## មាយាគតិ នយោបាយ

## Les illusions politiques

មកទល់នឹងពេលបច្ចុប្បន្ននេះ ការតស៊ូដើម្បី សេរីភាព ពុំទាន់ចប់ សព្វគ្រប់ នៅឡើយទេ។ ដោយសំអាង ទៅលើមូលហេតុផ្សេងៗ ពួកអ្នកកាន់អំណាចផ្តាច់ការ នៅតែមាន អត្ថិភាព បន្តមកទៀត ។ ខ្វះបង្រួមសេចក្តីត្រូវការចាំបាច់ របស់មនុស្ស មកត្រឹម ការមានអាហារបរិភោគ ។ ប៉ុន្តែមនុស្ស ក៏ដូចជា សត្វដែលគ្មានការអប់រំផ្នែកសីលធម៌ ក៏នៅតែត្រូវការសេរីភាពដដែល។ ដូច្នេះឃើញថា នៅក្នុងសង្គម ដែលដឹកនាំដោយអ្នកកាន់អំណាចផ្តាច់ការ មនុស្សត្រូវគេបង្រួម មកត្រឹមសត្តនិករ អន់ថយ ជាងសត្វទៅទៀត។ មនុស្សតែងតែស្វែងរក ន័យ នៃ ជីវិតរបស់គេ ជានិច្ច ហើយតែងតែមានសេចក្តីប្រាថ្នាផ្សេងៗ ផងទៀត។ មនុស្សម្នាក់ៗ ចង់ចេញផុត ពីស្ថានភាពជីវិត ដែលគេពិបាករស់នៅ ឬដែលធ្វើឲ្យ គេអផ្សុកតប់ប្រមល់ ។ អ្នកគ្មានសេរីភាព ក្នុងសង្គម កុម្មុយនិស្ត ព្រមទាំងសង្គមផ្តាច់ការ ផ្សេងៗទៀត ចង់បានសេរីភាព របស់គេ មកវិញ។ អ្នកក្របង់មានប្រាក់កាសធូរធារ ហើយអ្នកមានខ្វះដែលធុញទ្រាន់ នឹងរបៀបរស់នៅ ឬ អំពើមិនល្អ នៃមជ្ឈដ្ឋាន របស់ពួកគេ បែរជាមាន ការធុញទ្រាន់ និង ស្អប់ខ្ពើមមជ្ឈដ្ឋាននោះទៅវិញ ហើយ តែងតែចង់ចេញឲ្យឆ្ងាយពីមជ្ឈដ្ឋាននោះ ទោះជា ត្រូវក្លាយទៅជា មនុស្សអនាថាក្តី។ មនុស្សខ្វះចង់ចេះហោះដូចសត្វស្លាប ហើយខ្វះទៀតចង់យល់ដឹង ពីឫសគល់ ឬ ព្រហ្មលិខិត របស់ ខ្លួន ។ មនុស្សជាសត្វដែល មានសេចក្តីប៉ងប្រាថ្នា (rêves et aspirations)។ នៅក្នុងន័យនេះ ការលុបបំបាត់ សិទ្ធិគិតពិចារណា និង ការដាក់ទោស

អ្នកដែលគិតរំដោះខ្លួនចេញពី ស្ថានភាព អាប់អួ ទាំងនោះរបស់គេ សុទ្ធតែជាអំពើប្រឆាំងនឹងមនុស្សទាំងអស់។ ជាការពិតហើយ ដែលថា សុបិនមិនមែននាំទៅរកភាពល្អប្រសើរទាំងអស់នោះទេ ដូចជាការចង់ក្លាយខ្លួនទៅជាអាទិទេពជាដើម ប៉ុន្តែ គឺ ជាសុបិនមួយដ៏ធំបើគេចង់ប្រែក្លាយមនុស្ស ឲ្យទៅជាសត្តនិករ ម៉្យាង ដែលមានលក្ខណៈអន់ថយជាងសត្វទៅទៀតនោះ។ គេអាចនិយាយបានថា សង្គ្រាម មានពីរយ៉ាង គឺ សង្គ្រាម ដើម្បីបង្រួមមនុស្ស មកឲ្យធ្វើត្រឹមទាសករ និង សង្គ្រាម ដើម្បីតាមទារ យកសេរីភាពមកវិញ ។ ក៏ប៉ុន្តែ សំនួរដែលគេអាចោទសួរ គឺថាហេតុដូចម្ដេច បានជាប្រជាពលរដ្ឋ នៃប្រទេសខ្លះពុំព្រមងើបឡើងបះបោរដេញអ្នកកាន់អំណាចផ្ដាច់ការ ចេញពីអំណាច? ការពិត គ្មានទេប្រទេសឬ ប្រជាជនបែបនោះ! គឺគ្រាន់តែជាការយល់ច្រឡំប៉ុណ្ណោះ ព្រោះថា សូម្បី តែសត្វ ក៏វាបម្រះចេញឲ្យផុត ពីក្រញាំដៃអ្នកដែលចង់បំបាត់ សេរីភាពរបស់វាដែរ។ យ៉ាងណាមិញ នៅក្នុងប្រវត្តិសាស្ត្រ ការស្វែងរកសេរីភាព និង យុត្តិធម៌ តែងតែមាន មិនដាច់ទន្ទឹមនឹងការសោកល្បង លុបបំបាត់សេរីភាពនោះ។ ដូច្នេះឃើញថា គឺគ្រាន់តែជា បញ្ហាពេលវេលាតែប៉ុណ្ណោះ ។ ក្រុមអ្នកដឹកនាំ របបផ្ដាច់ការខ្លះ បេះពន្យាពេល ដោយប្រើវិធីផ្សេងៗ ដូចជាការបំភាន់មិតិជាដើម ឬ ក៏ការបំបែរអារម្មណ៍ប្រជាជន ផ្ដោះទៅរកទិសដៅផ្សេងទៀត ហើយទន្ទឹមនោះ បន្ថយការបេះដឹង ជ្រៅជ្រះ មកត្រឹមអ្វីដែលគេឲ្យដឹងប៉ុណ្ណោះ និង លើកទឹកចិត្ត ឲ្យឈ្លក់វង្វេងក្នុង អំពើពាលា ការស្រឡាញ់ ទ្រព្យសម្បត្តិបុណ្យសក្តិ អំណាចលោកៗលៗ)។ ប៉ុន្តែ របស់ ទាំងអស់នេះ តែងតែ នាំមក នូវការលោភោទោសោ និង ការក្បត់គ្នា ដោយគេចពុំផុត ព្រោះ ជាមាគ៌ា ដែលមិនស្របនឹងគតិបណ្ឌិត ។ របបផ្ដាច់ការ ពុំសូវមានអាយុវែងទេ ហើយអ្នកស្លូតត្រង់ ក៏មិនមែនសុទ្ធតែត្រូវស្លាប់ផុតពូជ ទាំងអស់នោះដែរ ។ ជាការពិតណាស់ ដែលថា គេពុំអាចលុបបំបាត់ អំពើអាក្រក់បាន ជាស្ថាពរ ហើយការទាមទាររក យុត្តិធម៌ ក៏ចេញមក ពី សង្គមដែលគ្មានយុត្តិធមដែរ។ នៅក្នុងខ្លួនមនុស្សម្នាក់ៗ មានបដិវាទកម្ម រវាង ធាតុល្អ និងធាតុអាក្រក់ជានិច្ច ។ អំពើអាក្រក់ ពិបាកយកឈ្នះទៅលើ អំពើល្អបានណាស់ នៅក្នុងករណី ដែលមានការយុទ្ធតស៊ូមិនដាច់ រវាង អ្នកស្រឡាញ់ គោរព វិចារណញ្ញាណ និង





មនុស្សពាល ដែលគំរាមសង្គម ទាំងមូល ។ ទោះជាយ៉ាងណាក្ដី អ្នកតំណាងសភាវល្អត្រូវប្រើពេលយូរណាស់ ទើបបានឈ្នះ។ ប៉ុន្តែឈ្នះ អាចក្លាយជាចាញ់ បើអ្នកឈ្នះក្លាយទៅជាមនុស្សអាក្រក់។ នៅក្នុងរឿងភាមក្ករ៍ ពេលដែលព្រះលក្ខណ៍ ហៀបតែនឹងប្រល័យជីវិត ឥន្ទ្រជិត ស្រាប់តែពិភេកក បែរជាឃាត់ទៅវិញ ព្រោះត្រូវសុំច្បាប់ ពី ព្រះព្រហ្មសិន បើមិនដូច្នេះទេ ពិភពលោក នឹងរលាយសាបសូន្យមិនខាន។ មានតែការឈ្នះផ្លូវធម៌ប៉ុណ្ណោះ ដែលអាចឋិតថេរបាន។ អ្នកមាន សីលធម៌ល្អប្រសើរ ដែលយកធម៌បិសាច មកប្រើដើម្បីឈ្នះ ក៏មិនអាចចាត់ទុកថា ឈ្នះបានឡើយ ។ យ៉ាងណាមិញ គេសង្កេតឃើញថា អ្នកកាន់ធម៌បិសាចយកឈ្នះបាន ក៏ដោយសារយកធម៌ល្អ មកគ្របបិទបាំងដែរ។ គេកម្រឃើញ អ្នកកាន់ឥរិយាបថបិសាច យកឈ្នះ ដោយប្រកាសលើកតម្កើងអំពើ អាក្រក់ របស់គេណាស់ ។

ប្រវត្តិសាស្ត្រ ពោរពេញទៅដោយ ការប្រយុទ្ធ រវាង សភាវល្អ និងសភាវអាក្រក់។ រីឯ ព្រំខ័ណ្ឌ រវាង សភាវទាំងពីរនេះ បានត្រូវអ្នកនយោបាយ និង ទស្សនវិជ្ជាខ្លះ ធ្វើឲ្យមានលក្ខណៈស្រពេចស្រពិល។ នៅចុងសតវត្សរ៍ទី ១៩ និង ដើមសតវត្សរ៍ ទី ២០ ដោយមានការសង្ស័យថា គ្មានព្រះឯណា ជាអ្នកគ្រប់គ្រងពិភព លោកគេក៏ យល់ថា អ្នកណាតាំងខ្លួនធ្វើជាព្រះ ក៏បានដែរ។ តួអង្គម្នាក់នៅក្នុង ប្រលោមលោករបស់ អ្នកនិពន្ធរុស្ស៊ី ដុស្តូយយ៉េវស្គី (Dostoïevski, ១៨២១-១៨៨១) បាននិយាយដូច្នេះថា ៖ «Si Dieu est mort, alors les hommes seront des dieux les uns pour les autres» ។ នៅ សតវត្សរ៍ ទី ១៩ ទស្សនវិទូ នីត្ស (Friedrich Nietzsche, ១៨៤៤-១៩០០) យល់ឃើញថា៖ សីលធម៌ ជាអាវុធ របស់អ្នកខ្សោយ សម្រាប់តទល់នឹង អ្នកខ្លាំង ។ ទស្សនវិជ្ជា របស់ នីត្ស បានត្រូវគេយក ទៅបកស្រាយខុសទិសជាហេតុបណ្ដាលឲ្យពួក «ណាហ្ស៊ី» ធ្មៀតបង្កើតសោកនាដកម្មមួយ ដ៏ធំនៅក្នុង ប្រវត្តិសាស្ត្រ។ ទស្សនៈ របស់នីត្ស គឺ ការមិនយល់ស្រប នឹង ទស្សនវិជ្ជា សម័យទំនើបមួយចំនួន ដែលអាចនាំទៅរក ការចុះដុនដាប នៃ ទ្វីបអឺរ៉ុប ។ លោកលាតត្រដាង នូវទិដ្ឋភាពអវិជ្ជមាន នៃទស្សនវិជ្ជា សុញ្ញនិយម ទាំងឡាយ (les aspects du «nihilisme

passif)» នៃ សីលធម៌ ជាប្រពៃណី ដូចជា ចរន្ត ទស្សនវិជ្ជា របស់ សហគមន៍ ជ្វីស និង គ្រីស្តសាសនា (courant judéo-chrétien) ជាដើម ដែលលោកយល់ថា មាន ឫសគល់មកពី ទស្សន វិជ្ជាសូក្រាតនិយម ហើយដែលកាត់បន្ថយ ថាមពល ពិតប្រាកដ របស់ មនុស្សតែប៉ុណ្ណោះ ។ នីត្ស យល់ថា ទស្សនវិជ្ជាទាំងនោះ នាំមនុស្ស ឲ្យគេចវេះ ពី ជីវិតពិតប្រាកដ របស់ គេ។ បើតាមទស្សនៈនេះ របស់ នីត្ស អ្នកខ្លាំង អ្នកពូកែត្រូវ រណប នឹង អ្នកខ្សោយទៅវិញ ។ ពាក្យថា «មនុស្សឧត្តម»(« surhomme ») ដែលនីត្ស បាន យកមកព ីករី ហ្គឺត មានន័យថា មនុស្សត្រូវខំប្រឹងប្រែងដើរឲ្យហួស ពីចរិត ទន់ខ្សោយរបស់ខ្លួន («volonté de puissance») ដើម្បីឈាន ទៅធ្វើអំពើ ដ៏ឧត្តម ដែល អាចជំនួសព្រះបាន ក្នុងការស្រោចស្រង់មនុស្សជាតិ ដោយហេតុថា ព្រះពុំមាន អត្ថិភាព នៅក្នុងលោកយើងនេះឡើយ។ គួរកត់សម្គាល់ថា ពួកណាហ្ស៊ី ពុំមានឥរិយាបថ ជាអ្នក ស្រោចស្រង់ ជួយយកអាសា មនុស្សឡើយ។

# សម្តេច នរោត្តម សីហនុ សាកល្បងបង្កើត រដ្ឋាភិបាលចម្រុះ រវាង គណបក្ស ហ្វុនស៊ីនប៉ិច និង គណបក្ស ប្រជាជន

## Norodom Sihanouk entend créer un gouvernement de coalition entre le F.U.N.C.I.N.P.E.C. et le P.P.C

អង្គប្រជុំ «ក្រុមប្រឹក្សាជាតិជាន់ខ្ពស់» នៅទីក្រុងភ្នំពេញលើកដំបូងបង្អស់ បានប្រព្រឹត្តទៅ នៅថ្ងៃ ២២ វិច្ឆិកា ឆ្នាំ ១៩៩១ គឺ ៥ ថ្ងៃ ក្រោយពេលដែល សម្តេច នរោត្តម សីហនុ យាងមកដល់ ប្រទេសកម្ពុជា ។ សូមរំឭកឡើងវិញថា សម្តេច នរោត្តម សីហនុ ជាក្សត្រខ្មែរមួយអង្គ ដែលបារាំងបានជ្រើសរើសឲ្យឡើងសោយរាជ្យនៅឆ្នាំ ១៩៤១ ។





នៅឆ្នាំ ១៩៥៥ ព្រះអង្គ បានដាក់រាជ្យសម្បត្តិថ្វាយ ទៅព្រះរាជបិតា និង ព្រះរាជមាតា របស់ព្រះអង្គ ដើម្បីចូលប្រឡូកក្នុងឆាកនយោបាយ ។ ពេលដាក់រាជ្យ ព្រះអង្គបានត្រូវ តែងតាំងជាព្រះប្រមុខរដ្ឋ នៃ ប្រទេសកម្ពុជា ដោយសភាទាំងពីរ ។ នៅថ្ងៃ ១៨ មិនា ឆ្នាំ ១៩៧០ ព្រះអង្គ បានត្រូវសភាទាំងពីរ ដកចេញពីមុខតំណែងនេះ ដើម្បីបើកផ្លូវឲ្យ ឧត្តម សេនីយ៍ លន់ នល់ ដែលកាលនោះ ជានាយករដ្ឋមន្ត្រី នៃ រដ្ឋាភិបាល «ស្រោចស្រង់ ជាតិ» ដេញកងទ័ពវៀតមិញ និងវៀតកុង ចេញពីស្រុកខ្មែរ ។ ពេលខ្មែរក្រហម ឡើងកាន់ អំណាច បន្ទាប់ពីបានត្រូវតែងតាំងជាប្រមុខរដ្ឋ នៃរបបនេះ ព្រះអង្គ បានត្រូវខ្មែរក្រហម យកទៅដាក់ឃុំឃាំង នៅក្នុងព្រះរាជវាំង ។ នៅថ្ងៃ ៦ មករាឆ្នាំ ១៩៧៩ គឺ មួយថ្ងៃមុន ពេលដែល កងទ័ពវៀតណាម ចូលមកដល់ទីក្រុងភ្នំពេញ វាយរំលំបង្អើយ របប ប៉ុល ពត ព្រះអង្គបានត្រូវយន្តហោះរដ្ឋាភិបាលចិន ដឹកចេញ ជាបន្ទាន់ ពីប្រទេសកម្ពុជា ដើម្បី កុំឲ្យ ធ្លាក់ទៅក្នុងកណ្តាប់ដៃ ទីក្រុងហាណូយ។ នៅទីបំផុត បន្ទាប់ពីស្ថិតនៅក្រៅប្រទេស អស់រយៈពេល ១២ ឆ្នាំ ព្រះអង្គ បានវិល មក មាតុប្រទេស វិញ ហើយ ម្តងនេះ ក្នុង នាមជាប្រធាន «ក្រុមប្រឹក្សាជាតិជាន់ខ្ពស់» ក្នុងក្របខ័ណ្ឌ នៃ អន្តរាគមន៍ របស់ អង្គការ សហប្រជាជាតិ ។ នៅក្នុងអង្គប្រជុំ «ក្រុមប្រឹក្សាជាតិជាន់ខ្ពស់» នាថ្ងៃ ២២ វិច្ឆិកា ឆ្នាំ ១៩៩១ នោះ គេពុំឃើញ វត្តមាន លោក សុន សេន និង លោក ខៀវ សំផន អ្នក តំណាងក្រុមខ្មែរក្រហមទេ ។ ចំពោះ សម្តេច នរោត្តម សីហនុ បញ្ហាសំខាន់ចំពោះមុខ គឺធ្វើយ៉ាងណា បង្កើតក្រុមនយោបាយមួយ ដែលគណបក្សរាជានិយម «ហ្វុនស៊ីនប៉ិច» ដឹកនាំដោយ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ជាកូន របស់ព្រះ អង្គធ្វើ សហការជិតស្និទ្ធ ជាមួយអតីត បក្សកុម្មុយនិស្ត ដឹកនាំ ដោយ លោក ហ៊ុន សែន ។ នៅថ្ងៃ ២៣ វិច្ឆិកា ឆ្នាំ ១៩៩១ ដដែលនោះ សម្តេច នរោត្តម សីហនុ ទ្រង់បានប្រកាសប្រាប់ថា នឹងមាន ការបង្កើត រដ្ឋាភិបាលចម្រុះមួយ រវាង គណបក្ស នយោបាយទាំង ២ ។ ប៉ុន្តែ លោក ស៊ឺន សាន ដែលតំណាងអ្នកប្រជាធិបតេយ្យ នៅពេលនោះ មិនយល់ស្របទេ ហើយ ចាត់ទុកថា «ក្រុមប្រឹក្សាជាតិជាន់ខ្ពស់» ជា រដ្ឋាភិបាលខ្មែរតែមួយគត់។ នៅក្នុងន័យនេះ នៅថ្ងៃ ២៦ វិច្ឆិកា ការិយាល័យ «ក្រុមប្រឹក្សាជាតិជាន់ខ្ពស់» បានចេញផ្សាយ សេចក្តី

ជូនដំណឹង មួយបញ្ជាក់ជាផ្លូវការថា សម្ដេច នរោត្ដម សីហនុ ជាព្រះប្រមុខរដ្ឋស្រប ច្បាប់ និង ពេញសិទ្ធិ នៃ ប្រទេសកម្ពុជា ។ ទោះជាយ៉ាងណាក្ដី បញ្ហាដែលពុំទាន់បានត្រូវដោះស្រាយនៅឡើយ គឺ បញ្ហាខ្មែរក្រហម។ គេនៅចាំបានថា នៅថ្ងៃ ២៣ កុម្ភៈ គឺ នៅដើមឆ្នាំ ១៩៩១ បន្ទាប់ពី មានរដ្ឋប្រហារមួយនៅប្រទេសថៃ ឧត្ដមសេនីយ៍ថៃ សុចិន្ដា បានថ្លែងថា : «បើចង់ ដោះស្រាយ បញ្ហាខ្មែរ គេត្រូវចែកអំណាច ឲ្យខ្មែរក្រហមផង។ នៅថ្ងៃ ២៧ វិច្ឆិកា បន្ទាប់ពីក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ផ្ដល់តួនាទីប្រមុខរដ្ឋ ថ្វាយទៅសម្ដេច នរោត្ដម សីហនុ លោក ខៀវ សំផន បានមកដល់ ទីក្រុងភ្នំពេញ ។ ប៉ុន្ដែបាតុកម្មមួយបានត្រូវរៀបចំឡើង ដើម្បីថ្កោលទោសលោក ខៀវ សំផន ជាសាធារណៈ។ ពួកបាតុករខ្លះ បាននាំគ្នា វាយលោកខៀវ សំផន រហូតដល់បែកក្បាលចេញឈាម ដើម្បីបញ្ចេញកំហឹង របស់គេ អំពី ការដែលរបបខ្មែរក្រហម បានកាប់សម្លាប់ប្រជាជនខ្មែរកាលពី ឆ្នាំ ១៩៧៥-១៩៧៩ ។ បើកុំតែកម្លាំង របស់លោក ហ៊ុន សែន ធ្វើអន្ដរាគមន៍ទាន់ លោកខៀវ សំផន ប្រហែលជាត្រូវពួក បាតុករ យកទៅសម្លាប់ចោល បាត់ទៅហើយ។ យោងទៅ តាមអ្នកសង្កេតការណ៍ខ្លះ បាតុកម្មនេះ បានត្រូវរៀបចំឡើងដោយគណបក្ស «ប្រជាជន» ប៉ុន្ដែ ដោយមាន ការពុះកញ្ជ្រោលខ្លាំងពេក នៅពេលនោះគេក៏បារម្ភខ្លាចមិនអាចទប់ទល់នឹង ការវិវត្ដន៍ របស់វាបាន ។ ក្រោយ ឧបទ្ទវហេតុនេះបន្ដិច ខៀវ សំផន បានសម្រេច ត្រឡប់ទៅ ទីក្រុងបាងកក វិញ។

ពីរថ្ងៃក្រោយ អង្គប្រជុំ «ក្រុមប្រឹក្សាជាតិជាន់ខ្ពស់»នាថ្ងៃ ៣ ធ្នូ នៅ ប៉ាតាយ៉ាពោលគឺ នៅថ្ងៃ ៥ ធ្នូ សម្ដេច នរោត្ដម សីហនុ ទ្រង់បានថ្លែងថា : សម្ព័ន្ធភាព រវាងគណបក្ស «ហ្វ៊ុនស៊ិនប៉ិច» នឹង គណបក្ស«ប្រជាជន» មិនអាច ក្លាយទៅជារដ្ឋាភិបាលចម្រុះ មុនការបោះឆ្នោតបានទេ ព្រោះព្រះអង្គទុកចិត្តទៅលើ លោក ហ៊ុន សែន តែ ៥០ ភាគរយប៉ុណ្ណោះ។ នៅថ្ងៃ ៥ ធ្នូនោះឯង នៅប្រទេសកម្ពុជា អ្នកកាសែតបានរកឃើញឯកសារ មួយចំនួន នៅក្នុងការិយាល័យខ្មែរក្រហម នៅភ្នំពេញដែលបានត្រូវគេវាយកំទេច។ តាមរយៈឯកសារនោះ គេបានដឹងថា ពួកខ្មែរក្រហមនៅ ភ្នំពេញផ្ញើរបាយការណ៍ជារឿយៗ ទៅ ប៉ុល ពត។ នៅ ថ្ងៃ ១៣ ធ្នូ អ្នកដឹកនាំខ្មែរក្រហម បាន





រួមប្រជុំគ្នា នៅប៉ៃលិន ដើម្បីវាយតម្លៃ សភាពការណ៍ ស្ដីពីការអនុវត្ដន៍ កិច្ចព្រមព្រៀងសន្ដិភាព។ នៅខែធ្នូនោះដែរ មានព្រឹត្ដិការណ៍មួយ បានកើតឡើង។ នៅថ្ងៃ ១៧ ធ្នូ នៅក្នុងបាតុកម្មហឹង្សាមួយ និស្សិត និង សិស្សសាលាជាច្រើន បាននាំគ្នាថ្កោលទោស អំពើពុករលួយ។ នគរបាល បានចេញធ្វើអន្ដរាគមន៍ ហើយ បានបាញ់រះ ទៅលើបាតុករតែម្ដង។ បាតុកម្មនេះ ដែលបានប្រព្រឹត្ដទៅ រហូតដល់ ថ្ងៃ ២៣ ធ្នូ បានបណ្ដាលឲ្យមនុស្ស ១១ នាក់ យ៉ាងតិច បាត់បង់ជីវិត ។ មួយថ្ងៃបន្ទាប់មក បណ្ដាឯកអគ្គរដ្ឋទូតនៃប្រទេសមហាអំណាចទាំង ៥ នៅភ្នំពេញ បានបើកអង្គប្រជុំ រង្វើការងារ រៀបចំ អន្ដរាគមន៍ របស់អង្គការ សហប្រជាជាតិ ។ អង្គប្រជុំ របៀបនេះ ចេះតែមានជាហូរហែបន្ទាប់មកទៀត ហើយបានពង្រីកដល់ទៅ ១១ ប្រទេស។ នៅ ថ្ងៃ ២៨ ធ្នូ ក្រុមយោធាចម្រុះ នៃបណ្ដាប្រទេសដែលត្រូវធ្វើអន្ដរាគមន៍ បានរួមប្រជុំគ្នាធ្វើកិច្ចការ យ៉ាងមមាញឹក ហើយនៅថ្ងៃ ៣០ ធ្នូ «ក្រុមប្រឹក្សាជាតិជាន់ខ្ពស់» ក៏ បើកអង្គប្រជុំរបស់ គេដែរ។ សមាជិកទាំងអស់ នៃក្រុមប្រឹក្សាបានចូលរួម ហើយបាន អំពាវនាវ ជាផ្លូវការ ឲ្យអង្គការសហប្រជាជាតិ បញ្ជូន បេសកជន នានា របស់ខ្លួន ឲ្យមករៀបចំ អភិក្រម សន្ដិភាពនៅ កម្ពុជា។

# យុទ្ធសាស្ដ្រ របស់លោក ហ៊ុន សែន នៅពេលដែល អង្គការ សហប្រជាជាតិ ចាប់ផ្ដើមចូល មកធ្វើអន្ដរាគមន៍ នៅឆ្នាំ ១៩៩២

## La stratégie de Hun Sèn au début de l’intervenrion de l’O.N.U. en 1992

នៅដើមឆ្នាំ ១៩៩២ នៅពេលដែលអង្គការ សហប្រជាជាតិ ចាប់ផ្ដើមធ្វើអន្តរាគមន៍ នៅកម្ពុជា រដ្ឋាភិបាល របស់ លោក ហ៊ុន សែន រិះរកគ្រប់មធ្យោបាយ ដើម្បីកាត់បន្ថយ ឥទ្ធិពល របស់ ភាគីខ្មែរផ្សេងៗទៀត។ ប៉ុន្តែ គឺនៅពេលនោះដែរ ដែលលោក ជា ស៊ីម និង លោក ហ៊ុន សែន ដណ្ដើមឥទ្ធិពលគ្នា ។ សូមកត់សំគាល់ថា នៅចន្លោះឆ្នាំ ១៩៧៩-១៩៨០ គឺនៅពេលដែលកងទ័ពវៀតណាម ចាប់ផ្ដើមពង្រឹងវត្តមាន នៃកងទ័ព របស់គេ នៅលើ ទឹកដីខ្មែរ លោក ជា ស៊ីម ដែលជាមេដឹកនាំការបះបោរ ប្រឆាំង នឹង ប៉ុល ពត នៅក្នុងស្រុក បានត្រូវទីក្រុងហាណូយ សាកល្បង ដកហូតចេញពីអំណាច ហើយដាក់លោក ប៉ែន សុវណ្ណ ជំនួសវិញ។ លោកប៉ែន សុវណ្ណ ដែលជាអ្នកតស៊ូជាមួយអង្គការវៀតមិញ នៅ អំឡុងឆ្នាំ១៩៥០[៣១] ហើយដែលក្រោយកិច្ចព្រមព្រៀង ទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤ បានត្រូវបញ្ជូន ទៅប្រទេសវៀតណាម។ នៅឆ្នាំ ១៩៧៩-១៩៨០ ទំនាស់ រវាង លោក ប៉ែន សុវណ្ណ និង លោក ជា ស៊ីម បានជម្រុញឲ្យ ទីក្រុងហាណូយ បញ្ឈរជើង លោក ជា ស៊ីម តែម្ដង។ ប៉ុន្តែ បន្ទាប់ពី មានការតស៊ូផ្ទៃក្នុងយ៉ាងខ្លាំង រវាង អ្នកដឹកនាំទាំងពីរនេះ លោក ប៉ែន សុវណ្ណ ក៏ត្រូវទីក្រុងហាណូយ ដកហូតអំណាច ហើយ និរទេស ទៅប្រទេសវៀតណាម នៅថ្ងៃ ៤ ធ្នូ ឆ្នាំ ១៩៨១ បន្ទាប់ពីបានកាន់មុខតំណែង ជាអគ្គលេខាធិការបក្ស «ប្រជាជនបដិវត្តកម្ពុជា» និង ជានាយករដ្ឋមន្ត្រី នៃ របប ««សាធារណរដ្ឋប្រជាមានិតកម្ពុជា» គាំទ្រដោយ វៀតណាម ។ ម៉្យាងទៀត លោក ប៉ែន សុវណ្ណ ក៏ដូចជា លោក ជា ស៊ីមដែរ សុទ្ធតែជាអ្នកដែលបានសាកល្បង រើបម្រាសចេញពីនឹម អាណានិគមន៍របស់ ប្រទេសវៀតណាម។ អតីតខ្មែរវៀតមិញម្នាក់ទៀត គឺ លោក ចាន់ ស៊ី បានត្រូវតែងតាំងដាក់

[៣១] លោក ប៉ែន សុវណ្ណ បានធ្វើការតស៊ូ ក្នុងចលនា ឥស្សរៈនៅចន្លោះឆ្នាំ ១៩៤៩-១៩៥៤។ លោក បានចូល ជាសមាជិក នៃ បក្សកុម្មុយនិស្តឥណ្ឌូចិន (P.C.I.) នៅឆ្នាំ ១៩៥១។





ជំនួស លោក ប៉ែន សុវណ្ណ ជានាយករដ្ឋមន្ត្រី។ ប៉ុន្តែ បន្ទាប់ពី លោក ចាន់ ស៊ី ទទួលមរណភាព [៣២] លោក ហ៊ុន សែន បានទទួលមុខតំណែងនេះ នៅថ្ងៃ ១៤ មករា ឆ្នាំ ១៩៨៥។ នៅចន្លោះ ឆ្នាំ ១៩៨៥-១៩៩១ លោក ជា ស៊ីម ដណ្ដើមអំណាចមិនបានវិញសោះ គឺ បានត្រឹម រត់តាមលោក ហ៊ុន សែន និង អ្នកតស៊ូ មកពីហាណូយ និង អ្នកជំនាន់ក្រោយដែលលោក ហ៊ុន សែន និង ទីក្រុងហាណូយបានអបរំ និង ឲ្យបុណ្យសក្តិ ជាបន្តបន្ទាប់មកទៀតតែប៉ុណ្ណោះ។ លោកនាយករដ្ឋមន្ត្រីហ៊ុន សែន បានផ្សះផ្សាក្រុមកុម្មុយនិស្ត បដិបក្ខទាំងពីរ [៣៣] ព្រមទាំងក្រុមផ្សេងៗទៀត [៣៤] ហើយ រួមរស់ជាមួយគ្នារហូត ដល់ ឆ្នាំ១៩៩០ ។ ប៉ុន្តែ លោក ជា ស៊ីម វិល មករកទីតាំងរបស់ លោក នៅចន្លោះ ឆ្នាំ ១៩៧៨-១៩៧៩ ដដែល។ នៅឆ្នាំ ១៩៩០ នៅពេលដែលលោក ហ៊ុន សែន កំពុងមាន មុខមាត់ នៅក្នុងការចរចា ជាមួយសម្ដេច នរោត្តម សីហនុ លោក ជា ស៊ីម ក៏គ្មាន តួនាទីអ្វីសំខាន់ដែរ ក្រៅពីមានឈ្មោះថា ជា «អ្នកតាចាំស្រុក» ម្នាក់ដែលមាន ការគោរព «ដ៏ខ្ពង់ខ្ពស់» ពីសំណាក់ បក្ស «ប្រជាជន» និង លោក ហ៊ុន សែន។ ការប្រយុទ្ធដណ្ដើមឥទ្ធិពលគ្នា ដោយមិនចេញមុខ រវាង លោក ហ៊ុន សែន និង លោក

[៣២] លោក ចាន់ ស៊ី ដែលជំនួសលោក ប៉ែន សុវណ្ណ បន្ទាប់ ពី លោកប៉ែន សុវណ្ណ ត្រូវដកហូតចេញពីអំណាច បានត្រូវតែងតាំងជាផ្លូវការជា នាយករដ្ឋមន្ត្រី ដោយអង្គប្រជុំរដ្ឋសភា ដែលបើក សម័យប្រជុំ ពីថ្ងៃ ៥ ដល់ ថ្ងៃ ១១ កុម្ភៈ ឆ្នាំ ១៩៨២ ។ លោក ទទួលមរណភាព នៅថ្ងៃ ៣១ ធ្នូ ឆ្នាំ ១៩៨៤ នៅមន្ទីរពេទ្យ ទីក្រុងម៉ូស្គូ ។

[៣៣] គឺ ក្រុម អតីតខ្មែរក្រហម ទិសបូព៌ា (សោ ភឹម,ហេង សំរិន, ជា ស៊ីម, អ៊ុក ប៊ុនធឿន ។ល។ )និង ក្រុមមកពី ប្រទេសវៀតណាម (ប៉ែន សុវណ្ណ, ជា សុទ្ធ, រស់ សាម៉ៃ, ឡាយ សាម៉ុន ។ល។ )។

[៣៤] ដូចជា ក្រុមកោះកុង (សាយ កូថង, ចា វៀង, ទៀ បាញ់ ។ល។ ) និង ក្រុមទិសព្វាសាន របស់ ប៊ូ ថង, ស៊ឹយ កែវ ជាដើម ។

ជា ស៊ីម នៅពេលអន្តរាគមន៍ របស់អង្គការ សហប្រជាជាតិ នៅតែមាន បន្តមកទៀត។ ប៉ុន្តែ លោក ហ៊ុន សែន បានក្លាយទៅជាមនុស្សខ្លាំង តែម្នាក់គត់ នៃ រដ្ឋកម្ពុជា រួចស្រេចទៅហើយ។ នៅ ថ្ងៃ ៣១ មករា ឆ្នាំ ១៩៩២ ដើម្បី សាកល្បង គេចឲ្យផុត ពីការត្រួតពិនិត្យ ពីអង្គការ «អាប្រូនុច» ( A.P.R.O.N..U.C.) ហើយ ដើម្បីប្រើឥទ្ធិពលរបស់ ភាគីម្ខាងទៀតផងដែរ លោក ហ៊ុន សែន បានបញ្ចូល ញាតិវង្សានុវង្ស របស់សម្តេច នរោត្តម សីហនុ មកក្នុងរដ្ឋាភិបាល របស់ លោក គឺ រដ្ឋាភិបាល មុនការបោះឆ្នោត ។ នៅពេលនោះ ព្រះអង្គម្ចាស់ចក្រពង្ស បុត្រ មួយអង្គ របស់ សម្តេច នរោត្តម សីហនុ [៣៥] បាន ត្រូវតែងតាំង ជាឧបនាយករដ្ឋមន្ត្រី ហើយព្រះអង្គម្ចាស់ក្សត្រី នរោត្តម បុប្ផាទេវី[៣៦] ព្រះរាជបុត្រីមួយអង្គទៀត បានទទួលតួនាទីជាអនុរដ្ឋមន្ត្រី បន្ទាប់មក ជា រដ្ឋមន្ត្រី ក្រសួងវប្បធម៌។ ដើម្បីសាក ល្បងបន្ធូរបរិយាកាស ជាមួយ លោក ជា ស៊ីម / លោក ស ខេង ដែលជាញាតិ ខាងលោក ជា ស៊ីម ក៏ បានត្រូវតែងតាំងជា ឧបនាយករដ្ឋមន្ត្រីដែរ។ យុទ្ធវិធីនេះ របស់ លោកហ៊ុន សែន នៅក្នុងតំណាក់ការទី ១ គឺឈានឆ្ពោះទៅរក ការប្រមូលកម្លាំង និង ឥទ្ធិពល ជាមួយសម្តេច នរោត្តម សីហនុ ឲ្យបានសិន ហើយ បន្ទាប់មក ឯកោ គូភាគីផ្សេងៗ ទៀត ដូចជា «រណសិរ្សរំដោះពលរដ្ឋខ្មែរ» របស់លោក សឺន សាន បក្សរាជានិយម «ហ្វ៊ុនស៊ីនប៉ិច» ដឹកនាំ ដោយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និង ពួកខ្មែរក្រហម ក្រុម ប៉ុល ពត-អៀងសារី ជាដើម ។ នៅចំពោះមុខ យុទ្ធវិធីនេះ របស់ លោក ហ៊ុន សែន ពួកខ្មែរក្រហម ខាង ប៉ុល ពត គ្មាន ជម្រើសអ្វីទៀត ក្រៅពីរំលោភទៅលើកិច្ចព្រមព្រៀងឈប់បាញ់គ្នានោះទេ។ នៅថ្ងៃ

[៣៥] ព្រះអង្គម្ចាស់ចក្រពង្ស ប្រសូតនៅថ្ងៃ ២១ ខែ តុលា ឆ្នាំ ១៩៤៥ ជាបុត្រ របស់សម្តេច នរោត្តម សីហនុ ជាមួយព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ពង្សានមុនី (២៦ មិថុនា ១៩២៩ -† ១៩៧៤) ។

[៣៦] ព្រះអង្គម្ចាស់ក្សត្រី នរោត្តម បុប្ផាទេវី ប្រសូតនៅថ្ងៃ ៨ មករា ឆ្នាំ ១៩៤៣ ជា បុត្រីរបស់សម្តេចនរោត្តម សីហនុ ជាមួយអ្នកម្នាងកញ្ញុល (១៩២០ -† ១៩៦៨) ។



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

១៧ មករាឆ្នាំ ១៩៩២ ដដែលនោះ ពួកខ្មែរក្រហម បានសាកល្បងបញ្ចូនខ្មែរ នៅជុំរុំអូរត្រាវ ចំនួន ប្រមាណ ១ ម៉ឺន ៧ ពាន់ ៦ រយ នាក់ (១៧ ០០០ នាក់) មករាយគ្នាក្នុងប្រទេសកម្ពុជា ។ ប៉ុន្តែ កិច្ចការនេះ បានទទួលបរាជ័យទាំងស្រុង ។

## សភាពការណ៍ នៃ គណបក្សនយោបាយ នានា មុនការបោះឆ្នោតសេរី លើកដំបូង បង្អស់ រៀបចំ ដោយ អ.ស.ប. នៅឆ្នាំ ១៩៩៣

## Situation des partis politiques avant les premières élections libres organisées par l'O.N.U. en 1993

នៅថ្ងៃ ២១ មករា ឆ្នាំ ១៩៩២ នៅពេលដែលលោក អាកាស៊ី អ្នកតំណាងពិសេស នៃ អគ្គលេខាធិការ អង្គការ សហប្រជាជាតិ អញ្ជើញមកធ្វើ ទស្សនកិច្ច នៅកម្ពុជា កងទ័ពខ្មែរក្រហម បានធ្វើការវាយប្រហារមួយដ៏ធំ នៅខេត្រកំពង់ធំ បណ្តាលឲ្យមនុស្ស ២១ នាក់បាត់បង់ជីវិត។ អង្គការ «មីប្រេនុប» របស់ អង្គការ សហប្រជា ជាតិដែលមាន បេសកកម្មរៀបចការបោះឆ្នោត នៅកម្ពុជា បានបញ្ជូន អង្គភាពយោធាមួយទៅបង្រ្កាប។ នៅពេលនោះ ប្រជាជននៅខេត្រកំពង់ធំ ប្រមាណ ១ ម៉ឺននាក់ នាំគ្នាឱបបង្ហេចរត់ចេញពី ការប្រយុទ្ធ សាជាថ្មីទៀត ។ ការរំលោភ ទៅលើ កិច្ចព្រមព្រៀងឈប់បាញ់គ្នានេះ ពីសំណាក់ ភាគីខ្មែរក្រហម មានគោលដៅធ្វើ ការគាបសង្កត់ ឲ្យមានការផ្តល់អំណាច ឲ្យបានកាន់តែច្រើនថែមទៀត ដល់សម្តេច នរោត្តម សីហនុ នៅក្នុង «ក្រុមប្រឹក្សាជាតិជាន់ខ្ពស់»។ នៅថ្ងៃ ៦ កុម្ភៈ ឆ្នាំដដែលនោះ ពួកខ្មែរក្រហម បានរួមប្រជុំគ្នា នៅប៉ៃលិន។ គោលដៅ គឺនាំគ្នាប្តេជ្ញាចិត្ត មិនព្រមអនុវត្ត កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍។ ប៉ុល ពត បានធ្វើសន្ទរកថាមួយ ដើម្បីជម្រុញ ឲ្យខ្មែរក្រហម ធ្វើអ្វីគ្រប់បែប

យ៉ាង ដើម្បី អុកឡុក ការអនុវត្តន៍ កិច្ចព្រម ព្រៀងសន្តិភាព។ នៅដើមឆ្នាំ ១៩៩២ នោះ គេសង្កេតឃើញមាន ព្រឹត្តិការណ៍ សំខាន់ៗមួយចំនួន។ នៅថ្ងៃ ២៦ មករា លោក ប៉ែន សុវណ្ណ អតីតនាយករដ្ឋមន្ត្រី នៃរបប «សាធារណរដ្ឋប្រជាមានិតុ កម្ពុជា» បានត្រឡប់ពីវៀតណាម មករស់នៅ កម្ពុជា ក្នុងខេត្រតាកែវ ស្រុកកំណើត របស់លោកវិញ។ ២ ថ្ងៃបន្ទាប់មក គឺនៅថ្ងៃ ២៨ មករា លោក អ៊ុង ផន ដែលជាមិត្តម្នាក់របស់ លោក ហ៊ុន សែន បានត្រូវ គេប៉ុនប៉ងធ្វើឃាត ព្រោះតែបានរិះគន់ អំពើ ពុករលួយ របស់អ្នកដឹកនាំអតីត របបកុម្មុយនិស្ត កន្លងមក។ លោក អ៊ុង ផន បានថ្លែងថា : អតីតជនកុម្មុយនិស្តទាំងនោះ បានក្លាយទៅជា មហាសេដ្ឋី មានប្រាក់រាប់ពាន់លាន។ នៅពាក់កណ្តាលខែកុម្ភៈ ឧត្តមសេនីយ៍ សាកស៊ុត សាខន បានវិលត្រឡប់មកទីក្រុងភ្នំពេញ។ លោក សាកស៊ុត សាខន ជាអតីតមេបញ្ជាការ កងទ័ពខ្មែរ កាលជំនាន់ ឧត្តមសេនីយ៍ លន់ នល់ ហើយដែលក្រោយមក បានធ្វើការតស៊ូនៅក្នុងជួរ «រណសិរ្សរំដោះពលរដ្ឋខ្មែរ» របស់ លោក សឺន សាន ។ នៅពេលមានទំនាស់ ជាមួយលោក សឺន សាន លោក សាក ស៊ុត សាខន បានសាកល្បងបង្កើតគណបក្សមួយមានឈ្មោះថា «គណបក្សសេរីនិយម» ។ គឺ នៅខែកុម្ភៈនោះហើយ ដែលពួកខ្មែរក្រហម បង្កើន ការប្រយុទ្ធ របស់ពួកគេយ៉ាងខ្លាំងក្លានៅខេត្រកំពង់ធំ។ ខ្មែរក្រហម បានប្រកាសមិនព្រមធ្វើសហការ ជាមួយកងទ័ព «មីប្រេនុប» របស់អង្គការ សហប្រជាជាតិ ហើយ មិនព្រមឲ្យ កងទ័ពសន្តិភាពនេះ ចូលមកក្នុងតំបន់ ដែលគេ កាន់កាប់ឡើយ។

នៅចំពោះមុខ ការមិនព្រមធ្វើសហការនេះ ពីសំណាក់ ក្រុមខ្មែរក្រហម សម្តេច នរោត្តម សីហនុ បានយាងទៅធ្វើទស្សនកិច្ច នៅប៉ៃលិន នៅថ្ងៃ ២៧ កុម្ភៈ។ ព្រះអង្គទ្រង់មាន ព្រះរាជបន្ទូល នៅពេលនោះថា ត្រូវតែគោរព កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ឲ្យបាន ១០០ ភាគរយ។ នៅថ្ងៃដដែលនោះ នៅ រំដោង ឯនោះវិញ គឺ តំបន់មួយ របស់អ្នកគាំទ្រ សម្តេច នរោត្តម សីហនុ ចលនា រាជានិយម «ហ៊្វុន ស៊ុនប៉េច» បានបើកអង្គប្រជុំមួយ ដើម្បីប្រែក្លាយ ចលនារាជានិយមនេះ ទៅជា គណបក្សនយោបាយមួយពេញលក្ខណៈ។ គឺនៅពេលនោះហើយ ដែលអ្នកដឹកនាំ កងទ័ពរាជានិយម គឺ ព្រះអង្គ





ម្ចាស់ នរោត្តម រណឫទ្ធិ បានត្រូវតែងតាំង ជាប្រធានពេញលក្ខណៈ ហើយដែលលក្ខន្តិកៈ ផ្សេងៗ ព្រមទាំងកម្មវិធី នយោបាយ មួយបានត្រូវអនុម័ត ។ មួយថ្ងៃ បន្ទាប់មក គឺ នៅថ្ងៃ ២៨ កុម្ភៈនៅ ទីក្រុងញូវយ៉ក ឯនោះវិញ ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហប្រជាជាតិ បានអនុម័ត ផែនការមួយ សម្រាប់អនុវត្ត កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍។ អង្គប្រជុំ បានសម្រេចថា នឹងធ្វើយ៉ាងណា អនុវត្ត ការឈប់បាញ់គ្នា ឲ្យបានសព្វគ្រប់នៅ ថ្ងៃ ៣១ ឧសភា ហើយសម្រេច បញ្ជូនកងទ័ព ចំនួន ៧០ ភាគរយ ជាលើកដំបូង ឲ្យបានមុនថ្ងៃ ៣០ កញ្ញា។ រីឯការបោះឆ្នោត ត្រូវប្រព្រឹត្តទៅ យ៉ាងយូរបំផុត នៅខែឧសភា ឆ្នាំ ១៩៩៣។ តាមការប្រមើមើលទុកជាមុន នូវឧបសគ្គ ក្នុងការអនុវតន៍ កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ គេឃើញមាន ឧបសគ្គតែមួយប៉ុណ្ណោះ គឺ ការមិនចូលរួមចំណែក ពីសំណាក់ខ្មែរក្រហម។ បើគេពិនិត្យមើល សភាពការណ៍នៅពេលនោះ គេសង្កេតឃើញថា គណបក្សរាជានិយម «ហ្វុនស៊ុនប៉េច» មានលក្ខណៈគ្រប់គ្រាន់ ដើម្បីប្រឈមមុខ នឹងអតីតគណបក្សកុម្មុយនិស្ត ព្រោះអ្នកបង្កើតចលនានេះ ជាសម្តេច នរោត្តម សីហនុ រីឯ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែលជាអ្នកដឹកនាំចលនា នេះ ក៏ជាព្រះរាជបុត្រ របស់ព្រះអង្គ ផងទៀត។

## បេសកកម្ម ៧ យ៉ាង របស់ អង្គការ «អាប្រូនុប»

## Les sept missions de l’A.P.R.O.N.U.C.

នៅថ្ងៃ ២៨ កុម្ភៈឆ្នាំ ១៩៩២ ក្រុមប្រឹក្សា សន្តិសុខ អង្គការ សហប្រជាជាតិ បានអនុម័ត ជាឯកច្ឆន្ទ នូវ សេចក្តីសម្រេចចិត្តមួយ លេខ ៧៤៥ ស្តីពី ការបង្កើតអាជ្ញាធរបណ្តោះអាសន្នមួយ នៅក្នុងប្រទេសកម្ពុជា ។ អាជ្ញាធរនេះ ដែលមានឈ្មោះ ជា

អក្សរកាត់ថា «អាប្រូនុច» (A.P.R.O.N.U.C.) [៣៧] ទទួលបន្ទុករៀបចំ ឲ្យមានសន្តិភាព វិញ នៅកម្ពុជា ហើយរៀបចំការបោះឆ្នោតដោយសេរី ដើម្បីឈានទៅបង្កើត សភាជម្មនុញ្ញ។ «កងទ័ពមួកខៀវ» ចំនួន១ ម៉ឺន ៥ ពាន់ ៩ រយនាក់ នឹង ត្រូវបញ្ជូនទៅស្រុកខ្មែរ ។ បើ គិតទាំងកងយោធា កងនគរបាល និង អ្នកធ្វើការ ស៊ីវិលផង គឺ មានទាំងអស់ ២ ម៉ឺន ២ ពាន់នាក់ ។ រីឯ បេសកកម្ម គឺមានការកិច្ច ប្រាំពីរយ៉ាង ខុសៗ ពីគ្នា គឺ ៖ ១) តម្រូវ ឲ្យ មានការគោរពសិទ្ធិមនុស្ស - ២) រៀបចំការបោះឆ្នោតដោយសេរី ឲ្យបានយ៉ាងយូរ បំផុត នៅខែ ឧសភា ឆ្នាំ ១៩៩៣ - ៣) ធានា ដំណើរការយោធា រដ្ឋបាលស៊ីវិល និង នគរបាល គឺ ផែនការដែល លោក ប៊ូត្រូស-ប៊ូត្រូសហ្កាលី [៣៨] បានគ្រោងទុកជាស្រេច - ៤) ការទទួលបន្ទុក រៀបចំ មាតុភូមិនិវត្តន៍ នៃ ជនភៀសសង្គ្រាម ចំនួនប្រមាណ ៣៦ ម៉ឺន នាក់ និង អ្នកដែលត្រូវគេប្តូរទីកន្លែង ចំនួនប្រហែល ១៧ ម៉ឺននាក់។ ទឹកប្រាក់ សម្រាប់ធ្វើ អន្តរាគមន៍នេះ ក្នុងរយៈពេល ១៥ ខែ គឺ ១ ពាន់ ៨ រយ ៧០ លានដុល្លារ [៣៩]។ អន្តរាគមន៍ នេះ ជាការអនុវត្តន៍ កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ដែលចុះហត្ថលេខា នៅថ្ងៃ ២៣ តុលា ឆ្នាំ ១៩៩១។ លោក ប៊ូត្រូស-ប៊ូត្រូស ហ្កាលី បានបញ្ជាក់ ហើយ បញ្ជាក់ទៀតថា : ជោគជ័យ នៃអន្តរាគមន៍នេះ ផ្អែកទាំងស្រុងទៅលើ ការសហការ ដ៏ ពេញទំហឹង ពីសំណាក់ អ្នកនយោបាយខ្មែរ និង ទៅលើ គូភាគី ទាំងអស់ដែលជាប់ ពាក់ព័ន្ធ។ អត្ថបទ នៃ សេចក្តីសម្រេចចិត្តលេខ ៧៤៥ នោះ ក៏បានស្នើសុំ ឲ្យអាជ្ញាធរ ខ្មែរយល់ព្រម រំសាយកងទ័ពរបស់គេ ទាំងអស់ផងដែរ។ កិច្ចការនេះត្រូវធ្វើឲ្យបាន ជាកំហិតមុន ការចុះឈ្មោះបោះឆ្នោត ។ នៅឆ្នាំ ១៩៩២ នោះ ព្រឹត្តការណ៍ជាច្រើន បាន

---

[៣៧] Autorité Provisoire de l’Organisation des Nations Unies au Cambodge (អាជ្ញាធរ បណ្តោះអាសន្ន នៃ អង្គការ សហប្រជាជាតិ នៅ កម្ពុជា).

[៣៨] Boutros-Boutros Ghali (ឈ្មោះលោក អគ្គលេខាធិការ អង្គការ សហប្រជាជាតិ នៅពេលនោះ ).

[៣៩] 1, 87 milliard de dollars





ស្តែងចេញឡើង ហើយបញ្ហាដែលចោទឡើងធំ ជាងគេ នៅពេលនោះ គឺការមិនព្រម ចូលរួមចំណែក ពីសំណាក់ខ្មែរក្រហមដែលធ្វើ ការវាយប្រហារ អុកឡុក អន្តរាគមន៍ របស់ អង្គការ សហប្រជាជាតិ ដោយឥតសំចៃ ។ នៅក្នុងអង្គប្រជុំ «ក្រុមប្រឹក្សាជាតិ ជាន់ ខ្ពស់» នាថ្ងៃ ៨ កក្កដា ភាគី ខ្មែរ ក្រហម បានបញ្ជាក់ម្តងទៀតថា គេពុំព្រមអនុវត្ត កិច្ចព្រមព្រៀងជាដាច់ខាត។ បន្ទាប់ពីការប្រយុទ្ធ ជាមួយកងទ័ព «រដ្ឋកម្ពុជា» នៅថ្ងៃ ១៨ មិថុនា ដណ្តើមយក ថ្នល់ជាតិ លេខ ១២ ដែលចងភ្ជាប់កំពង់ធំ នឹង ព្រះវិហារ កងទ័ពខ្មែរក្រហម បានធ្វើការវាយលុក ចូលទៅក្នុងខេត្តព្រះវិហារតែម្តង។ នៅថ្ងៃ ៣ សីហា ប្រទេស ថៃ មិនព្រមប្រកាស បញ្ឈប់ការរកស៊ី រវាង សហគ្រាសថៃមួយចំនួន និងពួកខ្មែរ ក្រហមទេ។ ប្រទេសចិន បានស្នើឲ្យទីក្រុងបាងកកយល់ព្រមពង្រីងអំណាច របស់ «ក្រុមប្រឹក្សាជាតិជាន់ខ្ពស់»។ នៅថ្ងៃ ៤ សីហា អ្នកការទូតចិនម្នាក់ បានទៅជួប ប៉ុល ពត ដោយសម្ងាត់ ប៉ុន្តែ ខ្មែរក្រហម មិនព្រមបន្ធូរឥរិយាបថ ដដែល។

ទោះជាពួកខ្មែរក្រហម ប្រកាន់ឥរិយាបថ រឹងរូស យ៉ាងណាក្តី ក៏ឧត្តមសេនីយ៍ សុន ឌែរសុន នៃ កងទ័ព «អាប្រូនុច» នៅតែមានជំនឿថា លោកនឹង អាចធ្វើយ៉ាងណា ឲ្យ ខ្មែរក្រហម អនុវត្ត កិច្ចព្រមព្រៀង សន្តិភាពបានដែរ ។ នៅ ថ្ងៃ ៥ សីហា នៅក្នុងអង្គ ប្រជុំ «ក្រុមប្រឹក្សាជាតិជាន់ខ្ពស់» នៅសៀមរាប លោក អាកាស៊ី អ្នកតំណាង លោក អគ្គលេខាធិការ អង្គការ សហប្រជាជាតិ បានប្រកាស ឲ្យប្រើច្បាប់បោះឆ្នោត ទោះបី ខ្មែរក្រហមមិនយល់ព្រមក៏ដោយ ។ ចាប់ពី ថ្ងៃ ១៧ សីហា គណបក្សនយោបាយ នានា បានសាកល្បងនាំគ្នា ចុះឈ្មោះ ជាបណ្តោះអាសន្ន ដើម្បីចូលប្រកួតប្រជែងក្នុង ការបោះឆ្នោត ហើយ នៅ ថ្ងៃ ២២ សីហា ប្រទេសថៃ និង ប្រទេសជប៉ុន បានស្នើ សុំឲ្យ បង្កើត របនាសម្ព័ន្ធ រដ្ឋបាលមួយ ដែលមាន «ក្រុមប្រឹក្សាជាតិជាន់ខ្ពស់» ជា អ្នក គ្រប់គ្រង។ លោក ខៀវ សំផន ខាងភាគីខ្មែរក្រហម ពុំបានច្រានចោល សំណើនេះ ទេ។ នៅក្នុងការរៀបចំឲ្យមាន សន្តិភាពឡើងវិញ នៅកម្ពុជា មានបញ្ហាមួយចោទឡើង៖ នៅក្នុងសេចក្តីសម្រេចចិត្ត របស់ ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហប្រជាជាតិ គេឥត មាននិយាយ ពីការបោះឆ្នោតជ្រើសតាំងប្រធានាធិបតីទេ ទោះបីមានការតវ៉ា ពីប្រទេស

ចិនក្តី។ នៅឆ្នាំ ១៩៩២ នោះ ទោះបី អង្គការ សហប្រជាជាតិ ចុះធ្វើ អន្តរាគមន៍ ទៅហើយក្តី ក៏អសន្តិសុខ កើតមានឡើង ឥតឈប់ឈរ ។

ចូលមកដល់ឆ្នាំ ១៩៩៣ បរិយាកាស អន្តិសុខនៅតែដដែល ។ នៅ ថ្ងៃ ១១ មករា ឆ្នាំ ១៩៩៣ លោក អាកាស៊ី បានថ្លែងថា : ការបង្កើតលក្ខណៈនយោបាយអព្យាក្រឹត ដែលចាំបាច់ សម្រាប់ធ្វើការបោះឆ្នោត ពុំទាន់អាចធ្វើបាននៅឡើយទេ។ ការលួចសម្លាប់សមាជិក គណបក្សរាជានិយម «ហ៊្វុនស៊ិនប៉ិច» ចេះតែកើតមានឡើងជាហូរហែ។ នៅថ្ងៃ ១៨ មករាព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ប្រធានគណបក្ស «ហ៊្វុនស៊ិនប៉ិច» បាននាំមុខបាតុកម្មគ្រួសារជនរងគ្រោះ ដើម្បប្រឆាំង នឹង ឃាតកម្មទាំងឡាយនោះ ។ ព្រះអង្គ បានចោទ លោក ហ៊ុន សែន លោក ជា ស៊ីម និង អភិបាលខេត្របាត់ដំបង ថាជាអ្នកដែលនាំ ឲ្យមានរឿងបែបនេះ។

## ទីតាំង របស់ ខ្មែរក្រហម នៅឆ្នាំ ១៩៩២ La position des Khmers rouges en 1992

នៅពេលដែល អង្គការ សហប្រជាជាតិ ធ្វើអន្តរាគមន៍ នៅ ប្រទេសកម្ពុជា ពួកខ្មែរក្រហម ដែលមានអ្នកតំណាងរបស់គេ ២ រូប នៅក្នុង «ក្រុមប្រឹក្សាជាតិ ជាន់ខ្ពស់» បែរជាប្រឆាំង នឹង អន្តរាគមន៍នេះ ទៅវិញ ។ មូលហេតុ នៃឥរិយាបថនេះ បែកចេញជាច្រើនកត្តា ប៉ុន្តែ កត្តាដែលសំខាន់ជាងគេ គឺ ការដែលពួកគេត្រូវបាត់បង់អំណាចទាំងអស់ នៅពេលបោះឆ្នោត។ មិនតែប៉ុណ្ណោះសោត គេអាចនឹងត្រូវបញ្ជូនខ្លួនទៅឲ្យ តុលាការកាត់ទោស ពីបទប្រល័យពូជសាសន៍ថែមទៀត ។ ទោះបី គេត្រូវប្រឈមមុខ នឹង សហគមន៍ អន្តរជាតិ ទាំងមូលក្តី ហើយ ទោះបីប្រទេស ចិនបានប្តូរយុទ្ធសាស្ត្រ របស់គេទៅហើយក្តី ក៏ពួកខ្មែរក្រហមទាំងនោះ គ្មានជម្រើស អ្វីទៀត ក្រៅពីបន្តការប្រយុទ្ធរបស់គេទេ ។ តាមការពិតទៅ ខ្មែរក្រហម ត្រូវរលំរលាយ តាំងពីចុងឆ្នាំ ១៩៧៨ មកឯណោះ ប៉ុន្តែ នៅពេលដែល កងទ័ពវៀតណាម វាយលុក មកក្នុងទឹកដីខ្មែរ នៅឆ្នាំ



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

១៩៧៩ ដោយមាន បង្អែកធំមហិមា ពីសហភាព សូវៀត ដើម្បីចូលមកវាយរំលំ របបខ្មែរក្រហម ដែលមានប្រទេសចិន ជាបង្អែក ប្រទេសមួយចំនួន នៃ សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅ «អាស៊ាន» ជា ពិសេសប្រទេសថៃ មានការភិតភ័យយ៉ាងខ្លាំងខ្លាចក្រែងសហភាពសូវៀត ពង្រីក ឥទ្ធិពលមក ដល់ប្រទេសរបស់គេ ថែមទៀត ។ ប្រទេសទាំងនោះ ដែលជាសម្ព័ន្ធ មិត្ត របស់ប្រទេសចិន ផង និង សហរដ្ឋ អាមេរិកផង ត្រូវបង្ខំចិត្តពង្រឹងកងទ័ព របស់ ខ្មែរក្រហម ឡើងវិញ ដើម្បីធ្វើការទប់ទល់ នឹងវៀតណាម ជាពិសេស នឹង សហភាព សូវៀត តែម្តង។ រីឯ សហរដ្ឋ អាមេរិក ដែលជាដៃគូ បដិបក្ខ របស់ សូវៀត នៅសម័យនោះ ក៏ត្រូវចូលរួមចំណែក ក្នុងការទប់ទល់នេះដែរ ។ ប៉ុន្តែ ដោយខ្មែរក្រហម បានត្រូវ មតិអន្តរជាតិ ចោទប្រកាន់ពី បទសម្លាប់ប្រជាជនឯង ជិត ២ លាននាក់ នៅពេលដែលពួកគេ កាន់អំណាច នៅឆ្នាំ ១៩៧៥-១៩៧៩ គេក៏ បង្កើតរណសិរ្សមួយ ដ៏ធំតែម្តង ដោយមានការចូលរួមចំណែក ពីកម្លាំង និង និន្នាការ នយោបាយផ្សេងៗទៀត ដូចជា ចលនារាជានិយម និង ចលនា អ្នកប្រជាធិបតេយ្យជាដើម។ ទោះជាយ៉ាងនេះក្តី ក៏ កម្លាំងកងទ័ពខ្មែរក្រហម ដឹកនាំដោយ ប៉ុល ពត នៅតែជា កម្លាំងប្រយុទ្ធ ធំជាងគេ ដដែល ។ នៅពេលដែល សហភាព សូវៀត រលំរលាយទៅ អ្នកដែលគាំទ្រ ក្រុមខ្មែរក្រហមនេះ ក៏គ្មានប្រយោជន៍អ្វីទៀត នឹង ពង្រឹងកម្លាំងខ្មែរក្រហមបន្តទៅទៀតដែរ។ សាជាថ្មីម្តងទៀត ពួកខ្មែរក្រហមត្រូវវិលទៅរកភាព «ម្ចាស់ការ» របស់គេវិញ ។ ប្រទេសចិនកុម្មុយនិស្ត ក៏ត្រូវបញ្ឈប់សង្គ្រាម នៅកម្ពុជាដែរ ដោយយោងទៅ តាមកាលៈទេសៈថ្មី ពោលគឺការប្រែប្រួល នៃ ការប្រជែងកម្លាំង នៅក្នុងតំបន់ ។ ទោះជាយ៉ាងនេះក្តី ទោះជាវៀតណាម និង ចិនត្រូវ ជានាគ្នា វិញក្តី ក៏ទីក្រុងប៉េកាំង នៅតែមិនទុកចិត្តទីក្រុងហាណូយដដែល ។ ដូចនេះ គេត្រូវតែ រក្សាកម្លាំងនេះ ក្នុងប្រទេសកម្ពុជាបន្តទៅទៀត ទោះបីជាត្រូវបញ្ឈប់ រាល់សកម្មភាពប្រយុទ្ធទ្រង់ទ្រាយធំ សិនក្តី ។

សន្និសីទ អន្តរជាតិ នៅខែកក្កដា ឆ្នាំ ១៩៨៩ នៅ ទីក្រុងប៉ារីស៍ បានខណ្ឌបញ្ចប់អធិករណ៍ រវាង ប្រទេសចិន ដែលមានឥទ្ធិពលធំនៅក្នុងតំបន់ និងសហភាព សូវៀត។

២ ឆ្នាំក្រោយមក កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ឆ្នាំ ១៩៩១ តម្រូវឲ្យ គូភាគីខ្មែរ ឈប់ប្រយុទ្ធគ្នាបន្តទៅទៀត ។ ដើម្បីរៀបចំ ឲ្យមានសន្តិភាព ឡើងវិញ នៅ កម្ពុជា អង្គការសហប្រជាជាតិ ក៏ចុះមកធ្វើអន្តរាគមន៍នៅឆ្នាំ ១៩៩២ ហើយរៀបចំការបោះឆ្នោត ដោយសេរី តាមបែបបទ លទ្ធិប្រជាធិបតេយ្យបស្ចិមប្រទេស ។ ប៉ុន្តែកិច្ចព្រមព្រៀងដ៏សំខាន់នេះ បែរជាហុចផលច្រើន ទៅឲ្យប្រទេសកុម្មុយនិស្ត នៅក្នុងតំបន់ទៅវិញ។ ដើម្បី រក្សាឥទ្ធិពល ឬ អនុត្តរភាព របស់គេ នៅប្រទេសកម្ពុជា ឲ្យនៅ ដដែល ជាពិសេស ដើម្បីទប់ទល់ កុំឲ្យបស្ចិមប្រទេស ចូលមកពង្រីកឥទ្ធិពល របស់គេបានវិញ ប្រទេសចិន និងប្រទេសវៀតណាម ដែលជាគូប្រជែងគ្នា នៅក្នុងការដណ្តើមយក ប្រទេសកម្ពុជា ត្រូវពង្រឹងកូនអុកចាស់ របស់គេ វិញរៀងៗខ្លួន ។ នៅក្នុងដំណាក់ការទី១ សម្តេច នរោត្តម សីហនុ គាំទ្រដោយប្រទេសចិន ត្រូវចាប់ដៃ ជាចាំបាច់ ជាមួយលោក ហ៊ុន សែន គាំទ្រដោយវៀតណាម ។ ប៉ុន្តែ ការកំណត់តុល្យភាព រវាង ទីក្រុងប៉េកាំង និងទីក្រុងហាណូយ នៅក្នុងប្រទេសកម្ពុជា នៅតែស្ថិតនៅ ជា បញ្ហា ពិបាកដដែល។ ខ្មែរក្រហម ខាង ប៉ុល ពត-អៀង សារី ត្រូវរិតខំធ្វើយ៉ាងណា បន្ថយ ឥទ្ធិពល របស់ របប «រដ្ឋកម្ពុជា» ដឹកនាំដោយ លោក ហ៊ុន សែនឲ្យបាន ។ សង្គ្រាមយោធា បានត្រូវបញ្ចប់ក៏ពិតមែន ប៉ុន្តែខ្មែរក្រហម ត្រូវធ្វើយ៉ាងណា ពង្រឹងឥទ្ធិពល របស់ សម្តេច នរោត្តម សីហនុ សិនដែរ។ គឺនៅក្នុងន័យនេះហើយ ដែល ខ្មែរក្រហម ត្រូវអុកឡុក អន្តរាគមន៍ របស់ អង្គការ សហប្រជាជាតិ ហើយ បង្អប់កម្លាំង របស់គេ នៅក្នុងតំបន់សំខាន់ៗ ។ ខ្មែរក្រហម យល់ឃើញ នៅពេលនោះ ថា បេសកកម្ម របស់ អង្គការ សហប្រជាជាតិ មាន រយះពេលតែ ១៨ ខែ ប៉ុណ្ណោះ។ ដូចនេះគេអាចនឹងបន្ត វត្តមាន របស់គេ នៅកម្ពុជាដដែល ដើម្បីទប់ទល់ នឹង ឥទ្ធិពល របស់ វៀតណាម នៅកម្ពុជា ជាពិសេស នៅក្នុង ករណីដែលវៀតណាម មានបង្អែកមួយ ថ្មីទៀត នៅ ពេលអនាគត ។ ទោះជាយ៉ាងណាក្តី នៅចំពោះមុខ ប្រទេសកុម្មុយនិស្ត ទាំង ២ នេះ ត្រូវរក្សាសាមគ្គីភាពគ្នាឲ្យបានសិនដែរ គឺដើម្បីបោះឈមមុខ នឹងកម្លាំងផ្សេងៗទៀត ជាពិសេស ការវិលមកវិញនៃ អ្នកនយោបាយខ្មែរ ដែលមាន និន្នាការ បស្ចិមប្រទេស ។





# បរិយាកាស មុនការបោះឆ្នោត ឆ្នាំ ១៩៩៣

## Avant les élections de 1993

ព្រឹត្តិការណ៍ ទាំងប៉ុន្មាន ដែលស្តែងចេញឡើង នៅឆ្នាំ ១៩៩២ គឺ នៅពេលដែលអង្គការ សហប្រជាជាតិ រៀបចំការបោះឆ្នោត ដោយសេរី បញ្ជាក់ឲ្យឃើញថា ខាងភាគី «រដ្ឋកម្ពុជា» គេនៅតែរក្សាប្រៀប របស់គេ បន្តមកទៀត ។ គ្មានភាគីខ្មែរណាមួយ ខាង «រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ» (G.C.K.D.) អាចយកប្រៀបទៅលើបានទេ។ ម្យ៉ាងទៀត កម្លាំងប្រឆាំង របស់ពួកខ្មែរក្រហម ដឹកនាំដោយ ប៉ុល ពត ក៏ពុំបានគ្របដណ្តប់ ទៅលើ ប្រទេសកម្ពុជា ទាំងមូលបានដែរ ។ ទោះជាយ៉ាងនេះក្តី ការសំខាន់ គឺ ការបោះឆ្នោតបង្កើត សភាធម្មនុញ្ញ និង រដ្ឋសភាឲ្យបានសិន ។ នេះជាផ្លូវតែមួយគត់ សម្រាប់ខណ្ឌបញ្ចប់ទំនាស់ ពិពេលមុន ។ តាមការពិតទៅ តួអង្គ ដែលសំខាន់ជាងគេ នៅពេលនោះ គឺ សម្តេច នរោត្តម សីហនុ និង លោក ហ៊ុន សែន តែប៉ុណ្ណោះ។ ប៉ុន្តែសាជាថ្មីម្តងទៀត គេសង្កេតឃើញថា សម្តេច នរោត្តម សីហនុ ដែលជាអ្នកបង្កើត ចលនា រាជានិយម «ហ្វុនស៊ីនប៉ិច» បែរជា ពុំចង់ឲ្យ ចលនានេះ ដែលដឹកនាំ ដោយព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ជាព្រះរាជបុត្រ ទទួលជ័យជំនះតែម្នាក់ ឯងនៅក្នុងការបោះឆ្នោតទៅវិញ។ គេនៅចាំបានថា កាលពីថ្ងៃ ១៥ វិច្ឆិកាឆ្នាំ ១៩៩១ នៅពេលដែល អ្នកតំណាងប្រទេស និង រដ្ឋាភិបាលចំនួនជាង ៣០ បានមក ប្រគល់សារតាំង នៅចំពោះមុខ «ក្រុមប្រឹក្សាជាតិជាន់ខ្ពស់» ដែលតំណាងអធិបតេយ្យ នៃប្រទេសកម្ពុជា ភាគីខ្មែរក្រហម បានធ្វើការអំពាវនាវ សុំឲ្យគណបក្ស «ហ្វុនស៊ីនប៉ិច» និង គណបក្ស «រណសិរ្សជាតិ រំដោះពលរដ្ឋខ្មែរ» របស់ លោក សឺន សាន រួបរួមគ្នានៅក្នុងការបោះឆ្នោត។ ប៉ុន្តែនៅថ្ងៃ ១៦ វិច្ឆិកា នៅពេលដែល សម្តេច នរោត្តម សីហនុ ថ្លែងសុន្ទរកថា នៅចំពោះមុខប្រជាជនខ្មែរ ព្រះអង្គទ្រង់បានបញ្ចេញ តម្រុយឲ្យដឹងថា ព្រះអង្គប្រាថ្នាចង់ ឲ្យគណបក្ស រាជានិយម «ហ្វុនស៊ីនប៉ិច» រួបរួមជាមួយ គណបក្ស «ប្រជាជន» ទៅវិញ។ ព្រះអង្គបានថ្លែងជាអាទិ៍ ថា : «ព្រះអង្គម្ចាស់រណឫទ្ធិ និង លោក

ហ៊ុន សែន ជាកូនពីរ របស់ ព្រះអង្គ» ។ នៅថ្ងៃ ២៣ វិច្ឆិកា ឆ្នាំ ១៩៩១ ដដែល នោះ សម្តេច នរោត្តម សីហនុ ទ្រង់បានប្រាប់ ឲ្យដឹងត្រង់ៗ តែម្តងថា នឹងមាន ការ រៀបចំបង្កើត រដ្ឋាភិបាលចម្រុះមួយ រវាង គណបក្ស រាជានិយម «ហ្វ៊ុនស៊ិន ប៉ែច» និង អតីតគណបក្សកុម្មុយនិស្តខ្មែរ គឺ «គណបក្សប្រជាជន» ។ នៅ ពេលនោះ លោក សឺន សាន នៅតែចាត់ទុកថា «ក្រុមប្រឹក្សាជាតិជាន់ខ្ពស់» ជា រដ្ឋាភិបាលតែមួយគត់ដដែល។ បីថ្ងៃបន្ទាប់មក គឺនៅថ្ងៃ ២៦ វិច្ឆិកា ការិយាល័យ នៃ ប្រធាន «ក្រុមប្រឹក្សាជាតិ ជាន់ខ្ពស់» បានចេញផ្សាយសេចក្តី ជូនដំណឹងមួយប្រាប់ឲ្យដឹងថា គូភាគីខ្មែរទាំង ៤ បាន ប្រកាសជាផ្លូវការថា សម្តេច នរោត្តម សីហនុ ជាប្រមុខរដ្ឋស្របច្បាប់ និង ពេញសិទ្ធិ នៃប្រទេសកម្ពុជា តាំងពីឆ្នាំ ១៩៦០ មក។ ការបោះឆ្នោតដោយសេរីរៀបចំឡើង ដោយ អង្គការ សហប្រជាជាតិ បានប្រព្រឹត្តទៅនៅថ្ងៃ ២៣ រហូតដល់ថ្ងៃ ២៨ ឧសភាឆ្នាំ ១៩៩៣ ។ ប្រជាជនខ្មែរ ជាច្រើន បានចូលរួមបោះឆ្នោតតែងតាំង សភាធម្មនុញ្ញ គឺ ៨៩, ៥៦ % ហើយនេះ ទោះបីមានការគំរាមកំហែង ពីសំណាក់ខ្មែរក្រហមក្តី។ សូមកត់ សំគាល់ថា នៅពេល រៀបចំ ការបោះឆ្នោត ជា ប្រវត្តិសាស្ត្រ នេះ បរិយាកាស មាន សភាព អាប់អួ ក្រៃលែង ។ ខាងជួរគណបក្ស រាជានិយម «ហ្វ៊ុនស៊ិនប៉ែច» អ្នកដែល ត្រូវគេធ្វើឃាត មាន ចំនួនប្រមាណ ៣០ នាក់។ ខ្មែរ ក្រហមដែលធ្លាប់ល្បីល្បាញ ខាង អំពើបែបនេះ បានត្រូវគេចោទប្រកាន់ថា ជាអ្នកធ្វើអំពើឃាតកម្ម ទាំងអស់នោះ។ ទន្ទឹម នោះដែរ ការិយាល័យ បោះឆ្នោត ជាច្រើនបានត្រូវវាយប្រហារអុកឡុក ហើយ អ្នកបក ប្រែភាសា មួយចំនួន បានត្រូវគេសម្លាប់ចោល។ សន្លឹកឆ្នោត ដែលគេចាត់ទុកថា មិន ត្រឹមត្រូវ តាមគោលការណ៍ បានត្រូវគេលួចយកឬកំទេចចោលអស់។ ការគំរាមកំហែង តាមរូបភាព ចេញមុខ ក៏ មានច្រើនណាស់ដែរ ។ កូនសិស្ស និង គ្រូបង្រៀន បានត្រូវ គេ កំហែងថា សញ្ញាបត្រ របស់ពួកគេ នឹង បាត់សុពលភាព បើគេសង្កេតទៅ ឃើញ ថា នៅក្នុងភូមិ សង្កាត់ របស់គេ មានអ្នកបោះឆ្នោតខុសទិស។ នៅក្នុងរយៈពេល ២ ខែ ចុងក្រោយ នៃយុទ្ធនាការឃោសនាបោះឆ្នោត អំពើហឹង្សា មានកម្រិតខ្ពស់ជាអតិបរមា។ អ្នកដែលបានត្រូវគេធ្វើឃាត មានចំនួន ២០០ នាក់។ ការវាយប្រហារផ្សេងៗ គិត សរុប





ទាំងអស់ មានចំនួន ៣៣៨ ករណី ហើយ ការចាប់មនុស្ស មានចំនួន ១១៤ ករណី។ ទោះជាយ៉ាងនេះក្តី ក៏ប្រជាជនខ្មែរនាំគ្នា ទៅបោះឆ្នោតយ៉ាងគគ្រឹកគគ្រេងគឺ ៩០ % នៃ ចំនួនអ្នក ដែលបានចុះឈ្មោះ បោះឆ្នោត ។ គណបក្សរាជានិយម «ហ្វ៊ុនស៊ិន ប៉ែច» បានទទួល ៤៥ % នៃ សន្លឹកឆ្នោត គឺ ឈ្នះបក្ស«ប្រជាជន» ដែលបានត្រឹម ៣៨ % ប៉ុណ្ណោះ។ បើគិតជាអាសនៈ គណបក្ស «ហ្វ៊ុនស៊ិនប៉ែច» បាន ៥៨ អាសនៈ គណ បក្ស «ប្រជាជន» បាន ៥១ អាសនៈ។ គណបក្ស របស់លោក សឺន សាន គឺ «រណ សិរ្ស ជាតិរំដោះពលរដ្ឋខ្មែរ» ដែលបានប្រែឈ្មោះមក ជាគណបក្ស «ប្រជាធិបតេយ្យ សេរីនិយម ពុទ្ធសាសនា» តាំងពី ថ្ងៃ ២១ ឧសភាឆ្នាំ ១៩៩២ មក បានទទួល ១០ អាសនៈ ។

## រដ្ឋាភិបាល ក្បាលពីរ ក្រោយការ បោះឆ្នោត ឆ្នាំ ១៩៩៣

## Le gouvernement bicéphale après les élections de 1993

នៅថ្ងៃ ១០ មិថុនា ឆ្នាំ ១៩៩៣ លោក អាកាស៊ី អ្នកតំណាង អគ្គលេខាធិការ អង្គការ សហប្រជាជាតិ ប្រកាសថា: «ការបោះឆ្នោតបានប្រព្រឹត្តទៅ ដោយសេរី និង ស្រប ទៅតាមគតិយុត្តិធម៌» ។ ប៉ុន្តែដោយគណបក្សរាជានិយម «ហ្វ៊ុនស៊ិនប៉ែច» បាន ទទួលជ័យជំនះ អតីតគណបក្សកុម្មុយនិស្ត ពោលគឺ គណបក្ស «ប្រជាជន» បែរជា ប្រកាស មិនទទួលស្គាល់ លទ្ធផល នៃ ការបោះឆ្នោតទៅវិញ។ មួយថ្ងៃបន្ទាប់មក ខ្មែរ ក្រហម ក្រោមការដឹកនាំ របស់ ប៉ុល ពត បាន ប្រកាសទទួលស្គាល់លទ្ធផល នៃ ការបោះឆ្នោត ហើយថែមទាំង អំពាវនាវ ឲ្យសម្លាប់ អ្នកដឹកនាំ ៦ នាក់ នៃ គណបក្ស «ប្រជាជន» ផងទៀត។ ដូច្នេះឃើញថា តាំងពីឆ្នាំ ១៩៥២ មក ជាពិសេស តាំងពី

ពេលដែលស្រុកខ្មែរធ្លាក់ទៅក្នុងក្ដក់សង្គ្រាម អស់រយៈពេល ២០ ឆ្នាំមក ការអនុវត្តន៍ គោលការណ៍ ប្រជាធិបតេយ្យ នៅកម្ពុជា ជាការមួយ ដ៏ពិបាកពន់ពេកក្រៃ។ រីឯ មូលហេតុ នៅឆ្នាំ ១៩៩៣ គឺ បណ្ដាលមកពី គណបក្ស «ប្រជាជន» ដែលមាន រចនា សម្ព័ន្ធ របស់គេ យ៉ាងរឹងមាំ នៅក្នុងប្រទេស ចាត់ទុកថា គណបក្ស នានាឯទៀត គ្រាន់តែជាគណបក្សសម្រាប់យក ទៅធ្វើជា រណប របស់គេ តែប៉ុណ្ណោះ ។ អ្វីដែលសំខាន់ ចំពោះពួកគេ គឺតួអង្គសម្ដេចនរោត្ដម សីហនុ តែមួយអង្គ ប៉ុណ្ណោះទេ ។ ក៏ប៉ុន្តែ គណបក្ស «ប្រជាជន» ជាពិសេស ក្រុមលោក ហ៊ុន សែន ផ្ទាល់តែម្ដង ក៏ពុំចង់ប្រគល់ អំណាចអ្វីមួយ ថ្វាយទៅព្រះអង្គដែរ គឺគ្រាន់តែ ទុកសម្រាប់ធ្វើជា រនាំង ធម្មានុរូប របស់ក្រុមគេប៉ុណ្ណោះ។ ចំពោះគណបក្សរាជានិយម «ហ្វុនស៊ិនប៉ិច»វិញ ក៏ គណ បក្ស «ប្រជាជន» ចាត់ទុកថា គ្មានរចនាសម្ព័ន្ធ គ្រប់គ្រាន់ សម្រាប់ប្រឈមមុខ នឹងស្ថានការណ៍ដែរ។ ប៉ុន្តែ នៅចំពោះមុខ គណបក្ស «ប្រជាជន» ត្រូវរិះរកគ្រប់មធ្យោបាយដើម្បីបំបាក់ស្មារតី បំបាត់តួនាទី នៃ ចរន្តនេះ នៅក្នុងប្រវត្តិសាស្ត្រ ឲ្យទាល់តែបាន ដោយហេតុថា ទោះបីវៀតណាម ដកកងទ័ពទៅហើយក្តី ក៏ បញ្ហា ភូមិសាស្ត្រ-នយោបាយនៅតែចោទដដែល ។ មួយវិញទៀត ចំពោះក្រុម លោក ហ៊ុន សែន ក្រុមរាជានិយមនេះអាច នឹង ក្លាយទៅជាបង្អែកមួយដ៏សំខាន់ របស់សម្ដេច នរោត្ដម សីហនុ ដែលជាកូនអុក របស់ចិន។ មួយផ្នែកទៀត ព្រះអង្គម្ចាស់រណឫទ្ធិ អាចនឹង នាំឲ្យមាន ការប្រែប្រួល ការប្រជែងកម្លាំង នៅក្នុងតំបន់ ដោយបែរទៅរកបស្ចិមប្រទេសតែម្ដង គឺផ្លូវដែលសម្ដេច នរោត្ដម សីហនុ ត្រូវរាំងស្កាត់ឲ្យទាន់ ទោះជាត្រូវបោះបង់ គណបក្ស «ហ្វុនស៊ិនប៉ិច» របស់ ព្រះអង្គ ចោលក្ដី ។ ប្រទេសកុម្មុយនិស្ត ទាំងពីរនេះ ធ្វើអ្វីគ្រប់បែបយ៉ាងដើម្បីបិទផ្លូវ មិនឲ្យបស្ចិមប្រទេស វិលមកវិញ បានដោយស្រួលៗ ពេកនោះឡើយ ព្រោះថា ចិនក៏ចង់វាតទីយកឥណ្ឌូចិន វៀតណាម ក៏ ចង់វាតទី យកឥណ្ឌូចិនដូចគ្នា ហើយ វៀតណាមអាច នឹង សម្រេចមហិច្ឆតា របស់គេបាន លុះណាតែ គេមានបង្អែក ដ៏មាំមួយទៀត បន្ទាប់ពី សហភាព សូវៀត រលំរលាយទៅ ។ ដូច្នេះ ឃើញថា ការបោះឆ្នោត នៅក្នុងប្រទេសកម្ពុជា ក៏ជារឿងមួយដ៏សំខាន់ ចំពោះចិន និងវៀតណាមដែរ។ នៅក្នុងយុទ្ធសាស្ត្រ របស់លោក ហ៊ុន សែន ក៏ដូចជា របស់ វៀតណាម សម្ដេច នរោត្ដម សីហនុ ជាកត្តាមួយដ៏សំខាន់ ។ និយាយមួយបែបទៀត គណបក្ស «ប្រជាជន» ដែលមាន លោក ហ៊ុន សែន ជាមនុស្សខ្លាំង ចង់បាន សម្ដេច សីហនុ ប៉ុន្តែ មិនចង់បាន អ្នកគាំទ្រព្រះអង្គទេ ។ មុនការបោះឆ្នោត សម្ដេច នរោត្ដម សីហនុ ក៏យល់ពីគោលបំណងនេះ របស់ លោក ហ៊ុន សែនដែរ ប៉ុន្តែ ព្រះអង្គយល់ថា ព្រះអង្គ អាចនឹងគ្របដណ្ដប់ទៅលើ លោក ហ៊ុន សែន បាន ពោលគឺ ល្បែង «ចចក ចាស់ និង ចចកក្មេង»។ ទោះជាយ៉ាងនេះក្ដី ក៏នៅពេលខ្លះ ព្រះអង្គ មានកង្វល់ខ្លាំង ណាស់ដែរ ។ នៅក្នុងព្រះរាជសារមួយ ជូនប្រជាជនខ្មែរ ចុះថ្ងៃ ៧ មករាឆ្នាំ ១៩៩៣ សម្ដេច នរោត្ដម សីហនុ ទ្រង់បានកត់សំគាល់ថា : «ក្នុងនាមព្រះអង្គ ជាប្រធានក្រុម ប្រឹក្សាជាតិជាន់ខ្ពស់ នៃ ប្រទេសកម្ពុជា ព្រះអង្គ គ្មានអំណាចអ្វីទេ ព្រះអង្គគ្រាន់តែជាអាយ៉ងមួយដែល គេចម្រាញ់យកឥទ្ធិពលសីលធម៌ និង ប្រជាប្រិយភាពតែប៉ុណ្ណោះហើយនេះគឺ ដើម្បីផ្ដល់នូវធម្មានុរូប និង ភាពស្របច្បាប់ ទៅឲ្យសេចក្ដីសម្រេចផ្សេងៗ ដែលភាគច្រើន មានលក្ខណៈផ្ទុយស្រឡះពីបាវចនា ស្នេហាជាតិ របស់ព្រះអង្គ ហើយផ្ទុយពី សារប្រយោជន៍ជាន់ខ្ពស់ របស់ ជាតិ មាតុភូមិ របស់យើងផងទៀត » ។

ទោះបី ព្រះអង្គឈ្វេងយល់ថា ក្រុមលោក ហ៊ុន សែន មាន ប្រៀបទៅលើព្រះអង្គក្ដី ក៏ព្រះអង្គគ្មានជម្រើសអ្វីទៀត ក្រៅពីសម្រប ទៅតាម សេចក្ដីសម្រេចចិត្ត របស់ អង្គការ សហប្រជាជាតិដែរ ជាពិសេស ព្រះអង្គត្រូវសម្រប ទៅតាមស្ថានភាពថ្មី ដែលទីក្រុងប៉េកាំង និង ទីក្រុងហាណូយ ត្រូវរ៉ូវគ្នា ជាបណ្ដោះអាសន្នឡើងវិញ។ ដូចនេះ ការដែលគណបក្ស «ហ្វុនស៊ិនប៉ិច» ឈ្នះឆ្នោត តែម្នាក់ឯង ក៏ អាចជា គ្រោះថ្នាក់មួយ សម្រាប់សម្ព័ន្ធភាព ជាបណ្ដោះអាសន្ន រវាងប្រទេស កុម្មុយនិស្ត ទាំងពីរ នេះដែរ ព្រោះថា ព្រះអង្គម្ចាស់ រណឫទ្ធិ ដែលពុំមានទស្សនៈនយោបាយ និងមនោគមវិជ្ជា ដូចព្រះអង្គ អាចនឹង ផ្ដាច់ប្រទេសកម្ពុជា ចេញពីខ្សែបន្ទាត់ដែលប្រទេសកុម្មុយនិស្ត ទាំងពីរនេះ បានកំណត់ រួចជាស្រេច ពោលគឺ រក្សាទុក តំបន់ឥណ្ឌូចិននេះ ជាទីតាំងដណ្ដើម ឥទ្ធិពលគ្នា ដោយនាំគ្នាបិទច្រក មិនឲ្យ បស្ចិមប្រទេស ចូលមកជ្រៀតជ្រែក

បាន។ ចំពោះវៀតណាម គេចង់ ម៉ៅយកតំបន់នេះ តែឯង ទោះជាថ្ងៃណាមួយ គេត្រូវចងសម្ព័ន្ធមិត្ត ជាមួយ បស្ចិមប្រទេសវិញ ដើម្បីទប់ទល់ នឹង ឥទ្ធិពលចិនក្តី។ រឿងសំខាន់បំផុត របស់ វៀតណាម គឺ ត្រួតត្រាឥណ្ឌូចិន មិនឲ្យធ្លាក់ទៅក្នុង កណ្តាប់ដៃ ចិនជាដាច់ខាត។ ប៉ុន្តែ ទន្ទឹមនោះ វៀតណាម ក៏មិនឲ្យអ្នកនយោបាយខ្មែរ បស្ចិមប្រទេសនិយម ជ្រៀតជ្រែក ចូលមកក្នុងយុទ្ធសាស្ត្រនេះ បានដែរ ។ គឺនៅក្នុងន័យនេះហើយដែលនៅថ្ងៃ ២០ វិច្ឆិកា ឆ្នាំ១៩៩១ គណបក្ស «ប្រជាជន» បានចេញសេចក្តីថ្លែងការណ៍មួយ ថ្កោលទោស ដល់អ្វីដែលគេហៅថា «រដ្ឋប្រហារថ្ងៃ ១៨ មិនាឆ្នាំ ១៩៧០» ហើយ សុខចិត្តទទួលស្គាល់សម្តេច នរោត្តម សីហនុ ជាប្រមុខរដ្ឋ តែមួយគត់ ។ មិនតែប៉ុណ្ណោះសោត ក្រោយមកទៀត នៅថ្ងៃ ១៤ មិថុនា ឆ្នាំ ១៩៩៣ សភាធម្មនុញ្ញ បានអនុម័ត ជាឯកច្ឆន្ទ នូវ សេចក្តីសម្រេចចិត្តមួយ ដែលលុបចោល ការបោះឆ្នោតរដ្ឋសភាដែល បានទម្លាក់សម្តេច នរោត្តម សីហនុ ចេញពីអំណាច នាថ្ងៃ ១៨ មិនាឆ្នាំ ១៩៧០ ផងដែរ ។ ហើយ គឺនៅក្នុងន័យនេះដែរ ដែលសម្តេច នរោត្តម សីហនុ បានជម្រុញឲ្យបង្កើតរដ្ឋាភិបាលចម្រុះ រវាង គណបក្ស«ហ្វុនស៊ីនប៉ិច» និង គណបក្ស «ប្រជាជន» ក្រោយការបោះឆ្នោតឆ្នាំ ១៩៩៣ ទោះបី គណបក្ស «ហ្វុនស៊ីនប៉ិច» ដែលជាគណបក្សរបស់ ព្រះអង្គសោះនោះ ឈ្នះឆ្នោត ក៏ដោយ។ នៅថ្ងៃ ១៦ មិថុនា ដដែលនោះ សម្តេច នរោត្តម សីហនុ តែងតាំងព្រះអង្គម្ចាស់ រណឫទ្ធិ និង លោក ហ៊ុន សែន ជាសហនាយករដ្ឋមន្ត្រី គឺនាយករដ្ឋមន្ត្រី ដល់ទៅ ពីររូប ក្នុងពេលតែមួយ ។ នេះជាព្រឹត្តិការណ៍ដែលមិនធ្លាប់ដែលមានសោះនៅក្នុងប្រវត្តិសាស្ត្រ។ បន្ទាប់ពីការតែងតាំងនេះ គណបក្ស «ប្រជាជន» ក៏សុខចិត្ត ទទួលស្គាល់លទ្ធផល នៃ ការបោះឆ្នោត នាឆ្នាំ ១៩៩៣ នោះ ។

# ព្រឹត្តិការណ៍ នាខែ មិថុនា ឆ្នាំ ១៩៩៣

## Les principaux événements de Juin 1993



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

នៅថ្ងៃ ៣ មិថុនា គឺ ប៉ុន្មានថ្ងៃ ក្រោយការបោះឆ្នោត ហើយមួយសប្តាហ៍ មុនថ្ងៃត្រូវប្រកាសលទ្ធផល ជាផ្លូវការ សម្តេច នរោត្តម សីហនុបាន ប្រកាសតែងតាំងខ្លួនព្រះអង្គជានាយករដ្ឋមន្ត្រី និង ជាអគ្គបញ្ជាការកងទ័ពខ្មែរ ដោយជ្រើសរើសព្រះអង្គម្ចាស់ រណឫទ្ធិ និង លោក ហ៊ុន សែន ជា ឧបនាយករដ្ឋមន្ត្រី ។ នេះជា ព្រឹត្តិការណ៍មួយ ដែលធ្វើឲ្យមានការភ្ញាក់ផ្អើល យ៉ាងខ្លាំង។ រីឯ រដ្ឋាភិបាលនោះ បានត្រូវប្រសិទ្ធិនាមថា «រដ្ឋាភិបាលជាតិ នៃ ប្រទេសកម្ពុជា» ។ ខ្មែរក្រហមដែលនៅស្ងប់ស្ងៀមអស់មួយរយៈពេល ធំពុំបានត្រូវបញ្ចូល មកក្នុងរដ្ឋាភិបាល នោះទេ ។ លោក អាកាស៊ី អ្នកតំណាង អគ្គលេខាធិការ អង្គការ សហប្រជាជាតិ និង ជាអ្នកទទួលខុសត្រូវអង្គការ «អាប្រូនុច» ក៏បាន ចាត់ទុកថា ការផ្តួចផ្តើមគំនិតនេះ របស់ សម្តេច នរោត្តម សីហនុ មាន សារៈសំខានដែរ ។ លោក ខៀវ កញ្ញារីទ្ធិ អ្នកនាំពាក្យម្នាក់ខាង «រដ្ឋកម្ពុជា» បានបញ្ជាក់ប្រាប់ថា ភាគី របស់ខ្លួន នឹង រំលាយរដ្ឋាភិបាល របស់ ខ្លួន គឺ រដ្ឋាភិបាល ដែលបានគ្រប់គ្រងប្រទេសអស់រយៈពេល ១៤ ឆ្នាំមកហើយ។ លោកខៀវ កញ្ញារីទ្ធិ បានថ្លែងថា : ការបង្កើតរដ្ឋាភិបាលថ្មីនេះ ពុំអាចជំនួស លទ្ធផល នៃ ការបោះឆ្នោតបានទេ ប៉ុន្តែគ្រាន់តែសម្រាប់ឆ្លងកាត់ អន្តរកាលមួយ ប៉ុណ្ណោះ។ ការពិត គឺថា ខាង «រដ្ឋកម្ពុជា» គេសុខចិត្តទទួលយកសម្តេច នរោត្តម សីហនុ ប៉ុន្តែ មិនអាចទទួលយក ព្រះអង្គម្ចាស់ រណឫទ្ធិ បានទេ។ ប្រទេសជប៉ុន ប្រទេស វៀតណាម និង ប្រទេសថៃក៏ពុំយល់ទាស់អ្វីនឹង ដំណោះស្រាយនេះដែរ ព្រោះគេ ចាត់ទុកថា គេគ្មានសិទ្ធិ ចូលជ្រៀតជ្រែក ក្នុងបញ្ហាខ្មែរទេ។ នៅថ្ងៃ ៣ មិថុនានោះ អ្វីៗ ហាក់បីដូចជា អាចធ្វើទៅបាន ។ ប៉ុន្តែស្រាប់តែថ្ងៃបន្ទាប់ គឺ ថ្ងៃ ៤ មិថុនា សម្តេច នរោត្តម សីហនុ បែរជាប្រកាសរំលាយ រដ្ឋាភិបាលនោះចោលទៅ វិញ។ ការសម្រេចចុងក្រោយនេះ របស់ សម្តេច នរោត្តម សីហនុ បណ្តាលមកពីការមិនយល់ព្រម ពីគណបក្ស«ហ្វុនស៊ីនប៉ិច» ។ ព្រះអង្គម្ចាស់ នរោត្តម សេរីវុឌ្ឍ នៃ គណបក្សរាជានិយមនេះ បានប្រកាស ឲ្យដឹងថា : សហគមន៍ អន្តរជាតិ ពុំអាចទទួលយករដ្ឋាភិបាលដែលកើតចេញ ពីការបរបាដូច្នេះបានទេ។ សូមកត់សំគាល់

ថា នៅពេលនោះ សហរដ្ឋ អាមេរិក ប្រទេសអង់គ្លេស ប្រទេសអូស្ត្រាលី ហើយ ប្រទេស ចិន ផងដែរ ក៏មិនយល់ស្រប នឹង ការបង្កើត រដ្ឋាភិបាលនេះដែរ។ សហរដ្ឋ អាមេរិក ខ្លាចក្រែងការប្រមាថដល់ ការបោះឆ្នោត បែបនេះ អាចមាន បន្តទៅទៀត នៅថ្ងៃមុខ ។ មួយវិញទៀត ការធ្វើរបៀបនេះ អាចប៉ះពាល់ យ៉ាងធ្ងន់ធ្ងរ ដល់ សភាធម្មនុញ្ញទៀតផង ព្រោះមាន តែ សភាធម្មនុញ្ញ ប៉ុណ្ណោះដែល មានភារកិច្ចប្រកាស អនុម័តរដ្ឋធម្មនុញ្ញ ។

ពីរថ្ងៃក្រោយ ការរំលាយ រដ្ឋាភិបាលនោះ អ្នកនាំពាក្យ ខាង «រដ្ឋកម្ពុជា» ប្រកាស ពុំទទួលស្គាល់ លទ្ធផល នៃ ការបោះឆ្នោតបន្តទៀត។ សាជាថ្មីម្តងទៀត ប្រទេសកម្ពុជា បានឈានចូល មកដល់ វិបត្តិមួយទៀត ។ អង្គការ សហប្រជាជាតិ ចាប់ផ្តើមមាន ការ បារម្ភសាជាថ្មី បន្ទាប់ពីបាន ទទួលជោគជ័យ ក្នុងការដឹកនាំ ការបោះឆ្នោត ដោយសេរី។ នៅថ្ងៃ ៨ មិថុនា អង្គការ «អាប្រូនុប» បានសុខចិត្ត ទទួលយក ផែនការ របស់ សម្តេច នរោត្តម សីហនុ ប៉ុន្តែអ្វីៗ ក៏ជ្រុលហួស អស់ទៅហើយ។ ខាងខ្មែរក្រហម គេក៏ប្រកាស គាំទ្រផែនការនោះ ដែរ។ អ្វីដែលគេកត់សំគាល់ នៅពេលនោះ គឺ ថា ខាង គណបក្ស «ប្រជាជាន» គេមិនដែលជឿថា គេអាចចាញ់ នៅក្នុង ការបោះឆ្នោតនោះទេ។ មិនតែប៉ុណ្ណោះ គេថែមទាំងជឿថា គេនឹងទទួលបាន ៧០ % នៃ សន្លឹកឆ្នោតទៀតផង ។ ប៉ុន្តែ នៅពេលរាប់សន្លឹកឆ្នោត គេបានដឹងថា គឺជាការភាន់ច្រឡំមួយ ដ៏ធំ ព្រោះអង្គការ «អាប្រូនុប» បានធ្វើអ្វី គ្រប់បែបយ៉ាង ដើម្បីឲ្យ ការបោះឆ្នោត ប្រព្រឹត្តទៅ ដោយត្រឹមត្រូវបំផុត។ នៅចំពោះមុខស្ថានភាពនេះ រដ្ឋាភិបាល «រដ្ឋកម្ពុជា» មិនព្រមឲ្យគណបក្ស «ហ្វុនស៊ិនប៉ិច» ឈ្នះជាដាច់ខាត។ នៅថ្ងៃ ៩ មិថុនា ឧត្តមសេនីយ៍ ជាង ៤០ នាក់ នៃ អតីតរបប «សាធារណរដ្ឋ ប្រជាមានិតុ កម្ពុជា»ដែលនៅក្នុងនោះ មានលោក តៀ បាញ់ រដ្ឋមន្ត្រីការពារជាតិផងដែរ បាន នាំគ្នាទៅគាល់ សម្តេច នរោត្តម សីហនុ នៅ ព្រះរាជវាំង។ ពួកគេ បានទាមទារ ឲ្យព្រះអង្គ ធ្វើការគាបសង្កត់ ទៅលើ គណបក្ស «ហ្វុនស៊ិនប៉ិច» ដើម្បីធ្វើការបែងចែកអំណាច។ នៅថ្ងៃ ១០ មិថុនា ព្រះអង្គម្ចាស់ចក្រពង្ស ឧបនាយករដ្ឋមន្ត្រី នៃ របប «រដ្ឋកម្ពុជា» បានប្រកាស ធ្វើអបគមន៍ តែម្តង ។ បើតាម





ការអះអាង របស់លោក អាកាស៊ី នៅពេលនោះ ៤០ % នៃទឹកដីខ្មែរ បានត្រូវប្រកាសឲ្យផ្តាច់ចេញ គឺ ខេត្រទាំងប៉ុន្មានដែលស្ថិតនៅត្រើយខាងកើត នៃ ទន្លេមេកុង ។

យោងទៅតាម កិច្ចព្រមព្រៀង ទីក្រុងប៉ារីស៍ ឆ្នាំ ១៩៩១ វាសនា របស់ ប្រទេសកម្ពុជា ត្រូវកំណត់ ដោយការបោះឆ្នោត ។ ភាគីខ្មែរណា ក៏យល់ព្រមដែរ ប៉ុន្តែ ក្រោយការបោះឆ្នោត គឺនៅពេល រាប់សន្លឹកឆ្នោត បណ្តើរៗ គេដឹងជាស្រេចថា គណបក្សរាជានិយម «ហ្វុនស៊ិនប៉ិច» នឹង ទទួលជ័យជំនះ ។ សម្តេច នរោត្តម សីហនុ ទ្រង់ ឈ្វេងយល់ថា បើគណបក្សរាជានិយម ឈ្នះមែននោះ វិបត្តិ នឹង អាចកើតមានឡើង ព្រោះ គណបក្ស«ប្រជាជន» នឹងមិនព្រមជាដាច់ខាត ដូចមានតម្រុយខ្លះៗ រួចមកហើយ នៅពេលយុទ្ធនាការ ឃោសនា បោះ ឆ្នោត ដែលសមាជិកគណបក្ស ជាច្រើនរូបបាន ត្រូវគេលួចសម្លាប់ចោល។ តាមការពិត ព្រះអង្គមិនទុកចិត្តព្រះអង្គម្ចាស់រណឫទ្ធិ ដែល អាច នឹងនាំប្រទេស ឆ្ពោះ ទៅទិសដៅមួយដែលព្រះអង្គមិនយល់ស្រប។ មួយវិញទៀត បញ្ហាក្នុងគ្រួសារ របស់ ព្រះអង្គ ក៏ចោទឡើង ក្នុងពេលជាមួយគ្នាដែរ ។ ខាងលោក ហ៊ុន សែន ឯនោះវិញ អ្វីដែលលោក ហ៊ុន សែន ប្រាថ្នាចង់បាន ក្នុងការបោះឆ្នោត នោះ គឺ ភាពស្របច្បាប់ និង ការទទួលស្គាល់ពីសហគមន៍ អន្តរជាតិ នូវ អំណាចមួយ ដែលបានត្រូវគេថ្កោលទោស អស់រយៈពេល ១៤ ឆ្នាំ មកហើយ ។ ប៉ុន្តែ ប្រជាជនខ្មែរ ភាគច្រើននៅពេលនោះ បែរជាបោះឆ្នោត ឲ្យគណបក្ស «ហ្វុនស៊ិនប៉ិច» ទៅវិញ ព្រោះ គេយល់ថា ជា គណបក្ស របស់ សម្តេច នរោត្តម សីហនុ ។ ទោះបី មានការគំរាមកំហែង ពីសំណាក់អតីតគណបក្សកុម្មុយនិស្ត យ៉ាងណាក្តី គេក៏ប្តូរផ្តាច់ នាំគ្នាបោះឆ្នោត ថ្វាយអំណាចទៅ អតីតប្រមុខរដ្ឋខ្មែរ កាលសម័យ «សង្គមរាស្ត្រនិយម» វិញដែរ ព្រោះ គេស្រណោះ សម័យកាលនោះ ដែលស្រុកខ្មែរ មានសន្តិភាព ។ ដោយគេពុំ បានដឹង អំពីទំនាស់ នយោបាយ និង អំណាច ដែលប្រទាក់ក្រឡាគ្នា យ៉ាងស្មុគស្មាញ ក្នុងគ្រួសារ គេសង្ឃឹមថា ព្រះអង្គម្ចាស់ រណឫទ្ធិ ដែលជាបុត្រមួយអង្គ របស់ សម្តេច នរោត្តម សីហនុ ពិតជានឹងនាំមក នូវអ្វីៗ ដែលខ្មែរបានបាត់បង់ នៅពេលសង្គ្រាម ជាពុំខាន ។ ទោះជាយ៉ាងណាក្តី គេសង្កេតឃើញថា នៅពេលនោះ លោក ហ៊ុន សែន ពុំ

អាចគ្រប់ដណ្ដប់ទៅលើ កិត្យានុភាព របស់ សម្ដេច នរោត្តម សីហនុ បានដែរ ទោះ បី ព្រះអង្គ ធ្លាប់បានបណ្ដោយខ្លួន ឲ្យពួកខ្មែរក្រហម ខាង ប៉ុល ពត យក កិត្យានុភាព របស់ ព្រះអង្គ ទៅប្រើប្រាស់មួយរយៈពេល ក៏ដោយ។ នៅចំពោះមុខ ការត្រូវបាត់បង់អំណាចបែបនេះ លោក ហ៊ុន សែន ត្រៀមលក្ខណៈ ជាស្រេច ដើម្បីដណ្ដើមយកអំណាចមកវិញ ។ មុនដំបូង គឺ មិនទទួលស្គាល់ លទ្ធផល នៃ ការបោះឆ្នោត ហើយ បន្ទាប់មក ធ្វើការគាបសង្កត់ ទៅលើ សម្ដេច នរោត្តម សីហនុ។ នៅពេលដែលសម្ដេច នរោត្តម សីហនុ ប្រកាសរំលាយ «រដ្ឋាភិបាលជាតិ» របស់ព្រះអង្គ កាលពីថ្ងៃ ១៤ មិថុនា គឺមួយថ្ងៃក្រោយ ការបង្កើតរដ្ឋាភិបាលនេះ រដ្ឋាភិបាលផុតអំណាច របស់ លោក ហ៊ុន សែន បាន បញ្ចេញប្រតិកម្មយ៉ាងខ្លាំង ។ បន្ទាប់ពី ឧត្តមសេនីយ៍ ៤០ រូប នៃ អតីតរបប កុម្មុយនិស្ត បាននាំគ្នាចូលទៅក្នុងព្រះរាជវាំង ដើម្បីទាមទារឲ្យធ្វើការបែងចែកអំណាច ព្រះអង្គម្ចាស់ចក្រពង្សព្រះរាជបុត្រមួយអង្គទៀត របស់ សម្ដេច នរោត្តម សីហនុ ដែលចូលខាង គណបក្ស «ប្រជាជន» របស់ លោក ហ៊ុន សែន បានសម្រេចធ្វើ អបគមន៍ ទឹកដីតែម្ដង ។ លោក ឧត្តមសេនីយ៍ ស៊ិន សុង អតីតរដ្ឋមន្ត្រីសន្តិសុខ នៃ រដ្ឋាភិបាលផុតអំណាច របស់ លោក ហ៊ុន សែន ក៏ ចូលរួមចំណែកក្នុងការទាមទារ ធ្វើ អបគមន៍ នោះដែរ ។

ព្រះអង្គម្ចាស់ ចក្រពង្ស បានទាមទារ នៅពេលនោះ សុំឲ្យបង្កើតរដ្ឋាភិបាលជាតិមួយ ដូចដែលសម្ដេច នរោត្តម សីហនុ ជាព្រះបិតា បានប្រកាសកាលពីថ្ងៃ ៣ មិថុនា ដូច្នេះដែរ។ នៅក្នុងពេលដដែលនោះ មានបាតុកម្ម ជាច្រើននៅទីក្រុងភ្នំពេញ ទាមទារឲ្យអង្គការ «អាប្រូនុប» ចេញពីប្រទេសកម្ពុជា ហើយ ទាមទារ ឲ្យគណបក្ស «ហ្វុនស៊ិនប៉ិច» និង គណបក្ស «ប្រជាធិបតេយ្យសេរីនិយមពុទ្ធសាសនា» របស់ លោក សឺន សាន ដកខ្លួនចេញ ពីតំបន់ អបគមន៍។ បាតុកម្មទាំងនោះ មានលក្ខណៈហឹង្សា ដ៏ខ្លាំងមហិមា គឺមានដល់ទៅអាវុធ បង្ខំឲ្យឧត្តម្កាគបក្រ របស់អង្គការ «អាប្រូនុប» ហោះ ចេញថែមទៀត។ ចរាចរណ៍ តាមផ្លូវគោក និង តាមផ្លូវទឹក បានត្រូវហាមឃាត់ ។ អ្នកជាប់ឆ្នោត នៃគណបក្ស «ប្រជាជន» ចំនួន ៣០ នាក់ បាន សុំលាលែងពីមុខតំណែង ។ ទោះ





ជាយ៉ាងនេះក្ដី ក៏ពួកអ្នកសង្កេតការណ៍ ពុំមានការព្រួយបារម្ភអ្វីដែរ ព្រោះ ប្រទេសវៀតណាម ពុំគាំទ្រ ការបះបោរ នេះ របស់ ព្រះអង្គម្ចាស់ ចក្រពង្ស និង៖ លោក ស៊ិន សុង ទេ ។ នៅចំពោះមុខ ស្ថានការណ៍នេះ ព្រះអង្គម្ចាស់ រណឫទ្ធិ ប្រកាសថា ព្រះអង្គត្រៀមលក្ខណៈជាស្រេច ដើម្បី ប្រមូល កងទ័ព របស់ព្រះអង្គចំនួន ៥ ពាន់ នាក់ ដើម្បីវាយដណ្ដើមយកខេត្តទាំងប៉ុន្មាននោះ មកវិញ ។

# ការប្រឈមមុខដាក់គ្នា
# រវាង ព្រះអង្គម្ចាស់ ចក្រពង្ស
# នឹង ព្រះអង្គម្ចាស់ រណឫទ្ធិ

## Les princes ennemis

បន្ទាប់ពី ព្រះអង្គម្ចាស់ចក្រពង្ស ប្រកាសធ្វើ អបគមន៍ខេត្តទាំងប៉ុន្មាន ដែលស្ថិត នៅ ខាងកើត ទន្លេមេកុង ព្រះអង្គម្ចាស់ នរោតម្ដ រណឫទ្ធិ អ្នកដឹកនាំ គណបក្សរាជា និយម «ហ្វុនស៊ិនប៉ិច» ហើយដែលជាបង របស់ព្រអង្គម្ចាស់ចក្រពង្ស[40] គំរាមថា នឹង កេណ្ឌទ័ព ៥ ពាន់នាក់ ់វាយយកខេត្ត ទាំងនោះមកវិញ ។ ព្រះអង្គម្ចាស់រណឫទ្ធិ កំញើញគណបក្ស «ប្រជាជន» ថា ព្រះអង្គនឹងយាងទៅប្រទេសនានា ក្នុងសកលលោក ដើម្បីស្នើឲ្យគេ កាត់ស្បៀង គណបក្ស «ប្រជាជន» ផងទៀត ។ ប៉ុន្តែ នៅពេលនោះ លោក អ៊ឹង ហួត ដែលជាអ្នកបាត់បែង យុទ្ធនាការ ឃោសនាបោះឆ្នោត របស់ គណ

---

[40] ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និង ព្រះអង្គម្ចាស់ នរោត្តម ចក្រពង្ស ជាបុត្រ របស់ សម្ដេច នរោត្តម សីហនុ ប៉ុន្តែ ម្ដាយទីទៃ ។ ម្ដាយ របស់ ព្រះអង្គម្ចាស់ រណឫទ្ធិ គឺ អ្នកម្នាង កញ្ញ៉ុល ហៅ ស៊ុយស្ហាន រីឯម្ដាយ របស់ ព្រះអង្គម្ចាស់ ចក្រពង្ស គឺ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ពង្សរានមុនី ។

បក្ស «ហ្វុនស៊ីនប៉ិច» បានផ្ដល់ជាយោបល់ដូច្នេះវិញថា : «យើងត្រូវប្រើប្រាស់ មធ្យោបាយ នយោបាយ និង គោលការណ៍ ប្រជាធិបតេយ្យវិញ ព្រោះយើងត្រូវចៀសវាងសង្គ្រាមឲ្យបាន» ។ នៅក្នុងពេល ដដែលនោះ សមាជិក គណបក្ស «ហ្វុនស៊ីនប៉ិច» ប្រមាណ ៤ ពាន់នាក់ បាននាំគ្នារត់ចេញពីខេត្តចំនួន ៣ ដែលស្ថិតនៅ ខាងកើត ទន្លេមេកុង ដើម្បីគេចពី ការវាយប្រហារ របស់ព្រះអង្គម្ចាស់ ចក្រពង្ស និង ឧត្ដមសេនីយ៍ ស៊ិន សុង ។ សូមកត់សំគាល់ថា ខាង «រដ្ឋកម្ពុជា» គេមានកងទ័ពចំនួន ៤ ម៉ឺន ៥ ពាន់នាក់ ហើយ កងជីវពល (milice) ចំនួន ១ ម៉ឺននាក់។ ឧត្ដមសេនីយ៍ ប៉ុល សារឿន ជាមេបញ្ជាការកងទ័ព រីឯលោក ស៊ិន សុង ជារដ្ឋមន្ត្រីមហាផ្ទៃ។ ខាង កងទ័ពព្រះអង្គម្ចាស់រណឫទ្ធិ បើបូករួមជា មួយកងទ័ព «រណសិរ្សជាតិ រំដោះពលរដ្ឋខ្មែរ» របស់ លោក សឺន សាន ផង គឺ មានចំនួនប្រមាណ ១ ម៉ឺននាក់ប៉ុណ្ណោះ ។ ទោះជាយ៉ាងនេះក្ដី ទោះបី គណបក្ស «ប្រជាជន» មិនព្រមទទួលស្គាល់ លទ្ធផល នៃ ការបោះឆ្នោតក្ដី ក៏គេធ្វើសេចក្ដីកែតម្រូវថា គ្មានរដ្ឋប្រហារ អ្វីណាមួយកើតឡើងទេ ។ នៅពេលដែលរឿង ទាំងឡាយនោះ កើតមានឡើង ខ្មែរក្រហម ប្រកាសថា គេ ប្រឆាំង នឹង អបគមន៍ នោះជាដាច់ខាត រីឯ សម្ដេច នរោត្ដម សីហនុ វិញ តាមរយៈវិទ្យុ ព្រះអង្គគ្រាន់តែថ្លែងថាព្រះអង្គមានកង្វល់យ៉ាងខ្លាំង ប៉ុន្តែព្រះអង្គ មិនដឹង ជាត្រូវដោះស្រាយបែបណាទេ ។ អ្នកសង្កេតការណ៍ខ្លះ យល់ឃើញថា ព្រះអង្គ ម្ចាស់ចក្រពង្ស ធ្វើដូច្នេះដោយមាន ការយល់ព្រម ពី សម្ដេច សីហនុ គឺ យុទ្ធសាស្ត្រមួយ សម្រាប់បង្ខំ ឲ្យគណបក្ស «ហ្វុនស៊ីនប៉ិច» រួបរួម ជាមួយ គណបក្ស «ប្រជាជន» ។ ប៉ុន្តែ អ្នកសង្កេតការណ៍ខ្លះទៀត យល់ឃើញថា: ពុំមែនដូច្នេះទេ ព្រោះព្រះអង្គម្ចាស់ចក្រពង្ស ប្រហែលជាអនុវត្ត ផែនការមួយ ដែលរៀបចំតាំង ពីឆ្នាំ ១៩៨៩ មកឯណោះ គឺ ក្រោយពេលដែលវៀតណាម ដកកងទ័ព ។ ផែនការនោះ ជាផែនការ របស់ គណបក្ស «ប្រជាជន» ដែលមាន គម្រោងទប់ទល់ នឹងកងទ័ពខ្មែរក្រហម នៅក្នុងករណី ដែលពួកនេះ វាយដណ្ដើម យកអំណាចតាមផ្លូវយោធា។ មុនពេលបើកអង្គប្រជុំ សភាធម្មនុញ្ញ នាថ្ងៃទី ១៤ មិថុនា គេកាត់ស្មានថា អ្នកដឹកនាំគណបក្ស «ប្រជាជន» នៅពីក្រោយ ។ ប៉ុន្តែ





ក្រោយអង្គប្រជុំ លោក ហ៊ុន សែន និង លោក ជា ស៊ីម បានលើកឡើង អំពីគ្រោះថ្នាក់ ដ៏ធំ ដែលអាចកើតចេញពី ការធ្វើអបគមន៍ នេះ ។

នៅថ្ងៃ ១១ មិថុនា ឆ្នាំ ១៩៩៣ អង្គការ «អាប្រូនុប» ប្រកាស ជាផ្លូវការ លទ្ធផល នៃការបោះឆ្នោត ហើយ ផ្សព្វផ្សាយ ឈ្មោះ អ្នកដែលបានត្រូវជ្រើសតាំងជាសមាជិក សភាធម្មនុញ្ញ ។ រីឯលទ្ធផល នៃ ការបោះឆ្នោត មានដូចតទៅ ៖

- គណបក្ស «ហ្វុនស៊ីនប៉ិច» បានទទួល ៤៥, ៤៧ % នៃ សន្លឹក ឆ្នោត។ បើគិតជាចំនួនអ្នកបោះឆ្នោតឲ្យគឺ ១ លាន ៨ សែន ២ ម៉ឺន ៤ ពាន់ ១៨៨ នាក់ ។ បើគិត ជា អាសនៈ គឺ ៥៨ អាសនៈ ។

- គណបក្ស «ប្រជាជន» បានទទួល ៣៨, ២២ % នៃ សន្លឹកឆ្នោត។ អ្នកបោះឆ្នោតឲ្យមានចំនួន ១ លាន ៥ សែន ៣ ម៉ឺន ៣ ពាន់ ៤៧១ នាក់ ។ បើគិត ជាអាសនៈ គឺ ៥១ អាសន។

- គណបក្ស «ប្រជាធិបតេយ្យ សេរីនិយម ពុទ្ធសាសនា» បាន ទទួល ៣, ៨១ % នៃ សន្លឹកឆ្នោត ។ អ្នកបោះឆ្នោត ឲ្យគណបក្សនេះ មានចំនួន ១ សែន ៥ ម៉ឺន ២ ពាន់ ៧៦៤ នាក់ ។ អាសនៈដែលត្រូវទទួល គឺ ១០ អាសនៈ ។

- គណបក្ស «មូលីណាកា»ដែលទទួលបាន ១, ៣៧ % នៃ សន្លឹកឆ្នោត បានតែ ១ អាសនៈ ប៉ុណ្ណោះ ។

សន្លឹកឆ្នោតក្លែងបន្លំ មានចំនួន ១ សែន ២ ម៉ឺន ២ ពាន់ ៧៦១ រីឯ សន្លឹក ឆ្នោតដែលពុំអាចទទួលយកបាន បន្ទាប់ពី ការពិនិត្យផ្ទួគ្គង មាន ១ សែន ៤ ម៉ឺន ១ ពាន់ ៨ រយសន្លឹក ។

គេសង្កេតឃើញថា ក្នុងចំណោម អ្នកតំណាងរាស្ត្រចំនួន ៥១ នាក់ នៃ គណបក្ស «ប្រជាជន» គេពុំឃើញមាន ឥស្សរជន ជំនាន់បក្សកុម្មុយនិស្ដ «ប្រជាជនបដិវត្ត កម្ពុជា»ទេ ។ សូមកត់សំគាល់ថា ទោះបីគណបក្សរាជានិយម «ហ្វុនស៊ីនប៉ិច» បានទទួលជ័យជំនះ ទៅលើគណបក្ស «ប្រជាជន» ក៏ដោយ ក៏ចំនួនអ្នកតំណាងរាស្ត្រភាគច្រើន នៅក្នុងរដ្ឋសភា ពុំគ្រប់គ្រាន់ សម្រាប់អនុម័តរដ្ឋធម្មនុញ្ញបានដែរ គឺមានចំនួន

តែ ៥៨ នាក់ ប៉ុណ្ណោះ ។ នៅថ្ងៃ ១១ មិថុនា គណបក្ស «ហ្វុនស៊ីនប៉ិច» និងគណបក្ស «ប្រជាធិបតេយ្យ សេរីនិយមពុទ្ធសាសនា» របស់ លោក សឺន សាន បានប្រកាស ធ្វើសម្ព័ន្ធភាព ។ ប៉ុន្តែ បើបូកសរុបទាំងអស់មក បានត្រឹម ៦៨ សំឡេង ប៉ុណ្ណោះ គឺ បើយោងទៅតាមកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ពុំមានលក្ខណៈគ្រប់គ្រាន់ សម្រាប់អនុម័តរដ្ឋធម្មនុញ្ញ បានទេ ។

# ការបែកអំណាចគ្នា រវាង គណបក្ស «ប្រជាជន» នឹង គណបក្ស «ហ្វុនស៊ីនប៉ិច» នៅឆ្នាំ ១៩៩៣

## Partage des pouvoirs entre Le P.P.C. et le F.U.N.C.I.N.P.E.C.

ពីរថ្ងៃ ក្រោយពេលដែល អង្គការ «អាប្រូនុច» បានប្រកាស លទ្ធផល នៃការបោះឆ្នោត ពោលគឺនៅថ្ងៃ ១៤ មិថុនា សភាធម្មនុញ្ញ បានបើកសម័យប្រជុំលើកដំបូងបង្អស់របស់ខ្លួន។ ខាងគណបក្ស «ប្រជាជន» មានអ្នកតំណាង ៥១ រូប។ ប្រការដែលគួរឲ្យកត់សំគាល់ គឺថា អ្នកដែលបានធ្វើការតស៊ូ នៅក្នុង អតីតរបបកុម្មុយនិស្តពីពេលមុន មានចំនួនតិចណាស់ ហើយ អ្នកដែលមាន ឥទ្ធិពល ដ៏ខ្លាំងក្លា នៅក្នុងរបបដែលបន្ទាប់ ដោយ កងទ័ពវៀតណាម ក៏មិនឃើញមាន នៅក្នុងចំណោម អ្នកតំណាងទាំង ៥១ រូបនោះដែរ ។ គេអាចសន្និដ្ឋានបានថា ចាប់តាំងពីថ្ងៃ ១៤ មិថុនាឆ្នាំ ១៩៩៣ នោះមក ប្រទេសវៀតណាម គ្មានឥទ្ធិពលអ្វីទៀតទេ ទៅលើប្រទេសកម្ពុជា ទោះបី អ្នកតំណាង ជាប្រវត្តិសាស្ត្រ នៃ របបចាស់ ដូចជា លោក ហេង សំរិន, ជា ស៊ីម, ហ៊ុន សែន ជាដើម នៅតែមានវត្តមាន បន្តមកទៀតក្ដី ។ អ្នកតំណាង ខាងគណបក្ស «ប្រជាជន» ច្រើនតែជាអ្នកដែល កាលពីរបបមុន ពុំមានអំណាចអ្វី ក្រៅពីតួនាទី របស់គេ ជា





អ្នកបច្ចេកទេស ឬ ជាអ្នកគ្រប់គ្រងរដ្ឋបាលនោះទេ ។ ខាងគណបក្ស «ហ្វុនស៊ីនប៉ិច» អ្នកតំណាងមាន ៥៨ រូប នៅក្នុងនោះ ៤០ រូប ជាអ្នកដែល បានរស់នៅក្នុងប្រទេស កាលពីពេលសង្គ្រាម ហើយដែលជា អ្នកដឹកនាំការ តស៊ូប្រឆាំង នឹងរបប ហេង សំរិន។ អ្នកទាំងនេះ ច្រើនតែជាកសិករ។ ក្រៅពីនោះ គឺសុទ្ធតែជាអ្នកដែលត្រឡប់មកពីបរទេស។ អ្នកតំណាងគណបក្ស រាជានិយម «ហ្វុនស៊ីនប៉ិច» នៅក្នុង សភាធម្ម នុញ្ញ ពុំមាន ចំនួនគ្រប់គ្រាន់ សម្រាប់ អនុម័ត រដ្ឋធម្មនុញ្ញទេ ។ ទោះបីចងសម្ព័ន្ធភាព ជាមួយគណបក្ស «ប្រជាធិបតេយ្យសេរីនិយម ពុទ្ធសាសនា» របស់ លោក សឺន សាន ក៏ដោយ ក៏ នៅតែពុំមានចំនួនគ្រប់គ្រាន់ដែរ។ នៅក្នុងអង្គប្រជុំសភាធម្មនុញ្ញ លើកដំបូងបង្អស់នាថ្ងៃ ១៤ មិថុនា នោះ តាមរយៈសេចក្ដីសម្រេចចិត្តមួយ គេបាន ប្រគល់អំណាចពេញលេញពិសេស ថ្វាយទៅសម្ដេច នរោត្តម សីហនុ។ ប៉ុន្តែ តាមការពិតទៅ គេពុំដឹងថា អំណាចនោះ មានវិសាលភាពប៉ុនណាទេ ។ ទោះជាយ៉ាងណាក៏ដោយ អង្គការ «អាប្រូនុច» បានកត់សំគាល់ នៅពេលនោះថា : សេចក្ដីសម្រេចចិត្តនោះ គ្មានអនុភាពអ្វីទាំងអស់ ដរាបណា សភាធម្មនុញ្ញ ពុំទាន់អនុម័តរដ្ឋធម្មនុញ្ញ ហើយពុំទាន់តែងតាំងរដ្ឋាភិបាលនៅឡើយ។ នៅក្នុង អង្គប្រជុំនាថ្ងៃ ១៤ មិថុនានោះ បណ្ដាអ្នកតំណាង បាននាំគ្នាយល់ស្របទៅ លើសេចក្ដីសម្រេចចិត្តមួយ ដែលចាត់ទុក ព្រឹត្តិការណ៍ ថ្ងៃ ១៨ មិនាឆ្នាំ ១៩៧០ ជាមោឃៈ ពោល គឺថ្ងៃដែល សភាទាំងពីរ កាល ពេលនោះ បានបោះឆ្នោតទម្លាក់ សម្ដេច នរោត្តម សីហនុ ពីមុខតំណែងប្រមុខរដ្ឋ។ នៅថ្ងៃ ១៦ មិថុនា ដោយផ្អែកទៅលើអំណាច ពិសេសដែលសភាធម្មនុញ្ញ បានថ្វាយ មកព្រះអង្គ សម្ដេច នរោត្តម សីហនុ បានប្រកាសថា បន្តិចទៀតនេះ នឹង មាន ការតែងតាំង រដ្ឋាភិបាលមួយ ដែលមានការយល់ព្រម ពី សភាធម្មនុញ្ញ ។

បញ្ហាដែលចោទឡើង គឺថា ការតែងតាំង រដ្ឋាភិបាលមួយ មុនការអនុម័តរដ្ឋធម្មនុញ្ញ បានត្រូវមតិខ្លះយល់ថា ពុំស្របទៅ នឹងកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍នាឆ្នាំ ១៩៩១ ទេ ព្រោះថា នៅពេលដែល សភាធម្មនុញ្ញ ពុំទាន់អនុម័ត រដ្ឋធម្មនុញ្ញផង គឺ ពុំទាន់ប្រែក្លាយខ្លួនជា អង្គការ និតិប្បញ្ញត្តិផង ស្រាប់តែគេ នាំគ្នាតែងតាំងរដ្ឋាភិបាល មួយ

ភ្លាម។ តាមការពិតកិច្ចព្រមព្រៀងនេះ ចែងយ៉ាងច្បាស់នៅក្នុងផ្នែក ទី១ ស្តី ពីរយៈកាលឆ្លងកាត់ត្រង់ ចំពូក ទី១ មាត្រា ១ ដូច្នេះថា ទាល់តែ សភាធម្មនុញ្ញ យល់ព្រម ទទួលយក រដ្ឋធម្មនុញ្ញសិន ហើយ ក្លាយទៅជា អង្គការ នីតិបញ្ញត្តិសិន ទើបអង្គការនេះ អាចតែងតាំងរដ្ឋាភិបាល ។ ប៉ុន្តែផ្ទុយទៅវិញ កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ និយាយតែពី ការប្រគល់ វាសនា នៃប្រទេស កម្ពុជា ទៅឲ្យការបោះឆ្នោត សេរី តែប៉ុណ្ណោះ ហើយ ក៏ ពុំនិយាយ ពីការតែងតាំងប្រមុខរដ្ឋសោះ។ ប៉ុន្តែ បន្ទាប់ពីការជម្រុញ ឲ្យតែងតាំង រដ្ឋាភិបាលមួយ ដោយសភាធម្មនុញ្ញតែម្តង ដោយ សភាធម្មនុញ្ញ មិនទាន់បាន អនុម័ត រដ្ឋធម្មនុញ្ញផង បញ្ហានីតិវិធី ក៏ចោទឡើង ។ តាមធម្មតា សភាធម្មនុញ្ញ ត្រូវ អនុម័ត រដ្ឋធម្មនុញ្ញសិន ទើបតែងតាំងរដ្ឋាភិបាលជាក្រោយ។ ប៉ុន្តែនៅពេលនោះ គេនាំគ្នាយល់ថា ការបង្កើត រដ្ឋាភិបាល មុនការអនុម័តរដ្ឋធម្មនុញ្ញ ក៏មិនមែនជាការរំលោភ ទៅលើកិច្ចព្រមព្រៀង ទីក្រុងប៉ារីស៍ឯណាដែរ ដរាបណាមាន ការយល់ព្រមពី ភាគីខ្មែរ ទាំង ៤ ហើយមាន ការយល់ព្រម ពី សភាធម្មនុញ្ញផងទៀតនោះ។ ភាគីខ្មែរក្រហម គេសុខចិត្តគាំទ្រ គំនិត មួយផ្សេងទៀត គឺការបង្កើត រដ្ឋាភិបាលបណ្តោះអាសន្នមួយ ប៉ុន្តែទាល់តែនៅ ក្នុងករណី ដែល សម្តេច នរោត្តម សីហនុ មានអំណាចពេញលេញដែរ ។ ទោះជាយ៉ាងណាក្តី គណបក្ស «ប្រជាជន» និង គណបក្សរាជានិយម បាននាំគ្នាគិតតែ ពីការចែកអំណាចគ្នា ប៉ុណ្ណោះសិន ទោះបី កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ សង្កត់ធ្ងន់ទៅលើ ការបោះឆ្នោតក្តី គឺ មិនឲ្យធ្វើការចរចាគ្នាបែបនេះឡើយ។ នៅថ្ងៃ ៣០ មិថុនា ឆ្នាំ១៩៩៣ ដដែលនោះ សភាធម្មនុញ្ញ បានឲ្យសច្ចាប័ន ទៅលើ សមាសភាព នៃ រដ្ឋាភិបាលតែម្តង។ រដ្ឋមន្ត្រី មាន ចំនួន ៣៣ រូប ហើយអនុរដ្ឋមន្ត្រី មានចំនួន ២៩ រូប។ លោក សឺន សាន បានត្រូវ តែងតាំងជា ប្រធាន នៃសភាធម្មនុញ្ញ ហើយ លោក ជា ស៊ីម ជាអនុប្រធាន ។ លោក ហ៊ុន សែន និង ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ បានត្រូវតែងតាំងជា នាយករដ្ឋមន្ត្រី ទាំងពីរនាក់តែម្តង សម្រាប់ដឹក នាំរដ្ឋាភិបាលតែមួយ។ នេះជាព្រឹត្តិការណ៍មួយ មិនធ្លាប់ ដែលមានសោះ ក្នុង ប្រវត្តិសាស្ត្រ។ រីឯ ការបង្កើត រដ្ឋាភិបាល មុនការអនុម័ត រដ្ឋ





ធម្មនុញ្ញ ក៏ ជាករណី ដែលមិនធ្លាប់ដែលមានដែរ នៅក្នុងប្រវត្តិ នៃ បណ្តាប្រទេស ប្រជាធិបតេយ្យ ។

## បញ្ហាខ្មែរក្រហម នៅពេលបង្កើត រដ្ឋាភិបាល បណ្តោះអាសន្ន នៅឆ្នាំ ១៩៩៣

## Problème relatif aux Khmers rouges pendant la formation du Gouvernement provisoire de Juillet 1993

ដោយពុំទាន់បង្កើត អង្គការនិតិប្បញ្ញត្តិ នៅឡើយ ហើយដោយសភាធម្មនុញ្ញ តែងតាំងរដ្ឋាភិបាល មុនការអនុម័ត រដ្ឋធម្មនុញ្ញ បញ្ហាចម្រូងចម្រាស ក៏ ស្តែងចេញឡើង។ បន្ទាប់ ពីរដ្ឋាភិបាល បណ្តោះអាសន្ន ដឹកនាំដោយ សហនាយករដ្ឋមន្ត្រីពីររូប គឺ ព្រះអង្គ ម្ចាស់រណឫទ្ធិ និង លោក ហ៊ុន សែន បានត្រូវ សភាធម្មនុញ្ញ ប្រគល់ការទុកចិត្ត បញ្ហាដែលចោទឡើងនៅពេលនោះ គឺបញ្ហា គ្មាន អង្គការនីតិប្បញ្ញត្តិ សម្រាប់តាក់តែង ច្បាប់ ព្រោះសភាធម្មនុញ្ញ មិនទាន់ក្លាយទៅជារដ្ឋសភានៅឡើយ។ ដូច្នេះឃើញថា ដោយរដ្ឋធម្មនុញ្ញ ក៏ពុំទាន់មានប្រព័ន្ធច្បាប់ ក៏ពុំទាន់មាន រដ្ឋាភិបាលពុំទាន់មានលក្ខណៈ គ្រប់គ្រាន់សម្រាប់ធ្វើដំណើរការឡើយ។ សភាធម្មនុញ្ញ ក៏សម្រេចយក នីតិកម្ម ចាស់ មកប្រើសិន។ ដូចនេះ ទោះបីក្រោយការបោះឆ្នោត ក៏ដោយ ក៏អ្វីៗត្រូវប្រព្រឹត្តទៅ នៅលើមូលដ្ឋាន នៃការស្រុះស្រួលគ្នា រវាងគូបដិបក្ខ បន្តទៅទៀតដែរពោលគឺ ពុំស្រប ទៅ តាមគោលការណ៍ នៃ កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ឡើយ ព្រោះ កិច្ចព្រមព្រៀងនេះ មិនឲ្យយក ការចរចាគ្នា សម្រាប់ដោះស្រាយបញ្ហាទេ ក្រោយការបោះឆ្នោត គឺឲ្យយក រដ្ឋធម្មនុញ្ញ ធ្វើជាមូលដ្ឋាន។ ខាងភាគីខ្មែរក្រហមឯនោះវិញ គេបានដាក់លក្ខខណ្ឌមួយ គឺថា ទាល់តែ សម្តេច នរោត្តម សីហនុ មានសិទ្ធិអំណាច គ្រប់គ្រាន់ ទើបគេយល់ស្រប។ ទោះជាយ៉ាងណាក្តី បន្ទាប់ពី រដ្ឋាភិបាលបណ្តោះអាសន្ននេះ បានត្រូវតែងតាំង

ខ្មែរក្រហម ក៏ បានស្នើសុំ តែសិទ្ធិ ធ្វើសកម្មភាព របស់គេ បន្តទៅទៀត តែប៉ុណ្ណោះ ។ ម្យ៉ាងទៀត នៅថ្ងៃ ៣ កក្កដា ឆ្នាំ ១៩៩៣ ដដែលនោះ លោកប្រមុខរដ្ឋ ចិន យ៉ង់ យ៉េមិញ និង លោកនាយករដ្ឋមន្ត្រី ទី ១ ចិន លីប៉ឹង បានផ្ញើលិខិតមួយសរសើរ សម្តេច នរោត្តម សីហនុ យ៉ាងជ្រាលជ្រៅ អំពី ការបង្កើតរដ្ឋាភិបាលនោះ ។ នៅពេលដែលគេកំពុងរៀបចំ រដ្ឋាភិបាលបណ្តោះអាសន្ន លោក ខៀវ សំផន អតីតប្រមុខរដ្ឋ របបខ្មែរក្រហម «កម្ពុជាប្រជាធិបតេយ្យ» ស្នើសុំ សម្តេច នរោត្តម សីហនុ ឲ្យអនុញ្ញាតឲ្យខ្លួនគេ បានវិលត្រឡប់មកកម្ពុជាវិញ ហើយទទ្ទឹមនោះ សុំរក្សាទុកក្រុមគេ ជាគណបក្សមួយ ដ៏សាមញ្ញប៉ុណ្ណោះ។ មុនដំបូង សម្តេច នរោត្តម សីហនុបានយល់ព្រម ប៉ុន្តែ ក្រោយមក បានប្រានសេចក្តីស្នើនេះចោលទៅវិញ។ មុនការបើកសម័យប្រជុំ សភាជម្មនុញ្ញ នាថ្ងៃ ២៦ មិថុនា សម្តេច នរោត្តម សីហន ប្រមុខរដ្ឋ នៃ របបថ្មី បានថ្លែងថា: «យើង ធ្លាប់បានស្គាល់រសជាតិ នៃ ពាក្យផ្អែមល្ហែម របស់ ខ្មែរក្រហមហើយ។ ផ្លែឈើ របស់ ប៉ុល ពត ល្វីងជូរចត់ណាស់ ហើយ មានពេលខ្លះ មានទាំងជាតិពុលទៀតផង» ។

នៅពេលដែលសម្តេច នរោត្តម សីហនុ ប្រានចោលសេចក្តីស្នើ របស់ ភាគី ខ្មែរក្រហម លោក ហ៊ុន សែន បែរជាបន្ធូរ ឥរិយាបថ បន្តិចទៅវិញ។ នេះជារឿង មួយ ដ៏ចម្លែក ព្រោះ កន្លងមក លោក ហ៊ុន សែន តែងតែប្រឆាំងដាច់អហង្ការ នូវ រាល់កិច្ចព្រមព្រៀង ជាមួយក្រុម ប៉ុល ពត ។ តាមការពិត លោក ហ៊ុន សែន ចង់បញ្ចូល កងទ័ពខ្មែរក្រហម មកក្នុងកងទ័ពជាតិ តែប៉ុណ្ណោះ គឺផ្តាច់កងទ័ពខ្មែក្រហម ចេញពីពួក មេដឹកនាំរបស់គេ។ ប៉ុន្តែគម្រោងការនេះ ពុំបានសម្រេចទេ ព្រោះពួកមេដឹកនាំ ធំៗ នៃ អតីតរបប «កម្ពុជាប្រជាធិបតេយ្យ» ដែលបានសម្លាប់ប្រជាជនខ្មែរអស់ជិត ២ លាន នាក់ បានដាក់លក្ខខណ្ឌ មួយ ជាបន្ទាន់ គឺ គេសុខចិត្តធ្វើដូច្នេះបាន ទាល់តែ ពួកគេ ស្ថិតនៅក្នុង ជួររដ្ឋាភិបាលដែរ ។ តាមការពិត ពួក ប៉ុល ពត គ្មានសង្ឃឹមថា នឹងអាច ចូលទៅក្នុងរដ្ឋាភិបាលទេ ប៉ុន្តែ គេនិយាយដូច្នេះ គឺ ដើម្បី យកចំណេញពេល តែប៉ុណ្ណោះ ព្រោះ គោលដៅពិតប្រាកដ របស់គេ នៅពេលនោះ គឺ កាន់កាប់តំបន់ របស់ ពួកគេបន្តទៅទៀត។ សភាពការណ៍នេះ ពុំមានអំណោយផលល្អប៉ុន្មាន សម្រាប់របប



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ថ្មីទេ ព្រោះ នៅក្នុងករណីនេះ ពួកខ្មែរក្រហម ដែលស្ថិតនៅ ក្រោមបញ្ជាការ របស់ ប៉ុល ពត ដដែលអាច នឹងដឹកនាំ សង្គ្រាមព្រៃ នៅក្នុងរបបថ្មី បន្តទៅទៀត គឺធ្វើឲ្យ របបនេះ គ្មានស្ថិរភាពល្អ ក្នុងការកសាងប្រទេសឡើងវិញ ។ ប្រទេសថៃ មានការបារម្ភ យ៉ាងខ្លាំង ចំពោះការទុកឲ្យ ខ្មែរក្រហមស្ថិត នៅក្រៅច្បាប់ដូច្នេះ។ លោក អាកាស៊ី អ្នកតំណាង អង្គការ សហប្រជាជាតិ ក៏ មានការបារម្ភ ដូចគ្នាអ៊ីចឹងដែរ។ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ សហនាយករដ្ឋមន្ត្រី ទី ១ នៃ រដ្ឋាភិបាលបណ្តោះអាសន្ន ក៏ ជឿថា ជា ការពុំស្រួលដែរ ។ ទោះជាយ៉ាងណាក្តី ខ្មែរក្រហម នៅតែទាមទារឲ្យមាន ការចរចា បន្តទៅទៀត។ អង្គការ សហប្រជាជាតិ បានដាក់លក្ខខណ្ឌមួយ គឺថា ទាល់តែខ្មែរ ក្រហម សុខចិត្តបញ្ចូលកងទ័ព របស់គេ ទៅក្នុងកងទ័ពជាតិ ហើយសុខចិត្តរណប នឹង រដ្ឋាភិបាលថ្មី។ នៅថ្ងៃ ៧ កក្កដា ឆ្នាំ ១៩៩៣ ដដែលនោះ ពួកខ្មែរក្រហម បានចូល កាន់កាប់ តំបន់ព្រះវិហារ តែម្តង ។

## ការគាបសង្កត់ របស់ ពួកខ្មែរក្រហម ទៅលើ រដ្ឋាភិបាល បណ្តោះអាសន្ន ថ្ងៃ ៣០ មិថុនា ឆ្នាំ ១៩៩៣

### La pression des Khmers rouges sur Gouvernement provisoire du 30 juin 1993

ដូចយើងបានដឹងរួចមកហើយ សមាសភាព នៃ រដ្ឋាភិបាលបណ្តោះ អាសន្នដែល បានត្រូវសភាជម្មនុញ្ញឲ្យសច្ចាប័ននៅថ្ងៃ ៣០ មិថុនាឆ្នាំ ១៩៩៣ ពុំមាន ការចូលរួម ពី អតីតអ្នកដឹកនាំ នៃរបប «កម្ពុជាប្រជាធិបតេយ្យ» ទេ។ ដើម្បីធ្វើការគាបសង្កត់ ទៅលើ រដ្ឋាភិបាលនេះ ដែលមាន នាយករដ្ឋមន្ត្រី ដល់ទៅ ២ រូប ពួកខ្មែរក្រហមបានធ្វើការ វាយប្រហារទៅលើ កងទ័ពលោក ហ៊ុន សែន នៅ ព្រះវិហារ នៅថ្ងៃ ៧ កក្កដា ។ នៅ

ពេលនោះ លោក ខៀវ កញ្ញារីទ្ធិ អ្នកនាំ ពាក្យ នៃរដ្ឋាភិបាលថ្មី បានចោទប្រទេសថៃ ថា បានជួយពួកខ្មែរក្រហម ឲ្យវាយយកប្រាសាទ ព្រះវិហារ។ ប៉ុន្តែ ទីក្រុងបាងកក បានទាត់ចោលការចោទ ប្រកាន់នេះដោយដាច់អហង្ការ។ នៅថ្ងៃ ១៦ កក្កដា រដ្ឋាភិបាល ខ្មែរ ក៏ បានទទួលស្គាល់ថា ប្រទេសថៃ ពុំមានជាប់ពាក់ព័ន្ធ ក្នុងរឿងនេះទេ ។ ទោះជា យ៉ាងនេះក្តី ក៏ រដ្ឋាភិបាល រណឫទ្ធិ - ហ៊ុន សែន ពុំអាចបណ្តោយឲ្យខ្មែរក្រហម កាន់ កាប់ ព្រះវិហារដែរ។ អ្វីដែលពួកខ្មែរក្រហម ចង់បង្ហាញឲ្យឃើញ នៅពេលនោះ គឺថា សង្គ្រាមផ្ទៃក្នុង នៅតែមានបន្តមកទៀត។ មួយថ្ងៃក្រោយការវាយយកព្រះវិហារ ពួកខ្មែរ ក្រហម បានវាយយក ភូមិជាច្រើននៅក្នុងខេត្រកំពង់ឆ្នាំង។ ប្រតិបត្តិការ យោធានេះ របស់ ពួកខ្មែរក្រហម បានប្រព្រឹត្តទៅ អស់រយៈពេល ៥ ថ្ងៃ ។ នៅថ្ងៃ ១៣ កក្កដា សម្តេច នរោត្តម សីហនុ បានទទួល គណប្រតិភូខ្មែរ ក្រហមមួយ ដឹកនាំដោយ លោក ខៀវ សំផន ។ គណប្រតិភូនេះដែលមាន លោក ចាន់ យូរ៉ាន់ លោក ម៉ក់ បែន និង លោក អ៊ិន សូភាព ជា សមាជិក បានស្នើសុំ បញ្ចូលកងទ័ពខ្មែរក្រហម មកក្នុងកងទ័ព រដ្ឋាភិបាលថ្មី ប៉ុន្តែជាថ្នូរ គេបានសុំឲ្យរដ្ឋាភិបាលនេះ តែងតាំង ទីប្រឹក្សាខ្មែរក្រហម មួយ ចំនួន ក្នុងជួររដ្ឋាភិបាល ។ សម្តេច នរោត្តម សីហនុ បានឆក់យកឱកាសនោះ ទាមទារ ឲ្យខ្មែរក្រហម ប្រគល់ព្រះវិហារ និងតំបន់កាន់កាប់ ដោយខ្មែរក្រហមមកឲ្យ រដ្ឋាភិបាល វិញ ។ សេចក្តីស្នើទាំងឡាយនេះ នឹង ត្រូវយកទៅពិនិត្យនៅក្នុង អង្គប្រជុំ តុមូលនៅ ខែកញ្ញា។ នៅចំពោះមុខ សភាពការណ៍នេះ  រដ្ឋាភិបាល រណឫទ្ធិ- ហ៊ុន សែន ដែល ជា រដ្ឋាភិបាលក្បាលពីរ ប្រទាញប្រទង់ដណ្តើមយកឥទ្ធិពលគ្នា ទៅវិញទៅមក ក៏ រិះរក មធ្យោបាយរៀងៗ ខ្លួន ដើម្បី ទាញយក ប្រយោជន៍ របស់គេ ម្នាក់ៗ ។ នៅក្នុងពេល ដដែលនោះ ពួកខ្មែរក្រហម បានធ្វើការវាយប្រហារ ទៅលើកងទ័ព អង្គការ សហ ប្រជាជាតិ នៅតាមតំបន់ ជាច្រើនទៀត។ នៅថ្ងៃ ៨ សីហា កងទ័ព រដ្ឋាភិបាល បានធ្វើ ការវាយលុក នៅ ក្នុងតំបន់ផ្សេងៗ ដែលខ្មែរក្រហមកាន់កាប់ ដូចជាព្រះវិហារ កំពង់ធំ សៀមរាប បន្ទាយមានជ័យ ជាដើម។ នៅថ្ងៃ ២៧ សីហា ក្រុមប្រឹក្សា សន្តិសុខ អង្គការ



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

សហប្រជាជាតិ បានសម្រេច បន្តអាណត្តិ អន្តរាគមន៍ របស់ខ្លួន នៅកម្ពុជា រហូតដល់ ពេលប្រទេសកម្ពុជា មាន រដ្ឋធម្មនុញ្ញ ។

នៅក្នុងការប្រយុទ្ធគ្នា រវាងពួកខ្មែរក្រហម នឹងរដ្ឋាភិបាលបណ្តោះអាសន្ន ពួកខ្មែរ ក្រហមមិនសង្ឃឹមថា នឹងអាចវាយរំលំរដ្ឋាភិបាលនេះទេ ហើយ ក៏មិនសង្ឃឹមថា រដ្ឋាភិ បាលនេះ សុខចិត្តធ្វើសម្បទានធំៗ អ្វីដែរ។ ប៉ុន្តែ អ្វី ដែលគេសង្ឃឹមទៅវិញនោះ គឺថា រដ្ឋាភិបាលថ្មី ពុំអាចកសាងប្រទេស បានទេ ព្រោះត្រូវប្រឈមមុខ នឹងសង្គ្រាមផ្ទៃក្នុង។ ម្យ៉ាងទៀត គេ ក៏មានលក្ខណៈគ្រប់គ្រាន់ ដើម្បី បំបែកបំបាក់ រដ្ឋាភិបាលថ្មីនេះដែរ។ ពួកគេ យល់ថា ការប្រទាញប្រទង់គ្នា ជាការគេចពុំផុត នៅក្នុងរដ្ឋាភិបាលក្បាលពីរ នេះ គឺ រវាង គណបក្សរាជានិយម នឹង គណបក្ស «ប្រជាជន» ។ ពួកខ្មែរក្រហម យល់យ៉ាង ច្បាស់ថា នៅក្នុងករណីបែបនេះ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ មុខជានឹង ត្រូវការកម្លាំង យោធាមួយ ដ៏ ខ្លាំងក្លា ដើម្បីទប់ទល់ នឹងលោក ហ៊ុន សែន ឬ យ៉ាង ហោចណាស់ ក៏ ដើម្បីយកប្រៀប ឬរក្សាតុល្យភាពដែរ។ ប៉ុន្តែ នេះជាកិច្ចការមួយ ដ៏ ពិបាក ចំពោះ ព្រះអង្គម្ចាស់រណឫទ្ធិ ដោយហេតុថា សហរដ្ឋ អាមេរិក ប្រឆាំងដាច់ខាត នឹង វត្តមាន របស់ ពួកខ្មែរក្រហម នៅក្នុងរដ្ឋាភិបាលខ្មែរ ។ មួយវិញទៀត ប្រទេស បារាំង ក៏ត្រៀមលក្ខណៈលុបកិច្ចព្រមព្រៀងយោធា របស់គេ ជាមួយកម្ពុជាដែរ នៅក្នុង ករណី ដែលរដ្ឋាភិបាលថ្មី បញ្ចូលកងទ័ពខ្មែរក្រហម មកក្នុងកងទ័ពជាតិ ។ ប៉ុន្តែបើមិន ធ្វើដូច្នេះទេ ប្រទេសកម្ពុជា នឹងត្រូវជួប នឹងសង្គ្រាមផ្ទៃក្នុងមួយ ដ៏យូរ ជាពុំខាន ។ នៅ ទីបំផុត ព្រះអង្គម្ចាស់ រណឫទ្ធិ បានសម្រេចប្រថុយ សុខចិត្ត ដាច់ជំនួយ បរទេសវិញ ដើម្បីបញ្ចប់សង្គ្រាមផ្ទៃក្នុង។ លោក ហ៊ុន សែន ក៏យល់ស្របនឹងគំនិតនេះដែរ។ លោក បានថ្លែងជាអាទិ៍ថា: ឯកភាពជាតិ វាប្រសើរ ជាងជំនួយបរទេស ហើយ ម្យ៉ាងទៀត គេពុំត្រូវបណ្តោយឲ្យបរទេស យកជំនួយ របស់គេ មកបំបែកបំបាក់ ឯកភាពជាតិទេ។ ដើម្បី ជម្រុញឲ្យរដ្ឋាភិបាល ជ្រើសរើសយកផ្លូវនេះ ពួកខ្មែរក្រហម ក៏បន្តវិនាសកម្ម ថែមទៀត ដោយម្តងនេះ បុកមុខព្រួញ ទៅរកអង្គការ «អាប្រូនុច» ដោយត្រង់ៗតែម្តង។

# រដ្ឋធម្មនុញ្ញខ្មែរ ដែលបានត្រូវប្រកាសឲ្យប្រើនៅថ្ងៃ ២៤ កញ្ញា ឆ្នាំ ១៩៩៣

## La Constitution khmère promulguée Le 24 septembre 1993

នៅពេលដែលខ្មែរក្រហមធ្វើការវាយប្រហារបង្កើតឲ្យមានអសន្តិសុខនៅក្នុងប្រទេសបន្ត មកទៀត កងទ័ពរដ្ឋាភិបាល ក៏ខិតខំ ធ្វើការទប់ទល់វិញ យ៉ាង ពេញទំហឹងដែរ។ ម្តងនេះ កងទ័ពខ្មែរក្រហម បាក់ទឹកចិត្តយ៉ាងខ្លាំង ព្រោះ គេត្រូវបំផ្លាញជីវិតមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធ របស់ ខ្មែរអស់ជាច្រើន។ ពួកគេបានបាញ់កាប់សម្លាប់ អ្នកធ្វើដំណើរស្លូតត្រង់ តាមរថភ្លើង កំទេចស្ពាន និង ថ្នល់ជាតិ ឥតរេកាតក្រែង ។ មួយវិញទៀត កងទ័ពរដ្ឋាភិបាល ក៏ដូចជាកងទ័ព «ហ្វុនស៊ីនប៉ិច» និង «រណសិរ្សរំដោះ ពលរដ្ឋខ្មែរ» ជាដើម ដែលធ្វើប្រតិបត្តិការសឹក ក្រោមទង់ របស់គេ ផ្ទាល់រៀងៗខ្លួន បានធ្វើការទប់ទល់ ខ្ទប់មិនឲ្យពួកខ្មែរក្រហមចេញ ពីតំបន់ ដែលគេកាន់កាប់ បានឡើយ។ គឺនៅពេលនោះហើយដែលយោធា ខ្មែរក្រហម ជាច្រើនរយនាក់ ព្រមទាំង នាយទាហាន សំខាន់ៗ របស់គេផងដែរ នាំគ្នាសុំចុះចូលរដ្ឋាភិបាល។ នៅថ្ងៃ ១៦ កញ្ញាឆ្នាំ ១៩៩៣ ជដែលនោះ គម្រោងរដ្ឋធម្មនុញ្ញ បានត្រូវយកមក ពិភាក្សា អស់ពេល ជាច្រើនថ្ងៃ ហើយនៅទីបំផុត បានត្រូវសភាធម្មនុញ្ញ អនុម័តតែម្តង ។ បន្ទាប់ពី បានអនុម័ត រដ្ឋធម្មនុញ្ញហើយ សភាធម្មនុញ្ញ ក៏បានក្លាយទៅជារដ្ឋសភា គឺអង្គការ នីតិប្បញ្ញត្តិ ពេញលក្ខណៈ។ នៅថ្ងៃ ២៤ កញ្ញារដ្ឋធម្មនុញ្ញ បានត្រូវប្រកាសឲ្យប្រើ ។ សម្តេច នរោត្តម សីហនុ បានត្រូវតែងតាំង





ជា ព្រះមហាក្សត្រ ហើយ ព្រះជាយា អ្នកម្នាង ម៉ូនិច [៤១] បានទទួលឋានៈជា ព្រះមហេសី។ លោក ហ៊ុន សែន និង ព្រះអង្គម្ចាស់រណឫទ្ធិ នៅតែជា សហនាយករដ្ឋមន្ត្រី ដដែល គឺ ព្រះអង្គម្ចាស់រណឫទ្ធិ ជា នាយករដ្ឋមន្ត្រី ទី ១ លោក ហ៊ុន សែន ជា នាយករដ្ឋមន្ត្រី ទី ២។ នៅពេលដែលមាន រដ្ឋធម្មនុញ្ញ មានរដ្ឋសភា មាន រដ្ឋាភិបាល ហើយ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ក៏ ត្រូវបញ្ចប់បេសកកម្ម របស់ ខ្លួន ជាស្វ័យប្រវត្តិ ។ ប្រការដែល គួរឲ្យកត់សំគាល់គឺថា តាមរយៈរដ្ឋធម្មនុញ្ញនេះ ប្រទេសកម្ពុជា បានក្លាយទៅជារាជាណាចក្រវិញ បន្ទាប់ពីបានឆ្លងកាត់ របប នយោបាយ ៣ គឺរបប «សាធារណរដ្ឋខ្មែរ»[៤២] របប «កម្ពុជាប្រជាធិបតេយ្យ»[៤៣] របប «សធារណរដ្ឋប្រជាមានិតុ កម្ពុជា»[៤៤] ដែល បានប្តូរឈ្មោះមកជា «រដ្ឋកម្ពុជា» នៅឆ្នាំ ១៩៨៩ ។

នៅក្នុង របបរាជានិយម ថ្មីនេះ ព្រះមហាក្សត្រ ទ្រង់គ្រងរាជ្យ ប៉ុន្តែ មិនកាន់អំណាចទេ ។ គេហៅថា របប «រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ» ប៉ុន្តែ មិនដូច របប «រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ» កាលឆ្នាំ ១៩៤៧ ទេ ព្រោះកាលនោះ ព្រះមហាក្សត្រ មានអំណាច អាចធ្វើអន្តរាគមន៍ បាន នៅក្នុងករណីដែលព្រះមហាក្សត្រយល់ថា ជាការចាំបាច់។ នៅក្នុងរបបរាជានិយម ឆ្នាំ ១៩៩៣ នេះ ព្រះមហាក្សត្រ ដែលត្រូវជ្រើសរើស ដោយក្រុមប្រឹក្សារាជសម្បត្តិមានតួនាទីជា ព្រះប្រមុខរដ្ឋអស់មួយជីវិត ។ រីឯរបបនយោបាយវិញ គឺ ត្រូវប្រកាន់យកលទ្ធិប្រជាធិបតេយ្យ សេរីនិយម ពហុបក្ស ដូចកាល

---

[៤១] Monique Izzi កើតនៅថ្ងៃ ១៨ មិថុនា ១៩៣៦ ។ នៅខែកុម្ភៈ ឆ្នាំ ១៩៩២ មានឋានៈជា «សម្តេច ព្រះរាជជាយា» ។ នៅឆ្នាំ ១៩៩៣ មានឋានៈ ជា «សម្តេច ព្រះមហេសី» ។

[៤២] របបប្រជាធិបតេយ្យ សេរីនិយម តាមបែបបទ បស្ចិមប្រទេស ។

[៤៣] របប កុម្មុយនិស្ត របស់ ខ្មែរក្រហម ប៉ុល ពត

[៤៤] របប កុម្មុយនិស្ត ហេង សំរិន

ជំនាន់ ឆ្នាំ ១៩៤៧ ដែរ គឺ សម័យបារាំងត្រួតត្រា[៤៥] ។ អង្គការនិតិប្បញ្ញត្តិ គឺ រដ្ឋសភា ត្រូវចេញពីការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និង តាមវិធីជ្រើសរើសឆ្នោត ជាសម្ងាត់ ។ នៅក្នុង រដ្ឋធម្មនុញ្ញ ដែលត្រូវប្រកាសឲ្យប្រើ នៅឆ្នាំ ១៩៩៣ នោះ ព្រឹទ្ធសភា ពុំទាន់បានត្រូវបង្កើតនៅឡើយទេ គឺ ទាល់តែ ថ្ងៃ ៨ មិនាឆ្នាំ ១៩៩៩ ទើបស្ថាប័ននេះបានត្រូវបង្កើត តាមរយៈ វិសោធនកម្មមួយ ។ ក្រៅពី ស្ថាប័នធំៗ ដូចជា រដ្ឋសភា រដ្ឋាភិបាល ជាដើម គេក៏ឃើញមានស្ថាប័នមួយដែរ សម្រាប់ធានាធម្មនុញ្ញភាព គឺ ក្រុមប្រឹក្សាធម្មនុញ្ញ។ ប៉ុន្តែ អង្គការនេះ គ្មាន ទីតាំងឋានានុក្រម នៅក្នុងអំណាចតុលាការទេ ។

នៅក្នុងរដ្ឋធម្មនុញ្ញ ១៩៩៣ ដែល បានត្រូវធ្វើវិសោធនកម្ម ២ ដង មកទល់នឹងពេលនេះ គឺ នៅថ្ងៃ ១៤ កក្កដាឆ្នាំ ១៩៩៤ ម្តង ហើយ នៅថ្ងៃ ៨ មិនាឆ្នាំ ១៩៩៩ ម្តង ឋានានុក្រម នៃ អំណាចតុលាការ មានតែ ៣ ប៉ុណ្ណោះ គឺ បើរាប់ពីក្រោមទៅលើ រួមមាន ៖ សាលាដំបូង សាលាឧទ្ធរណ៍ និង តុលាការកំពូល។ ដូចនេះ រដ្ឋធម្មនុញ្ញខ្មែរ ពុំមាន របៀបដូច រដ្ឋធម្មនុញ្ញ អង់គ្លូសាកសុងទេ ។ តាំងពីរដ្ឋធម្មនុញ្ញឆ្នាំ ១៩៤៧ រហូតមកដល់ឆ្នាំ ១៩៦៤ គេពុំដែល ឃើញមានប្រព័ន្ធ សម្រាប់ត្រួតពិនិត្យ ធម្មនុញ្ញភាពទេ។ នៅក្នុងមាត្រា ១១៩ នៃ រដ្ឋធម្មនុញ្ញ ១៩៩៣ គេឃើញមាន តែសិទ្ធិបកស្រាយអត្ថបទ រដ្ឋធម្មនុញ្ញ ប៉ុណ្ណោះ ។ មានតែរដ្ឋធម្មនុញ្ញ ថ្ងៃ ៣០ មេសាឆ្នាំ ១៩៧២ ប៉ុណ្ណោះដែលបានថែង ពីតុលាការធម្មនុញ្ញ ប៉ុន្តែ អង្គការនេះទៀត ក៏គ្មានតួនាទីអ្វី នៅក្នុងអំណាចតុលាការដែរ។ រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ បាន វិលទៅរក របៀបបារាំងដដែលវិញ ។ ទោះជាយ៉ាងនេះក្តី នៅក្នុងរដ្ឋធម្មនុញ្ញ នេះ ក្រុមប្រឹក្ស ធម្មនុញ្ញ មាន សមត្ថកិច្ច សំខាន់មួយចំនួនដែរ ដូចជាការត្រួតពិនិត្យច្បាប់ ការឲ្យសច្ចាប័ន ទៅលើ

[៤៥] នៅថ្ងៃ ១៥ មិថុនា ឆ្នាំ១៩៥២ ព្រះមហាក្សត្រខ្មែរព្រះបាទ នរោត្តម សីហនុ បានធ្វើអន្តរាគមន៍ យកអំណាចមកកាន់ ខ្លួនព្រះអង្គវិញដោយយក មាត្រា ២១ ធ្វើជាមូលដ្ឋាន ។ នៅឆ្នាំ ១៩៥៥ មាន វិសោធនកម្មមួយ ដ៏សំខាន់ ។



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

សន្ធិសញ្ញា និង អនុសញ្ញាអន្តរជាតិ ព្រមទាំង នីតិក្រមផ្សេងៗទៀតជា ដើម មុននឹងបញ្ជូនទៅថ្វាយព្រះមហាក្សត្រ រដ្ឋមន្ត្រី ទី ១ ប្រធានព្រឹទ្ធសភា ដើម្បីប្រកាសឲ្យចូលជាធរមាន។ ច្បាប់ ទាំងឡាយនោះ អាចនឹងត្រូវ ១ ភាគ ៤ នៃសមាជិកព្រឹទ្ធសភា និង ១ ភាគ ១០ នៃ សមាជិករដ្ឋសភា យ៉ាងតិចបំផុត ព្រះមហាក្សត្រ និង តុលាការបញ្ជូនទៅឲ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យ។ សមត្ថកិច្ច សំខាន់មួយទៀត របស់ក្រុមប្រឹក្សា ធម្មនុញ្ញ គឺការប្រកាសជាមោឃៈ នូវសេចក្តី សម្រេច ចិត្តទាំងឡាយ របស់ រដ្ឋសភា នៅក្នុងករណីដែលសេចក្តីសម្រេច ចិត្តទាំងនោះ ផ្ទុយនឹង គោលការណ៍ «រក្សាឲ្យបាននូវឯករាជ្យ បូណ៌ភាពដែនដី និង ឯកភាព នយោបាយ របស់ប្រទេសជាតិ» ។

# លទ្ធិប្រជាធិបតេយ្យ
# នៅ ប្រទេស កម្ពុជា
# ក្រោយការបោះឆ្នោត ឆ្នាំ១៩៩៣

## La démocratie au Cambodge après les élections de 1993

ចាប់តាំងពីឆ្នាំ ១៩៩៣ មក បន្ទាប់ពីមានរដ្ឋធម្មនុញ្ញហើយ ប្រទេសកម្ពុជា ត្រូវកសាងខ្លួនឡើងវិញ ប៉ុន្តែត្រូវយកលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ធ្វើជាមូលដ្ឋានជាកំហិត ព្រោះជាលក្ខខណ្ឌ នៃ កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍។ ដូចយើងបានដឹងរួចមកហើយ ការអនុវត្តន៍គោលការណ៍នេះ ជាកិច្ចការមួយ ដ៏ ពិបាកពន់ពេកក្រៃ ។ អ្វីៗដែលប្រវត្តិសាស្ត្របាន បន្សល់ទុកឲ្យ ដូចជាវប្បធម៌ ស្ថាប័នរាជានិយមទេវរាជ[៤៦] គំនិត

[៤៦] Monarchie de droit divin (Devarāja) ។ តាមទស្សនៈនេះ ព្រះមហាក្សត្រ ត្រូវបានតែងតាំងដោយពពួកទេវៈ ហើយជាអ្នកតំណាងទេវៈទាំងអស់នៅឋានមនុស្សលោក។

គ្រួសារនិយម ជាដើម នៅតែស្ថិតនៅ ជាកត្តា កំណត់ បដិវាទកម្ម វិបត្តិ អំណាច និង អស្ថិរភាព នយោបាយដដែលៗ គ្មានក្រុមនយោបាយខ្មែរណាមួយ សុខចិត្តលេងល្បែង ប្រជាធិបតេយ្យ ដោយសុទ្ធចិត្តទេៗ អ្នកវិភាគខ្លះយល់ថា បណ្ដាលមកពី កាកសំណល់ នៃ លទ្ធិកុម្មុយនិស្តផ្ដាច់ការៗ ការពិត គឺមកពីកត្តាទាំងពីរនេះរួមគ្នា មិនអាចផ្ដាច់ចេញពីគ្នាបានឡើយ ហើយនេះ ដោយ ពមុគិតពី ការគាបសង្កត់ ពីសំណាក់ប្រទេសកុម្មុយនិស្ត ដែលដណ្ដើមឥទ្ធិពលគ្នា ត្រួតត្រាស្រុកខ្មែរផងទេៗ អ្នកចាញ់ ក្នុងការបោះឆ្នោត ពុំព្រមចាញ់ទេ រីឯអ្នកឈ្នះនៅក្នុងករណីខ្លះ ក៏សុខចិត្តចាញ់ ទៅវិញដែរ ដោយប្រការផ្សេងៗ ដូចជាការកំហិត របស់ គ្រួសារសាច់ញាតិជាដើមៗ អ្នកប្រភេទ ចុងក្រោយនេះ សុខចិត្តបោះបង់សេចក្ដីប៉ងប្រាថ្នា របស់ អ្នកម្ចាស់ឆ្នោត ហើយសុខចិត្តធ្វើចាញ់ទៅវិញ ហើយ ទទួលអំណាច ក្លែងក្លាយ បន្តិចបន្តួច ដើម្បីប្រយោជន៍គ្រួសារ របស់ ខ្លួនផ្ទាល់ និង នៅចំពោះមុខការគំរាមកំហែងរបស់ អ្នកដែលខិតខំពង្រឹងបន្តមកទៀត នូវអំណាច ដែលគេធ្លាប់ មានពីពេលមុន គឺហាក់បីដូចជាស្រុកខ្មែរជាកម្មសិទ្ធិដាច់ថ្លៃ របស់គេដូច្នេះ ដែរៗ ទោះបី កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ឆ្នាំ១៩៩១ បានបញ្ជាក់យ៉ាងច្បាស់ថា វាសនា របស់ ប្រទេសកម្ពុជា ត្រូវកំណត់ ដោយការបោះឆ្នោត ក៏ដោយក្ដី ក៏ គោលការណ៍នេះ យកមកអនុវត្តត្រឹមត្រូវ មិនកើតទាល់តែសោះ គឺហាក់បីដូចជា អ្នកនយោបាយ ខ្មែរពុំទាន់មានស្មារតី សតិអារម្មណ៍ គ្រប់គ្រាន់សម្រាប់ សម្របទៅតាមគោលការណ៍ បែងចែកអំណាច និង គោលការណ៍ផ្ទេរអំណាច តាមបែបបទប្រជាធិបតេយ្យ សេរី ពហុបក្សសោះ (alternance) ។ ម្ល៉ោះហើយ ដើម្បីដោះស្រាយ វិបត្តិផ្សេងៗ អ្នកដឹកនាំ នៃ អំណាចនីមួយៗ តែងតែទៅរក ឲ្យព្រះមហាក្សត្រ ជួយ ទោះបី គេមិនបានប្រគល់ អំណាចអ្វីច្បាស់លាស់ ដល់ព្រះមហាក្សត្រក្ដី ។ ហេតុដូច្នេះហើយបានជាគេ តែងតែ និយាយថា គឺ ជារបប ប្រជាធិបតេយ្យមួយដ៏ក្មេងខ្ចី ។ អ្នកសង្កេតការណ៍ខ្លះ បានកត់សំគាល់ថា ក្រោយការបោះឆ្នោត នៅខែឧសភា ឆ្នាំ ១៩៩៣ ដែលប្រជាជនខ្មែរ ជាច្រើន អស្ចារ្យគឺជិត ៩០ % បានចូលរួម ប្រទេសកម្ពុជាធ្លាក់ បន្តិចម្ដងៗ ទៅក្នុង របៀបរបបចាស់ ពីមុនដដែលវិញ ។ គេតែងតែនិយាយថា ប្រជាជនខ្មែរពុំទាន់ មានកម្រិត





អនុវត្តលទ្ធិប្រជាធិបតេយ្យ ឲ្យបានល្អនៅឡើយ ។ ការចោទប្រកាន់បែប នេះពុំត្រឹមត្រូវទេ ព្រោះការពិត គឺ អ្នកនយោបាយទេ ដែលឈ្លោះប្រកែក ដណ្ដើមអំណាចដណ្ដើមលាភសក្ការគ្នា ដោយឥតកោតក្រែង គឺ ហាក់បីដូច ជាគេយក អំណាច សម្រាប់តែប៉ុណ្ណឹង គឺមិនមែន សម្រាប់ដោះស្រាយបញ្ហា ស្រុកទេសអ្វីឡើយៗ ស្ដីពីបញ្ហានេះ គេអាចធ្វើការវិភាគ ការវិវត្តន៍ របនាសម្ព័ន្ធ ក្រុមនយោបាយ (dynamique des groupes) នៅពេលនោះ ដូចតទៅ ៖ ក្រុមដែលខ្លាំងជាងគេ គឺក្រុម របស់ លោក ហ៊ុន សែន និង គណបក្ស «ប្រជាជន» គាំទ្រដោយវៀតណាមផងដែរៗ នៅក្នុង បរិបទ នៃ ទំនាស់ និងការជានាគ្នាវិញ ជាយុទ្ធសាស្ត្រ រវាង ចិន នឹង វៀតណាម គេអាចនិយាយបានថា លោក ហ៊ុន សែន និង គណបក្ស«ប្រជាជន» មានការគាំទ្រពីប្រទេស កុម្មុយនិស្តទាំងពីរនេះ តែម្ដង ដើម្បីប្រឈមមុខ នឹង ក្រុមអ្នកប្រជាធិបតេយ្យ សេរីនិយម បស្ចិមប្រទេសផង ហើយ ដើម្បីទុកកន្លែង សម្រាប់ពួកគេ ធ្វើវិនិយោគ និង ពង្រីកវិសាលភាព អនុត្តរភាព របស់គេ នៅក្នុងតំបន់ផង ជា ពិសេស ដើម្បី ប្រឆាំង នឹង គោលការណ៍ ប្រជាធិបតេយ្យ ពហុបក្ស និង សទ្ធិមនុស្ស ដែលបស្ចិមប្រទេស ដាក់កំហិតផងៗ ប្រទេសទាំងនោះគេយល់ថា បើប្រទេសកម្ពុជា ឬអ្នកដឹកនាំ តាមបែបបទប្រជាធិបតេយ្យ គេនឹងបាត់បង់លទ្ធ ភាពពង្រីកឥទ្ធិពល របស់គេ នៅក្នុងតំបន់ ជា ពុំខាន ។ រីឯក្រុមអ្នកប្រជាធិបតេយ្យ សេរីនិយមវិញ ពួកគេបានត្រូវពួកខ្មែរក្រហម ដែលជាសម្ព័ន្ធមិត្ត របស់ ចិន វាយកកំទេចចោល តាំងពីឆ្នាំ ១៩៧៥ មកឯណោះ ។ លោក សឺន សាន បានសាកល្បង កសាង ចលនានេះ ជាថ្មីម្ដងទៀត នៅឆ្នាំ ១៩៧៩ ប៉ុន្តែបានត្រូវ ខ្មែរក្រហម និង សម្ដេច នរោត្ដម សីហនុ គ្របដណ្ដប់វិញ ។ សូម្បីតែ គណបក្សរាជានិយម «ហ្វុនស៊ីនប៉ិច» ដែលជាគណបក្ស របស់ ព្រះអង្គ សោះនោះ ក៏ត្រូវព្រះអង្គបង្ខំ ឲ្យព្រះអង្គម្ចាស់រណឫទ្ធិ រួបរួម ជាមួយ គណបក្ស«ប្រជាជន»ដែរ គឺ ចៀសវាងដាច់ខាត មិនឲ្យរេ ទៅតាមបស្ចិមប្រទេស ។

ក្រុមនយោបាយធំ មួយទៀត គឺ ក្រុមរបស់ ព្រះអង្គម្ចាស់ នរោត្ដម រណឫទ្ធិ អ្នកតំណាងរបបរាជានិយមនៅស្រុកខ្មែរៗ បន្ទាប់ពីសម្ដេច នរោត្ដម សីហនុ បង្ខំឲ្យព្រះអង្គ

ម្ចាស់រណឫទ្ធិ រួបរួមជាមួយ លោក ហ៊ុន សែន គណបក្សរាជានិយមនេះ ក៏ អាចចាត់ទុកថា ស្ថិតនៅក្នុងចង្កោម នៃមហាគ្រួសារ នយោបាយ ប្រឆាំង នឹងបស្ចិមប្រទេសដែរ ហើយដែលនៅក្នុងនោះ មាន ក្រុមអ្នកអតីតកុម្មុយនិស្តៗ ទោះបី មានពេលខ្លះអ្នកដឹកនាំ នៃ គណបក្ស រាជា និយមខ្មែរនេះ រេចុះរេឡើង ឬ ពឹងផ្អែកទៅលើកម្លាំងផ្សេងៗ ទៀត នៅពេល មានទំនាស់ផ្ទៃក្នុងម្តងៗក្តី ក៏តាមការពិត គេពុំអាចផ្តាច់ខ្លួនចេញពី មហាគ្រួសារនេះដែរ ។ រីឯទំនាស់ផ្ទៃក្នុង ដែល កំណត់ការបត់បែន ទាំងប៉ុន្មាននោះ គឺអាស្រ័យទៅតាមកាលៈទេសៈផង និង តាមការចាំបាច់ កំណត់តុល្យភាព រវាងដៃគូ របស់គេផង ព្រោះគេសង្ឃឹមថា គេអាច ដណ្តើមយកអំណាច ពីលោក ហ៊ុន សែនបាន ទោះនៅក្នុងបរិបទភូមិសាស្រ្ត-នយោបាយដដែលក្តីៗ គោលដៅ គឺរក្សាអត្តិភាព របស់គេផងហើយ វាយយក ទីតាំងដៃគូ របស់គេតែម្តងបើ ឱកាសហុចឲ្យ ជាពិសេសបើមានការប្រែប្រួលការប្រជែងកម្លាំង នៅក្នុងតំបន់ ឬ ការចុះខ្សោយ របស់ លោក ហ៊ុន សែន ដែលជា មនុស្សខ្លាំង ។ គេ នឹងសង្កេតឃើញ ជាបន្តបន្ទាប់ នៅពេលក្រោយៗ មកទៀតថា ដើម្បីធ្វើកិច្ចការនេះ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែលជា ព្រះរាជបុត្រមួយអង្គរបស់ព្រះមហាក្សត្រ នរោត្តម សីហនុ ផង ហើយ ដែលកាលពីពេលធ្វើយុទ្ធនាការឃោសនាបោះឆ្នោត បានផ្តល់ការសង្ឃឹម ដ៏ច្រើន ទៅឲ្យបស្ចិមប្រទេស តែងតែត្រូវការកម្លាំង ទី ៣ ជានិច្ច គឺ បើគ្មាន គឺត្រូវបង្កើតឲ្យមាន ហើយ បើមានរួចហើយ ត្រូវចេះប្រើកម្លាំងនោះ ដោយស្មារតីច្នៃប្រឌិតបំផុត ពោលគឺ មិនឲ្យមាន ទំនាស់ ជាមូលដ្ឋានឡើយ ហើយ បើមាន ត្រូវកំចាត់ចេញជាបន្ទាន់ៗ ជាពិសេស ត្រូវ ធ្វើយ៉ាងណា កុំឲ្យកម្លាំងទី ៣ នោះ ដណ្តើមយកអំណាចបាន ជាដាច់ខាត ។ ដោយប្រើ នយោបាយនេះ ព្រះអង្គម្ចាស់រណឫទ្ធិ សម្លឹងមើលការប្រែប្រួល នៃសភាពការណ៍ជានិច្ច ហើយសង្ឃឹមថា ថ្ងៃណាមួយ អាចនឹង យកអំណាចបានទាំងមូលមកវិញៗ ដូច្នេះ រវាង កម្លាំងមួយដែលអាចចុះឥទ្ធិពល នឹង កម្លាំងមួយទៀតដែល កំពុងចាប់ផ្តើម កកើតឡើង សាជាថ្មី ព្រះអង្គម្ចាស់រណឫទ្ធិ ធ្វើ ការថ្លឹងថ្លែង យ៉ាងហ្មត់ចត់ ។ រីឯគោលការណ៍ គឺត្រូវមានវត្តមានជានិច្ច ក្នុងឆាកនយោបាយៗ ការពិត នៅពេលមួយដែល ចិន និង វៀតណាមមាន





ឥទ្ធិពល នៅក្នុងតំបន់ យុទ្ធសាស្រ្តនេះ ពុំងាយ នឹងអនុវត្តបានឡើយៗ ផ្ទុយទៅវិញ ព្រះអង្គម្ចាស់រណឫទ្ធិ ស្ថិតនៅជា គ្រោះថ្នាក់មួយដ៏ធំសម្រាប់អតីតជនកុម្មុយនិស្ត ដែលរក្សាជានិច្ច នូវ គំនិត បណ្តេញព្រះអង្គ ចេញពី ឆាកនយោបាយខ្មែរៗ សូម្បីតែព្រះមហាក្សត្រ ក៏ពុំអាចមាន គំនិត ផ្សេងពី អ្នកទាំងនោះ បានឡើយ ។ គឺនៅក្នុងបរិបទភូមិសាស្រ្ត - នយោបាយនេះហើយ ដែលលទ្ធិប្រជាធិបតេយ្យ នៅ កម្ពុជា តែងតែជួបនឹង វិបត្តិ ជារឿយៗ ។

# ខ្លឹមសារ នៃ រដ្ឋធម្មនុញ្ញ នៃ ប្រទេសកម្ពុជា ឆ្នាំ ១៩៩៣ ( រដ្ឋធម្មនុញ្ញ ដែលបានត្រូវអនុម័ត នៅថ្ងៃ ២១ កញ្ញាហើយដែលបានត្រូវប្រកាសឲ្យប្រើ នៅថ្ងៃ ២៤ កញ្ញាឆ្នាំ ១៩៩៣

## Le contenu de la Constitution du Cambodge de 1993

( adoptée le 21 septembre 1993 et
promulguée le 24 septembre 1993)

រដ្ឋធម្មនុញ្ញខ្មែរ ដែលបានត្រូវអនុម័ត នៅថ្ងៃ ២១ កញ្ញា ឆ្នាំ ១៩៩៣ ហើយដែលបានត្រូវប្រកាសឲ្យប្រើ ២ ថ្ងៃបន្ទាប់មក (គឺ រដ្ឋធម្មនុញ្ញដែលពុំទាន់បានត្រូវធ្វើវិសោធនកម្មនៅឡើយ) មានទាំងអស់ ១៣៩ មាត្រា ហើយចែកចេញ ជា ១៤ ជំពូក ។ បើគេអានមួយត្រួសជាលើកដំបូង គេដឹងភ្លាមថា គឺជា រដ្ឋធម្មនុញ្ញមួយ ដែលត្រូវតាក់តែងឡើង នៅក្នុង កាលៈទេសៈមួយ ដែលប្រទេសកម្ពុជា កំពុងឆ្លងកាត់ដំណាក់ការប្រវត្តិសាស្រ្តមួយ ដ៏ស្មុគស្មាញ ពោលគឺ វិបត្តិ នយោបាយមួយ ដ៏ តឹងតែងបំផុតៗ គេ

សង្កេតឃើញថា បញ្ហាការការ ពារអធិបតេយ្យ ជាបញ្ហាមួយដ៏ធំ ហើយ បានត្រូវលើក ឡើង យ៉ាងមធ្យ័តបំផុត។ បញ្ហារក្សាប្រពៃណីជាតិ ក៏ដូចគ្នាអីចឹងដែរ។ ទាំងនេះ សុទ្ធតែ ជាសក្ខីកម្ម ដែលបញ្ជាក់ថា អ្នកសរសេរអត្ថបទ មានស្មារតីប្រុងប្រយ័ត្នខ្ពស់ ក្នុងការ ការពារ ជាតិមាតុភូមិ របស់ខ្លួន ទប់ទល់ នឹង ការជ្រៀតជ្រែក ពីសំណាក់ បរទេស គឺ ហាក់បីដូចជា ប្រមាន រួចជាស្រេច ដល់អ្នកដឹកនាំស្ថាប័ននានា។ គេអាចនិយាយបានថា គឺជា ការដកបទពិសោធន៍មួយ ដ៏ ម៉ឹងម៉ាត់ ក្រោយពេលដែល បរទេស បានចូលមក ជ្រៀតជ្រែកក្នុងប្រទេស សឹងតែរកកលដោះខ្លួនពុំរួច ហើយក្រោយពេលដែលប្រទេស កម្ពុជា បានផុងខ្លួន ទៅក្នុងសង្គ្រាមអស់រយៈពេលជាង ២០ ឆ្នាំមកព្រោះតែអ្នកដឹកនាំខ្លះ មើលស្រាលសភាពការណ៍ ហើយ ធ្វេសប្រហែស ទុកចិត្ត មហាមិត្ត របស់ គេ ជ្រុល ហួសហេតុពេក ។ គឺនៅក្នុងន័យនេះហើយ ដែលមាត្រា ១ វាក្យខណ្ឌទី ២ បាន ចែងថា : ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋ ឯករាជ អធិបតេយ្យ សន្តិភាព អព្យាក្រឹតអចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ ។ ក្រៅពីការដកបទពិសោធន៍ ផ្នែកប្រវត្តិសាស្ត្រនេះ គេក៏សង្កេត ឃើញផងដែរថា គេមានការពិបាកច្រើន ក្នុងការប្រគល់ ការខុសត្រូវផ្សេងៗ ព្រោះត្រូវ ចៀសវាង មិនឲ្យគណបក្សនយោបាយផ្សេងៗ មានការថ្នាំងថ្នាក់។ ក៏ប៉ុន្តែ នីតិវិធីសភា មានការស្មុគស្មាញក្រៃលែង ដែលជាហេតុធ្វើឲ្យមានការពិបាក និង ការបង្អៀតបង្អល់ យ៉ាងខ្លាំង ក្នុងការផ្ទេរអំណាចម្តងៗតាមបែបបទលទ្ធិប្រជាធិបតេយ្យ។ ជាការពិតហើយ ដែលថា ប្រទេសកម្ពុជា បានជ្រើសរើសយក របបសេដ្ឋកិច្ច សេរី ប៉ុន្តែ មាន មាត្រាជា ច្រើន ដែលខិតខំយ៉ាងណា ដើម្បីកុំឲ្យធ្លាក់ទៅក្នុង ការប្រកួតប្រជែង ដាច់បង្ហៀរ។ អត្ថបទជាច្រើនធ្វើការទប់ទល់ យ៉ាងមធ្យ័ត ដើម្បី រក្សាយុត្តិធម៌សង្គម និង សិទ្ធិបុគ្គល ជា ពិសេស សិទ្ធិរបស់ស្ត្រី។ បើប្រៀបធៀប ទៅនឹង រដ្ឋធម្មនុញ្ញ របស់ ប្រទេសមួយចំនួន គេអាចនិយាយបានថា រដ្ឋធម្មនុញ្ញខ្មែរ ឆ្នាំ ១៩៩៣ នេះ មានកល្ខណៈជឿនលឿនច្រើន ដូចជា ការទទួលស្គាល់សទ្ធិរបស់នារី ស្មើនឹង បុរស ក្នុងការជ្រើសរើសមុខរបរ ក៏ដូច ជាការទទួលប្រាក់បំណាច់ស្មើគ្នា ចំពោះការងារដូចគ្នាជាដើម។ សិទ្ធិនេះ មានចែង យ៉ាង ច្បាស់ នៅក្នុងមាត្រា ៣៦ ។



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

តាមរយៈមាត្រា ៧ ជំពូក ទី ២ ប្រទេសកម្ពុជា បានវិល មករក របប រាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញវិញ បន្ទាប់ពីបានឆ្លងកាត់ របប សាធារណរដ្ឋ ពីរ និង របប ប៉ុល ពត ដែលគ្រាន់តែចែងថា : «រដ្ឋកម្ពុជា ជារដ្ឋប្រជាធិបតេយ្យ ជារដ្ឋ របស់ កម្មករ កសិករ និង ពលករ នៃ ស្រទាប់សង្គម នានា តែប៉ុណ្ណោះ» ។ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ផ្តល់ទៅឲ្យប្រទេសកម្ពុជា នូវ របបរាជានិយមមួយ ដែល ព្រះមហាក្សត្រ ទ្រង់ គ្រងរាជ្យសម្បត្តិ ប៉ុន្តែមិនកាន់អំណាចទេ។ ប៉ុន្តែ មាត្រា ៧ ដដែល ក៏ចែងផងដែរថា ព្រះមហាក្សត្រ ជាព្រះប្រមុខរដ្ឋមួយជីវិត។ ដើម្បីសម្របទៅតាមស្ថានភាពបច្ចុប្បន្ន ផង ហើយ ដើម្បី ចៀសវាង វិបត្តិ នៅពេលអនាគតផង មាត្រា ១០ ចែងយ៉ាងច្បាស់ថា «របបរាជានិយម កម្ពុជា ជារបបជ្រើសតាំង»។ ព្រះមហាក្សត្រ ឥតមានអំណាច ជ្រើស តាំង ព្រះរជ្ជទាយាទ សម្រាប់គ្រប់គ្រង រាជសម្បត្តិឡើយ។ បន្ទាប់មក មាត្រា ១៣ បញ្ជាក់យ៉ាងច្បាស់ថា ព្រះមហាក្សត្រថ្មី នៃ ព្រះរាជាណាចក្រកម្ពុជា ត្រូវជ្រើសរើស ដោយក្រុមប្រឹក្សារាជសម្បត្តិ ។ ក្រុមប្រឹក្សារាជសម្បត្តិមាន ៖ ប្រធានរដ្ឋសភា នាយក រដ្ឋមន្ត្រី សម្តេចព្រះសង្ឃរាជ គណៈមហានិកាយ និង គណៈធម្មយុត្តិកនិកាយ អនុប្រធាន ទី ១ និងអនុប្រធាន ទី ២ នៃ រដ្ឋសភា។ គេសង្កេតឃើញថា ប្រធានរដ្ឋសភា មានតួនាទីមួយ ដ៏សំខាន់ នៅក្នុងរបបនយោ បាយខ្មែរនេះ គឺតាក់តែង នីតិកម្មទាំងមូល របស់ប្រទេស ក៏ប៉ុន្តែ គេពុំឃើញមាន ការកំហិតឲ្យមាន អង្គប្រជុំជាអចិន្ត្រៃយ៍ទេ ។ រីឯលទ្ធភាពពិតប្រាកដរបស់ អ្នកតំណាងរាស្ត្រ ក្នុងការត្រួតពិនិត្យសកម្មភាព របស់រដ្ឋាភិបាល ក៏ តិចតួចស្តួច ស្តើងទៅទៀត ។ នៅក្នុងរដ្ឋធម្មនុញ្ញ សម័យទំនើបៗ ដែល ជ្រើសរើសយក របបសភា គេឃើញមានបច្ចេកទេសច្រើនណាស់ សម្រាប់ត្រួតពិនិត្យ អំណាច នីតិប្រតិបត្តិ ។

នៅក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ទោះបី មានការចែង យ៉ាងច្បាស់ថា ព្រះមហាក្សត្រ នៃ ប្រទេសកម្ពុជា ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែ មិនកាន់អំណាចក្តី ក៏ គេសង្កេត ឃើញផងដែរថា ព្រះមហាក្សត្រទទួលខុសត្រូវកិច្ចការប្រទេស គ្រប់វិស័យ គឺតាំងពីជានា ឯករាជ្យជាតិ អធិបតេយ្យ បូណ៌ភាពដែនដី ធានា ការគោរពសិទ្ធិ និង សេរីភាព

របស់ពលរដ្ឋ ធានាការគោរព សន្ធិសញ្ញាអន្តរជាតិរហូតដល់ទៅ ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យតែងតាំងផ្លាស់ប្តូរ ឬដកហូត ចៅក្រមផ្នែកយុត្តាធិការទៀតផង។ ប៉ុន្តែការសម្រេច យ៉ាងណានោះ អំពី កិច្ចការផ្សេងៗ ដែលព្រះមហាក្សត្រ ត្រូវទទួលខុសត្រូវ គឺ មានតែ រដ្ឋសភា និង រដ្ឋាភិបាលប៉ុណ្ណោះ ដែលជាអ្នកមានសិទ្ធិសម្រេច ព្រោះយោងទៅតាមមាត្រា ១៨ ព្រះមហាក្សត្រ ទ្រង់ទាក់ទង ជាមួយរដ្ឋសភា ដោយ ព្រះរាជសារ ប៉ុណ្ណោះ ហើយព្រះរាជសារនេះទៀត រដ្ឋសភា មិនអាចយកទៅ ជជែកពិភាក្សាបានឡើយ។ ដូច្នេះឃើញថា ព្រះមហាក្សត្រ មិនមែនត្រឹមតែជា និមិត្តរូប នៃ ប្រទេសជាតិប៉ុណ្ណោះទេ តែទ្រង់ ក៏ត្រូវទទួលខុសត្រូវលើកិច្ចការ ដែលព្រះអង្គ មិនបានសម្រេច ឬ យល់ព្រម ផងទៀត ។ ចំពោះស្ថាប័នដែលមានសទ្ធិធ្វើ និង សម្រេចកិច្ចការផ្សេងៗ ក៏ សម្រេចអ្វី មិនបានត្រឹមត្រូវ តាមនីតិវិធី ដែរ បើគ្មាន ការឡាយព្រះហស្តលេខា ឬ វត្តមាន ជានិមិត្តរូប របស់ ព្រះមហាក្សត្រ។ បើព្រះមហាក្សត្រ ទ្រង់មិនយល់ស្រប នឹង អំពើ ឬការសម្រេចផ្សេងៗ របស់ ស្ថាប័នរដ្ឋនានា ព្រះមហាក្សត្រ ក៏គ្មានសិទ្ធិដាក់រាជ្យទៀត ព្រោះមាត្រា ៧ វាក្យខណ្ឌ ទី ២ ចែងថា ព្រះមហាក្សត្រទ្រង់ជាព្រះប្រមុខរដ្ឋមួយជីវិត។ ទោះបីព្រះមហា ក្សត្រខ្មែរគ្រាន់តែជានិមិត្តរូប នៃប្រទេសជាតិក្តី ក៏គេមើលទៅឃើញថា វាពុំមែនដូច្នេះទាំងអស់នោះទេ ព្រោះព្រះមហាក្សត្រ ក៏មានសិទ្ធិ ផ្តួចផ្តើមគំនិតដែរ ឲ្យតែមានការយល់ព្រមពី អំណាចនីតិប្បញ្ញត្តិ និង អំណាចនីតិប្រតិបត្តិ។ ឧទាហរណ៍: មាត្រា ១៣២ នៅក្នុងជំពូកទី ៣ ស្តីពីអានុភាពការសេរី និង វិសោធនកម្មរដ្ឋធម្មនុញ្ញ ចែងដូច្នេះថា: ការផ្តើមគំនិតសេរី ឬការផ្តើមគំនិត ធ្វើវិសោធនកម្ម រដ្ឋធម្មនុញ្ញ ជាសិទ្ធិ របស់ព្រះមហាក្សត្រ របស់ នាយករដ្ឋមន្ត្រី និង របស់ប្រធានរដ្ឋសភាតាមសេចក្តីស្នើ របស់អ្នកតំណាងរាស្ត្រមួយភាគ ៤ (១/ ៤) នៃចំនួន សមាជិក រដ្ឋសភាទាំងមូល ។

ទោះជាយ៉ាងនេះក្តី អ្វីដែលគេកត់សំគាល់ នៅក្នុងរដ្ឋធម្មនុញ្ញ ដែលបានត្រូវអនុម័តនៅ ថ្ងៃ ២១ កញ្ញាឆ្នាំ ១៩៩៣ នោះ គឺថា គេបានធ្វើអ្វីគ្រប់បែបយ៉ាងដើម្បី កុំឲ្យព្រះមហាក្សត្រចូលមកជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋ ពោលគឺ ជាការដកបទពិសោធន៍ ដ៏ជូរចត់



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ពីរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ ដែលមាត្រា ២១ ចែងថា អំណាចទាំងអស់ ជា របស់ ព្រះមហាក្សត្រ ប៉ុន្តែ អំណាច ទាំងនោះ ត្រូវប្រើទៅតាមបែបបទ ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញ។ ការពិត គឺមានន័យថា : គឺព្រះមហាក្សត្រទេដែលជាម្ចាស់អំណាច គឺ មិនមែន ប្រជារាស្ត្រឯណាដែលជា ម្ចាស់អំណាចនោះ។ ប៉ុន្តែនៅក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៤៧ នោះ ការប្រើប្រាស់អំណាច របស់ព្រះមហាក្សត្រ ជាភារកិច្ច របស់ឥស្សរជន ឬស្ថាប័នផ្សេងៗ។ នៅក្នុងន័យនេះ ព្រះមហាក្សត្រ អាចវិលត្រឡប់ មកកាន់អំណាចវិញ នៅក្នុងកាលៈទេសចាំបាច់ គឺ ពេលដែលអង្គការផ្សេងៗ មិនអាចធ្វើសកម្មភាពបាន។ នៅក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ព្រះមហាក្សត្រ ពុំអាច យកអំណាចបានសោះឡើយ គឺ បិទជិតស្កុងទាំងអស់។ ចំពោះការធ្វើវិសោធនកម្ម ដើម្បីប្តូររបប «រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ» ក៏ពុំអាចធ្វើទៅបានដែរ ព្រោះមាត្រា ១៣៤ ហាមដាច់ខាតមិនឲ្យធ្វើ។ ក៏ប៉ុន្តែ ការប៉ះពាល់ដល់ ប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស ក៏មិនអាចធ្វើទៅបានដែរ។ និយាយដោយសង្ខេប ទោះបី ព្រះមហាក្សត្រ មិនកាន់អំណាចក៏ដោយ (ឬ បើនិយាយឲ្យចំ គឺ មិនកាន់អំណាចមែន តែជាអ្នកទទួលខុសត្រូវរួម) ក៏ វត្តមាន និង ការឡាយព្រះហស្តលេខា របស់ ព្រះមហាក្សត្រ ជាការចាំបាច់ ហើយ នៅក្នុងមាត្រាខ្លះ ព្រះអង្គមានសិទ្ធិដែរ ប៉ុន្តែ សិទ្ធិនោះ ស្រពេចស្រពិលណាស់ ព្រោះត្រូវចងភ្ជាប់ ជាមួយ សិទ្ធិ របស់ស្ថាប័ននានាដដែល ។ កិច្ចការទាំងឡាយ និង ដំណើរការ នៃ រដ្ឋធម្មនុញ្ញ មិនអាចប្រព្រឹត្តទៅ តាមនីតិវិធីត្រឹមត្រូវទេ បើគ្មាននិមិត្តរូបទាំងអម្បាលម៉ាននោះ។ ទាល់តែមានវិសោធនកម្មមួយនៅថ្ងៃ ១៤ កក្កដាឆ្នាំ ១៩៩៤ ទើបប្រមុខរដ្ឋស្តីទី អាចចុះហត្ថលេខាជំនួសបាន ។ ប៉ុន្តែនៅក្នុងករណីនេះ គឺទាល់តែព្រះមហាក្សត្រ មានជម្ងឺឈឺធ្ងន់ធ្ងរ ដោយមាន ការបញ្ជាក់ ដូចមានចែងក្នុងអត្ថបទ ។

# អំណាច នីតិប្បញ្ញត្តិ និង អំណាច នីតិប្រតិបត្តិ នៅក្នុង រដ្ឋធម្មនុញ្ញខ្មែរ ឆ្នាំ ១៩៩៣

## Le pouvoir législatif et le pouvoir exécutif dans la Constitution khmère de 1993

ដូចយើងបានឃើញរួចមកហើយ រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ជារដ្ឋធម្មនុញ្ញ ដែលជ្រើសរើសយក របបនយោបាយ ប្រជាធិបតេយ្យសេរីនិយមពហុបក្ស ។ នៅក្នុងន័យនេះ អំណាចទាំងមូល ជា របស់ប្រជាពលរដ្ឋ។ មាត្រា ៥១ ចែង យ៉ាងច្បាស់ អំពីប្រភពនៃអំណាចនេះ ដោយបញ្ជាក់ថា : «ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់វាសនា នៃ ប្រជាជាតិរបស់ខ្លួន។ អំណាចទាំងអស់ ជារបស់ពលរដ្ឋ ។ ប្រជាពលរដ្ឋប្រើអំណាច របស់ខ្លួន តាមរយៈ រដ្ឋសភា រាជរដ្ឋាភិបាល និង សាលាជម្រះក្តី» ។ វិសោធនកម្ម នាថ្ងៃ ៦ មិនាឆ្នាំ ១៩៩៩ បានបន្ថែម ស្ថាប័នមួយទៀត គឺព្រឹទ្ធសភា ។ រដ្ឋសភា មានតួនាទី ដ៏សំខាន់ ព្រោះអនុលោម ទៅតាមមាត្រា ៧៦ វាក្យខណ្ឌទី ២ ជាស្ថាប័ន ដែលបានត្រូវជ្រើសតាំង ដោយប្រជាពលរដ្ឋ តាមការបោះឆ្នោត ជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និង តាមវិធីជ្រើសឆ្នោតជាសម្ងាត់។ ស្តីពី ការចាត់តាំង នាយករដ្ឋមន្ត្រី -គឺអ្នកដឹកនាំរដ្ឋាភិបាល- មាត្រា ១១៩ ថ្មី ចែងថា: «តាមសេចក្តីស្នើពីប្រធានរដ្ឋសភា ដោយមានមតិ ឯកភាព ពី អនុប្រធានទាំងពីរ នៃ រដ្ឋសភា ព្រះមហាក្សត្រ ទ្រង់ចាត់តាំង វរជនមួយរូប ក្នុងចំណោមអ្នកតំណាងរាស្ត្រ នៃ គណបក្ស ដែលឈ្នះឆ្នោត ឲ្យបង្កើតរាជរដ្ឋាភិបាល»។ រដ្ឋធម្មនុញ្ញខ្មែរនេះមានលក្ខណៈប្រហាក់ប្រហែល នឹង រដ្ឋធម្មនុញ្ញបារាំងឆ្នាំ ១៩៤៦ ដែលផ្តល់ទៅឲ្យរដ្ឋសភា នូវ តួនាទីមួយ ដ៏សំខាន់ ហើយ ដែលចង់ចងភ្ជាប់រដ្ឋសភា នឹង រដ្ឋាភិបាល ឲ្យបាន ជិតស្និទ្ធ ដើម្បីចៀសវាង កុំឲ្យមាន វិបត្តិ រដ្ឋាភិបាលច្រើនពេក។ នៅក្នុងរដ្ឋធម្មនុញ្ញបារាំងឆ្នាំ ១៩៤៦ នោះ ប្រធានាធិបតី



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

គ្រាន់តែ ចង្អុលបង្ហាញ នាយករដ្ឋមន្ត្រី ប៉ុណ្ណោះ ប៉ុន្តែ គឺ រដ្ឋសភាទេ ដែលជាអ្នកផ្តល់ការទុកចិត្ត ឬ មិនទុកចិត្ត។ នៅក្នុងរដ្ឋធម្មនុញ្ញខ្មែរសព្វថ្ងៃ ក៏ដូចជារដ្ឋធម្មនុញ្ញបារាំង ឆ្នាំ ១៩៤៦ អ៊ីចឹងដែរ អង្គការដែលធ្វើច្បាប់ ពោលគឺ អង្គការនីតិប្បញ្ញត្តិ ជាអង្គការតែមួយគត់ ដែលជ្រើសតាំង នាយករដ្ឋមន្ត្រី ក៏ពិតមែន ក៏ប៉ុន្តែ រដ្ឋាភិបាលឬ អង្គការ នីតិប្រតិបត្តិ មានអំណាច ដ៏ធំធេង ព្រោះមានអ្នកតំណាងរាស្ត្រ នៃ គណបក្ស របស់គេ ដែលជាអ្នកឈ្នះឆ្នោត គឺ មតិភាគច្រើន ជាអ្នកធ្វើច្បាប់ ឬ អនុម័តសេចក្តីសម្រេច របស់ រដ្ឋាភិបាល ដដែលជាដដែល។ បើចំនួននេះ ឈានទៅដល់ ២ ភាគ ៣ នៃ ចំនួនសមាជិក រដ្ឋសភាទាំងមូលនោះ គឺរដ្ឋាភិបាលតែម្តង ដែលជាអ្នកសម្រេចវាសនា របស់ប្រទេស។ ជាការពិតណាស់ដែលថា រដ្ឋសភា ជា អ្នកឃ្លាំមើលសកម្មភាព របស់រដ្ឋាភិបាល ប៉ុន្តែ នៅក្នុងរដ្ឋធម្មនុញ្ញ សព្វថ្ងៃ នេះ មធ្យោបាយ និង បច្ចេកទេស មានមិនគ្រប់គ្រាន់ទេ សម្រាប់ធ្វើកិច្ចការ ដ៏ធំនេះ ។ នៅក្នុងរដ្ឋធម្មនុញ្ញខ្មែរឆ្នាំ ១៩៩៣ គេពុំឃើញមានបច្ចេកទេសសំខាន់ៗ សម្រាប់ ឲ្យរដ្ឋសភា ត្រួតពិនិត្យសកម្មភាព របស់រដ្ឋាភិបាល ឲ្យបានជិតដល់ទេ។ គេពុំឃើញមានចែងឲ្យបានច្បាស់ អំពី លទ្ធភាពចាត់តាំង គណកម្មការ សម្រាប់ធ្វើការអង្កេត សំណុំរឿងផ្សេងៗ ឬ ក៏សវនកម្មអ្វីច្បាស់លាស់ទេ។ គេឃើញមានតែ សំនួរ ជា លាយលក្ខណ៍អក្សរ និង ការហៅសួរ ដេញដោល តែមួយពេលប៉ុណ្ណោះ ។

ជាការពិតហើយដែលថាមាត្រា ៩៦ ចែងអំពីការត្រួតពិនិត្យនេះ ។ ប៉ុន្តែនៅក្នុងមាត្រា ៩៦ ដដែលនោះ នៅត្រង់ វាក្យខណ្ឌ ទី ៥ ចំពោះ ចម្លើយផ្ទាល់មាត់ ប្រធានរដ្ឋសភា អាចសម្រេចបើកឲ្យមាន ឬ មិនឲ្យមាន ការជជែក ដេញដោល ហើយ នៅត្រង់ វាក្យខណ្ឌទី ៦ នៅក្នុងករណីដែលបើកឲ្យមាន ការដេញដោល ក៏ ការប្តូរយោបល់នោះមិនអាចមាន ថេរវេលា ហួសពី មួយពេលប្រជុំ បានឡើយ។ យោងទៅតាមមាត្រា ៩៨ រដ្ឋសភាអាចទម្លាក់ សមាជិក គណរដ្ឋមន្ត្រី ឬ ទម្លាក់រដ្ឋាភិបាល ពី តំណែង ដោយ អនុម័ត ញត្តិបន្ទោស (motion de censure) តាមសំឡេងឆ្នោត ២ ភាគ ៣ នៃ ចំនួនសមាជិក រដ្ឋសភា ទាំងមូល ។ ប៉ុន្តែ រដ្ឋសភា អាចលើកយក បញ្ហានេះ មកពិនិត្យបាន

ទាល់តែមានអ្នកតំណាងរាស្ត្រចំនួន ៣០ នាក់ បានស្នើឡើង។ ដូច្នេះឃើញថា បញ្ហាដែលសំខាន់ គឺ ការឃ្លាំមើលសកម្មភាព របស់រដ្ឋាភិបាល។ ដែលក្តាប់អំណាច សឹងតែទាំងអស់ទៅហើយ ពោលគឺ ផែនការរដ្ឋទាំងអស់ រីឯរដ្ឋសភាគ្រាន់តែអនុម័ត ប៉ុណ្ណោះ។ នៅក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ រដ្ឋសភា ប្រជុំជា សាមញ្ញ ២ ដងក្នុងមួយឆ្នាំ ។ សម័យប្រជុំ នីមួយៗ មានថេរវេលា យ៉ាងតិច ៣ ខែ ។ បើមានសំណូមពរ ពីព្រះមហាក្សត្រ ឬ សេចក្តីស្នើ ពីនាយករដ្ឋមន្ត្រី ឬ ពី សមាជិករដ្ឋសភា ចំនួន ១ ភាគ ៣ យ៉ាងតិច គណកម្មាធិការអចិន្ត្រៃយ៍ រដ្ឋសភា កោះប្រជុំរដ្ឋសភាជា វិសាមញ្ញ។ ដូចនៅក្នុងរដ្ឋធម្មនុញ្ញ ឯទៀតៗដែរ រដ្ឋសភាអនុម័ត ថវិកាជាតិ ផែនការរដ្ឋ ការឲ្យរដ្ឋមន្ត្រីខ្ចីប្រាក់ពីគេ ឬ ក៏ ឲ្យគេ ខ្ចីប្រាក់ កិច្ចសន្យានានា ផ្នែកហិរញ្ញវត្ថុ និង ការកែប្រែ ឬ លុបចោលពន្ធដារ ព្រមទាំងកិច្ចការប្រទេសជាតិធំៗ មួយចំនួនទៀត ដូចជាការយល់ព្រម ឬ លុបចោល សន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិ ការអនុម័តច្បាប់ស្តីពី ការប្រកាស សង្គ្រាម ការអនុម័តច្បាប់ ស្តីពីការលើកលែងទោសជាដើម ។ កិច្ចការនេះ មានទំហំធំណាស់ ហើយបើរដ្ឋសភាគ្មាន គណកម្មការ អង្កេត ច្រើនទេ គឺ អាច នឹងត្រូវ រណបទាំងស្រុង ទៅតាមអង្គការ នីតិប្រតិបត្តិ ។





# «ល្បើកចចក»

# La fable du loup

# ជំពូក ១១
# វិលមករកចំណុចដើមវិញ

នៅសតវត្សរ៍ ទី ១៩ កវីខ្មែរ សន្ធរ ម៉ុក បាននិពន្ធរឿង «ល្បើកចចក» [៤៧] ដើម្បីនិយាយពី គំនិតចង់ធំ លើសគេឯង របស់ចចក ដែលនៅទីបំផុតក្លាយ ទៅជាចចកវិញ ប៉ុន្តែត្រូវបាត់បង់ នារីជាទីស្រឡាញ់ និងសេចក្ដីសុខសាន្ត ដែលធ្លាប់ មានកាលពីពេលមុន ។ ព្រឹត្តិការណ៍ ដែលកើតមាន នៅស្រុកខ្មែរ ក៏អាចប្រៀបបាន ទៅនឹង រឿងនេះដែរ។ ពេលដែលខ្មែរបានឯករាជ្យពីបារាំង ខ្មែរមានលទ្ធភាព គ្រប់គ្រាន់ទាំងអស់ ដើម្បីកសាងប្រទេសជាតិ ឲ្យដើរទាន់សម័យ ហើយមានការធានាអន្តរជាតិ សព្វបែបយ៉ាង។ ប៉ុន្តែ ផ្ទុយទៅវិញ អ្នកដឹកនាំ ខ្មែរបែរជាបោះបង់ ភ័ព្វសំណាងនេះ ចោលទាំងអស់ទៅវិញ (សន្និសីទទីក្រុងហ្សឺណែវ ឆ្នាំ ១៩៥៤)។ ក្រោយការរលំរលាយសហភាព សូវៀត នៅឆ្នាំ ១៩៩១ ខ្មែរបានទទួល ភ័ព្វសំណាងមួយទៀត គឺ កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ប៉ុន្តែ សាជាថ្មីទៀត អ្នកដឹកនាំខ្មែរ នាសម័យនោះ បានបោះបង់ កិច្ចព្រមព្រៀង នោះចោលទៀត ដើម្បីវិលទៅរក ការខុសឆ្គង កាលពី ទសវត្សរ៍ ១៩៦០។ កវី សន្ធរ ម៉ុក បាននិទាន រឿងចចក ដូច្នេះថា ៖ ពេល ចចក និយាយថា ខ្លួនគេប្រាថ្នា ចង់កើត ជាព្រះសុរិយា យក្សប្រេតមួយ ដែលស្វែងរកអាហារ ហើយដែលបានស្ដាប់ឮ អស់សេចក្ដី ក៏កាឡាខ្លួន ជាព្រះឥន្ទ្រាធិរាជ មកជួបចចក ។ យក្សប្រេតនោះ ប្រាប់ ចចកថា គឺជាការងាយណាស់ គឺគ្រាន់តែបណ្ដោយខ្លួន ឲ្យយក្សបិសាចធីសាច់ឈាមគឺជាការស្រេច។

---

[៤៧] *ប្រជុំរឿងព្រេងខ្មែរ* ភាគ ៤, Institut Boudhique, 3ème Edition ; Institut de l’Asie du Sud-Est, 1982





កិច្ចព្រមព្រៀង សន្តិភាព ទីក្រុងប៉ារីស៍ បានត្រូវ យកមកអនុវត្តបានត្រឹមការបោះឆ្នោតសេរី ឆ្នាំ ១៩៩៣ ប៉ុណ្ណោះ ហើយ មិនបានដូចគោលដៅដែល កិច្ចព្រមព្រៀងនោះបានកំណត់ផង ព្រោះ លោក ហ៊ុន សែន មិនព្រមទទួលស្គាល់លទ្ធផល នៃ ការបោះឆ្នោត ដែលបានប្រព្រឹត្តទៅ តាមគោលការណ៍ត្រឹមត្រូវ។ បក្ស ប្រជាជន និង បក្សរាជានិយម ហ៊្វុនស៊ិនប៉ិច បែរជា បែងចែកអំណាចគ្នា ដើម្បីរាំងស្កាត់កុំឲ្យបក្សផ្សេងទៀតយកអំណាចបាន ហើយប្លន់ឃោបាយក្រៅប្រទេស របស់ពួកគេ។ ដោយអ្នកដឹកនាំខ្មែរនៅពេលនោះ មិនគោរព គោលការណ៍ កិច្ចព្រមព្រៀង អន្តរជាតិនោះ ដែលកំហិតឲ្យយកលទ្ធផល នៃ ការបោះឆ្នោតជាធំ សហគមន៍ អន្តរជាតិ ដែលប្រញាប់បញ្ចប់អធិករណ៍ រវាង ប្រទេស ដែលជាប់ពាក់ព័ន្ធ ក៏ អស់លទ្ធភាព ជួយខ្មែរទៀត ហើយបណ្ដោយឲ្យស្ថានការណ៍ វិវត្ត ទៅតាម យថាកម្មតែម្ដងទៅ។ សម្ដេច នរោត្តម សីហនុ ដែលចង់បង្រួបបង្រួមខ្មែរ ដោយផ្ទាល់ព្រះអង្គ ក៏ធ្វើការបង្រួបបង្រួមនេះ ពុំកើត ហើយយកអំណាចពី បក្សប្រជាជនវិញ ក៏ពុំកើត។ រដ្ឋប្រហារខែកក្កដា ឆ្នាំ ១៩៩៧ បាន បញ្ចប់អផិក្រម សន្តិភាពនេះ ហើយ បើកផ្លូវ ឲ្យសង្គ្រាមមួយទៀត ចាប់ផ្ដើម សាជាថ្មី ទៀត។ ប្រទេសវៀតណាមដែលគាំទ្រលោកហ៊ុន សែន នៅពេលនោះ ចាប់ផ្ដើមលេប ទឹកដីខ្មែរ ហើយ ប្រទេសចិន ដែលមានសម្ដេច សីហនុ ជាកូនអុក  ក៏ខំធ្វើយ៉ាងណា យកទឹកដីខ្មែរវិញ ឲ្យបានដូចកាលជំនាន់ ប៉ុល ពត ។ ជនជាតិខ្មែរដែលយល់ពីរឿងនេះ ហើយដែលមកជ្រកកោន នៅបរទេស ជាពិសេស នៅ សហរដ្ឋ អាមេរិក និង ប្រទេសបារាំង ខិតខំទាមទារ ឲ្យយក កិច្ចព្រមព្រៀង សន្តិភាពទីក្រុងប៉ារីស៍ មកអនុវត្ត វិញ ប៉ុន្តែ អន្តរជាតិ មានការស្ទាក់ស្ទើរ ព្រោះខ្លាចរឿង ចក្រចលនា ធាក់ថយក្រោយ ដដែលនេះកើតមានឡើងម្ដងទៀត។

# ស្ថានភាព ភូមិសាស្ត្រ-នយោបាយ នៃ ប្រទេស កម្ពុជា នៅឆ្នាំ ១៩៩៣

## Situation géopolitique du Cambodge en 1993

ដូចយើងបានដឹង រួចមកហើយ រដ្ឋាភិបាល ដែលបានទទួលការទុកចិត្ត ពី រដ្ឋសភា នៅថ្ងៃ ២៩ តុលា ឆ្នាំ ១៩៩៣ ជា «រដ្ឋាភិបាលក្បាលពីរ» (Gouverne-ment bicéphale) ព្រោះមាន នាយករដ្ឋមន្ត្រី ដល់ទៅពីររូប គឺ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ អ្នកដឹកនាំ គណបក្សរាជានិយម «ហ្វុនស៊ីនប៉ិច» និង លោក ហ៊ុន សែន អ្នកដឹកនាំម្នាក់ នៃអតីតគណបក្សកុម្មុយនិស្ត កាលសម័យកងទ័ពវៀតណាម លើកទ័ព ចូល មកក្នុងទឹកដីខ្មែរ វាយរំលំ របប ប៉ុល ពត ដែលជា សត្រូវរបស់គេ ហើយដែល បានសម្លាប់ប្រជាជនខ្មែរ អស់ជិត ២ លាននាក់ ។ ចំពោះប្រវត្តិសាស្ត្រខ្មែរ វរជនទាំង ពីររូបនេះ សុទ្ធតែមានគុណូបការៈរៀងៗ ខ្លួន។ លោក ហ៊ុន សែន ដែលកាលនោះ ស្ថិតនៅក្រោមការដឹកនាំ របស់គណបក្ស «ប្រជាជនបដិវត្តកម្ពុជា» បានរំដោះប្រជាជន ខ្មែរឲ្យផុតពី ក្រញាំពួកខ្មែរក្រហម ប៉ុល ពត ប៉ុន្តែ ក៏ជាអ្នកដែលបាននាំ កងទ័ព វៀតណាម ចូលមកក្នុងប្រទេសកម្ពុជាដែរ។ តាមការពិត ទោះបីគ្មានលោក ហ៊ុន សែន ក៏ដោយ ក៏ប្រទេសវៀតណាម ត្រូវតែចូលមកស្រុកខ្មែរ វាយរំលំ របប ប៉ុល ពត ដែរ ព្រោះនៅពេលនោះ ទីក្រុងហាណូយក៏ដូចជាទីក្រុងម៉ូស្គូដែរ គេមិនអាចទុកឲ្យ «បដិវត្តន៍ ខ្មែរក្រហម» ដែលជាដៃជើង របស់ចិន តាំងទីនៅស្រុកខ្មែរបានទេ ។ វៀតណាមខ្លាច ក្រែង ប្រទេសចិនប្រើ ប៉ុល ពត ឲ្យវាយលុកប្រទេសគេ ដើម្បីពង្រីកពង្រឹង ឥទ្ធិពល លទ្ធិម៉ៅនិយមផង ហើយ វាតទឹកដីរបស់គេ នៅក្នុងអតីតឥណ្ឌូចិនបារាំងទាំងមូលផង។ រីឯខ្មែរក្រហម ខាង ប៉ុល ពតវិញ គេមានជំនឿថា តាមរយៈ យុទ្ធសាស្ត្រនេះ គេអាច





ធ្វៀតរំដោះ ទឹកដីខ្មែរ ដែលប្រទេសវៀតណាមបានលេប តាំងពីសតវត្សរ៍ទី ១៧ មក វិញបានផងទៀត។ ដោយ ព្រោះតែហេតុនេះហើយ បានជាប្រទេសវៀតណាម ដែល មានការគាំទ្រ យ៉ាងពេញទំហឹងពី សហភាព សូវៀត តាំងពីសម័យ ហូ ជីមិញ មក បានសាកល្បងក្តាប់យក តំបន់នេះ ឲ្យបានមុនចិន។ រីឯព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដែល បានទទួលជ័យជំនះទៅលើ លោក ហ៊ុន សែន នៃគណបក្ស «ប្រជាជន» នៅ ក្នុងការបោះឆ្នោតសេរី លើកដំបូងបង្អស់ ក្រោមឱវាទ របស់ អង្គការ សហប្រជាជាតិ ជាព្រះរាជបុត្រមួយអង្គ របស់ ព្រះមហាក្សត្រខ្មែរ ព្រះបាទ នរោត្តម សីហនុ ដែល ក្រោយពេលបានឯករាជ្យពីបារាំង បានជ្រើសរើសយក ប្រទេសចិនកុម្មុយនិស្ត ធ្វើជា សម្ព័ន្ធមិត្ត យុទ្ធសាស្ត្រ ។ នៅ ចុងទសវត្ស ១៩៨០ ដោយ សហភាព សូវៀត រលំ រលាយបាត់ទៅ ប្រទេស វៀតណាម ក៏អស់បង្អែកមួយ ដ៏សំខាន់ ។ ទីក្រុងហាណូយ ត្រូវបែរទៅរក ចិនវិញ ដើម្បីការពារ របបកុម្មុយនិស្តរបស់គេ ឬបើនិយាយឲ្យចំ ដើម្បីការពារ អ្នកដឹកនាំកុម្មុយនិស្ត របស់គេ បន្តទៅទៀត ។ ហេតុដូច្នេះហើយបានជា អ្នកដឹកនាំកុម្មុយនិស្តខ្មែរ ទាំងពីរក្រុម ដែលទាស់ទែងគ្នា ពីពេលមុនត្រូវចាប់ដៃគ្នាវិញ ដើម្បីកុំឲ្យ បស្ចិមប្រទេស ចូលមកជ្រៀតជ្រែកទាន់។ ព្រោះថា បើ បស្ចិមប្រទេសវិល មកវិញ ចិន ក៏ដូចជា វៀតណាម អាច នឹង ជួបឧបសគ្គ មួយដ៏ធំ ក្នុងការវាតទឹកដី របស់គេ នៅក្នុងតំបន់ ។ ជាការពិតហើយដែលថា ចិន និង វៀតណាម មិនត្រូវគ្នា ព្រោះតែរឿងនេះ ប៉ុន្តែ ដើម្បីរក្សា របបកុម្មុយនិស្តរបស់គេ វៀតណាម គ្មានជម្រើសអ្វី ទៀត ក្រៅពីត្រូវនឹង ចិនវិញ សិនទេ ទម្រាំរកបង្អែកថ្មីបាន។ ចំពោះព្រះអង្គម្ចាស់ រណឫទ្ធិវិញ ទោះបី ព្រះអង្គជាព្រះរាជបុត្រ របស់ សម្តេចនរោត្តម សីហនុក្តី ក៏ ព្រះ អង្គ ចង់រំដោះស្រុកខ្មែរឲ្យចេញផុតពី ឥទ្ធិពល នប្រទេស កុម្មុយនិស្តទាំងពីរនេះដែរ។ ប៉ុន្តែនៅក្នុងកាលៈទេសៈនោះ គឺ ជា ការយល់សប្ត មួយ ដ៏ធំ ព្រោះតាំងពីពេល ដែល សហរដ្ឋ អាមេរិក បោះបង់ឥណ្ឌូចិនចោលទៅ គឺ តាំងពីពេលដែល របប «សាធារណ រដ្ឋខ្មែរ» ត្រូវខ្មែរក្រហមវាយរំលំចោល ហើយ នៅពេលចុងក្រោយ តាំងពីពេលដែល សហភាព សូវៀត រលំរលាយទៅ ប្រទេសចិន មិនបណ្តោយ ឲ្យ តំបន់ឥណ្ឌូចិន របូត

បេញពីដៃរបស់គេឡើយ។ ប៉ុន្តែ ក្នុងកាលៈទេសៈ ដដែលនោះ ប្រទេសថៃ ក៏ចង់មាន តួនាទីមួយ ដ៏ សំខាន់ដែរ គឺ ដូចកាលពីមុន ពេលដែលបារាំង ចូលមកស្រុកខ្មែរ។

ប្រទេសថៃ ដែលមានព្រំប្រទល់ ជាប់នឹងស្រុកខ្មែរ យល់ឃើញ ថា ស្ថានភាព ប្រទេសកម្ពុជា ក្រោយសង្គ្រាម ជាឱកាសមួយដ៏ល្អ សម្រាប់ជួយ «កសាង» ប្រទេស នេះ។ ហេតុដូច្នេះហើយបានជា ពាណិជ្ជករប្រទេសថៃ ចូលមកធ្វើវិនិយោគ យ៉ាងសន្ធឹក សន្ធាប់នៅស្រុកខ្មែរ ហើយប្រើគ្រប់មធ្យោបាយដើម្បីឲ្យក្រុម លោក ហ៊ុន សែន ទទួល យកវិនិយោគទាំងនោះ ដែលភាគច្រើន មិនសូវហុចប្រយោជន៍ ជាមូលដ្ឋានអ្វី ប៉ុន្មានទេ ដល់កម្ពុជា ឡើយ ។ នៅចំពោះមុខ ស្ថានភាពនេះ លោក សម រង្ស៊ី ដែលកាលនោះ ជារដ្ឋមន្ត្រី ហិរញ្ញវត្ថុ ចង់រៀបចំ ឲ្យការធ្វើវិនិយោគ នៅស្រុកខ្មែរ មានលក្ខណៈល្អត្រឹម ត្រូវឡើងវិញ។ នៅថ្ងៃ ២៥ វិច្ឆិកា ឆ្នាំ ១៩៩៣ ដដែលនោះ លោក បានបញ្ជាក់ ជា ផ្លូវការ នូវ គោលបំណងនេះ ។ ប៉ុន្តែស្រាប់តែ ៣ ថ្ងៃ ក្រោយមក គឺនៅថ្ងៃ ២៨ វិច្ឆិកា ពាណិជ្ជករថៃម្នាក់ ដែលមានទំនាស់ជាមួយ លោក សម រង្ស៊ី បានផ្តល់យន្តហោះមួយ ជាអំណោយ ដល់ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រី ទី ១ និង លោក ហ៊ុន សែន នាយករដ្ឋមន្ត្រី ទី ២។ សហនាយករដ្ឋមន្ត្រីខ្មែរទាំងពីររូប នៃ «រដ្ឋាភិបាល ក្បាលពីរ» ក៏សុខចិត្តទទួលយកអំណោយនោះ [៤៨]។ ទំនាក់ទំនង រវាង ប្រទេស កម្ពុជា នឹង ប្រទេសថៃ នៅពេលនោះ នៅពុំទាន់ល្អនៅឡើយទេ ព្រោះ ជាង ២ ខែក្រោយ ពេលដែលរដ្ឋសភា ផ្តល់ការទុកចិត្ត ទៅឲ្យ រដ្ឋាភិបាល រណឫទ្ធិ-ហ៊ុន សែន មេសេនា ធិការដ្ឋានកងទ័ពថៃ គឺ ឧត្តមសេនីយ៍ វិមល នៅតែចាត់ទុកថា រដ្ឋាភិបាលខ្មែរ ពេល នោះ គ្រាន់តែជារដ្ឋាភិបាល នៃ ភាគីខ្មែរមួយប៉ុណ្ណោះ ដោយហេតុថា គ្មានការយល់ ព្រមពី ភាគីខ្មែរក្រហម ខាងប៉ុល ពត។ នៅថ្ងៃ ៨ ធ្នូ ឆ្នាំ ១៩៩៣ ដដែលនោះ នៅក្នុង ភូមិថៃមួយ ក្បែរព្រំប្រទល់ប្រទេសកម្ពុជា គេបានរកឃើញ កន្លែងលាក់អាវុធ ដ៏ធំមួយ

[៤៨] យោងទៅតាមឯកសារ របស់ លោក រ៉ាអ៊ូល ជេណា ( Raoul Jennar) ។ In Les Clés du Cambodge de Raoul Jennar, Maisonneuve & Larose, page 124 ។



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

របស់ពួក ប៉ុល ពត ។ ១០ ថ្ងៃក្រោយព្រឹត្តិការណ៍ នេះ គឺ នៅថ្ងៃ ១៩ ធ្នូ កាសែត អាមេរិក «ញីវយ៉ក ថែម» បានចុះផ្សាយអត្ថបទមួយ យ៉ាងវែង ធ្វើនិទស្សន៍ ថា ប្រទេសថៃ គាំទ្រ ពួកខ្មែរក្រហម ។

# ការវិលត្រឡប់មកវិញ នៃ របប រាជានិយម នៅឆ្នាំ ១៩៩៣ និង អំពីបញ្ហាធំៗដែល រាជរដ្ឋាភិបាលខ្មែរ ត្រូវប្រឈមមុខ

## Du retour de la monarchie en 1993 et des problèmes auxquels le Gouvernement royal devait faire face

នៅដើម ខែកញ្ញា ឆ្នាំ ១៩៩៣ គណកម្មាធិការតាក់តែងរដ្ឋធម្មនុញ្ញ បានសម្រេចផ្តល់ ទៅឲ្យ ប្រទេសកម្ពុជា នូវ របប រាជានិយម អាស្រ័យរដ្ឋធម្ម នុញ្ញ ។ ប៉ុន្តែ នៅថ្ងៃ ៤ កញ្ញា ឆ្នាំ១៩៩៣ នៅក្នុង ព្រះរាជសារលិខិតមួយ ផ្ញើ មកពីក្រុងប៉េកាំង សម្តេច នរោត្តម សីហនុ ទ្រង់បានបញ្ជាក់ថា ព្រះអង្គ ពុំប្រាថ្នាចង់បាន របបរាជានិយមទេ។ ប្រតិកម្មនេះ របស់ អតីតព្រះមហាក្សត្រខ្មែរ [៤៩] បានស្តែងចេញឡើង មួយថ្ងៃក្រោយ ពេលដែល សហនាយករដ្ឋមន្ត្រីទាំងពីរ នៃ រដ្ឋាភិបាលបណ្តោះអាសន្ន គឺ ព្រះអង្គម្ចាស់ រណឫទ្ធិ និង លោក ហ៊ុន សែន បានយក គម្រោងដំពូកដើម នៃ រដ្ឋធម្មនុញ្ញទៅ សុំព្រះរាជយោបល់ នៅ ទីក្រុងប៉េកាំង ។ សម្តេច នរោត្តម សីហនុដែលកាលពី ៣៨

[៤៩] ព្រះបាទនរោត្តម សីហនុ សោយរាជ្យ ពីឆ្នាំ ១៩៤១ មកដល់ ឆ្នាំ ១៩៥៥ ។ នៅឆ្នាំ ១៩៥៥ នោះព្រះអង្គដាក់រាជ្យថ្វាយទៅព្រះបិតា និងព្រះមាតា របស់ព្រះអង្គ ។

ឆ្នាំមុននេះ គឺ នៅថ្ងៃ ៣ មិនាឆ្នាំ ១៩៥៥ បានដាក់រាជសម្បត្តិ ថ្វាយទៅព្រះរាជបិតា និង ព្រះមាតា របស់ព្រះអង្គដើម្បីចូលប្រឡូកប្រយុទ្ធ តទល់នឹងគណបក្ស នយោ បាយនានា នៅពេលនោះ បានបញ្ជាក់ប្រាប់ លោក  ហ៊ុន សែន និង ព្រះអង្គ ម្ចាស់រណឫទ្ធិថា ព្រះអង្គបារម្ភខ្លាចក្រែង ការវិល ទៅរក របប រាជានិយមវិញ នឹងនាំមកនូវការបែកបាក់ ។ តាមការពិត អ្វីដែល សម្តេច នរោត្តមសីហនុ ប្រាថ្នា ចង់បានក្រោយការបោះឆ្នោតឆ្នាំ ១៩៩៣ នោះ គឺ របបមួយដែលមាន ព្រះអង្គជាប្រមុខរដ្ឋ។ ប៉ុន្តែ សហនាយករដ្ឋមន្ត្រី នៃ រដ្ឋាភិបាលបណ្តោះអាសន្ន ទាំងពីររូប មានការបារម្ភ ខ្លាចក្រែងតួនាទីនេះ ធ្វើឲ្យមាន ការពិបាក ទៅថ្ងៃក្រោយ។ ហេតុដូច្នេះហើយ បានជា អ្នកដឹកនាំទាំងពីរ សម្រេចយក របបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញវិញដោយធ្វើយ៉ាងណា កុំឲ្យព្រះអង្គអាចចូលជ្រៀតជ្រែកក្នុងកិច្ចការរដ្ឋបាន ។ នៅពេលនោះ គណកម្មការ តាក់តែងរដ្ឋធម្មនុញ្ញ ដែលមាន សមាជិក ១៥ រូប ក៏ពុំចង់បានរបប រាជានិយមរបៀបនេះដែរ។ សមាជិកសភា ធម្មនុញ្ញ ១២ រូប បានស្នើឡើងនូវរបបនយោបាយមួយ ផ្សេងពីនេះ គឺ របបសភា មួយដែលមាន ប្រមុខរដ្ឋបោះឆ្នោតជ្រើសតាំង ៥ ឆ្នាំម្តង។ ប៉ុន្តែ នៅទីបំផុត គោលការណ៍ ជាមូលដ្ឋាន នេះ សម្រាប់អនាគត រដ្ឋធម្មនុញ្ញខ្មែរ បានត្រូវបោះបង់ចោលទៅវិញ ហើយ របបរាជានិយមអាស្រ័យសភា បានត្រូវអនុម័ត នៅថ្ងៃ ១៥ កញ្ញា ដោយ សភាធម្មនុញ្ញ ។ បន្ទាប់មក រដ្ឋធម្មនុញ្ញទាំងមូល បានត្រូវអនុម័ត នៅថ្ងៃ ២១ កញ្ញា ដោយ ១១៣ សំឡេង ទល់នឹង ៥ ហើយ អនុបវាទ ២ សំឡេង ។ ដូច្នេះឃើញថា ការតវ៉ា របស់ សម្តេច នរោត្តម សីហនុ នាថ្ងៃ ៤ កញ្ញា ពុំបានសម្រេច ដូចគោលបំណងឡើយ។ ទោះជាយ៉ាងណាក្តី ក៏សម្តេច នរោត្តម សីហនុ ដែលបានត្រូវតែងតាំង ជាព្រះមហាក្សត្រ នៃ ប្រទេសកម្ពុជា បានសព្វព្រះរាជហឫទ័យ ប្រកាសឲ្យប្រើ រដ្ឋធម្មនុញ្ញនេះ នៅថ្ងៃ ២៤ កញ្ញាដែរ ។

ក្រោយព្រឹត្តិការណ៍នេះ គេសង្កេតឃើញថា ថ្វីត្បិតតែព្រះមហាក្សត្រ គ្រងរាជ្យ ប៉ុន្តែមិនកាន់អំណាចក្តី ក៏ព្រអង្គនៅតែមានឋានៈជាប្រមុខរដ្ឋ ដដែល។ ដោយអនុលោម ទៅតាមមាត្រា ១៩ និង មាត្រា ១០០ នៅ ពេលនោះ ព្រះអង្គ ក៏តែងតាំង ព្រះអង្គម្ចាស់





រណឫទ្ធិ និង លោក ហ៊ុន សែន ជានាយករដ្ឋមន្ត្រី ទាំងពីរនាក់តែម្តង។ តាំងពីពេលនោះ មក សហនាយករដ្ឋមន្ត្រីទាំងពីរ លែងជាអ្នកដឹកនាំ រដ្ឋាភិបាលបណ្តោះអាសន្ន ទៀត ហើយ គឺ បានក្លាយ ជានាយករដ្ឋមន្ត្រី ត្រឹមត្រូវតាមច្បាប់។ ក្រោយមក មាត្រា ១០០ បានត្រូវយកទៅដាក់ជាមាត្រា ១១៩ ថ្មីវិញនៅត្រង់ជំពូកទី ១០ ថ្មីស្តីពី រាជរដ្ឋាភិបាល។ នៅពេលដែលស្ថាប័នរដ្ឋធំៗទាំងអស់ ចាប់ផ្តើមធ្វើដំណើរការ ប្រទេសកម្ពុជាត្រូវប្រឈមមុខ នឹង បញ្ហានយោបាយសំខាន់ៗ ដូចជា បញ្ហាខ្មែរក្រហម ដែលនៅតែពុំព្រមចុះចូល រាជរដ្ឋាភិបាល ហើយ សុខចិត្ត បង្កអសន្តិសុខ នៅក្នុងស្រុកបន្តទៅទៀត បញ្ហាកសាង ប្រទេស ទៅតាម បែបបទលទ្ធិប្រជាធិបតេយ្យសេរីនិយម ពហុបក្ស និង បញ្ហាទាក់ទង នឹង ប្រទេសថៃ ដែលនៅតែចាត់ទុកថា រដ្ឋអំណាចថ្មីគ្រាន់តែជា រដ្ឋអំណាច របស់ ខ្មែរ មួយក្រុមប៉ុណ្ណោះ ដោយហេតុថា គ្មានការចូលរួម ចំណែកពីពួកខ្មែរក្រហមខាង ប៉ុលពត ។ មិនតែប៉ុណ្ណោះ ប្រទេសថៃ ថែមទាំងជួយខ្មែរក្រហមទៀតផង ។ តាមការពិត ទីក្រុងបាងកក មានគោលបំណងមួយទៀត ទៅលើប្រទេសកម្ពុជា រួចស្រេចទៅហើយ គឺ ដាក់ទំនាក់ទំនងជិតស្និទ្ធ បំផុតជាមួយទីក្រុងភ្នំពេញ។ នៅថ្ងៃ ១២ មករា ឆ្នាំ ១៩៩៤ លោកនាយករដ្ឋមន្ត្រីថៃ ជាន់ឡីកប៉ៃ បានមកធ្វើទស្សនកិច្ច នៅរាជធានីខ្មែរ ដើម្បីសុំដែង ការគាំទ្រដល់រដ្ឋាភិបាលខ្មែរ។ នៅឱកាសនោះ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និង ព្រះអង្គម្ចាស់ នរោត្តម សេរីវុឌ្ឍ [៥០] ដែលជារដ្ឋមន្ត្រីការបរទេស ទូលថ្លែងថា : «បើលោកនាយករដ្ឋមន្ត្រីថៃ អញ្ជើញមកប្រទេសកម្ពុជា ក្នុងគោលដៅគាំទ្ររដ្ឋាភិបាលខ្មែរ គឺមិន គាំទ្រ ពួកខ្មែរក្រហមនោះ យើងមានសេចក្តី ត្រេកអរណាស់» ។ ព្រះអង្គម្ចាស់ នរោត្តម

---

[៥០] ព្រះអង្គម្ចាស់ នរោត្តម សេរីវុឌ្ឍជាបុត្រ របស់ព្រះបាទ នរោត្តម សុរាម្រិត ជាមួយឃុន ទេពកញ្ញា សុភាព (គឹមអានយៀប) ហើយជាប្អូន របស់ សម្តេច នរោត្តម សីហនុ ។ ជាមួយ ឃុន គឹម អានយៀប ព្រះបាទនរោត្តម សុរាម្រិត មានកូនពីរទៀត គឺព្រះអង្គម្ចាស់ក្សត្រី នរោត្តម វិច្ឆារា និង ព្រះអង្គម្ចាស់នរោត្តម ប្រែយាសុភ័ណ ។

សេរីវុឌ្ឍ បាននិយាយចោទប្រកាន់ ប្រទេសថៃ ជាច្រើនប្រការទៀត ។ ខ្ញុំនឹងលើកឡើង អំពី បញ្ហានេះជាបន្តបន្ទាប់ ។

## ទស្សនកិច្ច របស់ លោក នាយករដ្ឋមន្ត្រីថៃ ជាន់ឡីកប៉ៃ នៅប្រទេសកម្ពុជា នៅ ខែ មករា ឆ្នាំ ១៩៩៤

## La visite du Premier ministre thai Chuan Leekpaï au Cambodge en janvier 1994

នៅឱកាសទស្សនកិច្ច របស់លោកនៅកម្ពុជា ឆ្លើយតប នឹងការនិយាយដាក់ផ្ទៃក្ដា របស់ រដ្ឋមន្ត្រីការបរទេសខ្មែរ ព្រះអង្គម្ចាស់នរោត្តមសេរីវុឌ្ឍ លោក រដ្ឋមន្ត្រីការបរទេសថៃ ជាន់ឡីកប៉ៃ ថ្លែងថា: លោក មកប្រទេសកម្ពុជានៅពេលនេះ គឺដើម្បីសន្យាចំពោះរដ្ឋាភិបាលខ្មែរថា ប្រទេសថៃ មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង របស់ ខ្មែរទេ ហើយ វិនិយោគ ទាំងឡាយ របស់ ថៃ នៅក្នុងប្រទេសកម្ពុជា ត្រូវឈរនៅលើ ប្រយោជន៍ទាំងសងខាង។ សូមកត់សំគាល់ថា ជាច្រើនលើក ច្រើនដងរួចមកហើយ ប្រទេសថៃ តែងតែបានបញ្ជាក់ថា គេក៏ជា ប្រទេសហត្ថលេខី នៃ កិច្ចព្រមព្រៀងទីក្រុងប៉ារីសដែរ ហើយនៅក្នុងន័យនេះ ត្រូវអនុវត្ត សេចក្ដីសម្រេចចិត្តរបស់ អង្គការ សហប្រជាជាតិ ពោលគឺត្រូវទទួលស្គាល់ របប ដែលមានរដ្ឋធម្មនុញ្ញគ្រប់គ្រង ត្រឹមត្រូវ ហើយដែលចេញមក ពី ការបោះឆ្នោត ។ តាមការពិត រដ្ឋមន្ត្រី ការបរទេសខ្មែរ ចង់ទាញអារម្មណ៍ លោក ជាន់ ឡីក ប៉ៃ ទៅលើការដែលពួកខ្មែរក្រហមរកស៊ីលក់ត្បូងជាមួយ ថៃនៅក្នុងតំបន់ ប៉ៃលិន ។ សូមបញ្ជាក់ថា នៅថ្ងៃ ១០ ឧសភា គឺ ២ខែ ថ្ងៃមុនទស្សនកិច្ច របស់ លោក ជាន់ ឡីកប៉ៃ នៅកម្ពុជា លោក ប្រាសុង សុនស៊ីរី រដ្ឋមន្ត្រី ការបរ ទេសថៃ បានបញ្ចេញ នូវ ការគ្នាន់គ្នាញ់ របស់ លោក យ៉ាងខ្លាំង បន្ទាប់ពី សារពត៌មាន បានសរសេរថា ឧត្តមសេនីយ៍ខ្មែរម្នាក់





បានចោទប្រកាន់ សាជា ថ្មីទៀតថា ប្រទេសថៃបានបណ្ដោយឲ្យពួកខ្មែរក្រហមប្រើ ទឹកដីថៃដើម្បីធ្វើការ វាយប្រហារទៅលើទឹកដីខ្មែរ ។ លោក ប្រាសុង សុនស៊ីរី បានថ្លែងជាអាទិ៍ថា: វាជាការស្រួលណាស់ ដែលគេយក ការសំអាងបែបនេះមកប្រើ។ ខ្មែរគួរតែរកពាក្យសំដី ដែលមានលក្ខណៈកសាង មកនិយាយវិញទើបត្រឹមត្រូវ គឺ គួរចៀសវាងធ្វើឲ្យប្រទេសថៃ អាក់អន់ស្រពន់ចិត្ត ។ សូមកត់សំគាល់ថា នៅពេលនោះ លោក សម រង្ស៊ី រដ្ឋមន្ត្រីសេដ្ឋកិច្ច និង ហិរញ្ញវត្ថុខ្មែរ មិនពេញចិត្តសោះ នឹង របៀបធ្វើពាណិជ្ជកម្ម របស់ថៃ នៅកម្ពុជា ។ នៅក្នុងកិច្ចសន្ទនាមួយ ជាមួយកាសែតថៃ មួយឈ្មោះ «ប្រជាជាតិ» (The Nation) នាថ្ងៃ ១០ មករា លោក សម រង្ស៊ី បាននិយាយទៅ សាធារណមតិថៃថា បើប្រទេសថៃ បញ្ជូនតែពួក «កូវបោយ» (cow boys) មកស្រុកខ្មែរដូច្នេះ ហើយ ចាត់ទុកស្រុកខ្មែរថាជា «ហ្វារវ៉េស»(Far West) ដូច្នេះនោះ ប្រទេសថៃពុំអាចរកសន្តិភាព និង មិត្តភាព ជាមួយខ្មែរបានទេ ។

នៅដើមឆ្នាំ ១៩៩៤ នោះ លោក សម រង្ស៊ី កំពុងចាប់ផ្ដើមរៀបចំ សេដ្ឋកិច្ចខ្មែរ ដែលនៅពេលនោះ មានលក្ខណៈអានាធិបតេយ្យ យ៉ាងសម្បើម អស្ចារ្យ។ លោក រដ្ឋមន្ត្រីសេដ្ឋកិច្ចខ្មែរ សម រង្ស៊ី បានលើកឡើងជាឧទាហរណ៍ នូវករណីមួយចំនួន ដូចជា «ផ្ទះទឹក» ទំនើបថៃមួយនៅមាត់ទន្លេ មុខព្រះរាជវាំង ជាដើម ដែលគ្មានកិច្ចសន្យា អ្វីទាំងអស់។ លោក សម រង្ស៊ីក៏បានលើកឡើងផងដែរ អំពីបណ្ដាញទូរទស្សន៍ថៃមួយ ដែលបានទទួលការយល់ព្រម ពីរដ្ឋាភិបាលមុន ឲ្យធ្វើសកម្មភាពរបស់គេ នៅក្នុងរយៈពេល ៩៩ ឆ្នាំ។ ក្រោយពេល ដែលលោក សម រង្ស៊ី បានលើកឡើងអំពី សំណុំរឿង ទាំងនេះ «ផ្ទះទឹក» ថៃ នៅមុខព្រះរាជវាំង ក៏ចេញបាត់ទៅវិញទៅ រីឯកិច្ចសន្យាបណ្ដាញទូរទស្សន៍ថៃ ក៏បានសុខចិត្តបន្ថយមកត្រឹម ៣០ ឆ្នាំវិញ។ ប៉ុន្តែ នៅពេលក្រោយនោះបន្តិច បន្ទាប់ពីមានទំនាស់មួយ រវាង លោក សម រង្ស៊ី នឹង ពាណិជ្ជករថៃ ដ៏គ្រាក់ ម្នាក់ដែលមានការគាំទ្រយ៉ាងមាំ ពីព្រះអង្គម្ចាស់រណប្ញទ្ធិ នាយករដ្ឋមន្ត្រីទី ១ និស្សិត និង ពាណិជ្ជករខ្មែរ បានសំដែងការគាំទ្ររបស់គេ ចំពោះលោក សម រង្ស៊ី។ នៅថ្ងៃ ២០ មករា ឆ្នាំ ១៩៩៤ ដដែលនោះ និស្សិត និង ពាណិជ្ជករខ្មែរ រាប់ពាន់នាក់ បាននាំគ្នាធ្វើបាតុកម្ម

មួយដ៏ធំ ដើម្បីគាំទ្រ លោក សម រង្ស៊ី ។ ក្បួនបាតុករបាននាំគ្នា មកសំដែងការគាំទ្រនោះ នៅពីមុខអាគាររដ្ឋសភា។ ព្រះ អង្គម្ចាស់រណប្ញទ្ធិ បានកត់សំគាល់នៅពេលនោះដូច្នេះ ថា លោក សម រង្ស៊ី កំពុងតែធ្វើអ្វីដែលព្រះអង្គហៅថាប្រជាភិថុត។ នៅខែមិនាឆ្នាំ ១៩៩៤ នោះ ព្រះអង្គម្ចាស់ នរោត្តម រណប្ញទ្ធិ ទ្រាំទ្រ នឹងលោក សម រង្ស៊ី ទៀតលែងកើត។ នៅថ្ងៃ ២៧ កញ្ញា វិទ្យុ របស់ រដ្ឋាភិបាលខ្មែរ បាននិយាយ ថា ពាណិជ្ជករថៃ ម្នាក់បានត្រូវព្រះអង្គមាស់ នរោត្តម រណប្ញទ្ធិ ប្រទាន មេដាយ ឥស្សរយយស ។ យោងទៅតាមឯកសារមួយ របស់ លោក រ៉ាអ៊ូល យ៉េណា [៥១] ពាណិជ្ជករ ថៃនោះ បានផ្តល់ យន្តហោះមួយគ្រឿង និង គ្រឿងឧបភោគបរិភោគមួយ ចំនួនទៅឲ្យកងទ័ពខ្មែរ។ ឯកសារដដែលបានបញ្ជាក់ថា គឺពាណិជ្ជករនោះហើយ ដែលមាន ទំនាស់ជាមួយ លោក សម រង្ស៊ី។ នៅទីបំផុត នៅថ្ងៃ ២០ តុលា ឆ្នាំ ១៩៩៤ ដដែលនោះ លោក សម រង្ស៊ី បានត្រូវ គេដកហូត ពីមុខតំណែង ហើយ បានត្រូវគេដាក់ លោក គាត ឈន់ ជំនួសវិញ ។

# ស្ថានភាព ប្រទេសកម្ពុជា មួយឆ្នាំ ក្រោយពេលបង្កើត រដ្ឋាភិបាលទី១ ចេញពី ការបោះឆ្នោតសេរី ដោយមានការឧបត្ថម្ភ ពី អ.ស.ប.

## La situation du Cambodge

[៥១] យោងទៅតាមឯកសារ របស់ លោក រ៉ាអ៊ូល យ៉េណា (Raoul Jennar) ។ In *Les clés du Cambodge* de Raoul Jennar, Maisonneuve & Larose, page 124. opc.





## un an après la mise en place du 1er gouvernement issu des Elections libres organisées par l'O.N.U.

ក្រោយការប្រកាសឲ្យប្រើ រដ្ឋធម្មនុញ្ញ នៅខែកញ្ញាឆ្នាំ ១៩៩៣ ហើយក្រោយពេលដែលព្រះអង្គម្ចាស់ នរោត្តម រណប្ញទ្ធិ និង លោក ហ៊ុន សែន បាន ត្រូវតែងតាំង សាជាថ្មីទៀត ជា សហនាយករដ្ឋមន្ត្រី រដ្ឋាភិបាលខ្មែរមិនត្រឹមតែ ត្រូវប្រឈមមុខ នឹង អសន្តិសុខ ដែលពួកខ្មែរក្រហមបង្កើតឡើងប៉ុណ្ណោះទេ តែក៏ត្រូវប្រឈមមុខនឹងការបុះស្រុត នៃសេដ្ឋកិច្ច ផងទៀត។ បញ្ហាចុងក្រោយនេះ ជាបញ្ហាដ៏សំខាន់ជាងគេ ព្រោះ ដោយខ្វះសព្វខ្វះគ្រប់ កងទ័ពរដ្ឋាភិបាល ក៏គ្មានសម្ភារនិងទឹកចិត្តគ្រប់គ្រាន់ដើម្បីប្រយុទ្ធនឹង សកម្មភាពរបស់ពួកខ្មែរក្រហមដែរ។ ទាហាន នៃ រាជរដ្ឋាភិបាល ក៏ ពុំបានទទួលប្រាក់ខែជា ទៀងទាត់។ ស្ថានភាពនេះ ពុំសម្រួលដល់ ការបោសសំអាតពួកខ្មែរក្រហមទេ ទោះបីខាងពួកខ្មែរក្រហម គេមាន បញ្ហានេះ ដូចតែគ្នាក្តី ។ ពួកខ្មែរក្រហម រាប់រយនាក់ បានសុំចុះចូលរាជរដ្ឋាភិបាល ។ គេអាចនិយាយបានថា គឺ ជា សង្គ្រាមផ្ទៃក្នុងមួយ បែបដែលអស់ទឹកចិត្ត ហើយទន់ដៃទាំងសងខាង ព្រោះតែគ្មានជំនួយ ពីបរទេស។ ពេលដែលប្រទេសធំៗគេបញ្ចប់សង្គ្រាមៗនៅក្នុងស្រុក ក៏ពុំអាច បន្តទៅទៀត យូរបានដែរ ។ បន្ទាប់ពីបង្កសង្គ្រាម ដ៏សាហាវមួយ នៅស្រុកខ្មែរ ប្រទេសធំៗជាបដិបក្ខ គេក៏នាំគ្នាបញ្ចប់សង្គ្រាម។ តាមរយៈសន្និសីទទីក្រុងប៉ារីស៍ ឆ្នាំ ១៩៨៩ និង តាមរយៈកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ រវាង គូបដិបក្ខខ្មែរ ប្រទេសដែលធ្វើសង្គ្រាម គេនាំគ្នាដោះដៃចេញអស់ ពី អធិករណ៍ខ្មែរ ដែលតាមការពិតជា អធិការណ៍ របស់ ពួកគេ តែប៉ុណ្ណោះ ។ នៅចំពោះមុខ ស្ថានភាពបែបនេះ ដែលបានត្រឹមតែធ្វើឲ្យប្រទេសទាំងមូលបុះដុនដាប ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ ទ្រង់ឈ្វេងយល់ថា គួរតែរកដំណោះស្រាយ ផ្លូវនយោបាយវិញ។ លោក ហ៊ុន សែន និងព្រះអង្គម្ចាស់ រណប្ញទ្ធិ ក៏ មានទស្សនៈ ដូចគ្នាអីចឹងដែរ ទោះបី គេពុំសូវមានជំនឿ ប៉ុន្មានថាជា ដំណោះស្រាយមួយ ដែលអាចធ្វើទៅកើតក្តី ។ ប៉ុន្តែ បើនឹងបន្ត

ការប្រយុទ្ធផ្នែកយោធា ក៏ឃើញថា មិនអាចបន្តទៅទៀតបានដូចតែគ្នា។ តាមការពិត ព្រះមហាក្សត្រខ្មែរដែលតាំងពីបានត្រូវតែងតាំង ជា «ព្រះមហាក្សត្រគ្មានអំណាច» មក ទ្រង់ចង់សាកល្បងហក់ចូល ក្នុងឆាកប្រយុទ្ធ នយោបាយ ម្តងទៀត ព្រោះថា នៅក្នុងករណីដែលព្រះអង្គ មានអំណាច ពួកខ្មែរក្រហម ក៏ អាចបន្ធូរបន្ថយឥរិយាបថ របស់ គេដែរ ។ ប៉ុន្តែ នេះ ជាការមួយដែលពុំអាចធ្វើទៅបានឡើយ ដោយហេតុថា បើខ្មែរក្រហម មាន វត្តមាន នៅក្នុងរដ្ឋាភិបាល អន្តរជាតិមុខជាផ្តាច់ជំនួយជាពុំខាន ។ ម៉្យាងទៀត រវាងព្រះមហាក្សត្រ នរោត្តម សីហនុ និង លោក ហ៊ុន សែន ដែលជា «មនុស្សខ្លាំង»នៅប្រទេសកម្ពុជា វាមាន ទំនាស់ ភូមិសាស្ត្រ- នយោ បាយមួយទៀត ដែលមិនអាច ដោះស្រាយបានទេ។ យ៉ាងណាមិញ ទីក្រុងហា ណូយ នឹង ពុំព្រមឲ្យអតីតសម្ព័ន្ធមិត្ត របស់ ចិន គ្រប់គ្រងប្រទេស កម្ពុជា ជាដាច់ខាត នៅក្នុងខណៈដែលចិនស្ថិតនៅជា ការគំរាមកំហែងមួយ ដ៏ធំចំពោះ ប្រទេសគេ ។ វៀតណាមខ្លាចប្រទេសចិន ពង្រីកឥទ្ធិពលរបស់ គេនៅស្រុក ខ្មែរ ដែលមានព្រំប្រទល់ ជាប់នឹង ស្រុកគេ។ គឺនៅក្នុងន័យនេះហើយ ដែលឥទ្ធិពល របស់ ព្រះមហាក្សត្រខ្មែរនៅក្នុងឆាកនយោបាយ ត្រូវទីក្រុងហាណូយធ្វើអ្វីគ្រប់បែបយ៉ាង ដើម្បីកាត់បន្ថយឲ្យបានច្រើនបំផុត។ នៅពេលដដែលនោះ ពួកខ្មែរក្រហម ដែលជាសម្ព័ន្ធមិត្ត របស់ ចិន និងជាមូលដ្ឋាន នៃកម្លាំងកងទ័ព របស់ សម្តេច នរោត្តម សីហនុ នៅតែខិតខំពង្រឹងកម្លាំង របស់គេ បន្តទៅ ទៀត ដែលជាហេតុ ធ្វើឲ្យអ្នកដែលមក ធ្វើវិនិយោគ នៅស្រុកខ្មែរ មានការស្ទាក់ស្ទើរ ។

នៅពាក់កណ្តាលឆ្នាំ ១៩៩៤ នោះ ក្រៅពីបញ្ហាសន្តិសុខ នៅក្នុងប្រទេស រដ្ឋាភិបាលខ្មែរ ត្រូវដោះស្រាយ បញ្ហាសេដ្ឋកិច្ច ជាបន្ទាន់ឱរ ។ នៅខែធ្នូ ឆ្នាំ ១៩៩៤ រដ្ឋសភាបានអនុម័ត ថវិការដ្ឋ ជាលើកដំបូងបង្អស់។ ចំណាយខាងផ្នែកយោធា មានទំហំធំក្រៃលែង។ នៅក្នុង ស្ថានភាពបែបនេះ ការកសាងប្រទេសឡើងវិញ ស៊ីងតែធ្វើទៅពុំកើត ។ ប្រាក់ចំនួន ១ ពាន់ លានដុល្លារ ដែលប្រទេសជប៉ុន និង បណ្តាប្រទេសផ្តល់ជំនួយ ព្រមទាំងអង្គការអន្តរជាតិផ្សេងៗទៀត បានសន្យាផ្តល់ឲ្យ ក៏ស៊ីងតែ អាក់ដំណើរ គឺ គេបន្តក់ឲ្យ តែបន្តិចៗ សិនប៉ុណ្ណោះ ។ បញ្ហាចំពោះមុខនៅពេលនោះ គឺ ការកសាង ហេដ្ឋារចនាសម្ព័ន្ធឡើងវិញ និងបញ្ហារៀបចំ ហិរញ្ញវត្ថុសាធារណៈឲ្យបានស្អាតស្អំ។ ទិសដៅ ចំពោះមុខ របស់ ពួកខ្មែរក្រហម គឺ កំទេច រចនាសម្ព័ន្ធ ទាំងនោះចោលតែម្តង។ នៅក្នុងស្ថានភាពបែបនេះ បើគ្មានជំនួយផ្នែកយោធាទេ គឺ កសាងប្រទេស ក៏ពុំកើតដែរ ។ ទន្ទឹមនឹងនោះដែរ អំពើចោរកម្មកើតឡើង ព្រោងព្រាតក្នុងទូទាំងប្រទេស។ ការបង្កបង្កើតផលប្រព្រឹត្តទៅដោយពិបាក។ នៅក្នុងវិស័យឧស្សាហកម្ម អគ្គីសនី ត្រូវកាត់ផ្តាច់ជារឿយៗ ។ សម្រេចសម្រួចទៅ គ្មានអ្នកណា ធ្វើអ្វីកើតទាំងអស់ ។ ដើម្បីជួយដោះស្រាយបញ្ហានេះ ក្រុមហ៊ុន ប្រេងសាំង អាមេរិក អ៊ីនទែរក័រ (Intercore) គិតមកធ្វើវិនិយោគនៅស្រុកខ្មែរ នៅក្នុងកម្រិត ១៥៦ លានដុល្លារ ។ ដោយស្ថានភាពសេដ្ឋកិច្ច មានលក្ខណៈ ធ្ងន់ធ្ងរ ទាហានរាជរដ្ឋាភិបាលក៏ចាប់ផ្តើមអស់សង្ឃឹម ហើយធ្វើសកម្មភាពមិនគួរគប្បី។ សារពត៌មាន ក៏រិះគន់រាជរដ្ឋាភិបាល ដោយឥតសំចៃ ជាហេតុបង្កើតឡើង នូវទំនាស់ រវាង អ្នកកាសែត នឹង អាជ្ញាធរ ។





## របប នយោបាយខ្មែរ ក្រោយការបោះឆ្នោត ឆ្នាំ ១៩៩៣ : តើជា របប ប្រជាធិបតេយ្យ ឬ ជា របប អប្បជនាធិបតេយ្យ ?

## Cambodge 1994 : démocratie ou oligarchie ?

នៅឆ្នាំ ១៩៩៤ ការកសាងប្រទេសឡើងវិញ បានជួបនឹងឧបសគ្គ ធំៗជាច្រើន ជាពិសេស បញ្ហាអសន្តិសុខ ដែលបណ្តាល មួយចំណែក មកពីខ្មែរ ក្រហម បញ្ហាដែលកើតឡើងព្រោះតែមានការប្រជែងកម្លាំងគ្នា រវាង គណបក្ស នយោបាយនានា

បញ្ហាសម្របទៅតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ ដោយ ពិបាក និងបញ្ហាទាក់ទងនឹងការអភិវឌ្ឍន៍។ ការបង្រួបបង្រួមជាតិឡើងវិញក្រោយពេលសង្គ្រាម ក៏ជួបនឹងឧបសគ្គដែរ ព្រោះនៅក្នុងបរិបទថ្មីនេះ សង្គ្រាមនៅតែមានបន្តទៀត ប៉ុន្តែ ក្រោមរូបភាពបិទមុខ ដែលជាហេតុ ធ្វើឲ្យអ្នកសង្កេតការណ៍ បកស្រាយ សភាពការណ៍ ផ្ទុយស្រឡះពីគ្នាទាំងស្រុង ។ តាមការពិត ហេតុការណ៍ទាំងឡាយនេះ បណ្ដាលមកពី កត្តាប្រវត្តិសាស្ត្រផង ហើយមកពីឥរិយាបថអន្តរជាតិផង ព្រោះថា អន្តរជាតិសុខចិត្តទទួលយកដំណោះស្រាយមួយ ដែលមានលក្ខណៈ ផ្ទុយទាំងស្រុងពី កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ។ សម្រេចសម្រួចទៅ ព្រោះតែ មើលស្រាលពេក ទៅលើ គោលការណ៍ លទ្ធិប្រជាធិបតេយ្យ ប្រទេសកម្ពុជា ក៏ ធ្លាក់សាជាថ្មីម្ដងទៀត ទៅក្នុងសង្គ្រាមក្នុងស្រុក ។ ក្រុមនយោបាយនីមួយៗ មិនព្រមយល់ទាល់តែសោះថា ការសម្របខ្លួន ទៅតាមគោលការណ៍ នៃ លទ្ធិប្រជាធិបតេយ្យ ទៅតាមរដ្ឋធម្មនុញ្ញ ជាកត្តាតែមួយគត់ដែលអាចបញ្ចប់ការវិវាទ។ គេបែរជានាំគ្នា យកព្រះមហាក្សត្រ ដែលគ្មានអំណាចសោះនោះ មកធ្វើជាឡប់ឡែសម្រាប់ទាក់ទាញការទុកចិត្ត ពីប្រជាជនទៅវិញ។ ក្រោយការបោះឆ្នោតឆ្នាំ ១៩៩៣ អ្នកណា ក៏សង្ឃឹមដែរថា ប្រទេសកម្ពុជា មុខជា លែងត្រូវការ អ្នកនយោបាយមុនៗ ដែលមានឥទ្ធិពល ហើយដែលបាន ធ្វើឲ្យប្រទេសជាតិលិចលង់ ទៀតហើយ គឺអំណឺះតទៅមានតែរដ្ឋធម្មនុញ្ញមួយប៉ុណ្ណោះ ដែលជាស្មារតី របស់ ប្រទេសជាតិ។ ប៉ុន្តែផ្ទុយពី ការប៉ាន់ស្មានដ៏ឆោតនេះ គេសង្កេតឃើញថា ការបង្កើត នីតិរដ្ឋមួយ ឲ្យបានត្រឹមត្រូវ ជាការមួយដ៏ពិបាកក្រៃលែង ។ គេបែរជានាំគ្នាវិលទៅរក របនាសម្ព័ន្ធចាស់ទៅវិញ ដោយលេងល្បែងថ្លឹនថ្នែក ជាមួយគោលការណ៍ នៃ លទ្ធិប្រជាធិបតេយ្យ សេរីនិយម ពហុបក្ស ។ មួយវិញទៀត អ្នកនយោបាយធំៗ ដែលដឹកនាំប្រទេស គិតតែពីការពារផលប្រយោជន៍ របស់ក្រុមបក្សពួកខ្លួន ទោះជាត្រូវប្រមាថដល់ប្រជាជន និង អ្នកដែលមានគំនិតទៀងត្រង់ ហើយ ស្មោះត្រង់ នឹង គោលការណ៍ ច្បាប់ក៏ដោយ ។ អ្នកដឹកនាំទាំងនោះ ភ្លេចគិតទាំងស្រុងថា គេជាអ្នកដឹកនាំរបបមួយ ដែលគេត្រូវប្រគល់សិទ្ធិ សេរីភាព ទៅឲ្យប្រជាជនវិញ បន្ទាប់ពីបានយក សិទ្ធិនេះទៅជាន់ឈ្លីនឹងជើង ។ ការពិត អ្នកទាំងនេះ ដែលសុទ្ធ



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

តែជាអ្នកដែលគ្មានវប្បធម៌ ប្រជាធិបតេយ្យ នៅក្នុងការអប់រំរបស់គេ នៅតែពុំទាន់យល់អំពី តួនាទី ជាប្រវត្តិសាស្ត្រ របស់ គេ ដដែល។ គេនៅពុំទាន់យល់ថា គេជាអ្នកដឹកនាំពលរដ្ឋពេញលក្ខណៈ មានសិទ្ធិ សេរីភាព ត្រឹមត្រូវ គឺ មិនមែនដឹកនាំ ទាសករឯណា? ពួកគេនាំគ្នា យកអំណាច និងឥទ្ធិពលផ្សេៗ ទៅប្រើ ដើម្បីប្រមូលការគាំទ្រ បុគ្គលខ្លួនគេម្នាក់ៗ ហើយមិនព្រម ប្រគល់សិទ្ធិសំខាន់ៗ ដែលជាកត្តារីកចម្រើន ទៅឲ្យពលរដ្ឋឡើយ ទោះបី គេដឹងថា អ្វីដែលប្រជាជនភាគច្រើនចង់បាន គឺសិទ្ធិជាពលរដ្ឋ ថ្លៃថ្នូរ គឺមិនមែនជាការសុំជ្រកកោន ក្រោមអំណាចបារមី របស់អ្នកដឹកនាំបក្សនេះ ឬ បក្សនោះឯណា ?

ការវិលសាជាថ្មីទៀត តាំងពីឆ្នាំ ១៩៩៤ មក ទៅររករបនាសម្ព័ន្ធ អំណាច ដូចកាលពីមុន បាននាំមក នូវ អយុត្តិធម៌ក្នុងសង្គម ដូចពីពេលមុន អ៊ីចឹងដែរ គឺ និន្នារមួយ ដែលនាំទៅរកតែ របបអប្បជនាធិបតេយ្យ (oligarchie) ពោលគឺ អំណាចស្ថិតនៅក្នុងកណ្ដាប់ដៃ នៃ ក្រុមបក្សពួក គ្រួសារ របស់ ជនមួយក្ដាប់ ។ នៅក្នុង របបបែបនេះ សមត្ថកិច្ចធំៗ ត្រូវប្រគល់ទៅ ឲ្យក្រុមគ្រួសារ នៃ ពួកអ្នកដែលមាន អំណាចឥទ្ធិពល។ អ្នកណាដែលទាមទារយក សិទ្ធិ របស់ ពួកគេ តាមគោលការណ៍ ប្រជាធិបតេយ្យ ឬ ទាមទារឲ្យអ្នកដឹកនាំ គោរព គោលការណ៍ច្បាប់ ជាធរមាន មិនងាយ នឹង បានសម្រេចទេ ។ អ្នកដែលចង់រស់នៅ ដោយឯករាជ្យ ដោយ សមត្ថភាពខ្លួនឯង ក៏ មិនងាយ នឹងធ្វើទៅកើតដែរ គឺ ត្រូវរណបទៅ នឹង បក្សណាមួយ ឬ ឥស្សរជន ដ៏ខ្លាំងក្លា ណាម្នាក់ ទើបគ្មានអ្នកណាហ៊ានធ្វើបាប ប្រមាថសិទ្ធិ សេរីភាព។ ប្រទេសកម្ពុជា បានឆ្លងកាត់ របបនយោបាយជាច្រើន ព្រោះតែគេចង់បានភាពថ្លៃថ្នូរ មិនធ្វើខ្ញុំកញ្ជះអ្នកណា ។ អ្នកតស៊ូជាច្រើនបានពលីជីវិត របស់គេ ដើម្បីមូលហេតុនេះ ប៉ុន្តែ សម្រេចសម្រួចទៅ ក្រោយអន្តរាគមន៍ របស់ អង្គការ សហប្រជាជាតិ ប្រទេស បានធ្លាក់មកចំណុចដើមដដែល ។ អ្នកមានឧត្តមគតិ កប់បាត់ទៅក្នុងភក់ជ្រាំ ដូចពាក្យគេថា «ឃ្លោកលិចអំបែងអណ្ដែត» ដូច្នេះដែរ ហើយនេះ ព្រោះតែគេទទូចទាមទារ ឲ្យអនុវត្តច្បាប់ ជាធរមាន ឬ ក៏ ទាមទាររបបមួយ ដែលគេរស់នៅ ដោយរក្សាបាន ជានិច្ច នូវឧត្តមគតិ របស់គេ ។ នៅពេល ជាមួយគ្នានោះ អ្នកដែលយល់ថាគេត្រូវសម្របខ្លួន ទៅតាមកាលៈទេសៈ ក៏ បោះបង់ចោល

នូវ គំនិតតស៊ូ របស់គេ ទៅទៀត ហើយ បណ្ដាយខ្លួន ទៅតាមសភាពការណ៍ តែម្ដង គឺ ឥតហ៊ានក្អកទេ ព្រោះខ្លាចបាត់បុណ្យសក្តិ លាភសក្ការៈរបស់គេ។ អ្នកទាំងនោះ ទោះត្រូវអ្នកកាន់អំណាច ប្រមាថ យ៉ាងណាក្តី ក៏ នៅតែឱនក្បាល ឲ្យគេខាកព្រឹកល្ងាចដែរ ហើយ បញ្ចេញឫក ហ៊ឺហា ក្រអឺតក្រទម ដាក់អ្នកដែលមាន ឥស្សរភាពពិតប្រាកដ ថែមទៀត។ នៅឆ្នាំ ១៩៩៤ នោះ ហើយ និង នៅពេលក្រោយៗ មកទៀតដែរ ប្រទេសកម្ពុជា ពុំបានឈានទៅរក របបប្រជាធិបតេយ្យ ពិតប្រាកដឡើយ គឺ បានធ្លាក់ទៅក្នុង របប អប្បជនាធិបតេយ្យទៅវិញ ។

# វិបត្តិ នយោបាយ
# នៅឆ្នាំ ១៩៩៤

## La crise politique de 1994

ដូចយើងបានដឹង រួចមកហើយ ក្រោយការបោះឆ្នោត ឆ្នាំ១៩៩៣ ព្រះមហាក្សត្រខ្មែរ ព្រះបាទនរោត្តម សីហនុដែលបានត្រូវ រដ្ឋធម្មនុញ្ញតែងតាំង ជាព្រះមហាក្សត្រ និង ជាប្រមុខរដ្ឋ បានទទួលភារកិច្ចមួយ ជាប្រវត្តិសាស្ត្រ គឺ ការបង្រួបបង្រួមជាតិឡើងវិញ។ នៅក្នុងន័យនេះ ព្រះអង្គបានខិតខំផ្សំផ្គុំ គណបក្សរាជានិយម «ហ្វុនស៊ីនប៉ិច» នឹងគណបក្សកុម្មុយនិស្ត «ប្រជាជន» ពោល គឺ ព្រះអង្គម្ចាស់ រណឫទ្ធិ និង លោក ហ៊ុន សែន ទោះបីអ្នកទាំងពីរនេះ មាន និន្នាការ នយោបាយខុសគ្នាក្តី។ គោលដៅនេះពុំស្របទៅ នឹង កិច្ចព្រមព្រៀង ទីក្រុងប៉ារីស៍ឡើយ ព្រោះកិច្ចព្រមព្រៀងនេះ កំណត់ឲ្យយកការបោះឆ្នោតជាធំ។ ប៉ុន្តែ ដូចការបារម្ភ របស់ ក្រសួងការបរទេស សហរដ្ឋ អាមេរិកដូច្នេះដែរ ការផ្សំផ្គុំនេះ ជារូបភាពមួយយ៉ាងជាក់ស្តែង នៃអ្វីដែលទីក្រុងវ៉ាស៊ីងតោន ហៅថា «ដំណោះស្រាយក្រហម» ( «solution rouge») នោះ ។ គណបក្ស «ហ្វុនស៊ីនប៉ិច») បានទទួលជ័យជំនះនៅក្នុងការបោះឆ្នោត ក៏ពិតមែន ប៉ុន្តែក្រោមផ្លាក នៃការបង្រួបបង្រួមជាតិ អ្នកឈ្នះ ក៏មិនព្រមឈ្នះ រីឯអ្នកចាញ់ ក៏ពុំព្រមចាញ់ ព្រោះរឿងសំខាន់ គឺ រារាំង មិនឲ្យក្រុមអ្នកប្រជាធិបតេយ្យ វិល មកកាន់ អំណាចវិញតែប៉ុណ្ណោះ។ ព្រឹត្តិការណ៍ដែលកើតមានឡើងជាបន្តបន្ទាប់ បញ្ជាក់យ៉ាងច្បាស់ នូវ ការដណ្តើម យកអំណាច ទាំងកម្រោលនៃ ក្រុមអ្នកអតីត កុម្មុយនិស្ត ។ សម្តេច នរោត្តម សីហនុដែលស្អប់ខ្ពើមបស្ចិមប្រទេស ហើយ ដែលបានជ្រើសរើសយកចិន ជាបង្អែក ជាអ្នកជួយរុញច្រាន ឲ្យមានសាមគ្គីភាព រវាង ខ្មែរកុម្មុយនិស្ត និយមទីក្រុងប៉េកាំង នឹង ខ្មែរកុម្មុយនិស និយមទីក្រុងហាណូយ ដោយយកគំនិតបង្រួបបង្រួមជាតិ របស់ព្រះអង្គធ្វើជាលេស។ នៅទីបំផុត មេគណបក្សបដិបក្ខទាំងពីរនេះ បានត្រូវតែងតាំងជានាយករដ្ឋមន្ត្រី ទី ១ ទាំងអស់គ្នា នៅក្នុងពេលតែមួយ ព្រោះទោះបីជា បានទទួលបរាជ័យ នៅក្នុងការបោះឆ្នោត ក៏ដោយ ក៏លោកហ៊ុន សែន មិនសុខចិត្តចាញ់ជាដាច់ខាត។ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ប្រធានគណបក្សឈ្នះឆ្នោត បានត្រូវតែងតាំង ជានាយករដ្ឋមន្ត្រី ទី១ ហើយលោក ហ៊ុន សែន បេក្ខជននៃគណបក្ស «ប្រជាជន» ដែលចាញ់ឆ្នោត បានត្រូវតែងតាំងជា នាយករដ្ឋមន្ត្រី ទី ២ ។ បន្ទាប់ពីបានសម្រេចក្នុងការចងសម្ព័ន្ធភាព រវាង គណបក្សទាំងពីរនេះរួចហើយ ព្រះមហាក្សត្រខ្មែរ ត្រូវប្រឈមមុខ នឹង សង្គ្រាមផ្ទៃក្នុង គឺការប្រយុទ្ធ នឹងកងទ័ពព្រៃ របស់ពួកខ្មែរក្រហម។ នៅថ្ងៃ ៦ កក្កដាឆ្នាំ ១៩៩៤ រដ្ឋសភា ប្រទេសកម្ពុជា បានអនុម័តច្បាប់មួយ ដាក់ពួកខ្មែរក្រហម ឲ្យនៅក្រៅច្បាប់ ។ ព្រះមហាក្សត្រខ្មែរ ដែលត្រូវបង្រួបបង្រួមជាតិឲ្យបាន ទ្រង់មិនយល់ស្រប នឹងច្បាប់នេះទេ។ ពួកខ្មែរក្រហម ដែលត្រូវពិកពលោកទាំងមូល និង ប្រជាជនខ្មែរ ចោទ ទោស ពីបទ សម្លាប់ប្រជាជនខ្មែរ អស់ជិត ២ លាននាក់ ក៏បន្តសកម្មភាព សង្គ្រាមផ្ទៃក្នុង របស់គេ ជាហូរហែមកទៀត។ នៅថ្ងៃ ២៦ កក្កដាឆ្នាំដដែលនោះ ពួកខ្មែរក្រហម បានចាប់អ្នកទេសចរ បរទេស ៣ នាក់ នៅក្នុងនោះ មានយុវជនបារាំងម្នាក់ឈ្មោះ ហ្សង់ មីសែល ប្រាកកេ។ រដ្ឋាភិបាល ធ្វើការចរចាជាមួយ ខ្មែរក្រហមហើយសុខចិត្តយកប្រាក់ជំរឹត ដែលពួកនេះទាមទារទៅលោះជនរងគ្រោះ។ កិច្ចការនេះបានប្រព្រឹត្តទៅនៅក្នុងភាពស្មុគស្មាញ និងពោរពេញ ទៅដោយ អាថ៌កំបាំង ។ នៅទីបំផុត គឺនៅថ្ងៃ ២៩ តុលា គេបានដឹងថា ចំណាប់ ខ្មាំងទាំង ៣ នាក់ បានត្រូវខ្មែរក្រហម



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ប្រហារជីវិតចោល។ នៅថ្ងៃ ២៩ តុលា នោះ វិទ្យុខ្មែរក្រហម បានបញ្ជាក់ អំពី ឧក្រិដ្ឋកម្ម ដ៏ សាហាវព្រៃផ្សៃនេះ ដោយថែមទាំង ធ្វើអត្ថាធិប្បាយថា «គឺជាបំណុលឈាម ដែល ពួកបស្ចិមប្រទេស ត្រូវចេញថ្លៃទៀតផង» ។ នៅឆ្នាំ ១៩៩៤នោះ មិនមែនត្រឹមតែពួកខ្មែរ ក្រហមប៉ុណ្ណោះទេ ដែលធ្វើឲ្យរាជរដ្ឋាភិបាលក្រពុលមុខ ហើយធ្វើឲ្យការស្វែងរកសន្តិ ភាព ជួបនឹងឧបសគ្គ។ នៅក្នុងជួររដ្ឋាភិបាល ក្រៅពីការក្រួតប្រជែង រវាង គណបក្ស សម្ព័ន្ធភាពទាំងពីរ មានបញ្ហាមួយទៀតបានកើតឡើង គឺ ទំនាស់រវាង ព្រះអង្គម្ចាស់ រណឫទ្ធិ នឹង លោក សម រង្ស៊ី រដ្ឋមន្ត្រីហិរញ្ញវត្ថុ និង ជាសមាជិក គណបក្សរាជានិយម «ហ្វុនស៊ិនប៉ិច»។ លោក សម រង្ស៊ី ដែលចង់ រៀបចំឲ្យការធ្វើវិនិយោគបរទេស នៅ ស្រុកខ្មែរ មានសណ្តាប់ធ្នាប់ល្អ ពុំបានធ្វើ ឲ្យព្រះអង្គម្ចាស់ រណឫទ្ធិ សព្វព្រះទ័យទេ ។

លោក សម រង្ស៊ី ដែលបានខិតខំធ្វើផែនការសម្រាប់ កាត់បន្ថយអតិផរណា ពី ១៧៧ % មក ១៧ %ជាមួយ លោក គាត ឈន់ បានត្រូវ គេដកហូតចេញពី រដ្ឋាភិ បាល នៅថ្ងៃ ២០ តុលា ឆ្នាំ១៩៩៤ ហើយនៅ ខែឧសភា ឆ្នាំ ១៩៩៥ បានត្រូវបណ្តេញ ចេញ ពីគណបក្ស «ហ្វុនស៊ិនប៉ិច» ទៀត។ លោក សម រង្ស៊ី បានត្រូវគេចោទប្រកាន់ថា ជាអ្នកដែលនាំ លទ្ធិសេរីនិយម សេដ្ឋកិច្ច មកក្នុងប្រទេសកម្ពុជា។ នៅថ្ងៃ ៣ វិច្ឆិកា ឆ្នាំ ១៩៩៤ ទីក្រុងភ្នំពេញ ទាមទារឲ្យទីក្រុងបាងកក បញ្ជូនឧត្តមសេនីយ៍ ស៊ិន សុង មក ស្រុកខ្មែរវិញ ។ លោក ស៊ិន សុង បានត្រូវតុលាការយោធា ទីក្រុងភ្នំពេញកាត់ទោស ពីបទ ប៉ុនប៉ងធ្វើ អបគមន៍ ឲ្យជាប់គុក ១៨ ឆ្នាំ នៅថ្ងៃ ២៨ តុលា ។ រីឯព្រះអង្គម្ចាស់ ចក្រពង្ស ដែលជាមេដឹកនាំ ការធ្វើអបគមន៍នេះ បានត្រូវនិរទេសទៅប្រទេស ម៉ាឡេស៊ី។ នៅដើមឆ្នាំ ១៩៩៥ គឺនៅថ្ងៃ ៤ មករា រដ្ឋសភា បានអនុម័ត គម្រោងថវិកាលើក ដំបូងបង្អស់ ។ នៅក្នុងមុខចំណាយទាំងអស់ ៤ រយ ៦ លាន ដុល្លារ ១ ភាគ ៣ ត្រូវ ផ្តល់ ទៅឲ្យវិស័យការពារប្រទេស ។ បើគិត ជាទឹកប្រាក់ គឺ ប្រមាណ ៨៥ លាន ៤ សែន ដុល្លារ ។ រីឯខាងក្រសួងមហាផ្ទៃ គឺ ៤៨ លាន ៤ សែនដុល្លារ។ ចំពោះ ការ ហាមឃាត់ មិនឲ្យកាប់ និង ធ្វើអាជីវកម្មព្រៃឈើ គឺត្រូវអនុវត្ត បន្តទៅទៀត។ សូមកត់ សំគាល់ថា ការកាប់ ព្រៃឈើខុសច្បាប់ មានទំហំធំក្រៃលែងនៅពេលនោះ។ ចំពោះ



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ប្រាក់ចំណូលរដ្ឋ ក្នុងការយកអាករ គឺបានត្រឹម ៦ លានដុល្លារ ប៉ុណ្ណោះ ។ ប៉ុន្តែបើតាម ទំហំអាជីវកម្ម នៅពេលនោះ គឺត្រូវបានដល់ទៅ ១០០ លានដុល្លារ ។ នេះបើ យោង ទៅតាមការអះអាង របស់ លោក សម រង្ស៊ី ។ បញ្ហាដែលធ្វើ ឲ្យគេបារម្ភជាងគេ នៅ ពេលនោះ គឺ ព្រៃឈើខ្មែរ បានត្រូវកាប់អស់ជិតពាក់កណ្តាល នៃ ព្រៃឈើទាំងអស់ នៅប្រទេសកម្ពុជា ហើយដែលជាហេតុនាំឲ្យមាន ការបាត់តុល្យភាព បរិស្ថាន ផងទៀត ពោល គឺទឹកជំនន់។ សូមកត់សំគាល់ថានៅឆ្នាំ ១៩៦៩ ព្រៃនៃប្រទេសកម្ពុជាមាន ៧៣ % នៃទឹកដីខ្មែរ ។ នៅឆ្នាំ ១៩៩៤នោះ គឺមាននៅ សល់តែ ៤៩ %ប៉ុណ្ណោះ។ នៅក្នុងវិស័យ សេដ្ឋកិច្ច អត្រាលូតលាស់ ពុំបានឈានដល់គោលដៅ ដូចការកំណត់ទេ គឺបានត្រឹម ៥, ៥ % ប៉ុណ្ណោះ ។ រីឯផែនការដែលត្រូវដើរឲ្យដល់ គឺ មានរហូតទៅដល់កម្រិត ៧,៥% សម្រាប់ ឆ្នាំ ១៩៩៥ ។

## បញ្ហាលើកលែងទោស មេខ្មែរក្រហម អៀង សារី

## L'amnistie du chef khmer rouge Ieang Sary

ព្រឹត្តិការណ៍ ដែលកើតមានឡើង នៅក្នុងឆ្នាំ ១៩៩៥ ច្រើនតែជា ព្រឹត្តិការណ៍ទាក់ ទង នឹងការកសាង សេដ្ឋកិច្ច។ រីឯ ការដកហូត លោក សម រង្ស៊ី ចេញពីមុខតំណែង រដ្ឋមន្ត្រី ហិរញ្ញវត្ថុ នៅខែតុលាឆ្នាំ ១៩៩៤ ក៏ទាក់ទងនឹងបញ្ហានេះដែរ។ ដំណើរការ សេដ្ឋកិច្ច នៅឆ្នាំ ១៩៩៥ មាន ការរអាក់រអួល យ៉ាងខ្លាំង ព្រោះណាមួយ ត្រូវកសាង ប្រទេសឡើងវិញ ណាមួយត្រូវពង្រឹងកងទ័ព ដើម្បីប្រយុទ្ធ នឹងខ្មែរក្រហម។ ដើម្បី ដឹក នាំកិច្ចការនេះ លោក ទៀ បាញ់ រដ្ឋមន្ត្រីការពារប្រទេស បានទាមទារ ឲ្យបង្កើន ថវិកា ក្នុងផ្នែកនេះ យ៉ាងសន្ធឹកសន្ធាប់ ថែមទៀត គឺ រហូតដល់ទៅ ៤ % ។ នៅឆ្នាំនោះឯង ពួកខ្មែរ ក្រហមបាន បង្កើនសកម្មភាព អុកឡុក កាន់តែខ្លាំងទៅៗ ។ ពីពេលមុន គេដុត

បំផ្លាញតែ លំនៅឋាន របស់ អ្នកមានទ្រព្យសម្បត្តិ ស្តុកស្តម្ភ ប៉ុណ្ណោះ ប៉ុន្តែ ចាប់ពីឆ្នាំ ១៩៨៥មក ពួកឧទ្ទាម ក៏ដុតបំផ្លាញផ្ទះសម្បែង របស់ប្រជាជនក្រីក្រតោកយ៉ាកដែរ។ នៅចំពោះមុខស្ថានភាពនេះ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ នាយករដ្ឋមន្ត្រីទី ១ បានកំណត់យកនយោបាយមួយ ដើម្បីធ្វើការទប់ទល់ គឺធ្វើការវាយ ប្រហារសម្រុកយ៉ាង ខ្លាំងទៅលើពួកខ្មែរក្រហមផង ហើយ បង្ខំឲ្យពួក ឧទ្ទាមចុះចូលផង។ រីឯលទ្ធផល ក៏បានខ្លះៗដែរ ព្រោះពួក ខ្មែរក្រហមមាន ការ នឿយណាយ យ៉ាងខ្លាំង ក្នុងការប្រយុទ្ធ។ នៅឆ្នាំ ១៩៩៤ -១៩៩៥ ពួកខ្មែរ ក្រហម ត្រូវប្រឈមមុខ នឹងការបែកបាក់ផ្ទៃក្នុង ហើយការប្រេះឆានេះបាន ស្តែងយ៉ាងច្បាស់ នៅពាក់កណ្តាលឆ្នាំ ១៩៩៦។ នៅថ្ងៃ ៨ សីហាឆ្នាំ ១៩៩៦ អៀង សារី អតីតរដ្ឋមន្ត្រី ការបរទេសខ្មែរក្រហម ហើយដែលជាមនុស្សខ្លាំងទី ២ នៅក្នុង របប ប៉ុល ពត បានផ្តាច់ខ្លួនចេញពី ប៉ុល ពត និង តាម៉ុក។ អៀង សារី បាននាំទ័ពខ្មែរក្រហម ប្រមាណបីពាន់នាក់ មកជាមួយផង។ ប៉ុន្តែនៅពេលនោះ ពួកខ្មែរក្រហម ដែលផ្តាច់ខ្លួនចេញពី ប៉ុល ពត ទាំងនោះបានបញ្ជាក់ប្រាប់ថា គឺមិនមែន ដើម្បីសុំចុះចូល រាជរដ្ឋាភិបាលនោះទេ ។ អៀង សារី មាន គោលបំណង បង្កើតចលនា នយោបាយមួយទៀត គឺចលនា ប្រជាធិបតេយ្យ រួបរួមជាតិ ដើម្បីធ្វើការចរចា ជាមួយភាគី ខ្មែរផ្សេងៗ ទៀត ។ អស់រយៈពេល ពីរខែ រដ្ឋាភិបាលទីក្រុងភ្នំពេញ បានសាកល្បងអូសទាញ អៀង សារី ឲ្យចូលមករួបរួមក្នុង សហគមន៍ជាតិវិញ ប៉ុន្តែ អាចធ្វើកិច្ចការនេះបាន គឺទាល់តែ លើកលែងទោសឲ្យ អៀង សារី ជាមុនសិនដែរ ។

ការលើកលែងទោសឲ្យ អៀង សារី បានចោទឡើង ជាបញ្ហាមួយ ដ៏ធំ ព្រោះ អៀងសារី បានត្រូវតុលាការនៃរបប ហេង សំរិន កាត់ទោសពីបទ ប្រល័យពូជ សាសន៍ កាលពីឆ្នាំ១៩៧៩។ ប៉ុន្តែ កាលនោះ ប្រទេសកម្ពុជា ស្ថិត នៅក្រោមការឈ្លានពាន របស់កងទ័ពវៀតណាម។ លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីទី ២ ដែលបានចូលមកក្នុងទំព័រប្រវត្តិសាស្ត្រខ្មែរ ដោយការទំប្រឹងប្រែង របស់ទីក្រុងហាណូយ និងអ្នកដែលគាំទ្រ ទីក្រុងហាណូយ មានការបារម្ភដែរ ប៉ុន្តែ លោក ក៏យល់ផងដែរថា បើមិនលើកទោសឲ្យ អៀង សារី ទេ ការកសាងប្រទេស ក៏ពិបាក ធ្វើទៅកើតដែរ ។ ម្យ៉ាងទៀត ព្រះមហាក្សត្រខ្មែរ





ព្រះបាទ នរោត្តម សីហនុ ទ្រង់បានបញ្ជាក់ នៅក្នុងលិខិតមួយ ឆ្លើយតបទៅ នឹង លិខិតសុំលើកលែងទោស របស់ អៀង សារី ថា ព្រះអង្គ នឹង យកសំណើនេះ ទៅពិនិត្យ បើនាយករដ្ឋមន្ត្រីខ្មែរ ទាំងពីររូប ស្នើបញ្ហានេះមកព្រះអង្គ គឺ នៅក្នុងករណីដែលអ្នកតំណាងរាស្ត្រ ២ ភាគ ៣ សុខចិត្តយល់ព្រមផងដែរ ។ នៅទីបំផុត សហនាយករដ្ឋមន្ត្រី ទាំង ពីរ ក៏សម្រេចធ្វើសេចក្តីស្នើនេះ ដល់ព្រះមហាក្សត្រ។ នៅថ្ងៃ ១៤ កញ្ញា ឆ្នាំ ១៩៩៦ គេបានដឹងថា ព្រះមហាក្សត្រខ្មែរ បានឡាយព្រះហស្តលេខា ទៅលើក្រឹត្យមួយលើកលែងទោសឲ្យ អៀង សារី ព្រោះ ក្រឹត្យនោះ បានត្រូវរាជរដ្ឋាភិបាល ផ្សព្វផ្សាយ ជាសាធារណៈតែម្តង គឺដោយមិនទាន់មាន ការយល់ព្រម ពីរដ្ឋសភាផង។ ព្រះមហាក្សត្រខ្មែរ ទ្រង់បានបញ្ចេញប្រតិកម្មយ៉ាងខ្លាំង ចំពោះ ការខុសច្បងនេះ។ ប៉ុន្តែ បើតាមពាក្យចចាមអារ៉ាម នៅពេលនោះ រដ្ឋសភាប្រហែលជាមិនជំទាស់ទេ ។ ទោះជាយ៉ាងនេះក្តី ការលើកលែងទោសឲ្យអៀង សារី ជារឿងមួយ ដ៏ ស្មុគស្មាញ ព្រោះ ជារឿងដែលទាក់ទង នឹង សហគមន៍អន្តរជាតិទាំងមូល។ នៅចំពោះមុខព្រឹត្តិការណ៍នេះ សហរដ្ឋ អាមេរិក មិនបញ្ចេញ ប្រតិកម្មអ្វីឡើយ ដោយគេចាត់ទុក ថាជាបញ្ហាផ្ទៃក្នុងរបស់ខ្មែរ។ ប៉ុន្តែ អង្គការ «លើកលែងទោសអន្តរជាតិ» (Amnesty International) បានបញ្ចេញប្រតិកម្មយ៉ាងខ្លាំង រីឯ សមាគម អាស៊ាន ក៏មាន ការបារម្ភយ៉ាងខ្លាំងដែរ ។

## ការបែកបាក់សាមគ្គី
## នៅក្នុងក្រុមខ្មែរក្រហម
## ខាង ប៉ុល ពតនៅឆ្នាំ ១៩៩៦

### 1996 : dislocation du mouvement khmer rouge de la faction polpotienne

ដូចយើងបានដឹងរួចមកហើយ ចលនា ខ្មែរកុម្មុយនិស្ត បានបែកខ្លួន ជា ២ ក្រុម នៅឆ្នាំ ១៩៦៦ បន្ទាប់ពី ប៉ុល ពត ត្រឡប់មកពីប៉េកាំង និង ហាណូយវិញ។ នៅខែ កញ្ញាឆ្នាំ ១៩៦៦ នោះ ប៉ុល ពត បានប្រែឈ្មោះ ពី «បក្សពលករកម្ពុជា» (P.T.K.) មកជា «បក្សកុម្មុយនិស្តកម្ពុជា» (P.C.K.) តែម្តង ។ គឺ នៅពេលនោះហើយ ដែលក្រុមកុម្មុយនិស្តខ្មែរ ដឹកនាំដោយ ប៉ុល ពត បែកខ្លួន ចេញពីវៀតណាម ហើយ ចងសម្ព័ន្ធភាពជាមួយ ម៉ៅ សេ ទុង វិញ។ ៣០ ឆ្នាំក្រោយមក គឺ នៅថ្ងៃ ៨ សីហា ឆ្នាំ ១៩៩៦ អៀង សារី មនុស្សខ្លាំងទី ២ នៃ ក្រុមខ្មែរក្រហម ដែលស្មោះត្រង់ នឹងចិន បានផ្តាច់ខ្លួនចេញពី ប៉ុល ពត ហៅ «បងទី ១» ដោយនាំកងទ័ពខ្មែរក្រហម ប្រមាណ ៣ ពាន់នាក់ មកជាមួយផង។ ប៉ុន្តែ នៅពេលនោះ អៀង សារី មិនចុះចូលរាជរដ្ឋាភិបាលតែម្តងទេ ព្រោះចង់បង្កើត ចលនាមួយ ទៀតដើម្បីធ្វើការចរចា ជាមួយភាគីខ្មែរផ្សេងៗទៀត ។ លោក សហនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលស្មោះត្រង់ នឹង ទីក្រុងហាណូយ បានគំរាមថា : បើមិនព្រមចុះចូលទេ លោក នឹង គាំទ្រ ការបង្កើតតុលាការកាត់ទោស អៀង សារី នៅក្នុងករណី ដែលមានភស្តុតាងគ្រប់គ្រាន់ ។ ការគំរាមកំហែងនេះ ពុំបានហុច នូវ លទ្ធផលវិជ្ជមានអ្វីទាំងអស់។ ដូចនេះ រាជរដ្ឋាភិបាលគ្មាន ជម្រើសអ្វីទៀតក្រៅពី បំផុសពួកខ្មែរក្រហមកុំឲ្យនាំគ្នាចុះចូលនឹង អៀង សារី ហើយថែមទាំងទាក់ទាញអ្នកទាំងនោះ ឲ្យចុះចូល នឹងរាជរដ្ឋាភិបាលវិញទៀតផង ។ នៅក្នុងខណៈដដែលនោះ អៀងសារី គិតតែពីធ្វើការវាយប្រហារទៅលើទីតាំងផ្សេងៗទៀត របស់ក្រុមដែលស្មោះត្រង់ នឹង ប៉ុល ពត។ នៅថ្ងៃ ១ តុលាឆ្នាំ ១៩៩៦ ដដែលនោះ កងទ័ព របស់ អ៊ី ឈៀង ដែលជា សម្ព័ន្ធមិត្តរបស់ អៀង សារី បានវាយយក មូលដ្ឋាន របស់ ប៉ុល ពត នៅ សម្លូត គឺ មូលដ្ឋានមួយដែលស្ថិតនៅជាង ២០ គ.ម. ពី ប៉ៃលិន ហើយ ដែលស្ថិតនៅក្រោមបញ្ជាការរបស់ នួន ជា និង សុន សេន។ ការវាយប្រហារនោះ បានបង្ខំឲ្យអ្នកទាំងពីរ រត់ទៅប្រទេសថៃបាត់ទៅ។ ប៉ុន្តែ ខ្មែរក្រហមខ្លះទៀត នាំគ្នាសុំចុះចូល នឹង អៀង សារី ហើយខ្លះទៀត សុំចុះចូល នឹង កងទ័ព នៃ បក្ស «ប្រជាជន» ដោយមានការបញ្ចុះបញ្ចូល ពី កែវ ប៊ុង អតីតមេបញ្ជាការខ្មែរក្រហមម្នាក់ ដែលបានចុះចូល នឹងកងទ័ព រាជរដ្ឋាភិបាល



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

នៅឆ្នាំ ១៩៩៥ ។ នៅក្នុងរយៈពេលតែ ជាងមួយសប្តាហ៍ ប៉ុណ្ណោះ កងទ័ពខ្មែរ ក្រហម ប្រមាណ ៨ កងពលតូច បានសុំចុះចូលរាជរដ្ឋាភិបាល បើគិតជាចំនួនទាំងអស់ គឺ ជាង ២ ពាន់ ៤ រយ នាក់។ នៅថ្ងៃ ១១ តុលា ឆ្នាំ ១៩៩៦ គឺ ឆ្នាំដដែលនោះ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ សហនាយករដ្ឋមន្ត្រី ទី ១ បានយាងទៅ ប៉ៃលិន ដោយគ្មានអ្នកណាដឹងជាមុន ទាល់តែសោះ។ បើតាមប្រភពមួយ នៃ គណបក្សរាជានិយម ហើយដែលមានឯកសារខ្លះបញ្ជាក់ផងដែរនោះ គឺ អៀង សារី តែម្តង ដែលបានយាង ព្រះអង្គទៅទីនោះ។ លោកសហនាយក រដ្ឋមន្ត្រីទី ២ ហ៊ុន សែន ដែលបានជួប អៀង សារី ម្តងរួចមកហើយនៅថ្ងៃ ២ សីហា នៅស៊ីសុផុន ពុំបានបញ្ចេញប្រតិកម្ម អ្វីឡើយ នៅពេលនោះ។ ប៉ុន្តែ ក្រោយនោះបន្តិច លោក បានប្រាប់ថា លោក ប្រហែលជា នឹង អញ្ជើញទៅប៉ៃលិន នៅថ្ងៃ ១៥ តុលា។ ការពិត ទាល់តែថ្ងៃ ២២ តុលា ទើបលោកអញ្ជើញ ទៅជួប អៀង សារី នៅទីនោះ ។

សូមកត់សំគាល់ថា ជិតមួយខែ ក្រោយពេលដែល អៀង សារី ផ្តាច់ខ្លួនចេញពីក្រុម ប៉ុល ពត កងទ័ពស្មោះត្រង់ នឹង ប៉ុល ពត គឺខ្មែរក្រហម ប្រមាណ ២០០ នាក់ នៃ កងពលតូច ៥១៩ បានធ្វើការវាយប្រហារ ទៅលើ ពួក អៀង សារី នៅជួប គគី ក្នុងខេត្តឧត្តរមានជ័យ ។ ប៉ុន្តែ ការវាយប្រហារ របស់ ក្រុម ប៉ុល ពត នេះ មិនបានសម្រេចទេ ព្រោះរាជរដ្ឋា ភិបាលបានបញ្ជូនគ្រឿងសញ្ញាវុធ និង កងទ័ពប្រមាណ ៤០០ នាក់ ឲ្យទៅ ជួយពួក អៀង សារី ។ នៅពេលនោះ ប្រជាជនប្រមាណ ២០០ នាក់ បាននាំ គ្នារត់ឆ្លងដែន ទៅប្រទេសថៃ ។ សូមបញ្ជាក់ថា ការវាយប្រហារនេះ បានកើតមានឡើងនៅថ្ងៃ ៣ សីហា គឺ ១ថ្ងៃ ក្រោយពេលដែល លោក នាយករដ្ឋមន្ត្រី ទី ២ ហ៊ុន សែន បានជួបអៀង សារី នៅស៊ីសុផុន ។ នៅ ពេលដែលលោក នាយករដ្ឋមន្ត្រី ហ៊ុន សែន ជួប អៀង សារី លើកទី ២ គឺ នៅថ្ងៃ ២២ តុលា៖ នាះ លោកបានប្រាប់ អៀង សារីថា លោកនឹង មិនដកហូតអាវុធ ពីកងទ័ពរបស់ អៀង សារី ទេ ហើយក៏មិនកែប្រែឋានន្តរសក្តិ នៃអ្នកទាំងនោះដែរ ។ នៅក្នុងឱកាសនោះ លោកបានប្រគល់ លិខិតឆ្លងដែនការទូតទៅឲ្យ អ៊ី ឈៀង និង សុក ភាព។ លោកបានថ្លែង ថា ប្រសិនណាជា អៀង

សារី ចង់បានដែរ លោក នឹង ប្រគល់លិខិតឆ្លងដែន ការទូតនេះ មួយទៀតទៅឲ្យ អៀង សារី ។

## គណបក្ស «ជាតិខ្មែរ» របស់ លោក សម រង្ស៊ី
## Le PNK de Sam Raingsy

នៅឆ្នាំ ១៩៩៦ នៅពេលដែល បញ្ហាលើកលែងទោស ឲ្យ អៀង សារី កំពុងចោទឡើង លោក សហនាយករដ្ឋមន្ត្រី ហ៊ុន សែន បានស្នើសុំឲ្យកាត់បន្ថយថវិកា សម្រាប់ធ្វើសង្គ្រាម ដើម្បីយកទៅបង្កើនមូលនិធិ រៀបចំការចុះចូល របស់ពួកខ្មែរក្រហម។ នៅពេលនោះ លោកសហនាយករដ្ឋមន្ត្រី ទី ២ ត្រៀមលក្ខណៈជាស្រេចដើម្បីទទួលស្គាល់ចលនា នយោបាយថ្មី របស់ អៀង សារី ដែលបង្កើន ការវាយប្រហារ ជាញឹកញាប់ទៅលើ ពួក ប៉ុល ពត ដោយមាន ជំនួយពីកងទ័ព របស់ រាជរដ្ឋាភិបាល។ ប៉ុន្តែពួក ប៉ុល ពត ក៏បានធ្វើការតបតវិញយ៉ាងខ្លាំងក្លាដែរ។ បន្ទាប់ពីការវាយប្រហារ របស់កងទ័ពខ្មែរក្រហម ដែលស្មោះនឹង ប៉ុល ពត ទៅលើកងទ័ព អៀង សារី នៅ ជួប គគី ក្នុងខែត្រឧត្តរមានជ័យ នៅថ្ងៃ ៣ កញ្ញា កងពលធំលេខ ៥១៩ របស់ ខ្មែរក្រហម បានត្រូវបែកចេញជា ២ ក្រុមដែលប្រយុទ្ធគ្នាយ៉ាងស្វិតស្វាញ។ នៅពេលនោះ ពួកខ្មែរក្រហមខាង ប៉ុល ពត បានខិតខំពង្រឹងទីបញ្ជាការ របស់គេ នៅ អន្លង់វែង ដើម្បីត្រៀមលក្ខណៈទប់ទល់ នឹង កងទ័ពរាជរដ្ឋាភិបាល ។ បើគិតជា ចំនួនកងទ័ព គឺ មានប្រមាណ ២៥០០នាក់ ប៉ុន្តែ សុទ្ធតែជា កងទ័ព ចំណានៗ បំផុត ដូចជា កងពល ៩២០ និង ៨០១ ជាដើម ។ ប៉ុន្តែ ការពង្រឹង កងទ័ពនៅ អន្លង់វែង បានធ្វើឲ្យទីតាំងផ្សេងៗទៀត របស់ ប៉ុល ពត នៅកំពង់ធំ កំពង់ចាម ស្ទឹងត្រែង និង រតនគីរី ចុះខ្សោយយ៉ាងខ្លាំង។ នៅពេលដែល កម្លាំងខ្មែរក្រហមទាំងមូល កំពុងបែកបាក់គ្នា ដំណើរការពាណិជ្ជកម្ម និង ការអភិវឌ្ឍន៍ នៅខាងផ្នែកពាយព្យ នៃប្រទេសកម្ពុជា បានរីកចម្រើនឡើងវិញជាលំដាប់។





ពាណិជ្ជករ ថៃ ប្រមាណរាប់ពាន់នាក់ បាននាំ គ្នាចូលមករកស៊ី នៅលើទឹកដីខ្មែរ ។ នៅឆ្នាំ ១៩៩៦ នោះដែរ គណបក្ស «ជាតិខ្មែរ» របស់លោក សម រង្ស៊ី ដែលបាន ត្រូវបង្កើតនៅឆ្នាំ ១៩៩៥ បានទាមទារ ឲ្យគេទទួលស្គាល់ខ្លួន ជាផ្លូវការ ព្រោះ លោក ហ៊ុន សែន ក៏ បម្រុង នឹងទទួលស្គាល់ បក្សថ្មី របស់ អៀង សារីដែរ ។ នៅពេលនោះ គេបានលើកឡើងនូវ ទឡ្ហីករណ៍មួយដែលថា បើយោងទៅ តាមរដ្ឋធម្មនុញ្ញ ពលរដ្ឋមានសិទ្ធិស្មើគ្នា នៅចំពោះមុខច្បាប់ ចុះហេតុដូចម្តេច បានជាខាងពួកកុម្មុយនិស្ត និង អតីតពួកកុម្មុយនិស្ត គេអាចទទួលសិទ្ធិ សមភាពនេះ ជាងពួកប្រកាន់និន្នាការ សេរីនិយម និង ពួកប្រជាធិបតេយ្យ នៅក្នុងរបបមួយ ដែលគេសន្មតថាជា របប ប្រជាធិបតេយ្យនោះ ។

ការចូលមកក្នុងឆាកនយោបាយ របស់ គណបក្ស «ជាតិខ្មែរ» របស់ លោក សម រង្ស៊ី ជាការមួយដ៏ពិបាកពន់ពេកក្រៃ ព្រោះនៅក្នុងបរិបទភូមិសាស្ត្រ-នយោបាយក្រោយឆ្នាំ ១៩៩៣ ពួកកុម្មុយនិស្តខ្មែរ គឺ ទាំងអ្នកនិយម ចិន ទាំងអ្នកនិយមវៀតណាម រួមបញ្ចូលទាំងឥស្សរជន ជាប្រវត្តិសាស្ត្រ មួយចំនួនផង នៅតែស្ថិតនៅជា អ្នកក្តោបក្តាប់ជោគ វាសនា របស់ ប្រទេសកម្ពុជា បន្តមកទៀត គឺ គេគ្រាន់តែឈប់ទាស់គ្នាផ្លូវអាវុធតែប៉ុណ្ណោះ ។ គោលដៅ របស់ អ្នកនយោបាយទាំងនោះ គឺ មិនឲ្យអ្នកប្រជាធិបតេយ្យដែលមាននិន្នាការបស្ចិមប្រទេស ដណ្តើមយកអំណាចបាន ជាដាច់ខាត ។ ដើម្បីសម្រេចកិច្ច ការ នេះ គេសុខចិត្តទទួលយក អ្នករាជានិយម នៃ គណបក្ស «ហ្វ៊ុនស៊ិនប៉ិច» មកធ្វើជាសម្ព័ន្ធមិត្ត ជាមូលដ្ឋាន នៅក្នុងករណី ដែលចលនា រាជានិយមនេះមាន កម្លាំងប្រជាប្រិយភាព ជាងពួកអតីតកុម្មុយនិស្ត ។ នៅក្នុងបរិបទនេះ លោក សម រង្ស៊ី ស៊ឹងតែគ្មានប្រកចេញ។ ក៏ប៉ុន្តែ នៅក្នុងរាត្រី ដ៏ យូរលង់នេះ លោក សម រង្ស៊ី សង្ឃឹមថា បើ បរិយាកាសប្រជាធិបតេយ្យអាច នឹងកើតមានឡើងកាលណា គេនឹងអាច យកឈ្នះបាន។ មួយវិញទៀត បើប្រជាជនខ្មែរចេញពី ភាពក្រីក្រមិនរួចទេ ហើយបើអំពើពុករលួយ នៅតែមានបន្តទៅទៀត នោះ អំពើអយុត្តិធម៌ ក៏ នឹងកើន ឡើងដែរ ។ គឺនៅក្នុងន័យនេះហើយដែល គណបក្ស លោក សម រង្ស៊ី ចេះតែមាន អត្ថិភាព បន្តមក ។ ប៉ុន្តែ បើគេគិតពីវេទនាសម្ព័ន្ធ ភូមិសាស្ត្រ-នយោបាយ និង ទេសៈកាលៈ បច្ចុប្បន្ននេះ គឺគេនៅតែ ពិបាក

ដដែល ហើយដរាបណា ការគំរាមកំហែងគ្នាទៅវិញទៅមក តាមគ្រប់រូបភាព នៅតែមានជាហូរហែ បរិយាកាស ប្រជាធិបតេយ្យ ក៏ ពិបាក នឹង កើតមានឡើងដែរ។ កំណត់សំគាល់មួយ ទៀត គឺ របនាសម្ព័ន្ធ នៃ អំពើពុករលួយ ដែលមានលក្ខណៈស្មុគស្មាញជាទីបំផុត ហើយ ដែលគេពិបាក នឹង ព្យាបាល ឲ្យបានឆាប់រហ័ស ។

## ទិដ្ឋភាពខ្លះៗ នៃ សង្គមខ្មែរ នៅឆ្នាំ ១៩៩៦

### Quelques aspects de la situation sociale du Cambodge en 1996

ព្រឹត្តិការណ៍នយោបាយ ព្រមទាំង បាតុភូតសង្គម ទាំងឡាយ ដែលបានស្តែងចេញឡើង នៅប្រទេសកម្ពុជា ចាប់តាំងពី ឆ្នាំ ១៩៩៥ មក ពុំមាន ឫសគល់ មកតែពីក្នុងប្រទេសទាំងអស់ នោះទេ។ អំពើពុករលួយ ដែលចាប់ ផ្តើមកើតឡើង នៅពេលនោះពុំអាច រីកដុះដាល បានទេ ប្រសិនណាជា គ្មាន អ្នករកស៊ី មកពីខាងក្រៅ។ និយាយមួយបែបទៀត បើគ្មានអ្នកសូកទេ អ្នកស៊ីសំណូកក៏គ្មានដែរ ។ គេសង្កេតឃើញថា នៅក្នុងបរិបទ នៃសង្គមខ្មែរ នៅ ពេលនោះ វប្បធម៌ នៃ អំពើពុករលួយ បានវាយរំលំ វប្បធម៌ នៃ ឧត្តម គតិបានយ៉ាងស្រួល ព្រោះតែ សីលធម៌ស្អាតស្អំ គោរពសច្ចធម៌ វិចារណញ្ញាណ និងគតិបណ្ឌិត បានបាត់បង់ផ្អែករបស់វា ស្ទើងតែអស់គ្មានសល់ទៅ ហើយ។ ច្បាប់ នៃ ការធ្វើវិនិយោគបរទេស មានគ្រប់គ្រាន់ទាំងអស់ ប៉ុន្តែ យក ទៅអនុវត្តឲ្យបានត្រូវនឹងសារប្រយោជន៍ របស់ប្រទេសជាតិ មិនកើត ព្រោះតែ វប្បធម៌ថ្មី បានស៊ីរូងផ្ទៃក្នុងស្ទើងតែគ្រប់វិស័យ។ ប៉ុន្តែ គេក៏ត្រូវយល់ ផងដែរ ថា នៅក្នុងការអភិវឌ្ឍន៍ បើគ្មានច្បាប់សម្រាប់គ្រប់គ្រង ឲ្យបានសមស្របទេនោះ អំពើពុករលួយ ក៏ចេញមកជាមួយផង ដែរ។ ច្បាប់ទាំងនោះ អាចនឹង យក ទៅអនុវត្ត ដោយជោគជ័យបាន លុះណាតែ បរិយាកាសសង្គម មាន អំណាយផល ផងដែរ គឺ មានន័យថា ទាល់តែ ពលរដ្ឋ ម្នាក់ៗ ជាពិសេស





សមាជិកគ្រួសារអ្នកអន្រើ្ទសៗ គេនាំគ្នាស្អប់ខ្ពើមប្រាក់កាសទ្រព្យសម្បត្តិ ដែល បានមកដោយ អំពើស្មោគគ្រោក បែបនេះផងដែរ។ ប៉ុន្តែនៅក្នុង បរិបទ នៃ សង្គមខ្មែរពេលនោះក៏ដូចជា នៅពេលក្រោយៗមកទៀតដែរ គេសង្កេតឃើញ ថា ចំពោះអ្នកខ្លះ ប្រាក់កាសដែលបានមក ដោយការសូកប៉ាន់ ឬ ដោយ ការជិះជាន់ផ្សេងៗ ពុំបញ្ចេញនូវក្លិនអសោចរបស់វា សោះ គឺ បែរជាក្លាយទៅជា ប្រភព នៃ កិត្តិយសមួយ ដ៏ ចម្លែកទៅវិញ។ អ្នកមានប្រាក់ច្រើន ទោះចេញមកពីប្រភពណាក្តីបានត្រូវគេគោរពកោតស្ញែងខ្លាច ស្រឡាញ់រាប់អាន ជាទីបំផុត រីឯអ្នកក្រីក្រ ទៀងត្រង់ បែរជាត្រូវគេប្រមាថ មើលងាយ បន្អាប់បន្ថោនថា ខ្វះគំនិតប្រាកដនិយមទៅវិញ ។ ដូចនេះ នៅក្នុងទំនាក់ទំនង រវាង មនុស្ស នឹង មនុស្ស នៅក្នុងមជ្ឈដ្ឋាន នានា បើអ្នកណានិយាយពី ឥរិយាបថ ស្អាតស្អំ គេស្តាប់ពុំចូលត្រចៀកឡើយ។ កត្តាសំខាន់មួយទៀត គឺ ការដែលរដ្ឋអំណាច ពុំបានលើកទឹកចិត្ត ដល់អ្នកដែលរស់នៅក្នុងឧត្តមគតិ ដូចពី សម័យមុនៗ។ គេនាំគ្នាស្មានថា ការអភិវឌ្ឍន៍ មានក្រឹតក្រមសត្យានុម័ត របស់វា គឺមិនចាំបាច់សម្រប ទៅតាមឧត្តមគតិអ្វីពេកទេ។ តាមធម្មតា ការរកស៊ីមានបាន ជាឥរិយាបថដែលត្រូវបានទទួល នូវ ការសរសើរ ក៏ ប៉ុន្តែ ទាល់តែអ្នកនោះ ជាផលិតករ ដែលចេះយកផលិតផលល្អៗ របស់ខ្លួនទៅលក់ នៅបរទេសផង ដែរ។ បើផ្ទុយពីនេះ គឺ ជាការបើកផ្លូវ ឲ្យឈ្មួញបរទេស ប្រកបមុខរបរនេះជំនួស ដោយយកប្រាក់សំណូកសម្រាប់ធ្វើជាអ្នកមាន ហើយទុកឲ្យប្រជាពលរដ្ឋ ស្ថិតនៅត្រាំត្រែង តែលតោល គ្មានសកម្មភាព អ្វីទាំងអស់។ កត្តាទាំងឡាយខាងលើនេះ មិនគ្រប់គ្រាន់ទេ សម្រាប់ពន្យល់មូលហេតុ នៃ អំពើពុករលួយស្របច្បាប់ ឬ ដែលគ្មានច្បាប់ហាមឃាត់នៅ ក្នុងសង្គមខ្មែរនៅពេលនោះ ។ បញ្ហាការងារ ឬសមត្ថភាពធ្វើការងារក៏ ជាកត្តាមួយដែរ ។ បើរដ្ឋ ពុំលើកទឹក ចិត្ត និង លើកកម្ពស់ គុណភាពផលិតកម្មក្នុងប្រទេសទេនោះ របស់របរ មកពីក្រៅ នឹងចូលពេញទីផ្សារក្នុងប្រទេសហើយ សម្ងាប់ផលិតផលក្នុងប្រទេស ដោយគេចពុំផុត។ ការបាត់បង់ការងារ និង សន្ទុះផលិតកម្ម ក៏នាំមកនូវ អំពើចោរកម្ម អំពើ បោកប្រាស់ គ្រប់រូបភាព ព្រមទាំង ការរំលោភគ្រប់ប្រភេទ ពីសំណាក់មន្ត្រី ទៅលើប្រជាជន ដើម្បីបំប៉នគ្រួសារ របស់ ខ្លួនផ្ទាល់ ដូចជា ការដណ្តើម

យកដីធ្លី របស់ប្រជាជន ជាដើម ដោយសំអាង ទៅលើការខុសច្បាប់ និង ខុសផែនការ អភិវឌ្ឍន៍ របស់ រដ្ឋាភិបាល។ គឺ កត្តាទាំងឡាយនេះ ហើយ ដែលជាមូលហេតុ ដ៏ចម្បង នៃភាពក្រីក្ររបស់ប្រជាជន និង ការកើតឡើង នៃអ្នកមានប្រាក់កាសរាប់លានដុល្លារ ។ ធ្ងន់ជាងនេះទៅទៀត អ្នកមានទាំង នោះ ពុំបានយកប្រាក់ ទៅបង្កើតសហគ្រាស សម្រាប់ បង្កើតការងារអ្វីទាំងអស់ គឺគេនាំគ្នាយកទៅចាយវាយ ហ៊ឺហា បំប៉នសហគ្រាស បរទេស ជាងគិតគូរ លើកតម្កើង ផលិតផលជាតិ ឬមួយ ក៏យកទៅ ឲ្យក្រុមគ្រួសារ របស់គេ បំផ្លាញចោល ជាអាសាបង់តែម្តង។ នៅក្នុងប្រទេសប្រជាធិបតេយ្យ គេប្រយ័ត្នមិនឲ្យ បាតុភូតគ្រួសារនិយម (le népotisme) នេះ កើតមានឡើងទេ ព្រោះវា តែងតែធ្វើឲ្យ ប៉ះពាល់ដល់ការអភិវឌ្ឍន៍ និងតម្លៃ នៃគុណាណូបការ នៃ អ្នកដែលមានទេព្យកោសល្យ គឺ អ្នកដែលធ្វើឲ្យសង្គមរីកចម្រើន និង មានកេរ្តិ៍ឈ្មោះ។ នៅក្នុងប្រទេសទាំងនោះ កូន ណាដែលរស់នៅជាមួយ ឪពុកម្តាយយូរពេក ហើយ បង្ខំឲ្យឪពុកម្តាយ ចិញ្ចឹមរហូត ដល់ចៅ អាចនឹងមានការពិបាកចុះសម្រុង ក្នុងជីវិតនៅថ្ងៃក្រោយ ដោយមិនគិតពី ការ យឺតយ៉ាវ ក្នុងការរីកចម្រើនចាស់ទុំផ្លូវគំនិត របស់ក្មេងផង ។ រីឯ ឪពុកម្តាយវិញ គឺ មានប្រេកតែមួយប៉ុណ្ណោះ ដើម្បីរកប្រាក់ ចិញ្ចឹមកូន ។ បើជានាម៉ឺន គឺ មានតែអំពើខុស ច្បាប់ប៉ុណ្ណោះ បើពុំនោះសោតទេ នឹង ត្រូវគេនិន្ទាជុំទិស ហើយដល់យូរៗទៅ ត្រូវគេ ស្អប់ទៀតផង។ បញ្ហាចំពោះមុខ របស់ រដ្ឋនៅពេលនោះ គឺថា តើត្រូវផ្តល់អាទិ៍ភាព ទៅឲ្យការលូតលាស់ផ្នែកសេដ្ឋកិច្ចតែម្តង ឬក៏ ត្រូវរៀបចំ រចនាសម្ព័ន្ធ សង្គម ឲ្យបានមាំ សិន។ ប៉ុន្តែទោះបីរដ្ឋធម្មនុញ្ញបានចែងយ៉ាងច្បាស់ថា ត្រូវយកចិត្តទុកដាក់ អំពី ស្ថានភាព របស់ប្រជាជនក្តី ក៏តាមការពិត គេបានជ្រើសរើស យកការលូតលាស់ផ្នែកសេដ្ឋកិច្ច រួចបាត់ទៅហើយ ប៉ុន្តែតាមការពិត គឺ ជាផលប្រយោជន៍ របស់ បរទេស ឯនោះវិញទេ ព្រោះ ខ្មែរពុំទាន់មានលទ្ធភាព សមស្រប ដើម្បីទទួលយក លទ្ធផល នៃ ការរីកចម្រើន សេដ្ឋកិច្ចនោះនៅឡើយ។ នៅក្នុង រចនាសម្ព័ន្ធសង្គមខ្មែរ គ្រួសារក្រុមបក្សពួក ជារបស់ សក្ការ ប៉ះពាល់ មិនបាន ។ ដោយគ្មានស្ថាប័ន សង្គម និង ច្បាប់ទម្លាប់ សម្រាប់លើក តម្កើង សេរីភាព និង ភាពថ្លៃថ្នូរ របស់ បុគ្គល អ្នកអន្រ្ទើស។ ត្រូវបង្ខំចិត្ត ចិញ្ចឹមបង





ប្អូន ក្រុមគ្រួសារ របស់គេ ជាហេតុធ្វើឲ្យ អំពើពុករលួយ កាន់តែរីកធំទៅៗ ជាលំដាប់ ។ ដើម្បីសម្របទៅតាម ទម្លាប់ជាទូទៅ របស់ សង្គមខ្មែរ អ្នកដែលមាន តួនាទី នៅក្នុងរដ្ឋ បាល ត្រូវតែទទួល ភារកិច្ចចិញ្ចឹមបងប្អូន សាច់ញាតិ ជិតឆ្ងាយ ទាំងអស់ ហើយទទួល ភារកិច្ចបណ្តុះបណ្តាលអ្នកទាំងនោះ ជាកំហិត រហូតដល់ថ្នាក់ជាប់ផុងខ្លួនឯងតែម្តង។ បើ គេគេចពីភារកិច្ចដ៏ធ្ងន់ធ្ងរនេះ គេនឹងត្រូវបងប្អូន និង សង្គមទាំងមូលនិន្ទា ជាពុំខាន។ ជាទូ ទៅ គេពុំអាចគេចពីបន្ទុកនេះបានទេ ទោះបន្ទុកនោះ ជា បន្ទុក របស់ រដ្ឋ សោះនោះ ។ គ្រួសារអ្នកអន្រ្ទើសនីមួយៗ តែងតែគេចពុំផុត ពីសភាពការណ៍នេះ។ មួយថ្ងៃៗ គេតែង តែត្រូវបងប្អូន អុកឡុកព្រឹកល្ងាច ប៉ុន្តែពុំធ្វើអ្វី ទាំងអស់ ដើម្បីកសាង ស្ថាប័ន ជាមូល ដ្ឋាន សម្រាប់ដោះស្រាយ បញ្ហាសង្គម ដ៏ធំនេះ ។ នេះជាកត្តាមួយ ដ៏សំខាន់នៃ អំពើពុក រលួយ របស់កម្មាភិបាល នៅក្នុងរចនាសម្ព័ន្ធ នៃសង្គមខ្មែរ ។ ម្យ៉ាងទៀត អ្នកអន្រ្ទើស ទាំងនោះ ពុំសូវចង់ផ្តល់សិទ្ធិសេរីភាព អ្វីប៉ុន្មាន ទៅឲ្យពលរដ្ឋខ្មែរទេ គឺ ទុកសម្រាប់ ឲ្យរណប នឹងគេជានិច្ច ដោយបារម្ភខ្លាចក្រែង មាន ការបះបោរទាមទារ សិទ្ធិ សេរីភាព ឬ ផលវិបាកផ្សេងៗ ដល់ខ្លួនគេ ទៅថ្ងៃក្រោយ ។

ក្រៅពីបាតុភូត រចនាសម្ព័ន្ធ ទាំងឡាយខាងលើនេះ គេសង្កេត ឃើញថា ច្បាប់ខ្លះ មានលក្ខណៈមិនសមស្រប គឺ ជួនកាលធូរពេក ជួនកាល តឹងពេក ។ ការពិត គឺមិន មែនត្រូវតែតឹង ទាំងអស់នោះទេ គឺ នៅក្នុងករណីខ្លះ ត្រូវបើកផ្លូវឲ្យការអភិវឌ្ឍន៍ អាច មានលទ្ធភាពគ្រប់គ្រាន់ដែរ ។ មានករណីខ្លះ គេត្រូវដាក់ទោស ជាទម្ងន់ ប៉ុន្តែ មានករណី ខ្លះ គេត្រូវបន្ធូរបន្ថយ ឬ ជួយជ្រោមជ្រែង ទៅវិញដែរ ។ នៅក្នុងកម្រិតអភិវឌ្ឍន៍ នៃ ប្រទេស កម្ពុជា គេត្រូវមានទស្សនាទានសេដ្ឋកិច្ចមួយឲ្យបានស៊ីចង្វាក់ រវាង រចនាសម្ព័ន្ធ សង្គម នឹង រចនាសម្ព័ន្ធ សេដ្ឋកិច្ច ។ បើគេយល់ថា ត្រូវផ្តល់អាទិ៍ភាព ទៅឲ្យ ការលូត លាស់សេដ្ឋកិច្ច ឲ្យបានឆាប់រហ័សពេកនោះ សង្គមក៏អាចបែកបាក់ឱរេ ព្រោះត្រូវបញ្ចូល កម្លាំង និង សមត្ថភាពផ្សេងៗ មកពីក្រៅប្រទេស ហើយត្រូវក្តិច ឬ បោះបង់ចោលកម្លាំង ដែលកំពុងរីកចម្រើនបន្តិចម្តងៗ នៅក្នុងប្រទេស។ បើកម្លាំងនេះ រីកចម្រើនពុំទាន់ សភាព ការណ៍ ទេនោះ ប្រជាជនខ្មែរ ក៏បាត់អត្តិភាព របស់ ខ្លួនដែរ។ មិនតែប៉ុណ្ណោះសោត គឺ

អាចបាត់ ទាំង មូលដ្ឋានវប្បធម៌ទៀតផង ។ ប៉ុន្តែបើ នឹង ផ្ដល់អាទិភាពទៅឲ្យ ការដោះស្រាយ បញ្ហាសង្គមតែមួយមុខ ការរីកចម្រើនសេដ្ឋកិច្ច ក៏មិនអាចប្រព្រឹត្តទៅ ដោយឆាប់រហ័សបានដែរ។ ប្រការដែលគួរឲ្យកត់សំគាល់ គឺ ថា រដ្ឋអំណាច មិនដឹងជាត្រូវធ្វើយ៉ាងណា ។ ទន្ទឹមនោះដែរ អ្នកអន្ដ្រើសៗ ក៏ពុំបានផ្ដល់នូវ គំរូវិជ្ជមាន សមស្របជាក់លាក់ណាមួយ សម្រាប់ ការអភិវឌ្ឍន៍ ក្នុងប្រទេសទៅទៀត ក្រៅពីគំរូសម្របទៅតាមទេសកាលមួយ ជាកំណត់ គឺកាលៈទេសៈមួយដែលរេ ទៅតាមទ្រឹស្ដី បដិបក្ខធំៗពីរ ដែលបានបង្កើតអស្ថិរភាព និង សង្គ្រាមត្រជាក់ នៅក្នុងលោក អស់រយៈពេល ជាង ១ សតវត្សមកហើយ។ តាមការពិត អ្នកស្នេហាជាតិមិនមែនជា អ្នកដែលចេះនិយាយ តែពី ការស្នេហាជាតិ និង ការស្រឡាញ់ វប្បធម៌ជាតិ ប៉ុណ្ណោះទេ តែ ក៏ ជាផលិតករ ចំណានៗ ដែលអាចយក ផលិតផល របស់ ប្រទេសខ្លួន ទៅ វាយលុក ចូលក្នុងផ្សារក្រៅប្រទេសផងដែរ ។

## ព្រឹត្តិការណ៍ ថ្ងៃ ៥ កក្កដា ឆ្នាំ ១៩៩៧
## Le coup de force du 5 juillet 1997

នៅឆ្នាំ ១៩៩៧ នៅពេលដែល ការកសាងប្រទេស ជួបនឹង បញ្ហាស្មុគស្មាញជាពិសេស អំពើពុករលួយ ដែលស៊ីរូងផ្ទៃក្នុង គ្មានអ្វីអាចទប់ទល់បាន ហើយ នៅពេលដែលអ្នកមក ធ្វើវិនិយោគសំខាន់ៗ នៅក្នុងប្រទេស ត្រូវ មន្ត្រីពុក រលួយ ជំរិតយកប្រាក់ដោយឥតអាសូរ ឬ ក៏ទទួលយកសំណូក ពីក្រុមហ៊ុន «វិលល្វាច»[៥២]ដោយគ្មានកោតក្រែង ទំនាស់ រវាង សហនាយករដ្ឋមន្ត្រីទាំងពីរ ក៏ចេះតែបន្តទៅទៀត ហើយបានចូលមក ដល់ដំណាក់ការមួយ ដែលនាយក រដ្ឋមន្ត្រី ទាំងពីរប្រយុទ្ធគ្នាស្លាប់រស់ ។ នៅថ្ងៃ ៥ កក្កដា ការបង្ហូរឈាមមួយ បានកើតមានឡើង នៅទីក្រុងភ្នំពេញ។ កងទ័ពរបស់ លោក ហ៊ុន សែន ខាងគណបក្ស «ប្រជាជន» និង កងទ័ពរាជានិយម របស់ ព្រះអង្គម្ចាស រណឫទ្ធិ ខាងគណបក្ស «ហ្វុនស៊ិនប៉េច» បានប្រយុទ្ធគ្នាអស់ រយៈពេល ២ ថ្ងៃ ។ បន្ទាប់មក តាមរយៈកញ្ចក់ទូរទស្សន៍ លោក នាយករដ្ឋមន្ត្រីទី ២ ហ៊ុន សែន ដែលពុំទាន់ដោះឯកសណ្ឋានយោធា នៅឡើយ បានប្រកាស ជ័យជំនះ របស់កងទ័ព នៃគណបក្ស ប្រជាជន ហើយ និងការរត់ចាកចេញពីប្រទេស របស់ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ សហនាយក រដ្ឋមន្ត្រី ទី ១ នៃរាជរដ្ឋាភិបាល។ ទោះបីព្រឹត្តិការណ៍នេះ ជារឿងដែលគេចពុំផុតក្តី ក៏ចំពោះសាធារណមតិ វាជាការមួយដែលរកយល់សឹងពុំបាន។ បើនិយាយ មួយបែបទៀត លោកសហនាយករដ្ឋមន្ត្រីទី ២ យកឈ្នះទៅលើ លោកនាយករដ្ឋមន្ត្រីទី ១ ដោយពុំមានមូលហេតុ នយោបាយអ្វីមួយច្បាស់លាស់ដែរ ព្រោះថា បើគណបក្ស«ប្រជាជន» ដែលជាអតីតគណបក្សកុម្មុយនិស្ត បានធ្វើរដ្ឋប្រហារ វាយរំលំរបបរាជានិយម ហើយដាក់របប សាធារណរដ្ឋ មួយ មកជំនួសវិញ ក៏មិនត្រូវដែរ ព្រោះរបប រាជានិយម នៅតែមាន វត្តមាន បន្តមកទៀត ក្រោយព្រឹត្តិការណ៍នេះ ។ នៅថ្ងៃ ១៦ កក្កដា លោក អ៊ឹង ហួត ដែលជា អ្នករាជានិយម ហើយ ជា សមាជិក ដ៏ សំខាន់ម្នាក់ នៃ គណបក្ស របស់ ព្រះអង្គម្ចាស់ រណឫទ្ធិ បានត្រូវតែងតាំងជា នាយករដ្ឋមន្ត្រី ទី ១ ជំនួស ព្រះអង្គម្ចាស់ រណឫទ្ធិ ។ សូមបញ្ជាក់ថា នៅពេល មុនព្រឹត្តិការណ៍នេះ ព្រះអង្គម្ចាស់ រណឫទ្ធិ ពុំដែលបានត្រូវគណបក្សរាជានិយមនេះ ដកហូត ពីមុខតំណែង ប្រធានគណបក្ស ឬក៏បណ្ដេញចេញពីគណបក្សអ្វីទេ។ ចំពោះ អ្នកសង្កេតការណ៍ខ្លះ នេះពុំមែនជារឿងអ្វីថ្មីនោះទេ នៅប្រទេសកម្ពុជា ព្រោះ នៅក្នុងប្រទេសនេះ ការបោះឆ្នោតរដ្ឋសភាក្ដី រដ្ឋធម្មនុញ្ញក្ដី គ្រាន់តែជាឡប់ឡែ សម្រាប់ឲ្យអ្នកនយោបាយ មានទំនាក់ទំនងល្អ ជាមួយបណ្ដាប្រទេស ដែលកាន់លទ្ធិប្រជាធិបតេយ្យ តែប៉ុណ្ណោះ ជាពិសេស សម្រាប់ យកជំនួយ ពី ប្រទេសទាំងនោះ ។ ប៉ុន្តែបើគេពិនិត្យមើល អំពី ការប្រជែង កម្លាំងគ្នា រវាង គណបក្ស «ប្រជាជន» ដែលគាំទ្រដោយវៀតណាមពីពេលមុន នឹង គណបក្ស «ហ្វុនស៊ិនប៉េច» ដែលនៅពេល

[៥២]ក្រុមហ៊ុនដែលកើតឡើង ហើយ រលាយ បាត់ទៅវិញ ឬ ក៏ បាត់ស្រមោល តែម្ដង នៅក្នុរយៈកាលមួយដ៏ខ្លី ។



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

នោះ តំណាងប្រយោជន៍ របស់ អ្នកដែលប្រឆាំង នឹង អតីតរបបកុម្មុយនិស្ត គេសង្កេតឃើញថា រឿងអតីតកាល នៅមិនទាន់ចប់សព្វគ្រប់នៅឡើយទេ។ នៅក្នុងន័យនេះ ការជោគជ័យ របស់ ព្រះអង្គម្ចាស់ រណឫទ្ធិ នៅខែ កក្កដា ឆ្នាំ ១៩៩៧ នោះ ជាការបាត់តុល្យភាព ភូមិសាស្ត្រ-នយោបាយមួយដ៏ធំ ។ ដោយហេតុនេះហើយ បានជា ទាំងទីក្រុងវ៉ាស៊ីងតោន ទាំងទីក្រុងប៉េកាំង ព្រមទាំងអង្គការ សហប្រជាជាតិ គេនាំគ្នាធ្វើការគាបសង្កត់គ្រប់បែបយ៉ាង ទៅលើលោក ហ៊ុន សែន ដើម្បីឲ្យព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ វិលត្រឡប់មក កម្ពុជាវិញ ។

នៅក្នុងរយៈពេល នៃ ការប្រជែងកម្លាំងគ្នា សាជាថ្មីទៀត និង ដោយ បិទមុខនេះ គេសង្កេតឃើញថា ចាប់តាំងពីឆ្នាំ ១៩៩៦ មក គូបដិបក្ខទាំងពីរ ខិតខំរកមធ្យោបាយប្រើកម្លាំងខ្មែរក្រហម រៀងៗខ្លួន ក៏ ប៉ុន្តែ ពួកខ្មែរក្រហម ក៏ បានបែកគ្នាជា ២ ក្រុមបដិបក្ខ ដូចគ្នាអ៊ីចឹងដែរ ។ ក្រុមមួយ ដឹកនាំដោយ អៀង សារី ត្រៀមលក្ខណៈ ជាស្រេច ដើម្បីចងសម្ព័ន្ធភាព ជាមួយ លោក ហ៊ុន សែន។ នៅក្នុងន័យនេះ អៀង សារី បានបង្កើតចលនា នយោបាយមួយ គឺ ចលនា «សហព័ន្ធ ប្រជាធិបតេយ្យ» ។ ក្រុមមួយទៀត គឺ ក្រុម របស់ ប៉ុល ពត ដែល នៅចន្លោះឆ្នាំ ១៩៨២-១៩៩១ ជាសម្ព័ន្ធមិត្តចាស់ របស់ គណបក្ស រាជានិយម «ហ្វ៊ុនស៊ិនប៉ិច»។ នេះមិនមែនជារឿងអ្វីថ្មី នោះទេ ព្រោះចលនាកុម្មុយនិស្តខ្មែរ តាំងពីចាប់កំណើតមក បែកជាពីរ ដូច្នេះរួចស្រេចទៅហើយ ព្រោះ ទីក្រុងហាណូយ និង ទីក្រុងប៉េកាំង តែងតែដណ្ដើមយកស្រុកខ្មែរ តែរៀងៗខ្លួន ។ នៅក្នុងដំណាក់ការថ្មីនេះ ក្រុមខ្មែរក្រហម នីមួយៗ ស្វែងកសាងខ្លួន ជាថ្មីឡើងវិញ។ ក្រុម អៀង សារី ប្រកាសថា គេគ្មានជាប់ពាក់ព័ន្ធអ្វី នឹងការសម្លាប់រង្គាល កាលពីឆ្នាំ ១៩៧៥-១៩៧៩ ទេ។ រីឯ ក្រុម ប៉ុល ពត វិញ គេ នាំគ្នាទម្លាក់ទោសទៅលើ ប៉ុល ពត តែម្នាក់ ។ នៅថ្ងៃ ២៥ កក្កដាឆ្នាំ ១៩៩៧ នោះ ពួកខ្មែរក្រហម ខាង ប៉ុល ពត បានបង្កើត ឆាកល្ខោនមួយ ដោយយកមេរបស់ពួកគេ ពោល គឺ ប៉ុល ពត ទៅកាត់ទោសឲ្យជាប់គុក របស់ ពួកគេ អស់មួយជីវិត ។





ការប្រយុទ្ធដណ្ដើមអំណាចគ្នា រវាង លោក ហ៊ុន សែន នឹងព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ នៅខែកក្កដាឆ្នាំ ១៩៩៧ បើយោងទៅ តាមហេតុការណ៍ ទាំងប៉ុន្មានខាងលើនេះ ពុំមានមូលហេតុមនោគមវិជ្ជាអ្វី ច្បាស់លាស់ទេ។ ប៉ុន្តែទំនាស់នេះ ក៏មិនមែន ជាការដណ្ដើមអំណាច រវាង បុគ្គលអ្នកកាន់អំណាចពីរនាក់ ដ៏សាមញ្ញដែរ។ នៅពេលដែល សហគមន៍អន្តរជាតិ ធ្វើការគាបសង្កត់ គ្រប់បែបយ៉ាង ដើម្បី បញ្ចូលព្រះអង្គម្ចាស់ រណឫទ្ធិ មកក្នុងឆាកនយោបាយខ្មែរវិញ គេក៏បានយល់យ៉ាងច្បាស់ថា ក្រោមរូបភាព នៃការតតាំងគ្នា រវាងគណបក្សរាជានិយម នឹងអតីតគណបក្សកុម្មុយនិស្ត មាន ការបង្កប់ នូវ ការប្រជែងកម្លាំងភូមិសាស្ត្រ-នយោបាយ មួយ ដ៏ក្ដៅគគុក រវាង ប្រទេសវៀតណាម នឹង ទីក្រុងប៉េកាំង។ ជាការពិតហើយដែលថា ក្រោយសន្និសីទអន្តរជាតិទីក្រុងប៉ារីស៍ឆ្នាំ ១៩៨៩ និង កិច្ចព្រមព្រៀងឆ្នាំ ១៩៩១ ទំនាស់ ភូមិសាស្ត្រ-នយោបាយនេះ ត្រូវបញ្ចប់ ។ ប៉ុន្តែអ្វីដែល ប្រទេសវៀតណាម នៅតែភ័យខ្លាច គឺ ឥទ្ធិពល ដ៏ធំមហិមា និង ប្រកបដោយគ្រោះថ្នាក់ របស់ប្រទេសចិន នៅក្នុង ប្រទេសកម្ពុជា ។ នៅក្នុងវិស័យយុទ្ធសាស្ត្រ ទីក្រុងហាណូយ យល់ថា បើចិន ក្ដាប់ប្រទេសកម្ពុជាបានមែន ប្រទេសគេ ពិតជាស្ថិតនៅក្នុងការឡោមព័ទ្ធ របស់ចិន។ ចំពោះទីក្រុងហាណូយ វត្តមាន និងឥទ្ធិពល របស់លោក នាយករដ្ឋមន្ត្រី ហ៊ុន សែន នៅក្នុងប្រទេសកម្ពុជា ជាការធានាមួយ ដែលមិនអាចអត់បាន ព្រោះតាមរយៈនេះ ប្រទេសវៀតណាម អាចត្រួតពិនិត្យ សភាពការណ៍យោធា នៅត្រង់ចំណុចដ៏សំខាន់នេះ ។ ប្រទេសវៀតណាមមិនចង់ឲ្យ អតីតឥណ្ឌូចិនបារាំង ធ្លាក់ទៅក្នុងកណ្ដាប់ដៃចិនទេ ប៉ុន្តែដោយគ្មានកម្លាំង និង មធ្យោបាយគ្រប់គ្រាន់ ក្រោយការរលំរលាយ នៃ សហភាព សូវៀត ប្រទេសនេះ ក៏គ្មានជម្រើសអ្វីទៀត ក្រៅពីវិលទៅស្ថិតនៅក្រោមឥទ្ធិពល របស់ ចិន ដូច កាលពីមុនវិញឡើយ ។ ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ឆ្នាំ ១៩៩១ សម្ដេច នរោត្តម សីហនុ បានយាងត្រឡប់ពីទីក្រុងប៉េកាំង មកភ្នំពេញវិញ ដើម្បី ចាប់ដៃ ធ្វើសហការ ជាមួយលោក ហ៊ុន សែន។ ប៉ុន្តែពួកខ្មែរក្រហម ខាង ចិន ពោល គឺ ពួក ប៉ុល ពត នៅតែ ខិតខំ សាកល្បងធ្វើការប្រយុទ្ធ យោធាបន្តមកទៀត ។ ទោះបីពួកគេមានសង្ឃឹមតិចក្ដី ក៏ ជាការគាបសង្កត់ មួយ ដ៏ធំដែរ ទៅលើទីក្រុងភ្នំពេញ និង ទីក្រុងហាណូយ។ ដូច្នេះឃើញថា ទោះជា

សម្តេច នរោត្តម សីហនុ ដែលមាន ចិន ជាបង្អែក វិលមក កម្ពុជាវិញ ក្តី ក៏ ចិន ក្តាប់ប្រទេសកម្ពុជា មិនបានគ្រប់ជ្រុងជ្រោយដដែល។ មួយវិញទៀត កម្លាំង របស់ខ្មែរក្រហម ក៏ចុះអន់ថយ ជាលំដាប់ ហើយថែមទាំងបែកគ្នា ជាពីរក្រុមដូចកាលពីឆ្នាំ ១៩៦០ ដូច្នេះដែរ។ នៅពេលដែលព្រះអង្គ ម្ចាស់ រណ ឫទ្ធិ ប្រធាន នៃ គណបក្ស «ហ្វុនស៊ិនប៉ិច» បានទទួលជ័យជំនះនៅក្នុងការបោះឆ្នោត ឆ្នាំ ១៩៩៣ ការដែលលោក ហ៊ុន សែន មិនព្រមចាញ់ ជាដាច់ខាត ក៏ ព្រោះតែ បញ្ហាភូមិសាស្ត្រ-នយោបាយនេះដែរ។ ជាការពិតហើយដែលថា វាក៏អាចជាបញ្ហាដណ្តើម អំណាចគ្នាផ្ទាល់ខ្លួនដែរ ប៉ុន្តែ បើគ្មានការគាំទ្រដោយសម្ងាត់ពី វៀតណាម និង ពីសំណាក់បណ្តាប្រទេស និង ពិភពអ្នកដែលមិនចង់ឲ្យឥណ្ឌូចិន ធ្លាក់ទៅក្នុងកណ្តាប់ដៃចិន ព្រមទាំង សម្តេច នរោត្តម សីហនុ និង ខ្មែរក្រហម ផងទេ ក៏ ក្រុមលោក ហ៊ុន សែនមិនហ៊ានដេញព្រះអង្គម្ចាស់រណឫទ្ធិចេញពីរាជរដ្ឋាភិបាលដែរ។ ការកត់សំគាល់មួយទៀតគឺ ព្រឹត្តិការណ៍ ខែកក្កដាឆ្នាំ ១៩៩៧ កើតមានឡើងមុនការបោះឆ្នោតសកាសម្រាប់នីតិកាល ទី ២ ។ លោក ហ៊ុន សែន យល់ថា ព្រះអង្គម្ចាស់រណឫទ្ធិ ជា គ្រោះថ្នាក់មួយ ដ៏ ធំចំពោះ គណបក្ស«ប្រជាជន»។ ដូចនេះ លោកត្រូវតែកំចាត់ ព្រះអង្គ ចេញពី ឆាកនយោបាយ ឲ្យបានឆាប់រហ័សបំផុត ។

ផ្ទុយពីការដែល សាធារណមតិ យល់ឃើញជាទូទៅ និង ជា ហូរហែ តាមរយៈសកម្មភាព ជាផ្លូវការ សភាពការណ៍ នៅកម្ពុជា ចាប់តាំង ពីឆ្នាំ ១៩៩៣ មក ពុំដែលមានការប្រែប្រួលអ្វីប៉ុន្មានទេ ៖ ការប្រជែងកម្លាំងរវាង វៀតណាម និង ចិន នៅតែមានបន្តមកទៀត ប៉ុន្តែគ្រាន់តែតាមរូបភាព ផ្សេងទៀតប៉ុណ្ណោះ ។ រីឯកិច្ចព្រមព្រៀងអន្តរជាតិនានា និងសកម្មភាពការទូត រវាង រវាងប្រទេសទាំងពីរនេះ ក៏ដោះស្រាយបានតែបញ្ហាចំពោះមុខប៉ុណ្ណោះដែរ។ មួយវិញទៀត ប្រទេសកុម្មុយនិស្តទាំងពីរនេះ ត្រូវពួតដៃគ្នាសិន ដើម្បីធ្វើយ៉ាងណា កុំឲ្យបស្ចិមប្រទេសលូកដៃ ចូលក្នុងការប្រជែងកម្លាំង នៅក្នុងតំបន់បាន ព្រោះថាបើបស្ចិមប្រទេស មានកាលានុវត្តនភាព ចូលមកក្នុង ប្រទេសកម្ពុជា ទាំងចិន ទាំងវៀតណាម ក៏បាត់បង់ឱកាសលេប យកស្រុកខ្មែរ និង ស្រុកលាវ ដូចតែគ្នា។ គឺនៅក្នុងន័យនេះហើយ ដែលប្រទេសកុម្មុយនិស្តទាំងពីរ ពង្រឹងសាមគ្គីភាព នឹងគ្នា ជាបណ្តោះអាសន្នសិន។





តែនេះ គ្រាន់តែ ជាយុទ្ធសាស្ត្រ នយោបាយ របស់ លោក យ៉ាំងយ៉េមិញ (Jiang Zemin) តែប៉ុណ្ណោះ។ សភាពការណ៍នៅប្រទេសកម្ពុជា អាច នឹងប្រែប្រួលនៅពេលមាន អ្នកដឹកនាំចិនថ្មីណាម្នាក់ ដែលយល់ឃើញថា ប្រទេសកម្ពុជាអាចនឹងធ្លាក់ទៅក្នុងដៃ អ្នកណា ផ្សេងៗទៀត បើ ពុំពង្រឹង ឥទ្ធិពល របស់គេ នៅ ឥណ្ឌូចិន ឲ្យបានឆាប់រហ័សទេនោះ។ អ្វីដែលប្រទេសចិន រង់ចាំ គឺ ការធ្លាក់ចុះឥទ្ធិពល របស់ លោក ហ៊ុន សែន ដោយប្រការផ្សេងៗ ។ ប៉ុន្តែនៅក្នុងឆាកនយោបាយ ខ្មែរមិនមែន មានតែអ្នកនយោបាយ ដែលផ្អែក វាសនារបស់គេ តែទៅលើចិន ឬ វៀតណាម ប៉ុណ្ណោះទេ។ គឺនៅ ក្នុងន័យនេះហើយ ដែល លោក សម រង្ស៊ី ខិតខំធ្វើសកម្មភាពនយោបាយ យ៉ាងមមាញឹក។ រីឯ ព្រះអង្គម្ចាស់រណឫទ្ធិវិញ ក៏ខិតខំរកប្រកបេញ ពីចិនដែរ ។ ប៉ុន្តែ គឺជាការមួយ ដ៏ពិបាក ហើយ អាចនឹង ត្រូវឆ្លងកាត់ផ្លូវមួយទៀតដែលគ្មានការទៀងទាត់ ។

ដូចយើងបានដឹងរួចមកហើយ មិនមែនតែបញ្ហាភូមិសាស្ត្រ-នយោបាយ ប៉ុណ្ណោះទេ ដែលបានជំរុញឲ្យមាន ព្រឹត្តិការណ៍ ខែកក្កដាឆ្នាំ ១៩៩៧ ។ បញ្ហាដណ្តើមអំណាចគ្នារវាង សហនាយករដ្ឋមន្ត្រី ទាំងពីរ ក៏ ជាបញ្ហាសំខាន់ឧរ ។ បញ្ហាភូមិសាស្ត្រ-នយោបាយជាបញ្ហាមូលដ្ឋាន រីឯ បញ្ហាដណ្តើមអំណាចគ្នា ក៏ជាបញ្ហាដែលចេញមកពីបញ្ហាភូមិសាស្ត្រ-នយោបាយនេះដែរ ។ មួយឆ្នាំមុនការបោះឆ្នោតនីតិកាលទី ២ គ្រោងរៀបចំនៅឆ្នាំ ១៩៩៨ គណបក្ស «ប្រជាជន» មានការបារម្ភយ៉ាងខ្លាំង ខ្លាចក្រែងចាញ់ឆ្នោតគណបក្ស «ហ្វុនស៊ិនប៉ិច» ម្តងទៀត។ ការប្រយុទ្ធគ្នា រវាង កងទ័ព «ហ្វុនស៊ិនប៉ិច» និង កងទ័ពដែលស្មោះត្រង់នឹងគណបក្ស «ប្រជាជន» ពីថ្ងៃ ៥ កក្កដាមកទល់ នឹងថ្ងៃ ៧ កក្កដាឆ្នាំ ១៩៩៧ នៅកណ្តាលទីក្រុងភ្នំពេញ ក៏បានត្រូវអ្នកសង្កេតការណ៍ខ្លះ ពិពណ៌នាថា មានមូលហេតុ មកពីការបារម្ភនេះដែរ ។ ក៏ប៉ុន្តែ នៅពេលនោះ លោក សហនាយករដ្ឋមន្ត្រី ទី២ ហ៊ុន សែនបានចោទព្រះអង្គម្ចាស់រណឫទ្ធិ ប្រធាន នៃ គណបក្ស «ហ្វុនស៊ិនប៉ិច» ថា បានប្រើកម្លាំងខ្មែរក្រហមវាយ រំលំលោកចេញពីរាជរដ្ឋាភិបាល។ រីឯ ព្រះអង្គម្ចាស់រណឫទ្ធិវិញ ដែលនៅពេលមុនព្រឹត្តិការណ៍ នេះ បានធ្វើការចរចា ជាមួយ ខៀវ សំផន ទ្រង់បានអះអាងថា : លោក ហ៊ុន សែន ក៏បានធ្វើការចរចាជាមួយ អៀង សារី ឧរ ។ ព្រះអង្គម្ចាស់ រណឫទ្ធិ ទ្រង់បានគូស

បញ្ជាក់បន្ថែមទៀតថា ការសុំចុះចូល នៃ ពួកខ្មែរក្រហម មិនមែន ជាជោគជ័យ របស់គណបក្សណាមួយទេ តែជាជោគជ័យ របស់រដ្ឋាភិបាល ខ្មែរទាំងមូល។ សំនួរដែលគេចោទសួរនៅពេលនោះ គឺថា តើការប្រយុទ្ធគ្នា នាថ្ងៃ ៥ កក្កដាឆ្នាំ ១៩៩៧ បណ្តាលមក ពីមូលហេតុអ្វីវិញ ក្រៅពី ការដណ្តើមអំណាចគ្នា ជាប្រពៃណីនោះ? មតិខ្លះយល់ថា ជាការពិតហើយ ដែលថា ក្រោយសន្និសីទអន្តរជាតិ ទីក្រុងប៉ារីស៍ឆ្នាំ ១៩៨៩ និង កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ឆ្នាំ ១៩៩១ ប្រទេសដែលបានគាំទ្រគូបដិបក្ខ ទាំងសងខាង បាន ដកខ្លួនចេញអស់ ពីអធិករណ៍ខ្មែរ ក៏ប៉ុន្តែ ដោយ ការបង្រួបបង្រួមជាតិឡើងវិញ ដោយពុំយកការបោះឆ្នោតជាធំ ពុំបានទទួលជោគជ័យ ដូច ការគ្រោងទុក របស់ សម្តេច នរោត្តម សីហនុ ដែលចង់ផ្តល់ជ័យជំនះ ទៅឲ្យ តែក្រុមកុម្មុយនិស្ត ដូចគ្នា / ការវិវាទគ្នាឡើងវិញ តាមបែបទមុនឆ្នាំ ១៩៩៣ ក៏ បេះតែបន្តទៅទៀត ។ នៅពេលដែលសម្តេច នរោត្តម សីហនុ ដែលបានត្រូវគេចាត់ទុក ថាជា «បិតា នៃ ឯករាជ្យជាតិ» សព្វព្រះទ័យ ចរចាជាមួយ លោក ហ៊ុន សែន មុនកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ឆ្នាំ ១៩៩១ ព្រះអង្គទ្រង់ឈ្វេងយល់ថា ព្រះអង្គអាចមានឥទ្ធិពល ទៅលើ លោកហ៊ុន សែន។ ប៉ុន្តែ តាមការពិត លោក ហ៊ុន សែន ដែលមានប្រៀបផ្នែកយោធា និង ផ្នែករដ្ឋបាលទៅលើ ចលនាប្រឆាំង នឹង វៀតណាម នៅពេលនោះ ចង់ប្រើឥទ្ធិពលរបស់ សម្តេច សីហនុ ទៅវិញទេ គឺ ដើម្បីធ្វើការគាបសង្កត់ ទៅលើក្រុមខ្មែរដែលគ្មានប្រវត្តិ តស៊ូជាមួយពួកកុម្មុយនិស្ត ប៉ុន្តែ ដែលត្រូវមក កាន់កាប់វាសនាប្រទេសកម្ពុជាឡើងវិញ បន្ទាប់ពីអំពើវិនាសកម្ម ដែលពួកខ្មែរកុម្មុយនិស្ត បានធ្វើទៅលើប្រទេស និង ទៅលើប្រជាជនខ្មែរ។ គណបក្ស «ប្រជាជន» បានជួយរំដោះប្រជាជនខ្មែរ ពីរបប ប៉ុល ពត ក៏ពិតមែន ប៉ុន្តែ ការពិត គឺមកពី ប្រទេសវៀតណាម និង សហភាពសូវៀតវាយរំលំ របប ប៉ុលពត ដែលមាន ប្រទេសចិន នៅពីក្រោយ តែប៉ុណ្ណោះ។ ពេលវៀតណាម ដកកងទ័ពចេញពីស្រុកខ្មែរ ហើយនៅពេលដែលសហភាពសូវៀត រលំរលាយទៅ លោក ហ៊ុន សែន នៅតែកាន់កាប់ ទឹកដីខ្មែរ ដដែល ព្រោះ កងទ័ពរំដោះ ពុំមានប្រៀបអ្វីប៉ុន្មាន ទៅលើ របបទីក្រុង ភ្នំពេញ ដែលត្រៀមលក្ខណៈជាស្រេច ដើម្បី រក្សាអំណាចរបស់គេជានិច្ច ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ។ និយាយមួយបែបទៀត កិច្ចព្រម





ព្រៀង សន្តិភាព ទីក្រុងប៉ារីស៍ គ្រាន់តែបាន បញ្ចូល មកក្នុង របប ហ៊ុន សែន នូវ វរជននយោបាយ ដែលធ្វើសង្គ្រាមប្រឆាំងគ្នានៅក្នុងបរិបទ នៃ ទំនាស់ រវាង បងប្អូន កុម្មុយនិស្តទាំងពីរ តែប៉ុណ្ណោះ ព្រោះ ប្រទេសមហាអំណាច គេនាំគ្នា ផ្អាកសង្គ្រាមអស់ទៅ បន្ទាប់ពីសហភាព សូវៀត បែកខ្ញាត់ខ្ចាយ ។ អ្នកដែលបានចំណេញ ក្នុងការអនុវត្តន៍ កិច្ចព្រមព្រៀងសន្តិភាព មិនមែន ចលនារំដោះទេ តែគឺរបបដែលវៀតណាម និងសហភាព សូវៀតបានពង្រឹងជាស្រេចមុន នឹងចេញទៅ ។ រីឯអ្នកខាតច្រើនជាងគេ គឺ អ្នកប្រជាធិបតេយ្យសេរីនិយមដែល ក្រោយមក បានត្រូវគេគាបសង្កត់ សឹងតែងើបមុខមិនរួច ។ ចំពោះអ្នករាជានិយម ក៏មិនបានចំណេញប៉ុន្មានដែរ ព្រោះ ទាំងសម្តេច នរោត្តម សីហនុ ទាំង ព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ដណ្តើមយកអំណាច ពីគណបក្ស «ប្រជាជន» មិនបានដដែល ។ ទោះជាយ៉ាងណាក្តី «សង្គ្រាមត្រជាក់» រវាងប្រទេសកុម្មុយនិស្ត ទាំងពីរ នៅក្នុងរចនាសម្ព័ន្ធនយោបាយខ្មែរ នៅមិនទាន់ចប់សព្វគ្រប់ នៅឡើយទេ ។

សម្តេច នរោត្តម សីហនុ ដែលសាកល្បងបង្រួបបង្រួម ក្រុមកុម្មុយនិស្តខ្មែរទាំងពីរ ពុំបានទទួលជោគជ័យទេ ព្រោះព្រះអង្គមិនមែនជា អាជ្ញា កណ្តាល ។ ព្រះអង្គជាកូនអុករបស់ចិន ដូចនេះ ពុំអាចអូសទាញ លោក ហ៊ុន សែនដែលជាកូនអុករបស់ វៀតណាមបានទេ ។ ទោះបីព្រះអង្គ ផ្លាស់ទីតាំង ជាច្រើនដងក្តី ក៏ព្រះអង្គ មិនអាចបោះបង់ចិនចោលបានឡើយ។ ប្រទេសវៀតណាម ដកកងទ័ពរបស់គេចេញពីកម្ពុជា ក៏ពិតមែន ប៉ុន្តែ គេ ក៏មិនណោយ ឲ្យក្រុមខ្មែរ ដែលចិនគាំទ្រ ពង្រឹងកម្លាំង និងឥទ្ធិពលរបស់ខ្លួននៅកម្ពុជា បានឡើយ។ ពីឆ្នាំ ១៩៩១ ដល់ឆ្នាំ ១៩៩៣ ហើយពី ឆ្នាំ ១៩៩៣ ដល់ឆ្នាំ ១៩៩៧ នោះ លោក ហ៊ុន សែន ដែលជាមនុស្សខ្លាំង នៃ របបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ ថ្មី និង ជាមនុស្សខ្លាំង នៃ គណបក្ស «ប្រជាជន» មិនត្រឹមតែ រក្សាយុទ្ធសាស្ត្រ ថ្ងៃ ៧ មករារហូតប៉ុណ្ណោះទេ គឺ ថែមទាំង បំបែក កម្លាំងពួកខ្មែរក្រហមជាពីរ បានទៀតផង មុននឹង ចលនា ខ្មែរក្រហម ខាងចិននេះ ត្រូវបាក់បែកខ្ចាត់ខ្ចាយគ្នាអស់ នៅចន្លោះ ថ្ងៃ ៥ នឹង ថ្ងៃ ១៣ មិថុនា ឆ្នាំ ១៩៩៨ គឺ ជាងពីរខែក្រោយពេលដែល ព្រះអង្គម្ចាស់រណឫទ្ធិ វិលត្រឡប់មក កម្ពុជាវិញ ហើយ ពីរខែក្រោយមរណភាព របស់ ប៉ុល ពត ។ នៅចន្លោះថ្ងៃ

៥ នឹង ថ្ងៃ ១៣ មិថុនា ឆ្នាំ ១៩៩៨ នោះ កងទ័ព និង កម្មាភិបាល នយោបាយ ខ្មែរក្រហម ចំនួន ៤ ពាន់នាក់ បានសុំចុះចូលរាជរដ្ឋាភិបាល។ ព្រឹត្តិការណ៍ថ្ងៃ ៥ កក្កដា ឆ្នាំ ១៩៩៧ ក៏ស្ថិតនៅក្នុងបរិបទ នៃការប្រជែងកម្លាំង រវាង គូបដិបក្ខ ភូមិសាស្ត្រ-នយោបាយ ខាងលើ នេះដែរ។ គឺជាការបាត់តុល្យភាពមួយដ៏ធំ ដែលធ្វើឲ្យបណ្ដាប្រទេសហត្ថលេខីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ឆ្នាំ ១៩៩១ មិនអាចទទួលយកបានឡើយ ។

# ការគាបសង្កត់ របស់ សហគមន៍ អន្តរជាតិ ទៅលើ លោក ហ៊ុន សែន ក្រោយ ព្រឹត្តិការណ៍ ថ្ងៃ ៥ កក្កដា ១៩៩៧

## La pression de la Communauté internationale après l'événement du 5 juillet 1997

ក្រោយព្រឹត្តិការណ៍ថ្ងៃ ៥ កក្កដាឆ្នាំ ១៩៩៧ សហគមន៍អន្តរជាតិ ធ្វើការគាបសង្កត់យ៉ាងខ្លាំងទៅលើលោក ហ៊ុន សែន ។ ការប្រយុទ្ធគ្នា រវាងកងទ័ព សហនាយករដ្ឋមន្ត្រី បដិបក្ខទាំងពីរ នៃ រាជរដ្ឋាភិបាល នៅកណ្ដាលទីក្រុងភ្នំពេញ និង នា អូរ ស្មាច់ បានបណ្ដាលឲ្យប្រជាជនខ្មែរ ម្រាណ ២ ម៉ឺន ៥ ពាន់នាក់ នាំគ្នារត់ទៅជ្រកកោន នៅ ត្រាត គឺ ខេត្តមួយស្ថិតនៅ ខាងត្បូងប្រទេសថៃ ហើយ ជាង ២ ម៉ឺននាក់ទៀត ប្រាលទៅដល់ជុំវិស្សូរិន ។ នៅថ្ងៃ ២៦ សីហា ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ បាន យាងពី ប៉េកាំងមកស្រុកខ្មែរវិញ ប៉ុន្តែព្រះអង្គទ្រង់ទៅគង់នៅខេត្តសៀមរាប ដោយមិនឆ្លងកាត់ទីក្រុងភ្នំពេញទេ ។ នៅសៀមរាប ព្រះអង្គទ្រង់ទទួល ការចូលគាល់ របស់ លោក ហ៊ុន សែន និង លោក អ៊ឹង ហួត ដែលជា សហនាយករដ្ឋមន្ត្រីថ្មី ជំនួស ព្រះអង្គម្ចាស់ រណឫទ្ធិ។ ដោយលោក ហ៊ុន





សែន ពុំព្រមផ្សះផ្សាវិញ ជាមួយព្រះអង្គម្ចាស់រណឫទ្ធិ ព្រះអង្គ ក៏ទ្រង់តែងតាំង អ្នកទាំងពីរនាក់នេះ ឲ្យតំណាងប្រទេសកម្ពុជា នៅអង្គការ សហប្រជាជាតិ។ ប៉ុន្តែនៅថ្ងៃ ១៩ កញ្ញា ឆ្នាំ ១៩៩៧ ដដែលនោះ គណកម្មការត្រួតពិនិត្យ របស់ អង្គការ សហប្រជាជាតិ ដែលមានអ្នកតំណាងសហរដ្ឋអាមេរិក អ្នកតំណាងប្រទេសចិន និង អ្នកតំណាង ប្រទេសរុស្ស៊ី ជាសមាសភាព បានសម្រេចដាក់អាសនៈ ប្រទេសកម្ពុជា នៅអង្គការ សហប្រជាជាតិឲ្យស្ថិតនៅទំនេរ ដូច្នេះវិញ។ សូមកត់សំគាល់បន្ថែមថា មួយថ្ងៃមុន សេចក្ដីសម្រេចនេះ របស់អង្គការ សហប្រជាជាតិ ភ្នាក់ងារនគរបាល ខ្មែរចំនួនជាង ១០០ នាក់ ដែលមាននិន្នាការទៅខាងព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិបាត់ខ្លួនរកមិនឃើញ ហើយ ៤ ថ្ងៃ មុនការសម្រេចនោះ គឺ នៅ ថ្ងៃ ១៦ កញ្ញា រដ្ឋសភាពុំព្រមអនុម័ត គម្រោងរៀបចំ គណរដ្ឋមន្ត្រីថ្មី ដែលលោក ហ៊ុន សែន បានស្នើឡើងនោះទេ ។ គឺជា វិធានការមួយ របស់ លោក ហ៊ុន សែន ដែលមានគោលដៅ ជម្រុះបក្សពួកព្រះអង្គម្ចាស់ រណឫទ្ធិ ចេញពីរដ្ឋាភិបាល។ មានតែ អ្នកតំណាងរាស្ត្រចំនួន ៦៧ រូបប៉ុណ្ណោះដែលបានបោះឆ្នោត យល់ព្រម ។ បើគិតតាមចំនួនជាកំហិត នៃអ្នកតំណាងរាស្ត្រដែល ចូលរួមអង្គប្រជុំ ដើម្បី អាចបើកអង្គប្រជុំបាន (ចំនួន ២ ភាគ ៣) គឺ ឃើញថាខ្វះ ១៣ សំឡេងទៀត ។ នៅពេលនោះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និង លោក ប្រធានរដ្ឋសភា ជា ស៊ីម បានប្រជុំគ្នា ដើម្បីពិនិត្យមើល ស្ថានការណ៍ ព្រោះ ម្ដងនេះ រដ្ឋសភា ប្រកាន់ជំហរមួយដ៏រឹង មិនធ្លាប់ដែលមានសោះ ពីពេលមុន ។

នៅទីបំផុត គេបានសម្រេចបោះឆ្នោត ផ្ដល់ការទុកចិត្ត ទៅឲ្យ លោក អ៊ឹង ហួត និងការដកអភ័យឯកសិទ្ធិ ពី ព្រះអង្គម្ចាស់ន នរោត្តម រណឫទ្ធិ ដោយ វិធីលើកដៃ ។ ទោះជាយ៉ាងណាក៏ដោយ ក៏អង្គការ មូលនិធិ រូបិយវត្ថុ អន្តរជាតិ (FMI) និង ធនាគារពិភពលោក ( Banque mondiale) បាន សម្រេចលុបចោល ឬ ពន្យាពេល កម្មវិធី ផ្ដល់ជំនួយចំនួន ១២០ លាន ដុល្លារ ទៅឲ្យកម្ពុជាដែរ។ មួយវិញទៀត អង្គការ ហិរញ្ញវត្ថុ អន្តរជាតិទាំងពីរនេះ មានការបារម្ភខ្លាចក្រែងមាន ការកិបកេងប្រាក់ ដែលបានមក ពីការលក់ព្រៃឈើផងទៀត។ រីឯ គម្រោងការ ឲ្យប្រទេសកម្ពុជា ខ្ចីប្រាក់ សម្រាប់រៀបចំហេដ្ឋារចនាសម្ព័ន្ធ ក៏ត្រូវទុកចោលសិនដែរ ។ បន្ទាប់ពី ការបាត់វិធានការនេះ របស់អង្គការ មូលនិធិ

រូបិយវត្ថុ អន្តរជាតិ និង ធនាគារ ពិភពលោក ប្រទេសកម្ពុជាទាំងមូល មានការតក់ស្លុតយ៉ាងខ្លាំង។ ចំពោះលោក ហ៊ុន សែន វិញ បញ្ហាចំពោះមុខ ដែលលោកបារម្ភជាងគេ គឺការបោះឆ្នោតសកាឆ្នាំ ១៩៩៨ ព្រោះពេលវេលាកាន់តែខិតជិតមកដល់ ។ នៅក្នុងសន្និសីទមួយនា ថ្ងៃ ២៤ កញ្ញានៅទីក្រុងប៉ារីស៍ លោកនាយករដ្ឋមន្ត្រីខ្មែរ ហ៊ុន សែន បានព្រមានដល់អង្គការ សហប្រជាជាតិ អំពី ការដែល អង្គការ អន្តរជាតិនេះ អាច នឹងប្រើតួនាទី របស់គេនៅក្នុងការបោះឆ្នោត ឆ្នាំ ១៩៩៨ ។ លោក ហ៊ុន សែន បានចោទសួរថា តើ អង្គការសហប្រជាជាតិ បំពេញតួនាទី របស់គេ តាមបែបណាដែរ បើអាសនៈកម្ពុជា នៅអង្គការ សហប្រជាជាតិនៅទំនេរដូច្នេះនោះ ? ការគាបសង្កត់ របស់ សហគមន៍ អន្តរជាតិ មានជាច្រើនទៀត តាមរូបភាពផ្សេងៗ ។

# ការរៀបជើងព្រួល

# បោះឆ្នោត សកា សម្រាប់ នីតិកាលទី ២

## Préparation des législatives pour la 2ème législature

ការប្រយុទ្ធគ្នា រវាង គណបក្សរាជានិយម «ហ្វុនស៊ីនប៉េច» និង គណ បក្ស «ប្រជាជន» ពោលគឺ អតីតគណបក្សកុម្មុយនិស្តខ្មែរ នៅឆ្នាំ ១៩៩៧ បាន ស ឲ្យឃើញថាការប្រជែងកម្លាំងគ្នា រវាង ក្រុមបដិបក្ខទាំងពីរ គ្មានចាញ់ គ្មាន ឈ្នះ ថ្វីត្បិតតែលោក ហ៊ុន សែន បានសម្រេចធ្វើឲ្យព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ចាកចេញពីប្រទេសក៏ដោយ ។ នៅទីបំផុត ដោយមាន ការគាបសង្កត់ ពីអន្តរជាតិ និង ពី បណ្តាប្រទេស នៅក្នុងតំបន់ហើយ ជាពិសេស ពីអង្គការ ហិរញ្ញវត្ថុអន្តរជាតិ ព្រះអង្គម្ចាស់ រណឫទ្ធិ បានវិលត្រឡប់មកក្នុងឆាក នយោបាយវិញ។ ជាការពិតហើយដែលថា គណបក្ស «ប្រជាជន» នៅតែក្តាប់ប្រទេសកម្ពុជា បន្តមកទៀត ប៉ុន្តែបើគ្មានការទទួលស្គាល់និងជំនួយប្រាក់កាស ពីសហគមន៍





អន្តរជាតិទេ លោក ហ៊ុន សែន ក៏ពុំអាចធ្វើអ្វីតែម្នាក់ឯងបានដែរ។ ម៉្យាងទៀត ការប៉ះពាល់ដល់ របបប្រជាធិបតេយ្យ សេរីពហុបក្ស ដែលមានចែងយ៉ាងច្បាស់ ក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ក៏ នឹងអាចធ្វើឲ្យស្ថានភាពនៅក្នុង ប្រទេសកម្ពុជា ក្រឡាប់ចាក់ដែរ ដោយហេតុថា រដ្ឋធម្មនុញ្ញនោះ ជាការធា   ធានាមួយ ដ៏ធំសម្រាប់ឲ្យប្រទេសកម្ពុជា អាចមាន ទំនាក់ទំនងល្អ ត្រឹមត្រូវ ជាមួយ សហគមន៍ អន្តរជាតិ ។ ពិតមែនតែ រដ្ឋធម្មនុញ្ញនេះ បានត្រូវរំលោភជា បន្តបន្ទាប់ ក៏អង្គការ សហប្រជាជាតិសុខចិត្តបិទភ្នែកសិនដែរ ព្រោះតែប្រទេសធំៗដែលជាប់ពាក់ព័ន្ធ ក្នុងវិបត្តិខ្មែរ ប្រញាប់ដកខ្លួនគេ ចេញពីអធិករណ៍នេះ ។ ទោះជាយ៉ាងនេះក្តីការរំលោភជាញឹកញាប់ពេក ក៏អាចប នឹងបណ្តាលឲ្យប្រទេសធ្លាក់ ក្នុងវិបត្តិចាស់ សាជាថ្មីទៀតដែរ។ គេសង្កេតឃើញថា ការប្រជែងកម្លាំងនៅក្នុងតំបន់ ជាកត្តាមួយ ដែលអាចជំរុញឲ្យប្រទេសកម្ពុជា ធ្លាក់ ទៅក្នុងភាពប្របូកប្របល់ អនាធិបតេយ្យ ឬ ក៏របបផ្តាច់ការ តែម្តងក៏អាចថាបាន។ ប្រការដែលគួរឲ្យកត់សំគាល់ គឺថា ការផ្សះផ្សារវាង ភាគីបដិបក្ខនានា បានទទួលបរាជ័យទាំងស្រុង ព្រោះតែគេពុំព្រមយក ការបោះឆ្នោត ធ្វើជាមូលដ្ឋាន នៃ ការដោះស្រាយបញ្ហា។ គណបក្ស «ប្រជាជន» ពុំព្រមដកថយ ពីអំណាច ជាដាច់ខាត ទោះនៅក្នុងករណីណាក៏ដោយ គឺ ទោះជាទទួលបរាជ័យ នៅក្នុងការបោះឆ្នោតក្តី ។ បើពិនិត្យមើលយុទ្ធសាស្ត្រ នយោបាយ របស់ គណបក្ស «ប្រជាជន» គេសង្កេតឃើញថា គណបក្សនេះគោរពច្បាប់ពាក់កណ្តាល មិនគោរពពាក់កណ្តាល ជាហេតុ ធ្វើឲ្យមាន ការពិបាកចាប់ថ្នាក់ពន់ពេកក្រៃ ជា ពិសេស នៅក្នុងប្រទេសមួយ ដែលវប្បធម៌ និទណ្ឌភាព បានយកឈ្នះទៅលើ គាលការណ៍ នីតិរដ្ឋបាន ។

ទោះជា គោរពច្បាប់ ឬមិនគោរពក្តី ការបោះឆ្នោតសកា នៅតែស្ថិត នៅជាប្រកែតមួយ សម្រាប់ ឲ្យគណបក្សទាំងពីរនេះ តតាំងគ្នាបន្ត ទៅទៀត ។ បើបោះបង់ចោល នូវគោលការណ៍នេះ ក៏ឃើញថា គ្មានគណបក្ស ណាមួយ អាចយកចំណេញ បានទេ។ ម៉្យាងទៀត បើគេចេញមុខ ប្រយុទ្ធគ្នា តាមផ្លូវ អាវុធ ក៏បានត្រឹមខាត ទាំងចុង ទាំងដើមតែប៉ុណ្ណោះ ព្រោះគ្មានប្រទេស ជា មិត្តណា គេហ៊ានរំលោភ គោលការណ៍ សន្និសីទអន្តរជាតិ ទីក្រុងប៉ារីស៍ ឆ្នាំ ១៩៨៩ និង កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ ឆ្នាំ ១៩៩១

ឡើយ ។ គឺនៅ ក្នុងន័យនេះហើយ ដែលគណបក្សរាជានិយម «ហ្វុនស៊ីនប៉ិច» បានចង សម្ព័ន្ធភាព ជាមួយ គណបក្ស «ជាតិខ្មែរ» របស់ លោក សម រង្ស៊ី និង គណបក្ស «ប្រជាធិបតេយ្យសេរីនិយម ពុទ្ធសាសនា» របស់លោក សឺន សាន ។ រីឯគណបក្ស «ប្រជាជន» គេ ក៏ចងសម្ព័ន្ធភាពជាមួយក្រុមមួយទៀត របស់ គណបក្សចុងក្រោយនេះដែរ គឺ ក្រុមដែលដឹកនាំដោយលោក អៀង មូលី។ ដើម្បីយកសំឡេងឲ្យបានច្រើនថែម ទៀត គណបក្ស «ប្រជាជន» បានចងសម្ព័ន្ធ ភាពជាមួយគណបក្ស «មូលីណាកា» [៥៣] និង គណបក្សចំនួន ៨ ទៀត ដែល កាលពីនីតិកាល ទី ១ គ្មាន អ្នកតំណាង នៅក្នុងរដ្ឋសភា ។ គណបក្ស ២ ក្នុង ចំណោមគណបក្ស ទាំង ៨ នោះ មាននិន្នាការ សាធារណរដ្ឋនិយម។ នៅពេល នោះ ព្រោះតែមានចរន្ត អ្នកសាធារណរដ្ឋនិយម នៅក្នុងសម្ព័ន្ធភាព របស់ គណបក្ស «ប្រជាជន» ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ ទ្រង់បានគំរាមថា នឹង ដាក់រាជ្យតែម្តង ។

## ទីអវសាន នៃ ចលនា ខ្មែរក្រហម នៅឆ្នាំ ១៩៩៧-១៩៩៨

## La fin du Mouvement khmer rouge en 1997 – 1998

មុនការបោះឆ្នោតសភា នីតិកាលទី ២ ដែលគ្រោងធ្វើនៅថ្ងៃ ២៦ កក្កដា ឆ្នាំ ១៩៩៨ មានព្រឹត្តិការណ៍សំខាន់ ៣ គួរឲ្យកត់សំគាល់។ ព្រឹត្តិការណ៍ទី ១ គឺ ការវាយកំទេចមូលដ្ឋានពួកខ្មែរក្រហម នៅអន្លង់វែង ដោយរាជរដ្ឋាភិបាល និងកម្លាំងកងទ័ព របស់ អៀង សារី រួមគ្នា។ ព្រឹត្តិការណ៍ ទី ២ គឺ មរណភាព របស់ ប៉ុល ពត នៅថ្ងៃ ១៥ មេសា ឆ្នាំ ១៩៩៨ ហើយ ព្រឹត្តិការណ៍ ទី ៣ គឺ ការវិលមកស្រុកខ្មែរវិញ របស់ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ

[៥៣] MOULINAKA : ចលនា រំដោះជាតិ ខ្មែរ ។





នៅថ្ងៃ ៣០ មិនា បន្ទាប់ពីបានត្រូវនិរទេសខ្លួន អស់រយៈពេល ជិតមួយឆ្នាំ ។ មួយឆ្នាំមុន មរណភាព របស់ ប៉ុល ពត គឺ នៅ ឆ្នាំ ១៩៩៧ ពួកមេដឹកនាំខ្មែរក្រហម បែក បាក់គ្នាអស់ ហើយចលនាខ្មែរក្រហម ទាំងមូលស្ថិតនៅក្នុងភាពច្របូកច្របល់ មួយដែលបញ្ជាក់ថា ចលនាកុម្មុយនិស្តខ្មែរ ដ៏ល្បីល្បាញនេះ បានឈានមកដល់ ទីអវសាន ។

ដូចយើងបានដឹង ខ្លះៗ រួចមកហើយ នៅខែសីហាឆ្នាំ ១៩៩៦ អៀង សារី ដែលជាមេខ្មែរក្រហម លំដាប់ថ្នាក់ ទី ២ បន្ទាប់ពី ប៉ុល ពត ហៅ «បងទី ១» ហើយដែលបានធ្វើបដិវត្តន៍ ជាមួយគ្នា សឹង កន្លះសតវត្ស មកហើយ បានផ្តាច់ខ្លួន ចេញពី ប៉ុល ពត ហើយ មកចងសម្ព័ន្ធភាពជាមួយលោក ហ៊ុន សែន វាយកំទេចពួក ប៉ុល ពត នៅអន្លង់វែង បែកបាក់ខ្ចាត់ខ្ចាយអស់ ។ មុននឹងត្រូវរលាយបាត់ទៅ ក្រុមខ្មែរក្រហមនៅអន្លង់វែង មានការប្រេះឆាផ្ទៃ ក្នុងមួយដ៏ធំ រួចស្រេចទៅហើយ។ នៅខែមិថុនា ឆ្នាំ ១៩៩៧ មេដឹកនាំខ្មែរក្រហម ២ នាក់ នៅអន្លង់វែង គឺ សុន សេន និង តាម៉ុក បានត្រូវក្រុមគ្រួសារ និងបក្សពួក របស់គេ ដែលបានរត់ ទៅចូលក្នុងជួរ រាជរដ្ឋាភិបាលបញ្ចុះបញ្ចូល ឲ្យសុំចុះចូលរាជរដ្ឋាភិបាល ដូចពួកគេដែរ។ ដោយបានដឹងអំពីរឿងនេះ ប៉ុល ពត ក៏បញ្ជា ឲ្យគេសម្លាប់ សុន សេន ដែលជា មេបញ្ជាការ កងទ័ពរបស់ខ្លួន ព្រមទាំងក្រុមគ្រួសារទាំងអស់ របស់ សុន សេន ចំនួន ១១ នាក់ ។ ប៉ុន្តែ បន្ទាប់ពី បានសម្លាប់ សុន សេន និង ក្រុមគ្រួសាររបស់គេរួចមក ប៉ុល ពត និង ក្រុមដែលស្មោះត្រង់ នឹង ប៉ុល ពត បានត្រូវ តាម៉ុក យកទៅដាក់ឃុំឃាំង រួចយក ប៉ុល ពត ទៅកាត់ទោសនៅ ខែកក្កដា ឆ្នាំ១៩៩៧ ។ នៅពេលនោះ តាម៉ុក ដែលជាមេខ្មែរក្រហមម្នាក់ល្បីល្បាញ ខាងការប្រព្រឹត្តិ អំពើកាចសាហាវព្រៃផ្សៃ ក៏ ចាប់ផ្តើមកាន់កាប់មូលដ្ឋាន អន្លង់វែង តែម្នាក់ឯង ។ អ្នកណា ក៏ ខ្លាចតាម៉ុកនេះដែរ ព្រោះឲ្យតែអ្នកណា ធ្វើឲ្យគាត់ទាស់ចិត្ត គាត់យកទៅធ្វើទារុណកម្ម រួចសម្លាប់ចោល ដោយឥតអាសូរ។ ដោយទ្រាំមិនបាន ពួកខ្មែរក្រហម ក៏នាំគ្នា បះបោរប្រឆាំង ហើយ រត់ចូលរាជរដ្ឋាភិបាលតែម្តង។ នៅទីបំផុត តាម៉ុកបានត្រូវរាជរដ្ឋាភិបាល ចាប់ខ្លួនបាន។ មុន នឹង ឈានមកដល់ការ រលំរលាយនៅឆ្នាំ ១៩៩៨ ចលនា ខ្មែរក្រហម បានឆ្លងកាត់ ដំណាក់ការ ជា

ច្រើនៗ កាលដើមឡើយ គឺជាចលនា របស់ខ្មែរ កុម្មុយនិស្តមួយក្រុម ដែលបានកកើតឡើង ដោយសារការឧបត្ថម្ភ របស់ បក្សកុម្មុយនិស្ត វៀតណាម ។

នៅក្នុងជំពូក ជាបន្តបន្ទាប់ទៅនេះ ខ្ញុំ សូមលើកឡើង អំពី ប្រវត្តិ ពិស្តារ នៃចលនា ខ្មែរក្រហមនេះ ដើម្បីរក្សាទុក ជាឯកសារ តរៀងទៅ ។

## ប្រវត្តិ នៃ ចលនាខ្មែរក្រហម ពីឆ្នាំ ១៩៥៣ ដល់ឆ្នាំ ១៩៩៨

### Le Mouvement khmer rouge de 1953 à 1998

នៅឆ្នាំ ១៩៥៣ នៅពេលដែល សាឡុត ស ហៅ ប៉ុល ពត ត្រឡប់ មកពីស្រុកបារាំងវិញ គេបានចូលទៅបម្រើ ចលនា កុម្មុយនិស្តខ្មែរមួយក្រុម តាមរយៈ ចលនា កុម្មុយនិស្តវៀតណាម។ កាលដើមឡើយ ចលនា កុម្មុយនិស្តខ្មែរនោះ ដែលបានត្រូវបង្កើតឡើងដោយ ចលនា យួនវៀតមិញ មានឈ្មោះថា «បក្សប្រជាជនបដិវត្ត កម្ពុជា»[៥៤] ដោយមាន សឺង ង៉ុក មិញ ជាប្រធាន និង ទូ សាមុត ជាអនុប្រធាន ។ នៅបណ្តាឆ្នាំ ៥០-៦០ ចលនានោះ ពុំសូវមានសកម្មភាពអ្វី គួរឲ្យចាប់អារម្មណ៍ប៉ុន្មានទេ ប៉ុន្តែក្រោយមក ដោយមាននិស្សិត បញ្ញវន្តជាច្រើន ចូលរួមចំណែក ក្រុមខ្មែរកុម្មុយនិស្តនោះ ក៏ មានសកម្មភាពនៅក្នុងទំហំ នយោបាយមួយ ដ៏ធំ ។ និស្សិតខ្មែរនៅស្រុកបារាំង ដែលមានសញ្ញាបត្រ ធំៗ បានប្រែក្លាយ ចលនានោះ ឲ្យទៅជា ចលនា នយោបាយមួយ ដែលធ្វើឲ្យ ស្តេច នរោត្តម

[៥៤] ការកំណត់ថ្ងៃកំណើត បក្សនេះ ពោលគឺថ្ងៃ បើកមហាសន្និបាត ទី ១ មាន ការខ្វែងគំនិតគ្នា នៅក្នុងជួរ ជនកុម្មុយនិស្តខ្មែរៗ ខ្លះថាថ្ងៃ ១៩ កុម្ភៈ ១៩៥១ ខ្លះថា ថ្ងៃ ២៨ មិថុនា ឆ្នាំ ១៩៥១ ខ្លះទៀតថា ថ្ងៃ ៣០ កញ្ញាឆ្នាំ ១៩៥១ ។





សីហនុ មានកង្វល់ យ៉ាងខ្លាំង ។ នៅ ខែកក្កដា ឆ្នាំ ១៩៦២ ស្រាប់តែ ទូ សាមុត ត្រូវបាត់ខ្លួននៅក្នុងភាពដ៏អាថ៌កំបាំង ។ ខ្លះថាត្រូវ ប៉ូលីស របស់ ស្តេច សីហនុ ចាប់ ប៉ុន្តែ ឯកសារខ្លះធ្វើការសន្និដ្ឋានថា បានត្រូវ ប៉ុល ពត សម្លាប់ ចោលតែម្តង ។ រីឯមូលហេតុដែលគេបានយកមកសំអាង គឺ ការវិវាទរវាង ជនកុម្មុយនិស្តខ្មែរ និង យួនៗ យោងទៅតាម និក្ខេបបទនេះ ប៉ុល ពត ប្រហែលជាសម្លាប់ ទូ សាមុត ព្រោះតែ ទូ សាមុត មានជំនឿទៅលើការដឹកនាំ របស់ វៀតណាម។ ប៉ុល ពត និងក្រុម របស់គេ ស្អប់វៀតណាមណាស់ ហើយ ប៉ុល ពត ខ្លួនឯង ចង់ក្លាយខ្លួនទៅ ជាមេដឹកនាំ បដិវត្តន៍ កុម្មុយនិស្តខ្មែរ ដាច់ស្រឡះចេញពីវៀតណាមតែម្តង។ សូមកត់សំគាល់ថា នៅឆ្នាំ ១៩៦០ «បក្សប្រជាជន បដិវត្ត កម្ពុជា» (P.P.R.K.) បានប្រែឈ្មោះមកជា «បក្សពលករកម្ពុជា» (P.T.K.) ហើយក្រោយមកទៀត គឺ នៅខែកញ្ញាឆ្នាំ ១៩៦៦ បានប្រែឈ្មោះពី «បក្សពលករ កម្ពុជា» មកជា «បក្សកុម្មុយនិស្តកម្ពុជា» (P.C.K.) តែម្តង។ អ្វីដែលគេបានដឹងច្បាស់ គឺនៅពេលដែល ប៉ុល ពត សម្រេចប្តូរឈ្មោះពី «បក្សពលករកម្ពុជា» មកជា «បក្សកុម្មុយនិស្តកម្ពុជា» ប៉ុល ពត បានសម្រេចចូលក្នុង ចលនា កុម្មុយនិស្ត របស់ ចិន ដែលប្រឆាំង នឹង ចលនា កុម្មុយនិស្តវៀតណាម ព្រោះតែ វៀតណាម យក សហភាព សូវៀត ជាបង្អែក។ ទំនាស់ រវាង បងប្អូនកុម្មុយនិស្តទាំង ២ នេះ មានទំហំធំណាស់ បន្ទាប់ពីចិន ទាស់នឹង សហភាព សូវៀត តាំងពី ឆ្នាំ ១៩៥៩ មក។ នៅខែមេសាឆ្នាំ ១៩៧៥ ពួកកុម្មុយនិស្តខ្មែរ មហាជាតិនិយម ទាំងនេះ ដែលបានត្រូវសម្តេច នរោត្តម សីហនុឲ្យឈ្មោះថា «ខ្មែរក្រហម» បានវាយរំលំរបប «សាធារណរដ្ឋខ្មែរ» របស់ ឧត្តមសេនីយ៍ លន់ នល់ និង សិរិមតៈ ហើយ ឡើងកាន់អំណាច គ្រប់គ្រងស្រុកខ្មែរអស់រយៈពេលជាង ៣ ឆ្នាំ ។ នៅក្រោមរបបនេះ ដែលអ្នកដឹកនាំ ទាស់ទែងគ្នា ព្រោះតែការបែងចែក រវាង អ្នកមាននិន្នាការ ទៅខាងចិន និង អ្នកមាននិន្នាការទៅខាងវៀតណាម ប្រជាជនខ្មែរជិត ២ លាននាក់ បានត្រូវពួកនេះ ធ្វើទារុណកម្ម យ៉ាងព្រៃផ្សៃរហូត ដល់បាត់បង់ជីវិត។ នៅខែ មករាឆ្នាំ ១៩៧៩ កងទ័ព វៀតណាម បានចូលមកលុកលុយស្រុកខ្មែរ ហើយវាយរំលំ របប ប៉ុល ពត ចោលបាត់ទៅ ។ កងទ័ព ខ្មែរក្រហមក្រោមបញ្ជាការ របស់ ប៉ុល ពត បានរួបរួមគ្នា ជា ចលនា រំដោះ ប្រទេសកម្ពុជា ពីការ

ត្រួតត្រា របស់ វៀតណាម ហើយក្រោយអន្តរាគមន៍ របស់អង្គការ សហប្រជាជាតិ នៅឆ្នាំ ១៩៩២ ក៏បាក់បែកគ្នាអស់ព្រោះពួកគេ ពុំព្រមអនុវត្ត កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍។

## ចលនាខ្មែរក្រហមក្រោមការដឹកនាំ របស់ ប៉ុល ពត

មែកធាងមួយ នៃចលនា ខ្មែរកុម្មុយនិស្ត ដែលសាឡុត សរ ហៅ ប៉ុល ពត បានចាប់ផ្តើមកសាង នៅខែ កុម្ភៈឆ្នាំ ១៩៦៣ បានត្រូវរលំរលាយទៅវិញ ៣៤ ឆ្នាំក្រោយមក នៅខែមិថុនា ឆ្នាំ ១៩៩៧ បន្ទាប់ពី ប៉ុល ពត បានបញ្ជា ឲ្យគេសម្លាប់ សុន សេន ដែលជារដ្ឋមន្ត្រីទទួលបន្ទុកខាងកងទ័ព។ កាលនោះ ប៉ុល ពត បានមកតាំងទីនៅអន្លង់វែង។ នៅ ខែសីហា ឆ្នាំ ១៩៩៦ អៀង សារី បានផ្តាច់ខ្លួនចេញពី ប៉ុល ពត ហើយ ចងសម្ព័ន្ធភាពជាមួយ រាជរដ្ឋាភិបាល វាយកំទេច មូលដ្ឋាន អន្លង់វែង របស់ ប៉ុល ពត។ នៅថ្ងៃ ២៥ កក្កដាឆ្នាំ ១៩៩៧ តាម៉ុក មេខ្មែរក្រហមម្នាក់ទៀត ដែលជាសហការី របស់ ប៉ុល ពត តាំងពីឆ្នាំ ១៩៩៦៣ មក [៥៥] បានយក ប៉ុល ពត ទៅកាត់ទោស។ នៅទីបំផុត ប៉ុល ពត ទទួលមរណភាព នៅថ្ងៃ ១៥ មេសាឆ្នាំ ១៩៩៨ នៅក្នុងស្ថាន ភាពមួយ ដ៏គួរឲ្យកត់សំគាល់ គឺត្រូវមិត្តភក្តិ ខ្មែរក្រហមដូចគ្នា បោះបង់ចោលហើយ យកសព ទៅដុតចោលលើ គំនរកៅស៊ូកង់ឡាន។ គ្មានខ្មែរក្រហមណាម្នាក់ រវល់យកចិត្តទុកដាក់អ្វីទាំង អស់ក្រៅពីប្រពន្ធក្មេងទី ២ របស់ ប៉ុល ពត ។

នៅឆ្នាំ ១៩៦៣ សាឡុត សរ ហៅ ប៉ុល ពត បានដណ្តើម ចង្កូត «បក្សពលករកម្ពុជា» គឺ នៅពេលដែល «បក្សប្រជាជនបដិវត្តកម្ពុជា» បើក មហាសន្និបាត ប្តូរឈ្មោះមក

[៥៥] តាម៉ុក បានចូលជា សមាជិក មជ្ឈិមបក្ស នៅពេលបើក មហាសន្និបាត «បក្សពលករកម្ពុជា» នៅថ្ងៃ ២០-២១ កុម្ភៈឆ្នាំ ១៩៩៦៣ ។ គឺ នៅពេលនោះ ហើយដែល ប៉ុល ពតឡើងធ្វើជាលេខាបក្ស ដោយឥតឆ្លងកាត់ ការបោះឆ្នោត ជ្រើសតាំង។ សមាជិកមជ្ឈិមបក្សកាលនោះ មានជាអាទិ៍ ៖ សោ ភឹម, អៀង សារី, នួន ជា និង វន វេត។





ជា «បក្សពលករ កម្ពុជា» ។ ប៉ុល ពត ឡើងកាន់ មុខតំណែង ជា អគ្គលេខាធិការបក្សជំនួស ទូ សាមុត ដោយគ្មាន ការជ្រើស តាំងតាំង ឬ តែងតាំងអ្វីទាំងអស់ ។ តាមការពិតគឺ សោ ភឹម ទេ ដែល ត្រូវទទួលមុខតំណែងនេះ នៅពេលដែល ទូ សាមុត បាត់ខ្លួននៅថ្ងៃ ២០ កក្កដា ឆ្នាំ ១៩៦២ ។ នៅខែកុម្ភៈឆ្នាំ ១៩៦៣ បន្ទាប់ពីឡើងកាន់តួនាទី ជា លេខាបក្ស ប៉ុល ពត បានបង្កើត ការិយាល័យ នយោបាយមួយ ដែលមាន អៀង សារី, នួន ជា, សោ ភឹម និង វន វេត ជា សមាជិក ។ គឺ នៅពេលនោះដែរដែល តាម៉ុក ចូលជាសមាជិកគណមជ្ឈិម ។ តាំងពីឆ្នាំ ១៩៦៣ នោះមក បក្សកុម្មុយនិស្តខ្មែរ មានទំនាស់មួយ ដ៏ធំ ប៉ុន្តែដោយមិនចេញមុខ រវាងអ្នកដែលបាន ទទួលការបំពាក់បំប៉ននយោបាយ និងមនោគមវិជ្ជាពីទីក្រុងហាណូយ នឹង ពួកអ្នកកុម្មុយនិស្តខ្មែរ ជាតិនិយម ដែលមាន ចិន ជាបង្អែក ហើយដែលដក ខ្លួន ចេញបន្តិចម្តងៗ ពី ការដឹកនាំ របស់ ទីក្រុងហាណូយ ។ អ្នកដែលមានជំនឿទៅលើយុទ្ធសាស្ត្រ របស់ វៀតណាមជាច្រើន បានបាត់ខ្លួន ជាបន្តបន្ទាប់តាំង ពីពេលនោះមក។ នៅខែកញ្ញាឆ្នាំ១៩៦៦ បន្ទាប់ពី ត្រឡប់មក ពីប្រទេសចិន និង ពីប្រទេសវៀតណាមវិញ តាមផ្លូវលំ ហូ ជីមិញ ពេលដែលមកដល់ ការិយាល័យលេខ ១០០ នៅក្រូចឆ្មារភ្លាម ប៉ុល ពត បានប្តូរឈ្មោះ «បក្សពលករ កម្ពុជា» មកជា «បក្សកុម្មុយនិស្តកម្ពុជា» តែម្តង ។

នៅខែមេសាឆ្នាំ ១៩៧៥ គឺ ១២ ឆ្នាំក្រោយមក ពួកខ្មែរក្រហម ដឹកនាំដោយ ប៉ុល ពត បានវាយរំលំ របប «សាធារណរដ្ឋខ្មែរ» ដឹកនាំដោយ ឧត្តមសេនីយ៍ លន់ នល់ និងអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ។ នៅថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ នោះ ខ្មែរក្រហម ចូលមកដល់ទីក្រុងភ្នំពេញ ហើយ ដេញប្រជាជន ឲ្យចេញអស់ គ្មានសល់ពីទីក្រុង។ ទោះបីមានទំនាស់ផ្ទៃក្នុង ដ៏ខ្លាំងក្លាក្តី ខ្មែរក្រហម គ្រប់គ្រង ប្រទេសកម្ពុជា អស់រយៈពេល ជាង ៣ ឆ្នាំ ក្រោមឈ្មោះថា «ប្រទេសកម្ពុជាប្រជាធិបតេយ្យ» ហើយដែលខ្មែរក្រហមហៅថា «អង្គការ» ពោលគឺ គ្មានអ្វី ក្រៅពី «បក្សកុម្មុយនិស្តកម្ពុជា» ដឹកនាំដោយ ប៉ុល ពត នោះ ឡើយ។ នៅឆ្នាំ ១៩៧៨-៧៩ កងទ័ពវៀតណាម ដែលមានបង្អែកដ៏មាំ ពីសហភាព សូវៀត បានចាប់ផ្តើមវាយរំលំ របប កម្ពុជា បជាធិបតេយ្យ របស់ ប៉ុល ពត ដែលមានចិនជាបង្អែក ហើយ បានទទួលជ័យជំនះ នៅថ្ងៃ ៧ មករាឆ្នាំ ១៩៧៩ ។ នៅក្រោម របប ខ្មែរក្រហម

ដឹកនាំដោយ ប៉ុល ពត គឺ នៅចន្លោះថ្ងៃ ១៧ មេសាឆ្នាំ ១៩៧៥ នឹង ថ្ងៃ ៧ មករាឆ្នាំ ១៩៧៩ ប្រជាជនខ្មែររស់ នៅក្នុងទុរ្ភិក្ស ក្នុងការភិតភ័យ ត្រូវគេយកទៅធ្វើទារុណកម្មសម្លាប់ចោល សឹង ជារៀងរាល់ថ្ងៃ។ ប្រជាជនស្លូតត្រង់ ដែលបាត់បង់ជិវិត នៅក្នុងរបបនេះ មាន ចំនួន ប្រមាណជិត ២ លាន នាក់។ ភាគច្រើន នៃ អ្នកទាំងនេះ បានត្រូវពួកខ្មែរក្រហមយក ទៅធ្វើទារុណកម្ម យ៉ាងព្រៃផ្សៃ មុននឹង យកទៅសម្លាប់ ដោយ វាយ នឹងត្បូងចប។ មាគ៌ា នយោបាយ របស់ ប៉ុល ពត នៅពេលឡើងកាន់ អំណាច បាននាំមកនូវការ កាប់សម្លាប់ ប្រជាជនឯង ដោយឥតធម៌មេត្តា អ្វី បន្តិចបន្តួចឡើយ។ រីឯ បក្សកុម្មុយនិស្ត របស់គេ ក៏ ទាស់ទែងបែកបាក់គ្នាដែរ។ ឃាតកម្មកម្មាភិបាល មានតាំង ពីថ្នាក់លើ រហូតដល់ថ្នាក់ក្រោម ពោលគឺ តាំង ពី គណមជ្ឈិម រហូតដល់ ប្រធានភូមិ ។ នៅឆ្នាំ ១៩៧៨ កម្មាភិបាលខ្មែរ ក្រហម បាននាំគ្នាងើបឡើង បះបោរ ប្រឆាំង នឹង ប៉ុល ពត ។ ប៉ុន្តែទាល់តែកងទ័ព វៀត ណាម ចាប់ផ្តើមវាយចូលមក ក្នុងស្រុកខ្មែរ តែម្តង ទើបពួក ប៉ុល ពត បែកបាក់ខ្ចាត់ខ្ចាយ រត់ចោលស្រុកអស់ ។ នៅពេលវាយលុកចូល មកក្នុងស្រុកខ្មែរ កងទ័ពវៀតណាម បាន បង្កើត «បក្សប្រជាជនបដិវត្ត កម្ពុជា» ឡើងវិញ ដោយមាន លោក ហេង សំរិន និង លោក ប៉ែន សុវណ្ណ ជាអ្នកដឹកនាំ ។ សូមបញ្ជាក់ឡើងវិញថា ការដែលបក្សកុម្មុយនិស្តខ្មែរ បែកជាពីរដូច្នេះ គឺ មកពីមានទំនាស់ រវាង បដិវត្តន៍ចិន នឹង បដិវត្តន៍ វៀតណាម ដែល មាន សហភាព សូវៀតជាមេកើយ។ ប៉ុន្តែ នៅពេលដែល សហភាព សូវៀត រលំរលាយ ទៅ ទីក្រុងប៉េកាំង និង សហរដ្ឋអាមេរិក ដែលជាសត្រូវ នឹងសហភាព សូវៀត បានតម្លើង ពួកប៉ុលពតឡើងវិញ ដើម្បីពួតដៃ ជាមួយ ពួករាជានិយម និង អ្នកប្រជាធិបតេយ្យខ្មែរ វាយដេញកងទ័ពវៀតណាមចេញពីស្រុកខ្មែរ ។ នៅទីបំផុត ដោយអស់បង្អែក វៀតណាម ត្រូវបង្ខំចិត្ត ដកកងទ័ពចេញពីស្រុកខ្មែរ។ ប៉ុន្តែ ក្រោយអន្តរាគមន៍ របស់ អង្គការ សហប្រជាជាតិ នៅឆ្នាំ ១៩៩២-១៩៩៣ ភាគីខ្មែរក្រហមដឹកនាំដោយ ប៉ុល ពត បានត្រូវភាគីខ្មែរ ផ្សេងៗទៀត ទាត់ ចោល នៅទីបំផុត ព្រោះរបប ខ្មែរក្រហម នៅចន្លោះឆ្នាំ ១៩៧៥-១៩៧៩ បាន ត្រូវ សកលលោកទាំងមូល ថ្កោលទោស ហើយ ទាមទារឲ្យយកទៅកាត់ទោស ពីបទ ប្រល័យមនុស្សជាតិ ។



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

# ការបោះឆ្នោតសភា នៅ ខែកក្កដា ឆ្នាំ ១៩៩៨

## Les législatives de Juillet 1998

ការបោះឆ្នោតសភានីតិកាលទី ២ ដែលប្រព្រឹត្តទៅនៅថ្ងៃ ២៦ កក្កដា ឆ្នាំ ១៩៩៨ បានត្រូវមជ្ឈដ្ឋានខ្លះ និង ប្រទេសមហាអំណាច មួយចំនួន ចាត់ទុកថា មាន លក្ខណៈល្អ ប្រសើរ ទោះបី មិនល្អដល់ ១០០ %ក្តី។ អ្នកដែលចូលរួម ក្នុងការបោះឆ្នោត មានរហូត ដល់ទៅ ៩៣, ៧៤ % ។ ប៉ុន្តែ ការរាប់សន្លឹកឆ្នោត និង ការកំណត់ចំនួនអាសនៈ នៅក្នុង រដ្ឋសភា បានចោទឡើង ជាបញ្ហាមួយ ដ៏ស្មុគស្មាញ។ នៅថ្ងៃ ២៨ កក្កដា នៅពេលដែល គេកំពុងរាប់សន្លឹកឆ្នោត គណបក្ស «ប្រជាជន» លើកឡើង អំពី ជ័យជំនះរបស់គេ ទុក មុនជាស្រេច។ នៅពេល ដដែលនោះ គណបក្សប្រឆាំង បានប្រកាសថា មាន ការបន្លំ សន្លឹកឆ្នោត និង មានការគំរាមកំហែង ពី សំណាក់ គណបក្សកាន់អំណាច ។ លោក សម រង្ស៊ី ខាង គណបក្សប្រឆាំង គឺ គណបក្ស «សម រង្ស៊ី»[៥៦] បានអះអាងថា ដំណើរ នៃ ការ បោះឆ្នោត ពុំមានលក្ខណៈ ត្រឹមត្រូវឡើយ នៅក្នុងខេត្តស្វាយរៀង សៀម រាប ពោធិសាត់ និង កំពង់ឆ្នាំង ។ គណបក្សប្រឆាំងបានគំរាមថា នឹង មិនទទួលស្គាល់ រដ្ឋសភាថ្មីឡើយ បើគេ មិនពិនិត្យមើល បាតុភាពមិនល្អ ទាំងឡាយនោះទេ។ លោក យ៉េម រ៉ាប៊ីន អ្នកនាំពាក្យ នៃក្រសួងការបរទេស សហរដ្ឋ អាមេរិក បានស្នើសុំ ឲ្យរដ្ឋាភិបាលខ្មែរ ធ្វើការ អង្កេតអំពី បញ្ហានេះជា បន្ទាន់ ដើម្បីបញ្ជាក់ថា លទ្ធផល នៃការបោះឆ្នោត ពិតជា ឆ្លុះ

[៥៦] លោក សម រង្ស៊ី ជាកូន របស់ លោក សម សារី អតីតមន្ត្រីជំនាន់ របប «សង្គម រាស្ត្រនិយម»។ នៅឆ្នាំ ១៩៦៥ លោក សម រង្ស៊ី ទៅសិក្សានៅប្រទេសបារាំង ហើយ វិល ត្រឡប់មកស្រុកខ្មែរវិញ នៅឆ្នាំ ១៩៩២។ កាលនោះលោកជា សមាជិក គណបបក្សរាជា និយម «ហ្វុនស៊ិនប៉ិច»។ នៅឆ្នាំ ១៩៩៥ លោក បង្កើតគណបក្សផ្ទាល់ របស់លោក ដែលលោកឲ្យឈ្មោះ ថា គណបក្ស «ជាតិខ្មែរ» ។ នៅឆ្នាំ ១៩៩៨ គណបក្ស «ជាតិខ្មែរ» ប្តូរឈ្មោះ មក ជាគណបក្ស «សម រង្ស៊ី» វិញ ។

បញ្ចាំង នូវឆន្ទៈ របស់ ប្រជាជនខ្មែរមែនៗ នៅថ្ងៃ ៣០ កក្កដា លោក ហ៊ុន សែន នាយករដ្ឋមន្ត្រី អស់អាណត្តិ នៅពេលនោះ បានស្នើសុំឲ្យគណបក្សប្រឆាំងទាំងពីរ គឺគណបក្ស «ហ៊្វុនស៊ិនប៉ិច» និងគណបក្ស «សម រង្ស៊ី» ចូលរួមជាមួយគណបក្ស «ប្រជាជន» របស់លោក បង្កើតរដ្ឋាភិបាលចម្រុះមួយ គឺរដ្ឋាភិបាលគណបក្ស ៣ រួមគ្នាតែម្តងៗ នៅពេលដែលគេប្រកាសលទ្ធផលខ្លះៗ គេក៏ចាប់ផ្តើម ធ្វើការកំណត់ ចំនួនអាសនៈក្នុងរដ្ឋសភាៗ នៅថ្ងៃ ៣០ កក្កដា គណកម្មាធិការជាតិ នៃ ការបោះឆ្នោត (គ. ជ. ប.) បានប្រកាសបញ្ជាក់ប្រាប់ថា ការកំណត់ចំនួន អាសនៈត្រូវធ្វើ ទៅតាមប្រព័ន្ធសមាមាត្រមធ្យម ភាគច្រើនជាងគេ (système proportionnel à la plus forte moyenne) ពោល គឺ ទៅតាមរូបមន្ត «យ៉េហ្វហ្វែរស៊ុន» (Jefferson) ។ គឺ ជាប្រព័ន្ធមួយបែប ដែលសម្រួលដល់ គណបក្សដែលបានសន្លឹកឆ្នោតច្រើនជាងគេៗ ប៉ុន្តែ បញ្ហាដែលចោទឡើង នៅពេលនោះ គឺថា មាត្រា ១១៩ នៃរដ្ឋធម្មនុញ្ញ ពុំបានបញ្ជាក់ប្រាប់ អំពីប្រព័ន្ធ ដែលគេត្រូវប្រើ សម្រាប់ការបោះឆ្នោតសោះៗ រីឯ មាត្រា ១៦ នៃច្បាប់បោះឆ្នោត ក៏ប្រគល់ ភារកិច្ច សម្រេច អំពី បញ្ហានេះ ទៅឲ្យគណកម្មាធិការ គ.ជ.ប. ទាំងស្រុងដែរៗ នៅក្នុងន័យនេះ នៅ ថ្ងៃ ៦ ឧសភា គ.ជ.ប. បានផ្សព្វ ផ្សាយ ឯកសារមួយ ចំនួន ២០០ ទំព័រ ដើម្បីពន្យល់ អំពី ប្រព័ន្ធបែងចែក គឺ ប្រព័ន្ធ មួយបែប ដែលឈរនៅលើរូបមន្ត «យ៉េហ្វហ្វែរស៊ុន» ។

បើគិតតាមរូបមន្ត «យ៉េហ្វហ្វែរស៊ុន» គណបក្ស «ប្រជាជន» ដែល បានទទួល ២ លាន ៣ ម៉ឺន ៨០២ សំឡេង ត្រូវបាន ៤១, ៤២ % ។ បើគិត ទៅតាមប្រព័ន្ធដើម គណបក្សនេះបានត្រឹម ៥៩ អាសនៈប៉ុណ្ណោះៗ បើគិត តាមរូបមន្ត «យ៉េហ្វហ្វែរស៊ុន» គឺត្រូវបានរហូតដល់ទៅ ៦៤ អាសនៈ គឺ សំឡេង ភាគច្រើនដាច់ខាតៗ បើគិតតាមរបៀប បែងចែកដែលអង្គការ «អាប្រូនុច» បានប្រើ កាលពីការបោះឆ្នោតឆ្នាំ ១៩៩៣ គណបក្ស «ប្រជាជន» នឹង ទទួល ៥៦ អាសនៈៗ ដោយគិតទៅតាមប្រព័ន្ធ «យ៉េហ្វហ្វែរស៊ុន» លទ្ធផល នៃការបោះឆ្នោត ដែលបានត្រូវប្រកាសជាផ្លូវការនៅថ្ងៃ ៦ សីហា មាន ដូចតទៅ៖ គណបក្ស «ប្រជាជន» ដែលបានទទួល ៤១% នៃ សន្លឹកឆ្នោត ត្រូវបាន ៦៤ អាសនៈៗ គណបក្ស «ហ៊្វុនស៊ិនប៉ិច» ដែលបានទទួល ៣២ % នៃ សំឡេង ត្រូវបាន ៤៣ អាសនៈ ។ គណបក្ស





«សម រង្ស៊ី» ដែលបានទទួល ១៤ % នៃ សំឡេង ត្រូវមានអ្នកតំណាង ១៥ រូប នៅរដ្ឋសភា ។ នៅចំពោះមុខ លទ្ធផលនេះ គណបក្សប្រឆាំង ក៏ ចាប់ផ្តើមចោទថា គ. ជ. ប. បានប្តូររូបមន្ត ដោយមិនបានប្រាប់ជាមុនៗ រី ឯ កំហុស ក៏ធ្លាក់ទៅលើ លោក ថេអូណូអែល គឺ ជនជាតិ កាណាដាម្នាក់ ដែលជាទីប្រឹក្សា របស់ គ.ជ.ប.ៗ នៅ ថ្ងៃ ២៤ កញ្ញា រដ្ឋសភា រួមប្រជុំគ្នា ដើម្បីធ្វើវិសោធនកម្ម ដ៏សំខាន់មួយ ដែលព្រះមហាក្សត្រ នរោត្តម សីហនុ បានស្នើឡើងឲ្យបន្ថែម ទៅលើ រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ ។ វិសោធនកម្មនោះ ទាមទារឲ្យមាន មតិភាគច្រើន ២ ភាគ ៣ ពោលគឺ ៧៣ សំឡេង ទើបអាចចាត់តាំង រដ្ឋាភិបាលបានៗ ការបន្ថែមនេះ គឺ សម្រាប់បង្កើត រដ្ឋាភិបាលចម្រុះ តែប៉ុណ្ណោះ ប៉ុន្តែ ក៏ជា កត្តាមួយដែលនាំឲ្យធ្វើអ្វី ក៏ពុំចេញដែរ ។ បើយោងទៅតាម លទ្ធផល នៃ ការបោះឆ្នោត គេសង្កេតឃើញថា គ្មានគណបក្សណាមួយ អាចយក ៧៣ សំឡេងបាននោះទេៗ ដូចនេះ ការបង្កើតរដ្ឋាភិបាលចម្រុះ ជាការចាំបាច់ ។

## អំពីយុទ្ធសាស្ត្រ នៃ ការកសាងប្រទេសឡើងវិញ

## Stratégie de la reconstruction du pays

ដូចយើងបានដឹងរួចមកហើយ ក្រោយការបោះឆ្នោតឆ្នាំ ១៩៩៨ គណបក្សប្រឆាំងមិនព្រមទទួលស្គាល់លទ្ធផល នៃការបោះឆ្នោតទេៗ នៅ ថ្ងៃ ៣ កញ្ញា និស្សិតប្រមាណ ៣ ពាន់នាក់ ព្រមទាំងព្រះសង្ឃ ៥០ អង្គ បាននាំគ្នា ធ្វើបាតុកម្ម យ៉ាងគគ្រឹកគគ្រេង នៅមុខទីស្នាក់ការ សហភាពអឺរ៉ុប និង នៅមុខ ស្ថានទូតមួយចំនួន មានជាអាទិ៍ ស្ថានទូត សហរដ្ឋអាមេរិក ស្ថានទូតជប៉ុន និងស្ថានទូតវៀតណាម ដើម្បី សំដែងការមិនព្រមទទួលយក លទ្ធផល នៃការបោះ ឆ្នោតនោះៗ នៅថ្ងៃ ៣ កញ្ញានោះ ប្រទេសជប៉ុន ទទួលស្គាល់លទ្ធផល នៃការបោះឆ្នោតជាផ្លូវការ ហើយស្នើសុំឲ្យគណបក្សទាំងឡាយនោះបង្កើតរដ្ឋាភិបាលៗ មួយថ្ងៃបន្ទាប់មក បណ្តាប្រទេសនៃ សមាគមអាស៊ីអាគ្នេយ៍ (A.S.E.A.N.) ក៏ ស្នើសុំ ដូចគ្នា អ៊ីចឹង

ដែរ ទោះបី អ្នកសង្កេតការណ៍ នៃ ប្រទេសទាំងនោះ នាំគ្នាយល់ថា ការទាត់ចោលពាក្យ ប្ដឹង របស់គណបក្សប្រឆាំង ជាការដែលមិនអាចទទួលយកបានក្ដី ដោយហេតុថា បើមិន ដោះស្រាយ បណ្ដឹង ទាំងនោះទេ គេនៅតែយល់ថា លទ្ធផល នៃ ការបោះឆ្នោត មិនគួរឲ្យ ជឿជដែល។ នៅក្នុងពេល ជដែលនោះ អង្គប្រជុំបណ្ដាប្រទេស អាស៊ាន និយាយសម្រុះ សម្រួលគ្នា តាមរបៀបគ្រួសារ គឺ របៀប ដែលព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ ទ្រង់ បានគ្រោងរៀបចំជាស្រេច នៅថ្ងៃ ៥-៦ និង ៧ កញ្ញា នៅសៀមរាប។ ដំណោះ ស្រាយនោះ បានទទួលបរាជ័យទាំងស្រុង។ លោក ហ៊ុន សែន បានអញ្ជើញ ទៅរួមប្រជុំ ប៉ុន្តែ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ប្រធាន នៃ គណបក្ស «ហ្វ៊ុន ស៊ីនប៉ិច» និងលោក សម រង្ស៊ី អ្នកដឹកនាំ គណបក្ស «សម រង្ស៊ី» បានបញ្ជូន ត្រឹមអ្នកជំនាញការរបស់គេតែ ប៉ុណ្ណោះឲ្យទៅចូលរួម។ នៅទីបំផុត អ្នកតំណាង សហភាព អឺរ៉ុប ក៏បានស្នើសុំឲ្យ សហរដ្ឋ អាមេរិក កាត់ជំនួយ របស់គេ ទុក សិនដើម្បីទុកពេលឲ្យគេពិនិត្យពាក្យបណ្ដឹង ឲ្យបាន ត្រឹមត្រូវ។ សូមកត់សំគាល់ថា តាំងពីឆ្នាំ ១៩៩២ មក ប្រទេសកម្ពុជា រស់នៅ និងកសាង ខ្លួនឡើងវិញ ដោយ ជំនួយបរទេស ។ សម្រាប់ឆ្នាំ ១៩៩២ មកដល់ឆ្នាំ ១៩៩៥ សហគមន៍ អន្តរជាតិ បានសន្យាផ្ដល់ប្រាក់ជំនួយ ចំនួន ២ ពាន់ ២៩០ លានដុល្លារ គឺ បើគិតជាមធ្យម គឺ ៥៧២ លាន ដុល្លារ ក្នុងមួយឆ្នាំៗ។ ប៉ុន្តែ ក្រោយមក ដោយគម្រោងការផ្សេងៗ ពុំសូវ មានគុណភាពល្អ គេក៏ផ្ដល់ត្រឹម ១ ពាន់ ៣៥០ លាន ដុល្លារ ប៉ុណ្ណោះវិញ ។ ទោះជាយ៉ាង ណាក្ដី អ្វីដែលគេកត់សំគាល់ គឺថា ទោះបី ប្រទេសកម្ពុជា ស្ថិតនៅក្នុងការប្រទាញប្រទង់ រវាង ប្រទេសចិន និង ប្រទេសវៀតណាម ក្ដី ក៏ តាមការពិត ការកសាងប្រទេសឡើងវិញ រណបទាំងស្រុង ទៅនឹង ប្រទេសផ្ដល់ជំនួយទាំង ១៦ ប្រទេស និង ស្ថាប័ន ហិរញ្ញវត្ថុ អន្តរជាតិ ចំនួន ៦ ដែរ នៅក្នុងនោះ មាន អង្គការ («មូលនិធិ រូបិយវត្ថុ អន្តរជាតិ » (FMI) និង អង្គការ «ធនាគារ ពិភពលោក» (Banque mondiale) ដែរ ។

ការដែលប្រទេសកម្ពុជា កសាងខ្លួន ឡើងវិញ ដោយ ជំនួយ បរទេស នេះ ជាពិសេសជំនួយ របស់ ជប៉ុន និង ជំនួយ ពីបស្ចិមប្រទេស មានជា អាទិ៍ ប្រទេសបារាំង ជាការមួយ ដែលបញ្ជាក់ថា ប្រទេសកម្ពុជាមាន ជំហរ មួយ ដ៏មាំសម្រាប់ទប់ទល់ នឹង





មហិច្ឆតា នៃ ប្រទេសជិតខាង ជាពិសេស ប្រទេសចិន។ បើជំនួយទាំងនេះត្រូវកាត់ផ្ដាច់ ប្រទេសទាំងមូល នឹងធ្លាក់ទៅក្នុង កណ្ដាប់ដៃ នៃ ប្រទេសចិនជាពុំខាន ។ ប៉ុន្តែប្រការ ដែល គួរឲ្យសោកស្ដាយ គឺ ការដែលអ្នកដឹកនាំប្រទេស នៅពេលនោះ ប្រមូលលក្ខណៈសម្បត្តិ មិនបាន គ្រប់គ្រាន់ ដើម្បី ពង្រឹងគោលជំហរ ឲ្យបានរឹងមាំ សម្រាប់ កសាង នយោបាយ អព្យាក្រឹត របស់ខ្លួន ដូចការគ្រោងទុក នៃ កិច្ចព្រមព្រៀង សន្តិភាព ទីក្រុងប៉ារីស៍ឡើយ។ បន្តិចម្ដងៗ ប្រទេសកម្ពុជា ធ្លាក់ទៅក្នុងក្រញាំ នៃប្រទេស ដែលចង់យកខ្មែរធ្វើជារណប តាំងពីពេលដែលបារាំងចេញបាត់ទៅ។ គឺនៅក្នុងន័យ នេះហើយ ដែលឥស្សរជន ជាប្រវត្តិ សាស្ត្រធំៗ បន្តពង្រឹងឥទ្ធិពល របស់ពួកគេ បន្តទៅទៀត ។ និយាយមួយបែបទៀត គឺមាន ន័យថា : កសាងខ្លួនឡើងវិញ ដោយមានការឧបត្ថម្ភ ពីប្រទេសផ្ដល់ជំនួយ ប៉ុន្តែ បែរទៅជា សម្រប ទៅតាមផលប្រយោជន៍ របស់ប្រទេសដែលធ្លាប់បានធ្វើបាបខ្លួននៅពេលថ្មីៗ កន្លង មក ទៅវិញ។ តែនេះ ជានយោបាយ របស់សម្ដេច នរោត្តម សីហនុ តាំងពីពេល ទាមទារ ឯករាជ្យ ពីបារាំងបានមក ។ ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ដោយទ្រង់ស្អប់ បស្ចិម ប្រទេស ពេក ព្រះអង្គនៅ តែខិតខំ បម្រើផលប្រយោជន៍ របស់ ប្រទេសទាំងនោះ បន្តទៅ ទៀត។ សភាពការណ៍នេះបញ្ជាក់ឲ្យឃើញថា អ្នកដឹកនាំខ្មែរនៅក្នុងទសវត្ស ១៩៩០ ពុំព្រម ដកមេរៀន ប្រវត្តិសាស្ត្រ អ្វីទាំងអស់។

រយៈពេលមួយឆ្នាំបានកន្លងផុតទៅហើយ ប៉ុន្តែ អ្នកដឹកនាំខ្មែរនៅតែចេញពីទស្សនះ នយោបាយ អន្តរជាតិចាស់មិនរួចដដែល ទោះបីអ្នកដែលបានទទួលរងគ្រោះដោយ របប កុម្មុយនិស្ត ទើបនឹងបាននាំគ្នា វាយរំលំ កំផែងប៊ែរឡាំង នៅពេលថ្មីៗ ចោល ទៅហើយក្ដី។ ប្រសិនណា ជាគេនាំគ្នាប្រើប្រាស់ជំនួយទាំងនោះ ដើម្បីខិតខំកសាងប្រទេសឡើងវិញ ទៅ តាមមាគ៌ាមួយដែលកំណត់ ដោយ កិច្ចព្រមព្រៀង សន្តិភាព ទីក្រុងប៉ារីស៍ - គឺ កិច្ចព្រម ព្រៀងមួយ ដែលអាចដោះស្រាយបញ្ហាភូមិសាស្ត្រ-នយោបាយ បានទាំងស្រុង - ប្រទេស កម្ពុជា ក៏ នឹងអាចគេចផុត ពីមហិច្ឆតា របស់ ប្រទេសជិតខាង និងនៅក្នុង តំបន់បានដែរ ។

នៅថ្ងៃ ២៧ និង ២៨ តុលា ឆ្នាំ ១៩៩៩ អ្នកតំណាងបណ្ដាប្រទេស ផ្ដល់ជំនួយទាំង ១៦ និងអ្នកតំណាង អង្គការ ហិរញ្ញវត្ថុ អន្តរជាតិ ចំនួន ៦ បាន បើកអង្គប្រជុំ មួយ នៅទី

ក្រុងភ្នំពេញ ដើម្បីធ្វើការវាយតម្លៃ ការប្រើប្រាស់ជំនួយ ដោយរដ្ឋាភិបាលខ្មែរ។ អង្គប្រជុំបានសង្កេតឃើញថា មានការជឿនលឿនល្អ ប៉ុន្តែ ពុំទាន់មានការអនុវត្តន៍ ជាក់ស្តែងនៅឡើយ គឺមាននៅតែលើក្រដាសប៉ុណ្ណោះ។ ទន្ទឹមនោះដែរ អង្គប្រជុំបានស្នើសុំឲ្យ រដ្ឋាភិបាលខ្មែរ ពង្រឹង ការប្រយុទ្ធ នឹង អំពើពុករលួយ អំពើ ឧក្រិដ្ឋកម្ម ដែលកំពុងរីករាលដាល និង ជា ពិសេស ការកាប់ព្រៃឈើខុសច្បាប់។ សូមកត់សំគាល់ថាសម្រាប់ឆ្នាំ ១៩៩២- ១៩៩៥ សហគមន៍អន្តរជាតិ បានសន្យាផ្តល់ជំនួយ ២ ពាន់ ២៩០ លានដុល្លារ គឺ ៥៧២ លាន ក្នុងមួយឆ្នាំៗ ។ តាមការពិត ប្រទេសកម្ពុជា បានទទួលត្រឹម ៥៩ % នៃ ជំនួយប៉ុណ្ណោះ ព្រោះ កម្មវិធី កែទម្រង់ មិនសូវមាន គុណភាព។ នៅ ឆ្នាំ១៩៩៩ ប្រទេស ជប៉ុន បាន សម្រេច បន្ថយ ជំនួយ របស់ គេ មកត្រឹម ១០០ លានដុល្លារ ក្នុងមួយឆ្នាំៗ តែប៉ុណ្ណោះ ។ នៅឆ្នាំ ១៩៩៩ នោះ លោក រដ្ឋមន្ត្រី សេដ្ឋកិច្ច និង ហិរញ្ញវត្ថុខ្មែរ គាត ឆុន ក៏បាន បញ្ជាក់ផងដែរថា អតិផរណា បានចុះពីជាង ១២ % នៅឆ្នាំ ១៩៩៨ មកត្រឹម ៥ % រី ឯ ប្រាក់ចំណូល បានមក ពីការយកអាករ បានកើនដល់ ៥៨ % រួមបញ្ចូលទាំងអាករ T.V.A.[៥៧] ផង។ លោក គាត ឆុន ក៏ បានបញ្ជាក់ផងដែរថា ចំណាយសាធារណៈ បាន កើន ១៦ % នៃ ថវិការដ្ឋ ហើយពាក់កណ្តាល នៃ ចំណាយនេះ ទាក់ទង នឹង ការផ្គត់ផ្គង់កងទ័ព និង ភ្នាក់ងារសន្តិសុខ។ នៅខែកញ្ញាឆ្នាំ ១៩៩៩ ប្រទេស កម្ពុជា បានទទួលជំនួយ គិតជាទឹកប្រាក់ ចំនួន ២៨០ លាន ដុល្លារ គឺ ៦០ លាន ជាអំណោយ ហើយ ១២០ លាន ជាប្រាក់ដែល ធនាគារ ពិភពលោក និង ធនាគារ អាស៊ី ឲ្យខ្ចី ។ គេកត់សំគាល់ថា នៅឆ្នាំ ១៩៩៨-១៩៩៩ នោះ វិនិយោគ មកពីបណ្តាប្រទេសអាស៊ី ចុះថយយ៉ាងខ្លាំងមហិមា ព្រោះតែ វិបត្តិ សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ នៅអាស៊ី ។ រី ឯ វិនិយោគមកពីអឺរ៉ុប ក៏ចុះខ្សោយទៅទៀត។ មានតែវិនិយោគមកពី សហរដ្ឋ អាមេរិក ប៉ុណ្ណោះ ដែលកើនឡើងដល់ ទៅ ៤ ដង គឺ បានកើន ពី ៤ លាន ៥ សែន ដុល្លារ នៅឆ្នាំ ១៩៩៨ ដល់ ១៦ លាន ៧ សែន ដុល្លារ នៅឆ្នាំ ១៩៩៩ ។ យោងទៅតាមការវិភាគ របស់ អ្នកឯកទេស ការដែលវិនិយោគអាស៊ី

[៥៧] Taxe sur la valeur ajoutée





បានចុះថយ គឺពុំមែនមក ពី វិបត្តិហិរញ្ញវត្ថុ នៅអាស៊ី ប៉ុន្មានទេ ប៉ុន្តែ គឺមកពីកង្វះ ហេដ្ឋារចនាសម្ព័ន្ធ ពាណិជ្ជកម្ម ជាពិសេស មធ្យោបាយ ដឹកជញ្ជូន មានតម្លៃ ថ្លៃពេក ។ ក្រៅពីនោះ គឺ មកពី អំពើ ពុករលួយ និង កង្វះច្បាប់ស្តីពី ដីធ្លី ។

នៅក្នុងរយៈពេល ១០ ឆ្នាំកន្លងមក បើយោង ទៅតាមប្រភពខ្លះ ការនាំចូល បាន កើនឡើងជាលំដាប់ គឺ បានកើន ពី ១៧៧ លានដុល្លារ នៅឆ្នាំ ១៩៨៩ មក ១១០៩ លានដុល្លារ នៅឆ្នាំ ១៩៩៦។ បើតាមការគន់គូរ របស់ អង្គការ មូលនិធិ រូបិយវត្ថុ អន្តរជាតិ ការនាំចូលនៅឆ្នាំ ១៩៩៦ ស្ថិតនៅក្នុងកម្រិត ៧៨៧ លានដុល្លា រប៉ុណ្ណោះ ។ ទន្ទឹមនោះ ការនាំចេញ ក៏មានកម្រិតខ្ពស់ ដែរ គឺ បានកើន ពី ៨០ លានដុល្លារ នៅឆ្នាំ ១៩៨៩ ដល់ ៣២៨ លាន ដុល្លារ នៅឆ្នាំ ១៩៩៦ ហើយនៅឆ្នាំ ១៩៩៨ បានកើនដល់ ៦០៣ លាន ដុល្លារតែម្តង។ នៅឆ្នាំ ១៩៩៨ នោះ ឱនភាព ជញ្ជីងពាណិជ្ជកម្ម បានចុះថយ ៦, ១ % គឺ ស្ថិត នៅក្នុងកម្រិត ៩, ២ % ប្រៀបធៀបទៅ ឆ្នាំ ១៩៩៦ គឺ មុនពេល មានវិបត្តិ ហិរញ្ញវត្ថុនៅអាស៊ី។ រីឯរូបិយបណ្ណ (devises) រក្សាទុក គឺ ស្ថិតនៅក្នុងកម្រិត ៣៩០ លាន ដុល្លារ ប៉ុណ្ណោះ។ ប្រការដែលគួរឲ្យកត់សំគាល់ គឺថាដោយ ជាប់រវល់តែបញ្ហាសន្តិសុខ រដ្ឋាភិបាល មិនបានផ្តល់អាទិ៍ភាពទៅ ឲ្យវិស័យសិក្សាធិការទេ ទោះបី វិស័យនេះ ជាសរសៃទ្រូង នៃ ការអភិវឌ្ឍន៍ក្តី។ ប្រទេសនីមួយៗ អាចខ្លាំងបាន លុះណាតែមាន អ្នកចេះដឹង និងអ្នកបច្ចេកទេស ។ រី ឯ ការអប់រំ ការហាត់ហ្វឹកហ្វឺនផ្សេងៗ ត្រូវចាយពេលវេលា ច្រើនណាស់ ។ បើធ្វើពុំទាន់ទេ គឺ មុខជា នឹង ទទួលផលវិបាកជាពុំខាន នៅក្នុងការប្រកួតប្រជែង សេដ្ឋកិច្ច ក៏ដូចជានៅក្នុង វិស័យសង្គម។ ព្រោះតែ សង្គ្រាមដណ្តើមអំណាចគ្នា ដោយមាន បរទេស នៅពីក្រោយ វិស័យនេះ ពុំបានលូតលាស់ ទៅតាមកាលៈទេសៈ [៥៨] ឡើយ។ គឺ ការខាតបង់ពេល ដ៏ធំ នេះហើយ ដែលបណ្តាល ឲ្យប្រទេស កម្ពុជា ស្ថិតនៅ ក្នុងភាពទន់ខ្សោយ គ្រប់វិស័យ រហូតដល់ពេល ត្រូវប្រកួតប្រជែង ជាមួយប្រទេសផ្សេងៗទៀតតែម្តង។

[៥៨] ពាក្យ *ទេសកាល* នេះ មានប្រើនៅក្នុង *វចនានុក្រមខ្មែរ* របស់ សម្តេច ជួន ណាត ។ ជាទូទៅ គេច្រើនប្រើ *កាលៈទេសៈ* ដូច្នេះវិញ ។

# អ្នកទទួលមតក៌

# Les héritiers





# ជំពូក ១២
# ឧបសគ្គ នៃអភិក្រមទំនើបកម្ម
# នៅប្រទេសកម្ពុជា

បញ្ហាដែលគេចោទសួរថា ហេតុដូចម្ដេច បានជា ខ្មែរមានការពិបាកច្រើន ក្នុងការសម្រប ខ្លួន ទៅនឹង បរិបទអន្តរជាតិ។ គេអាចនិយាយបានថា ចាប់តាំងពី ពាក់កណ្ដាល ឆ្នាំ ១៩៦០ មក ការកសាងកម្មវិធី សិក្សាធិការជាតិ បានជួបនឹង ឧបសគ្គមួយចំនួន ដែលកាលនោះ ពុំមានអ្នកណាចាប់អារម្មណ៍ អ្វីប៉ុន្មានឡើយ ហើយ បែរជាបានទទួលការអបអរសាទរទៅ វិញ ដូចជាការកាត់ផ្ដាច់ចរន្តនៃ ការបេះដឹងសកល ដើម្បីត្រៀមលក្ខណៈយុវជន ឲ្យកសាង ខ្លួនទៅតាម របបនយោ បាយមួយដែលអ្នកជំនាន់ក្រោយ បាត់បង់ទាំងស្រុងនូវ លទ្ធភាពនាំ ប្រទេសជាតិ ឆ្ពោះទៅរក បរិបទសម័យទំនើប ផ្លូវគំនិត ។ ដើម្បីកុំឲ្យឃើញសភាពការបែប នេះច្បាស់ពេក គេ បង្វែរអារម្មណ៍ យុវជន ឲ្យយល់ថា ប្រទេសជាតិ ត្រូវការតែ បច្ចេក ទេស វិស្វកម្ម និង មុខវិជ្ជាដែលមិននាំគ្រោះថ្នាក់» ដល់ អ្នកកាន់អំណាច នយោបាយតែ ប៉ុណ្ណោះ។ ការពិចារណា ផ្នែកទស្សនវិជ្ជា ជាពិសេស ទស្សនវិជ្ជានយោបាយ បានត្រូវកាត់ ជា កង់ៗ រីឯភាសាបារាំង និងអង់គ្លេសបានត្រូវបង្រួម មកត្រឹម របៀបរបបរស់នៅប្រចាំថ្ងៃ ផងទៀត។ អ្នកដែលបានសិក្សាត្រឹមត្រូវ មុនការកែទម្រង់នេះ បានក្លាយទៅជា អ្នកប្រឆាំង នឹងរបបនយោបាយ កាល សម័យនោះ ស្ទើរតែទាំងអស់។ ពួកគេជាគ្រូបង្រៀន ជាសាស្ត្រា ចារ្យ ក៏ពិតមែន ប៉ុន្តែ ក៏ត្រូវរដ្ឋអំណាចគាបសង្កត់ដោយឥតអាសូរ រួមបញ្ចូលទាំងសាស្ត្រា ចារ្យជាតិបារាំង និង សាស្ត្រាចារ្យបង្រៀនអក្សរសិល្ប៍ខ្មែរផងដែរ។ មុនការ គាបសង្កត់នេះ គេពុំបានដឹង នៅឡើយថាអក្សរសិល្ប៍ខ្មែរ មិនត្រឹមតែជាចំណែកមួយ ដ៏សំខាន់ នៃ សម្បត្តិ

វប្បធម៌មនុស្សជាតិ ប៉ុណ្ណោះទេ តែក៏ជាថ្នាំ និង ជាកត្តា នៃ វិចារណញ្ញាណ និងការរីកចម្រើន ដូចអក្សរសិល្ប៍ នានាឯទៀត នៅក្នុងពិភពលោកដូច្នេះដែរ ។ លុះបានដឹងកាលណាសាស្ត្រាចារ្យអក្សរសិល្ប៍ខ្មែរ ដែលចេះវប្បធម៌បារាំង និង អង់គ្លេសយ៉ាងស្ទាត់ជំនាញដែរនោះ ក៏ត្រូវគេ ចាត់ទុកថាជា អ្នកប្រឆាំងដែរ ។ ទោះបី អ្នកដឹកនាំ និង វរជនសំខាន់ៗ រស់នៅតាមបែបបារាំង អានសៀវភៅ បារាំងអង់គ្លេស សឹងតែទាំងអស់គ្នាក្តី ក៏ គេធ្វើអ្វី គ្រប់បែបយ៉ាងដើម្បីរាំងស្កាត់ មិនឲ្យ ប្រពៃណីនេះ មាន បន្តមកទៀត នៅស្រុកខ្មែរដែរ ។ មូលហេតុមានពីរ គឺ ៖ ១) ត្រៀមលក្ខណៈយុវជន ឲ្យចាំទទួលយករបប ផ្តាច់ការ-២) មិនឲ្យអ្នកជំនាន់ ក្រោយ មានអាវុធបញ្ញា និង វិជ្ជាគ្រប់គ្រាន់សម្រាប់ នាំសង្គម ឆ្ពោះទៅរកសេរីភាពផ្លូវគំនិតជាពិសេស លទ្ធិ ប្រជាធិបតេយ្យ តាមបែបបទបស្ចិមប្រទេស ។ អ្នកនយោបាយអភិរក្ស និង អ្នកដែលប្រាថ្នា កាន់អំណាចផ្តាច់ការ តាមបែប ប្រទេសសង្គមនិយម មានទស្សនៈនេះដូចគ្នា ហើយចូលដៃគ្នា អនុវត្តនយោបាយ អន្ធការនិយមនេះ តែម្តង ។ គេប្រើពាក្យជាតិនិយម ដើម្បី លាក់បំបាំង គោលដៅនេះ ប៉ុន្តែ គេ ក៏ដឹងយ៉ាងច្បាស់ ដែរថា អ្នកស្រឡាញ់ជាតិ ពិតប្រាកដ ជាអ្នកដែល នាំប្រទេស ឆ្ពោះទៅរក ការរីកចម្រើន គ្រប់វិស័យដូច្នេះដែរ។ ការពិត គេចង់បានប្រទេសកម្ពុជាមួយ ដែលមានតែទាសករប៉ុណ្ណោះ ហើយមិនចង់គ្រប់គ្រងអ្នកចេះដឹងឡើយ គឺផ្ទុយស្រឡះ ពីសេចក្តីប៉ងប្រាថ្នា របស់ ប្រជាពលរដ្ឋខ្មែរដែលសុខចិត្តលក់ដីស្រែចម្ការ ដើម្បីឲ្យកូន អាចបន្ត ការរៀនសូត្រ ហើយ ថែមទាំង មានមោទនភាព ដ៏ខ្លាំងក្លា កាលបើកូនបានទៅរៀននៅបរទេស។ នៅសម័យ ប៉ុល ពត អ្នកទាំងនេះបានត្រូវ គេយកទៅសម្លាប់ចោល សឹងផុតពូជ រួមបញ្ចូលទាំង ជនកុម្មុយនិស្តខ្មែរដែលគាំទ្រខ្មែរក្រហមផងទៀត។ កាលនោះ គេពុំបានដឹងទេ ថា ប្រទេសកាន់លទ្ធិកុម្មុយនិស្ត នៅអាស៊ី មានគោល បំណងផ្សេងទៀត ក្រៅពីការប្រែក្លាយតំបន់ទាំងមូល ឲ្យទៅជាកុម្មុយនិស្ត ។ ការដណ្តើមគ្នាគ្រប់គ្រង អតីតឥណ្ឌូចិនបារាំង បានស្តែងចេញឡើងយ៉ាងច្បាស់ នៅពេលក្រោយៗមកទៀត។





# អំពី របប សេដ្ឋកិច្ច នានា នៃ ប្រទេសកម្ពុជា តាំងពីឆ្នាំ ១៩៥៥ មក

## Des divers régimes économiques du Cambodge depuis 1955

ការកសាង សេដ្ឋកិច្ច ប្រទេសកម្ពុជា បានឆ្លងកាត់ ដំណាក់ការជាច្រើន ទម្រាំបាន មកដល់ របបសេដ្ឋកិច្ចបច្ចុប្បន្ន ដែលអនុវត្ត ប្រព័ន្ធសេដ្ឋកិច្ចផ្សារ (Economie de marc-hé) ទាំងស្រុងតែម្តង។ នៅឆ្នាំ ១៩៤២ រ៉េស៊ីដង់ ស៊ូប៉េរី យេរ បារាំងបានកត់សំគាល់ ដូច្នេះថា: តួនាទីសេដ្ឋកិច្ច នៃប្រទេសកម្ពុជា គឺ មួយផ្នែកធំ ផ្គត់ផ្គង់ផ្សារសាយហ្គូន (Saïgon) និង ចឹឡុង ហើយមួយផ្នែកទៀត សម្រាប់ផ្គត់ផ្គង់ ផ្សារឥណ្ឌូចិនទាំងមូលតែម្តង។ សេដ្ឋកិច្ចវិទូ បារាំង រ៉េមី ព្រូដោម (Rémy Prud'homme) [៥៩] បានកត់សំគាល់ នៅក្នុងសៀវភៅមួយ របស់ លោកដូច្នេះថា ៖ «សេដ្ឋកិច្ច នៃ ប្រទេស កម្ពុជា គឺជាសេដ្ឋកិច្ចមួយ ដែលមានលក្ខណៈជាសេដ្ឋកិច្ច អាណានិគម» ។ នៅឆ្នាំ ១៩៥៥ សម្តេច នរោត្តម សីហនុ ដែល បានបង្កើតចលនា នយោបាយមួយ មានឈ្មោះថា «សង្គមរាស្ត្រនិយម» បានផ្តល់ទៅឲ្យ ប្រទេសកម្ពុជា នូវរបបមួយ ដែលអ្នកស្រាវជ្រាវ បារាំងម្នាក់ ឈ្មោះ ហ្វីលីព ប្រ៉េហ្ស[៦០] (Philippe Preschez) នៃ «វិជ្ជាស្ថានសិក្សានយោបាយ ទីក្រុងប៉ារីស៍» ពិពណ៌នាដូចតទៅ ៖ «គឺ ជារបបសេដ្ឋកិច្ច មួយបែប ដែល ប្រព័ន្ធមូលធននិយម ឯកជន របៀបបុរាណ ប្រកួតប្រជែង នឹង មូលធននិយមរដ្ឋ ដែលគេទើប នឹងបានបង្កើត។ ក្រុមនីមួយៗ ធ្វើសកម្មភាព របស់គេ តាមបែបបទ របស់គេផ្ទាល់ ដោយប្រើប្រាស់កម្លាំងផលិតកម្ម ដែលមាន នៅ ក្នុងប្រទេស» ។ ហ្វីលីព ប្រ៉េហ្ស កត់សំគាល់ បន្តមកទៀតថា: «អ្នកមូលធននិយម

---

[៥៩] Rémy Prud'homme, *L'Economie du Cambodge*, P.U. F. , Paris, 1969

[៦០] Prechez Philippe, *Essai sur la démocratie au Cambodge*, Paris, C.E.R.I. Série C, Recherche n° 4, 1961.

នៅស្រុកខ្មែរ ពិតជា មានមែន ប៉ុន្តែ នៅក្នុងប្រទេសមួយ ដែល ឧស្សាហកម្ម កំពុងកកើតឡើង ហើយដែល ៨០ % នៃ ប្រជាជន ប្រកបមុខរបរ ជា កសិករ គេ ក៏មិនត្រូវផ្តល់តម្លៃនយោបាយ និងសេដ្ឋកិច្ចខ្ពស់ពេក ទៅឲ្យអ្នកមូលធននិយម ទាំងនោះឡើយ ។ បើនិយាយឲ្យចំទៅ អ្នកមូលធន និយមទាំងនោះ ច្រើនតែ ជាអ្នកចងការប្រាក់ អ្នករកស៊ី បន្តិចបន្តួច ឬ ជាម្ចាស់សហគ្រាស ប៉ុណ្ណោះ ។ ប៉ុន្តែ ពួកគេមាន តួនាទីសំខាន់ នៅក្នុងដំណើរការសេដ្ឋកិច្ច» ។ សូមកត់សំគាល់ថា ចំពោះអ្វីដែល ហ្វីលីព ប្រ៉េហ្សេ ហៅថា «អ្នកមូលធននិយមរដ្ឋ» («capitalistes d’Etat») គេមានតួនាទីមួយដ៏សំខាន់បំផុត នៅក្នុងជីវិត សេដ្ឋកិច្ច នៃ ប្រទេសកម្ពុជា ។ នៅ ក្នុងរបប «សាធារណរដ្ឋ ខ្មែរ» ពីឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ មាត្រា ១៤ នៃ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៧២ ចែងដូច្នេះថា : រដ្ឋទទួលស្គាល់ និង ធានា ដល់កម្មសិទ្ធិឯកជន។ រដ្ឋលើកទឹកចិត្តឲ្យប្រជាពលរដ្ឋ ឈានឲ្យបានដល់កម្មសិទ្ធិ។ ការប៉ះពាល់ ដល់កម្មសិទ្ធិ ត្រូវហាមឃាត់ លើកលែងតែនៅក្នុងករណីត្រូវបម្រើសេចក្តីត្រូវការប្រយោជន៍សាធារណៈ ។ ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៩៣ គឺ អស់រយៈពេល ១៨ ឆ្នាំ ប្រទេសកម្ពុជា រស់នៅក្នុងរបប កុម្មុយនិស្ត ដែលកម្មសិទ្ធិឯកជន ពុំមាន ការធានាអ្វីទាំងអស់ គឺ ត្រូវវាយរំលំចោល ទាំងស្រុង តែម្តង ដើម្បីកសាង របប សមូហភាពនិយម (collectivisme, communisme) ។

នៅក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣ មាត្រា ៥៦ ចែងថា : ព្រះរាជាណា ចក្រ កម្ពុជា អនុវត្ត ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ។ ការរៀបចំ និង ការប្រព្រឹត្តិទៅ នៃ ប្រព័ន្ធសេដ្ឋកិច្ចនេះ នឹង មានកំណត់ក្នុងច្បាប់។ ការរៀបរាប់ទាំងឡាយ ខាងលើនេះ សឲ្យឃើញថា ប្រជាជនខ្មែរ បានរស់នៅក្នុង របប សមូហភាពនិយម អស់រយៈពេល ១៨ ឆ្នាំ ។ នៅក្នុងរបបមុនឆ្នាំ ១៩៧៥ គេ ក៏ពុំឃើញមាន ការអប់រំ និង ការត្រៀមលក្ខណៈ ឲ្យបានគ្រប់គ្រាន់សមស្រប សម្រាប់ ប្រកាន់ឥរិយាបថ សេរីនិយម (comportement libéral) ឲ្យបានរឹងប៉ឹងអ្វីដែរ។ មួយវិញទៀត ព្រោះតែសង្គ្រាម និង ព្រោះតែរបប សមូហភាពនិយម គេ មិនត្រឹមតែបាត់បង់ នូវ កម្មសិទ្ធិឯកជន របស់គេ អស់លើងប៉ុណ្ណោះទេ គឺ ថែមទាំង បាត់បង់ នូវជំហរ កសាងខ្លួនគេ ជាអ្នកទទួលខុសត្រូវ នៃ ជោគវាសនារបស់ ខ្លួនគេម្នាក់ៗ





ផ្ទាល់ផងទៀត។ គឺនៅក្នុងបរិបទនេះហើយ ដែលប្រទេសកម្ពុជា ត្រូវកសាងរបប សេដ្ឋកិច្ចផ្សារ ឬ សេរីនិយម ចាប់តាំងពីឆ្នាំ ១៩៩៣ មក។ នៅក្នុងការអភិវឌ្ឍន៍ប្រទេស ទៅតាមប្រព័ន្ធសេដ្ឋកិច្ច សេរីនិយម ប្រទេសកម្ពុជា ត្រូវប្រឈមមុខ នឹងបញ្ហាធំៗ ជាច្រើន ជាពិសេស ការកសាងច្បាប់ កសាងប្រព័ន្ធនីតិកម្ម ឲ្យបានសមស្រប ជាពិសេស ប្រព័ន្ធយុត្តិធម៌ ។ ប៉ុន្តែអ្វីដែលគួរឲ្យកត់សំគាល់ គឺ ការជួប នឹង ឧបសគ្គ រាប់មិនអស់ ជាបឋម ការលើកកម្រិតជីវភាព ប្រជាជន និង ការអនុវត្តន៍ច្បាប់ ជាធរមាន ។ នៅពេលក្រោយសង្គ្រាម ប្រជាជនគ្មានអ្វី សម្រាប់ការពារខ្លួន និងកម្មសិទ្ធិ ត្រឹមត្រូវ របស់គេ ទេ ព្រោះការគោរពច្បាប់ មានការជាប់ពាក់ព័ន្ធ យ៉ាងស្មុគស្មាញ នឹង ស្ថានភាពនយោបាយ ដ៏ពុះកញ្ជ្រោល និងលក្ខណៈសង្គម-វប្បធម៌មួយដែលមានមក តាំងពី បុរាណ កាលមក ពោលគឺ ការបែងចែក មិនបានច្បាស់ រវាងប្រយោជន៍ គ្រួសារ បក្សពួក នឹង ប្រយោជន៍ របស់ប្រទេសជាតិ ។

## ឧបសគ្គផ្សេងៗ នៃ ការអភិវឌ្ឍន៍ ចាប់តាំង ពីឆ្នាំ ១៩៩២

## Les divers obstacles rencontrés dans le processus de développement à partir de 1992

ការអភិវឌ្ឍន៍ ប្រទេសកម្ពុជា ចាប់ពី ពេលដែលប្រទេសនេះ ចាប់ផ្តើមប្រកាន់យករបបសេដ្ឋកិច្ចផ្សារ ឬ សេរីនិយម នៅក្រោយពេល អន្តរាគមន៍ របស់ អង្គការ សហប្រជាជាតិ បានជួបនឹង ឧបសគ្គជាច្រើន ។ ឧបសគ្គ ធំជាង គេ គឺ អស្ថិរភាព នយោបាយ ព្រមទាំងការប្រយុទ្ធ រវាងបក្សពួករវាងក្រុមអ្នកឆ្លៀតឱកាសនានា ដើម្បីបម្រាញ់យកប្រយោជន៍ផ្ទាល់ខ្លួន ពោលគឺ រូបភាពមួយ នៃ អំពើ ពុករលួយ ។ ប៉ុន្តែទន្ទឹមនោះ គេក៏ឃើញមាន

ការប្រយុទ្ធដណ្ដើម ឥទ្ធិពលគ្នា នៅក្នុងក្របខណ្ឌ ភូមិសាស្ត្រ-នយោបាយ ក្នុងវិស័យកសាង សេដ្ឋកិច្ច ឡើងវិញដែរ ។ ប្រទេសកម្ពុជា កសាងខ្លួន ឡើងវិញ ដោយ ផ្អែក ទៅលើជំនួយ របស់ អង្គការ ហិរញ្ញវត្ថុអន្តរជាតិ ធំៗ ដូចជា អង្គការ មូលនិធិ រូបិយវត្ថុ អន្តរជាតិ និង ធនាគារ ពិភពលោកជាដើម ព្រមទាំងការធ្វើវិនិយោគទុន របស់ បណ្ដាប្រទេស នៅអាស៊ី ដែលមុនពេលមាន វិបត្តិ ហិរញ្ញវត្ថុ មានទាំងអស់ ៨០ % នៃ វិនិយោគបរទេស ។ ច្បាប់ សម្រាប់ធ្វើវិនិយោគមាន គ្រប់គ្រាន់ ទាំងអស់ ប៉ុន្តែ ទិសដៅ នៃ ការអភិវឌ្ឍន៍ ពុំមាន លក្ខណៈច្បាស់លាស់ឡើយ ។ ដោយព្រោះតែ មានការប្រយុទ្ធគ្នា រវាង គណបក្សនយោបាយ បន្តមកទៀត ការកំណត់ថវិកា ពុំមានតុល្យភាពល្អឡើយ រវាង ការរក្សាសន្តិសុខ នៅក្នុងប្រទេស និង ការកសាងធនធានបញ្ញា សម្រាប់ការអភិវឌ្ឍន៍ ដែលមាន ជាអាទិ៍ៈ ការបង្កើនចំណេះវិជ្ជា និង សមត្ថភាពវិជ្ជាជីវៈ របស់ប្រជាជនខ្មែរ ជាពិសេសយុវជនៗ ម៉្យាងទៀត ការផ្សាភ្ជាប់ក្រឹត្យក្រម នៃ ការអភិវឌ្ឍន៍ ទៅនឹង ទំនៀមទម្លាប់ របៀបរបបរស់ នៅ ជាប្រពៃណីរបស់ខ្មែរ ក៏ ជួបនឹង បដិវាទកម្ម ច្រើនណាស់ឧរ ។ គំនិតគ្រួសារនិយម គិតបងប្អូនក្រុមគ្រួសារ ធំជាង ប្រយោជន៍សង្គមបានធ្វើឲ្យប៉ះពាល់ យ៉ាងធ្ងន់ធ្ងរ ដល់អភិក្រម នៃការរីក ចំរើន តាមក្រឹត្យក្រមសត្យានុម័ត ពោលគឺអភិក្រម ប្រជាធិបត្យូបនិយកម្ម[៦១] និងសណ្ដាប់ធ្នាប់សង្គមៗ នៅក្នុងវិស័យ ការអប់រំផ្នែកសីលធម៌ គេបានយក ការ និយមបុណ្យសក្តិ ប្រាក់កាសធ្វើជាធំ ហើយ ប្រមាថយ៉ាងខ្លាំង ដល់អ្នកធ្វើ សកម្មភាពផ្នែក បញ្ញា និងអ្នកដែលផ្អែកវាសនា របស់គេទៅលើគតិច្បាប់ និងទៅលើគតិបណ្ឌិតៗ ការផ្ដល់ និយមន័យ ទៅឲ្យពាក្យ បញ្ញា ក៏មានលក្ខណៈពុករលួយដែរ គឺគេឲ្យតម្លៃទៅលើ អ្វីដែល

[៦១] ចំពោះពាក្យ បារាំងdémocratisation វចនានុក្រមរបស់ លោក Rogatien Rondineau ប្រែជាខ្មែរថា ប្រជាធិបតេយកម្ម ។ ប៉ុន្តែ លោក សម ថាំង ប្រែ ថា ប្រជាធិបត្យូបនិយកម្ម ដូច្នេះវិញ ។



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

គេហៅថា «មនុស្សឆ្លាត» ចេះបត់បែនតាមស្ថានការណ៍ ចេះកេងប្រវ័ញ្ចចេះភូតកុហក់ បោក ប្រាស់ ចេះត្បួកអង្អែលក្បាលអ្នកធំ អ្នកតូច ចេះសូកទិញយកសញ្ញាបត្រ បន្ទំ យកខុស ជា ត្រូវ ល្អជាអាក្រក់ៗ នៅក្នុងវិស័យ នយោបាយ ក៏ ដូចគ្នាអ៊ីចឹងដែរ ។ អ្នកខ្លាំងប្រភេទនេះ តែងតែ បានត្រូវគេកោតស្ញែង គោរពរាប់អាន ការពារ ហើយ អ្នកដែលទាមទារសិទ្ធិ ត្រឹម ត្រូវ របស់ខ្លួន បានត្រូវគេចាត់ទុកថា ជាខ្មាំង ជាបច្ចាមិត្តទាំងអស់ ។

សំនួរដែលគេចោទសួរ គឺថា តើហេតុដូចម្ដេច បានជាសង្គមខ្មែរ នៅ ពេលនោះ បានជ្រើសរើសយក របៀបរស់នៅបែបនេះ ? តាមការពិតទៅ មិនមែនតែ ពេលនោះទេ ដែល សង្គមខ្មែរ និយមមនុស្ស ដែលមានលក្ខណៈបែបនេះ ។ តាំងពីដើមមក គេតែងតែ គោរពមន្ត្រី នាម៉ឺន អ្នកមានអំណាច ជាងអ្នកចេះដឹង អ្នកមានវិជ្ជាជ្រៅជ្រះ ។ នៅឆ្នាំ ១៩៥០-១៩៦០ រហូតដល់ ឆ្នាំ ១៩៧៥ បញ្ញជន អ្នកបច្ចេកទេស មានតួនាទី ដ៏សំខាន់ ។ សាស្ត្រាចារ្យ មានប្រាក់ខែហួសពីប្រាក់ខែ អភិបាលខេត្ត ទៅទៀត ហើយត្រូវគេ ចាត់ទុក ថា ជាមន្ត្រី ជាន់ខ្ពស់ដែរៗ ការចេះដឹងបានត្រូវគេលើកតម្កើងនៅគ្រប់មជ្ឈដ្ឋាន ។ នៅក្រោម របប ប៉ុល ពត គ្រូបង្រៀន អ្នកចេះដឹង ជាសត្រូវ របស់រដ្ឋអំណាច ។ នៅ ក្នុងរបបបន្ទាប់ ដែលជារបបកុម្មុយនិស្តដូចគ្នា ប្រទេសទាំងមូលបានធ្លាក់ទៅក្នុងអាណានិគមយួន ដែល យកបញ្ញវន្តខ្មែរ ទៅឲ្យរៀនសូត្រតាមក្រឹត្យក្រម របស់ប្រទេសគេ ។ ពួករដ្ឋអំណាច បាន យកអ្នកទាំងនោះ ដែលនៅសល់ពី ការកាប់សម្លាប់ក្រោមរបប ប៉ុល ពត ទៅឲ្យកសាង ប្រទេសឡើងវិញ ក៏ពិតមែន ប៉ុន្តែ ដោយស្ថិតនៅក្រោម ការគាបសង្កត់ របស់ អ្នកដឹកនាំ គណបក្សកុម្មុយនិស្តដដែល គឺ ដូចនៅប្រទេសកុម្មុយនិស្ត នានាឯទៀតដែរៗ នៅក្នុងរបប ក្រោយឆ្នាំ ១៩៩៣ អ្នកចេះដឹង អ្នកមានឧត្តមគតិ ត្រូវរណប នឹង មនុស្សខ្លាំង និង អ្នកមានប្រាក់កាសច្រើន ទើបអាចរស់បានៗ ដោយបញ្ញាគតិបណ្ឌិត នៃ សង្គមទាំងមូល បានត្រូវគេប្រមាថ ដូច្នេះ អ្នកដែលមានបក្សពួក បានឡើងទៅ កាន់ចំណុច ជាយុទ្ធសាស្ត្រ នៃសេដ្ឋកិច្ច និងអំណាចទាំងមូល របស់ប្រទេស ជាហេតុធ្វើឲ្យ អំពើ ពុករលួយ ក្លាយ ទៅជាក្រឹត្យក្រម នៃ «ការរីកចំរើន»ទៅវិញៗ រីឯលទ្ធផល គឺដូចពាក្យ គេថា «ឃ្លោកលិច អំបែងអណ្តែត» ដូច្នេះ ដែរៗ សម្រេចសម្រួច ទៅប្រជាជនក្រីក្រ កាន់តែក្រីក្រថែមទៀត រី

ឯ អ្នកបេះ ដីង កាន់តែធ្លាក់ជ្រៅទៅៗ ទៅក្នុងភាពឥតប្រយោជន៍ ឬ ក៏ក្លាយទៅជា ទាសករ ទាសាទាសី ដាច់ថ្លៃ របស់អ្នកមានប្រាក់កាសតែម្តង ។ តើនេះ ជា បាតុភូត សម័យទំនើប នៃ ពិភពលោក ឬ ក៏ជា កល្លណៈពិសេស របស់ សង្គម-នយោបាយខ្មែរ (exception cambodgienne) ក្រោយរបប ប៉ុល ពត ?

## ស្ថានភាព សង្គម-សេដ្ឋកិច្ច ៧ ឆ្នាំក្រោយ អន្តរាគមន៍ របស់ អង្គការ សហប្រជាជាតិ

### Situation économique et sociale 7 ans après l'intervention de l'O.N.U.

ប្រាំពីឆ្នាំក្រោយអន្តរាគមន៍ របស់ អង្គការសហប្រជាជាតិ ប្រទេសកម្ពុជា បានត្រូវ ធនាគារ ពិភពលោក ចាត់ទុកថា ជាប្រទេសមួយ ក្នុងចំណោមប្រទេស ទាំង ២៩ ដែល ការអភិវឌ្ឍន៍ មានកម្រិតទាបជាងគេបំផុត ក្នុងពិភពលោក ។ ផលទុនប្រចាំឆ្នាំមធ្យម នៃ ប្រជាជនម្នាក់ៗស្ថិតនៅក្នុងកម្រិត ២៨០ ដុល្លារប៉ុណ្ណោះ ។ ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ១៩៩៧ ចំនួនអ្នកក្រីក្រ ដែលគ្មាន លទ្ធភាពរស់នៅត្រឹមត្រូវ បានចុះថយបន្តិចមកវិញ គឺ បានចុះពី ៣៩ % មក ៣៦ % ។ នៅទីក្រុងភ្នំពេញ អ្នកក្រីក្រ តាមចំណាត់ថ្នាក់នេះ មានចំនួន ១១ % ប៉ុន្តែ នៅតាមទីប្រជុំជនខេត្តផ្សេងៗមានចំនួន ៣០% ហើយនៅតាមជនបទ សុទ្ធ សាធ គឺ មានចំនួនរហូតដល់ទៅ ៤០ % ។ ទោះជាយ៉ាងនេះក្តី ក៏ការលូត លាស់ សេដ្ឋកិច្ច នៃ ប្រទេសទាំងមូល បានឈាន ពី ៤ % ទៅ ៥ % ដែរ ។ តាមការពិត អ្នកដែលទទួលផល ពី ការលូតលាស់នេះ គឺ ច្រើនតែ ជា អ្វី ដែលគេហៅថា «អ្នកមាន» ប៉ុណ្ណោះ ព្រោះ បើពិនិត្យមើលស្ថិតិ នៃ ការលូតលាស់នេះ គេនឹងឃើញថា ជីវភាពនៃអ្នកក្រីក្របំផុត ដែល មានចំនួន ប្រមាណ ២០ % នៅតែពុំឈានទៅរក លក្ខណៈប្រសើរសោះៗ ទន្ទឹមនោះ





បើគេពិនិត្យ មើលកម្រិតជីវភាព អ្នកមានជាងគេបំផុត វិញ គឺ បានកើនទៅ ដល់ ១៨ % ។ ហេតុដូចម្តេចបានជាអ្នកក្រ ងើបចេញពុំរួច ពីភាពក្រីក្រសោះដូច្នេះ ? អ្វី ដែលគេសង្កេត ឃើញជាបឋម គឺ ក្នុងចំណោមភូមិ ទាំងអស់ចំនួន ១ ៣. ៤០៦ ចំនួន សាលារៀន បឋម សិក្សា មានមិនដល់ពាក់កណ្តាល នៃ ចំនួនភូមិទាំងអស់ នោះផង ។ បើគេពិនិត្យមើល ស្ថានភាពការងារវិញ គឺ ឃ្លាតឆ្ងាយច្រើនណាស់ ពីនិយាមដែលច្បាប់បានកំណត់ៗ នៅក្នុង ចំណោមរោងចក្រ ដែលមានច្បាប់ត្រឹម ត្រូវទាំងអស់ចំនួន ២៥០ នៅក្នុងរយៈពេលនោះ គឺ មានតែជាង ១៧៨ រោង ចក្រ ប៉ុណ្ណោះ ដែលមាន ដំណើរការប្រក្រតី ។ គេសង្កេតឃើញ ម៉្យាងទៀតថា ៣០ % នៃ កូតា នាំផលិតផល វាយនភ័ណ្ឌ ចូលទៅ សហរដ្ឋអាមេរិក បាន ត្រូវប្រទេសជិតខាងដណ្តើមយកអស់ ទោះបីសុទ្ធតែមានផ្លាកប្រាប់ថា «ផលិតនៅកម្ពុជា» ក្តី (made in Cambodia) ។ នៅក្នុងវិស័យយុត្តិធម៌ គេក៏ពុំឃើញ មាន លក្ខណៈល្អប្រសើរ ដូចគ្នាអ៊ីចឹងដែរ ។ ច្បាប់បានត្រូវនាម៉ឺន និង កងយោ ធា រំលោភជារឿយៗ ជាពិសេស ការដណ្តើមយក ដីធ្លី របស់ ប្រជាកសិករ ជាហេតុធ្វើឲ្យមាន ពាក្យគេនិយាយ នៅពេល នោះថា : «កាលពីមុន យើងភ័យខ្លាច ពួកបរទេស លួចទឹកដី របស់យើង ។ បច្ចុប្បន្ននេះ យើងខ្លាច រដ្ឋអំណាច របស់ យើងតែម្តង» ។

នៅពេលដែលច្បាប់ បានត្រូវគេរំលោភទាំងកម្រោល អំពើឧក្រិដ្ឋកម្មក៏ស្តែងចេញ ឡើងយ៉ាងពេញទំហឹង គ្មានអ្វីអាចទប់ទល់បានឡើយ ។ ការអង្កេត ករណី ឧក្រិដ្ឋកម្មនានា កម្រវែកមុខរកជនឧក្រិដ្ឋឃើញណាស់ៗ គឺនៅក្នុងបរិយាកាស ដ៏គួរឲ្យព្រឺព្រួចផង់ខ្ពងនេះហើយ ដែលនៅថ្ងៃ ៦ កក្កដា ឆ្នាំ ១៩៩៩ នោះ សិល្បការិ ដ៏ល្បីម្នាក់ឈ្មោះ ពិសិដ្ឋ ពាលិកា បាន ត្រូវគេធ្វើឃាតៗ នៅពេលដែល អំពើ ចោរកម្ម កើតឡើងព្រោងព្រាត អត្រា ពេស្យាចារ ក៏ កើន ឡើងយ៉ាងខ្លាំងដែរ ។ នៅឆ្នាំ ១៩៩៩ នោះ អង្គការ យូនីសេហ្វ (U.N.I. C.E.F.) កត់សំគាល់ថា ចំនួនស្ត្រី ដែលប្រកបមុខរបរ នេះ មានចំនួនពី ៦ ម៉ឺន (៦០ ០០០) ទៅ ៧ ម៉ឺន (៧០ ០០០) នាក់ នៅក្នុងប្រទេសទាំងមូល ហើយ នៅក្នុងរាជធានីខ្មែរ ស្ត្រីពេស្យាមាន ចំនួន ១ ម៉ឺន ៥ ពាន់ ( ១៥ ០០០ ) នាក់ ។ ចំពោះបញ្ហាពេស្យាចារនេះ គេសង្កេត ឃើញម៉្យាងទៀតថា ៣៥ % មាន អាយុ ពី ១៥ ទៅ ១៨ ឆ្នាំៗ រី ឯ មូលហេតុ គឺ

ភាពក្រីក្រនេះឯង ។ ដោយទាល់ ប្រកពេក ឪពុកម្ដាយ ដាច់ចិត្តលក់កូនតែម្ដង ដើម្បីយកប្រាក់ចិញ្ចឹមជីវិត។ វិបត្តិ សង្គមមួយទៀត ដែលសង្គ្រាមបានបន្សល់ទុកឲ្យ គឺចំនួនដ៏ច្រើន នៃ ជនពិការ។ ជនពិការ នៅក្នុងសង្គមខ្មែរ ចាប់តាំង ពីពេលក្រោយសង្គ្រាម មានចំនួន ២០ ម៉ឺន ៣ ពាន់ (២០៣ ០០០) នាក់ គឺ ២, ២ % នៃ ចំនួនប្រជាជនទាំងអស់ ។ ប៉ុន្តែជនពិការទាំងនោះ មិនមែន សុទ្ធតែជាជន ដែលទទួលរងគ្រោះ ដោយសង្គ្រាម ប៉ុណ្ណោះ ទេ ។ ២០ % បណ្ដាលមកពីសង្គ្រាម និងការជាន់គ្រាប់មីន នៅតាម វាលស្រែ ហើយ ១ ភាគ ៣ បណ្ដាលមកពីជម្ងឺ ។ កុមារដែលបានចូលរៀន នៅតាមទីក្រុង មានចំនួនច្រើន គឺ ៩៥ % ប៉ុន្តែ នៅតាមជនបទ មានតែ ៤០ % ប៉ុណ្ណោះ។ ទិដ្ឋភាពសង្គមខ្មែរ ប្រាំពីរឆ្នាំក្រោយ អន្តរាគមន៍ នៃ អង្គការ សហប្រជាជាតិ មានលក្ខណៈគួរឲ្យកត់សំគាល់។ នៅពេលដែល ក្រុមអ្នក នយោបាយ ប្រយុទ្ធដណ្ដើមអំណាចគ្នា ហើយនៅពេលដែលអ្នកមានប្រាក់ វាល់លានដុល្លារ កាន់តែមានទៅៗ អ្នកក្រ អ្នកគ្មានបង្អែក បានធ្លាក់ទៅក្នុង ភាពអស់សង្ឃឹមមួយប្រកប ទៅដោយគ្រោះថ្នាក់ ។

## អំពីបញ្ហាកាត់ទោសពួក អតីត មេដឹកនាំ ខ្មែរក្រហម

### Le problème de jugement des chefs khmers rouges

ចាប់តាំង ពីចុងឆ្នាំ ១៩៩៨ មកបញ្ហា ដែលចោទឡើង ចំពោះលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏ ដូចជាចំពោះ របបដែលក្ដាប់អំណាច តាំងពីឆ្នាំ ១៩៩៣ មកដែរ គឺ ការកាត់ទោស អតីតមេដឹកនាំខ្មែរក្រហម។ នៅពេលដែល សហគមន៍អន្តរជាតិ ធ្វើការគាបសង្កត់ ឲ្យយកពួកអ្នកទាំងនោះទៅ ឲ្យតុលា ការវិនិច្ឆ័យទោស -ព្រោះគេចាត់ទុកថាអ្វីៗដែលខ្មែរក្រហម បានធ្វើ កន្លងមក ទៅលើ ប្រជាជនខ្មែរ ជាការធ្វើឲ្យប៉ះពាល់ យ៉ាងធ្ងន់ធ្ងរ ទៅលើ មនុស្សជាតិ ទាំងមូលផងដែរ - លោកនាយករដ្ឋមន្ត្រីហ៊ុន សែន និង ព្រះមហាក្សត្រខ្មែរ





បានខិតខំ រកពាក្យដោះសា គ្រប់បែបយ៉ាង ។ ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ ការពារផលប្រយោជន៍ របស់ ប្រទេសចិន កុម្មុយនិស្ត នៅចំពោះមុខការចោទប្រកាន់ទោស និង ការចាប់ថ្នាក់ របស់ សហគមន៍អន្តរជាតិ ។ រីឯ លោក ហ៊ុន សែន ដែលបានត្រូវ ប្រទេសវៀតណាម បន្ទុបឲ្យឡើងមក កាន់អំណាចនៅស្រុកខ្មែរ សុខចិត្តធ្វើសម្ព័ន្ធភាព ជាមួយខ្មែរក្រហមវិញ ដើម្បីរាំងស្ទះ កុំឲ្យខ្មែរមក ពីប្រកពបស្ចិមប្រទេស ឡើងមកកាន់អំណាចបាន បន្ទាប់ពីលទ្ធិកុម្មុយនិស្ត ចុះស្រុត និងអ័ព្ទស្មី ។ ការដែលគួរ ឲ្យកត់សំគាល់ នៅពេលនោះ គឺ ថា មាន ពេលខ្លះ អ្នកដឹកនាំ ជាប្រវត្តិសាស្ត្រ ទាំងពីរនេះ ទាមទារឲ្យកាត់ទោស ពួកមេខ្មែរក្រហម ហើយមានពេលខ្លះ បែរជាសំដែង ការព្រួយបារម្ភខ្លាចការកាត់ទោសនេះ អាច នឹង ធ្វើឲ្យ មានការបាក់បែករវាងខ្មែរ នឹង ខ្មែរទៅវិញ។ ការពិត យួនមិនត្រូវនឹង ចិន ក៏ពិតមែន ប៉ុន្តែបន្ទាប់ពី សហភាពសូវៀត រលំរលាយទៅ ទីក្រុងហាណូយ ក៏អស់បង្អែក ហើយគ្មានជម្រើសអ្វីទៀតក្រៅពី បែរទៅរក ចិនវិញសិន។ នយោបាយ របស់ វៀតណាម នៅពេលនោះ គឺប្រមូលយកខ្មែរ ក្រហម មកដាក់ ក្រោមឃ្នាប របស់ គណបក្ស «ប្រជាជន» ដែលស្មោះត្រង់ នឹងវៀតណាមវិញ ដើម្បី កាត់ផ្ដាច់ឥទ្ធិពលចិន នៅស្រុកខ្មែរ ។ រីឯ សម្ដេច នរោត្តម សីហនុ ដែលបានពឹង កម្លាំងខ្មែរក្រហម និងកងទ័ពវៀតកុង ឲ្យវាយ រំលំ របប«សាធារណរដ្ឋខ្មែរ» របស់ឧត្តមសេនីយ៍ លន់ នល់ និង សិរិមតៈ ព្រះអង្គបានត្រូវ ខ្មែរក្រហម ដែលជាកូនអុកពិតប្រាកដ របស់ ចិន ឡើងមកកាន់អំណាចជំនួស នៅពេល ដែលសាធារណរដ្ឋខ្មែរ រលំបាត់ទៅ ។ អ្វីដែលស្ដែងចេញឡើង យ៉ាងច្បាស់ គឺ ចិន មិន យល់ស្រប នឹងការកាត់ទោសនោះទេ រីឯ វៀតណាម គេទាមទារឲ្យមាន ការកាត់ទោសនេះ ដើម្បីកាត់បន្ថយឥទ្ធិពល របស់ចិន និង ពួកខ្មែរក្រហម។ នៅឆ្នាំ ១៩៧៩ នៅពេល ដែល វៀតណាម វាយរំលំ របប ប៉ុល ពត បានហើយ ពួកគេបានជំរុញ ឲ្យរបប ហេង សំរិន បើកតុលាការមួយ កាត់ទោសពួក អ្នកដឹកនាំខ្មែរក្រហម នៃ របប«កម្ពុជា ប្រជាធិបតេយ្យ» ស្មោះត្រង់ នឹង ចិន ។ ប៉ុន្តែក្រោយមក នៅឆ្នាំ ១៩៨៩ វៀតណាម ហាក់បីដូចជា ត្រូវបង្ខំចិត្តដក ឃ្លាមួយរយៈសិន ពីរឿងនេះ។ តាមការពិត សភាពការណ៍ នេះ មិនពិបាកយល់ ប៉ុន្មានទេ ព្រោះក្រោយឆ្នាំ ១៩៨៩ ប្រទេសវៀតណាមដែលស្ថិតនៅ ក្រោមការគាបសង្កត់

របស់ ចិន បានប្តូរនយោបាយវិញ។ រីឯសម្តេច នរោត្តម សីហនុ ដែលបានត្រូវខ្មែរក្រហម ធ្វើបាបដែរនោះ នៅពេលដែល ពួកនេះ កាន់អំណាច ព្រះអង្គ ក៏ ស្ថិតនៅក្រោមការគាប សង្កត់ របស់ចិនដែរ ។ ដូចនេះ ទោះបី លោក ហ៊ុន សែន ក្តី សម្តេច នរោត្តម សីហនុ ក្តី ចង់កាត់ទោស ខ្មែរក្រហម ដែលស្មោះត្រង់ នឹង ចិន ក៏ដោយ ក៏ សភាពការណ៍នៅពេល នោះ ដែលចិនកំពុងមាន ឥទ្ធិពលខ្លាំង នៅក្នុងតំបន់ មិនអនុញ្ញាត ឲ្យអ្នកដឹកនាំទាំងពីរនេះ សម្រួលការកាត់ទោសនេះ បានឡើយ ។ បញ្ហាសំខាន់ ចំពោះអ្នកទាំងពីរនេះ ដែលចេញ មក ពីប្រកពកុម្មុយនិស្ត ពីរខុសគ្នា គឺ ដណ្តើមអំណាចគ្នា បន្តទៅទៀត ក្រោយកិច្ចព្រម ព្រៀងទីក្រុងប៉ារីស៍ ប៉ុន្តែតាម វិធី នយោបាយសេដ្ឋកិច្ច និង ច្បាប់។ ប៉ុន្តែ ទន្ទឹមនោះ គេក៏ ត្រូវបាត់បង់នូវជំនឿ និងការទុកចិត្ត ពីសំណាក់ សាធារណមតិ និង ប្រជាជនខ្មែរដែលបាន ទទួលរងគ្រោះក្រោមរបប ប៉ុល ពត ដែរ។ សីលធម៌ ក៏ដូចជា យុត្តិធម៌ មាន លក្ខណៈ ប្របូកប្របល់ ពន់ពេកក្រៃ ព្រោះការបែងចែកអំណាចទាំងបី (séparation des pouvoirs) ក៏ដូចជា ការបោះឆ្នោត មានលក្ខណៈមិនច្បាស់លាស់ ជាពិសេស «វប្បធម៌ និទណ្ឌភាព» ។ នៅក្រោមរូបភាព នៃ របបប្រជាធិបតេយ្យ ប្រទេសកម្ពុជា ជារបបផ្តាច់ការនិយមមួយ ដែល កូនអុក របស់ចិន និង កូនអុក របស់យួន ដណ្តើមអំណាចគ្នា ដោយរាំងស្កាត់ជានិច្ច មិនឲ្យអ្នកប្រជាធិបតេយ្យ ចូលមកបាន ។ ក្រៅពីការគាបសង្កត់ ភូមិសាស្ត្រ-នយោបាយ គេសង្កេតឃើញ ម៉្យាងទៀតថា អតីតកាល និង របៀបពិចារណា របស់ អ្នកដឹកនាំទាំង ពីរនេះ បានវិលត្រឡប់មកវិញដដែល។ គេសុខចិត្តរណបបន្តទៅទៀត នឹងប្រទេស កុម្មុយ និស្តទាំងពីរ នៅក្នុងតំបន់ ហើយ មិនព្រម រកប្រកចេញពី បរិបទនេះទាល់តែសោះ ព្រោះ តែម្នាក់ៗ ចង់រក្សាអំណាច របស់គេរៀងៗខ្លួន។ ទាំងនេះ សុទ្ធតែជាកត្តាដែលកំណត់ ការ រារែក របស់ អ្នកនយោបាយទាំងពីរ នៅក្នុងបញ្ហាកាត់ទោស មេដឹកនាំខ្មែរក្រហម។ ខាង បស្ចិមប្រទេស គេយល់ថា បើមិនកាត់ទោសខ្មែរក្រហមទេនោះ ប្រទេស នានាឯទៀត អាច នឹង យកតម្រាប់តាម។ ចំពោះអ្វីដែលទាក់ទង នឹង អតីតកាល វា ក៏ជាចំណែកមួយ នៃ ការអល់អែកនេះដែរ។ ទោះបី អ្នកដឹកនាំទាំងពីរនេះ ស្អប់ខ្ពើម ពួកខ្មែរក្រហម យ៉ាងណាក្តី





ក៏គេពុំអាចគេចផុត ពីចំណាងបក្សសម្ព័ន្ធ ដែលពួកគេ ជា ចំណែកមួយ ដ៏សំខាន់ ដែលគេពុំ អាចប្រកែកបាន ។

ក្រោយ អន្តរាគមន៍ របស់ អង្គការ សហប្រជាជាតិ លោក ហ៊ុន សែន និង សម្តេច នរោត្តម សីហនុ បានទទួលការកិច្ចរៀងៗខ្លួនមួយទៀត គឺយកឈ្នះ ទៅលើអ្នក ប្រជាធិបតេយ្យ ឲ្យទាល់តែបាន។ អំណាច និង បង្កូត ដឹកនាំប្រទេសកម្ពុជាថ្មី មិនអាចត្រូវ ប្រគល់ទៅឲ្យអ្នកចុងក្រោយនេះ ជាដាច់ខាត។ គឺនៅក្នុងន័យនេះហើយ ដែល នៅក្នុងពេល បោះឆ្នោតម្តងៗ ការប្រយុទ្ធគ្នា មានលក្ខណៈកាចសាហាវរកអ្វីប្រៀបផ្ទឹមពុំបាន។ នៅក្នុងភូមិ ភាគអាស៊ី នេះ លទ្ធិប្រជាធិបតេយ្យ តាមបែបបទបស្ចិមប្រទេស មានទំនាស់មួយ យ៉ាងធំ ជាមួយ របនាសម្ព័ន្ធ សង្គម-វប្បធម៌ដែលនៅតែរណបជានិច្ចនឹង របបដឹកនាំ មួយប្រភេទ ដែលមិនប្រគល់ ជោគវាសនា ប្រទេស ទៅឲ្យប្រជាជនឡើយ ទោះបី របៀបរស់នៅ ផ្នែក សម្ភារៈ មានលក្ខណៈ សម័យទំនើប មិនចាញ់ បស្ចិមប្រទេសក្តី ។ ការសិក្សា អំពី ប្រវត្តិ សាស្ត្រ នៃប្រទេស ទាំងឡាយនោះ - រួមបញ្ចូលទាំង ប្រទេសចិនផងដែរ - បានចុះឲ្យ ឃើញថា លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស នៅមានកម្រិតទាបណាស់ ហើយ តាមការពិតទៅ ក៏មិនមែន ជាកង្វល់ ឬជាគោលដៅ នៃ របបនយោបាយ នៃ ប្រទេស ទាំង នោះឡើយ។ អ្នកមានអំណាច មានប្រាក់កាស ត្រូវមានគេគោរពជានិច្ច ហើយ ចាត់ ទុកថា ជាអ្នកមានបុណ្យបារមី ពីជាតិមុនទៀតផង ។ ប្រទេសកម្ពុជា ដែលស្ថិត នៅក្នុងបរិបទ ភូមិសាស្ត្រនោះ មានការពិបាកច្រើន ក្នុងការអនុវត្តន៍ គោលការណ៍ ប្រជាធិបតេយ្យ និង គោលការណ៍ សិទ្ធិមនុស្សតាមបែបបទបស្ចិមប្រទេស ។ មួយវិញទៀត ស្មារតី ជាតិនិយម បានត្រូវអ្នកដឹកនាំ ទាំងនោះយកទៅធ្វើអាជីវកម្មសម្រាប់ពង្រឹងអំណាច របស់គេ និងរបស់ បក្សពួក គ្រួសារ របស់ គេថែមទៀត ។ គឺ នៅក្នុងន័យនេះហើយ ដែលមានអ្នកដឹកនាំខ្លះ ហ៊ានរហូតដល់ទៅ និយាយថា ពួកមេដឹកនាំខ្មែរក្រហម ជា ជនឧក្រិដ្ឋ ប៉ុន្តែមិន មែនជាជន ក្បត់ជាតិទេ។ ប៉ុន្តែអ្នកដែលនិយាយបែបនេះ មិនបានគិតសោះឡើយ ដល់ប្រជាជនអ្នក ទទួលរងគ្រោះជិត ២ លាននាក់ និង ការធ្លាក់ចុះ នៃ អារ្យធម៌ មួយ រហូតដល់ កម្រិតសូន្យ ទៅហើយនោះ ។

# ការបូកសរុបព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រ នៃ ប្រទេសកម្ពុជា ពីឆ្នាំ ១៨៦៣ ដល់ ឆ្នាំ ២០០០

## Rappel succinct des événements de 1863 à 2000

ព្រឹត្តិការណ៍ ប្រវត្តិសាស្ត្រខ្មែរ ដែលខ្ញុំបាននិយាយរៀបរាប់ ជាហូរហែ មកនេះ លាតសន្ធឹងពី ពេលអាណាព្យាបាលបារាំង មកទល់ នឹង ឆ្នាំ ២០០០។ នៅក្នុងរយៈពេលជាងមួយសតវត្សកន្លងមកនេះ ប្រទេសកម្ពុជា បានឆ្លងកាត់ សម័យកាលជាច្រើន ៖ ពីឆ្នាំ ១៨៦៣ ដល់ឆ្នាំ ១៩៥៣ គឺ សម័យ «អាណាព្យា បាលបារាំង»។ នៅក្នុងសម័យកាលនោះ ការបះបោរប្រឆាំង នឹង វត្តមានបារាំង មានជាហូរហែរ រហូតដល់ បារាំង សុខចិត្តផ្តល់ឯករាជ្យឲ្យខ្មែរនៅឆ្នាំ ១៩៥៣ តាមការទាមទារ ដ៏ទទូច របស់ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ ។ ពីឆ្នាំ ១៩៥៣ ដល់ឆ្នាំ ១៩៧០ ប្រទេសកម្ពុជា ស្ថិត នៅក្នុងសន្តិភាព ក៏ ពិតមែន ប៉ុន្តែការប្រទាញប្រទង់គ្នា រវាង អ្នកនយោបាយអភិរក្សនិយម និងកុម្មុយនិស្ត បានរុញច្រានប្រទេសបន្តិចម្តងៗ ឆ្ពោះទៅរកសង្គ្រាម រវាងប៉ុកលោកសេរី នឹងលោកកុម្មុយនិស្ត នៅឥណ្ឌូចិន។ សម្តេច នរោត្តម សីហនុ ប្រកាន់ខ្សែបន្ទាត់ នយោបាយ រេទៅរកប្រទេសកុម្មុយនិស្តចិន និងយួន ដែលក្រោយពេលបារាំងចេញបាត់ទៅ មានមហិច្ឆតា ចង់ដើរតួ ជំនួសបារាំងនៅឥណ្ឌូចិន។ ប៉ុន្តែ ឧត្តមសេនីយ៍ លន់ នល់ និង អ្នកគ្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈ មិនយល់ស្របនឹង នយោបាយនេះ របស់សម្តេច នរោត្តម សីហនុទេ ។ នៅថ្ងៃ ១៨ មិនាឆ្នាំ ១៩៧០ សភាទាំងពីរ ដែលបានតែងតាំង សម្តេច នរោត្តម សីហនុ ជាប្រមុខរដ្ឋ បានទម្លាក់ព្រះអង្គ ពី អំណាចវិញ ដើម្បីដេញកងទ័ពវៀតកុង និង វៀតណាមខាង ជើង ចេញពីទឹកដីខ្មែរ។ ពី ឆ្នាំ ១៩៧០ ដល់ឆ្នាំ ១៩៧៥ ប្រទេសកម្ពុជា បានកសាងរបប សាធារណរដ្ឋលើកទីមួយ នៅក្នុងប្រវត្តិសាស្ត្រ នៃ ប្រទេស កម្ពុជា ប៉ុន្តែ ត្រូវប្រឈមមុខ នឹង កងទ័ព





វៀតណាមកុម្មុយនិស្ត ព្រមទាំងកងទ័ពខ្មែរក្រហម គឺក្រុមអ្នកកុម្មុយនិស្តជាតិនិយម ដែលបានរំដោះខ្លួន ចេញពី កុម្មុយនិស្តវៀតណាម ហើយចូលទៅក្នុង បរិបទ នៃបដិវត្តន៍ កុម្មុយនិស្តចិន។ ទោះមានទំនាស់បែបនេះក្តី ក៏នៅទីបំផុត កងទ័ពខ្មែរក្រហម និងកងទ័ព វៀតណាមម្មុយនិស្ត បានវាយរំលំ របប «សាធារណរដ្ឋខ្មែរ» បានទាំងស្រុង ។ ពួកខ្មែរក្រហមឡើងមកកាន់អំណាច នៅខែមេសាឆ្នាំ ១៩៧៥ ប៉ុន្តែ ដោយបង្ក វិនាសកម្ម ច្រើនពេក របប «កម្ពុជាប្រជាធិបតេយ្យ» របស់ខ្មែរក្រហម បានត្រូវអតីតសម្ព័ន្ធមិត្តរបស់គេ - គឺ ប្រទេសវៀតណាម - ចូលមកឈ្លានពានស្រុកខ្មែរ វាយរំលំចោលនៅថ្ងៃ ៧ មករា ឆ្នាំ ១៩៧៩ ហើយ ដាក់ពួកខ្មែរ ក្រហមដែលបានបះបោរប្រឆាំង នឹង ប៉ុល ពត ឲ្យឡើងកាន់អំណាចវិញ។ សង្គ្រាម រវាងបងប្អូនកុម្មុយនិស្តទាំងពីរ បន្តរហូតដល់ពេលដែល សហភាព សូវៀតរលំរលាយ បាត់ទៅ ។ ក្រោមការគាបសង្កត់ ពីសំណាក់ សហគមន៍ អន្តរជាតិ ជាពិសេសពីសំណាក់ប្រទេស ចិន និង បស្ចិមប្រទេស វៀតណាម ត្រូវបង្ខំចិត្តដកកងទ័ពចេញអស់ពីស្រុកខ្មែរ។ នៅខែកក្កដាឆ្នាំ ១៩៨៩ សន្និសីទអន្តរជាតិ ទីក្រុងប៉ារីស៍ បានសម្រេច បញ្ចប់សង្គ្រាមនៅកម្ពុជា ពោលគឺ សង្គ្រាម រវាង បងប្អូន កុម្មុយនិស្ត ទាំងពីរ ដែលបានធ្វើឲ្យប្រទេសធំៗជាច្រើន ជាប់ពាក់ព័ន្ធជាមួយផងដែរ។ នៅថ្ងៃ ២៣ តុលាឆ្នាំ ១៩៩១ កិច្ចព្រមព្រៀងមួយ រវាង ខ្មែរទាំង ៤ក្រុម បានកំណត់បញ្ចប់ អធិករណ៍ នៅកម្ពុជា។ នៅឆ្នាំ ១៩៩២ អង្គការ សហប្រជាជាតិ ធ្វើអន្តរាគមន៍បញ្ចប់សង្គ្រាមនៅស្រុកខ្មែរ ហើយ បើកឲ្យមានការបោះឆ្នោតសេរី ។ ប៉ុន្តែសាជាថ្មីម្តងទៀត ប្រទេសកម្ពុជា ធ្លាក់ទៅក្នុងការប្រទាញប្រទង់ រវាងចិន នឹង វៀតណាមដដែល ព្រោះ អ្នកនយោបាយខ្មែរ ដែលបានបង្កវិនាសកម្មដោយរុញច្រានប្រទេស កម្ពុជា ឲ្យធ្លាក់ទៅក្នុង កណ្តាប់ដៃ កុម្មុយនិស្ត បានវិលមកវិញដដែល នៅក្នុងរបបថ្មី ។ ដូច្នេះឃើញថា ប្រទេសកម្ពុជា មានសង្គ្រាម រហូត ពី ឆ្នាំ ១៩៧០ មកដល់ឆ្នាំ ១៩៩២ គឺ នៅពេលដែលអង្គការ សហប្រជាជាតិ ចុះមកធ្វើអន្តាគមន៍ ។ អសន្តិសុខ ដែលខ្មែរក្រហមបានបង្ក នៅពេលអន្តរាគមន៍ របស់ អង្គការ សហប្រជាជាតិជា សង្គ្រាមតូចមួយ ដែលគ្មានបរទេសនៅពីក្រោយ ហើយដូចនេះ អង្គការខ្មែរក្រហម ត្រូវបាក់បែក រលំរលាយខ្លួនឯងតែម្តង ក្នុងរយៈកាលមួយ ដ៏ខ្លី ។

# ប្រទេសកម្ពុជា មុន ពេលវត្តមាន របស់បារាំង

មុនពេល ដែលបារាំងមកតាំងទី នៅប្រទេសកម្ពុជា ប្រទេសនេះស្ថិតនៅ ក្នុងការប្រទាញប្រទង់ រវាង ចក្រភពអាណ្ណាម[៦២] និង ប្រទេសសៀមដែលក្រោយឆ្នាំ ១៩៣៨ បានប្តូរឈ្មោះជាប្រទេសថៃ ។ នៅឆ្នាំ ១៨៥៣ ដោយខ្លាច ចក្រភពអាណ្ណាម និង ស្រុកសៀម យកស្រុកខ្មែរទៅចែកគ្នា មួយចំហៀងម្នាក់ ព្រះបាទ អង្គ ឌួង បានសុំឲ្យបារាំង មកជួយធ្វើអន្តរាគម៍។ ប៉ុន្តែ ទាល់តែ ១០ ឆ្នាំ ក្រោយមកទើបបារាំង បានសម្រេចមកជួយខ្មែរ តាមរយៈសន្ធិសញ្ញា អាណាព្យាបាលបារាំង ចុះហត្ថលេខានៅ ថ្ងៃ ១១ សីហាឆ្នាំ ១៨៦៣ ។ វត្តមានរបស់បារាំង បាននាំឲ្យមានការប្រឆាំងយ៉ាងខ្លាំង ពីសំណាក់អ្នកតស៊ូខ្មែរ អស់រយៈពេល ៩០ ឆ្នាំ គឺ រយៈពេលដែលបារាំង ត្រួតត្រាស្រុកខ្មែរ។ នៅក្នុងរយៈពេលនោះ បារាំងបានផ្តាច់ប្រទេសកម្ពុជាពី អំណាចឥទ្ធិពល របស់សៀម ប៉ុន្តែ មុននឹងចាកចេញពី ឥណ្ឌូចិន ពុំបាន គិតគូរប្រគល់ទឹកដីខ្មែរ ដែលប្រទេសវៀតណាម បានកាត់ផ្តាច់យកទៅ តាំងពីសតវត្ស ទី ១៧ មកឲ្យខ្មែរវិញឡើយ។ ទោះបីមាន ការតស៊ូយ៉ាងខ្លាំងក្លា ពីសំណាក់ចលនាដេញបារាំង ចេញពីស្រុកក្តី - គឺ តាំងពី អាចារ្យ សួរ (ឬ អាចារ្យស្វា) ពោធិកំបោរ, ស៊ីវត្ថា, រហូតដល់ សឺង ង៉ុក ថាន់, សឺង ង៉ុក មិញ, អាចារ្យ ហែម ចៀវ ជាដើម - ក៏បារាំង បានជួយប្រទេសកម្ពុជា ឲ្យក្លាយទៅជា ប្រទេសសម័យទំនើបមួយដែរ ។ នៅឆ្នាំ ១៩៥៣ បន្ទាប់ពី មានការតស៊ូ ទាមទារឯករាជ្យ ពីសំណាក់ ចលនាខ្មែរផ្សេងៗ ជាពិសេសពីសំណាក់ព្រះមហាក្សត្រខ្មែរ ព្រះបាទ នរោត្តម សីហនុ បារាំង ក៏សុខចិត្ត ប្រគល់ឯករាជ្យឲ្យខ្មែរ ប៉ុន្តែ ដោយមានការទីសទាល់ក្រៃលែង ដោយហេតុថា ផុតពីបារាំងទៅ ស្រុកខ្មែរនឹង ក្លាយទៅជាចំណី របស់បណ្តាប្រទេសកុម្មុយនិស្ត នៅក្នុងតំបន់ ពោល គឺ វៀតណាម និង ប្រទេសចិន ជាពុំខាន។ ការប្រមើមើលទុកជាមុននេះ របស់ បស្ចិមប្រទេស (គឺ បារាំង និង សហរដ្ឋ អាមេរិក) ពុំខុស បន្តិចណាឡើយ ព្រោះចាប់តាំងពីឆ្នាំ ១៩៦០ មក នយោ

[៦២] បច្ចុប្បន្ននេះ អាណ្ណាម គឺ ជាតំបន់ភាគកណ្តាល នៃ ប្រទេសវៀតណាម ។





បាយអព្យាក្រឹតភាពខ្មែរបានត្រូវ គំរាមកំហែង ដោយប្រទេស ចិន និង ប្រទេសវៀតណាម ដែលនៅពេលនោះ ខិតខំពង្រីកពង្រឹងលទ្ធិកុម្មុយនិស្តនៅក្នុងតំបន់យ៉ាងមមាញឹក។ ប្រទេសវៀតណាម ខាងជើង តាមរយៈ ចលនា វៀតមិញ បានបង្កើត ចលនា កុម្មុយនិស្តខ្មែរមួយនៅស្រុកខ្មែរ។ រីឯ សម្តេច នរោត្តម សីហនុ ក៏គាំទ្រចលនានេះដែរ ដោយ បើកដៃឲ្យកងទ័ព វៀតកុង តាំងទីនៅលើទឹកដីខ្មែរ តាមការស្នើសុំ ពីប្រទេសចិន ដែលកាលនោះមានផែនការ វាយសហរដ្ឋ អាមេរិក ឲ្យចេញអស់ ពីឥណ្ឌូចិន ដើម្បីក្តាប់យក ភូមិភាគនេះទាំងមូលតែម្តង។ កាលដើមឡើយ សម្តេច នរោត្តម សីហនុ ប្រមុខរដ្ឋ នៃ ប្រទេសកម្ពុជាគ្រាន់តែប្រឆាំង នឹង សហរដ្ឋ អាមេរិកប៉ុណ្ណោះ ព្រោះអាមេរិក បានលើកទ័ព មកធ្វើសង្គ្រាម ប្រឆាំង នឹង លទ្ធិកុម្មុយនិស្ត នៅលើទឹកដី ប្រទេសវៀតណាម ។ ប៉ុន្តែក្រោយមកព្រះអង្គ ក៏ធ្លាក់ បន្តិចម្តងៗ ទៅក្នុងកណ្តាប់ដៃ ចិន រើបម្រះខ្លួនលែងរួច ។

នៅឆ្នាំ ១៩៥៩ ចិន និង សហភាពសូវៀតដែលជាប្រទេសកុម្មុយនិស្តដូចគ្នាទាស់ទែងគ្នា យ៉ាងខ្លាំង។ ក្រោយទំនាស់នោះ ចលនាកុម្មុយនិស្ត នៅស្រុកខ្មែរ ក៏បែកចេញជាពីរ ក្រុមបដិបក្ខ ឌរេ ។ ក្រុមមួយ ឧបត្ថម្ភដោយ ចលនា វៀតមិញ-ប្រទេសវៀតណាមខាងជើង- មានសហភាព សូវៀតគាំទ្រ ។ ហូ ជីមិញ ខ្លាចចិនយកទឹកដី ក៏ បែរទៅរកបដិវត្តន៍ សូវៀតវិញ ។ កាលដើមឡើយ ប៉ុល ពត ក៏ស្ថិតនៅក្នុង ចលនា នេះដែរ ប៉ុន្តែចាប់ពីឆ្នាំ ១៩៦៦ បាន សម្រេចយកចិន ជាបង្អែកវិញ ហើយ បង្កើត «បក្សកុម្មុយនិស្តកម្ពុជា»។ នៅខែ មេសាឆ្នាំ ១៩៧៥ ក្រុម ប៉ុល ពត ដែលសម្តេច នរោត្តម សីហនុ ឲ្យឈ្មោះថា «ខ្មែរក្រហម» បានវាយរំលំរបប «សាធារណរដ្ឋខ្មែរ» ដឹកនាំដោយឧត្តមសេនីយ៍ លន់ នល់ និង សិរិមត: ហើយដែលមាន សហរដ្ឋ អាមេរិកជាអ្នកគាំទ្រ។ ការវាយរំលំរបប លន់ នល់ នេះ បានត្រូវសម្តេច នរោត្តម សីហនុ ចូលរួម ផងដែរ ព្រោះ ព្រះអង្គស្មានថា បើរបប លន់ នល់ រលំ ព្រះអង្គ នឹង បានវិលត្រឡប់ មកកាន់អំណាចវិញ។ ប៉ុន្តែការពិត គឺ ប៉ុល ពត ទេ ដែលជាកូនអុក របស់ចិន ពិតប្រាកដ។ អំណាចទាំងអស់ ធ្លាក់ទៅក្នុងដៃខ្មែរក្រហម នៅថ្ងៃ ១៧ មេសាឆ្នាំ ១៩៧៥ រីឯព្រះអង្គ បានត្រឹមមាន តួនាទី ជាប្រមុខរដ្ឋគ្មានអំណាច ប៉ុណ្ណោះ មុន នឹង ក្លាយខ្លួនទៅជាអ្នកទោស របស់ ពួកនេះ បន្ទាប់

ពីព្រះអង្គ សុំលាលែងពីមុខតំណែង ។ ប៉ុល ពត បានយកព្រះអង្គ និង ក្រុមគ្រួសារ ទៅឃុំទុក ក្នុងព្រះរាជវាំង។ ចិន ក៏ពុំខ្វីរវល់ នឹង វាសនា បែបនេះ របស់ អតីតប្រមុខរដ្ឋ ខ្មែរ រូបនេះដែរ ព្រោះនៅពេលនោះ ប្រទេសចិនដែលបានទទួល ជ័យជំនះទាំងស្រុង នៅកម្ពុជា ពុំត្រូវការ ព្រះអង្គ ទៀតឡើយ ។ ប៉ុន្តែ អ្វីដែលចិន មិនបានគ្រោងទុកជាមុន គឺ ការដែលប្រទេសវៀតណាម និង សហភាព សូវៀត ឆ្លៀតយក ឱកាសដែលខ្មែរក្រហម សម្លាប់ប្រជាជនឯងដោយវង្កាល ហើយបែកបាក់ផ្ទៃក្នុង ដើម្បីវាយយកប្រទេសកម្ពុជាតែម្តង។ ទំនាស់ រវាង បងប្អូន កុម្មុយនិស្ត ទាំងពីរនេះ ដែលគេហៅថា «frères ennemis» មានជាយូរមកហើយ ប៉ុន្តែ ទាល់តែឆ្នាំ ១៩៧៨-១៩៧៩ ទើបវៀតណាម វាយរំលំរបបខ្មែរក្រហមបាន ហើយដាក់ខ្មែរក្រហម មួយក្រុមទៀត ឲ្យមកជំនួស។ នៅពេលដែល ប្រទេសវៀតណាម ត្រួតត្រាស្រុកខ្មែរទាំងមូលអស់រយៈពេល ១០ ឆ្នាំ ប្រទេសដែលជាសត្រូវ នឹងសហភាព សូវៀត មាន ជាអាទិ៍ ប្រទេសមួយ ចំនួន នៃសមាគម អាស៊ីអាគ្នេយ៍ ព្រមទាំងប្រទេសចិន និង សហរដ្ឋ អាមេរិកផងដែរ បាននាំគ្នាជួយចលនារំដោះខ្មែរ យ៉ាងពេញទំហឹង គឺ ចលនាតស៊ូខ្មែរ ៣ ក្រុម ដែលនៅក្នុងនោះ មាន ពួកខ្មែរក្រហមផងដែរ។ រីឯក្រុម ២ ទៀត គឺក្រុម រាជានិយម និង ក្រុមអ្នកប្រជាធិបតេយ្យ។ នៅទីបំផុត បន្ទាប់ពី សហភាពសូវៀត រលំរលាយទៅ វៀតណាម គ្មានជម្រើសអ្វីទៀត ក្រៅពីដកទ័ពថយឡើយ។ សន្និសីទអន្តរជាតិទីក្រុងប៉ារីស៍ ឆ្នាំ ១៩៨៩ និង កិច្ចព្រមព្រៀងសន្តិភាព ឆ្នាំ ១៩៩១ បានបញ្ចប់អធិករណ៍ខ្មែរ ដោយមាន អន្តរាគមន៍ ពី អង្គការ សហប្រជាជាតិ នៅឆ្នាំ ១៩៩២ ។

## ឆ្ពោះទៅរកការបញ្ចប់សង្គ្រាម

នៅឆ្នាំ ១៩៩០ ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហប្រជាជាតិ បានសម្រេចធ្វើអន្តរាគមន៍ នៅកម្ពុជា ដោយបង្កើតអង្គការពិសេសមួយ គឺអង្គការ«អាប្រូនុច» (A.P.R.O. N.U.C.) សម្រាប់រៀបចំ ការបោះឆ្នោត តាមបែបបទ ប្រជាធិបតេយ្យពេញលក្ខណៈ។ អង្គការ «អាប្រូនុច» ត្រូវធ្វើសហការ ជាមួយអង្គការមួយទៀត ដែលមានឈ្មោះ ថា «ក្រុម





ប្រឹក្សាជាតិជាន់ខ្ពស់» (Conseil national supérieur) ពោលគឺអង្គការ ដែលតំណាងអធិបតេយ្យ នៃប្រទេសកម្ពុជា នៅក្នុងរយៈកាលឆ្លងកាត់។ នៅថ្ងៃ ១៤ វិច្ឆិកា ឆ្នាំ ១៩៩១ សម្តេច នរោត្តម សីហនុ យាងមក ប្រទេសកម្ពុជាវិញ បន្ទាប់ពីបាននិរទេសខ្លួន អស់រយៈពេលជាង ២០ ឆ្នាំ។ បន្ទាប់ពីមាន ការខ្វែងគំនិតគ្នាអស់រយៈពេល ២ ឆ្នាំ នៅក្នុងការបែកអំណាចគ្នា រវាង គូភាគី ខ្មែរទាំង ៤ ក្រុម ជាពិសេស រវាងក្រុមអ្នកតស៊ូ រំដោះប្រទេសកម្ពុជា ចេញពី ការឈ្លានពាន របស់ កងទ័ព វៀតណាម និង ក្រុមអ្នកដឹកនាំប្រទេសក្រោយពេលដែលកងទ័ពវៀតណាម ចូលមកវាយរំលំរបប ប៉ុល ពត អង្គការ «អាប្រូនុច» ក៏រៀបចំការបោះឆ្នោត នៅឆ្នាំ ១៩៩២។ ខ្មែរក្រហម ដែលត្រូវគូភាគីខ្មែរ ៣ ទៀត ដោះដៃចេញ បានអុកឡុក ការបោះឆ្នោត ដោយឥតកោតក្រែង។ ប៉ុន្តែ នៅទីបំផុតនៅខែឧសភា ឆ្នាំ ១៩៩៣ ការបោះឆ្នោត ក៏បានប្រព្រឹត្តទៅ តាមការគ្រោងទុកប៉ុន្តែ ក៏មិនស្របទាំងស្រុង ទៅតាមគោលការណ៍ នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ឆ្នាំ ១៩៩១ ប៉ុន្មានដែរ ។ ប្រជាជនខ្មែរ ចំនួន ៨៩, ៥៦ % បានចូលរួមបោះឆ្នោត ។ ក្នុងចំណោមគណបក្ស ចំនួន ២០ ដែលឈរឈ្មោះបោះឆ្នោត គេឃើញមានតែ គណបក្ស ៣ ប៉ុណ្ណោះ ដែលលេចធ្លោជាងគេ គឺ គណបក្ស «ប្រជាជន» ដែលជាអតីតគណបក្សកុម្មុយនិស្តខ្មែរ គាំទ្រដោយវៀតណាម គណបក្សរាជានិយម «ហ្វ៊ុនស៊ិនប៉ិច» ដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និង គណបក្ស «ប្រជាធិបតេយ្យសេរី ពុទ្ធសាសនា» របស់ លោក សឺន សាន។ គណបក្សរាជានិយម «ហ្វ៊ុនស៊ិនប៉ិច» បានទទួលលទ្ធផលឈ្នះគេ គឺ បាន ៤៥, ៤៧ % រីឯ គណបក្ស «ប្រជាជន» ដែលមាន លោក ហ៊ុន សែន ជាបេក្ខជន បានទទួល ៣៨, ២២ % ។ គណបក្ស លោក សឺន សាន បានត្រឹម ៣, ៨១ % ប៉ុណ្ណោះ ។ បន្ទាប់ពីការប្រកាសលទ្ធផល លោក ហ៊ុន សែន នៃគណបក្ស ប្រជាជន ពុំ ព្រមទទួលស្គាល់ជ័យជំនះ របស់ គណបក្សរាជានិយមទេ។ នៅពេលនោះ ប្រទេសកម្ពុជា ហៀបតែ នឹង ត្រូវបែងចែកជា ២ តំបន់ ដោយព្រះអង្គម្ចាស់ នរោត្តម ចក្រពង្ស និង លោក សិន សុង នៃ គណបក្ស «ប្រជាជន» រៀបចំ ធ្វើអបគមន៍ ។ ដោយភ័ពសំណាងល្អ ចលនានេះ គ្មានអ្នកណាគាំទ្រឡើយ ។

ដើម្បីដោះស្រាយទំនាស់នេះ គេក៏ នាំគ្នាបង្កើត រដ្ឋាភិបាលចម្រុះមួយ ដែលព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ អ្នកដឹកនាំ គណបក្សរាជានិយម «ហ្វ៊ុនស៊ីនប៉ិច» និង លោក ហ៊ុន សែន នៃ គណបក្ស «ប្រជាជន» ឡើង កាន់អំណាច ជា នាយករដ្ឋមន្ត្រី ទាំងពីរនាក់ក្នុងពេលជាមួយគ្នា តែម្តង។ ចាប់ពីពេលនោះមក ការដណ្តើមអំណាចគ្នាចេះ តែមានបន្តមកទៀត ដូចកាលពី ពេលមុន ទោះបីក្រោមរូភាព នៃការបោះឆ្នោតតាមបែបបទ ប្រជាធិបតេយ្យក្តី។ តាមការពិត ការធ្វើរបៀបនេះ ខុសទាំងស្រុងពីគោលការណ៍ នៃ កិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស៍ ឆ្នាំ ១៩៩១ ដែលកំណត់យក ការបោះឆ្នោតជាធំ ហើយទាត់ចោលទាំងស្រុងរាល់ការចរចារវាង គូបដិបក្ខ  គឺ មានន័យថា អ្នកឈ្នះឆ្នោត ត្រូវតែឈ្នះ អ្នកចាញ់ត្រូវតែចាញ់ ព្រោះជាឆន្ទៈ របស់ ប្រជាជន ជាម្ចាស់ឆ្នោត។ ទោះជាយ៉ាងនេះក្តី ដោយប្រទេស មហាអំណាច ដែលជាប់ពាក់ ព័ន្ធក្នុងរឿងខ្មែរ គេប្រញាប់ដកខ្លួនចេញ ពីអធិករណ៍ខ្មែរ ឲ្យបានឆាប់រហ័សបំផុត គេ ក៏នាំគ្នាបិទភ្នែកសុខ ចិត្តទទួលយក ស្ថានភាពនេះតែម្តងទៅ។ ការចរចា គ្នា រវាងគូភាគីទាំងពីរ ចេះតែមានជាហូរហែ បន្តទៅទៀត ហើយពេលបោះ ឆ្នោតម្តងៗ អំពើហឹង្សា និង ការគំរាមកំហែង ពីសំណាក់គណបក្ស «ប្រជាជន» កើតមាន ឥតឈប់ឈរ ។ គេសង្កេតឃើញថា តាំងពីឆ្នាំ ១៩៩៣ មកការអនុវត្តន៍ លទ្ធិប្រជាធិបតេយ្យនៅស្រុកខ្មែរ បានទទួល បរាជ័យទាំងស្រុង ។ រី ឯ ទំនាស់ ភូមិសាស្ត្រ-នយោបាយ ពីពេលមុន ក៏ពុំមានការប្រែប្រួលអ្វី ជា មូលដ្ឋានដែរ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលកាលពី ទសវត្ស ១៩៨០-៩០ មានការគាំទ្រយ៉ាងមាំ ពី ប្រទេសវៀតណាម មានប្រៀបផ្នែក រចនាសម្ព័ន្ធជាង ក្រុមអ្នកតស៊ូរំដោះប្រទេស កម្ពុជា ចេញ ពីអាណានិគមវៀតណាម។ សម្តេច នរោត្តម សីហនុ ដែលមានការគាំទ្រពីចិន បានទទួលត្រឹម តួនាទីកិត្តិយសប៉ុណ្ណោះ គឺ រហូតដល់ ព្រះអង្គអស់សង្ឃឹមខ្លាំង ក៏ សម្រេច ដាក់រាជ្យតែម្តងនៅឆ្នាំ ២០០៤។ រីឯព្រះអង្គម្ចាស់ រណឫទ្ធិវិញ ដោយដណ្តើម យកអំណាចពី លោក ហ៊ុន សែន មិនបាន ក៏សព្វព្រះទ័យ ធ្វើសហការជិតស្និទ្ធ ជាមួយលោក ហ៊ុន សែន តែម្តងទៅ ។ ទោះជា យ៉ាងណាក្តី ពួកអ្នកប្រជាធិប តេយ្យខ្មែរ ទោះនៅទីណាក៏ដោយ ក៏នៅតែខិតខំតស៊ូបន្តទៅទៀតដែរ ទោះមានឬ គ្មានការគាំទ្រ ពី បស្ចិមប្រទេសក្តី ។





# បរិបទ អន្តរជាតិ និង ភូមិសាស្ត្រ-នយោបាយ

អស់រយៈពេលជាង ៤០ ឆ្នាំកន្លងមក គឺតាំងពីឆ្នាំ ១៩៦៥ មក ទល់ នឹង ឆ្នាំ២០០៥[៦៣] ប្រទេសកម្ពុជា បានធ្លាក់ទៅក្នុង អស្ថិរភាព នយោបាយ មួយ រកច្រកចេញសឹងពុំរួច។ រីឯមូលហេតុ គឺ មិនមែន មកតែពីការដណ្តើម អំណាចផ្ទៃក្នុង ប៉ុណ្ណោះទេ។ បរិបទអន្តរជាតិ ជាពិសេសការប្រជែងកម្លាំងគ្នា រវាងប្រទេសធំៗ នៅក្នុងតំបន់ ដោយមានបង្អែកពីប្រទេស មហាអំណាច ផងដែរ  ក៏ជាកត្តាមួយ ដ៏ចម្បងដែលគេពុំអាចប្រកែកបានឡើយ។ ពីឆ្នាំ ១៩៦០ មកទល់ នឹង ឆ្នាំ ១៩៧៥ ប្រទេសកម្ពុជា ស្ថិតនៅក្នុងការប្រជែងកម្លាំង រវាងលោកសេរី នឹង លោកកុម្មុយនិស្ត ហើយ ពីឆ្នាំ ១៩៧៥ មកដល់ ឆ្នាំ ១៩៩១ ស្រុកខ្មែរ បានទទួលរងគ្រោះ ដោយអធិករណ៍ រវាងប្រទេស កុម្មុយនិស្តធំៗ ២ ដែលដណ្តើមគ្នាក្តាប់ឥណ្ឌូចិន ពោលគឺ រវាង ប្រទេសចិន នឹង ប្រទេសវៀតណាម ដែលមាន សហភាពសូវៀត ជាអ្នកជួយគាំទ្រយ៉ាងពេញទំហឹង។ ដូចយើងបានដឹងរួច មកហើយនៅឆ្នាំ ១៩៧៨-៧៩ ឆ្លៀតពេលដែល របប ប៉ុល ពត -ដែលមាន ចិនគាំទ្រ - ចុះទន់ខ្សោយ ប្រទេសវៀតណាម ដែលបានទទួល ជំនួយ យោធា[៦៤] ពី សហភាព សូវៀត បានវាយយក ប្រទេស

[៦៣] ពេលដែលខ្ញុំ សរសេរ សៀវភៅប្រវត្តិសាស្ត្រនេះ ។

[៦៤] នៅថ្ងៃ ៣ វិច្ឆិកា ឆ្នាំ ១៩៧៨ ប្រទេសវៀតណាម និង សហភាព សូវៀត បានចុះហត្ថលេខាទៅលើ សន្ធិសញ្ញា មិត្តភាព និង សហប្រតិបត្តិការ ។ ប្រាំខែមុនសន្ធិសញ្ញានេះ គឺ នៅថ្ងៃ ២៨ មិថុនា ឆ្នាំដដែលប្រទេសវៀតណាម ចូល ទៅក្នុងអង្គការ ជំនួយសេដ្ឋកិច្ចទៅវិញទៅមក នៃ បណ្តាប្រទេសសង្គមនិយម ដែលរណប នឹង សហភាព សូវៀត។ សូមអាន បន្ថែម សៀវភៅ *Le Cambodge dans la tourmente – Le troisième conflit indochinois* របស់ Nicolas Regaud, L'Harmattan, Paris, 1992, p. 157 .

កម្ពុជាតែម្តង ។ ការឈ្លានពាន នេះ របស់ប្រទេសវៀតណាម បានត្រូវមតិខ្លះបកស្រាយថា ជាការវាយរំលំ របបខ្មែរក្រហម ដែលប្រជាជនខ្មែរ ស្អប់ខ្ពើមជាអតិបរមា។ ប៉ុន្តែ មតិខ្លះទៀតកត់ សំគាល់ថា ជាការឈ្លានពាន ដោយមិនអាចប្រកែកបាន ព្រោះគ្មានអន្តរាគមន៍ ពីអង្គការ សហប្រជាជាតិ។ ម៉្យាងទៀត គឺ ជាទំនាស់ រវាង បងប្អូនកុម្មុយ និស្តទាំងពីរ ។ ថ្ងៃ ៧ មករាឆ្នាំ ១៩៧៩ ជាជ័យជំនះរបស់ សហភាព សូវៀត និង វៀតណាម ទៅលើ ចិន និងខ្មែរក្រហមដែល ជាសត្រូវរួម របស់ពួកគេ។ ទោះជាយ៉ាងណាក្តី ដោយព្រោះតែការវាយប្រហារ របស់ វៀតណាម ទៅលើ ប្រទេសកម្ពុជានេះ រចនាសម្ព័ន្ធ ភូមិសាស្ត្រ-នយោបាយ នៅក្នុងតំបន់មាន ការរង្គោះរង្គើរ យ៉ាងខ្លាំង ជាហេតុធ្វើឲ្យប្រទេសខ្លះនៃ «សមាគមប្រជាជាតិ អាស៊ីអាគ្នេយ៍»ហៅ «អាស៊ាន» ភ័យខ្លាច សហភាព សូវៀត វាតទី មកក្នុងភូមិភាគទាំងមូល។ ចាប់តាំងពីថ្ងៃ ៧ មករាឆ្នាំ ១៩៧៩ នោះមក កម្លាំងប្រយុទ្ធរំដោះ ប្រទេសកម្ពុជា ពីនឹមអាណានិគមនិយម វៀតណាម និង សូវៀត ក៏បាន កកើតឡើង ដោយមានការគាំទ្រ ពីសត្រូវ របស់សហភាពសូវៀត ជាពិសេស សហរដ្ឋ អាមេរិក និង ប្រទេសចិន។ ចលនា តស៊ូខ្មែរ នោះ រួមមានកម្លាំង របស់ ខ្មែរក្រហម ដែលខំប្រមែប្រមូលគ្នាឡើងវិញ ក្រោយការវាយប្រហារ របស់ វៀតណាម កម្លាំង របស់ អ្នកប្រជាធិបតេយ្យខ្មែរនិយមបស្ចិមប្រទេស កម្លាំង របស់ ចលនា រាជានិយម របស់ សម្តេច នរោត្តម សីហនុ និង ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ព្រះរាជបុត្រ មួយអង្គ របស់ សម្តេច នរោត្តម សីហនុ។ នៅទីបំផុត នៅពេល ដែលសហភាព សូវៀត កំពុងធ្លាក់ទៅក្នុង អកិក្រម នៃការរលំរលាយខ្លួន វៀតណាម គ្មានជម្រើសអ្វីទៀតក្រៅ ពីការដកកងទ័ព របស់គេ ថយទៅវិញទេ ប៉ុន្តែ មុននឹងដកកងទ័ពចេញពីប្រទេសកម្ពុជា វៀតណាមនិងសូវៀត បានពង្រឹងមូលដ្ឋានរបស់គេ យ៉ាងមាំ ដើម្បី រក្សាឥទ្ធិពល របស់គេ នៅក្នុងស្រុកខ្មែរ។ នៅឆ្នាំ ១៩៩២ អង្គការ សហ ប្រជាជាតិ ក៏ធ្វើអន្តរាគមន៍ នៅកម្ពុជា ដើម្បី រៀបចំឲ្យមានការបោះឆ្នោតត្រឹមត្រូវតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ តរៀងទៅ។ ប៉ុន្តែការអនុវត្តន៍ពុំបានសម្រេចជាស្ថាពរទេ ព្រោះប្រទេស កុម្មុយនិស្តទាំងពីរ ពុំបានប្រគល់ ជោគវាសនា របស់ ប្រទេសកម្ពុជា ទៅឲ្យខ្មែរ វិញឡើយ ។ គេបានធ្វើអ្វីគ្រប់បែបយ៉ាង ដើម្បីរក្សាទុក អ្នកនយោបាយ





ខ្មែរ ដែលពួកគេធ្លាប់គាំទ្រ និងដឹកនាំ កាលពីពេលមុនកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស៍ ឆ្នាំ ១៩៩១ ។ នៅពេលនោះ ប្រទេស វៀតណាម និង ប្រទេសចិន ត្រូវបង្ខំចិត្តត្រូវរ៉ូវគ្នាវិញ ដើម្បីរាំងស្កាត់ កុំឲ្យបស្ចិមប្រទេសលូកដៃចូល ក្នុងលានប្រជែងកម្លាំង របស់ពួកគេ ។ ទោះជាយ៉ាងនេះក្តី ក៏ទំនាស់ រវាង ប្រទេសវៀតណាម នឹង ប្រទេស ចិននៅតែមានបន្តមកទៀត ព្រោះទីក្រុងហាណូយ មិនព្រមដាក់ ឥណ្ឌូចិនឲ្យស្ថិតនៅ ក្រោមឥទ្ធិពល របស់ ចិនឡើយ ។

នៅក្នុងក្របខណ្ឌ នៃ ការប្រយុទ្ធដណ្តើមឥទ្ធិពលគ្នា រវាង ចិន និង វៀតណាម និង នៅក្រោមរូបភាព នៃ ការបោះឆ្នោត តាមបែបបទ ប្រជាធិបតេយ្យគូភាគីខ្មែរ ដែលមានចិនគាំទ្រ និងក្រុមអ្នកដែល កាលពីមុន បានត្រូវ វៀតណាមបន្តុប ឲ្យកាន់អំណាច ប្រយុទ្ធដណ្តើមអំណាចគ្នាយ៉ាងស្វិតស្វាញ។ គេសង្កេតឃើញថា អ្នកដែលធ្លាប់បានត្រូវវៀតណាមគាំទ្រ ពីពេលមុន មានជំហរ រឹងប៉ឹងជាងអ្នកដែល មានចិនគាំទ្រ។ សម្តេច នរោត្តម សីហនុ ដែលមាន ចិនគាំទ្រ ក្តាប់អំណាច មិនបានទាល់តែសោះ ។ នៅទីបំផុត គឺនៅឆ្នាំ ២០០៤ សម្តេច នរោត្តម សីហនុ ក៏សម្រេចដាក់រាជ្យ តែម្តង ប៉ុន្តែ បានប្រគល់រាជ្យទៅ ឲ្យព្រះរាជបុត្រមួយអង្គ គឺ ព្រះអង្គម្ចាស់ នរោត្តម សីហមុនី [៦៥] ដោយ មានការគាំទ្រ ពីចិនផងដែរ។ នៅពេលក្រោយមកទៀត ចលនារាជានិយម ដឹកនាំដោយព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ[៦៦] ក៏សុខចិត្តធ្វើសហការ ជិតស្និទ្ធ ជាមួយ អតីតគណបក្សកុម្មុយនិស្តខ្មែរ ដែល វៀតណាម បានបង្កើតតែម្តង។ នៅក្នុងពេលដដែលនោះ ចលនា អ្នកប្រជាធិបតេយ្យខ្មែរនៅតែខិតខំធ្វើការតស៊ូ បន្តមកទៀត ទោះបីមាន ឬ គ្មានការគាំទ្រ ពី បស្ចិមប្រទេសក្តី ។ ភាគច្រើននៃអ្នកទាំងនោះសុខចិត្តរស់នៅ យ៉ាងលំបាកលំបិននៅក្រៅប្រទេសជាពិសេស នៅប្រទេស

---

[៦៥] ព្រះអង្គម្ចាស់ នរោត្តម សីហមុនី ដែលជាបុត្រ របស់ សម្តេច នរោត្តម សីហនុជាមួយអ្នកម្នាង ម៉ូនិច ប្រសូតនៅថ្ងៃ ១៤ ឧសភាឆ្នាំ ១៩៥៣ ។

[៦៦] បុត្ររបស់ សម្តេច នរោត្តម សីហនុ ជាមួយអ្នកម្នាង កញ្ញុល។ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ប្រសូតនៅថ្ងៃ ២ មករា ឆ្នាំ ១៩៤៤ ។

បារាំង និង សហរដ្ឋ អាមេរិក ព្រោះ គេយល់ឃើញថា អ្នកដឹកនាំខ្មែរ ក្រោយកិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស៍ឆ្នាំ ១៩៩១ នៅតែស្ថិតនៅ ក្នុងវង្វង់ឥទ្ធិពល នៃប្រទេស វៀតណាម និងប្រទេសចិនដដែល រីឯលទ្ធិប្រជាធិបតេយ្យ កំពុងតែវិវត្តឆ្ពោះទៅរក របបផ្តាច់ការទៀតផង។ រីឯមូលហេតុ នៃ ការតស៊ូរបស់ ពួកគេ គឺការរំដោះប្រទេសកម្ពុជា ឲ្យចេញផុតពីការឃុំគ្រង របស់ វៀតណាម និង ចិន តាមរយៈអ្នកដឹកនាំខ្មែរ ដែលសុខចិត្ត រណប នឹង ប្រទេសទាំងនោះ បន្តទៅទៀត ដើម្បីរក្សាអំណាចរបស់ គេ និងក្រុមបក្សពួក របស់គេ ដែលបើកដៃ ឲ្យជនបរទេស មករកស៊ី នៅស្រុកខ្មែរ នៅក្នុងភាពអនាធិបតេយ្យ ។ នៅក្នុងបរិបទបែប នេះ អំពើ ពុករលួយ កាន់តែ រីករាលដាល យ៉ាងខ្លាំង បង្កើតឡើង នូវ ភាពក្រីក្រមួយបែបដែលស្រុកខ្មែរ មិនដែលជួបប្រទះ។ អ្វីដែលពួកគេ ប្រាថ្នាចង់បាន ជាទីបំផុត គឺលុបបំបាត់លទ្ធិ ប្រជាធិបតេយ្យពិតប្រាកដ ជាពិសេសការគោរពសិទ្ធិមនុស្សដើម្បីសម្រួលដល់ សកម្មភាពខុសច្បាប់ របស់ ពួកគេ ។

# វាសនា ដ៏ អភ័ព្វ នៃ គណបក្សប្រជាធិបតេយ្យ

គណបក្ស «ប្រជាធិបតេយ្យ» ដែលបញ្ញវន្តខ្មែរមួយក្រុមបានបង្កើត នៅខែមេសា ឆ្នាំ ១៩៤៦ បានដើរតួនាទីមួយ ដ៏សំខាន់ នៅក្នុងទំព័រ ប្រវត្តិសាស្ត្រខ្មែរ ។ កាលដើមឡើយ ស្ថាបនិក នៃ គណបក្សនេះ មានជា អាទិ៍ លោក ស៊ិម វ៉ា និង លោក អៀវ កើះ ។ នៅខែមិថុនា ឆ្នាំ ១៩៤៦ ដដែលនោះ អ្នកអង្គម្ចាស់ស៊ីសុវត្ថិ យុត្តិវង្ស[៦៧] បានត្រឡប់មកពីស្រុកបារាំងវិញ ហើយចូលរួមប្រយុទ្ធ យ៉ាងសកម្មនៅក្នុងគណបក្សនេះ។ មិនយូរប៉ុន្មាន ព្រះអង្គបានត្រូវជ្រើសតាំង ជាប្រធាន គណបក្សនេះ តែម្តង។ ទិសដៅដែលគណបក្ស «ប្រជាធិបតេយ្យ» បានកំណត់នៅពេលនោះ គឺការទាមទារឯករាជ្យ ពី បារាំងផង ហើយធ្វើទំនើបកម្ម[៦៨] ប្រទេសកម្ពុជាផង។ ពាក្យថា «ទំនើបកម្ម» សំដៅជាពិសេសទៅលើ ការរៀបចំ ស្ថាប័នដឹកនាំ ប្រទេសឲ្យមានលក្ខណៈ សម័យទំនើប ព្រោះរបបរាជានិយមខ្មែរតាំងពីដើមសតវត្សទី ៩ មក នៅ តែស្ថិតនៅជា របប«ទេវរាជ» ដដែល ទោះបីព្រះមហាក្សត្រត្រូវជ្រើសតាំង ដោយក្រុមប្រឹក្សា រាជបល្ល័ង្កក្តី ហើយទោះបី បានវិវត្តពី ការគោរពបូជា ព្រះសិវលិង្គ មកដល់ ការគោរពលទ្ធិពុទ្ធសាសនា ថេរវាទ (ហីនយាន) ក្តី ដោយ ធ្វងកាត់ការគោរព បូជាសក្ការបុគ្គល «លោកេស្វរៈ» គឺ រូបភាព «ពោធិសត្វ» (ពុទ្ធសាសនា មហាយាន) តាមបែបខ្មែរកាលជំនាន់ ព្រះបាទជ័យវរ្ម័ន ទី ៧ ។ តាមរយៈស្ថាប័នទាំងឡាយនោះ អំណាចទាំងមូលមានប្រភពចេញ មកពី ព្រះមហាក្សត្រ ដែលគេចាត់ទុកថា ជាតំណាងរបស់ ពពួកទេវៈ ។ ការតស៊ូ របស់ គណបក្ស «ប្រជាធិបតេយ្យ» ក្រោមការដឹកនាំ របស់ អ្នកអង្គម្ចាស់យុត្តិវង្សដែលជាខ្សែ ញាតិវង្សព្រះបាទ អង្គអេង បានរកប្រកបោះជំហានទៅ រកទំនើបកម្ម ស្ថាប័នដឹកនាំឃើញ នៅឆ្នាំ ១៩៤៦ ដដែលនោះ គឺប្រែក្លាយ របបរាជានិយម ជាប្រពៃណីឲ្យទៅជា របប «រាជានិយមអាស្រ័យ ដ្ឋធម្មនុញ្ញ» (monarchie constitutionnelle) គឺ របប រាជានិយមដែលគ្រប់គ្រងប្រទេសពី ឆ្នាំ ១៩៤៧ មកទល់ នឹង ឆ្នាំ ១៩៧០ ហើយដែល បន្ទាប់ពី របប «សាធារណរដ្ឋខ្មែរ» (១៩៧០-១៩៧៥) របបខ្មែរក្រហម (១៩៧៥-១៩៧៩) របប «សាធារណរដ្ឋ ប្រជាមានិតកម្ពុជា» (១៩៧៩-១៩៨៩ ) របប «រដ្ឋកម្ពុជា» (១៩៨៩-១៩៩៣ ) បានវិលមកវិញនៅឆ្នាំ ១៩៩៣។ ប៉ុន្តែ ដោយខ្វះបទពិសោធន៍គ្រប់គ្រាន់ របប រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ សម័យឆ្នាំ ១៩៤៧ នោះបានប្រគល់អំណាចទៅថ្វាយព្រះមហាក្សត្រដដែលវិញ ព្រោះតែមាន មាត្រាមួយ បានបើកផ្លូវឲ្យព្រះមហាក្សត្រ ធ្វើដូច្នេះបាន នៅក្នុងកាលៈទេសៈចាំបាច់។ ទោះជាយ៉ាងណាក្តី ក៏គេអាចនិយាយបានថា គណបក្ស «ប្រជាធិបតេយ្យ» បានផ្តល់ទៅឲ្យប្រទេសកម្ពុជា នូវ រដ្ឋធម្មនុញ្ញមួយ លើកដំបូងបង្អស់

[៦៧] អ្នកអង្គម្ចាស់ យុត្តិវង្ស ជាបុត្រទី ៥ របស់ ព្រះអង្គម្ចាស់ ចំរើនវង្ស (ខ្សែរាជវង្សព្រះបាទអង្គអេង) ជាមួយអ្នកអង្គម្ចាស់ ស៊ីសុវត្ថិ យុពិផាន់ (ខ្សែរាជវង្សព្រះបាទស៊ីសុវត្ថិ) ។ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស (១៩១២-១៩៤៧) ដែលភ្ជាប់ ជាមួយ ខ្សែ របស់ព្រះមាតាបានទៅសិក្សានៅប្រទេសបារាំងហើយបានសញ្ញាបត្របណ្ឌិតរដ្ឋខាងវិទ្យាសាស្ត្រ (docteur ès sciences) ផ្នែក រូបវិទ្យា។

[៦៨] ប្រើពាក្យ ទំនើបភាវូបនីយកម្ម ក៏បាន ។

សម្រាប់ដឹកនាំប្រទេសដែរ គឺ ខុសពីពេលអតីតកាល ដែលអំណាចទាំងអស់ ជាកម្មសិទ្ធិដាច់ថ្លៃ របស់ ព្រះមហាក្សត្រ ។ ទោះបី នៅពេលក្រោយមក ព្រះមហាក្សត្រ បានយកអំណាច ទៅកាន់តែម្នាក់ព្រះអង្គវិញតាមរយៈការបង្កើតស្ថាប័នថ្មីមួយ[៦៩]ទន្ទឹមគ្នាក្តី ក៏បញ្ញវន្តនិង អ្នកចេះដឹងគ្រប់ប្រភេទ មានសិទ្ធិធ្វើការតស៊ូបន្តទៅទៀត តាមផ្លូវច្បាប់ដែរ។ ក៏ ប៉ុន្តែជាអកុសល ការតស៊ូនោះ បានទទួលបរាជ័យទៅវិញ នៅឆ្នាំ ១៩៥២ ក្រោម កិត្យានុភាព ដ៏ធំមហិមា របស់ ព្រះមហាក្សត្រខ្មែរ ព្រះបាទ នរោត្តម សីហនុ ដែលបានធ្វើការតស៊ូទាមទារឯករាជ្យ រហូត ដល់បានសម្រេច ដោយ គ្មានការបង្ហូរឈាម។ ទោះជាយ៉ាងនេះក៏ដោយ ក៏ ជីវិត នយោបាយ ពុំមាន លក្ខណៈដូចកាលពី ពេលមុនទាំងអស់ដែរ ។

ជោគជ័យ ដ៏ធំ បំផុត និងជាប្រវត្តិសាស្ត្រ នៃគណបក្ស«ប្រជាធិបតេយ្យ» បានស្តែងចេញឡើង នៅពេលបោះឆ្នោតជ្រើសតាំង សភាធម្មនុញ្ញ នៅថ្ងៃ ១ កញ្ញាឆ្នាំ ១៩៤៦។ នៅពេលនោះ គណបក្ស «ប្រជាធិបតេយ្យ» បានទទួល ៥០ អាសនៈនៅក្នុង សភាធម្មនុញ្ញ ក្នុងចំនួនអាសនៈទាំងអស់ ៦៩ ។ គណបក្ស «ប្រជាធិបតេយ្យ» ដែលមានការគាំទ្រយ៉ាងមាំពី សំណាក់បញ្ញវន្ត មន្ត្រីរដ្ឋការ រក្សា ជោគជ័យនេះបាន បន្តមកទៀត នៅពេលបោះឆ្នោតសភា ខែកញ្ញា ឆ្នាំ ១៩៥១ គឺ បានទទួលដល់ទៅ ៥៤ អាសនៈ ទោះបី នៅពេលនោះ មានការបង្កើតគណបក្ស នយោបាយ ជាច្រើនថែមទៀត ដើម្បីសាកល្បងកាត់ បន្ថយឥទ្ធិពលរបស់ គណបក្ស «ប្រជាធិបតេយ្យ» នេះក្តី ។ នៅក្នុងរយៈ ពេលតស៊ូ ដ៏ ក្តៅគគុក របស់ខ្លួន គណបក្ស «ប្រជាធិបតេយ្យ» បានឆ្លងកាត់ ឧបសគ្គ និង ការវាយប្រហារជាច្រើន។ ព្រះអង្គម្ចាស់យុត្តិវង្ស ទទួលមរណភាពនៅថ្ងៃ ១១ កក្កដាឆ្នាំ ១៩៤៧ ហើយលោក អៀវកើះ បានត្រូវគេធ្វើឃាត នៅថ្ងៃ ១៤ មករាឆ្នាំ ១៩៥០ ។ នៅពេលក្រោយមក គេសង្កេតឃើញមានចរន្ត ជាច្រើននៅក្នុងគណបក្ស «ប្រជាធិបតេយ្យ»នេះ។ ខ្លះ ជាអ្នកតស៊ូតាមបែប

[៦៩] នៅថ្ងៃ ១៤ មិថុនាឆ្នាំ ១៩៦០ សម្តេច នរោត្តម សីហនុ បានត្រូវតែងតាំង ដោយរដ្ឋសភា ជាប្រមុខរដ្ឋ ប្រទេសកម្ពុជាបន្ទាប់ពីព្រះអង្គ បានដាក់រាជ្យថ្វាយទៅ ព្រះមាតា និងព្រះបិតា នៅ ថ្ងៃ ៣ មិនា ឆ្នាំ ១៩៥៥ ។



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

បទ លទ្ធិម៉ាក្សនិយម ខ្លះទៀតជា កម្លាំងបង្កប់ របស់ ពួកអ្នកអភិរក្ស ។ មួយចំនួន ទៀតជាអ្នកឈរកណ្តាលដោយទទួលស្គាល កិត្យានុភាព របស់ព្រះមហាក្សត្រ ហើយខ្លះទៀតជាអ្នកឱកាសនិយមសុទ្ធសាធ។ នៅឆ្នាំ១៩៥៧ គឺ ២ ឆ្នាំក្រោយ ពេលដែលព្រះមហាក្សត្រ នរោត្តម សីហនុ ដាក់រាជ្យហើយ បង្កើតចលនា «សង្គមរាស្ត្រនិយម» គណបក្ស ប្រជាធិបតេយ្យ ក៏បាត់ស្រមោលតែម្តង ។ នៅថ្ងៃ ១១ សីហា ឆ្នាំ ១៩៥៧នោះ ក្រោយ ការតតាំងជា សាធារណៈមួយ ជាមួយ សម្តេចឧបយុវរាជ នរោត្តម សីហនុ អំពើ ហឹង្សាមួយបានឲ្យ សញ្ញាថា អំណឹះតទៅប្រទេសកម្ពុជា នឹង មានគណបក្ស តែមួយប៉ុណ្ណោះ គឺ គណបក្សរបស់ សម្តេច នរោត្តម សីហនុ ផ្ទាល់តែម្តង ។

លក្ខណៈពិសេស នៃ គណបក្ស «ប្រជាធិបតេយ្យ» ខ្មែរ គឺ សមាសភាព ដ៏គួរឲ្យកត់សំគាល់ នៃស្ថាបនិក និង អ្នកដឹកនាំ។ គឺជាលើកដំបូងហើយ ដែលអ្នកចេះដឹង ចេញមកពីមជ្ឈដ្ឋាន និងស្រទាប់សង្គមនានា បានមូលមតិគ្នា ធ្វើការតស៊ូរំដោះប្រទេស ឲ្យចេញផុតពីអំណាច របស់ «ពួកសក្តិភូមិ» ប៉ុន្តែ និន្នាការនិងចរន្ត ក៏មានលក្ខណៈសម្បូណ៌បែបដែរ ។ មួយចំណែក អ្នកមាន និន្នាការសេរីនិយម ហើយមួយចំណែកទៀត អ្នកដែលមានទំនោរ ទៅរកលទ្ធិ ម៉ាក្សនិយម [៧០]។ ទោះជាយ៉ាងណាក្តី គោលដៅ របស់ បណ្តាបញ្ញវន្តទាំងនោះ មានតែមួយប៉ុណ្ណោះ នៅពេលនោះ គឺ ទាមទារឯករាជ្យ ពីបារាំងឲ្យបានសិន។ អ្នកជំនាន់ទី ១ មានជាអាទិ៍ លោក ស៊ីម វ៉ា លោក អៀវកើះ, លោក ឈាន វ៉ម និងអតីតអ្នកកាសែត «នគរវត្ត»មួយ ចំនួនផងដែរ គឺ កាសែត ដែលបានត្រូវបង្កើតឡើង នៅ

[៧០] ឯកសារជាច្រើន បានកត់សំគាល់ថា អ្នកអង្គម្ចាស់យុត្តិវង្សបានអាន សៀវ ភៅ *Manifeste du Parti communiste* របស់ កាល ម៉ាក្ស និង អង់ហ្គែល ដែល លោក ដាក់ជាប្រចាំ នៅក្បាលដំណេក ។

ឆ្នាំ ១៩៣៦ ដោយ លោក សឺង ង៉ុក ថាន់ [៧១] លោក ប៉ាច ឈឺន និង លោក ហែម ចំរើន ។ បន្ទាប់មកទៀត អ្នកអង្គម្ចាស់យុត្តិវង្ស និង លោក ថុន អ៊ុក ដែលបានទៅបំពេញវិជ្ជា នៅស្រុកបារាំង បានវិលត្រឡប់ មកកម្ពុជាវិញ ហើយ ចូលជា សមាជិក គណបក្សនេះដែរ នៅឆ្នាំ ១៩៤៦។ បួនឆ្នាំក្រោយមកទៀត ចាប់ពីឆ្នាំ ១៩៥០ មកទល់នឹងឆ្នាំ ១៩៥៥ និស្សិតខ្មែរដែលទៅរៀន នៅស្រុក បារាំងហើយដែល បានទទួលសញ្ញាបត្រ ឧត្ដមសិក្សា សំខាន់ៗ ក៏ បានវិលមកវិញជាបន្តបន្ទាប់ ហើយនាំគ្នាធ្វើសកម្មភាព នយោ បាយ នៅក្នុងគណបក្ស «ប្រជាធិបតេយ្យ»នេះ យ៉ាងមមាញឹក។ ភាគច្រើន មាននិន្នាការឆ្វេងនិយម តួយ៉ាង ព្រះអង្គម្ចាស់ នរោត្តម ភូរិស្សរា [៧២] លោក សិន ខេមកូ, លោក ស្វាយ សូ, លោក កេង វ៉ាន់សាក់, លោក ជួន មុម្ម ។ នៅពេលនោះ សាឡុត ស (ប៉ុល ពត) និង អៀង សារី ដែលក្រោយមក បានក្លាយទៅជាមេខ្មែរ ក្រហម ក៏មានទំនាក់ទំនង នឹង «គណបក្ស ប្រជាធិបតេយ្យ» នេះដែរ ប៉ុន្ដែ មិនចូលជាសមាជិកទេ។ ក្រៅពីអ្នកដែលមាន និន្នាការ ឆ្វេង និយម សមាជិកភាគច្រើន សុទ្ធតែជាអ្នកដែលមាន និន្នាការ «កែទម្រង់និយម» ហើយ ចង់ផ្ដល់ទៅឲ្យ ប្រទេសកម្ពុជា នូវ របបសភានិយម ។ អ្នកខ្លះ ទៀត ដែលគេពិពណ៌នាថា ជាអ្នកមាននិន្នាការសេរីនិយម (libéraux) ច្រើនតែជាអ្នកដែលមានគំនិត និង យុទ្ធសាស្ត្រ អភិរក្ស ដូចជាលោក ប៉ែន នុត និង លោក សឺន សាន ជាដើម។ មុនដំបូង ឥស្សរជន

[៧១] អ្នកវិភាគខ្លះ កត់សំគាល់ថា លោក សឺង ង៉ុក ថាន់ ជាអ្នកជាតិយម ប្រឆាំងនឹង បារាំង ហើយពុំជឿថា លោកជាអ្នកប្រជាធិបតេយ្យ យ៉ាងណានោះ ទេ។ ប៉ុន្ដែ អ្នកប្រជាធិបតេយ្យ ខ្មែរ ជាច្រើន ចាត់ទុកលោកថា ជាអ្នកប្រជាធិបតេយ្យ ។

[៧២] ប្រសូតនៅឆ្នាំ ១៩១៩ ព្រះអង្គម្ចាស់ន រោត្តម ភូរីស្សរា ជាបុត្ររបស់ ព្រះអង្គម្ចាស់ នរោត្តម ផានុវង្ស ជាមួយ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សង្វារី ។ ព្រះអង្គម្ចាស់ ផានុវង្ស (១៨៧១-១៩៣៧) ជាបុត្រ របស់ ព្រះបាទ នរោត្តម ជាមួយ ឃុន ថាន់ ។ បុត្រ ៣ អង្គទៀត របស់ ព្រះបាទនរោត្តម ជាមួយ ឃុន ថាន់ គឺ ៖ ព្រះអង្គម្ចាស់ ដួង ចក្រ (សុគតនៅឆ្នាំ ១៨៩៧) យុគន្ធរ (បាត់ខ្លួន នៅឆ្នាំ ១៩០០) និង ហាស្សកាន់ សុគត នៅឆ្នាំ ១៨៨៨) ។



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ទាំងពីរនេះ មានការអល់អែកបន្តិចដែរ មុន នឹងចូលជាសមាជិក នៃ គណបក្ស «ប្រជាធិបតេយ្យ» នេះ។ ប៉ុន្ដែនៅឆ្នាំ ១៩៤៧ លោក ប៉ែន នុត ក៏បានសម្រេចចូលក្នុង គណបក្សនេះ ដោយ សមាជិកជាច្រើន នៃគណបក្ស បានស្នើប្រគល់មុខនាទី ជាប្រធានសភាជម្មនុញ្ញ ទៅឲ្យលោក ដើម្បីជំនួសលោក ឈាន វ៉ម។ រីឯ លោក សឺន សានវិញ លោកភ័យខ្លាចក្រែង គណបក្ស «ប្រជាធិបតេយ្យ» មានគោលដៅ ប្រែក្លាយ រាជាណាចក្រខ្មែរ ឲ្យទៅជ ារបប សាធារណរដ្ឋ តែម្ដង ។ មុនដំបូង លោក រេរា បន្តិចដែរ ប៉ុន្ដែ ដោយឃើញ ព្រះអង្គម្ចាស់ យុត្តិវង្ស ជាអ្នកដឹកនាំចលនា លោកក៏មានការកក់ក្ដៅវិញ ។ នេះបើយោងទៅ តាមការសិក្សាស្រាវជ្រាវ របស់ លោកស្រី ម៉ារី អាឡេចសង់ឌ្រីន ម៉ារតាំង [៧៣] ។

នៅឆ្នាំ ១៩៤៧ គណបក្ស «ប្រជាធិបតេយ្យ»ដែលគេនិយមហៅ ថា «គណបក្សក្បាលដំរី» កាន់តែមានសមាជិកអ្នកចេះដឹង ច្រើនឡើងៗ អ្នកដែលមានសញ្ញាបត្រធំៗមក ពីស្រុកបារាំង ក៏ចូលរួមចំណែកដែរ។ គេសង្កេតឃើញ មានជាអាទិ៍ ៖ លោក ហ៊ុយ កន្ធុល លោក សុន វ៉ុនសៃ លោក សម ញ៉ាន លោក យ៉ែម សារុង។ ទោះជាយ៉ាងនេះក្ដី នៅពេលនោះ គេមានការពិបាក នឹង ជឿថា គណបក្សនេះអាចនឹងទទួលជ័យជំនះ នៅពេល បោះឆ្នោតខាងមុខ ព្រោះ បារាំងដែលគាំទ្រ ព្រះមហាក្សត្រ នរោត្តម សីហនុ ក៏ខ្លាំង ណាស់ដែរ នាពេលនោះ ។ ប៉ុន្ដែ គួរឲ្យអស្ចារ្យណាស់ នៅទីបំផុត គណបក្ស «ប្រជាធិបតេយ្យ» បានទទួលជ័យជំនះដ៏ធំ នឹកស្មានមិនដល់។ នេះជាសក្ខីកម្មដែលបញ្ជាក់ថា ប្រជាជនខ្មែរ ដ៏ច្រើនលើសលុប ពិតជាស្រឡាញ់ លទ្ធិប្រជាធិបតេយ្យ ហើយ មានជំនឿទៅលើអ្នកចេះដឹងខ្មែរ ជាងពួកនាម៉ឺនស្ដេច។ ខ្លះទៀតយល់ថា គឺ មកពី គណបក្ស «ប្រជាធិបតេយ្យ» មានព្រះអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស ដែលជា អភិជន ជាអ្នកដឹកនាំ ។ ទោះជាយ៉ាងណាក្ដី ក្រោយមរណភាព របស់ ព្រះអង្គម្ចាស់ យុត្តិវង្ស គណបក្ស «ប្រជាធិបតេយ្យ» បានទទួលជ័យជំនះ កាន់តែខ្លាំងថែមទៀត ។ នៅពេលបោះឆ្នោត ឆ្នាំ ១៩៥១ គណបក្ស «ប្រជាធិបតេយ្យ» បានទទួលដល់ទៅ ៧០ នៃ អាសនៈនៅរដ្ឋសភា។ ប៉ុន្ដែក្រោយមកទៀត គណ

[៧៣] Marie Alexandrine Martin, *Le mal cambodgien*, Paris, Ha-chette, 1989.

បក្សនេះ ដែលជាស្នាដៃដ៏ធំ និងជាប្រវត្តិសាស្ត្រ របស់បញ្ញវន្តខ្មែរ បានត្រូវអ្នកខ្វាំង និងពួកអ្នកឱកាសនិយម បំបែកបំបាក់ខ្ទេចខ្ទីអស់។ ទោះជាយ៉ាងនេះ ក៏ដោយ ក៏ប្រវត្តិសាស្ត្រ បានចារទុក នូវ សេចក្តីក្លាហានអង់អាច របស់អ្នកបេះដូងខ្មែរ កាលជំនាន់នោះដែរ ។

## អភិក្រមទំនើបកម្ម ប្រទេស កម្ពុជា ចាប់តាំង ពីដើមសតវត្ស ទី ២០

ប្រវត្តិសាស្ត្រខ្មែរ កាលជំនាន់ អាណានិគមបារាំង ពុំមែនតែជា សម័យ កាលមួយដែលសកម្មភាព នៃចលនាតស៊ូ របស់ អ្នកស្នេហាជាតិ ជា ព្រឹត្តិការណ៍ សំខាន់តែមួយមុខប៉ុណ្ណោះទេ។ ទន្ទឹម នឹងការបះបោរ របស់ ពួក អ្នកដែលប្រឆាំង នឹង បារាំងអស់រយៈពេល ៩០ ឆ្នាំ គឺ ពីឆ្នាំ ១៨៦៣ មកទល់ នឹងឆ្នាំ ១៩៥៣ - ដែលខ្វះមានប្រទេសវៀតណាមនៅពីក្រោយ -ប្រទេស កម្ពុជា ក៏ បោះជំហានសន្សឹមៗ ឆ្ពោះទៅរក ភាពសម័យទំនើបដែរ ដោយ ការ ខំប្រឹងប្រែង របស់ បារាំង ទោះជាតិចជាង នៅប្រទេសវៀតណាម ដែលជាប្រទេសអាណានិគមបារាំងផ្ទាល់ក្តី [៧៤]។ ការធ្វើទំនើបកម្មប្រទេសកម្ពុជា ដែលជាប្រទេសធ្លាប់មានអារ្យធម៌ ដ៏ស្ពឹមស្លៃ មិនមែន ជាការងាយស្រួលឡើយ ចំពោះអ្នកដែលចង់កសាងមូលដ្ឋាន អភិវឌ្ឍន៍ មួយថ្មីទៀត ដែលមានលក្ខណៈ ខុសទាំងស្រុង ពី របៀបរស់នៅ ជាប្រពៃណី របស់ អ្នកម្ចាស់ស្រុក។ មួយវិញទៀត គឺ ការកសាងមូលដ្ឋាន អភិវឌ្ឍន៍ តាម របៀបស្រុកបារាំង នេះតែម្តង ជាពិសេស ការរំលោភទៅលើអធិបតេយ្យ របស់ ខ្មែរ

[៧៤] ទោះបីប្រទេសកម្ពុជាត្រូវគេចាត់ទុកថាជា ប្រទេសអាណានិគម បារាំងក្តី ក៏ តាមការពិត វត្តមានបារាំង នៅកម្ពុជា ឈរនៅលើគោលការណ៍ «អាណាព្យាបាល» របស់ បារាំងតែប៉ុណ្ណោះ (Protectorat français) ។ ប៉ុន្តែ បន្តិចម្តងៗ បារាំងបានដើរហួស ពីគោលការណ៍ នេះទៅទៀត ជាហេតុនាំឲ្យមាន ការបះបោរ ដ៏ ខ្លាំងក្លា ក្នុងទូទាំងប្រទេស ។



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ដោយ រ៉េស៊ីដង់បារាំង ដែលជាកត្តា នៃការបះបោរផ្សេងៗរបស់ប្រជាជន ជាពិសេស របស់ស្តេច និង មន្ត្រី របស់ ស្តេច ។ បារាំងត្រួតត្រា ស្រុកខ្មែរជំនួសស្តេចខ្មែរ ហើយថែមទាំងយកអំណាចទាំងមូល ពីស្តេចខ្មែរទៀតផង ។ ដើម្បីរៀបចំ មូលដ្ឋាននេះ ដែលគេហៅថា «ការកែទម្រង់» បារាំងបានដណ្តើមយកអំណាច ពីព្រះមហាក្សត្រខ្មែរ ដោយត្រង់ៗ នៅឆ្នាំ ១៨៨៤ ម្តង និង នៅឆ្នាំ ១៨៩៧ ម្តងទៀត ។ នៅឆ្នាំ ១៨៨៤ ការប៉ុនប៉ង មុនដំបូង បង្អស់ របស់ បារាំង [៧៥]បានទទួលបរាជ័យទាំងស្រុង ព្រោះ មានមហាកុបកម្មមួយ បានផ្ទុះឡើង ហើយ បានផ្តាច់ជីវិត ទាហានបារាំង អស់ជាច្រើន។ ប៉ុន្តែ នៅឆ្នាំ ១៨៩៧ [៧៦] បារាំង បានសម្រេចផែនការនេះរបស់គេ។ ចាប់តាំងពីពេលនោះមក ដំណើរការទំនើបកម្ម បានប្រព្រឹត្តទៅ ដោយពុំជួប នូវ ឧបសគ្គ អ្វីធំដុំឡើយ ។ នៅ ឆ្នាំ ១៨៩៧ នោះ នៅក្នុងក្របខណ្ឌ នៃការកែទម្រង់រដ្ឋបាល ព្រះបាទនរោត្តម បាន ចេញព្រះរាជក្រឹត្យមួយចុះថ្ងៃ ១១ កក្កដា បង្កើតក្រុមប្រឹក្សារដ្ឋមន្ត្រី ពោល គឺ រដ្ឋាភិបាល តាមបែបបទបស្ចិមប្រទេស ។ ប៉ុន្តែ កាលនោះ ក្រសួង មានតែប្រាំ ប៉ុណ្ណោះ ។ នៅ ឆ្នាំ ១៩០១ បារាំង បាន បែងចែក ប្រព័ន្ធរដ្ឋបាល ជាឃុំ (communes) ប៉ុន្តែ មិនបានសម្រេច ។ ទាល់តែឆ្នាំ ១៩០៨ ទើបធ្វើទៅបាន ។ នៅក្នុងពេលជាមួយគ្នានោះ បារាំង បានវាយរំលំ របបទាសភាព ចោលតែម្តង ហើយអំណាច របស់ព្រះមហាក្សត្រ ក៏ចុះខ្សោយដែរព្រោះដើម្បីធ្វើទំនើបកម្ម ស្ថាប័នដឹកនាំនានា រ៉េស៊ីដង់ស៊ុបេរ៉ីយើរបារាំង ក្តាប់យកអំណាចទាំងមូល ។ យ៉ាងណាមិញ អ្នកដឹកនាំក្រុមប្រឹក្សារដ្ឋមន្ត្រី គឺរ៉េស៊ីដង់បារាំងតែម្តង។ នៅឆ្នាំ ១៩៤៧ បញ្ញវន្តខ្មែរមួយក្រុម បានប្រែក្លាយ របបរាជានិយម ប្រពៃណីខ្មែរ ឲ្យទៅជារបប «រាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ»[៧៧]។

[៧៥] អនុសញ្ញាដែលបារាំងបង្ខំឲ្យខ្មែរទទួលយក នៅថ្ងៃ ១៧-២៤ មិថុនា ឆ្នាំ ១៨៨៤ តម្រូវឲ្យស្តេចខ្មែរយល់ព្រមឲ្យ បារាំង ធ្វើការកែទម្រង់ ផ្នែករដ្ឋបាល ផ្នែកច្បាប់ ផ្នែកហិរញ្ញវត្ថុ និង ផ្នែកពាណិជ្ជកម្ម ។

[៧៦] រាជក្រឹត្យ ចុះថ្ងៃ ១១ កក្កដា ឆ្នាំ ១៨៩៧ ។

[៧៧] ព្រះមហាក្សត្រ សោយរាជ្យ ប៉ុន្តែ មិនកាន់អំណាចដោយផ្ទាល់ទេ ។

គឺ តាំងពីពេលនោះ មកហើយ ដែលប្រទេសកម្ពុជា មានរដ្ឋធម្មនុញ្ញដឹកនាំ ដោយមានការបែងចែក អំណាចត្រឹមត្រូវ ទៅតាមលទ្ធិប្រជាធិបតេយ្យ តាមបែបបទបស្ចិមប្រទេស ។ ក្រោយការ រលំរលាយ នៃ គណបក្ស «ប្រជាធិបតេយ្យ» របប បែងចែកអំណាចនៅតែមានរូបរាងបន្តទៅទៀត ទោះបី សម្តេច នរោត្តម សីហនុ ក្តាប់អំណាចរដ្ឋ ទាំងមូលតាមរយៈចលនា «សង្គមរាស្ត្រនិយម» ក្តី គឺចលនា មួយដែលព្រះអង្គបានបង្កើត ដើម្បីឈានទៅដល់របប «បក្សតែមួយ» ដូចនៅ ក្នុងបណ្តាប្រទេសកុម្មុយនិស្ត ។

នៅក្នុងសម័យសង្គមរាស្ត្រនិយម គឺ ពីឆ្នាំ ១៩៥៥ មកដល់ថ្ងៃ ២៨ ធ្នូ ឆ្នាំ ១៩៦៩ សម្តេច នរោត្តម សីហនុ បានបន្ត អភិក្រមទំនើបកម្ម យ៉ាងសកម្មដែរ ប៉ុន្តែការគោរព គោលការណ៍ ប្រជាធិបតេយ្យ មានការរង្គោះរង្គើ យ៉ាងខ្លាំង ជាហេតុធ្វើឲ្យ ការកំណត់នយោបាយ ក្រៅប្រទេស មានលក្ខណៈអត្តនោម័តប្រកបដោយគ្រោះថ្នាក់ គឺ ឃ្លាតឆ្ងាយ ពីនយោបាយអព្យាក្រឹតភាព ហើយ រយ៉ាងខ្លាំង ទៅរក ប្លុក បណ្តាប្រទេសសង្គមនិយម ដែលជា សត្រូវយុទ្ធសាស្ត្រ របស់ លោកសេរី។ នៅពេលនោះ លទ្ធិកុម្មុយនិស្តកំពុង តែមានឥទ្ធិពល ខ្លាំងមហិមា ទៅលើបញ្ញវន្ត និងអ្នកនយោបាយ នានា នៅក្នុងតំបន់ហើយ ប្រទេសកម្ពុជា ក្រោមការដឹកនាំ របស់ សម្តេច នរោត្តម សីហនុ ក៏ ចេញពុំផុតពីឥទ្ធិពលនេះដែរ ។ ទោះជាយ៉ាងនេះក្តី ក៏ វប្បធម៌ បារាំង ដែលត្រូវអ្នកមានទំនោរ ទៅរកលទ្ធិម៉ាក្សនិយម ចាត់ទុកថា ជាវប្បធម៌ «ប្រតិកិរិយា» នៅតែមានជំហរ បន្តមកទៀត គឺមានរហូតដល់ ពេលទីអវសាន នៃ របប «សាធារណរដ្ឋខ្មែរ»។ បញ្ញវន្តមួយភាគធំ ដែលបានទទួលឥទ្ធិពល ពីវប្បធម៌បារាំង បានដើរតួនាទីមួយ ដ៏សំខាន់ នៅក្នុងការបង្កើត របបសាធារណរដ្ឋខ្មែរនេះ មុន និងក្រោយពេល ដែលសភាទាំងពីរ បានទម្លាក់សម្តេច នរោត្តមសីហនុ ពី តួនាទីប្រមុខរដ្ឋ គឺ មុខតំណែងដែលសភា បានប្រគល់ ថ្វាយព្រះអង្គ នៅថ្ងៃ ១៤ មិថុនាឆ្នាំ ១៩៦០ ។ នៅពេលដែល ព្រះអង្គ ក្តាប់ រដ្ឋកម្ពុជាទាំងមូល តែម្នាក់ព្រះអង្គសម្តេច នរោត្តម សីហនុ បានសាកល្បងកែស្ថាប័នរដ្ឋខ្លះៗ ដើម្បីដោះស្រាយ ទំនាស់ផ្សេងៗ រវាងស្ថាប័ន ចម្លងពីបារាំង នឹង វប្បធម៌ខ្មែរ ប៉ុន្តែនេះ ជាអភិក្រមទំនើបកម្ម មួយបែប ដែលពុំបានផ្តល់សន្ទុះ សេដ្ឋកិច្ច អ្វីប៉ុន្មាន ទៅឲ្យកម្ពុជាទេ ព្រោះ តាមការពិត គឺជា





ស្ថាប័ន ដែលចម្លងចេញពី នៃ បណ្តាប្រទេស កុម្មុយនិស្ត ហើយ ដែលគ្មាន ការបែងចែកអំណាច ។ រដ្ឋក្តាប់អំណាចសេដ្ឋកិច្ច យ៉ាងណែន ជាហេតុធ្វើឲ្យ អំពើ ពុករលួយ រីករាលដាលនៅក្នុងស្ថាប័ន នានា ។ ការប្រជែង រវាង សេដ្ឋកិច្ចរដ្ឋ និង សេដ្ឋកិច្ចឯកជន បានត្រឹមធ្វើឲ្យ សេដ្ឋកិច្ចទាំងមូល បាត់បង់ នូវ សន្ទុះដើម តែប៉ុណ្ណោះ ។

## របបនយោបាយ ជំនាន់ «សង្គមរាស្ត្រនិយម»

នៅក្នុងរយៈពេល ៩០ ឆ្នាំ ក្រោមការគ្រប់គ្រង របស់ «អាណាព្យា បាលបារាំង» ប្រទេសកម្ពុជា បានឆ្លងកាត់ រាជ្យស្តេច ៤ អង្គ គឺ ព្រះបាទ នរោត្តម (១៨៦០-១៩០៤) ដែលមានព្រះនាមដើម អង្គ វត្តី ព្រះបាទស៊ីសុវត្ថិ (១៩០៦-១៩២៧ ) ព្រះបាទ ស៊ីសុវត្ថិ មុនីវង្ស (១៩២៧- ១៩៤១) និង ព្រះបាទ នរោត្តម សីហនុ។ គឺនៅក្នុងរាជ្យទី ១ (១៩៤១-១៩៥៥) នៃ ព្រះបាទ នរោត្តម សីហនុ នេះហើយ ដែលប្រទេសកម្ពុជា បានទទួលឯករាជ្យពីបារាំង (៩ វិច្ឆិកា ឆ្នាំ ១៩៥៣)។ ក្រោយពេលបានឯករាជ្យ ព្រះបាទនរោត្តម សីហនុ គ្រងរាជ្យ បានតែ ២ ឆ្នាំប៉ុណ្ណោះ ព្រោះព្រះអង្គ បានដាក់រាជ្យថ្វាយទៅព្រះមាតា និងព្រះបិតា របស់ព្រះអង្គ ដើម្បីចូលប្រយុទ្ធក្នុងឆាកនយោបាយ តទល់នឹងគណបក្ស «ប្រជាធិបតេយ្យ»។ ២ ឆ្នាំក្រោយ ពីនោះមកទៀត គណបក្ស «ប្រជាធិបតេយ្យ» ដឹកនាំដោយបញ្ញវន្ត ត្រូវបែកបាក់ខ្ចាត់ខ្ចាយអស់។ តាំងពីពេលនោះមក សម្តេច នរោត្តម សីហនុ គ្រប់គ្រងប្រទេស ដោយគ្មានដៃគូ។ ក្រោយពេលដាក់រាជ្យ ព្រះអង្គមានព្រះរាជឋានៈជា សម្តេចឧបយុវរាជ [៧៨] ហើយ នៅថ្ងៃ ២៣ មិនា ឆ្នាំ ១៩៥៥ ដដែលនោះ ព្រះអង្គ បានបង្កើតចលនា នយោបាយមួយ មានឈ្មោះថា «សង្គមរាស្ត្រនិយម»។ ឥស្សរជន នយោបាយ និងបញ្ញវន្ត ដែលមាននិន្នាការ ស្តាំ អភិរក្ស បានចូលរួមក្នុង ចលនានេះ តួយ៉ាង លោក ស៊ិមវ៉ា លោក សម សារី ជាដើម។ នៅឆ្នាំ ១៩៦០ ព្រះអង្គ ត្រូវសភាទាំងពីរ តែងតាំងជា

[៧៨] Vice-roi

ប្រមុខរដ្ឋ [៧៩] នៃ ប្រទេសកម្ពុជា ។ របប នយោបាយ ដែលសម្ដេច នរោត្ដម សីហនុ បាន បង្កើតនៅក្នុងក្របខណ្ឌ នៃចលនានេះ គឺ របប ដែលគ្មានគណបក្សប្រឆាំង នៅក្នុងរដ្ឋសភា ព្រោះគណបក្សចំនួន ៩ ដែលមាន ពីមុន បានត្រូវរលំរលាយអស់ ដោយឥស្សរជន សំខាន់ ៗ នៃគណបក្សទាំងនោះ បានចូលរួមក្នុងចលនា «សង្គមរាស្ត្រនិយម» នេះ អស់ ទៅហើយ ។ ក្រោយមក ចលនា «សង្គមរាស្ត្រនិយម»នេះ ដែលកាលដើមឡើយ មានតែ អ្នកស្ដាំអភិរក្សនិយម បានទទួលសមាជិកថ្មីៗទៀត ដែលមាននិន្នាការ ឆ្វេងនិយម ឬ ក៏ កុម្មុយនិស្តតែម្ដង ក៏អាចថាបាន ។ ខាងនិន្នាការ ស្ដាំនិយមអភិរក្ស និង សេរីនិយម លោក សម សារី លោក ស៊ិម វ៉ា លោក យ៉ែម សំបូ ។ រីឯចលនា សេរីនិយម ឯករាជ្យ តាមគំរូ បស្ចិមប្រទេស មានលោក ឌុក រ៉ាស៊ី ជាអ្នកតំណាង ។ នៅឆ្នាំ ១៩៦៦ លោក ឌុក រ៉ាស៊ី និង លោក ប៉ូល លីតែសួន ដែលមិនយល់ស្រប នឹងមាគ៌ា នយោបាយ របស់ សម្ដេច នរោត្ដម សីហនុ បានបង្កើតកាសែតប្រឆាំងមួយ គឺ ទិនានុប្បវត្តិ ជាភាសាបារាំង *Phnom Penh Presse* ។ ក្រៅពីនិន្នាការស្ដាំ អភិរក្ស និង សេរីនិយម តាមបែបបស្ចិមប្រទេស គេឃើញមាន ចលនា របស់ បញ្ញវន្តឆ្វេងនិយម ដែលតំណាងដោយ លោក ចៅ សេង លោក ហ៊ូ យន់ លោក ខៀវ សំផន លោក សូ ណែម ។ នៅឆ្នាំ ១៩៦៦ ទិនានុប្បវត្តិ ជាភាសាបារាំង *La Dépêche du Cambodge* បាន ប្ដូរឈ្មោះ មកជា *La Nouvelle Dépêche du Cambodge* ហើយបានត្រូវ លោក ចៅ សេង យកទៅប្រើធ្វើ ជាឧបករណ៍ នយោបាយ សម្រាប់អ្នកឆ្វេងនិយម ដែលមាននិន្នាការបែរទៅកេបដិវត្តន៍ចិន បន្ទាប់ពី លោក ស៊ិម វ៉ា ចេញបាត់ទៅ។ នៅ «សម័យសង្គមរាស្ត្រនិយម» (១៩៥៥-១៩៦៩) នោះ

[៧៩] បើនៅក្នុងរបប សាធារណរដ្ឋ គឺ ប្រធានាធិបតី។ អ្នកវិភាគខ្លះយល់ថា គឺជា រដ្ឋប្រហារ មួយដែល បានប្រព្រឹត្តទៅ ដោយស្ងាត់ៗ ។ របបរាជានិយម នៅដដែល ក៏ ពិតមែន ប៉ុន្តែ អំណាចទាំងមូល ស្ថិតនៅក្នុងដៃប្រមុខរដ្ឋទាំងអស់ រីឯព្រះមហាក្សត្រ ទាំងពីរអង្គដែលគ្រង រាជ្យ គ្រាន់តែជានិមិត្តរូប ដែលតំណាងរាជវង្សប្រជិបក្ខធំៗទាំងពីរ ប៉ុណ្ណោះ គឺ ខ្សែ នរោត្តម និង ខ្សែ ស៊ីសុវត្ថិ ។





អ្នកប្រកាន់និន្នាការ បដិបក្ខទាំងពីរ ប្រុយទ្ធគ្នាយ៉ាងខ្លាំងក្លា នៅក្នុងរដ្ឋសភា ក៏ដូចជា នៅក្នុង រដ្ឋាភិបាល «សង្គមរាស្ត្រនិយម» នៅក្នុងវិស័យសិក្សាធិការជាតិ ក៏ដូចជា នៅក្នុងវិស័យ សារពត៌មាន ជាហេតុធ្វើ ឲ្យមានការផ្លាស់ប្ដូររដ្ឋាភិបាល ជាញឹកញាប់។ ទន្ទឹមនឹងដំណើរការ នៃ ស្ថាប័នដឹកនាំ ដែលកំណត់ ដោយ រដ្ឋធម្មនុញ្ញ ប្រជាធិបតេយ្យ ឆ្នាំ ១៩៤៧ [៨០] សម្ដេច នរោត្តម សីហនុ បានបង្កើតស្ថាប័នមួយចំនួនទៀត ដើម្បីសាកល្បងកាត់បន្ថយតួនាទី នៃ អំណាច និតិប្បញ្ញត្តិ ដូចជា សមាជជាតិ និង សភាប្រជាជន នៅតាមខែត្រជាដើម ។ គេអាចនិយាយបានថា បន្ទាប់ពី ការកែទម្រង់ រដ្ឋធម្មនុញ្ញ តាមរយៈប្រជាមតិ ថ្ងៃ ៧ កុម្ភៈ ឆ្នាំ ១៩៥៥ គឺ មួយខែ មុនការដាក់រាជ្យ របស់ ព្រះអង្គ សម្ដេច នរោត្តម សីហនុ បានផ្ដល់ ទៅឲ្យប្រជាប់កំពូលខ្មែរ នូវរបៀបគ្រប់គ្រងមួយថ្មីទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល នឹង របប ដែលមាន នៅក្នុងប្រទេស កុម្មុយនិស្ត ។

តាំងពីពេលដែលព្រះបាទនរោត្តម សីហនុ ដាក់រាជ្យសម្បត្តិ ហើយបង្កើត ចលនា «សង្គមរាស្ត្រនិយម» ជីវិតនយោបាយ នៃ ប្រទេសកម្ពុជា ស្ថិតនៅក្រោមឥទ្ធិពលនៃសមាជ ជាតិ ដែលសម្ដេចនរោត្តម សីហនុ ដឹកនាំ ដោយផ្ទាល់ព្រះអង្គ ក្នុងនាមព្រះអង្គ ជាមេ ចលនានេះផង ហើយ ក្នុងនាម ជាប្រមុខរដ្ឋផង។ សូមកត់សំគាល់ថា «សមាជជាតិ» មាន លក្ខណៈពុំខុសប៉ុន្មាន ពីមហាសន្និបាតបក្ស នៅក្នុងរបបប្រទេសកុម្មុយនិស្ត ដែលគណ បក្សកុម្មុយនិស្ត ត្រួតត្រារដ្ឋ ដោយផ្ទាល់នោះទេ។ រីឯ ឈ្មោះ ចលនា «សង្គមរាស្ត្រនិយម» ដែលព្រះអង្គបានឲ្យឈ្មោះ ក៏ ប្រហាក់ប្រហែល នឹង ពាក្យ សង្គមនិយមដែរ ។ ដូចនេះ គេអាចយល់ យ៉ាងច្បាស់ អំពីគោលបំណង របស់ ព្រះអង្គ គឺ ក្ដាប់អំណាចរដ្ឋ ទាំងមូល តាមរយៈចលនា «សង្គមរាស្ត្រនិយម» របស់ព្រះអង្គ ដើម្បីឈានទៅត្រួសត្រាយមាគ៌ា នយោបាយ មួយថ្មី ខុស ពី របបប្រជាធិប តេយ្យ តាមបែបបទ បស្ចិមប្រទេស សម្រាប់

[៨០] រដ្ឋធម្មនុញ្ញ នេះ បានត្រូវ សម្ដេច នរោត្តម សីហនុ ធ្វើវិសោធនកម្ម យ៉ាង ដំណាំ តាមរយៈនីតិក្រមចុះថ្ងៃ ១៥ ធ្នូ ឆ្នាំ ១៩៥៥ ហើយ ដែលត្រូវប្រកាស ឲ្យ ប្រើ នៅថ្ងៃ ១៤ មករា ឆ្នាំ ១៩៥៦ ។

ប្រទេសកម្ពុជា សម័យទំនើប ហើយ ក្នុងពេលជាមួយគ្នានោះ ស្អាត់ផ្លូវមិនឲ្យបញ្ញវន្ត ដែលនិយម លទ្ធិប្រជាធិបតេយ្យសេរីនិយម ចូលមកក្នុងឆាក នយោបាយ បានផង ។ មិនតែប៉ុណ្ណោះ ព្រះអង្គ ក៏ មានគោលដៅមួយទៀតដែរ គឺកាត់បន្ថយឥទ្ធិពល ពួកគហបតី ដែលជាមូលដ្ឋាន នៃ អ្នកនយោបាយសេរីនិយម ។ នៅក្នុងគោលដៅនេះ គេ សង្កេតឃើញថាព្រះអង្គ ទ្រង់ធ្វើអ្វី គ្រប់បែបយ៉ាង ដើម្បីបន្ថន់ល្បឿន នៃ អភិក្រម សេរីកម្មសេដ្ឋកិច្ច ឲ្យបានច្រើនបំផុត។ បើគេមិននិយាយ ពី ការលុបបំបាត់ចោល បន្តិចម្តងៗ នូវគោល ការណ៍បែងចែកអំណាច តាមបែបបទ លទ្ធិប្រជាធិបតេយ្យសេរីនិយមទេនោះ ការខំប្រឹងប្រែងនេះក៏ បានកាត់បន្ថយ ឥទ្ធិពល ដ៏ខ្លាំងមហិមា នៃ អ្វីដែលគេហៅថា «អ្នកមូលធននិយម» ផងដែរ។ បញ្ហាដែលចោទ គឺថា តើឲ្យអ្នកមូលធននិយម ក្តាប់សេដ្ឋកិច្ច ឬ មួយត្រូវឲ្យរដ្ឋ ក្តាប់សេដ្ឋកិច្ច តែម្តង? ប៉ុន្តែដោយមន្ត្រី ជាអ្នកដឹកនាំសេដ្ឋកិច្ច ការអភិវឌ្ឍន៍ក៏ចុះថយជាលំដាប់ ដូចនៅក្នុង របបសេដ្ឋកិច្ចរដ្ឋនានាដូច្នេះដែរ។ មួយវិញទៀត ដោយ នយោបាយក្រៅប្រទេសកាត់ផ្តាច់ ទំនាក់ទំនងចេញ ពីសហរដ្ឋ អាមេរិក សេដ្ឋកិច្ចខ្មែរនៅពេលនោះ ក៏បាត់បង់សន្ទុះអភិវឌ្ឍន៍ របស់វា ជាច្រើនកម្រិត។ នៅថ្ងៃ ១៨ មិនាឆ្នាំ ១៩៧០ សភាទាំងពីរ បានទម្លាក់សម្តេច នរោត្តម សីហនុ ពីតួនាទីព្រះអង្គជាប្រមុខរដ្ឋ ដោយ មូលហេតុនយោបាយមួយ ដ៏ក្តៅ គគុកនៅពេលនោះ គឺ ការដែលកងទ័ពវៀតមិញ និង វៀតកុង បានយក ទឹកដីខ្មែរទៅប្រើប្រាស់ដើម្បីប្រយុទ្ធ នឹង កងទ័ពអាមេរិក នៅប្រទេសវៀតណាម ។ ក្រោយការទម្លាក់សម្តេច នរោត្តម សីហនុ ប្រទេសកម្ពុជា ក្រោមការ ដឹកនាំ របស់ ឧត្តមសេនីយ៍ លន់ នល់ និង សិរិមតៈ ដែលមានការគាំទ្រ ពី សហរដ្ឋ អាមេរិក បានជ្រើសរើសយករបប សាធារណរដ្ឋ សម្រាប់គ្រប់គ្រងប្រទេស  ប៉ុន្តែ ពួកខ្មែរក្រហម ក្រោមកិត្យានុភាពរបស់ សម្តេច នរោត្តម សីហនុ បានវាយរំលំរបប នេះនៅថ្ងៃ ១៧ មេសាឆ្នាំ ១៩៧៥ ។ តាំងពីពេល នោះមក ប្រទេសកម្ពុជា ធ្លាក់ទៅក្នុងជ្រោះ នយោបាយមួយ ដ៏ មហាសែនជ្រៅរហូតមកដល់ឆ្នាំ ១៩៩២-៩៣ គឺ ពេលដែល អង្គការ សហប្រជាជាតិ ធ្វើអន្តរាគមន៍ នៅកម្ពុជា ។





# ការប្រយុទ្ធក្នុងឆាកនយោបាយ
# របស់ សម្តេច នរោត្តម សីហនុ

ដូចយើងបានឃើញ ជាហូរហែរួចមកហើយ ចាប់តាំងពីឆ្នាំ ១៩៣៦ មក បញ្ញវន្តខ្មែរបានធ្វើការតស៊ូប្រឆាំង នឹងបារាំង យ៉ាងខ្លាំងក្លា តាមរយៈចលនា តស៊ូផ្សេងៗ ។ ចលនាខ្លះផ្អែកទៅលើគំនិត ជាតិនិយម [៨១] សុទ្ធសាធ ខ្លះប្រាថ្នាចង់រំដោះប្រទេសពី បារាំងផង ហើយផ្តល់ទៅឲ្យស្រុកខ្មែរ នូវប្រព័ន្ធដឹកនាំ ប្រជាធិបតេយ្យផង ។ ខ្លះទៀត ជាសាខា នៃចលនាកុម្មុយនិស្ត ឥណ្ឌូចិនតែម្តង។ បញ្ញវន្តអ្នកជាតិនិយម ជាអ្នកចង់រក្សាវប្បធម៌ ខ្មែរទាំងស្រុង ពោលគឺ របៀបរបបរស់នៅ របៀបគិតពិចារណា និង ដឹកនាំប្រទេស តាមបែបបទប្រពៃណីខ្មែរ។ រីឯអ្នកប្រជាធិបតេយ្យជំនាន់ទី ១ ដែលភាគច្រើន ជាបញ្ញវន្តដែល បានទៅសិក្សានៅប្រទេសបារាំង គេចង់ធ្វើការកែទម្រង់គ្រប់វិស័យ គឺ ទាំងវិស័យ ស្ថាប័នគ្រប់គ្រងប្រទេស ទាំង វិស័យចិត្តគំនិត និង ការអភិវឌ្ឍន៍ ។ អ្នកប្រជាធិបតេយ្យជំនាន់ ទី ២ ដែលច្រើនតែជាអ្នកដែលបាន ធ្វើការសិក្សា នៅស្រុកបារាំងដូចអ្នកជំនាន់ទី ១ ដែរ ចង់ប្រែក្លាយស្រុកខ្មែរឲ្យទៅជាប្រទេស ដែលកាន់លទ្ធិសង្គមនិយមតែម្តង ។ បញ្ហាដែលចោទឡើងនៅពេលនោះ គឺ បដិវាទកម្ម រវាងវប្បធម៌ខ្មែរ នឹង ក្រឹត្យក្រមរីកចម្រើន តាមបែបបទបស្ចិមប្រទេស ឬតាមបែបបទប្រទេសកុម្មុយនិស្ត។ ចំពោះបញ្ញវន្ត ជាតិនិយម ជាពិសេស ចំពោះបញ្ញវន្ត អភិរក្សនិយម វប្បធម៌ខ្មែរ មានលក្ខណៈសម្បត្តិ គ្រប់គ្រាន់ សម្រាប់ធ្វើដំណើរ

---

[៨១] អ្នកអង្គម្ចាស់នរោត្តម ចន្ទរង្សី និង លោក សឺន ង៉ុក ថាន់ បានត្រូវអ្នក សង្កេតការណ៍ខ្លះចាត់ទុកថា ស្ថិតនៅ ក្នុងចរន្តនេះ។ បញ្ញវន្តភាគច្រើន ដែលធ្វើការតស៊ូ ក្នុងជួរគណបក្ស «ប្រជាធិបតេយ្យ» ធ្វើការទាមទារឯករាជ្យផង ហើយចង់បានលទ្ធិប្រជាធិបតេយ្យផង។ អ្នកតស៊ូមួយចំនួនស្ថិតនៅក្នុងចលនា បក្សកុម្មុយនិស្តឥណ្ឌូចិនដែល ហូ ជីមិញ បានបង្កើតនៅឆ្នាំ ១៩៣០ ។

ឆ្ពោះទៅរកភាពសម័យទំនើប ទោះបីត្រូវរក្សា ស្ថាប័នដឹកនាំចាស់ក្តី ។ សូមកត់សំគាល់បន្ថែមថា បញ្ញវន្តអភិរក្សនិយម ដែលបានទៅធ្វើការសិក្សា នៅប្រទេសបារាំង ច្រើនមាននិន្នាការ ទៅរកបស្ចិម ប្រទេស [៨២] ។ បញ្ហាសំខាន់ របស់ អ្នកទាំងនេះ ក៏ ដូចជារបស់ចលនាតស៊ូទាំងអស់ដែរ គឺ រំដោះខ្លួនចេញពី ការគ្រប់គ្រងរបស់បារាំង។ ចំពោះអ្នក ដែលចង់ធ្វើការកែទម្រង់ គឺត្រូវរំដោះខ្លួន ពីបារាំងផង ហើយរៀបចំស្ថាប័នគ្រប់គ្រងប្រទេស ទៅតាម ប្រព័ន្ធប្រជាធិបតេយ្យ តាមបែបបារាំងផង ។ ក្រោយសម័យ លោក សឺន ង៉ុក ថាន់ ដែលបុកមុខព្រួញតែមួយ - គឺការដេញបារាំងចេញ ពីស្រុកខ្មែរតែប៉ុណ្ណោះ ទោះត្រូវចងសម្ព័ន្ធភាព ជាមួយ ចក្រភពជប៉ុន ដែលកាលនោះកំពុងវាតទឹកដីនៅអាស៊ីអាគ្នេយ៍ ក៏ដោយក្តី - ការតស៊ូ របស់ បញ្ញវន្តខ្មែរ ក្រោមការដឹកនាំ របស់ គណបក្ស «ប្រជាធិបតេយ្យ» មានលក្ខណៈ ជាការតស៊ូ ដែលមានមុខព្រួញពីរ ក្នុងពេលជាមួយគ្នា គឺ ដើម្បីទាមទារ ឯករាជ្យពីបារាំងផង ហើយប្តូររបនាសម្ព័ន្ធប្រទេសផង ។ ប៉ុន្តែគ្មានអ្នកណា ម្នាក់ហ៊ាននិយាយឲ្យបានច្បាស់ អំពី ការវិវត្តន៍ ឆ្ពោះទៅរក របបសាធារណរដ្ឋ ទេ ព្រោះសង្គមខ្មែរនៅជំនាន់នោះ ពុំទាន់រំដោះខ្លួនផុត ពីការមានជំនឿ ដ៏ មោះមុត ទៅលើ តួនាទីដឹកនាំជាសក្ការៈរបស់ព្រះមហាក្សត្រឡើយ។ ចំពោះ បណ្តាជន ខ្មែរជាទូទៅ ព្រះមហាក្សត្រ គឺ ជាព្រះអាទិទេពជាអ្នកមានបុណ្យ ដែលចុះ ពីទេវលោក មកជួយយកអាសា និង ត្រួតត្រាមនុស្សលោក។ ដូចនេះ ការ ប្រមាថ ចេស្តាព្រះមហាក្សត្រ ជា អំពើខុសឆ្គងមួយ ដែលមានទោសធ្ងន់ធ្ងរ ។ គឺ នៅក្នុងន័យនេះហើយ ដែលក្រោយការបាត់បង់ ជីវិត របស់ អ្នកអង្គម្ចាស់ យុត្តិវង្ស ព្រះបាទនរោត្តម សីហនុ បានឆ្លៀតឱកាស ដណ្តើមយកអំណាច ពី គណបក្ស «ប្រជាធិប

[៨២] កាលដើមឡើយ សម្តេច នរោត្តម សីហនុ ក៏មាន និន្នាការបែបនេះដែរ ប៉ុន្តែ ក្រោយមក ព្រះអង្គបែរទៅរក របៀបសង្គមនិយមវិញ ។ ផ្ទុយទៅវិញ អ្នកអង្គម្ចាស់ នរោត្តម ចន្ទរង្សី រក្សានិន្នាការស្តាំ អភិរក្សនិយមដដែល។ នៅ ពេលទម្លាក់សម្តេច នរោត្តម សីហនុ អ្នកអង្គម្ចាស់ នរោត្តម ចន្ទរង្សី បានចូលរួមចំណែកក្នុងការកសាង របបសាធារណរដ្ឋខ្មែរ។





តេយ្យ» បានវិញ ជាពិសេស នៅពេលដែល ព្រះអង្គចាប់ ផ្តើមធ្វើ «ព្រះរាជបូជនីយកិច្ចទាមទារឯករាជ្យ» (croisade royale pour l’Indépendance) ពី បារាំង ។

នៅក្នុងការធ្វើទំនើបកម្មប្រទេសកម្ពុជា អ្វីដែលព្រះមហាក្សត្រខ្មែរព្រះបាទ នរោត្តម សីហនុ បារម្ភខ្លាំងជាងគេ គឺការបែងចែកអំណាច តាមលទ្ធិប្រជាធិបតេយ្យ របៀបបស្ចិមប្រទេស និង តួនាទី ដ៏ សំខាន់ នៃ ពួកអ្នកមូលធននិយម ដែលក្តាប់សេដ្ឋកិច្ចប្រទេស។ នៅអឺរ៉ុប គឺ ពួកមូលធននិយមនេះ ហើយដែលតំណាង «វណ្ណៈគហបតី» (la bourgeoisie) ហើយដែលជាអ្នក មានអំណាចពិតប្រាកដ នៅក្នុងសង្គម សេរីនិយម។ ដូចការយល់ឃើញរបស់ ម៉ាក្ស និងអង់ហ្គែល អ៊ីចឹងដែរ សម្តេច នរោត្តម សីហនុ ពុំចង់ឲ្យវណ្ណៈ គហបតី នេះកាន់អំណាចទេ ព្រោះព្រះអង្គខ្លាច អ្នកទាំងនេះ ក្តាប់អំណាច នៅពេលដែលមាន ការរីកចម្រើនផ្នែកឧស្សាហកម្ម ។ ដើម្បីរាំងស្កាត់ការវិវត្តន៍នេះ ព្រះអង្គ ក៏ដាក់រាជ្យចូល ប្រយុទ្ធក្នុងឆាកនយោបាយ ដើម្បីយកជ័យជំនះ ឲ្យបានមុនជាស្រេច កុំឲ្យបដិវត្តន៍ គហបតី វាយរំលំបាន ហើយជួយចលនា បញ្ញវន្ត ឆ្វេងនិយម ឲ្យវាយរំលំ វណ្ណៈគហបតី។ ដើម្បី ចៀសវាងកុំឲ្យបដិវត្តន៍ កុម្មុយនិស្ត យកអំណាចបាន ព្រះអង្គ ក៏រកបង្អែក ពី សំណាក់ចិនកុម្មុយនិស្ត ដែលនៅពីក្រោយខ្មែរកុម្មុយនិស្ត ។ ប៉ុន្តែ ជាការឥតប្រយោជន៍។ សម្រេចសម្រួចទៅកាលបើវាយរំលំពួកគហបតីបានហើយពួកខ្មែរក្រហម យកអំណាចសម្រាប់ពួកគេតែម្តង ។ តួនាទី របស់ សម្តេច នរោត្តម សីហនុ នៅក្នុងចលនា កុម្មុយនិស្តខ្មែរ បានត្រូវបង្រួមមកត្រឹម ជាយុទ្ធវិធី របស់ពួកកុម្មុយនិស្ត ដើម្បី សម្រួលដល់ការវាយរំលំ ក្រុមខ្មែរដែលមាននិន្នាការស្តាំ អភិរក្សតែប៉ុណ្ណោះ។ រីឯ បដិវត្តន៍ កុម្មុយនិស្តខ្មែរវិញ ទោះខាងវៀតណាម ឬខាងចិនក្តី ក៏បានត្រឹម បម្រើ អនុត្តរភាព នៃ ប្រទេសកុម្មុយនិស្ត ទាំងពីរនេះតែប៉ុណ្ណោះ ។

នៅចន្លោះឆ្នាំ ១៩៦០-១៩៧៥ ក្រោយពេលដែល សម្តេច នរោត្តម សីហនុ ប្រមុខរដ្ឋ ដ៏មានអំណាច នៃ ប្រទេសកម្ពុជា ទាស់ទែងយ៉ាងខ្លាំង នឹង លោក សម សារី បញ្ញវន្ត ស្តាំអភិរក្សនិយមម្នាក់ដែលប្រឆាំង នឹង នយោបាយប ម្រើបក្សសម្ព័ន្ធកុម្មុនិស្ត របស់សម្តេច នរោត្តម សីហនុ ប្រទេសកម្ពុជាផ្តាច់ខ្លួនបន្តិចម្តងៗ ពីលោកសេរី ជាពិសេសពីសហរដ្ឋ អាមេរិក ។ គឺនៅ ពេលនោះហើយ ដែលបញ្ញវន្តឆ្វេងនិយម មានជាអាទិ៍ លោក

ខៀវ សំផន លោក ចៅ សេង លោក ហ៊ូ យន់ លោក ហ៊ូ នឹម លោក សូ ណែម អែប សម្តេច សីហនុ យ៉ាងខ្លាំង ដើម្បីវាយបំបាក់ អ្នកស្តាំនិយមអភិរក្ស ដែលមានឧត្តមសេនីយ៍ លន់ នល់ និង អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរិមតៈ ជា បង្អែកៗ តាមការពិត នៅពេលនោះ អ្នកឆ្វេងនិយម ទាំងនោះ ដែលមានចិន នៅពី ក្រោយ រង់ចាំតែពេល វេលា របស់ ពួកគេ តែប៉ុណ្ណោះ ព្រោះចលនា របស់ពួកគេ កំពុងតែរីកចម្រើនយ៉ាងខ្លាំង ក្រោមការដឹកនាំ របស់ សាឡុត សរ (ប៉ុល ពត) និង អៀង សារី ។ នៅថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហម បានវាយរំលំ របបសាធារណរដ្ឋ របស់ ឧត្តមសេនីយ៍ លន់ នល់ ប៉ុន្តែ ពុំបាន ប្រគល់អំណាចមក ឲ្យសម្តេចនរោត្តម សីហនុ ទេ។ នៅពេលដែលកងទ័ព វៀតណាម ចូលឈ្លានពាន ប្រទេសកម្ពុជា វាយរំលំ របប ប៉ុល ពត នៅថ្ងៃ ៧ មករាឆ្នាំ១៩៧៩ [៨៣] ពួកខ្មែរក្រហម ក៏ យកព្រះអង្គ ទៅប្រើសាជាថ្មីទៀត ។ បន្ទាប់ពី សហភាព សូវៀត រលំ រលាយទៅ នៅឆ្នាំ ១៩៩០ ប្រទេសមហាអំណាច ក៏បញ្ចប់សង្គ្រាម [៨៤] នៅក្នុងតំបន់ ហើយ ចិន ក៏ត្រូវរ៉ូវ នឹងវៀតណាមវិញ ។ សម្តេច នរោត្តម សីហនុ ក៏ ចាប់ដៃ សហការជាមួយ លោក ហ៊ុន សែន ដែលស្ថិតនៅជាកូនអុក របស់ ទីក្រុងហាណូយបន្តមកទៀត។ សាជាថ្មី ម្តងទៀត សម្តេច នរោត្តម សីហនុ ទ្រង់សង្ឃឹមថា នឹងបានគ្រប់គ្រង ប្រទេសកម្ពុជាវិញ ប៉ុន្តែនៅទីបំផុត បានទទួលត្រឹមតួនាទីកិត្តិយសប៉ុណ្ណោះ។ នៅចុងឆ្នាំ ២០០៤ ព្រះអតីតអគ្គ មគ្គុទេសក៍ខ្មែរ ដ៏ឆ្នើមនេះ ហើយ ដែលត្រូវទទួលកិត្តិយស ជា «វិរបុរស នៃឯករាជ្យជាតិ» និង ជា «ព្រះវិរក្សត្រ» គ្មានជម្រើសអ្វីទៀត ក្រៅពីដាក់រាជ្យទៅវិញឡើយ ។

---

[៨៣] នៅក្នុងបរិបទ ភូមិសាស្រ្ត-នយោបាយ ទំនាស់ រវាង ខ្មែរក្រហម ខាងចិន នឹង ខ្មែរក្រហមខាងវៀតណាម ជាទំនាស់ រវាងចិន នឹង សហភាព សូវៀត។ ថ្ងៃ ១៧ មេសាឆ្នាំ ១៩៧៥ ជាថ្ងៃជ័យជំនះ របស់ បដិវត្តន៍ ចិន នៅកម្ពុជា រីឯ ថ្ងៃ ៧ មករាឆ្នាំ ១៩៧៩ ជាជ័យជំនះ របស់ បដិវត្តន៍ វៀតណាមដែលមាន សហភាពសូវៀត នៅពីក្រោយ ។

[៨៤] សន្និសីទ អន្តរជាតិ ទីក្រុងប៉ារីស៍ឆ្នាំ ១៩៨៩, កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ឆ្នាំ១៩៩១ និង អន្តរាគមន៍ របស់ អង្គការ សហប្រជាជាតិ នៅឆ្នាំ ១៩៩២- ១៩៩៣ ។





# កាលប្បវត្តិ

## ១៩៨៩

ថ្ងៃ ១២ មិនា :នៅទីក្រុងប៉េកាំង «រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ» បង្កើតក្រុម ប្រឹក្សាការពារជាតិជាន់ខ្ពស់។ គោលដៅៈ ពង្រឹងសាមគ្គីភាព សហប្រតិបត្តិការ រវាងកងទ័ព ខ្មែរទាំង ៣ ក្រុម ដែលប្រឆាំង នឹងវត្តមាន កងទ័ពវៀត ណាមនៅលើទឹកដីខ្មែរ ។ ថ្ងៃ ៧ មករា : ខួបទី ១០ នៃ កំណើត សាធារណរដ្ឋ ប្រជាមានិតុ កម្ពុជា។ នៅក្នុងឱកាសនោះ លោក ង្វៀង វ៉ាន់ លិន អគ្គលេខាធិការ បក្សកុម្មុយនិស្តវៀតណាម សន្យាថា នឹង ដក កងទ័ពវៀតណាមទាំងអស់ ចេញពីកម្ពុជា នៅដំណាច់ខែកញ្ញា។ ថ្ងៃ ១៨ មករា : នៅទីក្រុងប៉េកាំង ការចុះហត្ថលេខា ទៅលើកិច្ចព្រមព្រៀង រវាង ចិន និង វៀតណាម ស្តីពី ការដក កងទ័ពវៀតណាម ចេញពីកម្ពុជា ក្រោមការត្រួតពិនិត្យអន្តរជាតិ នៅដំណាច់ខែ កញ្ញា ។ ថ្ងៃ ២៣ មករា : គណប្រតិភូ អ្នកតំណាងសភា ថៃ ធ្វើទស្សនកិច្ច នៅ កម្ពុជា ។ ថ្ងៃ ២៥-២៧ មករា : លោក ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃ របប សាធារណរដ្ឋ ប្រជាមានិតុ កម្ពុជា ធ្វើទស្សនកិច្ច ក្រៅផ្លូវការនៅប្រទេសថៃ។ លោកជួបសន្ទនា ជាមួយ លោក ឆាត់ទីចៃ ជនហាវ៉ែន រដ្ឋមន្ត្រី ទី ១ ថៃ, លោក សិទ្ធិ សាវេតសីលា រដ្ឋមន្ត្រី ការបរទេស, ឧត្តមសេនីយ៍ ឆាវ៉ាលិត យ៉ុងចៃយុត មេបញ្ជាការ សេនាធិការដ្ឋាន កងទ័ពថៃ ។ ថ្ងៃ ២៦ មករា : នៅទីក្រុង ប៉េកាំង សម្តេច នរោត្តម សីហនុ បានបញ្ចេញការខក ព្រះទ័យយ៉ាងខ្លាំង អំពី ការដែលទីក្រុងបាងកក ទទួលលោក ហ៊ុន សែន ។ ព្រះអង្គ ទ្រង់ សម្រេចព្រះ ហឫទ័យ មិនចូលរួម ក្នុងការចរចារហូតដល់ខែកញ្ញា ព្រោះ ផែនការសន្តិភាព ដែលព្រះអង្គ បានស្នើឡើង ពុំមាន ភាគីណាមួយសុខចិត្តទទួលយក។ ថ្ងៃ ៩ កុម្ភៈ :

ភាគីខ្មែរទាំងបី នៃ «រដ្ឋាភិបាលចម្រុះ កម្ពុជាប្រជាធិបតេយ្យ» (G.C.K. D.) ដែលប្រឆាំង នឹងវត្តមាន កងទ័ពវៀតណាម នៅកម្ពុជា រួមប្រជុំគ្នានៅ ទី ក្រុងប៉េកាំង។ ភាគីខ្មែរទាំង ៣ បានស្រុះស្រួលគ្នា ទទួលយក ផែនការសន្តិភាព ។ ថ្ងៃ ១២ កុម្ភៈ : សម្តេច សីហនុ វិល ត្រឡប់ មកបំពេញភារកិច្ច ជាប្រធាន «រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ» បន្ត មក ទៀត។ ថ្ងៃ ១៧-១៨ កុម្ភៈ : ក្រុមការងារ គូភាគីខ្មែរទាំង ៤ រួមប្រជុំគ្នា នៅទីក្រុងយ៉ាកាតា ។ ថ្ងៃ ១៩-២១ កុម្ភៈ : អង្គប្រជុំក្រៅផ្លូវការ ទី២ (JIM II) រវាង គូភាគីខ្មែរទាំង ៤។ មាន ការនិយាយមិនចុះសម្រុងគ្នា អំពីលក្ខខ័ណ្ឌ: និង សមាសភាព នៃការបង្កើតរចនាសម្ព័ន ចតុភាគី បណ្តោះអាសន្ន សម្រាប់ប់ជំនួសស្ថាប័ន នៃរបបសាធារណរដ្ឋប្រជាមានិតុកម្ពុជា។ ថ្ងៃ ២៣ មិនា : របបសាធារណរដ្ឋ ប្រជាមានិតុកម្ពុជា បង្កើតគណកម្មការមួយដើម្បី កែប្រែ រដ្ឋធម្មនុញ្ញ។ ថ្ងៃ ២៦ មិនា : នៅ ទីក្រុង ប៉េកាំង សម្តេច នរោត្តម សីហនុ បានទទួល លិខិតមួយពី លោក ហ៊ុន សែន។ តាមរយៈលិខិតនោះ លោកនាយករដ្ឋមន្ត្រី នៃ របប សាធារណរដ្ឋ ប្រជាមានិតុកម្ពុជា ស្នើសុំពិភាក្សាជាមួយព្រះអង្គ ដើម្បីលើកឡើងអំពី សម្ប ទាន សំខាន់ៗ ២ ចំណុច។ ថ្ងៃ ២៩ មិនា : លោក ស្តេហ្វេន សូឡា សមាជិកសមាជ សហរដ្ឋ អាមេរិក អញ្ជើញមកជួបលោក ហ៊ុន សែន នៅទីក្រុងភ្នំពេញ។ ពេលត្រឡប់ទៅ សហរដ្ឋ អាមេរិកវិញ លោកសូឡា ស្នើសុំឲ្យសមាជអាមេរិក បង្កើនជំនួយ ដល់ភាគីខ្មែរ ដែលប្រឆាំង នឹង កុម្មុយនិស្ត ។ នៅថ្ងៃ ២៩ មិនា ដដែលនោះ គណបក្សប្រជាជន បដិវត្ត កម្ពុជា បើកមហាសន្និបាត វិសាមញ្ញ នៃ គណកម្មាធិការមជ្ឈិម។ ថ្ងៃ ២ មេសា : សម្តេច នរោត្តម សីហនុ ស្នើ ជួបលោក ហ៊ុន សែន នៅ ទីក្រុងយ៉ាកាតា នៅថ្ងៃ ២ ឧសភា។ ថ្ងៃ ៥ មេសា : ទីក្រុងហាណូយ ជូនដំណឹងថា គេ នឹងដកកងទ័ព របស់គេ អស់ចេញពី ប្រទេស កម្ពុជា នៅដំណាច់ខែកញ្ញា ។ ថ្ងៃ ៦ មេសា : សម្តេច នរោត្តម សីហនុ ស្នើ សុំ ឲ្យប្រទេសបារាំង បើកសន្និសីទអន្តជាតិមួយ។ ថ្ងៃ ៧ មេសា : ប្រទេសបារាំង បញ្ចេញ ការពេញចិត្ត របស់ គេចំពោះ ការដកកងទ័ពវៀតណាម និង ជំនួប រវាង សម្តេច នរោត្តម សីហនុ និង លោក ហ៊ុន សែន គ្រោងធ្វើ នៅថ្ងៃ ២ ឧសភា។ ប្រទេសបារាំង អបអរសាទរ ផងដែរ អំពី ការបើកអង្គប្រជុំ រវាង គូភាគីខ្មែរ ហើយ សន្យាថា នឹង រៀបចំ សន្និសីទ





អន្តរជាតិមួយ នៅចុងបញ្ចប់ ការ ប្រជុំនោះ។ ថ្ងៃ ២៤ មេសា : កងកម្លាំង ទ័ពវៀតណាម និង កងទ័ពសាធារណ រដ្ឋ ប្រជាមានិតុកម្ពុជា វាយប្រហារ ទៅលើមូលដ្ឋាន កងទ័ពខ្មែរ ក្រហម ។ ថ្ងៃ ២៨ មេសា : នៅទីក្រុងបាងកក លោករដ្ឋមន្ត្រីទី ១ ថៃ លើកឡើង នូវ គោលនយោបាយថ្មីមួយ នោះគឺ ការប្រែក្លាយ តំបន់ឥណ្ឌូចិន ដែលរងគ្រោះ ដោយសារ សង្គ្រាម ឲ្យទៅជាតំបន់ពាណិជ្ជកម្មវិញ ។ ថ្ងៃ ២៩-៣០ មេសា : រដ្ឋសភា នៃរបប សាធារណរដ្ឋ ប្រជាមានិតុកម្ពុជា បើកអង្គប្រជុំវិសាមញ្ញមួយ ដើម្បីកែប្រែរដ្ឋធម្មនុញ្ញ។ អង្គ ប្រជុំបានសម្រេចប្រែឈ្មោះពី «សាធារណរដ្ឋប្រជាមានិតុកម្ពុជា» មកជា «រដ្ឋកម្ពុជា» វិញ។ ទង់ជាតិ ដែលមានប្រាសាទអង្គរ កំពូល ៥ ផ្លាស់មកជា ទង់ជាតិដើមដែល ប្រាសាទអង្គរ មានកំពូល ៣ វិញ។ ទោសប្រហារជីវិត ត្រូវលុបចោល ពុទ្ធសាសនាត្រូវកំណត់ជា សាស នា របស់រដ្ឋ សេដ្ឋកិច្ច សមូហភាពត្រូវជំនួសដោយ កម្មសិទ្ធិឯកជន និង សេដ្ឋកិច្ចផ្សារ ។ រីឯ នយោបាយក្រៅប្រទេស គឺ អព្យាក្រឹតភាព និង គោរពគោលការណ៍ មិនចូលបក្ស សម្ព័ន្ធ ។ ថ្ងៃ ២ និង ៣ ឧសភា : ជំនួបទី ៤ រវាង សម្តេច នរោត្តម សីហនុ និង លោក ហ៊ុន សែន នៅទីក្រុងយ៉ាកាតា។ អ្នកនយោបាយខ្មែរទាំងពីរ យល់ស្របគ្នាអំពី ការចាំបាច់ ត្រូវមានយន្តការអន្តរជាតិមួយ ដើម្បីត្រួតពិនិត្យការដកកងទ័ពវៀតណាម ។ នៅក្នុងឱកាស នោះដែរ លោកហ៊ុន សែន ក៏ បានជួបសន្ទនាជាមួយ លោក សឺន សាន ផងដែរ។ ថ្ងៃ ៧ ឧសភា : ខ្មែរ ក្រហម ដាក់គ្រាប់បែក កំទេច ស្ពានពីរ នៅតាមផ្លូវ ភ្នំពេញ-បាត់ដំបង ។ ថ្ងៃ ១៥-១៨ ឧសភា : ទស្សនកិច្ចជាផ្លូវការ របស់ លោក ហ្គ័របាត់ចេហ្វ អគ្គលេខាធិការ បក្សកុម្មុយនិស្ត សូវៀត នៅទីក្រុងប៉េកាំង។ គឺជាទស្សនកិច្ចលើកទី ១ បន្ទាប់ពី ការដាច់ ទំនាក់ទំនងគ្នា នៅឆ្នាំ ១៩៥៩។ ថ្ងៃ ១៧ ឧសភា : សម្តេច នរោត្តម សីហនុ ស្នើសុំឲ្យ គេប្រាប់ឈ្មោះខ្មែរនៅបរទេស ដែលចូលទៅទីក្រុងភ្នំពេញ។ ថ្ងៃ ១៨ ឧសភា : នៅក្នុងអង្គ ប្រជុំកំពូលមួយ នៅទីក្រុងប៉េកាំង រវាង ចិន និង សហភាព សូវៀត គូភាគីទាំងសងខាង បានយល់ព្រមគ្នា កាត់បន្ថយ ជំនួយបរទេស ទៅឲ្យក្រុមខ្មែរ នៅក្នុងស្រុក ដើម្បីចៀសវាង កុំឲ្យមាន សង្គ្រាមផ្ទៃក្នុងនៅកម្ពុជា ហើយដើម្បីសម្រួលដល់ ការជានាគ្នាវិញរវាង ខ្មែរ និង ខ្មែរ។ ថ្ងៃ ១ មិថុនា : លោក រ៉ូឡង់ ឌុយមាស៍ រដ្ឋមន្ត្រីការបរទេសបារាំង ជួបលោក អាលី

អាឡាតាស្ស រដ្ឋមន្ត្រី ការបរទេស ឥណ្ឌូណេស៊ី នៅទីក្រុងប៉ារីស៍ ដើម្បី រៀបចំសន្និសីទអន្តរជាតិមួយ នៅទីក្រុងប៉ារីស៍ នៅក្នុងករណីដែលការចរចា រវាង គូភាគីខ្មែរ ទាំង ៤ មានការជឿនលឿន ។ ថ្ងៃ ៣ មិថុនា : ការបះបោរ និស្សិតចិនដែល និយមលទ្ធិប្រជាធិបតេយ្យ នៅទីវាល តៀន អាន់ម៉េន ទីក្រុង ប៉េកាំង។ កម្លាំងយោធាធ្វើការបង្ក្រាបបាតុកម្មជាហេតុធ្វើឲ្យមាន ការបង្ហូរឈាម មួយ ជា ប្រវត្តិសាស្ត្រ ហើយ ដែលគេហៅថា «និទាឃរដូវ» ទីក្រុងប៉េកាំង ។ ថ្ងៃ ១៦ មិថុនា : ប្រទេសថៃ ជួសជុលផ្លូវរទេះភ្លើង ដែលចងភ្ជាប់ អារញ្ញប៉ាថេត ទៅនឹងទួលដែនខ្មែរ ។ ថ្ងៃ ២០ ទៅ ថ្ងៃ ២៣ មិថុនា : លោកង្វៀង កូ ថាច់ រដ្ឋមន្ត្រីការបរទេសវៀតណាម ធ្វើទស្សនកិច្ច នៅប្រទេសបារាំង ដើម្បីផ្សា ភ្ជាប់មិត្តភាពរវាងប្រទេសទាំងពីរឡើងវិញ ។ ថ្ងៃ ២៥ មិថុនា : សម្តេច នរោត្តម សីហនុ ដែលគង់នៅ ទីក្រុងព្យុងយ៉ាង ប្រទេសកូរ៉េ ខាងជើង ទ្រាំទ្រ សឹងមិនបាន អំពីការដែលព្រះអង្គ មិនមែនជា ដៃគូ ចរចា ជាមួយប្រទេស មហាអំណាច ។ ព្រះអង្គបានគំរាមថា ព្រះអង្គនឹងមិនចូលរួមក្នុងសន្និសីទអន្តរ ជាតិនៅទីក្រុងប៉ារីស៍ឡើយ បើប្រទេសមួយចំនួននៅតែសំរួលដល់ របបទីក្រុង ភ្នំពេញ ។ ថ្ងៃ ៥ មិថុនា : នៅទីក្រុងប៉េកាំង សម្តេច នរោត្តម សីហនុ ប្រកាន់ ជំហរ របស់ ខ្មែរក្រហម ដោយទាមទារឲ្យ ការដកកងទ័ព វៀតណាម ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ អង្គការសហប្រជាជាតិ ហើយសុំឲ្យរំលាយរដ្ឋបាល រដ្ឋកម្ពុជាបោលទាំងស្រុង។ ទន្ទឹមនោះដែរ ព្រះអង្គប្រកាស មិនទទួលស្គាល់ រដ្ឋធម្មនុញ្ញ នៃ របបរដ្ឋកម្ពុជា ដោយសំអាងថា មានទាហានវៀតណាមចំនួន ៣ ម៉ឺននាក់ នៅក្នុងជួរកងទ័ព នៃ របបនោះ ព្រមទាំងមាន កងជីវពល [៨៥] វៀតណាម ចំនួន ១០ម៉ឺន នាក់ និង ជនអន្តោប្រវេសន៍ ១ លាន នាក់ផងទៀត ។ ថ្ងៃ ១៨ ទៅ ២៣ កក្កដា : នៅទីក្រុងភ្នំពេញ មានបើកសិក្ខាសាលា អន្តរជាតិ មួយស្តីពី ការប្រល័យពូជសាសន៍ ។ ថ្ងៃ ២០ កក្កដា : នៅ

[៨៥] វចនានុក្រម បារាំង-ខ្មែរ របស់ លោក Rogatien Rondineau បកប្រែពាក្យ «កងជីវពល» មកជាពាក្យបារាំងថា milice ។ រីឯពាក្យ «កងស្វ័យត្រាណ» លោក បកប្រែមក ជាបារាំង ថា unité d’autodéfense ដូច្នេះវិញ ។



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ទីក្រុងវ៉ាស៊ីនតោន សមាជអាមេរិកអនុញ្ញាត ឲ្យដឹកអាវុធទៅឲ្យក្រុមខ្មែរ មិនមែនកុម្មុយនិស្តនៃ «រដ្ឋាភិបាលចម្រុះកម្ពុជា ប្រជាធិបតេយ្យ» ។ ទន្ទឹមនោះ នៅក្នុងជំរំ ខ្មែរក្រហម នាយទាហាន អាមេរិក និងអង់គ្លេស ធ្វើការបង្ហាត់ហ្វឹកហ្វឺនយោធា។ ថ្ងៃ ២១ កក្កដា : នៅទីក្រុងប៉ារីស៍ សម្តេច នរោត្តម សីហនុ ស្នើសុំឲ្យ កងទ័ព នៃ គូភាគីខ្មែរនីមួយៗ កាត់បន្ថយចំនួនកងទ័ព មកត្រឹមចំនួន ១ ម៉ឺននាក់។ ក្រៅពីសំណើផ្សេងៗទៀត ដែលព្រះអង្គបានលើកឡើងកាលពី ថ្ងៃ ៥ មិថុនា នៅទីក្រុងប៉េកាំង ព្រះអង្គបានថ្លែងថា បើទុកខ្មែរក្រហមឲ្យនៅក្រៅច្បាប់ គឺជាគ្រោះថ្នាក់មួយធំ សម្រាប់ប្រទេសកម្ពុជា ។ ថ្ងៃ ២៤ កក្កដា : ក្រោយជំនួបទី ៥ រវាង សម្តេច នរោ ត្តម សីហនុ និង លោក ហ៊ុន សែន អ្នកនយោបាយទាំងពីរយល់ឃើញថា គេពុំបានឈានដល់ កាស្រុះស្រួល អ្វីណាមួយឡើយ គឺ ស្ថិតនៅចំពោះមុខការរាំងស្ទះ ដដែល ។ សម្តេច សីហនុ ចោទ លោក ហ៊ុន សែនថា មិនព្រមទទួលយកគោលការណ៍ ពហុបក្ស រីឯ លោក ហ៊ុន សែន វិញ លោកចោទ សម្តេច សីហនុ ថា បោះមួយជំហានទៅមុខ ហើយពីរជំហាន ថយក្រោយ។ លោក ហ៊ុន សែន ចោទប្រកាន់ អង្គការ សហប្រជាជាតិ ថា មានលំអៀង តាំងពីឆ្នាំ ១៩៧៩ មក ។ ថ្ងៃ ២៥-២៧ កក្កដា : គូភាគីខ្មែរទាំង ៤ ជួបប្រជុំគ្នា នៅ សែល សាំង គ្លូដ៍ [៨៦] ប្រទេសបារាំង ។ នៅថ្ងៃ ២៧ កក្កដា នោះដែរ លោក ហ៊ុន សែន ជួបសន្ទនា ជាមួយលោក រ៉ូកាដ៍ រដ្ឋមន្ត្រីទី ១ បារាំង ។ ថ្ងៃ ៣០ កក្កដា - ១ សីហា : សន្និសីទអន្តរជាតិ ស្តីពី បញ្ហាខ្មែរ បើកអង្គប្រជុំ នៅទីក្រុងប៉ារីស៍ ក្រោមអធិបតីភាព នៃសហប្រធានពីររូប គឺ លោក រ៉ូឡង់ ឌុយមាស៍ រដ្ឋមន្ត្រីការបរទេសបារាំង និង លោក អាលី អាឡាតាស្ស រដ្ឋមន្ត្រីការបរទេស ប្រទេសឥណ្ឌូណេស៊ី។ ថ្ងៃ ២៧ សីហា : សម្តេច នរោត្តម សីហនុ សុំលាលែង ពីមុខតំណែង ប្រធានគណបក្សរាជានិយម «ហ៊្វុនស៊ីនប៉ិច» ដើម្បីសំដែងការមិនសព្វព្រះហឫទ័យ នឹង ការបាក់បែកគ្នា ក្នុងគណបក្ស របស់ព្រះអង្គ ។ ថ្ងៃ ២៨ សីហា : ប្រជុំពេញអង្គ នៃ សន្និសីទអន្តរជាតិ ទីក្រុងប៉ារីស៍ ។ ថ្ងៃ ៣០ កក្កដា : សន្និសីទទីក្រុងប៉ារីស៍ ផ្អាកអង្គប្រជុំ ព្រោះតែ

[៨៦] Celle-Saint-Cloud

រកប្រកបេញមិនរួប ក្នុងបញ្ហាអង្គការបាត់តាំង រចនាសម្ព័ន្ធអំណាចមួយសម្រាប់អន្តរកាល។ ឧបសគ្គចម្បង គឺលក្ខន្តិកៈខ្មែរក្រហម ។ នៅក្នុង ឱកាសនោះ សម្តេច នរោត្តម សីហនុ ស្នើសុំឲ្យឈប់ប្រើពាក្យ «ប្រល័យពូជសាសន៍» (génocide)។ ថ្ងៃ ៩ កញ្ញា : នៅប្រទេសកម្ពុជា ជនជាតិវៀតណាមជាច្រើន នាំគ្នាវិលត្រឡប់ទៅស្រុកគេវិញ ដោយខ្លាចមានការសងសឹក។ ថ្ងៃ ២១-២៦ កញ្ញា : វៀតណាម ដកកងទ័ព ដែលនៅសេសសល់ ជាផ្លូវការ ចំនួន ២ ម៉ឺន ៦ ពាន់នាក់ ។ អ្នកកាសែត និង អ្នកសង្កេតការណ៏ ២៥០ នាក់ បានមកពិនិត្យមើលការដកកងទ័ពនេះ ។ ប៉ុន្តែ បើយោងតាមប្រទេសថៃ មាននៅសល់ ទាហានវៀតណាមស្លៀកពាក់ស៊ីវិល បង្កប់ខ្លួន ចំនួន ៥ ម៉ឺន នាក់ទៀត ដែលមិនទៅស្រុកវិញ។ ថ្ងៃ ២៨ កញ្ញា: លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីខ្មែរ សុំឲ្យលោក អគ្គលេខាធិការ អង្គការសហប្រជាជាតិ បញ្ជូនបេសកកម្ម មួយ មកស្រុកខ្មែរ ដើម្បីពិនិត្យមើល ការដកកងទ័ពវៀតណាម ទាំងអស់ចេញ ពី ប្រទេសកម្ពុជា ។ ថ្ងៃ ៣០ កញ្ញា : កងទ័ព សមេច្ច នរោត្តម សីហនុ ហៅ អា អិន អេស (A.N.S.)[៨៧] វាយប្រហារយក ភ្នំស្រុក ក្នុងខែត្របន្ទាយមានជ័យ។ នៅថ្ងៃដដែលនោះ ជាមួយកងទ័ព រណសិរ្សជាតិ រំដោះពលរដ្ឋខ្មែរ បានវាយ យកតំបន់ថ្មពួក / ស្វាយចេក។ រីឯ កងទ័ពខ្មែរក្រហម គេឈានទៅវាយយក ប៉ៃលិន តែម្តង ។ ថ្ងៃ ៦ តុលា : វិមាន «ប៉ង់តាហ្គោន» (ក្រសួងការពារជាតិ និង សេនាធិការដ្ឋាន អាមេរិក) បានឈានមកដល់ ការសន្និដ្ឋានមួយថា បើគិត តាមទស្សនៈយុទ្ធសាស្ត្រ គេអាចនិយាយបានថា កងទ័ពវៀតណាម បានដកចេញពី កម្ពុជា ។ ថ្ងៃ ១២ តុលា : លោក ស៊ិម វ៉ា អតីតអ្នននយោបាយខ្មែរ ដែលបានជួយជ្រោមជ្រែង បង្កើតគណបក្ស «ប្រជាធិបតេយ្យ» (ឆ្នាំ ១៩៤៦) ទទួលមរណភាព នៅទីក្រុងប៉ារីស៍ ។ នៅថ្ងៃដដែលនោះ នៅទីក្រុងភ្នំពេញ មានការចុះហត្ថលេខាទៅលើពិធីសារ សហប្រតិបត្តិការ រវាង មហាវិទ្យាល័យ ពីជេ-សាល់ប៉េតទ្រីយែរ ទីក្រុងប៉ារីស៍ និង មហាវិទ្យាល័យ វេជ្ជសាស្ត្រ ទីក្រុងភ្នំពេញ ។ ថ្ងៃ ២២

[៨៧] A.N.S. : Armée nationale sihanoukiste ។ ក្រោយមក ប្តូរឈ្មោះមក ជា A.N.K.I. : Armée nationale pour un Cambodge indépendant .





តុលា : ខ្មែរក្រហម វាយយកទីក្រុងប៉ៃលិន បាន។ ខាងកងទ័ព សីហនុនិយម គេវាយយកភ្នំស្រុក បាន។ ថ្ងៃ ២៣ តុលា : លោក ដាយ ក្វាក សមាជិកព្រឹទ្ធសភា អាមេរិក មកជួបសន្ទនាជាមួយ លោក ហ៊ុន សែន នៅទីក្រុងភ្នំពេញ។ ថ្ងៃ ៣០ តុលា : ទីក្រុងភ្នំពេញ បិទចរាចរណ៍ ពេលរាត្រីសាជាថ្មីទៀត បន្ទាប់ពីបានបើកនៅថ្ងៃ ៦ ឧសភា ។ ថ្ងៃ ៣ វិច្ឆិកា : ខ្មែរក្រហមវាយយក ត្រែង បាន (ពាក់កណ្តាលផ្លូវ ចន្លោះ ប៉ៃលិន និង បាត់ដំបង) ។ ថ្ងៃ ៨ វិច្ឆិកា : ប្រទេសអង់គ្លេសជឿថា វៀតណាម ពិតជា បានដកកងទ័ពចេញពីកម្ពុជាមែន។ ថ្ងៃ ៩ វិច្ឆិកា : ការវាយរំលំ កំផែងទីក្រុងប៊ែរឡាំង។ ថ្ងៃ ១៦ វិច្ឆិកា : មហាសន្និបាតអង្គការ សហប្រជាជាតិ អនុម័ត ញត្តិ ប្រចាំឆ្នាំរបស់ខ្លួន (១២៣ សំឡេងយល់ស្រប; ១៧ សំឡេង ប្រឆាំង; ១២ សំឡេង អនុបវាទ) តម្រូវឲ្យ រក្សាទុក នូវការហាមឃាត់មិន ឲ្យមាននាវា ដឹកទំនិញចូលប្រទេសកម្ពុជា ព្រមទាំងមិនឲ្យជឿទៅលើការដកកងទ័ពវៀតណាមផងទៀត។ ថ្ងៃ ២០ វិច្ឆិកា : កងទ័ព «រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ» (G.C.K.D.) រួមកម្លាំងគ្នា ទាំង ៣ ក្រុម បើកយុទ្ធនាការ វាយលុកចូលជ្រៅទៅ ក្នុងដើម្បីស្កាត់កុំឲ្យកងទ័ពរដ្ឋាភិបាលលោក ហ៊ុន សែន វាយប្រហារមុនបាន។ កងទ័ពខ្មែរទាំង ៣ ក្រុម នៃរដ្ឋាភិបាលចម្រុះប្រឆាំង នឹងវៀតណាម បានចាត់តាំងរណសិរ្សមួយប្រវែង ១៦០ គ.ម.។ ថ្ងៃ ២២ វិច្ឆិកា : ខ្មែរក្រហមបាន បង្ខំប្រជាជន ដែលរស់នៅក្នុងជំរំ ជនភៀសសង្គ្រាម ខៅឡឹម ឲ្យទៅតាំងទីនៅក្នុងតំបន់ ជុំវិញភ្នំ ចាដា ដែលពួកគេទើបនឹង វាយយកបាន។ នៅថ្ងៃដដែលនោះ កងទ័ព «រណសិរ្សជាតិ រំដោះពលរដ្ឋខ្មែរ» វាយយកស្វាយចេកបាន។ ថ្ងៃ ២៤ វិច្ឆិកា : លោក ហ្គារ៉េត អ៊ីវ៉ែន រដ្ឋមន្ត្រី ការបរ ទេសអូស្ត្រាលី បាន លើកឡើងនៅចំពោះមុខព្រឹទ្ធសភា អំពីឧបសគ្គធមមួយ ក្នុងការអនុវត្តន៍ផែនការសន្តិភាពនៅកម្ពុជា គឺការបង្កើតរដ្ឋាភិបាលអន្តរកាល។ លោក ហ្គារ៉េត អ៊ី វ៉ែន ស្នើឲ្យអង្គការ សហប្រជាជាតិ បង្កើតរដ្ឋបាល អន្តរកាលមួយ ដែលស្ថិតនៅក្រោមអាជ្ញាធរ អង្គការសហប្រជាជាតិ ។ ថ្ងៃ ២៧ វិច្ឆិកា : សម្តេច នរោត្តម សីហនុ ថ្លែងថា ព្រះអង្គយល់ស្រប នឹង ចំណុចមួយចំនួន នៃផែនការសន្តិភាព របស់ប្រទេសអូស្ត្រាលី។ ថ្ងៃ ៣ ធ្នូ : សមាគមខ្មែរ នៅទីក្រុងប៉ារីស៍ចំនួន ៧ បាននាំគ្នាបង្កើតក្រុមនយោបាយមួយដែលមានឈ្មោះថា: «សហភាពខ្មែរសេរី» (Union

des Khmers libres) ដែលមាន និន្នាការប្រឆាំង នឹងរបប ដែលគាំទ្រ ដោយវៀតណាម។ ថ្ងៃ ១០ ធ្នូ :លោក ហ៊ុន សែន បានប្រាប់ឲ្យដឹងថា លោក ត្រៀមលក្ខណៈជាស្រេច ដើម្បីពិភាក្សា អំពីផែនការសន្តិភាព របស់ប្រទេសអូស្ត្រាលី។ ថ្ងៃ ១៤ ធ្នូ : «រណសិរ្សជាតិរំដោះពលរដ្ឋខ្មែរ» បានអញ្ជើញអ្នកកាសែត ឲ្យមកមើល តំបន់ប្រយុទ្ធ។ ថ្ងៃ ១៥ ធ្នូ : លោកហ្គារ៉ែត អ៊ីវ៉ែន បង្ហាញ ប្រាប់ផែនការ សន្តិភាព របស់លោក ។ ថ្ងៃ ៣០ ធ្នូ : លោក អាលី អាឡាតាស្ស រដ្ឋមន្ត្រី ការបរទេស ឥណ្ឌូណេស៊ី ប្រកាសប្រាប់ថា នឹង មានការបើក សន្និសីទមួយ នៅខែកុម្ភៈឆ្នាំ១៩៩០ ដើម្បីពិភាក្សា អំពី ផែនការសន្តិភាព របស់ ប្រទេស អូស្ត្រាលី ។

# ១៩៩០

ថ្ងៃ ៣ មករា : លោក កាស្តេឡូ អនុរដ្ឋមន្ត្រី ការបរទេស អូស្ត្រាលី មកទីក្រុងបាងកក បង្ហាញផែនការសន្តិភាព អូស្ត្រាលីដល់ «រដ្ឋាភិបាលចម្រុះកម្ពុជា ប្រជាធិបតេយ្យ» (G.C. K. D.) ។ ថ្ងៃ ៧ - ៨ មករា : លោក ហ៊ុន សែន ជួប សន្ទនាជាមួយ លោក កាស្តេឡូ ។ នៅថ្ងៃដដែលនោះ ខ្មែរក្រហមវាយប្រហារ ទៅលើខេត្តបាត់ដំបង ។ ថ្ងៃ ១១ មករា : នៅ ទីក្រុងប៉ារីស៍ លោកប្រធានា ធិបតីបារាំង ហ្វ្រង់ ស្វ័រ មីតេរ៉ង់ ថ្លែងថា : ការសម្រុះសម្រួល ជាមួយ ខ្មែរក្រហម ជាការមួយដែលពុំអាចទទួលយកបានឡើយ។ នៅទីក្រុងភ្នំពេញ លោក ហ៊ុន សែន រក ទាហានបន្ថែម ឲ្យបានជាកំហិត ។ ថ្ងៃ ១៥-១៧ មករា : ប្រទេស មហាអំណាច ទាំង៥ នៃ គណៈអចិន្ត្រៃយ៍ ក្រុមប្រឹក្សាសន្តិសុខ រួមប្រជុំគ្នានៅទីក្រុងប៉ារីស៍ ដើម្បីពិភាក្សាអំពី ផែនការសន្តិភាពអូស្ត្រាលី ហើយស្វែងរកមូលដ្ឋាន ដើម្បីឲ្យ អង្គការ សហប្រជាជាតិ ធ្វើអន្តរាគមន៍បញ្ចប់ អធិករណ៍ នៅ កម្ពុជា។ ថ្ងៃ ១៧ មករា : នៅទីក្រុងប៉េកាំង សម្តេច នរោត្តម សីហនុ ប្រកាស ថា ព្រះអង្គ ឈប់ចូលរួមក្នុងអង្គប្រជុំ អន្តរភាគីខ្មែរ ទៀតហើយ ។ ថ្ងៃ ១៨ មករា : សម្តេច នរោត្តម សីហនុ ថ្លែងថា: ការបង្កើត ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ជាគំនិត របស់ លោក ហ៊ុន សែន និង វៀតណាម ដូចនេះ ព្រះអង្គ នឹង មិនប្រមដឹកនាំ ក្រុមប្រឹក្សានោះឡើយ ហើយ ក៏នឹងមិនព្រមចូល ជាសមាជិក ក្រុមប្រឹក្សានោះ





ដែរ ។ ថ្ងៃ ២១ មករា : ខ្មែរក្រហម បង្ខំប្រជាជន ខ្មែរ ដែលរស់នៅ ក្នុងជំរំ របស់ខ្លួនចំនួន ៣ ម៉ឺននាក់ឲ្យចេញទៅច្បាំង។ ថ្ងៃ ២៤ មករា : សម្តេច នរោត្តម សីហនុ លាលែង ពីមុខតំណែងប្រធាន «រដ្ឋាភិបាលចម្រុះកម្ពុជា ប្រជាធិបតេយ្យ» (G.C.K.D.) ។ ថ្ងៃ ៣ កុម្ភៈ : សម្តេច នរោត្តម សីហនុ ប្រាប់ឲ្យ ដឹងថា ខ្មែរក្រហម សុខចិត្តប្តូរឈ្មោះ «រដ្ឋាភិបាលចម្រុះកម្ពុជាប្រជាធិបតេយ្យ» (G.C.K.D.) មកជា «រដ្ឋាភិបាលជាតិ កម្ពុជា» (G.N.K.) ។ ថ្ងៃ ៦ កុម្ភៈ : នៅកោះកុង ទាហានចំនួន ២៥០ នាក់ នៃ របប រដ្ឋកម្ពុជា នាំគ្នា បះបោរ ។ ថ្ងៃ ៩ កុម្ភៈ : វៀតណាម បង្កើតកងទ័ពសម្រាប់ធ្វើអន្តរាគមន៍ ឆាប់រហ័ស នៅកម្ពុជា តាមសំណើ របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ។ ថ្ងៃ ១២ កុម្ភៈ : អង្គការ សហប្រជាជាតិ សម្រេចបង្កើតកម្លាំងត្រៀមធ្វើភារកិច្ច (task force) ជាយថាហេតុ នៅប្រទេសកម្ពុជា។ ថ្ងៃ ១៣ -១៤ កុម្ភៈ : អ្នកតំណាង ប្រទេសមហាអំណាច ទាំង៥ នៃ គណៈអចិន្ត្រៃយ៍ អង្គការ សហប្រជាជាតិ រួមប្រជុំគ្នានៅទីក្រុងញូវយ៉ក។ អង្គប្រជុំ បានឈានមកដល់ ការស្រុះស្រួល គ្នា លើ ៤ ចំណុចសំខាន់ៗ ៖ ១) របៀប ត្រួតពិនិត្យ ការដកកងទ័ពវៀតណាម ២) ការចាំបាច់ នៃ ការឈប់បាញ់គ្នា - ៣) ការចាំបាច់ បញ្ឈប់រាល់ ការផ្តល់ជំនួយ យោធា ដល់គូភាគីខ្មែរទាំងអស់ -៤) ការចាំបាច់ យកកងទ័ពភាគីខ្មែរទាំងអស់ មកដាក់ជុំគ្នាមួយកន្លែង។ ថ្ងៃ ១៨ កុម្ភៈ : នៅក្នុងជំនួប អង្គការសេដ្ឋកិច្ច អឺរ៉ុប-អាស៊ាន នៅ គូជីង ប្រទេស ម៉ាឡេស៊ី បណ្តាប្រទេស នៃសហគមន៍អឺរ៉ុប បានប្រាប់ឲ្យដឹងថា គេឈប់គាំទ្រឲ្យ «រដ្ឋាភិបាលជាតិ» (G.N.C.) មាន អាសនៈនៅអង្គការ សហប្រជាជាតិ បន្តទៅទៀតហើយ។ ថ្ងៃ ២១ កុម្ភៈ : ជំនួបទី ៦ រវាង លោក ហ៊ុន សែន និង សម្តេច នរោត្តម សីហនុ នៅ ទីក្រុងបាងកក ។ អ្នកទាំងពីរបានស្រុះស្រួលគ្នា អំពី ការចាំបាច់ នៃ វត្តមានសមស្រប នៃ អង្គការសហប្រជាជាតិ នៅប្រទេសកម្ពុជា នៅក្នុងរយៈកាលឆ្លងកាត់ ហើយ ក៏យល់ស្រប អំពីការតម្រូវឲ្យមាន ក្រុមប្រឹក្សាជាតិមួយ សម្រាប់ តំណាងអធិបតេយ្យ និង ឯកភាពជាតិផងដែរ ។ ថ្ងៃ ២៣ កុម្ភៈ : សម្តេច នរោត្តម សីហនុ ប្រាប់ថាព្រះអង្គ នឹង មកគង់នៅ ប្រទេសកម្ពុជា ជាស្ថាពរ នៅក្នុងភូមិ«សេរីភាព» ក្នុងតំបន់ កាន់កាប់ ដោយ «កងទ័ពជាតិនិយម សីហនុ (A.N.S.) ។ នៅថ្ងៃដដែលនោះ កងទ័ព រដ្ឋកម្ពុជា វាយយក ស្វាយ ចេក

បានមកវិញ ។ ថ្ងៃ ២៦-២៨ កុម្ភៈ : អង្គប្រជុំ អន្តរជាតិមួយ ស្តីពី ប្រទេសកម្ពុជាដែលស្ថិតនៅក្នុងក្របខណ្ឌនៃសន្និសីទទីក្រុងប៉ារីស៍បានត្រូវបើកនៅទីក្រុងយ៉ាកាតា។ អ្នកតំណាងខាង «រដ្ឋាភិបាលជាតិ»ខាង «រដ្ឋកម្ពុជា» អ្នកតំណាងប្រទេសទាំង ៦ នៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ប្រទេសលាវ ប្រទេសវៀតណាម ប្រទេសអូស្រ្តាលី ប្រទេសបារាំង និង អគ្គលេខាធិការ អង្គការ សហប្រជាជាតិ បានចូលរួមប្រជុំ ។ ភាគីខ្មែរ ទាំង ៤ រក្សាទីតាំងរបស់គេរៀងៗ ខ្លួនដដែល។ ថ្ងៃ ៦ មិនា : លោក ឆាទីឆៃ ជនហាវ៉ែន រដ្ឋមន្ត្រីទី ១ ថៃ ស្នើឲ្យបង្កើតជំរំអេព្យាក្រឹតមួយ សម្រាប់ ជនជ្រកកោនខ្មែរនៅទល់ដែន គឺ នៅក្នុងគោលដៅចៀសវាង កុំឲ្យមាន ការគាបសង្កត់ នយោបាយ ។ ថ្ងៃ ១២-១៣ មិនា : ប្រទេសមហាអំណាចទាំងប្រាំ នៃ គណៈអចិន្រ្តៃយ៍ ក្រុមប្រឹក្សា សន្តិសុខ អង្គការ សហប្រជាជាតិ បើកអង្គប្រជុំ នៅទីក្រុងប៉ារីស៍។ អង្គប្រជុំ យល់ស្របគ្នាអំពី អភិក្រមបោះឆ្នោត។ ថ្ងៃ ៣០ មិនា : បេសកកម្មបច្ចេកទេស លើកទី ២ របស់ អង្គការ សហប្រជាជាតិ នៅកម្ពុជា ដើម្បីសិក្សាការត្រៀមលក្ខណៈ ធ្វើប្រតិបត្តិការ ជាយថាហេតុ ។ ថ្ងៃ ៨ ដល់ថ្ងៃ ២៥ មេសា : ការប្រយុទ្ធគ្នា មានសភាពខ្លាំងក្លាជាទីបំផុត។ ថ្ងៃ ១២ មេសា : កងទ័ពអាកាស របប «រដ្ឋកម្ពុជា» ទម្លាក់គ្រាប់បែក យ៉ាងខ្លាំងក្លា ទៅលើទីតាំងកងទ័ព នៃគូភាគីខ្មែរទាំង ៣ ទៀត ជាហេតុធ្វើឲ្យសម្តេច នរោត្តម សីហនុ ត្រូវបង្ខំចិត្ត ចាកចេញពី «ភូមិសេរីភាព» ។ ថ្ងៃ ២០-២៥មេសា : ទស្សនកិច្ច នៅកម្ពុជា របស់ គណៈប្រតិភូ សភា អឺរ៉ុប ដឹកនាំដោយលោក ក្លូដ សៃសុង។ ថ្ងៃ ៣ ឧសភា : ក្រសួងការបរទេស សហរដ្ឋ អាមេរិក ប្រាប់ឲ្យដឹងថា ប្រទេសចិន ផ្តល់អាវុធ ដ៏សន្ធឹកសន្ធាប់ ឲ្យខ្មែរក្រហម។ ថ្ងៃ ៧ ឧសភា : សម្តេច នរោត្តម សីហនុ ប្រកាសលាលែង ពីមុខតំណែងប្រធាន «រដ្ឋាភិបាលជាតិកម្ពុជា» (G.N.C.)។ ថ្ងៃ ១៧ ឧសភា : និស្សិតខ្មែរ ដែលទៅរៀន នៅសកលវិទ្យាល័យទីក្រុងហាណូយ ទាស់ទែងនឹងនិស្សិតវៀតណាមអស់រយៈពេល ២ សប្តាហ៍។ និស្សិតខ្មែរ ៥៨០ នាក់ វិលត្រឡប់មកស្រុកខ្មែរវិញ ។ ថ្ងៃ ២១ ឧសភា : អ្នកតស៊ូ កុម្មុយនិស្ត នៅក្នុង គណបក្ស «ប្រជាជនបដិវត្ត កម្ពុជា» ធ្វើការកាត់បន្ថយឥទ្ធិពល លោក ហ៊ុន សែន នៅក្នុង ការិយាល័យ នយោបាយ (Bureau politique)។ ឥស្សរជន ៦ រូបដែលត្រូវសង្ស័យថា នាំគ្នាបង្កើត គណបក្ស





ថ្មី បានត្រូវចាប់ខ្លួន ។ ខ្លះទៀតត្រូវចាប់បង្ខំ ឲ្យចូលនិវត្តន៍ ហើយខ្លះទៀតត្រូវផ្លាស់ ចេញ ។ ថ្ងៃ ២៤ ឧសភា : ឧត្តមសេនីយ៍ សាកស៊ុត សាខន អតីត មេបញ្ជាការសេនាធិការដ្ឋានកងទ័ពខ្មែរ ជំនាន់ សាធារណរដ្ឋខ្មែរ និង ជាអតីតសមាជិក «រណសិរ្សជាតិរំដោះពលរដ្ឋខ្មែរ» របស់ លោក សឺន សាន បង្កើត «គណបក្សសេរីនិយម ប្រជាធិបតេយ្យ» ។ ថ្ងៃ ២៥ ឧសភា : អ្នកតំណាងប្រទេស មហាអំណាច ទាំង ៥ នៃ គណៈអចិន្ត្រៃយ៍ ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហប្រជាជាតិ រួមប្រជុំគ្នានៅទីក្រុងញូវយ៉ក ដើម្បីលើកឡើង នូវ លក្ខខណ្ឌជាមូលដ្ឋាន សម្រាប់ឲ្យអ្នកដឹកនាំខ្មែរគោរពដូចជា: ការត្រួតពិនិត្យការឈប់បាញ់គ្នា ដោយអង្គការ សហប្រជាជាតិ -ការបញ្ឈប់រាល់ជំនួយបរទេស ដល់ភាគីខ្មែរនីមួយៗ - ការបោះឆ្នោតដោយសេរីក្រោមការឧបត្ថម្ភ របស់ អង្គការ សហប្រជាជាតិ និង គោរពការបោះឆ្នោតឲ្យបានទៀងទាត់ - ការជ្រើសរើសយក របប នយោបាយមួយ ដែលគោរពសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋាន - ការធានាអន្តរជាតិ នូវឯករាជ្យបូណ៌ភាពដែនដី អព្យាក្រឹតភាព និង ឯកភាពជាតិ។ ថ្ងៃ ២៩ ឧសភា : សម្តេច នរោត្តម សីហនុ វិលមកដឹកនាំ «រដ្ឋាភិបាលជាតិកម្ពុជា» វិញ ។ ថ្ងៃ ៤-៥ មិថុនា : ជំនួបទី ៧ រវាង លោក ហ៊ុន សែន នឹង សម្តេច សីហនុ ដែលម្តងនេះ ប្រព្រឹត្តទៅនៅ ទីក្រុងតូក្យូ។ ថ្ងៃ ១៩ មិថុនា : ប្រតិបត្តិការសឹករួម នៃកងទ័ព និយមសីហនុ (A.N.S.) នឹង កងទ័ពខ្មែរ ក្រហម ជុំវិញ កំពង់ធំ និង នៅតាមកន្លែង នានាទៀត ដូចជា កំពង់ឆ្នាំង កំពត កំពង់ស្ពឺ ។ ការប្រយុទ្ធទាំងនេះ បណ្តាលឲ្យប្រជាជន ប្រមាណ ១៥ ម៉ឺននាក់ ក្នុងទូទាំងប្រទេស រត់ចោលផ្ទះសំបែង ភូមិឃុំ របស់គេ។ ថ្ងៃ ១ កក្កដា : ខ្មែរក្រហម វាយប្រហារទៅលើ រថភ្លើងមួយ ដែលចេញពី កំពង់សោម ទៅទីក្រុងភ្នំពេញ បណ្តាលឲ្យអ្នកដំណើរ ២៦ នាក់ បាត់បង់ជីវិត ហើយ ៥២ នាក់ត្រូវ របួស និង ១០ នាក់ បាត់ខ្លួន ។ ការវាយប្រហារ ចុងក្រោយនេះ ធ្វើឲ្យប្រជាជនខ្មែរនិងបស្ចិមលោក មានការបារម្ភយ៉ាងខ្លាំង ខ្លាចខ្មែរក្រហម វិលមកវិញ។ ថ្ងៃ ៥ កក្កដា : រដ្ឋាភិបាលសឹង្ហបុរី សម្រេចដកហូតលិខិតឆ្លងដែន ពី អនិកជន ដែលចង់ទៅរកស៊ីនៅស្រុកខ្មែរ។ ថ្ងៃ ១៥ កក្កដា : ខ្មែរក្រហម វាយប្រហារ ទៅលើរថភ្លើង ភ្នំពេញ- បាត់ដំបង នៅត្រង់ស្រុក ទឹកផុស ខេត្តកំពង់ឆ្នាំង បណ្តាលឲ្យមនុស្ស ៥៣ នាក់ បាត់បង់ជីវិត និង របួស

រយនាក់ត្រូវរបួស។ ក្នុង ចំណោមអ្នកចុងក្រោយនេះ ខ្វះស្លាប់ នៅមន្ទីរពេទ្យ។ ថ្ងៃ ១៦-១៧ កក្កដា : អ្នកតំណាងប្រទេសមហាអំណាចទាំង ៥ នៃ គណអចិន្ត្រៃយ៍ ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហប្រជាជាតិ រួមប្រជុំគ្នា នៅទីក្រុងប៉ារីស៍។ កម្មវត្ថុ នៃការពិភាក្សា ៖ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ តំណាងអធិបតេយ្យកម្ពុជា ព្រមទាំងបញ្ហាយោធា ។ ថ្ងៃ ១៨ កក្កដា : លោក យ៉េម បេគែរ រដ្ឋមន្ត្រីការបរទេស សហរដ្ឋ អាមេរិក សម្រេចឈប់គាំទ្រ «រដ្ឋាភិបាលជាតិកម្ពុជា» (អតីតរដ្ឋាភិបាល ចម្រុះ កម្ពុជា ប្រជាធិបតេយ្យ G.C.K.D.) ឲ្យមានអាសនៈនៅ អង្គការ សហប្រជាជាតិ ។ លោក បេគែរ ក៏បានសម្រេចផងដែរ បង្កើនការផ្តល់ជំនួយ មនុស្សធម៌ ដល់ប្រទេសកម្ពុជា និងចាប់ផ្តើម បើកការប្រស្រ័យទាក់ទង ជាមួយទីក្រុងហាណូយស្តី ពីបញ្ហាខ្មែរ ។ ថ្ងៃ ២០ កក្កដា : យោងទៅតាម ពត៌មាន ដែលគេផ្តល់ទៅឲ្យព្រឹទ្ធសភាអាមេរិក ជំនួយដែលប្រទេសចិនកុម្មុយនិស្ត ផ្តល់ទៅឲ្យខ្មែររកហម មានចំនួនគិតជាទឹកប្រាក់ ១០០ លាន ដុល្លារ ។ ថ្ងៃ ២៤ កក្កដា : រដ្ឋមន្ត្រីការបរទេសបណ្តាប្រទេសអាស៊ាន មិនយល់ស្រប នឹង នយោបាយ សហរដ្ឋអាមេរិក ដែលប្រកាសនៅថ្ងៃ ១៨ កក្កដា។ ថ្ងៃ ៥ សីហា : លោក យ៉េម បេគែរ រដ្ឋមន្ត្រីការបរទេស សហរដ្ឋអាមេរិក ប្រាប់ឲ្យ ដឹង អំពី ការចរចា ជាមួយ «រដ្ឋកម្ពុជា» ។ ថ្ងៃ ២២ សីហា : អ្នកដឹកនាំ ៣ រូបនៃ «រដ្ឋាភិបាលជាតិកម្ពុជា» ត្រៀមលក្ខណៈជាស្រេច ដើម្បីចូលរួម ក្នុងអង្គប្រជុំជាមួយ របប «រដ្ឋកម្ពុជា» ដើម្បីបង្កើតក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ។ ថ្ងៃ ២៧- ២៨ សីហា : អង្គប្រជុំ ប្រទេសមហាអំណាចទាំងប្រាំ នៃ គណអចិន្ត្រៃយ៍ ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហប្រជាជាតិ នៅទីក្រុងញូវយ៉ក បានឈាន មកដល់ ការឯកភាពគ្នាស្តីពី ឯកសារ-ក្របខណ្ឌ ដែលដោះស្រាយវិបត្តិ នយោបាយខ្មែរទាំងមូល។ ខាង រដ្ឋាភិបាលជាតិ កម្ពុជា គេយល់ព្រមទាំងស្រុង ប៉ុន្តែខាងរដ្ឋកម្ពុជា គេចោទសួរថា តើមានភាពលំអៀងឬទេ តើការដកហូតអាវុធពី ភាគីខ្មែរក្រហម ពិតជាធ្វើទៅបាន ឬ ក៏ យ៉ាងណា ។ ថ្ងៃ ៣-៤ កញ្ញា : ជំនួបកំពូលសម្ងាត់ រវាង ចិន និង វៀតណាម នៅ ចេង ឌូ ដើម្បី ដាក់ទំនាក់ទំនង ជាប្រក្រតីឡើងវិញ រវាង ប្រទេសទាំងពីរ។ ថ្ងៃ ៩-១០ កញ្ញា : អង្គប្រជុំ ក្រៅ ផ្លូវការលើកទី ២ នៅទីក្រុងយ៉ាកាតា រវាង គូភាគីខ្មែរទាំង ៤ ។ កម្មវត្ថុ : ពិនិត្យ កិច្ចព្រមព្រៀង-ក្រប





ខណ្ឌ។ ភាគី ខ្មែរទាំង ៤ យល់ព្រមទាំងអស់គ្នា ។ លោក ហ៊ុន សែន និង លោកខៀវ សំផន ចាប់ដៃគ្នា។ ថ្ងៃ ១៨-២០ កញ្ញា : អង្គប្រជុំក្រុមប្រឹក្សាជាតិជាន់ខ្ពស់ នៅទីក្រុងបាងកក។ ការតែងតាំង សម្តេច នរោត្តម សីហនុ ជាសមាជិក ទី ១៣ នៃ ក្រុមប្រឹក្សា ធ្វើឲ្យមានការរាំងស្ទះ ព្រោះមាន ការបាត់តុល្យភាព ។ ថ្ងៃ ១២ តុលា : អាសនៈកម្ពុជា នៅ អង្គការ សហប្រជាជាតិ ស្ថិតនៅទំនេរ ។ ប៉ុន្តែ ខ្មែរក្រហម ខំប្រឹងប្រែងទាមទារយកអាសនៈឲ្យ «រដ្ឋាភិបាលជាតិ» បន្តទៅទៀត នៅទីស្នាក់ការ អង្គការ សហប្រជាជាតិ នៅទីក្រុងញូវយ៉ក ព្រោះមានសេចក្តីសម្រេចចិត្តមួយ ដែលគាំទ្រការខំប្រឹងប្រែងនេះ បានត្រូវអនុម័តដោយ មហាសន្និបាត អង្គការ សហប្រជាជាតិ។ នៅពាក់កណ្តាលខែតុលានោះ ខ្មែរក្រហម បានវាយប្រហារ ទៅលើ ថេភ្លើង ដែលចេញដំណើរពី កំពង់សោម ទៅភ្នំពេញ។ អ្នកដំណើរ ៥០ នាក់ ត្រូវបាត់បង់ជីវិត ។ ថ្ងៃ ២៥ តុលា : បរាជ័យ នៃ «ដំណោះស្រាយក្រហម» («solution rouge»)។ ការតស៊ូមតិ នៅក្នុងក្រុមជនកុម្មុយនិស្ត នៃ របប ហេង សំរិន ដើម្បីធ្វើការផ្សះផ្សា រវាង ជនកុម្មុយនិស្តដូចគ្នា (ខ្មែរក្រហមខាង ប៉ុល ពត និង ខ្មែរក្រហម ខាង ហេង សំរិន) បានត្រូវលោកហ៊ុន សែន ប្រានបោល ទោះបី មានការគាំទ្រពីទីក្រុងប៉េកាំង និង ទីក្រុងហាណូយក្តី។ ថ្ងៃ ២០ វិច្ឆិកា : ប្រទេសចិន ផ្តល់ឧបករណ៍កាំភ្លើងធំ ដល់ខ្មែរក្រហម ។ ថ្ងៃ ២៤-២៥-២៦ វិច្ឆិកា : អ្នកតំណាងប្រទេសមហាអំណាចទាំង៥ នៃ គណអចិន្ត្រៃយ៍ ក្រុមប្រឹក្សា សន្តិសុខ អង្គការ សហប្រជាជាតិ រួមប្រជុំគ្នានៅទីក្រុងប៉ារីស៍ ។ ថ្ងៃ ២១-២៣ ធ្នូ : សមាជិកទាំង ១២ រូប នៃ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដែលតំណាងអធិបតេយ្យប្រទេសកម្ពុជា រួមប្រជុំគ្នា នៅទីក្រុងប៉ារីស៍ ជាមួយ សហប្រធានទាំងពីរ នៃសន្និសីទទីក្រុងប៉ារីស៍ និង អ្នកតំណាងអង្គការ សហប្រជាជាតិ។ ខាង «រដ្ឋាភិបាលជាតិកម្ពុជា» គេយល់ព្រមទទួលយកផែនការ របស់ប្រទេសមហាអំណាច ទាំង ៥ ប៉ុន្តែ ខាង «រដ្ឋកម្ពុជា» គេនៅមានការប្រុងប្រយ័ត្ន។ លោក ហ៊ុន សែន ខ្យល់គរសន្ធប់បាត់ស្មារតី ហើយត្រូវគេដឹកទៅមន្ទីរពេទ្យ ។

# ១៩៩១

ថ្ងៃ ៤ មករា : សម្តេច នរោត្តម សីហនុ ប្រកាសថា ព្រះអង្គ មិនស្ថិតនៅក្នុង គណបក្សនយោបាយណាមួយទេ ប៉ុន្តែ ព្រះអង្គស្ថិតនៅជាប្រធាន «រដ្ឋាភិបាលជាតិកម្ពុជា» ដដែល។ ថ្ងៃ ៥ មករា : រដ្ឋាភិបាល «រដ្ឋកម្ពុជា» មិនព្រមរំលាយ រចនាសម្ព័ន្ធ រដ្ឋបាល និង កងទ័ពរបស់ខ្លួន មុនការបោះឆ្នោតទេ ព្រោះ មិនទុកចិត្ត ខ្មែរក្រហមនៅក្នុងរយៈពេល ឆ្លងកាត់។ ថ្ងៃ ២៣ កុម្ភៈ : រដ្ឋប្រហារនៅប្រទេស ថៃ។ ឧត្តមសេនីយ៍ សុចិន្តា អ្នកដឹកនាំធ្វើរដ្ឋប្រហារថ្លែងថា : បើប្រទេសកម្ពុជា ចង់ដោះស្រាយបញ្ហា ត្រូវចែកអំណាច ជាមួយ ខ្មែរក្រហម។ ថ្ងៃ ២៨ កុម្ភៈ : រដ្ឋសភា «រដ្ឋកម្ពុជា» បើកអង្គប្រជុំ ហើយ ចេញសេចក្តីសម្រេចចិត្តមួយ រិះគន់ គម្រោង ផែនការកិច្ចព្រមព្រៀង របស់ ប្រទេស មហាអំណាច ទាំង ៥ ។ ថ្ងៃ ១៦ មិនា : ខ្មែរក្រហម និង រណសិរ្ស ជាតិរំដោះពលរដ្ឋខ្មែរ រួមគ្នាធ្វើប្រតិបត្តិ ការសឹក ទប់ទល់ នឹង កងទ័ពរដ្ឋាភិបាល នៅ ថ្មពួក ។ ថ្ងៃ ២៥ មិនា : បរាជ័យ របស់ កងទ័ព រដ្ឋាភិបាល ក្នុងការវាយយក ប៉ៃលិន មកវិញ ។ ថ្ងៃ ៣០ មិនា : ការបើកផ្លូវអាកាសចរណ៍ ឡើងវិញ រវាង ទីក្រុងភ្នំពេញ និង ទីក្រុងបាងកក ។ ថ្ងៃ ៥-៨ មេសា : ទស្សនកិច្ច របស់ សមាជិកព្រឹទ្ធសភា សហរដ្ឋ អាមេរិក ក្រាម និង ម៉ាក់ កេន ព្រមទាំង អនុរដ្ឋមន្ត្រីរង អាមេរិក លើរន៍ ក័រណឺ នៅប្រទេសកម្ពុជា ហើយជួបសន្ទនា ជាមួយ លោក ជា ស៊ីម លោក ហ៊ុន សែន និង លោក ហោ ណាំហុង ។ ថ្ងៃ ៨ មេសា : ប្រទេសជប៉ុនផ្តល់ជំនួយ មនុស្សធម៌ ចំនួន ១ លាន ៣ សែន ៦ ម៉ឺន ដុល្លារដល់ «រដ្ឋកម្ពុជា» ។ ថ្ងៃ ២០ មេសា : លោក ហ៊ុន សែន ចូលព្យាបាលរោគ ១ សប្តាហ៍ នៅទីក្រុងតូក្យូ ប្រទេសជប៉ុន ។ ថ្ងៃ ២២ មេសា : ប្រទេសបារាំង ប្រទេសឥណ្ឌូណេស៊ី និង លោក អគ្គលេខាធិការ អង្គការ សហប្រជាជាតិ អំពាវនាវឲ្យមានការឈប់បាញ់គ្នា នៅកម្ពុជា ចាប់តាំងពីថ្ងៃ ១ ឧសភា។ ថ្ងៃ ២៦ មេសា : នៅទីក្រុងបាងកក នៅពេលជួបសន្ទនា ជាមួយលោករដ្ឋមន្ត្រីទី ១ ថៃ អាណន្ត ប៉ាន់ យ៉ារជន លោក ខៀវ សំផន ព្រះអង្គម្ចាស់ រណឫទ្ធិ និង លោក សឺន សាន ប្រាប់ឲ្យដឹងថា ភាគីរបស់ខ្លួន យល់ព្រមទទួលយកការឈប់បាញ់គ្នា ។ នៅថ្ងៃ ដដែលនោះ



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

លោក ហ៊ុន សែន ដែលទើប នឹងចេញពីមន្ទីរពេទ្យនៅទីក្រុងតូក្យូ ក៏ប្រាប់ឲ្យដឹងថាលោក ក៏ទទួលយល់ព្រមដែរ ។ ថ្ងៃ ២៩ មេសា : សហរដ្ឋ អាមេរិក ផ្តល់ជំនួយ គិតជាទឹកប្រាក់ ចំនួន ៧ លាន ដុល្លារ ដល់ភាគីខ្មែរដែល មិនមែនកុម្មុយនិស្ត ។ ថ្ងៃ ១ ឧសភា : ការចាប់ផ្តើម នៃ ការឈប់បាញ់គ្នា នៅកម្ពុជា ។ ថ្ងៃ ៣ ឧសភា : ទស្សនកិច្ច លោក យ៉ុន គែរី សមាជិកព្រឹទ្ធសភា អាមេរិកនៅកម្ពុជា ។ ពេលត្រឡប់មក សហរដ្ឋ អាមេរិកវិញ លោក បានប្រាប់ឲ្យដឹងថា សហរដ្ឋ អាមេរិក ត្រូវមានការិយាល័យ សម្រាប់ទាក់ទងគ្នាមួយ នៅភ្នំពេញ ហើយ ខ្មែរក្រហម ត្រូវដកចេញពី អភិក្រមសន្តិភាព ។ ថ្ងៃ ១៥ ឧសភា : ប្រទេសឥណ្ឌូណេស៊ី យាងសម្តេច នរោត្តម សីហនុ មកធ្វើទស្សនកិច្ច នៅទីក្រុងយ៉ាកាតា នៅ ឱកាសបើកអង្គប្រជុំ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ នៅដើមខែ មិថុនា ។ ថ្ងៃ ១៨ ឧសភា : ខ្មែរក្រហមគំរាមថា នឹងចេញប្រយុទ្ធសាជាថ្មីទៀត បើរដ្ឋកម្ពុជា មិនយល់ព្រម ទទួលយក ផែនការ របស់ ប្រទេសមហាអំណាច ទាំង ៥ នៃ គណអចិន្ត្រៃយ៍ ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហប្រជាជាតិ។ ថ្ងៃ ២០ ឧសភា : របប រដ្ឋកម្ពុជា ប្រារព្ធ យ៉ាងអធិកអធម ទិវាថ្កោលទោស «របបប្រល័យពូជសាសន៍»។ ថ្ងៃ ២៨- ៣១ ឧសភា :លោកស្រីករិយា លោក ប្រធានាធិបតីបារាំង ហ្វ្រង់ស្វ័រ មីត្តេរ៉ង់ ធ្វើទស្សនិច្ចនៅកម្ពុជា ។ លោកស្រី បានជួប សន្ទនាជាមួយ លោក ហ៊ុន សែន និង លោក ហោ ណាំហុង។ ថ្ងៃ ១ មិថុនា : ជំនួប រវាង លោក ហ៊ុន សែន និង សម្តេច នរោត្តម សីហនុ នៅទីក្រុងយ៉ាកាតា ។ អ្នកទាំងពីរសុខចិត្តយល់ព្រម អំពី អធិបតីភាព នៃ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ (CNS) ដែល តំណាងអធិបតេយ្យ ប្រទេសកម្ពុជានៅក្នុងរយៈពេលឆ្លងកាត់ អំពីការពន្យាពេល ការឈប់ បាញ់គ្នា និង អំពី ការផ្តាច់ជំនួយ បរទេសឲ្យអស់ពី ភាគីនីមួយៗ ។ ថ្ងៃ ២ - ៣ មិថុនា : ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ បើកអង្គប្រជុំនៅទីក្រុងយ៉ាកាតា ក្រោមអធិបតីភាព នៃ សហប្រធាន ទាំងពីរ នៃ សន្និសីទ ទីក្រុងប៉ារីស៍ គឺ បារាំង និង ឥណ្ឌូណេស៊ី ។ ថ្ងៃ ៤ មិថុនា : ការប្រយុទ្ធគ្នាមួយ ផ្ទុះឡើង រវាងខ្មែរក្រហម និង កងទ័ព រដ្ឋកម្ពុជា នៅជុំវិញប៉ៃលិន ។ គឺជា ការរំលោភទៅលើ គោលការណ៍ ឈប់បាញ់គ្នា លើកដំបូងបង្អស់។ ថ្ងៃ ៦ មិថុនា : សម្តេច សីហនុ ប្រកាសថា ព្រះអង្គ ត្រៀមលក្ខណៈជាស្រេច ដើម្បីឆ្លើយតប ទៅនឹង ការ

ដែលលោក ហ៊ុន សែន បានយាងព្រះអង្គ ទៅទីក្រុងភ្នំពេញ។ ថ្ងៃ ៧ មិថុនា : លោក ក្បាង គីចិន រដ្ឋមន្ត្រី ការបរទេសចិន រិះគន់ អាកប្បកិរិយា របស់ខ្មែរក្រហម ដោយចំហ ។ ថ្ងៃ ១០-១៧ មិថុនា : ទស្សនកិច្ច លោក ជាស៊ីម នៅទីក្រុងប៉ារីស៍។ ថ្ងៃ ១១ មិថុនា : ប្រទេសថៃ ធ្វើការគាបសង្កត់ទៅលើប្រទេសចិន ឲ្យចិនធ្វើការគាបសង្កត់បន្ត ទៅលើខ្មែរក្រហម ដើម្បីឲ្យខ្មែរក្រហម ប្រកាន់ឥរិយាបថ បេះបត់បែនតាមស្ថានការណ៍។ ថ្ងៃ ២៤-២៦ មិថុនា : អង្គប្រជុំក្រុមប្រឹក្សាជាតិជាន់ខ្ពស់ នៅ ប៉ាតាយ៉ា ប្រទេសថៃ ។ សម្តេច នរោត្តម សីហនុ ដឹកនាំអង្គប្រជុំនេះ ជាលើកដំបូងបង្អស់ ។ ថ្ងៃ ១១ កក្កដា : ប្រទេសចិនអញ្ជើញ លោក ហ៊ុន សែន ទៅធ្វើទស្សនកិច្ច ជាផ្លូវការនៅ ប្រទេសចិន ។ ថ្ងៃ ១៦-១៧ កក្កដា : ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ បើកអង្គប្រជុំ នៅទីក្រុងប៉េកាំង ។ គឺជាលើកដំបូងបង្អស់ហើយ ដែលលោក ហ៊ុន សែន មកប្រទេសចិន ប្រជាមានិត្ត ។ ថ្ងៃ ១៨ កក្កដា : អ្នកតំណាង ប្រទេសមហាអំណាចទាំង ៥ នៃ គណអចិន្ត្រៃយ៍ក្រុមប្រឹក្សា សន្តិសុខ អង្គការ សហប្រជាជាតិ បើកអង្គប្រជុំនៅទីក្រុងប៉េកាំង ដើម្បីឆ្លើយតបទៅនឹង ការអំពាវនាវរបស់ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ឲ្យអង្គការសហប្រជាជាតិ ទៅបំពេញ បេសកកម្ម នៅប្រទេសកម្ពុជា ។ ថ្ងៃ ១៩ កក្កដា : សមាគម ប្រជាជាតិ អាស៊ីអាគ្នេយ៍ ទទួលស្គាល់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ។ ថ្ងៃ ២០-២១ កក្កដា : សម្តេច សីហនុ និងលោក ហ៊ុន សែន ធ្វើទស្សនកិច្ចនៅ ប្រទេសកូរ៉េខាងជើង ។ ថ្ងៃ ២២-២៤ កក្កដា : ទស្សនកិច្ច ជាផ្លូវការ របស់លោក ហ៊ុន សែន នៅសាធារណរដ្ឋ ប្រជាមានិត្ត ចិន។ ថ្ងៃ ២៤ កក្កដា : សហរដ្ឋ អាមេរិក អំពាវនាវ ឲ្យមានការប្រុងប្រយ័ត្ន ចំពោះ ការដោះស្រាយតែ ភាគខ្លះ នៃ អធិករណ៍ខ្មែរគឺបណ្តោយឲ្យ ទីក្រុងប៉េកាំងធ្មៀតយក «ដំណោះស្រាយក្រហម» មកជំនួស។ សហរដ្ឋ អាមេរិក បញ្ជាក់ហើយបញ្ជាក់ទៀត អំពីលក្ខណៈ សំខាន់ នៃ ការបោះឆ្នោត ដោយសេរី នឹងទៀងទាត់ ។ ថ្ងៃ ២៧ កក្កដា : ការបាញ់គ្នា រវាងអ្នកការពារសន្តិសុខ លោក ជា ស៊ីម នឹង អង្គរក្ស របស់លោក ហ៊ុន សែន ។ ថ្ងៃ ១០ សីហា : ប្រទេស ចិន និង ប្រទេសវៀតណាម ដាក់ ទំនាក់ទំនងគ្នាជាប្រក្រតីឡើងវិញ។ ថ្ងៃ ២២ សីហា : ក្រសួងការបរទេសសហរដ្ឋ អាមេរិក តាមរយៈលោក សាឡូម៉ុង ឧបការី លោកយ៉េម បេគែរ បាន បញ្ចេញឲ្យដឹង អំពីការបារម្ភខ្លាចក្រែង



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ដំណោះស្រាយមិនគ្រប់ជ្រុងជ្រោយ នៃ អធិករណ៍ខ្មែរ ក្លាយជា«ដំណោះស្រាយក្រហម» ។ ថ្ងៃ ២៣ សីហា : នៅទីក្រុង បាងកក លោក សូ ឌុបសិន អនុរដ្ឋមន្ត្រី ការបរទេសចិន ធ្វើការកែតម្រូវថា ដំណោះស្រាយ អធិករណ៍ខ្មែរ ដែលកំពុងធ្វើដំណើរការ មិនមែន ជា «ដំណោះស្រាយក្រហម» ទេ ។ លោក បានបញ្ជាក់នូវការគាំទ្ររបស់ ប្រទេសចិនចំពោះ ផែនការ របស់ ប្រទេសមហាអំណាចទាំងប្រាំ នៃ គណអចិន្ត្រៃយ៍ ក្រុមប្រឹក្សា សន្តិសុខ អង្គការ សហប្រជាជាតិ។ នៅទីក្រុងហ្សឺណែវ អនុគណកម្មការ សិទ្ធិមនុស្ស អង្គការ សហប្រជាជាតិ ទទួលស្គាល់ជាលើកដំបូងបង្អស់ថា ពិតជាមាន អំពើប្រល័យពូជសាសន៍ និង អំពើឧក្រិដ្ឋប្រឆាំង នឹង មនុស្សជាតិមែន នៅកម្ពុជា នៅសម័យខ្មែរក្រហមកាន់អំណាច ។ ថ្ងៃ ៣១ សីហា :ទឹកជំនន់ នៅស្រុកខ្មែរ។ មនុស្ស ១១០ នាក់ បាត់បង់ជីវិត។ ថ្ងៃ ៥ កញ្ញា : ប្រទេសចិន ប្រកាសឈប់ផ្តល់ជំនួយឲ្យខ្មែរក្រហម ប៉ុន្តែបន្តផ្តល់ជំនួយសេដ្ឋកិច្ច ។ ថ្ងៃ ១០ កញ្ញា : ការសន្ទនា រវាងរដ្ឋមន្ត្រី ការបរទេស ចិន និងរដ្ឋមន្ត្រីការបរទេស វៀតណាមនៅទីក្រុងប៉េកាំង។ គឺជាជំណាក់ការទី ២ នៃ អភិក្រមសន្តិភាវូនីយកម្ម រវាង ប្រទេសទាំងពីរ។ ថ្ងៃ ១៤ កញ្ញា : ជំនួបរវាង សម្តេច នរោត្តម សីហនុ និង លោក ប្រធានាធិបតី បារាំង ហ្វ្រង់ស្វ័រ មីត្តេរ៉ង់ ។ ថ្ងៃ ១៦ កញ្ញា : ជំនួប រវាង សម្តេច នរោត្តម សីហនុ និង លោក ហ៊ុន សែន នៅទីក្រុងញូវយ៉ក។ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ បានទទួលអាសនៈ នៅ អង្គការ សហប្រជាជាតិ។ ថ្ងៃ ១៩ កញ្ញា : អង្គប្រជុំក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៅ ទីក្រុងញូវយ៉ក ជាមួយ អ្នកតំណាង អង្គការ សហប្រជាជាតិ : ការរកឃើញ នូវដំណោះស្រាយស្តីពីការបោះឆ្នោត ៖ ភាគីខ្មែរស្រុះស្រួលគ្នាយកការបោះឆ្នោត របៀបសមាមាត្រ ប៉ុន្តែ សម្រាប់អនុវត្ត តែនៅតាមខេត្តនីមួយៗ តែប៉ុណ្ណោះ ។ ថ្ងៃ ២៤ កញ្ញា: សម្តេច នរោត្តម សីហនុ ជួបសន្ទនា នៅទីក្រុង ញូយ៉ក ជាមួយលោក ប៊ូស្ហ[៨៨] ប្រធានាធិបតី សហរដ្ឋ អាមេរិក ។ លោក ប៊ូស្ហ សំដែងការបារម្ភ ខ្លាចក្រែង ខ្មែរក្រហម វិលមកកាន់អំណាចវិញ។ សម្តេច

[៨៨] លោក ប៊ូស្ស ឪពុក លោក វ៉ល់គែរ ប៊ូស្ហ ជាប្រធានាធិបតី សហរដ្ឋ អាមេរិក ពីឆ្នាំ ១៩៨៨-១៩៩២ ។

នរោត្តម សីហនុ ប្រាប់លោក ប៊ូស្ហ វិញថា គឺ លោក ហ៊ុន សែន ទេ ដែលនឹងឈ្នះ នៅក្នុងការបោះឆ្នោត នៅក្នុងពេលខាងមុខ។ ថ្ងៃ ១០ តុលា : ប្រទេសកម្ពុជា ចូលរួមក្នុង អង្គសភាប្រចាំឆ្នាំ នៃ អង្គការ «ធនាគារពិភពលោក» ។ លោក ស៊ឹន សាន បានត្រូវបាត់តាំងឲ្យតំណាងក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៅក្នុងអង្គសភានោះ។ សូមបញ្ជាក់ថាក្រោយឆ្នាំ ១៩៧៤ មកទល់នឹងឆ្នាំ ១៩៩១ នោះ ប្រទេសកម្ពុជា គ្មានអ្នកតំណាងរបស់ ខ្លួននៅក្នុងអង្គការនោះទេ។ ថ្ងៃ ១៧-១៨ តុលា : គណបក្ស «ប្រជាជនបដិវត្តកម្ពុជា» បើកមហាសន្និបាត វិសាមញ្ញរបស់ខ្លួន ។ គឺនៅក្នុង មហាសន្និបាត នេះហើយ ដែល គណបក្ស «ប្រជាជនបដិវត្តកម្ពុជា» បានប្តូរឈ្មោះមកជា គណបក្ស «ប្រជាជនកម្ពុជា» ដូចកាលពីឆ្នាំ ១៩៦២ ហើយប្តូរ ទស្សនះសេដ្ឋកិច្ច ម៉ាក្សនិយម មកជា សេដ្ឋកិច្ច ផ្សារ និងប្រកាសគោរព គោលការណ៍សិទ្ធិមនុស្ស។ គឺតាំងពីពេលនោះមកដែរ ដែលលោក ជា ស៊ីម ត្រូវតែងតាំង ជាប្រធានគណបក្ស ហើយលោក ហ៊ុន សែន ជាអនុប្រធាន ។ ថ្ងៃ ១៦ តុលា : ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហប្រជាជាតិ បង្កើតអង្គការ «មីប្រេនុច» (MIPRENUC) សម្រាប់ធ្វើបេសកកម្ម រៀបចំអន្តរាគមន៍ របស់អង្គការ សហប្រជាជាតិ នៅកម្ពុជា។ ថ្ងៃ ២៣ តុលា : សន្និសីទអន្តរជាតិ ទីក្រុងប៉ារីស៍ : រដ្ឋាភិបាលចំនួន ១៨ ព្រមទាំង ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ផង ចុះហត្ថលេខា ទៅលើកិច្ចព្រមព្រៀង ដែលដោះស្រាយ បញ្ហាអធិករណ៍ខ្មែរ ជាសរុបតែម្តង។ ថ្ងៃ ២៥ តុលា : អង្គប្រជុំក្រុម ប្រឹក្សាជាតិជាន់ខ្ពស់ នៅទីក្រុងប៉ារីស៍ ។ ថ្ងៃ ៣០ តុលា : របបរដ្ឋកម្ពុជា ដោះលែងអ្នកទោសចំនួន ១០៣៤ នាក់ ។ ថ្ងៃ ៣១ តុលា : ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហប្រជាជាតិ គាំទ្រ កិច្ចព្រមព្រៀងថ្ងៃ ២៣ តុលា ហើយបាត់តាំង ឲ្យលោក អគ្គលេខាធិការ អង្គការ សហប្រជាជាតិ រៀបចំ ធ្វើអន្តរាគមន៍ នៅកម្ពុជា ។ ថ្ងៃ ១១ វិច្ឆិកា : លោក ហ៊ុន សែន ធ្វើដំណើរ ទៅទីក្រុងប៉េកាំង ដើម្បីយាងសម្តេច នរោត្តម សីហនុ វិលត្រឡប់មកស្រុកខ្មែរវិញ។ ថ្ងៃ ១៤ វិច្ឆិកា : សម្តេច នរោត្តម សីហនុ យាងមកទីក្រុងភ្នំពេញ បន្ទាប់ពី គង់នៅ បរទេស អស់រយៈពេលជាង ១២ ឆ្នាំ ។ ថ្ងៃ ១៥ វិច្ឆិកា : ខ្មែរក្រហម អំពាវ នាវឲ្យសមាសភាព «រដ្ឋាភិបាលចម្រុះ កម្ពុជាប្រជាធិបតេយ្យ» មានគណបក្ស «ហ្វុនស៊ីនប៉េច» និង «រណសិរ្សជាតិរំដោះពលរដ្ឋខ្មែរ» ជាដើម



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

ធ្វើការតស៊ូ បន្ត ទៀតហើយស្នើឲ្យមាន អ្នកតំណាងរួមគ្នា ក្នុងការបោះឆ្នោត ។ ថ្ងៃ ១៦ វិច្ឆិកា : សម្តេច នរោត្តម សីហនុ ថ្លែង នៅចំពោះមុខប្រជាជនខ្មែរថា : លោក ហ៊ុន សែន និងព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិជា «កូន» ព្រះអង្គ ទាំងពីរ ។ ព្រះអង្គ បានថ្កោលទោសការឈ្លានពាន របស់កងទ័ពវៀតណាម ប៉ុន្តែ ទ្រង់បញ្ជាក់ផងដែរថា បើគ្មានកងទ័ពវៀតណាម យើងទាំងអស់គ្នាស្លាប់បាត់អស់ទៅហើយ។ នៅក្នុងឱកាសនោះដែរ សម្តេច នរោត្តម សីហនុ ទ្រង់បានថ្លែងថា ព្រះអង្គពុំយល់ទាស់ ពី ការយកខ្មែរក្រហម ទៅឲ្យតុលាការ កាត់ទោសទេ ។ ថ្ងៃ ១៧ វិច្ឆិកា : គណាប្រតិភូខ្មែរក្រហមមួយ ដឹកនាំដោយ សុន សេន មកដល់ទីក្រុងភ្នំពេញ។ ថ្ងៃ ២០ វិច្ឆិកា : រដ្ឋាភិបាល «រដ្ឋកម្ពុជា» និង គណបក្ស «ប្រជាជនកម្ពុជា» ផ្សាយ សេចក្តីថ្លែងការណ៍រួមមួយថ្កោលទោសអ្វីដែលពួកគេហៅថា «រដ្ឋប្រហារ ថ្ងៃ ១៨ មិនាឆ្នាំ១៩៧០» ហើយទទួលស្គាល់ សម្តេច នរោត្តម សីហនុ ជាប្រមុខរដ្ឋ ។ ថ្ងៃ ២២ វិច្ឆិកា : ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ បើកសម័យប្រជុំ នៅទីក្រុងភ្នំពេញ ។ នៅក្នុងអង្គប្រជុំ គេពុំឃើញវត្តមាន របស់ អ្នកតំណាងខ្មែរ ក្រហមទេ ។ ថ្ងៃ ២៣ វិច្ឆិកា : សម្តេច នរោត្តម សីហនុ ប្រកាសបង្កើត រដ្ឋាភិបាលចម្រុះមួយដែលមានគណបក្ស «ហ្វុនស៊ីនប៉េច» និងគណបក្ស «ប្រជាជន» ចូលរួមគ្នា។ លោក ស៊ឹន សាន ប្រកាសដូច្នេះវិញថា មុនការបោះឆ្នោតក្រុមប្រឹក្សាជាតិ ជាន់ខ្ពស់ ជា រដ្ឋាភិបាលតែមួយគត់ នៅកម្ពុជា។ ថ្ងៃ ២៦ វិច្ឆិកា : ការិយាល័យ ប្រធានក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ចេញផ្សាយ សេចក្តីជូនដំណឹងមួយ បញ្ជាក់ថា គូភាគីខ្មែរទាំង ៤ ថ្លែងជាផ្លូវការ ថា សម្តេច នរោត្តម សីហនុ ជាប្រមុខរដ្ឋស្របច្បាប់ និង ពេញសិទ្ធិ នៃប្រទេសកម្ពុជា តាំងពីឆ្នាំ ១៩៦០មក ។ ថ្ងៃ ២៧ វិច្ឆិកា : លោកខៀវសំផនត្រឡប់មកស្រុកខ្មែរវិញ។ បាតុករ មួយក្រុមបាននាំគ្នាវាយ លោក ខៀវ សំផន បែកក្បាលចេញឈាម។ ទោះបីមានអន្តរាគមន៍ ពីរដ្ឋអំណាចក្តី លោក ខៀវ សំផន សម្រេចវិលទៅទីក្រុងបាងកកវិញ។ ថ្ងៃ ៣ ធ្នូ : ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ បើកអង្គប្រជុំនៅ ប៉ាតាយ៉ា ប្រទេសថៃ។ ថ្ងៃ ៥ ធ្នូ : នៅ ប៉ាតាយ៉ា សម្តេច នរោត្តម សីហនុ ថ្លែងថា : សម្ព័ន្ធភាព រវាង គណបក្ស «ហ្វុនស៊ីនប៉េច» នឹង គណបក្ស «ប្រជាជន» មិននាំ ទៅរកការបង្កើត រដ្ឋាភិបាលចម្រុះ មុនការបោះឆ្នោតឡើយ ព្រោះព្រះអង្គ ទុកចិត្ត លោក ហ៊ុន

សែន តែ ៥០% ប៉ុណ្ណោះ ។ ថ្ងៃ ១៣ ធ្នូ : អ្នកដឹកនាំ ខ្មែរ ក្រហមប្រជុំគ្នានៅជិត ប៉ៃលិន ដើម្បីធ្វើការវាយតម្លៃ ការអនុវត្តន៍ កិច្ចព្រមព្រៀងសន្តិភាព។ ថ្ងៃ ១៧-២៣ ធ្នូ : និស្សិត ធ្វើបាតុកម្មថ្កោលទោស អំពើពុករលួយ។ មនុស្ស១១ នាក់បាត់បង់ជីវិត ហើយសាលារៀន និង សកលវិទ្យាល័យ ត្រូវបិទទ្វារ។ ថ្ងៃ ៣០ ធ្នូ : អង្គប្រជុំលើកដំបូងបង្អស់នៅភ្នំពេញ នៃ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ។

## ១៩៩២

ថ្ងៃ ១ មករា : «ធនាគារ នៃ ប្រទេសកម្ពុជា» (ធនាគារកណ្តាល) ចាប់ដំណើរ ការឡើងវិញ បន្ទាប់ពីត្រូវបិទទ្វារ នៅ ខែមេសា ឆ្នាំ ១៩៧៥។ ថ្ងៃ ៤ មករា : សហរដ្ឋ អាមេរិក បើកឲ្យ មានទំនាក់ទំនងពាណិជ្ជកម្ម ជាមួយ កម្ពុជាវិញ បន្ទាប់ពីត្រូវកាត់ផ្តាច់ នៅឆ្នាំ ១៩៧៥។ ថ្ងៃ ៦ មករា : សម្តេច សីហនុ ប្រាប់ឲ្យដឹងថា ព្រះអង្គ បានទទួលប្រាក់ ឧបត្ថម្ភ ពីប្រទេសចិន ចំនួន ៣០ ម៉ឺនដុល្លារ ក្នុង ១ ឆ្នាំៗ ។ ថ្ងៃ ៩ មករា : លោក យ៉ាស៊ូស៊ុ អាកាស៊ុ បាន ត្រូវតែងតាំងជា អ្នកតំណាងពិសេស របស់ លោកអគ្គលេខាធិការ អង្គការ សហប្រជាជាតិ ។ ថ្ងៃ ១៤ មករា : សម្តេច នរោត្តម សីហនុ សម្តែង ការមិនសព្វព្រះហឫទ័យ ចំពោះ ការរំលោភកិច្ចឈប់បាញ់គ្នា មិនឈប់ឈរ ពីសំណាក់ខ្មែរក្រហម។ ព្រះអង្គ គំរាមថា ព្រះអង្គ ចង់លាលែង ពីមុខតំណែង ប្រធានក្រុមប្រឹក្សាជាតិ ជាន់ខ្ពស់។ ថ្ងៃ ១៧ មករា : ការចាប់កំណើត នៃសមាគម ADHOC។ គឺជាសមាគម ការពារសិទ្ធិមនុស្ស ទី ១ ដែល កើតឡើងនៅស្រុកខ្មែរ ហើយដែលមានលោក ធន សារ៉ាយ ជាប្រធាន។ ថ្ងៃ ២១ មករា : ការវាយប្រហារអុកឡុក របស់ខ្មែរក្រហម នៅកំពង់ធំ។ អង្គការ «មីប្រេនុច» បញ្ជូនកងទ័ព មួយអង្គភាពទៅបង្ក្រាប។ មនុស្ស ២១ នាក់ បាត់បង់ជីវិត ហើយប្រជាជន ១ ម៉ឺន នាក់ រត់ បោលផ្ទះសម្បែង។ ថ្ងៃ ២២ មករា : លោក ទៀ ប៊ុនឡុង អ្នកទទួលខុសត្រូវ កិច្ចការ សាសនា នៃ របបរដ្ឋកម្ពុជា បានត្រូវគេធ្វើឃាត។ លោកបានធ្វើ ការរិះគន់ អំពើពុករលួយ យ៉ាងចាស់ដៃ ។ នៅថ្ងៃដដែលនោះសម្តេច នរោត្តម សីហនុ ទ្រង់ស្នើសុំ ឲ្យអង្គការ «អាប្រូ





នុច» ប្រញាប់ចុះធ្វើអន្តរាគមន៍ ។ ថ្ងៃ ២៥ មករា :សម្តេច នរោត្តម សីហនុ អះអាងថា អស់មានកងទ័ពវៀតណាម ទៀតហើយ នៅកម្ពុជា។ ថ្ងៃ ២៦ មករា : លោក ប៉ែន សុវណ្ណ ដែលត្រូវដក ហូតពីអំណាច នៅឆ្នាំ ១៩៨១ វិលត្រឡប់មករស់នៅ ក្នុងខែត្រតាកែវវិញ។ ថ្ងៃ ២៨ មករា : លោក អ៊ឹង ផន អតីតកម្មាភិបាល របប«សាធារណរដ្ឋប្រជាមានិតកម្ពុជា» ហើយដែលជាមិត្តម្នាក់ របស់ លោក ហ៊ុន សែន បានត្រូវគេ ប៉ុនប៉ងធ្វើឃាត។ មុន ឧបទ្ទវ ហេតុនេះ លោក អ៊ឹង ផន បានធ្វើការរិះគន់ កម្មាភិបាល កុម្មុយនិស្ត មួយចំនួន ដែលបាន ក្លាយទៅជាអ្នកមានប្រាក់រាប់លាន។ លោក មានគោលបំណង បង្កើតបក្សមួយថ្មីទៀត ជា មួយ ខាន់ ម៉ន និង យ៉ង់ ហ៊ាន។ បន្ទាប់ពី បានជួបលោក ថ្វាយនីញ ឯកអគ្គរដ្ឋទូត សហ រដ្ឋអាមេរិក លោក អ៊ឹង ផនត្រូវលោក ហ៊ុន សែន ឲ្យទៅ ស្នាក់អាស្រ័យ នៅផ្ទះលោក ដើម្បីស្រួលការពារសន្តិសុខ។ គឺនៅពេលនោះហើយ ដែល បរិយាកាសភ័យខ្លាច កើតមាន ឡើង នៅទូទាំងប្រទេស។ យោងទៅតាមការសន្និដ្ឋានខ្លះ បរិយាកាសនេះ បណ្តាលមកពី សមាជិក នៃអតីតគណបក្សកុម្មុយនិស្តមួយចំនួន ដែលមិនពេញចិត្ត នឹង គណបក្ស «ហ្វុន ស៊ីនប៉ិច» និង «រណសិរ្សជាតិ រំដោះពលរដ្ឋ ខ្មែរ» ។ ថ្ងៃ ៣១ មករា : រដ្ឋាភិបាល លោក ហ៊ុន សែន ធ្វើការផ្លាស់ប្តូរ សមាសភាពសំខាន់ៗ។ មតិខ្លះយល់ថា គឺជា ការរកកលដោះ ដៃចេញពី ការត្រួតពិនិត្យ របស់អង្គការ «អាប្រូនុច» នៃ អង្គការ សហប្រជាជាតិ ។ លោក ជា សុទ្ធ លោក ប៊ូ ថង ត្រូវដកចេញ ។ លោក ស ខេង អ្នកជំនិតរបស់លោក ជា ស៊ីម និង ព្រះអង្គម្ចាស់ចក្រពង្ស បានត្រូវតែងតាំង ជាឧបនាយករដ្ឋមន្ត្រី រីឯ ព្រះអង្គម្ចាស់ ក្សត្រី បុប្ផាទេវី ជា អនុរដ្ឋមន្ត្រីក្រសួងវប្បធម៌។ ថ្ងៃ ៦ កុម្ភៈ :ខ្មែរក្រហម ប្រជុំគ្នានៅ ប៉ៃលិន ហើយសម្រេច មិនអនុវត្ត កិច្ចព្រមព្រៀងទីក្រុងប៉ារីស៍ ។ ថ្ងៃ ១១ កុម្ភៈ : ទស្សន កិច្ច របស់លោករដ្ឋមន្ត្រីការបរទេសចិន នៅកម្ពុជា។ ថ្ងៃ ១៨ កុម្ភៈ : និកាយពុទ្ធសាសនា ទាំងពីរគណៈ គឺ គណៈមហានិកាយ និង គណៈធម្មយុត្តិកនិកាយ បានត្រូវបង្កើតឲ្យមាន ឡើងវិញ ។ ថ្ងៃ ១៩ កុម្ភៈ : ឧត្តមសេនីយ៍ សាកស៊ុត សាខន អតីតអគ្គបញ្ជាការ សេនា ធិការដ្ឋានកងទ័ព ក្នុងរបប សាធារណរដ្ឋខ្មែរ បានមកដល់ទីក្រុងភ្នំពេញ។ ថ្ងៃ ២៥ កុម្ភៈ : ការប្រយុទ្ធគ្នា រវាង កងទ័ពខ្មែរក្រហម នឹងកងទ័ពរាជរដ្ឋាភិបាល កាន់តែមានលក្ខណៈខ្លាំង

ក្លាថែមទៀត នៅផ្នែកខាងជើង នៃខេត្តកំពង់ធំ។ ថ្ងៃ ២៧ កុម្ភៈ : សម្តេច នរោត្តម សីហនុ យាងទៅ ប៉ៃលិន។ ថ្ងៃ ២៧-២៩ កុម្ភៈ : នៅ រំជៀង គណបក្ស «ហ្វុនស៊ិនប៉ិច» បើកមហាសន្និបាតរបស់ខ្លួន។ គឺនៅថ្ងៃ នោះហើយដែលចលនារាជានិយម «ហ្វុនស៊ិនប៉ិច» ប្រែក្លាយជា គណបក្សនយោបាយ ពេញលក្ខណៈ។ ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ បានត្រូវតែងតាំង ជាប្រធាន។ ថ្ងៃ ២៨ កុម្ភៈ : នៅទីក្រុងញូវយ៉ក ក្រុមប្រឹក្សាសន្តិសុខ អង្គការសហប្រជាជាតិ អនុម័ត ការអនុវត្តន៍ កិច្ចព្រមព្រៀង សន្តិភាព ទីក្រុងប៉ារីស៍។ ទឹកប្រាក់សម្រាប់ ធ្វើកិច្ចការនេះ មានចំនួន ២ ពាន់ ៨ រយលាន ដុល្លារ។ នៅពេលដដែលនោះ នៅប៉ៃលិន ខ្មែរក្រហម សម្រេចសាជាថ្មីម្តងទៀតមិនអនុវត្ត កិច្ចព្រមព្រៀងសន្តិភាព។ ថ្ងៃ ១០ មិនា : អ្នកកាសែតម្នាក់ នៃ «រណសិរ្សជាតិរំដោះពលរដ្ឋខ្មែរ» បានត្រូវគេប៉ុនប៉ងធ្វើឃាត។ ថ្ងៃ ១១ មិនា : ខ្មែរក្រហមធ្វើ ការវាយប្រហារមួយ ដ៏ខ្លាំងក្លានៅកំពង់ធំ ។ ថ្ងៃ ១៥ មិនា : ថ្ងៃចាប់ផ្តើម នៃអាណត្តិ របស់អង្គការ «អាប្រូនុច»។ ថ្ងៃ ៣០ មិនា : ជនភៀសសង្គ្រាមខ្មែរ ចំនួន ៥២៦ នាក់ នៅជំរំ ទី ២ បានត្រូវបញ្ជូនមកស៊ីសុផុន ។ ថ្ងៃ ៥-៦ មេសា : រដ្ឋសភា នៃ របបរដ្ឋកម្ពុជា បើកសម័យប្រជុំ ៖ វិសោធនកម្ម មាត្រា ៦១ នៃ រដ្ឋធម្មនុញ្ញ។ ថ្ងៃ ៨ មេសា : បាតុកម្ម សកិក នៅភូមិ បន្ទាយដែក ខាងកើត ទីក្រុងភ្នំពេញ បន្ទាប់ពី ក្រសួងកសិកម្ម បានលក់ដីរបស់ប្រជាជន ឲ្យ សហគ្រាសបរទេសមួយ។ ថ្ងៃ ១៨-២១ មេសា : លោក ប៊ូត្រូស-ប៊ូត្រូសហ្គាលី អគ្គលេខាធិការអង្គការ សហប្រជាជាតិ ញ្ជើញមកកម្ពុជា។ ថ្ងៃ ២០ មេសា : ក្រុមប្រឹក្សាជាតិជាន់ខ្ពស់បើកអង្គប្រជុំ ។ កុមប្រឹក្សាចុះហត្ថលេខា យល់ពមទទួលយក នុសញ្ញាអន្តរជាតិពីរ នៅក្នុងនោះ មានអនុសញ្ញាស្តីពី ការគោរពសិទ្ធិមនុស្ស នៅក្នុងឱកាសនោះដែរ លោក ខៀវ សំផន តំណាងភាគីខ្មែរក្រហម ប្រឆាំងនឹងការផ្តល់ប្រាក់ចំនួន១១១ លានដុល្លារ សម្រាប់ដំណើរការ រចនាសម្ព័ន្ធ រដ្ឋបាលកម្ពុជា។ ថ្ងៃ ១២ ឧសភា : ព្រះអង្គម្ចាស់ រណឫទ្ធិ អះអាងថា ទាហានវៀតណាម ដែលមានវត្តមាននៅស្រុកខ្មែរ មានចំនួន ៤ ម៉ឺន នាក់ ហើយប្រជាជនវៀតណាម ដែលចូលមកនៅស្រុកខ្មែរ មានចំនួន ១ លាន នាក់ ។ ថ្ងៃ ២១ ឧសភា : «រណសិរ្សជាតិរំដោះពលរដ្ឋខ្មែរ» បើកមហាសន្និ បាតនៅភ្នំពេញ ហើយ ប្រែក្លាយខ្លួនទៅជា គណបក្ស នយោបាយ ពេញលក្ខណៈ





មានឈ្មោះ ថា គណបក្ស «សេរីនិយម ប្រជាធិបតេយ្យ ពុទ្ធសាសនា» (P.D. L.B.) ។ ថ្ងៃ ៣០ ឧសភា : នៅក្នុងអងប្រជុំមួយ ជិតព្រំដែនថៃ ខ្មែរក្រហម សម្រេច មិនអនុវត្តកិច្ចព្រមព្រៀង សន្តិភាពរហូត។ អៀង សារី និង សុន សេន ដែលមិនយល់ស្របនឹងសេចក្តីសម្រេចនេះ បានត្រូវគេដកហូត ពីការកិច្ចរបស់ ខ្លួន។ ថ្ងៃ ១៨ មិថុនា : ការប្រយុទ្ធគ្នាយ៉ាងខ្លាំងក្លា រវាង កងទ័ព របបរដ្ឋកម្ពុជា និង កងទ័ពខ្មែរក្រហមដើម្បីដណ្តើមយក ផ្លូវជាតិ ១២ គឺ ផ្លូវជាតិ កំពង់ធំ- ព្រះវិហារ។ ថ្ងៃ ១៩ មិថុនា : កងទ័ពថៃ យល់ស្រប តាម ខ្មែរក្រហម ហើយ មិនព្រមចូលរួមចំណែក ក្នុងការដាក់ទណ្ឌកម្ម ទៅលើខ្មែរក្រហម។ ថ្ងៃ ២២- ២៣ មិថុនា : សន្និសីទ នៅទីក្រុងតូក្យូ ស្តីពី ការកសាង ប្រទេសកម្ពុជា ឡើងវិញ។ ថ្ងៃ ២៧ មិថុនា : គណបក្សប្រជាជន ថ្លែងថា គណបក្សរបស់គេ ជាការបន្តវេនពី គោលការណ៍ «សង្គមរាស្ត្រនិយម» របស់ សម្តេច នរោត្តម សីហនុ។ ថ្ងៃ ៣០ មិថុនា : លោក អ៊ឹង ផន នៃ គណបក្ស «ប្រជាជន» ចូលជាសមាជិក គណបក្ស «ហ្វុនស៊ិនប៉ិច»។ ថ្ងៃ ២១ កក្កដា : ខ្មែរក្រហមសម្លាប់ជានជាតិ វៀតណាម ៨ នាក់ ព្រមទាំងកូនខ្ចីម្នាក់ នៅភូមិទូកមាស។ ថ្ងៃ ៤ សីហា : អនុរដ្ឋមន្ត្រី ការបរទេសចិន ជួបខ្មែរក្រហម ដោយសម្ងាត់ ដើម្បីសុំឲ្យខ្មែរក្រហម បន្ទន់ឥរិយាបថ។ ថ្ងៃ ៥ សីហា : លោក អាកាស៊ី អ្នកតំណាងអគ្គលេខាធិការអង្គការ សហប្រជាជាតិ ប្រកាសឲ្យប្រើច្បាប់បោះឆ្នោត។ ថ្ងៃ ១៧ សីហា :គណបក្សនយោបាយចាប់ផ្តើមចុះឈ្មោះ ជាបណ្តោះអាសន្ន ដើម្បីឈរឈ្មោះក្នុងការបោះឆ្នោត ។ ថ្ងៃ ២១ សីហា : អង្គការ «អាប្រូនុច» ពិនិត្យមើលសញ្ជាតិ និងដើមកំណើតនៃ អ្នករដ្ឋការរបប «រដ្ឋកម្ពុជា» ។ ថ្ងៃ ២៨ សីហា : ជនជាតិខ្មែរ ប្រមាណ ១០ ម៉ឺននាក់ ត្រូវគេកញ្ជូនឲ្យវិលត្រឡប់មកស្រុកខ្មែរ វិញ។ ថ្ងៃ ៤ កញ្ញា : បណ្តារដ្ឋមន្ត្រីការបរទេស នៃ សមាគមប្រជាជាតិអាស៊ី អាគ្នេយ៍ ដែលបើកអង្គប្រជុំ នៅទីក្រុងយាកាតា ជំទាស់ នឹង ការបាត់តាំងការបោះឆ្នោត ដោយគ្មានការចូលរួមពីក្រុមខ្មែរក្រហម។ ថ្ងៃ ២៣ កញ្ញា : ប្រទេស ចិនគាំទ្រគំនិត ឲ្យមាន ការបោះឆ្នោតតែងតាំងប្រមុខរដ្ឋ ដោយផ្ទាល់តែម្តង។ ថ្ងៃ ២ វិច្ឆិកា : សម្តេច នរោត្តម សីហនុ ធ្វើដំណើរទៅ ទីក្រុងព្យុងយ៉ាង ប្រទេស កូរ៉េខាងជើង ។ ថ្ងៃ ១៥ វិច្ឆិកា : អគ្គលេខាធិការ អង្គការ សហប្រជាជាតិ ប្រកាស ខណ្ឌបញ្ចប់ រាល់ សកម្មភាពយោធា

នៅលើទឹកដីខ្មែរ។ ថ្ងៃ ២៩ វិច្ឆិកា : ជនជាតិខ្មែរ ដែលបាន រត់ទៅជ្រកកោន នៅ បរទេស ចំនួន ២០ ម៉ឺននាក់ បានត្រូវបញ្ជូនមកស្រុកខ្មែរវិញ ។ ថ្ងៃ ៣០ វិច្ឆិកា : ខ្មែរក្រហម បង្កើត គណបក្ស «រួបរួមជាតិកម្ពុជា» (PUNC) ។ ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហប្រជាជាតិ ហាមឃាត់ មិនឲ្យ ដឹកប្រេងឥន្ធនៈ ទៅឲ្យខ្មែរក្រហម នៅក្នុង តំបន់ ដែលពួកនេះកាន់កាប់។ ការនាំចេញព្រៃឈើ និងត្បូងត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ របស់អង្គការ «អាប្រូនុប»។

## ១៩៩៣

ថ្ងៃ ៤ មករា : សម្តេច នរោត្តម សីហនុ ខណ្ឌបញ្ចប់សហប្រតិបត្តិការ រវាង «ក្រុម ប្រឹក្សាជាតិជាន់ខ្ពស់» និងអង្គការ «អាប្រូនុប» ព្រមទាំងរបប«រដ្ឋកម្ពុជា» ផងដែរ ដោយមូលហេតុ សមាជិក គណបក្ស «ហ៊្វុនស៊ិនប៉ិច» ចំនួន ១៤ នាក់ បានត្រូវគេលបធ្វើឃាត។ ថ្ងៃ ៨ មករា : សម្តេច នរោត្តម សីហនុ សម្រេចធ្វើសហប្រតិបត្តិការ ជាមួយ អង្គការ «អាប្រូនុប» បន្តទៀត បន្ទាប់ពី លោក អាកាស៊ី ទៅគាល់ព្រះអង្គ នៅទីក្រុងប៉េកាំង ។ ថ្ងៃ ១៨ មករា : ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ដឹកនាំក្បួនបាតុកម្ម របស់ គ្រួសារដែលទទួលរងគ្រោះ ដោយអំពើហឹង្សា នយោបាយ។ ព្រះអង្គម្ចាស់ រណឫទ្ធិទ្រង់ចោទ លោក ហ៊ុន សែន លោក ជា ស៊ីម និង អភិបាល ខេត្តបាត់ដំបង ថាជាអ្នកទទួលខុសត្រូវ។ ថ្ងៃ ១ កុម្ភៈ : កងទ័ព «រដ្ឋកម្ពុជា» វាយយក ប៉ៃលិន ប៉ុន្តែ បានត្រូវលោក ហ៊ុន សែន ឃាត់វិញជាបន្ទាន់ ដោយមាន ការព្រមាន ពី អង្គការ «អាប្រូនុប» ។ ថ្ងៃ ១១-១២ កុម្ភៈ: ទស្សនកិច្ចរបស់ លោកហ្វ្រង់ស្វ័រ មីត្តេរ៉ង់ ប្រធានាធិបតីបារាំង នៅកម្ពុជា។ ថ្ងៃ ១០ មិនា : ជនជាតិ វៀតណាម ៣៥ នាក់ នៅភូមិ ចុងឃ្នាស បានត្រូវ ខ្មែរក្រហម វាយប្រហារ ។ ថ្ងៃ ១៧ មិនា : ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ប្រកាស ហាមឃាត់ មិនឲ្យ ប្រើប្រាស់អាវុធ ដោយគ្មាន ការអនុញ្ញាត។ វិសោធនកម្ម ក្រមព្រហ្មទណ្ឌខ្មែរ។ ថ្ងៃ ២៤ មិនា : ខ្មែរក្រហម វាយប្រហារ ទៅលើ កប៉ាល់ នេសាទ បីគ្រឿងនៅ ធ្នូកទ្រូ (ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង) ។ ថ្ងៃ ២៨ មិនា : ទាហានអង្គការ សហប្រជាជាតិ ២ នាក់ បានត្រូវខ្មែរក្រហមសម្លាប់។ ថ្ងៃ ២៩





មិនា : ខ្មែរក្រហម គប់គ្រាប់បែកទៅលើភោជនីយដ្ឋាន វៀតណាមមួយ នៅទីក្រុងភ្នំពេញ បណ្តាលឲ្យមនុស្ស ២ នាក់ បាត់បង់ជីវិត ហើយ ២៤ នាក់ត្រូវរបួស ។ ខ្មែរក្រហម គប់គ្រាប់បែកទៅលើ រោងវីដេអូ មួយ នៅកំពង់ធំ បណ្តាលឲ្យមនុស្ស ៣០ នាក់ត្រូវរបួស ។ នៅ ថ្ងៃដដែលនោះ ខ្មែរក្រហម វាយប្រហារ ទៅលើទីស្នាក់ការ គណបក្ស «ហ៊្វុនស៊ិនប៉ិច» នៅបាត់ដំបង ជាហេតុបណ្តាលឲ្យសមាជិកគណបក្ស «ហ៊្វុនស៊ិនប៉ិច» ៣ នាក់ បាត់បង់ជីវិត។ នៅ អង្គរវត្ត ឯនោះវិញ សមាជិក អង្គការ «អាប្រូនុប» ៥ នាក់ បានត្រូវខ្មែរក្រហមសម្លាប់។ ថ្ងៃ ២ មេសា : ទាហាន អង្គការ សហប្រជាជាតិ ៣ នាក់ បានត្រូវខ្មែរក្រហម ចាប់យកទៅ សម្លាប់ចោល យ៉ាងឃោឃៅ។ ថ្ងៃ ៣ ឧសភា : ខ្មែរក្រហម វាយលុកទីក្រុងសៀមរាប បណ្តាលឲ្យ ទាហាន ៨ នាក់ និង ប្រជាជន ស៊ីវិល ៤ នាក់ បាត់បង់ជីវិត។ ថ្ងៃ ៤ ឧសភា : ខ្មែរក្រហម វាយប្រហារទៅលើ អង្គភាព យោធា ចិន នៃ កម្លាំងអន្តរាគមន៍ អាប្រូនុប នៅកំពង់ធំ។ ថ្ងៃ ៥ ឧសភា : ខ្មែរក្រហម វាយប្រហារ រថភ្លើងដែល ឆ្លងកាត់ ស្រុកមោងឫស្សី។ អ្នកដំណើរ ១៩ នាក់ បាត់បង់ជីវិត ហើយ ៨០ នាក់ត្រូវរបួស។ ថ្ងៃ ២៣-២៨ ឧសភា : ការបោះឆ្នោតជ្រើសតាំង សមាជិកសភា ធម្មនុញ្ញ។ ទោះបីមានការគំរាមកំហែង ពីសំណាក់ខ្មែរក្រហមក្តី ក៏អ្នកដែលបានទៅចូលរួមបោះឆ្នោត មានចំនួនច្រើនដែរ គឺ ៨៩, ៥៦ %។ លទ្ធផល នៃ ការបោះឆ្នោត គឺ គណបក្សរាជានិយម «ហ៊្វុនស៊ិនប៉ិច» ជាអ្នកឈ្នះគណបក្ស ប្រជាជន គឺបាន ៤៥ % នៃ សំឡេង រីឯគណបក្ស «ប្រជាជន» បានត្រឹម ៣៨ % ប៉ុណ្ណោះ ។ គណបក្ស «ប្រជាជន» ប្រកាសពុំទទួលស្គាល់ លទ្ធផល នៃការបោះឆ្នោតនោះ ជាដាច់ខាត។ ថ្ងៃ ២៦ ឧសភា : សម្តេច នរោត្តម សីហនុ បានថ្លែងថា ៖ព្រះអង្គឈប់ ស្នើឲ្យ បង្កើត រដ្ឋាភិបាល ចម្រុះ ចតុភាគី ទៀតហើយ។ ថ្ងៃ ៣ មិថុនា : សម្តេច នរោត្តម សីហនុ ទ្រង់ បានស្នើឲ្យបង្កើតរដ្ឋាភិបាល ចម្រុះរវាង គណបក្ស «ហ៊្វុនស៊ិនប៉ិច» នឹង គណបក្ស «ប្រជាជន» ដោយ មាន ព្រះអង្គ ជា នាយករដ្ឋមន្ត្រី។ នាយក អង្គការ «អាប្រូនុប» ចាត់ទុកគំនិតនេះថា ជាការប៉ះពាល់ ដ៏ធ្ងន់ធ្ងរ ដល់រដ្ឋធម្មនុញ្ញ។ សហរដ្ឋ អាមេរិក ប្រឆាំង នឹង ការបង្កើត រដ្ឋាភិបាល បណ្តោះអាសន្ន បែបនេះ ។ ថ្ងៃ ៤ មិថុនា : ប្រទេសបារាំង គាំទ្រ ការបង្កើតរដ្ឋាភិបាលបណ្តោះអាសន្ននេះ ។ ថ្ងៃ ៩ មិថុនា :

អ្នកទទួលខុសត្រូវសំខាន់ៗ និង អ្នកតំណាងកងទ័ព នៃ របប «រដ្ឋកម្ពុជា» បាននាំគ្នាចូលទៅ ព្រះរាជវាំង ដើម្បីសុំជែងការគាំទ្រ គំនិតបង្កើត រដ្ឋកិបាលបម្រុះ ដែលមាន សម្ដេច នរោត្តម សីហនុ ជាអ្នកផ្ដួចផ្ដើមគំនិត។ ថ្ងៃ ១០ មិថុនា : ក្រុមប្រឹក្សាជាតិជាន់ ខ្ពស់បើក អង្គប្រជុំ។ លោក អាកាស៊ី ថ្លែងថា ៖ ការបោះឆ្នោត បានប្រព្រឹត្តទៅ ដោយសេរី និង ប្រកប ដោយសមភាព ។ ប៉ុន្តែអ្នកតំណាង គណបក្ស «ប្រជាជន» នៅតែ មិនព្រមទទួល ស្គាល់លទ្ធផល នៃ ការបោះឆ្នោតដដែល។ ព្រះអង្គម្ចាស់ចក្រពង្ស និង លោក សិន សុង ខាងគណបក្ស «ប្រជាជន» ឲ្យតម្រុយថា ពួកគេ នឹងធ្វើអបគមន៍ បែងចែកទឹកដីខ្មែរជាពីរ។ ទោះជាយ៉ាងណា ក្ដី ក៏អង្គការ «អាប្រូនុច» ប្រកាស លទ្ធផល នៃ ការបោះឆ្នោតនោះ ជាផ្លូវការដែរ ។ ថ្ងៃ ១១ មិថុនា : ខ្មែរក្រហម ប្រកាសទទួលស្គាល់ លទ្ធផល នៃ ការបោះឆ្នោត។ ថ្ងៃ ១៣ មិថុនា : សមាជិកគណបក្ស «ហ្វុនស៊ីនប៉េច» និង គណបក្ស «ប្រជាធិបតេយ្យ សេរីនិយម ពុទ្ធសាសនា» ដែលបំពេញ បេសកកម្ម នៅផ្នែក ខាងកើត ទន្លេមេគុង នាំគ្នា រត់ចេញ ពីតំបន់នោះ ព្រោះអាជ្ញាធរនៅទីនោះ សម្លាប់ ពួកគណបក្សដែលឈ្នះឆ្នោត ដោយឥតកោតក្រែង។ ថ្ងៃ ១៤ មិថុនា : សភាធម្មនុញ្ញ បើកអង្គប្រជុំ។ ជាកិច្ចចាប់ផ្ដើម គេចេញសេចក្ដីសម្រេចចិត្ត មួយ ចាត់ទុក ជាមោឃៈ ការបោះឆ្នោត ទម្លាក់ សម្ដេច នរោត្តម សីហនុ ពីអំណាច ដោយសភាទាំងពីរ កាលពីថ្ងៃ ១៨ មិនាឆ្នាំ ១៩៧០ ដើម្បីចាត់តាំង សម្ដេច នរោត្តម សីហនុ ជា ប្រមុខរដ្ឋ សាជាថ្មី ។ អង្គការ «អាប្រូនុច» ចាត់ទុកថា សេចក្ដីសម្រេចចិត្តនោះ គ្មានមូលដ្ឋាន គតិយុត្តអ្វីឡើយ ។ ថ្ងៃ ១៥ មិថុនា : ក្រុមប្រឹក្សា សន្តិសុខ អង្គការ សហប្រជាជាតិ បញ្ជាក់ទទួលស្គាល់ លទ្ធផល នៃ ការបោះឆ្នោត ។ ថ្ងៃ ១៦ មិថុនា : សម្ដេច នរោត្តម សីហនុ តែងតាំង ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ ប្រធានគណបក្ស «ហ្វុនស៊ីនប៉េច» និង លោក ហ៊ុន សែន នៃ គណបក្ស «ប្រជាជន» ជាសហនាយករដ្ឋមន្ត្រី នៃ រដ្ឋាភិបាលបណ្ដោះអាសន្ន នៃ ប្រទេសកម្ពុជា ទាំងពីរនាក់តែម្ដង។ ថ្ងៃ ១៧ មិថុនា : អភិក្រម អបគមន៍ ឈានមកដល់ទីបញ្ចប់។ ថ្ងៃ ២០ មិថុនា : គណបក្ស «ប្រជាជន» ប្រកាសទទួលស្គាល់ លទ្ធផល នៃ ការបោះឆ្នោត ។ ថ្ងៃ ១ កក្កដា : សភាធម្មនុញ្ញ សម្រេចយកច្បាប់ចាស់ មកប្រើសិន ទម្រាំមាន នីតិកម្ម ថ្មី ។ គណប្រតិកូ ខ្មែរក្រហមមួយ





ដឹកនាំដោយ លោក ចាន់យ៉ូរ៉ាន់ មកដល់ទីក្រុងភ្នំពេញ ហើយ បានត្រូវទទួលឲ្យជួបសន្ទនា ជាមួយ សម្ដេច នរោត្តម សីហនុ ។ ថ្ងៃ ២ កក្កដា : លោក អាកាស៊ី ទទួលអ្នកតំណាង ពួកខ្មែរក្រហម។ ថ្ងៃ ៥-៦ កក្កដា : ទស្សនកិច្ច នៅកម្ពុជា របស់ លោកស្រី ម៉ាដឺឡែន អ៊ុលប្រាយ ឯកអគ្គរដ្ឋទូត សហរដ្ឋ អាមេរិក ប្រចាំអង្គការ សហប្រជាជាតិ។ សហរដ្ឋ អាមេរិក ប្រឆាំងដាច់ខាត មិនឲ្យមានខ្មែរក្រហម នៅក្នុងរដ្ឋាភិបាលខ្មែរថ្មី ។ ថ្ងៃ ៧ កក្កដា : ខ្មែរក្រហម វាយយកព្រះវិហារ ដោយមានជំនួយ ពី កងទ័ពថៃ។ ថ្ងៃ ៨- ១២ កក្កដា : ខ្មែរក្រហម ធ្វើការវាយប្រហារ ភូមិមួយចំនួន ក្នុងខេត្តកំពង់ ឆ្នាំង។ ថ្ងៃ ១៣ កក្កដា : ខៀវ សំផន ដឹកនា គណប្រតិភូខ្មែរក្រហមមួយមក ទីក្រុងភ្នំពេញ។ សម្ដេច នរោត្តម សីហនុ ឆ្លៀតឱកាសនោះ ទាមទារឲ្យ ខ្មែរក្រហម ប្រគល់ ព្រះវិហារ មកឲ្យរដ្ឋាភិបាលខ្មែរវិញ។ ថ្ងៃ ៨ សីហា : កងទ័ព រដ្ឋាភិបាល វាយយក មូលដ្ឋានដែលខ្មែរក្រហមកាន់កាប់ (កំពង់ធំ ព្រះវិហារ សៀមរាប បន្ទាយមានជ័យ) ។ ថ្ងៃ ២៧ សីហា : ក្រុមប្រឹក្សាសន្តិសុខ អង្គការ សហប្រជាជាតិ បន្តអាណត្តិ អង្គការអាប្រូនុច រហូតដល់ពេល អនុម័តរដ្ឋធម្មនុញ្ញ ហើយ ត្រូវចេញ ពីប្រទេសកម្ពុជា នៅថ្ងៃ ១៥ វិច្ឆិកា។ ថ្ងៃ ១៦-២១ កញ្ញា : សភាធម្មនុញ្ញ ពិភាក្សា និងអនុម័ត រដ្ឋធម្មនុញ្ញ បន្ទាប់មក ប្រែក្លាយខ្លួនជារដ្ឋសភា គឺ អង្គការ នីតិប្បញ្ញត្តិ ពេញលក្ខណៈ។ ថ្ងៃ ២៤ កញ្ញា : រដ្ឋធម្មនុញ្ញ ត្រូវប្រកាសឲ្យប្រើ។ ថ្ងៃ ៥ តុលា : អ្នកធ្វើវិយោគថៃ ចាប់ផ្ដើម ធ្វើយុទ្ធនាការ វាយប្រហារទៅលើ លោក សម រង្ស៊ី រដ្ឋមន្ត្រី សេដ្ឋកិច្ចខ្មែរ បន្ទាប់ពីលោក មានផែនការរៀបចំ រំដោះសេដ្ឋកិច្ចប្រទេសកម្ពុជា ពីភាពអានាធិបតេយ្យ។ ថ្ងៃ ៧ តុលា : បាតុកម្មនិស្សិត ប្រឆាំង នឹង ការប្រើភាសាបារាំង នៅឧត្តមសិក្សា ផ្នែកបច្ចេកទេស។ ថ្ងៃ ១៤ តុលា :ខ្មែរក្រហមដាក់គ្រាប់បែក កំទេចស្ពាន ចំនួន ៤ នៅផ្លូវជាតិលេខ ៥។ ថ្ងៃ ៣០ តុលា : ព្រះសង្ឃ ៤ អង្គត្រូវខ្មែរក្រហមសម្លាប់។ ថ្ងៃ ១៥ វិច្ឆិកា : អង្គការ «អាប្រូនុច» ដកកម្លាំងអន្តរាគមន៍ ចេញពីប្រទេសកម្ពុជា។ ថ្ងៃ ២១ វិច្ឆិកា : ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ ស្នើសុំឲ្យបញ្ចូលខ្មែរក្រហម មកក្នុងរដ្ឋាភិបាល។ ថ្ងៃ ២៤ វិច្ឆិកា :ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ សហនាយករដ្ឋមន្ត្រី កត់សំគាល់ថា ការបញ្ចូលខ្មែរក្រហម មកក្នុងរដ្ឋាភិបាល ជាការផ្ទុយ នឹង រដ្ឋធម្មនុញ្ញ ។ ថ្ងៃ ២៨

វិច្ឆិកា :សហនាយករដ្ឋមន្ត្រីទាំងពីរ ទទួលយក អំណោយយន្តហោះមួយគ្រឿង ពីឈ្មួញថៃ ដែលទាស់ទែង នឹងលោក សម រង្ស៊ី រដ្ឋមន្ត្រី សេដ្ឋកិច្ចខ្មែរ ។ ថ្ងៃ ១៧ ធ្នូ : ព្រះអង្គម្ចាស់ រណឫទ្ធិ ជួបលោក ខៀវ សំផន នៅទីក្រុងបាងកក ហើយទាមទារ ឲ្យមានការឈប់បាញ់គ្នាសិន ទើបធ្វើការចរចា ។

## ១៩៩៤

ថ្ងៃ ១២-១៥ មករា : ទស្សនកិច្ចជាផ្លូវការ របស់លោកនាយករដ្ឋមន្ត្រី ថៃ ជួន ឡីកប៉ៃ។ ថ្ងៃ ១៨ មករា : និស្សិត នីតិសាស្ត្រ និងសេដ្ឋកិច្ច នៃ សកលវិទ្យាល័យភ្នំពេញ ចំនួន ៤០០ នាក់ ធ្វើបាតុកម្ម ប្រឆាំងនឹង អំពើ ពុករលួយ របស់ សាស្ត្រាចារ្យ និងរដ្ឋបាល។ ថ្ងៃ ២០ មករា : និស្សិត និងអ្នកជំនួញខ្មែរ រាប់ពាន់នាក់ធ្វើបាតុកម្មគាំទ្រ លោកសមរង្ស៊ី ដែលទាស់ទែងនឹងឈ្មួញថៃៗ ដែលមានការគាំទ្រ ពី ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ សហនាយក រដ្ឋមន្ត្រី ។ ថ្ងៃ ៥ កុម្ភៈ : កងទ័ពរដ្ឋាភិបាល វាយយក អន្លង់វែង មូលដ្ឋានកស្ដុភារខ្មែរក្រហម ដែលមាន តាម៉ុក មេទ័ពខ្មែរក្រហម ជាអ្នកកាន់កាប់ ។ តាម៉ុក ដកថយ ហើយទៅតាំងទីនៅ ត្រពាំងគល់ ដែលស្ថិតនៅជិតព្រំប្រទល់ថៃ និង លាវ ។ ថ្ងៃ ២៤ កុម្ភៈ :ខ្មែរក្រហម វាយយក អន្លង់វែង បានមកវិញ។ ថ្ងៃ ១៧ មិនា : ព្រះអង្គម្ចាស់រណឫទ្ធិ ធ្វើទស្សនកិច្ច នៅប្រទេសបារាំង រីឯលោកហ៊ុន សែន ធ្វើទស្សនកិច្ច នៅទីក្រុងប៉េកាំង។ ថ្ងៃ ២៣ មិនា : ង៉ួន នន់ អ្នកនិពន្ធនាយក កាសែត ដំណឹងពេលព្រឹក បានត្រូវចាប់ខ្លួន ដោយហេតុ លោកធ្វើអង្កេត អំពី អំពើពុករលួយ។ ថ្ងៃ ២៤ មិនា : ទីស្នាក់ការ កាសែត អន្ទរាគមន៍ ត្រូវរងគ្រោះ ដោយ ការគប់គ្រាប់បែក។ មនុស្ស ៥ នាក់ ត្រូវរបួស។ ថ្ងៃ ១១ មេសា :ស្ត្រីអូស្ត្រាលីម្នាក់ និងជនជាតិអង់គ្លេសពីនាក់ត្រូវខ្មែរក្រហមចាប់យក ទៅសម្លាប់ចោល។ ថ្ងៃ ១៩ មេសា : ខ្មែរក្រហមប្រមាណ ៣ ពាន់នាក់ បានវាយយក ប៉ៃលិន បានវិញ។ ថ្ងៃ ២៩ មេសា : គេបានដំណឹងថា ឧត្ដមសេនីយ៍ សាក ស៊ុត សាខន អតីតអគ្គសេនាធិការដ្ឋានកងទ័ព ជំនាន់ឧត្ដមសេនីយ៍ លន់ នល់ ហើយ ដែលបានត្រូវតែងតាំង ជា





ទីប្រឹក្សារាជរដ្ឋាភិបាល បានបាត់បង់ជីវិត នៅក្នុងប្រតិបត្តិការសឹក។ ថ្ងៃ ១៧ ឧសភា : ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ អំពាវនាវ ឲ្យមាន ការរួមប្រជុំមួយ រវាង គូភាគីខ្មែរទាំងអស់។ ថ្ងៃ ២៧-២៨ ឧសភា : អង្គប្រជុំ តុមូល រវាង គូភាគីខ្មែរ នៅទីក្រុងព្យ៉ុងយ៉ាងក្រោមអធិបតី នៃព្រះមហាក្សត្រខ្មែរ។ អង្គប្រជុំ បានទទួលបរាជ័យ ទាំងស្រុង ។ ថ្ងៃ ១៥-១៦ មិថុនា : អង្គប្រជុំ តុមូល ម្ដងទៀត ប៉ុន្តែក្នុងកម្រិតបច្ចេកទេស។ បរាជ័យសាជាថ្មីទៀត។ ថ្ងៃ ១០ កក្កដា : ខ្មែរក្រហមប្រកាស បង្កើត រដ្ឋាភិបាល បណ្ដោះអាសន្នមួយដែលមាន ខៀវ សំផន ជារដ្ឋមន្ត្រី ទី១។ ថ្ងៃ ១៤ កក្កដា: រដ្ឋសភា ធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ ដើម្បីផ្ដល់សិទ្ធិ ទៅឲ្យប្រមុខរដ្ឋស្ដីទី ចុះហត្ថលេខា ទៅលើ នីតិក្រម នានា នៅពេលអវត្តមានព្រះមហាក្សត្រ។ ថ្ងៃ ២៦ កក្កដា : សហនាយករដ្ឋមន្ត្រី ទាំងពីរ ប្រកាសជាផ្លូវការ សុំជំនួយយោធាពី សហរដ្ឋ អាមេរិក ។ នៅពេលដដែលនោះ ខ្មែរក្រហម វាយប្រហារ ទៅលើរថភ្លើងមួយ ត្រង់ ស្រុកកំពង់ត្រាច បណ្ដាលឲ្យ អ្នកដំណើរ ១០ នាក់បាត់បង់ជីវិត ។ ជនជាតិខ្មែរ ១១ នាក់ ជនជាតិវៀតណាម ៣ នាក់ ជនជាតិ អូស្ត្រាលីម្នាក់ ជនជាតិអង់គ្លេសម្នាក់ និង ជនជាតិបារាំងម្នាក់ បានត្រូវខ្មែរក្រហមចាប់ខ្លួន។ ថ្ងៃ ៣១ កក្កដា : ទឹកជំនន់នៅ កំពង់ស្ពឺ និងនៅខេត្តកណ្ដាល។ មនុស្ស ៤ ម៉ឺននាក់គ្មានជម្រក ។ ដំណាំ ជិត ១០ ម៉ឺន ហិកតា ត្រូវខូចខាត ។ ថ្ងៃ ២៦ សីហា : រដ្ឋសភា បាន អនុម័តច្បាប់មួយ ស្ដីពី ជនអន្តោប្រវេសន៍។ ច្បាប់នោះ បានធ្វើឲ្យទីក្រុងហាណូយ ព្រួយបារម្ភយ៉ាងខ្លាំង (៩៧ សំឡេងទល់នឹង១) អគ្គលេខាធិការ អង្គការ សហប្រជាជាតិ ស្នើសុំឲ្យព្រះមហាក្សត្រខ្មែរ ពិនិត្យច្បាប់នោះឡើងវិញ។ ថ្ងៃ ៧ កញ្ញា : នួន ជន អ្នកនិពន្ធ នាយកកាសែត សំឡេងយុវជន បានត្រូវគេធ្វើឃាត ។ ថ្ងៃ ១៩ កញ្ញា : បេសកកម្ម យោធាសហរដ្ឋ អាមេរិក មួយ មកធ្វើទស្សនកិច្ច ៥ ថ្ងៃ នៅកម្ពុជា។ ថ្ងៃ ២១ កញ្ញា : អគ្គលេខាធិការ អង្គការ សហប្រជាជាតិ ស្នើសុំឲ្យច្បាប់ ស្ដីពី ជនអន្តោប្រវេសន៍ សម្របទៅតាមគោល ការណ៍ច្បាប់អន្តរជាតិ។ ខ្មែរក្រហមចោទថា អង្គការ សហប្រជាជាតិ ចង់ឲ្យជនជាតិវៀតណាមចំនួន ៤ លាន នាក់ ដែលកំពុងរស់នៅក្នុងស្រុកខ្មែរ ស្ថិតនៅក្នុងស្រុកខ្មែរបន្តទៀតតាមផ្លូវច្បាប់។ ថ្ងៃ ២២ កញ្ញា : ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ បានប្រកាស

ឲ្យប្រើច្បាប់ស្ដីពី ជនអន្តោប្រវេសន៍ ដែលបាន ត្រូវអនុម័តដោយរដ្ឋសភា។ ថ្ងៃ ១៥ តុលា : វរសេនីយឯកខ្មែរក្រហម ឈ្មោះ ឈូក រីន បានកៀសខ្លួន ចេញពីជួរកងទ័ព រាជរដ្ឋាភិបាល។ ឈូក រីន ជាអ្នកទទួលខុសត្រូវ នៃការវាយប្រហារ ទៅលើរថភ្លើង កាលពីថ្ងៃ ២៦ កក្កដា ហើយ ដែលបណ្ដាលឲ្យមនុស្ស ១៣ នាក់ បាត់បង់ជីវិត និងជាអ្នកដែលទទួលខុសត្រូវ នៃ ការចាប់ជនជាតិខ្មែរ ១១ នាក់ ជនជាតិអូស្ត្រាលីម្នាក់ ជនជាតិអង់គ្លេសម្នាក់ និង ជនជាតិបារាំងម្នាក់។ ថ្ងៃ ២០ តុលា : លោក សម រង្ស៊ី រដ្ឋមន្ត្រីសេដ្ឋកិច្ច បានត្រូវដកហូតពី មុខតំណែង បន្ទាប់ពីមានទំនាស់ ជាមួយ ព្រះអង្គម្ចាស់ រណឫទ្ធិ និង ឈ្មួញថៃម្នាក់។ ថ្ងៃ ២៨ តុលា : ព្រះអង្គម្ចាស់ ចក្រពង្ស លោក ស៊ិន សុង និង លោក ស៊ិន សេង អ្នកដែលបានប៉ុនប៉ង ធ្វើអបគមន៍ បានត្រូវកាត់ទោស ដោយកំបាំងមុខ ឲ្យជាប់ពន្ធនាគារ ២០ ឆ្នាំម្នាក់ ។ ថ្ងៃ ៨ ធ្នូ : អ្នកកាសែតម្នាក់ ឈ្មោះ ចាន់ ដារា បានត្រូវគេធ្វើឃាត ។ ថ្ងៃ ២៧ ធ្នូ : លោក សឺន សាន អ្នកដឹកនាំគណបក្ស «ប្រជាធិបតេយ្យ សេរីនិយម ពុទ្ធសាសនា» អំពាវនាវសុំឲ្យប្រគល់អំណាចចាំបាច់ ទៅថ្វាយព្រះមហាក្សត្រ ដើម្បីព្រះអង្គអាចធ្វើការផ្សះផ្សាជាតិ។ ថ្ងៃ ២៩ ធ្នូ : ខ្មែរក្រហម ៤០០ នាក់ បានសុំចុះចូល រាជរដ្ឋាភិបាល។ ប៉ុន្តែគណបក្ស ប្រជាជន ជាពិសេស លោក ហ៊ុន សែន ប្រឆាំងដាច់ខាត នឹងការវិល មកកាន់អំណាចវិញ របស់ ព្រះមហាក្សត្រ ដោយសំអាងទៅលើរដ្ឋធម្មនុញ្ញ ដែលចែងថា «ព្រះមហាក្សត្រសោយរាជ្យ ប៉ុន្តែ មិនកាន់អំណាចទេ» ។

## ឆ្នាំ ១៩៩៥

ថ្ងៃ ២៣ មករា : ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ ប្រកូកហៅ ឲ្យខ្មែរក្រហម ចូលមករួបរួមក្នុងជីវិត នយោបាយថ្មី ។ ថ្ងៃ ២៤ មករា : ខ្មែរក្រហមវាយយក ថ្ម គោល។ នៅឆ្នាំ ១៩៩៥ នោះ ខ្មែរក្រហម វាយប្រហារជាច្រើនកន្លែង ក្នុងទូទាំងប្រទេសកម្ពុជា ជាហេតុពិបាកលើកឡើងឲ្យបានគ្រប់ជ្រុងជ្រោយ។ ប៉ុន្តែ ការវាយប្រហារ សំខាន់ៗ មានជាអាទិ៍ នៅ បាត់ដំបង បាវិល បាណាម រតនមណ្ឌល មោងឫស្សី ។ ថ្ងៃ ៣០ មករា : ពាមឯក។





ថ្ងៃ ៧ កុម្ភៈ: កំពង់ ព្រៀង អូសទូក។ ថ្ងៃ ១៣ កុម្ភៈ សំបុក ឪក។ល។ ខែធ្នូ :លោក សរ គឹម លុត អ្នកកាន់ហិរញ្ញវត្ថុខ្មែរក្រហម បានចុះចូលរាជរដ្ឋាភិបាល នៅទីក្រុងភ្នំពេញ ។

## ឆ្នាំ ១៩៩៦

ថ្ងៃ ៨ សីហា : អៀង សារី ផ្ដាច់ខ្លួនចេញពី ប៉ុល ពត ដោយនាំកងទ័ពខ្មែរ ក្រហម ប្រមាណ ៣០០០នាក់ ទៅជាមួយផង។ ថ្ងៃ ១៤ កញ្ញា : គេបានដឹងថា ព្រះមហាក្សត្រ បានឡាយព្រះហស្ថលេខា ទៅលើក្រឹត្យមួយ លើកលែងទោសឲ្យ អៀង សារី ។ ថ្ងៃ ១ តុលា: កងទ័ពរបស់ អ៊ី ឈាង ដែលជាសម្ព័ន្ធមិត្ត របស់ អៀង សារី បាន វាយយក មូលដ្ឋាន របស់ ប៉ុល ពត នៅ សម្លូត ។ ថ្ងៃ ១១ តុលា: ព្រះអង្គម្ចាស់រណឫទ្ធិ សហនាយករដ្ឋមន្ត្រីទី ១ យាងដោយសម្ងាត់ទៅ ទីក្រុងប៉ៃលិន បន្ទាប់ពី បានយាងទៅ ស៊ីសុផុន នៅថ្ងៃ ២ សីហា ឆ្នាំដដែល ។ ថ្ងៃ ២២ តុលា : លោក ហ៊ុន សែន នាយករដ្ឋមន្ត្រីទី ២ ទៅជួប អៀង សារី នៅ ប៉ៃលិន ។

## ឆ្នាំ ១៩៩៧

ថ្ងៃ ៣០ មិនា : គ្រាប់បែកមួយ បានត្រូវមនុស្សមិនស្គាល់មុខ គប់ ទៅលើអ្នកធ្វើបាតុកម្ម បណ្ដាលឲ្យមនុស្ស ១៦ នាក់ បាត់បង់ជីវិត។ ថ្ងៃ ១០ មិថុនា : មេ បញ្ជាការកងទ័ព របស់ ប៉ុល ពត គឺ សុន សេន បានត្រូវ ប៉ុល ពត សម្លាប់ ចោលទាំងគ្រួសារ (១១ នាក់) ។ ថ្ងៃ ១៧ មិថុនា : វិទ្យុខ្មែរក្រហមចោ្ទលទោស ប៉ុល ពត ថា បានក្បត់ ចលនា ខ្មែរក្រហម។ ថ្ងៃ ២០ មិថុនា : តាម៉ុក ចាប់ ប៉ុល ពត បាន។ នៅថ្ងៃដដែលនោះ លេខាផ្ទាល់ របស់ ប៉ុល ពត សុំចុះចូល រាជរដ្ឋាភិបាល។ ថ្ងៃ ២៨ មិថុនា : ខៀវ សំផន ធ្វើសន្និសីទកាសែតមួយ នៅព្រះវិហារ ដើម្បីក្រាសថា ចលនា ខ្មែរក្រហម បានឈាន មកដល់ ទីអវសាន ហើយ ។

ខៀវ សំផន ប្រកាសផ្តាច់ខ្លួនចេញពី ប៉ុល ពត ហើយគាំទ្ររាជរដ្ឋាភិបាល និង រដ្ឋធម្មនុញ្ញដោយឥតលក្ខខណ្ឌ។ លោក ហ៊ុន សែន ជំទាស់នឹង សន្និសីទកាសែតនោះ ហើយតម្រូវឲ្យខៀវសំផន ចុះចូលដោយឥតលក្ខខណ្ឌ។ ថ្ងៃ ៥ កក្កដា : កងទ័ពស្មោះត្រង់ នឹង ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ និង កងទ័ពស្មោះត្រង់នឹងលោក ហ៊ុន សែន ប្រយុទ្ធគ្នានៅចំកណ្តាលទីក្រុងភ្នំពេញ និង នៅអូរស្មាច់ ។ ថ្ងៃ ១៦ កក្កដា : លោក អ៊ឹង ហួត ប្រកាសដាក់បេក្ខភាព ធ្វើសហនាយករដ្ឋមន្ត្រីទី១ ជំនួស ព្រះអង្គម្ចាស់ រណឫទ្ធិដែលរត់ទៅបរទេស ។ ថ្ងៃ ២៥ កក្កដា : ប៉ុល ពត បានត្រូវក្រុម របស់ខ្លួនផ្ទាល់ និង តាម៉ុក យកទៅកាត់ទោស។ ថ្ងៃ ២៧ កក្កដា : ព្រះអង្គម្ចាស់ រណឫទ្ធិ ដែលភៀសខ្លួនទៅបរទេស ប្រកាសដេញលោក អ៊ឹង ហួត ចេញពីគណបក្ស «ហ៊្វុនស៊ិនប៉ិច»។ ថ្ងៃ ៦ សីហា : រដ្ឋសភាដកអភ័យឯកសិទ្ធិ ពីព្រះអង្គម្ចាស់រណឫទ្ធិ ប៉ុន្តែ ពុំដកហូតព្រះអង្គពីមុខតំណែងទេ។ ថ្ងៃ ៨ សីហា :លោកស្រីម៉ាដឺឡែន អុលប្រាយ រដ្ឋមន្ត្រីការបរទេស សហរដ្ឋ អាមេរិក សម្រេចព្យួរទុកសិន ជំនួយដែល សហរដ្ឋ អាមេរិក ត្រូវផ្តល់ទៅឲ្យកម្ពុជា។ សហរដ្ឋ អាមេរិក ពុំទទួលស្គាល់ លោក អ៊ឹង ហួត ថា ជា នាយករដ្ឋមន្ត្រី ដែលបានត្រូវតែងតាំង តាមរបៀបប្រជាធិបតេយ្យទេ។ ថ្ងៃ ៣០ សីហា : ព្រះមហាក្សត្រខ្មែរ នរោត្តម សីហនុ ដែលគង់នៅសៀមរាប ស្នើឲ្យបើក ការចរចា ក្រៅផ្លូវការ រវាងលោក ហ៊ុន សែន និង ព្រះអង្គម្ចាស់ រណឫទ្ធិ។ ថ្ងៃ ១៦ កញ្ញា : រដ្ឋសភា ពុំព្រមអនុម័ត គម្រោងរៀបចំ គណរដ្ឋមន្ត្រីថ្មី ដែលលោក ហ៊ុន សែន បានស្នើឡើង។ ថ្ងៃ ១៩ កញ្ញា: គណកម្មការត្រួតពិនិត្យ របស់ អង្គការសហប្រជាជាតិ សម្រេចដាក់អាសនៈប្រទេសកម្ពុជា នៅអង្គការ សហប្រជាជាតិ ឲ្យនៅទំនេរ។ ថ្ងៃ ២៤ កញ្ញា: នៅក្នុងសន្និសីទ កាសែតមួយ នៅទីក្រុងប៉ារីស៍ លោក ហ៊ុន សែន ចោទសួរអង្គការ សហ ប្រជាជាតិថា តើអង្គការសហប្រជាជាតិ បំពេញតួនាទី របស់ខ្លួននៅកម្ពុជា របៀបណាទៅ បើអាសនៈកម្ពុជា នៅទំនេរដូច្នេះ? ថ្ងៃ ១១ វិច្ឆិកា :ព្រះអង្គម្ចាស់ រណឫទ្ធិ បញ្ចេញកំហឹង ដោយចោទប្រទេសបារាំងថា មាន នយោបាយ ស្របតាមប្រទេសវៀតណាម។ ថ្ងៃ ១៤ វិច្ឆិកា : ព្រះអង្គម្ចាស់រណឫទ្ធិ ថ្លែងថា ព្រះអង្គ សព្វព្រះទ័យ យាងត្រឡប់ទៅកម្ពុជាវិញ ហើយ មិនទាមទារ យកតំណែង នាយករដ្ឋមន្ត្រី មកវិញទេ ឲ្យតែ





រដ្ឋាភិបាល លោក ហ៊ុន សែន ដកពាក្យបណ្តឹងចេញ។ ថ្ងៃ ២៦ វិច្ឆិកា : ព្រះមហាក្សត្រ នរោត្តម សីហនុ ថ្លែងថា ការវិនិច្ឆ័យទោស ព្រះអង្គម្ចាស់ រណឫទ្ធិជា អំពើ អយុត្តិធម៌ ព្រោះអ្នកដែលបានគាំទ្រព្រះអង្គម្ចាស់ រណឫទ្ធិ កាលពីខែកក្កដា និង ឧសភា ពុំបានត្រូវគេវិនិច្ឆ័យទោសផងទេ។ ថ្ងៃ ២៧ វិច្ឆិកា : លោក សម រង្ស៊ី ត្រឡប់មកស្រុកខ្មែរវិញ។ ថ្ងៃ ១ ធ្នូ : គណប្រតិភូ សមាជិកសភា មកជួបលោក ហ៊ុន សែន ហើយដាក់លក្ខខណ្ឌចំនួន ១៥ ១ នៅក្នុងនោះ មានលក្ខខណ្ឌ ៤ គឺ ការឈប់បាញ់គ្នា នៅផ្នែកខាងជើង និង ខាងលិច ការបង្កើត គណកម្មការបោះឆ្នោតមួយ ដែលមានជំហរ ឯករាជ្យ ការវិលត្រឡប់មកវិញ របស់ ព្រះអង្គម្ចាស់រណឫទ្ធ ដោយឥតដាក់លក្ខខណ្ឌ ការប្រគល់ ប៉ុស្ត ទូរទស្សន៍ និង វិទ្យុ មកឲ្យគណបក្ស «ហ៊្វុនស៊ិនប៉ិច» វិញ។ លោក ហ៊ុន សែន សុខចិត្តអនុញ្ញាតឲ្យ ឧត្តមសេនីយ៍ ញឹក ប៊ុនឆាយ វិលត្រឡប់ មកវិញ ប៉ុន្តែឲ្យផ្តាច់ខ្លួនចេញពីព្រះអង្គម្ចាស់រណឫទ្ធិ។ លោក ញឹក ប៊ុន ឆាយ មិនយល់ព្រមនឹងសំណើនេះទេ។ ថ្ងៃ ៣ ធ្នូ : លោក ប៉ែន សុវណ្ណ អតីតនាយករដ្ឋមន្ត្រី របប «សាធារណរដ្ឋប្រជាមានិត្ កម្ពុជា» ហើយដែលទើបនឹងបានបង្កើតគណបក្ស គាំទ្រជាតិខ្មែរ បានវិលត្រឡប់ មកកម្ពុជាវិញ ។នៅថ្ងៃ ដដែលនោះ ព្រះមហាក្សត្រ ក៏យាងវិលមក កម្ពុជា វិញដែរ ។

## ឆ្នាំ ១៩៩៨

ថ្ងៃ ២១ មករា : លោក ប៉ែន សុវណ្ណ អតីតនាយករដ្ឋមន្ត្រី របប «សាធារណរដ្ឋ ប្រជាមានិត្កម្ពុជា» បង្កើតគណបក្ស «គាំទ្រជាតិខ្មែរ»។ ថ្ងៃ ២៥ មករា : លោក អ៊ុក កុរិ បានត្រូវជ្រើសតាំងជា ប្រធានគណបក្ស «ប្រជាធិបតេយ្យ» ជំនួសលោក អ៊ិន តាំ។ ថ្ងៃ ១ កុម្ភៈ លោក អ៊ឹងហួត សហនាយករដ្ឋមន្ត្រី ទី ១ ជំនួសព្រះអង្គ ម្ចាស់រណឫទ្ធិ បង្កើតគណបក្ស «រាស្ត្រនិយម» ហើយ លោក ឡយ ស៊ិមឈាង បង្កើតគណបក្ស «សង្គមថ្មី» ។ ថ្ងៃ ២៨ មករា : លោក សឺន សាន ប្រធានគណបក្ស «ប្រជាធិបតេយ្យ សេរីនិយម ពុទ្ធសាសនា» ព្រមទាំង អ្នកតំណាង ប្រទេសអង់គ្លេស ប្រទេសបារាំង ប្រទេសចិន ប្រទេសរុស្ស៊ី និង

សហរដ្ឋ អាមេរិក នាំគ្នាធ្វើការគាបសង្កត់ ទៅលើ ព្រះមហាក្សត្រ នរោត្តម សីហនុ ឲ្យវិលត្រឡប់ មកកម្ពុជាវិញ ដើម្បីរៀបចំ ការបោះឆ្នោត ។ ថ្ងៃ ៣ កុម្ភៈ :លោក ទួន ឆាយ ប្រកាសថា លោក នឹង បង្កើតគណបក្ស «រួបរួមជាតិ» ។ ថ្ងៃ ៤ កុម្ភៈ : លោក សម រង្ស៊ី អំពាវនាវសុំឲ្យព្រះមហាក្សត្រ ត្រឡប់មកស្រុក ខ្មែរវិញ បើពុំដូច្នោះទេ លោក នឹង រៀបចំមហាបាតុកម្មមួយ នៅថ្ងៃ ២២ កុម្ភៈ ដើម្បីសុំឲ្យព្រះអង្គបំពេញភារកិច្ច របស់ ព្រះអង្គ ជា «បិតាជាតិ»។ ព្រះមហាក្សត្រខ្មែរ បានដោះសាថា ទាល់តែខែមេសា ទើបព្រះអង្គយាងចូលស្រុក ព្រោះនៅពេលនេះ ព្រះអង្គកំពុងព្យាបាល ព្រះរាជសុខភាព ។ ថ្ងៃ ៧ កុម្ភៈ: អ្នកតំណាងរាស្ត្រ ៣ រូបទៀត នៃគណបក្ស «ហ្វុនស៊ិនប៉ិច» គឺ លោក សិទ្ធិ សួយ លោក គង់ សុផាត និង លោក ណុប លៀង បាននាំគ្នាចូលជាសមាជិក គណបក្ស «ពលរដ្ឋខ្មែរ» របស់ លោក ង៉ួន សឿ។ ថ្ងៃ ៣០ មិនា :ព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធិ វិលមកស្រុកខ្មែរវិញ ដោយមានលោក ស្តេហ្វែន សូឡា សមាជិកព្រឹទ្ធសភា អាមេរិក លោក ឡាក់ខាន់ ម៉េរ៉ូត្រា អ្នកតំណាងអគ្គលេខាធិការ អង្គការ សហប្រជាជាតិ នៅកម្ពុជា ជូនដំណើរផង។ ថ្ងៃ ១៥ មេសា : ប៉ុល ពត ទទួលមរណភាព។ ថ្ងៃ ៥ និង ១៨ មិថុនា :កងទ័ព និង កម្មាភិបាលខ្មែរក្រហមចំនួន ៤០០០ នាក់ បានសុំចុះចូលរាជរដ្ឋាភិបាល។ ថ្ងៃ ២៦ កក្កដា : ការបោះឆ្នោតសភា សម្រាប់នីតិកាល ទី ២។ លទ្ធផល៖ គណបក្ស «ប្រជាជន» បាន ៤១, ៤២% នៃ សំឡេង, គណបក្ស «ហ្វុនស៊ិនប៉ិច» បានទទួល ៣១, ៧០%, គណបក្ស សម រង្ស៊ី បាន ១៤, ៧៥ % ។ ថ្ងៃ ៣០ កក្កដា : គណកម្មាធិការជាតិ នៃ ការបោះឆ្នោត ហៅ គ. ជ. ប. ប្រកាសបញ្ជាក់ប្រាប់ថា ការកំណត់ចំនួនអាសនៈ ត្រូវធ្វើ ទៅតាមប្រព័ន្ធ សមាមាត្រ មធ្យមភាគច្រើន ។ ថ្ងៃ ៣ កញ្ញា : គណបក្សប្រឆាំង មិនព្រមទទួលស្គាល់ លទ្ធផល នៃការបោះឆ្នោត ។ និស្សិតប្រមាណ ៣០០ នាក់ ព្រមទាំងព្រះសង្ឃ ៥០ អង្គ បាននាំគ្នាធ្វើបាតុកម្ម យ៉ាងគគ្រឹកគគ្រេងនៅមុខទីស្នាក់ការ សហភាព អឺរ៉ុប នៅមុខស្ថានទូតបារាំង ស្ថានទូត សហរដ្ឋ អាមេរិក និង ស្ថានទូតវៀតណាម។ ថ្ងៃ ៨ កញ្ញា : បាតុករនៅ «ទីលាន ប្រជាធិបតេយ្យ» ត្រូវ រដ្ឋាភិបាល អស់អាណត្តិ បង្ក្រាប យ៉ាងស្តែងអស្ចារ្យដោយ ប្រើកងទ័ពប្រដាប់អាវុធ ៤ កាម្មុង។ ថ្ងៃ ១០ កញ្ញា : លោក កឹម សុខា អ្នកតំណាងរាស្ត្រ នៃ





គណបក្ស «ប្រជាធិបតេយ្យ សេរីនិយម ពុទ្ធសាសនា» បានត្រូវឃាត់ខ្លួន នៅពេលលោក ហៀប នឹង ឡើងយន្តហោះ។ ថ្ងៃ ១១ កញ្ញា : នៅសៀមរាប ព្រះមហាក្សត្រ សុំឲ្យ គណបក្សប្រឆាំង ទទួលស្គាល់លទ្ធផល នៃការបោះឆ្នោត។ ថ្ងៃ ១៤ កញ្ញា : ថ្ងៃទី ៨ នៃបាតុកម្ម បាតុករនាំគ្នាដើរពាស ពេញមហាវិថី ម៉ៅសេទុង។ ថ្ងៃ ២១ កញ្ញា : លោក ម៉ម សូណង់ដូ នាយកវិទ្យុឯកជន «សំបុកឃ្មុំ» បានត្រូវគេឃាត់ខ្លួន នៅ ព្រលានយន្តហោះ ពោធិចិន្តុង នៅពេលដែលលោករៀបឡើងយន្តហោះ។ ថ្ងៃ ២៤ កញ្ញា : រដ្ឋសភារួមប្រជុំគ្នាដើម្បីធ្វើវិសោធនកម្ម សំខាន់មួយ នៃ រដ្ឋធម្មនុញ្ញ តាមសេចក្តីស្នើ របស់ព្រះមហាក្សត្រ។ វិសោធនកម្មនោះ តម្រូវឲ្យ មានមតិភាគច្រើន ២ ភាគ ៣ ពោលគឺ ៧៣ សំឡេង ទើបអាចចាត់តាំង រដ្ឋាភិបាលបាន។ នៅថ្ងៃដដែលនោះ លោក ហ៊ុន សែន បានត្រូវគេប៉ុនប៉ងធ្វើឃាត។ ថ្ងៃ ២៤ កញ្ញា : លោក ហ៊ុន សែន អនុញ្ញាតឲ្យអ្នកតំណាងរាស្ត្រប្រឆាំង អាចចេញទៅក្រៅប្រទេស។ ព្រះអង្គម្ចាស់រណឫទ្ធិ និង លោក សម រង្ស៊ី ព្រមទាំង ភរិយា ក៏ ចេញដំណើរ ទៅប្រទេសបារាំង នៅថ្ងៃនោះដែរ។ ការចាកចេញពីប្រទេស នៃ អ្នកតំណាងរាស្ត្រ នៃគណបក្សប្រឆាំង ធ្វើឲ្យរាំងស្ទះ ដល់ការចាត់តាំងរដ្ឋាភិបាលថ្មី។ ថ្ងៃ ២៥ កញ្ញា : អ្នកតំណាងរាស្ត្រ កឹម សុខា នៃ គណបក្ស «ប្រជាធិបតេយ្យសេរីនិយមពុទ្ធសាសនា» ហើយដែលជាប្រធាន គណកម្មការ សិទ្ធិមនុស្ស នៃ រដ្ឋសភា បានត្រូវ នគរបាល កោះហៅ ដោយត្រូវចោទប្រកាន់ថា ជាអ្នកដែលបំផុសបំផុល ឲ្យមានបាតុកម្ម មិនទទួលស្គាល់លទ្ធផល នៃការបោះឆ្នោត។ ខែ តុលា : ការចរចា ដើម្បីធ្វើការផ្សះផ្សា រវាង មតិភាគច្រើន នឹង គណបក្សប្រឆាំង ទទួលបរាជ័យទាំងស្រុង។ ថ្ងៃ ៧ វិច្ឆិកា : មុននឹងចេញដំណើរទៅទីក្រុងប៉េកាំងវិញ ព្រះមហាក្សត្រ នរោត្តម សីហនុ ប្រកាសសុំឲ្យអ្នកតំណាងរាស្ត្រ ដែលចេញទៅបរទេស ត្រឡប់មកវិញ ដោយមាន ព្រះអង្គ ជាអ្នកធានាសន្តិសុខ ។ ថ្ងៃ ៩ វិច្ឆិកា : លោក សម រង្ស៊ី ពុំព្រម ព្រោះលោកយល់ថា បើត្រឡប់ទៅវិញ អ្នកតំណាងរាស្ត្រ ទាំងនោះនឹងក្លាយ ទៅជាចំណាប់ របស់ លោក ហ៊ុន សែនជាពុំខាន ។ ថ្ងៃ ១១ វិច្ឆិកា : រដ្ឋាភិបាល ប្រកាសធានា សន្តិសុខ ដល់អ្នកតំណាងរាស្ត្រ ដែលបានភៀសខ្លួន ទៅបរទេស។ ថ្ងៃ ១២ វិច្ឆិកា : ព្រះអង្គម្ចាស់រណឫទ្ធិ មកដល់ ព្រលានយន្តហោះ ពោធិ

ចិន្តុង។ នៅ ល្ងាចថ្ងៃដដែលនោះ ព្រះអង្គ បានចូលរួមក្នុងពិធីថតរូប ដែលគេឃើញមាន លោក ហ៊ុន សែន លោក ជា ស៊ីម ព្រមទាំងអ្នកដឹកនាំផ្សេងៗ ទៀត នៃគណបក្ស «ប្រជាជន» ។ ថ្ងៃ ១៣ វិច្ឆិកា : អ្នកដឹកនាំ គណបក្ស «ប្រជាជន» និង អ្នកដឹកនាំ គណបក្ស «ហ្វ៊ុនស៊ិនប៉ិច» ចុះហត្ថលេខា យល់ព្រមគ្នា បង្កើតរដ្ឋាភិបាលចម្រុះ។ ការបែកអំណាចរវាង គណបក្សពីរនេះ ៖ លោក ហ៊ុន សែន នាយករដ្ឋមន្ត្រី ព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភា។ ថ្ងៃ ២ ធ្នូ : នៅពេលអង្គប្រជុំ លើកដំបូងបង្អស់ នៃក្រុមប្រឹក្សារដ្ឋមន្ត្រី លោក ហ៊ុន សែន អំពាវនាវ ឲ្យមេខ្មែរក្រហម ចុះចូលរាជរដ្ឋាភិបាល។ ថ្ងៃ ៣ ធ្នូ : លោក ហោ ណាំហុង រដ្ឋមន្ត្រីការបរទេសខ្មែរ ផ្សព្វផ្សាយសារ របស់ ព្រះមហាក្សត្រដល់ អង្គទូតទាំងអស់ នៅទីក្រុងភ្នំពេញ ដើម្បីប្រាប់ឲ្យដឹងថា ប្រទេសកម្ពុជា បានយកអាសនៈ របស់ខ្លួន នៅ អង្គការ សហប្រជាជាតិ វិញហើយ បន្ទាប់ពីវិបត្តិ ថ្ងៃ ៥-៦ កក្កដាឆ្នាំ ១៩៩៧ ។ ថ្ងៃ ១៤ ធ្នូ : កូដកម្ម គ្រូបង្រៀនទាមទារឡើងប្រាក់ខែ ពី ២០ ដុល្លារ រហូតដល់ ៣១៩ ដុល្លារ។ ថ្ងៃ ២៥ ធ្នូ : ខៀវ សំផន និង នួន ជា សរសេរសំបុត្រមួយ មក លោកហ៊ុន សែន សុំរស់នៅ ក្នុងសង្គមជាតិ ជា ប្រជាជនសាមញ្ញ ។ ថ្ងៃ ២៩ ធ្នូ : ខ្មែរក្រហមទាំងពីរនេះ បានមកដល់ទីក្រុងភ្នំពេញ តាមឧត្តម្ភាគចក្រ ហើយបានទទួលបដិសណ្ឋារកិច្ច ពីលោក ហ៊ុន សែន ។

# ឆ្នាំ ១៩៩៩

នៅដើមឆ្នាំ ១៩៩៩ សមាគម សិទ្ធិមនុស្ស ADHOC សំដែងការព្រួយបារម្ភ យ៉ាងខ្លាំង ដោយឃើញ យោធា រឹបអូសយក ដី ប្រជាជន ដោយឥតកោតក្រែង (ករណីជាច្រើន កើតមានឡើងនៅក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង កំពង់ចាម កំពង់ស្ពឺ ភ្នំពេញ។ ល ។) ។ ថ្ងៃ ២៥ មករា : លោក ហ៊ុន សែន ប្រគល់ការកិច្ចអគ្គបញ្ជាការ កងទ័ព ទៅឲ្យឧត្តមសេនីយ៍ កែ គឹមយ៉ាន់។ ថ្ងៃ ៥ កុម្ភៈ: នៅពេលទស្សនកិច្ច ជាផ្លូវការរបស់លោក នៅប្រទេសម៉ាឡេស៊ី លោក ហ៊ុន សែន បានថ្លែងថា : ការបង្កើតតុលា ការកាត់ទោស មេដឹក





នាំ ខ្មែរក្រហម នឹង នាំទៅរកសង្គ្រាម ។ ថ្ងៃ ៣០ មេសា : ប្រទេសកម្ពុជា ចូលជាសមាជិក សមាគមអាស៊ាន។ នៅឆ្នាំ ១៩៩៩ នោះ ឃាតកម្មទៅលើតារាភាពយន្ត ក៏ស្តែងចេញឡើងដែរ។ ថ្ងៃ ៦ កក្កដា :អ្នកចម្រៀង និង តារាភាពយន្ត ពិសិដ្ឋ ពីលីកា បានត្រូវជនមិនស្គាល់មុខ បាញ់សម្លាប់។ ថ្ងៃ ២៧- ២៨ តុលា: អ្នកតំណាងប្រទេសផ្តល់ជំនួយ ចំនួន ១៦ ប្រទេស បានបើកអង្គប្រជុំ នៅទីក្រុងភ្នំពេញ ។

# Bibliographie


ALBERTI J-B : *L'Indochine d'autrefois et d'aujourd'hui*, Paris, Société d'Etudes géographiques maritimes et coloniales, 1934.

AVIMOR Shimon : *Histoire contemporaine du Cambodge d'un point de vue israélien 1949-1975*, thèse de doctorat, Université d'Aix-Marseille, 1982.

AYMONIER Etienne : *Notice sur le Cambodge*, Paris, Leroux, 1875.

AYMONIER Etienne : *Géographie du Cambodge*, Paris, 1876.

AYMONIER Etienne : *Le Cambodge*, III volumes, Paris (1900-1904).

AYMONIER Etienne, *Chronique des anciens rois du Cambodge*, in Excur-sions et Reconnaissances n°4, pp. 149-184.

AYMONIER Etienne, *Chronique royale du Cambodge*, in Revue de Cochin-chine, 1880-1883.

AYMONIER Etienne, *Critique du " Royaume du Cambodge " de M. Moura*, in Excursion et Reconnaissances, n° 5, pp. 207- 220.

AZIS Philippe : *Angkor et les civilisations birmane et thaie*, Genève, Famot, 1976.

BARTHELEMY P. : *En Indochine, 1894-1895 : Cambodge, Cochin-chine, Laos, Siam méridional*, Paris, Plon, 1899, tome I.

BATZ (lieutenant) : *Histoire de l'occupation militaire du Cambodge par les troupes françaises, de 1855 à 1910*, B.S.E.I. , 1931, t.6, fasc. 1-2.

BAUDOIN François : *Le Cambodge pendant et après la Grande guerre (1914-1927)*, Phnom Penh, Société d'Editions khmères, 1927.

BAUDOIN François : *Monographie de la circonscription résidentielle de Kompong Cham*, Saïgon, Publication de la Société d'Editions khmères, 1927.

BAULMONT : *La première insurrection cambodgienne Pu Kom Bo, mars 1866 – 3 décembre – 1867*, R.I. 15 juin 1905.

BECKER Elisabeth : *Les larmes du Cambodge*, 1986, Les Presses de la Cité, 1988 pour la traduction française

BENISTI Mireille, *Rapports entre le premier art khmer et l'art indien*, Mémoire archéologique, Paris, EFEO, 1970.

BERNADINI Pierre *: le caodaïsme au Cambodge*, thèse de doctorat en histoire, Paris VII, 1974.







BITARD Pierre : *Les membres de la Famille royale du Cambodge et leurs titres d'après l'ordonnance de S.M. An Duon*, BEFEO XL VIII, 1957.

BIZOT François *: La guirlande de joyaux*, E.F.E.O. , Paris - Chiang Mai – Phnom Penh – Vientiane, 1994.

BOISSELIER J. : *Le Cambodge*, Picard, Paris, Manuel d'archéologie d'Extrême-Orient 1/1, 1966.

BONGERT Yvonne : *La monarchie cambodgienne*, in *La monocratie* I, Bruxelles, Société Jean Bodin, 1970.

BOUDILLON A. : *Le regime de la propriété foncière en Indochine (rapport au Ministère des Colonies)*, Hanoï, 1915.

CARR Earl A. : *Origin of the Khmer Revolution*, PhD thesis, S. Illinois University, 1977.

C.E. Bouilleveaux : *Voyage dans l'Indochine* 1848-1856, Paris, 1858.

C.E. Bouilleveaux : *L'Annam et le Cambodge. Voyages et notices historiques*, Paris, Victor Palmé, 1874.

BITARD P**.**, *Mission d'assistance technique auprès de l'Office national de Coopération (OFFINACO*), B.D.P.A., 1969.

BIZOT F., *Le Figuier à cinq branches, Recherches sur le bouddhisme khmer*, Paris,Ec. Fran. Ext. Orient, CVII, 1976.

BOURDILLON A**.**, *Le régime de la propriété foncière en Indochine (rap-port au Ministère des Colonies)*, Hanoï, 1915.

BOURDILLON A**.**, *La réforme du régime de la propriété foncière en Indochine (rapport au Gouverneur général)* 1927.

BRIGGS L.P., *Siamese attacks on Angkor before 1430*, in Far Eastern Quarterly, VIII, 1948.

BRIGGS L. Palmer, *Spanish intervention in Cambodia : 1593 – 1603*,
 in, TP , vol.XXXLX**,** livre 1 –3, pp. 132 – 160, 1949.

BRIGGS L. Palmer**,** *Les missionnaires portugais et espagnols au Cambodge (1555 – 1603)* in BSEI, n° sp., 1er trimestre, vol. 25, fasc. 1, pp. 5 – 29, 1950 .

COEDES G., *La fondation de Phnom Penh au XV ème siècle d'après la Chronique Cambodgienne*, in BEFO, t. XIII, fasc. 6, pp. 6-11, 1913.

COEDES G., *Histoire du Cambodge par A Leclère*, compte-rendu in BEFEO, t. XIV, fasc. 9, pp. 47-54, 1914.

COEDES G., *Essai de classification des documents historiques cambodgiens conservés à la bibliothèque de l'EFEO*, in BEFEO, t. XVIII, fasc. 9, pp. 15-28, 1918.
COEDES G**,** *L'origine du cycle des douze animaux au Cambodge,* in TP, vol. XXXI, pp. 315-320, 1934.
COEDES G., *L'ancienne civilisation khmère,* in France-Asie, t. l, n° 7, pp. 398-405, t II, n° 8, pp. 476-482, 1946.
COEDES G., *Les langues de l'Indochine,* Extrait des conférences de l'Institut de linguistique de l'Uni-versité de Paris VII, année 1940-1948, pp. 63-81 ., 1949.
COEDES G., *Les règles de la succession royale dans l'ancien Cambodge,* in BSEI, n° sp., t. XXVI, n° 2, pp. 117 – 131.
COEDES G., *Les Etats hindouisés d'Indochine et d'Indonésie,* Paris, DE Boccard, 1964.
COEDES G**.**, *Les peuples de la pénisule indochinois,* Paris, Dunod, 1962.
CHANDA Nayan**,** *Les frères ennemis. La péninsule indochinois après Saïgon,* Paris, CNRS, 1987.
CHANDLER David : *Cambodia before the French : politics in a tributary kingdom 1794-1848,* University of Michigan (Ph. D in history, modern), 1973.
CHANDLER David : *Pol Pot, frère Numéro Un*, Plon, Paris 1992.
CHAU Séng : *Education et Développement au Cambodge,* thèse 3 ème cycle, Paris, Faculté des Lettres, 1970.
CHHAY Hoc Phéng : *Le conflit armé au Cambodge* , thèse de doctorat en droit public, Paris II, 1980.
CHHIM Khet : *Les Khmers rouges et le développement politique au Cambodge*, Mémoire DES, Paris I , 1975.
CHUT Khay : *Comment j'ai menti aux Khmers rouges,* Paris, L'Harmattan, 2004.
COMTE Maurice : *Economie, idéologie et pouvoir : la société cambodgienne (1863-1886),* Lyon II, 1980.
CORFIELD Justin : *The political Machinations of the Khmer Republic*, BA (Hons) thesis, University of Hull, 1989.
CLAIRON Marcel *: Droit civil khmer*, Phnom Penh, 1960.
CLAIRON Marcel : *Notions essentielles de droit civil khmer,* Phnom Penh, E.K.L.I.P., 1963.
COLANY Madeleine, Recherches sur le préhistorique indochinois, B.E.F.O., XXX, Hanoï, 1930



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

CROCHET Soizick : *Le Cambodge*, Karthala, Paris, 1997.
DELVERT Jean : *Le paysan cambodgien,* thèse, Paris, 1961, Mouton &
CO La Haye, 1961.
DELVERT Jean : *Le Cambodge*, Paris, P.U.F. et Collection Que sais-je, Paris, 1963.
Documentation française, *La situation économique du Cambodge* (19 pages), Paris. Notes et études documentaires n° 2823, 1961.
DUPONT Pierre**,** *La dislocation du Tchen-La et la formation du Cambodge angkorien,* B.E.F.E.O., XLIII.
DUPONT Pierre, *Les débuts de la royauté angkorienne,* B.E.F.E.O., XLVI.
FABRICIUS Pierre, *Prolégomènes à l'Histoire khmère,* in France-Asie, t. 17, n° 164, pp. 1451 – 1472., 1960., n° 164, pp. 1451 – 1472., 1960.
FERAY Pierre-Richard**,** *Le Vietnam*, Paris, PUF " Que sais-je ", 1984.
FOREST Alain : *Le Cambodge et la colonisation française*, L'Harmat-tan, Paris, 1980.
FOREST Alain : *Le culte des génies protecteurs au Cambodge*, Paris, L'Harmattan, 1992.
FREDERIC Louis *: La vie quotidienne de la péninsule indochinoise à l'époque d'Angkor* (800-1300), Hachette, Paris, 1981.
GITEAU Madeleine, *Histoire du Cambodge*, Paris, 1962
GITEAU Madeleine, *Les Khmers, cultures khmères, reflets de la civilisation d'Angkor,* Fribourg, Office du Livre , Paris 1972.
GOUR Claude Gilles : *Institutions constitutionnelles et politiques du Cambodge*, Dalloz,Paris, 1965.
GROSLIER Bernard-Philippe**,** *Indochine carrefour des arts,* Paris, Albin Michel, 1961.
GROSLIER B. Ph.**,** *Angkor et le Cambodge au XVI ème siècle d'après les sources portugaises et espagnoles*, Paris, 1958.
GROSLIER B. Ph., *Agriculture et religion dans l'empire angkorien,* in Etudes rurales, 1974.
GROSLIER B. Ph., *Angkor Hommes et Pierres,* Paris, Arthaud, 1965 ; Grenoble, 1968.
GROSLIER B. Ph., *Pour une géographie historique du Cambodge,* cahier d'Outre-mer ; Bordeaux, 1973.
GROSLIER B. Ph., *Inscriptions du Bayon*, Paris, E.F.E.O., 1973.

GROSLIER B. Ph., *Recherche sur les Cambodgiens d'après les textes et les documents,* Paris, Challamel, 1921.
HAMEL Bernard : *De sang et de larmes,* Albin Michel, Paris, 1977.
HAMEL Bernard : *Sihanouk et le drame cambodgien*, Paris, L'Harmattan, 1993.
HEDUY Philippe : *Histoire de l'Indochine la perle de l'Empire 1624-1954,* Paris, Albin Michel, 1998.
HOU Yuon : *La paysannerie du Cambodge et ses projets de modernisation*, Paris, thèse de droit, 1955.
IMBERT Jean : *Histoire des institutions khmères*, Annales de la Faculté de Droit de Phnom-Penh, II, 1961.
JENNAR Raoul : *Les Constitutions du Cambodge 1953-1993,* La Documentation française, Paris, 1994.
JENNAR Raoul : *Les clés du Cambodge,* Paris, Maisonneuve & Larose, 1995.
NEPOTE Jacques et SISOWATH Ravivaddhana Monipong, *Etat présent de la Maison Royale du Cambodge*, Institut de la Maison Royale du Cambodge, Courbevoie, France, 1994.
KAO Kan : *Les relations sino-cambodgiennes (1963-1970)*. Thèse pour le doctorat de 3 ème cycle, EPHE, VI ème section, Paris, 1973.
KEM Chhoeun, *Le rôle des entreprises publiques du Cambodge (1969-1973)*, thèse de doctorat en sciences économiques, Montpellier I, 1976.
KENG Vannsak : *Recherche d'un fond culturel khmer*, thèse de 3 ème cycle en Lettres, Paris-Sorbonne, 1971.
KE Khi You *: L'Insurrection générale de 1885-1886 au Cambodge*, Paris, Mémoire de maîtrise sous la direction de J. Chesneaux, Université Paris VII, 1971.
KHIEU Samphân : *L'économie du Cambodge et ses problèmes d'indu-strialisation,* thèse pour le doctorat en sciences économiques, Paris, 1959.
KHIM Y : *Le Cambodge et le problème de l'extension des espaces maritimes dans le Golfe de Thailande,* thèse de doctorat en droit public, Paris II, 1978.
KHIN SOK : *Le Cambodge entre le Siam et le Vietnam de 1775 à 1860*, thèse de doctorat en ethnologie, Paris, EHESS, 1987.
KHIN Sok : *les Vietnamiens au XIX ème siècle d'après les deux poèmes du vénérable Bâtum Baramey Pich*, Editions You-Feng, Paris, 2002.



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

KHIN Sok : *Les chroniques royales khmères*, Mon-khmer Studies VI : 191-215
KHING Hoc Dy : *Ecrivains et expressions littéraires du Cambodge au XX ème siècle,* L'Harmattan, Paris, 1993.
KHING Hoc Dy : *Aperçu général sur la littérature khmère* (en khmer), Paris, L'Harmattan, 1997.
KHING Hoc Dy : *Anthologie de la littérature khmère du XIX ème siècle* (en khmer), P.Penh, 2003.
KHING Hoc Dy : *Anthologie de la littérature khmère au XX ème siècle* (en khmer), Paris, Editions de la plus haute tour, 2002.
KHING Hoc Dy : *Un épisode du Ramayana khmer* (en khmer), Librairie Angkor, Phnom penh, 2004.
KHING Hoc Dy *: Dav Ek, introduction, traduction annotée et textes khmers* (en khmer), Librairie Angkor, Phnom penh, 2005.
KHY Phanra *: La communauté vietnamienne au Cambodge à l'époque du Protectorat français (1863-1953)*, thèse de doctorat en études indiennes et extrême-orientales, Paris III, 1974.
LAMANT Pierre : *L'Affaire Duong Chakr*, Revue française d'Histoire d'Outre-Mer, LXVII, n° 246-7, 1er et 2 ème trimester,1980.
LAMANT Pierre : *L'Affaire Yukanthor, autopsie d'un scandale colonial.* , Société française d'Outre-Mer, Paris, 1989.
LECLERE Adhémard : *Histoire du Cambodge.*, Paul Geutthner, Paris,1914.
LECLERE Adhémar : Recherches sur la législation cambodgienne, Droit privé, Paris, 1890.
LECLERE Adhémar : *Recherches sur le droit public des Cambodgiens*, *Paris, Augustin Challamel*, 1894.
LUCIOLLI Esmeralda : *Le mur de bambou*, Régine Deforges Medecins sans Frontières, Paris, 1988.
LTTAYE Edouard : *Les pratiques institutionnelles sous Sihanouk*, thèse de doctorat du 3 ème cycle, Faculté des Lettres et des Sciences Humaines, Paris, 1971.
MAK Phoeun : *Les Chroniques royales du Cambodge (de 1594 à 1677),* thèse de 3 ème cycle, Paris, 1975.
MAK Phoeun : *Histoire du Cambodge de la fin du XVIII ème siècle (1554-1700),* thèse de doctorat en études indiennes et extrême-orientales, Paris VII, 1992.

MAK Phoeun, *Essai de tableau chronologique des rois du Cambodge de la période post-angkorienne*, Journal asiatique, 290.1 (2002): 101-161
MARTIN Marie-Alexandrine : *La riziculture et la maîtrise de l'eau dans le Kampuchéa démocratique*, Etudes rurales, Paris, 1981.
MARTIN Marie- Alexandrine : *L'Industrie dans le Kampuchéa démocratique*, Etudes rurales, Paris, 1983.
MARTIN Marie-Alexandrine : *La politique alimentaire des Khmers rouges*, Etudes rurales, Paris, 1985
MARTIN Marie-Alexandrine : *Vietnamised Cambodia. A silent Ethno-cide*, Singapour, Indochina Reports, 1986.
MARTIN Marie-Alexandrine : *Le mal cambodgien*, Hachette, Paris, 1989.
MASPERO Georges, *L'Empire khmer*, histoire et documents, Paris, 1921, et articles articles divers in B.E.F.E.O.
MAU Say : *La monnaie cambodgienne à l'heure du Fonds Monétaire International*, Phnom Penh, Faculté de Droit et de Sciences économiques, 1960.
MEAS Yang : *Le bouddhisme au Cambodge*, Paris, Etudes orientales, 1978.
MEYER Charles *: Insurrections nationales du siècle dernier*, Phnom Penh, Etudes Cambodgiennes, janvier-Mars 1967, n °9 ; avril-juin 1967 n° 10 ; Juillet-Septembre 1967 n° 11 ;Octobre-Décembre 1967 n°12.
MEYER Charles : *Derrière le sourire khmer*, Plon, Paris, 1971.
MEYER Roland : *Saramani danseuse khmère*, , Albert Portail, Saïgon, 1919.
M.E. Osborne : *Notes on early Cambodian provincial history*, France-Asie, été 1966, vol. XX, n° 186.
M.E. Osborne : *The French presence in Cochinchina and Cambodia : rule and response (1859-1905)*, Inthaca /London, Cornell University Press, 1969.
MIGOZZI J. : *Cambodge, faits et problèmes*, Paris, Edit. du C.N.R.S., 1973.
MORICE Jean : *Cambodge : du sourire à l'horreur*, France-Empire, Paris, 1977.
MOURA Jean : *Le royaume du Cambodge*, Paris, 1883.
NAYAN Chanda : *Les frères ennemis*, Presses du CNRS, Paris, 1987.





NEPOTE Jacques : *Le palais du roi Norodom I. Histoire et description suivies de l'analyse structurale de la symbolique du palais royal de Phnom Penh*, Thèse 3ème cycle d'Etnologie, Université de Paris X Nanterre,1973.
NEPOTE Jacques : *Parenté et organisation sociale dans le Cambodge moderne et contemporain. Quelques aspects et quelques applications du modèle les régissant*, Genève : Olizane ( Etudes Orientales) & Cédoreck (Bibiothèque khmère), 1992.
NORODOM Rannariddh : *Le domaine maritime du Cambodge*, Aix-en-Provence, Faculté de droit, thèse d'Etat, 1976.
NORODOM Sihanouk : *Souvenirs doux et amers*, Hachette, Paris, 1981.
NORODOM Sihanouk : *Prisonnier des Khmers Rouges*, Hachette, Paris, 1986.
NORODOM Sihanouk : *Chronique de guerre et…d'espoir*, Hachette, Paris, 1986.
OSBORNE M.E.: *History and Kingship in contemporary Cambodia*, Journal of South East Asian History, mars, 1966, vol. VII, n° 1.
OSBORNE M.E. : *King-making in Cambodia : from Sisowath to Sihanouk*, Journal of South East Asian Studies, sept. 1973, vol. IV, n° 2.
PANNETIER A. (Dr) : *Notes cambodgiennes. Au cœur du Pays Khmer*, Paris, Payot, 1921, Réimp.Paris, Cedoreck,1983.
PELLIOT Paul : *Mémoires sur les coutumes du Cambodge de Tchéou Ta- K ouan*,Paris, Maisonneuve, 1951.
PHOUK Chhay : *Les élites khmères*, thèse de droit, Phnom Penh, Faculté de droit,1965.
PHUNG Ton : *La crise cambodgienne*, Paris, thèse de droit, 1954.
PICQ Laurence : *Au delà du ciel, cinq ans chez les Khmers Rouges*, Bernard Barrault, Paris, 1984.
POMONTI Jean-Claude et Serge THION: *Des courtisans aux partisans, la crise cambodgienne*, Gallimard, Paris, 1971.
PONCHAUD François : *Le Cambodge, année zéro*, Paris, Julliard , 1977.
PRESCHEZ Philippe : *Essai sur la démocratie au Cambodge*, Paris, C.E.R.I. Série C, Recherche n° 4, 1961.
PRUD'HOMME Rémy : *L'économie du Cambodge*, P.U.F., Paris, 1969.

REGAUD Nicolas : *Le Cambodge dans la tourmente*, Paris, L'Harmat- tan, 1992.
RAINSY Sam, *Des racines dans la pierre*, Calmann-lévy, Paris, 2008.
ROS Chantraboth *: La République khmère*, Paris, L'Harmattan, Paris, 1993.
SAHAI Sachchidanand : *Les institutions politiques et l'organisation administrative du Cambodge ancien ( VI °-XIII ° siècles)*, EFEO ( PEFEO LXXV), Paris, 1970.
SAINT-LOUP Gérard : *Phnom penh, la douceur assassine*, L'Harmat-tan, Paris, 1997.
SARIN Chhak : *Les frontières du Cambodge*, tome I, Paris, Dalloz, 1966.
SAY Bory : *L'administration rurale au Cambodge et ses projets de réforme*, thèse 3ème cycle en sciences administratives, Paris II, 1974.
SCALABRINO C. : *Cambodge – Histoire et enjeux 1945- 1985*, Paris, L'Harmattan, 1985.
SENG Ly Try : *Le bouddhisme dans la société khmère contemporaine*, Paris, mémoire de DEA, 1986.
SHAWCROSS William : *Une tragédie sans importance*, Balland, 1979 (pour la traduction française). Titre original : *Shideshow*, Simon et Schuster, New York.
SHAWCROSS William : *Le poids de la pitié*, Paris, Balland,1985.
SIN Kim Suy : *Les Chinois du Cambodge*, Etude sociologique, thèse de doctorat de 3 ème cycle, Paris, INALCO, 1986.
SOLA Richard : *Communismes d'Asie, le crépuscule de l'espoir*, Sudestasie, Paris, 1992.
SOU Chamroeun : *Achar Sva* (en khmer), Phnom Penh, 1968.
SOU Chamroeun : *Po Kambor*, Diffusion de La Bibliothèque de la Culture khmère, Phnom Penh, 1971.
STERN Philippe, Le Temple-montagne khmèr le culte du Linga et le Devārāja, B.E.F.E.O., 1934.
TAN Kim Huon : *Géographie du Cambodge, de l'Asie des Moussons et des Principales Puissances*, Phnom Penh, 1963.
THAI Sok : *Traités de morale des Cambodgiens, du XIV au XIX ème siècle*, thèse pour le doctorat de l'université de Paris,1964.
THIERRY Solange : *Les Khmers*, Paris, Seuil, 1964.
THIOUNN Thioum : *Le pouvoir monarchique au Cambodge*, Paris, these de droit, 1952.
THION Serge : *Watching Cambodia* , Bangkok, White Lotus, 1993.





THION Serge, KIERNAN Ben : *Khmers rouges. Matériaux pour l'Histoire du communisme au Cambodge*, Paris, Hallier- Albin Michel, 1981.
TICHIT L. : *L'agriculture au Cambodge*, Agence de Coopération culturelle et technique, 1981.
TITH Huon : *Problème de l'assainissement dans la fonction publique cambodgienne*, thèse pour le doctorat en sciences administratives, Paris II, 1976.
VANDY Kaonn : *Cambodge 1940-1991 : la politique sans les Cambodgiens*, L'Harmattan, Paris, 1993.
VANDY Kaonn : *Réflexion sur la littérature khmère*, Institut de Sociologie de Phnom Penh, 1981.
VANDY Kaonn : *Contribution à l'étude de l'histoire de Thnenh Chey*, (1 ère édition : Phnom Penh, 1973) ; ( 2 ème édition : Association Cambodge-Asie, France 2008 ).
VANDY Kaonn : *Contribution à l'étude du Cambodge et de ses difficultés d'insertion au monde moderne*, thèse pour le doctorat d' Histoire, Faculté des Lettres et Sciences Humaines de l'Université de Nice-Sophia Antipolis, Première partie, 1998.
VANDY Kaonn : *Eléments d'Economie*, Paris, 2008.
VICKERY M. : *Kampuchéa – Politics, economics and society*, Sidney, Allen & Unwin, Australia, 1986.
VICKERY Michael : *Cambodia after Angkor : the Chronicular Evidence for the Fourteenth to Sixteenth Centuries*, PhD, dissertation, Yale University, 2 vol., 1977.

## Méthodologie

ALTHUSSER Louis : *Montesquieu. La politique et l'histoire*, Paris, P.U.F., 1981, p. 15).
ANDERSON Bnedict : *L'imaginaire national, Réflexions sur l'origine et l'essor du nationalisme*, Ed. La Découverte & Syros, Paris, 2002
ATTALI Jacques : *1492*, Paris, Arthème Fayard, 1991 ; col. livre de poche, Edit. 4 , 2004
BLOCH Marc : *Apologie pour l'histoire ou Métier d'historien*, Paris, Armand Colin, 2007.
BRAUDEL Fernand : *Ecrits sur l'histoire*, Paris, Flammarion, 1969.

COLLIOT-THERESE Catherine : *Max Weber et l'histoire*, Paris, P.U.F., 1990, p. 13.
DOSSE François : *L'histoire*, Paris, Armand Colin, 2 000
FOUCAULT Michel : *Les mots et les choses. Une archéologie des sciences humaines*, Paris, Gallimard, 1966.
HARTOG François : *Le XIX è siècle et l'histoire. Le cas de Fustel de Coulanges*, Paris, P.U.F., 1988.
HEGEL : *La Raison dans l'histoire*, Paris, 10/18, 1965.
LEVI-STRAUSS Claude : *Anthropologie structurale*, Paris, Plon, 1958, p. 3-4.
LEVI- STRAUSS Claude : *La pensée sauvage*, Paris, Plon, 1962, p. 345.
MICHELET Jules : *Histoire de France*, dans *Œuvres complètes*, IV, Paris, Flammarion, 1974, p.11.
MONTESQUIEU( Charles-Louis de Secondat, baron de la Brède et de ) : *De l'esprit des lois*, 1748, XIX, 4, Les Belles-Lettres, Paris, 1950-1961.
MONTESQUIEU : *Considération sur les causes de la grandeur et de la décadence des Romains*, 1737.

## Faits historiques et documents

( Alain Forest : *Le Cambodge et la colonisation française : Histoire d'une colonisation sans heurts (1897-1920*), L'Harmattan, 1980.)
- H. de Vernrville propose le prince Sisowath comme successeur à Norodom et dénonce Yukanthor (Cf. Lettre du Résident supérieur au Gouverneur Général en date du 30 janvier 1896, AOM, NF 587.).
- Relation impossible entre Norodom et de Verneville ( Cf. Lettre du Résident Supérieur au Gouverneur Général en date du 16 mai 1896, AOM, Aix 24673.).
- Création du Conseil des ministres par le Gouverneur Général (Cf. Rapport du Gouverneur Général du 31 Août 1897, AOM, carton 8.).
- Pouvoir conféré au Résident Supérieur comme chef de gouvernement (de fait et de droit) du Cambodge (Cf. Paul Doumer, L'Indochine française : souvenirs, Paris, Vuibert et Nony, 1905, p. 236.).





- Le Roi du Cambodge ne consulte ni ne conseille plus le Conseil des ministres (Cf. Rapport du Gouverneur Général du 24 novembre 1897, AOM, carton 8.).
- Le roi Norodom porte plainte contre Ducos (Cf. Lettre de Norodom au Gouverneur Général en date du 21 Août 1899, AOM, Aix 5820. C'est une lettre dans laquelle Norodom accepte aussi l'Union française).
- Le roi est élu par ses ministres. Les membres de la Famille Royale sont exclus des délibérations et du vote (Cf. A. Leclère, Droit public, pp 19-20).
-Tentative de Khun Than de faire couronner son fils Phanouvong Cf.Lettre de M. Calan au Gouverneur Général Rousseau, 10 juin 1896, AOM, Aix 5820.).
- De Verneville présente favorablement le prince Sisowath (Cf. Rapport du Résident Supérieur au Gouverneur Général, 26 janvier 1897, AOM, Aix 5820.).
- Sisowath doit prendre à sa charge toute la solde de ses dignitaires (Cf. Rapport du Gouverneur Général, 1 er trimestre 1904, AOM, carton 9.).
- Par le Conseil des ministres, Doumer veut imposer l'autorité coloniale aux gouverneurs de provinces (Cf. Rapport du Gouverneur Général, 4 ème trimestre 1898, AOM, carton 8.).
- Limogeage des « partisans tièdes » du Protectorat. Ducos a reçu de Poc l'accord d'une action concertée (Cf. Rapport du Gouverneur Général, 3 ème trimestre, 1899, AOM, carton 8.).
- Refus de payer l'impôt à Kompong Cham et Tbaung Khmum (Cf. Rapport du Gouverneur Général, Juillet 1897, AOM, carton 8.).
- Tout passe par le Résident Supérieur (O.R. du 11 août 1901).
- L'administrateur est aussi le juge (O.R. du 11 juillet 1897.).
- Abolition des cérémonies de *Châng day tra* ( 25 janvier 1897).
- Réforme de la Justice ( O.R. 1902) ; voir aussi : Collard *: Cambodge et Cambodgiens. Métamorphose du Royaume khmer par une méthode française du Protectorat*, Paris, Société d'Editions géographiques maritimes et coloniales, 1925.
- Mariage des princes et princesses : pour les princes et les pricesses qui voulaient se marier à leur guise avec les gens du commun, ils doivent renoncer à leurs droits, honneurs et prérogatives (O.R. du 1er janvier 1907.).

- Sisowath propose Monivong comme son successeur (Cf. Lettre de Sisowath adressée au Résident Supérieur Luce et au Gouverneur Général Klobukowski, 2 février 1909.). Outrey n'est pas d'accord (Cf. Lettre du Résident Supérieur au Gouverneur Général, 9 novembre 1902, AOM, carton 15). Albert Sarrault est d'accord avec Outrey (Cf. Lettre du Gouverneur Général au Ministre des Colonies, 3 septembre 1913, AOM, NF 579.).
- Interdiction aux fonctionnaires de fumer l'opium et le chanvre indien (Loi du 6 décembre 1907.).
- Etablissement de la propriété ( O.R. du 24 janvier 1908 et du 8 janvier 1912.).

Tableau 1 : **Stratification de la société khmère avant la présence française**











Tableau 1 A : **Répartition des Propriétaires de terres de rizières en 1930**

(D'après enquête de Y. Henry [1])

Enquête dans cinq provinces cambodgiennes (1930)

| Provinces | Moins de 5 hectares | 5 à 10 Ha | 10 à 50 ha | Plus de 50 ha |
|---|---|---|---|---|
| Battambang | 76,3 % | 18,3 % | 5,3 % | 0,12 % |
| Prey Veng | 87 % | 10,5 % | 2,4 % | 0,14 % |
| Svay Rieng | 80, 3 % | 16, 5 % | 3 % | 0,12 % |
| Kampong | 96,8 % | 2,8 % | 0,4 % | 0 |

| | | | | |
|---|---|---|---|---|
| cham | | | | |
| Kandal | 99 % | 0,9 % | 0,1 % | 0 |

(1) Henry Y. ; *Economie agricole de l'Indochine, Gouvernement Général de l'Indochine, Hanoï,1932*

## Tableau 5 : **La population de la région d'Angkor au XI ème siècle**

(D'après l'hypothèse de Henri Sterling 1)

| | Population | Superficie | Nombre d'agriculteurs |
|---|---|---|---|
| Population urbaine<br><br>(Yaçodhapura) | 250 000 hab. | 16km2 (2) | |
| Population rurale | 450 000 hab. (3) | | 300 000 à 350 000 individus Riziculture uniquement :<br><br>120 000 à 150 000 individus |
| Population de la région d'Angkor | 700 000 hab. | | |

## Tableau 6 : La population du royaume khmer en 1830

(D 'après les documents établis par le Protectorat français en 1874)

| **1830** | **Individus** | | **1900** | **1964** |
|---|---|---|---|---|
| Cambodgiens | 746 424 | | 2. 057 000 | 6. 030 000 |
| Chinois | 06 784 | | 104 523 (4) | 450 000 |





| | | | | |
|---|---|---|---|---|
| Annamites | 4452 (5) | | 69 886 | 230 000 |
| Chams et Malais | 25 599 | | | 90 000 (6) |
| Bonzes | 1263 | | | |
| Mandarins | 13 401 | | | |
| Serviteurs de palais | 154 | | | |
| Population de Phnom Penh | 30 000 | | | |
| Village chrétien de Phnom Penh | 1957 | | | |
| Tagaïs | 197 | | | |
| Kuoys de Kampong Svay | 2930 | | | |
| Phnongs et Stiengs | 1698 | | | |
| Prisonniers | 115 | | | |
| Population flottante | 5000 | | | |
| **TOTAL**. | **945 974** | | | |

1- Henri Sterling. *Angkor*,Collection A*rchitecture Universe*lle, Office du Livre, Fribourg 1970.

2- La surface habitable aurait été de 10 km2, celle occupée par les temples, les quartier du palais, les canaux, les rues, les demeures de*s seigneurs totalisant 6 km2*.

3- Dont entre *2*0 000 et 1*50 000 étaient de*s riziculteurs. La classe des agriculteurs est estimée à 350 000 individus. Le reste représente les pêcheurs, les artisans, les ouvriers et les esclaves.

4- En 874, le nombre des Chinois vivant au Cambodge est 106 784 individus.

5- Ce chiffre ne correspond pas à la réalité.

6- Le nombre total des ethniques est de 30 000 individus.

Tableau 7 : **La population chinoise au Cambodge en 1911 et**

**en 1921 (répartie dans les provinces).** D'après A. Forest

| 1911 | | | 1921 | | |
|---|---|---|---|---|---|
| Provinces | Population chinoise | | Chinois | Métis | Chinois et Métis |
| Battambang | 10 000 | | 4 860 | 5750 | 10 610 |
| Kampot | 8.744 | | 22 510 | 2160 | 24 670 |
| Kandal | 17.070 | | 13 310 | 18 320 | 31 630 |
| Kampong Cham | 12.532 | | 6 960 | 19 080 | 26 040 |
| Kampong Chhnang | 5 193 | | 7 720 | | 7 720 |
| Kampong Thom | 3760 | | 1940 | 6870 | 8810 |
| Kratié | 7891 | | 4370 | 20 | 4390 |
| Prey Vèng | 11 275 | | 4130 | 7170 | 11 300 |
| Pursat | | | 2430 | 1120 | 3550 |
| Svay Rieng | | | 5610 | 380 | 5990 |
| Stung Trèng | 321 | | 510 | 130 | 640 |
| Takéo | 9651 | | 6930 | 7430 | 14 360 |
| Phnom Penh | 18 096 | | 19 920 | 3 700 | 23 620 |
| **Total** | **104 533** | | **101 200** | **72 700** | **173 330** |





Tableau 7 A : **Pourcentage des Chinois par rapport aux Cambodgiens**

| | | | | |
|---|---|---|---|---|
| Phnom Penh | 76,51 % | | Kampong Thom | 6,69 % |
| Kampot | 19,97 % | | Takéo | 5,56 % |
| Kratié | 10,16 % | | Svay Rieng | 5,49 % |
| Kandal | 9,90 % | | Prey Vèng | 5,47 % |
| Kampong Cham | 8,59 % | | Battambang | 3,84 % |
| Kampong Chhnang | 7,50 % | | **Total Cambodge** | **8, 76 %** |
| Pursat | 7,08 % | | | |

1 – A. Forest, *Le Cambodge et la colonisation française*, Op. Cit., 472

Tableau 9 : **Situation de l'Instruction publique au Cambodge en 1873 – 1920**

Fréquentation scolaire des Cambodgiens

| Années | Nombre d'élèves dans le pays | Nombre de filles par rapport aux garçons | dépenses budgets locaux | Population (habitants) |
|---|---|---|---|---|
| 1873<br>1880<br>1885 | | | | 1.000 000 |

| | | | | |
|---|---|---|---|---|
| 1890<br>1893<br>1902 | | | | entre 2.057 000<br>et 2. 163 000 |
| 1903<br>1905<br>1907<br>1908<br>1908-1909 | | | 4,4 % | 2. 274 000 |
| 1909<br>1910<br>1911<br>1912 | | | | |
| 1913 | 2025 | | | 2.274 000 |
| 1914 | 1803 | | | 2.414 000 |
| 1915 | 2613 | G : 2213<br>F : 400 | | |
| 1916 | 2727 | G : 2373<br>F : 354 | | |
| 1917 | 2911 | G : 2575<br>F : 336 | | |
| 1918 | 3947 | G : 3607<br>F : 340 | | |
| 1919 | 4708 | G : 4215<br>F : 393 | | |
| 1920 | 5097 | G : 4541<br>F : 556 | | 2.562 000 |





| | | | | |
|---|---|---|---|---|
| 1913-1920 | | | 67,5 % | |
| 1921 | 5846 | G : 5351<br>F : 495 | | |

## Tableau 10 : **population urbaine et population rurale**

| Années | Population rurale | Par rapport à la population totale | Population urbaine | Par rapport à la population totale | Ana-phalb. urbaine | Ana-phalb. rural |
|---|---|---|---|---|---|---|
| 1921 | | 2.562 000 | 130 000 | 5 % | | |
| 1962 | | 5.740 000 | 600 000 | 10 % | 36 % | 61 % |
| 1966 | +600 000 | 6.336 000 | | | | |
| 1967 | | 6.494 000 | 700 000 | 12 % | | |

## Tableau 11 : **Dépenses des ménages**

En million de riels courants

| | 1962 | 1963 | 1964 |
|---|---|---|---|
| Consommation | 16 265 | 16 906 | 17 508 |
| Intérêts et assurances | 14 | 22 | 23 |
| Impôts directs | 815 | 876 | 890 |
| Dépenses extérieures | 145 | 149 | 130 |

| | | | |
|---|---|---|---|
| Opérations diverses de répartition | 299 | 137 | 120 |
| Cotisations sociales | | 176 | 94 |
| Epargne | 2 142 | 3 158 | 4017 |
| Total des revenus des ménages | 19 680 | 21 534 | 23 113 |

Source : Comptes économiques

Tableau 14 : **L'Enseignement au Cambodge, 1930 – 1966**
Tableau 14 A.

| Année | Primaire (1) | | Secondaire (2) | |
|---|---|---|---|---|
| | Ecoles | Effectifs | Etablissement | Effectifs |
| 1930 (3) | 3 014 | 65 000 | 2 | 310 |
| 1935 (4) | 1 072 | 56 200 | 3 | 370 |
| 1940 | 1 300 | 72 000 | 3 | 390 |
| 1945 | 1 369 | 89 000 | 3 | 680 |
| 1950 | 1 928 | 183 000 | 4 | 1 570 |
| 1955 | 2 498 | 286 000 | 7 | 3 810 |
| 1956 | 2 805 | 344 000 | 10 | 5 410 |
| 1957 | 2 946 | 400 000 | 12 | 7 960 |
| 1958 | 3 153 | 449 000 | 18 | 11 340 |
| 1959 | 3 316 | 526 000 | 28 | 14 080 |
| 1960 | 3 470 | 542 000 | 32 | 16 840 |
| 1961 | 3 533 | 583 000 | 35 | 20 230 |
| 1962 | 3 515 | 563 000 | 47 | 30 360 |
| 1963 | 3 646 | 596 000 | 63 | 33 020 |
| 1964 | 3 634 | 626 000 | 71 | 44 810 |
| 1965 | 3 718 | 660 000 | 85 | 59 930 |
| 1966 | 3 521 | 757 000 | 95 | 66 520 |

Sources. De 1930 à 1950 inclus : *Annuaire Statistiques.* De 1955 à 1966 : Office National de Planification de l'Education.

*Notes :*





1 – De 1930 à 1950 : y compris les écoles rénovées de pagodes et l'enseignement privé ; ensuite : enseignement public seulement.

2 – De 1930 à 1950 : y compris l'enseignement privé ; ensuite : enseignement public seulement.
3 – En fait, chiffres de 1931
4 – En fait, chiffres de 1936. *Qualité* : incertaine

D'après Rémy Prud'homme, *L'Economie du Cambodge*, Paris, P.U.F., 1969.

Tableau 14 B : **L'Enseignement au Cambodge, 1930 – 1966** (suite)

| Année | Technique | | Supérieur | |
|---|---|---|---|---|
| | Etablissements Effectifs | | Etablissements Effectifs | |
| 1930 | 2 | 400 | - | - |
| 1935 | 2 | 260 | - | - |
| 1940 | 2 | 320 | - | - |
| 1945 | 3 | 280 | - | - |
| 1950 | 5 | 280 | 2 | 240 |
| 1955 | 5 | 330 | 2 | 350 |
| 1956 | 5 | 390 | 2 | 390 |
| 1957 | 5 | 440 | 2 | 530 |
| 1958 | 7 | 550 | 3 | 910 |
| 1959 | 7 | 670 | 3 | 1090 |
| 1960 | 7 | 980 | 5 | 1430 |
| 1961 | 7 | 1090 | 5 | 1730 |
| 1962 | 7 | 1650 | 5 | 2170 |
| 1963 | 10 | 2020 | 5 | 2570 |
| 1964 | 10 | 3230 | 5 | 2380 |
| 1965 | 10 | 3810 | 37 | 4760 |
| 1966 | 10 | 4020 | 37 | 7360 |

D'après Rémy Prud'homme, *L'Economie du Cambodge*, Paris, P.U.F., 1960

Tableau 14 C : **Les écoles de pagodes " rénovées "**

| Années | Nbre d'élèves éc. de pagode | Nombre de bonze | Ecole publiques | Nombre d'instituteurs laïcs |
|---|---|---|---|---|
| 1945 | 53 000 él. | | 32 000 | |
| 1957 | 85 895 (1) | 65 000 | 305 000 | 6 525 |

(1) 1 465 écoles de pagodes

Tableau 15 : **Dépenses des ménages, 1962 – 1964**

En millions de riels

| | 1962 | 1963 | 1964 |
|---|---|---|---|
| Consommation | 16 265 | 16 906 | 17 502 |
| Intérêts et Assurances | 14 | 22 | 23 |
| Impôts directs | 815 | 876 | 890 |
| Dépenses extérieures | 145 | 149 | 130 |
| Opérations diverses de répartition | 299 | 137 | 120 |
| Citisations sociales | | 176 | 94 |
| Epargne | 2 142 | 3 158 | 4 017 |
| | | | |
| Total des revenus des ménages | **19 680** | **21 534** | **23 113** |

Tableau 15 B : **Consommation des ménages en 1963**

(Source : comptes économiques 1963). En millions de riels

| | Production locaux | Auto-consom. | Prod. import. | Total | % |
|---|---|---|---|---|---|
| | 10.888 | 5.870 | 1.114 | 12.002 | 71,0 |
| **A- Alimentation** | 4.050 | 3.353 | 27 | 4.077 | 24,1 |
| | 1.191 | 265 | 43 | 1.135 | 7,3 |
| 1- Céréales | 734 | 281 | 1 | 735 | 4,4 |
| 2- Viandes et volailles | 163 | 120 | _ | 163 | 1,0 |
| 3- Poissons | 2.558 | 1.710 | 128 | 2.686 | 15,8 |
| 4- Tunercules | 124 | 4 | _ | 124 | 0,7 |
| 5- Fruits et légumes | 162 | 21 | 16 | 178 | 1,1 |
| 6- Condiments | 19 | _ | 329 | 348 | 2,2 |
| 7- Oléagineux | 1.369 | 418 | 334 | 1.704 | 10,0 |
| 8- Prod.laiters-œufs | | | | | |
| 9- Boissons et tabacs | 718 | 93 | 235 | 753 | 4,5 |
| 10- Autres produits | 1.082 | 431 | 266 | 1.348 | 8,0 |
| Alimentaires | 1.082 | 431 | 141 | 1.223 | 7,2 |
| **B- Habitation** | _ | _ | 125 | 125 | 0,8 |
| 1-Entretien du logement | 245 | _ | 1.480 | 1.725 | 10,2 |
| 2-Equipement du logement | | | | | |





| | | | | | |
|---|---|---|---|---|---|
| | 255 | - | 457 | 712 | 4,2 |
| C- Habillement | 619 | _ | 474 | 1.123 | 6,6 |
| **D- Transport et communication** | 13.119 | 6.303 | 3792 | 16.911 | |
| **E- Distraction, culture, hygiène** | 76,6 | 37,3 | 22,4 | 100 | |
| **Total** | | | | | |
| **En pourcentage** | | | | | |

Tableau 16 : **Noms des principales variété de paddy Vossa employés dans la province de Kampong Cham**

| Année | Surfce (cultivé en milliers d'hectares) | Travailleurs (en milliers) | Production (en milliers de tonnes) | Rendement (tonnes à l'hectares) | Rendement (tonnes par travailleurs) |
|---|---|---|---|---|---|
| 1900 | 400 | 935 | 560 | 1,40 | 0,59 |
| 1905 | 450 | 980 | 540 | 1,20 | 0,55 |
| 1910 | 500 | 1.010 | 550 | 1,10 | 0,60 |
| 1915 | 570 | 1.040 | 627 | 1,10 | 0,60 |
| 1920 | 620 | 1.080 | 682 | 1,10 | 0,63 |
| 1925 | 700 | 1.120 | 735 | 10,5 | 0,66 |
| 1930 | 800 | 1.160 | 816 | 1,06 | 0,70 |
| 1935 | 920 | 1.220 | 920 | 1,00 | 0,76 |
| 1940 | 1.100 | 1.280 | 1.012 | 0,92 | 0,79 |
| 1945 | 1.100 | 1.340 | 935 | 0,95 | 0,70 |
| 1950 | 1.660 | 1.400 | 1.580 | 0,95 | 1,13 |
| 1955 | 1.740 | 1.450 | 1.490 | 0,85 | 1,00 |
| 1956 | 1.840 | 1.490 | 1.790 | 0,97 | 1,20 |
| 1957 | 1.940 | 1.520 | 1.990 | 1,02 | 1,30 |
| 1958 | 2.030 | 1.550 | 2.120 | 1,04 | 1,37 |
| 1959 | 2.100 | 1.580 | 2.083 | 0,99 | 1,32 |
| 1960 | 2.150 | 1.620 | 2.340 | 1,09 | 1,44 |
| 1961 | 2.110 | 1.660 | 2.380 | 1,09 | 1,44 |
| 1962 | 2.210 | 1.690 | 2.040 | 0,92 | 1,20 |
| 1963 | 2.250 | 1.720 | 2.620 | 1,17 | 1,52 |
| 1964 | 2.296 | 1.770 | 2.760 | 1,20 | 1,56 |
| 1965 | 2.340 | 1.820 | 2.500 | 1,07 | 1,37 |
| 1966 | 2.410 | 1.880 | 2.380 | 0,98 | 1,26 |
| 1967 | 2.510 | 1.920 | 2.280 | 0 ,91 | 1,19 |

Tableau 17 : **Culture du paddy, 1900 – 1966**





| Paddy tardifs | | |
|---|---|---|
| Vernaculaure | en français | genres |
| 1- *Chhmar sâr* | Chat blanc | |
| 2- *Chhmar krâhâm* | Chat rouge | |
| 3- *Anchoeum sék* | Sourcil de perroquet | |
| 4- *Anchoeum prâveuk* | Sourcil de sarcelle | |
| 5- *Banla pdau* | Epine de rotin | |
| 6- *Buon kuor* | Quatre tiges | |
| 7- *Phkar daung* | Fleur de cocotier | |
| 8- *Kâ puos* | Cou de serpent | |
| 9- *Tong chhouk* | Tige de lotus | |
| 10- *Chhaeung puos* | Os de serpent | riz gluant |
| 11- *Kantuy damrey* | Queue d'éléphant | |
| 12- *Ansong oeut* | Œil d'iguane | |
| 13- *Damrey chhor* | Eléphant debout | |
| 14- *Phkar sla* | Fleur d'aréquier | |
| 15- *Krâchâk chrouk* | Ongle de porc | |
| 16- *Pram roy* | Cinq cents | |
| 17- *Kaun trei* | Petit poisson | |
| Paddys moyen | | |
| 1- *Pong téa* | Œuf de cane | riz gluant |
| 2- *Romang samley* | Flocon de coton | |
| 3- *Khmao kroap* | Graine noir | riz gluant |
| 4- *Damnoeup lhuong* | Paddy gluant royal | riz gluant |
| 5- *Kroap krauch* | Grain de citron | |
| 6- *Srauv chen* | Paddy chinois | |
| 7- *Damnoeup kaun khmom* | Paddy gluant de petit abeille | riz gluant |
| 8- *Chhaeung moan* | Os de poulet | |
| 9- *Phnom run* | Montagne de joncs | |
| 10- *Krâya* | Repas royal | |
| 11- *Phdau* | Rotin | |
| Paddys hâtifs | | |
| 1- *Kambor* | Chaux | |
| 2- *Pong chap* | Œuf de moineau | |
| 3- *Damnoeup srâmoch* | Fourmis | riz gluant |
| 4- *Phkar ampil* | Fleur de tamarinier | |
| 5- *Phkar de popel* | Fleur de popel | |
| 6- *Kâng pol* | Troupe d'armée | |
| 7- *Théang chék* | branche de bananier | |

Sources :1900 à1930 : R.Morizon, *Manographie du Cambodge*, Hanoï, 1931 Imprimerie de l'Extrême-Orient, p. 106
1930 : Y. Henry, *Economie Agricole de l'Indochine*, Hanoï, 1932
1930 à 1950 : Annuaire Stat. Rétrospectif du Cambodge, p.36.
1950 : Docum de la Direction de l'Agriculture.
Calculs : Intrapolation de Rémy Prud'Homme, *L'Economie du Cambodge*, Paris,P.U.F., 1969.

Tableau 18 : **Entreprises industrielles par secteur**, 1956 – 1965

Nombre d'entreprises

| Année | Industries alimentaires | Energie et Eau | Matières premières | Industries mécaniques | Textiles et cuirs | Divers | Total |
|---|---|---|---|---|---|---|---|
| 1956 | 753 | 17 | 336 | - | 3 | 32 | 1.141 |
| 1957 | 851 | 17 | 349 | - | 4 | 33 | 1.254 |
| 1958 | 1.006 | 17 | 399 | 3 | 9 | 35 | 1.469 |
| 1959 | 1.159 | 17 | 441 | 6 | 12 | 45 | 1.680 |
| 1960 | 1.243 | 17 | 457 | 11 | 12 | 56 | 1.796 |
| 1961 | 1.319 | 17 | 461 | 18 | 14 | 66 | 1.895 |
| 1962 | 1.379 | 17 | 345 | 29 | 15 | 84 | 1.869 |
| 1963 | 1.447 | 23 | 579 | 43 | 19 | 104 | 2.215 |
| 1964 | 1.576 | 30 | 633 | 100 | 56 | 195 | 2.590 |
| 1965 | 1.589 | 32 | 674 | 123 | 74 | 201 | 2.693 |

Nomenclature des genres d'entreprises de chaque secteur :

1) Industries alimentaires : rizeries, distilleries, saumureries, fabrique de sauce de soja, eau gazeuses…
2) Energie et Eau : usines électriques
3) Industries des matières premières et des demi-produits : scieries, four à charbon, briquetteries, fabriques de peinture…
4) Industries mécaniques : ateliers de construction et de réparation, fabriques d'article métallurgiques manufacturés…
1) Textiles et cuirs : tanneries, usines de tissage, fabriques de filets de pêche…
2) Industries diverses : fabriques des articles en plastique, fabriques des articles en caouchouc, imprimeries et fabriques des articles en papier et carton, savonneries, manufactures d'allumettes et de cigarettes.

Source : Ministères de l'industrie, d'après A.S.C. 1963-1964 et 1965. Voir aussi : Rémy Prud'homme, *L'Economie du Cambodge*.Op. Cit

Population active (1962) : 44 % de la population total.
Population urbaine :
1921 : 130 000 (5 % de la pop. tot.)
1962 : 600 000 (10 % de la p.t.)



សុបិន និង ការពិត - ភាគ ២ - Rêves et réalités Tome II

1967 : 700 000 (12 %)
N.B. Entre 1921 et 1967, la population du Cambodge a augmenté de 3.149 000 habitants.

Distribution de la population active dans trois principaux secteurs économiques
Secteur primaire : 81 %
Secteur secodaire : 4 %
Secteur tertiaire : 15 %

Répartition dans le secteur primaire
Riziculteurs : 81 %
Autres agriculteurs : 16 %
Pêcheurs : 3 %

tableau 19 : **Revenu national 1962 – 1964**
En million de riels
Source : Comptes Economiques

| | 1962 | 1963 | 1964 |
|---|---|---|---|
| Revenus bruts de la propriété et de l'entreprise | 15.070 | 17.045 | 18.089 |
| Opérations divers | 303 | 318 | 341 |
| Impôts directs moins subvention | 2.556 | 2.652 | 2.801 |
| Rémunération des salariés | 1.978 | 2.164 | 2.269 |
| | 19.907 | 22.180 | 23.500 |
| Production intérieur brute | 3.097 | 3.257 | 3.752 |
| Rémunération des salariés des administrations | 90 | 116 | 98 |
| | 23.097 | 25.553 | 27.350 |
| Rémunération des salariés des institutions financières | | | |
| Produit intérieur brut | | | |

វ៉ាន់ឌី កាអុន

# សុបិន និង ការពិត



បន្ទាប់ពី របប « សាធារណរដ្ឋខ្មែរ » ត្រូវប្រទេសកុម្មុយនិស្ត នៅក្នុងតំបន់ វាយរំលំ នៅថ្ងៃ ១៧ មេសា ឆ្នាំ ១៩៧៥ ប្រទេសកម្ពុជា បានធ្លាក់ទៅក្នុងវិនាសកម្មមួយ ដ៏គ្រៀមក្រំ ។ នៅក្នុង របប ខ្មែរក្រហម ដឹកនាំដោយ ប៉ុល ពត ហើយដែលមាន ប្រទេសចិនកុម្មុយនិស្តជាបង្អែក ប្រជាជនខ្មែរជាង ១ លាន នាក់ បានត្រូវគេសម្លាប់នៅក្នុងស្ថានភាព គួរឲ្យសង្វេគពន់ពេកក្រៃ ។ នៅដើមឆ្នាំ ១៩៧៩ កងទ័ពវៀតណាម ដែលមានជំនួយ ពីសហភាព សូវៀត បានចូលមកក្នុងស្រុកខ្មែរវាយរំលំ របបកម្ពុជា ប្រជាធិបតេយ្យ។ អធិករណ៍ រវាងកុម្មុយនិស្តចិន និង កុម្មុយនិស្ត វៀតណាម តាមរយៈអ្នកដឹកនាំខ្មែរ ចេះតែមានបន្តទៀត។ កិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស៍ ឆ្នាំ ១៩៩១ និង អន្តរាគមន៍ របស់អង្គការសហប្រជាជាតិ នៅឆ្នាំ ១៩៩២ បានរៀបចំ ការបោះឆ្នោតសេរី ដែលបានផ្តល់ជ័យជំនះទៅឲ្យគណបក្សរាជានិយម ដឹកនាំដោយព្រះអង្គម្ចាស់នរោត្តម រណឫទ្ធិ ។ ប៉ុន្តែ រដ្ឋប្រហារ ខែកក្កដា ឆ្នាំ ១៩៩៧ បានបើកផ្លូវ ឲ្យបក្សប្រជាជនកាន់អំណាចបន្តទៀត។ សុបិន របស់ប្រទេសដែលជណ្តើមគ្នាលេបទឹកដីខ្មែរ កំពុងតែក្លាយទៅជាការពិត ។ អ្នកដឹកនាំខ្មែរ ព្រមទាំងប្រទេសជាប់ពាក់ព័ន្ធ ពុំព្រម អនុវត្តកិច្ចព្រមព្រៀងសន្តិភាព ទីក្រុងប៉ារីស៍ឡើយ ហើយរុញច្រាន ស្រុកខ្មែរឲ្យធ្លាក់ជ្រៅទៅៗ ទៅក្នុងមហន្តរាយមួយ ដ៏ ធំធេង សាជាថ្មីទៀត។

**Cambodge : rêves et réalités**

**Vandy Kaonn**

MCSerey

វ៉ាន់ឌី កាអុន សុបិន និង ការពិត